បណ្ឌិតសភាចារ្យ ខ្លួត ធីតា

# សាសនាសកល

រក្សាសិទ្ធិ

ព.ស. ២៥៦១ គ.ស. ២០១៨

## មាតិកា

-អារម្ភកថា ៖......................................................................................ii

-សេចក្ដីផ្ដើម ៖ .................................................................................. ១

ជំពូកទី១ ៖ កំណើតនៃជំនឿលើសកលលោក..............................................៥

ជំពូកទី២ ៖ កំណើតនៃសាសនាសកល......................................................៤៣

ជំពូកទី៣ ៖ ទស្សនៈស្ដីអំពីសាសនាសកល............................................ ៦២

ជំពូកទី៤ ៖ សាសនាសិក្ខ សាសនាក្រុមអារ្យ៉ែនសាសនាព្រាហ្មណ៍-ហិណ្ឌូ សាសនា ពុទ្ធសាសនាសិក្ខ................................................១៣៨

ជំពូកទី៥ ៖ សាសនា ក្រុមសេមិទិក សាសនាជិហ្វ សាសនាគ្រិស្ដ សាសនាឥស្លាម សាសនាជិហ្វ "យូដា".............................. ៣១១

ជំពូកទី៦ ៖ អំពីលោកធាតុនៃសាសនា..................................................៤៣៨

## អារម្ភកថា

ការប្រៀបធៀបជាវិធីមួយដ៏សំខាន់បំផុតរបស់វិទ្យាសាស្ត្រ ដែលមិនទាន់មានទីពិសោធន៍ (Labora-tory) ដូចជាសង្គមវិទ្យា* ទស្សនវិជ្ជា ចិត្តវិទ្យាជាដើម។ ការសិក្សាសាសនាក៏គេរាប់បញ្ចូលក្នុងវិទ្យាសាស្ត្រនៃសង្គមដែរ ខាងផ្នែកទស្សនវិជ្ជាទូទៅ និងទស្សនវិជ្ជាសង្គម។ ដូចនេះ វិធីប្រៀបធៀបជាការចាំបាច់បំផុតនៃការសិក្សាសាសនា ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនុមាន និងឯកភាពខាងជំនឿ និងប្រតិបត្តិ ឬភាគទ្រឹស្ដី និងភាគប្រតិបត្តិនៃសាសនាមួយៗ ។ ក្នុងទីនេះ ដើម្បីរកបំណុលស្របគ្នានិងផ្សេងគ្នានៃមហាសាសនាទាំង ៥ នោះ យើងត្រូវធ្វើអត្ថាធិប្បាយមហាសាសនានីមួយៗ តាមលំអាននៃមាត្រាឬលក្ខណៈទាំង៣ ដែលបានចែងនៅក្នុងមាតិការឿងស្រាប់ តែមុននឹងធ្វើអត្ថាធិប្បាយយើងត្រូវដឹង ៖

១-គោលការណ៍នៃសាសនា

ក-ប្រធានារម្មណ៍នៃសាសនា

ខ-អត្ថន័យនិងមុខងារនៃសាសនា និង

គ-វិធីសិក្សានៃសាសនា (Method = regular arrangement)

២-មូលហេតុនៃសាសនា

៣-អំពីលោកធាតុ សភាពមនុស្ស និងវាសនាបន្ទាប់ពីសេចក្ដីស្លាប់ សីលធម៌ និងសាសនាពិធីនៃសាសនានីមួយៗ។

**ក-ប្រធានារម្មណ៍នៃសាសនា (Subject matter of Religion)**

តាំងពីពេល ដែលមនុស្សចេះរួមរស់នៅជាពួក-ក្រុមមក មនុស្សលោកម្នាក់ៗកើតសេចក្ដីត្រូវការ និងចេះបន្ដាប់ខ្លួនឯងឱ្យពិចារណារកជំនឿដែលជាមតិកនិងជាវត្ថុមាន និងឧត្តមគតិ ដើម្បីរកឯកភាពនៃការពិសោធន៍រវាងបច្ចុប្បន្នកាលនិងអតីតកាល ហើយជំរុញការពិសោធន៍នេះឱ្យដល់ស្ថានភាពនិងចំណុចដ៏ខ្ពង់ខ្ពស់ ដែលអាចបំពេញសេចក្ដីត្រូវការនៃអារម្មណ៍ និងការត្រិះរិះនៃចិត្ត។ បើកាលណាការពិសោធន៍នេះមានឯកភាព ពេញលេញហើយ មនុស្សមានការទុកចិត្តលើខ្លួនឯង។ ការទុកចិត្ត ខ្លួនឯងដែលជាលទ្ធភាពនៃឯកភាពក្នុងការពិសោធន៍ អាចទុកជាថាមពលនៃអាវុធសម្រាប់ការពារខ្លួន និង តទល់នឹងជីវិត អនាគត។ ការពិសោធន៍ បានក្លាយទៅជាសាសនា។ ប៉ុន្តែសាសនាគេចាត់ទុកជាស្ថាប័ន នៃសង្គមទី៤ ទោះបីសង្គមនោះតូចក្ដី ធំក្ដី និងជាធម្មតាត្រូវតែសិក្សាតាមរបៀបវិទ្យាសាស្ត្រ ព្រោះមានសភាវៈ ទៀតទាត់សម្រាប់ដោះស្រាយបញ្ហាជីវិតមនុស្សលោកទាំងក្នុងបច្ចុប្បន្ន

កាលនេះទាំងក្នុងអនាគតកាល។ គេទុកសាសនាជាសភាវៈពិតដោយខ្លួន (Religion is a reality sui genaris) តាមអ្នកសង្គមវិទូសម័យថ្មីម្នាក់ គឺលោក អេ ដឿកខែម (E.Durkheim) ជាអ្នកសង្គមវិទូជាតិបារាំងជំនាន់សតវត្សទី១៩។ សាសនា បើតាម លក្ខណៈដ៏ទូលំទូលាយ គេចាត់ទុកជាវប្បធម៌ខាងផ្លូវគំនិត (Non material culture) ដែលវិវឌ្ឍទៅជាមួយនឹងកំណើតនៃសង្គមមួយក្នុងលោកនេះ។

បើប្រសិនជានៅបច្ចុប្បន្នកាលនេះ មានវិញ្ញូជនជាច្រើនបានចាប់អារម្មណ៍ទៅលើការសិក្សាសាសនាជា របៀបស្រាវជ្រាវនិងរិះគន់តាមបែបវិទ្យាសាស្ត្រ ការសិក្សាសាសនា ត្រូវតែបង្កើតជំហានឱ្យមានល្បឿនជាង សព្វថ្ងៃនេះ ព្រមទាំង ៖ ១-ធ្វើឱ្យមានវិវឌ្ឍន៍យ៉ាងរហ័សនូវវិជ្ជានេះនិងផ្លូវគំនិតជារបៀបវិទ្យាសាស្ត្រ, ២-ធ្វើ ឱ្យការចូលចិត្តខាងប្រាជ្ញាឱ្យជ្រាលជ្រៅក្នុងវិជ្ជានេះ, ៣-ផ្សាយនិន្នាការដ៏ទូលំទូលាយទៅក្នុងសកលលោកក្នុង លក្ខណៈកែទម្រង់ឬស្ថាបនាសាសនាជាថ្មីឬក៏បង្កើតគំនិតថ្មីដែលប្រកបដោយហេតុផលប្រកបដោយវិទ្យាសាស្ត្រដែលមិនមានជំនឿឥតហេតុផលឈាយប្រឡំ (Superstitions) ជំនួសសាសនាក្នុងលោក ឬក៏ជ្រើសរើសយកសាសនាណាមួយដែលមានផលត្រឹមត្រូវក្នុងបណ្តាមហាសាសនាទាំង ៥ មកអនុវត្តនៅក្នុងលោកនេះ, ៤-ធ្វើសាសនាឱ្យទៅជាមនោគមន៍វិជ្ជាសម្រាប់អនុវត្តប្រើក្នុងជីវភាពសង្គម ក្នុងរចនាសម្ព័ន្ធនៃសង្គមនយោបាយទូទៅនិងក្នុងហេតុការណ៍ ឬស្ថានការណ៍អន្តរជាតិ ដែលកាលពីដើម សាសនាធ្លាប់តែមានឥទ្ធិពលទៅលើ គោលការណ៍ទាំងអស់នេះ។ បើកាលណាតម្លៃនៃសីលធម៌និងចរិយាសាស្ត្រ កាតព្វកិច្ចនិងបច្ចយាការផ្សេងៗ គេត្រូវទាក់ទងដល់តម្លៃនៃសាសនាក៏ត្រូវចេញមុខឡើងដើម្បីជាសក្ខីភាពនៃ គោលការណ៍ទាំងអស់នោះដែរ។

ម្យ៉ាងទៀត យើងសម្គាល់ឃើញការពិសោធន៍ទាំងអស់ បានបង្ខំដោយជៀសវាងបានឱ្យសើរើពិចារណា ជាថ្មីនូវឧត្តមគតិ ដែលជាគោលការណ៍សំខាន់ៗ ទោះបីគោលការណ៍ទាំងនោះៗ មានសភាវៈជាសាសនាសុទ្ធសាធ ឬជាក់ស្តែងក្តី មិនមានក្តី។ ជាទីបំផុត បញ្ហាធម៌ជោគវាសនានៃមនុស្សជាតិ ទីដៅនៃមនុស្សជាតិ ព្រះ ម្ចាស់សួគ៌ ឬអាទិទេព។

វាឡូក៏ត្រូវឧប្បត្តិឡើង ហើយបញ្ហាទាំងអស់នេះ ត្រឡប់មកចូលនឹងបញ្ហាសម្ព័ន្ធភាពទាំងឡាយរវាងសាសនានិងផ្លូវគំនិតសប្រមាន(Validity) របស់វិជ្ជាធម្មតានិងវិចារជារបៀបប្រតិបត្តិនៃការពិសោធន៍ ព្រមទាំងសច្ចៈនិងបរមត្ថធម៌ទៅវិញជាពុំខាន។

ឧទាហរណ៍ ៖ មនោគមន៍វិជ្ជាសម័យថ្មី គឺលទ្ធិប្រជាធិបតេយ្យ មានការនិយមតាមរបៀបលោកសេរី លោករួមសំបាច់ លោកសង្គមនិយម លោកអព្យាក្រឹតនិយម ជាដើម។

ប៉ុន្តែអ្នកសិក្សាសាសនា ត្រូវតែជៀសវាងរបៀបចរិយាប្រកាន់ម្ខាងៗ ឬមានចិត្តអគតិទៅលើសាសនាមួយៗ ព្រោះថាយើងមិនអាចលើកយកបំណុលផ្ទាល់ខ្លួន ឬចំណុចប្រកាន់ក្នុងសាសនាមួយៗ មកធ្វើជាមូលហេតុនៃការសិក្សាសាសនា នឹងក្លាយជាអវិទ្យាសាស្ត្រដោយពិត។ រួមមកយើងត្រូវតែសិក្សាភាគទ្រឹស្តីនិងភាគ ប្រតិបត្តិនៃសាសនាមួយៗក្នុងលោកនេះតាមសរីរូប (Physiology) និងចិត្តរូប (Psychology) នៃសាសនានោះៗ។ ដូច្នេះយើងត្រូវតែពិនិត្យទាំងអស់នូវអន្តរកិរិយា និងអាកប្បកិរិយា ដែលជាសាសនាសុទ្ធសាធ មិនមែនសុទ្ធសាធអន្តរកិរិយានិងចរិយា ដែលជាគ្រហស្ថនិយមសុទ្ធ អន្តរកិរិយានិងចរិយា ដែលជាការប្រឆាំងសាសនា និងការរិះគន់ជាដើម។ នេះទើបគេឱ្យឈ្មោះថា“ការសិក្សាសាសនាមានលក្ខណៈជាវិទ្យាសាស្ត្រ”។

**១-អត្ថន័យនិងមុខងារនៃសាសនា**

យើងត្រូវធ្វើអត្ថន័យសាសនាតាមលក្ខណៈរបស់សាសនាមួយៗ ព្រោះយើងមិនអាចរកឯកភាព ឬមានភាពនៃអត្ថន័យរបស់សាសនាទាំងអស់ក្នុងលោកបានឡើយ។ លក្ខណៈនោះគឺជំនឿ ការប្រតិបត្តិ អារម្មណ៍ ចិត្តព្រឹត្តភាពឬអាការៈជាដើម (Beliefs, practices, feelings, moods, attitudes etc.)។ វាខុសពីសាសនាមួយទៅសាសនាមួយ ត្រង់ប្រយោគ (Employment) ឧបយោគ (Utility) និង ការអនុវត្តន៍ (Application)។ យើងអាចប្រៀបការផ្សេងគ្នានៃសាសនាទ្រឹស្តី និងការប្រតិបត្តិទៅនឹងលទ្ធិឬមនោគមវិជ្ជា សម័យថ្មីបាន ដោយហេតុថា លទ្ធិឬមនោគមវិជ្ជា ទោះណាជាមានគោលការនិងទីដៅតែមួយ គឺការរក្សាការ រៀបរយ និងការបំពេញសេចក្តីត្រូវការនៃប្រជាពលលោកក៏ដោយ តែងមានលក្ខណៈ កិច្ចការនិងកាតព្វកិច្ច ផ្សេងៗគ្នាជាដរាប។ យើងឱ្យអត្ថន័យយ៉ាងនេះក៏បាន “សាសនា ណាដែលមានពាក្យប្រៀនប្រដៅ មានមូលដ្ឋានទៅលើព្រះម្ចាស់សួគ៌ ព្រះព្រហ្ម ឬព្រះអាទិទេព ហៅថា “លទ្ធិ” សាសនាណាដែលផ្ទុយពីលក្ខណៈខាងលើនេះ ហើយមានមូលដ្ឋានទៅលើភាពពិតទាំងស្រុងហៅថា “សាសនា”។ ប៉ុន្តែគួរយើងសំគាល់ថា ជួនកាលអក្សរនៃលទ្ធិ ឬមនោគមវិជ្ជានោះៗដូចគ្នា តែអត្ថនិយមត្រូវគ្នា តែអក្សរផ្សេងគ្នាក៏មាន។ សាសនាទាំងអស់ក្នុងលោកក៏មានលំនាំស្រដៀងគ្នានឹងលទ្ធិឬមនោគមវិជ្ជាទាំងឡាយក្នុងលោកដែរ។ តែសាសនាលទ្ធិ ឬមនោគមវិជ្ជានោះៗ ត្រូវយើងយល់ថា មានអក្ខរារូប អត្ថរូប សរីររូប និងចិត្តរូបជាឯកភាព

រៀងៗខ្លួន។ អ្នកសិក្សាក៏ត្រូវស្រាវជ្រាវតាមរូបនោះៗ ហើយប្រៀបធៀបគ្នា ដើម្បីរកចំណុចស្របនិងផ្ទុយគ្នានៃសាសនា លទ្ធិឬមនោគមវិជ្ជានោះៗ ឬក៏រកការប្រសើរវិសេស ជាងគ្នានៃសាសនា លទ្ធិឬមនោគមវិជ្ជានោះៗ។ ជាពិសេសការរកបែបនេះ ឈ្មោះថារកធម្មតាពទូទៅ (General Law) នៃការសិក្សាសាសនាប្រៀបធៀបនេះ។

យើងអាចសន្និដ្ឋានយកអត្ថន័យនៃសាសនាថា ៖ "ពាក្យបណ្ដាំ ពាក្យផ្ដាំផ្ញើពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ពាក្យប្រកាស ការប្រកាសប្រាប់ការជឿស្ដាប់ ការដាក់ទណ្ឌកម្ម ការផ្ដាលទោស ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា "តាមវចនានុក្រមខ្មែរក៏បាន"។ ប៉ុន្តែការពោលមកទាំងអស់នេះ មានការទាក់ទងត្រឹមតែរូបសព្ទជា "សាសនៈ ឬសាសនា" ប៉ុណ្ណោះ ពុំបានទាក់ទងដល់ គោលជំនឿ ទ្រឹស្ដី ការប្រតិបត្តិសាសនាពិធី ទីដៅដែលសាសនាបានកំណត់សម្រាប់អ្នកប្រតិបត្តិ អារម្មណ៍ ចិត្តព្រឹត្តភាពនិងអាការៈនៃសាសនាមួយៗក្នុងលោកឡើយ។ ឯមុខងារនៃសាសនាទាំងអស់ ទោះណា ជាមាន លក្ខណៈទ្រឹស្ដីនិងការប្រតិបត្តិផ្ទុយ ឬស្របគ្នាក៏ដោយ តែងមានគោលការសម្រាប់បំពេញដល់សេចក្ដីត្រូវការនៃមនុស្សលោកដូចនេះ ៖

១-សម្រាប់បម្រើសេចក្ដីត្រូវការរបស់មនុស្សម្នាក់ៗ (Individual)

២-សម្រាប់ធ្វើសម្ពន្ធភាពនៃមនុស្សម្នាក់ៗទៅនឹងអ្នកដទៃ (In its relation to others)

៣-សម្រាប់សម្ពន្ធភាពនៃជនគ្រប់រូបទៅនឹងទីបំផុតទុក្ខ នឹងព្រះអាទិទេព ឬវត្ថុស័ក្ដិសិទ្ធិ (In its relation to the higher power)

ទី១ និងទី៣ ទាក់ទងនឹងបញ្ហាជីវិតបច្ចុប្បន្ន និងវាសនាបន្ទាប់ពីសេចក្ដីស្លាប់ជីវិតអនាគតនៃបុគ្គលម្នាក់ៗរស់នៅឬនៅនឹងសង្គមលោកជិតខាង។

**គ-វិធីសិក្សានៃសាសនា (Methods for Religious studies)**

ដើម្បីសិក្សាឱ្យយល់ច្បាស់និងរកធម្មតាពទូទៅនៃសាសនាវិស័យនេះ យើងត្រូវដឹងជាចាំបាច់នូវវិធីសិក្សានៃសាសនា។ បានជាយើងត្រូវដឹង ព្រោះតាមធម្មតាគ្រប់តែអ្នកអាន តែងតែចង់ដឹងពីសាសនារបស់ខ្លួន ត្រង់ចំណុចនិងមូលហេតុទាំងឡាយដ៏សំខាន់ៗនៃសាសនានោះៗ។ គេពុំសូវយកចិត្តទុកដាក់ពិនិត្យត្រង់សញ្ញាណ ទូទៅនៃសាសនាទាំងអស់ក្នុងលោកឡើយ។ ជាពិសេសគេច្រើនតែយកការប្រកាន់ស្អិតនៃចិត្តនិងជំនឿផ្ទាល់ ខ្លួនមកធ្វើជា មូលដ្ឋានហើយផ្ដេកទៅលើការពិសោធន៍ការត្រិះរិះឬចិន្តា ឧត្តមគតិនិងវិធីសិក្សារបស់ ខ្លួនថា ជាសច្ចធម៌ឬបរមត្ថធម៌។ ទាំងនេះមកពីគេភ្លេចថា "ចិត្តកក្ដីពុំមែនជាវិទ្យាសាស្ត្រ (Faith is not science)។ ម្យ៉ាងទៀត ដើម្បីឱ្យជាក់ច្បាស់ជាងនេះទៅទៀត អ្នកកាន់សាសនាដូចគ្នា ឬ

ជាមួយគ្នា គង់មានការពិសោធន៍ ចិន្តានិងឧត្តមគតិខុសគ្នាដែរ ឧទាហរណ៍ពុទ្ធសាសនាបែកជាពីរនិកាយធំៗគឺ មហាយាននិងហីនយាន ឬដូចជា កាតូលិក និងប្រូតេស្តង់ជាដើម។

ដូចពោលមកខាងលើនេះ យើងឃើញថាមនុស្សលោកចូលចិត្តប្រើការពិសោធន៍ចិន្តាឧត្តមគតិ និងវិធីសិក្សាផ្សេងៗគ្នាទៅលើលទ្ធិចាស់ឬថ្មី មនោគមវិជ្ជាចាស់ឬថ្មី ឬក៏សាសនាបែបចាស់ឬថ្មី សូម្បីលទ្ធិមនោគមវិជ្ជា ឬសាសនាជាមួយគ្នាឬដូចគ្នាក៏ដោយ មិនចាំបាច់ពោលដល់របស់ដទៃឡើយ។ កាលបើការផ្សេងគ្នាខាងយោបល់និងវិធីសិក្សាកើតឡើងក្នុងបញ្ហាទាំងឡាយនៃសាសនាតាមបុគ្គលម្នាក់ៗ ហើយយើងមិនអាចសិក្សារកធម្មភាពទូទៅនៃសាសនាបានឡើយ។ ហើយការចាប់ផ្ដើមជាដំបូងជាមួយទ្រឹស្ដីនិងការប្រតិបត្តិ ឬការវិនិច្ឆ័យនូវបរមត្ថធម៌ ឬក៏សូម្បីផ្ដើមយកចំណុចសំខាន់ណាមួយមកប្រឆាំង និងចំណុចណាមួយរបស់សាសនាណាមួយ នឹងក្លាយទៅជាការឥតប្រយោជន៍សម្រាប់ការចេះដឹងទូទៅទៅវិញ។ ដូចនេះ ការចេះវិធីសិក្សាសាសនា ជាដំបូងជាការចាំបាច់បំផុតសម្រាប់និស្សិតខាង សាសនាទូទៅ ដើម្បីកម្ចាត់បង់ការយល់ខុស និងការភ្លាំងភ្លាត់ ក្នុងការសម្រេចរកច្បាប់ជាឯករូបនិងធម្មភាពទូទៅនៃសាសនាវិស័យ។

ឯវិធីសិក្សានៃសាសនាគឺ ៖ ១-វិធីប្រៀបធៀប ២-ប្រវត្តិសាស្ត្រវិធីនិងសង្គមវិទ្យាវិធី ៣-ចិត្តវិទ្យាវិធី និង ៤-ទស្សនវិជ្ជាវិធី។

**ឃ-ការសរុប (Generalization)**

បណ្ដាវិធីទាំង ៤ នេះ វិធីប្រៀបធៀបគឺសម្រាប់សិក្សាវិទ្យាសាស្ត្រដែលមិនមានទីពិសោធន៍ដូចជា សេដ្ឋកិច្ចវិទ្យា សាសនាជាដើម ជាមួយនឹងវិធីសិក្សាទាំងពីរខាងដើម ដែលគេទុកជាបុព្វភាគ និងប្រព័ន្ធវិភាគ ដែលគេទុកជាជំនួយដល់វិធីប្រៀបធៀបនេះ។ ក្នុងពិធីរកធម្មជាតុ ឬបាតុភូតនៅក្នុងការសិក្សាសាសនាប្រៀបធៀប យើងត្រូវយកវិធីសិក្សាទាំងពីរខាងដើមមកប្រើគឺ ៖ ការសង្កេតនិងការតម្រៀបតាមមជ្ឈដ្ឋាននៃការសន្និដ្ឋាន (Hypothesis) របស់អ្នកសិក្សា។ ឯការសន្និដ្ឋានក្នុងកម្មវិធីសិក្សាយើងនេះគឺ ៖ "ចំណុចស្រប និងផ្សេងគ្នានៃលោកធាតុ សភាពមនុស្សក្នុងបច្ចុប្បន្ន និងវាសនាបន្ទាប់ពីសេចក្ដីស្លាប់ សីលធម៌ និងសាសនពិធីនៃមហាសាសនាទាំង៥"។ ការសន្និដ្ឋាន ត្រូវតែប្រាកដនិងច្បាស់លាស់ដូចខាងលើនេះ ដើម្បីងាយស្រួលដល់ការសង្កេតនិងការតម្រៀបមូលហេតុនិងធម្មជាតុ ឬបាតុភូដែលមានក្នុងសាសនាមួយៗ។ វិធីសង្កេតត្រូវប្រតិបត្តិនៅក្នុងខេត្តការ (Fieldwork) ជាទីពិសោធន៍ ទីសម្រាប់ប្រតិបត្តិការនៅលើភូមិភាគដែលអ្នកសិក្សា បានកំណត់សម្រាប់ធ្វើ ការ

ពិសោធន៍ ដើម្បីរកបាតុភូតដែលមានក្នុងសាសនាមួយៗ។ បាតុភូតដែលប្រមូលបាននោះឈ្មោះថា (Ethnographic data) ឯកសារសេមោជាន ហើយបាតុភូតមួយៗ ត្រូវតែធ្វើអត្ថាធិប្បាយឱ្យ ពិស្តារទៀងទាត់ពិតនិងមុះមុតទៅតាមព្រំដែន ទីដៅកំណើត ប្រក្រតី ព្រមទាំង ឱ្យអត្ថន័យនៃអក្សរនិងអត្ថនិយម។ តមកយើងត្រូវយកវិធីតម្រៀបមកប្រតិបត្តិ។ យើងត្រូវធ្វើ ៖

១-ត្រូវតម្រៀបបាតុភូតឱ្យមានអង្គការជាប្រព័ន្ធ (Systematic organization)

២-ត្រូវតម្រៀបបាតុភូតឱ្យមានកក្តីភាព អនុមានការី (Inductive) និង

៣-បាតុភូតដែលមិនត្រូវគ្នា ត្រូវដកចេញ និងបាតុភូតដែលត្រូវគ្នា ត្រូវបញ្ចូល។

កាលបើយើងបានតម្រៀបបាតុភូតទាំងអស់រួចហើយ យើងត្រូវយកវិធីប្រៀបធៀបមកអនុវត្ត ហើយក្នុងការអនុវត្តន៍នេះ យើងត្រូវយកប្រព័ន្ធវិភាគមកប្រើជាជំនួយដល់វិធីប្រៀបធៀបផង ដើម្បីរែកញែកបាតុ ភូតទាំងអស់នៃសាសនាទាំង ៥ ដែលមានចំណុចដូច ឬ ស្រប និងផ្សេងគ្នា។ ការធ្វើដូចនេះ គឺដើម្បីរកការសំអាង និទស្សន៍ និងសប្រមាន ឬប្រត្យក្សនៃការសន្និដ្ឋានដែលយើងបានកំណត់ទុកជាមាគ៌ាសម្រាប់ប្រតិបត្តិការ។ តមក ការបើការសន្និដ្ឋាននោះមាននិទស្សន៍រួចហើយ យើងអាចអនុវត្តវិធីសិក្សាមួយទៀតគឺ ការសរុប (Generalization) ។ វិធីសរុបនេះ គេអនុវត្ត ដើម្បីរកច្បាប់ជាសមានភាព (General law ) នៃសាសនាប្រៀបធៀបនោះ ដែលជាប្រណិធានឬជាចិរភាពទីបំផុតនៃវិទ្យាសាស្ត្រទាំងអស់ខាងសង្គម។

២-ប្រវត្តិសាស្ត្រវិធី និងសង្គមវិទ្យាវិធី ៖ វិធីសិក្សាទាំងពីរនេះ ជាគ្រឿសម្រាប់ចុះមើលការរីកចម្រើនការស្វែងរកចិរភាពនិងលទ្ធភាពនៃស្ថានការណ៍ដែលកើតឡើងក្នុងយុគសម័យសាសនាមួយៗ។ វិធីសិក្សាទាំងពីរនេះ គេប្រើជំនួយគ្នាទៅវិញទៅមក។ តាមពិតសាសនានីមួយៗដែលកើតឡើង ក្នុងលោកតែងទាក់ទងឬមានសម្ព័ន្ធភាពជាមួយ នឹងនយោបាយសេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ និងប្រជាជន។ ក្នុងទីនេះ យើងត្រូវចាប់អារម្មណ៍ថែមទៀត ទៅលើឥទ្ធិពលទូទៅនៃវត្ថុជុំវិញខ្លួន (បរិវិគតៈ) (Environment) ដូចជាស្រុកភ្នំ ទីវាល សមុទ្រ ខ្សាច់ (ឬវាលខ្សាច់) ជាដើម ដែលមានការទាក់ទងដ៏ជិតស្និទ្ធជាមួយនឹងវប្បធម៌ខ្ពស់ឬទាបព្រម ទាំងឧបាយនៃការទាក់ទងរវាងគ្នានិងគ្នា (Means of communication)។ មិនតែប៉ុណ្ណោះ ប្រវត្តិសាស្ត្រវិធី ដោយមានភូមិសាស្ត្រជាជំនួយ ត្រូវយកទៅពិនិត្យទៀតនូវបរិវិគតវត្ថុដែលផ្តល់អាហារដល់មនុស្សជាតិ ព្រមទាំងជីវភាពទូទៅនៃប្រទេសភូមិភាគនោះៗ។ បរិវិគតវត្ថុទាំងអស់នេះ តែមានឥទ្ធិពលទៅលើផ្នត់គំនិតខាងសាសនា ដូចជាការបរបាញ់សត្វ និង

កសិកម្មជាដើម ដែលជាមាគ៌ាតែមួយនៃអាជីវកម្មនៃសង្គមមនុស្សបូរាណ ។ ការពោល មក នេះ គឺចំពោះប្រវត្តិសាស្ត្រវិធី ដែលគេប្រើសម្រាប់ចុះមើលការរីកចម្រើនខាងផ្នត់គំនិតនៃសាសនារបស់ប្រជាជនបូរាណ។ ព័ត៌មាននិងឯកសារទាំងឡាយដែលជាជំនួយ ដល់អ្នកប្រើប្រវត្តិសាស្ត្រវិធីក្នុងការពិនិត្យសាសនាបូរាណនោះគឺ ៖ ១-ប្រវត្តិសាស្ត្រវប្បធម៌បូរាណនៃប្រទេស ឬតំបន់ ឬក៏សង្គមមនុស្សនៅក្នុងលោក បើប្រសិនជាមាន ២-សេចក្តីរាយការណ៍នៃបូរាណវត្ថុ បើប្រសិនជាមាន ៣-សេចក្តីរាយការណ៍ពីនរជាតិពន្ធសាស្ត្រ (Ethnology) ៤-ពហុភាសាវិទ្យា (Linguistic) ៥-សិលាចារឹក និងសេចក្តីរាយការណ៍ ៦-បើប្រសិនជាពុំមានទាំង ៥ នេះទេ យើងត្រូវប្រើសង្គមវិទ្យា វិធីទៅពិនិត្យនិងសិក្សាដោយផ្ទាល់។

ចំពោះការរីកចម្រើននៃសាសនា យើងក៏ត្រូវប្រើប្រវត្តិសាស្ត្រវិធី និងសង្គមវិទ្យាវិធីដែរ។ ដោយហេតុថា សាសនាទាំងអស់នោះមានកំណើត អាយុ និងកន្លែងកើតខុសគ្នា ព្រមទាំងការរីកចម្រើននិងការវិវត្តក៏ខុសគ្នាទៀត តាមស្ថានហេតុនយោបាយ សេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ និងប្រជាជន។ ការប្រែប្រួល ការកែទម្រង់ ការរីកចម្រើននិងការវិបត្តិនៃសាសនានោះៗ កើតមានឡើងតាមយុគនិងសម័យ ដោយសារការបង្ខំការសង្កត់សង្កិនពីស្ថាន ការណ៍នយោបាយ សេដ្ឋកិច្ចសង្គម និងប្រជាជនជាដើមនៃប្រទេសនីមួយៗ។ ជាពិសេស ទៅទៀតសាសនាទាំងអស់នេះបានផ្សាយពាសពេញសាកលលោក ហើយថែមទាំងរលាយចូលជាមួយនឹងទំនៀមទម្លាប់ស្រុកនីមួយៗថែមទៀត។ ទាំងអស់នេះ បញ្ជាក់ឱ្យឃើញថាជាកត្តាសម្រាប់យកប្រវត្តិសាស្ត្រវិធី និងសង្គមវិទ្យាវិធីទៅពិនិត្យ។ ពត៌មាននិងឯកសារទាំងឡាយដែលជាជំនួយដល់វិធីសិក្សាទាំងពីរនេះ មានគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សាតាមយុគនិងសម័យនៃការប្រែប្រួល វិបត្តិ និងការរីកចម្រើន ដូចបានពោលហើយខាងដើមក្នុងវិធីសិក្សាសាសនាបូរាណតាំងពីលេខ ១ ដល់លេខ ៥។ ឯត្រង់លេខ ៦ បើ យើងចង់បញ្ជាក់ពីសេចក្តីពិតដែលមាននៅក្នុងឯកសារនោះៗ ហើយនិងជីវភាពនៅបច្ចុប្បន្ននេះ យើងត្រូវ ប្រើខត្តការវិធីនៃសង្គមវិទ្យា ដើម្បីធ្វើការសិក្សាសាសនានេះឱ្យ វិសេសវិសាលតាមរបៀបវិទ្យាសាស្ត្រថែមទៀត។

៣-ចិត្តវិទ្យាវិធី ៖ គេត្រូវតែធ្វើការពិនិត្យនិងសង្កេតទ្រឹស្តីទាំងឡាយនៃការរីកចម្រើនសាសនា តាមការផ្លាស់ប្តូរនៃប្រវត្តិសាស្ត្រ និងទិដ្ឋភាពនៃចិត្តវិទ្យារបស់សាសនាទាំងអស់ក្នុងលោក។ កាលណាសាសនាណា មានភាពស្មុគស្មាញខាងផ្លូវគំនិត សាសនានោះមុខជាបញ្ជាក់ពីភាពស្មុគស្មាញខាងផ្លូវគំនិត សាសនានោះមុខជាបញ្ជាក់ពីភាពស្មុគស្មាញខាង

*ប្រវត្តិសាស្រ្តជាប្រាកដ។ ព្រោះតាមពិតភាពស្មុគស្មាញខាងប្រវត្តិសាស្រ្តតែងបង្កើតភាពស្មុគស្មាញខាងគំនិត។ ប្រវត្តិសាស្រ្តវិធី យើងបាននិយាយរួមមកហើយ នៅទីនេះ ត្រូវយកចិត្តវិទ្យាវិធី ទៅប្រើក្នុងការពិនិត្យភាពស្មុគស្មាញខាងផ្លូវគំនិត។*

*ក្នុងសេចក្តីពិតតាមការរីកចម្រើនខាងផ្លូវគំនិត យើងសង្កេតឃើញថា ចលនានៃគំនិតមានការផ្លាស់ប្តូរជាញឹកញាប់ ពិបាកនឹងកត់សម្គាល់ណាស់ ទោះណាជាការផ្លាស់ប្តូរនោះបានទុកលទ្ធផលជានិត្យភាពយ៉ាងណាក៏ដោយ។ ទាំងអស់នេះ គឺជាលទ្ធភាពនៃព្រឹត្តិការណ៍ជាបឋមដ៏យឺត ដែលស្ទើរតែកត់សម្គាល់ពុំបាន។ បរិវិគតវត្ថុទាំងអស់នេះ មានចលនាយ៉ាងយឺតជាងការកែទម្រង់ឬនិន្នាការនៃការកែទម្រង់ ដែលជាស្ថានិកភាព ជាឯកប្បញ្ញត្តិ ជាអបរិបណ្ណភាពនិងជាពិសេសជាអន្តិមភាព។ សេចក្តីពិតរបស់ការរីកចម្រើននៃសាសនាទាំង អស់ក្នុងលោក និងសម្ព័ន្ធភាពរវាងសម័យខុសគ្នានៃព្រឹត្តិការណ៍ គេអាចធ្វើឱ្យជាក់ច្បាស់តាមការសិក្សានៃប្រវត្តិសាស្រ្ត។ ទាំងអស់នេះបានបញ្ជាក់ឱ្យឃើញថា ជំនឿនិងទំនៀមទម្លាប់ ពុំអាចរសាយចូលគ្នាជាស្វ័យប្រវត្តិដោយងាយបានទេ ថែមទាំងបានបញ្ជាក់ថា កត្តាទាំងឡាយទោះជាជាតិពន្ធុសាស្រ្ត និងវប្បធម៌ក្តី ឬជាប្រវត្តិសាស្រ្តក្តី តែងមានចិត្តវិទ្យាជាមូលដ្ឋាន។ តាមចំណុចនៃចិត្តវិទ្យានេះ យើងសង្កេតឃើញថា បញ្ហាទាំងឡាយនៃឥទ្ធិពលខាងក្រៅមិនសូវសំខាន់ប៉ុន្មានដូចជា ចិត្តកត្តា និងចិត្តព្រឹត្តិដែលសម្បយុត្ត ឬមានសំយោគ ជាមួយនឹងសមត្ថភាពនៃឯកត្តជនសម្រាប់ទទួលរក្សានិងប្រើប្រាស់ឧត្តមគតិខ្លះ ការរីកចម្រើននៃចិត្តជាបឋមខ្លះ សេចក្តីត្រូវការនិងការដេកដង្ហើមស្រួលនៃមនសម្ព័ន្ធ ចរិយាសម្ព័ន្ធ និងធម្មិកសម្ព័ន្ធខ្លះនៃឯកត្តជននោះៗ។ ការពោលមកនេះ គេចង់បញ្ជាក់ឱ្យឃើញថា ចិត្តវិទ្យាវិធី គឺត្រូវតែទាក់ទងជាមួយមនុស្សលោក សម្រាប់ត្រួតពិនិត្យមើលចិត្តសម្បទា ផលប្រយោជន៍ និងការថ្លៃថ្នូរនៃមនុស្សលោកនោះៗ ព្រមទាំងពិនិត្យនិងសិក្សាពីសម្ព័ន្ធភាពរវាងសាសនាឬធម៌ ជាមួយនឹងជីវភាព និងគំនិតនៃមនុស្សលោកនោះៗថែមទៀត។ ជាពិសេសទៀត ចិត្តវិទ្យាវិធីនេះគេប្រើពិនិត្យនូវតម្លៃរបស់អត្តនិយមនៃ ជំនឿនិងការប្រតិបត្តិនៃឯកត្តជន។ តែមុននឹងប្រតិបត្តិការចិត្តវិទ្យាវិធីនេះ គេត្រូវតែធ្វើការស្រាវជ្រាវពាវរក ឱ្យពិតប្រាកដនូវកត្តាទាំងឡាយដែលមានសម្ព័ន្ធភាពជាមួយគំនិតជាសារវន្ត មុនពេលកថាពន្ធ* (Symthetic statement) *។ ធ្វើដូច្នេះដើម្បីកុំឱ្យមានការស្មានពីអ្វីទាំងអស់ ដែលទាក់ទងដល់ព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិរបស់សាសនាមួយៗក្នុងលោក។ តាមធម្មតា មនុស្សលោកមានការពិសោធន៍ ដែលបង្ខំឱ្យចែកអ្វីដែលហៅថា “ទេវៈ” បញ្ហាធំៗទាំងឡាយដែលមនុស្សលោកត្រូវជួបប្រទះ។*

លក្ខណៈនៃចិត្តវិទ្យាខាងសាសនាមាន ២ ប្រភេទ ៖

១-ចិត្តសម្បទានៃមនុស្ស

២-ប្រជុំនៃឯកសារសោមោជានផ្នែកជំនឿនិងការប្រតិបត្តិទាំងអស់នៃសាសនា។

ឯវត្ថុបំណងទូទៅនៃចិត្តវិទ្យា គឺក្ជាប់លក្ខណៈសំខាន់ដែលរួបរួមសភាវធម៌ និងអសភាវធម៌នៃប្រក្រតីរបស់មនុស្សជាតិដូចជា ទេវសភាវៈនៃព្រះរាជា សន្តិជននិងវីរជនក្នុងអតីតកាលដែលមានសភាពដូចគ្នានិងវីរភាពរាជគោរពនិងបុព្វគោរពជាដើម។ ទាំងនោះគឺ បញ្ជាក់ពីការអស្ចារ្យនៃបុគ្គលិកភាពនៃឯកត្តជនជាមេដឹកនាំ នៃពួកក្រុមសមាគមនិងសាសនា ដែលមានអាការៈផ្សេងៗពីគ្នា។ការអស្ចារ្យនៃបុគ្គលិកភាពរបស់មេដឹកនាំនៃក្រុមពួកសមាគម និងសាសនាទាំងអស់នោះ តែងមានឥទ្ធិពលទៅលើទឹកចិត្ត និងបុគ្គលិក ភាពនៃសិស្ស សាវកទាំងឡាយដែលមានអាកប្បកិរិយា អន្តរកិរិយាច្បាស់លាស់នៅបច្ចុប្បន្នកាលនេះ។ ម្យ៉ាងទៀត ការសិក្សាប្រក្រតីនៃមនុស្សជាតិ តាមលក្ខណៈចិត្តវិទ្យាទូទៅ ត្រូវទាក់ទងដល់ សភាវៈទាំងឡាយ ដូចជា បាប បុណ្យ ការខមាទោស ឬសម្តែងទោស ការអត់ទោសឱ្យការ បូជា ស្មរណាបិភោជ (Participation in Lord's Supper) ការសូត្រធម៌បួងសួង ការសម្លាប់សត្វបូជាព្រះអាទិទេព ឬសម្លាប់មនុស្សបូជាអាទិទេព ជាដើម។ មិនតែប៉ុណ្ណោះ យើងត្រូវពិនិត្យថែមទៀតនូវការពិត ដែលទាក់ទងដល់ប្រក្រតីនៃមនុស្សជាតិ ដើម្បីពិនិត្យនូវគំនិតនៃសាសនាទូទៅ។ ឯសាសនាធំៗទាំង ៥ តែងតាមទិដ្ឋភាពទូទៅផ្នែកចិត្តវិទ្យាគ្រប់គ្រាន់ សម្ភារៈសម្រាប់វិទ្យាសាស្ត្រនៃប្រក្រតីរបស់មនុស្សជាតិ។ ការសិក្សាចិត្តសម្បទានៃមនុស្ស គឺជាការសំខាន់ បំផុតដើម្បីពុទ្ធិទូទៅនៃសាសនា ហើយនឹងបរមធម៌ថែមទៀត។ ការទូទៅ ចិត្តវិទ្យាវិធី ត្រូវប្រើដើម្បីរក ៖

ក-ការសំខាន់ និងមូលដ្ឋានដូចគ្នាខាងផ្លូវចិត្តគ្រប់មនុស្សជាតិនៅក្រោមជំនឿ និងការប្រតិបត្តិផ្សេងៗគ្នា។

ខ-តម្លៃអត្តនិយម (Introspection) របស់ឯកត្តជននៃសាសនាខ្លួន និងស្ថានការណ៍ដទៃទៀត ដែលផ្សេងគ្នាពីតម្លៃ ឬការថ្លៃថ្នូររបស់មនុស្ស ឬបរិកតវត្ថុដទៃទៀត។

គ-និន្នាការនៃសាសនា។

៤-ទស្សនវិជ្ជាវិធី ៖ ទស្សនវិជ្ជាមានអត្ថន័យថា ការគិតអំពីលោក ជាពិសេសអំពីមនុស្សលោក ហើយអត្ថន័យនេះបានប្រព្រឹត្តទៅក្នុងលក្ខណៈដ៏ពិតប្រាកដ។ ប៉ុន្តែអត្ថន័យនេះត្រូវការធ្វើអត្ថាធិប្បាយបន្ថែម ហើយត្រូវមានតក្កវូបជាមូលដ្ឋាន ដើម្បីតម្រូវលក្ខណៈពិសេសនៃទស្សនវិចារណ៍ថែមទៀត។ ប្រធានារម្មណ៍នៃទស្សនវិជ្ជា គឺការពិសោធន៍ទូទៅ

*ក្នុងបញ្ហាសោកនិងសត្វលោក។ វត្ថុបំណងនៃទស្សនវិជ្ជា គឺដើម្បីបង្ហាញ នូវគោលការណ៍ដ៏សំខាន់បំផុតដែលទាក់ទងដល់វិចារណ៍ទូទៅដែលឱ្យមានជាតំណ អត្ថន័យ និងតម្លៃទៅលើការពិសោធន៍ទូទៅ។ គេបានចែកទស្សនវិជ្ជា ៖ ១-សីលធម៌ (ភាគទ្រឹស្តីនិងភាគប្រតិបត្តិ), អត្ថិរូបនិយម (ភាគទ្រឹស្តីនិងភាគអនុវត្ត)។ កាលបើសិស្សនិងអស្តិរូបនិយមទាំងពីរនេះមានលក្ខណៈពិតប្រាកដឡើង ហើយមានតក្ករូបជាមូលដ្ឋាន ទើបទស្សនៈនោះក្លាយជាប្រព័ន្ធពិតប្រាកដជាពិសេសទស្សនៈ ដែលមានប្រព័ន្ធពិតប្រាកដហើយនោះ តែងមានលក្ខណៈដោះស្រាយបញ្ហាលោកនិងសត្វលោក ៖ បញ្ហាពុទ្ធិ បញ្ហាសុខៈ បញ្ហា ភាវៈ។*

*ដូចម្តេចបានជាសាសនាត្រូវការយកទស្សនៈមកបកស្រាយ ? យើងអាចឆ្លើយថា ពីព្រោះសាសនាមានទិដ្ឋភាពដ៏សំខាន់ នៃការពិសោធន៍របស់មនុស្សលោក។ម្យ៉ាងទៀត សាសនាមានប្រវត្តិសាស្ត្រដ៏ពិតប្រាកដ ដែលមានកំណើតឡើងជាមួយនឹងវឌ្ឍនាការ ជាមួយនឹងសង្គមលោក។ ជាពិសេសទៅទៀត សាសនាគឺជាតំណាងនៃកំណើតរបស់អន្តោវិសោធនកិច្ច* (The existence of winner experienced activitied) ។

*ទស្សនសាសនាដែលពិនិត្យបញ្ហាលោកនិងសត្វលោក មានលក្ខណៈផ្សេងពីសាសនាមួយទៅសាសនាមួយ ទៅសាសនាមួយទៀត។ អ្នកសិក្សាត្រូវយកទស្សនវិធីទៅពិនិត្យសាសនាគឺ ៖ -ការផ្សេងខាងគំនិតរវាង ប្រជាជនដើមនិងអារ្យជន, ២-គំនិតមានហេតុផលនៃអារ្យជននិងប្រជាជនដើម, ៣-ការផ្សេងគ្នានៃគំនិតជាលោកិយ៍និងលោកុត្តរៈនៃសាសនានីមួយៗ, ៤-គំនិតផ្សេងគ្នារវាងមនុស្សម្នាក់ៗ និងក្រុមឬពួកដែលគេហៅថា បុគ្គលិកញាណនិងសហញាណ* (Individual and collective consciences) , *៥-សេចក្តីពិតតាមការសន្មត និងសេចក្តីពិតតាមធម្មជាតិ ព្រមទាំងធម្មជាតុ និងធម្មភាពខាងផ្លូវគំនិត, ៦-មនុស្សលោកនិងអាទិទេព ឬព្រះ និព្វានឬមោក្សៈ, ៧-សភាពមនុស្សលោក និងវាសនាបន្ទាប់ពីសេចក្តីស្លាប់, ៨-ទ្រឹស្តីនិងការអនុវត្ត, ៩-លោកជាតុ។*

## ឧទ្ទិសកថា

*ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ចំពោះវិញ្ញាណក្ខន្ធមាតាបិតា បងប្រុស បងស្រី និង បុព្វការីជនដល់អ្នកស្នេហាជាតិគ្រប់ជំនាន់ ដែលបានចាកឋាន ដោយបុព្វហេតុជាតិមាតុភូមិ !*

**បណ្ឌិតសភាចារ្យ ខ្លួត ធីតា**

- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
- ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតី-តេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន**
- ទទួលបន្ទុកការងារធម្មការ និង សាសនា
- អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ
- សមាជិកគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

# សេចក្តីផ្តើម

នៅពេលដែលមនុស្សបានជួបប្រទះនូវការជិះជាន់កេងប្រវ័ញ្ចពីអ្នកដទៃ ឬត្រូវគេបៀតបៀន លួច ប្លន់...។ល។ មនុស្សតែងតែពឹងផ្អែកទៅលើជំនឿផ្សេងៗក្រៅខ្លួនដើម្បីរស់។ ក្រោយមកគេមិនអាចយកជ័យជំនះ រួមទាំងការរស់នៅដោយទទួលរងនូវអំពើឃោរឃៅទៀតផងនោះ ទើបមនុស្សខិតខំស្វែងរកនូវគោលការណ៍អ្វីមួយជា ចាំបាច់សម្រាប់ការពារខ្លួនរបស់គេ។ ជាមួយនឹងការស្វែងរកសេចក្តីសុខមនុស្សនាំគ្នាបង្កើតនូវជំនឿ ទំនៀមទម្លាប់សាសនាដើម្បី ជាបង្អែកសម្រាប់រស់នៅឱ្យបានល្អប្រពៃទៀតផង។ ពេលខ្លះគេមានការតស៊ូរើបម្រះយ៉ាងខ្លាំង ហើយសំឡេងស្រែកហៅរកយុត្តិធម៌ សីលធម៌ ព្រះធម៌ មនុស្សធម៌ (ព្រះ) កើតមកជាមួយគ្នាផងដែរ។

សង្គ្រាមបានកើតឡើង យើងក៏បានឮសូរសម្រែកគ្រប់ទិសទី "យុត្តិធម៌" ប្រហែលជាបាត់សាបសូន្យ អស់ហើយមើលទៅ? ព្រះធម៌បានលេចចេញជារូបរាងតំណាលគ្នានឹងរូបរាងសង្គមមនុស្ស។ សង្គមតែងតែលើកឡើងនូវសីលធម៌សាសនាទាំងនេះ ចំពោះសមាជិកសង្គម រីឯច្បាប់និងសីលធម៌បានវិវត្តព្រមគ្នានឹងការវិវត្តរបស់សង្គមក្រោមទ្រង់ទ្រាយនៃទំនាក់ទំនងផលិតកម្ម។

សង្គមបុព្វកាលសីលធម៌ពុំសូវមានតម្លៃទេ។ សីលធម៌មានលក្ខណៈជាសាកលសម្រាប់សមាជិកទាំងអស់នៅពេលដែលមានវណ្ណៈកើតឡើង និងតម្រូវឱ្យសីលធម៌អនុលោមទៅតាមផលប្រយោជន៍របស់វណ្ណៈនីមួយៗ។ ទស្សនវិទូក្រិចបុរាណសម័យបានលើកឡើងនូវទស្សនៈសីលធម៌ ទៅតាមការពិចារណា របស់គាត់ដើម្បីអប់រំដល់ជីវិតរស់នៅរបស់មនុស្ស។

ចិត្តលោភលន់គ្មានព្រំដែន ការលោភអំណាច ស្រឡាញ់កិត្តិយស បុណ្យស័ក្តិ មាសប្រាក់ហួសហេតុ គឺជាការបាត់បង់ សីលវិទ្យារវាងបុគ្គលគ្រួសារ និងសង្គមនេះឯង។ សង្គ្រាមអូសបន្លាយរហូត ធ្វើឱ្យបុគ្គលមួយចំនួនឆ្លៀតឱកាសប្រើប្រាស់សីលធម៌ខុសទិសដៅ ឬបំពានលើសីលធម៌ ប្រព្រឹត្តអំពើអសីលធម៌ដើម្បីកេងយកចំណេញ។ ពេលនោះចោរកម្មអំពើភេរវកម្ម ក៏មានមិនចេះចប់មិនចេះហើយធ្វើឱ្យមនុស្សទូទាំងពិភពលោកទទួលរងនូវភាពដ៏គួរឱ្យភ័យរន្ធត់។

ព្រះធម៌ជាបញ្ញត្តិមួយគ្មាននរណាម្នាក់ស្អប់ទេ សូម្បីតែសត្វក៏ពេញចិត្តជាមួយសកម្ម-ភាពដែលមានធម៌របស់ម្ចាស់វាដែរ ប៉ុន្តែហេតុអ្វីក៏ពិភពលោកនៅមានសង្គ្រាមឥតឈប់ឈរ? តើសង្គ្រាមកើតឡើងដោយសារអ្វី? គឺដោយខ្វះការត្រិះរិះ ខ្វះសីលធម៌ ខ្វះមនុស្សធម៌ ខ្វះចិត្តធម៌ ខ្វះការយោគយល់អធ្យាស្រ័យ ឬ ខ្វះការអត់ឱនតាមសមធម៌ តាមក្រឹត្យក្រមច្បាប់ឬ?

ម្យ៉ាងទៀតជាប្រវត្តិសាស្ត្រមនុស្សត្រូវការជម្រក មនុស្សត្រូវការម្ហូបអាហារចិញ្ចឹមជីវិត គឺមនុស្សត្រូវការភាពសុខសាន្ត ទាំងខ្លួនប្រាណ ទាំងស្មារតីទៀតផង។ ភាពសុខសាន្តសំខាន់ណាស់សម្រាប់មនុស្ស ប៉ុន្តែបញ្ហានេះមិនមែនជាការងារមួយងាយទេ ព្រោះនរណាក៏ចង់រស់ចង់សុខ ក៏ប៉ុន្តែមកទល់ពេលនេះរកសុខនៅតែមិនទាន់ឃើញដដែល។ សម័យមុនដើម្បីភាពសុខសាន្ត មានសន្តិភាពផ្ទាល់ខ្លួន សង្គមគ្រួសារ មនុស្សត្រូវការប្រយុទ្ធជាមួយស្ថានភាពជុំវិញខ្លាំងណាស់។ បច្ចុប្បន្ននេះជាសម័យបច្ចេកវិទ្យាទំនើប ការប្រុងប្រយ័ត្នសម្រាប់រស់កាន់តែស្មុគស្មាញថែមទៀត។ ហេតុនេះទើប យើងខ្ញុំខិតខំស្រាវជ្រាវសម្រិតសម្រាំងជ្រើសរើសយកគន្លឹះរស់នៅតាមបែប សីលធម៌សាសនាពាហិរសាសនា មករួមវិភាគទានជួយមនុស្សជាតិ និងមាតុភូមិក៏ដូចជាតំបន់និងសកលលោក។

ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ បានផ្អែកលើរបាយការណ៍មន្ទីរធម្មការ គ្រប់ខេត្ត/ក្រុងស្ទើរតែទាំងអស់ ហើយខ្ញុំខិតខំជ្រើសរើសយកនូវជំពូកណា ដែលចាំបាច់បំផុតសម្រាប់ការងារនេះ។ អត្ថបទនេះ មិនហួសសម័យ មិនបុរាណពេក មិនទំនើប ទោះជាពេលណាក៏វាបម្រើបានទាំងអស់ ទាំងខ្មែរទាំងបរទេសឥតរើសមុខ។ ចំណោទដែលធំបំផុតលើការស្រាវជ្រាវដើម្បីលាតត្រដាងនូវគំនិតអ្នកប្រាជ្ញខាងសីលធម៌ តើខ្មែរយើងអាចស្គាល់សីលធម៌ព្រះពុទ្ធច្បាស់ហើយឬនៅ? តើសាសនិកស្គាល់ព្រះធម៌ច្បាស់ហើយឬនៅ? មានលក្ខណៈបែបវិទ្យាសាស្ត្រហើយឬនៅ? បើមានវប្បធម៌បច្ចេកវិទ្យាទំនើបមកដល់ តើយើងគួរឈរត្រង់ណា?

អ្នកស្រាវជ្រាវបរទេសមួយចំនួនច្រើននិយាយថា ខ្មែរមួយចំនួនធំឆាប់ភ័យជាមួយនឹងស្ថានភាពថ្មីណាស់ (បច្ចេកវិទ្យាទំនើប) នេះជាគំនិតពិតឬយ៉ាងណា?។ បើយើងពិនិត្យការវិវត្តវប្បធម៌អរិយធម៌របស់យើងឱ្យបានល្អិតជ្រៅជ្រះបន្តិចនោះ យើងយល់ឃើញថា ខ្មែរក្នុងសម័យមហានគរនិយមចូលចិត្តចារឆ្លាក់អក្សរ ពាក្យបណ្តាំដំបូន្មាន ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗ នៅលើផ្ទាំងថ្មតាមប្រាង្គប្រាសាទនានាណាស់។ មានន័យថា បុព្វបុរសខ្មែរ យើងមិនខ្ជិលទេ ទោះជាគ្មានក្រដាសស្នាមក៏ដោយ ក៏គាត់ខិតខំចារឆ្លាក់ទុកបន្សល់ឱ្យយើងយល់ដឹង

ដែរ។ ពួកគាត់យល់ថា ឯកសារប្រភេទដែលចារឆ្លាក់នៅលើថ្មដា អាចរក្សាទុកបានយូរច្រើនសតវត្ស មិនងាយរលុបហើយក៏មិនងាយបាត់បង់ស្រួលៗដែរ។ ម្យ៉ាងវិញទៀត សិលាចារឹកទាំងនេះដែលរួមមានប្រាសាទតូចធំរាប់ពាន់ ជាសក្ខីភាពកស្តុតាងជាក់ស្តែង បញ្ជាក់អំពីអនុភាពខ្លាំងពូកែ ក្លាហានមានប្រាជ្ញាភ្លឺថ្លា មុតមាំ និងស្គាល់តែសេចក្តីថ្លៃថ្នូរថ្កុំថ្កើងរបស់ខ្មែរយើងសម័យមុនៗ ត្រង់នេះបង្ហាញឱ្យឃើញថា ខ្មែរពីមុនមិនមែនឆាប់ក័យដូចបរទេសថានោះទេ ខ្មែរពុទ្ធសាសនិកពិត ជាអាចស្ថិតនៅចំពោះមុខបច្ចេកវិទ្យាទំនើបបានដោយមិនទន់ជ្រាយជាដាច់ខាត។ ប៉ុន្តែខ្មែរអាចទន់ជ្រាយនៅពេលណាខ្មែរបាត់បង់ធម៌ក្នុងខ្លួន បាត់បង់ពាក្យបណ្តាំ បាត់បង់សាមគ្គីភាព គឺថ្ងៃណាដែលខ្មែរលែងមានធម៌ក្នុងខ្លួនខ្មែរ អាចបែកបាក់ រត់ខ្ចាត់ខ្ចាយព្រាត់ប្រាសក្រុមគ្រួសារ។ ខ្មែរអាចនឹងរងទុក្ខវេទនា ស្គាល់តែភ្លើងសង្គ្រាម ស្គាល់តែការកាប់ចាក់គ្នា។ លោក Alleent instain បានបញ្ជាក់ថា "មិនចាំបាច់គិតពីព្រះពុទ្ធសាសនាទេនៅសម័យបច្ចេកវិទ្យានេះ ព្រោះព្រះពុទ្ធសាសនាបានដើរហួសពីវិទ្យាសាស្ត្ររួចទៅហើយ"។ ចំណែកពាហិរសាសនាក៏មានបំណង មិនខុសពីព្រះពុទ្ធសាសនាដែរ។

ដូច្នេះដើម្បីជៀសវាងកុំឱ្យសត្រូវលួចបន្លំឬបំផ្លិចបំផ្លាញច្បាប់គម្ពីរ និងវប្បធម៌ជាតិបាន យើងគ្មានវិធីណាមួយក្រៅពីខិតខំរៀនសូត្រចំណេះដឹងក្បួនខ្នាត សិល្បសាស្ត្រដែលបុព្វបុរសខ្មែរយើងតែងតែលួចបង្ហាត់បង្រៀនពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយប្រកបដោយទស្សនៈខ្ពង់ខ្ពស់បំផុតនោះទេ។ ជាងនេះទៅទៀត ដើម្បីឆ្លើយតបទៅនឹងសម័យបច្ចេកវិទ្យានេះខ្មែរយើង ក៏គួរគប្បីសំយោគទាំងចំណេះថ្មីទំនើបបច្ចុប្បន្ន ទាំងចំណេះដឹងចាស់ទៀតផង ទើបយកជ័យជំនះបាន។

ការសិក្សាវិភាគ ៖ ការងារនេះ យើងខ្ញុំបានសិក្សាស្រាវជ្រាវនូវស្នាដៃមួយចំនួន ដូចតទៅដូចជា ស្នាដៃព្រះសង្ឃធម្មបាល ខៀវ ជុំ "សកលចិន្តាប្រជាធិបតេយ្យ ចាស់ទុំ" ព្រះគ្រូប៉ាងខាត់ "ព្រះពុទ្ធសាសនា២៥០០ ព្រះពុទ្ធសាសនានៅកម្ពុជា សាសនានៅសកលលោក ។ល។ ទាំងនេះត្រូវបានរូបខ្ញុំផ្ទាល់ជាមួយនឹងនិស្សិតទស្សនវិជ្ជា នៃរាជបណ្ឌិត្យសភាកម្ពុជា ថ្នាក់បរិញ្ញាបត្រជំនាន់ទី១ ទី២ ទី៣ និងទី៤ ក្រុមនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអក្សរសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ក្រុមសាមណៈនិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១ ទី២ ឆ្នាំ២០០២-២០០៤ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ច្បាប់ សេដ្ឋកិច្ច និងទេសចរណ៍ និងមុខវិជ្ជាដទៃទៀត (ឆ្នាំ២០០២-២០០៤) បណ្ឌិតគ្រប់ជំនាន់ នៅ

សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា នៅអឺរ៉ុបអាស៊ី ពិសេសនៅរាជបណ្ឌិត្យសភាកម្ពុជា ទាំងអាហារូបករណ៍ ៣ជំនាន់ និងបង់វិភាគទាន២ជំនាន់ ដែលបានសរសេរអំពីធម្មសាស្ត្រ ចរិយាសាស្ត្រ ទស្សនវិជ្ជា អក្សរសាស្រ្ត ច្បាប់ ភាសា ។ល។ ហើយបាននឹងកំពុងស្វែងយល់ស្រាវជ្រាវ នៅតាមបណ្ណាគារ និងតាមបណ្ណាល័យនានាទាំងក្នុងនិងក្រៅប្រទេស ពិសេសតាមប្រព័ន្ធព័ត៌មានទំនើប។

# ជំពូកទី១
# កំណើតនៃជំនឿ លើសកលលោក

*(ស្រាវជ្រាវដោយ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា)*

## ១.១. អត្ថន័យរបស់សាសនា

*ដូចម្ដេចហៅថា សាសនា ? ដូចម្ដេចហៅថា សាសនាម្ចាស់ស្រុក? ដូចម្ដេចហៅថា ព្រះពុទ្ធសាសនា ? ដូចម្ដេចហៅថា ព្រហ្មញ្ញសាសនា? ដូចម្ដេចហៅថា ពាហិរសាសនា?*

***តើសាសនាជាអ្វី ?***

*សាសនានិងសន្តិភាព គឺជាពាក្យសព្ទពីរដែលអាចដាក់និយមន័យស្រដៀងគ្នា និង បកស្រាយផ្សេងគ្នា អាស្រ័យទៅតាមជំនឿនិងកម្រិតនៃការយល់ផ្សេងៗគ្នារបស់មនុស្ស។ អ្នកប្រាជ្ញនិងទស្សនវិទូទាំងឡាយ បានមើលឃើញសាសនាក្នុងន័យផ្សេងៗគ្នា។ អ្នកខ្លះបាន ដាក់និយមន័យឱ្យសាសនាក្នុងន័យចង្អៀតហើយមានកម្រិត ចំណែកអ្នកខ្លះទៀតបានផ្ដល់ ន័យទូលំទូលាយជាង។*

*វចនានុក្រម* Oxford *កំណត់និយមន័យសាសនាថា ជាប្រព័ន្ធនៃជំនឿនិងសក្ការៈ ការ ទទួលស្គាល់ របស់មនុស្សចំពោះតួអង្គព្រះ ដែលគេត្រូវតែគោរពស្ដាប់បង្គាប់ និងផលនៃការ ទទួលស្គាល់នោះ ទៅលើអាកប្បកិរិយារបស់មនុស្ស។*

***តូម៉ាសផេន*** (Thomas paine) *ទស្សនវិទូអង់គ្លេសបាននិយាយថា ពិភពលោកគឺជា ប្រទេសរបស់ខ្ញុំ។ មនុស្សជាតិ គឺជាបងប្អូនរបស់ខ្ញុំ ហើយការធ្វើល្អគឺជាសាសនារបស់ខ្ញុំ។ ឥរិយាបថបែបនេះ ចំពោះសាសនានិងពិភពលោកមានសារសំខាន់ក្នុងការនាំមកនូវសន្តិភាព និងភាពសុខដុមចំពោះពិភពដែលយើងរស់នៅ ។*

***អេចជីវែល*** (H.G.wells) *និយាយថា "សាសនាគឺជាស្នូលនៃការអប់រំរបស់យើង ដែលកំណត់ការប្រព្រឹត្ត ផ្នែកគំនិតប្រាជ្ញារបស់យើង ។*

*ចំណែកទស្សនវិទូជាតិអាល្លឺម៉ង់ដ៏ល្បីល្បាញ **អ៊ីម៉ានុយអែលកង់*** (Emmanuel Kant) *និយាយថា "សាសនា គឺជាការទទួលស្គាល់គោលការណ៍សីលធម៌របស់យើងថា ជាច្បាប់ ដែលមិនត្រូវប្រព្រឹត្តកន្លង ។*

*រីឯ **កាល់ម៉ាក្ស***(Karl Marx) *មើលឃើញថា"សាសនាជាអាភៀនរបស់មនុស្ស" ដែល ផ្ដល់ដល់មនុស្សនូវភាពអស្ចារ្យទៅតថភាព ការសង្ឃឹមបែបមើមមាយទៅលើសុភមង្គល ក្នុងជីវិតក្រោយមរណភាពដែលនឹងទូទាត់ឱ្យអំពើអាក្រក់ឃោរឃៅ នៃអត្ថិភាពបច្ចុប្បន្ន។*

ចំពោះ **អង់ហ្គែល** (Engels) "សាសនា គ្មានអ្វីក្រៅពីការគិតចម្លែកក្នុងគំនិតរបស់មនុស្សអំពីកម្លាំងខាងក្រៅទាំងឡាយ ដែលត្រូវត្រួតត្រាជីវិតជាតិមុនរបស់គេ។

តាមរយៈបណ្តានិយមន័យ ដែលបានលើកឡើងខាងលើយើងអាចសន្និដ្ឋានបានថា សាសនាជាទម្រង់ មួយនៃស្មារតីរបស់មនុស្សដែលកំណត់ព្រំដែនឬបើកទូលាយដល់ការគិតនិងសកម្មភាពរបស់មនុស្សក្នុងការស្វែងរកសុភមង្គលផ្លូវចិត្ត។និយមន័យនេះចង់បញ្ជាក់ថាបើស្មារតីមនុស្សមិនជិតជាមដោយសាសនាណាមួយទេ ក៏គង់មានជិតជាមដោយទម្រង់ស្មារតីណាមួយផ្សេងទៀតដែលអាចត្រឹមត្រូវឬមិនត្រឹមត្រូវចំពោះខ្លួនគេ។ ប៉ុន្តែទោះ ជាយ៉ាងណាក៏ដោយ ក៏ស្មារតីរបស់មនុស្សម្នាក់តែងតែមានឥទ្ធិពលតិចឬច្រើន ចំពោះការរស់នៅរបស់មនុស្សនិងបរិស្ថានជុំវិញខ្លួនគេជានិច្ច។

## ១.២. ទីតាំងសាសនានានាលើសកលលោក

### ១- ទ្វីបអាស៊ី (CONTINENT D'ASIE)

**ទីតាំង** ៖ ស្ថិតនៅអឌ្ឍគោលខាងជើងជាប់នឹងទ្វីបអាហ្វ្រិក។ **សាសនា** ៖ ទ្វីបអាស៊ីមានប្រភពសាសនា ច្រើនហើយរាលដាលពាសពេញពិភពលោក។ ឥណ្ឌាកាន់ព្រហ្មញ្ញសាសនា មានអ្នកកាន់ចំនួន ៥០០.០០០.០០០នាក់ ព្រះពុទ្ធសាសនាមានជាបន្តនៅឥណ្ឌា-ទីបេ-ចិននិងម៉ាន់ជូរី។ ប្រទេសចិននិងប្រទេសជិតខាងកាន់សាសនាកុងហ្វូយ ស៊ិស-តៅអ៊ីស និង ស៊ីនតូអ៊ីស(ជប៉ុន)មានអ្នកកាន់ប្រហែល ៣៧០.០០០.០០០នាក់។ នៅមជ្ឈិមបូព៌ាមានអ្នកកាន់សាសនាអ៊ិស្លាម និងក្រៅពីនេះនៅតាមមាត់សមុទ្រ មេឌីទែរ៉ាណេ មានអ្នកកាន់សាសនាយ៉ូយដាអ៊ិស ចំនួន ២.០០០.០០០ នាក់ និងគ្រិស្តសាសនាចំនួន ៥០.០០០.០០០ នាក់។

### ២- ទ្វីបអាហ្វ្រិក (CONTINENT D'AFRIQUE)

**ទីតាំង** ៖ ស្ថិតនៅចន្លោះមហាសមុទ្រអាត្លង់ទិកនិងមហាសមុទ្រឥណ្ឌា។ **សាសនា** ៖ ភាគច្រើននៃប្រជាជនអាហ្វ្រិកមានជំនឿលើការគោរពទូវសារណាវត្ថុ ការគោរពសត្វ ការជឿលើប្រព័ន្ធដែលនាំឱ្យយល់ថា អាត្ម័នជាបុព្វហេតុនៃជីវិតនិងខាងសតិបញ្ញា (ជីវចលនិយម) និងក្រៅពីនេះគេគោរពតាមជំនឿតាមស្រុករបស់គេ។ សាសនាអ៊ិស្លាមច្រើនកាន់នៅអាហ្វ្រិកភាគខាងជើង។ គ្រិស្តសាសនាបែបកាតូលិកនិងអ័រតូដុក ច្រើនជនជាតិអឺរ៉ុបមកនៅអាហ្វ្រិកផ្នែកខាងជើងកាន់ ឯបែបប្រូតេស្តង់វិញ ច្រើនពួកផ្នែកខាងត្បូងកាន់។

### ៣- ទ្វីបអាមេរិក (CONTINENT D'AMERIQUE)

**ទីតាំង** ៖ ស្ថិតនៅក្នុងអឌ្ឍគោលទាំងពីរខាងកើតជាប់នឹងមហាសមុទ្រអាត្លង់ទិក ខាងលិចជាប់នឹងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ អាមេរិកភាគខាងជើងនិងកណ្ដាល ការប្រដៅឱ្យចូលជា គ្រិស្តបរិស័ទបានរីកដុះដាលពាសពេញ (បែបកាតូលិកនិងប្រូតេស្តង់)។ អាមេរិកខាងត្បូងមួយផ្នែក ច្រើនមានជំនឿតាមជំនឿស្រុករបស់គេ។ មួយផ្នែកទៀត ច្រើនជាជនជាតិស្បែកស និងជាអ្នកស៊ីវិល័យកាន់គ្រិស្តសាសនា ដែលភាគច្រើនៗ បែបកាតូលិក ប៉ុន្តែការប្រកាសខ្លួនចូលបែបប្រូតេស្តង់ក៏មានចំនួនគួរឱ្យកត់សម្គាល់ដែរ។

### ៤- ទ្វីបអឺរ៉ុប (CONTINENT D'EUROPE)

**ទីតាំង** ៖ ស្ថិតនៅក្នុងអឌ្ឍគោលខាងជើងចំពីសានមហាសមុទ្រអាត្លង់ទិកខាងកើតជាប់នឹងទ្វីបអាស៊ី ត្រង់ភ្នំអូរ៉ាល់និងកូសាស្ស ខាងត្បូងឃ្លាតពីទ្វីបអាហ្វ្រិកដោយសមុទ្រមេឌីទែរ៉ាណេ។ **សាសនា** ៖ គ្រិស្តសាសនា បានរីកដុះដាលពាសពេញ ការប្រកាសខ្លួនចូលកាតូលិក ប្រូតេស្តង់ និងអ័រតូដុក មានយ៉ាងសន្ធឹកសន្ធាប់។ ក្រុមជនជាតិភាគតិចមិនកាន់គ្រិស្តសាសនាបានប្រកាសខ្លួនចូលអ៊ិស្លាមសាសនា ជ្វីហ្វ និងពុទ្ធសាសនា។

### ៥- ទ្វីបអូសេអានី (CONTINENT D'OCEANIE)

**ទីតាំង** ៖ ស្ថិតនៅអាគ្នេយ៍ទ្វីបអាស៊ី ខាងលិចជាប់នឹងមហាសមុទ្រឥណ្ឌា ក្រៅពីនេះជាប់នឹងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ ដោយសារជនជាតិស្បែកស ច្រើនចូលមកដាក់អាណានិគមលើទឹកដីនៃទ្វីបនេះ បានជាមានប្រជាជន៧៧% កាន់សាសនាគ្រិស្តយ៉ាងឆាប់រហ័ស។ ពួកអ្នកប្រកាសខ្លួនចូល **ប្រូតេស្តង់** មានច្រើនលើសលប់។ ជនជាតិដើមមានជំនឿលើការគោរពសត្វ ការជឿលើប្រព័ន្ធដែលនាំឱ្យយល់ថា អាត្ម័នជាបុព្វហេតុនៃជីវិត និងខាងសតិបញ្ញា (ជីវចលនិយម) និងជាទូទៅជាអ្នកគោរពបូជាអនិស្សរណវត្ថុនានាមានអារក្ខអ្នកតាជាដើម ដែលមានវិធីរៀបចំយ៉ាងច្រើនក្បួនច្បាប់បំផុត។

### ៦- ទ្វីបអង់តាកទិក (CONTINENT D'ANTARCTIQUE )

**ទីតាំង** ៖ ស្ថិតនៅក្នុងអឌ្ឍគោលខាងត្បូង ត្រង់កន្ទឹបប៉ូលខាងត្បូងព័ទ្ធជុំវិញ ដោយមហាសមុទ្របីគឺ ប៉ាស៊ីហ្វិក អាត្លង់ទិក និងមហាសមុទ្រឥណ្ឌា។

៧- កម្ពុជា (KAMPUCHEA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍ត្រង់ភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ចន្លោះខ្សែស្របទី១០ និង ទី១៥ នៃរយៈទទឹងខាងជើង និង នៅចន្លោះខ្សែបណ្តោយទី១០២ និងទី១០៨ នៃរយៈបណ្តោយខាងកើត។ ដូចនេះ កម្ពុជានៅតំបន់ត្រូពិកត្រង់អឌ្ឍគោលខាងជើង ដែលជាតំបន់ដីមានជីជាតិអំណោយផល ពិសេសដល់ការលូតលាស់នៃរុក្ខជាតិ ឬដំណាំគ្រប់ប្រភេទ។ កម្ពុជាមានរាងជាពហុកោណស្ទើរស្មើជ្រុង មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសថៃ ហើយមួយភាគធំទៀតជាប់នឹងឡាវ ខាងកើតជាប់នឹងប្រទេសវៀតណាមខាងត្បូង ខាងលិចជាប់នឹងឈូងសមុទ្រថៃ ហើយមួយភាគទៀតជាប់នឹងប្រទេសថៃ។ **សាសនា** ៖ សំខាន់ៗមាន ១-ពុទ្ធសាសនាមានអ្នកកាន់ប្រមាណ៩០% ២-អ៊ិស្លាមមានអ្នកកាន់ប្រហែល៧០.០០០ នាក់ ៣-គ្រិស្តបែបកាតូលិក (ស្ថិតិឆ្នាំ១៩៧០) មានអ្នកកាន់ ៦០.០០០ នាក់ ៤-គ្រិស្តបែបប្រូតេស្តង់ មានចំនួនតិច។

៨- កាតា (QATAR)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងនិរតីត្រង់តំបន់មជ្ឈិមបូព៌ា ជាជ្រោយលយចូលជ្រៅក្នុងឈូងសមុទ្រពែរ្ស ត្រង់ដែនដីអារ៉ាប៊ីសាអ៊ូឌីតភាគខាងកើត បណ្តោយប្រវែង១៦០ គ.ម. ទទឹង៩០គ.ម.។ **សាសនា** ៖ អ៊ិស្លាម។

៩- កាណាដា (CANADA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកខាងជើង មានព្រំប្រទល់ខាងជើងជាប់នឹងមហាសមុទ្រគ្លះស៊្យាល់អាកទិក ខាងកើតជាប់នឹងមហាសមុទ្រអាត្លង់ទិក ខាងលិចជាប់នឹងមហាសមុទ្រប៉ាស៊ីហ្វិក ឈៀងពាយ័ព្យជាប់នឹងផែនដីអាឡាស្កា (សហរដ្ឋអាម៉េរិក) ខាងត្បូងជាប់នឹងសហរដ្ឋអាមេរិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់ ។

១០- កាណារី "ប្រជុំកោះ" (CANARIES "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

១១- កាមេរូន (CAMEROUN)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកជាប់នឹងចុងខាងកើតនៃឈូងសមុទ្រហ្គីណេ មានព្រំដែនខាងជើងទល់នឹងនីហ្សេរីយ៉ា ខាងកើតទល់នឹងឆាដនិងអាហ្វ្រិកកណ្តាល ខាងត្បូងទល់នឹង

ហ្គីណេអេក្វាទ័រ កាមេរូន ហ្គាបុង និងកុងហ្គោ។ **សាសនា** ៖ គោរពសរណាវត្ថុ (ពី៤០ ទៅ ៥០%) គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក (ពី៣៥ទៅ៤០%) នៅសល់កាន់សាសនាអ៊ិស្លាម។

**១២- ការ៉ូលីន "ប្រជុំកោះ" (CAROLINES) "iles de"**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងលិច ត្រង់តំបន់មីក្រូនេស៊ី ចំខាងកើតប្រជុំកោះ ប័រណេអូ (ឥណ្ឌូណេស៊ី)។ **សាសនា** ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១៣- កាប់វែរ "ប្រជុំកោះ" (CAPVERT) "iles de"**

**ទីតាំង** ៖ ប្រជុំកោះកាប់វែរស្ថិតនៅកណ្តាលមហាសមុទ្រអាត្លង់ទិក ចំខាងលិចប្រទេសសេណេហ្គាល់ (ទ្វីបអាហ្វ្រិក) ចម្ងាយ៥១៥ គ.ម.។ **សាសនា** ៖ គ្រិស្តនិងគោរពសរណាវត្ថុ។

**១៤- កុងហ្គោ (CONGO)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច ចំត្រង់បន្ទាត់អេក្វាទ័រ។ មានព្រំប្រទល់ជាមួយប្រទេស ហ្គាបុង កាមេរូន អាហ្វ្រិកកណ្តាល និងស្ហាអៀរ។ **សាសនា** ៖ គោរពសត្វ (៥០%) នៅសល់គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់ ។

**១៥- កូកូស "ប្រជុំកោះ" (COCOS "iles de" )**

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌា ចម្ងាយប្រហែល ១៣០០ គ.ម ខាងត្បូងឈៀងខាងលិច ហ្សាវ៉ា (ឥណ្ឌូណេស៊ី) និងប្រហែល៣៧០០ គ.ម. ពីដាវីន។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក ក្រៅពីនេះមានជំនឿលើការគោរពសត្វ។

**១៦- កូតឌីវ័រ (COTE D'IVOIRE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិចជាប់នឹងឆ្នេរមហាសមុទ្រអាត្លង់ទិក ខាងជើងទល់នឹងប្រទេសម៉ាលីនិងអូតវ៉ុលតា ខាងកើតទល់នឹងហ្គាណា ខាងលិចទល់នឹងហ្គីណេ។ **សាសនា** ៖ជឿលើការគោរពសត្វ(៦០%) អ៊ិស្លាម(២២,៨%) គ្រិស្តបែបកាតូលិក (១៣,៥%)។

**១៧- កូម៉រ "ប្រជុំកោះ" (COMORES "iles de")**

**ទីតាំង** ៖ ស្ថិតនៅខាងកើតអាហ្វ្រិកម្តុំខាងជើងដៃសមុទ្រមូហ្សំប៊ិចក្នុងមហាសមុទ្រឥណ្ឌាត្រង់ចន្លោះ ទ្វីបអាហ្វ្រិកនិងកោះម៉ាដាហ្គាស្កា។ **សាសនា** ៖ មុយស៊ុលម៉ង់។

១៨- គូរីល "ប្រជុំកោះ" (KOURILES "ILES DE")

**ទីតាំង**៖ស្ថិតនៅទ្វីបអាស៊ីក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងជើងខាងលិចសហភាពសូវៀតភាគ ខាងកើតនិងចំខាងកោះសាខាលីន(សូវៀត)ខាងជើងប្រទេសជប៉ុន។ **សាសនា** ៖ ប្រជាជនមានសេរីភាពលើជំនឿសាសនា វឌ្ឍបង្កើនជំនឿលើវិទ្យាសាស្ត្រ មានសល់បន្តិចបន្តួច ជឿលើគ្រិស្តសាសនាបែបកាតូលិកបែបប្រូតេស្តង់និងសាសនាអ៊ិស្លាម។ល។

១៩- គូរ៉េខាងជើង (COREE DU NORD)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើតជាប់នឹងសមុទ្រជប៉ុន។ មានព្រំដែនខាងជើងទល់នឹងចិន ចំណ្យសានទល់នឹងសូវៀត ខាងកើតទល់នឹងសមុទ្រជប៉ុន ខាងត្បូងទល់នឹងកូរ៉េខាងត្បូង ហើយខាងលិចទល់នឹងសមុទ្រលឿងនិងឆកនៃប្រទេសកូរ៉េ។ **សាសនា** ៖ ពុទ្ធសាសនានិងកុងហ្វឺស៊ីស។

២០- គូរ៉េខាងត្បូង (COREE DU SUD)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីខាងកើតត្រង់ចន្លោះសមុទ្រជប៉ុននិងឈូងសមុទ្រលឿងចំ ខាងលិចទីក្រុងតូក្យូ(ប្រទេសជប៉ុន)។ **សាសនា** ៖ ពុទ្ធសាសនាកុងហ្វឺស៊ីស និងគ្រិស្តបែបកាតូលិក និង ប្រូតេស្តង់។

២១- គូវ៉ែត (KOWEIT)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគនិរតីត្រង់តំបន់មជ្ឈិមបូព៌ាផ្នែកពាយ័ព្យឈូងសមុទ្រពែរ្ស៊ិក ជាប់នឹងប្រទេសអារ៉ាប៊ីសាអ៊ូឌីតនិងអ៊ីរ៉ាក់។ សាសនា ៖ អ៊ិស្លាម។

២២- គូស្តារីកា (COSTARICA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល ខាងលិចជាប់នឹងមហាសមុទ្រប៉ាស៊ីហ្វិក ខាងកើតជាប់នឹងសមុទ្រអង់ទីយ៍ ខាងជើងជាប់នឹងប្រទេសនីការ៉ាហ្គា ខាងត្បូងជាប់នឹងប្រទេសប៉ាណាម៉ា។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

២៣- គូឡុមប៊ី (COLOMBIE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង ផ្នែកពាយ័ព្យ ខាងជើងនិងខាងលិចជាប់នឹងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៩០%) នៅសល់កាន់បែបប្រូតេស្តង់ និងសាសនាជ្វីហ្វ។

**២៤- កេនយ៉ា (KENYA)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើតជាប់នឹងមហាសមុទ្រឥណ្ឌា។ **សាសនា** ៖ គោរពសរណៈវត្ថុ (៧០%) គ្រិស្តបែបកាតូលិក (២៥%)។

**២៥- កៃម៉ាន់ "ប្រជុំកោះ" (CAYMAN "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាលត្រង់តំបន់ការ៉ាអ៊ីប។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ និងកាតូលិក។

**២៦- ក្រិក (GRECE)**

**ទីតាំង** ៖ស្ថិតនៅទ្វីបអឺរ៉ុបភាគអាគ្នេយ៍ជាប់នឹងឈូងសមុទ្រមេឌីទែរ៉ាណេ។ **សាសនា** ៖ ក្រិកបែបអ័រតូដុក។

**២៧- ក្រែត "កោះ" (CRETE "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូងក្នុងសមុទ្រមេឌីទែរ៉ាណេ ភាគខាងកើតចំ ខាងត្បូងប្រទេសក្រិក។ **សាសនា** ៖ គ្រិស្តបែបអ័រតូដុកកាន់ភាគច្រើន ហើយនៅសល់កាន់ គ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់ សាសនាអ៊ិស្លាមនិងសាសនាជ្វីហ្វមានកាន់បន្តិច បន្តួច។

**២៨- ខុក "ប្រជុំកោះ" (COOK "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងត្បូង ត្រង់ខាងលិចកោះតាហ៊ីទី។ **សាសនា** ៖ គ្រិស្តបែបពួកអង់គ្លេស៣២% គ្រិស្តបែបប្រូតេស្តង់ ២០% នៅសល់មានជំនឿសាសនាផ្សេងៗទៀត។

**២៩- គ័រស្ស "កោះ" (CORSE "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុប ត្រង់ចន្លោះសមុទ្រមេឌីទែរ៉ាណេនិងសមុទ្រហេនីញ៉េន។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក។

**៣០- គ័រហ្វ៊ូរ "កោះ" (CORFOU "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូង។ **សាសនា** ៖ គ្រិស្តបែបអ័រតូដុក។

**៣១- គីរីបាទី "ប្រជុំកោះ" (KIRIBATI "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានីក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក ។

**៣២- គុយបា (CUBA)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាម៉េរិកភាគកណ្ដាល។ **សាសនា** ៖ ប្រជាជនមានសេរីភាពក្នុងជំនឿសាសនា គេឃើញមានការកាន់គ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់ សាសនាជ្វីហ្វមានកាន់ខ្លះ។

**៣៣- ហ្គីយ៉ាន (GUYANE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកខាងត្បូង ផ្នែកខាងជើងជាប់នឹងឈូងសមុទ្រអង់ទីយ៍ (ការ៉ាអ៉ីប) មានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសសូណាំ ខាងត្បូងនិងខាងលិចទល់នឹងវេណេស៊ុយអេឡា និងប្រេស៊ីល។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ ៥០% នៅសល់កាន់សាសនាហិណ្ឌូ និងមុយស៊ូយម៉ង់។

**៣៤- ហ្គីយ៉ានបារាំង (GUYANE FRANCAISE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាម៉េរិកភាគខាងត្បូង ផ្នែកខាងជើងជាប់នឹងឈូងសមុទ្រអង់ទីយ៍ (ការ៉ាអ៉ីប) ព្រំប្រទល់ខាងលិចជាប់នឹងប្រទេសស៊ូរីណាំ ខាងត្បូងនិងខាងកើតជាប់នឹងប្រទេសប្រេស៊ីល។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក ។

**៣៥- គុយរ៉ាកាវ (CURACAO "iles de")**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងក្នុងសមុទ្រអង់ទីយ៍ចំខាងជើងប្រទេស វេណេស៊ុយ អេឡា គឺកោះគុយរ៉ាកាវ និងកោះចំនួន៥ ទៀតនៅជុំវិញ។ **សាសនា** ៖ គ្រិស្ត បែបកាតូលិក។

**៣៦- គែគ្លើលែន "ប្រជុំកោះ" (KERGUELEN "iles de")**

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌាភាគខាងត្បូង ជិតមកប៉ូលខាងត្បូង។ សាសនា ៖ គ្រិស្ត បែបកាតូលិកនិងបែបប្រូតេស្តង់។

**៣៧- គ្រេណាដា (GRENADA)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាលក្នុងតំបន់ការ៉ាអ៉ីប។ សាសនា ៖ គ្រិស្ត បែបកាតូលិក និង សាសនាមុយស៊ូយម៉ង់។

**៣៨- គ្រិសម៉ាស់ "កោះ" (CHRISTMAS "iles de")**

**ទីតាំង** ៖ស្ថិតនៅជាប់តែឯងក្នុងមហាសមុទ្រឥណ្ឌាខាងត្បូងកោះហ្សាវ៉ា(ឥណ្ឌូណេស៊ី)។ **សាសនា** ៖ ប្រកាសខ្លួនចូលកាន់តាមបែបសាសនាអង់គ្លេស និងតាមគ្រិស្តបែបកាតូលិក។

**៣៩- គ្រិស្តម៉ាស់កោះនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក**

**ទីតាំង** ៖ ស្ថិតនៅត្រង់ប្រជុំកោះម៉ុបន្ទាត់អេក្វាទ័រ ចំខាងត្បូងកោះហាវ៉ៃ។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៤០- ឃ្លីបពែរតុង "កោះ" (CLIPPERTON "iles de")**

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ជិតមកទ្វីបអាមេរិកខាងជើង ត្រង់ខាងលិចប្រទេស ម៉ិកស៊ិកចម្ងាយ១៣០០ គ.ម ពីឆ្នេរ។ **សាសនា** ៖ គ្រិស្តបែបកាតូលិក ភាគច្រើននៅសល់គ្រិស្តបែប ប្រូតេស្តង់។

**៤១- ចិន (CHINE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើត មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសម៉ុងហ្គោលីនិងសូវៀត ។ **សាសនា** ៖ កុងហ្វូយស្ស៊ីស តៅអ៉ីស និងពុទ្ធសាសនា។

**៤២- ចិនតៃវ៉ាន់ (CHINE TAIWAN)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើត ចំខាងកើតប្រទេសចិនដីគោកចម្ងាយ ១៣៥ គ.ម (ក្នុងសមុទ្រចិន) ត្រង់ខាងត្បូង នៃភាគខាងលិចមហាសមុទ្រប៉ាស៊ីហ្វិកខាងជើងប្រជុំកោះហ្វីលីពីន។ **សាសនា** ៖ ភាគច្រើននៃប្រជាជនបានប្រកាសខ្លួនកាន់ហ្វុយស៊ីស ប៉ុន្តែក្រុមពុទ្ធសាសនានិងតៅអ៉ិស មានកាន់ច្រើន។ គ្រិស្តបែបកាតូលិកមានប្រហែល ២៥០០០ នាក់។ ពួកកុលសម្ព័ន្ធគោរពសត្វ។

**៤៣- ឆាដ (TCHAD)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគកណ្តាល ជាប់ជាមួយប្រទេសលីប៊ី អាហ្វ្រិកកណ្តាល ស៊ូដង់ នីហ្សេ នីហ្សេរីយ៉ា និងកាមេរូន។ **សាសនា** ៖ គោរពសរណៈវត្ថុ (តំបន់ខាងត្បូង) និងអ៊ិស្លាម (តំបន់ខាងជើង)។

**៤៤- ឆេកូស្លូវ៉ាគី (TCHECOSLOVAQUIE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៧០%) និងបែបប្រូតេស្តង់(១៥%) នៅសល់កាន់សាសនាជ្វីហ្វគ្រិស្តបែបអ័រតូដុក ឬមិនច្បាស់លាស់ជាសាសនាអ្វីទេ។

**៤៥- ជប៉ុន (JAPAN)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីខាងកើត ទល់នឹងព្រំប្រទល់សមុទ្រជប៉ុននិងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ ស៊ីនតូ ពុទ្ធសាសនា និងគ្រិស្តបែបប្រូតេស្តង់។

**៤៦- ជីលី** (CHILI)

**ទីតាំង** ៖ ស្ថិតនៅអាមេរិកខាងត្បូងចុងខាងលិច ជាប់នឹងឈូងសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិក(៨៥%) នៅសល់កាន់បែបប្រូតេស្តង់ និងសាសនាដ៏ទៃ។

**៤៧- ដាណឺម៉ាក់** (DANEMARK)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងជើង ជាជ្រោយលយចេញពីប្រទេសអាល្លឺម៉ង់ខាងលិច។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ភាគច្រើន (៩៨%) នៅសល់កាន់សាសនាគ្រិស្តបែបកាតូលិក ជឿលើសម្មាធិ និងសាសនាដ៏ទៃ។

**៤៨- ដូមីនីកែន** (DOMINICAINE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល ផ្នែកខាងកើតកោះហៃអ៊ីទី ក្នុងតំបន់ការ៉ាអ៊ីបខាងជើង។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៤៩- ណ័រហ្វុល "កោះ"** (NORFOLK "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកចម្ងាយ ១៥០០គ.ម. ឦសាន។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក និងមានជំនឿលើការគោរពសត្វខ្លះៗ។

**៥០- ណាមីប៊ី** (NAMIBIE)

**ទីតាំង** ៖ស្ថិតនៅទ្វីបអាហ្វ្រិកភាគនិរតីជាប់នឹងមហាសមុទ្រអាត្លង់ទិក។ **សាសនា** ៖ គោរព សរណៈវត្ថុ (ជនជាតិដើម) និងគ្រិស្ត (ជនជាតិស្បែកស)។

**៥១- ណោរុ "កោះ"** (NAURU "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ត្រង់ខាងត្បូងបន្ទាត់ "អេក្វាទ័រ"។ **សាសនា** ៖ គ្រិស្ត បែបកាតូលិក។

**៥២- តង់ហ្សានី** (TANZANIE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើត ជាប់នឹងមហាសមុទ្រឥណ្ឌាប្រវែង ៨០០ គ.ម។ **សាសនា** ៖ គោរពសរណៈវត្ថុ (៤៣%) អ៊ិស្លាម (៣២%) នៅសល់កាន់គ្រិស្តសាសនា។

**៥៣- តាហ៊ីទី "កោះ"** (TAHITI "ile de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៥៤- តាសស្មានី "កោះ"** (TASMANIE "ile de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ចំត្រង់ខាងត្បូងប្រទេសអូស្ត្រាលី។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក។

**៥៥- តុងហ្គា "ប្រជុំកោះ"** (TONGA "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងសមុទ្រប៉ាស៊ីហ្វិកភាគខាងត្បូង ចម្ងាយ ៥០០ គ.ម.។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៥៦- តូហ្គោ** (TOGO)

**ទីតាំង** ៖ ស្ថិតនៅភាគខាងលិចនៃទ្វីបអាហ្វ្រិក មានព្រំប្រទល់ខាងត្បូងជាប់នឹងឈូងសមុទ្រហ្គីណេ។ **សាសនា** ៖ គោរពសរណៈវត្ថុ (៧០%) នៅសល់កាន់គ្រិស្តបែបកាតូលិក បែបប្រូតេស្តង់ និង មានកាន់សាសនាអ៊ិស្លាមខ្លះៗ។

**៥៧- តូកឺឡូវ "ប្រជុំកោះ"** (TOKELAU "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ចម្ងាយប្រហែល ៣២០០ គ.ម.។ **សាសនា** ៖ គ្រិស្តបែបពួកអង់គ្លេសកាន់ (៣២%) នៅសល់កាន់ផ្នែកមួយបែបនៃប្រូតេស្តង់និងកាតូលិក។

**៥៨- ថៃ** (THAILANDE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ី មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសភូមានិងឡាវ ខាងលិចជាប់នឹងភូមា ខាងត្បូងជាប់នឹងម៉ាឡេស៊ី និងឈូងសមុទ្រថៃ ខាងកើតជាប់កម្ពុជានិងឡាវ។ **សាសនា** ៖ ពុទ្ធសាសនា (៩៤%)អ៊ិស្លាម (៣.៨%) ហិណ្ឌូ (១.៦%) នៅសល់កាន់គ្រិស្តសាសនា។

**៥៩- ទីម័រ "កោះ"** (TIMOR "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគអគ្នេយ៍ចុងខាងត្បូងបំផុត។ **សាសនា** ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

***៦០- ទុយនីស៊ី* (TUNISIE)**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងជើង ជាប់និងសមុទ្រមេឌីទែរ៉ាណេ។* ***សាសនា*** *៖ អ៊ិស្លាម (៩៣%) នៅសល់កាន់សាសនាគ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់។*

***៦១- ទុយវ៉ាលុយ "ប្រជុំកោះ"* (TUVALU "iles de")**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិកចម្ងាយ ៤ ០០០គ.ម.។* ***សាសនា*** *៖ គ្រិស្តបែបកាតូលិក។*

***៦២- ទូអាម៉ូទូ ឬ ទុយអាម៉ូទុយ "ប្រជុំកោះ"* (TOUAMOTOU OU TUAMOTU "ilesde" )**

***ទីតាំង*** *៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។* ***សាសនា*** *៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។*

***៦៣- ទូប៊ូអៃ ឬ ទុយប៊ុយអៃ "ប្រជុំកោះ "* (TOUBOUAI OU TUBUAI "iles de")**

***ទីតាំង*** *៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។* ***សាសនា*** *៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។*

***៦៤- ទួរគី* (TURQUIE)**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអាស៊ីនិងអឺរ៉ុប។* ***សាសនា*** *៖ អ៊ិស្លាម(៩៨,២%)នៅសល់កាន់សាសនាផ្សេងៗ។*

***៦៥- ទៀកនិងកៃកូស "ប្រជុំកោះ"* (TURKS ET CAICOS "iles de")**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងកណ្ដាល។* ***សាសនា*** *៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក។*

***៦៦- ទែរដឺហ្វឺ "កម្រងកោះ"* (TERRE DE FEU "Archipel de la")**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអាមេរិកខាងត្បូង។* ***សាសនា*** *៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។*

***៦៧- ទែរណឺវ* (TERRE-NEUVE)**

***ទីតាំង*** *៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងជើង ខាងកើតប្រទេសកាណាដា ត្រង់ខាងកើតឈូងសមុទ្រ សាំងល្វរ៉េង។* ***សាសនា*** *៖ គ្រិស្តបែបកាតូលិក (៤៥%) ក្រៅពីនេះជាអ្នកប្រើវិធីត្រិះរិះសញ្ជឹងរកអភិញ្ញាណនិងគោរពតាមបព្វជិត កាតូលិកតាមបែបកាល់វ៉ាំង ដែលជឿថាអភិបាលវិញ្ញាណកាតូលិក ជាតំណាងចម្រុះគឺបាស្ទ័រនិងឡាក់។*

៦៨- ទ្រីនីដាត និងតូបាហ្គោ (TRINIDAD ET TOBAGO)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក និង បែបប្រូតេស្តង់ និងមានអ្នកឥណ្ឌូខ្លះៗ។

៦៩- ទ្រិស្តង់ដាគុញ៉ា "ប្រជុំកោះ" (TRISTAN DA CUNHA "iles de")

**ទីតាំង** ៖ ស្ថិតនៅចំកណ្តាលនៃភាគខាងត្បូងមហាសមុទ្រអាត្លង់ទិក ត្រង់ខាងលិច ជ្រោយបោន អេស្តេរ៉ង់ (ប្រទេសអាហ្វ្រិកខាងត្បូង)។ **សាសនា** ៖ អង់គ្លីកាន (សាសនាបែប ពួកអង់គ្លេស) និងគ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

៧០- ទ្រុយស៊ីអាល់ស្តេត (TRUCIAL STATES)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគនិរតី តំបន់មជ្ឈិមបូព៌ា ។ **សាសនា** ៖ អ៊ិស្លាម។

៧១- ន័រវែស (NORVEGE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងជើង។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់។

៧២- នីការ៉ាហ្គា (NICARAGUA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក៩៥% និងបែបប្រូតេស្តង់ ៥%។

៧៣- នីកូបា "កោះ" (NICOBAR "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីក្នុងមហាសមុទ្រឥណ្ឌាត្រង់ឈូងសមុទ្របង់ហ្គាល់ ចំខាង កើតកោះស្រីលង្កា។ ផ្ទៃកោះលាតសន្ធឹងពីជើងទៅត្បូង ទិដ្ឋភាពដូចតភ្ជាប់ពីជួរភ្នំប្រទេស ភូមា។ **សាសនា** ៖ ហិណ្ឌូ (៨២,៧%) អ៊ិស្លាម(១០,៦%) នៅសល់កាន់គ្រិស្តបែបកាតូលិក និង ពុទ្ធសាសនា។

៧៤- នីហ្សេ (NIGER)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគកណ្តាល។ **សាសនា** ៖ អ៊ិស្លាម (៨៥%) គោរព សត្វ (១៤%) នៅសល់កាន់គ្រិស្តសាសនា។

៧៥- នីហ្សេរីយ៉ា (NIGERIA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ **សាសនា** ៖ អ៊ិស្លាម (៥០%) គ្រិស្តបែប កាតូលិក (៤០%) និងនៅសល់ជឿលើការគោរពសត្វ។

៧៦- នូគូហ៊ីវ៉ា "កោះ" (NUKU HIVA "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកត្រង់តំបន់ប្រជុំកោះប៉ូលីណេស៊ី។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

៧៧- នូវែលហ្សេឡង់ "ប្រជុំកោះ" (NOUVELLE ZELANDE "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានីភាគអាគ្នេយ៍ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់(៦៥%) បែបពួកអង់គ្លេស (២០%) និងបែបកាតូលិក(១៥%)។

៧៨- នួយ "កោះ" (NUIE "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានីក្នុងសមុទ្រប៉ាស៊ីហ្វិក ភាគខាងត្បូងជិតប្រជុំកោះតាហ៊ីទីក្នុងម្តុំកោះខុកឰសាន នូវែល សេឡង់ ចម្ងាយ ៣ ២០០គ.ម.។ **សាសនា** ៖ គ្រិស្តបែបពួកអង់គ្លេស បែបកាតូលិក និងបែបប្រូតេស្តង់។

៧៩- បង់ក្លាដែស (BANGLADESH)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីខាងត្បូង។ **សាសនា** ៖ មូយស៊ុលម៉ង់(៨០%) ហិណ្ឌូ (១៨,៤%) នៅសល់កាន់ពុទ្ធសាសនា គ្រិស្តសាសនា និងជឿលើការគោរពសត្វ។

៨០- បារាំង (FRANCE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងលិច ជាប់នឹងមហាសមុទ្រអាត្លង់ទិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៩០%) នៅសល់កាន់បែបប្រូតេស្តង់។

៨១- បារ៉ែន "ប្រជុំកោះ" (BAHREIN "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិចត្រង់តំបន់មជ្ឈិមបូព៌ា។ **សាសនា** ៖ អ៊ិស្លាម។

៨២- បារបាដុស "កោះ" (BARBADE "iles de")

**ទីតាំង** ៖ ស្ថិតនៅតំបន់ការ៉ាអ៊ីប ទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ (ភាគច្រើន) បែបកាតូលិក និងមានក្រុមខ្លះកាន់សាសនាអ៊ិស្លាម និង សាសនាហិណ្ឌូ។

៨៣- បារប៊ុដ "កោះ" (BARBUDE "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**៨៤- បាហាម៉ា “ប្រជុំកោះ” (BAHAMAS “iles de”)**

**ទីតាំង** ៖ ស្ថិតនៅក្នុងទ្វីបអាមេរិកភាគកណ្ដាលប៉ែកខាងកើត។ **សាសនា** ៖ គ្រិស្តបែបកាតូលិកបែបប្រូតេស្តង់ និង បែបសាសនាថ្មីហ្វ។

**៨៥- បាឡេរិស “ប្រជុំកោះ” (BALEARES “iles de”)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបក្នុងសមុទ្រមេឌីទែរ៉ាណេភាគខាងលិច។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៨៦- ប៊ូរុនឌី (BURUNDI)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិក។ **សាសនា** ៖ គោរពសរណាវត្ថុ(៤៥%)គ្រិស្តបែបកាតូលិក (៤២%) និងបែបប្រូតេស្តង់ (២%) អ៊ិស្លាម(១%)។

**៨៧- បូណែរ “កោះ” (BONAIRE “iles de”)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

**៨៨-បូលីវី (BOLIVIE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកខាងត្បូងផ្នែកកណ្ដាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក(៩៤%) នៅសល់ជឿលើការគោរពសត្វ។

**៨៩- បុតស្វាណា (BOTSWANA)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងត្បូង។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៧៥%) ក្រៅពីនេះមានទម្លាប់សែនព្រេនតាមប្រពៃណី។

**៩០- បេណាំង (BENIN)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិកជាប់នឹងឆ្នេរឈូងសមុទ្រហ្គីណេ ភាគខាងជើងខាងលិចជាប់នឹងប្រទេសតូហ្គោ ខាងកើតជាប់នឹងនីហ្សេរីយ៉ា ខាងជើងជាប់នឹងនីហ្សេនិងប៊ួគីណាហ្វាសូ (អូតវ៉ុលតា)។ **សាសនា** ៖ គោរពសរណាវត្ថុ (៧១%) អ៊ិស្លាម (១៧%) គ្រិស្តបែបកាតូលិក (១២%)។

**៩១- បេលីស្ស (BELIZE)**

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

៩២- ប៉ង់តែលឡេរីយ៉ា "ប្រជុំកោះ" (PANTELLERIA "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងសមុទ្រមេឌីទែរ៉ាណេភាគខាងកើត។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

៩៣- ប៉ាក់ "កោះ" (PAQUES "iles de")

**ទីតាំង** ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់។

៩៤- ប៉ាគីស្ថាន (PAKISTAN)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង។ **សាសនា** ៖ អ៊ិស្លាម (៩៧%) នៅសល់កាន់សាសនាហិណ្ឌូ សាសនាគ្រិស្ត ពុទ្ធសាសនានិងជឿលើការគោរពសត្វ។

៩៥- ប៉ាណាម៉ា (PANAMA)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាលផ្នែកចុងខាងត្បូង។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៧២%) ជនជាតិភាគតិចកាន់បែបប្រូតេស្តង់ និងសាសនាជ្វីហ្វ។

៩៦- ប៉ាណាម៉ា "តំបន់ព្រែកជីក" (PANAMA "zone canal de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក។

៩៧- ប៉ាពូអាស៊ី និង នូវែលហ្គីណេខាងកើត (PAPOU ASIE ET NOUVELLE-GUINEE ORIENTALE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ខាងជើងប្រទេសអូស្ត្រាលី។ **សាសនា** ៖ គ្រិស្តបែបកាតូលិកនិងបែបប្រូតេស្តង់។

៩៨- ប៉ារ៉ាហ្គាយ (PARAGUAY)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងផ្នែកកណ្ដាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៨០%) នៅសល់កាន់គ្រិស្តបែបប្រូតេស្តង់។

៩៩- ប៉ាឡេស្ទីន (PALESTINE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិច ត្រង់តំបន់មជ្ឈិមបូព៌ា។ **សាសនា** ៖ ជ្វីហ្វ និងអ៊ិស្លាម។

**១០០- ប៉េរូ** (PEROU)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងផ្នែកខាងលិច។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (៨២%) នៅសល់កាន់បែបប្រូតេស្តង់។

**១០១- ប៉េរីម "កោះ"** (PERIM "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ី ត្រង់តំបន់មជ្ឈិមបូព៌ា ។ **សាសនា** ៖ មូស្លីមយ៉េម៉ង់។

**១០២- ប៉េអីបា** (PAYS –BAS)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងលិច។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ និង បែបកាតូលិក។

**១០៣- ប៉ូឡូញ** (POLOGNE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងកើត។ **សាសនា** ៖ គ្រិស្តបែបកាតូលិក (ភាគច្រើន) នៅសល់កាន់បែបអ័រតូដុក បែបប្រូតេស្តង់និងសាសនាជ្វីហ្វ។

**១០៤- ប៊ីហ្គិន-អាណានិគមអង់គ្លេស"កោះ"**(BIGIN–COLONIE ANGL AIS "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក។

**១០៥- ប៊ីហ្គិន-អាណានិគមអាមេរិក"កោះ"**(BIGIN–COLONIE AMERIQUE "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ **សាសនា** ៖ គ្រិស្តបែបកាតូលិកនិងប្រូតេស្តង់។

**១០៦- ប៊ុលហ្គារី** (BULGARIE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគអាគ្នេយ៍។ **សាសនា** ៖ គ្រិស្តបែបអ័រតូដុក (ភាគច្រើន) នៅសល់កាន់បែបកាតូលិក និងសាសនាអ៊ិស្លាម។

**១០៧- ប៊ូតង់** (BHOUTAN)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីកណ្តាលភាគខាងត្បូង។ **សាសនា** ៖ ពុទ្ធសាសនាមហាយានគោរពយ៉ាងតឹងតែងតាមគម្ពីរ។

**១០៨- ប៊ែរមូដ "កោះ"** (BERMUDES "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងជើង។ **សាសនា** ៖ អង់គ្លីកានីស (សាសនាអង់គ្លេសកាល រាជ្យអេលីហ្សាប៊ែត)។

**១០៩-បែលហ្ស៊ិក** (BELGIQUE)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងលិច។ **សាសនា** ៖ គ្រិស្តបែបកាតូលិក ស្ទើងទាំងអស់។

**១១០- ប្រាំងស្ស "កោះ"** (PRINCE "iles de")

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាហ្វ្រិក។ **សាសនា** ៖ គ្រិស្តបែបកាតូលិកនិងមានគោរពតាមទំនៀមទម្លាប់ដើមរបស់ខ្លួនខ្លះៗ។

**១១១- ប្រាំងស្ស អេឌូអា** (PRINCE-EDOUARD)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក(៤៥%) ក្រៅពីនេះ កាន់សាសនាផ្សេងៗដូចជាសាសនាដើមរបស់កាណាដានិងរបស់អង់គ្លេស។

**១១២- ប្រេស៊ីល** (BRESIL)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងផ្នែកខាងកើត។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១១៣- ព្រុយណេ** (BRUNEI)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍ត្រង់ពាយ័ព្យប័រណេអូ (ឥណ្ឌូណេស៊ី)។ សាសនា ៖ អ៊ិស្លាម ។

**១១៤- ព័រទុយហ្គាល់** (PORTUGAL)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគនិរតី។ សាសនា ៖ គ្រិស្តបែបកាតូលិក (៩៧%)។

**១១៥- ពីតកែន "ប្រជុំកោះ"** (PITCAIRN "iles de")

ទីតាំង ៖ ប្រជុំកោះស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១១៦- ពុយអែរតូរីកូ "ប្រជុំកោះ"** (PUERTO-RICO "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១១៧- ភូមា (មីយ៉ាន់ម៉ា)** (BIRMANIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីត្រង់ចន្លោះខ្សែរយៈទទឹងខាងជើងទី១៥ ដល់ទី៣០ និងត្រង់ខ្សែរយៈបណ្តោយខាងកើតទី៩០ ដល់ទី១០៩ ខាងកើតទល់នឹងប្រទេសថៃ និងឡាវ ខាងជើងឈៀងខាងកើតទល់នឹងចិន ខាងលិចទល់នឹងឥណ្ឌានិងបង់ក្លាដែស ខាងត្បូងទល់នឹង

សមុទ្របង់ហ្គាល់។ សាសនា ៖ ពុទ្ធសាសនា(៨២%)អ៊ិស្លាម (៤%)ហិណ្ឌូ(៤%) គោរពសត្វ (៥%)និងគ្រិស្ត(៥%)។

**១១៨- ម៉ិកស៊ិក** (MEXIQUE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖គ្រិស្តបែបកាតូលិក (៩៦%) នៅសល់កាន់បែបប្រូតេស្តង់។

**១១៩- មីលលីឡា** (MELILLA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងជើង។ សាសនា ៖ អ៊ិស្លាម។

**១២០- ម៉ូណាកូ** (MONACO)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១២១- មេត "កោះ"** (MAIT "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក និង បែបប្រូតេស្តង់។

**១២២- ម៉ាកាវ** (MACAU)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើត ។ សាសនា ៖ គ្រិស្តបែបកាតូលិក និង ព្រះពុទ្ធសាសនា។

**១២៣- ម៉ាលី** (MALI)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ អ៊ិស្លាម៧៥% គោរពសត្វ ២០% និងគ្រិស្ត ៥%។

**១២៤- ម៉ារីយ៉ាន "ប្រជុំកោះ"** (MARIANNES "ilse de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់។

**១២៥- ម៉ារីហ្គាឡង់ "កោះ"** (MARIE GALANTE "ilse de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១២៦-ម៉ារ៉ុក** (MAROC)

ទីតាំង ៖ ស្ថិតនៅចុងខាងជើងឈៀងខាងលិចនៃទ្វីបអាហ្វ្រិក។ សាសនា ៖ អ៊ិស្លាម (៧២%) នៅសល់កាន់សាសនាគ្រិស្ត និងជ្វីហ្វ។

**១២៧- ម៉ាដាហ្គាស្កា "កោះ"** (MADAGASCAR "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ គោរពសត្វ (៥៧%) គ្រិស្តបែបកាតូលិក (៣៨%) នៅសល់កាន់សាសនាអ៊ិស្លាម។

**១២៨- ម៉ាឌែរ "កោះ"** (MADERE "íles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១២៩- ម៉ាទីនិក "កោះ"** (MARTINIQUE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៣០- ម៉ាយ៉ូត "ប្រជុំកោះ"** (MAYOTTE "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក។

**១៣១- ម៉ាឡាវី** (MALAWI)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើត។ សាសនា ៖ គោរពសរណៈវត្ថុ(៥០%) និងគ្រិស្តបែបកាតូលិក (១៥%) នៅសល់កាន់សាសនាមុយស៊ុយម៉ង់។

**១៣២- ម៉ាឡេស៊ី** (MALAISIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីចុងខាងត្បូងឈៀងខាងកើត ព្រំប្រទល់មហាសមុទ្រឥណ្ឌានិងសមុទ្រចិន។ សាសនា៖ អ៊ិស្លាម(ភាគច្រើន)នៅសល់កាន់ពុទ្ធសាសនា និងហិណ្ឌូ។

**១៣៣- ម៉ាន់ "កោះ"** (MAN "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងសមុទ្រអៀរឡង់ភាគខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១៣៤- ម៉ាល់ត៏ និង ហ្គោហ្សូ "ប្រជុំកោះ"** (MALTE ET GOZO "iles de")

ទីតាំង៖ស្ថិតនៅត្រង់ភាគកណ្ដាលនៃសមុទ្រមេឌីទែរ៉ាណេភាគខាងជើងទ្វីបអាហ្វ្រិក។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៣៥- ម៉ាល់ឌីវ "ប្រជុំកោះ"** (MALDIVES "iles de")

ទីតាំង៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូងក្នុងមហាសមុទ្រឥណ្ឌា។ សាសនា៖អ៊ិស្លាម។

**១៣៦- ម៉ាកគី "ប្រជុំកោះ"** (MARQUIS "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១៣៧- ម៉ាកសាល "កោះ"** (MARSHALL "ile de")

ទីតាំង ៖ ស្ថិតនៅក្នុងទ្វីបអូសេអានីក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក។

**១៣៨- ម៉ុងសេរ៉ាត "ប្រជុំកោះ"** (MONTSERRAT "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១៣៩- ម៉ុងហ្គោលី** (MONGOLIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីខាងជើង។ សាសនា ៖ ពុទ្ធសាសនាបែបមហាយាន។

**១៤០- ម៉ូរីស "កោះ"** (MAURICE "ile de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌាភាគខាងត្បូង។ សាសនា ៖ ហិណ្ឌូ (៤៩%) គ្រិស្តបែបកាតូលិក(៣៣%) អ៊ិស្លាម(១៤%) ពុទ្ធសាសនា(២%) និងនៅសល់កាន់តៅអ៊ីស។

**១៤១- ម៉ូរីតានី** (MAURITANIE)

ទីតាំង ៖ ស្ថិតនៅពាយ័ព្យនៃទ្វីបអាហ្វ្រិក ។ សាសនា ៖ អ៊ិស្លាម ។

**១៤២- ម៉ូសំប៊ិក** (MOZAMBIQUE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគអាគ្នេយ៍ ជាប់នឹងឈូងសមុទ្រឥណ្ឌា ។ សាសនា ៖ ជឿលើការគោរពសត្វ (ភាគច្រើន) មួយចំនួនទៀតកាន់គ្រិស្តបែបកាតូលិក និងសាសនាមុយស៊ុលម៉ង់។

**១៤៣- យីប៊ូទី** (DJIBOUTI)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើតជាប់នឹងឈូងសមុទ្រអាដែន។ សាសនា ៖ ភាគច្រើនកាន់សាសនាអ៊ិស្លាម។

**១៤៤- យូហ្គោស្លាវី** (YOUGOSLAVIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគអាគ្នេយ៍។ សាសនា ៖ ប្រជាជនមានសេរីភាពក្នុងជំនឿសាសនា គេឃើញមានកាន់គ្រិស្តបែបអ័រតូដុក(៤១%) បែបកាតូលិក (៣១%) នៅសល់បែបប្រូតេស្តង់ និង កាន់សាសនាអ៊ិស្លាម។

**១៤៥- យេម៉ែនខាងត្បូង** (YEMEN DU SUD)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ី ក្នុងតំបន់មជ្ឈិមបូព៌ា។ សាសនា ៖ អ៊ិស្លាម។

**១៤៦- យេម៉ែនខាងជើង** (YEMEN DU NORD)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ី ត្រង់តំបន់មជ្ឈិមបូព៌ាជាប់មាត់សមុទ្រក្រហមចុងខាងត្បូង។ សាសនា ៖ អ៊ិស្លាម ។

**១៤៧- រីយូគីយូ "ប្រជុំកោះ"** (RYUKYU "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើតត្រង់ព្រំប្រទល់សមុទ្រខាងកើត។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៤៨- រីយោមុយនី "ចំណែកដែនដី"** (RIOMUNI "Partie continentale")

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៤៩- រ៉ូដ "កោះ"** (RHODES "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូងជាប់នឹងសមុទ្រមេឌីទែរ៉ាណេភាគខាងជើង។ សាសនា ៖ គ្រិស្តបែបអ័រតូដុក។

**១៥០- រ៉ូទ្រិច "កោះ"** (RODRIQUES "ile de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ ហិណ្ឌូ (ភាគច្រើន) ក្រៅពីនេះមានកាន់សាសនាអ៊ិស្លាម ពុទ្ធសាសនានិងគ្រិស្តបែបកាតូលិក។

**១៥១- រវ៉ាន់ដា** (RWANDA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគកណ្ដាល។ សាសនា ៖ គ្រិស្តបែបកាតូលិក(៥០%) គោរពសរណៈវត្ថុ (៤៤%) អ៊ិស្លាម (១%) នៅសល់កាន់គ្រិស្តបែបប្រូតេស្តង់ ។

**១៥២- រូម៉ានី** (ROUMANIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងកើត។ សាសនា ៖ ប្រជាជនមានសេរីភាពខាងជំនឿសាសនា គេឃើញភាគច្រើននៅកាន់គ្រិស្តបែបអ័រតូដុក។

**១៥៣- រ៉េអ៊ុយនីញ៉ុង "កោះ"** (REUNION "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌាប៉ែកខាងលិច។ សាសនា ៖ គ្រិស្តបែបកាតូលិក (៨៥%) នៅសល់កាន់សាសនាអ៊ិស្លាម។

**១៥៤- លីប៊ី** (LYBYE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងជើងជាប់នឹងឈូងសមុទ្រមេឌីទែរ៉ាណេ។ សាសនា ៖ អ៊ិស្លាម។

**១៥៥- លីបង់** (LIBAN)

ទីតាំង ៖ ស្ថិតនៅចុងខាងលិចនៃទ្វីបអាស៊ី ជាប់នឹងឈូងសមុទ្រមេឌីទែរ៉ាណេ។ សាសនា ៖ អ៊ិស្លាម (ភាគច្រើន) គ្រិស្តបែបកាតូលិក និងបែបអ័រតូដុក។

**១៥៦- លីបេរីយ៉ា** (LIBERIA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ គោរពសរណៈវត្ថុ(៩០%) គ្រិស្តបែប ប្រូតេស្តង់(៧%) និងអ៊ិស្លាម(៣%)។

**១៥៧- លិចតិនស្តាញ** (LIECH TENSTEIN)

ទីតាំង ៖ស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្តាលនៅចន្លោះប្រទេសស្វ៊ីស និងប្រទេសអូទ្រីស្ត។ សាសនា ៖ គ្រិស្តបែបកាតូលិក (៩២%)។

**១៥៨- លុចសំបួ** (LUXEMBOURG)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងលិច ត្រង់ចន្លោះប្រទេសបារាំង ប៊ែលហ្ស៊ិក និងអាល្លឺម៉ង់ខាងលិច។ សាសនា ៖ គ្រិស្តបែបកាតូលិក (៩៤%)។

**១៥៩- វិចតូរីយ៉ា** (VICTORIA)

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី។ សាសនា ៖ គោរពតាមសាសនាអង់គ្លេសភាគច្រើន ក្រៅពីនេះកាន់គ្រិស្តបែបកាតូលិក និងសាសនារបស់ជនជាតិដើម។

**១៦០- វីយែក្សអាមេរិកែន "ប្រជុំកោះ"** (VIERGES AMERICAINES "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក។

**១៦១- វីយែក្សអង់គ្លេស "ប្រជុំកោះ"** (VIERGES BRITANNIQUES "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាលត្រង់តំបន់ការ៉ាអ៊ីប។ សាសនា ៖ អង់គ្លីកានីស (សាសនាអង់គ្លេសមានតាំងពីរាជ្យស្តេចអេលីហ្សាបិត) និងគ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក។

**១៦២- វៀតណាម** (VIETNAM)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគអគ្នេយ៍។ សាសនា ៖ ពុទ្ធសាសនានិកាយមហាយាន និងកាន់សាសនាតៅអ៊ីស កុងហ្វូយស៊ីសខ្លះៗជនជាតិភាគតិចភាគខាងត្បូងនៃប្រទេសកាន់គ្រិស្តបែបកាតូលិក។

**១៦៣- វ៉ាទីកង់ "បូរី"** (VATICAN "cité du")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូង ក្នុងប្រទេសអ៊ីតាលី។ សាសនា ៖ គ្រិស្តបែបកាតូលិក ។

**១៦៤- វ៉ាលី និងហ្វូយទុយណា "ប្រជុំកោះ"** (WALLIS ET FUTUNA "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ និងបែបកាតូលិក។

**១៦៥- វ៉ានូអាទូ** (VANUATU)

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ និង បែបកាតូលិក និង សាសនាជ្វីហ្វមានកាន់ខ្លះៗ។

**១៦៦- វ៉េណេស៊ុយអេឡា** (VENEZUELA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងប៉ែកខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក (ភាគច្រើន) និងមានជំនឿលើការគោរពសត្វខ្លះៗ។

**១៦៧- សហរដ្ឋអាមេរិក** (ETATS-UNIS D'AMERIQUE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់ (មានកាន់ភាគច្រើន) សាសនាជ្វីហ្វ (មានកាន់ភាគតិច)។

**១៦៨- សាខាលីន "កោះ"** (SAKHALINE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគឦសាន។ សាសនា ៖ ប្រជាជនមានសេរីភាពខាងជំនឿសាសនា វេជ្ជបង្កើតជំនឿលើវិទ្យាសាស្ត្រ មានសល់បន្តិចបន្តួចកាន់គ្រិស្តបែបកាតូលិក បែបប្រូតេស្តង់ និង អ៊ិស្លាម។

**១៦៩- សាហារ៉ាខាងលិច** (SAHARA OCCIDENTAL)

ទីតាំង ៖ ស្ថិតនៅពាយ័ព្យនៃទ្វីបអាហ្វ្រិក ។ សាសនា ៖ អ៊ិស្លាម និងគ្រិស្តបែបកាតូ-លិក។

**១៧០-សាឡូម៉ុង "ប្រជុំកោះ"** (SALOMON "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងត្បូង។ សាសនា ៖ សាសនាបែបពួកអង់គ្លេសកាន់ និងគ្រិស្តបែបប្រូតេស្តង់ខ្លះៗ។

**១៧១- សារដែញ "កោះ"** (SARDAIGNE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងសមុទ្រមេឌីទែរ៉ាណេភាគខាងលិច។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៧២- សាវតូម និង ប្រាំងស៊ីប "ប្រជុំកោះ"** (SAOTOME ET PRINCIPE "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្តបែបកាតូលិក (៨០%) នៅសល់គោរពតាមទំនៀមទម្លាប់ស្រុកកំណើតរបស់ខ្លួន។

**១៧៣- សាម័រអាមេរិក** (SAMOA AMERICAINES)

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តសាសនាបែបប្រូតេស្តង់ និងបែបកាតូលិក។

**១៧៤- សាម័រខាងលិច** (SAMOA OCCIDENTALES)

ទីតាំង ៖ ស្ថិតនៅក្នុងចំណោមប្រជុំកោះប៉ូលីណេស៊ី នៃទ្វីបអូសេអានី នាកណ្តាលមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ (៨០%) និងនៅសល់កាន់បែបកាតូលិក។

**១៧៥-ស្រីលង្កា** (SRI LANKA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង។ សាសនា ៖ ពុទ្ធសាសនា (៦៤%) ហិណ្ឌូ (២០%) និងក្រៅពីនេះមានកាន់សាសនាអ៊ិស្លាមនិងគ្រិស្តបែបកាតូលិក។

**១៧៦- សិង្ហបុរី** (SINGAPOUR)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគអាគ្នេយ៍ខាងត្បូងភាគខាងលិចនៃប្រទេសម៉ាឡេស៊ី។ សាសនា ៖ ពុទ្ធសាសនា អ៊ិស្លាម ហិណ្ឌូ តៅអ៊ីស និងកុងហ្វូយស៊ីស ។

**១៧៧- សឺតា** (CEUTA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិក ជាប់ឆ្នេរសមុទ្រម៉ារុក។ សាសនា ៖ អ៊ិស្លាម។

**១៧៨- សូកូតូរ៉ា "កោះ"** (SOCOTORA "ile de")

ទីតាំង ៖ ស្ថិតនៅជិតទ្វីបអាស៊ី និងអាហ្វ្រិក។ សាសនា ៖ មហាហ្មុត ឬអ៊ិស្លាម។

**១៧៩- សូម៉ាលី** (SOMALIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើត។ សាសនា ៖ អ៊ិស្លាមនិងកាន់គ្រិស្ត បែបកាតូលិកខ្លះៗ។

**១៨០- សូវៀត** (SOVIET)

ទីតាំង ៖ស្ថិតនៅផ្នែកបូព៌ានៃទ្វីបអឺរ៉ុបនិងទ្វីបអាស៊ីភាគខាងជើងនិងភាគកណ្ដាល។ សាសនា ៖ ប្រជាជនមាន សេរីភាព លើជំនឿសាសនា ការអប់រំយកទ្រឹស្ដីម៉ាក្សស៊ីសជាធំ (មុនឆ្នាំ ១៩១៧ ប្រជាជន ៨០% កាន់គ្រិស្តបែបអ័រតូដុក បន្ទាប់មកមានកាន់បែបកាតូលិក អ៊ិស្លាម)។

**១៨១- សូស្យេតេ "ប្រជុំកោះ"** (SOCIETE "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**១៨២- សេណេហ្គាល់** (SENEGAL)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកចុងខាងលិចជាប់នឹងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ អ៊ិស្លាម (៨៥%) នៅសល់ជឿលើការគោរពសត្វ និងកាន់គ្រិស្តសាសនាតាមបែបផ្សេងៗ។

**១៨៣- សេស្ហែល "ប្រជុំកោះ"** (SEYCHELLES "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ គ្រិស្តបែបកាតូលិក និងសាសនាអ៊ិស្លាម។

**១៨៤- សាំងគ្រិស្តូហ្វិន "ប្រជុំកោះ"** (SAINT CHRISTOPHEN "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៨៥- សាំងព្យែរ និង មីកឺឡុង“ប្រជុំកោះ”**(SAINT-PIERRE ET MIQUELON “iles de”)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងជើង ។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៨៦- សាំងម៉ារតាំង “កោះ”** (SAINT MARTIN “ile de”)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក និង បែបប្រូតេស្តង់។

**១៨៧- សាំងម៉ារាំង** (SAINT-MARIN)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងប្រទេសអ៊ីតាលី។ សាសនា ៖ គ្រិស្តបែបកាតូលិក ។

**១៨៨- សាំងលូស៊ី “ប្រជុំកោះ”** (SAINTE-LUCIE “iles de”)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**១៨៩- សាំងវាំងសង់ “កោះ”** (SAINT-VINCENT “íle de”)

ទីតាំង ៖ ស្ថិតនៅអាមេរិកកណ្តាលក្នុងតំបន់ការ៉ាអ៊ីប។ សាសនា ៖ គ្រិស្តបែប កាតូលិក។

**១៩០- សាំងហេលែន “កោះ”** (SAINTE-HELENE “ile de”)

ទីតាំង ៖ ស្ថិតនៅខាងលិចទ្វីបអាហ្វ្រិក។ សាសនា ៖ គ្រិស្តបែបកាតូលិក ដែលពួក អង់គ្លេសកាន់ (អង់គ្លីកាន ឬ បាទីស្ត)។

**១៩១- ស្វាហ្ស៊ីឡង់** (SWAZILAND)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគចុងខាងកើត។ សាសនា ៖ គោរពបូជាតាមទំនៀម ទម្លាប់អ្នកស្រុក និងតាមបែបផ្សេងៗនៃគ្រិស្តសាសនា។

**១៩២- ស៊ីរី** (SY RIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិចត្រង់តំបន់មជ្ឈិមបូព៌ា។ សាសនា ៖ មុយ ស៊ុយម៉ង់ (៨៥%) នៅសល់កាន់សាសនាគ្រិស្ត និងសាសនាជ្វីហ្វ។

**១៩៣- សៀរ៉ាឡេអូន** (SIERRALEONE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច នៅជាប់នឹងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គោរពសារណោវត្ថុ(៨០%) អ៊ិស្លាម(១៦,៥%) និងគ្រិស្តបែបកាតូលិក(៣,៥%)។

**១៩៤- ស៊ុីស** (SUISSE)

ទីតាំង ៖ ស្ថិតនៅចំកណ្តាលទ្វីបអឺរ៉ុប។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ ៤៧,៧% និងបែបកាតូលិក ៤៩,៤% នៅសល់កាន់សាសនាដ៏ទៃ។

**១៩៥- ស៊ីប "កោះ"** (CHYPRE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ី ក្នុងមហាសមុទ្រមេឌីទែរ៉ាណេភាគខាងកើត។ សាសនា ៖ ពួកក្រិក កាន់គ្រិស្តបែបអ័រតូដុក និងពួកទៀតកាន់សាសនាអ៊ិស្លាម។

**១៩៦- ស៊ីកគីម** (SIKKM)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង។ សាសនា ៖ ហិណ្ឌូ (កាន់ភាគច្រើន) និងពុទ្ធសាសនា។

**១៩៧- ស៊ីតឡង់ "ប្រជុំកោះ"** (SHETLAND "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងមហាសមុទ្រអាត្លង់ទិកភាគខាងជើង។ សាសនា ៖ គ្រិស្តបែបពួកអង់គ្លេសកាន់ គឺរៀបចំជាអង្គភាពស្វ័យភាពមិនរណបព្រះវិហាររ៉ូម៉ាំង ដែលមានពីសតវត្សទី១៦មក។

**១៩៨- ស៊ុយអ៊ែត** (SUEDE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងជើង ត្រង់តំបន់ស្កង់ឌីណាវ។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ (៩៩%) នៅសល់កាន់បែបកាតូលិក ។

**១៩៩- ស៊ូដង់** (SOUDAN)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគកណ្តាល ជាប់នឹងសមុទ្រក្រហម។ សាសនា ៖ អ៊ិស្លាម (៧០%) និង ជឿលើការគោរពសត្វ (តំបន់ខាងត្បូង)។

**២០០- ស៊ូរីណាំ** (SURINAM)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងប៉ែកឦសាន។ សាសនា ៖ អេស្ប៉ាញ៉ុល (ផ្លូវការ) ពីមុនប្រើភាសាហូល្លង់ ស្រាម៉ុង និងតុងហ្គោ។

**២០១- ហាវ៉ៃ "ប្រជុំកោះ"** (HAWAIL "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ចំកណ្តាលមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**២០២- ហាអ៊ីទី "ផ្នែកមួយនៃកោះ"** (HAITI "une partie d'ile")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបកាតូលិក (ភាគច្រើន) វ៉ូឌូ និងសក្ការៈ អាហ្វ្រិក។

**២០៣- ហុងកុង** (HONG-KONG)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងកើត។ សាសនា ៖ ពុទ្ធសាសនានិងគ្រិស្ដបែបកាតូលិក។

**២០៣- ហុងគ្រី** (HONGRIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបកាតូលិក (៦០%) បែបប្រូតេស្ដង់ និងបែបអ័រតូដុក និងសាសនាជ្វីហ្វ (មួយចំនួនតូច)។

**២០៥- ហុងឌូរ៉ាស** (HONGDURAS)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបកាតូលិក។

**២០៦- ហៃណាម "កោះ"** (HAI-NAM "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ី ត្រង់ឆ្នេរសមុទ្រចិនភាគខាងត្បូងក្នុងឈូងសមុទ្រតុងកឹង។ សាសនា ៖ កុងហ្វូយស៊ីស ពុទ្ធសាសនា និងសាសនាតាវអ៊ីស។

**២០៧- ហ្សកហ្ស៊ីខាងត្បូង "កោះ"** (GEORGIE DU SUD "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង ក្នុងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្ដបែបកាតូលិក។

**២០៨- ហ្ស៊កដានី** (JORDANIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិច ត្រង់តំបន់មជ្ឈិមបូព៌ា។ សាសនា ៖ អ៊ិស្លាម (ភាគច្រើន) និងគ្រិស្ដសាសនាបែបផ្សេងៗ។

**២០៩- ហ្សាម៉ាអ៊ិច "កោះ"** (JAMAIQUE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបប្រូតេស្ដង់ និងបែបពួកអង់គ្លេសកាន់ (ភាគច្រើន) នៅសល់កាន់សាសនាជ្វីហ្វ។

**២១០- ហ្សាអៀរ** (ZAIRE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគកណ្ដាល។ សាសនា ៖ គោរពសរណៈវត្ថុ (៥០%) អ៊ិស្លាម (៥០%)។

**២១១- ហ្សាហ្គោស "ប្រជុំកោះ"** (CHAGOS "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ ហិណ្ឌូ គ្រិស្តបែបកាតូលិក និងសាសនាអ៊ិស្លាម។

**២១២- ហ្គាហ្សា** (GAZA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិចបំផុត។ សាសនា ៖ អ៊ិស្លាម។

**២១៣- ហ្គាដឺលូព "កោះ"** (GUADE LOUPE "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២១៤- ហ្គាណា** (GHANA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ភាគច្រើនជឿលើការ គោរពសត្វ នៅសល់កាន់គ្រិស្តសាសនា (បែបកាតូលិកនិងប្រូតេស្តង់)និងសាសនាមុយស៊ុយម៉ង់។

**២១៥- ក្វាតេម៉ាឡា** (GUATEMALA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក (ភាគច្រើន) និងបែបប្រូតេស្តង់។

**២១៦- ហ្គាបុង** (GABON)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិក។ សាសនា ៖ គ្រិស្តបែបកាតូលិក(៦០%) នៅសល់ជឿលើការគោរពសត្វ។

**២១៧- ហ្គាម "កោះ"** (GUAM "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា៖ គ្រិស្តបែបប្រូតេស្តង់ និង បែបកាតូលិក។

**២១៨- ហ្គាឡាប៉ាហ្គោស "កោះ"** (GALAPAGOS "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២១៩- ហ្វ៉កលែន "ប្រជុំកោះ"** (FALKLAND "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២២០- ហ្វារ៉ូអែរ "កោះ"** (FAROER "île de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្តបែបកាតូលិក និង មានមួយចំនួនកាន់សាសនាជ្វីហ្វ។

**២២១- ហ្វីលីពីន** (PHILIPPINES)

**ទីតាំង** ៖ ស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍ ត្រង់ព្រំប្រទល់សមុទ្រចិន និងមហាសមុទ្រ ប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក (៩៦%)មូស្លីម (៤%)។

**២២២- ហ្វីជី "ប្រជុំកោះ"** (FIDJI "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់និងបែបកាតូលិក។

**២២៣- ហ្វេនិក "ប្រជុំកោះ"** (PHCENIX "iles de")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែប កាតូលិក។

**២២៤- ហ្វាំងឡង់** (FINLANDE)

ទីតាំង ៖ ស្ថិតនៅជ្រោយស្កង់ឌីណាវ ក្នុងទ្វីបអឺរ៉ុបភាគខាងជើង។ សាសនា ៖ ភាគច្រើនប្រកាសខ្លួនជាសមាជិកនៃវិហារគ្រិស្តបែបប្រូតេស្តង់។

**២២៥- ហ្គីណេ** (GUINEE)

ទីតាំង ៖ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិចជាប់នឹងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ អ៊ិស្លាម (៥០%) និង ជំនឿលើការគោរពសត្វ (៥០%)។

**២២៦- ហ្គីណេប៊ីស្សូ** (GUINEE BISSAU)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិក ចុងខាងលិចជាប់នឹងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ មុយស៊ុលម៉ង់ (៦៤%) នៅសល់គោរពសរណាវត្ថុ។

**២២៧- ហ្គីណេអេក្វាតូរីយាល់** (GUINEE EQUATORIALE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ ភាគច្រើនកាន់គ្រិស្តសាសនាបែបកាតូលិក។

**២២៨- ហ្ស៊ីលី ឬ ហ្សូកឡាំងគីស "ប្រជុំកោះ"** (SCILLY OU SORLINGUES "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបក្នុងមហាសមុទ្រអាត្លង់ទិកភាគខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២២៩- ហ្ស៊ីប្រ៉ាល់តារ** (GIBRALTA)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគនិរតី។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៣០- ស៊ីមបាវ៉េ** (ZIMBABWE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិក ត្រង់ខាងត្បូងអាហ្វ្រិកភាគកណ្តាល។ សាសនា ៖ គោរពសរណាវត្ថុ (ភាគច្រើន) នៅសល់ជឿសាសនាគ្រិស្ត ពិសេសបែបប្រូតេស្តង់។

**២៣១- ហ្ស៊ីមមុយនិងកាស៊ីមៀរ "រដ្ឋ"** (JAMMU ET CACHEMIRE " état ")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង។ សាសនា ៖ មុយស៊ុយម៉ង់ (ពីរភាគបីនៃប្រជាជនកាន់) នៅសល់កាន់សាសនាហិណ្ឌូ។

**២៣២- សំប៊ី** (ZAMBIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងត្បូងប៉ែកកណ្តាល ។ សាសនា ៖ ភាគច្រើនគោរពសត្វនៅសល់ប្រហែល២០% កាន់គ្រិស្តសាសនាបែបកាតូលិកនិងបែបប្រូតេស្តង់។

**២៣៣- ហ្គំប៊ី** (GAMBIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច។ សាសនា ៖ អ៊ិស្លាម (ភាគច្រើន) ក្រៅពីនេះជឿលើការគោរពសត្វ និងគ្រិស្តបែបប្រូតេស្តង់ ច្រើនអ្នកនៅទីក្រុងកាន់។

**២៣៤- ហ្គំប៊ីយេ "ប្រជុំកោះ"** (GAMBIER "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអូសេអានីក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ គ្រិស្តបែបកាតូលិក និងបែបប្រូតេស្តង់។

**២៣៥- ហ្គ្រូអែនឡង់ "កោះ"** (GROENLAND "ile de")

ទីតាំង ៖ ស្ថិតនៅឦសានទ្វីបអាមេរិកជាប់នឹងប៉ូលខាងជើង ក្នុងមហាសមុទ្រអាត្លង់ទិកភាគខាងជើង។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ និងពួកអេស្គីម៉ូ មានជំនឿលើការគោរពសត្វ។

**២៣៦- ឡាវ** (LAOS)

ទីតាំង៖ស្ថិតនៅទ្វីបអាស៊ីភាគអាគ្នេយ៍។ សាសនា ៖ ពុទ្ធសាសនាភាគច្រើនមានមួយភាគតូចកាន់សាសនាគ្រិស្តបែបកាតូលិកនិងមានជំនឿលើការគោរពសត្វ(ភាគខាងជើង)។

**២៣៧- ឡាក់កឺឌីវ "ប្រជុំកោះ"** (LAQUEDIVES "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង ក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ ហិណ្ឌូ (ភាគច្រើន) និងអ៊ិស្លាមខ្លះៗ។

**២៣៨- ឡឺសូថូ** (LESOTHO)

ទីតាំង ៖ ស្ថិតនៅចំកណ្តាលប្រទេសអាហ្វ្រិកខាងត្បូង។ សាសនា ៖ ជាងពាក់កណ្តាលនៃប្រជាជនគោរពសត្វ នៅសល់កាន់សាសនាគ្រិស្តបែបកាតូលិក (២០%) និងបែបប្រូតេស្តង់ (២០%)។

**២៣៩- អង់គ្លោ-ន័រម៉ង់ដ៍ "កោះ"** (ANGLO-NORMANDES "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងសមុទ្រម៉ង់ភាគខាងលិច។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៤០- អង់គីឡា "កោះ"** (ANGUILLA "ile de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៤១- អង់គ្លេស** (ANGLETERRE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបផ្នែកពាយ័ព្យមានសមុទ្រព័ទ្ធជុំវិញ។ សាសនា ៖ សាសនាអង់គ្លេស (៦០%) គឺមានបែបដូចគ្រិស្តសាសនា តែរៀបចំជាអង្គភាពស្វ័យភាពមិនរណបព្រះវិហាររ៉ូម៉ាំង ដែលមានតាំងពីសតវត្សទី ១៦ មក។

**២៤២- អង់ដូរ៉** (ANDORRE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគនិរតី។ សាសនា ៖ ភាគច្រើនកាន់សាសនាគ្រិស្ត បែបកាតូលិក។

**២៤៣- អង់ដាម៉ាន់ "ប្រជុំកោះ"** (ANDAMAN "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីក្នុងមហាសមុទ្រឥណ្ឌា។ សាសនា ៖ ហិណ្ឌូនិងមុយស៊ុយម៉ង់ (ភាគច្រើន)។

**២៤៤- អង់ទីហ្គា "ប្រជុំកោះ"** (ANTIGUA "iles de")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបប្រូតេស្តង់។

**២៤៥- អង់ហ្គោឡា** (ANGOLA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិចផ្នែកខាងត្បូង។ សាសនា ៖ គ្រិស្ដបែបកាតូលិក (ភាគច្រើន) និងជឿលើការគោរពសត្វ។

**២៤៦- អាហ្សង់ទីន** (ARGANTINE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង។ សាសនា ៖ គ្រិស្ដបែបកាតូលិក (៩០%) នៅសល់កាន់បែបប្រូតេស្តង់ ២% និងកាន់សាសនាជ្វីហ្វ។

**២៤៧- អារ៉ាប៊ីសាអូឌីត** (ARABIE SEOUDITE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីត្រង់តំបន់មជ្ឈិមបូព៌ា ។ សាសនា ៖ អ៊ិស្លាម (មានស្នាក់ការសាសនា អ៊ិស្លាមពីរធំៗគឺ ឡាម៉ិកនិងម៉េឌីនអធិកភាពរបស់មូយស៊ុយម៉ង់ ស៊ុយនីត )។

**២៤៨- អារុយបា "កោះ"** (ARUBA "ile d' ")

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបកាតូលិក។

**២៤៩- អាហ្គរ "ប្រជុំកោះ"** (ACORES "iles d' ")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិក ។ សាសនា ៖ គ្រិស្ដបែបកាតូលិក។

**២៥០- អាឡាស្កា** (ALASKA)

ទីតាំង ៖ ស្ថិតនៅទិសពាយ័ព្យនៃទ្វីបអាមេរិកភាគខាងជើង។ សាសនា ៖ គ្រិស្ដបែបប្រូតេស្តង់។

**២៥១- អាល្លឺម៉ង់ខាងកើត** (ALLEMAGNE DE L' EST)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្ដាល។ សាសនា ៖ គឺជារដ្ឋគ្រហស្ថ ៖ ប្រជាជនមានសេរីភាព ខាងជំនឿសាសនាទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ (គ្រិស្ដបែបប្រូតេស្តង់ និងបែបកាតូលិក) ។

**២៥២-អាល្លឺម៉ង់ខាងលិច** (ALLEMAGNE DE L'OUEST)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្ដាល។ សាសនា ៖ គ្រិស្ដបែបប្រូតេស្តង់ និងបែបកាតូលិក (៤៤%) ក្រៅពីនេះមានជំនឿតាមទំនៀមទម្លាប់នៃតំបន់នីមួយៗ។

**២៥៣- អាល្លឺម៉ង់ ៖ ប៉ែរឡាំងខាងលិច** (ALLEMAGNE :BERLIN- OUEST)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងប្រទេសអាល្លឺម៉ង់ខាងកើត។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ (៨០%) និងបែបកាតូលិក (២០%)។

**២៥៤- អាហ្វ្រិកកណ្ដាល** (AFRIQUE CENTRAL)

ទីតាំង ៖ ស្ថិតនៅចំកណ្ដាលទ្វីបអាហ្វ្រិក ។ សាសនា ៖ គោរពសរណៈវត្ថុ (៦០%) គ្រិស្តបែបកាតូលិក និងអ៊ិស្លាមមានតិចតួច។

**២៥៥- អាហ្វ្រិកខាងត្បូង** (AFEIQUE DU SUD)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកចុងខាងត្បូងបំផុត។ សាសនា ៖ សំខាន់គ្រិស្តតាមបែបផ្សេងៗ និង ជាអ្នកប្រើវិធីត្រិះរិះជញ្ជឹងរកអភិញ្ញាណ។

**២៥៦- អាល់បានី** (ALBANIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគអគ្នេយ៍។ សាសនា៖ គ្មានសាសនាផ្លូវការទេ ប្រជាជនកាន់សាសនាអ៊ិស្លាម (៦៥%) គ្រិស្តបែបអ័រតូដុកនៅភាគខាងត្បូង(២៥%) និងបែបកាតូលិកនៅភាគខាងជើង (២៥%)។

**២៥៧- អាល់ហ្សេរី** (ALGERIE)

ទីតាំង ៖ ស្ថិតនៅអាហ្វ្រិកខាងជើង ជាប់នឹងសមុទ្រមេឌីទែរ៉ាណេភាគខាងលិច។ សាសនា ៖ អ៊ិស្លាម ៩០% នៅសល់កាន់គ្រិស្តបែបកាតូលិក។

**២៥៨- អាសង់ស្យុង "កោះ"** (ASCENSION "ile de l' ")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាត្លង់ទិកភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៥៩- អាហ្វហ្គានីស្ថាន** (AFGHANISTAN)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគកណ្ដាល។ សាសនា ៖ អ៊ិស្លាមរីតសុននីត។

**២៦០- អ៊ីតាលី** (ITALIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបកាតូលិក (ទឹកដីប្រកបនៃវិហារសាសនា កាតូលិក)។

**២៦១- អ៊ីរ៉ង់** (IRAN)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងលិច ត្រង់ចន្លោះសមុទ្រកាសព្យែន និងឈូងសមុទ្រពែរស៊ិក។ សាសនា ៖ អ៊ិស្លាម ៩៣% ក្រៅពីនេះមានកាន់គ្រិស្តបែបអាមេនីញាង ជ្វីហ្វ និងប៉ាហ៊ិរ្យ។

**២៦២- អ៊ីរ៉ាក់** (IRAK)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគនិរតី។ សាសនា ៖ អ៊ិស្លាម (៩៦%) នៅសល់កាន់គ្រិស្តសាសនា។

**២៦៣- អ៊ុយរូហ្គាយ** (URUGUAY)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូងប៉ែកអាគ្នេយ៍។ សាសនា ៖ គ្រិស្តបែបកាតូលិក (ភាគច្រើន) ជនជាតិភាគតិចកាន់គ្រិស្តបែបប្រូតេស្តង់។

**២៦៤- អ៊ីស្លង់** (ISLAND)

ទីតាំង៖ ស្ថិតនៅខាងជើងមហាសមុទ្រអាត្លង់ទិក។ សាសនា៖ គ្រិស្តបែបប្រូតេស្តង់។

**២៦៥- អ៊ីស្រាអែល** (ISRAEL)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីចុងខាងលិច ក្នុងតំបន់មជ្ឈិមបូព៌ា។ សាសនា ៖ ជ្វីហ្វ (ភាគច្រើនបំផុត) នៅសល់កាន់សាសនាមុយស៊ុយម៉ង់។

**២៦៦- អូម៉ង់** (OMAN)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគនិរតី ត្រង់តំបន់មជ្ឈិមបូព៌ា។ សាសនា ៖ អ៊ិស្លាម។

**២៦៧- អូទ្រីស** (AUTRICHE)

ទីតាំង ៖ ស្ថិតនៅប៉ែកខាងត្បូងនៃទ្វីបអឺរ៉ុបភាគកណ្ដាល។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់ (៩០%) បែបកាតូលិក (៦%) និងសាសនាជ្វីហ្វ (០,២%)។

**២៦៨- អូស្ត្រាលី** (AUSTRALIE)

ទីតាំង៖ ស្ថិតនៅទ្វីបអូសេអានីក្នុងអឌ្ឍគោលខាងត្បូង ចន្លោះមហាសមុទ្រប៉ាស៊ីហ្វិក និងមហាសមុទ្រឥណ្ឌា។ សាសនា ៖ គោរពតាមបែបអង់គ្លេស (៣៥%) គ្រិស្តបែបកាតូលិក (២៦%)គោរពតាមបុព្វជិតកាតូលិកតាមរបៀបកាល់វ៉ាំងដែលជឿថា អភិបាលវិហារកាតូលិកជាតំណាងចម្រុះគឺបាស្ទ័រ និងឡាក់(២៩%) អ្នកប្រើវិធីត្រិះរិះសញ្ជឹងរកអវិញ្ញាណ(១០%) ហើយជនជាតិ ដើមច្រើនជាជីវចលនិយម។

**២៦៩- អួរស្ស** (OURS)

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រអាកទិក។ សាសនា ៖ គ្រិស្តបែបប្រូតេស្តង់។

**២៧០- អូតវ៉ុលតា** (HAUTE-VOLTA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងលិច ។ សាសនា ៖ គោរពសរណៈវត្ថុ (៧៦%) អ៊ិស្លាម (២០%) និងគ្រិស្ត(៤%) ភាគច្រើនបែបកាតូលិក។

**២៧១- អៀរឡង់** (IRLANDE)

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគខាងលិច ព័ទ្ធជុំវិញដោយមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្តបែបកាតូលិកប្រហែល (៩៥%) និងបែបប្រូតេស្តង់ (៥%) ។

**២៧២- អេក្វាទ័រ** (EQUATEUR)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគខាងត្បូង។ សាសនា ៖ គ្រិស្តបែបកាតូលិក(៩០%) នៅសល់កាន់គ្រិស្តបែបប្រូតេស្តង់ និងសាសនាថ្មីៗ។

**២៧៣- អេត្យូពី** (ETHIOPIE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើត ។ សាសនា ៖ គ្រិស្ត (៥០%) អ៊ិស្លាម (៣៥%) និង កាន់តាមប្រពៃណីជាតិ (១៥%)។

**២៧៤- អេមីរ៉ាតអារ៉ាប់រួម** (EMIRATS ARABES UNIS)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគនិរតីត្រង់តំបន់មជ្ឈិមបូព៌ា។ សាសនា ៖ អ៊ិស្លាម ។

**២៧៥- អេស្ប៉ាញ** (ESPAGNE)

ទីតាំង៖ ស្ថិតនៅទ្វីបអឺរ៉ុបភាគនិរតី ដោយមានរួមទាំងប្រជុំកោះនៅតាមបណ្តោយឆ្នេរទ្វីបអាហ្វ្រិក ក្នុងមហាសមុទ្រអាត្លង់ទិក។ សាសនា ៖ គ្រិស្តបែបកាតូលិកស្ទើរតែទាំងអស់។

**២៧៦- អេហ្ស៊ីប** (EGYPTE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគឦសាន ។ សាសនា ៖ អ៊ិស្លាម (៩២%) នៅសល់កាន់សាសនាគ្រិស្តបែបកាតូលិក និកាយកូប សហគមកាតូលិក ប្រូតេស្តង់ និងសាសនាថ្មីៗ។

**២៧៧- អែលសាលវ៉ាឌ័រ** (EL SALVADOR)

ទីតាំង ៖ ស្ថិតនៅទ្វីបអាមេរិកភាគកណ្តាល។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៧៨- អាំងឌីយាង "ដែនដី"** (INDIEN "territoire ")

ទីតាំង ៖ ស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌាភាគខាងលិច។ សាសនា ៖ កាន់សាសនារបស់ពួកអង់គ្លេស និងគ្រិស្តបែបកាតូលិក។

**២៧៩- អ៊ូហ្គង់ដា** (UGANDA)

ទីតាំង ៖ ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងកើត។ សាសនា ៖ ភាគច្រើនគោរពសរណៈវត្ថុមួយចំនួនតូច កាន់សាសនាគ្រិស្ត និងសាសនាអ៊ិស្លាម។

**២៨០- អែល្បៃ "កោះ"** (ELBLE "ile d' ")

ទីតាំង ៖ ស្ថិតនៅទ្វីបអឺរ៉ុប ក្នុងសមុទ្រទីរេហេនីញែនភាគខាងជើង។ សាសនា ៖ គ្រិស្តបែបកាតូលិក។

**២៨១- ឥណ្ឌា** (INDE)

ទីតាំង ៖ ស្ថិតនៅទ្វីបអាស៊ីភាគខាងត្បូង។ សាសនា ៖ ហិណ្ឌូ (៨៤%) គ្រិស្ត (២,៥%) និងពុទ្ធសាសនា (១,៧%)។

**២៨២- ឥណ្ឌូណេស៊ី** (INDONESIE)

ទីតាំង ៖ ស្ថិតនៅចន្លោះទ្វីបអាស៊ី និងប្រទេសអូស្ត្រាលី ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ សាសនា ៖ អ៊ិស្លាម (៩០%) នៅសល់កាន់ហិណ្ឌូ និងពុទ្ធសាសនា[១]។

[១] កាន់ ម៉ន ៖ ជំនួយស្មារតីស្គាល់ដីងនិងប្រជាជនលើពិភពលោក ឆ្នាំ១៩៨៤ ទំព័រ ៤៥០-៦៥១

# ជំពូកទី២
# កំណើតនៃសាសនាសកល

(ស្រាវជ្រាវដោយ បណ្ឌិតសភាចារ្យ **ខ្ចួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា)

សាសនាគឺជាអ្វី? អត្ថន័យរបស់ពាក្យសាសនា **លទ្ធិ** ទស្សនវិទូនិងចរិយាធម៌ បញ្ហាចោទឡើងថា សាសនាគឺជាអ្វី បើបំបែកចេញជាសំណួរមាន២យ៉ាង ដំបូងគឺជាបញ្ហានៃពាក្យថា **សាសនា** ត្រូវគ្នាឬខុសគ្នាយ៉ាងណាដែរ និងពាក្យថា **Religion** របស់បារាំងនៅទីបំផុតគឺបញ្ហាថាសាសនាគឺជាអ្វី?

បញ្ហាទាំងនេះមិនស្រួលជាធំដុំប៉ុន្មានទេ ប៉ុន្តែជាបញ្ហាពិបាក មានការជជែកគ្នាក្នុងចំណោមបណ្ដាពួកបណ្ឌិតអ្នកប្រាជ្ញជនជាតិខាងលិចកាលបើជជែកគ្នាច្រើន សេចក្ដីត្រូវការអត្ថន័យពាក្យថា សាសនា កាន់តែច្រើនដែរ ការផ្លាស់ប្ដូរពាក្យនិងគោលគំនិតសព្វក៏បែកខ្ញែកចេញកាន់តែច្រើនឡើងៗ ពួកខ្លះបានបែកខ្ញែកចេញរហូតដល់ពុទ្ធសាសនាមិនមែនជាសាសនា គ្រាន់តែជាទស្សនវិជ្ជាមួយរបស់ជីវិតប៉ុណ្ណោះ ទាំងអស់នេះកើតមកពីការកាន់ប្រឡំក្នុងការឱ្យអត្ថន័យនៃស័ព្ទ។

ការឆ្លើយបញ្ហាថា សាសនាគឺអ្វី ឱ្យនិយមន័យជិតបំផុតនោះ ត្រូវយល់ព្រមគ្នាជាមុនសិន ថាយកត្រឹមណានឹងនិយាយពីសាសនាណា ឬនឹងនិយាយរួមគ្នាទៅមិនថាសាសនាណាៗ...? (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគទី១ ទំ១០)

បើនិយាយពីដើមដំបូង គឺនិយាយពីសាសនាប្រភេទណា ត្រូវនិយាយវែកញែកទៅតាមប្រភេទរបស់សាសនាគឺ សាសនាតាមបែបបារាំង ឬសាសនាតាមបែបរបស់ខ្មែរយើងភាគច្រើនគឺពុទ្ធសាសនា?។ បារាំងអធិប្បាយពាក្យ Religion របស់គេ ដែលយើងយកមកប្រែថាសាសនា ខុសពីអត្ថន័យក្នុងពាក្យសាសនារបស់យើង (តាមន័យរបស់ពុទ្ធសាសនា) ជាច្រើន។ ក្រៅពីពាក្យថា Religion បារាំងនៅមានពាក្យមួយទៀតថា Doctrine ដែលនាំគ្នាយកមកប្រែថាលទ្ធិ រឿងក៏កាន់តែច្របូកច្របល់ច្រើនឡើង ព្រោះមានទាំងលទ្ធិនិងសាសនា គឺលទ្ធិមួយបែបសាសនាមួយបែប អ្នកខ្លះហៅថាសាសនារួមគ្នាក៏មានដែរ តែត្រឹមប៉ុណ្ណោះ នៅមិន ទាន់អស់រឿងច្របូកច្របល់ទេ លុះការសិក្សាធម៌ចម្រើនឡើងក៏មានពាក្យកើតឡើងថ្មីមួយទៀតគឺ ទស្សនវិជ្ជាដែលប្រែមកពីភាសាបារាំង (Philosophy)។ មានអ្នកខ្លះអធិប្បាយថាពុទ្ធសាសនាជាទស្សនវិជ្ជា ក្រៅពីនេះមានពាក្យថា Ethics ដែលប្រែថា សីលធម៌ អភិសមា

ចារបុារាំងដែលមិនយល់ពាក្យថា ពុទ្ធសាសនាឱ្យបានច្បាស់ ទើបហៅពុទ្ធសាសនាថា សីលធម៌តែម្តងទៅក៏មាន។

ពាក្យបារាំង ៤ ពាក្យគឺ ៖

១- RELIGION ប្រែថាសាសនា

២- DOCTRINE ប្រែថាលទ្ធិ

៣- PHYLOSOPHY ប្រែថាទស្សនវិជ្ជា

៤- ETHICS ប្រែថាសីលធម៌ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១១)

ពាក្យថា Religion ជាភាសាអង់គ្លេសចេញពីភាសាឡាតាំងថា Religare ឬ Religare ត្រូវនឹងពាក្យថា Together គឺ ការរួមចូលជាមួយគ្នារវាងរបស់មួយនិងរបស់មួយទៀត មានន័យថាចងភ្ជាប់ឬសម្ព័ន្ធរវាងរបស់២យ៉ាងឱ្យទៅជារបស់តែមួយ។ យើងអាចអធិប្បាយពាក្យ Religion បានថា ការសម្ព័ន្ធរវាងមនុស្សនិងអំណាចនៅលើមនុស្សតាមន័យដោយត្រង់ក្នុងទីនេះគឺ ការចងសម្ព័ន្ធខាងវិញ្ញាណរវាងមនុស្សនិងព្រះជាម្ចាស់ តាមន័យសព្ទមានសេចក្តីដូច្នោះ។ ពាក្យថា Religion ដែលយើងយកមកបកប្រែ សាសនាទីនេះជារឿងនៃការចងសម្ព័ន្ធដោយសទ្ធារវាងមនុស្សនិងព្រះជាម្ចាស់ មិនមែនមានន័យថា សាសនាតាមន័យពាក្យថា ពុទ្ធសាសនានោះទេ។

សាសនាតាមការយល់របស់បារាំង មានលក្ខណៈ៤ប្រការគឺ ៖

១-មានគោលការណ៍គោរពជឿថា ព្រះជាម្ចាស់ជាអ្នកសាងលោក និងរបស់ទូទៅក្នុងលោក។

២-មានគោលការណ៍ជឿថា ពាក្យប្រៀនប្រដៅផ្សេងៗមកពីព្រះជាម្ចាស់ ទាំងផ្នែកសីលធម៌ និង ច្បាប់ក្នុងលោក។

៣-មានគោលការណ៍ជឿថា ពុំគួរគិត (អចិន្ត្រៃយ៍) ឱ្យជឿទៅតាមពាក្យប្រៀនប្រដៅដោយមិនបាច់នឹកគិតដល់ការពិសោធតាមគោលវិទ្យាសាស្ត្រ។ តែអាស្រ័យអានុភាពព្រះជាម្ចាស់អ្នកដែលនៅលើមនុស្សជាធំ។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១២)

៤-មានគោលការណ៍ព្រមប្រគល់ខ្លួន ប្រគល់ការធ្វើរបស់ខ្លួននិងអ្វីៗផ្សេងទៀតដែលទាក់ទងជាមួយខ្លួន ឱ្យព្រះជាម្ចាស់ដោយភក្តីភាព មិនត្រូវជំទាស់តវ៉ា ខនេះសុំដូចបារាំងជា

*ម្ចាស់នៃសព្ទ* Religion *សរសេរទុកជា* Submit oneself to (the) God *គឺការព្រមប្រគល់សេរីភាពរបស់ខ្លួនថ្វាយចំពោះព្រះជាម្ចាស់។*

Religion *តាមន័យរបស់បារាំងនេះ មាននៅក្នុងសាសនាសំខាន់ៗនៃសកលលោកជាច្រើនដូចជា សាសនាព្រហ្មណ៍ឬហិណ្ឌូ ដែលអ្នកខ្លះហៅថាលទ្ធិព្រហ្មណ៍ សាសនាគ្រិស្ត និងសាសនាឥស្លាម។ សាសនាទាំងនេះចាប់ផ្ដើមពាក្យប្រៀនប្រដៅថា មានព្រះជាម្ចាស់ជាអ្នកកសាងលោក សាងមនុស្សសព្វសត្វ និងរបស់សព្វសារពើដែលជាធម្មជាតិ មានការទាក់ទងនឹងជីវិតនៃការរស់នៅ ដូចជាព្រះអាទិត្យ ព្រះចន្ទ ដួងតារា។ល។ គោលការណ៍ក្នុងសាសនាទាំងអស់នេះអះអាងថា ការប្រៀនប្រដៅដែលជាសីលធម៌ក្នុងសាសនារហូតដល់ច្បាប់ពាក្យបង្គាប់បញ្ជាផ្សេងៗក្នុងសង្គមក៏មកពីអំណាចរបស់ព្រះជាម្ចាស់ទាំងអស់ ដោយហេតុមកពីមនុស្សគ្រប់រូប កើតឡើងដោយអំណាចការកសាងរបស់ព្រះជាម្ចាស់។ ការបង្រៀនកាន់តែជ្រៅទៅទៀតថា ដួងវិញ្ញាណរបស់មនុស្សកើតចេញពីព្រះជាម្ចាស់ កាលរលត់ជីវិតទៅដួងវិញ្ញាណនឹងចូលមករួមជាមួយព្រះជាម្ចាស់។ ពាក្យប្រៀនប្រដៅទាំងប៉ុន្មាន មនុស្សត្រូវជឿស្ដាប់ ត្រូវប្រតិបត្តិតាមពាក្យប្រៀនប្រដៅចារឹកទុកយ៉ាងណា ត្រូវប្រតិបត្តិតាមយ៉ាងនោះ ប្រគល់ការថ្វាយខ្លួនឱ្យដល់ព្រះជាម្ចាស់ សេចក្ដីអាក្រក់ សេចក្ដីល្អយ៉ាងណា ដែលប្រតិបត្តិទៅហើយ ព្រះជាម្ចាស់ជាអ្នកកាត់សេចក្ដីឱ្យ ថាគួរនឹងបានទទួលរង្វាន់នៃសេចក្ដីល្អយ៉ាងណា ហើយនឹងទទួលទោសពីសេចក្ដីអាក្រក់នោះយ៉ាងណា ក្នុងសាសនាព្រហ្មណ៍ សាសនាគ្រិស្ត និងសាសនាអ៊ិស្លាម មានគោលការណ៍នៃជំនឿ គោលការណ៍នៃភក្ដី ភាពដូចអធិប្បាយមកដោយមានន័យប្រហាក់ប្រហែលគ្នា និងដោយន័យប្រតិបត្តិនេះឯង ហើយដែលជាការប្រតិបត្តិទៅតាមគោលបំណងរបស់ពាក្យ* Religion *ក្នុងភាសាបារាំង ដែលយើងនាំគ្នាយកមកប្រែជាសាសនា។* ( *ហេង គីមហោ* ***សាសនាប្រៀបធៀប*** *ភាគទី១ ទំព័រ ១៣)*

*ចំណែកពាក្យថាសាសនារបស់ពួកពុទ្ធសាសនិកជនមានន័យផ្ទុយពី អំពីន័យ* Religion *របស់បារាំង កាលបើនឹងអធិប្បាយពាក្យសាសនានេះក៏ត្រូវអធិប្បាយអំពីន័យពាក្យពុទ្ធសាសនាដែលបារាំងយល់ថាមិនមែនជាសាសនានៅក្នុងរូបភាពរបស់ខ្លួនឯងនោះ។*

*ពាក្យថាសាសនានេះមានន័យថា លទ្ធិ ជំនឿរបស់មនុស្សដែលមានគោលការណ៍សម្ដែងពីកំណើត និង ការរលាយទៅវិញនៃសកលលោកជាដើម ដែលប្រព្រឹត្តទៅនៅក្នុងផ្នែកបរមត្ថមួយប្រការសម្ដែងគោលការណ៍ធម៌ដែលទាក់ទិននឹងបុណ្យបាប ប្រព្រឹត្តទៅក្នុង*

ផ្នែកសីលធម៌នោះមួយប្រការទៀត ព្រមទាំងលទ្ធិពិធីដែលធ្វើតាមការយល់ឃើញឬតាមពាក្យប្រៀនប្រដៅក្នុងជំនឿនោះៗ។

ពុទ្ធសាសនាគឺ ពាក្យប្រដៅរបស់ព្រះពុទ្ធ មានការប្រដៅរហូតដល់បរមត្ថសាសនាព្រះពុទ្ធទើបគ្មានន័យ ត្រូវនឹងពាក្យបារាំង Religion ព្រោះសាសនាក្នុងពាក្យថា ពុទ្ធសាសនា ប្រកបដោយ ៖

១-គ្មានគោលការណ៍ជឿថា ព្រះជាម្ចាស់ជាអ្នកសាងលោក មានតែគោលការណ៍ជឿថា កម្មជាអ្នកសាងលោក និងវត្ថុនានា (កម្មុនាវត្តលោកា)។

២-គ្មានគោលការណ៍ជឿថា ពាក្យប្រដៅផ្សេងៗមកពីព្រះជាម្ចាស់ តែមានជំនឿថាពាក្យប្រដៅផ្សេងៗមកពីអ្នកចេះដឹង (ព្រះពុទ្ធ) ជាអ្នកប្រៀនប្រដៅ (សព្វបាបស្សអករណំ ឯ តិ ពុទ្ធានសាសនំ)។

៣-គ្មានគោលការណ៍ជឿទៅតាមពាក្យប្រៀនប្រដៅ ដោយមិនបានគិតដល់ការពិសោធន៍ តែមានគោលការណ៍ឱ្យពិសោធន៍ពាក្យប្រៀនប្រដៅនោះ (កាលាមសូត្រ)។

៤-គ្មានគោលកាណ៌ព្រមប្រគល់ខ្លួនឱ្យដល់ព្រះជាម្ចាស់ តែមានគោលការណ៍ប្រគល់ឱ្យដល់ខ្លួនឯង (អត្តាហិ អត្តនោនាថោ)។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគទី១ ទំព័រ ១៤)

ប្រការមួយទៀត លក្ខណៈដែលហៅសាសនាបាន ទោះបីជាសាសនាក្នុងពាក្យថាពុទ្ធសាសនាក្តី ឬ ពាក្យថា Religion របស់បារាំងក្តី មានគោលការណ៍ដែលអ្នកប្រាជ្ញខាងសាសនាព្រមទទួលដូច្នេះគឺ ៖

ក-ត្រូវតែជារឿងដែលអាចជឿបាន ដោយមានសេចក្តីស័ក្តិសិទ្ធិនិងត្រូវគោរពបូជាទៅតាមជំនឿនោះ។

ខ-ត្រូវមានពាក្យប្រៀនប្រដៅ សម្តែងពីសីលធម៌និងច្បាប់ទម្លាប់ទាក់ទងនឹងអំពើប្រតិបត្តិ ដើម្បីសម្រេចផលដ៏ល្អប្រសើរដល់សង្គម។

គ-ត្រូវមានខ្លួនអ្នកប្រកាស អ្នកប្រៀនប្រដៅ ឬអ្នកតែងតាំង ហើយព្រមទទួលខ្លួនថាជាសេចក្តីពិតតាមប្រវត្តិសាស្រ្ត។

ឃ-ត្រូវមានអ្នកទទួលបន្តប្រតិបត្តិតាមពាក្យប្រៀនប្រដៅនោះ ប្រព្រឹត្តតាមគ្នាតៗមក ភាគច្រើន ហៅថាលោកសង្ឃ អ្នកព្រតឬអ្នកបួស ជាអ្នកមាននាទីធ្វើពិធីក្នុងសាសនានោះ។

*នេះជាលក្ខណៈដែលហៅថា “សាសនា” តាមន័យនៃពុទ្ធសាសនា ឬដែលបារាំងហៅថា* Religions *មួយបែបផងនោះ។ ឱកាសនេះមកដល់ពាក្យថា* Doctrine *ដែលប្រែថាលទ្ធិ។ ( ហេង គីមហោ **សាសនាប្រៀបធៀប** ភាគទី១ ទំ ១៥)*

*ពាក្យថាលទ្ធិនិងសាសនា ប្រើលាយឡំគ្នាណាស់ ជួនកាលយើងប្រើពាក្យលទ្ធិសាសនារួមជាមួយគ្នា ជួនកាលយើងបំបែកចេញពីគ្នាយើងហៅជំនឿម្យ៉ាងទៀតថា លទ្ធិ ហៅជំនឿម្យ៉ាងទៀតថាសាសនា តែជួនកាលជំនឿដែលមានលក្ខណៈជាសាសនាបរិបូណ៌តាមគោលការណ៍ដែលបរិយាយខាងដើម យើងនាំគ្នាហៅថា លទ្ធិក៏មាន ដូចយើងហៅលទ្ធិព្រហ្មណ៍ លទ្ធិគ្រិស្ត និងលទ្ធិអ៊ិស្លាមមានជារឿយៗផងដែរ។ យើងសាកល្បងបំបែកចេញ តើយើងអាចបំបែកបានឬទេ?*

Doctrine *វចនានុក្រមអង់គ្លេសប្រែថាជារឿងដែលប្រៀនប្រដៅគ្នា ជំនឿ ឱវាទរបស់និកាយណាមួយ។ វចនានុក្រមខ្មែរប្រែថាសេចក្តីយល់ឃើញ សេចក្តីប្រកាន់ជឿជំនឿដែលបានទទួលតៗគ្នាមក។*

*បើនឹងកាន់យកលក្ខណៈដែលពិពណ៌នាខាងដើម ថាគោលការណ៍ប្រកបលទ្ធិគឺ មិនមែនជាសាសនា តែទាំងអស់នេះត្រូវកុំភ្លេចថា ពាក្យប្រៀនប្រដៅរបស់សាសនាអង្គណាៗ ឬឱវាទរបស់អ្នកណាក៏ដោយ ដែលចាប់ផ្តើមបង្រៀនតៗគ្នាមក រមែងហៅថា លទ្ធិ របស់សាស្តានោះៗ ជាឱវាទរបស់អ្នកនោះៗដូចគ្នាទាំងអស់។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធកាលពីដើមមានអ្នកកាន់សាសនាក្នុងសម័យនោះហៅថា “លទ្ធិរបស់សមណគោតម” ពាក្យប្រៀនប្រដៅរបស់ព្រះយេស៊ូ កាលដែលប្រកាសផ្សាយថ្មីៗក៏មានពួករ៉ូម៉ាំងហៅថា លទ្ធិណាករិតពាក្យប្រៀនប្រដៅរបស់ពួកមហាហ្មុំត ក៏មានអ្នកហៅថាលទ្ធិដូចគ្នា។ ( ហេង គីមហោ **សាសនាប្រៀបធៀប** ទំព័រ ១៦)*

*បើយើងទទួលយកសេចក្តីពិតក្នុងប្រវត្តិសាស្ត្រនេះ យើងត្រូវព្រមទទួលថា “លទ្ធិ” គឺរឿងដើមដំបូងរបស់សាសនា ឬចំណុចចាប់ផ្តើមរបស់សាសនា។ កាលបើម្ខាងៗយល់ឃើញផ្សេងៗពីគ្នា ទើបគ្មានមធ្យោបាយណាអាចបំបែកចេញពីគ្នាបានឡើយ បើប្រសិនជាអាចបំបែកបានក៏អាចបំបែកត្រឹមតែរូបស័ព្ទប៉ុណ្ណោះ បំបែកបានត្រឹមតែនិយាយថា លទ្ធិពាក្យបង្រៀនចំពោះពួកដែលមានន័យចង្អៀតជាងសាសនា បើនឹងហៅថាលទ្ធិសាសនារួមជាមួយគ្នា ឬហៅសាសនាដោយឯកជន ក៏ត្រូវដូចគ្នាទាំង២យ៉ាង។*

អំពីពាក្យថាទស្សនវិជ្ជា Philosophy មានន័យថា វិជ្ជាដែលកើតឡើងពីទស្សនៈនិងសេចក្តីពិត។ ការចេះដឹង គិតឃើញទាក់ទងនឹងរឿងប្រព្រឹត្តទៅនៃលោកបុព្វហេតុផ្សេងៗ ឬអំពីជីវិតនៃមនុស្សនិងសត្វជាទស្សនវិជ្ជាវិទ្យាសាស្ត្រនិងទស្សនៈរបស់អ្នកប្រាជ្ញបុរាណក្រិកជាច្រើនរូប ដូចជាលោកសូក្រាត ប្លាតុង អរិស្តូត ជាដើម យើងហៅថាទស្សនវិជ្ជា។ លុះមកដល់សម័យព្រះពុទ្ធជាម្ចាស់ ទ្រង់បានរិះគិតតែហេតុការណ៍ប្រព្រឹត្តទៅនៃលោកនិងជីវិតមួយបែបផ្សេងទៀត អំពីអ្នកប្រាជ្ញបុរាណរិះគិតឃើញ ដូចជាទ្រង់អធិប្បាយពីគោល ការណ៍ដែលមានលោកនេះជារូប គោលការណ៍មានជីវិតប្រាកដឡើងក្នុងលោកទៅតាមគោលបដិច្ច-សមុប្បាទ ឬគ្រឿងប្រាស្រ័យទាក់ទងតៗគ្នាដូចច្នោះជាដើម យើងហៅទស្សនវិជ្ជារបស់ព្រះពុទ្ធដូចគ្នា។ ដោយសភាពយ៉ាងនេះហើយ ពាក្យប្រៀនប្រដៅក្នុងពុទ្ធសាសនា ទើបយើងហៅថាពុទ្ធទស្សនវិជ្ជា។

ចំណែកពាក្យ Ethics ដែលត្រូវយើងប្រែថាសីលធម៌ឬចរិយានោះ ដូចជាមិនបាច់អធិប្បាយ ទោះជាអ្នកប្រាជ្ញណានិយាយថាពុទ្ធសាសនាត្រឹមតែជាសីលធម៌មិនមែន Religion ឬមិនមែនសាសនា ឬនិយាយទំនងឯណាទៀតនោះ ក៏មិនត្រូវអធិប្បាយដែរ។ សូមឱ្យយល់សាជាថ្មីទៀតថា ពាក្យប្រៀនប្រដៅឯណាៗ ដែលមកអំពី Religion របស់បារាំងឬ មកពីពុទ្ធសាសនារបស់ជនជាតិយើងជាខប្រតិបត្តិធម៌ ជាសេចក្តីប្រព្រឹត្តត្រឹមត្រូវក្នុងសង្គមនិងជាពាក្យប្រៀនប្រដៅមកពីព្រះជាម្ចាស់ ឬពីមនុស្សក្តីក៏ជាសីលធម៌ទាំងអស់។

ដោយន័យដូចបានសម្តែងមក សេចក្តីដែលនឹងអធិប្បាយនៅខាងក្នុងពាក្យអធិប្បាយនេះ មិនត្រូវគិតដល់ស័ព្ទ Religion Doctrine & Ethices របស់បារាំង ឬស័ព្ទជាសាសនា នាំឱ្យមានការពិបាកកន្លែងណាវគ្គណា គួរនឹងហៅថាលទ្ធិសាសនារួមគ្នាក៏ហៅទៅ កន្លែងណាវគ្គណាគួរហៅត្រឹមសាសនា ឬហៅថាទស្សនវិជ្ជា ឬសីលធម៌ គួរនឹងហៅឬប្រើឱ្យបានសមរម្យទៅតាមលក្ខណៈនិងសេចក្តីក្នុងវគ្គនោះៗក៏ប្រើទៅ។ ទោះបីជា Religion របស់បារាំងក្តី ឬទោះជាសាសនាតាមន័យសេចក្តីក្នុងពុទ្ធសាសនាក្តី ពាក្យប្រៀនប្រដៅទាំងនោះជា ធម៌សាកលសម្រាប់សង្គម ជាគ្រឿងទ្រទ្រង់សង្គមឱ្យតាំងនៅបាន ជួយជុសខាត់សង្គមឱ្យរួចផុតពីភាពកាចសាហាវមកកាន់ការយល់ចិត្តយល់ថ្លើមស្រឡាញ់រាប់អានសាមគ្គីគ្នា។ សាសនាមិនមែនជាសម្បត្តិរបស់ជាតិណាមួយក្រុមណាមួយនោះទេ តែផ្លូវនៃការប្រតិបត្តិតាមធម៌ក្នុងសាស-នា ដើម្បីសេចក្តីរៀបរយក្នុងសង្គមនោះ រមែងមានការខុសគ្នាទៅតាមលក្ខណៈភូមិប្រទេស

និងសង្គម ហើយត្រូវជាការប្រតិបត្តិមិនទាក់ទងនឹងនយោបាយទេ។ ដរាបណាមាននយោ-បាយចូលមកទាក់ទងនឹងទំនៀមទម្លាប់របស់សង្គមនោះៗ ការប្រតិបត្តិនោះ មិនមែនជារឿងរបស់សាសនាក្នុងទីនេះទេ។ (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៨)

សទ្ធាគឺជំនឿ ជាចំណុចផ្ដើមរបស់សាសនាតូចធំទាំងឡាយ សទ្ធានោះមានពីរយ៉ាង បានដល់សទ្ធាជាសញ្ញាណសម្បយុត្តគឺ ជំនឿប្រកបដោយបញ្ញាដឹងហេតុផល និងសទ្ធាជាសញ្ញាណវិប្បយុត្តបានដល់ជំនឿ ដែលកើតពីមិនដឹងហេតុផល។

សាសនាតូចធំទាំងឡាយ កើតអំពីសទ្ធាទាំងពីរប្រការនេះ សាសនាដែលកើតឡើងហើយ មិនអាចតាំងនៅបានយូរ ព្រោះគ្មានហេតុផលតាមផ្លូវធម៌ ឯសាសនាដែលកើតឡើងតាំងនៅបានយូរ កើតអំពីសទ្ធាដែលជាសញ្ញាណសម្បយុត្ត ដោយបញ្ញា។

អធិប្បាយមកនេះជាទីតាំងឱ្យឃើញ មូលហេតុរបស់សាសនាទាំងឡាយទាំងពួងដែលជាផ្លូវនាំទៅកាន់មូលហេតុប្រការផ្សេងៗរបស់សាសនាដោយលំដាប់។ ប្រសិនបើនឹងបែងចែកឱ្យឃើញមូលហេតុរបស់សាសនាតាមការវិវត្តនៃគំនិតរបស់មនុស្ស តាំងពីសម័យបុរាណរហូតដល់ពេលបច្ចុប្បន្នគួរនឹងបំបែកជា៦ៗ កំណត់បានដូច្នេះ ៖

ក-កើតពីអវិជ្ជា "ការមិនដឹងហេតុផល"

ខ-កើតពីសេចក្ដីខ្លាច

គ-កើតពីសេចក្ដីស្រឡាញ់ "ភក្ដី"

ឃ-កើតពីបញ្ញា "សេចក្ដីដឹងហេតុផល" (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ២០)

ង-កើតពីឥទ្ធិពល "របស់មនុស្សសំខាន់"

ច-កើតពីលទ្ធិនយោបាយ

មូលហេតុនីមួយៗមានអធិប្បាយដូចតទៅនេះ ៖

កើតពីអវិជ្ជា ៖ អវិជ្ជាការមិនដឹង ក្នុងទីនេះបានដល់ការមិនដឹងហេតុផល ចាប់ផ្ដើមតាំងពីការមិនដឹងហេតុផល ខាងភូមិសាស្ត្រ មិនដឹងហេតុផលខាងតារាសាស្ត្រ។

មិនដឹងជីវសាស្ត្រនិងមិនដឹងធម្មជាតិផ្សេងៗដែលមាននៅជុំវិញខ្លួន។

មនុស្សក្នុងប្រទេសអេហ្ស៊ីបពីសម័យបុរាណ មិនធ្លាប់ធ្វើដំណើរឡើងទៅទ្វីបខាងជើង មិនដឹងទន្លេនីលហូរធ្លាក់ពីទ្វីបអាហ្វ្រិក នាំគ្នាមានគំនិតសន្មតបង្កើតជាទេពនិទាន មានជំនឿថាខ្សែទឹកហូរទន្លេនីល ជាទឹកភ្នែកទេពធីតាអៃស៊ិស យំសោកអាល័យដល់មហាទេព ឱ

សិរិស ព្រះស្វាមីអស់ព្រះជន្មាយុ លុះដល់រដូវទឹកជំនន់ នាំគ្នាធ្វើពិធីបួងសួងសែនព្រេនៗ ជនជាតិក្រិកសម័យបុរាណ មិនដែលឡើងទៅដល់កំពូលភ្នំឱលិមប៉ុស ក៏ជឿជាក់ថាកំពូលភ្នំឱលិមប៉ុស ជាឋានសួគ៌ជាទីកន្លែងស្ថិតនៅនៃទេវតានានា តែងជារឿងនិទានបង្រៀនមនុស្សតៗមក។ ផៅពង្សអារ្យ៉ននៅដងទន្លេសិន្ធុ និងគង្គា ក្នុងប្រទេសឥណ្ឌាគ្មានការបេះដឹង ខាងភូមិសាស្ត្រ ដែលទាក់ទងនឹងភ្នំហិមាល័យ ជាកន្លែងទឹកកក លុះពេលទឹកកករលាយហូរ ធ្លាក់ចុះមកអាងទន្លេសាប តែងរឿងនិទានឱ្យអាងទឹកនោះជាស្រះអនោត្ត ជាទីអាស្រ័យនៅនៃវិទ្យាធរ កាលណាទឹកហូរចុះមកទីទំនាបក៏យល់ថាលើកំពូលភ្នំជាឋានសួគ៌ កន្លែងស្ថិតនៅរបស់ពពួកទេវតា មានមហាទេពមួយអង្គព្រះនាមថា ឥសូរប្រទានទឹក ធ្លាក់មកទន្លេអង្គា ក្លាយទៅជាទឹកសួគ៌ស័ក្តិសិទ្ធិ អាចលាងបាបឱ្យដល់មនុស្សបាន។

ធម្មជាតិដែលកើតមានឡើងមានច្រើនដូចជាភ្លៀង ផ្គរ រន្ទះ ងងឹត ភ្លឺ។ល។ មនុស្សបុរាណមិនធ្លាប់ ដឹងមូលហេតុដែលកើតឡើងរបស់ធម្មជាតិទាំងនេះ ទើបយល់ថាព្រះជាម្ចាស់មានឫទ្ធីស័ក្តិសិទ្ធិ មានអំណាចលើខ្លួន (Supreme being) មានអំណាចគួរបូជា ក្រាបសំពះ និងគួរកោតក្រែង។

ក្នុងផ្លូវជីវសាស្ត្រនោះមនុស្សកើតមកយ៉ាងណា មកអំពីណា អ្នកណាឱ្យមកកើត កើតមកហើយហេតុអ្វីក៏ស្លាប់ មនុស្សបុរាណគ្មានមធ្យោបាយដឹងបាន កាលបើមិនបានដឹង ដោយខ្លួនឯងត្រូវអាស្រ័យអ្នកដទៃ ដោយខ្លួនគិតថាមានចំណេះដឹង សមត្ថភាពលើសជាងខ្លួន។ ក្នុងទីនេះគឺគ្មានអ្វីឱ្យប្រសើរជាងទេវតាឬទេពជាម្ចាស់ ឬវត្ថុស័ក្តិសិទ្ធិដែលស្រេចហើយតែយើងហៅនិងជឿថាជាអ្នកមានអំណាច ជាអ្នកធ្វើឱ្យមនុស្សកើតធ្វើឱ្យមនុស្សស្លាប់ធ្វើឱ្យភ្លៀង ធ្វើខ្យល់ ធ្វើឱ្យងងឹត ធ្វើឱ្យភ្លឺ។ល។ អវិជ្ជាដែលបិទបាំងបញ្ញាមនុស្សយ៉ាងដូច្នេះ ហើយក្លាយជាអណ្តូងឱ្យកើតសទ្ធានិងសាសនាដ៏ធំធេងគ្មានទីបញ្ចប់។

កើតពីសេចក្តីខ្លាច ៖ មូលហេតុសាសនាដែលកើតពីសេចក្តីខ្លាចគឺជាមូលហេតុដ៏សំខាន់ណាស់ ដែលបន្តមកពីអវិជ្ជា ព្រោះចិត្តគំនិតរបស់មនុស្សគិតឡើងដំបូង ក្រៅអំពីគិតអ្វីផ្សេងៗទៀតគឺខ្លាចរបស់ដែលខ្លួនឯងមិនដឹង ខ្លាចអំណាច ខ្លាចសេចក្តីទុក្ខ និងសេចក្តីស្លាប់។ ធម្មជាតិនៅជុំវិញមនុស្ស ដែលមនុស្សបានជួបប្រទះឃើញសម្លស្សមកតាំងពីកំណើតជាអាទិ៍ ងងឹត ភ្លឺ ក្តៅ ត្រជាក់ ខ្យល់ ព្យុះ និងផ្សេងៗទៀតជាអនេកប្បការ។

កាលបើគ្មានការចេះដឹងរឿងរ៉ាវនៃការប្រព្រឹត្តរបស់ធម្មជាតិទាំងនេះ សេចក្ដីសង្ស័យ និងការភ័យខ្លាចរមែងកើតឡើងនិងស្ថិតនៅជាដរាប។

ពិតមែនហើយមនុស្សដែលរស់នៅក្នុងលោកនេះបានត្រូវមាននាទីគឺ ការតស៊ូនឹងធម្មជាតិ តស៊ូនឹងមនុស្ស ពេលណាអាចមានជោគជ័យលើធម្មជាតិឬមនុស្សបានសេចក្ដីភ័យខ្លាចធម្មជាតិ និងខ្លាចក្រែងមនុស្សក៏គ្មានដែរ។

ពេលណាមិនអាចតស៊ូបានគឺមានការខ្លាចក្រែងអំណាចរបស់វត្ថុនោះ ពេលនោះហើយដែលមនុស្សត្រូវនាំគ្នាក្រាបសំពះបូជា សម្ដែងភក្ដីភាព ធ្វើពិធីសែនព្រេនដល់ធម្មជាតិដោយសេចក្ដីសង្ឃឹមឬអង្វរ សូមឱ្យកើតមានសេចក្ដីសម្រេចតាមក្ដីប្រាថ្នា ជាផលតបស្នងវិញបានដល់សេចក្ដីសុខ ផុតទុក្ខភ័យ និងបានរស់នៅក្នុងលោកតាមសេចក្ដីប្រាថ្នា។

មនុស្សបុរាណជាច្រើនពូជសាសន៍ នៅតាមដងទន្លេដៃក្រិសនិងយូប្រេធេសក្នុងមជ្ឈិមបូព៌ាខ្លាចផ្គរឺតណាស់ រហូតដល់សន្មតឱ្យនាមជាទេវតាកាចសាហាវ អាចបំផ្លាញពន្លឺដែលសន្មតជាទេវតាមួយអង្គទៀតទើប នាំគ្នាក្រាបសំពះតាក់តែងគ្រឿងសក្ការៈបូជាដោយសេចក្ដីភ័យខ្លាចផ្គរឺតនេះឯង។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ២៣)

ផ្គរនិងខ្យល់ព្យុះ ជាហេតុមានប្រាកដក្នុងធម្មជាតិ ដែលមនុស្សកោតខ្លាច មានបទសូត្រសរសើរអំពីភ័យនៃផ្គរនិងខ្យល់ព្យុះក្នុងគម្ពីររបស់ផៅពង្សអារ្យកតាំងពីបុរាណ។ ការខ្លាចធម្មជាតិរបស់មនុស្សដូចបានរៀបរាប់មកនេះ ជាអណ្ដូងឱ្យកើតលទ្ធិសាសនាមួយផ្នែកទៀតយ៉ាងទូលំទូលាយ។

ដោយន័យដូចបានអធិប្បាយមូលហេតុសាសនាកើតពីការភ័យខ្លាច បើពិចារណាដល់ផលដែលមនុស្ស សម្ដែងចេញ គឺនាំគ្នាក្រាបសំពះបូជាធម្មជាតិនោះៗអាចសន្និដ្ឋានបានថា មនុស្សធ្វើព្រោះចង់បានផលតបស្នងមកវិញតាមរូបភាពណាមួយ សេចក្ដីនេះឯងជាមូលហេតុឱ្យកើតលទ្ធិសាសនាឡើងបានក្នុងពេលជាមួយគ្នា។

មានពាក្យបង្រៀនថា ក្នុងកាលខាងមុខនឹងមានមនុស្សពិសេសកើតឡើងដើម្បីជួយសង្គ្រោះមនុស្ស មនុស្សគួរប្រព្រឹត្តឱ្យបានល្អត្រឹមត្រូវ និងមានឱកាសកើតមកជួបអ្នកវិសេសវិសាលថ្ងៃថ្នានោះ លោកអ្នកវិសេសស្ដេចនឹងមកជួយសង្គ្រោះ។ល។ គឺកើតមកពីសេចក្ដីសង្ឃឹមជាមូលហេតុទាំងអស់។

មូលហេតុសាសនាដូចបាននិយាយពីខាងដើម ជាសទ្ធាអវិជ្ជាបានគ្របដណ្ដប់មនុស្ស គ្មានបញ្ញាស្វែងរកសច្ចធម៌ ទើបប្រគល់ខ្លួនឱ្យវត្ថុនោះដែលខ្លួនយល់ថាមានអំណាចលើខ្លួនធំជាងខ្លួន។

កើតពីសេចក្ដីស្រឡាញ់និងភក្ដី ក្នុងវចនានុក្រមបានពន្យល់ពាក្យភក្ដីថា "សេចក្ដីរាប់អាន សេចក្ដីស្រឡាញ់ស្មោះ" បើនឹងអធិប្បាយឱ្យងាយយល់ក្នុងផ្លូវសាសនាគឺ ជំនឿនិងសេចក្ដីជ្រះថ្លាដោយដាក់ចិត្តថា របស់ដែលខ្លួនជឿនិងជ្រះថ្លានោះ មានសិរីអាចអំណោយផលដល់ខ្លួនបាន។ ជំនឿនិងសេចក្ដីជ្រះថ្លាដូចអធិប្បាយមកនេះ អាចកើតមានដល់អ្នកណាក្នុងរបស់ណាក៏បាន ហើយក៏អាចកើតឡើងដោយហេតុផលក៏មានឬ ដោយពុំមានហេតុផលដូចជាការជឿខ្មោច ព្រាយបិសាច រុក្ខទេវតា ឬព្រះជាម្ចាស់ ហើយជ្រះថ្លាក្រាបសំពះ បូជារបស់នោះៗ។

ការជឿថាវិញ្ញាណរបស់បុព្វបុរសមិនសាបសូន្យ នៅវិលវល់ជាមួយគ្រួសារដែលជាហេតុនាំឱ្យមានការក្រាបសំពះបូជាបុព្វបុរស Ancestor Whorship កើតមកអំពីភក្ដីដូចមានអធិប្បាយមកនេះ។

សេចក្ដីភ័យខ្លាចដែលពិពណ៌នាមកហើយ និងសេចក្ដីស្រឡាញ់ភក្ដី មានលក្ខណៈខុសគ្នាច្រើន។ សេចក្ដីខ្លាចកើតអំពីសេចក្ដីភ័យរន្ធត់ចិត្ត តែសេចក្ដីស្រឡាញ់ភក្ដី ជំនឿសេចក្ដីជ្រះថ្លា កើតមកពីសេចក្ដីទុកចិត្ត សប្បាយចិត្ត គ្មានភ័យញាប់ញ័រអ្វីឡើយ។

សេចក្ដីស្រឡាញ់ភក្ដីជាសទ្ធាមួយបែប ដែលមនុស្សគ្រប់សម័យរមែងទទួលថាជាកម្លាំងឱ្យកើតសេចក្ដីសម្រេចគ្រប់ពេល។ ពពួកជនជាតិអេហ្ស៊ីបអែយគម្ពីរបុរាណ ពពួកជនជាតិម៉ុងហ្គោលមានចិនជាដើមមានសេចក្ដីស្រឡាញ់ភក្ដីចំពោះដួងវិញ្ញាញបុព្វបុរស Ancestor Whorship សាងកន្លែងបញ្ចុះសពរហូតដល់ក្លាយជា សិល្បកម្មប្រចាំលោក។ "ពួកក្រុមសាសនិកដែលរាប់អានព្រះជាម្ចាស់ សាសនាជ្វីហ្វ សាសនាគ្រិស្ដនិងសាសនាអ៊ិស្លាមជាដើម" ប៉ងប្រាថ្នាយកភក្ដីភាពចំពោះព្រះជាម្ចាស់ ជាគោលបំណងធំក្នុងសាសនា។ ក្នុងក្រុមជនជាតិ អរិយកមានសាសនាព្រាហ្មណ៍ឬហិណ្ឌូ មានពាក្យបង្រៀនដល់ភកតិមគ្គគឺផ្លូវនៃភក្ដីភាព អាចនឹងញ៉ាំងបុគ្គលឱ្យដល់មោក្សៈគឺរួចផុតបាន។ សូម្បីក្នុងសាសនាក៏ទទួលថា សទ្ធាគឺជំនឿសេចក្ដីជ្រះថ្លាប៉ុណ្ណោះ ដែលនឹងឆ្លងឱ្យសង្សារបានក្នុងពុទ្ធសាសនា ផ្នែកមហាយាន ឬ

អាចរិយវាទ សម្តែងគោលគត្តិ កាន់តែច្រើនឡើង ដូចជារឿងទាក់ទងនឹងព្រះអមិតាភៈពុទ្ធជាដើម។(ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ២៥)

កើតអំពីបញ្ញា ៖ សទ្ធាដែលកើតពីបញ្ញា គឺជាមូលហេតុដ៏សំខាន់ណាស់ព្រោះថែកសទ្ធា២ប្រភេទដាច់ពីគ្នា ការនិយាយពីសេចក្តីដឹងហេតុផល ដែលជាមូលហេតុនាំឱ្យកើតសទ្ធាឬសាសនាឡើងមួយសាខាទៀតនោះ គប្បីយល់ថាសទ្ធាដ៏សម្បយុត្តិដោយបញ្ញាស្វែងរកសច្ចៈរបស់ធម៌ ប្រសិនបើនិយាយជាវេយៈកាលកើតឡើងនៃសាសនាអាចនិយាយបានថាជាវេយៈរបស់ហេតុផល គឺវេយៈដែលមនុស្សមានការគិតថារបស់ខ្លួន តាមហេតុផលនិងផលនៃធម៌ ហើយលះបង់ជំនឿគ្មានហេតុផលនិងការភ័យខ្លាចចេញឱ្យបាន។ សទ្ធាដ៏សម្បយុត្តិដោយបញ្ញាគឺសេចក្តីដឹងហេតុដឹងផលជាមូលហេតុឱ្យកើតឡើង នូវសាសនាមួយសាខាទៀត។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ២៦)

ហេតុផលរបស់ព្រះពុទ្ធជាម្ចាស់ គឺផលគ្រប់យ៉ាងដែលបង្កើតឡើងមកអំពីហេតុ គឺការធ្វើខាងផ្លូវកាយ វាចានិងចិត្ត កាលបើអ្នកណាធ្វើល្អរមែងទទួលបានផលល្អ កាលបើធ្វើអាក្រក់ក៏តែងតែទទួលផលអាក្រក់។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ២៧)

ទាំងផលល្អនិងផលអាក្រក់នោះជារបស់មិនទៀង គឺផលល្អជាមួយមនុស្សម្នាក់អាចជាផលអាក្រក់សម្រាប់អ្នកដទៃម្នាក់ទៀត ឬបើទៅកើតនឹងម្នាក់ទៀតអាចជាផលល្អទៅវិញក៏មាន ផលកើតឡើងទោះអាក្រក់ក្តី ល្អក្តី គឺនៅក្នុងចិត្តមនុស្សដដែល។

ការសរសើរឬការតិទៀន បើនិយាយគឺមានតម្លៃស្មើគ្នា តែមនុស្សចូលចិត្តទទួលការសរសើរ មិនចូលចិត្តការដែលគេទិតៀន គឺជាធម្មជាតិរបស់មនុស្សនេះឯង។ ការដែលយើងគិតថាល្អឬអាក្រក់ក៏ស្រេចតែចិត្ត គិតប្រែសេចក្តីទៅថាល្អឬអាក្រក់នោះមិនស្ថិតស្ថេរទេ មានការផ្លាស់ប្តូរជានិច្ច ព្រះពុទ្ធព្រះជាម្ចាស់ទើបបញ្ញត្តិធម៌មួយខទៀតឱ្យឈ្មោះថា លោកធម៌មានគោលការណ៍សំខាន់ថាផលល្អ ឬអាក្រក់ដែលបង្កើតឡើងនោះមិន គួរនឹងថា ជារបស់ពិតនោះទេ ព្រោះគ្រប់យ៉ាងផ្លាស់ប្តូរបានគ្រប់យ៉ាង មានការវិនាសបាត់បង់ ទៅជាធម្មតា និងរកថាជារបស់ខ្លួនពិតប្រាកដនោះគ្មានឡើយ។

បើមនុស្សយើងពេញចិត្តក្នុងគោលការណ៍ពុទ្ធសាសនា ដូចបរិយាយមកនេះអាចល្មមគ្រប់គ្រាន់ដល់សេចក្តីត្រូវការនៃជីវិតនិងអាចធ្វើឱ្យជីវិតជាសុខបាន តែមនុស្សគ្មានសេចក្តីពេញចិត្តត្រឹមប៉ុណ្ណោះទេ គឺត្រូវការផលតបស្នង លើសជាងនេះទៅទៀតកុំឱ្យដាច់

ហើយសេចក្តីគិតក្នុងខនេះឯងជាហេតុនាំឱ្យកើតលទ្ធិសាសនា ដែលនិយាយពីរឿងនរកនិង សួគ៌ ជាពាក្យអធិប្បាយក្នុងសាសនាធំៗជាច្រើនសាសនាដូចគ្នា។

កើតពីលទ្ធិបុគ្គលសំខាន់ៗ ៖ រឿងឥទ្ធិពលរបស់បុគ្គលសំខាន់ដែលធ្វើឱ្យកើតសាសនាជារឿងងាយយល់ ព្រោះជារឿងសម្ព័ន្ធជាមួយការបូជាបុព្វបុរសនៅក្នុងគ្រួសារ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ទំព័រ ២៨)

សាសនាដែលកើតពីសេចក្តីសំខាន់របស់បុគ្គល មានកើតឡើងគ្រប់ទីកន្លែងដែលបុគ្គលសំខាន់នោះរស់នៅដោយគ្មាននរណាប្រៀនប្រដៅឬផ្សព្វផ្សាយឡើយ។ បុគ្គលសំខាន់នោះអាចជាមនុស្សត្រង់ក្នុងប្រវត្តិសាស្ត្រ ដូចជាអ្នកតាឃ្លាំងមឿង ដែលបូជាជីវិតទៅកណ្តូបទ័ពខ្មោចទៅច្បាំងនឹងសៀម ព្រះបាទជ័យវរ្ម័នទី៧ឬបក្សីចាំក្រុងជាដើម។ ក្នុងប្រវត្តិសាស្ត្ររបស់ជនជាតិចិន កួនអ៊ូ ក្លាយជាទេវតានៃសេចក្តីស្មោះត្រង់ បើក្រឡេកទៅមើលប្រវត្តិសាស្ត្រក្រិកនិងរ៉ូម៉ាំងមនុស្សសំខាន់ៗក្លាយជាទេវតាជាច្រើន ក្នុងបច្ចុប្បន្ននេះសេចក្តីសំខាន់របស់ បុគ្គលធ្វើឱ្យក្លាយជាទេវតាមានមិនតិចដែរ។

សេចក្តីសំខាន់របស់បុគ្គលដែលជាបុព្វហេតុរបស់សាសនា គឺជាហេតុកើតឡើងដោយចិត្តបរិសុទ្ធរបស់មនុស្សមិនបាច់មានអ្នកណាមកបង្គាប់បញ្ជា មិនបាច់មានអ្នកណាមកដាក់គោលការណ៍អ្វីឡើយ អ្នកណារាប់អានសេចក្តីសំខាន់របស់អ្នកណានាំ គ្នាក្រាបសំពះគោរពបូជាអ្នកនោះដោយទឹកចិត្តរបស់ខ្លួនឯងទៅចុះ។

កើតពីលទ្ធិនយោបាយ ៖ លទ្ធិនយោបាយ ដែលជាមូលហេតុរបស់សាសនាឬក្លាយជាសាសនាជារឿងសម័យថ្មី បានមកពីសេចក្តីពិតដែលលទ្ធិនយោបាយរីកដុះដាលឡើងលទ្ធិនយោបាយនោះមានឥទ្ធិពលផ្សព្វផ្សាយចូលទៅក្នុងចិត្តមនុស្ស រហូតបោះបង់សាសនារបស់ខ្លួនចេញ ហើយកាន់យកលទ្ធិនយោបាយនោះថា ជាសាសនាប្រចាំសង្គមជាតិ លទ្ធិនយោបាយដែលក្លាយមកជាសាសនាអាចមើលឃើញក្នុងពេលបច្ចុប្បន្នកាលជាអាទិ៍ លទ្ធិណាស៊ីស របស់ជនជាតិអាល្លឺម៉ង់ ក្នុងសម័យហ៊ីត្លែរ គ្រប់គ្រងអាណាចក្រអាល្លឺម៉ង់នេះម្យ៉ាង លទ្ធិហ្វាស៊ីសរបស់ជនជាតិ អ៊ីតាលី ក្នុងសម័យមូស្សូលីនី គ្រប់គ្រងក្រុង រ៉ូមនិងលទ្ធិកុម្មុយនីស្តដែលបានរីកផ្សព្វផ្សាយក្នុងសកលលោកនេះម្យ៉ាងទៀត។

កាលដែលហ៊ីត្លែគ្រប់គ្រងអាល្លឺម៉ង់ និងម៉ូស្សូលីនីគ្រប់គ្រងអ៊ីតាលីសោយអំណាចជាកំពូល លទ្ធិផ្តាច់ការរបស់ប្រទេសនោះៗ ប្រកាសលទ្ធិជាតិនិយមមានឈ្មោះដូចពិពណ៌នា

ខានលើមកហើយ។ គោលការណ៍ប្រតិបត្តិរបស់ប្រជាជនក្នុងលទ្ធិណាស៊ីសនិងលទ្ធិហ្វា-ស៊ីស មានខប្រតិបត្តិជាសីល និងមានខបង្គាប់ជាវិន័យឱ្យយុវជននិងទាហានប្រតិបត្តិជាប្រចាំ មិនចាំបាច់ទៅព្រះវិហារ មិនចាំបាច់ទៅអានអំណាចព្រះជាម្ចាស់ដូចកាលពីមុន។ ជំនួសការទៅឯព្រះវិហារគ្រប់ៗគ្នាត្រូវទៅហាត់ទាហាន ត្រូវចេញទៅច្រៀងបទភ្លេងជាតិ ត្រូវទៅរួមធ្វើសម្បថថា ជាតិរបស់ខ្លួនជាអារ្យធំលើសលប់បំផុតជាងជាតិនានាទាំងអស់។

លទ្ធិកុម្មុយនីស្តធ្ងន់ជាងលទ្ធិផ្សេងៗ ព្រោះកើតមកយូរហើយ អាចនៅផ្សាយទៅលើប្រទេសជាច្រើន អ្នកប្រកាសលទ្ធិនេះ គឺឡេនីន ប្រកាសថាសាសនាជាពិសរបស់ប្រជាជន សាសនាជាគ្រឿងបំផ្លាញសង្គម របស់ដែលសាងសង្គមបានគឺកុម្មុយនីស្ត ប្រទេសដែលគ្រប់គ្រងដោយប្រទេសកុម្មុយនីស្តធំមានពីរប្រទេស គឺ រុស្ស៊ីនិងចិន កាន់យកលទ្ធិកុម្មុយនីស្តជាសាសនា។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ៣០)

ក្នុងប្រទេសជប៉ុន សម័យអ្នកមានបណ្ដាស័ក្តិខ្ពស់ មុនជប៉ុនបើកទ្វារប្រទេសទាក់ទងនឹងលោកខាងលិចលទ្ធិនយោបាយ ឬលទ្ធិជាតិនិយមមួយដែលហៅថា បូជិដោ ផ្សាយចេញទៅទូលំទូលាយណាស់។ លទ្ធិនេះបង្រៀនថា ជប៉ុនគ្រប់ៗរូបត្រូវតែជាទាហានជប៉ុន ត្រូវមានការឈឺចាប់សងសឹកដោយលាក់ទុកក្នុងចិត្តគំនិត។ ជាតិជប៉ុនកើតមកពីទេវតាឬព្រះអាទិត្យ ជាតិជប៉ុនខ្ពស់ជាងជាតិដទៃទៀតក្នុងលោក លទ្ធិនេះត្រូវបានសាបសូន្យក្នុងសម័យមួយមុនកើតសង្គ្រាមលោកទី២ ពួកទាហានក៏ជួយគ្នាបង្កបង្កើតលទ្ធិបូជិដោឱ្យកើតព្រោងព្រាតឡើងទៀតក្នុងពេលនោះ អ្នកដែលសូត្រមន្តក្នុងវត្ត ត្រូវតែនាំរឿងរបស់បូជិដោ ដាក់បញ្ចូលទៅក្នុងបទសូត្រមន្តផងទៀត។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣១)

លទ្ធិសាសនា ដែលកើតមានឡើងតាំងពីបុរាណ មានសភាពនៅគង់វង្សត្រឹមតែវិជ្ជាការ ទោះបីមនុស្សបច្ចុប្បន្នមិនបានរាប់អានក្ដី លទ្ធិសាសនាដែលកើតមានឡើងហើយនៅគង់វង្ស មានអ្នករាប់អានបន្តបន្ទាប់គ្នា មកដល់បច្ចុប្បន្ននេះក្ដី អ្នកប្រាជ្ញខាងផ្នែកសាសនាពិចារណាការប្រព្រឹត្តទៅរបស់មនុស្សតាមប្រវត្តិសាស្ត្រដែលមានមកនោះក្ដី មានកំណត់លំដាប់នៃការរាប់អានឬលំដាប់នៃសទ្ធាដែលមានមកតាមជំនាន់ បែងចែកបានជា៥លំដាប់តាមវិវឌ្ឍនាការនៃគំនិតរបស់មនុស្សគឺ ៖

**១-ការរាប់អានធម្មជាតិ (Animatism)** វត្ថុមានជីវិត ដឹងសុខ ដឹងទុក្ខ និងរបស់ដែលគ្មានជីវិត មិនដឹងសុខទុក្ខ មនុស្សនិងធម្មជាតិអ្នកណាកើតមុន កើតក្រោយ គ្មានបញ្ហាដែល

ត្រូវពិចារណា តែប្រវត្តិសាស្ត្របស់មនុស្សរមែងទទួលស្គាល់ថា កាលបើមានមនុស្សកើតឡើងក្នុងលោកយើងនេះ មានធម្មជាតិកើតឡើងនៅជិតខាងជាមួយមនុស្សផងដែរ មនុស្សបើកភ្នែកកើតមកក្នុងលោក វត្ថុដំបូងដែលមនុស្សបានឃើញ បានប៉ះពាល់មុនរបស់ដទៃ គឺធម្មជាតិនៅជុំវិញខ្លួនមនុស្សនេះឯង។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ៣២)

ភាពងងឹត ភ្លឺ រងា ក្តៅ ដួងអាទិត្យ ដួងច័ន្ទ ដួងតារា ផ្ទៃមេឃ ទន្លេ ស្ទឹងបឹងបួរ គឺ ធម្មជាតិអស់ទាំងនេះ មនុស្សបានឃើញ បានប៉ះពាល់ បានទទួលដឹងពីចលនាផ្លាស់ប្តូររបស់ធម្មជាតិទាំងនោះ។ ការដឹងនេះជួនកាលខ្លះជាក្តីសុខសប្បាយចិត្ត ជួនកាលជាទុក្ខមិនសប្បាយ ជាហេតុនាំឱ្យមនុស្សគិតថា ហេតុដែលធម្មជាតិជាដូច្នោះយ៉ាងនោះបាន ព្រោះមានអំណាចបណ្តាលឱ្យមានសេចក្តីសុខ ទុក្ខឱ្យខ្លួន ទើបនាំគ្នាជឿប្រកាន់យកធម្ម ជាតិនោះៗមានជីវិតហើយនាំគ្នាកោតខ្លាចក្រាបសំពះ។ ដើមហេតុនៃការរាប់អានត្រឹមប៉ុណ្ណោះ បាភាំងហៅថា Animatism គឺការរាប់អានធម្មជាតិរាប់ជាថ្នាក់ដំបូងនៃជំនឿរបស់មនុស្ស។ តពីនេះគំនិតរបស់មនុស្សក៏វិវត្ត មកដល់ថ្នាក់ទី២។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ៣៣)

**២-ការរាប់អានខ្មោចបិសាច ទេវតា (Animatism)**

ការវិវត្តនៃគំនិតរបស់មនុស្សកើតឡើង ព្រមទាំងសេចក្តីចម្រើននៅជុំវិញវត្ថុដទៃៗ មនុស្សមានសេចក្តីសង្ស័យថា ភាពងងឹត ភាពភ្លឺ ក្តៅ ត្រជាក់ ដួងអាទិត្យ ដួងច័ន្ទ ផ្ទៃមេឃ ទន្លេ សូម្បីដើមឈើធំៗ ដែលអាចបណ្តាលឱ្យកើតភាវៈប្រែប្រួលទៅផ្សេងៗបាន ក្នុងខ្លួនធម្មជាតិនោះក្តីនឹងនាំឱ្យមានផលបណ្តាលឱ្យកើតសេចក្តីទុក្ខ សេចក្តីសុខឡើងដល់មនុស្សបានក្តី ធម្មជាតិទាំងអស់នេះគង់មានវត្ថុអ្វីម្យ៉ាងស្ថិតនៅអំណាចដែលអាចបណ្តាលឱ្យប្រព្រឹត្តបាននោះហៅថាវិញ្ញាណ (Spirit)។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ៣៣)

ស្តីវិត ដែលមានអំណាចអាចធ្វើឱ្យកើតទុក្ខឡើង អាចជាមាដ៏អាក្រក់ ឬខ្មោចបិសាចបែបណាមួយដែលជាផ្នែកនាំសេចក្តីសុខមកឱ្យ អាចជាទេវៈប្រភេទណាមួយ ហើយមកដល់ថ្នាក់នេះយើងអាចបែងចែក ជំនឿខ្មោច ព្រាយ បិសាច ទេវតា ឬស្តីវិត ដែលទ្រទ្រង់អំណាចរបស់នៅក្នុងធម្មជាតិនោះៗចេញទៅបានជា ៣ លំដាប់លំដោយនៃការវិវត្តខាងផ្លូវគំនិតមនុស្សគឺ ៖

លំដាប់ទីមួយ ចាប់ផ្តើមពីធម្មជាតិនីមួយៗមុននឹងរីកចេញទៅដល់ធម្មជាតិគ្រប់យ៉ាងក្នុងលោកគឺ ជឿថារបស់គ្រប់យ៉ាងក្នុងលោកជាវត្ថុមានវិញ្ញាណទាំងអស់។

លំដាប់ទីពីរ មានជំនឿថាវិញ្ញាណទាំងអស់ក្នុងលោកមានអំណាចទៅម្នាក់ម្យ៉ាង អាចបណ្ដាលឱ្យសេចក្ដីល្អ សេចក្ដីអាក្រក់ សុខទុក្ខឱ្យដល់មនុស្សបានដោយឡែកៗ តាមអំណាចនៃសេចក្ដីករុណាដែលវិញ្ញាណទាំងនោះត្រូវមានរូបរាង (ប្រភេទកាយទិព្វ) ដែលមិនអាចឱ្យឃើញបានឡ

លំដាប់ទីបី កាលបើមិនអាចមើលឃើញបានក្ដី ឬកាលណាបើមើលឃើញរូបរាងដែលមនុស្សគិតថា មានតែមិនអាចមានប្រាកដឡើងក្ដី មនុស្សទើបចាប់ផ្ដើមកសាងរូបភាពឡើងដោយការនឹកគិតរបស់មនុស្សខ្លួនឯង រូបភាពដែលខ្លួនរាប់អាន ហៅថាព្រះជាម្ចាស់ ឬហៅថាខ្មោចបិសាច ទេវតាអ្វីក៏ដោយ គឺកើតឡើងតាំងពីពេលនោះឡ

ជំនឿនេះ ជាមូលហេតុមួយទៀតរបស់សាសនា ក្នុងសង្គមមនុស្សតាំងពីសម័យបុរាណមក អ្នកប្រាជ្ញហៅជំនឿលទ្ធិសាសនានេះថា Animism កើតពីភាសាឡាតាំង Animus មានអត្ថន័យត្រង់នឹងពាក្យថា Soul ឬ Spirit ក្នុងភាសាអង់គ្លេសឡ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣៤)

**៣. ការបូជាបុព្វបុរស** Ancestor Worship

ការបូជាបុព្វបុរសជាលំដាប់សទ្ធានៃលទ្ធិសាសនា ដ៏ធំធេងមួយក្នុងប្រវត្តិសាស្ត្រពីបុរាណរបស់មនុស្ស យើងអាចដឹងលំដាប់លំដោយនៃសទ្ធានោះបាន ដោយអាស្រ័យផលការងាររបស់អ្នកបុរាណវិទ្យា គឺការជីករុករកវត្ថុបុរាណក្នុងដីឡ

ផលនៃការជីករុករករបស់អ្នកបុរាណវិទ្យា ក្រៅអំពីជីកបានវត្ថុបុរាណផ្សេងៗដែលមានតម្លៃចំពោះប្រវត្តិសាស្ត្រ អ្នកបុរាណវត្ថុវិទ្យា បានជីករុករកជួបប្រទះសាកសពរបស់មនុស្សដែលមានតម្លៃដល់ការសិក្សាលទ្ធិសាសនារបស់មនុស្សក្នុងសម័យបុរាណផងដែរឡ

ហេតុអ្វីទើបនិយាយថាសាកសពដែលអ្នកបុរាណវត្ថុវិទ្យាជីករុករកបាន មានតម្លៃចំពោះការសិក្សាខាងផ្លូវសាសនា ព្រោះថាក្នុងបរិវេណដែលជួបសាកសពនោះ អ្នកបុរាណវិទ្យាបានជួបគ្រឿងបូជាសព ជួបស្នាម ជិតជាម តុបតែងរណ្ដៅកប់សព អ្នកសាសនាបានអាស្រ័យបុរាណវត្ថុស្រាវជ្រាវជួបទាំងអស់នេះ ជាគ្រឿងប្រដាប់ការសិក្សាទើបកំណត់សម្គាល់បានថា មនុស្សពីបុរាណរាប់អានការបូជាបុព្វបុរសរបស់ខ្លួន ហើយការរាប់អាន ការបូជាបុព្វបុរសនោះ ជាមូលហេតុមួយនៃលទ្ធិសាសនាផងដែរឡ

កាលបើមានការគោរពបូជារបស់អ្វីមួយឡើងហើយ ក៏ជាការធម្មតាដែលត្រូវមានពិធីកម្ម និងការតុបតែង ពាក្យពេជន៍ពោលសរសើរបុណ្យគុណអំណាចនោះៗជាពិសេស។ ពាក្យសូត្រអង្វរករក្តី ពិធីកម្មប្រកបដោយការបូជាដែលមានច្រើនបែបច្រើនយ៉ាងក្តី គម្ពីរឫគវេទ ឬសាសនាវេទរបស់ព្រាហ្មណ៍ជា បទសូត្រ និងសម្តែងយញ្ញពិធីផ្សេងៗជាផលបន្តមកពីមូលហេតុ ដែលបានបរិយាយពីខាងដើមស្រាប់។ ( ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣៥-៣៦)

### ៤-ការរាប់អានទេវតាច្រើនអង្គ Poly theism

គំនិតមនុស្សក្នុងវយៈនេះជាប់តមកអំពីគំនិត រឿងកសាងរូបភាពទេវតាតាមមនោគតិរបស់ខ្លួនសម្រេចតែបញ្ហាដែលគិតឃើញថា ធម្មជាតិយ៉ាងណាគួរនឹងមានរូបភាពដូចម្តេច និងស្រេចតែគិតថា ធម្មជាតិបែបណា មានអំណាចខ្ពស់ទាបជាងគ្នាយ៉ាងណាដែរ។ មានពួកខ្លះប្រកាន់ជឿថា ព្រះអាទិត្យជាទេវតាខ្ពស់បំផុត ពួកខ្លះប្រកាន់ជឿថាផ្ទៃមេឃជាទេវតាធំដាច់គេ តែពួកខ្លះទៀតប្រកាន់ថា ព្រះច័ន្ទជាទេវតាខ្ពស់បំផុតជាងទេវតាអង្គឯទៀតៗ ក៏មានការបែងចែកផ្សេងៗគ្នានៃឋានៈរបស់ទេវតា ដែលមានមកក្នុងសម័យនោះជាប្រការមួយ។

ប្រការមួយទៀត កាលណាដែលទេវតាកើតឡើងមានចំនួន និងប្រភេទសន្ធឹកសន្ធាប់ឡើង ព្រោះគំនិតរបស់មនុស្ស ហើយមនុស្សនេះឯងមានគំនិតផ្សេងៗតាមពួកតាមក្រុម ពួកខ្លះគិតថា ទេវតាមួយអង្គគួរមានរូបបែបនេះ តែពួកមួយទៀត បែរត្រឡប់គិតថា គួរនឹងមានរូបបែបនោះៗទៅវិញ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣៦)

ក្នុងប្រទេសអេហ្ស៊ីបបុរាណ មានទេវតានៃទន្លេនីល ទេវតានៃដួងអាទិត្យ ដួងច័ន្ទ ទេវតានៃដួងវិញ្ញាណ មច្ចុរាជ ទេវតានិងនៅមានទេវតាប្រចាំតំបន់ផ្សេងៗ ក្នុងតំបន់នីមួយៗ និងក្នុងក្រុងនីមួយៗ។ ក្នុងប្រទេសក្រិកបុរាណ មានទេវតាក្រុងឧលិមប៉ុលចំនួន១២អង្គ ក្នុងពពួកជនជាតិជ្វីហ្វ និងមនុស្សលើជ្រោយអារ៉ាប់មុនសម័យព្រះយេស៊ូនិងព្រះមហាហ្ម័ត លទ្ធិរាប់អានទេវតាច្រើនអង្គរីកផ្សព្វផ្សាយច្រើនហេតុការណ៍ ដូច្នោះ ព្រោះគំនិតនៃការវិវត្តរបស់មនុស្សដូចបានបរិយាយមកហើយ។

### ៥-ការរាប់អានទេវតាមួយអង្គរបស់ជនមួយក្រុម Heno-Theism

ការគិតរបស់មនុស្សក្នុងវយៈនេះ គឺការគិតរឿងទេវតាច្រើនអង្គ បើប្រសិនជាមានលក្ខណៈនៃការរាប់អានខុសឃ្លាតចេញទៅពីលក្ខណៈដើម ពោលគឺកាលបើមនុស្សចាប់

ផ្ដើមរួមគ្នាជាពួកមានមេកោយគ្រប់គ្រង មនុស្សពួកខ្លះ ក្រុមខ្លះ ក៏បែកនាទីរបស់ទេវតាចេញទៅទៀតឱ្យគ្រប់គ្រងមនុស្សមួយក្រុមៗ ជាទីគោរព ក្រាបសំពះរបស់មនុស្សដោយចំពោះសម្រាប់ក្រុមនីមួយៗ មិនច្រឡូកច្រឡំគ្នា សេចក្ដីសាមគ្គីក្នុងក្រុមរបស់មនុស្សក្នុងក្រុម ត្រូវបែកខ្ញែកដោយកំណត់យកឋានៈរបស់ទេវតាប្រចាំក្រុមនោះ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣៧)

ក្នុងប្រទេសជ្វីហ្វបុរាណមុនមោសេសប្រកាសបញ្ញត្តិ ១០ប្រការ គឺ TEN COMMAND-MENTS ប្រមាណ ២.០០០ ឆ្នាំ មុនព.ស.។ ជនជាតិអ៊ីស្រាអែល រាប់អានព្រះជាម្ចាស់តាមក្រុមនីមួយៗ។ ក្នុងប្រទេសក្រិកសម័យ **សេន្ត ច្បូន** នាំលទ្ធិគ្រិស្ទានចេញទៅផ្សព្វផ្សាយ ក៏បានឃើញការរាប់អានសាសនារបស់ក្រិក គោរពព្រះជាម្ចាស់តាមកុលសម្ព័ន្ធ។ ក្នុងប្រទេសឥណ្ឌា បុរាណ ការរាប់អាន ព្រះជាម្ចាស់ ក៏បែងចែកជាក្រុម ជាពួក តាមឋានៈរបស់មនុស្ស វណ្ណៈមួយត្រូវរាប់អានព្រះជាម្ចាស់មួយអង្គ មិនឱ្យប្រឡូកប្រឡំជាមួយព្រះជាម្ចាស់វណ្ណៈដទៃ ការរាប់អានព្រះជាម្ចាស់បែបនេះហៅថា Hano-Theism ហើយការរាប់អានព្រះជាម្ចាស់បែបនេះឯង គឺមូលហេតុធំឱ្យកើតការប្រកាសពាក្យប្រៀនប្រដៅបែបថ្មីរបស់មេដឹកនាំធំៗ ក្នុងពេលតមកមួយបែបទៀតគឺ Mono Theism ។

### ៦. ការរាប់អានព្រះជាម្ចាស់មួយអង្គ Mono theism

Mono Theism គឺការរាប់អានទេវតាមួយអង្គ ឬដែលហៅថា ឯកទេវនិយមកើតឡើងដោយអ្នកដឹកនាំគ្រប់គ្រងមនុស្សរបស់ខ្លួនធ្វើដំណើរទៅរកស៊ីក្នុងទីផ្សេងៗ។ មេក្រុមត្រូវការរួបរួមមនុស្សរបស់ខ្លួនទុកក្នុងក្រុមឱ្យខ្ជាប់ខ្ជួនមាំមួន ទើបប្រកាសប្រៀនប្រដៅក្រុមរបស់ខ្លួនថា ក្នុងលោកយើងនេះមានព្រះជាម្ចាស់ត្រឹមតែមួយអង្គ ទ្រង់ជាអ្នកកសាងសព្វសារពើ ព្រះអង្គជាមហាទេព ទ្រង់មានអំណាចដ៏ធំធេងអាចបណ្ដាលឱ្យរបស់ណានីមួយៗ និងមនុស្សណានីមួយៗ ទៅតាមបំណងរបស់ព្រះអង្គបាន ព្រះអង្គជាវីរបុរស ទ្រង់មានសេចក្ដីទៀងត្រង់ ទ្រង់មានសេចក្ដីព្រះមេត្តា ទ្រង់ជាអ្នកគ្រប់គ្រងរក្សានូវមនុស្សទូទៅទូទាំងសកល។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៣៨)

ការប្រកាសបញ្ញត្តិទាំង ១០ប្រការ ដោយអាងអំណាច យ:ហ្វូវ៉ា របស់មោសេស (ប្រមាណ២.០០០ ឆ្នាំមុនព.ស.) ក្ដីការប្រកាសគម្ពីរអ័លកុរ:អាន (កោហាន) របស់ព្រះមហាហ្មុត (ប្រមាណ ព.ស.១១១៣) ក្ដី ជាការវិវត្តនៃសេចក្ដីរាប់អានសាសនារបស់មនុស្ស

*នឹងកើតឡើងដោយមានគោលបំណងចង់រួបរួមមនុស្ស ក្នុងការគ្រប់គ្រងរបស់ខ្លួនឱ្យមានចំណុចខ្ពស់បំផុតខាងផ្លូវចិត្តតែមួយចំណុចដូចគ្នា ដើម្បីការរស់នៅជាមួយគ្នា។*

*ការសម្តែងមកនេះ ដើម្បីឱ្យឃើញថាលំដាប់នៃសទ្ធារបស់មនុស្សកើតឡើងមកយ៉ាងណា និងមានការវិវត្តជាលំដាប់យ៉ាងណា។*

***៧-ហេតុផល***

*លំដាប់តទៅនេះ ជាលំដាប់នៃមនុស្សមានការគិតឃើញជារបស់ខ្លួនឯង មិនព្រមចំណុះអំណាចរបស់មើលមិនឃើញនិងមិនអាចពិសោធន៍បាន ជាលំដាប់គំនិតប្រកបដោយហេតុផល នាំការមិនដឹង មិនយល់អាចគេចចេញបាន ការដឹងហេតុផលដូច្នេះ គឺជាលំដាប់ខ្ពស់នៃបញ្ញារបស់មនុស្សជាមូលហេតុនាំឱ្យកើតលទ្ធិសាសនា ដែលសំខាន់លើសជាងនេះទៅទៀត សាសនាមួយក្នុងលោកគឺ ពុទ្ធសាសនា ដូចបាននិយាយមកហើយ ដូចខាងដើម។*

***ហេតុផល គឺអ្វី ?***

*ហេតុគឺសមុដ្ឋានដែលកើតផល របស់ដែលកើតពីសមុដ្ឋាននេះ សមុដ្ឋានដែលទាក់ទងគ្នានេះគឺជាសាស្ត្រាមួយ យើងរួបរួមឱ្យឈ្មោះថា វិទ្យាសាស្ត្រ រាប់ថាសាស្ត្ររបស់ហេតុនិងផល។ (ហេង គីមហោ **សាសនាប្រៀបធៀប** ភាគ១ ទំព័រ ៣៩)*

*សម័យបុរាណមនុស្សជឿថាពិភពលោកសំប៉ែត មានជ្រុង មានជំនឿថា បើធ្វើដំណើរតាមកប៉ាល់ទៅតាមសមុទ្រ ថ្ងៃណាមួយកប៉ាល់នឹងអណ្តែតទៅ ហើយធ្លាក់អំពីព្រំដែនលោក ឧទាហរណ៍ យើងក្រឡេកមើលកប៉ាល់មកពីចម្ងាយ ដំបូងយើងឃើញសសរក្តោងលឹមៗនៅជាប់នឹងជើងមេឃ លុះកប៉ាល់បើកមកកាន់តែជិត ក្រឡេកឃើញរូបរាងពេញលេញ ហើយកាលបើពិនិត្យមើលសេចក្តីពិតពីរឿងគោចររបស់ព្រះអាទិត្យ នឹងពិសោធន៍ឃើញថា ផែនដីវិលជុំវិញខ្លួនឯង ទើបរួបរួមជំនឿថាផែនដីមូល។*

*សម័យបុរាណពេលខ្យល់ព្យុះបក់បោក មនុស្សមានជំនឿថា ព្រះជាម្ចាស់ទ្រង់មានអំណាចបណ្តាលឱ្យកើតឡើង តែមនុស្សដែលមានសេចក្តីចម្រើនអាចពិសោធបានតាមរយៈវិទ្យាសាស្ត្រគឺហេតុផល បានថា ខ្យល់ព្យុះកើតឡើងដោយផ្នែកផ្សេងនៃផែនដីផ្នែកនីមួយៗ មានកម្តៅមិនស្មើគ្នា ធ្វើឱ្យកើតឡើងមានការគៀបសង្កត់នៃធាតុអាកាសផ្សេងៗគ្នា។ ភ្លៀង រន្ទះ ផ្គរ ពុំមែនជាអំណាចរបស់នាងមេខលា ឬរបស់រាមាសូរនោះទេ ងងឹត ភ្លឺ ត្រជាក់*

ក្តៅ ទាំងអស់នេះក្តីជាហេតុផលរបស់ធម្មជាតិ មិនមែនជាអំណាចរបស់ព្រះជាម្ចាស់ណាមួយបណ្តាលឱ្យកើតឡើងនោះក៏ទេដែរ។

ចំណែករឿងដែលទាក់ទងនឹងជីវិតនេះក៏ដោយ អ្នកចេះដឹងបានស្រាវជ្រាវជួបហេតុផលហើយ ការបែកផ្សេងៗគ្នានៃជីវិត តាមការពិសោធបានកើតឡើងពីហេតុនិងផលនេះឯង ការបែកផ្សេងៗនៃជីវិតនោះ មិនមែនប្រព្រឹត្តទៅព្រោះព្រះអង្គម្ចាស់ណាមួយមកបញ្ជាឱ្យប្រព្រឹត្តនោះឡើយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៤០)

ព្រះពុទ្ធជាម្ចាស់ ជាអ្នកស្រាវជ្រាវជួបហេតុផលនិងការបែកផ្សេងគ្នារបស់ជីវិតមានប្រាកដសេចក្តីក្នុង ចូឡកម្មវិភង្គសូត្រ ដូច្នេះ ៖

ផល ៖ មនុស្សមានអាយុខ្លី ហេតុព្រោះជាអ្នកសម្លាប់អ្នកដទៃ មិនមែនជាហេតុបណ្តាលមកពីព្រះជាម្ចាស់ឱ្យកើតមានឡើងទេ។

ផល ៖ មនុស្សមានរូបអាក្រក់ មុខមាត់មិនស្អាតបាត ហេតុព្រោះជាមនុស្សខឹងច្រើន មិនមែនព្រះជាម្ចាស់បណ្តាលឱ្យកើតមានឡើងទេ។

ផល ៖ មនុស្សក្រីក្រ ហេតុព្រោះជាមនុស្សកំណាញ់ស្វិត មិនមែនព្រះជាម្ចាស់បណ្តាលនោះទេ។

ផល៖ ធ្វើមិនសម្រេច ហេតុព្រោះខ្ជិលច្រអូស មិនមែនព្រះជាម្ចាស់បណ្តាលនោះទេ។

ផល ៖ កើត ចាស់ ឈឺ ស្លាប់ ជាសេចក្តីទុក្ខ ហេតុព្រោះមានការផ្លាស់ប្តូរ មានការតស៊ូ ប្រព្រឹត្តទៅ តាមសេចក្តីត្រូវការមិនបានឡើយ។ ល។

វិទ្យាសាស្ត្រសម័យបច្ចុប្បន្ន អាចពិសោធទទួលដឹងហេតុផលដូចបានអធិប្បាយមកហើយសាសនាណាក្តី សទ្ធាណាក្តី ជាញាណសម្បយុត្ត កើតពីសេចក្តីដឹងហេតុ ដឹងផលតាមសេចក្តីពិតនៃធម៌ សាសនានោះ សទ្ធានោះ រមែងតាំងនៅបានយូរអង្វែង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៤១)

# ជំពូកទី ៣
# ទស្សនៈស្តីអំពីសាសនាសកល

ដើម្បីតម្រៀបមូលហេតុនៃលទ្ធិនិងសាសនា យើងត្រូវធ្វើការសង្កេតរូបភាពដែលដូចគ្នា នៃចិត្តវិទ្យានិងទស្សនវិជ្ជា នៃលទ្ធិនិងសាសនាទាំងអស់ក្នុងលោករួមទាំងសាសនាបុរាណដូចជាសត្តតិវង្សនិយម ( Totemisn ) មន្ត្រនិយម ( iwagic )ជាដើម ដែលមានការរីកចម្រើនខាងចិត្តវិទ្យា ទស្សនវិជ្ជា ប្រវត្តិសាស្ត្រ និងកត្តាទាំងឡាយដទៃទៀតតាមលំដាប់ៗ ជាពិសេសយើងត្រូវធ្វើការសង្កេតការទាក់ទងគ្នាដ៏ជិតស្និទ្ធរវាងទេវនិយម(Theristic Religion ) និងសត្តតិវង្សនិយម និងអទេវនិយម ( Non-theistic Religion )ជាដើមៗ សត្តិតិវង្សនិយមកើតមុនសាសនាទាំងអស់ក្នុងលោកៗ កាលណាមនុស្សលោករស់នៅជាក្រុម ជាពួកហើយសត្តតិវង្សនិយមក៏មានកំណើតឡើងនៅ ពេលនោះដែរ ព្រោះសត្តតិវង្សនិយមនេះ គេទុកជានិមិត្តរូបនៃសង្គម ក្រុមឬពួកនីមួយៗគេសង្កេតឃើញថា សត្តតិវង្សនិយមមាននិមិត្តរូបជាសញ្ញាផ្សេងៗពីសង្គមមួយទៅសង្គមមួយទៀតក្នុងលោក ៗ សង្គមខ្លះមានរូបសត្វ ដូចជាសិង្ហ ខ្លា ដំរី ក្អែក ត្មាតជាសញ្ញា សង្គមខ្លះមានដើមឈើ បន្លែ ស្រូវជាដើមជាសញ្ញា ហើយជាវត្ថុស័ក្តិសិទ្ធិទៀតៗ គេសង្កេតឃើញម្យ៉ាងទៀតថា សត្តតិវង្សនិយមនេះបង្កើតការបូជាផ្សេងៗគ្នាជាច្រើន ដូចជាបុព្វបុរសបូជាធម្មបូជា ភូតបូជា ( Animistic cults ) បិសាចបូជា អារក្ខជួបជាក្រុមញាតិ អ្នកភូមិ អ្នកស្រុកត្រង់កន្លែងដ៏គួរណាមួយៗ នៅពេលធ្វើនោះ គេមានធ្វើពិធីបញ្ចូលរូប បន់ស្រន់ឱ្យបានសុខចម្រើនជាដើមៗ គួរកត់សម្គាល់ថា ក្នុងនិមិត្តរូបនៃសត្តតិវង្សនិយមគេជឿថាមានខ្មោច ឬទេវសភាវៈស្ថិតនៅថែរក្សា ហើយជាអ្នកផ្តល់សេចក្តីសុខចម្រើន និងទុក្ខដល់កូនចៅ ក្រុមញាតិ ភូមិ ស្រុកជាដើមៗ ជំនឿនេះបានរីកចម្រើនទៅជាមន្ត្រនិយម ទេវនិយម អាទិទេវនិយម ព្រហ្មនិយម ធម្មជាតិនិយម អទេវនិយម អធម្មជាតិនិយមជាដើមៗ ខាងក្រោមមកការចម្រើននេះគេបានចម្រាញ់យកតែត្រង់ណាដែលមានហេតុផល ហើយគំនិតប្រកបដោយហេតុផលនេះបានចម្រើនរហូតដល់វិទ្យាសាស្ត្រ និងមនោគមវិជ្ជា ដូចយើងបានឃើញនឹងភ្នែកសព្វថ្ងៃនេះស្រាប់ៗ

ឯសាសនាពិធី ក៏មានលំនាំផ្សេងៗគ្នាតាមលំដាប់នៃការរីកចម្រើនក្នុងលទ្ធិនិងសាសនាទាំងនោះ ៗ ម្យ៉ាងទៀត សាសនាពិធីនោះបានត្រូវគេបដិសេធចោលទៀតតាំងពីពេលដែល

មនោគមវិជ្ជា និងវិទ្យាសាស្ត្របានរីកចម្រើនឡើងក្នុងលោក។ មូលហេតុនៃមូលហេតុទាំងឡាយនៃលទ្ធិនិងសាសនាទាំងអស់ក្នុងលោកសម្រាប់វិភាគដូចតទៅនេះ ៖

***ក-វត្ថុស័ក្តិសិទ្ធិ*** ៖ តាមចិត្តវិទ្យានិងទស្សនវិជ្ជា យើងសង្កេតឃើញថា វត្ថុស័ក្តិសិទ្ធិជាអសម្ភារៈក្តី ជាសម្ភារៈដែលមើលឃើញក្តី គឺមានសន្តានទៅនិងបណីតវត្ថុដែលគេទុកជាទីរព្វកនិងជាទីគោរព ដែលអាចធ្វើឱ្យបុគ្គលិកភាពនៃបុគ្គលម្នាក់ៗប្រសើរឡើងក្នុងចំណោមប្រជារាស្ត្រក្នុងក្រុមពួកជាមួយគ្នា ថែមទាំងជាវត្ថុសម្រាប់បង្កើតគំនិតនៃបុគ្គលម្នាក់ៗទៀតក្នុងមធ្យោបាយគ្រប់គ្រង។ វត្ថុស័ក្តិសិទ្ធិជាសភាពណាក៏ដោយ តែងមានកំណើតពីសន្តតិវង្សនិយម ហើយច្រើនតែនៅក្នុងកណ្តាប់ដៃមេដឹកនាំនៃក្រុម, ពួក, គ្រួសារ, សង្គម, ស្តេច និងបុរោហិត (Priest) ជាដើម។ ពួកនេះឬព្រមទាំងព្រះរាជា ច្រើនយកអំណាចវត្ថុស័ក្តិសិទ្ធិជាគ្រឿងអាងក្នុងកិច្ចការរបស់ពួកឬសង្គម។ គេច្រើនរក្សាវត្ថុស័ក្តិសិទ្ធិនិងបុគ្គលអ្នករក្សានោះៗទុកក្នុងកន្លែងដ៏ស្ងាត់ និងស្អាតសម្រាប់ជាទីសក្ការបូជា ព្រោះគេខ្លាចមានទោសកំហុសឬបាប (Tabu)។ នៅក្រោមអំណាចវត្ថុ ស័ក្តិសិទ្ធិមានត្រណមជាច្រើនសម្រាប់អ្នកកាន់ ដើម្បីការពារខ្លួននិងដើម្បីសេចក្តីសុខចម្រើននៃមនុស្សម្នាក់ៗ និងក្រុមឬពួក។ ការភ័យខ្លាច សេចក្តីត្រូវការ ជាហេតុឱ្យមនុស្សគ្រប់រូបស្វែងរកទីពឹង។ វត្ថុសម្រាប់ទីពឹង គឺ វត្ថុស័ក្តិសិទ្ធិដែលមានរូបជាសញ្ញាភាពជាសត្វ ជាដើមឈើជាដើម ដែលមានកំណើតពីគំនិតនៃសន្តតិវង្សនិយម។ ក្នុងន័យនេះ យើងសង្កេតឃើញពុទ្ធវចនៈក្នុងគាថាទី ១០ នៃពុទ្ធវគ្គ គម្ពីរខុទ្ទកនិកាយថា ៖

**ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា។**

មនុស្សទាំងឡាយភាគច្រើនកាលបើមានភ័យគ្របសង្កត់ហើយ តែងរត់ទៅរកភ្នំខ្លះ ព្រៃខ្លះ សួនច្បារខ្លះ ឈើខ្លះ និងចេតិយខ្លះជាទីពឹង ទីពំនាក់។ វត្ថុទាំងអស់នេះសុទ្ធតែរាប់បញ្ចូលក្នុងវត្ថុស័ក្តិសិទ្ធិនៃសន្តតិវង្សនិយម។ គំនិតក្នុងលទ្ធិឬនិយមនោះ បានរីកចម្រើនរហូតដល់ទទួលស្គាល់ថា មានកិច្ចសន្យារវាងមនុស្សលោកនិងព្រះអាទិទេព ឬមនុស្សលោកនិងអំណាចដ៏ខ្ពស់បំផុតនៃចក្រវាល។ សេចក្តីសុខនិងសេចក្តីទុក្ខ ការវិនាស និងការចម្រើន ព្រមទាំងកំណើតមនុស្សលោកត្រូវស្ថិតនៅក្នុងកណ្តាប់ដៃនៃព្រះម្ចាស់ចក្រវាឡជាដរាប។ បើចង់បានសេចក្តីសុខចម្រើន មនុស្សលោកត្រូវកាន់ត្រណមខ្លួនឯង ធ្វើពិធីបូជា ធ្វើប្រតិបត្តិខ្លួនឯង។ ទាំងអស់នេះបានបញ្ជាក់ដល់ការកើតឡើងនៃសេចក្តីចម្រើនខាងគំនិត ដែលមានក្នុង

*ចំណេះដ៏ប្រសើរបន្តិច ហើយទទួលខុសត្រូវលើអំពើដែលខ្លួនប្រព្រឹត្ត។ បើអ្នកណាបាន បំពេញអំពើទាំងអស់នេះឈ្មោះថា បានស្គាល់និងគោរពព្រះជាម្ចាស់លោកហើយ។ ទាំងអស់ នេះ ច្រើនតែមានក្នុងគំនិតលទ្ធិដែលមានទីដៅទៅលើព្រះអាទិទេពដូចជា លទ្ធិគ្រិស្ត, អ៊ិស្លាម ជាដើម។ ឯព្រះពុទ្ធសាសនា ពុំមានគោលគំនិតនេះឡើយ[២]។*

***១-ការបូជានិងការសូត្រធម៌បួងសួង*** *៖ ១-ចំពោះអាទិទេវលទ្ធិទាំងឡាយ ការបូជាគេ ទុកជាពិធីមួយដ៏ ប្រសើរបំផុតសម្រាប់យកជ័យជម្នះក្នុងការអង្វរករ ព្រះម្ចាស់លោក ឱ្យ ប្រោសប្រណីផ្តល់សេចក្តីសុខចម្រើនដល់កូនចៅ ព្រមទាំងការពារសេចក្តីវិនាសអន្តរាយ ថែមទៀត។ មិនតែប៉ុណ្ណោះ ការបូជាគេទុកជាការថ្វាយ អំណរគុណដល់ព្រះម្ចាស់សួគ៌ តែ ពិធីនេះគេច្រើនធ្វើនៅពេលជំណាច់ឆ្នាំមួយៗ ឬពេលណាមួយដែលគេបាន កម្រិតទុក។ ពិធី បូជានោះមាន ២យ៉ាងគឺ ការសម្លាប់សត្វបូជាឬមនុស្សបូជា និងការបូជាខ្លួនឯងដោយកាន់ ត្រណមឬធ្វើតបៈផ្សេងៗឬចូលបួស។ នៅពេលសម្លាប់សត្វបូជា គេត្រូវជួបជុំគ្នាធ្វើពិធី និង ទទួលកត្តរួមគ្នា ដែលហៅថា ស្នូរណាថិភោជ* (Communion food) *។*

*ឧទាហរណ៍ ៖ ចំពោះលទ្ធិហិណ្ឌូ យើងឃើញថាការបូជា គឺគេធ្វើឡើងឧទ្ទិសដល់ទេព្តា ជាច្រើន ដែលជានិមិត្តរូបនិងជាតំណាងនៃធម្មជាតិ ដែលមានប្រយោជន៍ដល់មនុស្សលោក ដូចជាសរស្វតិទេពធីតាជាម្ចាស់នៃការសិក្សា ព្រះឥន្ទ្រជាតំណាងនៃទឹកភ្លៀង ទុរគៈជា តំណាងនៃរាត្រីជាដើម។ ឯវត្ថុសម្រាប់បូជាវិញ មានទឹក ដោះគោ ស្រូវ អង្ករ ពោត សណ្តែក ជាដើម សម្រាប់បូជាដល់ទេព្តា ចំណែកទឹកដោះគោ គេទុកជាវត្ថុប្រសើរបំផុតជាងវត្ថុដទៃ ទៀត។*

*ឯលទ្ធិអ៊ិស្លាម យើងឃើញថាការបូជា គេក៏ចាត់ទុកជាពិធីមួយវិសេសវិសាលណាស់ ដែរ។ គម្ពីរកូរអាន ពុំបានបញ្ជាក់ថាឱ្យសម្លាប់សត្វឬមនុស្សបូជាឡើយ ប៉ុន្តែគម្ពីរនេះបាន បញ្ជាក់ពីអំណាចនិងគុណសម្បត្តិនៃព្រះអាឡាហ៍ ព្រមទាំងព្រះមេត្តាធម៌របស់ព្រះអង្គយ៉ាង ជាក់ច្បាស់ ដែលជាហេតុនាំឱ្យសិស្សសាវ័កមានសង្ឃឹមទៅលើព្រះអង្គទាំងស្រុង។ ដូច្នេះ ការសម្លាប់សត្វផ្សេងៗ មានគោ ពពែ ចៀម ជាដើម ត្រូវតែឧទ្ទិសដល់ព្រះអង្គ ហើយការ ឧទ្ទិស គេចាត់ទុកជាការបូជាដ៏ប្រសើរបំផុត។ ម្យ៉ាងទៀត ការសម្លាប់មនុស្សក្នុងសង្គ្រាម សាសនា* (Holy war) *ក្នុងនាមរបស់ព្រះអាឡាហ៍ ក៏ពុំមានទោសដល់អ្នកសម្លាប់ដែរ។*

---

[២] *ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ១៣*

ចំពោះលទ្ធិគ្រិស្ត ព្រះយេស៊ូខ្លួនឯង ត្រូវគេព្យួកសម្លាប់ គឺគេយល់ថា ជាការបូជាដ៏ប្រសើរជាទីបំផុត ចំពោះព្រះគ្រិស្ត។ ការបរបាញ់សត្វនៅថ្ងៃអាទិត្យ ក៏គេចាត់ទុកជាការបូជាដល់ព្រះគ្រិស្តដែរ។

ឯលទ្ធិសាកលនិយមចិន យើងឃើញថាមានការបូជាដល់ព្រះជាធំក្នុងឋានសួគ៌ ដែលជាលទ្ធភាពនៃទ្រឹស្តីតៅ។ គេគោរពទេវតាជាច្រើន ដូចជាលទ្ធិហិណ្ឌូដែរ។

ចំពោះព្រះពុទ្ធសាសនាវិញ យើងពុំឃើញការបូជាមានលក្ខណៈដូចក្នុងលទ្ធិទាំងអស់នោះឡើយ។ យើងបានឃើញតែអាមិសបូជា បានដល់សម្ភារៈវត្ថុផ្សេងៗ ឬ បច្ច័យ៤ និងប្រតិបត្តិបូជា ប៉ុន្តែព្រះពុទ្ធទ្រង់សរសើរ បដិបត្តិបូជា ថាជាការបូជាដ៏វិសេសបំផុត។

ឯការកាន់ត្រណម គេទុកជាការបូជាប្រសើរណាស់ទៅទៀត ព្រោះគេទុកជាអ្នកចូលបម្រើមុខក្រសួងព្រះម្ចាស់សួគ៌ផ្ទាល់។ ការបួស ឬការកាន់ត្រណម ត្រូវមានកំណត់ពេល ឬអស់មួយជីវិតតាមទម្លាប់របស់សង្គមនីមួយៗ។ ចិត្តត្រូវទទួលលទ្ធផលពីការកាន់ត្រណម ឬការបួស ឬការធ្វើតបៈធម៌នោះៗ។ ការបួសមានគ្រប់លទ្ធិនិងសាសនាទាំង ៥ ប៉ុន្តែមានលក្ខណៈផ្សេងៗគ្នាតាមមូលដ្ឋាននៃទ្រឹស្តី។

២-ការសូត្រធម៌បួងសួង មានវត្ថុបំណងជាបឋមគឺការសម្អាតខ្លួនឯង ដើម្បីចូលទៅគាល់ផ្ទាល់ព្រះម្ចាស់លោកឬអំណាចដ៏ខ្ពង់ខ្ពស់បំផុត។ ជាទុតិយនេះ ការសូត្រធម៌គេទុកជាសភាវៈសម្រាប់បញ្ជាក់សេចក្តីស្វាមីភក្តិនៃ បុគ្គលម្នាក់ៗចំពោះព្រះម្ចាស់លោក ហើយជាពិសេស គេសូមព្រះម្ចាស់លោកឱ្យទុកគេជាកូនចៅផ្ទាល់ ឬជាខ្ញុំបម្រើផ្ទាល់។ មួយផ្នែកទៀតគេត្រូវពិនិត្យរឿងនេះតាមលក្ខណៈចិត្តវិទ្យានៃមនុស្សជាតិដោយចោទជាចំណោទ ៖

១-តើសេចក្តីប្រាថ្នានិងបន់ស្រន់ ឬ បួងសួងចំពោះព្រះម្ចាស់លោកថាជាតួ ឬជាមជ្ឈមណ្ឌលនៃវិញ្ញាណ ឬព្រលឹងពិតប្រាកដ ឬមិនពិតប្រាកដ ?

២-តាមបរមត្ថ តើសេចក្តីប្រាថ្នានិងការបន់ស្រន់ឬបួងសួង មានផលជួយស្រោចស្រង់មនុស្សឱ្យមានសេចក្តីក្លាហាន និងការជឿទុកចិត្តខ្លួនឯងឬទេ ?

៣-តើព្រះម្ចាស់លោកទទួលអើពើចំពោះការបន់ស្រន់ ឬការបួងសួងនោះដែរឬទេ ?

ន័យមួយទៀត យើងគួរពិនិត្យថែមទៀតចំពោះរឿងនេះដែលមានលក្ខណៈផ្សេងៗគ្នា ប៉ុន្តែសេចក្តីពិត ការបួងសួងដែលមានលក្ខណៈផ្សេងៗគ្នានេះ មានកំណើតពីការសូត្រធម៌បួងសួងតែម្យ៉ាង។ លក្ខណៈផ្សេងគ្នា នៃការសូត្រធម៌បួងសួង យើងអាចសង្កេតបានដោយ

អំណាចនៃវិការ ឬចរិយាដែលប្រកបដោយសេចក្ដីត្រូវការ (Needs) ដើម្បីបម្រើតណ្ហារបស់ខ្លួនៗ ដោយអំណាចនេះ ការសូត្រធម៌បួងសួង ក៏ក្លាយទៅជាមន្តអាគមស្នេហ៍ជាដើមដ៏ពិតប្រាកដ។ នេះជាការល្បីល្បាញព្រមទាំងគេទទួលស្គាល់ពេញលក្ខណៈតាមប្រវត្តិ និងសេចក្ដីរីកចម្រើននៃលទ្ធិនិងសាសនា។ មិនតែប៉ុណ្ណោះ ការនេះគេអាចសន្និដ្ឋានថា ការសូត្រធម៌បួងសួងនេះ គឺគ្រាន់តែជា "សកកថា" មួយ ដែលផ្សេងពីហេតុការណ៍នៃចិត្តវិទ្យាក្នុងការសូត្រធម៌បួងសួងដ៏ត្រឹមត្រូវទៅវិញ។ ការសូត្រធម៌បួងសួងដែលប្រកបដោយចិត្តវិទ្យាដ៏ត្រឹមត្រូវ គឺជាគោលការណ៍ដ៏សំខាន់បំផុត ហើយរឹតតែប្រត្យក្សណាស់ទៅទៀត គឺនៅក្នុងសម័យសង្គមជាន់ដើម ដែលប្រតិបត្តិការសូត្រធម៌បួងសួងតាមបែប ឬលំនាំជាមន្តអាគម។ ចំពោះមហាសាសនាទាំង ៥ យើងសង្កេតឃើញដូចតទៅនេះ ៖

-លទ្ធិព្រាហ្មណ៍ ឬហិណ្ឌូ ៖ តាមគម្ពីរវេទ ការសូត្រធម៌ជារបៀបស្លោកនិងស្តុតីសរសើររៀបរាប់ពីអំណាចព្រមទាំងគុណសម្បត្តិនៃទេព្ដាមួយៗ។ ប៉ុន្តែការសូត្រធម៌បួងសួងច្រើនតែធ្វើជាមួយនឹងការបូជាផ្សេងៗ។ តើគេគោរពធម្មជាតិប្រសើរជាងគេចេះច្នៃធម្មជាតិទៅប្រើប្រាស់ឬ ?

-លទ្ធិគ្រិស្ដ ៖ និកាយកាតូលិក មានលំនាំការសូត្រធម៌បួងសួងដូចជាលទ្ធិព្រាហ្មណ៍ដែរ។ ម្យ៉ាងទៀត ខ្សែគំនិតក៏មានលក្ខណៈប្រហែលគ្នាសុទ្ធសាធ។ ឯនិកាយប្រូតេស្តង់ មានការសូត្រធម៌និងខ្សែគំនិតផ្សេងពីនិកាយកាតូលិក ត្រង់លក្ខណៈមិនប្រគល់ខ្លួនទាំងស្រុងតាមបែបភក្តីភាពដូចនិកាយកាតូលិកឡើយ ដូច្នេះ យើងឃើញថាខ្សែគំនិតនៃនិកាយប្រូតេស្តង់ មានឥទ្ធិពលទៅលើរបបមូលធននិយម គឺអ្នកណាក្រអ្នកនោះត្រូវទណ្ឌកម្មនៃព្រះជាម្ចាស់។

-លទ្ធិអ៊ិស្លាម ៖ លទ្ធិនេះជារបបកែទម្រង់នៃលទ្ធិហ៊ីប្រ៊ូយ៍និងលទ្ធិគ្រិស្ត។ លទ្ធិនេះជារបបជាតិនិយមនៃអារ៉ាប់ទាំងស្រុង។ គម្ពីរកូរអាន បានបញ្ជាក់យ៉ាងច្បាស់លាស់ពីគុណធម៌ព្រះអាឡាហ៍តែម្យ៉ាង។ នៅក្នុងគម្ពីរនេះ មាន (Surah) ជាច្រើនបញ្ជាក់ពីរបៀបថ្វាយបង្គំព្រមទាំងពិធីសូត្រធម៌បួងសួងចំពោះតែព្រះអាឡាហ៍មួយព្រះអង្គប៉ុណ្ណោះ។

-លទ្ធិសាកលនិយមចិន ៖ ក្បួនលទ្ធិតៅ បានបញ្ជាក់ពីអំណាចព្រះម្ចាស់សួគ៌ គឺយិននិងយ៉ាង (Yin and Yang) ដូច្នេះ គេមានពិធីសូត្រធម៌បួងសួងដែរ។ ឯក្បួនខុងជឺ ជាក្បួនមានលំនាំជារបៀបកែទម្រង់នៃលទ្ធិតៅទៅវិញ។ លទ្ធិខាងក្រោមនេះបានបញ្ជាក់ទៅលើការ

ប្រព្រឹត្តសីលធម៌ និងអំណាចការសិក្សានៃមនុស្សជាតិ, ដូច្នេះក្បួនខាងក្រោយនេះមាន ឥទ្ធិពលទៅលើផ្លូវចិត្តនៃសិស្សសាវ័កឱ្យបែរមកគោរពគុណធម៌នៃមេដឹកនាំទៅវិញ។

-ពុទ្ធសាសនានិយម ៖ គម្ពីរព្រះត្រៃបិដក ពុំមានបញ្ជាក់អ្វីតិចតួចពីអំណាចនៃអាទិទេពណាមួយឡើយ ប៉ុន្តែបានបញ្ជាក់ពីគុណធម៌នៃព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃយ៉ាងជាក់ច្បាស់, ដូច្នេះ ពិធីនមស្ការ គឺគ្រាន់តែរំឭកដល់គុណធម៌ទាំងអស់នោះ ដើម្បីជាគ្រឿងរំឭកដល់ខ្លួនអ្នកប្រតិបត្តិប៉ុណ្ណោះ ជាជំនួយស្មារតីនៃអ្នកប្រតិ បត្តិ។

**គ-ព្រលឹងនិងចិត្ត ៖** ១-យើងបានសង្កេតដោយហ្មត់ចត់ចំពោះសាសនាទាំងអស់ដែលមានប្រព័ន្ធខាង ព្រលឹងនិងចិត្ត បានឱ្យពន្ទឺគោលការណ៍និងគោលគំនិតដ៏សំខាន់ ២ យ៉ាងគឺ ៖

ក-មានឧត្តមគតិជាច្រើនថា មានទីភ្នាក់ងារឱ្យដំណឹង (Agency) ការណ៍ឬហេតុ (Causation) កិច្ចការ (Activity) ឬមុខងារ (Function) ក្នុងចក្រវាល (Universe) ដែលមនុស្សលោកអាចចូលទៅធ្វើសម្ព័ន្ធភាពជាមួយនឹងផលព្រឹត្តិ (Effective) និងដំណើរការ (Processes) ហើយអាចប្រើប្រាស់វត្ថុនោះៗបាន[៣]។

ខ-មនុស្សមិនមែនមានតែឥន្ទ្រិយវត្ថុប៉ុណ្ណោះទេ មានភាគវត្ថុផ្សេងទៀតដែលអាចលះបង់ចោលដោយ អត្តភាពពេលខ្លះបាន (ដូចជាការយល់សប្តិ, ការភ្លឹកពុំដឹងខ្លួន, ការឈឺភ្លឹក, ការភ្លឹកពុំដឹងខ្លួន, ការណ៍ភ្លឹក, ការសន្លប់បាត់ស្មារតីជាដើម)។ ភាគវត្ថុនេះមិនចេះស្លាប់ ឬរលាយទៅជាមួយខ្លួនទេ។ វាអាចប្រព្រឹត្តទៅ ហោះ ហើរដើរទៅឆ្ងាយបាន វាអាចទៅជាខ្មោចសម្រាប់លងបាន អាចចូលរួមនឹងការកើតទៀតបាន។ ឧត្តមគតិនេះ ប្រពាក់ប្រព័ន្ធគ្នានឹងឧត្តមគតិនៃព្រលឹងជាតិ ឬផ្នែកខ្លះដែលមិនមែនខ្លួនមនុស្សដែលគេបានពង្រីកនិងទាក់ទងនឹងជីវិតមនុស្សបន្ទាប់ពីសេចក្តីស្លាប់។ មិនតែប៉ុណ្ណោះ ឧត្តមគតិនេះបានទាក់ទងនឹងវត្ថុដែលមើលមិនឃើញ និងអំណាចឬហេតុការណ៍ ដែលភ្ជាប់ជាមួយនឹងអំណាចរបស់បុគ្គលម្នាក់ៗដូចជាខ្មោចនៃបុព្វបុរសឬវីរបុរស, សន្តិជន, ខ្មោចអារក្ស, ទេព្តា, និងអំណាចនៃធម្មជាតិជាដើម។

ប៉ុន្តែឧត្តមគតិទាំងអស់នេះពុំមានលក្ខណៈស្របគ្នា ថែមទាំងមានផ្នែកផ្សេងគ្នាទៀត។ ជីវិត វេទនារម្មណ៍, វិញ្ញាណ, ចិត្ត, នម: និងព្រលឹង ច្រើនតែច្រឡំគ្នា ពុំដូចសេរីភាព ចិត្តភាព សោកណាភាព ទេវកថានិងចំណុចដទៃៗទៀតឡើយ។ វឌ្ឍនភាពនៃការផ្សេងគ្នា គឺជាសញ្ញា

[៣] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ១៦

នៃវឌ្ឍនភាពខាងការសង្កេត និងការតម្រៀបៗ តាមពិតផ្នែកអរូបសភាវៈរបស់មនុស្សអាចប្រៀបបាននឹងវត្ថុដែលតូចឆ្មារ ឬជាតុជ៏ល្អិតនិងសុទ្ធជិតនៅក្នុងអាកាសដែល គេអាចសម្គាល់បានជាមួយនឹងផ្នែកខ្លះឬដែលកើតឡើងក្នុងខ្លួនមនុស្សៗ ចិន្តារបស់បស្ចិមប្រទេសសម័យថ្មី បានព្យាយាមចែកសម្ភារវត្ថុ បានប្រព្រឹត្តទៅហួសព្រំដែលនៃគំនិតធម្មតារបស់ អត្តភាព និង ចិត្តដែលមានសភាវៈគ្រោតគ្រាតនិងល្អិតសុខុមៗ ប៉ុន្តែគំនិតនេះ មានលក្ខណៈស្របតិចតួចណាស់ កាលណាគេចែករបស់នោះឱ្យទៅជាចិត្តនិងរូបៗ ការរស់នៅនិងការស្លាប់ ឬសវិញ្ញាណកៈ និងអវិញ្ញាណកៈ វត្ថុសព៌ាង្គកាយនិងអសព៌ាង្គកាយជាដើមៗ ទាំងអស់នេះ យើងពិបាកធ្វើការវិនិច្ឆ័យប្រៀបធៀបនឹងគំនិតយើងបានឡើយ ព្រោះគំនិតទាំងអស់នោះ មានលក្ខណៈមិនស្របគ្នាៗ

២-ឧត្តមគតិនៃព្រលឹងនិងចិត្ត គេពុំអាចសន្និដ្ឋានថាមានជីវិតរស់នៅបាន ឬពុំចេះស្លាប់ទេ សូម្បីគេបានស្វែងរកតាមប្រវត្តិសាស្ត្រ ឬមានជំនឿនិងការប្រតិបត្តិថាវត្ថុទាំងនោះមិនចេះស្លាប់យ៉ាងណាក៏ដោយៗ មាននិន្នាការមួយដើម្បីទទួលនូវឧត្តមគតិនេះ ព្រមទាំងវិនិច្ឆ័យនូវឧត្តមគតិនេះដែលមាន ឧទាហរណ៍ទាក់ទងដល់ការយល់សប្តិ ដែលមានកំណើតទាក់ទងជាមួយនឹងការរំជួលចិត្តៗ ប៉ុន្តែភាគច្រើននៃឧត្តមគតិនេះ ទាក់ទងជាមួយនឹងការពិសោធ និងចំណេះទូទៅរបស់បុគ្គលម្នាក់ៗដែលគេបានវែកញែករវាង មោ៉ងរញ្ជូកនិងមោ៉ងយល់សប្តិ ឬការពិសោធរបស់ខ្លួន ដែលមានការប្លែកដូចជាខ្មោចលងជាដើម ដែលថាមានការពិតខ្លះ ជាពុំខានៗ ទ្រឹស្តីធម្មតានៃកំណើតរបស់ឧត្តមគតិ ពុំបាននិយាយដល់ការរួមចូលគ្នារវាង សង្គមប្រព័ន្ធនិងពុទ្ធិប្រព័ន្ធឡើយៗ មិនតែប៉ុណ្ណោះ ទ្រឹស្តីនេះពុំមានមូលដ្ឋានលើឧត្តមគតិជាច់ដោយឡែក ឬការពិសោធក្នុងការយល់សប្តិឡើយៗ

៣-មានពាក្យជាច្រើនដែលបញ្ជាក់ពីអំណាចក្នុងរូបទូទៅ សម្ភារវត្ថុ ឬវត្ថុដទៃទៀត ទោះជាក្នុងមនុស្សជាតិក្តី ក្នុងសត្វក្តី ឬក្នុងបាតុភូតនៃធម្មជាតិក្តីៗ អ្នកនិពន្ធសម័យថ្មីជាច្រើនបាននិយមប្រើពាក្យ "មនះ" ជារបស់អ្នកកោះម៉េលាណេ ប៉ុន្តែពាក្យនេះប្រើនៅក្នុងតែកិច្ចការរបស់មនុស្សជាតិប៉ុណ្ណោះៗ ឯពាក្យដទៃទៀតពុំមានកម្រិតព្រំដែនដូចជាពាក្យ "មនះ" នេះឡើយៗ ឧទាហរណ៍ដូចជា (Holy Spirit, Holy power, Supernatural power) ជាដើមៗ ពាក្យទាំងអស់នេះមានលក្ខណៈអាចអនុវត្តបាន ២បែបគឺ ៖ ក-ក្នុងសមាធិ, ការអស្ចារ្យប្រកបដោយការរំជួលចិត្ត, ការស្ញើចក្នុងចិត្ត, ការគោរពនិងការធ្លាក់ចិត្តជាដើមៗ ខ-ក្នុងបាតុភូត

ដែលប្លែកពីធម្មតា, ដែលចូលចិត្តនិងចាប់អារម្មណ៍, ដែលជាក់ច្បាស់និងវិសេសវិសាល និង ដែលពុំអាចអធិប្បាយបាន។ បាតុភូតទាំងនេះស្ថិតនៅជាស្ថាពរក្នុងហេតុការណ៍នៃចក្រវាល។

ទិដ្ឋភាពទាំងឡាយ ជាសាសនាក្តី មិនមែនជាសាសនាក្តី និងជាធ្នូប់ អាបក្តី តែងមានការទាក់ទងគ្នាជានិច្ច ហើយគ្រប់កន្លែងទាំងអស់ តែងមាននិន្នាការដើម្បីធ្វើឱ្យមានការផ្សេងគ្នារវាងសាសនា ចរិយាសាស្ត្រ សោភណសាស្ត្រ និងចិត្តសាស្ត្រជាដើម ដែលមានបច្ច័យទាក់ទងទៅលើទំនៀមទម្លាប់ជាវត្តមាន, វិជ្ជានិងវត្ថុ ដែលមានកំណើតដើម្បីផ្សេងគ្នា។ ឯទិដ្ឋភាពប្រកបដោយចិត្តនៃអំណាចធម្មជាតិ (Natural power) គឺមាន កំណើតមុនជាងតក្កវិជ្ជាទៅទៀត។ ហើយជាពិសេស មាននិន្នាការមួយទៀតខាងក្រៅ លើការពិសោធធម្មតា បានបង្គាប់ឱ្យទទួលស្គាល់នូវកិច្ចការនិងហេតុការណ៍ពិបាកយល់និងដ៏ជ្រាលជ្រៅរបស់ចក្រវាល ហើយការនេះ បានឱ្យមានការចេះដឹងច្រើន ដែលជាហេតុដ៏ប្រកបដោយគ្រោះថ្នាក់ដល់ជំនឿ។ និន្នាការនេះ បានបង្ខំឱ្យដាក់ឈ្មោះអំណាចទាំងនោះជា “ធម្មជាតិ” (Natural) ទៅវិញ, ប៉ុន្តែការផ្សេងគ្នានៃឈ្មោះនិងគំនិតនេះ គេត្រូវតែទាញយកត្រង់លក្ខណៈមួយដែលកើតឡើងរវាងនិន្នាការទាំងឡាយដែលប្រកបដោយចិត្តវិទ្យា និង ជំនឿពិសេសណាមួយដែលកំពុងមានក្នុងបច្ចុប្បន្ន។ ដូចនេះទ្រឹស្តីទាំងឡាយនៃធម្មជាតិនិយម ពុំបាននិយាយដល់ “កំណើតដើម” ទេ គ្រាន់តែបង្ហាញឧត្តមគតិសាសនាដែលមានទំនងកើតឡើងបានប៉ុណ្ណោះ។ រឿងនេះមានលំនាំប្រហែលគ្នានឹងទ្រឹស្តីនៃការប្រែប្រួលទាំងឡាយនៃឯកាទិទេវនិយម (Monotheism) ពីពហុទិទេវ និយម (Polytheism) ឬដូចជាជំនឿក្នុងសាសនាព្រាហ្មណ៍ ឬហិណ្ឌូដែលក្លាយ ពីពហុទេវនិយមទៅជាសមូហាទិ ទេវនិយម (Pantheism) ខាងក្រោមនេះ បានបញ្ជាក់ពី សេចក្តីពិតដ៏សំខាន់ពីជំនឿក្នុងបាតុភូតច្រើន ដែលគេអាចតម្រៀបដាក់ក្នុងខណ្ឌជាមួយគ្នា ហើយឱ្យឈ្មោះតែមួយ ព្រោះបាតុភូតទាំងអស់នេះ មានដូចគ្នាដោយកន្លែងខ្លះ ដូចជាទេព្តា ខ្មោចអារក្សជាដើម។ ទាំងអស់នេះ តាមតក្កវិជ្ជា បានបញ្ជាក់ពីឯកភាពដែលមិនផ្សេងគ្នា បានជាគេហ៊ានឱ្យឈ្មោះតែមួយដូច្នេះ។

**ឃ-ជីវភាព និង មរណភាព** ៖ ក្នុងចំណោមឧត្តមគតិទាំងឡាយដែលគេបានស្មានទុកជាមុន ហើយដែលគ្រប់គ្រងនិងត្រួតត្រាកិច្ចការនៃមនុស្សជាតិ, ទោះជាបានគិតទុកជាមុនក្តី មិនបានគិតទុកជាមុនក្តី ឬដឹងខ្លួនក្តី មិនដឹងខ្លួនក្តី គឺជាសន្តានភាពនៃឯកត្តជន។ គេពុំអាចឱ្យការពិពណ៌នាដ៏ប្រកបដោយហេតុផលដល់ខ្លួនឯងឬ អ្នកដទៃប្រាសចាកការទាក់ទងដល់រឿងនេះ

ឡើយ, សូម្បីការជជែករកហេតុផលពីការកើតទៀត មានការជាក់ច្បាស់យ៉ាងណាក៏ដោយ ក៏ការពិសោធផ្ទាល់ខ្លួននិងគំនិតដ៏សំខាន់ៗ នៅតែមានលក្ខណៈផ្សេងគ្នាជា ដរាបៗ ដូចនេះគំនិតនេះត្រូវតែធ្លាក់មកលើសាសនាដោះស្រាយទៅវិញ។ ប៉ុន្តែសេចក្តីពិត ការស្លាប់និងការកើតនេះ ជាធម្មតានៃលោក ហើយដើម្បីរកទីបំផុតនៃការកើតនិងការស្លាប់ដែលត្រូវសាសនាដោះស្រាយ នៅត្រង់ចំណុចដ៏សំខាន់មួយគឺ តើមនុស្សកើតមកត្រូវធ្វើ ដូចម្តេចឱ្យបានសុខ? តើមនុស្សកើតទៀតឬទេ ? បញ្ហាទាំងអស់នេះ សាសនាទាំងអស់ក្នុង លោកមានការដោះស្រាយខុសៗគ្នាជាដរាបៗ សូម្បីនៅក្នុងសាសនារបស់ប្រជាជនដើម ក៏ មាន ការដោះស្រាយផ្សេងៗគ្នាដែរ។ ដូចនេះ យើងសង្កេតឃើញថា សាសនាទាំងអស់មាន ពិធី រៀបចំខ្លួនសម្រាប់បុគ្គលម្នាក់ៗក្នុងការទៅកាន់ភពថ្មីទៀត ដូចជាពិធីថ្វាយខ្លួន (Baptism) ពិធីចូលសាសនា ជាដើម។ ការធ្វើនេះមានបែបផ្សេងៗគ្នាតាមបែបរបស់សាសនាមួយៗ។

គំនិតដែលថា សេចក្តីស្លាប់ គឺគ្រាន់តែជាផ្លូវទៅកាន់ភពថ្មី និងថាបុគ្គលម្នាក់ៗមិនអាចជៀសវាងរួចពី ការកើតទៀត គឺជាគំនិតរបស់ប្រជាជនដើម ហើយមិនមែនជាគំនិតសាសនាព្រមទាំងមានការប្រតិបត្តិមិនសមហេតុផលផងទៀត។ ត្រង់នេះ យើងបានសង្កេតឃើញសាសនានៅប្រទេសឥណ្ឌា គេទុកជាឱសថសម្រាប់ព្យាបាលរោគបានទៀត។ នេះបើតាមគំនិតធម្មតា គេទុកជាធម្មតាដូចវត្ថុអ្វីៗក្នុងលោកដែរ ឬ ដូចជាស្មៅ ឬដើមឈើទាំង ឡាយលើផែនដី។ ប៉ុន្តែទោះជាគំនិតខាងការស្លាប់និងការកើតមានការផ្សេងគ្នាបែបណាក៏ដោយ មានចំណុចខ្លះស្របគ្នាដ៏សំខាន់មួយវាងសាសនាខ្លះក្នុងលោក គឺការមិនស្លាប់នៃព្រលឹងឬវិញ្ញាណនោះនៅក្នុងទីណាក៏ដោយ បន្ទាប់ពីសេចក្តីស្លាប់នៃរូប។ ម្យ៉ាងទៀត ឈ្មោះនៃមនុស្សម្នាក់ៗមិនចេះ ស្លាប់ទៅណាទេ ទោះជាមនុស្សនោះៗ ស្លាប់បាត់បង់ទៅហើយក្តី។ បានជាមិនស្លាប់ ព្រោះមនុស្សម្នាក់ៗនោះ បានបំពេញសេចក្តីល្អ សាធារណប្រយោជន៍ដល់ក្រុម-ពួក សង្គមនិងវត្ត ព្រមទាំងបង្កើតគំនិតជាបងប្អូនជាដើម។ សេចក្តីពិត ការស្លាប់ជាឱកាសនៃអារម្មណ៍ជាទុក្ខ និងការខ្សឹកខ្សួលយំសោក, អារម្មណ៍ជាសុខ, ជាបរមសុខ, ជាសេចក្តីសង្ស័យ និងនៃអារម្មណ៍មិនពិតប្រាកដ។ ម្យ៉ាងទៀត ជីវិតខាងក្រោយនៃសេចក្តីស្លាប់ត្រូវប្រកបដោយហេតុនៃការជានាអះអាងដ៏ប្រណីត ឬហេតុនៃវិប្បដិសារី បើបុគ្គលម្នាក់ៗបានបំពេញសេចក្តីល្អ ឬអំពើអាក្រក់។ ម្យ៉ាងទៀត ជីវិតអនាគតត្រូវសោយផលជីវិតបច្ចុប្បន្ននេះ ព្រោះហេតុនោះបានជាគេតែងតែគិតថា ពពួកទេវតាឬមនុស្សទាំងឡាយត្រូវ

ទទួលការរីករាយ សប្បាយមានព្រំដែន ហើយការរីករាយសប្បាយនោះៗ ពុំស្ថិតស្ថេរទៀងទាត់ឡើយ។ ដូចនេះយើងឃើញថា គ្រប់ទីកន្លែងទាំងអស់ កត្តាទាំងឡាយប្រកបដោយ ចិត្តវិទ្យានិងតក្កវិជ្ជា តែងតែប្រឈប់ចូលគ្នាជានិច្ចក្នុងប្រវត្តិ និងការរីកចម្រើននៃគំនិតឬ ឧត្តមគតិ ប៉ុន្តែទាំងអស់នេះ មានគុណផ្សេងគ្នាជាក់ច្បាស់ក្នុងលោកបច្ចុប្បន្ននេះជាងនៅលោកខាងមុខ ។ បណ្តាភាពផ្សេងគ្នាទាំងអស់នេះ មានការពិតនៃសេចក្តីផ្សេងគ្នាខ្លះ អធិប្បាយពីលក្ខណៈស្របគ្នានៃលទ្ធផលខាងប្រាជ្ញាការពិសោធន៍និងវេទនារម្មណ៍។

**ង-សាន្តេបបទនៃសក្តីភាព** ៖ ១-ជំនឿធម្មតាថា ព្រលឹងគឺដើមចមនៃជីវិតអាចនៅឆ្ងាយពីខ្លួនពេលខ្លះបាន នៅពេលដែលមនុស្សយល់សប្តិឬមានជំងឺ។ ជួនកាលវាអាចរលត់ វាអាចទាញស្រូបរបស់ដែលព្រលឹងជាប់ជំពាក់បាន។ ម្យ៉ាងទៀត ព្រលឹងនេះអាចផ្លាស់ប្តូរបាន ដូចនេះ គំនិតឬឧត្តមគតិនៃព្រលឹងទៀង (សស្ស តត្តភាព) ដែលមនុស្សជឿខ្លួនឯងថាមានសេរីភាពកាលណាព្រលឹងបានសុខសប្បាយ។ គំនិតនេះប្រហែលគ្នា ៖

ក-ជំនឿថា ឈ្មោះរបស់ខ្លួនដែលបានសរសេរទុក ឬចំណែកណាមួយនៃអត្តសម្ភារៈ ដូចជាសក់ជាដើម ឬ ក៏ទ្រព្យសម្បត្តិដែលនៅសល់នៅក្នុងកន្លែងដ៏ជាទីសក្ការៈបូជា ទាំងអស់នេះ គេទុកជាផ្នែកដ៏សំខាន់របស់ខ្លួន ហើយទុកជាប្រយោជន៍និងសេចក្តីសុខចម្រើនរបស់ខ្លួន។

ខ-គំនិតដ៏ខ្ពង់ខ្ពស់ថា គេអាចផ្ញើព្រលឹងទុកក្នុងបុគ្គលិកភាពនៃសន្និជន ឬទេព្តាឱ្យរក្សាទុកឱ្យផង ធ្មឹង ខ្មោចយកមកផ្ញើតាមវត្ថុឬចេតិយជាដើម និងមួយទៀត គេផ្ញើជីវិតគេនៅនឹងដើមឈើទុកជាសញ្ញានៃជីវិត ដើម្បីប្រមូលយកកម្លាំងប្រាជ្ញាសម្រាប់ការពារគ្រោះថ្នាក់ដល់ជីវិត[៤]។

២-ពួកលទ្ធិខ្លះ ដែលទទួលយកព្រះអាទិទេពជាមូលដ្ឋានជឿថា គ្រប់វត្ថុទាំងឡាយនៅលើលោកនេះ ព្រមទាំងតួចក្រវាឡទាំងមូល តែងមានទេវសភាវៈស្ថិតនៅជានិច្ច។ ដូចនេះ គេយល់ថាខ្លួនមនុស្សលោកត្រូវ មានព្រលឹង ២ គឺខាងក្រៅនិងខាងក្នុង។ ព្រលឹងទាំងពីរនេះតែងអាស្រ័យគ្នាទៅវិញទៅមកក្នុងកិច្ចការប្រចាំថ្ងៃ-យប់ ឬគ្រប់ឥរិយាបថទាំងអស់នៃមនុស្សគ្រប់រូបលើលោកនេះ។ ដូចនេះ បានជាមានជំនឿមួយថា "ព្រះអាទិទេពតែងស្ថិតនៅគ្រប់កន្លែង" បានកើតឡើង ហើយគេបានបង្កើតទេវរូបជានិមិត្តរូបនៃវត្ថុស័ក្តិសិទ្ធិច្រើន រាប់

---

[៤] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ២០

មិនអស់ ហើយពិធីបូជាក៏កើតមានឡើងមានសភាពផ្សេងៗគ្នាទៀតដែលគេហៅថា "លទ្ធិទេវនិយម"។ ទេវរូបទាំងអស់នេះ មិនមែនមានតែសាសនាតូចៗ ដូចជាសាសនាប្រចាំគ្រួសារ ក្រុមឬកុលសម្ព័ន្ធតូចៗនៅលើលោកប៉ុណ្ណោះទេ, សូម្បីសាសនាធំៗខ្លះ ដូចជាសាសនា ព្រាហ្មណ៍, សាសនាសាកលនិយមជាដើមក៏មានដែរ។ ឯជំនឿថា ព្រះអាទិទេពគឺមានតែមួយ នៅលើលោកនេះ ជាជំនឿដែលបានរីកចម្រើនខាងក្រោយមកទេ ដោយដាក់ឈ្មោះថា ឯកា ទេវនិយម ដូចជាជំនឿរបស់សាសនាគ្រិស្ត, អ៊ិស្លាម, ហិណ្ឌូ និងសាកលនិយមចិន។ ប៉ុន្តែ ជំនឿនេះ មានកំណើតពីពហុទិទេវនិយមដែរ។ នេះជាស្ពានហេតុដែលមានបញ្ជាក់យ៉ាង ច្បាស់លាស់តាម ប្រវត្តិនៃការរីកចម្រើនរបស់សាសនា។

ជាពិសេស លទ្ធិទាំងនោះជឿថា វិញ្ញាណរបស់អ្នកស្លាប់ត្រូវទេវសភាវៈខាងក្រៅគ្រប់គ្រងនិងឱ្យចាប់កំណើតជានេះជានោះឬនាំទៅសោយផលនៅឯស្ថានសួគ៌ថែមទៀត។ មនុស្សលោកប្រកបការងារទោះល្អក្តី អាក្រក់ក្តីក៏ទេវសភាវៈទាំងនោះកត់ត្រាទុកនិងដឹងឮទាំងអស់។ ប៉ុន្តែគួរឱ្យឆ្ងល់ណាស់ បើប្រសិនជាទេវសភាវៈខាងក្រៅ ចាំមើលត្រួតត្រាទេវសភាវៈខាងក្នុងនៃមនុស្ស-សត្វ, ហេតុដូចម្តេចបានជាទេវសភាវៈខាង ក្រៅនោះនៅស្ងៀមព្រងើយនៅពេលដែលមនុស្ស-សត្វ ត្រូវទេវសភាវៈខាងក្នុងដឹកនាំឱ្យធ្វើអំពើអាក្រក់ ? តើទេវសភាវៈខាងក្រៅនោះជាអ្វី ? ចំណុចនេះយើងគួរពិនិត្យឱ្យហ្មត់ចត់ ដើម្បីរកប្រភពនៃជំនឿនេះ។

៣-គំនិតខាងលើនេះ បានបញ្ជាក់ជាចាំបាច់នូវការដ៏ជ្រាលជ្រៅ ដ៏ពិបាកយល់អំពីព្រលឹងនិងចិត្ត, ប៉ុន្តែគេអាចរួបរួមឱ្យទៅជាគោលការណ៍ ឬលក្ខណៈសំខាន់ៗដូចតទៅនេះ ៖

ក-បុគ្គលម្នាក់ៗនៅលើលោកនេះ មិនមានលក្ខណៈជាម្ចាស់លើខ្លួនឯងបានទេ ព្រោះបុគ្គលម្នាក់ៗត្រូវមានការទាក់ទងជានិច្ចជាមួយនឹងទេវសភាវៈខាងក្រៅ។

ខ-ការផ្សេងគ្នារវាងជីវិតនិងមរណៈ លោកនេះនិងលោកខាងមុខ យើងមិនអាចនិយាយតាមបរមត្ថបានទេ ព្រោះគំនិតនេះផ្តេកទៅលើការពិសោធនិងការបកស្រាយ (Interpretations) ទាំងស្រុង។

គ-ជាទីបំផុត ការចូលចិត្ត ជំនឿ ការចាប់អារម្មណ៍នៃសភាវៈទាក់ទងដល់ព្រលឹងនិងចិត្ត តែងសម្រេចតាមទម្លាប់នៃជំនឿ ដែលសង្គមតូចឬធំបានកំណត់ទុក។

ឃ-វិភាគនៃអាទិទេវប្បញ្ញត្តិ (Analysis of the concept of “”God”)

១-ចំពោះលទ្ធិដែលមានអាទិទេពជាមូលដ្ឋាន មានបញ្ញត្តិផ្សេងគ្នាច្រើនជាទីបំផុតពីពាក្យថា "អាទិទេព" តាមលក្ខណៈនៃលទ្ធិនីមួយៗ។ ការផ្សេងគ្នានេះ ជាហេតុឱ្យពិបាកធ្វើអត្ថាធិប្បាយរកឯកភាពនៃជំនឿនេះ។ ដើម្បីអធិប្បាយរឿងនេះឱ្យបានច្បាស់លាស់ ហើយមានហេតុផលត្រឹមត្រូវផងនោះ យើងត្រូវលើកយកគោលការណ៍ដ៏សំខាន់មួយមកអធិប្បាយនិងពិនិត្យ តាមលក្ខណៈដ៏ពិតប្រាកដនៃការចាប់អារម្មណ៍នឹងពាក្យ ប្រៀនប្រដៅរបស់លទ្ធិដែលទាក់ទងដល់ជំនឿនេះ គឺបុគ្គលិកសម្ព័ន្ធភាពរវាងបុគ្គលម្នាក់ៗ ឬឯកត្តជននិងអំណាចដ៏ខ្ពង់ខ្ពស់ខាងក្រៅ (An internal transcendent power)។ ប៉ុន្តែសម្ព័ន្ធភាពនេះ មានការរីកសាយកាយនៅគ្រប់ទីកន្លែង ហើយជាមាគ៌ាដែលសាវ័កនៃសាសនាផ្នែកនេះ មានខ្សែគំនិតស្មើរតែដូចគ្នាទាំងអស់ ហើយយើងត្រូវកត់សម្គាល់ដូចតទៅនេះ ៖

ក-ឯកត្តជន មានសម្ព័ន្ធភាពដ៏ជិតស្និទ្ធជាមួយនឹងអំណាចដ៏ខ្ពង់ខ្ពស់ខាងក្រៅ គឺបុគ្គលម្នាក់ៗ ត្រូវយក អំណាចនោះជាទីពឹង ទីរឭកគ្រប់កាលទាំងពួង។

ខ-ឧត្តមគតិខាងសីលធម៌ ខាងសង្គម ខាងគតិប្រាជ្ញា ខាងសោភណភាព និងដទៃទាំងឡាយទៀត ត្រូវតែទាក់ទងដល់និងរួមចូលក្នុងសម្ព័ន្ធភាពនេះដែរ (Ethical, social, intellectual, easthotic and other idea involved)។ ជាពិសេសជាងនេះទៅទៀត លទ្ធិអាថ៌កំបាំង ឈានដល់ជាដើម បានចង្អុលបង្ហាញដល់ភាព តាមផ្លូវចិត្តនៃតម្លៃអត្តភាវនិយមយ៉ាងច្បាស់លាស់ (Intense subjective value) តែគេមានអារម្មណ៍ក្នុងការពិសោធនេះថាជា(Divine)= ទេវសភាវៈ "ប៉ុន្តែការទទួលស្គាល់និងដឹងច្បាស់នៃការផ្សេងគ្នារវាងសាសនាខុសនិងត្រូវការអាថ៌កំបាំងខុសនិងត្រូវជាដើម បង្ខំនូវការចាំបាច់នៃការបែងចែកឱ្យដាច់ស្រឡះពីគ្នានូវតម្លៃអត្តភាវនិយមនិងតម្លៃបរភាវនិយម (Supjective and objective value) នៃការពិសោធ បែបនោះៗ។ ដទៃពីនេះ យើងគួរពិនិត្យទៀតថា សម្ព័ន្ធភាពដ៏ជិតស្និទ្ធរវាងឯកត្តជន និង អំណាចដ៏ខ្ពង់ខ្ពស់ខាងក្រៅ មិនមានការចាំបាច់ឱ្យកត់សម្គាល់ថាជា "ទេព្ដា" ទេ ព្រោះថា នៅទីនោះហើយត្រូវមានការចាប់អារម្មណ៍ទៅលើការទាក់ទងគ្នារវាងការពិសោធ និងការបកស្រាយនៃជំនឿផ្សេងៗក្នុងសេចក្ដីពិតនៃអារក្ខទេព្ដា និងបុព្វបុរសវិញ្ញាណ ដែលមានបែបការពិសោធន៍ និងបែបនៃការបកស្រាយប្រហែលៗគ្នា។ ទាំងអស់នេះជាលក្ខណៈសំខាន់បំផុតតាមប្រវត្តិនិងការរីកចម្រើននៃសាសនា។ ដូចនេះ យើងត្រូវយល់ថា អ្វីទាំងអស់ដែលទាក់ទងដល់សម្ព័ន្ធភាពរវាងមនុស្សលោកទៅនឹងអំណាចដ៏ខ្ពង់ខ្ពស់ខាងក្រៅ ត្រូវមានការ

ពិសោធនិងឧត្តមគតិផ្សេងៗចូលរួមផង។ យើងមិនអាចធ្វើអត្ថាធិប្បាយដាច់ដោយឡែកចំពោះមូលហេតុណាមួយបានទេ។

២-ម្យ៉ាងទៀត បញ្ញត្តិទាំងអស់នេះ តែងទាក់ទងជានិច្ចជាមួយនឹងឧត្តមគតិនៃហេតុ (Causation) ការជាក់ស្តែង (ប្រត្យក្ស) នៃអំណាចដ៏ខ្ពង់ខ្ពស់ (Manifestation of supreme power) ជាដើម។ ឯជំនឿក្នុងអំណាចព្រះអាទិទេពកំពុងមានលទ្ធភាពយ៉ាងសកម្មលើសន្តានចិត្តនៃសាវ័ក ប៉ុន្តែទាំងនេះ តែងផ្អែកទាំងស្រុងទៅលើចរិតនៃមនុស្សនិងឧត្តមគតិនៃសាសនា (ការជាទីពឹងទីរឭក, ការសូត្រធម៌បួងសួង, សីលចរិយា) ជាដើម មិនមែនផ្អែកទៅលើឧត្តមគតិនៃមន្តអាគម (Magic) ទេ, ព្រោះបញ្ញត្តិនៃអាទិទេពគ្រាន់តែជាមាគ៌ានៃគំនិត ជាអរូបិយភាពប៉ុណ្ណោះ។ គំនិតនេះកើតឡើងពីការភ័យខ្លាច សេចក្តីត្រូវការនៃមនុស្សលោកដែលបណ្តាលឱ្យ មនុស្សរត់រកវត្ថុជាទីពឹងទីរឭក។ ការភ័យខ្លាចនៃមនុស្ស ដោយត្រង់អំណាចមើលមិនឃើញនិងហួសពីគំនិតធម្មតានៃមនុស្ស លោកដែលបណ្តាលមកពីការពិសោធ (Experience) ឃើញការជាក់ស្តែងខ្លះ ដូចជាមនុស្ស ស្លាប់ដោយគ្រោះថ្នាក់ផ្សេងៗដែលពុំបានគិតទុក, ការវិនាសអន្តរាយទ្រព្យសម្បត្តិជាដើម ឃើញការអស្ចារ្យ ចំពោះបាតុភូតផ្សេងៗដូចជា រន្ទះផ្គរបន្ទោរ ខ្យល់ព្យុះ ផែនដី រញ្ជួយដីជាដើម។ ប៉ុន្តែនៅសម័យនេះ ជំនឿនេះពុំសូវមានឥទ្ធិពលប៉ុន្មាន ហើយប្រជាពលលោកខ្លះក៏ពុំសូវអើពើដោយអំណាចឥទ្ធិពលនៃវិទ្យាសាស្ត្រនិងមនោគមវិជ្ជាមានកម្លាំងខ្លាំងក្លា ហើយបានរីកចម្រើនស្ទើរហួសវិស័យនៃមនុស្ស។ តែទោះជាការរីកចម្រើននៃវិទ្យាសាស្ត្រនិងមនោគមវិជ្ជាមានល្បឿនយ៉ាងណាក៏ដោយ ក៏ជំនឿនោះមិនរលប់រលាយសោះសូន្យឡើយ គ្រាន់តែមានឥទ្ធិពលតិច ឬខ្សោយប៉ុណ្ណោះ ព្រោះ ទ្រឹស្តីនៃជំនឿនិងការប្រតិបត្តិ មានលក្ខណៈប្រកបដោយហេតុ-ផលគួរណាស់ដែរ។ ទាំងនេះ ក៏វាអាស្រ័យនឹងសេចក្តីត្រូវការនៃសង្គមលោកដែរ គឺបើសង្គមលោកនៅមានមនុស្សត្រូវការពេលខ្លះជំនឿក៏នៅមានជីវិតរស់នៅដែរ បើសង្គមលោកលែងមានមនុស្សត្រូវការ ឬក៏ត្រូវការដែរ តែដោយអំណាចការបង្ខំនៃសង្គម ដូចជាប្រទេសពួកក្រហមជាដើម ក៏ជំនឿនោះត្រូវតែវិនាសសាបសូន្យទៅវិញដែរ។ ស្ថានហេតុនេះ មិនមែនកើតឡើងតែក្នុងខេត្តនៃអាទិទេវ ប្បញ្ញត្តិទេ សូម្បីក្នុងខេត្តនៃនិព្វានបញ្ញត្តិ ឬមោក្ខបញ្ញត្តិក៏កើតមានដែរ។ គ្រោះថ្នាក់ដែល មានដូច្នេះ ព្រោះសាវ័កនៃសាសនានោះៗ ពុំបានចេះដឹងពាក្យប្រៀនប្រដៅឱ្យច្បាស់លាស់ ហើយប្រឹងអនុវត្តពាក្យប្រៀនប្រដៅនោះៗឱ្យកើតជាផលឡើង។ មិនតែប៉ុណ្ណោះ គ្រោះថ្នាក់ នេះក៏

បណ្ដាលមកពីអ្នកកាន់សាសនាផ្ទាល់ឬអ្នកបួសដែរ ព្រោះអ្នកទាំងអស់នេះពុំបានអនុវត្ត ពាក្យប្រៀនប្រដៅនៃសាសនា ដែលខ្លួនប្រកាន់នោះទៅតាមសម័យនិងប្រទេស។ ជាពិសេសទៅទៀត គេពុំបានសិក្សាឱ្យច្បាស់លាស់អំពីចលនសាសនា និងអចលនសាសនាតាមបែបវិទ្យាសាស្ត្រផងទេ។ នេះជាការពិតណាស់ ព្រោះសាសនាអាស្រ័យផ្លូវចិត្តនៃជនអ្នកកាន់ ជាឧទាហរណ៍ជាក់ស្ដែងដើម្បីបញ្ជាក់រឿងនេះ យើងគួរសង្កេតសាវ័កខ្លះនៃសាសនាក្នុងលោក បើគេពេញចិត្តនឹងសាសនារបស់គេៗអាចស្ថិតនៅក្នុងសាសនានោះៗ ឬយកសាសនា នោះៗជាទីពឹងទីរឭក ដរាបសូន្យជីវិតទៅ។ តែបើគេមិនពេញចិត្ត ឬគេបានឃើញកំហុសណា មួយក្នុងសាសនានោះៗ ដែលធ្វើឡើងដោយសាសនាដូចគ្នា ឬអ្នកបួសដែលជាហេតុមិនឱ្យគេអត់ទ្រាំបាន ក៏គេគេចចេញពីសាសនានោះៗ ហើយទៅចូលនឹងសាសនាដទៃទៀត។ ម្យ៉ាងទៀត អ្នកចេះដឹងឬអ្នកសិក្សាក៏មានចេញពីសាសនារបស់ខ្លួន ហើយទៅចូលសាសនា ដទៃទៀតដែរដូចជា លោក Rhys David ជាជាតិអង់គ្លេសធ្លាប់កាន់សាសនាគ្រិស្ត និងលោក Hax Muller ជាជាតិអាឡឺម៉ង់ក៏ធ្លាប់កាន់សាសនាគ្រិស្តដែរ អ្នកទាំងពីរនាក់នេះបន្ទាប់ពីបានសិក្សាពុទ្ធសាសនាផ្នែកថេរវាទយ៉ាងច្បាស់លាស់ហើយ ក៏បានលះបង់សាសនាខ្លួន ហើយថ្វាយខ្លួនចូលកាន់សាសនាវិញ។ នៅមានហេតុការណ៍ជាច្រើនទៀត ដែលបណ្ដាលឱ្យ មនុស្សលះបង់សាសនាខ្លួន ហើយទៅចូលសាសនាដទៃទៀត ប៉ុន្តែយើងមិនបាច់លើកយក ហេតុការណ៍ទាំងនោះមកអធិប្បាយនៅទីនេះទេ។ ចំណុចសំខាន់ក្នុងរឿងនេះ ដែលយើងគួរ កាន់យក គឺការកាន់គោរពសាសនា អាស្រ័យនឹងចិត្តនៃមនុស្សម្នាក់ៗ មិនមានការបង្ខំពីជនណាមួយឡើយ។ បញ្ហាដ៏សំខាន់សម្រាប់អ្នកសិក្សាក្នុងខណ្ឌនេះ គឺត្រូវធ្វើការសង្កេត និងការសិក្សានូវធម្មជាតុទាំងអស់ដែលទាក់ទងរវាងឯកត្តជននិងព្រះអាទិទេព ឬអំណាចដ៏ខ្ពង់ខ្ពស់ ហើយសរុបរកកំណើតនិងឯកភាពនៃជំនឿនេះ។ ក្នុងជំនឿថា មានព្រះអាទិទេពច្រើន ឬតែមួយនៃសាសនាទាំងឡាយនោះ តាមលំដាប់នៃការរីកចម្រើននៃប្រវត្តិសាស្ត្រ ហើយត្រូវកត់ សម្គាល់ថា ទាំងអស់នេះមានលក្ខណៈតែមួយតាមទ្រឹស្ដី និងការអនុវត្តនៃសាសនារៀងៗ ខ្លួន ទោះជាមានកន្លែងខ្លះ ត្រូវបានគេកែប្រែទៅតាមកាលៈទេសៈក៏ដោយ។

៣-ម្យ៉ាងទៀតអាទិទេវប្បញ្ញត្តិបានរួបរួមបញ្ចូលទៅក្នុងខេត្តខ្លួននៃឧត្តមគតិនៃសហក្រម (Coordination) និងការប្រជុំចុះគោលការណ៍នៃឧត្តមគតិទាំងឡាយ (Systematization of ideas) ដ៏ខ្ពង់ខ្ពស់បំផុត និងដ៏មានព្រំដែនផង។ មិនត្រឹមតែប៉ុណ្ណោះ អាទិទេវប្បញ្ញត្តិតែងបំពេញឬ

បង្គ្រប់នូវសេចក្តីត្រូវការទាំងឡាយនៃអារម្មណ៍ និងការឈ្វេងយល់ព្រមទាំងជួយសង្គ្រោះដល់ការពិសោធទាំងឡាយ ដែលប្រកបដោយការខ្វីកខ្វល់អណ្តើកអណ្តក ឬទុក្ខសោម-នស្ស និងប្រកបដោយការសង្ស័យនៃជីវិតនិងបញ្ហាដ៏ជ្រាលជ្រៅ ឬគម្ពីរភាពនៃបញ្ហាថែមទៀត។ ក្នុងស្ថានហេតុនេះ អាទិទេវប្បញ្ញត្តិ (តាមលក្ខណៈទូទៅនៃធម្មជាតិ) មិនមែនគ្រាន់តែអាចបំពេញសេចក្តីពេញចិត្ត នៃបុគ្គលិកភាពរបស់មនុស្សជាតិគ្រប់ផ្នែកប៉ុណ្ណោះទេ បញ្ញត្តិថែមទាំងបានជួយផ្តល់ដល់សេចក្តីត្រូវការនៃសាសនា សីលធម៌ សោភណភាព និង ប្រាជ្ញាថែមទៀត។ ប៉ុន្តែគ្រប់ទីកន្លែងទាំងអស់ យើងសង្កេតឃើញមានការចាំបាច់ក្នុងការរួបរួមគ្នានៃបញ្ញត្តិ អាទិទេពនិងបញ្ញត្តិនៃធម្មជាតិ វិទ្យាសាស្ត្ររូបនិយម សង្គមនិងរដ្ឋជាដើម។ ព្រោះបញ្ញត្តិនេះមានការទាក់ទង ដ៏ជិតស្និទ្ធជាមួយនឹងសេចក្តីពិតជាបរមត្ថ និងតម្លៃនៃជីវិត ប៉ុន្តែគ្រប់ទីកន្លែងទាំងអស់យើងសង្កេតឃើញថា បញ្ញត្តិនេះមិនសូវរួបរួមគ្នាជាធ្លុងមួយទៅវិញ ដោយអំណាចបញ្ញត្តិនេះ មានការទាក់ទងទៅនឹងបញ្ញត្តិដទៃជាច្រើន ព្រមទាំងមានឥទ្ធិពលមកលើថែមទៀត។ បើពិតជាអាទិទេវប្បញ្ញត្តិហួសគំនិតធម្មតាទៅវិញ ឃើញថា បញ្ញត្តិនេះ បានទាក់ទងនឹងគំនិតដែលមានទំហំធំពេក និងមានព្រំដែនវែងឆ្ងាយហួសនិស្ស័យ (ដូចជា គាថាខ្លះ និយាយថា ភ្នំ ដើមឈើ ព្រៃព្រឹក្សាគឺជាព្រះអាទិទេពទាំងអស់ជាដើម) ឬក៏និយាយថាអាទិទេពគឺជាមេត្តា ដែលមិនមានព្រំដែនសោះ ឬមានតែព្រះអាទិទេពទេ ទើបមានយុត្តិធម៌ពិតប្រាកដជាដើម។ គំនិតបែបនេះគឺ គ្រាន់តែជាវង្វេងលំដាប់លេខរៀងនិងគណិត វិធីនៃខ្សែឬបែបគំនិតដែលថាព្រះអាទិទេព គេទុកជានិមិត្តរូបនៃមនុស្សអស្ចារ្យឬទេព្តា ដែលជាសញ្ញានៃគំនិត ដែលបានគិតចម្លងយកបែបជីវិត ដ៏សុខឥតប្រែប្រួលមកបង្ហាញប៉ុណ្ណោះ។ គំនិតនេះ គឺគ្រាន់តែជាការរីកចម្រើនតាមលំដាប់នៃប្រវត្តិសាស្ត្រសាសនានោះៗឯង ជាគំនិតថ្មីមួយដល់គំនិតចាស់ដែលមានមកហើយនោះ។ ទាំងអស់នេះ ពុំបានឆ្លើយឱ្យត្រង់ទៅលើការពិសោធជារៀងរាល់ថ្ងៃនៃជីវិតទេ។ គឺគ្រាន់តែទាក់ទងតាមផ្លូវគំនិតប៉ុណ្ណោះ ហើយដែលមិនអាចធ្វើការវែកញែកបានផងទៀត។ ព្រះអាទិទេព គួរយើងកត់សម្គាល់ថា ជានិមិត្តរូបនៃគំនិតដែលទាក់ទងដោយពិតប្រាកដជាមួយនឹងប្រវត្តិ និងការរីកចម្រើននៃផ្លូវគំនិត។

៤-សក្ខីភាពនៃការរីកចម្រើនបុគ្គលិកភាព ហើយនិងការរីកចម្រើននៃបញ្ញត្តិទាំងឡាយមានការទាក់ទងគ្នាជានិច្ច មិនដែលដាច់ចេញពីគ្នាឡើយ។ ឧទាហរណ៍យ៉ាងជាក់ស្តែងពីសន្តតិវង្សនិយមនៃក្រុមមានអនុរូបយ៉ាងជិតស្និទ្ធតែមួយជាមួយឧត្តមគតិ ដែលមិនទាន់បានរីក

*ចម្រើននៃបុគ្គលម្នាក់ៗ នៃមនុស្សសម័យដើមៗ ចំណែកឯសន្តតិវង្សផ្ទាល់ខ្លួនម្នាក់ៗឬខ្មោចអ្នករក្សាគ្រួសារឬផ្ទាល់ខ្លួន សូម្បីជាសម្បត្តិឯកជនយ៉ាងណាក៏ដោយ ក៏ទៅជាទេព្តាឯកជនទៅហើយៗរបស់នេះ គេបានយកចិត្តចាប់អារម្មណ៍ជាងគេបំផុតនៅក្នុងសង្គមជាន់ដើមៗ លុះសម័យសង្គមរីកចម្រើនយើងសង្កេតទៅឃើញថា គ្រប់សាសនាដែលមានប្រព័ន្ធជាមួយនឹងអាទិទេវប្បញ្ញត្តិ ក៏នៅមានសម្ព័ន្ធភាពដ៏ជិតស្និទ្ធរវាងបុគ្គលម្នាក់ៗនិងព្រះអាទិទេពដែរ ដូចជាសាសនាគ្រិស្ត អ៊ិស្លាម ជាដើមៗ ប៉ុន្តែឧត្តមគតិនេះ ត្រូវបានគេរិះគន់ជាអតិបរមា ដោយអំណាចរឿងនេះយកមកអនុវត្ត និងវែកញែកតាមលក្ខណៈវិទ្យាសាស្ត្រពុំកើតៗ ទាំងនេះបណ្តាលមកពីអាទិទេវប្បញ្ញត្តិនេះ គេយកទៅប្រើក្នុងមាគ៌ានៃជីវិត ហើយគេទុកគ្រាន់តែជានិមិត្តរូបនៃឧត្តមគតិ ដែលជាចំណងនៃជីវិតដ៏សុខសាន្ត ប្រាសចាកវត្ថុកាមនិងកិលេសកាមនិងសេចក្តីទុក្ខលំបាកគ្រប់យ៉ាងដែលមនុស្ស លោកត្រូវជួបប្រទះរៀងរាល់ថ្ងៃទៅវិញៗ គេពុំបានយកបញ្ញត្តិនេះទៅប្រើក្នុងវិទ្យាសាស្ត្រផ្សេងៗឡើយ ដូចជាវិទ្យាសាស្ត្រធម្មជាតិ វិទ្យា-សាស្ត្ររូបនិយម វិទ្យាសាស្ត្រគីមីជាដើមៗ តែទោះជាគំនិតនេះមិនអាចកែប្រែបានក៏មានសាវ័កជាច្រើនប្រតិបត្តិតាម ហើយការប្រតិបត្តិនេះគេទុកជាទំនៀមទម្លាប់សម្រាប់សង្គមគ្រួសារគេប៉ុណ្ណោះ ទោះណាជាគំនិតនោះ មានឬគ្មានហេតុផលយ៉ាងណាក៏ដោយៗ ត្រង់នេះគេចាត់ទុកជាជំនឿ តែយើងជឿរបស់អ្វីហើយ របស់នោះក្លាយជារបស់ពិតទាំងអស់ ប៉ុន្តែជឿមិនមែនវិទ្យាសាស្ត្រទេៗ*

## ***ការរីកចម្រើននៃសង្គមនិងសាសនា***

*១-ការរីកដុះដាលនិងការផ្សេងគ្នានៃសង្គម ទាំងការរីកចម្រើនក្នុងផ្ទៃក្នុងនិងការទាក់ទងរវាងសង្គមផ្សេងៗគ្នាខាងក្រៅរួមគ្នាជាបាច់មួយ បង្កើតការរីកចម្រើននៃសាសនាៗ ឧត្តមគតិនៃសាសនាទាំងឡាយ តែងពង្រីកឥទ្ធិពលខ្លួនទៅលើអ្វីទាំងអស់ដែលជាហេតុរក្សានូវជីវភាពនៃប្រជាករឱ្យរស់នៅជាស្ថាពរលើលោកនេះបានៗ ដូចនេះ យើងសង្កេតឃើញថានៅក្នុងខេត្តនៃការផ្តល់អាហារ ការរស់នៅជំនួញ សង្គ្រាម និងរដ្ឋាភិបាលជាដើម តែងមានការទាក់ទងដ៏ជិតស្និទ្ធជាមួយនឹងឧត្តមគតិ នៃសាសនាទាំងឡាយជាដរាប ព្រោះឧត្តមគតិនិងទ្រឹស្តីទាំងឡាយនៃខេត្តទាំងអស់នោះ មានឥទ្ធិពលនៃឧត្តមគតិរបស់សាសនាទាំងឡាយគ្របដណ្តប់ឃុំគ្រងដោយខានពុំបាននិងដោយចាំបាច់ៗ ទាំងនេះដោយហេតុថាឧត្តមគតិទាំងឡាយនៃសាសនាមានកំណើតមកជាមួយនឹងសង្គមលោកដែរ ហើយគេទុកឧត្តមគតិនៃ*

សាសនា ទាំងឡាយនោះជាតំណាងនៃមាគ៌ាជីវភាពនៃសង្គមទាំងផ្នែកសម្ភារៈនិយមទាំងផ្នែកអសម្ភារៈនិយម។ ប៉ុន្តែ អ្នកសិក្សាធម្មជាតិនៃសាសនានេះ ត្រូវជួបការលំបាកខ្លះនៅពេល ដែលការផ្សេងគ្នារវាងគំនិតសាសនានិងគំនិត មិនមែនជាសាសនាកើតឡើងនៅក្នុងសង្គមតែមួយ ពីព្រោះអ្នកសិក្សាមានការចាប់អារម្មណ៍ខ្លាំងទៅលើគំនិតណាមួយដូចជាគំនិតផ្សេងៗគ្នា រវាងច្បាប់និងសាសនាជាដើម។

យើងគួរកត់សម្គាល់ក្នុងការរីកចម្រើននៃសង្គមនិងសាសនាថា ៖ តាមហេតុការណ៍នៃប្រវត្តិសាស្ត្រទូទៅនៃសាសនា ពេលខ្លះការរីកចម្រើននៃសង្គមនិងសាសនានោះ មិនមានសន្ទានជាប់គ្នា មិនមានរបៀប ព្រមទាំងមិនមានកក្តីភាពផងទៀត ព្រោះពេលនៃការផ្តុំចូលគ្នានិងរួបរួមគ្នាខាងផ្លូវគំនិតត្រូវផ្លាស់វេនគ្នាជាមួយនឹងពេលវេលានៃការបែកចេញពីគ្នានិងការមិនស្របគ្នានៃផ្លូវគំនិត។ តែយ៉ាងណាក៏ដោយ គង់នៅមានការសំខាន់ខ្លះ ដែលជាមេគំនិតសម្រាប់ធ្វើជាបន្ទាត់នៃការស្រាវជ្រាវនិងពិនិត្យបានពុំខាន ព្រោះហេតុនោះ ការសិក្សាវិវឌ្ឍនភាពនៃសង្គមនិងសាសនា យើងមិនអាចមានការចាប់អារម្មណ៍ទៅលើតែធម្មជាតុថ្មីៗដែលមាននៅបច្ចុប្បន្នឬជាវត្តមានប៉ុណ្ណោះទេ គឺត្រូវតែយើងប្រើងភ្ជាប់ហេតុការណ៍ទាំងចាស់ទាំងថ្មី ហើយយើងទើបធ្វើការសរុបទៅប្រកបដោយហេតុផល និងវិទ្យាសាស្ត្របាន។ មិនតែប៉ុណ្ណោះ ហេតុការណ៍ទាំងចាស់ទាំងថ្មីនេះ គេត្រូវពិនិត្យតាមលក្ខណៈសង្គមនិងចិត្ត ថែមទៀត ដូចជាពិធីបូជាផ្សេងៗ មានការបូជាសត្វ វត្ថុ មានផ្កា-ទៀន ធូប ដល់ព្រះជាទីគោរពរបស់គេជាដើម។ ការធ្វើនេះតែង មានការជាក់ស្តែង និងផលវិបាកដល់សង្គមរបស់គេទាំងផ្នែកអង្គការសង្គម អង្គការសេដ្ឋកិច្ច អង្គការនយោបាយ និងអង្គការនៃគំនិតជាដើម។ ពិធីបូជាផ្សេងៗនោះ មានលក្ខណៈទាក់ទងដល់ជីវិតសង្គមដូចគ្នា ទោះជាពិធីបូជាតាមបែបសាសនាបូរាណក្តីសម័យក្តី។ អ្នកតំណាងនៃពិធីបូជាទាំងនោះ ច្រើនតែធ្លាក់ទៅលើបុគ្គលដែលមានអំណាច ឬឥទ្ធិពល ដូចជាមេរូបអារក្ស មេធ្មប់ មេអាប នាយកនៃក្រុម អ្នកមុខ អ្នកការ ស្តេច និងសន្តជនជាដើម។

២-ពិធីបូជាផ្សេងៗ ជាក្រុមឬជាការផ្ទាល់ខ្លួន ដូចជាសន្តតិវង្សបូជាជាដើម ដែលមានមេដឹកនាំជាប្រមុខ វត្ថុសម្រាប់បូជានិងវត្ថុផ្ទាល់ខ្លួនម្នាក់ៗនៃសង្គមជារបស់ព្រះទាំងអស់។ របស់ទាំងអស់ដែលមនុស្សក្នុងសង្គមប្រើប្រាស់ គេថាជារបស់ដែលព្រះប្រទានឱ្យទាំងជីវិតរបស់គេក៏ថាព្រះប្រទានឱ្យដែរ។ អ្នកតំណាងជានាយកនៃក្រុមក្តី ជាស្តេចក្តី ជាមេរូបអារក្សក្តី ត្រូវ

ប្រជាជនទាំងអស់ថែរក្សា គោរព និងផ្តល់វត្ថុសម្រាប់ចិញ្ចឹមជីវិតថែមទៀត ព្រោះគេយល់ថា គេទាំងឡាយនោះជាទូតឬជាមនុស្ស គឺព្រះជាម្ចាស់ចាត់មកមើលការខុសត្រូវនិងគ្រប់គ្រងក្រុម ពួកឬសង្គមជាដើមៗ ពួកទាំងអស់នោះ កាលបើគេតាំងឱ្យជាមេដឹកនាំក្នុងការបូជា ឬសាសន ពិធីក្លាយជាវង្សសំយោគសម្រាប់ក្រុម-ពួកឬសង្គមនោះៗជាដើម ឧទាហរណ៍បើឪពុកធ្លាក់ធ្វើជាមេដឹកនាំ ក្នុងរឿងនេះ កូនរបស់គាត់ បន្ទាប់ពីគាត់ស្លាប់ទៅ ក៏ទៅជាមេដឹកនាំក្នុងរឿងនេះជាស្វ័យប្រវត្តិ ពុំមានអ្នកណាម្នាក់ក្នុងក្រុម-ពួក ឬសង្គមហ៊ានតវ៉ាឡើយៗ ស្ថានការណ៍បែបនេះ មានបែបផ្សេងគ្នាពីសង្គមមួយទៅសង្គមមួយក្នុងលោកៗ ប៉ុន្តែតាមធម្មតា បើសង្គមណាមានទាំងអ្នកសាសនាយកគ្រប់គ្រង ទាំងមេដឹកនាំដែលមានអំណាចជាបុរោ-ហិតភាព ឬពួកបុរោហិត (Priest) ដែលមានអំណាចជាលោកិយ៍ ជាអ្នកគ្រប់គ្រង សង្គមនោះ តែងនាំទៅរកការប្រឆាំងដណ្តើមអំណាចគ្នាទៅវិញទៅមកជាដរាប ដូចជាការប្រឆាំងដណ្តើមអំណាចនៃព្រះវិហារ (Church) និងរដ្ឋនៅសតវត្សទី ១៥-១៦ នៃប្រទេសអង់គ្លេសជាដើមៗ ការប្រឆាំងគ្នាដណ្តើមអំណាច ច្រើនតែកើតឡើងដោយសារសេដ្ឋកិច្ច ឬប្រយោជន៍ទូទៅសម្រាប់ក្រុម-ពួករបស់ខ្លួនជាដើមៗ ទាំងនេះជាហេតុឱ្យមនុស្សក្នុងសង្គមតែមួយ បែកបក្សពួកគ្នា ប្រកាន់យកអំណាចក្នុងផ្លូវត្រូវទៅលើបញ្ហាសេដ្ឋកិច្ចនិងនយោបាយតែរៀងៗខ្លួនជាដើមៗ ដូចពោលមកក្នុងកថាខណ្ឌនេះ យើងគួរកត់សម្គាល់ថា ការរីកចម្រើនខាងសង្គមដល់ថ្នាក់នេះ បណ្តាលមកពីពិធីបូជាផ្សេងៗអនុវត្តឡើង ដោយអ្នកតំណាងម្នាក់នៃប្រជាជនក្នុងក្រុមឬពួក គឺអាចនិយាយដោយមានអ្នកតំណាងនៃក្រុមមួយ តំណាងឬទូតនៃព្រះជាម្ចាស់នៃក្រុមឬពួកមួយៗ

៣-នៅទីណាដែលក្រុមនិងវត្ថុស័ក្តិសិទ្ធិរបស់ក្រុមនោះៗ ដូចជារូបនិមិត្ត រូបនិមិត្តរបស់ក្រុម ទេវរូប កុលសម្ព័ន្ធជាដើមៗ គេបង្កើតឡើងជាអគ្គការតែមួយ ឬរួបរួមគ្នាជាផ្ទុំមួយនៅក្នុងអគ្គការតែមួយនៅទីនោះ ការជ្រើសរើសអ្នកតំណាង (នាយក ក្រុម បុរោហិត ឬជាស្តេច) ជាដើម តែងតែបង្កើតការកង្វល់ដល់អគ្គការនោះជាដរាបៗ ផលនៃការរីកចម្រើននេះ គេបានបង្ហាញយ៉ាងជាក់ច្បាស់ក្នុងសម្ព័ន្ធភាពផ្សេងៗរវាងប្រជាជន ឬប្រទេសអ្នកកាន់អំណាច ឬបុរោហិត និងព្រះអាទិទេពដូចជាសាសនាទាំងឡាយនៅក្នុងប្រទេសចិន ឥណ្ឌា អេហ្ស៊ីប បាប៊ីឡូនីជាដើម មានឧទាហរណ៍ច្រើនដែលជាផលវិបាកនៃស្ថានហេតុនោះៗៗ អ្នកអាជ្ញាកណ្តាលសម្រាប់ធ្វើការទាក់ទងរវាងប្រជាជននិងព្រះអាទិទេពៗ ម្យ៉ាងទៀត គេតែងទុកព្រះ

រាជាជាប្រភពនៃទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ហើយជាអ្នកទទួលរ៉ាប់រងសេចក្តីអន្តរាយឬភ័យដែលកើតឡើងដល់ប្រជារាស្ត្រ។ ព្រះអង្គជាតំណាងនៃមជ្ឈដ្ឋាន ដូចនេះ មានការចាំបាច់ជាច្រើនសម្រាប់ប្រជារាស្ត្រ ដើម្បីថែរក្សាការពារព្រះអង្គ ហើយគេបានទុកព្រះអង្គ ក្នុងទីដ៏ជាទីគោរពនិងស្ងាត់ ព្រមទាំងឱ្យមានក្រុមរក្សាព្រះអង្គថែមទៀត។ តាមពិតបុគ្គលម្នាក់ៗជាអ្នកតំណាង ទោះជាស្តេចឬបុរោហិតតែងចូលរួម ឬមានសម្ព័ន្ធភាពដ៏ជិតស្និទ្ធជាមួយនឹងព្រឹត្តិការណ៍នៃចក្រវាល ដែលការទិវង្គតរបស់ព្រះអង្គជូនកាលបណ្តាលឱ្យមានមហន្តរាយដល់លោកធាតុក៏មាន (Cosmical catastrophe)។ ទាំងនេះសឱ្យឃើញថា ព្រះអង្គជាអ្នកមានអំណាចឬមានបុណ្យ ដែលប្រជារាស្ត្រធ្លាប់មានជំនឿថាដូច្នេះ។ មិនមែនចំពោះព្រះរាជាទេ សូម្បីមេដឹកនាំដទៃទៀត ក៏ប្រជារាស្ត្រមានជំនឿទៅលើដែរ ឧទាហរណ៍នៅប្រទេសយើង ឥណ្ឌា ចិន អេហ្ស៊ីប ជាដើម ក៏មានហេតុការណ៍ជាច្រើនបានបញ្ជាក់រឿងនេះ។ មេដឹកនាំ ឬអ្នកតំណាងទាំងអស់នោះ មានឥទ្ធិពលខ្លាំងណាស់ទៅលើផ្លូវគំនិតនៃប្រជារាស្ត្រ គេតែងហៅមេដឹកនាំទាំងអស់នោះថា "ទូតរបស់ព្រះអាទិទេព" ចុះមកស្រោចស្រង់មនុស្សលោក។ គុណសម្បត្តិនៃមេដឹកនាំទាំងអស់នោះ តែងជឹតជាប់ក្នុងបេះដូងនៃប្រជារាស្ត្រ ឬ សាវ័កជានិច្ច។ គំនិតនេះមិនមែនទៅជាគោលការណ៍ត្រូវរីកចម្រើនតាមសង្គមលោកទេ គឺវាបានក្លាយពីពាក្យថា "កូនរបស់ព្រះម្ចាស់សួគ៌" មកជា "គ្រូរបស់មនុស្សនិងទេព្តា" វិញ, ដូចឧទាហរណ៍ព្រះពុទ្ធមហាវីរៈ ជាដើម[៥]។

តាមធម្មតានិងតាមការរីកចម្រើននៃសង្គម យើងសង្កេតឃើញថា មានអន្តរកិរិយារវាងឧត្តមគតិនៃបរមត្ថសច្ចៈនិងឧត្តមគតិនៃអ្នកតំណាង នៃការចាប់កំណើតទៀតជាដើម ដែលបណ្តាលឱ្យចរិយាល្អនិងអាក្រក់ នៃមនុស្សទាំងឡាយស្រូបយក ឬគ្របដណ្តប់លើឧត្តមគតិនៃមនុស្សអំពីរឿងអាទិទេពថាជាវត្ថុពិតឥតប្រែប្រួល ដូចជាការល្អនិងអាក្រក់ដែលមនុស្សទាំងឡាយរកឃើញក្នុងវត្ថុជុំវិញ បានមានឥទ្ធិពលទៅលើបញ្ញត្តិទាំងឡាយ (ខុងជឺ និង ឡាវសេ) ជាដើម។

៤-យើងបានសង្កេតឃើញច្បាស់ម្យ៉ាងទៀតថា ការចលនា និងការប្រែប្រួលវិចារណ៍នៃសាសនាទាំងឡាយក្នុងលោក បណ្តាលមកពីសម្ព័ន្ធការីរវាងក្រុមមួយទៅក្រុមមួយទៀត,

[៥] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ២៨

ការរីកចម្រើននៃអំណាចជាមជ្ឈមណ្ឌល (Central authority) និងការប្រែប្រួលជានិច្ចនៃប្រវត្តិសាស្ត្រ។

៥-ដើម្បីរៀបចំនិងរក្សាក្រុម ពួក កុលសម្ព័ន្ធ ឬសង្គមឱ្យមានសាមគ្គី ឯកភាពនៃការរួមរស់នៅជាមួយគ្នានិងការសុខសាន្ត យើងសង្កេតឃើញថា មានការចាំបាច់និងឧបាយជាច្រើនដែលជាគោលការណ៍នៃសាសនាទាំងឡាយ ទោះជាបញ្ញត្តិនៃព្រះម្ចាស់សួគ៌ក្តី ទោះជាឧត្តមគតិនៃទូតរបស់ព្រះម្ចាស់សួគ៌ក្តី អ្នកតំណាងក្តី ជាសីលធម៌នៃសង្គមក្តី បានប្រមូលរួបរួមគ្នាបង្កើតជាពិធីផ្សេងៗ ដូចជាពិធីបុណ្យខួបនៃអាទិទេវទូត បុណ្យខួបនៃមាតាបិតា និងបុណ្យទានផ្សេងៗជាច្រើន។ ពិធីទាំងអស់នេះ មានគោលបំណងតែមួយ គឺការរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីបម្រើឧត្តមប្រយោជន៍នៃក្រុម-ពួក កុលសម្ព័ន្ធសង្គមរបស់ខ្លួន។ ទាំងនេះជាគតិដើមបំផុតនៃការរួបរួមរវាងមនុស្សលោក ហើយគំនិតនេះស្ថិតនៅយូរទៅ ក៏ក្លាយជាទំនៀមទម្លាប់នៃសាសនារបស់ខ្លួនទៅ។ ត្រង់នេះសឱ្យឃើញថា ការរីកចម្រើនផ្នែកសង្គមនិងសាសនា តែងប្រព្រឹត្តទៅជាមួយ គ្នាជានិច្ចមិនដាច់ពីគ្នាឡើយ។

ជ-សម័យវិបត្តិ និងសម័យប្រែប្រួល ៖ ១-យើងសង្កេតឃើញថាការប្រែប្រួលនៃប្រវត្តិសាស្ត្រ តែងធ្វើឱ្យវិនាសនូវសាមគ្គី ឯកភាពនៃការរួបរួមគ្នា សេចក្តីសុខសាន្តនៃក្រុម ពួក កុលសម្ព័ន្ធ ឬសង្គមជាដរាប។ កាលបើមនុស្សបែកខ្ញែកគ្នាហើយ ផលប្រយោជន៍នៃគំនិត និងវិចារណ៍ដែលមានសាសនា ឬមនោគមវិជ្ជា ជាតំណាងក៏ត្រូវសាបសូន្យជាស្វ័យប្រវត្តិដែរ។ ការបាត់បង់នូវសាហារម្មណ៍ ការមិនមានអារម្មណ៍សាមគ្គីភាព ក្នុងវត្ថុបំណងរួមគ្នានិងប្រយោជន៍រួមគ្នានៃក្រុម-ពួកសង្គមជាដើម បណ្តាលមកពីការរីកចម្រើននៃអារម្មណ៍ក្នុងបុគ្គលនិយម (Individualism)។ រឿងនេះបានក្លាយទៅជាធម្មតារបស់សង្គមលោកទៅហើយៗអ្នកនៅក្នុងសង្គមវិទូបានចាត់ជាពេគនៃសង្គមតែម្តង។ ទាំងនេះបណ្តាលមកពីការរីកចម្រើននៃសង្គមតាមយុគសម័យ ហើយបើកាលណាការណ៍នេះបានកើតឡើងហើយខាងផ្នែកសាសនាឬខាងផ្លូវគំនិត ព្រមទាំងមនោគមវិជ្ជាសម័យថ្មីក៏ត្រូវប្រែរូបរាងដែរ។ ឯផ្នែកខាងសាសនា យើងសង្កេតឃើញថា បុគ្គលនិយមដែលមានកំណើតកើតបាន ក៏មានគ្រោះថ្នាក់ជាទីបំផុតដល់ការប្រែប្រួល ឬការសាបសូន្យនៃគោលគំនិតដើមរបស់លទ្ធិឬសាសនាក្នុងលោកដែរ។ បុគ្គលនិយមនេះ បណ្តាលឱ្យមានការផ្សេងគ្នារវាងសង្គមការងារ, ប្រាជ្ញានិងកិច្ចការដទៃទៀតជាច្រើន ហើយការរីកចម្រើនទាំងអស់នេះ នាំទៅរកការផ្សេងគ្នាខាងការ

វិនិច្ឆ័យផ្លូវគំនិតនិងប្រយោជន៍ជាដើម។ មិនតែប៉ុណ្ណោះវាអាចនាំបំបែកគំនិតចំពោះវត្ថុជុំវិញខ្លួនទាំងអស់តែម្តង។ ព្រោះហេតុនោះបានជាយើងសង្កេតឃើញថា គ្រប់សាសនាទាំងអស់ក្នុងលោកតែងមាននិកាយជាច្រើនទាំងនេះបណ្តាលមកពីហេតុដូចពោលខាងលើនេះ។ ដើម្បីជាថ្នាំកែរោគទាំងអស់នេះ មានអង្គការរួបរួមជាច្រើនក្នុងសាសនាមួយ ប៉ុន្តែជាការឥតប្រយោជន៍ទៅវិញ ព្រោះជំនឿនៃការក្សាក្រុមឬនិកាយរបស់ខ្លួន តែងស្ថិតនៅលើផ្លូវចិត្តនៃបុគ្គលម្នាក់ៗ យើងមិនអាចបង្ខំគេបានឡើយ បើយើងពោលតាមលក្ខណៈជាតិនិយម ឬក្រុមនិយមទៅវិញ ការបែកខ្ញែកគ្នាយ៉ាងនេះ នាំឱ្យមានគ្រោះថ្នាក់ជាទីបំផុតដល់អាយុជីវិតនៃរដ្ឋនិងសង្គម បើប្រសិនជាប្រជាពលរដ្ឋឬរដ្ឋាភិបាលបានចូលដៃនឹងនិកាយណាមួយ។ ជាការល្អ គួរយើងចេះការពារ ចៀសវាងការបែកខ្ញែកជាមុន ព្រោះរឿងនេះយើងអាចប្រៀបបាននឹងរោគរាតត្បាតដូចជា អាសន្នរោគឬរោគរបេងជាដើមដែរ។ មេរោគនៃសង្គមឬសាសនា ដ៏ធំបំផុតនោះ គឺបុគ្គលនិយមនេះឯង។

២-យើងសង្កេតឃើញថា គ្រប់យុគ គ្រប់សម័យទាំងអស់ ការមិនចុះសម្រុងគ្នាតែងនៅជាមួយឬតែងប្រព្រឹត្តទៅជាមួយនឹងជីវិតនៃសង្គម និងឧត្តមគតិជាគោលការណ៍ជានិច្ច។ ការមិនចុះសម្រុងគ្នានេះ តែងបើកផ្លូវទៅរកការបែកខ្ញែកគ្នាក្នុងសភាវៈគ្រប់ផ្នែកទាំងអស់នៃសង្គម ព្រមទាំងឱ្យផលអាក្រក់ដល់ស្ថានហេតុនៃសាសនាថែមទៀត។ ឧទាហរណ៍ ជំនឿ និងការប្រតិបត្តិនៃសង្គម និងសាសនាជាន់ដើមបានរលាយបាត់បង់ទៅ។ ការបាត់បង់ទៅនេះបណ្តាលមកពីការមិនចុះសម្រុងគ្នាខាងគំនិត ដែលនៅប្របូកប្របល់ក្នុងជីវិតសង្គមនិងសាសនាហ្នឹងឯង។ កាលបើដូច្នេះ សន្ទេហនិយម ឬវិចិកិច្ឆានិយម សម្មានិយមនិងទុទិដ្ឋិនិយម ក៏បានចូលមកគ្រប់គ្រងក្នុងជំនឿ និងការប្រតិបត្តិដើមរបស់ខ្លួនជំនួសវិញ។ មិនតែប៉ុណ្ណោះ វាអនុញ្ញាតឱ្យវប្បធម៌ និងអារ្យធម៌ថ្មី ចូលមកបង្កើតឥទ្ធិពលក្នុងគំនិត និងផ្លូវជីវិតនៃសង្គមនិងសាសនាថែមទៀត។ ដូចនេះ នៅពេលដែលមានស្ថានការណ៍ បែបនេះកើតឡើងនៅក្នុងសង្គមសាសនាណាហើយ យើងអាចពោលថាសង្គមនោះបានផ្លាស់ប្តូរ ឬប្រែពិភពលោកចាស់ទៅពិភពលោកថ្មីមួយទៀត ព្រោះគេតនភ័ណ្ឌវប្បធម៌របស់ខ្លួនបានបាត់បង់ទៅហើយៗ ទទួលយកវប្បធម៌ថ្មីមកជំនួសវិញ។

៣-បើកាលណាសាមគ្គីនៃក្រុម ពួកអ្នកសង្គមបានត្រូវរលត់រលាយហើយ ពួកល្មោភអំណាចក៏ត្រូវបានឱកាស ហើយគេឃោសនាបញ្ចុះបញ្ចូលតាមមនោគមវិជ្ជាផ្ទាល់របស់

គេ។ មិនយូរប៉ុន្មាន គំនិតនិងសកម្មភាពទាំងឡាយរបស់គេ និងក្លាយទៅជាវិសេសវិសាល និងប្រជាប្រិយភាពទូទៅក្នុងក្រុម ឬសង្គមមិនខានឡើយ។ ឧទាហរណ៍ដ៏ជាក់ស្តែងមួយក្នុងប្រទេសអេហ្ស៊ីបបានបញ្ជាក់ថា ៖ គេតែងជឿថា ស្តេចប្រទេសអេហ្ស៊ីបកាលណាចូលទិវង្គតហើយ ត្រូវតែចាប់កំណើតជាស្តេចប្រទេសអេហ្ស៊ីបវិញ។ ជំនឿនេះបានចាក់ឫសគល់ដ៏ជ្រៅនៅក្នុងដួងចិត្តនៃប្រជារាស្ត្រ។ ប៉ុន្តែពេលកលិយុគបានកើតឡើង គឺរាជត្រកូលត្រូវវិនាសសាបសូន្យ ការគ្រប់គ្រងរដ្ឋបានត្រូវធ្លាក់មកនៅក្នុងកណ្តាប់ដៃមនុស្សសាមញ្ញ។ ជំនឿដែលប្រជារាស្ត្រធ្លាប់បានជឿ ក៏ត្រូវប្រែក្លាយជាប្រការដទៃវិញ។ រឿងនេះជាការពិតណាស់ក្នុងប្រវត្តិសាស្ត្រនៃសាសនា។ តារាងខាងក្រោមនេះសម្រាប់បញ្ជាក់ហេតុការណ៍ខាងលើស្រាប់ និងហេតុការណ៍ដទៃទៀតកាលណាបើមានការបែកធ្លាយនៃរចនាសម្ព័ន្ធសង្គម ឬសាសនា ៖

| ទីដៅនៃការប្រតិបត្តិ | | | ការប្រតិបត្តិ |
|---|---|---|---|
| ១-តាមទីដៅ (Conformity) | – | – | តាមការប្រតិបត្តិ |
| ២-មិនតាមទីដៅ (Innovation) | + | – | តាមការប្រតិបត្តិ |
| ៣-តាមទីដៅ (Ritualism) | – | + | មិនតាមការប្រតិបត្តិ |
| ៤-មិនតាមទីដៅ (Retreatism) | + | + | មិនតាមការប្រតិបត្ត |
| ៥-បង្កើតទីដៅថ្មី (Rebellion) | +– | +– | បង្កើតការប្រតិបត្តិថ្មី |

សញ្ញាបន្ទាត់ត្រង់សម្រាប់សម្គាល់ថា ប្រព្រឹត្តតាមជំនឿដែលធ្លាប់បានជឿមក និងធ្លាប់ប្រតិបត្តិមក។ សញ្ញាកាកបាទ ឬជើងក្អែក សម្រាប់សម្គាល់ការប្រឆាំងនិងទីដៅ ព្រមទាំងការប្រតិបត្តិ។ ឯសញ្ញាជើងក្អែក ត្រួតលើសញ្ញាបន្ទាប់ត្រង់ សម្រាប់សម្គាល់ការបង្កើតទីដៅនិងការប្រតិបត្តិថ្មី។ តារាងនេះបានដៅបញ្ជាក់ហេតុការណ៍ដ៏សំខាន់មួយ គឺការបែកសាមគ្គីនៃពួកក្រុម សង្គម និងផ្លូវគំនិត។ កាលបើក្រុមចាស់បែកខ្ញែកគ្នាហើយ គេត្រូវតែបង្កើតក្រុម ពួក ឬសង្គម ឬក៏ផ្លូវគំនិតថ្មីទៀតជាដរាប។

៤-យើងគួរកត់សម្គាល់ថា កត្តាទាំងឡាយដែលនាំឱ្យបែកធ្លាយនិងប្រេះឆាសង្គមឬផ្លូវគំនិតនិងសាសនា កត្តាទាំងឡាយនោះឯងដែលនាំឱ្យក្លាយទៅ ជាមានការប្រកាន់ស្អិតនឹងទំនៀមទម្លាប់មិនអាចប្រែប្រួលបាន ហើយទាំងពីរនេះបង្កើតការរីកចម្រើនថ្មីៗ កាលសម័យនិងយុគថ្មីៗ ព្រមទាំងកងចក្រថ្មីសម្រាប់សង្គមនិងសាសនា។ ទាំងអស់នេះតែងរួមគ្នាជាធ្លុងមួយក្នុងឧត្តមគតិដ៏ជ្រាលជ្រៅជាទីបំផុត បង្កើតជាសការៈប្រកបដោយគ្រោះថ្នាក់ដល់សាមគ្គី

នៃសង្គមនិងសាសនា។ ប៉ុន្តែលក្ខណៈសំខាន់បំផុតក្នុងការប្រមូលផ្តុំសង្គមសាមគ្គី និង សាសនាថ្មីឡើងវិញនោះ មុនដំបូងកើតឡើងពីបុគ្គលមួយរូបៗ ក្រោយមកទើបប្រជារាស្ត្រ ផ្តើមធ្វើឱ្យមាន ការរីកចម្រើនជាលំដាប់តទៅទៀតដូចជា យើងបានដឹងច្បាស់ក្នុង ប្រវត្តិ សាស្ត្រនៃហិណ្ឌូនិយម (Induism) ពុទ្ធនិយម (Buddhism) គ្រិស្តនិយម (Christianism) ជាដើម។ សាសនាទាំងអស់នេះ មុនដំបូងកើតឡើងពីបុគ្គលពិសេស ឬមនុស្សអស្ចារ្យ (Charismatic men) ទេ ហើយក្រោយមកសាសនានោះៗ ក្លាយរបស់ប្រជារាស្ត្រ។ កាលបើដូច្នេះ សាសនានោះៗ ត្រូវតែធ្វើឱ្យស្របទៅនឹងថ្នាក់ឬស្រទាប់មនុស្ស ចិត្តអធ្យាស្រ័យនិងសេចក្តីត្រូវការនៃប្រជារាស្ត្រផ្សេងៗគ្នាច្រើនក្នុងសង្គមលោក។ និន្នាការនេះជាទិដ្ឋភាពទូទៅខ្លះនៃសាសនានិងជីវិត ហើយគេបានគិតឱ្យក្លាយទៅជាមានធុងតែមួយ ព្រមទាំងគេបានធ្វើឱ្យស្រប ប្រព្រឹត្តឱ្យស្របគ្នារវាងថ្មីនិងចាស់ គឺគេអាចនិយាយបានថា "ធ្វើសាសនាឱ្យជាសង្គមូបនីយកម្ម" ដែលផ្សេងស្រឡះពីសត្វទេវពិធី សីលពិធី និងទស្សនវិធីនៃជនអ្នកចេះមួយក្តាប់ (Selected Minds) (The Religion in Socialized one, as distinct form the theosophical, ethical or philosophical cults of select minds)។ គ្រប់ទីកន្លែងទាំងអស់ក្នុងលោក យុគនិងសម័យប្រែប្រួលទាំងអស់នោះ បានប្រាកដជាក់ស្តែងជាទីបំផុតសម្រាប់បុគ្គលអ្នកដឹកនាំម្នាក់ៗ និង ប្រជារាស្ត្រទូទៅទាំងពីរប្រភេទ។ បន្ទាត់ឬខ្សែនៃការរីកចម្រើន មិនដែលដាច់ស្រឡះពីគ្នាទេ គឺប្រទេសតែងមានការរៀបចំអង្គការថ្មីៗតាមយុគសម័យជានិច្ច ដូចជាប្រទេសឥណ្ឌា បាប៊ីឡូនី និងអេហ្ស៊ីបជាន់ដើមជាឧទាហរណ៍។ ពាក្យប្រៀនប្រដៅរបស់មេដឹកនាំសាសនា នៃប្រជារាស្ត្រអ៊ីស្រាអែល បានបង្កហេតុឱ្យមានការបដិវត្តយ៉ាងរហ័សនៅក្នុងសាសនា បុរាណរបស់ប្រជារាស្ត្រហ៊ីប្រ៊ូ ឯប្រទេសបាប៊ីឡូនីនិងអេហ្ស៊ីប ពាក្យប្រៀនប្រដៅរបស់មេដឹកនាំសាសនាគេបាននាំឱ្យមានការសុខស្ងប់រៀបរយដល់ប្រជារាស្ត្រទៅវិញ។ ប៉ុន្តែសតវត្សខាងក្រោយមក មានខ្សែបន្ទាត់នៃការរីកចម្រើនមួយត្រូវរលត់រលាយទៅវិញ គឺលទ្ធិហ្សូដ៍ ផ្នែកអ្នកបួសមួយបែប,តែលទ្ធិនេះបានរីកចម្រើនជាលទ្ធិថ្មីមួយទៀតជាមួយលទ្ធិគ្រិស្ត ហើយបានផ្សាយចេញទៅក្រៅប្រទេស។ លទ្ធិឥស្លាមដែលកើតឡើងអាស្រ័យមកពីការប្រឆាំងគ្នា រវាងលទ្ធិហ្សូដ៍និងពួកគ្រិស្ត។ លទ្ធិនេះមានសាសនបញ្ញត្តិផ្ទុយស្រឡះទៅនឹងលទ្ធិគ្រិស្ត និង លទ្ធិហ្សូដ៍ តែមានលក្ខណៈស្របនឹងផ្លូវចិត្ត និងវប្បធម៌នៃប្រជារាស្ត្រ។ មិនតែប៉ុណ្ណោះ លទ្ធិអ៊ិស្លាមនេះ មានកំណើតពីការប្រឆាំងគ្នារវាងសាសនាជាច្រើន មានលទ្ធិហ៊ីប្រ៊ូ និងលទ្ធិចាស់ ប្រទេសអារ៉ាប់ផងទៀត។ ព្រោះលទ្ធិនេះ មានការគោរពគ្នាជាច្រើន ហើយនិងមានសភាពផ្សេងៗគ្នាទៀត។

នៅពេលដែលការប្រឆាំងគ្នារវាងលទ្ធិហ្សូដ៍ និងលទ្ធិគ្រិស្តកើតឡើងដើម្បីរួបរួមប្រជារាស្ត្រឱ្យនៅក្នុងគ្រួសារតែមួយក្រោមព្រះអាទិទេពតែមួយគឺព្រះអាឡាហ៍(Allah)។ ជាពិសេសយើងគួរបញ្ជាក់ថា នៅពេលដែលលទ្ធិហ្សូដ៍និងគ្រិស្តផ្សាយពាសពេញនៅលើដែនដីអារ៉ាប់ហើយ លទ្ធិទាំងពីរនោះបានទទួល និងសម្រាប់តែពួកជនក្រុមអ្នកចេះដឹងនិងអ្នកគ្រប់គ្រងប៉ុណ្ណោះ ពុំបានផ្សាយដល់ប្រជារាស្ត្រទូទៅទេ។ ព្រោះហេតុនោះ បានជាមេដឹកនាំលទ្ធិអ៊ិស្លាម គឺ លោកមហាហ្មត់ បដិវត្តបង្កើតលទ្ធិឥស្លាមឡើង។ តាមពិតលទ្ធិឥស្លាម ប្រុងនឹងកើតឡើងមុនលទ្ធិហ្សូដ៍នឹងគ្រិស្តទៅទៀត ប៉ុន្តែពេលនោះកាលវេលាពុំទាន់ហុចឱ្យ។ លុះដល់លទ្ធិហ្សូដ៍និងគ្រិស្តបានផ្សាយចូលមក ហើយប្រជារាស្ត្រក៏បែកខ្ញែកជាច្រើនព្រោះ ឥទ្ធិពលនៃលទ្ធិទាំងពីរនេះ ក៏លទ្ធិអ៊ិស្លាមបានឱកាសបដិវត្ត និងបដិវត្តឡើង ប៉ុន្តែលទ្ធិអ៊ិស្លាម បានទទួលយកសាសនាប្បញ្ញត្តិនៃលទ្ធិហ្សូដ៍ និងគ្រិស្តមកប្រើប្រាស់និងអនុវត្ត។ មិនយូរប៉ុន្មាន លទ្ធិអ៊ិស្លាមក៏មានឥទ្ធិពលយ៉ាងខ្លាំងផ្សាយទៅគ្រប់ទីកន្លែងក្លាយជាប្រជាប្រិយភាពយ៉ាងឆាប់រហ័សជាទីបំផុត។ ការប្រែប្រួលបែបនេះ យើងសង្កេតឃើញ បានកើតឡើងនៅក្នុងប្រទេសឥណ្ឌា ចិន និងប្រទេសទាំងឡាយដទៃទៀតដែរ តែក្នុងស្ថានការតិចឬច្រើនជាងគ្នាតាមស្ថានហេតុនៃប្រទេស។

ឈ-ការជឿនលឿននៃផ្លូវគំនិត ៖ តាមលក្ខណៈទូទៅ យើងសង្កេតឃើញថា ការរីកចម្រើននៃសង្គមនិងសាសនា គេអាចឱ្យឈ្មោះតាមលក្ខណៈនៃការរីកចម្រើនឬការជឿនលឿននៃផ្លូវគំនិត ការបង្កើតអង្គការថ្មី និងការបែកធ្លាយនៃអង្គការរបស់សង្គមដែលស្រប នឹងឧត្តមគតិទាំងឡាយទោះជាច្បាស់លាស់ក្តី មិនច្បាស់លាស់ក្តីនៃជីវិតសង្គមនិងសាសនា។ ការពិសោធក្នុងជីវិត គឺជាគ្រូនៃមនុស្សលោក, របស់ចាស់ឬគំនិតចាស់ដែលកើតឡើងដោយស្នាដៃនិងស្នាគំនិតនៃមនុស្សលោកក៏ត្រូវបាត់បង់ទៅវិញ ប៉ុន្តែវាអាចជាជំនួយដល់គំនិតថ្មីដែរ។ ម្យ៉ាងទៀត ការច្នៃគ្នានៃវប្បធម៌ជាសភាវៈធម្មតានៃមនុស្សលោកដែរ។ ប្រវត្តិសាស្ត្រនៃសាសនាទាំងឡាយក្នុងលោកបានដៅយ៉ាងច្បាស់លាស់ក្នុងដំណើរនោះៗ។ ដូច្នោះ អ្នកសិក្សាសាសនាទាំងឡាយក្នុងលោក ត្រូវតែពិនិត្យរកដើមកំណើតនៃការរីកចម្រើននៃសាសនា និងស្ថានការណ៍នៃសង្គម ព្រមទាំងលក្ខណៈភូមិសាស្ត្រនោះៗ បានកើតឡើងផង។

ញ-គំនិតទាក់ទងជាមួយនឹងសាសនានិងមិនមែនសាសនា៖ ១-ដើម្បីពិនិត្យរកកំណើតនៃសាសនានៅពេលជាមួយគ្នានោះ យើងត្រូវពិនិត្យរកគំនិតដែលផ្ទុយពីសាសនាផង គឺ ការ

ផ្សេងគ្នានៃខ្សែគំនិត។ យើងគួរដឹងម្យ៉ាងទៀតថា ការសិក្សាសាសនាប្រៀបធៀប យើងមិនគ្រាន់តែទាក់ទងដល់សីលធម៌ អាទិទេពសម្ព័ន្ធ មោក្ខសម្ព័ន្ធ និងទស្សនវិជ្ជាប៉ុណ្ណោះទេគឺយើងត្រូវតែប្រៀបធៀបធម្មជាតិទាំងអស់នោះ នៃសាសនាមួយទៅនឹងសាសនាមួយទៀតផង។ ដូចនេះ យើងត្រូវតែពិនិត្យគំនិតផ្សេងៗ ដែលមិនមែនជាសាសនានៅក្នុងខេត្តនៃសាសនាមួយៗនោះផង ទើបការសរុបរបស់យើងមានលក្ខណៈពិតប្រាកដតាមបែបវិទ្យា-សាស្ត្រ។ ជំនឿនិងការប្រតិបត្តិនៃសាសនាតែងចង្អុលបង្ហាញគោលការសំខាន់ៗ ឧត្តមគតិការវិនិច្ឆ័យដែលសាសនាបានកំណត់ទុកជាគំរូ ហើយគោលការដ៏សំខាន់ ឧត្តមគតិ និងការវិនិច្ឆ័យនោះៗ គឺជាតំណាងនៃការពិសោធការសង្កេត និងការសញ្ជឹងត្រិះរិះនៃមនុស្សដែលប្រកបដោយចរិតផ្សេងៗគ្នា ព្រមទាំងមានផ្នត់គំនិតខុសៗគ្នាទៀតក្នុងប្រវត្តិនិងការរីកចម្រើនខាងផ្លូវគំនិត។ ការផ្សេងៗគ្នានៃចរិតរបស់មនុស្សម្នាក់ៗក្នុងលោកអាចប្រៀបបាននឹងគំនិតខាងសាសនា ទស្សនវិជ្ជា សីលធម៌ជាដើមដែរ។ នេះគឺជាសេចក្ដីសន្និដ្ឋាន។

២-ជាពិសេស ការពិនិត្យរកការផ្សេងគ្នានិងការស្របរវាងគំនិតសាសនា និងមិនមែនជាសាសនា យើងត្រូវសិក្សានិងពិនិត្យការប្រៀបធៀបគ្នាពីគោលការស្ដីពីពេលនមស្ការ និងសមាធិថែមទៀត។ ត្រង់នេះមានការទាក់ទងដល់ចេតសិកធម៌ដែលបុគ្គលម្នាក់ៗបានចម្រើននិងហ្វឹកហាត់ខ្លួនឯងដើម្បីរាវរកនិងវែកញែករក ចិត្តនិងចេតសិកណាដែលជាគ្រោះថ្នាក់នឹងចិត្ត ព្រមទាំងចេតសិកណាដែលបណ្ដាលឱ្យចិត្តស្ងប់រម្ងាប់ប្រាសចាកអារម្មណ៍ដែលជាសត្រូវ រាវរកនិងពិនិត្យហើយចម្រើនរកសច្ចធម៌ណាដែលចិត្តនៅក្នុងគោលការនៃជំនឿរបស់សាសនាពិតប្រាកដ។ ចិត្តនិងចេតសិកធម៌ ជាកាមាវចរៈ ចេះតែមានការប្រែប្រួលជាមួយនឹងការរីកចម្រើននៃបរិយេសនសង្ខារលោក (Artificial world) ។ លក្ខណៈចិត្តនិងចេតសិកដែលខ្ពង់ខ្ពស់ជាងនេះទៅទៀត គឺរូបលោក អរូបលោក និងលោកុត្តរៈ ត្រូវមានការរីកចម្រើនភាវនាឆ្លងកាត់ពីកាមាវចរៈ រូប អរូប ហើយចូលទៅកាន់លោកុត្តរៈទៀត ទើបបាន។ យើងត្រូវពិនិត្យឱ្យច្បាស់លាស់ហើយដោយប្រុងប្រយ័ត្នផង ក្នុងចិត្តសម្បទានោះៗតាមមាគ៌ា ទីដៅ និងផលនៃការចម្រើន។ សាសនាព្រាហ្មណ៍និងពុទ្ធសាសនា បានលើកយកផ្លូវចិត្តនិងចេតសិកធម៌នេះជាបញ្ហាពិសេស ហើយសិក្សានិងពិនិត្យដោយហ្មត់ចត់ជាទីបំផុត ។ ដើម្បីពិនិត្យរកកំណើតនៃមាយានិងមោហៈ ដែលជាប់ជំពាក់នឹងវត្ថុកាមនិងកិលេសកាមដែលជាសភាវៈជាប់មកជាមួយជីវិត សត្វលោក គេយកចិត្តវិទ្យា និងទស្សនវិជ្ជាជាកញ្ចក់

សម្រាប់ចុះមើល ហើយរៀបជាច្បាប់និងធម៌តាមលក្ខណៈ និងប្រក្រតីនោះ។ ច្បាប់តាំងធម៌ទាំងពីរនេះ គេបានរៀបចំឡើងក្រោមមូលដ្ឋាម ២ ប្រភេទគឺ ៖ ១-វាំងខ្ជួន មនុស្សនិងចិត្ត ឬខ្ជួនមនុស្សខាងក្រៅនិងខាងក្នុង, ២-លោកលក្ខណៈ និងបរមត្ថធម៌ ក្នុងមូលដ្ឋាននៃខ្សែគំនិតទាំងពីរនេះ សាសនាព្រាហ្មណ៍បានរកឃើញបរមត្ថធម៌ រូប អាត្ម័ន និងមោក្ស ឬព្រហ្ម័ន, ឯព្រះ ពុទ្ធសាសនាបាន រកឃើញចិត្ត ចេតសិកនិងនិព្វាន។ ក្នុងមូលដ្ឋានដដែលនេះ ខ្សែគំនិតអឺរ៉ុប រកឃើញ ៖ ផ្ទះឬកន្លែងនៃចិត្ត (Spiritual Home)។ ឯក្រិក គេបានរកឃើញមូលដ្ឋានទាំងពីរខាងលើនោះថា សភាវៈដ៏ខ្ពង់ខ្ពស់ជាងលោកនេះស្ថិតនៅលើការចម្រើនភាវនាយ៉ាងណាក៏ដោយខ្សែគំនិតរបស់អឺរ៉ុប ឬបស្ចឹមប្រទេសនិងបូព៌ាប្រទេសមានដំណើរខុសគ្នាស្រឡះ ហើយយើងមិនអាចរកឯកភាពក្នុងស្ថានហេតុនេះបានឡើយ ហើយកាលបើមូលដ្ឋាននៃគំនិតខុសគ្នា គំនិតសាសនានិងមិនមែនសាសនាក៏មានដំណើរខុសគ្នាដែរ។ ការពិសោធរបស់ពួកបូព៌ាប្រទេសដើម្បីជីវិតនៅលើលោកនេះនិងលោកកុត្តរៈ ច្រើនតែមិនធ្វើឱ្យផ្សេងគ្នា គឺច្រើនតែមិនលើកយកធម្មជាតុមកធ្វើការពិសោធឱ្យដាច់ស្រឡះពីគ្នា។ ឯបស្ចឹមប្រទេស ការពិសោធគេច្រើនតែលើកយកធម្មជាតុមួយៗ មកធ្វើការពិសោធជារបៀបឯកោសកម្ម និងវិទ្យាប្រយោគ។

៣-មិស្សភាពនៃគំនិត អាស្រ័យនិងស្របជាមួយនឹងមិស្សភាពនៃរចនាសម្ព័ន្ធនៃចិត្តរបស់បុគ្គលម្នាក់ៗ ឬឯកត្តជនដែលមានលក្ខណៈចិត្តខ្ពង់ខ្ពស់ជាងគ្នា ហើយមានថ្នាក់ចិត្តខុសគ្នាទៀត។ ការតម្រៀបធម្មជាតុទាំង អស់ទោះជាមិស្សភាពក្តី មិនមែនក្តី ច្បាប់ សីលធម៌ ឬចរិយាសាសនាជាដើម គឺជាលទ្ធផលនៃការរីកចម្រើន ព្រោះថាមិនមែនស្ថិតនៅជានិច្ចឡើយ។

ជ-ការផ្សេងគ្នានៃស្ថានការណ៍សង្គមសាសនាសកលលោក ៖ ១-អាស៊ី ៖ ក្នុងវគ្គនេះ យើងពិនិត្យស្ថានការណ៍ខុសគ្នានៃប្រទេស ឬទ្វីបដែលមានការផ្សេងគ្នានៃសង្គមនិងវប្បធម៌ ហើយការផ្សេងគ្នានេះបង្កើតជាសាសនាខុសៗគ្នាថែមទៀត។ ដូចនេះ បានជាយើងឃើញថា សាសនាគ្រិស្ត មហាហ្ម័ត ព្រះពុទ្ធសាសនា សាសនាហិណ្ឌូ ឬព្រាហ្មណ៍ និងសាសនាសាកលនិយមចិន សាសនាមួយៗ បង្កើតជាសង្គមសាសនាដ៏ធំមួយៗ ហើយមានសេដ្ឋកិច្ចសង្គម និងវប្បធម៌ផ្សេងៗគ្នាទៀត។ សាសនាទាំងអស់នេះ មានកំណើតនៅអាស៊ីយើងនេះ ប៉ុន្តែខាងក្រោយមកបានផ្សាយពាសពេញនៅអឺរ៉ុប អាហ្វ្រិក និងអាមេរិកថែមទៀត។

យើងអ្នកសិក្សា ត្រូវតែសិក្សារកកំណើតរបស់សាសនាទាំងអស់នេះនៅកន្លែងកំណើត និងនៅតាមប្រទេសមួយៗ ហើយបង្កើតការផ្សេងគ្នាទៅតាមស្ថានភាពនៃប្រទេសនោះៗ។

សាសនាហិណ្ឌូបែកជាច្រើននិកាយហើយមានលក្ខណៈផ្សេងៗគ្នាទៀត ប៉ុន្តែតាមលក្ខណៈនយោបាយ សាសនារួបរួមគ្នាដោយអំណាច សាសនានេះមិនបានផ្សាយទៅណាឡើយ , កើតនៅតែក្នុងប្រទេស លេចអណ្តែតក៏នៅតែមួយកន្លែង។ សាសនាខុងជឺ មានលក្ខណៈសីលធម៌និងនយោបាយរួបរួមគ្នាតែមួយ។ សាសនាហិណ្ឌូ ខុងជឺ មានបែបជាឯកភាពជាតិ។ ឯសាសនាអ៊ិស្លាម ពុទ្ធសាសនា និងសាសនាគ្រិស្ត បានផ្សាយពាសពេញសកលលោក[៦]។

ការផ្សេងគ្នាតាមលក្ខណៈជាតិនីមួយៗនៃការប្រតិបត្តិនិងការគោរព ព្រមទាំងនាំជំនឿនៃសាសនាទាំងអស់នោះ បានរីកចម្រើនឡើងរាល់ពេល ហើយមានឥទ្ធិពលទៅក្នុងគំនិតវិចារណ៍ ការគោរព និងអង្គការនៃជាតិនោះៗថែមទៀត។

មិនមានការលំបាកជាច្រើនក្នុងការរាវរកលក្ខណៈតាមវប្បធម៌ សង្គម និងចិត្តសាស្ត្រវាងសាសនា បុរាណនិងសាសនាដ៏ខ្ពង់ខ្ពស់ប៉ុន្មានទេ ប៉ុន្តែចំពោះសាសនាដ៏ខ្ពង់ខ្ពស់ដូចគ្នាវិញ យើងមិនអាចធ្វើតាមបែបខាងលិចនេះដោយងាយឡើយ ព្រោះសាសនាទាំងអស់នោះមានការកែទម្រង់ជាច្រើនលើកច្រើនគ្រាតាមយុគ្គនិងសម័យ។ ចំពោះសាសនាខុងជឺ យើងមានការសង្ស័យយ៉ាងខ្លាំងថាតើមានការប្រែប្រួលនិងការកែទម្រង់ឱ្យទៅជាសាសនាសម្រាប់អ្នកចេះដឹងឬអ្នកអានឬ? ចំណែកសាសនាអ៊ិស្លាមជាសាសនាសម្រាប់អ្នកចម្បាំង និងចំពោះពុទ្ធសាសនាវិញ ជាសាសនាសម្រាប់បញ្ញវន្ត។ នេះគឺគ្រាន់តែជាគំនិត ដែលប្រាសចាកការពិនិត្យ និងការពិសោធប៉ុណ្ណោះទេ។ សេចក្តីពិត ទោះណាជាសាសនាទាំងអស់នោះមានឥទ្ធិពលខាងនយោបាយនិងសង្គមទៅលើការគោរពបូជា និងខ្សែគំនិតនៃជាតិនោះៗក៏ដោយ យើងសង្កេតឃើញថា ៖ ឥទ្ធិពលនេះមាន ព្រំដែនមិនទូលំទូលាយដូចដែលយើងបានស្មាននោះទេ ព្រោះគ្មានសាសនាធំៗណាមួយសម្រាប់តែពួកអ្នកមាន អ្នកក្រ ថ្នាក់កណ្តាល ឬក៏ពួកកម្មករឡើយ។ ឧទាហរណ៍ ៖ ដូចជាព្រះពុទ្ធសាសនា មានការផ្សេងគ្នាយ៉ាងខ្លាំង ក្នុងសង្គមធម៌និងសេដ្ឋកិច្ច ជាពិសេសនៅក្នុងក្រុមមហាយាននិកាយជាមួយគ្នា។ ប៉ុន្តែសាសនាធំៗទាំងអស់ទោះមាននិកាយច្រើនយ៉ាងណាក៏ដោយក្នុងនិកាយមួយៗនោះ តែងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទម្រង់នៃសង្គមជាដរាប។ កាលណានិកាយនោះបានរីកចម្រើនហើយ នៅ

---

[៦] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ៣៥

ក្នុងសង្គមនីមួយៗក៏ផ្ដើមរួបរួមប្រជារាស្ត្រ ភាគច្រើននៃជាតិនីមួយៗនៃប្រទេសក្នុង សកលលោក រួចហើយប្រជារាស្ត្រក៏បែកជាក្រុម ជាពួក បណ្ដាលឱ្យមានការផ្សេងគ្នាខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ទូទៅ។ សភាវៈថ្មីៗទាំងឡាយនៃបញ្ញត្តិ ការប្រតិបត្តិ និងការអនុវត្ត ក៏បានរីកចម្រើនឡើងស្របនឹងស្ថានការណ៍ នៃសេចក្ដីត្រូវការនិងគ្រឿងប្រុងនៃសង្គម។ ទាំងនេះ គឺជាការធម្មតានៃវប្បធម៌ និងសាសនាក្នុងលោក។

ទិដ្ឋភាពទាំងឡាយនៃសាសនាគ្រិស្ត អ៊ិស្លាម ហិណ្ឌូ និងពុទ្ធ មានការកែសម្រួលជាច្រើនលើកច្រើនគ្រា តាមសម័យដែលសាសនានោះៗបានរីកចម្រើននិងមានឥទ្ធិពល។ មានការផ្សេងគ្នាជាច្រើនរវាងអ៊ិស្លាមនៃសិស្សគុណជាដំបូង នៃមេដឹកនាំសាសនារបស់ពួកអារ៉ាប់និងអាប់បាសែដ៍ កាលិហ្វាត ដែលមានវប្បធម៌យ៉ាង ពិសេសរវាងអ៊ិស្លាមរបស់រដ្ឋបរអាហ្វ្រិកខាងជើង ឬរាជាណាចក្រក្នុងរដ្ឋសូដាន និងរាជាណាចក្រ អ៊ុតតូម៉ាន នៃសតវត្សទី ១៩ រវាងអ៊ិស្លាមនៃសេរីថ្មី និងអេហ្ស៊ីប, ដទៃពីនេះ រវាងអារាប៊ី សាអូឌីត និងអាហ្គានីស្ថាន។ ម្យ៉ាងទៀតរវាងប្រទេសនិងសម័យដែលជាសាសនាអ៊ិស្លាមបានរីកចម្រើនឡើងក្នុងលក្ខណៈដើមដ៏បរិសុទ្ធនៃសាសនា ហើយប្រជារាស្ត្រភាគច្រើនបានគោរពនិងបូជា។ ពាក្យណែនាំនិងពាក្យប្រៀនប្រដៅរបស់មហាហ្មុត គឺមានលក្ខណៈត្រង់ៗ និងមានឥទ្ធិពលជាទីបំផុត។ ឯផ្លូវគំនិតនិងសីលធម៌ក៏មានការតឹងតែង មានបែបផែនជាទីបំផុតដែរ។ ជាពិសេសចំពោះសង្គមសាសនាមហាហ្មុត មានទ្រឹស្ដីប្រកបដោយពិសិដ្ឋភាពជាទីបំផុត ប៉ុន្តែមិនអាចអនុវត្តបានទាំងអស់ចំពោះកិច្ចការសង្គមឡើយ។

តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត សាសនាអ៊ិស្លាមបានបង្ហាញថា អាចកែប្រែនិងអនុវត្ត ទៅក្នុងគ្រប់ស្ថានហេតុទាំងអស់បាន។ នៅក្នុងបែបគ្រប់គ្រងសង្គម សាសនាអ៊ិស្លាម មានបែបរដ្ឋាភិបាលជាច្រើន ហើយក្នុងបែបមួយៗនោះ គេបានរួបរួមបញ្ចុះបញ្ចូលកិច្ចការអាជីវកម្មជាច្រើន ដូចជាសម្បត្តិ និងឋានៈ ស័ក្ដិជាដើម។

សាសនាហិណ្ឌូ មានលក្ខណៈជាផ្លូវប្រព័ន្ធសង្គម និងសាសនា ជាងសាសនាអ៊ិស្លាមទៅទៀត ដែលបានរីកចម្រើនឡើងតាំងពីសង្គមនៅជាសាមញ្ញរហូតដល់សង្គមមានលក្ខណៈប្រកបដោយរចនាសម្ព័ន្ធដែលកម្រិត និងខណ្ឌដោយវណ្ណៈទាំង៤, បុរាណវត្ថុនិយម និងបរម្បរានិយមជាទីបំផុត។ ប៉ុន្តែយើងសង្កេតឃើញថា ក្នុងការអនុវត្តសាសនានេះមានសភាពផ្ទុយនឹងសភាវៈពិត ដែលសង្គមត្រូវការទៅវិញ។ នៅក្នុងសាសនានេះ មានការផ្សេងគ្នាខាង

ផ្លូវគំនិត ទំនៀមទម្លាប់ និងអង្គការទូទៅនៃសង្គម ច្រើនជាអនេកប្បការ។ មិនមានប្រទេសណាក្នុងលោក មានថ្នាក់អ្នកមាននិងអ្នកក្រដាច់ស្រឡះពីគ្នាដូចជាប្រទេសឥណ្ឌាឡើយ។ គំនិតខាងលោកធាតុ សីលធម៌ ច្បាប់សម្រាប់គោរពបូជា ការផ្សេងគ្នានៃឋានៈ កិត្តិយស និងកេរ្តិ៍ឈ្មោះ តែងមានមូលដ្ឋានទៅលើធម្មប្បញ្ញត្តិនៃហិណ្ឌូ ប៉ុន្តែមានលក្ខណៈសំខាន់ខាងប្រវត្តិសាស្ត្រ បរមត្ថធម៌ និងសាសនាដ៏ជាក់ច្បាស់។ នៅសម័យនេះ ឥណ្ឌាមានរបៀបគ្រប់គ្រងឥតមានទាក់ទងដល់លក្ខណៈសាសនាទេ គេហៅថាគ្រហស្ថនិយម ព្រោះសាសនាបានធ្វើឱ្យអន្តរាយដល់កេតនកណ្ឌឯករាជ្យជាតិអស់ពេលជាច្រើនសតវត្ស។ ការគ្រប់គ្រងប្រកបដោយគ្រហស្ថនិយម បានក្លាយជាស្ថាប័នសម្រាប់ជាតិឥណ្ឌាទាំងមូលសព្វថ្ងៃនេះ។ ទាំងអស់នេះគឺ បណ្តាលមកពីបញ្ហាសេដ្ឋកិច្ចសង្គម និងនយោបាយ ទើបគ្រហស្ថនិយមគេបានរៀបចំឡើងតាំងពីក្នុងរយៈ ពេលដែលប្រទេសឥណ្ឌានៅក្រោមអាណានិគមនៃប្រទេសអង់គ្លេស និងសព្វថ្ងៃនេះ។ ស្ថានហេតុទាំងអស់នេះ បានឱ្យកម្លាំងដល់សាសនាប្រឆាំងនឹងសាសនាហិណ្ឌូ ដូចជាព្រះពុទ្ធសាសនានិងសាសនាជេនជាដើម។ ប៉ុន្តែសាសនាទាំង២នេះ ក៏បាន បែកជានិកាយជាច្រើន ហើយមានការផ្សេងគ្នាខាងទម្រង់នៃសង្គម នយោបាយ និងសេដ្ឋកិច្ច[៧]។

២-អឺរ៉ុប ៖ សាសនាក្នុងលោកដែលយើងបានពោលហើយទាំងអស់ គឺសុទ្ធតែជាសាសនាដែលមានកំណើតក្នុងទ្វីបអាស៊ី ការរីកចម្រើន ការចាំបាច់ បានមានសម្ព័ន្ធភាពទៅនឹងរូបនិយម សរីរភាព ចិត្តភាព នយោបាយ វប្បធម៌ សេដ្ឋកិច្ច បច្ចេកវិទ្យា សង្គម និងចរិយាសាស្ត្រ ជារបៀបអាស៊ី។ បស្ចិមប្រទេសរួមទាំងរុស្ស៊ីផង មានទីដៅនៃជីវិតផ្សេងគ្នា ការផ្សេងគ្នានេះបានផលិតលក្ខណៈស្ថានភាពផ្សេងគ្នាស្រឡះពីបូព៌ាប្រទេស។ ទីដៅនៃសាសនាគ្រិស្តបានចាក់ឫស យ៉ាងមាំនៅលើផែនដីនៃបស្ចិមទិស ហើយមានអារ្យធម៌រីក ចម្រើនក្លាយទៅជាមូលដ្ឋានដ៏សំខាន់នៃសង្គមសាសនាគ្រិស្ត។

ក្រិកចិន្តានិងស្ថាប័នរ៉ូម បានរួបរួមគ្នាបង្កើតជាវប្បធម៌មួយយ៉ាងវិសេស បានស្ថិតនៅសព្វថ្ងៃឬចាក់ឫសគល់នៅប្រទេសអ៊ីតាលីនិងអាល្លឺម៉ាញ។ យើងអាចចែកការរីកចម្រើននៃគំនិតសាសនាជា ៣ ផ្នែកគឺ ៖

[៧] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ៣៧

១-ការរីកចម្រើននៃគ្រឹះសង្គមជាដំបូងគឺសម្រេចដោយស្ថានការណ៍សង្គម សេដ្ឋកិច្ច វប្បធម៌នៃអាណាចក្ររ៉ូម ដែលបាត់បង់ទៅហើយ ហើយគ្រឹះសង្គមបែបថ្មីក៏មានកំណើតឡើងខ្លួនឯង។

២-ការរីកចម្រើននៃគ្រឹះសង្គមជាបន្តមកទៀត គឺសម្គាល់ដោយការស្ថាបនាលទ្ធិសក្តិភូមិនៃអឺរ៉ុប ជំនាន់កណ្តាល "គ.ស.១០០០ ទៅ ១៤០០ ឬ គ.ស.៥០០ ទៅ ១៥០០" ដែលបណ្តាលឱ្យសង្គមចែកថ្នាក់ ប្រជារាស្ត្រដូចជាវណ្ណៈនៅប្រទេសឥណ្ឌាដែរ។ សាសនាគ្រិស្តបានលាតត្រដាងឥទ្ធិពលដល់ប្រជារាស្ត្រគ្រប់ស្រទាប់នៅពេលនោះ ដែលប្លែកគ្នាស្រឡះពីជំនាន់អាណាចក្រសម័យមុន ហើយពេលនោះសាសនាគ្រិស្តជាសាសនាសម្រាប់តែប្រជារាស្ត្រថ្នាក់ខ្ពស់តែប៉ុណ្ណោះ។ ជាពិសេស គេមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះឥទ្ធិពលនៃសាសនាគ្រិស្តទៅលើប្រជារាស្ត្រគ្រប់ជាន់ថ្នាក់ ហើយឥទ្ធិពលនេះ គេបានទទួលស្គាល់ក្នុងពេលដែលសាសនានេះគេទុកជាសាសនាសម្រាប់រដ្ឋ។ តាមពិតកត្តាថ្មីៗទាំងឡាយ គេបានរួមបញ្ចូលក្នុងស្ថានការណ៍សង្គមទូទៅតាំងពីពេលដែលគេបានបញ្ចូលសាសន៍ពួលកុលសម្ព័ន្ធអាល្លឺម៉ង់ ហើយនិងសម័យលទ្ធិសក្តិភូមិនៃសង្គមអឺរ៉ុប។ ថ្នាក់ជាន់ខ្ពស់នៃសង្គមជំនាន់នោះ ព្រមទាំងអង្គការអាជីវកម្ម សេដ្ឋកិច្ចនិងសង្គម គេបានចុះឃើញយ៉ាងជាក់ច្បាស់ក្នុងពេលធ្វើការគោរពបូជានិងការប្រជុំនៃសាសនា។ សូម្បីមានជំនឿតែមួយ ការគោរពបូជាវត្ថុតែមួយក៏ដោយ ក៏សាសនបញ្ញត្តិ និងសាសនប្បតិបត្តិនៃពួកសេនាបតី អ្នកបួស អ្នកជាំជំណាំគ្រប់ប្រភេទ ព្រមទាំងកម្មករមិនមានការស្របគ្នាទាល់តែសោះ។ ការរីកចម្រើននៃទ្រឹស្តីអាណាព្យាបាលដ៏ពិសេស និងការថែរក្សា គោរពដល់ស្ត្រីព្រហ្មចារីនិងអ្នកស្ងប់បានបង្កើតជាក្រុមអាជីវកម្មមួយក្រុមឡើង ការស្មោះស្ម័គ្រចំពោះព្រះអាទិទេពក៏ក្លាយទៅជាសភាវៈដែលនៅក្រោមបញ្ជានៃពួកសក្តិភូមិនិងអ្នកគ្រប់គ្រងផែនដី។ ពួក ក្រុមអាជីវកម្មក៏បានបំពេញមុខងារជាក្រុមមានឯកភាពខាងការគោរពបូជា ហើយអង្គការថ្មីៗទាំងឡាយដូចជាក្រុមអ្នកមានស្វាមីភ័ក្តិ អ្នកមានចិត្តជាអ្នកសាសនា អ្នករចនា អ្នកសង្គម គេបង្កើតឡើងសម្រាប់គោលបំណងនៃសាសនា សាសនាគ្រិស្តជាផ្លូវការ និងសម័យកណ្តាល បានចុះបង្ហាញនូវគោលបំណងនៃទេសកជន ២ ក្រុម គឺពួកសេនាបតី និងពួកអ្នកបួស។ នៅពេលដែលពួកមូលធន

បានរីកចម្រើនឡើង ធម្មជាតុទាំងឡាយរូប រួមទាំងជីវិតក្នុងវត្តក៏បានកើតឡើង សម្រាប់អ្នកក្រុង[៨]។

៣-នៅទីបំផុតនៃសម័យអ្នកកណ្តាល មានប្រជារាស្ត្រមួយក្រុមទៀតបានរួបរួមចូលក្នុងក្រុមទាំងពីរនេះដែរ គឺពួកអ្នកស្រែ ដែលជាបុគ្គលញ៉ាំងសាសនាគ្រិស្តឱ្យបានរីកចម្រើនឡើង។

៤-ការរីកចម្រើននៃលទ្ធិនិងសាសនានីមួយៗ ៖ ក-ព្រហ្មញ្ញលទ្ធិបានរីកចម្រើនតាំងពីខាងដើមនៃការរុករានស្រុកនៃពួកអារ្យ៉ន ប្រហែលមុនគ.ស.១៧០០ (B.C.1700) រហូតដល់សព្វថ្ងៃនេះ យើងរួបរួមការរីកចម្រើននៃលទ្ធិនោះដូចតទៅនេះ ៖

១-ក្នុងបុព្វប្រវត្តិសាស្ត្រយើងពុំបានដឹងថាការរីកចម្រើននោះមានដំណើរដូចជាប្រទេសទាំងឡាយក្នុងលោកដែរ ឬពុំមែនទេឡើយ។

២-នៅសម័យដ្រាវិទ (Dravid) រាតត្បាតក៏យើងបានដឹងតិចតួចណាស់ដែរ សូម្បីតែបានជីកកកាយរកឃើញត្រង់មាត់ទន្លេសិន្ធូនូវបុរាណវត្ថុជាច្រើនហើយគេបានសន្និដ្ឋានថាបុរាណវត្ថុទាំងអស់នេះ បានឧប្បត្តិឡើងតាំងពីមុន គ.ស.៣០០០ ឆ្នាំក៏ដោយ។ ម្យ៉ាងទៀតគេបានបញ្ជាក់ថាសម័យនោះ គឺសម័យអារ្យធម៌ (Mahinjodaro) បុរាណវត្ថុដែលបានជីកត្រង់ទីក្រុងបណ្តាយប្រហែលជា ១០០ម៉ែត្រ នៅមាត់ទន្លេសិន្ធុ នោះ។

៣-នៅសម័យវេទនៃពួកអារ្យ៉ន ដែលបានឈ្នះសង្គ្រាមលើប្រជារាស្ត្រ Dravid ព្រមទាំងជាអ្នកពង្រីកអំណាចទឹកដីពីមុនគ.ស.៨០០ ដល់គ.ស.១៥០០ (សម័យវេទ)។

៤-នៅសម័យព្រាហ្មណ៍ពីមុនគ.ស.៥០០ ដល់៨០០ ស្ថាប័ននៃពួកព្រាហ្មណ៍កំពុងតែរីកចម្រើនសម័យ ព្រាហ្មណ៍។

៥-នៅសម័យទស្សនវិជ្ជា ពីមុនគ.ស.១០០ទៅ ៥០០ ហើយសាសនាជេននិងពុទ្ធសាសនាក៏រីកចម្រើន ជាបន្តបន្ទាប់គ្នា។

៦-នៅសម័យអវតារៈ ជាសម័យដែលទាក់ទងមកពីសម័យខាងដើមមក គឺតាំងពីមុនគ.ស.២០០ដល់គ.ស.៥០០រួមបញ្ចូលទាំងការផ្សាយចូលមកនៃលទ្ធិគ្រិស្ត(គ.ស.៤២៨ ផង)។

៧-សម័យការរុករាននៃពួកលទ្ធិអ៊ិស្លាមពី គ.ស.៦៦៤ ទៅ ១២០៦ ហើយបន្តមកទៀតដរាបដល់សតវត្សទី១៩ នៃគ.ស.គឺនៅពេលនៃការស្ថាបនា (Mughal) ចក្រពត្តិ។

---

[៨] ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ៣៨

៨-នៅសម័យកក្តិសន្តជន លទ្ធិបែបនេះបានរីកចម្រើនតាំងពីសតវត្សទី១៣-១៩ នៃ គ.ស.។

៩-នៅសម័យឥទ្ធិពលអឺរ៉ុប ចាប់តាំងពីអាណានិគមពួកព័រទុយហ្គេនៅទីបំផុតនៃសតវត្សទី១៥ រហូតដល់សព្វថ្ងៃនេះ កត្តាចាស់ៗនិងថ្មីៗជាច្រើនបានលាយច្របល់គ្នា។

លទ្ធិព្រាហ្មណ៍បានរីកចម្រើនតាំងពីទី១ដល់ទី៨ ប៉ុន្តែពីទី៥ដល់ទី៨ លទ្ធិព្រាហ្មណ៍បានរីកចម្រើនលាយច្របល់ជាមួយនិងពុទ្ធសាសនា និងសាសនាជេន។ តាមពិត ការរីកចម្រើនរបស់សាសនានេះ បានកម្រិតជាក់ច្បាស់ត្រឹមសម័យឧបនិសាដ គឺសម័យត្រឹមព្រះពុទ្ធសាសនាកើតឡើង។ ការរីកចម្រើននៃហិណ្ឌូទស្សនៈ និង អវតារសម័យ បានមានឥទ្ធិពលរហូតមកដល់សព្វថ្ងៃ ព្រោះហេតុនោះ គម្ពីរឧបនិសាដ គម្ពីរបូរាណទាំងឡាយ ដូចជា រាមាយណៈ មហាភារតៈជាដើម។ ភគវាដគីតា និងស្លោកកក្តីជាដើម អាចបង្កើតជាមូលដ្ឋាននៃវប្បធម៌សម្រាប់អ្នកចេះដឹង ឬអ្នកប្រាជ្ញឥណ្ឌាសម័យថ្មី។ ប៉ុន្តែទាំងអស់នេះ បាននៅក្រោមឥទ្ធិពលនៃសាសនាជេន ពុទ្ធសាសនា និងហិណ្ឌូកក្តិទស្សនៈថែមទៀត។ ឧទាហរណ៍ ៖ ពាក្យថា "អហិង្សា"និងមេត្តាធម៌ កើតឡើងនៅសម័យកាលរីកចម្រើននៃជេនសាសនានិងពុទ្ធសាសនា ហើយមានជីវិតរហូតដល់សព្វថ្ងៃនេះ។ ធម៌ទាំងពីរនេះមានឥទ្ធិពលទៅលើអ្នកហិណ្ឌូទូទៅ។ យើងអាចប្រៀបធៀបគ្នារវាងធម្មបទនៃពុទ្ធសាសនា និងភគវាដគីតានៃក្រឹស្ណអវតារៈ។ ធម្មបទកើតឡើងដោយព្រះពុទ្ធ អ្នកសន្តិភាពខាងសម្ភារៈនិងចិត្តនៅក្រោមមហា ពោធិព្រឹក្ស, ឯភគវាដគីតា កើតឡើងដោយ (Arjuna) អ្នកចម្បាំងនៅក្នុងសមរភូមិ។ អហិស្ស ឬមេត្តា ៖ ធម្មបទនៃពុទ្ធសាសនាពោលថា ៖ ចូរកុំឈ្លោះ ចម្បាំងឬសម្លាប់ឡើយ"។ ឯភគវាដ គីតា ពោលថាៈ "ចូរច្បាំងកាលណាអ្នកឃើញថាមានអ្វីកើតឡើង" នេះគឺសឲ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនា មានគោលគំនិតផ្សេងស្រឡះអំពីលទ្ធិហិណ្ឌូ ឬព្រាហ្មណ៍ សាសនាជេន ក៏មានគំនិតប្រហាក់ប្រហែលគ្នានឹងព្រះពុទ្ធសាសនាដែរ ប្លែកតែត្រង់ការអនុវត្ត។

យើងគួរពិនិត្យនូវលក្ខណៈសំខាន់ខ្លះនៃសម័យការរីកចម្រើននៃលទ្ធិហិណ្ឌូឬព្រាហ្មណ៍ ប៉ុន្តែសម័យទាំងពីរខាងដើមយើងមិនបាច់និយាយដល់ទេ ព្រោះថាសម័យនោះគេរាប់បញ្ចូលទៅក្នុងបុព្វប្រវត្តិសាស្ត្រ។ យើងគួរពិនិត្យសម័យទី៣ គឺសម័យវេទ។ នៅសម័យនេះយើងសង្កេតឃើញថា ពួកអារ្យ៉ន គឺពួកអឺរ៉ង់ បានចូលមករាតត្បាតពួកទ្រាជាវិទអស់ពេលជាច្រើនឆ្នាំ។ ពួកនេះបាននាំវប្បធម៌ថ្មីចូលមក គឺជំនឿក្នុងពហុទេវនិយម។ ជំនឿក្នុងព្រះព្រហ្ម គឺ

គេទុកជាព្រះអាទិទេពដ៏ខ្លាំងខ្ពស់មួយប៉ុណ្ណោះ ហើយគេទុកជាអ្នកបង្កើតលោកដែរ។ ជំនឿនេះ គេពុំទាន់បានអនុវត្តក្នុងផ្លូវទស្សនៈទេ ព្រោះអ្នកគោរពនិងអ្នកជឿពុំបានធ្វើការវែកញែកតាមលក្ខណៈវិទ្យាសាស្ត្រនៅឡើយ។ ជំនឿនៃពួកអារ្យ៉ែនជំនាន់នោះ ដែលគេថាជាជំនឿដ៏ប្រសើរនិងដ៏ប្រជាប្រិយ៍ គឺជំនឿក្នុងព្រះឥន្ទ្រ ដែលមានបុរិសភាពនៃថាមពលនៅក្នុងរន្ទះ ឬភ្លៀងផ្គរ។ គេបានទុកព្រះឥន្ទ្រនេះជាបុរសដ៏អង់អាចបំផុត ហើយចូលចិត្តផឹកទឹកស្រវឹងផងៗ ជំនឿដ៏ប្រជាប្រិយ៍មួយទៀត គឺជំនឿក្នុងព្រះអគ្គី ព្រះអាទិទេពភ្លើងឬអគ្និទេវៈនេះ គេទុកជាមិត្រដ៏សំខាន់បំផុតនៃគេហដ្ឋាន។ ព្រះអាទិទេពដ៏ធំមួយទៀតនៃពួកអារ្យ៉ែន គឺព្រះវរុណៈ ដែលគេទុកជាព្រះអាទិទេពមួយដ៏សំខាន់បំផុតដោយមានព្រះរុទ្រៈជាសេនា ហើយដែលគេទុកជាអំណាចដ៏អាក្រក់នៃធម្មជាតិ។ នៅក្នុងគំនិតសាសនា មិនមានឧត្តមគតិនៃបដិសន្ធិកើតឡើងនៅសម័យនោះទេ ប៉ុន្តែមានឧត្តមគតិថា ពួកអ្នកចម្បាំងទាំងឡាយ កាលណាស្លាប់ទៅហើយ តែងទៅកើតក្នុងឋានមួយដ៏ពិសេសសម្រាប់អ្នកចម្បាំង (Valhalla) ទេវាល័យ ។

នៅសម័យទី៤ គឺសម័យព្រាហ្មណ៍ យើងសង្កេតឃើញថាជំនឿក្នុងវណ្ណៈទាំង៤ ក៏បានកើតឡើង ហើយពួកបុរោហិត គឺអ្នកបួសវណ្ណៈជាព្រាហ្មណ៍ គេទុកជាអ្នកគួរដល់ការបូជា ហើយជាអ្នកចេះក្បួនច្បាប់និងគម្ពីរទាំងឡាយជាងវណ្ណៈដទៃៗទៀតទាំងអស់។ ប៉ុន្តែនៅពេលនោះ ពួកអ្នកបួសនិងអ្នកហិណ្ឌូទាំងអស់ ពុំទាន់មានគំនិតកសាងព្រះវិហារនិងវត្តសម្រាប់តម្កល់ទេវរូបទុកជាទីគោរពនៅឡើយ។ គំនិតកសាងព្រះវិហារនិងវត្ត បានកើតមានឡើងនៅពេលមុនសម័យគុប្តៈ គឺមុនគ.ស.៣២០ បន្ទាប់ពីការកើតឡើងនៃព្រះពុទ្ធសាសនា ហើយគេទុកព្រះវិហារនោះជាកន្លែងសម្រាប់គោរពបូជា មិនមែនជាកន្លែងសម្រាប់ធ្វើសង្ឃកម្មនិងជាវិទ្យាស្ថានសម្រាប់សិក្សាដូចជាព្រះពុទ្ធសាសនាទេ។ ការសិក្សាក្បួនច្បាប់ គម្ពីរបានតែពួកព្រាហ្មណ៍ ឯវណ្ណៈដទៃទៀតពុំបានអនុញ្ញាតឱ្យសិក្សាឡើយ។ មិនតែប៉ុណ្ណោះ វណ្ណៈកម្មករគេមិនអនុញ្ញាតឱ្យចូលទៅគោរពព្រះអាទិទេពក្នុងព្រះវិហារសោះឡើយ។ តាមពិតនៅសម័យនោះ ពិធីបុណ្យទាននិងការបូជាផ្សេងៗ គេតែងធ្វើនៅកណ្តាលទីវាលប្រហែលជានៅជុំវិញភ្នក់ភ្លើង។ រឿងនេះបញ្ជាក់ឱ្យឃើញច្បាស់ថា ពេលនោះមិនមានព្រះវិហារឬវត្ត ព្រោះពួកបុរាណវត្ថុបានជីករកត្រង់ទីក្រុងមហិនជោដារោ (Mahinjodaro) ពុំឃើញមានកន្លែងណាមួយដែលគេអាចសន្និដ្ឋានថាជាព្រះវិហារ ឬវត្តឡើយ។

នៅសម័យទី៥ គឺសម័យទស្សនវិជ្ជា យើងអាចសន្និដ្ឋានថាមានខ្សែគំនិតដូចជាប្រទេសទាំងឡាយដទៃទៀតដែរ គឺប្រទេសក្រិក ចិន និងកាតូលិកនៃអឺរ៉ុបៗ នៅសម័យនោះ យើងសង្កេតឃើញថា គ្រប់ទីកន្លែងទាំងអស់តែងមានឯកទេវនិយមទស្សនៈ និងពហុទេវនិយមទស្សនៈជាគូប្រឆាំងគ្នាជានិច្ចៗ សម័យនេះគឺជាសម័យប្រណាំងប្រជែងគ្នា ខាងផ្លូវគំនិតៗ គម្ពីរដីការបស់ឥណ្ឌាជំនាន់នោះពុំមានលក្ខណៈត្រឹមត្រូវ ដែលអាចចាត់ទុកថា ជាប្រវត្តិ សាស្ត្របានឡើយ ព្រោះច្រើនតែបញ្ជាក់ពីរឿងព្រេងផ្សេងៗ លើកលែងតែគម្ពីររាមាយណៈ និងមហាភារតៈចេញជាពិសេស គម្ពីរទាំងអស់នេះ គេមិនអាចប្រៀបបាននឹងគម្ពីរ ប៊ីប្លៃ លទ្ធិគ្រិស្ត និងព្រះត្រៃបិតកនៃថេរវាទពុទ្ធសាសនាឡើយៗ ប៉ុន្តែតាមពិតដោយសម័យនោះ អក្សរសាស្ត្រនិងគម្ពីរដីកាមានលក្ខណៈដូចគ្នាទាំងអស់ក្នុងសកលលោក គឺគេបានរក្សាទុក និងសិក្សាដោយបានចេះចាំបន្តបន្ទាប់គ្នា ដូចជាពីគ្រូទៅសិស្ស ហើយពីសិស្សទៅអនុសិស្សជាដើម ហើយសម្រាប់សាសនា គេបានទុកការចេះចាំទាំងអស់នេះ ជាលក្ខណៈសំខាន់បំផុត (ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤១) ។

ពាក្យថាវេទៈ ប្រែថាវិជ្ជា មាន១០០សៀវភៅ ហើយមានស្លោកនិងស្តុតី ១០២៨ កើតឡើងមុនគ.ស. រវាង១៥០ ទៅ១០០០ឆ្នាំ ឈ្មោះថាឫគ្វេទៈ (Rig-veda) សៀវភៅវេទ ដ៏ទៃទៀត គេបានរៀបចំខាងក្រោយមក ដូចជាសាមវេទ ដែលមានស្លោកបញ្ជាក់ពីរបៀប ធ្វើ ពិធីបូជា, យជុំវេទ ដែលមានស្លោកសម្រាប់សូត្របូជា និងអថិពវេទ ដែលមានស្លោកជា របៀបស្នេហ៍និងស្តុតី សម្រាប់សូត្រអន្ទងព្រមទាំងមន្តអាគមផងៗ គម្ពីរទាំងអស់ខាងលើនេះ គេអាចចាត់ទុកជាក្រុមទី១ នៃអក្សរសាស្ត្រសំស្ក្រឹតៗ ក្រុមអក្សរសាស្ត្រទី២ គឺគម្ពីរ ឧបនិសាទ ដែលមានអត្ថន័យថា "អង្គុយជិត" ប៉ុន្តែខាងក្រោយមក អត្ថន័យនេះ ក្លាយជា "អង្គុយជិតគ្រូ" ដើម្បីសិក្សានូវវចនៈដ៏អាថ៌កំបាំង ឬព្រះធម៌ដ៏កំបាំងជាដើមៗ

នៅក្នុងក្រុមអក្សរសាស្ត្រទី១ យើងសង្កេតឃើញថា គេបានរៀបរាប់ពីឈ្មោះទេព្តាជាច្រើន ហើយកម្រងស្លោកទាំងអស់ គេបានស្ថាបនាឡើងជារបៀបចម្រៀងសម្រាប់ច្រៀងរៀបរាប់ ដើម្បីសុំពពួកទេវតាទាំងអស់នោះអាណិតមេត្តា និងឱ្យនូវសេចក្តីសុខចម្រើនដល់គេៗ ចំណែកក្នុងក្រុមអក្សរសាស្ត្រទី២ គឺឧបនិសាទ យើងសង្កេតឃើញថា ជាអដ្ឋកថាសម្តែងពីសេចក្តីសំខាន់នៃទេព្តាទាំងអស់នោះ ប៉ុន្តែមានទស្សនៈវិជ្ជាដ៏ជ្រាលជ្រៅជាទីបំផុតជាពិសេសក្នុងការរែករកវត្ថុជាតុដើមនៃធម្មជាតិទាំងអស់ក្នុងលោកៗ អក្សរសាស្ត្រទាំងពីរ

ផ្នែកនេះ បានរីកចម្រើនដល់ការរកដើមកំណើតនិងទីបំផុតលោក។ ដើមកំណើតលោកគឺព្រះព្រហ្ម។ នៅក្នុងឫគ្វេទ ព្រះព្រហ្ម គេគ្រាន់តែនាំគ្នានិយាយថាជាព្រះអាទិទេពដ៏ខ្ពង់ខ្ពស់មួយប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងឧបនិសាទ យើងសង្កេតឃើញថា ព្រះព្រហ្មគេសំដៅយកទេព្តាដ៏ស័ក្តិសិទ្ធិ គឺជាអាទិទេពមួយដ៏ខ្ពង់ខ្ពស់ជាទីបំផុត ជាព្រះម្ចាស់លោក ជាអ្នកបង្កើតលោក និងជាឯកភាពនៃធម្មជាតុ។ នៅក្នុងមេទ្រីឧបនិសាទ យើងឃើញថាអត្ថន័យនៃព្រះព្រហ្ម សំដៅយកអាកាសធាតុ ជីវិត សេចក្តីរីករាយនិងសូន្យ។ ព្រះព្រហ្មនេះឯងជាឯកភាពស្ថិតនៅក្នុងគ្រប់ធម្មជាតិទាំងអស់ក្នុងលោកដែលផុតនិស្ស័យនិងធ្វើអត្ថន័យបាន, អសញ្ញាស័ព្ទ (Non-Being as Being)។ ជាមួយនឹងការរីកចម្រើននៃព្រហ្មចិន្តា អាត្មៈចិន្តា ក៏បានរីកចម្រើនដែរ។ ពាក្យថាអាត្ម័ន ប្រហែលគ្នានឹងពាក្យ អល្លឺម៉ាញ ថា “Atmen” បានសេចក្តីថា “ដកដង្ហើម” ប្រហែលគ្នានឹងពាក្យក្រិកថា “Atmos” បានសេចក្តីថា “ដកដង្ហើម” ដូចគ្នា។ ពាក្យនេះបានបញ្ជាក់នូវអទស្សនភាគនៃបុគ្គលភាព គឺសំដៅយកព្រលឹង ឬអាត្ម័ន ខ្លួនឬប្រាណ ប៉ុន្តែឧត្តមគតិនេះបានរីកចម្រើនបន្តិចម្តងៗតាមលំដាប់ ថាអត្ម័នគឺជាឯកភាពខ្លួនច្រើនមែន ប៉ុន្តែអាត្ម័នមានតែមួយគត់ដូចគ្នា[៥] គឺមានព្រះព្រហ្មជាមូលដ្ឋាន។ ការរីកចម្រើនខាងក្រោយ មកនៃឧត្តមគតិរបស់ព្រះព្រហ្ម គឺការកត់សម្គាល់រវាងឧត្តមគតិនៃព្រះព្រហ្មនិងឯកភាព នៃមហាត្ម័ន។ ប៉ុន្តែនៅពេលដែលការកត់សម្គាល់នេះ បានទៅដល់ចំណុចទីបំផុតក្នុងការរកឯកភាពរវាងឧត្តមគតិទាំងពីរ ទើបគេយល់ច្បាស់ថា តើព្រះព្រហ្មមានលក្ខណៈពិតប្រាកដដែរឬមិនមាន ឬក៏គ្រាន់តែជាផ្លូវគំនិតប៉ុណ្ណោះទេ ព្រោះឧត្តមគតិនៃព្រះព្រហ្មឋិតនៅត្រង់ចំណុចសូន្យនៃលោកជាតុ ដូច្នេះការរាវរកឯកភាពរវាងឧត្តមគតិនៃមហាត្ម័នឋិតនៅលើសមាធិចិត្ត និងការប្រព្រឹត្តិតបៈធម៌ ដែលមានលក្ខណៈមិនអាចមើលឃើញដោយភ្នែកទទេបាន។ តាមពិត ការរាវរកឯកភាពរវាងឧត្តមគតិទាំងពីរដែលគេចាត់ទុកថាមិនឥតអំពើបាន លុះត្រាតែឋិតនៅលើសមាធិចិត្តនិងតបៈធម៌ ដែលជាធម្មជាតុឋិតនៅក្នុងអាត្ម័នខ្លួនឯង។ កាលណាមនុស្សលោកមានសន្តានចិត្តប្រកបដោយសមាធិនិងតបៈធម៌ ពេលនោះគេ បានចូលទៅឋិតនៅក្នុងភាពជាមហាត្ម័ន។ គឺពេលនេះហើយដែលយើងអាចហៅថាសន្តានចិត្តនៃបុគ្គលនោះ ឋិតនៅត្រង់ចំណុចសូន្យនៃអារម្មណ៍។ ថ្នាក់ចិត្តនេះគេអាចពោលថាជាចិត្តពិត នៅជាមួយព្រះព្រហ្មបាន។ ដើម្បីបញ្ជាក់រឿងនេះ យើងគួរលើកយកស្លោកខ្លះក្នុង Brihadar anyaka-Upanishad ជា

---

[៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤២

ឧទាហរណ៍ដូចតទៅនេះ "អ្នកដែលបានឃើញ ហើយបានដាស់អាត្ម័នឱ្យភ្ញាក់ឡើង ពិភពលោកគឺជារបស់អ្នកនោះ។ តាមពិតអ្នកនោះគឺពិភពលោកហ្នឹងឯង (Brih.4/4/I3)។

ទាំងនេះ ប្រជារាស្ត្រតែងនិយាយថា ៖ ចូរអ្នកគោរពព្រះអាទិទេពនេះ ចូរអ្នកគោរពអាទិទេពនោះ គោរពព្រះអាទិទេពមួយហើយមួយទៀត។ ទាំងអស់នេះ ឈ្មោះថាការបង្កើតលោកខ្លួនឯងដោយពិត បានសេចក្តីថា អ្នកនោះឯងមិនគឺអ្នកណាក្រៅពីព្រះអាទិទេពនោះឡើយ (Brih.I.4.6)។

តាមពិត ប្រសិនបើអ្នកណាបានធ្វើកិច្ចការកុសលដ៏ធំ ប៉ុន្តែពុំបានដឹងថាពិភពលោកទាំងមូល គឺព្រះព្រហ្មឬអាត្ម័នទេ ឬមិនដឹងថាអាត្មាអញគឺព្រះព្រហ្មឬអាត្ម័ន ឬក៏មិនដឹងថាកិច្ចការរបស់ខ្លួនត្រូវវិនាសនៅទីបំផុតទេ អ្នកនោះគួរតែបន់ស្រន់ឬគោរពតែខ្លួនឯងមួយដែលគេទុកថាពិភពលោកដ៏ពិតប្រាកដ ហើយកិច្ចការរបស់អ្នកដែលគោរពខ្លួនឯងថា ជាពិភពលោកដ៏ពិតប្រាកដនោះ ទើបមិនវិនាសបាត់បង់ទៅវិញ (Brih.I.4.I5)។

ការពោលមកខាងលើនេះនាំឱ្យយើងយល់ថា ការរីកចម្រើនខាងផ្លូវគំនិតជាដំបូង គឺតាំងពីសម័យវេទ រហូតមកទល់នឹងសម័យឧបនិសាទ គឺសុទ្ធតែគំនិតខាងពហុទេវនិយមទាំងអស់ ប៉ុន្តែវាអាចឱ្យគំនិតដល់ឯកាទេវនិយមដែរ។ នៅសម័យឧបនិសាទ យើងឃើញថាមានតែព្រះព្រហ្មមួយតែប៉ុណ្ណោះ ដែលជាព្រះបង្កើតលោក តែងមានឯកភាពឋិតនៅក្នុងគ្រប់ធម្មជាតុទាំងអស់ក្នុងលោក[១០] ។

នៅគ្រប់ទស្សនវិជ្ជានៃលទ្ធិព្រាហ្មណ៍ឬហិណ្ឌូ យើងសង្កេតឃើញថា លោកនេះកើតឡើងដោយកម្លាំងជាតុ៤ ព្រមទាំងអាកាសជាតុ ដែលគេបានសន្មតថាជាព្រះអាទិទេពតាមលក្ខណៈនិងធម្មជាតុនៃលោកជាតុនោះៗ។ ព្រោះហេតុនោះបានជាមានឈ្មោះអាទិទេពទាំងអស់នោះៗ ដែលគេហៅថាសមូហាទិទេវនិយម (Pantheism)។ ការកើតឡើងនិងការវិនាសទៅវិញនៃលោកនេះ ក៏អាស្រ័យនឹងបំណងព្រះអាទិទេព គឺលោកនេះមានព្រះអាទិទេពជាមេតម្រួត។

នៅសម័យទាំងអស់គឺតាំងពីសម័យទី ៣-៤-៥ យើងឃើញថាមានឥទ្ធិពលខ្សែជីវិតលូតលាស់ជាអតិបរមា រហូតដល់កម្រិតព្រំដែនហិណ្ឌូត្រីមូត៌ិកើតឡើង។ ទាំងនេះបណ្តាលមកពីលក្ខណៈវិភាគបានជំរុញឱ្យយល់ច្បាស់នូវលក្ខណៈធម្មជាតិទូទៅ ហើយធម្មជាតុទាំង

---

[១០] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤៣

អស់ដែលឋិតនៅក្នុងគ្រប់ធម្មជាតិទាំងអស់នោះ លោកចែកជាប្រភេទមាន៣ គឺព្រះព្រហ្មជាតួព្រលឹងដែលមានលក្ខណៈឯកភាព និងជាតំណាងនៃចិត្តឬមនៈឋិតនៅក្នុងធម្មជាតិមានវិញ្ញាណ និងឥតវិញ្ញាណទាំងអស់ក្នុងលោក។ ព្រះសិវៈ ជាតំណាងជាតុដែលបង្កើត និងធ្វើឱ្យមានជីវិត ឬឋិតនៅជាបដល់អស់អាយុ។ ទាំង ៣នេះ គេចាត់ទុកជាត្រីមូតិ នៃលទ្ធិហិណ្ឌូ ហើយគេបានសន្និដ្ឋានថាព្រះទាំង៣អង្គនេះ មានបុរិសភាពជាតួបុគ្គលបាន ទើបគេសាងទេវរូបឡើងជាតំណាងឱ្យឧត្តមគតិទាំងអស់នោះ។ ឧត្តមគតិបែបនេះ បានរីកចម្រើនឡើងរហូតដល់សតវត្សទី៦ មុនគ.ស.។ លុះដល់ព្រះពុទ្ធកើតឡើងក្នុងលោក បានផ្សព្វផ្សាយពាក្យប្រៀនប្រដៅរបស់ព្រះអង្គពាសពេញប្រទេសឥណ្ឌា, ឧត្តមគតិហិណ្ឌូគ្រប់បែបដែលបានកើតឡើងហើយ រមែងសាបរលាបទៅវិញខ្លះ ព្រមទាំងមិនឱ្យរីកចម្រើនជាងនោះឡើយ។ ព្រះពុទ្ធសាសនាកើតឡើងហាក់ដូចជាព្រះអាទិទេពមានឥទ្ធិពលក្រៃលែង បំផ្លាញនូវភាពងងឹត ក្នុងលក្ខណៈទស្សនៈឱ្យវិនាសសូន្យអស់។ ព្រះពុទ្ធសាសនា បន្ទាប់ពីបរិនិព្វានព្រះពុទ្ធមក ពុំឋិតនៅក្នុងភាពធម្មតាឡើយ គឺមានការបែកនិកាយជាច្រើនដែលបណ្ដាលឱ្យលទ្ធិហិណ្ឌូ មានកម្លាំងឡើងវិញ។ តាមទំនួលនេះ យើងឃើញថាតាំងពីព្រះពុទ្ធកើតឡើងរហូតដល់បែកនិកាយធំៗ ២ជាមូលដ្ឋាន គឺហិនយាន គិតទៅចំនួន ១០០០ឆ្នាំ។ ដល់សតវត្សទី៧ នៃគ.ស. ដោយមានបំណងធ្វើឱ្យមានឯកភាពខាងផ្លូវគំនិតនៃហិណ្ឌូ លោកទស្សនវិទូ២រូប គឺសង្ករាចរិយៈ និងកុមារហេរិលៈ បានរួបរួមពាក្យប្រៀនប្រដៅទាំងអស់ដែលមានក្នុងគម្ពីរនេះ ភាគច្រើន ច្រើនតែមានពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយឋិតនៅក្នុងគំនិតទូទៅនៃជនជាតិឥណ្ឌាសម័យនេះ[១១]។

## ១-ព្រះពុទ្ធសាសនា

យើងសង្កេតឃើញថា ព្រះពុទ្ធសាសនាបានរីកចម្រើននិងអាប់អួរ ចាប់តាំងពីព្រះពុទ្ធបានត្រាស់ដឹង រហូតមកដល់សព្វថ្ងៃនេះ តាមឯកសាររបស់លោក Edward Thomas (Edward Thomas, A History of Buddhist Thought) ដូចតទៅនេះ៖

-មុនគ.ស. ៥២៨ឆ្នាំ ព្រះពុទ្ធបានត្រាស់ដឹង (សតវត្សទី៦ មុនគ.ស.) មុនគ.ស.៤៨៣ឆ្នាំ ព្រះពុទ្ធទ្រង់ចូលមហាបរិនិព្វាន រួចហើយព្រះអរហន្តជាសាវ័ក បានចាប់ផ្ដើមធ្វើសង្គាយនាលើកទី១នៅក្នុងក្រុងរាជគ្រឹះ មគធរដ្ឋ។

---

[១១] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤៤

-មុនគ.ស.៣៨៣ឆ្នាំ ព្រះអរហន្ត ទ្រង់ធ្វើសង្គាយនាលើកទី២ នៅក្នុងក្រុងវេសាលី។

-មុនគ.ស.២៦៩ឆ្នាំ ព្រះបាទអសោកមហារាជាធិរាជទ្រង់សោយរាជ្យ រួចហើយព្រះអរហន្តទ្រង់ធ្វើសង្គាយនាលើកទី៣ ក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះអង្គ បន្ទាប់មកទ្រង់បញ្ជូនសមណទូតទាំងឡាយទៅផ្សាយព្រះពុទ្ធសាសនាគ្រប់ទិកន្លែងក្នុងប្រទេសឥណ្ឌា និងក្រៅឥណ្ឌា។

-មុនគ.ស.២៤៦ឆ្នាំ បេសកកម្មនៃព្រះមហាហិន្ទត្ថេរទៅកោះសិរីលង្កា ការបែកនិកាយធំៗ ២គឺ ហីនយាន និងមហាយាន។ ហីនយាននិកាយ បែកជា ១៨និកាយទៀត ព្រះរាជាទាំងឡាយនៃកុលានវង្ស បានស្ថាបនារាជធានីក្រុងនៅឥណ្ឌាភាគនិរតី។

-មុនគ.ស.២៩-១៧ឆ្នាំ រជ្ជកាលនៃព្រះបាទវដ្តគាមិនីនៃកោះសិរីលង្កា។

-នៅសតវត្សទី១ នៃគ.ស. ព្រះបាទកនិស្កៈនៃកុលានវង្ស ទ្រង់បង្គាប់ឱ្យសរសេរព្រះត្រៃបិតកជាភាសាសំស្រ្កឹត សង្គាយនាលើកទី១ នៃនិកាយសរិស្តិវាទិន ជាមហាយាននិកាយក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះបាទកនិស្កៈ។

-នៅសតវត្សទី២ នៃគ.ស.មាននិកាយមហាយានមួយទៀតកើតឡើងឈ្មោះថា "មធ្យមកៈ" (សុញ្ញតវាទ) ក្រោមឱវាទនិងការដឹកនាំនៃអ្នកទស្សនវិទូព្រះនាម នាគាជ៊ុន (នាគ+ អាជ៊ុនៈ)។

-នៅសតវត្សទី៤នៃគ.ស. មាននិកាយមហាយានមួយទៀតកើតឡើងឈ្មោះ "យោគាចារៈ" ក្រោមឱវាទនិងការដឹកនាំនៃអ្នកទស្សនវិទូពីររូប គឺលោក វសុពន្ធុ និង អាសង្គៈ។ នៅសតវត្សទី៦នៃគ.ស. តក្កវិជ្ជានិកាយ ក្រោមឱវាទនិងការណែនាំនៃលោកឌិគ្នាគៈ បានកើតឡើងទៀត។ នៅសតវត្សទី៧នៃគ.ស. មានអ្នកទស្សនវិទូពីររូបលោកគឺលោក សន្តិទេវៈ និង ធម្មកិត្តិ បានមានកំណើតឡើង។ នៅពេលនោះមានអ្នកទស្សនវិទូពីររូបគឺ សង្ករាចារ្យ និង កុមារហរិឡៈ ជាពួកព្រាហ្មបានបន្ទំសិក្សាទ្រឹស្តីព្រះពុទ្ធសាសនាយ៉ាងជំនាញ ហើយបានកែទម្រង់លទ្ធិព្រហ្មណ៍ ដោយរួបរួមទ្រឹស្តីទាំងអស់នៅក្នុងឥណ្ឌា បង្កើតជាគម្ពីរព្រាហ្មណ៍មួយឈ្មោះថា "វេទាន្ត" (ទីបំផុតនៃវេទ)។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤៥)

នៅក្នុងអារម្ភបទនៃគម្ពីរនេះ យើងឃើញថាសង្ករាចារ្យ បានប្រារព្ធធ្វើនមស្ការ ចំពោះព្រះពុទ្ធដោយអស់ពីដួងចិត្ត ប៉ុន្តែក្នុងគំនិតកែទម្រង់នៃលទ្ធិព្រាហ្មណ៍របស់លោក ដោយយកព្រះពុទ្ធសាសនាជាយាននិងជាមូលដ្ឋាន យើងអាចចាត់ទុកការគោរពចំពោះព្រះពុទ្ធនោះជា

ថ្នាំពិសទៅវិញ។ នៅក្នុងផ្ទៃនៃគម្ពីរវេទាន្តៈទាំងមូលយើងឃើញថា មានទ្រឹស្តីព្រះពុទ្ធ-សាសនា យ៉ាងច្រើនជាទីបំផុត ហើយគំនិតទូទៅរបស់ឥណ្ឌាសព្វថ្ងៃនេះទាំងផ្នែកសម្ភារៈនិង ចិត្ត ឬអសម្ភារៈ មានគម្ពីរវេទាន្តៈនេះជាមូលដ្ឋាន។ គោលបំណងដ៏ធំបំផុតរបស់លោកសង្ករាចារ្យនិងកុមារហរិឡៈ ទាំងពីរនេះ គឺការកែទម្រង់លទ្ធិព្រាហ្មណ៍ឱ្យមានគំនិតឯកភាពសម្រាប់ជនជាតិឥណ្ឌាទាំងមូល ប៉ុន្តែយើងស្តាយណាស់ក្នុងរឿងនេះ ព្រោះលោកទាំងពីរនេះ លួចយកទ្រឹស្តីព្រះពុទ្ធជាម្ចាស់យើងទៅរួមបញ្ចូលក្នុងគម្ពីរវេទនាន្តៈនោះ ហើយបំបាត់ព្រះនាមព្រះពុទ្ធចេញអស់។ ដូច្នេះយើងអាចចាត់ទុកអ្នកកែទម្រង់ទាំងពីររូបនេះជាសត្រូវធំបំផុតចំពោះព្រះពុទ្ធសាសនាក្នុងការបន្លំមិនឱ្យគេដឹង[១២]។

តាំងពីសតវត្សទី៧ ដល់ទី១០នៃគ.ស. យើងឃើញថាតន្ត្រនិកាយមួយទៀតបានកើតឡើងដោយពុំមានប្រាកដឈ្មោះអ្នកទស្សនវិទូណាមួយឡើយ។ លុះដល់សតវត្សទី១២ នៃគ.ស. ព្រះពុទ្ធសាសនាទាំងពីរនិកាយក៏បានឃ្លាតស្រឡះពីប្រទេសឥណ្ឌា (គឺសូន្យ) តែម្តងដោយពួកមហាហ្មត់នៃលទ្ធិអ៊ិស្លាមរួមដៃជាមួយនឹងពួកព្រាហ្មណ៍ជាខ្មោចក្នុងផ្ទះ កម្ទេចអាគារសិក្សាវត្តព្រមទាំងសម្លាប់ព្រះសង្ឃនិងឧបាសក-សិកា ពុំមានសេសសល់។ ព្រះសង្ឃដែលមានជីវិតរស់នៅ ក៏រត់ទៅជ្រកនៅប្រទេសទីបេត៍ នេប៉ាល់ ភូតាន ស៊ិក្គឹម និងប៉ាគិស្ថានខាង កើតអស់ទៅ។

***កំណត់សម្គាល់*** ៖ តាំងពីសតវត្សទី១ រហូតដល់ទី១២នៃគ.ស. យើងបានពោលតែពីហេតុការណ៍ខ្លះនៃមហាយាននិកាយប៉ុណ្ណោះ ហើយយើងពុំបានពោលដល់ហេតុការណ៍ផ្សេងៗខាងផ្នែកហិនយាននៅទីនេះឡើយ (សូមមើលគម្ពីរចុល្លវគ្គវិន័យបិតកខ្មែរ ត្រង់បឋមសង្គីតិ និងទុតិយសង្គីតិ) (ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤៦)។

មូលដ្ឋាននិងការរីកចម្រើននៃព្រះពុទ្ធសាសនា ៖ តាមមូលដ្ឋានទូទៅ យើងឃើញថា ការអប់រំកាយ វាចា និងចិត្ត លោកហៅថាវិន័យនិងធម៌តាមលក្ខណៈពិតនៃព្រះពុទ្ធសាសនា។ ការអប់រំទាំងអស់នេះ ឋិតនៅលើតំណក់នៃសីលធម៌ សមាធិធម៌និងបញ្ញាធម៌។ ទាំងនេះបង្ហាញឱ្យឃើញថា មានលក្ខណៈស្របគ្នាតិចតួចជាមួយនឹងអស្តិរូបវិចារណ៍។ ប៉ុន្តែគោលការណ៍ទាំងអស់នោះបានបញ្ជាក់ជាពិសេសក្នុងបដិច្ចសមុប្បាទ ត្រង់ទ្រឹស្តីនៃវេទនាសម្ព័ន្ធនៃលោក។ គេជឿថា មនុស្សម្នាក់ៗកើតនិងស្លាប់មិនចេះឈប់ឈរសោះ លុះត្រាតែគេបាន

[១២] អ៊ុន សំបេត ពុទ្ធិកសិក្សាលេខ ១៧, ១៨, ១៩, អត្ថបទ ឈ្មោះ "ហេតុអ្វីបានជាឥណ្ឌាបាត់បង់ព្រះពុទ្ធសាសនា ?

គាស់ឫសនៃអវិជ្ជា រួចហើយបានត្រាស់ដឹងនូវប្រាជ្ញាដ៏ស្រួចស្រាល់។ ក្នុងគ្រប់ជាតិទាំងអស់ ដែលមនុស្សម្នាក់ៗបានអន្ទោលកើត-ស្លាប់ ហើយបានទទួលសុខឬទុក្ខក្នុងភពនោះៗ តែង អាស្រ័យនឹងគំនរនៃកម្មតែម្យ៉ាង។ ទាំងអស់នេះ គឺព្រះពុទ្ធជាម្ចាស់បានទ្រង់ទទួលស្គាល់ថាជា ធម្មជាតុពិតប្រាកដឥតប្រែប្រួលបាន តាំងពីពេលដែលព្រះអង្គបន្ទាប់ពីទ្រង់ធ្វើទុក្ករកិរិយា គឺ ការរៀនអនុវត្តនិងសិក្សាអស់រយៈវេលា ៦ឆ្នាំ ទ្រង់គង់ក្រោមមហាពោធិព្រឹក្ស ហើយទ្រង់ ចម្រើននូវបដិច្ចសមុប្បាទជាអនុលោមនិងបដិលោម។

ក្នុងជំនឿនិងទ្រឹស្តីដូចបានពោលមកហើយនេះ យើងសង្កេតឃើញថា នៅជំនាន់ឧប និសាទគេបានរកឃើញដែរដូចឧទាហរណ៍ខ្លះដែលយើងនឹងពោលក្នុងទំព័រខាងមុខនេះស្រាប់ គឺប្រព័ន្ធសំខ្យាទស្សនវិជ្ជានៃឥណ្ឌា "សម្រាប់សម្ព័ន្ធភាពជាបឋមនៃព្រះពុទ្ធសាសនាជាមួយ នឹងលទ្ធិព្រាហ្មណ៍ យើងបានសង្កេតឃើញថា លទ្ធិព្រាហ្មណ៍មានរបៀបប្រតិបត្តិនិងជំនឿដូច គ្នានឹងលទ្ធិបុរាណនិងទ្រឹស្តីបុរាណដែរ ហើយរឿងទាំងអស់នេះ មានចែងក្នុងគម្ពីរព្រាហ្មណ៍ និងឧបនិសាទ។ រឿងនេះជារឿងលំបាកក្រៃលែង ថាតើព្រះពុទ្ធសាសនាមានការទាក់ទង ដោយផ្ទាល់ជាមួយលក្ខណៈណាមួយនៃគម្ពីរទាំងអស់នេះដូចម្តេចខ្លះ។ បញ្ហានេះមិនមែន មានលក្ខណៈតិចតួចទេ ព្រោះមានសេចក្តីពិតខ្លះថាលទ្ធិព្រាហ្មណ៍ បានយោងចូលទៅក្នុង គម្ពីរព្រះពុទ្ធសាសនាជាច្រើនក្នុងលក្ខណៈកែទម្រង់។ រឿងនេះរឹតតែជាក់ច្បាស់ទៅទៀត កាលណាយើងឃើញថា ក្នុងគម្ពីរព្រះពុទ្ធសាសនា មានចែកភាសិតជា៤ប្រភេទគឺ ៖ ពុទ្ធ ភាសិត សាវ័កភាសិត ទេវតាភាសិត និងឥសីភាសិត។ ក្នុងលក្ខណៈទូទៅ យើងបានឃើញ ជាញឹកញាប់នូវន័យលក្ខណៈខ្លះដែលពោលអាងដល់ពាក្យថា បុរាណាចារ្យនៃពួកអដ្ឋកថា របស់គម្ពីរព្រះពុទ្ធសាសនា កាលណាអត្ថាធិប្បាយពុទ្ធវចនៈណាមួយក្នុងលក្ខណៈចង់ បញ្ជាក់ឱ្យបានរឹងរឹតតែជាក់ច្បាស់ឡើង។ ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់បានប្រឆាំងជាមួយគ្រូ ទាំង៦ ដែលប្រាកដនាមឡើងក្នុងពេលនោះគឺ ៖ និគន្ថនាដបុត្រ ដែលជាមេដឹកនាំនៃលទ្ធិជន បុរាណកស្សបៈ មក្ខលិគោសាល បកុធកច្ចាយនៈ អជិតកេសកម្ពលៈ និងសញ្ជយវេលដ្ឋ បុត្រ។ ចំពោះគ្រូឈ្មោះនិគន្ថនាដបុត្រ យើងឃើញថាទ្រឹស្តីនិងភាគអនុវត្តន៍ មានចែងក្នុងលទ្ធិ ជេនយ៉ាងច្បាស់លាស់ហើយៗ គោលទ្រឹស្តីនៃលទ្ធិនេះ មានលក្ខណៈតក្កវិជ្ជាយ៉ាងវិសេស វិសាលណាស់ ព្រមទាំងបដិសេធជំនឿក្នុងព្រះអាទិទេពដូចជាព្រះពុទ្ធសាសនាដែរ។ មិនតែ ប៉ុណ្ណោះ លទ្ធិជេនបានប្រឆាំងជាដាច់ខាតចំពោះវណ្ណៈថាមិនមែនជាសេចក្តីពិតនៃសង្គមនិង

មនុស្សធម៌ឡើយ ដែលប្រហែលគ្មានទ្រឹស្តីព្រះពុទ្ធសាសនាសុទ្ធសាធ ប៉ុន្តែគោលដៅដ៏ធំបំផុតនៃលទ្ធិនេះ ព្រមទាំងភាគអនុវត្ត មានលក្ខណៈជាអត្តកិលមត្ថានុយោគព្រមទាំងអន្តិមាថែមទៀត ដែលផ្ទុយស្រឡះពីព្រះពុទ្ធសាសនាត្រង់មជ្ឈិមាបដិបទានោះឯង។

ចំពោះលោកគ្រូទាំង ៥ទៀត យើងពុំបានដឹងថាមានទ្រឹស្តីដ៏ជាក់ស្តែងព្រមទាំងមានលក្ខណៈជាសាសនាពិតប្រាកដដូចជាលទ្ធិជេនឡើយ ប៉ុន្តែយើងសង្កេតឃើញថា ទស្សនវិជ្ជានៃឥណ្ឌាសព្វថ្ងៃនេះ មានបែបនិកាយជាច្រើន គឺមិមំសាទស្សនវិជ្ជា ន្យាយទស្សនវិជ្ជា ចារុវាកទស្សនវិជ្ជា (សម្ភារនិយម) ជាដើម។ យើងពុំបានដឹងថា តើប្រព័ន្ធទស្សនវិជ្ជាណាជារបស់គ្រូណាឡើយ។ ត្រង់ចំណុចនេះ យើងចាត់ទុកជាលក្ខណៈសំខាន់សម្រាប់ការស្រាវជ្រាវ ដើម្បីជាពន្លឺនិងឱ្យយល់ច្បាស់នូវការរីកចម្រើននៃព្រះពុទ្ធសាសនា ប៉ុន្តែយើងពុំមានឯកសារគ្រប់គ្រាន់ដើម្បីការដ៏ធំសម្បើមនេះ។

ចំពោះពាក្យប្រៀនប្រដៅរបស់គ្រូទាំង ៦នោះ "យើងឃើញថាព្រះពុទ្ធសាសនាបានប្រឆាំងជាដាច់ត្រង់ចំណុចដែលពុំមានលក្ខណៈពិតតាមប្រក្រតីដើម ដែលព្រះពុទ្ធជាម្ចាស់បានស្វែងរកឃើញ។ នៅក្នុងសាមញ្ញផលសូត្រយើងឃើញថា អជាតសត្តុនៃមគធរដ្ឋ បានចូលក្រាបបង្គំគាល់ព្រះពុទ្ធជាម្ចាស់ហើយទូលសួរថា "បពិត្រព្រះបរមគ្រូដ៏ចម្រើន មានមុខជំនួញនិងកិច្ចការនោះៗយ៉ាងពិតប្រាកដ។ ឯអ្នកទាំងអស់នោះ តែងរស់នៅជាសុខសាន្តជាមួយនឹងគ្រួសារព្រមទាំងមិត្រភក្តិរបស់ខ្លួន រួចហើយគេទាំងឡាយ បានឱ្យទានដល់ពួកសមណៈនិងព្រាហ្មណ៍ ហើយផលដែលកើតពីអំណោយទាននោះ គឺគេបានទៅសោយសុខក្នុងសុគតិភពជាដើម"។ "បពិត្រព្រះអង្គដ៏ចម្រើន តើព្រះអង្គអាចបង្ហាញនូវលទ្ធផលដ៏ពិតប្រាកដនៃសមណៈបានដែរឬទេ ? ចំពោះបញ្ហានេះ ព្រះពុទ្ធជាម្ចាស់បានត្រាស់សួរត្រឡប់ទៅព្រះបាទអជាតសត្តុវិញថា "បពិត្រព្រះសម្មតិទេព តើប្រស្នាដែលទ្រង់សាកសួរនេះ ព្រះអង្គមានយកទៅសួរសមណៈនិងព្រាហ្មណ៍ដទៃទៀតដែរឬទេ ? ព្រះបាទអជាតសត្តុក្រាបបង្គំទូលថា "ព្រះករុណាថ្លៃពិសេស ខ្ញុំព្រះអង្គបានសួររឿងនេះចំពោះសមណៈនិងព្រាហ្មណ៍ជាច្រើនហើយលោកបានដោះស្រាយប្រស្នានោះដូចតទៅនេះ ៖

១-បូរាណកស្សបៈ បានឆ្លើយថា "កម្មដែលមនុស្សទាំងឡាយបានធ្វើនិងប្រកបហើយនោះ ទោះជាល្អក្តី អាក្រក់ក្តី ពុំមានឱ្យផលជានោះឡើយ"។ ពាក្យប្រៀនប្រដៅរបស់គ្រូរូបនេះគេឱ្យឈ្មោះថា "អកិរិយវាទី"។

២-មក្ខលិគោសាល: បានឆ្លើយថា "បដិសន្ធិទាំងឡាយក្តី អំពើជាកុសលក្តី ជាង អកុសលក្តីនៃមនុស្សលោក ដែលបានកើតឡើង និងបានប្រព្រឹត្តនឹងមិនមានកើតទៀត និងឱ្យផលជានេះជានោះឡើយ។ កាលណាមនុស្សទាំងឡាយនោះផ្តើមមរណកាលទៅវិញ សូន្យតែម្តង"។ ពាក្យប្រៀនប្រដៅរបស់គ្រូរូបនេះ គេឱ្យឈ្មោះថា "សុញ្ញវាទី"[១៣]។

៣-អជិតកេសកម្ពល បានឆ្លើយថា "សត្វលោកគ្មានកម្មទេ។ មនុស្សទាំងឡាយកើតឡើងដោយកម្លាំងធាតុ៤ (ធាតុដី, ទឹក, ភ្លើង និងខ្យល់) ហើយកាលណាមនុស្សទាំងឡាយនោះស្លាប់ទៅវិញ គេយកទៅដុតរួចហើយ ធាតុទាំងអស់នោះ ក៏ត្រូវវិលត្រឡប់ទៅរកធាតុដើមវិញ។ អ្នកប្រាជ្ញនិងមនុស្សពាលទាំងឡាយត្រូវតែស្លាប់ទាំងអស់គ្នា ហើយបន្ទាប់ពីការស្លាប់ គេទាំងឡាយលែងកើតទៀតជាដាច់ខាត"។ ពាក្យប្រៀនប្រដៅរបស់គ្រូរូបនេះ គេឱ្យឈ្មោះថា "ឧច្ឆេទវាទី"។

៤-បកុធកច្ចាយនៈ បានឆ្លើយថា "សត្វលោកមួយរូបៗ ត្រូវបានកើតឡើងដោយកម្លាំងធាតុ៧យ៉ាង ដែលមិនចេះវិនាសសាបសូន្យទៅណាឡើយ។ កម្លាំងធាតុទាំងនោះគឺ ធាតុទឹក ដី ភ្លើង ខ្យល់ សុខ ទុក្ខ និងជីវិត ឬព្រលឹង។ លោកបានបញ្ជាក់ទៀតថា មិនមានអ្នកសម្លាប់ អ្នកឱ្យគេសម្លាប់ អ្នកដឹង ឬអ្នកឱ្យគេដឹងឡើយ។ អ្នកកាប់គេដោយដាវ អ្នកនោះមិនមែនសម្លាប់អ្នកណាម្នាក់ទេ គឺគេគ្រាន់តែធ្វើឱ្យមានប្រហោងដោយដាវត្រង់ចន្លោះនៃធាតុទាំង៧ ដែលមិនចេះវិនាសទៅណានោះទេតើ។ ពាក្យប្រៀនប្រដៅរបស់គ្រូរូបនេះ គេឱ្យឈ្មោះថា "អកិរិយវាទី" ដែរ។

៥-និគន្ថនាដបុត្រ: បានឆ្លើយថា "អ្នកដែលឈ្មោះថាជិនៈ អ្នកនោះត្រូវតែប្រកបដោយបដិញ្ញា៤យ៉ាងគឺ ៖ អាក្រាតកាយ, ផឹកទឹកដែលត្រងដោយធមក្រក, យកសំពត់សរុំមាត់និងច្រមុះ និងពេលដើរត្រូវបោសដីជាមុនសិន"។ ពាក្យប្រៀនប្រដៅរបស់គ្រូនេះឈ្មោះថា "និគន្ថវាទី ឬជិនវាទី" ដែលយើងឃើញប្រាកដជាលទ្ធិជេនសព្វថ្ងៃនេះ។ លទ្ធិនេះទទួលថាមានបុណ្យ-មានបាប។

៦-សញ្ជាយវេលដ្ឋបុត្រ បានឆ្លើយថា "អ្វីៗទាំងអស់គ្មានលក្ខណៈពិតជាមូលដ្ឋានឡើយ ហើយគ្រប់ពាក្យប្រៀបប្រដៅរបស់គ្រូទាំងឡាយសុទ្ធសឹងតែមិនបានការអ្វីទាំងអស់"។ ពាក្យប្រៀនប្រដៅរបស់គ្រូរូបនេះ គេឱ្យឈ្មោះថា "អប្រាកដវាទី" ។

---

[១៣] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៤៩

ចំពោះគ្រូទាំង៦នេះ យើងឃើញថា មានមកប្រាកដក្នុងគម្ពីរព្រះពុទ្ធសាសនា ប៉ុន្តែពាក្យប្រៀនប្រដៅរបស់គ្រូទាំង ២ រូបនោះមានលក្ខណៈហាក់ដូចជាពុំច្បាស់លាស់សោះ។ ប៉ុន្តែនិគន្ថនាដបុត្រនិងមក្ខលិគោសាលៈមានប្រវត្តិប្រាកដនៅក្នុងគម្ពីរលទ្ធិជេន ហើយមក្ខលិគោសាលៈនេះ នៅក្នុងគម្ពីរជេដែលនេះ ខាងក្រោយមក គេហៅថា "អាជីវិកៈ" ហើយឈ្មោះនេះគឺគេហៅតាមអាជីវកម្មរបស់គាត់ជាតាបសមានយោគៈជាសមុដ្ឋាន ហើយឈ្មោះនេះតាមពិតទៅហៅដោយពួកនិកាយប្រឆាំង។ ប៉ុន្តែពាក្យថា "អាជីវិកៈ" នេះ ពុំមានប្រាកដនៅក្នុងនិកាយណាមួយឡើយ។ ម្យ៉ាងទៀត ពុទ្ធសាសនិកពុំមែនហៅថា "អាជីវិកៈ" ចំពោះមក្ខលិគោសាលៈទេ គឺគេហៅពួកអ្នករស់នៅតាមអាជីវកម្ម តែពួកតាបសទាំងអស់ដែលមិនព្រមរំលាយលទ្ធិរបស់ខ្លួន ហើយប្រគល់ខ្លួនបម្រើព្រះពុទ្ធជាម្ចាស់។ តាមប្រភពរបស់ជេន យើងឃើញថា មក្ខលិគោសាលៈនេះ មានម្តងបានចូលរួមជាមួយនឹងមេដឹកនាំនៃលទ្ធិជេន ប៉ុន្តែខាងក្រោយមក បានឈ្លោះប្រកែកគ្នា ជាហេតុនាំឱ្យមក្ខលិគោសាលៈបែកចេញទៅតែម្នាក់ឯង។ យ៉ាងណាក៏ដោយ នៅក្នុងគម្ពីរព្រះពុទ្ធសាសនា យើងឃើញថាមក្ខលោគោសាសៈនេះ គឺជាគណាចារ្យមួយរូបដែរ នៅជំនាន់ព្រះពុទ្ធជាម្ចាស់ ហើយព្រះអង្គបានហៅពាក្យប្រៀនប្រដៅរបស់គាត់ថា "សុញ្ញវាទី" ។ ប៉ុន្តែគួរឱ្យកត់សម្គាល់ថា ក្នុងចំណោមគណាចារ្យទាំង ៦រូបនោះ គ្រូឈ្មោះនិគន្ថនាដបុត្រ មានឈ្មោះល្បីល្បាញជាងគេទបង្អស់ ហើយមានឈ្មោះប្រាកដជាមេដឹកនាំនៃលទ្ធិជេនថា "មហាវីរៈ" ជាគណាចារ្យរាប់បញ្ចូលជាតិចិន្ករៈទី២៤ ជាគណាចារ្យក្រោយគេបង្អស់ក្នុងប្រវត្តិនិងការរីកចម្រើននៃលទ្ធិជេន ហើយលទ្ធិនិងឈ្មោះនៃមេដឹកនាំបានមានប្រាកដជាញឹកញយក្នុងគម្ពីរព្រះពុទ្ធសាសនា។ ម្យ៉ាងទៀត ពាក្យប្រៀបប្រដៅរបស់លទ្ធិនេះ ព្រះពុទ្ធបានឱ្យឈ្មោះថា "កិរិយវាទី និគន្ថវាទី ឬ ជិនវាទី" តាមលក្ខណៈនិងប្រក្រតីគឺដើមនៃទីដៅរបស់លទ្ធិនេះ។

យើងជឿថាពាក្យប្រៀនប្រដៅរបស់គ្រូទាំងអស់ លើកលែងតែនិគន្ថនាដបុត្រមួយចេញសុទ្ធសឹងតែជាសម្ភារនិយមទាំងអស់។ តាមពិត ទ្រឹស្តីទាំងអស់នោះ កើតឡើងមុនសម័យព្រះពុទ្ធទៅទៀត។ ចំពោះលទ្ធិសម្ភារនិយមទាំងអស់នោះ គង់មានខ្សែស្រឡាយខាងផ្លូវគំនិតរហូតដល់សព្វថ្ងៃនេះពុំខាន ព្រោះហេតុនោះ បានជាយើងប្រព័ន្ធទស្សនវិជ្ជាឥណ្ឌាដូចជាយោគទស្សនៈ, វៃសេសិកទស្សនៈ និងចារុវាគទស្សនៈ (សម្ភារនិយម) ជាដើម មាននាំទ្រឹស្តីប្រហាក់ប្រហែលគ្នានឹងសម្ភារនិយមជំនាន់បុរាណដែរ។ ម្យ៉ាងទៀតយើងឃើញ

*ជាទស្សនរបស់គ្រូឈ្មោះ បកុធកច្ចាយនៈ ដែលថែងថា មានធាតុមិនចេះវិនាសទាំង៧ ជាមូលដ្ឋាននៃធម្មជាតិទាំងអស់ក្នុងលោក មានលក្ខណៈស្រដៀងគ្នានឹងនិន្នាការវាចារតណ្ហាសម័យសព្វថ្ងៃនេះត្រង់លក្ខណៈការស្វែងរកបរមត្ថធម៌ខាងក្រោមធម្មជាតិជាវិជ្ជមាន ជាជាងឯកភាពនៃការពិសោធនៃគំនិត ហើយគេធ្វើអត្ថាធិប្បាយនូវបរមធម៌នោះថាជាសភាវៈពិតវិញ។ ប៉ុន្តែគេពុំបានរកឃើញប្រភពដើមនៃទស្សនៈបែបនោះ ថាជាសភាវៈពិតវិញ។ ប៉ុន្តែ គេពុំបានរកឃើញនៅត្រង់កន្លែងណាមួយឡើយ[១៤]។*

*នៅទីបញ្ចប់នៃសាមញ្ញជលសូត្រនោះយើងសង្កេតឃើញថា មានប្រយោជន៍ជាពិសេសសម្រាប់ការត្រិះរិះដ៏ត្រឹមត្រូវ ដែលបញ្ជាក់ពីលក្ខណៈទូទៅនៃទ្រឹស្តីសម្ភារនិយមព្រមទាំងលក្ខណៈវិភាគ (វិភជ្ជវាទី) ចំពោះសីលធម៌និងផលដែលកើតឡើងពីសីលធម៌នោះៗ។ បន្ទាប់មក ព្រះពុទ្ធជាម្ចាស់បានបញ្ជាក់ពីផលរបស់សាមណៈ (អ្នកស្ងប់រម្ងាប់) ដែលផលិតចេញពីការហ្វឹកហាត់កាយ, វាចា និងចិត្ត។ ប្រព័ន្ធនៃសមាធិចិត្ត ដែលជាហេតុនាំឱ្យបានត្រាស់ដឹងច្បាស់លាស់នូវអរិយសច្ចៈ ហើយទ្រង់បញ្ជាក់ថា ទាំងនេះមានលក្ខណៈផ្ទុយពីអស្តិរូបនិយម ដែលស្ថាបនាឡើងដោយអ្នកទស្សនចិន្តានៅជំនាន់នោះ។*

*យើងសង្កេតឃើញថា នៅក្នុងគម្ពីរទីឃនិកាយ មានសូត្រមួយទៀតឈ្មោះថា ព្រហ្មជាលសូត្រ" (ចូរមើល គម្ពីរទីឃនិកាយសុត្តន្តបិដក ទ្រង់សូត្រទី១ ឈ្មោះ "ព្រហ្មចាលសូត្រ" សំណាញ់ ឬមកដ៏ប្រសើរ ឬធំ។) ដែលមានលក្ខណៈធម)ខ្ពង់ខ្ពស់ជាងសាមញ្ញផលសូត្រទៅទៀត។ នៅក្នុងព្រហ្មជាលសូត្រនោះ ព្រះពុទ្ធជាម្ចាស់បានរួបរួមទ្រឹស្តីដែលមានប្រាកដនៅសម័យនោះ មាន៦២ បែប ហាក់ដូចជាសំណាញ់ដ៏ធំមួយដែលអាចបត់យកមច្ចាជាតិគ្រប់បែបបានដូច្នោះដែរ។ នៅទីបញ្ចប់នៃសូត្រ ព្រះពុទ្ធបានប្រកាសថា បរមត្ថធម៌ ជាធម៌ដ៏លំបាកឃើញ លំបាកយល់ ជាធម៌ដ៏ល្អិតជ្រាលជ្រៅ និងជាធម៌ដ៏ប្រសើរបំផុតហួសវិស័យនៃពួកតក្កវិទូ ជាពិសេស ជាធម៌ដែលអាចនិងឃើញបានដោយពួកបណ្ឌិតដែលគ្មានធូលីក្នុងញាញប៉ុណ្ណោះ ។ បរមត្ថធម៌ទាំងអស់នោះ គឺព្រះតថាគតបានត្រាស់ដឹង ហើយបានប្រកាសទុក្ខ គឺអរិយសច្ចៈ ៤ប្រការនោះឯង។*

*ចំពោះទ្រឹស្តីទាំង ៦២ប្រការនោះ យើងឃើញថាលោកបែកចេញជា ២ក្រុមតាមលក្ខណៈនិងប្រក្រតីដើម ហើយទាំង ២ក្រុមនេះ ត្រូវបានសំណាញ់ដ៏ធំនៃព្រះពុទ្ធជាម្ចាស់ក្រសោប*

[១៤] *ប៉ែន សាអឿន* ***សាសនាប្រៀបធៀប*** *គ.ស.១៩៦៩ ទំ៥០*

យកទាំងអស់គ្មានសេសសល់ឡើយៗ នៅក្នុងសាមញ្ញផលសូត្រ ឃើញឃើញតែទ្រឹស្តីនៃគ្រូទាំង ៦ប៉ុណ្ណោះ ប៉ុន្តែនៅក្នុងព្រហ្មជាលសូត្រ យើងឃើញថា មានទ្រឹស្តីជាច្រើនរហូតដល់ ៦២ ប្រភេទៗ ដូច្នេះឱ្យយើងឃើញថា នៅជំនាន់ព្រះពុទ្ធជាម្ចាស់ មានអ្នកទស្សនចិន្តាច្រើនរាប់មិនអស់ៗ ម្យ៉ាងទៀត យើងអាចសន្និដ្ឋានថា អ្នកទស្សនចិន្តាទាំងអស់នោះ មិនមែនអន់ ឬអន់ខ្សោយនោះទេ អាចប្រៀបបានជាមួយនឹងសេះប្រណាំងបានដែរ ហើយនៅជំនាន់នោះ យើងអាចចាត់ទុកជាសម័យប្រណាំងប្រជែងខាងផ្លូវគំនិតក៏បានៗ ទាំងអស់នេះ នាំឱ្យយើងវិនិច្ឆ័យបានថា ព្រះពុទ្ធជាម្ចាស់បានប្រណាំងប្រជែងជាមួយនឹងសេះយ៉ាងលឿនពុំមែនជាមួយនឹងសេះខ្វក់ជើងឡើយៗ

ម្យ៉ាងទៀត យើងឃើញថា ក្នុងវិភាគទ្រឹស្តីដែលមានលក្ខណៈជាអតីតកាលនៃព្រះពុទ្ធជាម្ចាស់ ដែលទ្រង់មានបដិសម្ភិទាញាណ មានកម្រិតខ្ពស់ជាងវិទ្យាសាស្ត្រវិធីទៅទៀត ព្រោះនៅក្នុងបដិសម្ភិទាញាណនោះ មានមូលវិទ្យាទូទៅសម្រាប់វិភាគគ្រប់លក្ខណៈធម្មជាតុ ឬបាតុភូតគ្រប់បែបទាំងអស់នៅក្នុងលោកនេះនិងលោកខាងមុខព្រមទាំងទីបំផុតលោកៗ យើងអាចឃើញរឿងនេះនៅក្នុងបដិច្ចសមុប្បាទន័យ និងបដ្ឋានន័យដែលយើងនឹងពោលនៅទំព័រខាងមុខស្រាប់ៗ ប៉ុន្តែនៅទីនេះយើងត្រួតត្រាដោយសង្ខេប ដោយការគូសជាតារាងដូចតទៅនេះ [១៥]៖

មូលវិទ្យាទូទៅ

(GEHERAL EPISTEMOLOGY)

ឯកភាពនៃការពិសោធន៍ក្នុងចិន្តា (Uni ty of Experienccs in Thought) | ទ្រឹស្តី (Theory) | ទ្រឹស្តីអនុវត្តន៍ (Applied Theory)

ការយល់ត្រូវ (Right Understanding) | ចិន្តាត្រូវ (Right Thought) | សមាធិត្រូវ (Right Goncentration)

បញ្ញត្តិ ៦ យ៉ាង

(SIX CONCEPTS)

វិជ្ជមានបញ្ញត្តិ | អវិជ្ជមានបញ្ញត្តិ | វិជ្ជមាននេន អវិជ្ជមានបញ្ញត្តិ | អវិជ្ជមាននេន អវិជ្ជមានបញ្ញត្តិ | វិជ្ជមាននេន វិជ្ជមានបញ្ញត្តិ | វិជ្ជមាននេន អវិជ្ជមានបញ្ញត្តិ

[១៥] ប៉ែន សារឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥១

កំណត់សម្គាល់ ៖ មូលវិទ្យា ប្រែថា "វិទ្យាសិក្សាពីប្រភពដើម ប្រក្រតីដើម និងព្រំដែននៃវិទ្យា"។ ក្នុងលក្ខណវិភាគ គេអាចយកប្រធានរម្មណ៍នៃចិត្តប្រកបដោយកក្តីភាព ធ្វើកម្មវត្ថុវិភាគជាអនុលោម បដិលោម អនុលោមបដិលោមនិងបដិលោមានុលោម។ ម្យ៉ាងទៀតនៅក្នុងកម្មវត្ថុវិភាគ ត្រូវមានអាទិសង្កេត វត្តីករណ៍ ការប្រៀបធៀប និងការសរុបរកធម្មភាពទូទៅ ទើបយើងអាចរកឃើញបញ្ញត្តិទូទៅដែលមានកត្តាលក្ខណៈ៦បែបទៀត រួចហើយទើបយើងអាចបង្កើតទ្រឹស្តីបាន។ កាលណាមានទ្រឹស្តីហើយ ទើបមានទ្រឹស្តីអនុវត្តន៍។ កាលណា មានទ្រឹស្តីអនុវត្តន៍ហើយ ទើបមានផលវិបាក ឬលទ្ធភាព ដែលកើតពីទ្រឹស្តីអនុវត្តន៍នោះទៅបាន។

តារាងនៃមូលវិទ្យានេះ គ្រាន់តែបញ្ជាក់ឲ្យឃើញនូវ លក្ខណវិភាគសម្រាប់ពិនិត្យមើលទ្រឹស្តីទូទៅ ព្រោះហេតុនោះ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់អាចបដិសេធនឹងកែតម្រូវព្រមទាំងផ្ចាញ់ពួកអ្នកទស្សនចិន្តាទាំងឡាយនៅសម័យនោះបាន។

តទៅនេះ យើងសូមបរិយាយដោយសង្ខេបពីទ្រឹស្តីទាំង៦២ប្រការ ដែលលោកចែក ជា ២ ក្រុមតាមលក្ខណៈនិងប្រក្រតីដើម ដូចតទៅនេះ ៖

ទ្រឹស្តីទាំង ២ក្រុមនោះគឺ [១៦] ៖

១-សមណៈនិងព្រាហ្មណ៍ទាំងឡាយ ដែលបានស្ថាបនាទ្រឹស្តីមានលក្ខណៈទាក់ទងដល់អតីតកាល មាន ១៨យ៉ាង ៖

ក-ពួកសមណៈនិងព្រាហ្មណ៍ខ្លះយល់ថា "អាត្មន៑ និងពិភពលោកនេះទៀង (សស្សតទិដ្ឋិ) មាន ៤យ៉ាង។

ខ-ពួកខ្លះយល់ថា "អាត្មន៑ និងពិភពលោកនេះ ទៀងខ្លះ មិនទៀងខ្លះ មាន៤យ៉ាង។

គ-ពួកខ្លះយល់ថា "អាត្មន៑ និងពិភពលោកនេះ ប្រែប្រួលខ្លះ មិនប្រែប្រួលខ្លះ ប្រែប្រួលនិងមិនប្រែប្រួលខ្លះ ទាំងមិនប្រែប្រួលទាំងមិនមែនមិនប្រែប្រួលខ្លះ (និច្ចៈ) មាន៤យ៉ាង។

ឃ-ពួកខ្លះព្យាករក្នុងរបៀបមិនឱ្យអ្នកសួរចាប់ចំណុចបាន មានលក្ខណៈដូចជាចាប់អន្ទង់ក្នុងទឹក ហើយបដិសេធពុំព្រមឆ្លើយឱ្យច្បាស់លាស់ មាន៤យ៉ាង។

ង-ពួកខ្លះទៀតបានប្រកាសថា "អាត្មន៑និងពិភពលោកនេះ កើតឡើងដោយប្រាសចាកហេតុ មាន ៤យ៉ាង។

---

[១៦] សូមមើល អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៨ ត្រង់បញ្ញត្តិ ៦យ៉ាង

២-សមណៈនិងព្រាហ្មណ៍ពួកខ្លះ បានស្ថាបនាទ្រឹស្តីដែលមានលក្ខណៈទាក់ទងដល់អនាគតកាលមាន ៤៤យ៉ាងគឺ ៖

ក-ពួកខ្លះយល់ថា“អាត្មន័មិនប្រកបដោយសញ្ញាបន្ទាប់ពីសេចក្តីស្លាប់មាន ១៦ យ៉ាង។

ខ-ពួកខ្លះយល់ថា “អាត្មន័ប្រកបដោយសញ្ញា បន្ទាប់ពីសេចក្តីស្លាប់ មាន៨យ៉ាង។

គ-ពួកខ្លះយល់ថា “អាត្មន័ប្រកបដោយនេវសញ្ញា នាសញ្ញា បន្ទាប់ពីសេចក្តីស្លាប់ មាន ៨យ៉ាង។

ឃ-ពួកខ្លះយល់ថា “អាត្មន័ បន្ទាប់ពីសេចក្តីស្លាប់ ត្រូវសូន្យទៅតែម្តង” មាន ៧យ៉ាង។

ង-ពួកខ្លះយល់ថា “ព្រះនិព្វានគឺឋិតនៅក្នុងការរីករាយសប្បាយនៃជីវិតក្នុងបច្ចុប្បន្ន ឬការសប្បាយក្នុងកាមគុណ ឬក៏ការសប្បាយនៃជីវិតក្នុងឈាន” មាន ៥យ៉ាង។

សរុបទ្រឹស្តីរួមទាំងឡាយជាអតីតកាលនិងអនាគតកាលទាំងអស់នេះត្រូវជា៦២ប្រការ។

បណ្តាទ្រឹស្តីទាំង៦២នោះ យើងសង្កេតឃើញថា មានទ្រឹស្តីខ្លះបានទាក់ទងដល់លោកធាតុវិទ្យា (Cosmology) ហើយទ្រឹស្តីបែបនោះពុំមានលក្ខណៈច្បាស់លាស់បញ្ជាក់ពីនិកាយទស្សនៈណាមួយឡើយ។ ចំពោះទ្រឹស្តីសស្សតវាទី យើងឃើញថា សមណៈនិងព្រាហ្មណ៍ពួកខ្លះយល់ថាអាត្មន័និងពិភពលោកជាធម្មជាតិទៀង មិនចេះប្រែប្រួល វិនាសឬសាបសូន្យទៅជាប្រការដទៃទៀតឡើយ។ ក្នុងសូត្រនេះបញ្ជាក់ថា ពួកសមណៈនិងព្រាហ្មណ៍ពួកខ្លះ បានចម្រើនសមាធិចិត្ត ហើយចាំបានជីវិតអតីតៈជាច្រើនជាតិ បានប្រកាសថា “អាត្មន័និងពិភពលោកមានភាពទៀង មិនផលិតធម្មជាតុថ្មីទៀត (និច្ចលៈ) តាំងនៅស្ថិតស្ថេរជានិច្ច មិនប្រែប្រួលឬវិនាសឡើយ។ គេយល់ថា សត្វលោកមួយរូបៗ ត្រូវស្លាប់ហើយកាន់យកបដិសន្ធិ ឬកំណើតថ្មីទៀតជាធម្ម ប៉ុន្តែអាត្មន័និងពិភពលោកនេះ មិនស្លាប់ឬសាបសូន្យទៅណាឡើយជាសភាពទៀត (សស្សត)។ រឿងនេះព្រះពុទ្ធសាសនាបានប្រកាសប្រឆាំង នឹងទ្រឹស្តីនេះ ជាដាច់ខាត ថាគ្រប់ធម្មជាតិទាំងអស់ ដែលកើតឡើងដោយគ្រឿង ឬធាតុផ្សំមានលក្ខណៈ មិនឋិតថេរទៀងទាត់ (អនិច្ចៈ) មិនមានអាត្មន័ (អនត្តា) និងប្រកបដោយទុក្ខទាំងអស់ (ទុក្ខៈ)។ ទាំង៣នេះ ជាត្រៃលក្ខណ៍នៃលោកនេះ[១៧]។

ចំពោះទ្រឹស្តីក្រុមទី១ (ខ) យើងសង្កេតឃើញថា អ្នកទស្សនវិទូក្រុមនេះបានពោលបញ្ជាក់ដល់កំណើតនៃពពួកទេព្តា។ មហាព្រហ្មខ្លួនឯង បានចាប់កំណើតថ្មីទៀត ដូចជាសត្វ

---

[១៧] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥៣

ទាំងឡាយដទៃទៀតដែរ។ ព្រះព្រហ្មនេះ ព្រះឃោសាវបរយល់ថា ជាសត្វទី១និងជំបូងបង្អស់កើតឡើងមុនគេបង្អស់ ក្នុងកប្បថ្មីនីមួយៗ ហើយលោកគិតថាខ្លួនលោកជាអាទិទេពធំជាងគេបង្អស់ ព្រមទាំងរស់នៅមិនចេះស្លាប់ទៅណាឡើយ។ ព្រះព្រហ្មគិតថា សត្វលោកព្រមទាំងទេព្តាទាំងឡាយដទៃទៀត កើតឡើងក្រោយលោកទាំងអស់ ព្រមទាំងដោយកម្លាំង ញាណចិត្ត និងបំណងរបស់លោក គឺខ្លួនលោកជាអ្នកឱ្យកើតកំណើត ព្រោះហេតុនោះ បានជាសត្វព្រមទាំងទេព្តាទាំងឡាយនោះ ស្ថិតនៅក្នុងការមិនទៀងទាត់ និងអាយុខ្លី។

ក្នុងក្រុមទ្រឹស្តីជាមួយគ្នានេះ ទ្រឹស្តីមួយទៀតយល់ថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ត្រូវឋិតនៅក្នុងសភាវៈមិនទៀងទាត់ទាំងអស់។ ឯព្រលឹង ចិត្ត ឬវិញ្ញាណតែងឋិត នៅក្នុងសភាវទៀងទាត់ មិនមែនប្រែប្រួល ឬវិនាសទៅណាឡើយ។ ចំពោះទ្រឹស្តីទី១ (គ) យើងឃើញថា ពុំមានបញ្ជាក់ជាពិសេសចំពោះរឿងអាត្មនថា ទៀងឬមិនទៀងឡើយ។

យ៉ាងណាក៏ដោយ យើងគួរកត់សម្គាល់ថា ទ្រឹស្តីទាំង ១៨ ដែលទាក់ទងដល់អតីតកាលនៃចិន្តា មានការពោលដល់អាត្មន និងកំណើតដើមនៃអាត្មន និងលោកនេះទាំងអស់។

ដទៃពីទ្រឹស្តីទាំង១៨ នេះ មានទ្រឹស្តី ៤៤បែបទៀត បានទាក់ទងដល់អនាគតចិន្តារបស់អាត្មននិងពិភពលោក។ ទ្រឹស្តីទាំងអស់នោះ លោកចែកចេញជា ៥ក្រុម។ ទី១និងទី២ មានលក្ខណៈទ្រឹស្តីពុំសូវច្បាស់លាស់ ប៉ុន្តែលោកបានបញ្ជាក់ថា អាត្មនខាងក្រោយពីសេចក្តីស្លាប់ មានជីវិតរស់នៅបាន ដឹងបាន។ បើដូច្នោះ អាត្មននោះប្រហែលជាមានសញ្ញា មានព្រលឹង អាចទទួលសេចក្តីសុខ-ទុក្ខ និងប្រកបដោយលក្ខណៈដ៏ទៀងទាត់បានជាប្រាកដ។ ទាំងអស់នេះមានលក្ខណៈ ១៦យ៉ាង។ ឯក្រុមទី២ មាន ៨យ៉ាង ចែងថាអាត្មនបន្ទាប់ពីសេចក្តីស្លាប់ មិនមានសញ្ញា មិនប្រាកដថាអាចបង្កឱ្យនៅជារូបបានឬមិនបាន។ រួមទ្រឹស្តីទី១និងទី២ត្រូវជា២៤បែប។ ក្នុងទ្រឹស្តីទាំង ២៤នេះ ព្រះពុទ្ធឃោសាចារ្យ បានបញ្ជាក់ព្រមទាំង បានយាងទៅរកអាត្មនចិន្តា ដែលប្រកបដោយការស្មាន រួចហើយលោកបានធ្វើអត្ថាធិប្បាយថា ទ្រឹស្តីបែបនេះ ខ្លះជារបស់ពួកជីវិកៈ ខ្លះជារបស់ពួកអចេលលទ្ធិ (ជេន) ហើយខ្លះទៀតជារបស់ក្រុមដទៃពីក្រុមទាំងពីរនេះ[១៨]។

ឯក្រុមទ្រឹស្តីទី៣ ជារបស់ពួកតក្កវិទូ។ ចំពោះក្រុមទី៤វិញ យើងឃើញថាមានលក្ខណៈឧច្ឆេទវាទី ដែលនៅក្នុងសាមញ្ញផលសូត្រ (សូមមើលក្នុង សាមញ្ញផលសូត្រ , សូត្រទី២ នៃ

---

[១៨] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥៤

គម្ពីរទីឃនិកាយ, សុត្តន្តបិដក។) លោកថាជារបស់គ្រូឈ្មោះ អជិតកេសកម្ពលៈ។ ចំពោះក្រុមទ្រឹស្តីទី៥ គេយល់ថា ព្រះនិព្វានអាចប្រព្រឹត្តបានក្នុងលោកនេះ។ ទ្រឹស្តីនេះ បើគេគ្រាន់តែឃើញភ្លាម មុខជាគេស្មានថាមានលក្ខណៈដូចគ្នានឹងព្រះនិព្វាននៃព្រះពុទ្ធសាសនាដែរ ប៉ុន្តែតាមពិត ផ្ទុយទៅវិញទេ ព្រោះព្រះនិព្វាននោះ គេសំដៅយកការសប្បាយរីករាយ ឬក៏មោក្សៈនៃប្រាសាទទាំង៥ នៃមនុស្សលោកក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ។ យើងអាចចាត់ទុកទ្រឹស្តីនេះជាសម្ភារនិយមក៏បាន។

តាមការសន្និដ្ឋានថា ព្រហ្មជាលសូត្រ គឺព្រះពុទ្ធជាម្ចាស់មានបំណងរួបរួមទ្រឹស្តីទាំងអស់ នោះ ទោះជាមានលក្ខណៈស្របគ្នាក្តី មិនស្របគ្នាក្តី ឬទាំងស្របគ្នានិងមិនស្របគ្នាក្តី។ ទ្រឹស្តីទាំងអស់នេះ តាមយើងសង្កេតទៅឃើញថា ព្រះពុទ្ធជាម្ចាស់ពុំមែនបដិសេធទាំងស្រុងទេ គឺព្រះពុទ្ធព្រះអង្គមានបំណងយកនូវគុណធម៌មួយដ៏សំខាន់ គឺការរួបរួមទុកក្នុងក្រុមតែមួយសម្រាប់បញ្ជាក់ឱ្យឃើញថា តើទ្រឹស្តីទាំងអស់នោះបានបរិយាយពីអាត្មន័និងពិភពលោកនេះដូចម្តេចខ្លះ។ បណ្តាទ្រឹស្តីទាំងអស់នេះ យើងឃើញថាមានទ្រឹស្តីខ្លះជារបស់លទ្ធិព្រាហ្មណ៍ និងខ្លះទៀតជារបស់និកាយទស្សនវិជ្ជាទាំងឡាយដទៃទៀត ដែលវិវដ្តមានឡើងនៅសម័យនោះ។

ចំពោះអតីតកាលចិន្តា ត្រង់ទ្រឹស្តីទី១ ដែលថាអាត្មន័និងពិភពលោកជាធម្មជាតិទៀង (សស្សតៈ) នោះ , លោក អុលដិនប៊ើក (មើល "INDIM" , by oldonburg.) (Oldonburg) បានបញ្ជាក់ថា មានលក្ខណៈដូចគ្នានឹងប្រព័ន្ធសំខ្យាទស្សនវិជ្ជានៃឥណ្ឌា ត្រង់ចំណុចមួយដែលថា បុរិសៈ (Spirit) និងបកតិ (Nature) ទាំងពីរនេះជារបស់ទៀងដែរ។ ប្រព័ន្ធនេះបានប្រើការប្រៀបធៀបមួយថា អាត្មន័ (បុរិសៈ) តែងឋិតនៅមិនប្រែប្រួល ដូចជាតួភ្នំដែលឋិតនៅមិនកម្រើកដូច្នោះដែរ។ ចំពោះអាត្មន័បែបនេះ មានលក្ខណៈផ្ទុយនឹងវិវឌ្ឍនាការនៃលោកព្រមទាំងលោកធាតុ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានសម្តែងរួចហើយថា វត្ថុធាតុព្រមទាំងធម្មជាតុទាំងអស់ ជាធម្មជាតិមិនទៀតទាំងអស់។ នៅមានកន្លែងមួយទៀតដែលលោក អុលដឹកប៊ើក បានពោលថាដូចទ្រឹស្តីទី១ គឺត្រង់ចំណុចថា ភ្នែក ត្រចៀក ច្រមុះ អណ្តាតនិងកាយ ជា សភាវមិនទៀងទាត់ និងប្រែប្រួលជានិច្ច (អនិច្ចតា) , ឯចំណែកព្រលឹង គឺជាសភាវទៀង (និច្ចតា)។ ត្រង់ចំណុចនេះ យើងឃើញថាមិនពិតដែរ ព្រោះប្រព័ន្ធសំខ្យាទស្សនវិជ្ជាយល់ថា មិនមែនតែប្រាសាទទាំង៥នោះប៉ុណ្ណោះទេ ដែលជាអនិច្ចតា សូម្បីចិត្តសម្បទាក៏ជាអនិច្ចតា ដែរ។ លោក

អុលដឹនបើក មានការភ័ន្តច្រឡំក្នុងរឿងនេះ។ រឿងនេះយើងអាចសន្និដ្ឋានថា ទ្រឹស្តីដែលមានក្នុងព្រហ្មជាលសូត្រនៃព្រះពុទ្ធសាសនា ប្រហែលជាទ្រឹស្តីដើមមុនការរីកចម្រើននៃប្រព័ន្ធសំខ្យាទស្សនវិជ្ជាទៅទៀត[១៥]។

នៅក្នុងប្រព័ន្ធសំខ្យាទស្សនវិជ្ជា យើងសង្កេតឃើញថា មានលក្ខណៈធម្មប្រក្រតីបានពោលដល់រចនាសម្ព័ន្ធនៃលោកហៅថា "លោកនិម្មាណវិជ្ជា" (Cosmogony)។ នេះហើយដែលនាំឱ្យលោក ជាកូប៊ី (Jacobi) យល់ច្រឡំថាព្រះពុទ្ធសាសនា ត្រង់បដិច្ចសមុប្បាទន័យបានចម្លងយកតាមប្រព័ន្ធសំខ្យាទស្សនវិជ្ជាទាំងស្រុង។ យើងគួរបញ្ជាក់ពីប្រព័ន្ធទ្រឹស្តីសំខ្យាទស្សនវិជ្ជាដូចតទៅនេះ ៖

បកតិ (Nature) មានគុណធម៌ ៣យ៉ាងគឺ ៖

១-អតិសមភាវតា (Prefect Equilibrium)

២-សមភាវវិប្បលាយ (It is the uqsetting of the Equilibrium)

៣-អត្តលោកុប្បាទសម្ភារផលតា (The consequent elaboration of the constituents in different proportions which constitute the actual world both material and spiritual.)

គុណធម៌ទាំង៣នេះ ផលិតឡើងក្នុងរូបសភាវៈដែលមានលក្ខណៈស្រាល ចល័តនិងធ្ងន់ ហើយភាវៈទាំងអស់នេះ កើតប្រាកដឡើងក្នុងចិត្តជាកុសល អកុសល លោភៈ ទោសៈ មោហៈថែមទៀត។ នៅខាងក្រៅពីសភាវៈទាំងអស់នេះមានអាត្មន់ជានិច្ចតា (ទៀង) (Permanent Atman)។ បកតិធម៌មានសជាតិកពុទ្ធិ (Congenital Intellect) ដែលក្លាយជាអហង្ការៈ (Egoity) ដែលដូចគ្នានឹងបដិសន្ធិវិញ្ញាណនៃទ្រឹស្តីព្រះពុទ្ធសាសនា ដែលជាបច្ច័យនៃនាមរូប។ យើងអាចប្រៀបធៀបប្រព័ន្ធនៃទ្រឹស្តីរចនាសម្ព័ន្ធនៃលោករបស់ព្រះពុទ្ធសាសនា និងសំខ្យាទស្សនវិជ្ជាដូចតទៅនេះ ៖

| **បដិច្ចសមុប្បាទនៃព្រះពុទ្ធសាសនា** | **លោកនិម្មាណវិជ្ជានៃប្រព័ន្ធសំខ្យា** |
| --- | --- |
| អវិជ្ជា | បកតិ |
| សង្ខារ | គុណៈ |
| វិញ្ញាណ | ពុទ្ធិ |
| នាមរូប | អហង្ការៈ |

---

[១៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥៥

| | |
|---|---|
| សឡាយតនៈ | ឥប្បើ: ១០យ៉ាង |
| វេទនា | តំ មាត្រា |
| តណ្ហា | អភិនិវេសៈ ឫអាសី |
| ឧបាទាន | ធម្មាធម្មៈ |
| ភវៈ | គព្ភគតដ្ឋានៈ |
| ជាតិ | គព្ភគតដ្ឋានៈ |
| ជរា | គព្ភគតដ្ឋានៈ[២០] |

**កត់សម្គាល់៖** ក្នុងប្រព័ន្ធសំខ្យាទស្សនវិជ្ជា យើងសង្កេតឃើញថា ពុំមានរាប់ជាតិ និង ជរាមរណៈចូលក្នុងប្រព័ន្ធឡើយ។ នៅក្នុងប្រព័ន្ធទស្សនវិជ្ជាទាំងឡាយដទៃទៀត ក៏យើងពុំបានឃើញគេរាប់បញ្ចូលជាតិ និង ជរា-មរណៈដែរ, ព្រោះគេយល់ថា ជាតិ គឺផលវិបាកនៃវដ្ត-សង្សារ ឯជរា-មរណៈជាផលវិបាកនៃជាតិ។ ចំណែកបដិច្ចសមុប្បាទនៃព្រះពុទ្ធសាសនាមានរាប់ជាតិនិងជរា-មរណៈ នៅខាងមុខនៃកងចក្រលោក ហើយលោកចាត់ទុកជាវិបាកវដ្តៈ ដែលជាលទ្ធភាពនៃកិលេសវដ្តៈនិងកម្មវដ្តៈ។ កងចក្រនៃវដ្តសង្សាររបស់ព្រះពុទ្ធសាសនា មាន១២កាំ ឯប្រព័ន្ធនៃសំខ្យា មានតែ ១០កាំគត់។

ចំពោះប្រព័ន្ធសំខ្យា យើងសង្កេតម្យ៉ាងទៀតថា ព្រះពុទ្ធឃោសាចារ្យបានឱ្យឈ្មោះថា "បកតិវាទី"។ រឿងនេះ នាំឱ្យយើងយល់ថា នៅពេលដែលប្រព័ន្ធសំខ្យានេះនៅមិនទាន់រីកចម្រើននៅឡើយ ប្រព័ន្ធនេះប្រាកដជាពុំមានលក្ខណៈដូចសព្វថ្ងៃនេះជាដាច់ខាត ព្រោះនៅក្នុងព្រហ្មជាលសូត្រនៃព្រះពុទ្ធសាសនា លោកបានបញ្ចូលទៅក្នុងបញ្ជីទ្រឹស្តី ៦២ បែបនោះដែរ ត្រង់ក្រុមទ្រឹស្តីទី១-២ និងទី៣ ផ្នែកខាងអតីតកាល។ លោក Oldenburg, Jacohi, Pischel និង Dr.Schayer យល់ថា ប្រព័ន្ធសំខ្យាមានឥទ្ធិពលទៅលើព្រះពុទ្ធសាសនា ជាការមួយក័ន្តប្រឡំគួរឱ្យស្តាយ ព្រោះថាបើយើងគុណលេខទៅ យើងគង់នឹងឃើញថា ការរីកចម្រើននៃប្រព័ន្ធសំខ្យាមានកម្រិតអាយុក្រោយព្រះពុទ្ធសាសនាឆ្ងាយណាស់។ ម្យ៉ាងទៀតយើងសង្កេតឃើញថា ធម្មវិភាគនៃប្រព័ន្ធព្រះពុទ្ធសាសនា និងសំខ្យា ក៏មានលក្ខណៈខុសគ្នាស្រឡះ ទោះណាជាធម្មកត្តានិងធម្មជាតុខ្លះមានពាក្យដូចគ្នាក៏ដោយ ក៏អត្ថន័យនៃធម្មកត្តានិងធម្មជាតុនោះៗ មានលក្ខណៈប្រក្រតីដើម។ រីឯគោលបំណង ព្រំដែន ព្រមទាំងទីដៅក៏ខុសគ្នាដែរ។ ជា

[២០] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥៦

ទី បំផុត យើងយល់ថា ព្រះពុទ្ធជាមហាអ្នកប្រាជ្ញ ព្រះអង្គពុំដែលបដិសេធសច្ចធម៌របស់អ្នកណាទេ ហើយការមិនបដិសេធនោះ ពុំមែនបានន័យថាទ្រង់ស្រង់ឬរៀនយកពីគេនោះឡើយ។

តាមការសន្និដ្ឋានទូទៅ យើងឃើញថា ទស្សនពុទ្ធនិយមផ្នែកមហាយាន ប្រហែលជាមានឥទ្ធិពលពីប្រព័ន្ធទស្សនវិជ្ជាហិណ្ឌូពួកខ្លះពុំខាន ព្រោះនិកាយទស្សនៈមហាយាន ទើបនឹងរីកចម្រើនខាងក្រោយព្រះពុទ្ធបរិនិព្វាន ឯចំណែកទស្សនពុទ្ធនិយមផ្នែកខាងថេរវាទ ដែលមានព្រះត្រៃបិដកបាលីជាមូលដ្ឋាន គឺប្រាកដជាពុំមានឥទ្ធិពលពីប្រភពណាឡើយ។ បើទុកជាមានលក្ខណៈពីប្រភពទស្សនៈដទៃទៀតនៅជំនាន់នោះក៏ដោយ ក៏ក្នុងលក្ខណៈនៃការកែទម្រង់និងការកែសម្រួលដែរ។ នេះជាការពិតឥតប្រែប្រួល[២១]។

គ-លទ្ធិគ្រិស្ត ៖ ១-កក្កិធម៌ ( Mysti ci sme ) ប្រហែល ១៨០ ឆ្នាំកន្លងទៅហើយ យើងឃើញថា ពួកអ្នកវិចារណ៍ជាច្រើននៃពាក្យបណ្ដាំសម័យថ្មី ( New test ment ) នៃលទ្ធិគ្រិស្តមានការក័ន្តប្រទ្បំថា ចលនានៃលទ្ធិគ្រិស្តបានចាប់កំណើតពីត្រឹមមានសកម្មភាពរបស់សាស្ត្រាចារ្យទស្សនវិទូខ្លះ ដូចជាលោកសូក្រាត ( Socrates ) ស្តូអិក ( Stoic )ប្លាតុង( Plato ) ជាដើមហើយបានរីកចម្រើនគោរពព្រះអាទិទេព ជារបៀបវីរបុរសជាដើម។ តាមពិតលទ្ធិគ្រិស្តជាលទ្ធិកែទម្រង់នៃជំនឿរបស់ប្រជាជន ជ្វីហ្វ ដែលគេហៅលទ្ធិហ៊ីប្រូវ មានគម្ពីរប៊ីបជាមូលដ្ឋាន។ នៅសម័យនោះ វិភាគនៃឯកសារទូទៅបានបញ្ជាក់ថា ក្នុងវេលាដែលព្រះយេស៊ូកំពុងមានជីវិតរស់នៅក៏ដោយ ក៏ពុំឃើញថា លោកបានសម្ដែងគម្ពីរផ្សេងៗដែរ សូម្បីព្រះនាមព្រះយេស៊ូ ក៏ពុំបានលេចឮ នៅកន្លែងណាមួយឡើយ។ ក្បួនច្បាប់នៃលទ្ធិហ៊ីប្រ៊ូវទាំងអស់ គឺគេធ្វើឡើងតាមមូលដ្ឋាននៃព្រះគម្ពីរប៊ីប ដែលគេហៅថាពាក្យបណ្ដាំបូរាណ ( old Testament ) ជាព្រះ គម្ពីរដែលគេទុកជាអដ្ឋកថា នៃព្រះគម្ពីរប៊ីបមានមកសម្រាប់ ប្រជាជាតិជ្វីហ្វ ( Jews ) ។ ដូច្នេះយើងឃើញថានៅអរដ្ឋកថានៅសម័យមុនលទ្ធិគ្រិស្ត ប្រជាជាតិនៃជ្វីហ្វប្រតិបត្តិតាមលំអាននៃគម្ពីរបូរាណដែលស្ដែងពីមានជីវិតបច្ចុប្បន្ន និងអនាគតយ៉ាងច្បាស់លាស់។ នៅពេលនោះ លទ្ធិហ៊ីប្រ៊ូវ មានការស្ដែងពីការគោរពទេព្ដាជាច្រើនបែប ដែលគេ ហៅថា ពហុទេវនិយម មានទេព្ដាដ៏ជាធំមួយគេហៅថាព្រះយេហ៊ូវ៉ាហ៍ ( Jehuvah )ជាព្រះម្ចាស់លោក ជាព្រះតំណាងនៃធម្មជាតិទាំងអស់ និងជាព្រះបង្កើត លោក ប៉ុន្តែពុំមានអវតារ ណាមួយមកកើតលើលោកនេះឡើយ។

---

[២១] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៥៧

ចំពោះស្ថានភាពនៃគម្ពីរប៊ីប យើងឃើញថា គេទុកជាប្រភពដើមនៃលទ្ធិហ៊ីប្រ៊ូវ និង លទ្ធិគ្រិស្ត។ គេនិយាយថា ព្រះយេហូវ៉ាហ៍ជាអ្នកបង្កើតតាមប្រភពនៃលទ្ធិហ៊ីប្រ៊ូវ ឯតាម ប្រភេទនៃលទ្ធិគ្រិស្ត ឬយេស៊ូគ្រិស្ត គេនិយាយថា ព្រះគ្រិស្តជាអ្នកបង្កើត។ ពួកលទ្ធិហ៊ីប្រ៊ូវ មានគម្ពីរបូរាណឈ្មោះថា“ old Testament ” ពុំមានប្រាកដថា មានអវតារណា មួយជា អ្នក បង្កើតឡើយ ឯពួកលទ្ធិគ្រិស្ត ឬយេស៊ូគ្រិស្ត មានគម្ពីរ សម័យថ្មីមួយឈ្មោះថា “ New testament ”។

មានព្រះយេស៊ូហ្នឹងឯងដែលគេសន្និដ្ឋានថា ជាអវតារនៃព្រះគ្រិស្តជាអ្នកបង្កើត។ តាម ប្រភពទូទៅ យើងពុំឃើញថាព្រះយេស៊ូខ្លួនឯងបានសរសេរទុកនូវព្រះគម្ពីរថ្មីនៅឡើយ។ តាមពិត ព្រះគម្ពីរថ្មីនេះ “New testament” ប្រហែលជាកើតឡើងក្រោយ មរណកាលនៃព្រះ យេស៊ូ ព្រោះសិស្សសាវ័ករបស់លោកបានឃើញ សេចក្តីអស្ចារ្យនៃលោកគឺបន្ទាប់ពីការ ក្តាងសម្ងាប់នៃលោកមកចំនួន៣ ថ្ងៃប៉ុណ្ណោះ ស្រាប់តែរបើកផ្នូរឡើងបាត់រូបស្ពាប់របស់ព្រះ យេស៊ូតែម្តង។ រឿងនេះគេបានសន្និដ្ឋានថា ព្រះយេស៊ូបានរស់ឡើងវិញ ដោយអំណាចដ៏ ខ្ពង់ខ្ពស់នៃព្រះគ្រីស្ត។ ម្យ៉ាងទៀត ការអស្ចារ្យនេះបណ្តាលឱ្យគេសន្និដ្ឋានថា ព្រះយេស៊ូ ប្រាកដជាអវតារដែលព្រះគ្រិស្តចាត់មកឱ្យជួយស្រោចស្រង់ពិភពលោក តាំងពីពេលនោះ មកលទ្ធិគ្រិស្ត ឬ យេស៊ូគ្រិស្ត ក៏បានរីកចម្រើនឡើង ផ្សព្វផ្សាយពាសពេញមជ្ឈិមបូព៌ា និង អឺរ៉ុបថែមទៀត។ មិនតែប៉ុណ្ណោះ លទ្ធិគ្រីស្តមានបែកនិកាយជាច្រើនដូចជា លទ្ធិព្រាហ្មណ៍ ព្រះពុទ្ធសាសនា និងលទ្ធិអ៊ីស្លាមដែរ ប៉ុន្តែលទ្ធិនេះមាននិកាយធំៗ ២ គឺនិកាយកាតូលិក និង ប្រូតេស្តង់ ហើយនិកាយ នីមួយៗមានបែកជានិកាយតូចៗទៅទៀតជានិច្ច។

គួរកត់សម្គាល់ថា លទ្ធិគ្រិស្តទោះណាមាននិកាយច្រើនយ៉ាងនេះក៏ដោយ ក៏គោលដ៏ សំខាន់នៃជំនឿទូទៅ មានមូលដ្ឋានទៅលើព្រះអាទិទេព ដែលគេហៅថា“ព្រះគ្រិស្ត”ហ្នឹងឯង។ ម្យ៉ាងទៀតលទ្ធិគ្រិស្តមានអង្គការធំៗជាច្រើនក្នុងសកលលោក ហើយអង្គការទាំងនោះ សម្រាប់រក្សាជំនឿទូទៅនិងការផ្សាយ។ អង្គការដែលធំជាងគេ គឺអង្គការនៅវ៉ាទិកង់ ទីក្រុង រ៉ូមនៃប្រទេសអ៊ីតាលី ដែលមានព្រះមហាសង្ឃរាជ ( Pope) ជានាយក។ ឯលទ្ធិទូតទាំងអស់ ក្នុងពិភពលោក ត្រូវបានតែងតាំងនិងទទួលអំណាចពីលោកទាំងអស់។

នៅក្នុងព្រះគម្ពីរថ្មីនៃលទ្ធិគ្រិស្ត ( New testament ) យើងឃើញថា កក្តីធម៌ នៃលទ្ធិ គ្រិស្ត អ្នកនិពន្ធឈ្មោះ រ-ម-ជូន ( R.M. Jones )បានបញ្ជាក់ថា មានកក្តីធម៌ តិចតួចជាទី

បំផុតតាមលក្ខណៈបច្ចេកទេស។ សេចក្ដីសំអាងមាននិន្នាការថា លទ្ធិគ្រិស្ត មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងទ្រឹស្ដីរបស់លោកស្តូអិក ( Stoic ) ដែលយល់ថា សីលធម៌និងការស្ងប់ចិត្តជាសភាវៈល្អជាទីបំផុត សម្រាប់មនុស្សលោកគ្រប់រូប ហើយទ្រឹស្ដីរបស់លោកនេះបានប្រៀនប្រដៅឱ្យមនុស្សលោកមានអព្យាគត់ធម៌ ចំពោះការសប្បាយទៅវិញនៅក្នុងលោកនេះ ជាពិសេសឱ្យមានសេចក្ដីកំណត់ទុក្ខទូទៅ ព្រោះវាជាធម្មតានៃលោក។ នេះជានាំងនៃទឹកចិត្តរបស់មនុស្សម្នាក់រូបៗ។ ប៉ុន្តែទឹកចិត្តរបស់អ្នកគ្រិស្ត ត្រូវតែប្រកបដោយចិត្តរបស់ព្រះអាទិទេពព្រមទាំង ជាអ្នករក្សានូវសេចក្ដីប្រកាស ( Revelation )របស់ព្រះអង្គហើយកាលបើធ្វើដូច្នេះ គេម្នាក់ៗនឹងមានក្ដែកឋិតនៅហទយវត្ថុជានិច្ច។ ដូច្នេះយើងឃើញថាការពិសោធន៍ ពិសោធន៍ផ្ទាល់ខ្លួនរបស់ព្រះគ្រិស្តដូចជាបានឃើញក្នុងព្រះគម្ពីរនេះ គឺជាគំរូដ៏ខ្ពង់ខ្ពស់បំផុតនៃកក្ដីធម៌តែម្ដង។ កក្ដីធម៌បានន័យថា ម្នាក់ៗត្រូវមានកក្ដីស្វាមី កក្ដីចំពោះព្រះអាទិទេព ហើយ ប្រព្រឹត្តតាមប្រសាសន៍របស់ព្រះអង្គ។

២-ជីវប្រវត្តិសង្ខេបនៃព្រះយេស៊ូ ៖ ព្រះយេស៊ូកើតឡើងក្នុងលោក នៅក្នុងភូមិតូចមួយឈ្មោះ បេត្លេហិម ( Bethlehem ) ព្រះយេស៊ូកើតឡើងក្នុងលោកនៅក្នុងភូមិ ព្រះនាមនាង ម៉ារី ( Mary ) ព្រះបិតាព្រះនាម ជោ សេហ្វ ( Joseph )។ ប៉ុន្តែ ព្រះនាងម៉ារីពុំទាន់បានអាពាហ៍ពិពាហ៍ជាមួយនឹងជោ សេហ្វនៅឡើយ ក៏ព្រះនាងមាន ផ្ទៃពោះហើយប្រសូតមកបានកូនប្រុសព្រះនាមថា "យេស៊ូ ( Jesus )"។

មានសេចក្ដីជំណាលថា ព្រះយេស៊ូដែលចូលមកចាប់ផ្ទៃរបស់ព្រះនាងម៉ារី គឺដោយអំណាចដ៏ស័ក្ដិសិទ្ធិនៃព្រះអាទិទេពជាម្ចាស់ ហើយនៅពេលនោះ ព្រះនាងម៉ារីកំពុងឋិតនៅក្នុងវ័យព្រហ្មចារីយ៍នៅឡើយ។ នៅថ្ងៃដែលប្រសូតព្រះកុមារយេស៊ូ ព្រះអម្ចាស់ក៏បានមកឱ្យ ជោ សេហ្វ យល់សប្តិឃើញ ព្រះអង្គបានមកបង្គាប់លោកឱ្យទៅយកកូននិងព្រះនាង ម៉ារីសជាភរិយាទៅថែរក្សាផង ព្រោះព្រះនាងដែលមានកូននោះគឺបណ្ដាលមកពីអំណាចរបស់ព្រះម្ចាស់ទេ ហើយកូននេះនឹងក្លាយទៅជាមនុស្សអស្ចារ្យមួយរូប អាចស្រោចស្រង់ប្រជារាស្ត្ររបស់ខ្លួនឱ្យរួចពីបាបគ្រប់យ៉ាងបាន។ លោក ជោ សេហ្វ និមិត្តតែបានឮព្រះតម្រាស់នេះក៏ទទួលតាមព្រះឱង្ការ។ លុះព្រឹកឡើងលោកក៏ ម៉ម្នាទៅទទួលយកកូន នឹង ព្រះនាងម៉ារីមកថែរក្សាដូចជាភរិយា និងកូនរបស់ខ្លួន។

ព្រះយេស៊ូ កើតឡើងក្នុងលោក ក្នុងរជ្ជកាលព្រះរាជាមួយព្រះអង្គ ព្រះនាម ហេរ៉ូដ ( Herod ) នៃរដ្ឋជេរូសាឡិម ( Jerosalem )ដែលសព្វថ្ងៃនេះនៅក្នុងការគ្រប់គ្រងនៃរដ្ឋាភិបាលអ៊ីស្រាអែល ( Israel )។ សម័យមួយមានអ្នកប្រាជ្ញខ្លះមកពីបូព៌ាប្រទេស ហើយចូលមករដ្ឋជេរូសាឡិមដើម្បីក្រាបបង្គំព្រះរាជាអង្គនេះ។ គេបានក្រាបទូលសួរព្រះរាជាថា "មហារាជចុះព្រះរាជបុត្រដែលបានប្រសូតហើយនោះ ហើយដែលត្រូវបានជាព្រះរាជាគ្រប់គ្រងប្រជារាស្ត្រជ្វីហ្វ ទ្រង់គង់នៅទីណា ? ខ្ញុំព្រះអង្គទាំងអស់គ្នាដែលខំស្វះស្វែងមកដល់ទីនេះ គឺមានបំណងនឹងថ្វាយបង្គំព្រះអង្គ ព្រោះយើងទាំងអស់គ្នាបានឃើញផ្កាយមួយបានរះមានពន្លឺដ៏ត្រចះត្រចង់នៅទិសខាងកើត"។ ព្រះរាជាហេរ៉ូដ ក៏មានព្រះទ័យព្រួយបារម្ភ និមិត្តតែបានឮ នឹងព្រះរាជសណ្តាប់រឿង ដ៏អស្ចារ្យនេះ។ បន្ទាប់មក ទ្រង់ក៏ឱ្យប្រជុំពួកអ្នកប្រាជ្ញរាជបុរោហិតជាច្រើន ដើម្បីសាកសួរថា តើព្រះគ្រិស្តបានប្រសូតនៅកន្លែងណា។ ពួកអ្នកប្រាជ្ញរាជបុរោហិតទាំងអស់ ក៏ក្រាបបង្គំទូលថា ៖ " ព្រះគ្រិស្តកើតនៅភូមិតូចមួយឈ្មោះ បេត្លេហិម ( Bethlehem )ក្នុងខេត្តឈ្មោះ ជូដា ( Juda )ឯណោះ"។ ព្រះរាជាក៏ទ្រង់ត្រាសបង្គាប់ឱ្យពួកអ្នកប្រាជ្ញបុរោហិតទាំងអស់ទៅស្វែងរកព្រះគ្រិស្ត ហើយផ្តែផ្តាំថា៖ "បើព្រះគ្រិស្តមានព្រះតម្រាស់យ៉ាងណា សូមនាំពាក្យនោះមកប្រាប់ខ្ញុំវិញ ក្រែងថ្ងៃណាមួយខ្ញុំនឹងទៅថ្វាយបង្គំដែរ"។ អ្នកទាំងអស់គ្នាក៏ទទួលព្រះរាជឱង្ការហើយចេញដំណើរឆ្ពោះទៅតាមផ្កាយព្រះគ្រិស្ត។ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រមទាំងប្រគល់ខ្លួនចំពោះព្រះយេស៊ូ រួចហើយក៏ត្រឡប់ទៅកាន់លំនៅរៀងៗខ្លួន។ គេទាំងអស់គ្នា ពុំបានត្រឡប់ទៅថ្វាយដំណឹងចំពោះព្រះរាជហេរ៉ូដវិញឡើយ ព្រោះគេទាំងអស់គ្នា ជឿតាមការយល់សប្តិរបស់ពួកទេព្តាប្រាប់ថា កុំឱ្យគេទាំងអស់ត្រឡប់ទៅថ្វាយដំណឹងព្រះរាជា ហេរ៉ូដដោយខ្លាចមានគ្រោះថ្នាក់។

កាលបើពួកអ្នកប្រាជ្ញបុរោហិតទាំងអស់បានត្រឡប់ទៅផ្ទះវិញហើយ ពួកទេព្តាក៏ឱ្យយល់សប្តិជោសេហ្វ ( Joseph ) ឱ្យទៅនាំព្រះនាងម៉ារីនិងព្រះយេស៊ូរត់គៀសខ្លួនពីទីនោះទៅនៅឯប្រទេសអេហ្ស៊ីប ដើម្បីជៀសវាងពីគ្រោះថ្នាក់ គឺការពិឃាតនៃព្រះរាជាទេព្តា។ ព្រះនាងម៉ារី ព្រះយេស៊ូ និងជោ សេហ្វ បានឋិតនៅក្នុងប្រទេសអេហ្ស៊ីប នោះរហូតដល់ព្រះរាជា ហេរ៉ូដទ្រង់ចូលទិវង្គតទៅ។ កាលបើដូច្នោះ ពពួកទេព្តាក៏ឱ្យយល់សប្តិដល់ជោ សេហ្វ ជាឪពុកឱ្យនាំព្រះយេស៊ូនិងម្តាយត្រឡប់មកប្រទេសអ៊ីស្រាអែល វិញ។ ប៉ុន្តែលុះឮថា អារខែឡោះ ( Archelaus ) ជាព្រះរាជបុត្រនៃព្រះរាជា ហេរ៉ូដ បានឡើងជាព្រះរាជាស្នងព្រះរាជបិតា ដោ

សេហ្វ ក៏នាំព្រះយេស៊ូនិងម្ដាយទៅ រស់នៅឯទីក្រុងតូចមួយឈ្មោះ ណាហ្សារេដ ( Nazareth ) នៃរដ្ឋហ្គាលីលេ ( Galilee )។

តាមប្រកពខ្លះនិយាយថា គេតាំងគ្រិស្ដសករាជឡើងខាងក្រោយកំណើតនៃព្រះយេស៊ូ ៦ ឆ្នាំ នៅទីក្រុងណាសារេថ។ ព្រះយេស៊ូត្រូវបានគេយកទៅឆ្កាងសម្លាប់ និងយកទៅកប់នៅ គ.ស.២៩ឆ្នាំ គឺព្រះយេស៊ូបានព្រះជន្មត្រឹម ៣៦ ឆ្នាំ គត់។ តាមប្រកព ខ្លះនិយាយថា គេបាន តាំងសករាជឡើងចាប់តាំងពីថ្ងៃចាប់បដិសន្ធិនៃព្រះយេស៊ូ ហើយអ្នកប្រាជ្ញភាគច្រើនបាន យល់និងយកតាមប្រកពក្រោយនេះ។ ឯភូមិតូចឈ្មោះ បេត្លេហិមនោះ ឋិតនៅខាងក្រៅទី ក្រុងជេរូសាឡិមទេ ហើយជាទីឋាននិងស្រុកកំណើតនៃជោសេហ្វ ជាឪពុកមានមុខរបរជា ជាងឈើ។ នៅពេលព្រះយេស៊ូបានព្រះជន្ម ១២ ឆ្នាំ លោកបានទៅទស្សនាទីក្រុងជេរូសាឡិម ម្ដង។ តាំងពីពេលនោះមក យើងពុំបានឃើញថា ព្រះយេស៊ូបានទៅដល់ឬនៅត្រង់កន្លែង ណាឡើយ ព្រោះគ្មានប្រកពណាមួយបញ្ជាក់ ប៉ុន្ដែលុះដល់ព្រះជន្ម៣០ឆ្នាំ ទើបយើងឃើញ ថាព្រះយេស៊ូ ទ្រង់បញ្ចេញសកម្មភាព និងបំពេញមុខងារជាអ្នកប្រកាសលទ្ធិនៅទីក្រុងជេរូ សាឡិម។

៣-លទ្ធិកិច្ចនៃព្រះយេស៊ូ ៖ គ្រិស្ដកិច្ចនៃព្រះយេស៊ូ ចាប់តាំងពីព្រះជន្ម ៣០ ទៅ ៣៥ ឆ្នាំ គេចែកចេញជា៣ សម័យគឺ ៖

ក-១២ខែ នៃការប្រកាសលទ្ធិនៅទីក្រុងជេរូសាឡិម

ខ-ព្រះយេស៊ូ បានឈប់ប្រកាសលទ្ធិនៅពេលដែលមានគ្រោះកាចពីទេព្ដា សម្លាប់ពួក អេហ្ស៊ីបដែលរស់នៅទីក្រុងជេរូសាឡិមទាំងអស់ លើកលែងតែពួកជ្វីហ្វ (ពួកអ្នកលទ្ធិ ហ៊ីប្រ៊ូ វចេញ) គេហៅថា “ Passover ”។

គ-៩ខែឈប់សម្រាក ហើយបានបញ្ចប់នៅពេលដែលព្រះយេស៊ូទៅទស្សនា ទីក្រុង ជេរូសាឡិមម្ដងទៀត គឺនៅពេលខាងដើមខែមេសា។

លុះដល់ព្រះយេស៊ូមានព្រះជន្មបាន ៣៥ ឆ្នាំ ត្រូវប្រជារាស្ដ្រចាប់យកទៅចង ឆ្កាង សម្លាប់ ព្រោះការប្រកាសលទ្ធិរបស់លោក មានការប្រឆាំងជាមួយនឹងលទ្ធិហ៊ីប្រ៊ូវ ដែលជា លទ្ធិដើមរបស់ប្រជាជនជ្វីហ្វ។ បន្ទាប់ពីការឆ្កាងសម្លាប់មក គេបានយកសពព្រះយេស៊ូទៅ កប់ចោល។ លុះគម្រប់ ៣ ថ្ងៃ ព្រះយេស៊ូក៏រស់ឡើងវិញ ហើយរលាយរូបនិងព្រលឹងរបស់ ខ្លួនចូលទៅក្នុងរូបនិងព្រលឹងរបស់ព្រះគ្រិស្ដអស់។

គេជឿថា ការស្លាប់នៃព្រះយេស៊ូ ជាការសំខាន់បំផុតនៃលទ្ធិគ្រិស្ត ព្រោះជានិមិត្តរូបនៃសេចក្ដីសុខស្ងប់ ជាការបូជាសាកលចំពោះព្រះអាទិទេពដើម្បីមនុស្សលោក ជាតំណាងនៃអំពើបាបដែលមនុស្សទាំងឡាយបានប្រព្រឹត្តកន្លង ព្រមទាំងសេចក្ដីទុក្ខព្រួយគ្រប់បែបរបស់មនុស្សលោក។

ឃ-លទ្ធិអ៊ិស្លាម ៖ ១-ពាក្យថាអ៊ិស្លាម ជាឈ្មោះនៃជំនឿចំពោះព្រះអាឡាហ៍ ពាក្យថាមូស្លីម ជាឈ្មោះនៃអ្នកកាន់លទ្ធិអ៊ិស្លាម ឯពាក្យថា មហាហ្មុត ជាឈ្មោះនៃមេដឹកនាំលទ្ធិអ៊ិស្លាមនេះ ដែលគេបានជឿប្រាកដថា ព្រះអាឡាហ៍បានចាត់លោកមកឱ្យប្រកាសលទ្ធិអ៊ិស្លាមដល់ប្រជាជន គឺមហាហ្មុតនេះហើយជាព្រះរាជបុត្រនៃព្រះអាឡាហ៍។ ជាពិសេសមហាហ្មុតបានទទួលយកទំនៀមទម្លាប់ ការប្រតិបត្តិផ្សេងៗ ព្រមទាំងទ្រឹស្ដីប្រកបដោយសាសនាជារបស់ពួកអារ៉ាប់ទាំងអស់ទុកក្នុងលទ្ធិអ៊ិស្លាម។ ដូច្នេះយើងឃើញថា ព្រោះហេតុទាំងអស់នោះហើយ បានជាមហាហ្មុតបានក្លាយទៅជាមេដឹកនាំប្រកបដោយជាតិនិយមពិតប្រាកដ។ ប៉ុន្តែក្នុងលទ្ធិអ៊ិស្លាម មានការចម្លែកមួយដែលគ្រប់សាសនា និងលទ្ធិទាំងអស់ក្នុងលោកមិនដែលមាន គឺទេវរូបទាំងអស់ដែលគេធ្លាប់មានមកសម្រាប់គោរពបូជា ត្រូវតែកម្ទេច និងបំផ្លិចបំផ្លាញចោលទាំងអស់កុំឱ្យសេសសល់ឡើយ ព្រោះតាមពិត មហាហ្មុតមានបំណងចង់ឱ្យមានឯកភាពខាងជំនឿតែមួយ គឺព្រះអាឡាហ៍ ជាព្រះម្ចាស់លោក។ ម្យ៉ាងទៀតយើងសង្កេតឃើញថា បានជាមហាហ្មុតមានគំនិតកែទម្រង់បែបនេះព្រោះលោកយល់ឃើញថា ពួកលទ្ធិគ្រីស្តនិងពួកជ្វីហ្វ ( Jews )បានប្រកាសផ្សាយលទ្ធិគ្រិស្តនិង ហ៊ីប្រ៊ូវពាសពេញប្រទេសអារ៉ាប់និងប្រទេសទាំងឡាយនៅមជ្ឈិមបូព៌ាទាំងមូល។ មិនតែប៉ុណ្ណោះ លទ្ធិបុរាណរបស់ជនជាតិអារ៉ាប់ ក៏មានលក្ខណៈខ្វះឯកភាពជារបៀបពហុទេវនិយមថែមទៀត។ ជាពិសេសមហាហ្មុតឃើញថា លទ្ធិគ្រិស្តនិងលទ្ធិហ៊ីប្រ៊ូវបាននាំឱ្យប្រជាជនភ្លេចទំនៀមទម្លាប់និងសាសនារបស់ជាតិខ្លួនអស់ ព្រមទាំងជាលទ្ធិនិយមតែពួកអ្នកមានសម្បត្តិ និងអ្នកអំណាចក្នុងស្រុកដែលបណ្ដាលឱ្យមានការពុករលួយរវាងជាតិគ្នាឯង។ មហាហ្មុត ជាអ្នកតក្កវិទូប្រកបដោយជាតិនិយមពិតប្រាកដ ពុំមែនជាមនុស្សឈ្លើយដូចពួកគ្រិស្ត និង ពួកជ្វីហ្វបានសន្និដ្ឋាននិងឱ្យឈ្មោះនោះឡើយ។ ជាការធម្មតា ការបដិវត្តមនោគមវិជ្ជាថ្មី ត្រូវតែមានការប្រឆាំងពីមជ្ឈដ្ឋានអ្នកកាន់អំណាចក្នុងស្រុកនិងប្រជាជនខ្វះពុំខាន ដែលជាហេតុនាំឱ្យមហាហ្មុតប្រុងប្រៀបស្វែងរកមិត្រនិងទីកន្លែងដើម្បីប្រឆាំងតបតវិញ។ ដូច្នេះយើងឃើញថា

ជីវប្រវត្តិរបស់មហាហ្មាត់ ប្រកបដោយភាពគ្រោតគ្រាតណាស់ យើងមិនអាចហៅឬសន្និដ្ឋានថា “អ្នកសន្តិភាពដូចជាព្រះពុទ្ធ ខុងជឺ ឬយេស៊ូបានឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ពាក្យប្រៀនប្រដៅរបស់លោកមានលក្ខណៈប្រសើរជាងកិច្ចការប្រចាំជីវិតរបស់លោក។ នៅក្នុងគម្ពីរផ្សេងៗមានគម្ពីរគួរអានជាដើម នៅខាងចុងពាក្យប្រៀនប្រដៅនីមួយៗ លោកតែងប្រកាសថា ៖ “ប្រជាជនទាំងអស់ ដែលបានយកចិត្តទុកដាក់ស្តាប់ពាក្យប្រៀនប្រដៅរបស់ខ្ញុំ ត្រូវដឹងថា គ្រប់ពួកមូស្លីម ត្រូវតែមានចិត្តជាបង-ប្អូន (ភាតរភាព) រវាងមូស្លីមដូចគ្នាត្រូវតែមានសមភាពស្មើៗគ្នា។ កាលណាអ្នកប្រព្រឹត្តតាមលទ្ធិអ៊ិស្លាម ដល់ទីបំផុតនៃជីវិតរបស់អ្នក អ្នកនឹងទៅកើតក្នុងសាកលអាណាចក្រមួយដែលមាន តែជំនឿ ជាសាកលមួយគឺជំនឿក្នុងព្រះអាឡាហ៍ជាព្រះម្ចាស់លោក”។

ឥឡូវនេះ យើងក្រឡេកមើលទៅស្ថានហេតុទូទៅនៃអារ៉ាប់ម្តង តើមានលក្ខណៈយ៉ាងណា។ សម័យងងឹតល្ងង់នៃអារ៉ាប់ ( Jahiliya ) បានចប់ពីត្រឹមមហាហ្មាត់ បានទទួលប្រាជ្ញាដ៏ស័ក្តិសិទ្ធិពីព្រះហស្តនៃព្រះម្ចាស់ ព្រះនាម កាប្រីយែល ( Qabriel )។

ប្រជាជនអារ៉ាប់ គឺជាសញ្ជាតិរួមជាមួយនឹងប្រជាជនជ្វីហ្វ។ ប្រជាជនទាំងពីរក្រុមនេះមានជាតិបរិសុទ្ធស្អាត ហើយជំនឿរបស់គេទាំងពីរក្រុមមិនមែនជាឯកទេវនិយមឡើយ។ តាមប្រភពទូទៅបានបញ្ជាក់ថា ប្រជាជនទាំងអស់នេះជាពួកកុលនិយម។ យើងឃើញថា នៅខាងដើមសតវត្សទី៧ នៃគ.ស.ជំនឿរបស់ប្រជាជនអារ៉ាប់ គឺពហុទេវនិយម។ ទេវរូបដែលគេគោរព បើតាមការពិនិត្យ និងវិនិច្ឆ័យទូទៅឃើញថា មានលក្ខណៈប្រហាក់ប្រហែលគ្នា នឹងយុគសំរឹតក្នុងអតីតកាល។ នៅគ.ស.៦០០ ឆ្នាំ យើងឃើញថា លក្ខណៈសំខាន់នៃមាគ៌ាជីវិតជនជាតិអារ៉ាប់ គឺមានពួកយោគីជាច្រើន មាននិន្នាការជាឯកទេសនិយម ចូលចិត្តរស់នៅ ក្នុងទីរហោស្ថាន។ ពួកយោគីទាំងអស់នេះ តាមពាក្យអារ៉ាប់ហៅថា “ហានីហ្វ ( Hanif )” ជាក្រុមអ្នកអប់រំខាងផ្លូវចិត្ត។ តាមប្រវត្តិទូទៅនិងប្រភពទូទៅបានបញ្ជាក់ថា មហាហ្មាត់ ក៏ចូលទៅក្នុងពួកហានីហ្វ ប្រតិបត្តិយោគៈដូចពួកនោះដែរ។

នៅពេលមុនគម្ពីរគួរអានកើតឡើង នៅក្នុងគំនិតរបស់អារ៉ាប់ទូទៅ យើងឃើញថា ពុទ្ធិដ៏ខ្ពង់ខ្ពស់នៃមនុស្សដែលអាចមានប្រសិទ្ធភាពទៅបាន គឺការជឿចំពោះព្រះអាទិទេពប្រាប់ចាកជំនួយជានិមិត្តរូប “ មិនបាច់ឱ្យមានទេវរូបជាជំនួយ” ។ តាមពិតចំពោះគុណសម្បត្តិនៃទេវរូបដែលគេគោរព ពុំមានឧត្តមគតិណាមួយ អាចស្រោបយកគុណសម្បត្តិទាំងអស់នៃ

ព្រះអាទិទេពណាក្រៅពីមនុស្សជាតិឡើយ។ រឿងនេះ សូម្បីឧត្តមគតិនៃលទ្ធិជ្វីហ្វ(Jews) ដែលជាលទ្ធិប្រឆាំងជាមួយនឹងលទ្ធិហ៊ីប្រ៊ូវរបស់គម្ពីរបុរាណ ( old Testament ) និងលទ្ធិគ្រិស្ត ( New Testament )គម្ពីរសម័យក៏ដោយ ក៏បដិសេធរបៀបគោរពទេវរូបគ្រប់បែបដែរ។ ទាំងអស់នេះ នាំឱ្យយើងអាចសន្និដ្ឋានថា មហាហ្មាត់ ទទួលយកគំនិតរបស់អារ៉ាប់មួយបែបនេះត្រង់លក្ខណៈមិនគោរពទេវរូបជាមូលដ្ឋាននៃការបិដវត្តរបស់លោក ដែលជាគំនិតប្រឆាំងជាមួយនឹងពួកក្រុងម៉េកា អ្នកពហុទេវនិយម មានទេវរូប ៣៧ បែបសម្រាប់គោរព។

២-ជីវប្រវត្តិសង្ខេបនៃមហាហ្មាត់ ៖ មហាហ្មាត់ជាបុត្ររបស់លោក អាប់ឌុល្លា ( Abdulla )ជាសមាជិកមួយរូបនៃកុលសម្ព័ន្ធអារ៉ាប់មួយ ឈ្មោះគុយរ៉ៃស្ហ៍ ( Quraish ) នៅជិតទីក្រុងម៉េក្កា ( Mecca ) ហើយនៅទីនោះ មានព្រះវិហារមួយយ៉ាងធំសម្បើមអស្ចារ្យសម្រាប់តម្កល់ទេវរូបវិចិត្រឡើងពីថ្ម ជាទីសម្រាប់ធ្វើសក្ការបូជា។ បន្ទាប់មកលោកអាប់ឌុល្លា បានឡើងជានាយកជំនៃភូមិភាគនេះ។ តាមពិតកុលសម្ព័ន្ធគុយរ៉ៃស្ហ៍ ពុំមែនជាក្រុមកសិករទេ គឺជាអ្នកក្រុងដែរ ប្រកបមុខរបរជំនួញនិងធ្វើរបស់ប្រើប្រាស់ផ្សេងៗពីដៃ។ លោកមហាហ្មាត់កើតនៅ គ.ស. ៥៧០ឆ្នាំ នៅភូមិភាគដូចខាងលើ។ មាតារបស់លោមាននាមមិនប្រាកដ។ តាមជីវប្រវត្តិរបស់លោក យើងឃើញថា លោក អាប៊ូតាលិប ( Abutalib )ជាឪពុកមា បានចិញ្ចឹមបីបាច់ថែរក្សាមោហាម័តតាំងពីកុមារមកលុះមកដល់អាយុ ១២ឆ្នាំ ឪពុកមាបាននាំ មហាហ្មាត់ទៅទស្សនាប្រទេសស៊ីរី ហើយនៅទីនោះមហាហ្មាត់ បានជួបនិងស្តាប់ពួកជ្វីហ្វ និងពួកគ្រិស្ត ហើយបានកត់សម្គាល់ថា ពួកទាំងអស់នោះជាពិសេសចំពោះនិកាយខ្វះ បានប្រកាន់យកជំនឿដែលមិនប្រកបដោយហេតុ-ផល ព្រមទាំងបានប្រព្រឹត្តអំពើពុករលួយនិងបោកប្រាសប្រជាជន។ នៅទីនោះមិនយូរប៉ុន្មាន មហាហ្មាត់ក៏បានត្រឡប់មកកាន់ទីក្រុងម៉េក្កាវិញ ហើយរស់នៅទីនោះរហូតដល់អាយុ ៤០ ឆ្នាំ ប្រកបមុខរបរជំនួញ ព្រមទាំងបានជួយចាត់ចែងការស្ត្រីមេម៉ាយមានសម្បត្តិច្រើនមួយរូបឈ្មោះនាង ខាឌីជា (Khadije )។ ខាងក្រោយមកមិនយូរប៉ុន្មាន មហាហ្មាត់ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីមេម៉ាយនោះទៅ មានកូនប្រុសស្រី ៦ នាក់ ហើយកូន ២ នាក់ត្រូវស្លាប់តាំងពីក្មេង។ បន្ទាប់ពីកូនទាំងនោះស្លាប់ទៅ មហាហ្មាត់ដោយសេក្តីទុក្ខព្រួយនិងអាឡោះអាល័យកូនទាំងពីរនោះខ្លាំងលើសលប់ពេក ក៏ដើរត្រេចរង្គត់ផ្តេសផ្តាស លែងនឹកនាដល់ផ្ទះសម្បែង កូនប្រពន្ធសោះឡើយ។ ការបរិភោគអាហាររបស់លោកក៏លែងមាន។

ទាំងអស់នេះ បណ្ដាលឱ្យមហាហ្មុតក្លាយខ្លួនជាស្គាំងស្គម មានទោអាវរហែកដាច់ដាចរយ៉ៃ ព្រមទាំងមានភ្នែករូងខូង ដូចជា រូបអសុភគួរឱ្យខ្លាច។ អាកប្បកិរិយានិងសភាពទូទៅនៃមហាហ្មុតបែបនេះ បណ្ដាលឱ្យប្រជាជននៅទីនោះទាំងអស់ដែលធ្លាប់ស្គាល់លោក មានការចូលចិត្តព្រមទាំងបានសន្និដ្ឋានថា មហាហ្មុតបានចូលទៅរួមជាមួយពួក ហានីហ្វ (Hanifs ) ក្រុមអ្នកអប់រំខាងផ្លូវចិត្តនៅសម័យនោះ។

មហាហ្មុត កាលបើដើរផ្គេសផ្គាសទៅលើសមុទ្រខ្សាច់គ្មានឈប់ឈរ និងអស់កាលដ៏យូរក៏ក្លាយទៅជាមនុស្សមានជំងឺយ៉ាងធ្ងន់ ដេកដួលនៅលើផ្នូកខ្សាច់និងរូងភ្នំ ហើយលុះភ្ញាក់ស្មារតីឡើងវិញ លោកក៏បានឮសំឡេងស្រែកហៅចំឈ្មោះលោកថា " ក្នុងនាមរបស់អាទិទេព មហាហ្មុត គេត្រូវជ្រើសរើសឈ្មោះអ្នកឯងហើយ"។ លុះយប់ក្រោយមក មហាហ្មុតបានជាប់ក្នុងរូងភ្នំមួយទៀត យប់នោះ លុះខាងក្រោយមកគេហៅថា "យប់របស់ព្រះអាទិទេព" ( El Qadr )ហើយឮសំឡេងស្រែកថា "ព្រះសូត្រ" ជារបៀបកំណាព្យនិងសំឡេងមួយទៀតជាសម្រែក ( Cry )ដែលជាហេតុនាំឱ្យកិតភ័យពន់ប្រមាណ។ បន្ទាប់ពីស្នូរទាំងអស់នោះមក លោកបានឃើញសញ្ញាកាកបាទ " + " សរសេរលើស្បាំងសំពត់លាតត្រដាងនៅខាងមុខលោក គឺវគ្គទី១ នៃគម្ពីរគួរអាន ( First Surah of Qur'an ) ។ លុះបានឃើញហើយ មោហម័ត ដោយមានសេចក្ដីខ្លាចខ្លាំងពេក ក៏បានរត់ចេញមកក្រៅរូងភ្នំ ហើយហួសរហូតដល់ផ្ទះតែម្ដង ព្រោះលោកបានឃើញភ្នែកពីរធំៗ ដែលលោកជឿថា ជារបស់ព្រះម្ចាស់លោក ព្រះនាម ហ្គាប្រ៊ីយ៉ែល ( Gabriel )ហើយភ្នែកទាំងគូដែលលោកបានឃើញនោះ ក៏បានជីតជាប់នឹងរង្វង់ភ្នែករបស់លោក។ លុះលោករត់ទៅដល់ផ្ទះ ហើយក៏នៅពុំទាន់ដឹងខ្លួននៅឡើយ ដរាបដល់ភរិយា (នាងខាឌីជា Khadija ) មកឱបលោក ទើបលោកដឹងខ្លួនឡើងវិញ។

គេជឿថា មហាហ្មុតដែលមានជំងឺ ក៏ព្រោះតែលោកកំពុងតែមានចិត្តស្ងប់ចំពោះព្រះអាទិទេព ហើយដែលលោកបានឃើញនិមិត្តផ្សេងៗនឹងសំឡេងហៅរកឈ្មោះ គឺព្រះអាទិទេពចុះមកសណ្ឋិតក្នុងចិត្តរបស់លោកដែរ។ បានជាគេហ៊ានសន្និដ្ឋាន និងជឿដូច្នេះ ក៏ព្រោះគេឃើញថា នៅពេលដែលមហាហ្មុតបានជាលះស្បើយពីជំងឺវិញ ហើយលោកមានចិត្តតាំងនៅក្នុងសភាពប្រក្រតី។ បន្ទាប់ពីជាប់ក្នុងរូងភ្នំអស់ពេលមួយយប់ មកវគ្គទី២ នៃគម្ពីរគួរអាន ( The second surah of Qur'an )ក៏បានប្រាជកឡើង ដល់មហាហ្មុតម្ដងទៀត ជាលើកទី២ ដែលជាហេតុនាំឱ្យមហាហ្មុតបានទទួលនូវប្រាជ្ញាដ៏ខ្ពង់ខ្ពស់និងពិសេសឡើង។

នៅពេលខាងក្រោយមក មហាហ្មុំតបានជាសះស្បើយប្រាសចាកការភ័យខ្លាចអស់ ហើយបានស្លៀកពាក់ជាអ្នកជំនួញនៃទីក្រុងម៉េក្កាតាមភាពធម្មតាវិញ។ មហាហ្មុំតបានផ្ដើមនិយាយបរិយាយ ពីឧត្ដមគតិនៃអំណាចដ៏ធំបំផុតនៃព្រះអាឡាហ៍ ជាព្រះដ៏ធំបំផុតនៃលោក ការខ្លាចពីនរក ការឥតប្រយោជន៍នៃការគោរពទេវរូបផ្សេងនិងទណ្ឌកម្មរបស់ព្រះជាម្ចាស់ នៅឋានសួគ៌ជាដើម ដល់ពួកមិត្រដ៏ស្និទ្ធស្នាលខ្លះរួមទាំងកិរិយារបស់លោកផងៗ ជាដំបូង មហាហ្មុំតពុំទាន់មានបំណងនិងពុំទាន់ប្រាកដជាមេដឹកនាំនៃលទ្ធិនៅឡើយទេ ប៉ុន្តែ ៤-៥ ឆ្នាំ ខាងក្រោយមក ទើបមហាហ្មុំតផ្ដើមចេញមុខទេសនាប្រៀនប្រដៅប្រជាជន ព្រមទាំងមានបំណងប្រុងបង្កើតក្រុមមួយដ៏ខ្លាំងមាំមួនដោយរួមកម្លាំងជាមួយពួកជូដាយ ( Juddiists ) និងពួកអ្នកហ៊ីប្រ៊ូវ ( Hebrews )។ បានឃើញថា ការរួបរួមជាក្រុមជាមួយពួកនោះពុំបានផលល្អ មហាហ្មុំតក៏បានសម្រេចចិត្តធ្វើការឃោសនាតែម្នាក់ឯងៗ មុនដំបូង លោកផ្ដើមឃោសនាប្រឆាំងនឹងជំនឿរបស់ក្រុងម៉េក្កា ប៉ុន្តែខាងក្រោយមក លោកមានវិប្បដិសារីស្ដាយក្រោយទៅវិញ តែហួសពេលទៅហើយ កាលណាលោកឃើញប្រជាជននិងមេដឹកនាំនៃក្រុងម៉េក្កាប្រឆាំងតបតចំពោះលោកវិញ។ នៅពេលនោះ មហាហ្មុំតមានអាយុ៥០ឆ្នាំគត់។ ការចលាចលក៏បានចាប់កំណើតឡើងពេញបន្ទុក រហូតដល់ប្រើអាវុធតែរៀងៗខ្លួន។ ការចលាចលនេះ បណ្ដាលឱ្យភរិយានិងមិត្តខ្លះរបស់លោកមោហាម័តបាត់បង់ជីវិត។ ឃើញហេតុមិនស្រួល មហាហ្មុំតក៏ភៀសខ្លួនជាមួយមិត្តរួមដៃខ្លះទៅទីក្រុងមួយនៅជិតទីក្រុងម៉េក្កាដែរឈ្មោះថា ទីក្រុងយ័ត្ថរិព ( Yathrib )នៅគ.ស.៦២២។ នៅទីក្រុងនោះ ប្រជាជនបានទទួលស្វាគមន៍មហាហ្មុំតដោយអបអរសាទរប្រកបដោយមហោឡារិកជាទីបំផុត បន្ទាប់ពីការលំបាកអស់ពេលជាយូរថ្ងៃក្នុងការធ្វើដំណើររត់ចេញពីទីក្រុងម៉េក្កា។ យើងសូមបញ្ជាក់ថា នៅទីក្រុងយ័ត្ថរិពនេះ ប្រជាជនទាំងអស់ច្រើនតែពួកជ្វីហ្វ និងអ្នកលទ្ធិគ្រិស្ត ហើយនៅទីក្រុងនេះក៏បានស្ថាបនាឡើងដោយពួកទាំងអស់នោះដែរ។ បន្ទាប់ពីមហាហ្មុំតឋិតនៅទីនោះអស់ពេលដ៏យូរ ប្រជារាស្ត្រក៏មានសេចក្ដីស្រឡាក់លោកមហាហ្មុំតច្រើន ហើយទីនេះខាងក្រោយមក គេឱ្យឈ្មោះថា ម៉ាឌីណា អ៊ុនណាប៊ី ( Madina Un Nabi ) ប្រែថា "ទីក្រុងនៃប្រជាជន"។ លោកមហាហ្មុំតជឿជាក់ថា ពួកជ្វីហ្វនិងពួកគ្រិស្តមុខជាព្រមធ្វើ សហប្រតិបត្តិការប្រកាសលទ្ធិជាមួយលោកពុំខាន ប៉ុន្តែផ្ទុយទៅវិញ ពួកទាំងអស់នោះពុំព្រមឱ្យឱកាសដល់លោកឡើយ។ តាមពិតមានតែពួកអារ៉ាប់ខ្លះដែលស្រឡាញ់វប្បធម៌ដើម និងពួកជូដាយខ្លះ ដែល

អាចចូលរួមជាមួយមហាហ្មុតក្នុងការស្ថាបនាលទ្ធិអ៊ិស្លាម។ នៅទីនេះពួកប្រជាជនទាំងអស់ជឿ និងយល់ថា មហាហ្មុតជាអ្នកកែទម្រង់និងជាអ្នកជាតិនិយម មិនមែនជាមេដឹកនាំនៃលទ្ធិឡើយ។ នៅទីបំផុតឃើញថាមិនមានផលប្រយោជន៍ មហាហ្មុតក៏បានភៀសខ្លួនទៅកាន់ទីក្រុងមួយទៀតជិតខាង។ រឿងនេះបណ្តាលឱ្យប្រជាជននៃទីក្រុង នោះមានសេចក្តីក្តៅក្រហាយ ហើយកេណ្ឌពលទាហានចំនួន ១០.០០០ នាក់ប្រឆាំងតបតវិញយ៉ាងពេញទំហឹង។ ដើម្បីការពារទីក្រុងយ័ត្ថរិពឱ្យបានមាំមួន មហាហ្មុតក៏បង្គាប់ឱ្យទាហាននិងប្រជាជនលើកទីក្រុងយ័ត្ថរិពយ៉ាងខ្ពស់ ហើយស្ថាបនាគូព័ទ្ធជុំវិញទីក្រុងនោះ ដើម្បីតទល់សត្រូវមកពីក្រុងម៉ក្កា និងទីក្រុងជិតខាងនោះៗ។ ជាការកបជួន លុះរៀបចំទីក្រុងនិងកងទ័ពរួចហើយ ក៏ទទួលរដូវភ្លៀងធ្លាក់ជោគជាំមកដល់ ដែលបណ្តាឱ្យសត្រូវចូលមកសុំចុះសន្ធិសញ្ញាសន្តិភាពជាមួយមហាហ្មុតនៅទីក្រុងយ័ត្ថរិព។ ទាំងអស់នេះ នាំឱ្យប្រជាជនដាក់ឈ្មោះទុកជាអនុស្សាវរីយ៍ថា “សង្គ្រាមនិងទីក្រុងស័ក្តិសិទ្ធិ ( Holy City and holy war )”។ ចំពោះសង្គ្រាមស័ក្តិសិទ្ធិពាក្យអារ៉ាប់ ថា ជិហាដ (Jihad) ដែលជាគំនិតទី១ ចម្រាញ់យកពីជ័យជំនះនៅទីក្រុងយ័ត្ថរិពនៃមហាហ្មុត ក្នុងការបង្រ្កាបប្រជាជនអារ៉ាប់ឱ្យមានជំនឿចំពោះមេដឹកនាំលទ្ធិតែមួយ និងជំនឿតែមួយក្នុងព្រះអាទិទេព គឺព្រះអាឡាហ៍។ ខាងក្រោយមកសង្គ្រាមស័ក្តិសិទ្ធិនេះគេហៅថា “សង្គ្រាមផ្សាយលទ្ធិ” ទៅវិញ។ រឿងនេះបានសម្រេចដូចបំណងនៃមហាហ្មុតមែន គឺលទ្ធិអ៊ិស្លាមត្រូវបានផ្សាយទៅគ្រប់ទីកន្លែងក្នុងមជ្ឈិមបូព៌ាប្រទេសទាំងមូល។

កំណត់សម្គាល់ លទ្ធិអ៊ិស្លាមនិងអាវុធ តែងប្រព្រឹត្តទៅជាមួយគ្នាជានិច្ច ហើយនេះបានជ្រួតជ្រាបព្រមទាំងជាទឹកបន្សាំនៃស្ថាប័នសង្គមអ៊ិស្លាមគ្រប់ទីកន្លែងជាពិសេសលទ្ធិអ៊ិស្លាម និងនយោបាយ ក៏មានលក្ខណៈដូចជាសម្លមួយឆ្នាំងមានរសជាតិដូចៗគ្នាដែរ។ បើយើងសង្កេតឱ្យម៉ត់ចត់ទៅ គង់ឃើញថាពិតមែនតែលទ្ធិនេះក្នុងកន្លែង ខ្លះមានការប្រឆាំងជាមួយនឹងលទ្ធិប្រជាធិបតេយ្យសម័យថ្មី ក្នុងលក្ខណៈគ្រប់របបអន្តរជាតិនិងសិទ្ធិមនុស្សជាតិក៏ដោយ ក៏មានមធ្យោបាយច្រើនជាទីបំផុតក្នុងរបបពង្រីកទឹកដី ក្រុមនិងអំណាច ប៉ុន្តែរឿងទាំងអស់ នេះដឹងបានតែក្នុងសង្គមរបស់អ៊ិស្លាមប៉ុណ្ណោះ ព្រោះសង្គមពួកនេះមានលក្ខណៈស្ថាប័នជិតស្និទ្ធល្អណាស់ គឺគេធ្វើនៅជុំវិញព្រះអាឡាហ៍ដែលមានមហាហ្មុតជាអវតារ។ ឧទាហរណ៍ដ៏ជាក់ស្តែង គឺការចែកប្រទេសឥណ្ឌាជាពីរនៅឆ្នាំ១៩៤៨ គឺឥណ្ឌាសម្រាប់អ្នកហិណ្ឌូបាគិស្ថាន សម្រាប់អ្នកមូស្លីមឬអ៊ិស្លាម ជាពិសេស បាគិស្ថានមានខាងលិច ខាងកើត

ថែមទៀត។ ទាំងអស់នេះឱ្យឃើញថា បើអ្នកអ៊ិស្លាមនៅត្រង់ណាច្រើន គេនឹងសុំបែកកន្លែងនោះដាច់មុខពុំខាន។ ឧទាហរណ៍មួយទៀតគឺនៅឆ្នាំ១៩៦៣ នៅប្រទេសភូមា រឿងអ្នកអ៊ិស្លាមនេះ នាំឱ្យរដ្ឋាភិបាលលោក អ៊ូនុក លំបាកមិនតិចដែរ នៅពេលដែលរដ្ឋសភាភូមាអនុម័តយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

កាលដែលលោកមហាហ្មុតនៅមានជីវិតរស់នៅឡើយ ក្រុមលទ្ធិអ៊ិស្លាមមានការរួបរួមគ្នាជាទីបំផុតនៅជុំវិញមេដឹកនាំដ៏ធំបំផុត គេហៅថា កាលីហ្វ តំណាងលោកមហាហ្មុត។ ប៉ុន្តែនៅគ.ស.៦៣២ គឺមហាហ្មុតមានអាយុ ៦២ឆ្នាំ ហើយលោកក៏អនិច្ចកម្មទៅ។ លុះដល់ គ.ស. ៦៥៦ ការបែងបាក់គ្នាក៏កើតមានឡើងនៅជុំវិញហេតុការណ៍មួយ គឺការរើសមេដឹកនាំនៃលទ្ធិជំនួសមហាហ្មុត។ ការឈ្លោះប្រកែកគ្នានេះ បានលាតត្រដាងគំនិតជា ២ ផ្នែក គឺក្រុមទី១ ហៅថា ស៊ុន្នី ( Sunnis ) ជាក្រុមធំជាងគេបង្អស់ មានបំណងជ្រើសរើសមេដឹកនាំចំពោះអ្នកចេះដឹងណាមួយឱ្យជំនួសមហាហ្មុតទោះជាមិនមែនញាតិសន្តានរបស់មហាហ្មុតក៏ដោយ។ ក្រុមទី ២ មានបំណងជ្រើសរើសមនុស្សក្នុងត្រកូលអាលី ( Ali )ដែលត្រូវជាក្មួយរបស់លោក មហាហ្មុត មនុស្សក្នុងត្រកូលនេះ ទើបមានអំណាចទទួលមត៌កពីមហាហ្មុតបាន។ ក្រុមទី២នេះ គេហៅថា “ ស៊ី-អា ( Shi'a )”។ ក្រុមទាំងពីរនេះ ជានិកាយពីរដ៏ធំក្នុងលទ្ធិអ៊ិស្លាម ហើយការប្រឆាំងគ្នានៅតែបន្តរហូតដល់ឆ្នាំ ១៩១៨ ដែលនៅពេលនោះ នៅប្រទេសទួរគីមានមេដឹកនាំម្នាក់ឈ្មោះកេម៉ាលប៉ាស្ហា ( Kamal Pasha )បានរំលំមេដឹកនាំនិកាយស៊ុន្នី ( Sunnis ) នៅទីនោះបានតាំងពីពេលនោះមក ស្ថានការណ៍បានធ្វើឱ្យពួកស៊ុន្នីនិកាយគ្មានមេដឹកនាំដ៏ពិតប្រាកដ។ អង្គការលទ្ធិក៏មានលក្ខណៈរាត់រាយដែរ ហើយរឿងនេះបណ្តាលឱ្យអ្នកអ៊ិស្លាមគោរពមេដឹកនាំដែលគេតែងតាំងឡើង ជាពិសេសទៅតាមក្រុមទៅវិញ ដែលគេហៅថា “អ៊ីម៉ាម”។ ឯពួកស៊ី-អា ក៏មានការរីកចម្រើនបែកជានិកាយមួយទៀតឈ្មោះថា បាហាយ ( Bahai )ជានិកាយរួបរួមទាំងពួកអ៊ីម៉ាម និងពួកស៊ីអា ឱ្យមានឯកភាពរួមគ្នាទៅក្រោមអំណាចព្រះអាឡាហ៍ជាព្រះអាទិទេពតែមួយ។

៣-គោលការណ៍ដ៏សំខាន់នៃលទ្ធិអ៊ិស្លាម ៖ គោលការនៃលទ្ធិអ៊ិស្លាមមាន៣ប្រភេទគឺ ៖ ក-កំណើតដើមនៃពាក្យបណ្តាំឬប្រៀនប្រដៅរបស់មហាហ្មុត ខ-ព្រះគម្ពីរដែលចារឹកពាក្យប្រៀនប្រដៅរបស់មហាហ្មុត និងគ-ការរីកចម្រើននៃចលនាទាំងពីរគឺផ្នែកស្ថាប័ននិងផ្នែកទេវធម៌ ( Theology )។

ក-កំណើតដើមនៃពាក្យបណ្តាំ ឬប្រៀនប្រដៅរបស់មហាហ្មាត់ ៖ ពាក្យអាឡាហ៍ មិនមែនជាពាក្យត្រឹមត្រូវ តាមពិតពាក្យនេះក្លាយមកពីពាក្យថា អ័ល ឥឡាហ៍ ( Al Ilah )"ព្រះមានអំណាចខ្លាំងបំផុត ( Strong or mighty one )"។ ពាក្យបូរាណរបស់អ្នកកាន់សាសនានេះថា "រ័ព្វ" ( Rabb )ប្រែថា "ព្រះម្ចាស់ ( Lord )"។ តាមលក្ខណៈនៃឧត្តមគតិនេះ ព្រះអាទិទេពនៃអ៊ិស្លាមគឺអំណាចដ៏ខ្ពង់ខ្ពស់បំផុតនៃលោក គុណធម៌នៃព្រះអាទិទេពមាន ៩៩ យ៉ាង មានព្រះអាឡាហ៍ " ព្រះមានអំណាចផុតលោកជាដើម ហើយក្នុងការសូត្រធម៌ អ្នកអ៊ិស្លាមត្រូវសូត្រព្រះនាមគុណធម៌ទាំង ៩៩នោះផង ដើម្បីរំលឹកដល់ព្រះអង្គ។ អ្នកអ៊ិស្លាមត្រូវតែមានចិត្តស្វាមីភក្តិចំពោះព្រះអាឡាហ៍តែម្យ៉ាង ដែលជាព្រះអាចជួយឱ្យសេចក្តីសុខចម្រើន ព្រមទាំងផ្តល់ឱ្យនូវកំណើតថ្មីនៅស្ថានសួគ៌។ ព្រះអាឡាហ៍ជួយដល់អ្នកណា ដែលមានចិត្តស្វាមីភក្តិដល់ព្រះអង្គប៉ុណ្ណោះ ព្រមទាំងនាំអ្នកនោះទៅកាន់ភពថ្មីដែលព្រះអាឡាហ៍បានចាត់ចែងឱ្យ។ ទោះជាអ្នកអ៊ិស្លាមប្រកបអំពើចិញ្ចឹមជីវិតបែបណាក៏ដោយ ឱ្យតែមានចិត្តស្វាមីភក្តិនិងរលឹកដល់ព្រះអាឡាហ៍ជានិច្ចដូចជាពិធីថ្វាយបង្គំ វិធីកាន់ត្រណម និងវិធីចូលរួមបួសជាដើម ក៏ព្រះអាឡាហ៍តាមជួយស្រោចស្រង់អ្នកនោះដរាប តាំងពីលោកនេះ រហូតដល់លោកខាងមុខ។ អ្នកអ៊ិស្លាមត្រូវតែធ្វើខ្លួនឱ្យទៅខ្ញុំបម្រើនៃព្រះអាឡាហ៍។

ខ-ព្រះគម្ពីរដែលចារឹកពាក្យប្រៀនប្រដៅនៃមហាហ្មាត់ ៖ លទ្ធិអ៊ិស្លាមឋិតនៅលើព្រះគម្ពីរ បើព្រះគម្ពីរបង្គាប់ឬឱ្យធ្វើយ៉ាងណា អ្នកអ៊ិស្លាមត្រូវតែប្រព្រឹត្តតាមយ៉ាងនោះឥត មានប្រកែកឬរិះគន់ឡើយ។ គម្ពីរគួរអាន (Qur'an) គឺជាគម្ពីរដ៏ស័ក្តិសិទ្ធិបំផុតនៃលទ្ធិអ៊ិស្លាម ហើយជាគម្ពីរសម្រាប់សូត្ររបស់អ្នកអ៊ិស្លាម។ គម្ពីរនេះចារឹកពាក្យប្រៀនប្រដៅដ៏សំខាន់ៗបំផុតនៃមហាហ្មាត់ ដែលជាព្រះបុត្រផ្ទាល់របស់ព្រះអាឡាហ៍។ យើងគួរអធិប្បាយដោយសង្ខេបពីទ្រឹស្តីដែលចារឹកក្នុងគម្ពីរគួរអាន ( Qur'an )ដូចតទៅនេះ ៖

១-ទ្រឹស្តីពីព្រះអាទិទេព ៖ ក-ក្នុងបឋមកប្ប មនុស្សលោកទាំងឡាយ មានលទ្ធិតែមួយគត់ ខាងក្រោយមកទើបមានលទ្ធិច្រើននៅក្នុងលោក។ ( Q. IO. I9 )

ខ-មនុស្សលោកទាំងឡាយមានលទ្ធិតែមួយគត់ ព្រះអាទិទេពបានបញ្ជូនមេដឹកនាំសិទ្ធិទាំងឡាយមកលើផែនដីឱ្យជាអ្នកផ្តល់សេចក្តីសុខនិងជាអ្នកប្រកាស ហើយព្រះអង្គបានបញ្ជូនសច្ចធម៌មកជាមួយនឹងមេដឹកនាំទាំងអស់នោះ។ សម្រាប់ជម្រករកយុត្តិធម៌ឱ្យមនុស្សទាំងឡាយដែលទាស់ទែងគ្នា។ ( Q. 2: 2I3 )

គ-គ្មានវត្ថុអ្វីក្នុងលោកដូចជាព្រះអង្គឡើយ ។ ( Q. 41: 11 )

ឃ-គ្មានសត្វលោកណាមួយអាចមើលឃើញព្រះអង្គឡើយ ប៉ុន្តែព្រះអង្គអាចមើលឃើញអ្វីទាំងអស់ក្នុងលោក ។ ( Q. 6: 104 )

ង-ព្រះអង្គមានតែមួយ ជាព្រះអាទិទេពក្នុងលោក មនុស្សលោកទាំងអស់ត្រូវពឹងព្រះអង្គ

ព្រះអង្គគឺវត្ថុពិតនិងស័ក្តិសិទ្ធិក្នុងលោក ហើយពុំមានសត្វណាអាចប្រដូចនឹង ព្រះអង្គបាន។ ( Q. 112: 1-4 )

ច-បើអ្នកណាមួយប្រព្រឹត្តតាមព្រះអង្គព្រះអង្គនឹងជួយដឹកនាំអ្នកនោះវិញ។(Q.29:69 )

ឆ-នៅលើលោកនេះ មានមនុស្សអ្នកជឿខ្លួនឯង ប៉ុន្តែអ្នកកុំយកមនុស្សទាំងឡាយជាប្រមាណឡើយ។ ( Q. 51: 20-21 )

ដោយសង្ខេប ព្រះអាទិទេពក្នុងលទ្ធិអ៊ិស្លាម គឺជាឯកភាពនៃធម្មភាវៈ ដែលអាចឋិតនៅក្នុងគ្រប់ធម្មជាតុទាំងអស់ក្នុងលោក។ ព្រះអង្គប្រើមហាហ្ម៉ុតមកលើផែនដីដើម្បីដឹកនាំមនុស្សលោក ហើយមហាហ្ម៉ុតអាចស្លាប់ទៅវិញបាន តែព្រះអាទិទេពពុំស្លាប់ឡើយ។ ព្រះអាទិទេពនោះគឺព្រះអាឡាហ៍។

២-គុណវិសេសនៃធម្មទីតិ ៖ ព្រះអាទិទេពគេសំដៅយកឯកភាពនៃធម្មទីតិ ៖ករុណាយុត្តិធម៌ ព្រះមគ្គុទ្ទេសក៍ ឬព្រះគម្ពីរ។ ទាំងអស់នេះគេហៅថាគុណវិសេសនៃទេវធម្មទីតិ (Rabubiyat ) ហើយពាក្យនេះមកពីពាក្យថាព្រះម្ចាស់អ្នកបីបាច់ថែរក្សា ( Rabb )។ ធម្មជាតិមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី គឺនៅក្រោមអំណាចព្រះអាទិទេពតែមួយគត់។ បើពោលដោយរួបរួម ព្រះអាទិទេពក្នុងលទ្ធិអ៊ិស្លាម គឺអំណាចនៃធម្មជាតុហ្នឹងឯង។ ព្រះអាទិទេព ឬព្រះអាឡាហ៍បានបង្កើតទិដ្ឋភាពទាំងពីរបែបគឺ ទិដ្ឋភាពខាងក្រៅនិងខាងក្នុង។ ទិដ្ឋភាពខាងក្រៅសំដៅយកធម្មជាតិទាំងអស់រួមទាំងមនុស្សផង។ ទិដ្ឋភាពខាងក្នុងសំដៅយកចិត្ត ប្រាជ្ញា វិជ្ជាសម្រាប់ថ្លៃវត្ថុខាងក្រៅទាំងអស់នោះ សម្រាប់យកទៅបម្រើការរស់នៅរបស់មនុស្សលោក។

ចំពោះវាសនា បន្ទាប់ពីសេចក្តីស្លាប់ យើងឃើញថា គម្ពីរគួរអានបានបញ្ជាក់ដូចតទៅនេះ ៖

មនុស្សលោកគឺជាវត្ថុដ៏វិសេសវិសាលជាងវត្ថុទាំងអស់ក្នុងលោក។ សម្ព័ន្ធភាពរវាងមនុស្សលោកនិងព្រះអាទិទេពគឺមេត្តា កាលណាមនុស្សលោកមានមេត្រីភាពចំពោះព្រះអង្គ

ៗក៏មានមេត្រីភាពចំពោះមនុស្សលោកវិញដែរ។ កាលបើមនុស្សលោកយកព្រះអាឡាហ៍ ជាទីពឹងហើយ បន្ទាប់ពីសេចក្តីស្លាប់ ព្រះអង្គនឹងនាំមនុស្សលោកនោះទៅដាក់នៅឋានសួគ៌ ជាអាណាចក្រនៃព្រះអាទិទេព ហើយមានព្រះអាទិទេពគឺព្រះអាឡាហ៍តែមួយគត់ជាទីពឹង ទីរលឹកៗ កាលបើគេបានទៅដល់ទីនោះហើយ គេនឹងលែងជាមនុស្សលោកទៀតហើយៗ

គ-ការរីកចម្រើននៃចលនាទាំងពីរ ផ្នែកស្ថាប័ននិងទេវធម៌ ៖

១-ផ្នែកស្ថាប័ន ៖ -លទ្ធិអ៊ិស្លាមមានលក្ខណៈងាយស្រួល និងស្រួលនិងច្បាស់លាស់ក្នុងការអនុវត្តជីវិតដ៏ស្អាតបរិសុទ្ធឋិតនៅលើការប្រគល់ខ្លួនដល់ព្រះអាឡាហ៍ និងទទួលយកត្រណមគឺពេលខ្លះត្រូវអត់បាយ អត់ទឹកព្រមទាំងទទួលប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់មហាហ្មុំតជាព្រះរាជបុត្រផ្ទាល់របស់ព្រះអាឡាហ៍ៗ ប៉ុន្តែនៅពេលអនុវត្តគេមិន ឱ្យវៀរចាកមេថុនធម្មទៀត ហើយគេទុករឿងនេះជាការសប្បាយនៅលើលោកនេះៗ មានការប្រតិបត្តិដែលខានមិនបាន ៥ យ៉ាងដែលគេទុកជាសសរស្តម្ភនៃលទ្ធិអ៊ិស្លាម ៖

ក-កលិមា ( Kalima )ឬការសូត្រធម៌សម្រាប់រំលឹកព្រះនាមនៃត្រៃព្រះអាឡាហ៍មួយទេក្នុងលោក ហើយព្រះមហាហ្មុំតគឺជាព្រះបម្រើនៃព្រះអង្គៗ

ខ-សឡាត ( Salat ) ការសូត្រធម៌ថ្វាយបង្គំព្រះ១ ថ្ងៃ ៥ ដងជានិច្ច ព្រមទាំងលប់លាងវត្ថុអាថ៌កំបាំង ព្រលឹម ថ្ងៃត្រង់ ថ្ងៃរសៀល ថ្ងៃលិច ពេលដេកៗ

គ-ការអត់បាយ ( Fasting ) ជាពិសេសនៅថ្ងៃពេញបូណ៌មីខែកត្តិក

ឃ-ហ្សាកាត ( Zakat )ការឱ្យទានទឹកនិងបាយ

ង-ហ័ជ្ជ ( Hajj )ឬធម្មយាត្រាទៅទីក្រុងម៉េក្កា ។

ជួនកាលឬកន្លែងខ្លះ គេបន្ថែមជិហាដ សង្គ្រាមស័ក្តិសិទ្ធិក្នុងនាមព្រះអាឡាហ៍ គឺសង្គ្រាមផ្សាយសាសនាត្រូវជា៦ៗ នៅក្នុងលទ្ធិអ៊ិស្លាម គេហាមមិនឱ្យរកស៊ីជំនួញចងការប្រាក់ មិនឱ្យលេងល្បែងស៊ីសងផ្សេងៗ មិនឱ្យបរិភោគសាច់ជ្រូកនិងចិញ្ចឹមសត្វឆ្កែ និងមិនឱ្យផឹកឬសេពសុរា ប៉ុន្តែឱ្យសម្លាប់សត្វតុកកែនិងជីងចក់ព្រោះជាសត្វចង្រៃៗ ម្យ៉ាងទៀត គេបានឱ្យថែរក្សានិងឱ្យឱកាសដល់សត្វពីងពាង ជាពិសេសនៅក្នុង ( Mosque )(វិហារ) គេធ្វើសញ្ញាសំបុកពីងពាងជានិមិត្តរូបដល់អនុស្សាវរីយ៍ ក្នុងពេលដែលមហាហ្មុំតរត់ចេញពីក្រុងម៉េក្កា ហើយពេលនោះអ្នកក្រុងម៉េក្កា ដេញតាមសម្លាប់ ប៉ុន្តែលោកបានរួចខ្លួនដោយរត់ទៅចូលគុហារមួយហើយពីងពាងព័ទ្ធលោកជិត មិនឱ្យពួកអ្នកដេញតាមរកលោកឃើញឡើយៗ

លទ្ធិអ៊ិស្លាមបានអនុញ្ញាតឱ្យប្រុសមានប្រពន្ធច្រើនត្រឹម ៣ ចុះមកបាន។ ពេលថ្ងៃសុក្រ (គ្រប់ថ្ងៃសុក្រ)គេត្រូវតែចូលទៅ ( liosquo )ដើម្បីស្តាប់ធម៌ពីសំណាក់ពួកអាចារ្យ ដ៏ធំជាអភិបាលនៃវិហារនោះ។ នៅពេលថ្វាយបង្គំជាដំបូងគេត្រូវតែបែរមុខទៅក្រុងម៉េក្កា (Qibla)។

របៀបថ្វាយបង្គំព្រះមាន៨ បែប ៖

១-អ្នកថ្វាយបង្គំត្រូវឈរត្រង់ខ្លួន បែរមុខទៅទិសខាងលិច ហើយលើកដៃទាំងពីរឡើងត្រឹមត្រចៀក រួចសូត្រធម៌ម្តង ៖ " ព្រះអាទិទេព ព្រះអង្គធំជាងអ្វីទាំងអស់ក្នុងលោក"។

២-នៅឈរត្រង់ខ្លួនដដែលហើយទម្លាក់ដៃទាំងពីរមកក្រោម យកដៃស្តាំដាក់លើដៃឆ្វេងសូត្រធម៌ ៖ " ខ្ញុំព្រះអង្គសូមថ្វាយបង្គំ មានតែព្រះអង្គមួយទេដែលវិសេសជាងគេទាំងអស់ ខ្ញុំព្រះអង្គសូមថ្វាយតែព្រះអង្គមួយ"។ បន្ទាប់មកត្រូវសូត្រសុរាហ៍ទី១ (Surahl )នៃគួរអាន។

៣-ត្រូវឱនខ្លួនទៅមុខ ហើយដៃទាំងពីរច្រត់ជង្គង់ ៣ ដង ហើយម្តងៗត្រូវសូត្រ ៖ " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំ" ។

៤-ត្រូវក្រោកឈរឱ្យត្រង់ខ្លួនឡើងវិញ ហើយសូត្រ " សូមព្រះអង្គទទួលនូវកតញ្ញូធម៌ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះអង្គ ព្រោះព្រះអង្គប្រសើរវិសេសជាងវត្ថុទាំងអស់ក្នុងលោក" នៅវេះទី៤ នេះដដែល គេត្រូវលុតជង្គង់ចុះ ដាក់ដៃទាំងពីរទៅក្រោយ ហើយឱនក្បាលឱ្យដល់ដីគ្រប់ ៣ ដង ហើយម្តងៗត្រូវសូត្រថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាវត្ថុស័ក្តិសិទ្ធិក្នុងលោក"។

៥-អង្គុយលុតជង្គង់ ហើយដៃទាំងពីរដាក់លើក្បាលជង្គង់ទាំងពីរ សូត្រធម៌ដូចទី៣-៤។

៦-ក្រោកឈរឡើង ធ្វើឱ្យដូចទី២។ ៧ និង៨ - ត្រូវធ្វើឱ្យដូចទី ៥-៦ ។ ជួនកាលគេធ្វើ ( Rak'a ) ២ ដងក៏មាន ៣ ដងក៏មាន ៤ដងក៏មាន។ ដល់ទីបំផុតនៃការថ្វាយបង្គំម្តងៗគេត្រូវនិយាយអង្វរករព្រោះមហាហ្មាត់ សូមឱ្យលោកជួយរំដោះបាបដែលខ្លួនបានប្រព្រឹត្ត។ ជាទីបញ្ចប់គេត្រូវថ្វាយបង្គំទៅ ឆ្វេងម្តង ទៅស្តាំម្តង ហើយសូមព្រះអាឡាហ៍ផ្តល់សេចក្តីសុខសន្តិភាពព្រមតាំងសេចក្តីសន្តោសប្រោសប្រណីពីព្រះអង្គ។

២-ចលនាទេវធម៌ ( Movement of Theology ) ៖ តាំងពីពេលដែលលទ្ធិអ៊ិស្លាមផ្សាយចេញពីប្រទេសអារ៉ាប់ទៅពាសពេញសកលលោក លទ្ធិនេះបានត្រូវសម្រួលជាច្រើនហើយទទួលយកទំនៀមទម្លាប់ និងសាសនារបស់ប្រទេសនោះទុកក្នុងលទ្ធិនេះទាំងអស់ ដើម្បីឱ្យត្រូវនឹងស្ថានការណ៍របស់ប្រទេសនីមួយៗ។ ពាក្យប្រៀនប្រដៅណាដែលគេយកទុក គេក៏

ទុកសម្រាប់អនុវត្តទៅ ឯពាក្យប្រៀនប្រដៅដែលត្រូវតែបំបាត់ ឬកែសម្រួលគេក៏ត្រូវកែសម្រួលតាមការគួរ។ ត្រង់នេះមានលក្ខណៈដូចគ្នានឹងលទ្ធិគ្រិស្តដែរ។ នេះជាការធម្មតារបស់លទ្ធិឬសាសនានីមួយៗក្នុងលោក។ យើងអាចនិយាយថា លទ្ធិអ៊ិស្លាមសម័យមហាហ្ម៉ត លទ្ធិអ៊ិស្លាមសម័យក្រោយ លទ្ធិអ៊ិស្លាមរបស់ប្រទេសអារ៉ាប់ លទ្ធិអ៊ិស្លាមរបស់ស៊ីរី លទ្ធិអ៊ិស្លាមរបស់បាគិស្ថានជាដើម។ រឿងនេះដូចគ្នានឹងទឹកទន្លេ ឬ ស្ទឹងដែលមានប្រភពនៅត្រង់ណាមួយហើយហូរធ្លាក់ទៅប្រទេសជាច្រើនជាដើម។ បើយើងចង់បានទឹកដ៏សុទ្ធស្អាតលុះត្រាតែយកទឹកត្រង់ឱ្យស្អាត ឬក៏ទៅរកទឹកនោះត្រង់ប្រភពដើមនៃទន្លេឬស្ទឹងនោះ។

នៅក្នុងលទ្ធិអ៊ិស្លាមយើងឃើញការរីកចម្រើនក្នុងវិស័យចលនាទេវធម៌ជា ៣ ប្រភេទ ៖

១-អិជម៉ា ( I jma ) គំនិតស្របគ្នាទាំងស្រុងក្នុងចំណោមគ្រូទាំងឡាយគ្រប់សម័យ និងយុគហើយគ្រប់ទីកន្លែង

២-សុណ្ណា ( Sunna )ទំនៀមទម្លាប់ត្រូវបានគ្រូទាំងឡាយជាបន្ទាប់បន្សំគ្នា ទទួលស្គាល់និងយល់ព្រម ព្រមទាំងធ្វើឱ្យកិច្ចការនិងសកម្មភាពនៃម្ចាស់ដើមរបស់លទ្ធិ មានលក្ខណៈជាមួយនឹងទំនៀមទម្លាប់ ( Habith )ផង។

៣-គីយ៉ាស៍ ( Qiyas )ត្រូវមានអនុមាណ ( Inferences )និងឧទ្ទរណ៍ ( Deductions ) ពីពាក្យប្រៀនប្រដៅដើមនៃលទ្ធិ។

នៅក្នុងប្រទេសឥណ្ឌា យើងឃើញថាពួកអ្នកប្រាជ្ញអ៊ិស្លាមខ្លះបាន យកចិត្តទុកដាក់ជាទីបំផុតអំពីការចាំបាច់ក្នុងការសើរើពិនិត្យជាថ្មីនូវទេវធម៌នៃលទ្ធិអ៊ិស្លាមដូចតទៅនេះ ៖

១-ទេវធម៌នៃលទ្ធិអ៊ិស្លាមត្រូវតែរើសរៀបចំជាថ្មីក្នុង គ្រប់ទិដ្ឋភាពនិងទ្រឹស្តីទាំងអស់ហើយទស្សនវិជ្ជាសម័យថ្មី អស្តិរូបនិយម ចរិយាសាស្ត្រ ចិត្តសាស្ត្រ និងតក្កវិជ្ជា គឺយើងត្រូវតែអនុវត្ត ដើម្បីជាជំនួយដល់ការបង្កើតរូបមន្តនិងពាក្យប្រៀនប្រដៅបែបថ្មី នៃទ្រឹស្តីរបស់លទ្ធិ។

២-គម្ពីរនិងទំនៀមទម្លាប់ត្រង់កន្លែងណា ដែលស្តីពីធម្មជាតិនិងសេចក្តីពិតតាមលក្ខណៈវិទ្យាសាស្ត្រ គេត្រូវតែរៀបចំលក្ខណៈទាំងអស់នោះឱ្យមានរបៀបដែលអាចសាកសួរនិងវិភាគបាន។ គ្រប់វគ្គនិងគ្រប់អត្ថន័យទាំងអស់នៃគម្ពីរនោះ ត្រូវតែបកស្រាយទទួលយកគណិតវិទ្យា វិទ្យាគីមីនិងថ្នាំពេទ្យ។ បញ្ញត្តិនៃលោក ពេលវេលានិងលោកធាតុ បានប្រែប្រួលមិនមានសេសសល់និងយ៉ាងដាច់ហើសជាទីបំផុតតាំងពីសម័យនៃលោក ( Copernicas )

ម៉ូះដូច្នេះលទ្ធិអ៊ិស្លាម ត្រូវតែមានការប្រុងប្រយ័ត្នចំពោះការផ្លាស់ប្តូរទាំងអស់នោះ។ ម្យ៉ាងទៀតពាក្យប្រៀនប្រដៅណាដែលមិនប្រកបដោយហេតុផល ត្រូវតែកម្ចាត់ចេញឱ្យអស់ពីក្នុងលទ្ធិ។

៣-វិទ្យាសាស្ត្រនៃសាសនាប្រៀបធៀបត្រូវទុកជាជំនួយទី១ សម្រាប់ពុទ្ធិសិក្សាទាំងមូលនៃលទ្ធិអ៊ិស្លាម។

លទ្ធិសាកលនិយមចិន ៖ ប្រវត្តិសង្ខេបនៃវប្បធម៌ជាតិមុងគោលចែកចេញជា ៣ក្រុមគឺ ៖ មុងហ្គោលភាគខាងជើង មុងហ្គោលភាគខាងត្បូង និងមុងហ្គោលភាគសមុទ្រ។ មុងហ្គោលភាគខាងជើងបានដល់ជាតិទៀក (Turk) ជាច្រើនក្រុមគឺ ៖ ប្រជាជនហ្វិន្ន (Finns) , ល័ប្ប (Lapps), ប៊ិល្គារ (Bilgars)និងម័គយ៉ារ (Magyars)។ ពួកប្រជាជននេះបានលាយ ចូលជាមួយនឹងពួកអឺរ៉ុបភាគខាងជើងនិងខាងលិច គឺពួកន័រឌិក (Nordic) និងពួកអាល់ពីន (Alpine)។ មុងហ្គោលភាគខាងជើងនេះ យើងឃើញឋិតនៅក្នុងប្រទេសស៊ីប៊ីរី ភាគខាងកើត, ពួកមញ្ជូនៃប្រទេសចិន, ពួកជនជាតិជប៉ុន ពួករុស្ស៊ី (មុងហ្គោលជំនាន់យុគកណ្តាល) និងពួកកូរ៉េ។ មុងគោលភាគខាងត្បូងសំដៅយកប្រជាជនចិនទាំងអស់, ភូមា, សៀម, ខ្មែរ, លាវ, យួន, ទីបេត៍, អស្សម, ពួកហិមាល័យ (នេប៉ាល់, ហិមាល័យប្រទេស កាលីមតុង)។ មុងហ្គោលភាគសមុទ្រ បានដល់ពួកប្រជាជនម៉ាលយូ, សិង្ហបុរី, ឥណ្ឌូនេស៊ី, ហ្វីលីពីន, ម៉ាដាហ្គាស្ការ។

ចំពោះវប្បធម៌ យើងឃើញថាប្រជាជាតិចិនមានវប្បធម៌ទោះណាជាមិនចាស់ណាស់ណាជាងគេប៉ុន្មានក្នុងលោកក៏ដោយ ក៏វប្បធម៌នោះមានលក្ខណៈជាប់គ្នាល្អណាស់។ អ្នកប្រាជ្ញខ្លះគិតថាវប្បធម៌ជាតិនេះផ្សាយចេញមកពីអាស៊ីភាគនីរតី។ គេបានបញ្ជាក់ថាពាក្យស័ព្ទនិងប្រព័ន្ធតារាសាស្ត្រនៃចិន មានលក្ខណៈដូចគ្នានឹងជាតិអក្កាដា (Akkadia)។ ការផ្សាយវប្បធម៌មកពីទីនោះ ប្រហែលមិនមែនមកពីរបបអាណានិគមទេ គឺប្រហែលជាការទាក់ទងគ្នាខាងផ្លូវជំនួញតាមជើងគោកឬសមុទ្រ (ចេញពីកំពង់ផែ Eridu ត្រង់ច្រោយឈូងសមុទ្រប៉ែរ្ស (Perse) ដែលជាមជ្ឈមណ្ឌលនៃជំនួញ-ប្រហែលជា ៤ឬ៥ ពាន់ឆ្នាំកន្លងទៅហើយ)។

បណ្ឌិត ហ៊ូ ស្ហិ៍ (Hu-Shih) បានចែកការរីកចម្រើននៃលទ្ធិចិនជា ៣សម័យគឺ ៖

១-យុគស៊ីនីទិក (Sinitic Age) (មុន គ.ស.២០០០-៣០០)

២-ពុទ្ធសាសនាយុគ

*៣-ការរើរៀបចំជាថ្មីនូវវប្បធម៌ (ជោគជ័យនៃលទ្ធិខុងជឺបែបថ្មី ដែលចិនបានរក្សាទុករហូតដល់សម័យមុនលទ្ធិកុម្មុយនិស្ត)។*

***១-យុគស៊ីនីទិក*** *៖ ក-យើងឃើញថា នៅសម័យនេះប្រជាជនចិនមានលក្ខណៈវប្បធម៌នៃលទ្ធិ ២បែបគឺ៖*

*-ភាគខាងកើត ប្រជាជនគោរពបុព្វបុរសនិងបុព្វបុរសបូជា (មត្តកបូជា)*

*-ភាគខាងលិច ប្រជាជនគោរពសាង-ទី* (Shang-Ti) *ឬ ហាវ-ទៀន* (Hao-Tien) , *លទ្ធិនេះមិនមែនឈ្មោះជាឯកទេវនិយមទេ គឺគេគ្រាន់តែធ្វើការគោរពឱ្យមានមជ្ឈដ្ឋានទៅលើអាកាសទេវតាដ៏ខ្ពង់ខ្ពស់បំផុត* (Supreme Sky-god) *ប៉ុណ្ណោះ*[២២]។

*យុគស៊ីនីទិក* (Sinitic Age) *មុនគ.ស.២០០០-៣០០*

*ភាគខាងកើត* (Eastern)

*ការគោរពបុព្វបុរសនិងបុព្វបុរសបូជា (មតកបូជា)*

(Ancestor-Worship& Cult of the load)

*ភាគខាងលិច* (Western)

*ការគោពបូជាអាកាសទេវតាដែលមានអំណាចដ៏ខ្ពង់ខ្ពស់បំផុត។*

(The Worship of a Supreme sky-god)

*មានសេចក្តីបញ្ជាក់ថា ការគោរពសាង-ទី* (Shang-Ti) *ឬ ហាវ-ទៀន* (Hao-Tien) *ឬក៏អាកាសទេវតាដែលមានអំណាចខ្ពស់បំផុត មិនមែនជាអ្នកបង្កើតលោកទេ គឺជាគំនិតដើមហើយមានការវិវត្តឡើងព្រមគ្នា បេញមកពីព្រលឹងកើតឯង* (Self-Existence) *ដែលមានធាតុយិន និងយ៉ាង*(Yin & Yang = Yin is positive element &Yang is negative) *ជាមូលដ្ឋាន។ ធាតុយិន (Yin) គឺជាធាតុញី, ឯធាតុយ៉ាង (Yang) គឺជាធាតុឈ្មោល។ ឧត្តមគតិទាំងនេះ ក្នុងរជ្ជកាលនៃព្រះបាទស៊ូ និងស៊ី (Shu king & Shi kings) ខាងក្រោយជ័យជំនះនៃព្រះចៅជូ (Chou) មុនគ.ស.១១០០ គេបញ្ចូលពាក្យថា (ទៀង) Tien “ព្រះម្ចាស់សួគ៌” មកក្នុងឧត្តម គតិនោះ។*

*ពាក្យថា “Tion” នេះ មានន័យ២យ៉ាងគឺ ៖ ក-អាកាស (Sky), ខ-ទេព្តា (God) ហើយលោកខុងជឺ បានប្រើពាក្យថា “ទេព្តា” (God) ច្រើនជាងពាក្យថា “អាកាស (Sky)”។ ប៉ុន្តែសាស្ត្រាចារ្យគីលស៍ (Gils) បានបញ្ជាក់ថា ទៀង (Tien) គឺអសកម្មទេវតា (God in the*

[២២] *ប៉ែន សាអឿន* ***សាសនាប្រៀបធៀប*** *គ.ស.១៩៦៩ ទំ៧៣*

passive), ឯពាក្យថា សាង-ទី (Shang-Ti) គឺទេវតាមានអំណាចខ្ពង់ខ្ពស់បំផុត (Supreme God = Yin + Yong) ជាសកម្មទេវតា (God in the active)។ ការផ្សេងគ្នានៃឧត្តមគតិទាំង ២ នេះ មានលក្ខណៈពិតប្រាកដតាមអត្ថន័យ ព្រោះអបុរិសៈសភាវៈនៃគំនូរឧត្តមគតិប្រព្រឹត្តិទៅជាមួយគ្នានឹងអបុរិសភាពនៃឧត្តមគតិ ។

ចំពោះប្រជាជនភាពខាងកើត ដែលគោរពបុព្វបុរសនិងបុព្វបុរសបូជា ក៏មានបញ្ជាក់ពីទេវតាជាន់ខ្ពស់ដែរ ដែលជាអ្នកកត់ត្រាសេចក្តីរាយការណ៍នៃបុព្វបុរសដែលស្លាប់ទៅហើយ, ប៉ុន្តែពាក្យថាទេព្តាជាន់ខ្ពស់ពុំមានបញ្ជាក់លក្ខណៈពិសេសដូចជា សាង-ទី ឡើយ។

ចំពោះពិធីបូជាយើងឃើញថា ក្នុងការគោរពសាង-ទី ក្បួនលី-គី ជាសៀវភៅសម្រាប់បញ្ជាក់ពីពិធីបូជានិងរបៀបបូជា ៤ ប្រភេទគឺ ១-បុណ្យធំ (The Kiao- The great Hstang) ជាបុណ្យឧទ្ទិសដល់ទេព្តាដែលមានអំណាចធំបំផុត ដែលមានរូបនិងវិហារធំបំផុត ធ្វើពីថ្មកែវនៅទីក្រុងប៉េកាំង ១ឆ្នាំត្រូវម្តង ហើយព្រះអធិរាជខ្លួនឯងចូលមកគោពនមស្ការ។ ២-បុណ្យបូជាតូចៗ ត្រូវធ្វើ១ឆ្នាំ ៣ដង (Three Hsiang) ។ នៅក្នុងប្រទេសទី២នេះ គេចែកពិធីបូជាជា៣ប្រភេទ ហើយរួមជាមួយនឹងប្រភេទទី១ខាងដើម ត្រូវជា៤ប្រភេទ។ មានបុណ្យតូចមួយទៀតគេត្រូវធ្វើនៅពេលចូលឆ្នាំ" ហៅថាបុណ្យមួយឆ្នាំម្តង (One Hsiang)។ ព្រះអធិរាជគេទុកជាព្រះរាជបុត្រមៃព្រះម្ចាស់សួគ៌។ ពិធីបូជានៅពេលបុណ្យធំ (The Great Hsiang) មានភ្លេង, ច្រៀងជាពួក, ទៀនធូប, ពិធីសូត្របូជា, សំពត់សូត្រ, ស្រា, ក្រដាស, ក្រដាសប្រាក់គេធ្វើពីក្រដាសធម្មតា,ឈាមរបស់គោឡើងក, សម្លាប់សត្វបូជា, ភ្លើងសម្រាប់ដុតគ្រឿងបូជាទាំងអស់នោះ។

លទ្ធិចិនពីមុន គ.ស.៣០០០ ទៅ ១២០០ មានលក្ខណៈដូចគ្នានឹងយុគស្ពាន់ ដែលគេគោរពទេព្តាជាច្រើនបែបៗ កាលណាបើមានទេព្តាធំ តែងមានតូចៗមកទៀត ដូចជាភូមិទេវ-តា, ខ្មោច អារក្សជាដើមទៀត។ បុណ្យទានក៏មានច្រើនបែបដែរ ដូចជាបុណ្យរដូវហើយចម្រូត អាពាហ៍ពិពាហ៍។ ដែលគេធ្វើបុណ្យនោះឡើងគឺគេយល់ថាមានទេព្តារក្សាធម្មជាតិទាំងអស់នោះ ដើម្បីសូមឱ្យទេវតាទាំងអស់នោះជួយប្រសិទ្ធពរជ័យនិងឱ្យចម្រុងចម្រើនដល់ប្រជាជនជាកូនចៅ។

១-សម័យទស្សនវិជ្ជា មុនគ.ស.១២០០ ទៅ៣០០ នៅសម័យនេះយើងឃើញថា មានអ្នកទស្សនវិទូដ៏សំខាន់២នាក់គឺ ៖ ខុងជឺ (Kung-fu-Tzû = Confucius), Kung "សាស្តាចារ្យ" និង

ឡាវ-សេ (Lao-Tzu)។ ខុងជឺ កើតក្នុងអាណាចក្រស្តេចក្រាញ់មួយឈ្មោះ លូ (Lu) ផ្នែកនៃខេត្តសព្វថ្ងៃមួយឈ្មោះ សាង ទុង (Shantung)។ លោកកើតប្រហែលជានៅមុនគ.ស.៥៥១។ លោកជាបុគ្គលវិសេសហើយមានចរិយាសុភាពរាបសាតាំងពីក្មេងៗ គេនិយាយថា លោកនៅសល់ញាតិសន្តានព្រេងលានរហូតដល់សព្វថ្ងៃនេះៗ កេរ្តិ៍ឈ្មោះរបស់លោក និងកិច្ចការព្រមទាំងខ្សែគំនិតបានល្បីល្បាញទៅពាសពេញក្នុងសកលលោកៗ ឡាវសេ ប្រសូតនៅមុនគ.ស.៦០៤ មុនលោកខុងជឺ ប៉ុន្តែនៅពេលថ្មីៗនេះ មានការស្រាវជ្រាវច្រើនបានបញ្ជាក់ថាលោកឡាវសេមិនមែនជាមនុស្សទេ គឺជារឿងដែលគេប្រឌិតឡើង ហើយពាក្យប្រៀនប្រដៅរបស់គាត់ឱ្យឈ្មោះថាលទ្ធិតៅ។ ឈ្មោះឡាវសេនេះ មានមកតែក្នុងកិច្ចការរបស់សិស្សគណខាងក្រោយទេ ប៉ុន្តែខ្លួនលោកពុំដែលមានប្រវត្តិជាក់ច្បាស់ថាជាអ្នកមានការពិសោធក្នុងបញ្ហាមនុស្សលោកដូចជាលោកខុងជឺឡើយ[២៣]។

ប្រព័ន្ធទស្សនវិជ្ជាខុងជឺ និងឡាវសេ ទាំងពីរនេះ មានមូលដ្ឋានទៅលើពាក្យថា តៅ ដូចគ្នា។ ពាក្យថាតៅ មានលក្ខណៈពិបាកនឹងធ្វើអត្ថន័យជាទីបំផុតៗ តៅនេះជាឧត្តមគតិដើមមួយរបស់ជនជាតិចិនដែរៗ ជាដំបូង លទ្ធិនេះមានអត្ថន័យដូចជាលទ្ធភាពនៃធម្មជាតិ ប៉ុន្តែ លុះពាក្យនេះធ្លាក់មកក្នុងដៃអ្នកទស្សនវិទូ ក៏ក្លាយជាមានអត្ថន័យថា "អបុរិសៈសភាវៈទេវតាទៅវិញ ដែលមានលក្ខណៈដូចជានឹងពាក្យក្នុងភាសាក្រិកថា "ហេតុ" (Heason) ឬដូចគ្នានឹងពាក្យថា (Logos) នៃវិចារណ៍របស់ក្រិក-រ៉ូម និងហេល្លិនិស្តិកហ៊ីប្រ៊ូវ (Hellenistic Hebrew) ឬក៏ដូចគ្នានឹងបដិសំយោគព្រឹត្តិ (Dialectic Process) នៃលទ្ធិមាក្សនិយម(Marxism)។ម្យ៉ាងទៀតពាក្យថាតៅនេះ ដូចគ្នាពាក្យថា Absolutism មានតែព្រះអាទិទេពមួយទេ ទើបស្អាតបរិសុទ្ធ" នៃអ្នកមនោគតិទស្សនវិទូសម័យថ្មីៗ សេចក្តីផ្សេងគ្នារវាងប្រព័ន្ធខុងជឺ និងតៅរបស់ឡាវសេ ដូចនេះគឺ ប្រព័ន្ធខុងជឺមានលក្ខណៈជាសកម្មទៅលើបញ្ហាលោកៗ ឯប្រព័ន្ធរបស់ឡាវសេមានលក្ខណៈជាអសកម្មទៅលើបញ្ហាលោកៗ ម្យ៉ាងទៀត ប្រព័ន្ធតៅបានបញ្ជាក់ពីការស្ងប់ស្ងាត់នៃជីវិតឋិតនៅលើការគោរពដ៏ត្រូវ ដែលជាហេតុធ្វើឱ្យជីវិតស្ងប់ស្ងាត់ទៅបាន ហើយកុំឱ្យបៀតបៀនធម្មជាតិ ព្រោះធម្មជាតិក៏ហុចប្រយោជន៍សំខាន់ណាស់ដល់ជីវិតៗ ព្រោះហេតុនោះ យើងមិនត្រូវជ្រៀតជ្រែកម៉ាស៊ីនឬគ្រឿងយន្តរបស់វាទេៗ ឯលោកខុងជឺ គឺជាអ្នកហេតុវិទូ ដែលមានចិត្តចង់ឱ្យប្រកាប់ទំនៀមទម្លាប់ប្រកបដោយការអនុវត្តឬប៉ិនប្រសប់

---

[២៣] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៧៥

ហើយលោកបានរៀបចំនិងប្រៀនប្រដៅពីរបៀបកិច្ចការប្រចាំថ្ងៃនៃមនុស្សម្នាក់ៗ យ៉ាងប្រុងប្រយ័ត្នជាទីបំផុត។ លោកមិនមែនជាអ្នកអទេវនិយមទេ ទោះណាជាលោកចង់កុំឱ្យមានជំនឿក្នុងទេវសភាវៈជារបៀបមនុស្សក៏ដោយ ហើយលោកបានប្រើពាក្យថា "ឋានសួគ៌" ជំនួសវិញ ដែលមានន័យថាទេវនិយមដែរ។ លោកតែងពោលថា "ស្ថានសួគ៌បានទុកចិត្តលើរូបខ្ញុំជាអ្នកបេសកជន" ហើយជាពិសេសលោកតែងតែពោល និងបញ្ជាក់ជានិច្ចនូវមនុស្សប្រកបដោយឧត្តមគតិឬបរិសុទ្ធស្អាត ថាជាអ្នកទទួលអំណាចនិងបង្គាប់នៃឋានសួគ៌។ លោក បានដើរគ្រប់ច្រកល្ហក ខ្ទបប្រាំង-វស្សា ដើម្បីផ្សាយពាក្យប្រៀនប្រដៅរបស់លោក ព្រម ទាំងបានអង្គការក្រុមសិស្សានុសិស្សឱ្យជួយបំពេញបេសកកម្មនៃការប្រកាស និងការប្រៀនប្រដៅប្រជាជនឱ្យធ្វើសេចក្តីល្អ ព្រមទាំងឱ្យខំប្រឹងធ្វើការងារចិញ្ចឹមជីវិតដោយសុចរិត យុត្តិ-ធម៌។ ជីវិតនិងបេសកកម្មរបស់លោកខុងជឺ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងព្រះពុទ្ធនៃនេប៉ាល់ដែរ ព្រោះលោកបានជួបប្រទះគ្រោះថ្នាក់ពីគ្រប់មជ្ឈដ្ឋានពីធម្មជាតិនិងពីមនុស្សផងគ្នា។ លោកខុងជឺជាបុរសវិសេសហើយវាងវៃជាទីបំផុត ពាក្យប្រៀនប្រដៅរបស់លោកបានសង្កត់ធ្ងន់ទៅលើចរិយាសាស្ត្រ ហើយមានបំណងចង់ឱ្យមនុស្សលោកស្រឡាញ់គ្នា រាប់អានគ្នា ដោយមិនប្រកាន់ថ្នាក់ ជាន់ឬវណ្ណៈឡើយ គឺឱ្យមានមនុស្សធម៌ ក្នុងចំណោមមនុស្សលោកដូចគ្នាព្រមទាំងសត្វ។ លោកបដិសេធពិធីបូជាផ្សេងៗហើយនិងការបន់ស្រន់ផ្សេងៗដែលឥតប្រយោជន៍។ ន័យនេះមានការខ្វែងយោបល់ថា ការបដិសេធពិធីបូជា និងការបន់ស្រន់របស់គាត់មានការប្រឆាំងនឹងការទទួលឋានសួគ៌ ប៉ុន្តែរឿងនេះពុំមានការបញ្ជាក់ឡើយ[២៤]។

បញ្ហាជីវិតនៃមនុស្សតាមទស្សនៈរបស់គាត់ ត្រូវតែប្រកបដោយវីរិយភាពនិងសកម្ម ហើយត្រូវអនុវត្តនិងប្រព្រឹត្តតាមផ្លូវកណ្តាល។ ត្រង់នេះ មានលក្ខណៈប្រហាក់ប្រហែល គ្នានឹងមជ្ឈិមាបដិបទានៃព្រះពុទ្ធនិងអារីស្តូតដែរ។ ទ្រឹស្តីនៃមនុស្សដែលមានលក្ខណៈ ដូចខាងលើនេះ បានរីកចម្រើនឡើងដោយអ្នកប្រាជ្ញទស្សនខុងជឺម្នាក់ឈ្មោះ ម៉េង ស៊ឺ (Mencius) កើតនៅមុនគ.ស.ប្រហែល៤៥១។ លោកម៉េងជឺបានប្រកាសថា តាមទស្សនវិជ្ជាខុងជឺ មនុស្សគ្រប់រូបត្រូវមានខ្លួនឯងនូវគោលការណ៍ដ៏សំខាន់ ៤យ៉ាងគឺ សុចរិតធម៌ យុត្តិធម៌ កម្មសិទ្ធិ និងប្រាជ្ញ ពុទ្ធិ ហើយមនុស្សម្នាក់ៗត្រូវគោរពច្បាប់របស់ខ្លួន បើប្រសិនជាខ្លួនចង់ឱ្យបានជាមនុស្សស្លូតបូតវិសេស។ ទស្សនៈទាំងអស់នេះបានធ្លាក់ទៅក្នុងអនាគតទៅវិញ ព្រោះសម័យ

[២៤] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៧៦

មិនបើកឱកាសឱ្យ ហើយលោកខុងជឺត្រូវអនិច្ចកម្មដោយពេកបេះដូងដោយ គោលបំណងនៃការអនុវត្តរបស់លោកពុំមានជោគជ័យ។ លោក មោ-ទី កើតមុន គ.ស. ៤៨០-៣៩០ បានប្រកាសថាទស្សនៈខុងជឺមានវិបត្តិច្រើនក្នុងលក្ខណៈនៃសច្ចធម៌ឬភាវៈ។ តាមពិត យើងអាចដឹងព្រះអាទិទេពបាន ហើយយើងអាចធ្វើមូលដ្ឋានរបស់យើង ទៅលើ ចរិយារបស់ព្រះអង្គ។ បំណងរបស់ព្រះអង្គគឺមេត្តា សាធារណៈ និងប្រាសចាកការប្រកាន់ ឋានៈ។ សង្គ្រាមឬការឈ្លោះប្រកែកគ្នា ឬការកាប់សម្លាប់គ្នា គឺប្រឆាំងនឹងធម្មជាតិនិង ប្រក្រតីរបស់ព្រះអង្គ។ មោ-ទី ប្រកាសឱ្យមនុស្សមានមេត្តាជាសាកល។ ចំណែក ម៉េង-ជឺវិញ យើងឃើញថា លោកប្រឆាំងនឹងមេត្តាសាកលនៃលោកមោ-ទី ព្រោះលោកបានប្រកាសថា មេត្តាបែបនេះមិនអាចអនុវត្តទៅបានក្នុងចំណោមមនុស្សលោក ហើយមេត្តាបែបនេះ ត្រូវជួបប្រទះគ្រោះថ្នាក់លើខ្លួនឯង។ ត្រង់ចន្លោះនៃមុនគ.ស.៣៣២ និង២៩៥ ឆាង-សេ បានទំប្រឹងបញ្ចូលទស្សនៈតៅរបស់លោកឡាវសេទៅក្នុងទស្សនៈខុងជឺ ដើម្បីជាមគ្គុទេសក៍ នៃជីវិត។ បំណងរបស់លោកបានសម្រេចជោគជ័យដ៏ប្រសើរក្នុងការបង្កើតទ្រឹស្ដី។ លទ្ធិតៅ គឺជាជំនឿក្នុងអំណាចដ៏ខ្ពង់ខ្ពស់ជាច្រើន (Poly doemonistic Religion) ដូចជាលទ្ធិរបស់ប្រជាជនជាន់ដើម ហើយលោកឆាង-សេ (Chwang-Tse) បានសង្កត់ធ្ងន់ទៅលើជំនឿបែបនោះ[២៥]។

លុះដល់មុន គ.ស.២២១ ស្ដេច ស្ហិ-ហួង-ទី (Shih-Huang-Ti)បានឱ្យគេលុបចោល និងបំបាត់ចោលទស្សនៈនិងទ្រឹស្ដីរបស់ឡាវសេ និងខុងជឺអស់ ព្រោះលោកយល់ថាទស្សនៈទាំងពីរនេះ ជាឧបសគ្គដល់ការគ្រប់គ្រងរបស់ព្រះអង្គ។ លុះដល់ព្រះរាជវង្សហាន់ (Han) ទើបទស្សនវិជ្ជាខុងជឺមានជីវិតឡើងវិញ ដោយការអនុគ្រោះរបស់ព្រះចៅ លី-ប៉ាង (Liu-Pang) ទ្រង់អនុញ្ញាតឱ្យរៀបចំ ឱ្យរៀនទស្សនៈនេះឡើងវិញ។ ព្រះរាជាអង្គនេះទ្រង់ឱ្យស្វែងរកឈ្មោះអ្នកខ្លាំងពូកែដែលស្លាប់បាត់បង់ជីវិតទៅហើយ អ្នកទស្សនវិទូជនជាតិចិន ទាំងអស់ ហើយទ្រង់ឱ្យគេធ្វើពិធីបូជានិងរំឭកដល់វិញ្ញាណក្ខន្ធនៃជនទាំងអស់នោះ។ ពេលនេះ គំនិតអវតារក៏កើតឡើងដូចជាឧត្ដមគតិអវតារនៃឥណ្ឌាដែរ។

នៅសតវត្សទី៤ នៃគ.ស. មានអ្នកទស្សនវិទូម្នាក់ទៀតកើតឡើង។ អ្នកទស្សនវិទូនេះឈ្មោះ ស៊ុន-សេ(Hsun-Tsé) អ្នកបង្កើតចរិយាសាស្ត្រប្រឆាំងនឹងទស្សនៈឡាវសេនិងខុងជឺ។

[២៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៧៧

*លោកនេះបានប្រកាសថា មនុស្សលោកតាមកំណើតនិងប្រក្រតីដើម មានចិត្តអាក្រក់ ប៉ុន្តែគេត្រូវឈ្នះអំណាចចិត្តដោយការអប់រំនិងថែរក្សាឬអភិបាល។*

*តាមសេចក្តីសង្ខេតទូទៅ យើងឃើញថា មោ-ទី ក្តី, ឆាង-សេ ក្តី និងស៊ុន-សេ ក្តី ទាំង ៣ នេះជាចលនាដ៏តូចតាចនៅក្នុងវិចារចិន្តានៃជាតិចិន ហើយវិចារណ៍និងទស្សនទាំងអស់នេះមិនអាចប្រៀបបានទនឹងប្រជាប្រិយភាពនៃទស្សនៈខុងជឺនិងឡាវ-សេឡើយ ព្រោះប្រជាជនចិនស្ទើរតែទាំងអស់បានអនុវត្តតាមទស្សនៈនៃលោកទាំងពីរនេះ។*

*២-ពុទ្ធសាសនយុគ ៖ នៅវ័ណ្ណនេះ យើងមិនមានការចាំបាច់និងរៀបរាប់ពីព្រះពុទ្ធសាសនានៅប្រទេសចិនឡើយ ព្រោះយើងត្រូវការតែទស្សនៈនិងសាសនាចិនសុទ្ធសាធប៉ុណ្ណោះ។ ប៉ុន្តែដែលយើងត្រូវពោលខ្លះ ព្រោះព្រះពុទ្ធសាសនាបានកម្រិតប្រវត្តិសាស្ត្រនៃចិន្តាចិនដែរ។ នៅសតវត្សទី៦ នៃគ.ស. ព្រះពុទ្ធសាសនាបានផ្សាយចូលទៅប្រទេសចិនតាមជើងគោកខ្លះ ជើងទឹកខ្លះ។ សេចក្តីសំខាន់បានចំណុចជាពិសេស គឺនៅពេលដែលព្រះពុទ្ធសាសនាផ្សាយពាសពេញប្រទេសចិនហើយ លទ្ធិតៅនិងខុងជឺ បានខ្សោយឥទ្ធិពលជាខ្លាំងនៅក្នុងទឹកចិត្តនៃអ្នកប្រាជ្ញនិងអ្នកកាន់អំណាចស្រុកខ្លះ ប៉ុន្តែលទ្ធិទាំងពីរនេះ មានឥទ្ធិពលដែលក្នុងចិន្តាចិននៃប្រជាជនសាមញ្ញទូទៅក្នុងប្រទេស។*

*៣-លទ្ធិខុងជឺ បែបថ្មី ៖ នៅគ.ស.១១៣០-១២០០ មានអ្នកទស្សនវិទូ ២រូបកើតឡើងគឺលោក ជូ-ស្ហិ និង ជូ-សេ។ លោកទាំងពីររូបនេះជាអ្នកកែទម្រង់លទ្ធិខុងជឺ។ លោកបានប្រកាសដូចតទៅ ៖*

*ក-សម្ភារនិយម ៖ សំដៅយកការបដិសេធកំណើតបុរិសៈសភាវៈនៃព្រះអាទិទេព និងការមិនស្លាប់នៃព្រលឹង។*

*ខ-ទេវនិយម ៖ អនុវត្តតាមលទ្ធិខុងជឺត្រង់បុរិសៈសភាវៈ ជាធាតុដែលមានក្នុងព្រលឹងនៃឋានសួគ៌*[២៦]*។*

*លោកនេះបានបញ្ជាក់ថា* "Li= *ធម្មជាតុ" ឋិតនៅក្នុងព្រលឹងនៃឋានសួគ៌ឬព្រះអាទិទេពជា សស្សតសភាវៈ ដែលគេទុកជាសម្ភារសភាវៈដែលមានការទាក់ទងដល់ធាតុ* Yin *និង* Yang *នៃលទ្ធិខុងជឺ។ គេបានសន្តត់ថា* Yin *និង* Yang *ទាំងពីរនេះគឺជា ថាមពលរួមគ្នានៃធម្ម-ធាតុ។* Yang *បានដល់ធាតុដ៏សំខាន់ក្លីថ្លា ភេទឈ្មោល សកម្ម និងជាមេបង្កើត ឯធាតុយិន* (Yin) *បានដល់ធាតុដ៏ងងឹតមិនក្លីថ្លា ភេទញី ជាអសកម្មនិងជាកន្លែងសម្រាប់ទទួល។ ធាតុ* Yang *ឋិតនៅក្នុងសភាវៈនៃឋានសួគ៌និងព្រះម្ចាស់សួគ៌ឬទេព្តា ឯធាតុ* Yin *ឋិតនៅក្នុងលើ*

---

[២៦] *ប៉ែន សាអឿន* ***សាសនាប្រៀបធៀប*** *គ.ស.១៩៦៩ ទំ៧៨*

ផែនដី ព្រមទាំងផលិតផលទាំងអស់នៃធម្មជាតុ។ ធាតុទាំងពីរនេះ មានសម្ព័ន្ធភាពជារួមគ្នាជានិច្ច ហើយបង្កើតធាតុ ៥យ៉ាងទៀតគឺ ធាតុឈើ ដី ដែក ភ្លើង និងទឹក។ ធាតុទាំង ៥ យ៉ាងនេះបង្កើតជាសម្ភារវត្ថុទាំងឡាយក្នុងលោក។ នៅក្នុងធាតុដ៏សំខាន់ ៥នេះ លោក ជូ-ស៊្ហិ បានបន្ថែមលោកធាតុ (Wu-Ki-a potential cosmos) មួយទៀត ហើយធាតុដ៏បរិសុទ្ធស្អាត ដែលឋិតនៅក្នុងព្រលឹងនៃព្រះម្ចាស់គឺ T'ai Ki មួយថែមទៀត។ ធាតុទាំង ២ខាងក្រោយនេះ ជាថាមពលធំបំផុតលើធាតុទាំង៥ខាងដើម ជាគ្រឿងយន្តសម្រាប់បង្វិលធាតុទាំង៥នោះ។

# ជំពូកទី៤
# សាសនាសិក្ខ សាសនាក្រុមអារ្យ័ន សាសនាព្រាហ្មណ៍-ហិណ្ឌូ សាសនាពុទ្ធសាសនាសិក្ខ

## សាសនាព្រាហ្មណ៍ សទ្ធាមូលដ្ឋានរបស់អារ្យក

*សាសនាព្រាហ្មណ៍* (Brahmmanism) *ក្នុងពាក្យបរិយាយនេះសំដៅសាសនាហិណ្ឌូ* (Hinduism) *ដែលអ្នកប្រាជ្ញសាសនាហៅថាព្រាហ្មណ៍ថ្មី* (Neo-Brahmmanism) *ដែលនឹងពិពណ៌នាជារយៈតទៅខាងមុខៗ*

*ដូច្នោះពាក្យថាសាសនាព្រាហ្មណ៍ ឬសាសនាហិណ្ឌូ ជាសាសនាតែមួយក៏ថាបាន ឬផ្សេងៗគ្នាក៏ថាបានដែរ បើនឹងថាជាមួយគ្នានោះ ត្រូវយកសាសនាព្រាហ្មណ៍ជាមូលដ្ឋាន ឬយកគម្ពីរចាស់របស់សាសនាហិណ្ឌូជាមូលដ្ឋាន ប្រសិនដូចជាការកើតនៃសាសនាគ្រិស្ត មានសាសនាជ្វីហ្វជាមូលដ្ឋាន បើថាម្ខាងម្នាក់នោះគឺត្រូវ និយាយថា មានការគោរពពាប់អានមួយផ្នែកៗ ឯសម័យនីមួយៗគឺ សម័យដំបូងជាព្រហ្មណ៍ពិតប្រាកដ រហូតមកដល់បឋមពុទ្ធកាលនិងពេលក្រោយមកជា ហិណ្ឌូ សូមសម្តែងការគោរពពាប់អាននោះឱ្យបានឃើញ ដោយសង្ខេបដូចតទៅ ៖*

### ***បឋមសម័យ***

*សាសនាព្រាហ្មណ៍ជាផៅពង្សរបស់អារ្យក ឬឥណ្ឌូយូរ៉ុបកៀន* (Indo-European) *អាស្រ័យនៅភូមិភាគកណ្តាលនៃទ្វីបអាស៊ី* (Central Asia) *តែពីត្រឹមណាមួយមកនោះ គ្មានការបញ្ជាក់ឱ្យច្បាស់លាស់ទេៗ ពួកក្រុមអារ្យក រសាត់អណ្តែតធ្វើការរកស៊ីដូចគ្នានឹងមនុស្សបុរាណផៅពង្សផ្សេងៗ ជាហេតុធ្វើឱ្យមានការផ្លាស់ប្តូរតាំងពីប្រពៃណីនិងភាសា បែកចេញពីគ្នា ដើមដំបូងអារ្យកចែកជាក្រុមធំៗគឺ ៖* (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៥៧)

*ក្រុមដំបូង បែកទៅទិសខាងលិច ចូលទៅកាន់ទ្វីបអឺរ៉ុប ក្លាយជាជាតិផ្សេងៗក្នុងអឺរ៉ុបៗ*

*ក្រុមទី២ បែកចុះមកទិសអាគ្នេយ៍ប្រមាណជាជនជាតិអ៊ីរ៉ង់ ក្នុងប្រទេសពេក្ស បច្ចុប្បន្នៗ*

*ក្រុមទី៣ ជាក្រុមសំខាន់បំផុត ក្រុមនេះចុះមកទិសខាងត្បូងចូលមកអាស្រ័យនៅតាមទន្លេសិន្ធូ* (Sindhu) *អាស្រ័យដោយអារ្យក មួយចំណែកមកនៅអាស្រ័យតាមដងទន្លេនេះទើបមានឈ្មោះថាហិណ្ឌូ ហិន្ទូតាមសំឡេងភាសាអ៊ីរ៉ង់ៗ*

ជនជាតិអារ្យកគ្រប់ក្រុមជាផៅពង្សអ្នកមានបញ្ញា សមត្ថភាពចូលទៅកាន់ទីណា បានបណ្ដេញម្ចាស់ទីលំនៅមុគមាំ ធ្វើឱ្យមានការរីកចម្រើនគ្រប់ទីកន្លែង នាំវប្បធម៌របស់ម្ចាស់ដើម មកផ្សំជាមួយនឹងវប្បធម៌របស់ខ្លួនក៏មានដែរ។

ជនជាតិអារ្យកក្រុមក្រោយ ដែលចូលទៅរុករកអាស្រ័យនៅម៉ូហិង្ហ ទៅជួបជាមួយអ្នកស្រុកផៅពង្សមួយទៀត ហៅថាដ្រាវិទ (Dravidian) ឬមិនមានលក្ខណៈដែលសំដៅដល់មនុស្សព្រៃ ឬក៏ហៅថាទស្សុទាស បានដល់ទាសរបស់ពួកអារ្យកនោះឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ៥៨)

ពួកទស្សុឬទាសមានវប្បធម៌ មានជំនឿប្រកាន់សាសនាប្រចាំផៅពង្សរបស់ខ្លួនពីមុន ដូចជាគោរពបូជាធម្មជាតិ គោរពបូជាទេវៈជាម្ចាស់ប្រចាំត្រកូល និងស្រុកភូមិរបស់ខ្លួន នេះជាការចាប់ផ្ដើមសាសនារបស់ពួកអារ្យក ដែលហៅថាសាសនាព្រាហ្មណ៍។ លុះក្រោយមក ពួកអារ្យកនាំយកគោលសាសនារបស់ពួកទស្សុ គឺ ពួកអ្នកម្ចាស់ទីលំនៅដើមមកផ្សំបញ្ចូលគ្នាច្រើន។

អារ្យកក្រុមក្រោយ កាលបើបានរួបរួមគ្នាហើយ អ្នកមានបញ្ញានាំគ្នាស្រាវជ្រាវរិះរកសាសនាប្រចាំខ្លួនឡើង ដើម្បីជាគ្រឿងអាវុធសម្រាប់រួបរួមគ្នាឱ្យរឹងមាំ តាមគោលការណ៍នៃការរួបរួមគ្នាជាសង្គម មិនថាជាជាតិណាក្រុមណាទេ ប្រសិនបើគ្មានសាសនាប្រចាំក្រុមប្រចាំជាតិទេ ពួកក្រុមនោះមិនអាចរួបរួមបានឡើយ ព្រោះជាតិត្រូវអាស្រ័យសាសនាជាគ្រឿងចងភ្ជាប់ជាមួយគ្នា។

ដូចដែលបានអធិប្បាយមកហើយ សាសនាកើតឡើងពីមូលហេតុផ្សេងៗគ្នា សាសនាពីដើមជាជនជាតិអារ្យកក៏មកពីមូលហេតុមួយដែរ គឺមូលហេតុនៃការមិនដឹងភូមិសាស្ត្រ។ ជនជាតិអារ្យកពីដើមមិនដឹងពីមូលហេតុរបស់ធម្មជាតិ ទើបលើកតម្កើងធម្មជាតិប្រភេទផ្សេងៗជាទេពអម្ចាស់ (ទេវៈ) ទេពជាម្ចាស់ទាំងនេះ មានជាអាទិ៍ ដួងចន្ទ្រ ដួងអាទិត្យ ដួងអគ្គី ផ្ទៃមេឃ ព្យុះ ប្រថពី ។ល។ បានទទួលសន្មតនាមជាទេវៈ លើមនុស្សសាមញ្ញទូទៅ។

ពេលវេលាកន្លងមក ជនជាតិអារ្យកមានបញ្ញា បានបែងចែកទេវៈជាពួក ជាក្រុមខ្ពស់ទាប ដើម្បីងាយស្រួលក្នុងការគោរពបូជា និងធ្វើពលីកម្មបាត់ពិធីកម្ម ថ្វាយពពួកទេវៈនោះមាន៣ក្រុមគឺ ៖

ទេវៈលើឋានសួគ៌ មានដួងអាទិត្យ ដួងចន្ទ្រ ជាដើម។ ទេវៈលើអាកាសមានព្យុះ កិរុន ភ្លៀង ជាដើម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ៥៩) ទេវៈលើផ្ទៃដីមាន ភ្លើង អគ្គី ធរណី ផែនដី ជាដើម។

ទេវៈទាំងអស់នេះបានទទួលការបូជា ព្រោះជឿថាបានផលជាសេចក្ដីសុខសួស្ដីដល់អ្នកបូជា ការបូជានោះ មានអ្នកទទួលធ្វើកិច្ចការក្នុងពិធីគឺ ព្រាហ្មណ៍ក្នុងឋានៈក្រោមៗ ជនជាតិអារ្យកក្នុងសម័យបុរាណគោរព រាប់អានបុព្វបុរសអ្នកដែលធ្វើមរណៈកាល ទៅ ហើយសំខាន់ស្មើគ្នាដូចជាទេវៈ ទើបមានពិធីបូជាបុព្វបុរសផងដែរ។ ការគោរពរាប់អានក្នុង ខណៈនេះ ជាបឋមហេតុនៃការគោរពរាប់អានគឺថា មនុស្សដែលស្លាប់ទៅហើយ មានវត្ថុមួយគឺវិញ្ញាណមិនបានស្លាប់ទៅជាមួយផងទេ មានសភាពគង់វង្វេងវិញ្ញាណមានសេចក្ដីត្រូវការដូចជាមនុស្សធម្មតាដែរ កូនចៅ ទើបពិធីសែនបួងសួងជូនបាយ ត្រី អាហារ ដល់វិញ្ញាណនោះផង មុខងារសែនព្រេន ដួងវិញ្ញាណដូចពោលមកនេះត្រូវជាបន្ទុកទៅលើមេគ្រួសារ។

**សម័យព្រះវេទ**

លុះចំណេរតមក ប្រមាណ ១៥០០.១០០០ឆ្នាំមុនគ.ស. ជនជាតិអារ្យក បានរួបរួមបទសូត្រអង្វរករទេវៈ សម្រាប់ប្រើក្នុងវង្សត្រកូលទុកជាក្រុម ជាគម្ពីរ។ គម្ពីរទាំងនោះហៅថាវេទគឺវិជ្ជាបានដល់ការចេះដឹង ប្រកាន់យកជា សរុតិ បានដល់វិជ្ជាដែលទទួលស្គាល់មកពីទេវៈអ្នកមានយសស័ក្តិខ្ពង់ខ្ពស់ (ព្រហ្ម) ន័យមួយ ទៀតជាសំឡេងទិព្វ ឬសំឡេងសួគ៌ ដែលទេវៈអ្នកមានយសស័ក្តិ ប្រទានមកឱ្យឥសី ឬព្រហ្មណ៍អ្នកធំ ប្រៀនប្រដៅតៗគ្នាមក។ (ហេង គីមហោ **សាសនាប្រៀបធៀប** ភាគ១ ទំព័រ ៦០)

គម្ពីរព្រះវេទមាន (ក្នុងដើមដំបូង ៣ ក្បាល) ឫគវេទ ជាបទសរសើរគុណ ឬ ឫទ្ធិរបស់ទេវៈ ឬ ធម្មជាតិនិយាយអំពីប្រវត្តិការសាងលោកទាំងពួង និងមុខងារព្រះព្រហ្មណ៍ជាអ្នកសាងមនុស្សនិងសព្វសារពើ។

យជុរវេទ សម្ដែងពិធីបួងសួងផ្សេងៗ និងបទសូត្រក្នុងពិធីកម្មដែលហៅថា យជុញកម្ម ឬ យញ្ញកម្ម។

(តមកបំបែកជាយជុវេទ-ស និងយជុវេទខ្មៅ គម្ពីរដំបូងជាបទកាព្យឃ្លោង និងពាក្យជូនរណ្ដំ គម្ពីរ ក្រោយជាពាក្យសាមញ្ញធម្មតា ពុំមែនជាបទនិពន្ធកាព្យឃ្លោង និងប្រកាន់ទៅតាមនិកាយ ដែលបែកចេញពីគ្នា)។

សាមវេទ សម្តែងនាដសាស្ត្រ ឬសិល្បសាស្ត្ររួម ទាំងបង្កើតការច្រៀង រាំលេង ភ្លេងតូរ្យតន្ត្រី ជាបទ សូត្រសរសើរគុណ និងឫទ្ធិរបស់ទេវៈ ដែលកើតឡើងថ្មី និងនាំគ្នារាប់អានជាថ្មីក្នុងសម័យតមក។

ទាំង ៣ នេះហៅថា ត្រៃភេទ ឬ ត្រៃវេទ។

តមកទៀត (មកដល់ចុងសម័យព្រាហ្មណៈ និងពេលនៅវគ្គខាងក្រោយ) មានវេទបន្ថែមឡើងមួយ គម្ពីរទៀត ហៅថាអត្ថពវេទ ជាបទសូត្រគាថា ទាក់ទងនឹងសៃយសាស្ត្រ។

សម័យដែលពោលមកនេះ ប្រវត្តិសាស្ត្រ ហៅថា សម័យត្រៃវេទ មានរឿងប្រវត្តិសាស្ត្ររបស់ជនជាតិអារ្យកក្នុងសម័យនោះ ម្យ៉ាងទៀតគឺរឿងវណ្ណៈ ៤ពួករបស់មនុស្សដែលមានប្រាកដនៅក្នុងគម្ពីរឫគវេទ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦១)

អ្នកប្រាជ្ញព្រាហ្មណ៍កំណត់ថា គម្ពីរដែលបានតែងបន្ថែមឡើងក្នុងពេលក្រោយ ជាចំណែករួមផ្សំ ប្រកបរបស់គម្ពីរព្រះវេទ ដែលជា សុតិ ហៅថា សប្ញតិ ដូចគម្ពីរព្រហ្មណៈ ឧបនិស័ទអរណ្យក និងវេទាន្ត ជាដើម ជាគម្ពីរចងចាំថា និយាយប្រាប់តៗគ្នាមកទុកជាអត្ថកថារបស់គម្ពីរព្រះវេទផងដែរ។

**សម័យព្រាហ្មណៈ (ព្រាហ្មណ៍)**

សម័យនេះផៅពង្សអារ្យក បានពង្រាយគ្នាចុះមកភាគខាងជើងនៃជម្ពូទ្វីប រហូតទាល់តែឥណ្ឌាខាងជើងធ្លាក់ខ្លួននៅក្រោមអំណាចរបស់ផៅពង្សអារ្យកស្ទើរតែទាំងអស់។ លទ្ធិផ្សេងៗដែលគោរពរាប់អានក៏ ចេញមកពីគម្ពីរ ព្រះវេទ ដូចបានពោលមកហើយ បណ្តាក្រុមអារ្យកដែលដឹងថាខ្លួនជាមេដឹកនាំបានទទួលការ លើកតម្កើងពីមនុស្សទាំងឡាយថា ជាមេមានមុខនាទីធ្វើពិធីកម្មផ្សេងៗ ក៏ចាប់ផ្តើមសម្លឹងមើលមនុស្សដទៃ តូចទាបជាងខ្លួន ប្រកាសសេចក្តីស័ក្តិសិទ្ធិរបស់គម្ពីរដែលខ្លួនជឿប្រកាន់ដោយសំអាងថា សុតិ គឺពាក្យប្រៀន ប្រដៅដែលព្រះមានអំណាចខ្ពស់ប្រទានមកត្រង់ចំពោះខ្លួន ជាអាទិ៍ពាក្យប្រៀនប្រដៅក្នុងគម្ពីរនោះពុំមានដើមដំបូង បើពុំមានដើមដំបូងក៏ពុំមានចុងបញ្ចប់ដែរ។ កាលបើពុំមានទាំងពីរដូច្នេះ ទើបគ្មានការរលាយរលត់ គឺនៅគង់វង្សជានិរន្តរ៍ (ព្រះវេទនោះជួនកាលហៅថា ព្រហ្ម គឺព្រហ្ម និងព្រះវេទស្មើគ្នា)។

ក្នុងគម្ពីរឫគវេទ ពួកព្រាហ្មណ៍សម្តែងពីបញ្ហាចលនាលក្ខណៈឬភាវៈនៃលោកនិងជីវិតជាវដ្តសង្សារគឺ ការវិលវល់តាមផ្លូវនៃទស្សនវិជ្ជាកំណត់ធម្មជាតិជាមូលដ្ឋានដើម មាននៅគូ

គ្មានីងលោកហៅថាព្រហ្មមហា ព្រហ្ម បរព្រហ្ម អាទិព្រហ្ម កាល ហង្ស ឬបរមាត្ម័ន ប៉ុន្តែនាម ដែលផ្សព្វផ្សាយគឺបរមាត្ម័ន ជាមហាវិញ្ញាណ ¬Supreme soul¦ ជាដួងនៃវិញ្ញាណទាំងពួង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦២)

គួរយល់រឿងមហាព្រហ្មឬមហាត្ម័ន ដែលបានពោលមកនេះដើម្បីតនៅទស្សនវិជ្ជាដទៃ (ប្រាកដតាមគម្ពីរ សតបថព្រាហ្មណៈ) ទុកក្នុងទីនេះ។

បរមាត្ម័ន (បរម+ត្ម័ន) ប្រែតាមសព្ទថាដួងវិញ្ញាណឬអាតមដ៏ធំ (ជាម្ចាស់មួយអង្គនិង ព្រហ្ម ដែលជាអង្គមួយក្នុងត្រីមូរតិ)។ មហាព្រហ្មឬបរមាត្ម័នកើតឡើងឯង រស់ខ្លួនឯង មិនមានភេទជា (កណ្តាល) តែមានអំណាចកំណើតពីអ្វីចេញមក ពីអ្វីនោះក៏គ្មានអ្នកណាដឹង ដែរ ជាដើមហេតុនៃរបស់ទាំងឡាយគ្រប់បែបគ្រប់យ៉ាង សុទ្ធតែចេញពីបរមាត្ម័នទាំងអស់។ មហាព្រហ្មឬបរមាត្ម័ននោះជាមាគ៌ានៃសន្តិសុខរស់នៅដោយខ្លួនឯងជាអមតៈ មិនអាចមើល ឃើញដោយខ្សែចក្ខុបានទេ ជាអនាទិមិនមានខាងដើម និងមិនមែនទីបំផុត ជាបឋមវិញ្ញាណ នៃវិញ្ញាណទាំងពួង ឬជាបឋម អាត្ម័នទាំងពួង។

ដួងវិញ្ញាណទាំងឡាយ ចេញមកអំពីដួងវិញ្ញាណជាបឋមប្រៀបប្រដូចជាផ្កាភ្លើងខ្ទាត ចេញមកពីភ្លើងមួយ ដួងធំដែលជាដួងដើមដំបូង ឬប្រដូចជាដំណក់ទឹកតក់ៗដែលមកពីទឹក សមុទ្រ យ៉ាងណាមិញដួងវិញ្ញាណរបស់សត្វតូចធំទាំងឡាយរមែងមកពីវិញ្ញាណជាបឋម នេះ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៣)

ដូច្នេះបើវិញ្ញាណចេញពីបឋមវិញ្ញាណហើយចូលទៅក្នុងរូបរាងបែបផ្សេងៗជាច្រើនគ្រា ច្រើនជាតិផ្សេងៗ សម្រេចតែផលនៃអំពើដែលបានធ្វើ នាំឱ្យវិលវល់ប្រែប្រួលគ្មានឈប់ លុះ ត្រាតែបានសម្រេចដល់កំពូល ¬Summum bonum¦ ព្រោះការបំពេញព្យាយាមពេលនោះហៅ ថាមោក្សៈ គឺការរួចផុតឬដែលហៅថា និរវាន វិញ្ញាណនោះៗ ចូលទៅនៅនឹងបរមាត្ម័ន ជាដើម។

អ្នកប្រាជ្ញខាងព្រាហ្មណ៍ម្នាក់ឈ្មោះ សង្ការ ¬Shankar¦ ប្រមាណ (គ.ស.៧៧៥-៨០៧) អធិប្បាយពី ការសម្រេចសេចក្តីជាន់ខ្ពស់ (មោក្សៈ) ទុកថា ៖

សេចក្តីល្អខ្ពស់បំផុត (មោក្សៈ) ដែលមនុស្សយើងប្រាថ្នា មិនមែនសេចក្តីសុខកើតពី បានរបស់ដែលត្រូវការមកគ្រប់គ្រងនោះទេ គឺជាសេចក្តីស្ងប់ដែលកើតឡើងក្នុងដួងចិត្ត ជា សេចក្តីសុខ ជាស្ថាពរមិនសាបរលាបប្រែទៅជាបការៈដទៃទៀត។

លោកដែលយើងអាស្រ័យនៅមានការផ្លាស់ប្តូរគ្រប់ខណៈ ការប្រែប្រួលនេះជា មាយា បោកបញ្ឆោត ពុំមានការពិតស្ថិតស្ថេរទេ ការពិតដែលមើលមិនឃើញ គឺការពិតមិនផ្លាស់ប្តូរ ពុំមែនមាយា។

តាមប្រក្រតីមនុស្សវង្វេងគិតខុសថា របស់ដែលខ្លួនមើលមិនឃើញជាសេចក្តីពិត ទាំង នេះក៏ព្រោះមកពីធ្លាក់ទៅក្នុងអំណាចអវិជ្ជា (ប្រៀបធៀបនិងគោលការណ៍ក្នុងពុទ្ធសាសនា)។ ប្រៀបប្រដូចជាកញ្ចក់ (វ៉ែនតា) មានពណ៌ ពាក់ហើយធ្វើឱ្យមើលឃើញវត្ថុពណ៌សទៅជា ពណ៌ផ្សេងៗខុសពីសេចក្តីពិត។ ការមើលឃើញរបស់ពិតមិនត្រូវពាក់វ៉ែនតាទេ ខនេះយ៉ាង ណាមិញ ការកម្ចាត់វិជ្ជាឱ្យអស់ទៅ ដើម្បីមិនឱ្យមើលឃើញ មាយាមនុស្ស ត្រូវដឹងថា មាន របស់មួយដែលពិតប្រាកដ គឺ (មហា) ព្រហ្ម (បរមាត្ម័ន) ព្រោះជាមហាព្រហ្ម គឺសេចក្តី ពិត ដែលមើលមិនឃើញ និងមិនអាចប្រៀបជាមួយរបស់ផ្សេងៗបាន មនុស្សមិនអាចមាន សមត្ថភាព (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៤) បរិយាយលក្ខណៈរបស់មហាព្រហ្ម បានឡើយ ព្រោះថាមហាព្រហ្ម គឺសេចក្តីពិតដែលមើលមិនឃើញ ហើយនិងព្រោះមហា ព្រហ្មជារបស់ដែលស្ថិតនៅលើអំណាចមនុស្សក្នុងលោក។

ទស្សនៈវិទូរឿងមហាព្រហ្ម (បរមាត្ម័ន) របស់លោកសង្ករាបាននិយាយថា មហាព្រហ្ម មាននៅក្នុងរបស់គ្រប់យ៉ាង ជាអមតៈប្រហែលគ្នានឹងអមតៈរបស់អាត្ម័ន (របស់ដែលមើល ឃើញជាមាយាដែលមើលមិនឃើញជាអតមៈ) មនុស្សគប្បីឃើញព្រហ្ម ព្រោះព្រហ្មជា សច្ចៈ ជាអមតៈ ជានិរន្តរ៍ ឃើញព្រហ្មស្មើនឹងខ្លួនឯង ឃើញខ្លួនឯងស្មើនឹងឃើញព្រហ្ម ខនេះ ជាលក្ខណៈ ការបង្រៀនមិនអាចឈ្លក់វង្វេងក្នុងរបស់ដែលយើងមើលឃើញ គឺខ្លួនយើងនេះ ឯង។

សេចក្តីដូចដែលបានពោលមកនេះ គឺការចូលដល់មោក្សៈ មោក្សៈនោះជាភាពរបស់ ចិត្តដែលទំនេរ ប្រាសចាកពីអារម្មណ៍ ការរលត់នូវចិត្តមិនជំពាក់ដោយអារម្មណ៍ទៅក្នុងរយៈ ឬមួយខណៈដូចជាដួងចិត្តក្នុងពេលដេកលក់មាននាមថា ទៅដល់មោក្សៈបានមួយខណៈ ដោយអាចនិយាយបានថា ខណៈនោះជាខណៈដែលអាត្ម័នរបស់មនុស្សចូលទៅរួមជាមួយ បរមាត្ម័ន(លក្ខណៈតែមួយនឹងនិព្វានមួយខណៈក្នុងពុទ្ធសាសនា។ រីឯ មោក្សៈជាស្ថាពរដែល មនុស្សដល់នោះគឺការមិនវិលវល់ក្នុងវដ្តសង្សារតទៅទៀត ព្រោះមិនមានអំពើ (អារម្មណ៍)

ដែលមកទាក់ទាញក្នុងខ្លួនឯង កាលបើមិនទាក់ទាញហើយក៏មិនអាចមានសមត្ថភាពសាង កម្មតទៅទៀតបានដែរ។ (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៥)

ដរាបណាមិនទាន់ដល់មោក្ស: ដរាបនោះត្រូវវិលវល់ទៅតាមអំណាចរបស់អ្នកសាង គឺព្រហ្ម (មួយក្នុងត្រីមូរត៌ មានភេទជាប្រុស) និងមានការសាងវណ្ណៈ៤ពួករបស់មនុស្សដូច អធិប្បាយពីខាងដើម។ ដោយន័យនេះព្រាហ្មណ៍ទើបមានអធិប្បាយសរុបខាងក្រោយ ដើម្បី ឱ្យកើតសេចក្តីសំខាន់ដល់ខ្លួនថា លោកត្រូវតែប្រកបដោយលក្ខណៈសំខាន់៣ប្រការគឺ ៖

១-ត្រូវមានព្រាហ្មណ៍ (អ្នកបួស)

២-ត្រូវមានគម្ពីរព្រះវេទ

៣-ត្រូវមានវណ្ណៈ៤ពួក

បើសង្គមមនុស្សបាត់លក្ខណៈទាំង ៣ នេះ ពុំអាចរកសន្តិភាពបានឡើយ ព្រហ្មមួយក្នុង ត្រីមូរត៌ ដែលថាជាអ្នកសាងជួនកាលហៅថាវិស្វកម្ម វិស្ណុកម្ម ហិរញ្ញក និងប្រជាបតីក៏មាន។

មហាព្រហ្មឬបរិមាត្មន៍សាងទេវៈអង្គធំទុកមួយពួក ឱ្យមាននាទីទាក់ទងសង្សារវដ្ត ក្នុង សភាវៈនៃលោក៣ ប្រការ ទេវៈទាំង ៣ នោះគឺ ៖

-ព្រហ្មអ្នកសាង (Creator) មួយព្រះអង្គ

-វិស្ណុឬនារាយណ៍អ្នករក្សា (Presever) មួយព្រះអង្គ

-សិវៈឬឥស្វរ អ្នកបំផ្លាញលោក (Destroyer) មួយព្រះអង្គ (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៦)

ទេវៈទាំង៣នេះហៅថា ត្រីមូរត៌ ប្រែថា "រូបី" តាមលក្ខណៈស្តែងឱ្យឃើញជាធម្មាធិដ្ឋាន ថា លោកមានការកើតតាំងឡើង (ឧបាទិ) មានការរក្សាគឺការតាំងនៅ (ឋិត) ជាកណ្តាលនិងមាន ការរលត់រលាយទៅ (ភង្គៈ) ក្នុងទីបំផុត។ ការបូជាទេវៈទាំង៣នេះមានរូបជាបុគ្គលាធិដ្ឋានកាន់ ថា ជាការបូជាឱ្យដឹងដល់សភាវធម៌ទាំង៣ប្រការ ដែលជាគ្រឿងប្រកបនៅជាគូនឹងលោក យើងនេះ។

ដោយអធិប្បាយព្រហ្មមានភេទជាបុរស មានព្រះជាយាឈ្មោះសរស្វតី ជាអ្នកសាង មនុស្សនិងសត្វសព្វទាំងឡាយ។ រួមសេចក្តីមក ព្រះអង្គជាអ្នកសាងចក្រវាលឬសាងលោក។ លោកដែលព្រះអង្គទ្រង់សាងនោះ តាំងនៅបានជាយុគ និងវិនាសទៅវិញជាយុគរយៈកាល រវាងលោកតាំងនៅនិងវិនាស (លាងលោក) ហៅថា កប្ប៍។ មួយកប្ប៍បែងចែកជា ៤ យុគ

គឺក្រិតយុគ តេរដាយុគ ទវាបរយុគ និងកលីយុគ រួម៤យុគ ជាមហាយុគ ផុតមហាយុគជាមួយកល្ប៍ មួយកល្ប៍ជាពេលរួម ៤.៣២០.០០០ ឆ្នាំ ការប្រព្រឹត្តក្នុងយុគនីមួយៗ មានពិពណ៌នាដោយសង្ខេបដូច្នោះ៖

ក្រិតយុគ ហៅម្យ៉ាងទៀតថាសត្យយុគ ជាយុគនៃសច្ចធម៌ខ្ជាប់ខ្ជួន មានព្រះព្រហ្មតែមួយអង្គជាធំ គ្មានទេពទិវាជទៃទៀត គ្មានយក្ស គ្មានមារ អ្នកណាប្រាថ្នាអ្វីបានសម្រេច គ្មានការលក់ដូរ ផ្លាស់ប្តូរ គ្មានលោភ ក្រោធ ទុច្ចរិត កោងកាច និងគ្មានទោមនស្សអ្វីៗឡើយ។

តេរដាយុគ យុគនេះសច្ចធម៌ខូចបង់អស់ ១ក្នុង៤ គ្មានពិធីកម្ម មនុស្សប្រតិបត្តិធម៌ដើម្បីផលប្រយោជន៍ សង្ឃឹមអានិសង្សអំពីការប្រតិបត្តិធម៌នេះ។

ទវាបរយុគ យុគនេះសច្ចធម៌ខូចបង់អស់ ២ក្នុង៤ នរជនកើតឈឺចាប់ កើតតណ្ហា នរជននិយមធ្វើអំពើអាក្រក់ មានពិធីកម្មដើម្បីលាងអំពើអាក្រក់ ព្រះវេទទាំង៤កើតឡើង តែនរជនមិនយកចិត្តទុកដាក់។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៧)

កលីយុគ យុគនេះ (បច្ចុប្បន្ន) សច្ចធម៌សល់ត្រឹមតែ ១ក្នុង៤ សីលនិងធម៌ទាំងពួងត្រូវបាត់បង់នរជនពេញដោយរាគៈ ទោសៈ មោហៈ កេងប្រវ័ញ្ចគ្នាជាទូទៅ។ ល។

ការរាប់អានដូចពោលខាងលើមកនេះ កើតឡើងក្នុងសម័យអវតារ (នៃនារាយណ៍សម័យក្រោយ, សម័យហិណ្ឌូ) យុគនីមួយៗ ព្រះនារាយណ៍មានអ្នករាប់អានថា ជាមហាទេពខ្ពង់ខ្ពស់ ពេលក្រោយមកមាន ឋានៈជាអ្នកសាង បែងភាគចុះមកកើត (អវតារ) មានរូប ផ្សេងៗក្នុងយុគនីមួយៗ។

ពេលលោកវិនាស កើតអំពីអំណាចភ្លើង របស់គ្រប់យ៉ាងរលាយសូន្យអស់ទៅក្នុងភ្លើង សល់នៅតែអ្នកចេះដឹង (ឋានៈជាអ្នកទ្រង់ព្រះវេទ) ទេវៈ (ធម្មជាតិប្រចាំលោក) និងធាតុទាំង ៤ (ដី ទឹក ភ្លើង ខ្យល់) ដែលមានប្រចាំលោក (បន្ថែមអាកាសមួយទៀត ៥) សូម្បីព្រះព្រហ្មអ្នកសាងក៏អស់រលីងទៅជាមួយគ្រប់យ៉ាងទាំងអស់ រួមចូលទៅក្នុងធាតុទាំង៤ និយាយដោយខ្លីទៅ ធាតុទាំង៤មកប្រជុំគ្នា រយៈនោះវិញ្ញាណក្នុងលោកទាំងឡាយចូលទៅរួមក្នុងមហាព្រហ្មឬបរមាត្ម័ន។ លុះដល់វេលាដែលត្រូវឱ្យមកសាងលោកតាមយុគ តាមសម័យដែលបានកំណត់ដួងវិញ្ញាណទាំងឡាយក៏ចេញពីបរមាត្ម័នម្តងទៀត វិលវល់ចុះឡើង ជាវដ្តយ៉ាងនេះ មើលទស្សនវិជ្ជាធម៌ខាងមុខ។

បណ្ដាពាក្យប្រៀនប្រដៅទាំងឡាយក្នុងគម្ពីរព្រះវេទមួយហ្នឹង ដែលសំខាន់បំផុតរបស់លទ្ធិគឺពាក្យប្រៀនប្រដៅរឿងនាទីរបស់ព្រះអ្នកសាង ដែលមានព្រះនាមថាព្រហ្មា ឬ ព្រះព្រហ្មអង្គនេះមានភេទជាប្រុស ទ្រង់សាងមនុស្សទុកដើម្បីសន្តិដូច្នេះ ៖ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ៦៨)

-ទ្រង់សាងមនុស្សថ្នាក់ព្រាហ្មណ៍ (អ្នកបួស) ពីព្រះឧស្ន

-ទ្រង់សាងមនុស្សថ្នាក់ក្សត្រ (អ្នកចម្បាំង) ពីព្រះពាហា

-ទ្រង់សាងមនុស្សវេស្ស (អ្នកជំនួញ) ពីព្រះសោណី (ត្រគាក)

-ទ្រង់សាងមនុស្សសូត្រ (កម្មករ) ពីព្រះបាទ។

**គុណសម្បត្តិរបស់ព្រះព្រាហ្មណ៍**

១. សមៈ មានសេចក្ដីសុភាពក្នុងចិត្ត មានការវិលវល់ដោយសេចក្ដីលោភ ក្រោធវង្វេង។

២. ទមៈ រម្ងាប់ចិត្តបាន រញូកនៅក្នុងមេត្តាជានិច្ច។

៣. តបៈ ផ្ចាញ់ចំពោះសេចក្ដីលំបាក បំពេញដើម្បីរកការចេះដឹងគឺ ការពិត។

៤. សោចៈ (សុចិ) ធ្វើឱ្យខ្លួនឯងបរិសុទ្ធទាំងកាយនិងចិត្តថ្មីម។

៥. សន្តោស ពេញចិត្តនឹងសេចក្ដីសុខដែលមាន។

៦. កសមា មានសេចក្ដីអត់ធន់ មានមេត្តា ករុណា ជាទីតាំង។

៧. សរលតា មានសេចក្ដីស្មោះត្រង់ និយាយត្រង់ ធ្វើត្រង់។

៨. ញាណៈ ស្វែងរកសេចក្ដីចេះដឹង ដែលត្រូវ ដែលប្រពៃ។

៩. ទយា មេត្តាដល់ជីវទាំងពួង។

១០. អាសតិកតា ស្រឡាញ់ស្មោះកក្ដីចំពោះព្រះព្រហ្ម។

១១. សត្យ មានការយល់ឃើញដ៏សុចរិត មិនគិតទុរយសចំពោះអ្នកណា ប្រកបដោយនាទី ៦ទៀត ៖ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៦៩)

១.បឋនំ បានទទួលការសិក្សាជាន់ខ្ពស់។

២. បាឋនំ បានដល់ឱ្យការសិក្សាអ្នកដទៃ។

៣. យជនំ បានដល់ការធ្វើពិធីបូជាផ្សេងៗរបស់ខ្លួនឯង។

៤. យាជនំ បានដល់ការធ្វើពិធីបូជាផ្សេងៗរបស់អ្នកដទៃ។

៥. ទាន បានដល់ការធ្វើបុណ្យឱ្យទាន។

៦. បដិគហ បានដល់ការទទួលបុណ្យទាន ពីអ្នកមានសទ្ធា។

**គុណសម្បត្តិរបស់ក្សត្រ**

១. សូរតា ក្លាហានមិនចេះកោតខ្លាច

២. វិរយៈ មានព្យាយាម ក្នុងការប៉ះទង្គិចនឹងភ័យ។

៣. ធៃរយៈ រឹងប៉ឹងមិនរាថយ។

៤. តេជៈ មានយស មានកិត្តិយស ចេះដឹងប្រើអំណាចក្នុងផ្លូវដែលត្រូវ។

៥. ទានៈ យកចិត្តទុកដាក់ក្នុងការដែលឱ្យ។

៦. ទមៈ (មើលគុណសម្បត្តិរបស់ព្រាហ្មណ៍ខ២និង៦)។

៧. កសមា (មើលគុណសម្បត្តិរបស់ព្រាហ្មណ៍ខ២និង៦)។

៨. ព្រាហ្មណ៍កក្តី កក្តីចំពោះព្រាហ្មណ៍។

៩. បរសន្នតា រីករាយមិនចេះវិតក្ក។

១០. រក្សភាវៈ ព្រមទទួលរក្សាប្រទេសជាតិ ដើម្បីផ្តល់យុត្តិធម៌។

១១. សត្យៈ (មើលគុណលក្ខណៈព្រាហ្មណ៍ខ១១)។

ប្រកបដោយនាទី៣ គឺបឋនំ យជនំ ទានំ (តាមនាទីរបស់ព្រាហ្មណ៍)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ៧០)

តាមគម្ពីរព្រះធម្មសាស្ត្របានកំណត់ថា ក្នុងកាលវិបត្តិ អនុញ្ញាតឱ្យក្សត្រីយ៍ប្រកបអាជីវៈដទៃទៀតបានដូចជា អាជីវៈគ្រូបាអាចារ្យ ធ្វើពិធីបូជាយញ្ញ ការកុសលធ្វើកសិកម្មនិងលក់ដូរបានធ្វើមិនបាន (ដូចព្រាហ្ម ណ៍) តែម្យ៉ាង គឺការទទួលបុណ្យពីអ្នកមានសទ្ធា។

**គុណសម្បត្តិរបស់វេស្សៈ**

១. ឆ្លាតឈ្លមក្នុងការប្តូរមុខទំនិញ។

២. មានចំណេះដឹងក្នុងការរាប់ចំនួន។

៣. មានការស្រឡាញ់កក្តីចំពោះព្រះព្រហ្ម។

៤. រាប់អានព្រាហ្មណ៍ និងក្សត្រិយ៍ ដើម្បីស្វែងរកការចេះដឹង។

តាមប្រក្រតីវេស្សៈប្រកបមុខរបរអាជីវជាកសិករ និងលក់ដូរក្នុងកាលវិបត្តិ អនុញ្ញាតឱ្យប្រកបមុខរបរដទៃទៀតបានតាមកាលៈទេសៈគឺត្រូវមានអាជីវៈសុចរិត។

គុណសម្បត្តិរបស់សូទ្រ:

១. នទ្រតា មានសេចក្ដីស្ងប់ស្ងាត់

២. និសកបដ្ឋតា មិនមានការត្រឡប់ត្រឡិនធបោក

៣. សោច: (មើលគុណសម្បត្តិរបស់ព្រាហ្មណ៍៤និង១០)

៤. អាសតិកតា (មើលគុណសម្បត្តិរបស់ព្រាហ្មណ៍៤និង១០)

៥. អសតេយ្យ មិនលួចលាក់

៦. សត្យ (មើលគុណសម្បត្តិរបស់ព្រាហ្មណ៍ ១១)

៧. អាទរភាវ គោរពវណ្ណៈដែលខ្ពស់ជាងខ្លួន។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧១)

ព្រោះហេតុនៃការបែកបាក់ អំពីភាពខ្ពស់ទាបនៃអវៈយវៈរបស់ព្រះព្រហ្មជាធំ ដែលជាហេតុបែងចែកមនុស្សជា៤ពួក ហៅថាវណ្ណៈមនុស្សទាំងអស់ ទើបមានវណ្ណៈមិនស្មើគ្នា មិនអាចរួមគ្នា ដេក អង្គុយ ស៊ីចុក ជាមួយគ្នា សេពគប់គ្នាក៏មិនបាន អ្នកនាំគ្នាធ្វើពិធីបូជាព្រះព្រហ្មត្រូវជានាទីរបស់អ្នកមាន នាមថា "ព្រាហ្មណ៍" ជាវណ្ណៈជាន់ខ្ពស់ជាងវណ្ណៈដទៃ ព្រោះព្រះព្រហ្ម ទ្រង់សាងឡើងដោយអវៈយវៈខ្ពស់ មានមុខនាទីទាក់ទងជាមួយព្រហ្ម បានតែពួកនេះប៉ុណ្ណោះ។

លុះពេលក្រោយមក ព្រាហ្មណាចារ្យអ្នកតែងគម្ពីរអធិប្បាយពីព្រះវេទជាថ្មីមួយក្បាល ទំនងជាអត្ថកថា ហៅថាគម្ពីរព្រាហ្មណៈជាបទរៀនរបស់អ្នកបំពេញខ្លួនជាព្រាហ្មណ៍ និងតែងដីការបស់គម្ពីរព្រាហ្មណៈ ចេញទៅមួយក្បាលទៀតឈ្មោះ អារ្យណ្យកៈ ជាបទរៀនសូត្ររបស់អ្នកនៅព្រៃ។ គម្ពីរទាំងនេះជាបទបង្រៀនពីដំណើរជីវិតរបស់ព្រាហ្មណ៍ ពីកើតរហូតដល់ចេញទៅព្រៃបំពេញព្យាយាម ដើម្បីសម្រេចនូវមោក្សៈ ការប្រតិបត្តិតាម បទរៀនសូត្រនោះៗ ហៅថាការចូលទៅកាន់អាស្រម។

អាស្រមនៃការបំពេញព្យាយាម ប្រព្រឹត្តខ្លួនឱ្យទៅជាព្រាហ្មណ៍ ប្រតិបត្តិតាមគម្ពីរព្រាហ្មណៈនិង អារ្យណ្យកៈ មាន ៤ អាស្រម (ឬ៤លំដាប់) នៃការបំពេញព្យាយាមគឺ ៖

១. ព្រហ្មចារី ប្រែថា អ្នកប្រព្រឹត្តព្រហ្មចារិយៈ មានន័យថាអ្នកនោះជាកូនសិស្ស។

២. គ្រហស្ថ ប្រែថាអ្នកគ្រប់គ្រងផ្ទះ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧២)

៣. វនបរស្ថ ប្រែថាអ្នកនៅព្រៃ

៤. សន្យាសី ប្រែថាអ្នកស្វែងរកធម៌

អាស្រមទាំង ៤ គឺផ្លូវប្រតិបត្តិដែលជាឫសគល់នៃជីវិតរបស់ព្រាហ្មណ៍ ពួកហិណ្ឌូកាន់ជាធម៌ប្រចាំខ្លួន អ្នកមានបំណងដល់មោក្ខៈជាកន្លែងដែលនៅខាងមុខ និងសម្តែងឱ្យឃើញដោយខ្លី ដើម្បីជាគ្រឿងប្រៀបធៀបនិងការប្រតិបត្តិ របស់សាសនិកជនក្នុងសាសនាដទៃ។

អាស្រមទីមួយ ព្រហ្មចារី លំដាប់ដំបូងជីវិតកំណត់បុគ្គល (ប្រុស) អ្នកកើតក្នុងត្រកូលព្រាហ្មណ៍ ក្សត្រ និងវៃស្សៈមានអាយុគម្រប់៥ ឬ៨ឆ្នាំ ឬ ១៦ឆ្នាំបរិបូណ៌ ចូលពិធីមួយហៅថា ឧបានយនៈ (មានន័យថា នាំជីវិតទៅកាន់ឋានថ្មី) គឺពិធីនាំទារកទៅកាន់ គ្រឹស្ថានសិក្សាគរុ (គ្រូ) ពិធីនោះក្មេងត្រូវពាក់ដុំអំបោះស័ក្តិសិទ្ធិ ហៅថា សាយធុរ៉ ឬយជញោបវិតដែលគរុជាអ្នកបំពាក់ឱ្យ។ ការបំពាក់អំបោះស័ក្តិសិទ្ធិហើយស្មើគ្នាទៅនឹង ការត្រាស់ខ្លួនជាព្រហ្មចារីយ៍ តាំងចិត្តប្រព្រឹត្តព្រហ្មចារ្យសិក្សាសូត្ររៀននៅក្នុងសំណាក់គរុ ត្រូវប្រតិបត្តិតាមច្បាប់បង្គាប់បញ្ជារបស់ព្រហ្មចារីយ៍ ជាព្រាហ្មណ៍ដោយបរិបូណ៌។

កាលណាជាព្រាហ្មណ៍ហើយ បានសិទ្ធិជាព្រាហ្មណ៍តាមដែលព្រះព្រហ្មជាអ្នកប្រទានឱ្យ៥យ៉ាងគឺ ៖

១. សិក្សាគម្ពីរព្រះវេទ បានពេញភូមិភាគ (មនុស្សធម្មតាមិនមែនព្រាហ្មណ៍ប៉ះពាល់គម្ពីរព្រះវេទមិន បាន។ (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៣)

២.បង្រៀនគម្ពីរព្រះវេទដល់មនុស្សទាំងឡាយបាន(ត្រង់នេះប្រៀបស្មើជាអ្នកតំណាងរបស់ព្រះព្រហ្មអ្នកដទៃបង្រៀនមិនបានបាប)។

៣. ប្រតិបត្តិកិច្ចពិធីហៅថា យគ្គនម (ការបរិច្ចាគ) បាន។

៤. ទទួលបានទានពីអ្នកមានសទ្ធាទាំងឡាយបាន (បើពុំមែនព្រាហ្មណ៍ទទួល យកទានពីអ្នកដទៃពុំបានជាអពមង្គល។

មានច្បាប់ទទួលបាបធ្ងន់ (អនន្តរិយកម្ម) ទុកដល់ព្រាហ្មណ៍៥យ៉ាងគឺ ៖

១. ព្រហ្មហត្យ ប្រហារព្រាហ្មណ៍។

២. ស៊ីសុហត្យ ប្រហារក្មេងមិនទាន់សម្រាល (ពន្លូត)។

៣. សុរាបាណ ផឹកគ្រឿងស្រវឹង

៤. សវណៈសនេយ លួចមាស

៥. គុរុ តល្ប កាមន សាហាយនីងកិរិយារបស់គុរុឬរបស់អ្នកទ្រទ្រង់គុណធម៌ ក្រោយមកបន្ថែមមួយទៀត។

៦. បញ្ចបាតក សមាគមជាមួយអ្នកធ្វើបាបដូចខាងមួយបែបណាមួយ។

បាបទាំងអស់នេះ ជាបាបអនន្តរិយកម្ម មិនអាចលាងបាន មិនអាចអភ័យទោសបាន។

អាស្រមទី២ គ្រហស្ថ (លំដាប់ទី២) ព្រហ្មចារិយ៍អ្នកចប់សព្វគ្រប់ ការប្រតិបត្តិខាងដើម ហើយត្រឡប់មកផ្ទះបំពេញខ្លួនជាគ្រហស្ថ គឺអ្នកគ្រប់គ្រងផ្ទះ រៀបការមានប្រពន្ធកូន ធ្វើនាទីជាបុរសអ្នកកើតមក ក្នុងត្រកូលល្អដែលត្រូវធ្វើ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៤)

អ្នកគ្រប់គ្រងផ្ទះ ធ្វើកិច្ចការតាមទំនើងចិត្តដែលខ្លួនចង់ធ្វើ មិនត្រូវនៅក្រោមការគ្រប់គ្រងរបស់គុរុ ណាមួយ ត្រូវប្រតិបត្តិខ្លួនក្នុងឋានៈជាមេគ្រួសារ មានការបូជាទេវតាពេលព្រឹក វេលាល្ងាចប្រតិបត្តិនាទីរបស់ស្វាមី និងតាមច្បាប់ផ្សេងៗរបស់អ្នកគ្រប់គ្រងផ្ទះ។

អ្នកប្រតិបត្តិកិច្ចរបស់ព្រាហ្មណ៍ អ្នកមានគ្រួសាររហូតដល់ថ្នាក់ជាអ្នកគ្រប់គ្រងផ្ទះនេះ ហោថាព្រាហ្មណ៍ មេផ្ទះ ប្រតិបត្តិកិច្ចព្រាហ្មណ៍មេផ្ទះ។ ទៅតាមកំណត់២៥ឆ្នាំ កាលបើត្រូវការបំពេញព្យាយាមឱ្យកាន់តែខ្ពស់ឡើង ដើម្បីសម្រេចទៅដល់ការរួចផុត ត្រូវចេញពីផ្ទះ ចូលទៅក្នុងព្រៃ ចូលទៅកាន់អាស្រម បំពេញខ្លួនជាព្រាហ្មណ៍នៅព្រៃ។

ការបូជាទេវតារបស់គ្រហស្ថ ហៅថា សង្កល្ប (San-kalapa) ប្រកបដោយការគោរពបូជាក្នុងពេលព្រឹកព្រហាម និងពេលព្រលប់ ហៅពិធី សន្ធយា (Sandhaya) មានសេចក្តីពិស្តារច្រើន សូមនិយាយតែពីរឿង សង្កល្ប ប៉ុណ្ណោះ បឋមបទរបស់សន្ធិយាដើម្បីឱ្យយល់ពិធីកិច្ចមួយផ្នែករបស់គ្រហស្ថអ្នកជាព្រាហ្មណ៍។

សង្កល្ប សំដៅដល់អនុស្សតិថ្នាក់ខ្ពស់បំផុត(Intensive Contemplation) មាន ១៩យ៉ាងគឺ៖ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៥)

រំឭកដល់ព្រះវិស្ណុ, រំឭកដល់ព្រះព្រហ្ម, រំឭកដល់អវតាររបស់ព្រះវិស្ណុ ដែលប្លែងភេទជាជ្រូកព្រៃ ប្រហារហិរណ្យ យក្ស និងបំផ្លាញគ្រប់យ៉ាងក្នុងកលិយុគ រំឭកដល់ក្សត្រិយ៍, ភាតរៈអ្នកគ្រប់គ្រងជម្ពូទ្វីប, រំឭកដល់ភ្នំព្រះសុមេរុ, រំឭកដល់មួយផ្នែកនៃលោកហៅថា (Agnidika) ជាទីប្រថាប់របស់ព្រះអគ្គនី និងជាទីតាំងនៃជម្ពូទ្វីប, រំឭកភូមិប្រទេសជនជាតិដ្រាវិទ (Dravidian) អ្នកប្រើភាសាទមិឡ, រំឭកផ្លូវព្រះចន្ទគោច, រំឭកការវិលជុំវិញនៃកាលវេលា,

រំពូកការបន្ត (ayana) នៃជីវិតរបស់ខ្លួន, រំពូករដូវប្រចាំឆ្នាំ, រំពូកព្រះចន្ទក្នុង សុក្របក្សនិង កាលបក្ស, រំពូកដល់ថ្ងៃចុងសប្ដាហ៍, រំពូកដល់ផ្កាយប្រចាំថ្ងៃ, រំពូកដល់ការជំនុំនៃដួងតារា២៧ ដួង និងរំពូកដល់ករុណា (Karana) អំពើដែលខ្លួនឯងបានធ្វើ។

អាស្រមទី៣ វនបរស្ថ (លំដាប់ទី៣) ការនៅព្រៃជាកិច្ចប្រតិបត្តិរបស់ព្រាហ្មណ៍មួយថ្នាក់ទៀត កាន់យកការបំពេញព្យាយាមចូលឈានសមាបត្តិ ក្នុងដងព្រៃសាងបណ្ណសាលាជាទីអាស្រ័យមានជីវិតដោយសារអ្នកដទៃ កាលបើចិត្តគំនិតធ្លាក់នៅក្នុងថ្នាក់បរិសុទ្ធជាលំដាប់ហើយ ចាប់ប្រតិបត្តិកិច្ចតាមបែបរបស់អ្នកបដិវត្តន៍ថ្នាក់ខ្ពង់ខ្ពស់។

អាស្រមទី៤ សន្ន្យាសី (លំដាប់ចុងក្រោយ) អ្នកស្វែងរកធម៌ដើម្បីមោក្សៈបំពេញព្យាយាម (តាមមគ្គៈ៤ឬយោគៈ៤ ដែលនឹងពោលខាងមុខ) ចំណុចសំខាន់ចុងបំផុតឱ្យដួងវិញ្ញាណចូលដល់នូវដួងវិញ្ញាណជាបឋមគឺ ការស្វែងរកមោក្សៈធម៌រាវរកសេចក្ដីពិតថាមនុស្សគឺអ្នកណា? ក្នុងលោកនេះមានសារវត្ថុអ្វីខ្លះ? កាលបើបានចម្លើយហើយ បង្រៀនការចេះដឹងនោះដោយប្រកាន់ថា មនុស្សទាំងពួងជាចំណែករបស់ព្រះព្រហ្ម និង ជាអ្នករួមសុខទុក្ខជាមួយខ្លួន។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៦)

នៅចុងសម័យនេះ ព្រាហ្មណ៍តែងគម្ពីរព្រះវេទជាថ្មីមួយក្បាលទៀត គឺអត្ថពវេទ ជាក្បាលទី៤ សេចក្ដីក្នុងគម្ពីរនេះ មួយផ្នែកយកពីគម្ពីរ៣ក្បាល ដែលតែងទុកពីដើម ហើយនឹងមានការតែងបន្ថែមមួយទៀត ផ្នែកដែលបន្ថែមជាមន្តការពារ ខ្មោចបិសាច បិទបាំងរាំងរា មារកំណាចកាចអាក្រក់ ឱ្យក្លាយទៅជាសិរីមង្គល។

សម័យព្រាហ្មណៈ ដែលតែងតែពិពណ៌នាមកនេះ ព្រាហ្មណាចារ្យបំបែកនិកាយចេញទៅទៀតជាច្រើន ដោយអាស្រ័យគម្ពីរព្រាហ្មណៈ ដែលតែងឡើងជាអត្ថកថា គម្ពីរព្រះវេទដូចដែលយើងនិយាយពីខាងដើមគឺ ៖

អាស្រ័យគម្ពីរឫគវេទ រចនាគម្ពីរព្រាហ្មណៈចេញទៅជា ២ ក្បាលទៀតគឺ អៃតរេយព្រាហ្មណៈ និង កោសិតកិព្រាហ្មណៈ ជាគម្ពីររបស់ព្រាហ្មណ៍និកាយអៃរេយិន និងនិកាយកោស៊ីតកិន។

អាស្រ័យគម្ពីរសាមវេទ រចនាគម្ពីរព្រាហ្មណៈចេញទៅទៀត ៣ ក្បាលទៀតគឺ បញ្ចវិមសព្រាហ្មណៈ ជហន្ទទោគយព្រាហ្មណៈនិងទល្វាការព្រាហ្មណៈ ជាគម្ពីររបស់ព្រាហ្មណ៍និកាយទណ្ឌិន ជហន្ទទោគយិន និងទល្វាករ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៧)

អាស្រ័យគម្ពីរយជុរវេទ ដែលចែកចេញជា យជុរវេទខ្មៅ និងយជុរវេទស រចនាគម្ពីរព្រាហ្មណៈឡើង ២ក្បាលគឺ ផ្នែកយជុរវេទខ្មៅ មានតែតតិរិយព្រាហ្មណៈរបស់និកាយតៃតតិរិយិន កាឋក និងមៃត្រយាណីយ។ ចំណែករជុរវេទស មានគម្ពីរសតបថព្រាហ្មណៈរបស់ព្រាហ្មណ៍និកាយវាជសនេយិនជាដើម។

លើកលែងគម្ពីរអត្ថពវេទ ដែលតែងឡើងក្នុងពេលខាងក្រោយគ្មានអត្ថកថា ៖

សេចក្តីអធិប្បាយសម្តែងពីការរាប់អានរបស់ជនជាតិអារ្យកមកពីខាងដើម អ្នកប្រាជ្ញកាត់វគ្គជាសាសនាព្រាហ្មណ៍ តអំពីនោះចូលដល់យុគទស្សនវិទូរបស់ហិណ្ឌូ។ អ្នកប្រាជ្ញហៅលំដាប់នៃសទ្ធាតអំពីនេះហៅថា "សាសនាហិណ្ឌូ" និងក្នុងយុគនេះឯងដែលមានសាសនាសំខាន់របស់លោក ២សាសនា កើតពីមជ្ឈដ្ឋាននៃទស្សនវិទូរបស់ហិណ្ឌូគឺ សាសនាជេន (ជិនៈ) និងពុទ្ធសាសនា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៨)

## ទស្សនវិជ្ជារបស់ហិណ្ឌូ
## សាសនាហិណ្ឌូ (ព្រាហ្មណ៍ថ្មី)

សម័យនេះជាដើមពុទ្ធកាល (ប្រមាណ៦០០.៤៨០ឆ្នាំមុនគ.ស.) ជនជាតិអារ្យកលូតលាស់ច្រើន ទាំងលទ្ធិនិងសតិបញ្ញា ការគ្រប់គ្រងមានបែបផែនល្អឡើងជាងពីដើម ព្រាហ្មណាចារ្យអ្នកជា ទេវតាក្នុងពពួកមនុស្សនៅតែផ្សព្វផ្សាយរបស់ខ្លួនយ៉ាងធំទូលំទូលាយ ទូទៅក្នុងជម្ពូទ្វីបភាគខាងជើង។

សម័យនេះជំនឿក្នុងលទ្ធិសាសនារបស់ជនជាតិអារ្យកកើតឡើងជារូបថ្មីមួយទៀត ទាក់ទងនឹងដួងវិញ្ញាណមានភាវៈវិលវល់ កើតស្លាប់នៅក្នុងលោក។ ទស្សនវិជ្ជារបស់ព្រាហ្មណ៍ថ្មី មានចំណែកប្រហាក់ប្រហែលគ្នានឹងទស្សនវិជ្ជារបស់សាសនាថ្មីដែលកើតឡើងក្នុងជម្ពូទ្វីប ក្នុងសម័យជាមួយគ្នាគឺ សាសនាជេន និង ពុទ្ធសាសនា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៧៩)

ទស្សនវិទូរបស់ហិណ្ឌូដែលកើតថ្មី មានដូចជា ៖

១-មានជំនឿកាន់តែខ្ពស់ឡើងថា ដួងវិញ្ញាណជាអនន្ត ដួងវិញ្ញាណនោះធ្លងមកពីការកើត (ជាតិ) ដែលរាប់មិនបាន ជាតិនេះអាចកើតអាចកើតជាយ៉ាងណា អាចកើតជាមនុស្សមានឋានៈល្អ ជាអ្នកក្រខ្សត់មានបញ្ញាល្អ ជួនកាលជាមនុស្សល្ងង់ ជួនកាលអាចជាសត្វប្រភេទខ្លះ និងជាពូជរុក្ខជាតិខ្លះក៏មាន វិលវល់ទៅយ៉ាងណានេះ គ្មានឈប់ស្ងៀមទេ ទំព័រនឹង

ចូលដល់ការរួចផុត (មោក្សៈ) ចាកចេញពីការកើតចូលទៅនៅជាមួយ បឋមវិញ្ញាណគឺ មហាព្រហ្ម ឬ បរមត្មន៍ៗ

២-ការបែកផ្សេងគ្នារបស់ជីវិតយ៉ាងនោះប្រព្រឹត្តទៅដោយអំណាចរបស់កម្ម គឺអំពើធ្វើទុកពីជាតិមុន ហើយព្រោះតែកម្មនោះឯងដែលធ្វើឱ្យវិលវល់ស្លាប់កើតជាវដ្តសង្សារៗ

៣-ព្រោះជឿថាមានកម្មជាគ្រឿងបណ្តាលឱ្យកើត ដែលមានការមិនស្មើភាព ក៏ព្រោះតែអំពើនោះៗ ទើបមានលទ្ធិថ្មីបង្រៀនថា ដើម្បីកុំឱ្យមានការមិនស្មើភាគ និងដើម្បីកុំឱ្យវិលកើតវិលស្លាប់យ៉ាងនោះ ក៏គួរតែមានអកម្ម គឺការមិនធ្វើអំពើ ធ្វើឱ្យខ្លួនចូលដល់អកម្មៗ ក្នុងទីនេះអធិប្បាយថាគឺ ព្រហ្ម ការដែលមនុស្សគេច ផុតពីកម្មទៅកាន់អកម្ម មានតែផ្លូវមួយប៉ុណ្ណោះ គឺការលះបង់ផ្ទះសម្បែង ចូលទៅក្នុងព្រៃស្វែងរកធម៌ជាត្រីមុខៗ

៤-ដោយហេតុនៃការរាប់អានថា វិញ្ញាណត្រូវវិលវល់កើតស្លាប់ព្រោះតែកម្មដូចដែលពោលខាងដើម ទើបកើតមានលទ្ធិការផុតរលត់នៃលោកចាស់ និងការចាប់ផ្តើមនៃលោកថ្មី ប្រព្រឹត្តទៅតាមកាលសម័យ (ដូចពោលមកហើយ) ការកើតឡើងនៃលោក ឬការផុតរលត់នៃលោកជាទីរបស់ទេវៈអ្នកសាង និងទេវៈអ្នកបំផ្លាញៗ (ហេង គីមហោ *សាសនា ប្រៀបធៀប* ភាគ១ ទំព័រ ៨០)

ទាំងនេះជាគោលការណ៍នៃទស្សនវិជ្ជារបស់ហិណ្ឌូ ក្នុងរយៈចាប់ផ្តើម ក្រោយពីផុតសម័យព្រាហ្មណៈ ហើយក្រៅពីគោលការណ៍ទាំងនេះ មានឧបញ្ញាថ្មីឱ្យអ្នកដែលកើតឡើងក្នុងត្រកូលព្រាហ្មណ៍ក្សត្រិយ៍ ពេស្យ ចូលទៅប្រព្រឹត្តខ្លួនក្នុងអាស្រមទាំង៤ពួក មានការតឹងរឹងច្រើនជាងមុន និងការដែលជឿថា មានការសន្តិភាព ក្នុងលោកត្រូវតែមានព្រាហ្មណ៍ មានព្រះវេទ និងមានវណ្ណៈ៤ពួក ដូចដែលបានពោលមកហើយ គឺតឹងតែងច្បាស់លាស់ច្រើនឡើងទៀតៗ សម្តែងឱ្យឃើញថាក្នុងសម័យនេះ ជនជាតិអារ្យកមានទស្សនវិទូខ្ពស់ តែការបែកបាក់សាមគ្គីគ្នាក្នុងសង្គម ព្រោះរឿងវណ្ណៈទាំង៤ពួកក៏មានកាន់តែច្រើនឡើងដែរៗ

សម័យឧបនិស័ទ (ដើមពុទ្ធកាល) សម័យនេះជាសម័យសំខាន់នៃប្រវត្តិសាស្ត្ររបស់សាសនាទាំង ៣ រួមគ្នាគឺ សាសនាហិណ្ឌូ សាសនាជេន និងពុទ្ធសាសនា ដោយន័យថាលទ្ធិជំនឿជឿកាន់តែកើតឡើងប្រហាក់ប្រហែលគ្នា ដោយអាស្រ័យសាស្ត្រាចារ្យមានសមត្ថភាពរិះគិតស្រាវជ្រាវរកហេតុផលនៃលទ្ធិ ការជឿកាន់តែកើតឡើងបានក្នុងសម័យជាមួយគ្នា គិតជាកាលប្រមាណ៦០០ ដល់ប្រមាណ ៤០០ ឆ្នាំមុនគ.ស.ៗ

ឧបនិស័ទ តែងឡើងដោយទាញយកពីគម្ពីរព្រះវេទជាល័ក្ខ ទំនងតែមួយនឹងគម្ពីរព្រាហ្មណៈ ដែលជាអត្ថកថារបស់គម្ពីរព្រះវេទ ប្រែតាមព្យញ្ជនៈ ថាចូលទៅអង្គុយចុះ តាមសេចក្ដីន័យថា មេរៀនបានដល់មេរៀនជាផ្នែកអាថ៌កំបាំង (Esoteric Doctrine) ជាទស្សនវិជ្ជាទាក់ទងនឹងដួងវិញ្ញាណ ដែលមានទំនាក់ទំនងជាមួយព្រហ្ម ជាគម្ពីរសំខាន់មួយរបស់ហិណ្ឌូ ជាជំពូកទី៣ របស់គម្ពីរព្រះវេទ ជាអត្ថកថាអធិប្បាយសេចក្ដីរបស់គម្ពីរព្រះវេទ ទំនងតែមួយនឹងគម្ពីរព្រាហ្មណៈ។

មួយភាគធំតែងជាពាក្យកាព្យឃ្លោង ហើយកាន់ថាជាគម្ពីរចុងក្រោយបង្អស់នៃការសិក្សារៀនសូត្រ ដើម្បីឱ្យដល់ទីបំផុត ទើបទៅជាវេទានតៈ ប្រែថា ទីបំផុតនៃព្រះវេទផងដែរ សេចក្ដីត្រង់នេះមានន័យថា កាលបើសិក្សាចប់គម្ពីរឧបនិស័ទហើយ បានសេចក្ដីថា សិក្សាដល់ទីបំផុតហើយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨១)

ពាក្យប្រៀនក្នុងគម្ពីរឧបនិស័ទដែលបង្រៀនដ៏សំខាន់ក្នុងសម័យដែលពោលនេះ គឺដួងវិញ្ញាណក្នុងសកលលោក សកលចក្រវាល រួមចុះទៅក្នុងដួងវិញ្ញាណរបស់លោកគឺមហាព្រហ្មនិយមនោះឯង ជាដួងវិញ្ញាណរបស់លោក (ព្រះព្រហ្មអង្គនេះ ជាអ្នកសហត្រីមូរត៌ ហើយចែកឱ្យត្រីមូរត៌មាននាទីម្យ៉ាងម្នាក់ដូច ដែលបានពោលពីខាងដើម)។

ត្រង់នេះគម្ពីរឧបនិស័ទមានពាក្យអធិប្បាយសង្កត់ធ្ងន់ថា វិញ្ញាណគឺមហាព្រហ្មនេះឯងមិនមានភេទ វត្ថុនៅក្នុងរបស់ទូទៅ មហាព្រហ្មគឺដួងវិញ្ញាណនៃសកលលោកហៅថា បរមា-ត្ម័ន កាលបើវិញ្ញាណក្នុងលោកជាបរមាត្ម័ន របស់ចេញពីវិញ្ញាណនោះក៏ជាបរមាត្ម័នដែរ (អាត្ម័នដែលជាគូកំណើត ជាអាត្ម័នធំទើបហៅថា បរមាត្ម័ន)។

អធិប្បាយតទៅថា ដោយហេតុនេះវិញ្ញាណរបស់បុគ្គល (ដែលចេញពីមហាព្រហ្ម) គឺព្រហ្មនេះឯង ព្រមទទួលស្គាល់ថាខ្លួនឯងគឺ ព្រហ្ម ឬ ព្រហ្មជាខ្លួនឯង។ ការស្គាល់ខ្លួនឯងស្មើគ្នា នឹងការស្គាល់ព្រហ្ម ការស្គាល់ ព្រហ្មក៏ស្មើគ្នានឹងការស្គាល់ខ្លួនឯងដែរ។ ការចេះដឹងត្រង់កន្លែងនេះជាផ្លូវឱ្យចូលដល់មោក្សៈ (ត្រឡប់ទៅនៅជាមួយមហាព្រហ្មតាមដើមវិញ)។ មហាព្រហ្ម ឬបរមាត្ម័ន ជាដើមចមនៃរបស់របរក្នុងលោកយើងនេះ ជាតួសច្ចៈ ជាការស្ថិតស្ថេរ ជាការពិតមែន ជាការរីករាយ និងជារបស់ដែលនឹងចូលទៅបានដោយលំបាក(ជ្រាលជ្រៅពិបាកនឹងយល់)អ្នកណាស្គាល់មហាព្រហ្មថាជាសច្ចៈ ជាទីតាំងនៃចំណេះដឹងជាការស្ថិតស្ថេរ

ពិតមែន អ្នកនោះនឹងចូលទៅដល់របស់ដែលខ្លួនប្រាថ្នាបាន (តែតតិរិយៈឧបនិស័ទ)។ (ហេង គីមហោ **សាសនាប្រៀបធៀប** ភាគ១ ទំព័រ ៨២)

ដូចដែលបានពិពណ៌នាខាងដើម កាលណាកើតមានជំនឿក្នុងការវិលវល់ស្លាប់កើតនៃដួងវិញ្ញាណហើយ បណ្ដាអ្នកមានសង្ឃឹមថា នឹងរួចផុតពីទុក្ខ ទើបរកផ្លូវឱ្យដួងវិញ្ញាណ កុំឱ្យនៅវិលវល់តទៅទៀតក៏កើតមានបណ្ដាពួកអាចារ្យបានបង្រៀនទុកមកដោយវិធីផ្សេង ៗ គ្នា។ ពួកអាចារ្យខ្លះប្រកាសថា ត្រូវអាស្រ័យការចេះដឹងជាគោល ទើបនឹងផុតចាកទុក្ខបាន ពួកអាចារ្យខ្លះទៀតប្រកាសថា ត្រូវធ្វើពិធីពលីបូជា ឯពួកអាចារ្យផ្សេងទៀតថា ត្រូវបំពេញតបៈ ធ្វើកាយនិងចិត្តឱ្យលំបាកយ៉ាងខ្លាំងក្លាដូច្នេះក៏មាន និងនៅមានពួកអាចារ្យដែលមានគំនិតគិតជ្រៅមែនទែន ឃើញថាការបំពេញយ៉ាងនេះ មិនមែនជាការរួចផុតពីទុក្ខទេ និងឱ្យរួចផុតពីទុក្ខពិតប្រាកដបានត្រូវកាន់បដិបទាលះបង់ការបូជាទេវៈជាម្ចាស់ លះបង់ការសែនព្រេនផ្សេងៗ លះបង់ផ្ទះ សម្បែងចេញទៅកាន់ភេទជាបរិព្វាជនឬជាភិក្ខុ (អ្នកសុំ) ត្រូវត្រាច់រង្គត់ទៅក្នុងព្រៃ ដែលគប្បីបំពេញខ្លួនឱ្យលំបាកខ្លាំងក្លា បំពេញតបៈ ដុតរូបរាងក៏មាន បំពេញព្យាយាមផ្លូវកាយក៏មានបំពេញព្យាយាមផ្លូវចិត្តក៏មាន។ ពាក្យបង្រៀនរបស់អាចារ្យជំនាន់ក្រោយដែលកើតក្នុងសម័យនេះ គឺពាក្យបង្រៀនរបស់សាស្ដានៃលទ្ធិជេននិងលទ្ធិពុទ្ធ-សាសនារបស់ព្រះសមណៈគោតម ដែលកើតឡើងជិតសម័យជាមួយគ្នា។ (ហេង គីមហោ **សាសនាប្រៀបធៀប** ភាគ១ ទំព័រ ៨៣)

សម័យអវតារ មិនឃ្លាតឆ្ងាយពីសម័យឧបនិស័ទ មានការរាប់អានរបស់ជនជាតិហិណ្ឌូ លេចចេញមុខមកម្យ៉ាងទៀត គឺការរាប់អានលទ្ធិអវតារ (Incarnation) ពោលគឺជឿថាទេពជាម្ចាស់អង្គខ្លះទ្រង់ឫទ្ធិ អវតាកើតជាវីរៈបុរស ឬជាមនុស្សពិសេសជាអាទិ៍ ព្រះរាមក្នុងគម្ពីររាមាយណៈ (រាមកេរ្តិ៍) និងព្រះក្រិស្ណ ដែលប្រាកដក្នុងគម្ពីរមហាភាតរៈ ធ្លាប់រាប់អានថាជាវីរបុរសនោះៗ មកក្នុងសម័យក្រោយ មានអ្នករាប់អានកាន់តែច្រើនឡើង រហូតដល់កម្រិតថាព្រះវិស្ណុ (ទេវតាមួយអង្គក្នុងទេពត្រីមូរតិ៍) ជាអវតារ ចុះមកបង្ក្រាបយុគៈ ទុក្ខលំបាកក្នុងមនុស្សលោក (នារាយណ៍) អ្នករាប់អានព្រះវិស្ណុជាម្ចាស់បែកចេញជានិកាយហិណ្ឌូមួយនិយាយទៀតហៅថា វៃសណពនិកាយ និងមានសៃវៈនិកាយទៀតក្នុងពេលខាងក្រោយ។

ន័យនៃការរាប់អាន ព្រះវិស្ណុ (នារាយណ៍) ថាជាអ្នកមានឫទ្ធិអវតារចុះមកបង្ក្រាបយុគទុក្ខលំបាកនោះ គឺព្រះនារាយណ៍ជាមហាទេពដ៏ធំក្រៃលែងមួយ ព្រះអង្គហៅថា បរព្រហ្ម ជាអ្នកសាងរបស់ទាំងឡាយ។ ព្រះនារាយណ៍ឋិតនៅឋានសួគ៌ជាន់វៃស្ណវៈ (ជារបស់វិស្ណុ) ពេល

ណាកើតអធម៌ឡើងក្នុងលោក ស្តេចអវតារក៏ចុះមកលាងអធម៌ឱ្យអស់ចេញទៅពីលោក។ កាលណាបង្ក្រាបសម្រេចយុគទុក្ខលំបាកក្នុងលោកហើយ ក៏ត្រឡប់ទៅកាន់ឋានសួគ៌វិញ កំណត់តាមយុគៈមាន ១០ យុគ (នារាយណ៍ ១០លក្ខណៈ) មានពាក្យពោលតាមលក្ខខណ្ឌលទ្ធិហិណ្ឌូថា "លោកនេះកើតអំពីនារាយណ៍ តាំងនៅក្នុងនារាយណ៍ នារាយណ៍ជាច្បាប់នៃការតាំងនៅ និងការរលាយសាបសូន្យទៅទាំងសកលលោក អង្គនារាយណ៍នោះឯង គឺលោក"។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨៤)

សម័យជាមួយគ្នាមានជនជាតិហិណ្ឌូពួកខ្លះបែកទៅរាប់អានព្រះសិវៈ (ឥស្វរ) ថាជាទេពអ្នកសាង មានយសស័ក្តិច្រើនជាងព្រះវិស្ណុ ជួយគ្នាសាងឫទ្ធិនិងអំណាចឱ្យដល់ព្រះសិវៈ របស់ខ្លួនសន្មតឱ្យព្រះសិវៈជាគោ អ្នកឱ្យទឹកដោះនិងសាច់ ដើម្បីចិញ្ចឹមមនុស្សជាពាហណៈ គោក្លាយជាសត្វស័ក្តិសិទ្ធិ ដូចជាម្តាយរបស់មនុស្សទាំងឡាយ ហើយនិងសន្មតឱ្យលិង្គៈ (គ្រឿងសម្គាល់បុរសភេទ) ជារបស់ដែលគួរបូជា ហៅថាសិវលិង្គ ដោយន័យថា ប្រដាប់នៃភេទនោះជាអ្នកសាងរបស់សព្វសារពើក្នុងលោក ពួកអ្នករាប់អានព្រះសិវៈជាម្ចាស់ ជាហិណ្ឌូមួយនិយាយទៀតហៅថា សិវៈនិកាយ។

ទស្សនៈ ៦ (បរមត្ថវិជ្ជា)

សម័យជាមួយគ្នា មានម្ចាស់លទ្ធិកើតឡើង ៦រូប សម្តែងទិដ្ឋិ គឺការយល់ឃើញ (ហៅក្នុងទីនេះថា បរមត្ថវិជ្ជា) ចេញទៅផ្សេងៗគ្នា៦បែប ក្លាយទៅជាសាស្ត្រហិណ្ឌូ ៦ សាស្ត្រ ទស្សនៈទាំង៦មានឈ្មោះ ប្រវត្តិ និងពាក្យអធិប្បាយដោយសង្ខេបដូចតទៅនេះ ៖

ទស្សនៈទីមួយឈ្មោះ នយាយ មានន័យសេចក្តីថា ការស្រាវជ្រាវរកសេចក្តីពិតក្នុងធម៌ ដោយវិធីដ៏សមរម្យ អាស្រ័យការពិចារណាពីច្បាប់ទៅរកសេចក្តីពិតតាមហេតុផល ដ៏សមរម្យ អាស្រ័យការពិចារណាពីច្បាប់ទៅរកសេចក្តីពិត តាមហេតុផលដ៏សមគួរ ទើបហៅលទ្ធិនេះថាជាវិជ្ជាទាក់ទងនឹងការគិត ម្ចាស់លទ្ធិនេះឈ្មោះគោតមៈគម្ពីរ ក្នុងលទ្ធិគឺនយោបាយសូត្រ។

លក្ខណៈសំខាន់របស់និកាយឱ្យពិចារណាដល់សភាវៈ៥ គឺ សេចក្តីទុក្ខ ការកើតចលនានៃជីវិត ទោសៈ និងកំហុសជាសំខាន់ (ដែលកើតពីអវិជ្ជា) ដោយការពិចារណារកសេចក្តីពិតតាមការសមហេតុផល បង្រៀនឱ្យបុគ្គលលះបង់អកុសលកម្ម ឱ្យមានមេត្តាដល់គ្នា មានសច្ចៈបំពេញប្រយោជន៍ដល់គ្នា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨៥)

ទស្សនៈទីពីរ វៃសេសិក ម្ចាស់លទ្ធិឈ្មោះកណាទ ជាមនុស្សសម័យជាមួយគ្នា និង គោតមៈអ្នកជាម្ចាស់លទ្ធិនយោបាយ ពាក្យអធិប្បាយ សេចក្តីក្នុងទស្សនៈនេះ ទំនងជាអត្ថកថារបស់នយោបាយ គឺអធិប្បាយសេចក្តីក្នុងសភាវៈទាំង៥ ដែលសម្តែងមកហើយ។ គោលការណ៍បង្រៀនប្លែកគ្នាទៅទៀតគឺជឿការគង់វង្សរបស់លោក ដែលផ្លាស់ប្តូរដោយអាងថា ព្រោះលោកនោះប្រកបដោយធាតុ (បរមាណូ) ដែលជាអមតៈ អធិប្បាយដោយធម៌បរមាត្ម័ន ជាអ្នកសាងលោក គង់វង្សនៅក្នុងលោក ជាអនទ្ទគម្ពីរក្នុងលទ្ធិនេះគឺ វៃសេសិក សូត្រ។

ទស្សនៈទីបីសាង្ខ្យៈ ម្ចាស់គឺកបិល លទ្ធិនេះមិនប្រាប់ថា ពុំមានព្រះជាម្ចាស់និងមិនប្រាប់ថាមានរបស់សព្វសារពើដែលមាននៅក្នុងលោក ត្រូវកើតអំពីហេតុនិងផលរបស់វា របស់ដែលមាននៅហើយ ត្រូវកើតឡើងពីរបស់ដែលគ្មានយកជាមូលដ្ឋានមិនបាន មនុស្សគួរស្វែងរកសេចក្តីសុខអំពីមូលដ្ឋាន ដែលធ្វើឱ្យកើតទុក្ខ មានខ្លួនឯងជាហេតុ និងមានខាងក្រៅជាហេតុផល គម្ពីរក្នុងលទ្ធិគឺ សាង្ខ្យសូត្រ។

ទស្សនៈទីបួន យោគៈ ម្ចាស់លទ្ធិគឺ បតញ្ជលី លទ្ធិនេះប្រហែលនឹងសាង្ខ្យៈ មានទស្សនៈខាងផ្លូវទេព ជាម្ចាស់ទ្រង់ស័ក្តិមានអំណាចលើមនុស្ស សេចក្តីក្នុងទីនេះ គឺព្រះឥស្វរជាអ្នកធំលើសលប់ ស្មើនឹងបរមាត្ម័ន ដែលជាបឋមវិញ្ញាណ ទ្រង់សាងលោក គ្រប់គ្រងនិងបំផ្លាញលោក។ ទស្សនៈនេះកំណត់ឱ្យតាំងសមាធិគឺការ ពិចារណាឱ្យជាឯកគ្គតា មានបណិធានចិត្តត្រង់ទៅព្រះឥស្វរ (ញ៉ាំងអាត្មន័ឱ្យចូលដល់បរមាត្មន័)។

"ផ្លូវចូលដល់យោគមាន ៨ គឺ យម (ការទាក់ទាញ) និយម (ការប្រតិបត្តិក្នុងលទ្ធិ), អាសនៈ (វិធី អង្គុយធ្វើចិត្តឱ្យនឹងធឹង), បរាណាយាម (វិធីបន្ទូរខ្យល់ដកដង្ហើម), បរត្តយាហារ (ការធ្វើឱ្យលំបាកឥន្ទ្រីយ៍ ឬ ការដកឥន្ទ្រីយ៍ ចេញពីអារម្មណ៍), ធារាណ (ការតាំងចិត្តឱ្យមាំ), ញាណ (ការសម្លឹង) និងសមាធិ (ការមាន ដួងចិត្តនៅមួយកន្លែង) អ្នកប្រព្រឹត្តក្នុងយោគៈហៅថា "យោគី" គម្ពីរក្នុងលទ្ធិគឺយោគៈសូត្រ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨៦)

ទស្សនៈទីប្រាំ បុរវមិមំសា ហៅម្យ៉ាងទៀតថា កម្មិមំសា ម្ចាស់លទ្ធិឈ្មោះជៃមិនី គោលការណ៍ក្នុងលទ្ធិនេះឱ្យប្រើការត្រិះរិះក្នុងហេតុផលឱ្យធ្វើពិធីមាន ការពលីបូជា លះបង់គ្រឿងពលីបូជានោះជាគោលធំ គម្ពីរក្នុងលទ្ធិហៅថា កម្មិ មំសូត្រ។

ទស្សនៈទីប្រាំមួយ ឧត្តរមិមំសា ម្ចាស់លទ្ធិឈ្មោះវយាស ឬ ពាទ្រាយន៍ ទស្សនៈនេះគឺ វេទានតៈ គឺ ល័ក្ខសិក្សាជាទីបំផុតនៃវេទគោលនៃវេទានតៈ មានសេចក្តីថា ព្រះជាម្ចាស់ជា

មហាទេព ជាអ្នកធំលើសលប់ ជាអ្នកសាង ការសាងគឺជាព្រះប្រាថ្នារបស់មហាទេព ព្រះអង្គនោះគឺព្រហ្ម បើនិយាយឱ្យងាយយល់គឺ លោកស្មើនឹងព្រហ្ម របស់ផ្សេងៗចេញពីព្រហ្ម (ផលមកពីហេតុ) មនុស្សគ្រប់គ្នាត្រូវបូជា (ហេតុដែលកើត) គម្ពីរក្នុងលទ្ធិឈ្មោះវេទានសូត្រ ឬ ព្រហ្មសូត្រ ឬ សរីរកសូត្រ។

ទស្សនៈទាំង៦ នេះ ពួកហិណ្ឌូប្រកាន់ថា ជាបរមត្ថវិជ្ជារបស់ខ្លួនដោយពិតប្រាកដនិងហិណ្ឌូគ្រប់រូបមិនអាចលះបង់បានឡើយ។

សម័យដែលពោលមកនេះ មានរឿងដែលគួរឱ្យសិក្សាមួយរឿងទៀត គឺអក្សរសាស្ត្ររបស់ហិណ្ឌូ ដែលតែងឡើងថ្មីជាគោលឱ្យមនុស្សប្រព្រឹត្តតាមធម៌ជាគោលទូទៅសម្រាប់បុគ្គលទាំងឡាយ មិនថាចំពោះវណ្ណៈណា ពួកណាអក្សរសាស្ត្រទាំងនោះគឺ ៖

មានវិទ្យាសាស្ត្រឬមនុស្សសាស្ត្រ ដែលប្រែថាច្បាប់បង្គាប់បញ្ជារបស់ព្រះមនុ ហៅម្យ៉ាងទៀតថាមនុសញ្ញាហិតា បានដល់ច្បាប់របស់មនុស្សដែលប្រកាន់ថាជាឫសគល់ របស់វិជ្ជាច្បាប់របស់លោក។

រាមាយណៈ (រាមកេរ្តិ៍) ដែលពោលគឺរឿងព្រះរាម លោកជាវីរៈបុរសអវតាចុះមកពីព្រះវិស្ណុ ធ្វើនាទីជាអ្នកបង្រ្កាបអធម៌ក្នុងលោក។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨៧)

មហាភារតៈ ពោលគឺរឿងរបស់ព្រះក្រិស្ណៈ អ្នកជាវីរៈបុរសមកដល់ត្រង់វគ្គនេះ មានរឿងពង្រីកបន្ថែមឫទ្ធិឱ្យដល់ក្រិស្ណៈថា ជាអវតារមកពីព្រះវិស្ណុទៀតដូចគ្នា។ ដោយពាក្យអធិប្បាយមកដូច្នេះទើបកំណត់បានថា គម្ពីរសំខាន់ទាំងពីរនេះជាទីរាប់អានរបស់ហិណ្ឌូនិកាយវៃស្ណព អ្នករាប់អានព្រះវិស្ណុជាម្ចាស់ ជាជាងហិណ្ឌូនិកាយផ្សេងៗ (ទាំងរាមាយណៈ និងមហាភារតៈ ហៅថាឥតិហាសៈ គឺរឿងដែលជានិទានរបស់វីរបុរស)។

ភគវទ្គីតាជាអក្សរសាស្ត្រមួយក្បាលទៀតដ៏សំខាន់បំផុតកើតឡើងក្នុងយុគនេះ ភគវទ្គីតា ប្រែថា ភ្លេងរបស់អ្នកគួរគោរពបូជាបានដល់ព្រះក្រិស្ណៈ ជាអក្សរសាស្ត្រប្រភេទគោលធម៌ ឬបង្រៀនឱ្យបុគ្គលចេះដឹង គោលនៃការធ្វើចិត្តគំនិតឱ្យត្រូវដល់ហេតុការណ៍និងលោកដែលខ្លួនអាស្រ័យ ហើយនឹងបង្រៀនឱ្យមនុស្សប្រកាន់សេចក្តីព្យាយាម ដើម្បីឱ្យផុតសេចក្តីប្រាថ្នាដែលជាដើមហេតុឱ្យកើតកម្ម (កម្មយោគៈ)។ ក្រៅអំពីនេះ បង្រៀនឱ្យស្គាល់ភាពធំលើសលប់របស់ព្រះក្រិស្ណៈ អ្នកជាវីរៈបុរសឡើងបានព្រោះទ្រង់ប្រកបដោយសេចក្តីក្លាហាននឹងធម៌ដូចដែលបានពោលមកហើយ។

បុរាណៈមួយក្បាលទៀតតាមសព្ទប្រែថាគម្ពីរចាស់ (កើតមុនរាមាយណៈនិងមហាភារតៈ) បុរាណៈ និយាយពីរឿងទាក់ទងនឹងទេពជាម្ចាស់មិនមានរឿងរបស់មនុស្ស (អ្នកដែលព្រះជាម្ចាស់សាង) និងមានរឿងផ្សេងៗដែលកំណត់ទុកដោយលក្ខណៈប្រកប (តាមរចនារបស់អមរសិង្ហ) ជាមាន៥ប្រការគឺ ៖

ក. និយាយពីរឿងសាងលោក

១. និយាយពីការវិនាស និងការដែលលោកត្រឡប់មកជាថ្មី (ហេង គីមហោ *សាសនាប្រៀបធៀប* ទំព័រ ៨៨)

គ. រឿងពូជអម្បូររបស់ព្រះជាម្ចាស់ផ្សេងៗ

ឃ. រឿងការចាប់ផ្ដើមរបស់ព្រះមនុ និងយុគនៃព្រះមនុដែលហៅថាមនវន្តរ

ង. រឿងរបស់ដួងអាទិត្យ ដួងចន្ទ

គម្ពីរបុរាណៈត្រង់ដែលមានឈ្មោះច្រើនបំផុតគឺ វិស្ណុបុរាណៈ ដែលពោលដល់រឿងរ៉ាវរបស់ព្រះវិស្ណុជាម្ចាស់ លោកអ្នកប្រាជ្ញខ្លះអនុលោមថា គម្ពីរមានវសាស្រ្តជាមួយគ្នានឹងបុរាណៈ លទ្ធិភក្តិ សក្តិ និង តន្តរៈ។

ពុទ្ធសករាជកន្លងទៅហើយបានប្រមាណ ១.៥០០ឆ្នាំ គ្រានេះពុទ្ធសាសនាក្នុងឥណ្ឌាចាប់ផ្ដើមអន់ថយចុះ សាសនារបស់អាចារ្យក្រុមដទៃលែងជាគូប្រណាំងប្រជែងរបស់ពុទ្ធសាសនា មកពីដើមក៏បាត់បង់សេចក្តីស័ក្តិសិទ្ធិអំពីមូលដ្ឋានដើមនៃពាក្យប្រដៅរបស់សាស្តា ដូចលទ្ធិជេន ឬជៃនៈ របស់មហាវីរៈជាដើម។

ហេតុផលគឺការចម្រើនលូតលាស់របស់លទ្ធិហិណ្ឌូមានច្រើនឡើង ជាប្រការមួយដែលពុទ្ធសាសនាមិនអាចតាំងខ្លួននៅឯកឯងបាន ចូលផ្សំគ្នាជាមួយហិណ្ឌូ ទំនងដូចជាហៅថា ពុទ្ធនិងសៃវ រមែងអាស្រ័យគ្នាទៅវិញទៅមក ញុំាងហេតុផលខាងផ្លូវនយោបាយ។ សម័យពួកអ៊ិស្លាមគឺសាវ័ករបស់ព្រះមហាម៉ូហាម៉េត រុករានទន្រ្ទានទី មកបំផ្លាញវត្ថុ ទីស្ថាននិងលទ្ធិរបស់អ្នកស្រុកអស់ជាច្រើនប្រការមួយទៀត។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៨៩)

តាំងតែពុទ្ធសករាជ ១.៥០០ឆ្នាំឡើងទៅ បរមត្ថវិជ្ជារបស់ហិណ្ឌូនិងបរមត្ថវិជ្ជារបស់សាសនាដទៃទៀត ដែលនាំគ្នារាប់អានក្នុងជម្ពូទ្វីបចូលទៅជំពាក់ជាក់រិនជាមួយគ្នា។ នៅភាគខាងជើងរបស់ឥណ្ឌា ក្រុមអាចារ្យ របស់ហិណ្ឌូខ្លះមានបំណងប៉ងប្រាថ្នាផ្សព្វផ្សាយលទ្ធិរបស់ខ្លួនមិនឱ្យចាញ់ដល់លទ្ធិអ្នកដទៃដោយវិធីផ្លាស់ប្តូរ ការជឿប្រកាន់របស់មនុស្សឱ្យប្រព្រឹត្តទៅ

ក្នុងគោលបំណងរួបរួមគ្នាតែមួយ បដិសេធការបែកខ្ញែកជានិកាយ តូចតាចដែលជាគ្រឿងកាត់បន្ថយសេចក្តីសាមគ្គីឱ្យថយចុះ បើនឹងថាការប្រកាសសាសនាតាមបែបនេះ អ្នកប្រកាស បំណងយកប្រយោជន៍ខាងផ្លូវនយោបាយក៏ថាបាន។

ដូច្នោះសម័យនេះទើបមានលទ្ធិប្រកាសដល់ភក្តីភាព (Faith) ចំពោះព្រះអង្គម្ចាស់អង្គណាមួយ ពុំមានព្រះជាម្ចាស់អង្គដទៃ ពុំមានលទ្ធិនិកាយដទៃ ព្រះអង្គម្ចាស់អង្គនោះ ទោះបីជាអ្នកណាមិនអាចជ្រាបបាន តែមិនមែនព្រះព្រហ្ម មិនមែនព្រះវិស្ណុ មិនមែនព្រះសិវៈ មិនមែនទេពទេវីអង្គណាឡើយ ព្រះអង្គទ្រង់ករុណាដល់អ្នកគោរពព្រះអង្គ ព្រះអង្គទ្រង់ជាអ្នកប្រទានដួងវិញ្ញាណដល់មនុស្ស វិញ្ញាណរបស់មនុស្សមកពីព្រះអង្គ ដូច្នោះទើបដួងវិញ្ញាណរបស់មនុស្សមិនបែករលាយ។ ពាក្យបង្រៀនដែលសំខាន់ក្នុងលទ្ធិភក្តីភាពគឺបុគ្គលមិនថាក្នុងវណ្ណៈណា ភក្តីភាពរបស់ព្រះអង្គជាម្ចាស់បានគ្រប់វណ្ណៈ អ្នកណាភក្តីភាពចំពោះព្រះជាម្ចាស់ អ្នកនោះនឹងផុតទុក្ខទាំងអស់” ភក្តីភាពគឺគុណធម៌ខ្ពង់ខ្ពស់ជាងគុណធម៌ដទៃ ខ្ពស់ជាងការពលីកម្មបូជា (សូម្បីតែការពលីកម្មដែលហៅថាអស្វមេធ) ខ្ពស់ជាងអ្នកប្រើសតិបញ្ញា ការចេះដឹងណាៗទាំងអស់ និងខ្ពស់ជាងការសម្លឹង ពិនិត្យពិច័យណាៗទាំងអស់”។

អ្នកប្រកាសលទ្ធិភក្តីចំពោះព្រះជាម្ចាស់តែមួយ ដូចបានពោលមកនេះគឺ គុរុនានក់សាស្តាជំបូងរបស់សាសនាសិក្ខ និងដោយហេតុផលខាងនយោបាយដូចបានពោលមកពីដើម គឺមូលហេតុនៃការកើតឡើងរបស់សាសនានោះ (នឹងអធិប្បាយតទៅខាងមុខ)។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩០)

ហិណ្ឌូជំនាន់ក្រោយ កាលបើសេចក្តីនឹកគិតរបស់មនុស្សផ្សេងៗរលាយឡំគ្នាទៅ ទើបមាននិកាយនៃសទ្ធាដែលចែកចេញតទៅទៀត ជិតនឹងទៅជាអនាចារ ដែលគួរពោលទុកទីនេះដែរ ២និកាយ គឺនិកាយសក្តិ និងតន្ត្រៈ។

សកតិ ប្រែថា សក្តិសេចក្តីខ្ពស់អណ្តែត ឬអំណាច ឬគ្រឿងទំនុកបម្រុងឱ្យមានសិរីក្នុងទីនេះសំដៅដល់ទេវតាស្រី(ទេវី) ជាព្រះជាយារបស់ទេវតាប្រុស កើតឡើងមកដើម្បីបន្ថែមអំណាចឱ្យដល់ទេពជាស្វាមី។

ហេតុអ្វីទើបមានសក្តិកើតឡើង តាមធម្មតាដឹងបានថា របស់គ្រប់យ៉ាងជាគូគ្នា មានទឹកត្រូវមានភ្លើង មានក្តៅត្រូវមានត្រជាក់ កាលបើមានភេទប្រុសត្រូវមានភេទស្រីជាសំយោគនៅគូគ្នា លោកទើបមានតុល្យភាព គឺតាំងនៅបាន ទេវតាប្រុសមិនអាចនៅឯកឯង

បាន ត្រូវមានសក្តិ គឺត្រូវមានទេពីឬជាយាមកគូគាប់នឹងគ្នា ទើបមានរឿងនិយាយគ្នាតទៅទៀត បើគ្មានអ្វីរឿងនឹងចប់។

របស់សព្វសារពើក្នុងលោក តើអ្វីទំ ដែលប្រសើរជាងមនុស្សនោះ ព្រះជាម្ចាស់អង្គឯងក៏មិនធំស្មើដែរ សេចក្តីពិត ព្រះជាម្ចាស់មិនបានសាងមនុស្ស តែមនុស្សនោះឯងជាអ្នកសាងព្រះជាម្ចាស់ ប៉ុន្តែការដែលមនុស្សសន្មតថា ព្រះជាម្ចាស់ជាអ្នកសាងរបស់ទាំងឡាយនោះ ព្រោះតែសេចក្តីល្ងង់របស់មនុស្សនេះឯង ដូច្នេះត្រូវតែនិយាយថា ព្រោះមនុស្សជាអ្នកសាងព្រះជាម្ចាស់ឡើងដើម្បីរកប្រាក់។

ជនជាតិហិណ្ឌូបានសាងសក្តិគឺ ទេវីឬទេវតាស្រី ឡើងមកជាគូទេវតាប្រុសសន្មតឱ្យជាភរិយាស្វាមីនឹងគ្នា ដើម្បីជាអំណាចនិងជាគ្រឿងប្រដាប់ដល់គ្នានឹងគ្នាដោយប្រការនេះ ឯង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩១)

រឿងសាងសក្តិមានពាក្យអធិប្បាយជាផ្លូវធម៌ថា សក្តិឬទេពី ជាគ្រឿងសំគាល់ ឬសម្តែងឱ្យឃើញកម្លាំងកិលេស ផ្នែកអាក្រក់ និងបញ្ញាជារបស់ល្អ ដែលមានជាប្រការផ្សេងៗក្នុងស្ត្រីភេទ។

ប៉ុន្តែទោះបីជាយ៉ាងណាក្តី ទីបំផុតនៃការរាប់អានរឿងទេពី ឬទេវតាស្រីក្លាយមកជារឿងរកស៊ីមួយផ្នែកយ៉ាងធំ។ តាំងពីដើមមក គួរនឹងចាប់ផ្តើមឡើងពីនិកាយសៃវៈមុន ព្រោះមហាទេពីអ្នកមានសក្តិខ្ពស់ជាង មហាទេពីណាៗជាសក្តិ ជាជាយារបស់ព្រះសិវៈ ទ្រង់ព្រះនាមថា ឧមា តែមកខាងក្រោយមាននាមផ្សេងៗ ចេញទៅតាមសេចក្តីរាប់អានដែលស្រេចតែបំណងឱ្យមានន័យតាមកម្លាំងកិលេសដែលប្រព្រឹត្តទៅដូចជាមានថា ទេពី អម្ពិកា ឧមា បាវតី មហាវិទ្យា មហាមាតា នាយិកា យោគិនី ចណ្ឌី ចណ្ឌិកា កៃរវី ហេមវតី ភាវា ទុរគានិងកាលី ជាដើម។ ឯនិកាយ វៃស្ណព រមែងអាងព្រះនាមព្រះលក្ស្មី ជាសក្តិរបស់ព្រះវិស្ណុ នាមថា រាជជាយាព្រះក្រិស្ណៈ (អ្នកជាអវតាមកពីវិស្ណុ)។ ចំណែកឯក្នុងនិកាយដែលរាប់អានព្រះព្រហ្ម (និកាយព្រាហ្ម) រមែងអាងសក្តិព្រះព្រហ្មថាសរស្វតី ដូច្នោះ។

សក្តិឬទេពីគឺទេវតាស្រីដែលទ្រង់ព្រះនាមច្រើនយ៉ាងនេះ សេចក្តីពិតមានព្រះនាមតែមួយ (គឺឧមា ជាយាព្រះសិវៈ) តែបើព្រះសិវៈជាអវតាមានលក្ខណៈផ្សេងៗ ទេពីទើបមានព្រះនាមផ្សេងគ្នា មានព្រះរូបផ្សេងគ្នា មានការបូជា មានទេវាល័យជាទីស្ថិតនៅអាស្រ័យច្រើនសន្ធឹកសន្ធាប់ដោយរូបនិងពិធីផ្សេងគ្នា ការពលីបូជាចំពោះមហាទេវីទាំងនេះ ពិធីខ្លះ រូបខ្លះ

មានរហូតដល់ទៅថ្នាក់ទារុណកម្ម និងអនាចារផង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩២)

ការដែលមានអនាចារ និងទារុណកម្មនៅក្នុងពិធីបូជាព្រះម៉ែជាម្ចាស់ទាំងអស់នេះ ក៏ជារឿងទាក់ទងអំពីការនឹកគិតតាមធម្មតា ទីណាមានរឿងត្រូវការបរិភោគអាហារស្រស់ ឆ្អាប (ដែលអាងថាព្រះជាម្ចាស់សោយ) ទីនោះក៏មានឈាម មានការវាយប្រហារនិង ទារុណ កម្ម។ ទីណាមានរឿងរបស់ភេទគូ មានរឿងរបស់សេចក្តីប្រាថ្នាធំក្នុងកាម ទីនោះក៏មាន អនាចារនិងទុរាចារជាលំដាប់លំដោយ។ នៅទីទេវាល័យកន្លែងខ្លះ ក្នុងក្រុងកាល់គុត្តា (Calcutta) មានទីកន្លែងសាកសពដែលប្រហារពពែដើម្បីយកលោហិតសែនព្រះម៉ែកាឡី ទេវាល័យខ្លះមានទេពទាសីរង់ចាំជួយធ្វើអំពើ មេថុនធម្ម ដើម្បីសែនព្រះម៉ែជាម្ចាស់ក៏មាន។

អ្នកប្រាជ្ញផ្នែកហិណ្ឌូបានទទួលស្គាល់ថា និកាយតន្ត្រៈកើតមកពីការរាប់អានស័ក្តិ រឿងរ៉ាវរបស់ទេវតាស្រី ប្រពន្ធរបស់ទេវតាប្រុស ដែលក្លាយមកជាបែបផែនក្នុងពេលក្រោយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៣)

តន្ត្រៈន័យថា ពិធី ឬបែបផែន ច្បាប់កំណត់ ឬលក្ខខណ្ឌក្នុងពិធីផ្សេងៗតាមឋានៈនិងសភាពរបស់មនុស្សដែលសម្តែងចេញមក ដោយអំណាចរបស់កិលេស៣ប្រការ បានដល់ សភាពដែលកើតមកជាសត្វ សភាពនៃការជាអ្នកក្លាហាន និងសភាពនៃការជាអ្នកប្រសើរ សភាពទាំង៣នេះ មានទៅតាមវ័យដើម កណ្តាល និង ចុងបំផុតទៅតាមលំដាប់។

ការបូជាស័ក្តិតាមបែបផែនតន្ត្រៈនិងត្រូវធ្វើទៅតាមសភាពយ៉ាងនេះ និងត្រូវធ្វើតាមសភាពបែបណាមួយឱ្យស័ក្តិសមនឹងទេពជាស្វាមីពេញព្រះទ័យ តែការនឹងឱ្យទេពទាំងគូពេញចិត្តក៏គ្មានអ្វីក្រៅអំពីការពិពណ៌នាគុណនៃចំណង់ ហើយនឹងគុណនៃសេចក្តីស្រឡាញ់រវាងទេពីទាំងពីរនោះ ទីបញ្ចប់ដោយការប្រកបមេថុន។

អ្នកប្រាជ្ញនិកាយតន្ត្រៈអធិប្បាយថា ការធ្វើតាមច្បាប់ពិធីនេះជាចំណុចខ្ពស់បំផុតរបស់លទ្ធិតន្ត្រៈ អ្នកធ្វើពិធីត្រូវធ្វើតាមវិធីបន្ទាប់៥យ៉ាងហៅថា “ម” ទាំង ៥ ឬ មកា គឺ ៖

ក. មត្យៈ ឬ មជ្ជ ទឹកស្រវឹងមានន័យថា ត្រូវផឹកទឹកស្រវឹងឱ្យស្រវឹងស្ទើរភ្លេចស្មារតីក៏រិតតែល្អ។

ខ. មំសៈ សាច់ស្រស់មានន័យថា ត្រូវបរិភោគសាច់ស្រស់ផ្សំគ្នាជាមួយគ្រឿងស្រវឹងនោះ (មត្យយ គឺ ត្រី ក៏បាន)។

គ.មន្ត្រា សូត្រពាយមន្ត បទណានីមួយឱ្យធាប់កើតមានតម្រេក។

ឃ.មុទ្រា ល្ងីល្ងើធ្វើជាទំនងបែបណាមួយ ឱ្យធាប់កើតមានតម្រេក។

ង.មេថុន ប្រកបមេថុន។

វិធីនេះជារបស់វាមាចារិន គឺពួកស័ក្តិប្រុស ហៅម្យ៉ាងទៀតថាកាឡចក្រ (ចក្រខ្មៅ) រមែងធ្វើក្នុងពេលអធ្រាត្រ អ្នកជះថ្វាទាំងស្រីប្រុសមកប្រជុំគ្នានៅចំពោះស័ក្តិ (ព្រះឧមា) ហើយប្រតិបត្តិ ("ម" ៥) ដែលកំណត់។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៤)

អ្វីជាហេតុផលឱ្យធ្វើអំពើយ៉ាងនេះ ឆ្លើយតាមលក្ខខណ្ឌធម្មតាគឺ ព្រោះការប្រឫកប្របល់ និងការមិនសមរម្យក្នុងការរាប់អាន ក្នុងគ្រាដែលសាសនាមានវិបត្តិក្នុងជម្លោះទ្វីបនីងកំណត់ថាអ្វីជាពុទ្ធិ អ្វីជាហិណ្ឌូក៏កំណត់មិនបាន នៅសល់តែភាពលាមកអនាចារ។ ពុទ្ធសាសនិកជនពួកខ្លះក្នុងសម័យនោះ ព្រមទទួលយកភាគខ្លះរបស់តន្ត្រៈផ្សំគ្នា រហូតដល់មានពុទ្ធតន្ត្រៈកើតឡើងរីកសាយចូលទៅនៅក្នុង និកាយលាមៈរបស់ទីបេត៍មួយផ្នែកយ៉ាងធំ ហើយក៏ព្រោះមកពីការប្រតិបត្តិនេះបានធ្វើឱ្យពុទ្ធសាសនាអន់ថយអំពីឥណ្ឌាទៅផងដែរ។

បើឆ្លើយម្យ៉ាងទៀតក៏បាន គឺហេតុដែលត្រូវធ្វើលាមកអនាចារដល់ថ្នាក់នេះ មានអធិប្បាយរបស់ខាង ផ្នែកតន្ត្រៈថា មនុស្សយើងមានរាគៈ ទោសៈនិងមោហៈជាមួយកិលេសនៅក្នុងខ្លួន បើត្រូវការរំលត់កិលេសទាំងនេះ ត្រូវតែប្រព្រឹត្តយ៉ាងនោះឱ្យពោរពេញតាមការពេញចិត្តចង់ធ្វើនូវអំពើអ្វីធ្វើនូវអំពើនោះពេញទី ទំនងដូចជាបន្លាមុតត្រូវយកបន្លាជោះ ទីបំផុតក៏អាចកើតនិព្វានបាន ដោយការនឿយណាយទៅឯកជន។

### ខ.ប្រតិបត្តិរបស់ហិណ្ឌូបច្ចុប្បន្ន

ហិណ្ឌូក្នុងសម័យតមក ទាំងហិណ្ឌូអ្នកនៅផ្ទះនិងហិណ្ឌូអ្នកនៅព្រៃ គឺហិណ្ឌូអ្នកគ្រប់គ្រងផ្ទះ ហើយនិងហិណ្ឌូអ្នកលះបង់គេហដ្ឋាន ចេញទៅបំពេញព្រះព្រហ្មចារ្យនៅរឹងមាំក្នុងលទ្ធិភក្តិ (ចំពោះទេពជាម្ចាស់) និង ពិធីកម្មមានបែបយ៉ាងផ្សេងៗគ្នាតាមបែបរបស់ហិណ្ឌូមានផ្នែកដែលគួរសិក្សាឱ្យឃើញជារយៈក្រោយមកនៅជាច្រើនប្រការ។(ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៥)

កាលសម័យព្រាហ្មណៈ មានគម្ពីរអារណ្យកៈជាខបង្គាប់ឱ្យព្រាហ្មណ៍ប្រតិបត្តិខ្លួនតាមគោលរបស់អាស្រមទាំង៤គឺ ព្រហ្មចារីយ៍គ្រហស្ថវានបរស្ថនិងសន្យាសី តាមដែលពោល

មកហើយ យ៉ាងណាមិញរហូតដល់ពេលបច្ចុប្បន្ន ការប្រតិបត្តិដូចេះនៅតែគង់វង្សមួយផ្នែក និងមួយផ្នែកទៀតបន្ថែមចូលមកជាខប្រតិបត្តិយ៉ាងតឹងរ៉ឹងបំផុតដូចគ្នា។

ហិណ្ឌូក្នុងបច្ចុប្បន្នកំណត់បុគ្គលនឹងទៅជាហិណ្ឌូបានដោយអង្គប្រកបដ៏សំខាន់ពីរយ៉ាងគឺ ត្រកូលកំណើតត្រឹមត្រូវនឹងខបដិបត្តិមិនភ្លាំងភ្លាត់។

ត្រកូលកំណើតកំណត់បុគ្គល ដែលកើតក្នុងត្រកូលរបស់ព្រាហ្មណ៍ក្សត្រិយ៍ និងពេស្យ លើកលែងតែ បុគ្គលដែលកើតក្នុងត្រកូលទាបជាងនេះ ទើបអាចថាកើតមកក្នុង ជាតិត្រកូលដែលគួនឹងហិណ្ឌូបានមានន័យថានឹងធ្វើកិច្ចពិធីគឺប្រតិបត្តិការណាតាមលទ្ធិហិណ្ឌូដែលកំណត់ទុកក្នុងគម្ពីរមនុសាស្ត្រទើបបាន។

ចំណែកបដិបត្តិនោះ តាមគម្ពីរដូចបានពោលមកហើយ កំណត់ទុកផ្សេងគ្នាជាពិធីដែលហិណ្ឌូគប្បីបដិបត្តិជាប្រចាំដាច់មិនបាន បើមានដាច់បែបណានីមួយនោះក៏មិនមែនជាហិណ្ឌូដែរ។

មួយទៀតតាមដែលសម្តែងមកពីខាងដើម ជំនឿរបស់មនុស្សដែលនឹងជាហិណ្ឌូពិតប្រាកដ គឺមានជំនឿថា លោកត្រូវមានព្រាហ្មណ៍ ត្រូវមានគម្ពីរព្រះវេទ និងមានវណ្ណៈ៤ពួកទើបអាចទៅជាជំនឿរបស់ហិណ្ឌូពិតប្រាកដមកក្នុងជនក្រោយជំនឿ នេះក៏មិនចាំបាច់ តែការចាំបាច់នោះនៅក្នុងខប្រតិបត្តិដូច្នេះ សូមសម្តែងពីខប្រតិបត្តិរបស់ហិណ្ឌូ ដែលឃើញមានក្នុងបច្ចុប្បន្នតាមការគួរ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៦)

ខប្រតិបត្តិរបស់ហិណ្ឌូនៅគ្រប់គ្រងផ្ទះប្រកបដោយអង្គ ៤ គឺ ៖

១-ការរៀបអាពាហ៍ពិពាហ៍ អាហារ ការបរិភោគ ការចិញ្ចឹមជីវិត និងការស្នាក់អាស្រ័យ ជាអាទិ៍ការរៀបអាពាហ៍ពិពាហ៍ឱ្យត្រឹមត្រូវតាមគោត្រនាម តាមត្រកូល តាមវណ្ណៈមិនអាចលាយឡំប្រឡូកប្រឡល់គ្នាបាន។ រឿងអាហារ ការបរិភោគ មនុស្សក្នុងវណ្ណៈទាបមិនអាចធ្វើឱ្យមនុស្សក្នុងវណ្ណៈខ្ពស់បរិភោគបានទេ អ្នកមានវណ្ណៈផ្សេងមិនអាចបរិភោគជាមួយគ្នាបានឡើយ មិនអាចប៉ះពាល់អាហារនោះដែរ។ ការចិញ្ចឹមជីវិតក៏ដូចគ្នា អ្នកណានៅក្នុងវណ្ណៈណា ត្រូវធ្វើការចិញ្ចឹមជីវិតយ៉ាងនោះ រហូតដល់គេហដ្ឋាន ផ្ទះសម្បែងក៏ដូចគ្នា មិនអាចនរណាបដិបត្តិភ្លាំងភ្លាត់បានឡើយ ត្រូវកាត់ផ្តាច់ចេញពីត្រកូល។

២-ខប្រតិបត្តិសង្ស្ការគឺខប្រតិបត្តិរបស់បុគ្គលអ្នកជាទ្វិជាតិ ឬទ្វេជាតិ (កើត២ដង) បានដល់ព្រាហ្មណ៍ ក្សត្រិយ៍ ពេស្យ ត្រូវប្រតិបត្តិពិធីសង្ស្ការគឺ ៖

ក. ពិធីតាំងគភ៌ អំពីថ្ងៃវិវាហ៍ (គភ៌ាធាន)។

ខ. ពិធីធ្វើចំពោះទារកក្នុងផ្ទៃ កាលណាបើយល់ថាជាប្រុស ប្រមាណ៣ខែក្រោយពីរៀបការហើយ (បុំសវន)។

គ. ពិធីបំបែកសក់ស្រី (មាតា) អ្នកមានគភ៌ក្នុងរយៈ៤ខែ ៦ខែ ឬ៨ខែខ្លះ (សីមន្តោនយ័ន)។

ឃ. ពិធីប្រសូតបុត្រ (ជាតកម្ម)។

ង. ពិធីតាំងឈ្មោះក្មេង (នាមកម្ម) ក្នុងថ្ងៃទី១២ ឬទី១៤ ក្រោយពីការសម្រាលរួចហើយ។

ច. ពិធីនាំក្មេងចេញទៅមើលព្រះអាទិត្យនៅពេលអរុណរះ កាលណាក្មេងអាយុបាន៤ខែ (និសកម្ម)។

ឆ. ពិធីបញ្ចុកបាយក្មេង ក្នុងខែទី៤ ឬទី៦ (អន្នបរាស័ន)។

ជ. ពិធីកោរសក់ទុកជុក (ចូឌកម្ម) ៣ឆ្នាំ ក្រោយពីសម្រាលរួច។

ឈ. ពិធីកាត់សក់ បើជាព្រាហ្មណ៍កាត់កាលណាអាយុគ្រប់១៦ ក្សត្រិយ៍ កាត់កាលណាអាយុ ២២ ពេស្យ កាត់កាលណាអាយុ២៤ (កេសាន្តកម្ម)។

ញ. ពិធីចូលអាស្រម (ឱ្យបានយ័នដូចបានពោលពីដើម)។

ដ. ពិធីត្រឡប់មកផ្ទះ កាលណាសម្រេចការសិក្សាហើយ (សមាវត្តន) (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៧)

ឋ. ពិធីមង្គលការ (វិវាហកម្ម)

ក្នុងបច្ចុប្បន្ននៅដល់តែ ខ.ង.ឆ.ញ និង ដ។

៣- ខប្រតិបត្តិទក្ខិណានុប្បទាន គឺពិធីរបស់អ្នកមានសទ្ធាបានដល់ពិធីពលីជូនដល់ដួងវិញ្ញាណរបស់បុព្វបុរស (Ancestor Worship) ពិធីនេះកាន់តឹងរ៉ឹងណាស់ ទោះបីខ្វះខាតអ្វីក៏ដោយ តែមិនអាចខ្វះពិធីនេះបានឡើយ។

ការបូជាបុព្វបុរសគឺការសែនព្រេនដួងវិញ្ញាណរបស់លោកដោយបំនូតបាយ(បិណ្ឌៈ) អ្នកធ្វើពិធី ទក្ខិណានុប្បទាន គួរដល់កូនប្រុស ព្រោះនឹងជួយបុព្វបុរស មានមាតាបិតាជាដើមឱ្យផុតនរកអន្ទង់បុត្តៈ។ ទក្ខិណានុប្បទានដំបូងធ្វើមុនពេលយកសពទៅបូជា ធ្វើរហូតដល់ទៅ ១០ ថ្ងៃ តាំងតែពីថ្ងៃស្លាប់រហូតដល់ថ្ងៃទី ១១ ធ្វើដោយពិធីការរួបរួមញាតិ ដោយញាតិខាង

ផ្នែកឪពុកនិងញាតិខាងផ្នែកម្ដាយឡើងទៅ៣ជួរ និងចុះមកទៀត៣ជួរដែរ ទក្ខិណានុប្បទាន ទាំងនេះនឹងត្រូវប្រតិបត្តិធ្វើមួយខែម្ដងយ៉ាងតិចក្នុងមួយឆ្នាំ។

នៅមានពិធីទក្ខិណានុប្បទានប្រភេទផ្សេងៗ ធ្វើទាក់ទងនឹងមង្គលជាច្រើនទៀត មាន ជាអាទិ៍ ការធ្វើដើម្បីសុំកូន ធ្វើសុំជាសិរីសួស្ដីក្នុងការធ្វើដំណើរ និងដើម្បីឱ្យចម្រើនដល់ទ្រព្យ ជាដើម។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៨)

៤- ខប្រតិបត្តិទាក់ទងនឹងការបូជាទេវតា (Worship of gods) ខប្រតិបត្តិនេះ ដែលជា មូលហេតុសម្ព័ន្ធជាមួយនឹងការបូជាបុព្វបុរស ក្នុងលទ្ធិរបស់ជនជាតិផ្សេងៗដោយហេតុថា ហិណ្ឌូមានទេពជាម្ចាស់ដ៏ច្រើនសន្ធឹកសន្ធាប់ ចំនួនទេវតាបូជាលើសលប់នឹងគណនា មិនបាន ថែមទាំងប្រជាជាតិហិណ្ឌូដែលនៅក្នុងវណ្ណៈទាប ត្រូវគាបសង្កត់មិនអាចរាប់អានពួកទេវតា ក្នុងវណ្ណៈខ្ពស់បាន ទើបសាងទេវតារបស់ខ្លួនឡើងដើម្បីទុកបូជាតាមទំនើងចិត្តខ្លួន មានទេព ប្រចាំទេវាល័យនិងទេពប្រចាំភូមិស្រុក ប្រចាំគ្រួសារ រហូតទាល់តែមិនអាចជាយុត្តិធម៌បាន។

ជំនឿរបស់ហិណ្ឌូបច្ចុប្បន្នទាក់ទងនឹងការបូជាទេវតា នឹងពិពណ៌នាឱ្យឃើញពីជាភាព ប្រឡាក់ប្រឡូកអស់លក្ខណៈល្អជាអាទិ៍ ហិណ្ឌូនៅក្នុងវណ្ណៈខ្ពស់នាំគ្នាបូជាទេពជំនាន់ចាស់ មានទេពជាម្ចាស់ព្រះវិស្ណុ និងសិវៈ ជាដើម។ លុះមានលទ្ធិអវតារឡើងមានការបូជាព្រះក្រិស្ណៈ និងព្រះរាមឡើងទៀត ឯទេពម្ចាស់ហិណ្ឌូរបស់អ្នកនៅក្នុងវណ្ណៈទាប មានទេពបែកខ្ញែកចេញ ទៅតាមវណ្ណៈទៀតជាច្រើន ដូចជាព្រះម៉ែកាឡី ទេពស្វា ទេពពស់ ទេពអណ្ដើក ទេពរុក្ខ ទេព ដំរី លិង្គទេព ទេពកំណត់ភេទរបស់ស្រីថ្មភ្នំនិងទេវតាផ្សេងៗ គ្នាតាមភូមិ ទេវតា តូចធំ ហើយ និងភូមិស្រុកទាំងឡាយ ទាំងជាភាពគួរឱ្យស្អប់ខ្ពើម គួរឱ្យខ្លាច មិនគួរឱ្យក្រាប សំពះនិងខ្លះ មានភាពលាមកអនាចារប្រួមនៅជាមួយផង មិនថាទីណាៗឡើយ។

### គោលការណ៍ល្អបំផុត

ក្នុងទីនេះនឹងពិពណ៌នាដល់ថ្នាក់កំពូលនៃការប្រតិបត្តិធម៌ ដើម្បីសេចក្ដីខ្ពង់ខ្ពស់ (Summum bonum) ទាំងនៅក្នុងចំណែករបស់សាសនាព្រាហ្មណ៍ (ព្រាហ្មណ៍ចាស់) និង ចំណែកហិណ្ឌូ (ព្រាហ្មណ៍ថ្មី) ទុកក្នុងឱកាសជាមួយគ្នា នាវគ្គចុងក្រោយបង្អស់ តាមផ្លូវនៃការ ប្រតិបត្តិធម៌របស់ជនជាតិអារ្យក (ទាំងចាស់ ទាំងថ្មី) អ្នកប្រតិបត្តិធម៌ក្នុងសាសនាទាំងពីរ ដូចគ្នា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ៩៩)

សេចក្តីល្អខ្ពស់បំផុតរបស់ជនជាតិអារ្យកនេះ គឺការនាំអត្ម័នរបស់ខ្លួនចូលទៅកាន់បរមាត្ម័ន ជាមូលដ្ឋានដើម ដើម្បីប្រតិបត្តិធម៌ណាៗឱ្យវិញ្ញាណរបស់ខ្លួនចូលរួមនៅជាមួយបឋមវិញ្ញាណ ហៅថាការចូលទៅដល់មោក្ស: គឺការរួចផុតពីសង្សារវដ្តនៃជីវិត។

ការដំណើរជីវិតឱ្យចូលដល់នូវសេចក្តីខ្ពស់បំផុតគឺមោក្ស:នោះ ប្រព្រឹត្តទៅតាមគោលប្រតិបត្តិ ៤ (មើលគោលអាស្រម៤ ដែលពោលពីខាងដើម) ប្រកបដោយអង្គនៃការបំពេញព្យាយាមដុតកម្តៅកិលេសឱ្យសូន្យអស់ទៅក្នុងលំទីបំផុតនៃជីវិតគឺ លំដាប់សន្យាសី (អ្នកលះបង់ផ្ទះសម្បែងចេញបំពេញព្រតក្នុងព្រៃ។

សន្យាសី អ្នកនៅក្នុងព្រៃមានគោលប្រតិបត្តិដើម្បីសេចក្តីល្អខ្ពស់បំផុតនៃជីវិត (Summum bonum) គឺការចូលដល់នូវមោក្ស: អ្នកប្រាជ្ញកំណត់ទុក ៤ ផ្លូវប្រកបគ្នាគឺ ៖

កម្មមគ្គ (កម្មយោគ)

ជយាមគ្គ (ជយានយោគ:)

គក្តីមគ្គ (ភក្តិយោគ:)

រាជមគ្គ (រាជយោគ:)

កម្មមគ្គ ឬ កម្មយោគ: អ្នកប្រតិបត្តិហៅកម្មគោយិន កំណត់ថាកម្មជារបស់សំខាន់ទីបំផុតនៃជីវិត ជីវ:របស់មនុស្សម្នាក់ៗសុទ្ធតែវិលកើតវិលស្លាប់ កប់ប្រសព្វសេចក្តីសុខ កប់ប្រសព្វសេចក្តីទុក្ខ ដោយអាស្រ័យកម្លាំងកម្ម គប្បីពិចារណាថាកម្មណាជាហេតុឱ្យវិលវល់កើតស្លាប់ លះបង់នូវកម្មនោះចេញ និងកម្មយ៉ាងណា ដែលជាហេតុឱ្យរួចផុតចេញពីការវិលវល់កើតស្លាប់ (មោក្ស:) ប្រតិបត្តិនៅកម្មនោះដោយប្រើជយាន សេចក្តីច្បាស់និងភក្តីជាគ្រឿងប្រកបក្នុងការប្រកបកម្ម។ (ហេង គឹមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១០០)

ការប្រកបកម្មមាន ២ យ៉ាងគឺ ៖

ប្រកបកម្មដោយការសង្ឃឹមផលតបស្នង (សកាមកម្មយោគ:) តែគប្បីប្រតិបត្តិយ៉ាងត្រឹមត្រូវ និង ប្រកបដោយមិនសង្ឃឹមផលតបស្នងមកវិញ (និសកាមកម្មយោគ:) ប្រតិបត្តិដោយប្រកាន់នាទីជាលក្ខប្រកាន់ថា កើតមកជាមនុស្សក៏គួរប្រតិបត្តិតាមនាទីជាមនុស្ស ហើយនិងប្រតិបត្តិចំពោះរបស់ ព្រមទាំងបុគ្គលទាំងពួង ដោយស្មើភាពគ្នា។

ជយានមគ្គ ឬ ជយានយោគ: អ្នកប្រតិបត្តិហៅថាជយានយោគិន កំណត់ប្រតិបត្តិដោយការដឹងច្បាស់ ការយល់ត្រូវ ដែលជាផលពីការពិចារណាបរិសុទ្ធ មិនសាងទុក្ខវេទនា

ឱ្យដល់ជីវៈណាៗ គិតតែពីការសោធផលប្រយោជន៍ សេចក្តីល្អប្រសើរឱ្យដល់សាធារណជន តែម្យ៉ាង និងញ៉ាំងចំណេះដឹង ការយល់ត្រូវឱ្យមានជាឯកភាព។

ភក្តិមគ្គ ឬ ភក្តិយោគៈ អ្នកប្រតិបត្តិហៅថា ភក្តិយោគិន កំណត់ប្រតិបត្តិដោយការស្រឡាញ់និងភក្តីភាពចំពោះពាក្យប្រៀនប្រដៅរបស់ព្រះជាម្ចាស់ ឬបើនិយាយពីន័យមួយទៀត សំដៅដល់ការព្រមទទួលប្រើកម្ម (អំពើតាមនាទី) ដោយការប្រាកដក្នុងចិត្ត ពោលគឺមានទាំងការយកចិត្តទុកដាក់ និងសេចក្តីស្រឡាញ់ ដោយភក្តីភាពដល់អំពើប្រតិបត្តិចំពោះខ្លួនឯងនិងចំពោះជីវៈទាំងពួង។

ផលនៃការប្រតិបត្តិកំណត់ទុកថា អ្នកមានភក្តីខ្ពង់ខ្ពស់នឹងចូលទៅដល់ព្រាហ្មណ៍។

រាជមគ្គ ឬ រាជយោគៈ អ្នកប្រតិបត្តិហៅថារាជយោគិន ជាផ្លូវប្រតិបត្តិទាក់ទងនឹងការអប់រំផ្លូវចិត្ត បំណងបង្ក្រាប់បញ្ជាចិត្តឱ្យនៅក្នុងអំណាចដោយបំពេញយោគកិរិយា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ទំព័រ១០១)

អ្នកបំពេញយោគ មានអាស្រមជាច្រើននៅក្បែរក្រុងឥសីកេស ជើងភ្នំហិមាល័យ មានអ្នកបួសហិណ្ឌូសម័យថ្មីដែលហៅថា សាធុ តាំងអាស្រមនិងជុំវិសំពត់ ដេក អង្គុយ ឈរ ដើរបំពេញព្យាយាមក្នុងរូបនិងវិធីផ្សេងៗគ្នា ដែលអាក្រាតកាយ មានសម្លៀកបំពាក់តែត្រឹមមួយបន្ទះ អង្គុយធ្មេចភ្នែក ឈរសូត្រពាយមន្ត មានរាងកាយគ្របដណ្តប់ ដោយស្បែក ម្រឹគី និងខ្វះរកស្បែកម្រឹគីតែបន្តិចគ្មានផង។ ដូច្នេះគឺជាខប្រតិបត្តិ និងអ្នកប្រតិបត្តិ ដើម្បីការរួចផុត ដែលគេបានឃើញនៅពេលបច្ចុប្បន្ន។

លទ្ធិប្រតិបត្តិរបស់ជនជាតិឥណ្ឌា អ្នកប្រាជ្ញហិណ្ឌូកំណត់ថា ជាគោលបរមត្ថវិជ្ជានៃលោកនិងជីវិតធម៌ ក្នុងសាសនាហិណ្ឌូហៅថា សនាតនធម៌គឺធម៌ដែលទ្រង់ ទុកនូវការស្ថិតស្ថេរ មិនឱ្យសាបរលាប តាំងនៅជាគូជាមួយលោក ដើម្បីសន្តិដែលលោកប្រាថ្នា។

ក្នុងយុគក្រោយៗអំពើដែលប្រព្រឹត្តមក មានសាសនាចារ្យអ្នកប្រាជ្ញខាងផ្លូវសាសនាប្រកាសកែទម្រង់ សទ្ធា របស់ជនជាតិហិណ្ឌូ (ព្រាហ្មណ៍ថ្មី) ជាក្រុមធំ២ក្រុមទៀត ក្រុមសទ្ធាចូលជាមួយក្រុមសម័យបានដូច្នេះ ៖ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១០២)

ព្រាហ្មសមាជ (BrahamaSmaj) ក្រុមនេះតាំងឡើងកាល គ.ស.១៨២៨ (ព.ស.២៣៧១) មានសេដ្ឋី អ្នកសាសនាម្នាក់ឈ្មោះ លោករាមមោហ័នរ៉យ (Ram MohanRoy) ត្រូវប៉ះទង្គិចចិត្តពិការរុករានរបស់ជនជាតិមូស្លិមនិងត្រូវប៉ះទង្គិចចិត្តជួនគ្នាទៀតពីគណៈផ្សាយសាសនា

គ្រិស្ត ទើបរួមដៃគ្នាជាមួយត្រកូលឋាកូរ ដែលតែងតែហៅថា តះករ៍មានលោកទិវាករនាថ ឋាកូរ អ្នកប្រាជ្ញនិងអ្នកករីធំជនជាតិបង់ហ្គាលតាំងព្រហ្មសុភាត មកផ្លាស់ជាព្រហ្មសមាជ ប្រកាសគោលការណ៍ប្រដៅរបៀបថ្មីរបស់ហិណ្ឌូ ដើម្បីឱ្យសមតាមសម័យដោយមានគោលការណ៍ថា ៖

ហិណ្ឌូមិនមានរូបប្រៀបប្រដូច (បដិមាករ) របស់ទេពអង្គណាមួយជាសកល មានតែសេចក្តីល្អគឺសីល និងធម៌ជាព្រះអម្ចាស់ ឬន័យមួយទៀត ប្រសិនបើមានជំនឿថាមានព្រះជាម្ចាស់ក៏មានត្រឹមតែមួយអង្គ គឺព្រះ ព្រហ្ម (តួបរមាត្ម័ន) ឬធម៌ខ្ពង់ខ្ពស់ជាតួធម៌នោះឯង។

មានខគួរឱ្យសង្កេតពាក្យប្រៀនប្រដៅរបស់ព្រហ្មសមាជមួយបែបពាក្យប្រៀនប្រដៅថា មានព្រះមួយអង្គជាមតិតទល់គ្នា ក្រុមគ្រិស្តនិងក្រុមមូស្លិមដែលប្រដៅថា មានព្រះយេ-ហូវហ្វា ឬព្រះអាឡាហ៍ (អាល្លោះហ៍) មួយអង្គក្នុងសាសនារបស់ខ្លួន។

ក្នុងពេលធ្វើអត្ថាធិប្បាយនេះ ក្រុមព្រហ្មសមាជមានសាខាទូទៅក្នុងប្រទេសឥណ្ឌាមួយម៉ឺនកន្លែង។

អារ្យសមាជ (AryaSmaj) ក្រុមនេះតាំងឡើងកាលគ.ស.១៨៧៥ (ព.ស.២៤១៨) អ្នកប្រាជ្ញឈ្មោះ ជហានន្ទ ស្រាវស្តិ ពិចារណាឃើញថា មនុស្សសម័យថ្មីនាំគ្នាទៅរាប់អានសាសនាគ្រិស្ត ខ្លាចក្រែងទៅជាមានអន្តរាយ ខំព្យាយាមនឹងស្តាបនាហិណ្ឌូទុកមាំមួន ទើបប្រកាសគោលការណ៍ប្រៀនប្រដៅថ្មី (ប្រហែលនឹងព្រហ្មសមាជ) ឱ្យលើកលែងឈប់រាប់អានរូបបដិមាករ ដូចជាទេវផ្សេងៗ កំណត់ឱ្យរាប់អានវត្ថុតែមួយគឺ “កម្ម” របស់ខ្លួន។ ជរាបណាមានកម្មជរាបនោះរមែងមានល្អមានអាក្រក់ បុគ្គលគប្បីប្រកប “អកម្ម” មិនឱ្យមានធ្វើការ រួចផុត ដែលកើតឡើងបាន ព្រោះអកម្មប្រហែលនឹងបរមត្ថវិជ្ជារបស់លោកសង្ការ មើលពីខាងដើម។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១០៣)

ក្រុមអារ្យសមាជប្រកបការសាធារណៈប្រយោជន៍ដើម្បីក្រុមមនុស្សធំៗ ដូចជាបួសក្រុមគ្រិស្ត មានការកសាងសាលារៀន សាងមន្ទីរពេទ្យព្យាបាលរោគ ប្រកបការកុសលឱ្យដល់ក្រុមមនុស្សក្រតោកយ៉ាកជាដើម។

ការបរិភោគក្នុងសាសនាព្រាហ្មណ៍ (ចាស់) និងសាសនាហិណ្ឌូ (ព្រាហ្មណ៍ថ្មី) ដែលមានមកហើយ សម្តែងដោយឧបមេយ្យឧបមាបានថា ក្នុងព្រាហ្មណ៍និងហិណ្ឌូនោះ ប្រៀបដូចជាព្រៃធំពោរពេញទៅដោយព្រៃក្រាស់មានទាំងឈើតូច មានទាំងឈើធំ ឈើមានខ្លឹម ឈើ

មានតែស្រាយ ឈើមានពិស ឈើមិនមានពិស ជារុក្ខជាតិយកធ្វើថ្នាំកែរោគក៏មាន ធ្វើឱ្យកើតរោគក៏មាន មានតម្លៃតិចក៏មាន តម្លៃច្រើនក៏មាន លាយឡំច្របូកច្របល់គ្នាតាំងនៅខ្ពស់ជាពួក ជាក្រុម ពិបាកធ្វើឱ្យបុគ្គលអ្នកដែលមិនស្គាល់រុក្ខជាតិ គ្មានការវៃឆ្លាតមិនអាចនាំយករុក្ខជាតិនោះមកប្រើប្រាស់ជាប្រយោជន៍បាន ខនេះយ៉ាងណាមិញ អ្នកសាសនាដែលមិនឆ្លាតក៏គ្មានសមត្ថភាពកំណត់ជ្រើសរើសនាំព្រាហ្មណ៍និងហិណ្ឌូនោះមកប្រើឱ្យទៅជាប្រយោជន៍ក្នុងការសិក្សារបស់ខ្លួនក៏គ្មានដូចគ្នាយ៉ាងនោះដែរ។(ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ទំព័រ ១០៤)

***ពុទ្ធសាសនា***

ពាក្យបៀនប្រដៅរបស់អ្នកចេះដឹងដែលពិសោធន៍បានពាក្យបរិយាយរឿងព្រះពុទ្ធសាសនា សូមដំណើរសេចក្ដីជាដើមដំបូងដ៏សមគួរដល់ធម៌តាមវិស័យ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១០៥)

***ពុទ្ធសាសនានិងសង្គម***

ព្រះពុទ្ធសាមណគោត្តម ស្ដេចកើតឡើងមកក្នុងមជ្ឈដ្ឋាននៃសង្គមដែលច្របូកច្របល់ដោយអហង្ការ ច្របូលច្របល់ដោយការប្រកាន់ជាន់ថ្នាក់ វណ្ណៈ ការប្រកាន់ជាតិ ប្រកាន់យសស័ក្តិ ប្រកាន់ត្រកូលតាមលទ្ធិព្រាហ្មណ៍ដែលប្រៀនប្រដៅមក ទ្រង់ឃើញមូលហេតុនៃការបែកបាក់របស់សង្គមដែលកើតមកអំពីលទ្ធិនេះ។ លុះទ្រង់បំពេញព្យាយាមបានត្រាស់ដឹងធម៌ជាអរិយហើយ គ្រាដែលចែកចាយធម៌នេះ ទ្រង់ក៏បដិសេធលទ្ធិ ប្រកាន់ជាន់ថ្នាក់ ដែលជាហេតុឱ្យបែកបាក់សង្គម និងជានាសេរីភាពរបស់មនុស្សទាំងឡាយ។

***ព្រះពុទ្ធសម្ដែងថា***

កំណើតជាតិត្រកូល មិនមែនធ្វើឱ្យបុគ្គលជាព្រាហ្មណ៍។

កំណើតជាតិត្រកូល មិនមែនធ្វើឱ្យបុគ្គលជាក្សត្រិយ៍ ជាអ្នកលក់។

សេចក្ដីប្រព្រឹត្តរបស់បុគ្គល ជាគ្រឿងកំណត់បុគ្គល ជាតិត្រកូលមិនបានជាគ្រឿងកំណត់ការបែកផ្សេងគ្នារបស់បុគ្គលនោះឡើយ។

ព្រះពុទ្ធទ្រង់តាំងសង្ឃមណ្ឌលឡើង ជាមណ្ឌលនៃសេចក្ដីស្មើភាគនិងសេរីភាពមនុស្សគ្រប់គ្នាទោះបីកើតក្នុងក្នុងត្រកូលណាក៏ដោយ មកពីត្រកូលព្រាហ្មណ៍ ឬត្រកូលក្សត្រិយ៍ កាលបើចូលមកក្នុងព្រះពុទ្ធសាសនាត្រូវស្មើគ្នាដោយភាវៈទាំងអស់។ មានឧទាហរណ៍មួយព្រះឧបាលីថេរៈអ្នកវិសេសក្នុងព្រះវិន័យ មានអំពីត្រកូលផ្សេងៗដែលខ្ពស់

ជានក៏ដូចគ្នា ព្រះចរិយារបស់ព្រះពុទ្ធត្រង់នេះ អ្នកប្រវត្តិសាស្ត្រព្រមទទួលថាសាមណ គោត្តមជាបុគ្គលដំបូងបង្អស់ក្នុងលោក ដែលប្រកាសរបបសេរីភាព។

មួយទៀត ការដែលបុគ្គលនឹងចងភ្ជាប់មិត្តភក្តិឬសង្គមទុកបាននោះ ត្រូវប្រតិបត្តិធម៌ហៅថាសង្គហវត្ថុ ៤ ប្រការគឺ ៖

ក-**ទាន** មិនកំណាញ់ មិនស្វិតស្វាញ

ខ-**បិយវាចា** និយាយស្តីគួរឱ្យស្រឡាញ់

គ-**អត្ថចរិយា** ធ្វើប្រយោជន៍ឱ្យដល់គ្នា

ឃ-**សមានត្តតា** ធ្វើខ្លួនស្មើគ្នា (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៣៦)

**ព្រះពុទ្ធសាសនានិងស្ត្រី**

ឋានៈរបស់ស្ត្រីក្នុងជម្ពូទ្វីប ជាឋានៈនៃទាសរបស់បុរស ស្ត្រីមិនបានទទួលការស្មើភាគ សង្គមមិនព្រមទទួលសមត្ថភាពរបស់ស្ត្រី ព្រះពុទ្ធជាសាស្តាអង្គដំបូង ដែលទ្រង់លើកតម្កើងសមត្ថភាពរបស់ស្ត្រីឱ្យពួកបុរសឃើញថា ស្ត្រីនោះមានសេចក្តីអង់អាចមិនតិចជាងបុរសឡើយ ព្រះពុទ្ធជាអ្នកជានាស្ត្រីទុកក្នុងពុទ្ធមណ្ឌល ទ្រង់បដិសេធខដែលមានអ្នកចោទប្រកាន់ថា ស្ត្រីមិនអាចបព្វជាឧបសម្ប័ទបាន និងមិនអាចសម្រេចធម៌ពិសេសបាន។

ព្រះពុទ្ធសាសនាលើកតម្កើងឋានៈរបស់ស្ត្រី ដែលជាភរិយាថា ជាមិត្តដ៏ប្រសើរបំផុតរបស់ស្វាមី (ភរិយា បរមាសខា) ដែលស្វាមីមិនគួរប្រតិបត្តិដល់នាងដូចទាសៈ ពុទ្ធសាសនាលើកតម្កើងស្ត្រីគ្រប់គ្នាទុកក្នុងឋានៈជាមាតា គឺជាម្តាយដែលបុរសគប្បីឱ្យការគោរពស្រឡាញ់ដូចជាម្តាយរបស់ខ្លួន។

ក្នុងសង្ឃមណ្ឌល ព្រះពុទ្ធទ្រង់លើកតម្កើងបណ្តាញព្រះភិក្ខុអរហន្តខិណាស្រព ទុកក្នុងតំណែងពិសេស ដោយឋានៈផ្សេងៗគ្នា យ៉ាងណាមិញបណ្តាស្ត្រីអ្នកចូលមកបព្វជាឧបសម្ប័ទជាភិក្ខុណីក្នុងពុទ្ធសាសនា ដែលសម្រេចអភិញ្ញា ជាព្រះអរហន្តខិណាស្រព ក៏បានលើកតម្កើងពីព្រះពុទ្ធជាអ្នកវិសេស ដោយឋានៈផ្សេងៗក៏ដូចគ្នាដែរ។

**ពុទ្ធសាសនានិងជំនឿ**

ព្រះពុទ្ធត្រាស់ទុកក្នុងកាលាមសូត្រថា "ពួកជនកាលាមៈទាំងឡាយ ពួកអ្នកទាំងឡាយកុំជឿហើយប្រកាន់យក ៖ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៣៧)

១-ដោយស្តាប់តាមគ្នាមក ២-ដោយប្រតិបត្តិតគ្នាមក ៣-ដោយឮដំណឹង ៤-ដោយអាងតម្រា ៥-ដោយនឹកដៅខ្លួនឯង ៦-ដោយនឹកស្មានដោយខ្លួនឯង ៧-ដោយគិតយកតាមអាការដែលប្រតិបត្តិទៅ ៨-ដោយចូលចិត្តថាត្រឹមត្រូវតាមលទ្ធិរបស់ខ្លួន ៩-ដោយជឿថាអ្នកនិយាយគួរនឹងជឿបាន ១០-ដោយរាប់អានថា "លោកជាគ្រូអាចារ្យរបស់យើង"។

អត្ថន័យទាំងនេះបើអធិប្បាយតាមគោលការណ៍ពុទ្ធសាសនា ការដែលនឹងជឿអ្វីមួយមិនគួរជឿដោយគ្មានហេតុផល គួរជឿដោយមានហេតុផលគឺជឿដោយបញ្ញា ការចេះដឹងរបស់ខ្លួនឯង។ ក្នុងទីណាពុទ្ធសាសនាប្រដៅរឿងសទ្ធា និងការជឿពុទ្ធសាសនា ក៏ប្រដៅឱ្យមានបញ្ញាត្រួតត្រាទុកនៅទីនោះផងដែរ អ្នករាប់អានពុទ្ធសាសនាទើបជឿថា មានសេរីភាពក្នុងការប្រើជំនឿយ៉ាងពេញទី ពុទ្ធសាសនាមិននិយមការបង្ខាប់ឱ្យជឿ មិននិយមការបោកបញ្ឆោតឱ្យជឿក្នុងរបស់ទាំងឡាយ។

**ពុទ្ធសាសនិកនិងការពឹងខ្លួនឯង**

គោលការណ៍ទីពឹងខ្លួនឯង គឺការបដិសេធមិនព្រមពឹងរបស់ទាំងឡាយផ្សេងទៀត បដិសេធការអង្វកររបស់ផ្សេងៗ មានពាក្យប្រដៅក្នុងមហាបរិនិព្វានសូត្រផ្សេងៗថា "ភិក្ខុទាំងឡាយ ពួកអ្នកចូរមានខ្លួនជាទីពឹង កុំយករបស់ផ្សេងជាទីពឹងឡើយ ចូរមានធម៌ជាទីពឹង ចុះកុំមានរបស់ផ្សេងជាទីពឹងឡើយ"។

មានសេចក្តីមួយទៀត ប្រាកដក្នុងអានាថបិណ្ឌិកសូត្រថា "គហបតីអ្នកគ្រប់គ្រងផ្ទះ យើងតថាគតមិនបានពោលថា អាយុ ពណ៌សម្បុរ យស សុខ និងសួគ៌នឹងសម្រេចបាន ព្រោះហេតុសេចក្តីអង្វករសេចក្តីប្រាថ្នានោះឡើយ គហបតីអ្នកមានផ្ទះ បើប្រាថ្នារបស់ទាំងនេះ មិនគួរអង្វករ តែគួរប្រតិបត្តិធម៌ដើម្បីឱ្យរបស់ទាំងនេះកើតឡើងវិញ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៣៨)

មានសេចក្តីក្នុងព្រះពុទ្ធសាសនាទៀតជាច្រើនវគ្គប្រដៅថា សេចក្តីបរិសុទ្ធឬមិនបរិសុទ្ធជារបស់ខ្លួន អ្នកដទៃមិនអាចជួយបាន មនុស្សទាំងឡាយមិនគួរនឹងអង្វរករ ដើមឈើ ភ្នំ ដួងតារា និងរបស់ណាៗឡើយ ព្រោះរបស់ទាំងនោះហើយជាទីពឹងរបស់ខ្លួន អ្នកដទៃទោះបីជាអ្នកណាក្តី មិនអាចជាទីពឹងបានឡើយ។

**ពុទ្ធសាសនានិងរឿងឫក្សយាម**

រឿងឫក្សយាម ពុទ្ធសាសនាបដិសេធរឿងតារាសាស្ត្រនិងហោរាសាស្ត្រផង ព្រះពុទ្ធទ្រង់ត្រាស់ថា "អ្នកណាយកចិត្តទុកដាក់ នៅតែកាន់ឫក្សយាម ប្រយោជន៍នឹងធ្លងផុតពីមនុស្សល្ងង់ខ្លៅនោះចេញ ប្រយោជន៍នោះឯងជាឫក្សរបស់ប្រយោជន៍ ដួងតារានឹងធ្វើអ្វីឱ្យយើងបាន។

ពាក្យប្រដៅនេះ សម្ដែងថាការធ្វើសេចក្ដីល្អមិនថាពេលណាៗជាឫក្សល្អនិងជារឿងល្អទាំងអស់ តែបើសេចក្ដីអាក្រក់មិនថាជាធ្វើក្នុងពេលណាៗក៏ជាឫក្សអាក្រក់ និងជារឿងអាក្រក់ទាំងអស់។

**ពុទ្ធសាសនានិងការលាងបាប**

លទ្ធិព្រាហ្មណ៍និយមថា អ្នកមានបាបត្រូវការលាងបាប ទៅជម្រះបាបចេញក្នុងទន្លេគង្គានិងទន្លេដែលស័ក្ដិសិទ្ធិ តែក្នុងពុទ្ធសាសនា ព្រះពុទ្ធបដិសេធរឿងការលាងបាបក្នុងការបណ្ដេតបាប។

សេចក្ដីមានប្រាកដជាពុទ្ធឱវាទក្នុងវត្ថុបមសូត្រថា "មនុស្សពាលធ្វើសេចក្ដីអាក្រក់ទោះបីទៅកាន់ទន្លេណាក្ដី ក៏មិនអាចបរិសុទ្ធឡើងបានដែរ ទន្លេទាំងនោះនឹងជួយអ្វីបានដល់អ្នកដែលធ្វើបាបកម្ម មានតែការរក្សាសីល ការប្រព្រឹត្តល្អរមែងធ្វើឱ្យបុគ្គលបរិសុទ្ធ។ ម្នាលព្រាហ្មណ៍ លោកចូលងូតខ្លួនអ្នកដោយធម៌វិន័យនេះ បើអ្នកមិននិយាយកុហក មិនបៀតបៀនសត្វ មិនធ្វើចោរ មានជំនឿជឿតាមហេតុផល មិនកំណាញ់ស្វិតស្វាញ អ្នកមិនត្រូវទៅកាន់ទន្លេណាមួយទេ"។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៣៥)

អធិប្បាយត្រង់នេះសម្ដែងថា សេចក្ដីល្អអាក្រក់ទាំងឡាយរបស់បុគ្គល មិនមែននៅត្រង់ការស្អាតខាងក្រៅនោះទេ គឺនៅត្រង់ការប្រព្រឹត្តខាងក្នុង បើជឿថាទន្លេអាចលាងបាបបានមែនពិត សត្វទឹកទាំងឡាយដែលនៅក្នុងទឹកនោះគង់នឹងមានឱកាសបរិសុទ្ធជាជាងមនុស្សទៅទៀត ព្រោះបាននៅងូតទឹកនេះរហូតមួយជីវិត។

**ពុទ្ធសាសនានិងគោលកម្ម**

ពុទ្ធសាសនាប្រដៅគោលកម្មថា កម្មជាគ្រឿងបណ្ដាល កម្មជាគ្រឿងសាងរបស់គ្រប់យ៉ាង កម្មគឺជាអំពើដែលធ្វើ ធ្វើទុកយ៉ាងណារមែងកើតផលនៃការធ្វើដូច្នោះ ដូចជាអ្នកស្រែព្រួសពូជយ៉ាងណា រមែងបានទទួលផលនៃការព្រួសពូជទាំងនោះដូច្នោះ។

មានប្រាកដសេចក្តីក្នុងអភិណ្ហបច្ចវេក្ខណសូត្រថា "ស្រីប្រុស គ្រហស្ថ បព្វជិតគួរពិចារណាជានិច្ចថា យើងមានកម្មជានិច្ចថា យើងមានកម្មជារបស់ខ្លួន ជាអ្នកទទួលផលរបស់កម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីអាស្រ័យ យើងធ្វើកម្មណាទុកល្អក្តីអាក្រក់ក្តី យើងនឹងបានទទួលផលរបស់កម្មនោះ"។

សេចក្តីមួយទៀតប្រាកដក្នុងវាសេដ្ឋសូត្រថា ៖

បុគ្គលមិនបានទៅជាមនុស្សអាក្រក់ មិនបានទៅជាមនុស្សល្អ ព្រោះជាតិគឺកើតមកពីអំពើដែលធ្វើ បុគ្គលជាអ្នកស្រែ ជាសិល្បៈ ជាអ្នកជំនួញ ជាមនុស្សបម្រើ ជាចោរ ជាទាហាន ជាអ្នកបូជាយញ្ញ ជាព្រះរាជា ក៏ព្រោះអំពើដែលធ្វើ លោកប្រព្រឹត្តទៅដោយកម្ម សត្វទាំងឡាយជាប់ចំណងទៅនឹងកម្មដូចជុំរទេះជាគ្រឿងធ្វើឱ្យរទេះវិលទៅបានដូច្នោះ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤០)

ដើម្បីសម្តែងផលនៃកម្ម សូមលើកយកសេចក្តីក្នុងចូឡកម្មវិភង្គសូត្រ ដែលព្រះពុទ្ធត្រាស់ថា ៖

១-អ្នកមានអាយុខ្លី ព្រោះជាអ្នកសម្លាប់សត្វ អ្នកមានអាយុវែងព្រោះមិនមែនជាអ្នកសម្លាប់សត្វ។

២-អ្នកមានរោគតិច ព្រោះជាអ្នកមិនបៀតបៀនសត្វ អ្នកមានរោគច្រើនព្រោះជាអ្នកបៀតបៀនសត្វ។

៣-អ្នកមានរូបរាងមិនស្អាត មានសម្បុរមិនស្រស់ ព្រោះជាមនុស្សខឹងច្រើន ព្យាបាទគេ អ្នកមាន រូបរាងស្អាត មានសម្បុរស្រស់ព្រោះជាមនុស្សមិនខឹងសម្បារ មិន ព្យាបាទគេ។

៤-អ្នកមានយសស័ក្តិទាប ព្រោះចូលចិត្តឥច្ឆាប្រស្សាអ្នកដទៃ អ្នកមានយសស័ក្តិខ្ពស់ព្រោះមិនចូលចិត្ត ឥច្ឆាប្រស្សាអ្នកដទៃ។

៥-អ្នកក្រីក្រ ព្រោះមិនជួយសង្គ្រោះគេ អ្នកមានព្រោះជួយសង្គ្រោះគេ។

៦-អ្នកកើតក្នុងត្រកូលទាប ព្រោះជាអ្នករឹងត្អឹង ប្រកាន់ខ្លួន មិនចេះឱនលំទោន។

៧-អ្នកមានបញ្ញាអន់ខ្សោយ ព្រោះមិនចេះសាកសួរ មិនស្វែងរកចំណេះដឹង អ្នកមានបញ្ញាច្រើន ព្រោះ ចេះសាកសួរ ចេះដេញដោលស្វែងរកចំណេះដឹង។

**ពុទ្ធសាសនានិងការកើតថ្មី**

ពុទ្ធសាសនាប្រដៅរឿងកំណើតរបស់សត្វថាមាន ៤ បែបគឺ ៖

ក. ជលាពុជ: ពួកដែលកើតចេញមកជាខ្លួនដូចមនុស្ស ឬសត្វប្រភេទខ្លះ។

ខ. អណ្ឌជ: ពួកដែលកើតចេញមកជាពងហើយមកញាស់នៅខាងក្រៅ ទើបចេញខ្លួនដូចជាក្អែក មាន់ សត្វស្លាបជាដើម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ១៤១)

គ. ស្ដាសេទជ: ពួកដែលកើតឡើងក្នុងទីស្មោគគ្រោកអាប់អួរដូចជាសង្កើច មេរោគផ្សេងៗ។

ឃ. ឧប្បាតិក: ពួកកើតជាខ្លួនប្រាណដោយបរិបូណ៌មួយរំពេច មិនបានចេញជាពង ឬចេញពីគភ៌របស់មាតា មិនពិបាកអាស្រ័យឪពុកម្ដាយជាអ្នកឱ្យកំណើត ពេលស្លាប់ក៏ស្លាប់សូន្យទៅ បានដល់ពួកមានកាយទិព្វ ដូចប្រេត នរកពួកខ្លះ និងពួកទេវតា។

ការកើតគ្រប់បែប កើតអំពីកម្លាំងកម្ម ពុទ្ធសាសនាទទួលស្គាល់អំណាចរបស់កម្ម និងព្រោះតែរ៉ាប់រងកម្ម ដូច្នោះហើយទើបទទួលរាប់រងពីការវិលវល់របស់ជីវិតថា មានការកើតថ្មី វិលវល់កើតស្លាប់ ជាវដ្តសង្សារហូតទៅមានប្រាកដក្នុងសំយុត្តនិកាយថា ៖

“អវិជ្ជា សេចក្ដីល្ងង់ខ្លៅឬមិនដឹងក្នុងសច្ចៈធម៌ ជាបច្ច័យព្រោះហេតុនៃអវិជ្ជាតែមួយនោះ ជីវិតទើបវិលវល់ ដូច្នេះអវិជ្ជាជាបច្ច័យទើបកើតវិញ្ញាណ វិញ្ញាណជាបច្ច័យឱ្យកើតផស្ស: ផស្សៈជាបច្ច័យឱ្យកើតវេទនា វេទនាជាបច្ច័យឱ្យកើតតណ្ហា តណ្ហាជាបច្ច័យឱ្យកើតឧបាទាន ឧបាទានជាបច្ច័យទើបកើតភព ភពជាបច្ច័យឱ្យកើតជាតិ ជាតិជាបច្ច័យឱ្យកើតជរា មរណៈនិងសោកៈ បរិទេវៈ ទុក្ខទោមនស្សឧបាយាស”។

ដោយអធិប្បាយត្រឡប់ចុះឡើង រាប់ជាមណ្ឌលត្រឡប់ចុះត្រឡប់ឡើងនៃជីវិត បានជារូបទើបមានជរា មរណៈ ព្រោះមានជាតិ ជាតិមានព្រោះភព ភពមានព្រោះឧបទាន ដោយន័យដូច្នេះជាអាទិ៍ ៖

កាលបើប្រៀនប្រដៅពីការវិលវល់នៃជីវិត ដូចបានពោលមកពីខាងដើម ទើបទ្រង់ប្រៀនប្រដៅទទួលរាប់រងសេចក្ដីថា លោកដទៃមានទៀតដើម្បីទទួលការកើតថ្មីនៃដួងវិញ្ញាណ “កំណាត់ឈើដែលគេវែងទៅលើអាកាស តែងតែធ្លាក់ចុះមកវិញ ដោយមានគល់ធ្លាក់ចុះមកមុនខ្លះ យកចុងមកមុនខ្លះ យ៉ាងណាមិញសត្វទាំងឡាយដែលមានអវិជ្ជាជានិវរណមាន តណ្ហាជាគ្រឿងប្រកប រមែងត្រាច់រង្គាត់វិលកើត វិលស្លាប់ មិនចេះចប់ មិនចេះហើយគ្រា ខ្លះស្លាប់ពីលោកនេះទៅកាន់លោកដទៃ គ្រាខ្លះក៏ស្លាប់ពីលោកដទៃមកកាន់លោកនេះ

ដែល ជា (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤២) ដូច្នេះ ព្រោះមិនឃើញច្បាស់ក្នុង អរិយសច្ច ៤”។

បញ្ហាថាអ្វីទៅកើត ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ក្នុងមហាបរិទានសូត្រ មានសេចក្តីថា “ដួងវិញ្ញាណទៅកើត ដួងវិញ្ញាណនេះជាបច្ច័យឱ្យកើតនាមនិងរូប (កាយ និង ចិត្ត) បើដួងវិញ្ញាណមិនឈានចុះទៅកាន់គភ៌មាតាទេ នាមនិងរូប (កាយនិងចិត្ត) មិនអាច តាំងឡើងក្នុងពោះមាតាបានឡើយ ហើយកាលបើដួងវិញ្ញាណមិនអាស្រ័យនៅក្នុងនាមរូប ការកើតចាស់ឈឺស្លាប់ ការវិលវល់នៅក្នុងអន្ទាក់ទុក្ខក៏មិនអាចប្រាកដបានដូចគ្នា។

វិញ្ញាណដែលកើតមានទាំងនោះ ប្រព្រឹត្តទៅដោយកម្លាំងកម្ម លោកប្រៀបទុកថា កម្ម នោះដូចផ្ទៃដី ស្រែ វិញ្ញាណដូចជាគ្រាប់ពូជ តណ្ហានិងកិលេសប្រៀបដូចជាជ័រក្នុងគ្រាប់ ពូជ បើតណ្ហាមិនមាន គឺអស់ជ័រក្នុងគ្រាប់ពូជ ហើយគ្រាប់ពូជដែលគ្មានជ័រ មិនអាចដុះបាន ឡើយ ខនេះយ៉ាងណាមិញ អាចសរុបសេចក្តីបានថា តណ្ហានិងកិលេសនោះៗដែលមាន ឫសគល់៣ យ៉ាងគឺ លោភៈ ទោសៈ មោហៈ ជាហេតុកើតឡើងរបស់កម្មនោះឯង ឯអំណាច របស់កម្មនឹង ឱ្យផលយ៉ាងណា បានសម្តែងមកហើយពីខាងដើម។ (ហេង គីមហោ *សាសនាប្រៀប ធៀប* ភាគ១ ទំព័រ ១៤៣)

### ពុទ្ធសាសនានិងគោលការណ៍អនត្តា

រឿងការប្រកាន់ថារបស់ទាំងឡាយជារបស់ខ្លួន (អាត្ម័ន) តាមលទ្ធិព្រាហ្មណ៍ ព្រះពុទ្ធ ទ្រង់បានបំបែកចេញដោយជ្រះស្រឡះ ទ្រង់អធិប្បាយថា របស់ដែលហៅថាខ្លួនប្រាណយើង គេនោះគឺគ្រាន់តែជាការសន្មត ¬Conditional Truth) ទាំងអស់សូម្បីពាក្យប្រៀនប្រដៅឱ្យខ្លួន ជាទីពឹងខ្លួន ក៏មិនឱ្យប្រកាន់អ្វីជាទីតាំងដែរ មិនឱ្យប្រកាន់យកជាការពិត ជាមែន ព្រោះថា របស់នោះៗឬខ្លួននោះ ក្នុងទីបំផុតក៏បែកធ្លាយទៅតាមធាតុដើមរបស់វា ទោះបីជារាងកាយ ឬ ចិត្ត ក៏មានការប្រែផ្លាស់រលាយទៅ កើតហើយរលត់ទៅវិញជានិច្ច មិនមែនមានការគង់វង្ស នៅបានឡើយ។

ក្នុងទុតិយទេសនា គឺអនត្តលក្ខណសូត្រ ដែលទ្រង់សម្តែងចំពោះភិក្ខុបញ្ចវគ្គីយ៍ ទ្រង់ បដិសេធអនត្តាទុកជាសេចក្តីថា ៖

“រូប (រាងកាយ) វេទនា (ការដឹងសុខទុក្ខ មិនសុខមិនទុក្ខ) សញ្ញា (ការចាំ) សង្ខារ (ការគិត) វិញ្ញាណ (ការដឹងអារម្មណ៍ ផ្លូវភ្នែក ត្រចៀកជាដើម) ការមិនមែនខ្លួន (អនត្តា) បើ

ជាខ្លួនក៏គួរបង្គាប់បញ្ជាបាន មិនឱ្យទៅជាយ៉ាងនេះបាន យ៉ាងនោះបាន.... តើគួរដែរឬទេ ដែលនឹងឃើញរបស់នោះថាជារបស់យើង យើងជារបស់នោះ នោះជាខ្លួនរបស់យើង... ព្រោះដូច្នោះរូប វេទនា សញ្ញា សង្ខារ វិញ្ញាណទាំងក្នុងអតីតកាល អនាគតកាលនិងបច្ចុប្បន្ន ខាងក្នុងនិងខាងក្រៅ គ្រោតគ្រាតឬល្អិត អាក្រក់ឬល្អ ឆ្ងាយឬជិត ទាំងអស់នោះមិន មែន របស់យើង យើងមិនមែនជាដូច្នោះ និងរបស់នោះមិនមែនជាខ្លួនរបស់យើង។

**ពុទ្ធសាសនានិងគោលការណ៍រួចផុត (និព្វាន)**

សព្ទនាមរបស់ពាក្យរួចផុត មានការហៅផ្សេងគ្នា ហៅថា មោក្សៈ ក៏មាន និរវាន ក៏មាន ក្នុងពុទ្ធសាសនាហៅតាមភាសាបាលីថា និព្វាន កាន់យកជាភាវៈថ្នាក់ខ្ពស់បំផុត ដែលជាផលរបស់ការប្រតិបត្តិធម៌។

និព្វានប្រែបានជាច្រើនយ៉ាង ប្រែថាធម្មជាតិដែលរលត់ មានន័យសេចក្តីថា ប្រដូចជាប្រទេះដែលអស់ប្រេង ហើយក៏រលត់ទៅឯង ម្យ៉ាងទៀតប្រែថាធម្មជាតិ ដែលប្រាសចាកគ្រឿងរិតរួត មានន័យសេចក្តីថា មិនមានកិលេស នៅរិតរួតនៅក្នុងភាវៈនោះ មិនមែនជាការរំលត់ខ្លួនឯងរបស់និព្វាន ឬមិនមែនជារិតរួតខ្លួនឯងរបស់និព្វាន។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៤)

បើអធិប្បាយដោយន័យធម្មតា ឱ្យឃើញនិព្វានបានអំពីការរំលត់កិលេសនីមួយៗ ដូចជាមនុស្សខឹងច្រើន រំលត់ខឹងចេញបានក៏សប្បាយចិត្ត អ្នកល្មោភដោយរាគៈ រំលត់រាគៈបានក៏មិនក្តៅក្រហាយក្នុងចិត្ត អ្នកលះបង់អំពើអាក្រក់ដោយប្រតិបត្តិតាមសីល៥ ក៏អាចរំលត់សេចក្តីក្តៅក្រហាយក្នុងចិត្តបាន តាមលំដាប់នៃការប្រតិបត្តិ ខនេះយ៉ាងណាមិញ ការប្រតិបត្តិធម៌ជាន់ខ្ពស់ ក៏រមែងរំលត់ទុក្ខបានច្រើនជាលំដាប់រហូតដល់ថ្នាក់ចុងក្រោយបំផុត ជាការរំលត់ទុក្ខក្តៅក្រហាយក្នុងចិត្ត អស់កិលេស អស់តណ្ហា ដួងចិត្តថ្លាស្អាត ក្ខីនិងស្ងប់ ប្រាសចាកគ្រឿងរិតរួតណាមួយដូចគ្នាការរលត់ទុក្ខ ដែលសម្តែងជាលំដាប់មកនេះហើយ គឺអធិប្បាយឱ្យឃើញការរលត់ដោយអត្ថន័យរបស់និព្វាន សមដូចពុទ្ធឱវាទ សម្តែងថា ៖

និព្វានំ បរមំ វទន្តិ ពុទ្ធា

អ្នកចេះដឹងទាំងឡាយ ពោលថានិព្វានជាកំពូល។

និព្វានំ បរមំ សុខំ

និព្វានជាសុខក្រៃលែង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៥)

**ពុទ្ធសាសនានិងគោលការណ៍គ្រប់គ្រងផ្ទះ**

ពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅសមគួរដល់ចរិត និងការគ្រប់គ្រងជីវិតរបស់បុគ្គលគ្រប់ជំនាន់វណ្ណៈ អ្នកណាមានប្រាថ្នានូវការរួចផុត លះបង់គេហដ្ឋានចេញទៅកាន់ភេទជាអ្នកបួស ព្រះពុទ្ធក៏ទ្រង់ប្រៀនប្រដៅធម៌ ដើម្បីការគួរតាមភេទនិងការប្រតិបត្តិ ប្រសិន បើអ្នកណាប្រាថ្នានៅក្នុងវិស័យឃរាវាសជាគារិកនៅគ្រប់គ្រងផ្ទះក៏មានធម៌ គ្រឿងប្រតិបត្តិសមគួរដល់ការជាអ្នកនៅផ្ទះរបស់អ្នកនោះ។

ធម៌របស់ឃរាវាសនោះមានជាច្រើនយ៉ាង តែសូមលើកយកមកសម្តែងដោយសង្ខេបដូច្នេះ ៖

អ្នកគ្រប់គ្រងផ្ទះគួរប្រកបធម៌ជាទីតាំងចិត្ត៤យ៉ាងគឺ សច្ចៈ មានការស្មោះត្រង់ដល់គ្នា ទមៈ មានការទូន្មានចិត្តរបស់ខ្លួន ខន្តី សេចក្តីអត់ធ្មត់ និងចាគៈ មានការបែងចែកលះបង់ មានចិត្តមិនចង្អៀតចង្អល់។

ទាំងអស់នេះជាគោលធម៌ ដែលអ្នកគ្រប់គ្រងផ្ទះត្រូវប្រតិបត្តិជាមូលដ្ឋាន មានធម៌ទាំងនេះហើយ ក៏នៅមិនទាន់ល្មមគ្រប់គ្រាន់ ត្រូវប្រតិបត្តិធម៌ងាយៗជាច្រើនយ៉ាងទៀត។

ព្រះពុទ្ធទ្រង់ប្រៀនប្រដៅថា សេចក្តីសុខរបស់អ្នកគ្រប់គ្រងផ្ទះមាន ៤ ប្រការគឺ សុខកើតពីការមានទ្រព្យ សុខកើតពីការបានប្រើប្រាស់ចាយទ្រព្យនោះតាមសមគួរ សុខកើតពីការមិនជំពាក់បំណុលគេ និងសុខ កើតអំពីការងារដែលប្រាសចាកទោស។

ទ្រង់ប្រៀនប្រដៅគោលការណ៍របស់ការទ្រទ្រង់វង្សត្រកូលទុក ៤ ខគឺ ៖ ត្រូវស្វែងរករបស់របរដែលបាត់ទៅ ត្រូវជួសជុលរបស់របរដែលចាស់ទ្រុឌទ្រោម ត្រូវដឹងប្រមាណក្នុងការប្រើទ្រព្យសម្បត្តិ និងក្នុងត្រកូលនោះ អ្នកជាធំគឺមេផ្ទះ មានឪពុកម្តាយត្រូវមានសីល។

ទ្រង់ប្រៀនប្រដៅមិនឱ្យអ្នកគ្រប់គ្រងផ្ទះធ្លាក់នៅក្នុងអបាយមុខ គឺផ្លូវនៃសេចក្តីវិនាស ៦យ៉ាង បានដល់ការផឹកទឹកស្រវឹង ការដើរលេងពេលយប់ ការដើរមើលការសម្តែងផ្សេងៗ ការលេងល្បែងភ្នាល់ ការសេពគប់មនុស្សអាក្រក់ជាមិត្ត និងការខ្ជិលច្រអូសធ្វើការងារ។

ទ្រង់ប្រៀនប្រដៅកុំឱ្យអ្នកគ្រប់គ្រងផ្ទះជាអ្នកលេងស្រី ជាអ្នកផឹកស្រា ជាអ្នកលេងល្បែងភ្នាល់និងមិនឱ្យសេពគប់មនុស្សអាក្រក់ធ្វើជាមិត្ត។

សេចក្ដីអធិប្បាយទាំងអស់នេះ ជាធម៌របស់អ្នកគ្រប់គ្រងផ្ទះ អ្នកណាប្រព្រឹត្តបាន សង្ឃឹមថាមុខជាមានសេចក្ដីសុខក្នុងការគ្រប់គ្រងផ្ទះនេះជាប្រាកដ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៦)

## អាការដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅធម៌

ព្រះពុទ្ធទ្រង់ប្រៀនប្រដៅធម៌ដោយអាការ ៣ យ៉ាងគឺ ៖ ទ្រង់ប្រៀនប្រដៅដើម្បីឱ្យអ្នកស្ដាប់ដឹងពិតឃើញពិត តាមធម៌ដែលគួរដឹងគួរឃើញ ទ្រង់ប្រៀនប្រដៅមានហេតុផល ដែលអ្នកស្ដាប់អាចត្រងត្រាប់តាម ឱ្យឃើញពិតប្រាកដបាននិងទ្រង់ប្រៀនប្រដៅជាអស្ចារ្យ គឺអ្នកប្រតិបត្តិបានទទួលប្រយោជន៍គួរដល់ការប្រតិបត្តិ។

ការដែលនឹកឃើញបានថា វិធីប្រៀនប្រដៅធម៌មានអាការ៣យ៉ាងដូច្នេះ ព្រោះថាធម៌របស់ព្រះពុទ្ធនោះ ប្រកបដោយប្រយោជន៍ ទាំងក្នុងដើមដំបូង កណ្ដាល និងចុងបំផុត គឺឱ្យកើតប្រយោជន៍ដល់អ្នកប្រតិបត្តិ ជាថ្នាក់ៗតាំងពីដើមដំបូងរហូតដល់ចុងបំផុត ស្រេចហើយតែចរិតនិងកម្លាំងរបស់អ្នកប្រតិបត្តិអាចប្រតិបត្តិបានត្រឹមប៉ុនណា។

ប្រយោជន៍ដំបូងគឺទិដ្ឋធម្មិកត្ថប្រយោជន៍ បានដល់ប្រយោជន៍កើតអំពីការប្រតិបត្តិធម៌ដែលគប្បីបាន ទទួលក្នុងលោកនេះ មាន៤យ៉ាងគឺ ៖

ក-ដល់ព្រមដោយសេចក្ដីព្យាយាមហៅថាឧដ្ឋានសម្បទា បានដល់ការឧស្សាហ៍ប្រឹងប្រែងកសាងខ្លួន ឧស្សាហ៍សិក្សារៀនសូត្រ ឧស្សាហ៍ស្វែងរកទ្រព្យក្នុងផ្លូវប្រពៃ ឧស្សាហ៍ប្រកបការងារដែលជាប្រយោជន៍។

ខ-ដល់ព្រមដោយការរក្សា ហៅថាអារក្ខសម្បទា បានដល់កិច្ចការពារទ្រព្យសម្បត្តិនិងវិជ្ជាការចេះដឹង ដែលបានមកនិងមានហើយមិនឱ្យបាត់បង់ទៅ នាំវិជ្ជានិងទ្រព្យសម្បត្តិទាំងនោះមកប្រើឱ្យជាប្រយោជន៍ រក្សាវិជ្ជានិងទ្រព្យដែលរកបានមកមិនឱ្យខូចប្រយោជន៍ ហើយនិងរក្សាការងារដែលបានធ្វើល្អហើយកុំឱ្យបាត់បង់ទៅ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៧)

គ-គប់មិត្តល្អ ហៅថាកល្យាណមិត្ត គឺហាមមិនឱ្យគប់មនុស្សអាក្រក់ជាមិត្ត។

ឃ-ឱ្យជាអ្នកស្គាល់កិច្ចការចិញ្ចឹមជីវិត ហៅថាសមជីវិតា គឺការចាយវាយប្រើប្រាស់ឱ្យល្មមសមគួរដល់កម្លាំងទ្រព្យ ដែលបានមកមិនឱ្យខ្ជះខ្ជាយពេក និងមិនឱ្យត្បិតត្បៀតហួសហេតុពេក។

ប្រយោជន៍ជាន់កណ្តាលនិងសម្បរាយិកត្ថប្រយោជន៍ បានដល់ប្រយោជន៍ដែលនឹងទទួលក្នុងលោកខាងមុខមាន៤យ៉ាង ៖

ក-ដល់ព្រមដោយជំនឿ សទ្ធាសម្បទា បានដល់ជំនឿក្នុងពុទ្ធសាសនា ជាជំនឿដ៏យុត្តិធម៌ដោយហេតុផល ជឿដោយយល់ត្រូវតាមធម៌ មិនឱ្យជឿខ្វះការពិចារណារកហេតុផល ជាជំនឿដោយហេតុផល មិនឱ្យជាមនុស្សប្រាសចាកពីសាសនា ឱ្យសាសនាជា គ្រឿងកាត់សេចក្តីប្រព្រឹត្តរបស់ខ្លួន។

ខ-ឱ្យដល់ព្រមដោយសេចក្តីប្រព្រឹត្តល្អហៅថា សីលសម្បទា គឺឱ្យប្រព្រឹត្ត ទាំងកាយវាចានិងចិត្ត ប្រព្រឹត្តយ៉ាងណាកុំឱ្យមានទោសយ៉ាងទាបបំផុតឱ្យនៅត្រឹមសីល៥។

គ-ឱ្យដល់ព្រមដោយការលះបង់ ហៅថា ចាគសម្បទា គឺការឱ្យមានអធ្យាស្រ័យចែកចាយលះបង់ មិនមែនជាមនុស្សចង្អៀតចង្អល់ជាការចែកសេចក្តីសុខដល់ដទៃ។

ឃ-ឱ្យដល់ព្រមដោយការចេះដឹង ក្នុងរបស់ដែលគួរដឹង ហៅថាបញ្ញាសម្បទា គឺឱ្យស្គាល់អធ្យាស្រ័យរបស់ធម្មតា ដូចជាស្គាល់ទុក្ខ ស្គាល់សុខ ហេតុនៃសេចក្តីសុខ និងសេចក្តីទុក្ខជាដើម។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៨)

ប្រយោជន៍ជាន់ខ្ពស់បំផុតគឺបរមត្ថប្រយោជន៍ ប្រយោជន៍ថ្នាក់នេះសំដៅដល់និព្វាន អ្នកបំពេញព្យាយាមនឹងត្រូវប្រតិបត្តិខ្លួនតាមធម៌ថ្នាក់ខ្ពស់បំផុតជាលំដាប់តទៅ ចាប់តាំងពីការប្រតិបត្តិខ្លួនពីថ្នាក់ទាប គឺមានសីល ខ្ពស់ឡើងទៅទៀត មានសមាធិហើយនឹងបញ្ញា ហៅថា ប្រតិបត្តិខ្លួនឱ្យមានត្រៃសិក្ខា លោកប្រៀបទុកថា សីល សមាធិ បញ្ញា ដែលអប់រំ បានពេញទី មានការសម្ព័ន្ធគ្នាដូចជាខ្សែ៣សរសៃ យកដៃចាប់ត្រង់កន្លែងណា ដែលប៉ះទង្គិចទៅទាំង ៣សរសៃ នឹងអំណោយផលឱ្យដោយរលត់ភ្លើងកិលេស ភ្លើងទុក្ខបាន។

**គុណលក្ខណៈធម៌ក្នុងព្រះពុទ្ធសាសនា**

អស់លោកសាស្តានីមួយៗ រមែងប្រៀនប្រដៅធម៌ដើម្បីសាសនិករបស់ខ្លួនតាមគួរដល់បុគ្គល កាលៈនិង ទេសៈ មានបែបម្យ៉ាងម្នាក់មិនដូចគ្នា និងដឹងថាធម៌បែបណាជារបស់សាស្តាអង្គណា ត្រូវមើលគុណលក្ខណៈរបស់ធម៌នោះៗ។

ក្នុងព្រះពុទ្ធសាសនាសម្តែងគុណលក្ខណៈនៃធម៌របស់ព្រះពុទ្ធមាន ៨យ៉ាងដូចតទៅនេះ ៖

១-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីឱ្យចិត្តមានសេចក្តីតម្រេក។

២-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រកបដោយទុក្ខ។

៣-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីបំប៉នកិលេស។

៤-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាធំ។

៥-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសន្តោស (គឺមានយ៉ាងនេះហើយ ចង់បានយ៉ាងនោះ ទៀត)។

៦-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីច្របូកច្របល់ដោយពួកគណៈ។

៧-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស។

៨-ធម៌នោះមិនត្រូវប្រព្រឹត្តទៅ ដើម្បីការចិញ្ចឹមពិបាក។

ប្រសិនបើធម៌ឯណា ពាក្យប្រៀនប្រដៅឯណាប្រព្រឹត្តដោយលក្ខណៈផ្ទុយគ្នា ធម៌ពាក្យប្រៀនប្រដៅនោះ មិនមែនជាធម៌ក្នុងព្រះពុទ្ធសាសនាទេ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៤៩)

**ពុទ្ធនិព្វាន**

ព្រះពុទ្ធប្រកាសធម៌ឱ្យវេនេយ្យជនបានដឹងធម៌ ឱ្យអ្នកប្រតិបត្តិធម៌បានទទួលសម្បត្តិសុខ អំពីការប្រតិបត្តិធម៌នោះ ទ្រង់តាំងព្រះវិន័យបញ្ញត្តិទុកជាបែបគ្រប់គ្រងឱ្យប្រុសបួសជាភិក្ខុ ស្រីជាភិក្ខុនី អ្នកពេញចិត្តនៅ វិស័យឃរាវាស ទ្រង់ក៏ប្រៀនប្រដៅឱ្យជាអ្នកមានសីល ជារបស់អ្នកគ្រប់គ្រងផ្ទះ វៀរចាកការប្រព្រឹត្តអាក្រក់ ផ្លូវកាយ វាចា ចិត្ត។ ប្រុសប្រកាសជាឧបាសក ស្រីជាឧបាសិកា មានសីលគួរដល់ការជាអ្នកគ្រប់គ្រងផ្ទះដ៏ល្អ ជាបរិស័ទ៤ពួក ក្នុងធម៌វិន័យ ព្រះពុទ្ធទ្រង់ប្រកាសធម៌នៅរហូត ៤៥ វស្សា ទ្រង់ប្រតិស្ឋានពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនក្នុងជម្ពូទ្វីបដោយប្រការដូច្នេះ។

កន្លងមកដល់វស្សាទី៤៥ ព្រះពុទ្ធសម្រាន្តឥរិយាបថនៅនាភោគនគរប្រថាប់នាអម្ពវ័នចម្ការស្វាយរបស់នាយចុន្ទ ជាបុត្ររបស់ជាងមាស នាយចុន្ទកាលបើបានដឹងថាព្រះពុទ្ធទ្រង់មកប្រថាប់នៅនាបរិវេណចម្ការរបស់ខ្លួន ទើបចូលគាល់ទូលនិមន្តស្តេចទទួលភត្តាហារនៅផ្ទះរបស់ខ្លួន ក្នុងពេលព្រឹកនៃថ្ងៃពិសាខបូណ៌មី ព្រះច័ន្ទពេញវង់ពាក់កណ្តាលខែ៦ ដែលជាថ្ងៃតែមួយក្នុងតិថីប្រសូត្រ និងត្រាស់ដឹង។

នាយចុន្ទទូលថ្វាយសុក្ករមទ្ទវៈ (យល់ថាគឺជាផ្សិតមួយបែបដែលសុក្ករចូលចិត្តបរិភោគ ជាពូជបន្លែដែលនាំឱ្យកើតកម្លាំងដល់រាងកាយ។ ព្រះពុទ្ធសោយសុក្ករមទ្ទវៈនោះជា

ការបំពេញសទ្ធា ល្មមសមគួរដល់ពុទ្ធចរិយា ទ្រង់អនុមោទនាផលនៃមច្ឆិមទាន ដែលព្រះអង្គទ្រង់សោយជាព្រះអាហារក្រោយបំផុត ហើយបញ្ជាឱ្យនាយ ចុន្ទនាំអាហារនោះយកទៅចាក់ចោល។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥០)

លុះទ្រង់ធ្វើអនុមោទនា ញ៉ាំងនាយចុន្ទឱ្យជ្រះថ្លាសោមនស្សក្នុងផលបច្ឆិមទានរបស់ខ្លួនហើយព្រមដោយភិក្ខុសង្ឃជាបរិវារ ស្ដេចទ្រង់ក៏ត្រឡប់ទៅកាន់កុសិនារា។ ក្នុងរវាងដំណើរយាងតាមផ្លូវ ទ្រង់ប្រឈួន ដោយរាគព្រះលោហិត មានវេទនាជាទុក្ខក្រៃលែង តែទ្រង់មានព្រះសតិសម្បជញ្ញៈមិនអន្ទះអន្ទែង ទ្រង់អត់ធ្មត់បាននូវទុក្ខវេទនានោះ ដោយអធិវាសនខន្តី ស្ដេចឧស្សាហ៍ធ្វើដំណើរទៅរហូតទាល់តែដល់ក្រុងកុសិនារា (ខេត្តកាស្សៀក្នុងពេលបច្ចុប្បន្ន) ប្រថាប់នៅបរិវេណម្ចប់ដើមរាំង ដែលជាទីសម្រាករបស់មល្លក្សត្រិយ៍នាជាយ ព្រះនគរ ទ្រង់សម្រេចសីហសេយ្យា (ដេកដូចរាជសីហ៍) ផ្អៀងទៅស្ដាំដាក់ព្រះបាទគង់ លើព្រះបាទ មានព្រះ សតិសម្បជញ្ញៈ ទ្រង់កំណត់ជាអនុដ្ឋានសេយ្យាមនសិការ (គឺការកំណត់មិនក្រោកឡើងទៀត) ជាសេយ្យអវសាន្តចន្លោះនាសាលព្រឹក (ដើមរាំង) ២ ដើម។

អត្ថកថាចារ្យពិពណ៌នាអភិនិហារ ដែលកើតឡើងពីឫទ្ធានុភាព ក្នុងអវសាន្តនៃ ព្រះពុទ្ធទុកថា សម័យនោះ ដើមរាំងទាំងពីរក៏ចេញផ្កាក្នុងសម័យដែលមិនត្រូវនឹងរដូវកាលរីកស្គុះស្គាយជុំវិញពុទ្ធមណ្ឌល តាំងពីគល់រហូតដល់ចុង ផ្កានៃសាលព្រឹក្សនោះជ្រុះរោយ ធ្លាក់មកបូជាព្រះជាម្ចាស់ ផ្កាបទុមបុស្សដែលមាននៅក្នុងសួគ៌ និងកម្ទេចខ្លឹមចន្ទន៍សុគន្ធជាតិរបស់ទិព្វក៏ធ្លាក់មកជាពុទ្ធបូជា ទេវតានាំគ្នាប្រគុំតន្ត្រីទិព្វ បន្លឺសំឡេងនៅក្នុង អាកាសជា មហានក្ខត្តឫក្សកោលាហល ដើម្បីបូជាសម្ដេចព្រះទសពលក្នុងកាលអវសាន្ត។

មុនពេលដែលស្ដេចចូលបរិនិព្វាន អត្ថកថាចារ្យសម្ដែងពុទ្ធកិរិយា ជាមហាករុណាគ្រាចុងក្រោយនៃព្រះ ជន្មជីវិត ទុកជាច្រើនប្រការ។

ប្រការទី១ ទ្រង់សម្ដែងរឿងសំវេជនីយដ្ឋាន គឺស្ថានដែលគួរឱ្យកើតសេចក្ដីសង្វេគដោយធម៌៤កន្លែង គឺ:

១-ទីស្ថានព្រះពុទ្ធប្រសូត្រ (លុម្ពិនីវ័ន)

២-ទីស្ថានព្រះពុទ្ធត្រាស់ដឹង (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥១)

ព្រះអនុត្តរព្រះសម្មាសម្ពោធិញ្ញាណ (ពុទ្ធគយា)

៣-ទីស្ថានព្រះពុទ្ធសម្ដែងទេសនាធម្មចក្រ (ឥសិបតនមិគទាយវ័ន)

៤-ទីស្ថានព្រះពុទ្ធបរិនិព្វាន (កុសិនារា) ទីស្ថាន៤តំបន់នេះ ជាមហាសក្ការៈស្ថានគួរដល់ធម៌សង្វេគ ជាហេតុឱ្យបង្អោនចិត្តរំពឹងនឹកដល់ពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ជាផ្លូវឱ្យចម្រើនកុសលសម្មាបដិបត្តិ។

ប្រការទី២ ពេលកន្លងចូលរាត្រី ព្រះអាការកាន់តែប្រឈួនខ្លាំងឡើង តែព្រះពុទ្ធទ្រង់នៅព្រះមហាករុណា ទ្រង់បើកឱកាសឱ្យសុភទ្ទបរិព្វាជក (អ្នកបួសក្រៅពុទ្ធសាសនា) ចូលគាល់ទូលសួរបញ្ហាធម៌បាន ទ្រង់ឧស្សាហ៍រិសជ្ជនាធម៌ឱ្យបរិព្វាជកនោះបានទទួលសេចក្តីជ្រះថ្លា បានឧបសម្បត្តិជាបច្ឆិមសក្ខិសាវក (សាវកអង្គចុងក្រោយបង្អស់របស់ព្រះពុទ្ធ)។

ប្រការទី៣ ទ្រង់ទ្រាំទ្រសតិសម្បជញ្ញៈ ទ្រង់រួបរួមធម៌វិន័យដែលទ្រង់សម្តែងទុករហូតមក ៤៥វស្សា រួមបញ្ចូលក្នុងអប្បមាទធម៌ គឺសេចក្តីមិនប្រមាទជាមច្ឆិវាទ ប្រទានដល់ពុទ្ធបរិស័ទក្នុងអវសានកាលថា ៖

"ឥឡូវនេះ យើងសូមដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានការទ្រុឌទ្រោមទៅជាធម្មតា អ្នកទាំងឡាយចូរធ្វើសេចក្តីមិនប្រមាទឱ្យដល់ព្រមចុះ។

តអំពីនោះ ព្រះពុទ្ធមិនបានត្រាស់អ្វីទៀតទេ ទ្រង់បំពេញបរិនិព្វានកម្មព្រះសង្ខារក៏រលត់ស្ងាត់ឈឹង ពន្លឺរស្មីនៃលោករលត់ចុះហើយ ក្នុងថ្ងៃវិសាខពេញបូណ៌មី ខែ៦ ឆ្នាំម្សាញ់ កាលព្រះជន្មាយុគម្រប់ ៨០វស្សា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥២)

**គម្ពីរព្រះពុទ្ធសាសនា**

ព្រះពុទ្ធទ្រង់ស្តេចចូលកាន់បរិនិព្វានហើយអស់ពេលជាង ២.៥០០ឆ្នាំ របស់ដែលនៅសល់តំណាងព្រះអង្គ គឺធម្មវិន័យដែលទ្រង់បានសម្តែង ព្រះសង្ឃ សាវកទាំងឡាយចងចាំទុកថា នាំមកប្រៀនប្រដៅចំពោះពុទ្ធសាសនិកជន រហូតមកដល់បច្ចុប្បន្ន ធម្មវិន័យរបស់ព្រះពុទ្ធនោះចែកចេញជាពីរប្រភេទ មួយប្រភេទកំណត់ថា ជាតម្រាស់របស់ព្រះពុទ្ធជាម្ចាស់ពិត ហៅថាត្រៃបិដក មួយប្រភេទទៀតជាពាក្យរបស់អត្ថកថាចារ្យនិងរបស់ អ្នកប្រាជ្ញដទៃៗ ដែលតែងឡើងជំនាន់ក្រោយ ហៅថាអត្ថកថាដីកា អនុដីកា យោជនា និងដទៃៗទៀត។

ត្រៃបិដកចែកចេញជាបីប្រភេទ ពាក្យថាបិដក មានផ្លូវប្រែបានច្រើនយ៉ាង ប្រែថាតម្រាក៏បាន ភាជនៈ ឬកញ្ជើក៏បាន បើប្រែជាតម្រា សំដៅយកតម្រា៣ជំពូក បើប្រែថាភាជនៈ កញ្ជើ គួរសំដៅថា ជាទីរួបរួមដាក់បញ្ចូលធម៌ទាំងឡាយទុកជាពួក ជាក្រុម ប្រដូចជាភាជនៈដាក់របស់របរដូច្នោះ។ អ្នកប្រាជ្ញភាសាទិសខាងលិច ឈ្មោះជិលដ័រ (Childer) ប្រែទុកគួរ

ឱ្យចង់ស្តាប់ណាស់ គឺប្រែពាក្យបិដកថា រណ្តាប់ទ្រព្យឬឃ្លាំងទ្រព្យ សំដៅ ដល់ឃ្លាំងនៃទ្រព្យដ៏ប្រសើរ ដែលព្រះពុទ្ធប្រទានទុកឱ្យលោកយើងនេះ។

ត្រៃបិដកមានក្នុងគម្ពីរផ្សេងៗច្រើនភាសារបស់ពពួកជនជាតិជាច្រើនពួកដែលរាប់អានព្រះពុទ្ធសាសនា ដែលជាភាសាបាលីគឺជាភាសាពុទ្ធវចនៈ ដែលជនជាតិខ្មែរគោរព ចែក ចេញ ៤៥ក្បាល ត្រូវស្របគ្នានឹងចំនួនឆ្នាំ ៤៥ឆ្នាំ ដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅធម៌។ ព្រះត្រៃ បិដកទាំង៤៥ក្បាល មានការពិនិត្យផ្ទៀងផ្ទាត់ជាច្រើនដង រាប់តាំងពីព្រះពុទ្ធជាម្ចាស់បរិនិព្វានមកហើយ ការពិនិត្យផ្ទៀងផ្ទាត់នេះហៅថា សង្គាយនា។

ជំពូកវិន័យមាន៥គម្ពីរគឺ ១-អាទិកម្ម មានឈ្មោះម្យ៉ាងទៀតថាមហា (ភិក្ខុ) វិភង្គ ២-បាចិត្តិយមានឈ្មោះម្យ៉ាងទៀតថាភិក្ខុនីវិភង្គ ៣-មហាវគ្គ ៤-ចុល្លវគ្គ និង៥-បរិវាររាប់ថាជាធម្មខន្ធ (ជំពូកធម៌) បាន ២១.០០០ធម្មខន្ធ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៣)

ជំពូកសូត្រ មាន៥គម្ពីរ ឈ្មោះហៅថានឹងចំនួនសូត្រដូច្នេះ ៖

១-ទីឃនិកាយ មាន ៣៤សូត្រ

២-មជ្ឈិមនិកាយ មាន១៥២សូត្រ

៣-សំយុត្តនិកាយ មាន៧.៧៦២សូត្រ

៤-អង្គុត្តរនិកាយ មាន៩.៥៥៧សូត្រ

៥-ខុទ្ទកនិកាយ មិនបានចែកជាសូត្រ ចែកគម្ពីរមាន១៤គម្ពីរ

ជំពូកព្រះសូត្រ រាប់ធម្មខន្ធបាន ២១.០០០ ធម្មខន្ធ (រួមទាំងព្រះសូត្រពិត ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ ដោយព្រះអង្គឯង និងបាលីបណ្តាព្រះសាវក ពោលទុកដោយបានស្តាប់មកពីព្រះពុទ្ធជាម្ចាស់)។

ជំពូកអភិធម្មមាន៧គម្ពីរ (តាមប្រក្រតីហៅថាព្រះធម៌ប្រាំពីរគម្ពីរ) មានឈ្មោះដូច្នេះ ១.សង្គនី ២.វិភង្គ ៣.ធាតុកថា ៤.បុគ្គលបញ្ញត្តិ ៥.កថាវត្ថុ ៦.យមក ៧.បដ្ឋាន រាប់ជាធម្មខន្ធបាន ៤២.០០០ធម្មខន្ធ រួមព្រះ ត្រៃបិដកទាំង៣ពួក មាន១៧ គម្ពីរ រួមធម្មខន្ធទាំងអស់មាន ៨៤.០០០ ធម្មខន្ធ។

(ព្រះត្រៃបិដកពួកអភិធម្ម តាមផលនៃការស្រាវជ្រាវរបស់អ្នកប្រាជ្ញខាងលិចសន្និដ្ឋានថា មិនបានចងក្រងទុកក្នុងសម័យដំបូង ក្រោយពុទ្ធបរិនិព្វានទើបមកចាត់ជាពួក ជាក្រុមឡើងក្នុងសម័យព្រះបាទអសោករវាងពុទ្ធសករាជ ៣០០ឆ្នាំ មានការផ្ទៀងផ្ទាត់ (សង្គា-

យនា) ព្រះធម៌និងវិន័យគ្រាដំបូងចំនួន៣ខែក្រោយពុទ្ធបរិនិព្វាន។ ព្រះសង្ឃអ្នកមានបញ្ញាចាំធម៌វិន័យបានដោយមុខបាន គឺការរៀនផ្ទាល់ពីមាត់ត្រូវសូត្រគ្នាមក មិនបានកត់ត្រាជាលាយលក្ខណ៍អក្សរដែលគួរឱ្យជឿថា មានព្រះសង្ឃអ្នកមានបញ្ញាមួយចំនួនរកមធ្យោបាយចារឹកទុកជាតួអក្សរ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៤)

**និកាយក្នុងពុទ្ធសាសនា**

ការយល់នូវធម៌ជាពាក្យប្រៀនប្រដៅរបស់សាសនិកជនក្នុងសាសនាទាំងឡាយមានការប្រព្រឹត្តទៅ ប្រែប្រួលទៅតាមសតិបញ្ញារបស់ខ្លួន ដោយយល់ឃើញថា ការប្រតិបត្តិធម៌យ៉ាងណាជាការគួរដល់កាលៈទេសៈយ៉ាងណានោះ ទើបមានប្រាកដឡើងថា ពាក្យប្រៀនប្រដៅដើមក្នុងសាសនាទាំងឡាយ បានប្រែរូបរាងចេញទៅ អ្នករប់អានមានការយល់ឃើញបែកខ្ញែកគ្នាជាពួក ជាក្រុម ដូចគ្នាទូទៅទាំងអស់។ ក្នុងពុទ្ធសាសនា ការយល់ឃើញរបស់ពុទ្ធសាសនិកផ្លាស់ប្តូរទៅតាមកាលវេលា និងសតិបញ្ញាបែកចេញជានិកាយធំ ២ និកាយ គឺ ៖

១-ហិនយានឬថេរវាទ មានឈ្មោះហៅជាច្រើន ឈ្មោះជាអាទិ៍ សថវីរ សន្ធាសតិវាទ វិភជ្ជវាទិន សាវកយាន និងអរហន្តយាន ប្រកាន់យកគោលពុទ្ធសាសនាពីដើម ជាទក្ខិណនិកាយ (Southern Buddhis) ផ្សាយចេញទៅរប់អានក្នុងប្រទេសប៉ែកខាងត្បូងមាន លង្កា ភូមា ថៃ លាវ និង ខ្មែរជាដើម។

២-មហាយានឬអាចារិយវាទ មានឈ្មោះហៅជាច្រើនឈ្មោះជាអាទិ៍ មហាសង្ឃិក ឯកយាន អនុត្តរយាន ពុទ្ធយាន ពោធិសត្វយាន ប្រកាន់យកពាក្យប្រៀនប្រដៅ ដែលផ្លាស់ប្តូរបែកខ្ញែកចេញជាថ្មីក្នុងពេលខាងក្រោយ ជាឧត្តរនិកាយ ផ្សាយចេញទៅរប់អានក្នុងប្រទេសប៉ែកខាងជើងមាន ចិន យួន កូរ៉េ ជប៉ុន និងទីបេតិ៍ ជាដើម។

សារត្ថៈដែលបែកផ្សេងគ្នារបស់ពុទ្ធសាសនាទាំងពីរនិកាយ ដែលគួរប្រៀបធៀបជាដំបូងក្នុងពាក្យបរិយាយនេះគឺ ៖

-ប៉ែកថេរវាទ (ហិនយាន)

១. បំណងប្រតិបត្តិតាមផ្លូវ អរហត្តមគ្គ ដើម្បីនាំខ្លួនទៅដល់ព្រះអរហន្តអស់កិលេសអស់ទុក្ខទៅ ដើម្បី ខ្លួនឯងជាមុន។

២. បំណងរក្សាសីល ២២៧ខ យ៉ាងតឹងរ៉ឹង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៥)

៣. បដិសេធគោលលទ្ធិត្រីកាយ (ធម្មកាយនិរមាណកាយ និងសម្ភោគកាយ) របស់ព្រះពុទ្ធជាម្ចាស់។

៤. មិនទទួលពុទ្ធភាវៈ ថាមាននៅក្នុងសព្វសត្វ។

៥. បុគ្គលនឹងត្រាស់ដោយអរហត្តមគ្គផ្លូវតែមួយ។

-ប៉ែកអាចារិយវាទ (មហាយាន)

១. បំណងប្រតិបត្តិតាមផ្លូវពោធិសត្វមគ្គ នៅមិនទាន់ប្រាថ្នាការរួចផុត លុះត្រាតែជួយសត្វដទៃឱ្យរួចទុក្ខជាមុនសិន។

២.បំណងរក្សាធម៌ជាជាងវិន័យថែម វិន័យរបស់ព្រះពោធិសត្វសម្តែងភាវៈការប្រតិបត្តិធម៌ទៀត ៥៨ ខ

៣. សម្តែងលទ្ធិត្រីកាយទទួលថា ព្រះពុទ្ធជាម្ចាស់មានព្រះកាយជា៣។

៤. ធានាអះអាងថា ព្រះពុទ្ធភាវៈមាននៅក្នុងសត្វមិនរើសមុខ សូម្បីតែតិរច្ឆាន។

៥. បុគ្គលនឹងត្រាស់ដឹងបាន (រួចផុត) ផង។

ក-ដោយការសិក្សាអំពីគម្ពីរ (បរិយត្តិ)។

ខ-ដោយការបំពេញផ្លូវចិត្ត (ប្រតិបត្តិ)។

គ-ដោយសទ្ធាចំពោះព្រះពុទ្ធជាម្ចាស់។

មានអត្ថមួយទៀត

ក-ដោយប្រតិបត្តិតាមអដ្ឋង្គិកមគ្គ (បែបថេរវាទ)

ខ-ដោយគោលឈាន (និកាយសេន)

គ-ដោយគោលតន្ត្រយាន

ឃ-ដោយគោលភក្តីដល់ព្រះអមិតាភពុទ្ធជាម្ចាស់។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៦)

ក្នុងនិកាយធំទាំងពីរ នៅមាននិកាយបន្ទាប់បន្សំក្រុមតូចៗជាច្រើននិកាយទៀតបែកចេញទៅតាមប្រទេស តាមក្រុម តែទោះបីជាយ៉ាងណាអ្នកប្រាជ្ញកត់សម្គាល់ថា ការបែកខ្ញែករបស់ពុទ្ធសាសនាជា និកាយធំ២និកាយនោះ បានជួយឱ្យពុទ្ធសាសនាផ្សព្វផ្សាយទៅទូទាំង

ពិភពលោក ប្រៀបដូចស្ពាបរបស់សត្វ ដែលមានស្ពាបពីរអាចនាំខ្លួនសត្វឱ្យហើរបានទៅកាន់ទីឋានដែលប្រាថ្នា។

***អវសាន្ត***

ពុទ្ធសាសនាជាសាសនាមានធម៌ ជាគ្រឿងគ្រប់គ្រងជីវិតនិងគ្រប់គ្រងលោក ជាសារណៈជីវិត និងជាសារណៈនៃលោក ជាសាស្ត្រាដែលរួមដោយសាស្ត្រ មិនថាជាសាស្ត្រសាខាណា ចាប់ផ្ដើមតាំងពីគេហសាស្ត្រ ដែលជាសាស្ត្រសម្រាប់អ្នកគ្រប់គ្រងផ្ទះ សរីរសាស្ត្រដែលជាសាស្ត្រសម្រាប់អ្នកគ្រប់គ្រងរាងកាយ ចិត្តសាស្ត្រ ដែលជាសាស្ត្រសម្រាប់អ្នកគ្រប់គ្រងចិត្ត វិទ្យាសាស្ត្រជាន់ទាបរហូតដល់ជាន់ខ្ពស់បំផុត សម្រាប់អ្នកត្រូវការយកឈ្នះធម្មជាតិ ក៏រួមបញ្ចូលនៅក្នុងពុទ្ធសាសនាទាំងអស់។ ពុទ្ធសាសនាតើបជាមនុស្សសាស្ត្រ គឺជាសាស្ត្រសម្រាប់មនុស្សនិងសម្រាប់លោក ហើយនិងជាធម្មសាស្ត្រ គឺជាធម៌អាចឃុំគ្រងលោកបានផង។

ផលទាំងនេះ ព្រោះព្រះពុទ្ធសមណគោតម អ្នកប្រកាសធម៌នេះជាអ្នកមិនមានកិលេសរួមរិត ជាអ្នកដឹងសេចក្ដីពិតដ៏ប្រសើរ ជាអ្នកដឹងច្បាស់នូវលោក ជាអ្នករំដោះរបបទាសរបស់មនុស្សមុនដំបូងក្នុងលោកធម៌របស់ព្រះអង្គមិនបានប្រព្រឹត្តទៅដើម្បីជាទាស នៃសង្គមនិងនៃលោក ដោយប្រការណាឡើយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៧)

**ពុទ្ធវចន ៣ យ៉ាង**

***បឋមពុទ្ធវចនៈ ១ មជ្ឈិមពុទ្ធវចនៈ១ បច្ឆិមពុទ្ធវចនៈ១***

រៀបរាប់ពុទ្ធវចនៈមួយៗដែលមានមកនៅក្នុងគម្ពីរផ្សេងៗគ្នា ដូចខាងក្រោម ៖

***បឋមពុទ្ធវចចនៈ***

នៅក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់ជរាវគ្គ បឋមពោធិវត្ថុ ទំព័រ ១៧៨ ភាគទី៥ បានបញ្ជាក់អំពីព្រះអង្គ ដែលទើបត្រាស់ដឹងនូវ អនុត្តរ សម្មាសម្ពោធិញ្ញាណថ្មីៗបាន បន្លឺនូវពុទ្ធវចនៈជាដំបូងដោយន័យដូចខាងក្រោម ៖

បឋមពុទ្ធវចន ជាព្រះវាចារបស់ព្រះមានព្រះភាគទ្រង់ បន្លឺក្នុងពេលដែលទើបបានត្រាស់ដឹងជាដំបូងថ្មីៗ នៅលើរតនបល្ល័ង្កក្រោមម្លប់ ពោធិព្រឹក្ស ជាព្រះវាចាត្រង់បន្លឺបន្ទុះបន្ទាប់តណ្ហាថា ៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ

(កាលតថាគតមិនទាន់បានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណនៅឡើយ) តថាគតស្វែងរកជាងផ្ទះគឺ តណ្ហាមិនទាន់ជួបប្រទះ តថាគតក៏ត្រេចរង្គត់ទៅមកៗ ក្នុងវដ្តសង្សារអស់ជាតិជាអនេក ការកើត (ក្នុងកំណើតផ្សេងៗ) ក៏ជាទុក្ខឥតស្រាក នែ ! ជាងផ្ទះគឺតណ្ហា ឥឡូវនេះតថាគតឃើញជាងឯងហើយជាងឯងនឹងសង់ផ្ទះ គឺ អត្តភាពរបស់តថាគតតទៅទៀតមិនបានទេព្រោះឆ្អឹងជំនី (គឺកិលេសដ៏សេស) ទាំងអស់របស់ជាងឯង តថាគតកាច់បំបាក់អស់រលីងគ្មានសល់ទេ ទាំងដំបូលផ្ទះគឺអវិជ្ជា តថាគតក៏រុះរើចោលចេញអស់រលីងហើយដែរ ចិត្តរបស់តថាគតបានដល់នូវព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគតបានដល់នូវព្រះនិព្វាន ដែលប្រាសចាកសង្ខារ ហើយតថាគត ដល់នូវការអស់តណ្ហាទាំងឡាយហើយ តថាគតដល់នូវការអស់តណ្ហាទាំងឡាយហើយៗ ព្រះវាចានេះហៅថា បឋមពុទ្ធវចនៈ ព្រោះជាពុទ្ធដីកាជាដំបូងបង្អស់ ។

**មជ្ឈិមពុទ្ធវចន**

មជ្ឈិមពុទ្ធវចន ជាព្រះវាចាដែលព្រះអង្គត្រង់សម្តែងជាកណ្តាលឬចន្លោះនៃវចនៈទាំងពីគឺបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈមានសេចក្តីពិស្តារណាស់ មិនអាចនឹងយក មកអធិប្បាយបានទេ ព្រោះរយៈពេល ៤៥ ឆ្នាំ ចាប់តាំងពីព្រះអង្គបានត្រាស់ដឹង មករហូតដល់បរិនិព្វានទៅ វិញមានសេចក្តីច្រើនណាស់ ធម៌វិន័យណាដែលព្រះអង្គ ទ្រង់សម្តែង ហើយបញ្ញត្តហើយនៅចន្លោះនៃពុទ្ធវចនៈទាំងពីរ ធម៌វិន័យនោះឯងជាមជ្ឈិមពុទ្ធវចនៈសូមជ្រាបប៉ុណ្ណឹងទៅចុះ ។

**បច្ឆិមពុទ្ធវចន**

បច្ឆិមពុទ្ធវចនៈ ជាព្រះវាចាចុងក្រោយបង្អស់របស់ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ។

នៅក្នុងសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ត្រង់បច្ឆិមវាចារបស់ព្រះមានព្រះភាគ មហាបរិនិព្វានសូត្រទំព័រ ៣២០-៣២១ ក្បាល ១៦ បានបញ្ជាក់ថា ៖

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទ ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅ ហើយគ្រូ

របស់យើងឈ្មោះថាមិនមានឡើយ ម្នាលអានន្ទ សេចក្តីនេះ អ្នកកុំចូលចិត្តយ៉ាងនេះឡើយ។ ព្រះអង្គបានបញ្ជាក់ទៀតថា ៖

យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តីដែលតថាគត សម្តែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌និងវិន័យនេះ ជាគ្រូរបស់អ្នកទាំងឡាយហើយ ។

ចុងក្រោយបំផុតទំព័រ៣២៤ព្រះអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា៖

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ម្នាលភិក្ខុទាំងឡាយណ្ហើយចុះ ឥឡូវនេះតថាគតប្រាប់អ្នកទាំងឡាយឱ្យ បានដឹង សង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។

អយំ តថាគតស្ស បច្ឆិមា វាចា នេះជាសម្តីចុងក្រោយរបស់តថាគតហើយ ។

រួចហើយព្រះអង្គក៏យាងចូលឈានតាមលំដាប់លំដោយ បរិនិព្វានទៅនៅថ្ងៃអង្គារ ១៥ កើតខែ ពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក នៅក្រោម ដើមសាលព្រឹក្សទាំងគូក្នុងនគរ កុសិនា រា

ទោសនៃបុគ្គលទ្រុស្តសីល ៥ យ៉ាង ៖

នៅក្នុងសុត្តន្តបិដក ទីឃនិកាយមហាវគ្គ ត្រង់មហាបរិនិព្វានសូត្រ ទំព័រ ១៨៤ ក្បាល ១៦ បានបញ្ជាក់ថា ៖

លំដាប់នោះព្រះមានភាគត្រាស់ នឹងពួកឧបាសកអ្នកបាដលិគ្រាមថា ម្នាល គហបតីទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីលមាន ៥ ប្រការ គឺ ៖

**១-បមាទាធិករណំ មហតិំ ភោគជានិំ និគច្ឆតិ** (ម្នាលគហបតីទាំងឡាយ បុគ្គល ទ្រុស្តសីលវិបត្តិចាកសីលក្នុងលោកនេះ ) តែងដល់ នៅសេចក្តីវិនាសនៃភោគៈដ៏ធំ មានសេចក្តីប្រមាណជាហេតុ ។

**២-បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** (ម្នាលគហបតីទាំងឡាយ)កិត្តិស័ព្ទដ៏អាក្រក់នៃបុគ្គលទ្រុស្តសីលតែងផ្សាយទៅសព្វទិស ។

**៣-យញ្ញទេវ បរិសំ ឧបសង្កមតិ** (ម្នាលគហបតីទាំងលាយបុគ្គល ទ្រូស្តសីល វិបត្តិចាកសីល ) ទោះចូលទៅរកបរិស័ទណាៗគឺ ខត្តិយ បរិស័ទក្តី ព្រាហ្មណ៍បរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នក មិនក្លៀវក្លាចូលទៅទាំងអៀនអន់ ។

**៤-សម្មូឡ្ហោ កាលំ ករោតំ** (ម្នាលគហបតីទាំងឡាយបុគ្គលទ្រូស្តសីល វិបត្តិចាកសីល ) ជាបុគ្គលវង្វេង ពេលដែលជិតធ្វើមរណកាល ។

**៥-កាយស្ស ភេទា បរម្មរណា អាបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ** (ម្នាល គហបតីទាំងឡាយ បុគ្គលទ្រូស្តសីលវិបត្តិចាកសីល) លុះបែកធ្លាយរាងកាយទៅខាងមុខ អំពីសេចក្តីស្លាប់ទៅរមែងទៅកើត ក្នុងកំណើត តិរច្ឆានប្រេត អសុរកាយនរក ។

**អានិសង្សនៃបុគ្គលមាន សីល ៥ យ៉ាង**

នៅក្នុងសុត្តន្តបិដកទីឃនិកាយ មហាវគ្គ ត្រង់មហាបរិនិព្វានសូត្រ ទំព័រ ១៨៥ ក្បាល ១៦ បានបញ្ជាក់ថា ៖

១-អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ (ម្នាលគហបតីទាំងឡាយ បុគ្គលមានសីលដល់ព្រម ដោយសីលក្នុងលោកនេះ រមែងមានគំនរទ្រព្យដ៏ធំដែលមានសេចក្តី មិនប្រមាទជាហេតុ ។

២-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ (ម្នាលគហបតីទាំងឡាយ) កិត្តិស័ព្ទដ៏ពិរោះរបស់បុគ្គលមានសីល ដល់ព្រមដោយសីលតែងផ្សាយទៅសព្វទិស ។

៣-យញ្ញទេវ បរិសំ ឧបសង្កមតិ(ម្នាលគហបតីទាំងឡាយបុគ្គល មានសីលដល់ព្រមដោយសីល) ទោះចូលទៅរកបរិស័ទណាៗគឺខត្តិយបរិស័ទក្តីព្រាហ្មណ៍បរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តីជា បុគ្គលមានសេចក្តីក្លៀវក្លា ចូលទៅដោយមិនអៀនអន់ ។

៤-អសម្មូឡ្ហោ កាលំ ករោតិ (ម្នាលគហបតីទាំងឡាយបុគ្គលមានសីលដល់ព្រមដោយសីល ) ជាបុគ្គលមិនវង្វេងនៅពេលដែលជិត ធ្វើមរណកាល ។

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ (ម្នាលគហបតីទាំងឡាយបុគ្គលមានសីលដល់ព្រមដោយសីល) លុះបែកធ្លាយរាងកាយខាងមុខអំពី សេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងលោក គឺមនុស្ស សុគតិ និង ឋានសួគ៌ ។

**អបរិហានិយធម៌ ៧**

នៅក្នុងសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ត្រង់មហាបរិនិព្វានសូត្រទំព័រ ១៥៧ ក្បាល ១៦ បានបញ្ជាក់ថា ៖

ព្រះមានព្រះភាគទ្រង់សម្តែងប្រាប់អបរិហានិយមធម៌ ៧ យ៉ាងរបស់ពួកស្តេចដែនវជ្ជី ដល់ព្រះអានន្ទដែលលោកកំពុងតែគង់បក់ផ្លិត ពីខាងក្រោយៗ អបរិហានិយមធម៌ ៧ យ៉ាង នេះគឺ ៖

**១-អភិណ្ហសន្និបាតា** ម្នាលអានន្ទបើពួកស្តេចក្នុងដែនវជ្ជី នឹងមានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើនអស់កាលត្រឹមណា ម្នាលអានន្ទសេចក្តីចម្រើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានអស់កាលត្រឹមណោះ ។

**២-សមគ្គា សន្និបតិស្សន្តិ** ម្នាលអានន្ទបើពួកស្តេចក្នុងដែនវជ្ជី ព្រមព្រៀងប្រជុំគ្នា ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីអស់កាលត្រឹមណា ម្នាល អានន្ទសេចក្តីចម្រើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមាន ឡើយ អស់កាលត្រឹមណោះ ។

**៣-អប្បញ្ញត្តំ ន បញ្ញាបេស្សន្តិ** ម្នាលអានន្ទបើពួកស្តេចក្នុងដែន វជ្ជីនឹងមិនបញ្ញត្តិ ច្បាប់ ដែលស្តេចពីដើមមិនបានបញ្ញត្តហើយ មិនដកច្បាប់ដែលបានបញ្ញត្តហើយកាន់តាមប្រព្រឹត្ត តាមច្បាប់ក្នុងដែនវជ្ជីអំពី បុរាណដែលបានបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា ម្នាល អានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែកវជ្ជី សេចក្តីសាបសូន្យមិនមាន ឡើយ អស់កាលត្រឹមណោះ ។

**៤-វជ្ជីនំ វជ្ជីមហល្លកា** ម្នាលអានន្ទបើពួកស្តេចក្នុងដែនវជ្ជីនឹងធ្វើ គ្រឿងសក្ការៈ គោរពរាប់អានបូជាដល់ពួកវជ្ជីក្សត្រ ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រទាំងឡាយ ទាំង ជឿពាក្យគួរស្តាប់របស់ពួកក្សត្រ ដែលមានព្រះជន្មច្រើនទាំងនោះអស់កាលត្រឹមណា ម្នាល អានន្ទសេចក្តីចម្រើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តី សាបសូន្យមិនមាន ឡើយអស់កាលត្រឹមណោះ ។

**៥-កុលិត្ថិយោ កុលកុមារិយោ** ម្នាលអានន្ទបើពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួក ស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឱ្យនៅរួមអស់ កាលត្រឹមណា ម្នាលអានន្ទ សេចក្តី ចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយអស់កាល ត្រឹមណោះ។

***៦-វជ្ជីនំ វជ្ជីចេតិយានិ*** *ម្នាលអានន្ទបើពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើសក្ការៈគោរពរាប់អានបូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែន វជ្ជីដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកប ដោយធម៌ ដែលគេធ្លាប់ថ្វាយធ្លាប់ធ្វើដល់ ចេតិយទាំងនោះឱ្យសាបសូន្យ ទៅអស់កាលត្រឹមណា ម្នាលអានន្ទសេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុង ដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយអស់កាលត្រឹមណោះ ។*

***៧-វជ្ជីនំ អរហន្តេសុ*** *ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងចាត់ចែងដោយត្រឹម ត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ក្នុងព្រះអរហន្តទាំងឡាយដោយបំណងថាធ្វើម្តេចហ៎ ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឱ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយដែលមកសោប់ហើយ ក៏សូមឱ្យគង់ នៅជាសុខក្នុងដែនរបស់យើងអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ អស់កាលត្រឹមណោះ ។ អយំ ពុទ្ធវចនកថា ទេសិតំ និដ្ឋិតា ពុទ្ធវចនកថា ដែលខ្ញុំបានសម្តែងមកនេះសន្មតថាចប់តែប៉ុណ្ណោះឯង ។*

**២-តើត្រូវជំនះឧបសគ្គយ៉ាងដូចម្តេច?**

***១-សេចក្តីខ្លាច និង សេចក្តីកង្វល់ចិត្ត***

*សេចក្តីភ័យខ្លាច និងសេចក្តីកង្វល់ចិត្តកើតចេញមកពីសភាវៈស្រមើស្រមៃចិត្ត ដែលត្រូវបរិស្ថានជីវិតលោកីយ៍ជះឥទ្ធិពលមកលើ។ ភ័យខ្លាច និងកង្វល់ចិត្តមានឫសគល់នៅក្នុងតណ្ហា និង ឧបាទាន។ តាមពិត ជីវិតប្រៀបដូចរូបភាពយន្ត(ឬកុន) ដែលនៅក្នុងរូបភាពយន្ត(ឬកុន)នេះអ្វីៗទាំងអស់តែងចល័ត និងប្រែប្រួលជាប្រចាំ។ គ្មានអ្វីនៅក្នុងលោកនេះ ស្ថិតស្ថេរ ឬស្ថិតនៅនឹងថ្កល់ទេ។ អ្នកទាំងឡាយណា ដែលមានវ័យនៅក្មេងមានកម្លាំងមាំមួន តែងមានសេចក្តី ភ័យខ្លាចស្លាប់ទាំងនៅក្មេង។ អ្នកទាំងឡាយណាដែលមានវ័យចាស់ហើយមានជំងឺផង តែងព្រួយកង្វល់ចិត្តអំពីជីវិតរស់នៅយូរពេក។ ស្ថិតនៅក្នុងចន្លោះមនុស្សទាំងពីរក្រុមនេះ គឺពពួកអ្នករក់តែនិងសេចក្តីសប្បាយពីមួយឆ្នាំទល់មួយឆ្នាំ ។*

*សេចក្តីសង្ឃឹម ប្រកបដោយសេចក្តីរីករាយរបស់ពួកអ្នកសប្បាយចិត្តហាក់ ដូចកន្លងទៅឆាប់ពេក។ សេចក្តីរង់ចាំប្រកបដោយសេចក្តីភ័យខ្លាចរបស់ពួកអ្នកមិនសប្បាយចិត្ត បង្កើតឱ្យមានសេចក្តី ព្រួយកង្វល់ចិត្ត ដែលហាក់ដូចជាមិនព្រមឃ្លាតទៅណាសោះ។ អារម្មណ៍ទាំងឡាយបែបនេះ គឺជាសភាវៈធម្មតា។ ជីវិតរស់នៅប្រែប្រួលម្តងចុះម្តងឡើង*

*បែបនេះដើរតួដោយអត្តៈឬជីវមាយា* (an illusory self or ego ) *ដូចរូបតុក្កតាដែលញាក់ទៅតាមខ្សែ។ ប៉ុន្តែចិត្តគឺដូចជាសភាវៈដ៏ប្រសើរដោយខ្លួនឯងផ្ទាល់។ ការហ្វឹកហ្វឺនចិត្តដែលគេហៅម្យ៉ាងទៀតថា ចិត្តវប្បកម្ម* (mental culture) *គឺជាជំហានដំបូង ឆ្ពោះទៅរកការបង្ក្រាបសភាវៈប្របូកប្របល់នៃចិត្ត។*

*ព្រះពុទ្ធបានពន្យល់ថា « សេចក្តីទុក្ខព្រួយកើតចេញពីតណ្ហា » សេចក្តីភ័យខ្លាច កើតចេញពីតណ្ហា សម្រាប់អ្នកដែលរំដោះផុតពីតណ្ហាបានទាំងស្រុងហើយ សេចក្តីទុក្ខព្រួយ សេចក្តីភ័យខ្លាច សូម្បីតែតិចតួចមិនមានទេ ។*

*សេចក្តីជាប់ជំពាក់ចិត្តគ្រប់យ៉ាង (ឧបាទាន) និងបញ្ចាប់នៅត្រឹមសេចក្តីសោកស្តាយ។ មិនមែនទឹកភ្នែកទាំងមិនមែនការឱបរឹតសាសងលាគ្នាដ៏យូរអាចបញ្ចប់អនិច្ច ភាពនៃជីវិតបានទេ។ សង្ខារវត្ថុទាំងអស់មិនស្ថិតស្ថេរជាអចិន្ត្រៃយ៍ទេ។*

*ទាំងចាស់ ទាំងក្មេង រងទុក្ខដូចគ្នានៅក្នុងជីវិតនេះ។ គ្មាននរណាម្នាក់ត្រូវបានលើកលែងឡើយ។ ពួកក្មេងៗជាច្រើនកំពុងមានសេចក្តីឈឺចាប់ខ្លាំងឡើងៗដោយពួកគេមិនមែនជាកន្ត្រែប ឬជាកូនក្អាត់។ ពួកយុវជនមានបទពិសោធន៍យល់ដឹងតិច ក្នុងការកសាងទំនាក់ទំនងជាប់ លាប់ជាមួយសមាជិកមានភេទផ្ទុយគ្នា។ ពួកគេខិតខំ បង្អួតសម្រស់របស់គេ ដើម្បីខិតខំទាក់ទាញចិត្តយុវជនមានភេទផ្ទុយគ្នា ដែលកំពុងស៊ីជោរដោយមើលឃើញខ្លួនឯងថាជាកម្មវត្ថុនៃភេទ។ ភេទទាំងពីរបានខិតខំធ្វើឫកពាដែលពួកគេយល់ថា ជាឫកពាមនុស្សពេញវ័យ។ ពួកគេភ័យខ្លាចថាបើគេធ្វើ ឫកពាធម្មតា ទៅពួកគេនឹងត្រូវគេសើចចំអក។ ឫកពាដូចនេះ មានសក្តានុពល សម្រេចជោគជ័យ ។ គេមានសេចក្តីបារម្ភខ្លាចការបដិសេធក៏ដូចជាសេចក្តីព្រួយកង្វល់ចិត្តអំពីអត្តភាពរបស់គេស្រុតចុះ។ សេចក្តីស្នេហាមិនបានសម្រេចជាញឹកញយតែ «ទម្ងុះទម្ងាយ » បេះដូងយុវជនជាច្រើន ពីព្រោះពួកគេមានអារម្មណ៍ថាពួកគេជា មនុស្សធោតល្ងង់។ យុវជនខ្លះឈានរហូតដល់ធ្វើអត្តឃាត។ ប៉ុន្តែជំងឺផ្លូវចិត្តបែបនេះ អាចជៀសវាងបានប្រសិនបើជីវិតត្រូវបាន គេមើលឃើញតាមធម្មជាតិពិតរបស់វា។ គេត្រូវផ្តល់ដល់យុវជននូវវិធីដោះស្រាយបញ្ហាជីវិតតាមបែបបទពុទ្ធសាសនា ដើម្បីឱ្យពួកយុវជនអាចប្រកាន់យកមាគ៌ាត្រឹមត្រូវឈានចូលទៅក្នុងដំណាក់កាលមានចិត្តចាស់ទុំ។*

*ព្រះពុទ្ធទ្រង់មានបន្ទូលថា «ក្នុងទីណាមានសេចក្តីភ័យខ្លាចកើតឡើង. វាកើតឡើងក្នុងមនុស្ស ទុប្បញ្ញា. មិនមែននៅក្នុងបណ្ឌិតឡើយ »។ សេចក្តីភ័យខ្លាច គ្មានអ្វី ក្រៅតែពី*

ស្ថានភាពនៃចិត្តទេ ។ ស្ថានភាពនៃចិត្តរបស់បុគ្គលម្នាក់ ត្រូវតែស្ថិតនៅក្រោមការត្រួតត្រា និង ការតម្រង់ទិស. ការប្រើប្រាស់គំនិត ខុសបែបបទ បង្កើតចេញនូវសេចក្តីភ័យខ្លាច. ការប្រើប្រាស់គំនិតបានត្រឹមត្រូវ រមែងបង្កើតបានសេចក្តីសង្ឃឹមនិងឧត្តមគតិ។ ជម្រើសស្ថិតនៅក្នុងដៃយើងទាំងស្រុង។ មនុស្សម្នាក់មានសមត្ថភាពដើម្បីត្រួតត្រាចិត្តរបស់ខ្លួនឯងដោយផ្ទាល់ ធម្មជាតិបានប្រគល់មកឱ្យមនុស្សនូវការត្រួតត្រាដាច់ខាតទៅលើចិត្តគំនិត។ អ្វីៗដែលមនុស្សបង្កើតឡើងគឺចាប់ផ្តើមក្នុងទ្រង់ទ្រាយនៃគំនិត។ នេះគឺជាកូនសោរ ដើម្បីជួយបុគ្គលណាម្នាក់ឱ្យយល់នូវគោលការណ៍ ដើម្បីអាចយកមកប្រើសម្រាប់ម្ចាស់ការលើសេចក្តីភ័យខ្លាច ។ កាយវិភាគវិទូ (Anatomist) សញ្ជាតិអង់គ្លេសដ៏ល្បីល្បាញម្នាក់មានពេលមួយនោះត្រូវបាននិស្សិតម្នាក់ចោទសួរថា តើអ្វីជាឱសថដ៏ប្រសើរបំផុតសម្រាប់ព្យាបាលសេចក្តីភ័យខ្លាច. បន្ទាប់មកលោកបានឆ្លើយថា «ចូរខិតខំធ្វើអ្វី មួយសម្រាប់អ្នកណាម្នាក់ »។

និស្សិតនោះមានសេចក្តីងឿងឆ្ងល់យ៉ាងខ្លាំងចំពោះចម្លើយនោះ ហើយបានសុំសេចក្តីបំភ្លឺទូលំទូលាយជាងនេះទៀត ។ ពេលនោះ លោកសាស្ត្រាចារ្យបាននិយាយថា «អ្នកឯងមិនអាចមានគំនិតពីរ បែបផ្ទុយពីគ្នានៅក្នុងចិត្តរបស់អ្នកឯងនៅពេលតែមួយនិងជាដែលបានទេ»។ គំនិតមួយបែបនឹងបណ្តេញគំនិតមួយបែបផ្សេងទៀតចេញជានិច្ច។ យកជាឧទាហរណ៍ប្រសិនបើចិត្តរបស់លោក អ្នកជាប់ជំពាក់ទាំងស្រុង ដោយចំណង់បរទត្តភាពដើម្បីជួយជនណាម្នាក់ លោកអ្នកមិនអាចរក្សានៅក្នុងចិត្តរបស់លោកអ្នកនូវគំនិតភ័យខ្លាចអ្វី មួយនៅពេល ជាដែលបានទេ។

សេចក្តីព្រួយកង្វល់ធ្វើឱ្យឈាមហួតឆាប់ជាងវ័យ «(គឺធ្វើឱ្យរូបកាយឆាប់ចាស់ជាងអាយុ)។ សេចក្តីភ័យ ខ្លាចនិងសេចក្តីព្រួយកង្វល់ មិនហួសប្រមាណ គឺជាសភាវ គតិធម្មតានៃកិច្ចការពារឬថែរក្សាខ្លួន ។ ប៉ុន្តែសេចក្តីភ័យខ្លាចឥតហេតុ ផលជាប្រចាំ និងសេចក្តីព្រួយកង្វល់ចិត្ត រយៈពេលយូរ គឺជាសត្រូវដ៏គ្រោះថ្នាក់ ចំពោះសរីរាង្គមនុស្ស។ វាបង្កវិបត្តិដល់ដំណើរប្រព្រឹត្តទៅជាធម្មតារបស់សរីរាង្គ ។

**២-ចូរគ្រប់គ្រងចិត្តរបស់លោក-អ្នក**

ចិត្តរបស់មនុស្ស មានឥទ្ធិពលគ្របដណ្តប់លើសរីរាង្គយ៉ាងជ្រាលជ្រៅ។ ចិត្តមានសក្តានុភាពដ៏ខ្លាំងក្លា ជាងឱសថក៏ដូចជាវាមានសក្តានុភាពដ៏ខ្លាំងក្លាជាពិសពុលដែរ។ កាលណាចិត្តជាសភាវៈអាក្រក់វាអាចសម្លាប់ជីវិតមួយបាន ប៉ុន្តែកាលណាចិត្តនោះមិនទ្រេត-

ទ្រោតឧស្សាហ៍ព្យាយាមវាអាចផ្តល់អត្ថប្រយោជន៍ដល់មនុស្សឯទៀត។ កាលណាចិត្តតាំងនៅស៊ប់ក្នុងគម្រិះត្រូវ (សម្មាសង្កប្បៈ) ហើយមានសេចក្តីព្យាយាមត្រូវ(សម្មាវិរិយៈ) និងសេចក្តីយល់ដឹងត្រូវ(សម្មាទិដ្ឋិ) គាំទ្រផងផលដែលចិត្តនេះបង្កើតបាន គឺមានទំហំធំធេងណាស់។ ចិត្តប្រកបដោយគម្រិះបរិសុទ្ធ និងជាកុសលនាំឱ្យមានជីវិតរស់នៅប្រកបដោយសុខភាពល្អ និងមានភាពល្ហែស្រាកស្រាន្តចិត្ត ។

ព្រះពុទ្ធទ្រង់មានបន្ទូលថា «គ្មានសត្រូវណាមួយអាចបង្កសេចក្តីឈឺចាប់ដល់បុគ្គលច្រើនស្មើនឹងគំនិត អំពីលោភៈ គំនិតអំពីទោសៈ គំនិត អំពីឥច្ឆាជាដើម .. របស់បុគ្គលខ្លួនឯងផ្ទាល់នោះទេ» ។

មនុស្សដែលមិនចេះសម្របសម្រួលចិត្តរបស់ខ្លួនទៅតាមកាលៈ ទេសៈ គឺទុកដូចជាមនុស្សស្លាប់។ ចូរបង្វែរចិត្តរបស់លោកអ្នកឆ្ពោះមកឲ្យដីផ្ទៃក្នុងរបស់លោក-អ្នក ហើយសាកល្បងរកឱ្យឃើញ សេចក្តីសប្បាយនៅឲ្យដីផ្ទៃក្នុងរបស់លោកអ្នក។

មានតែពេលណាចិត្តត្រូវបានគ្រប់គ្រង ហើយតម្រែតម្រង់យ៉ាងត្រឹមត្រូវប៉ុណ្ណោះទេទើបវាប្រែក្លាយជា មានប្រយោជន៍ដល់ម្ចាស់វានិង ដល់សង្គមបាន។ ចិត្តគ្រប់គ្រងមិនបាន គឺជាក្តីកង្វល់ដល់ម្ចាស់វាផង ដល់អ្នកដទៃទាំងឡាយផង។ មហន្តរាយទាំងអស់ដែលកើតមានក្នុងពិភពលោកនេះ គឺជាស្នាដៃរបស់មនុស្ស ដែលមិនបានចេះវិធីគ្រប់គ្រងចិត្តធ្វើចិត្តឱ្យមានតុល្យភាពនិងស្ងប់ស្ងៀម។

ភាពស្ងប់ស្ងៀមមិនមែនជាភាពទន់ខ្សោយទេ។ ឥរិយាបថស្ងប់ស្ងៀមក្នុងគ្រប់ពេលវេលា បង្ហាញឱ្យឃើញថា មនុស្សនោះមានវប្បធម៌។ វាពុំមែនជាការពិបាកសម្រាប់បុគ្គលម្នាក់ត្រូវប្រកាន់ឥរិយាបថស្ងប់ស្ងៀម កាលណាមានរឿងហេតុប្រកបដោយសេចក្តីអនុគ្រោះនោះទេ ប៉ុន្តែការប្រកាន់ឥរិយាបថស្ងប់ស្ងៀម កាលណាមានរឿងហេតុខុសឆ្គង គឺជារឿងពិបាកមែនទែន។ គឺគុណសម្បត្តិដ៏ពិបាកនេះហើយ ដែលវាមានតម្លៃស័ក្តិសមនឹងការខិតខំសម្រេចឱ្យបានពីព្រោះ ដោយសារការហ្វឹកហាត់ស្ងប់ស្ងៀមនិងការគ្រប់គ្រងចិត្តបែបនេះមនុស្សកសាងពង្រឹងចរិតរបស់ខ្លួនបាន។

**៣-សំឡេងរបស់ធម្មជាតិ**

មនុស្សសម័យថ្មីមិនសូវយកចិត្តទុកដាក់ស្តាប់សំឡេងរបស់ធម្មជាតិទេ ពីព្រោះតែគេជាប់រវល់ខ្លាំងពេក តែជាមួយនឹងលាភជាសម្ភារៈនិងសេចក្តីសប្បាយ។ សកម្មភាពផ្លូវចិត្ត

*របស់គេជាប់រវល់តែនឹងកាមសុខលោកិយ៍ពេកទៅ ទាល់តែគេភ្លេចគិតពីសេចក្តីត្រូវការខាងស្មារតីនៃអត្តៈរបស់គេ។ ចរិតមិនធម្មតារបស់មនុស្សសហសម័យ បង្កើតចេញជាលទ្ធផលភ្លាមៗ នូវលោកទស្សនៈខុសឆ្គងមួយចំពោះជីវិតមនុស្ស និងបំណងប្រាថ្នាចុងក្រោយរបស់វា។ នេះគឺជាមូលហេតុនៃសេចក្តីខកចិត្ត សេចក្តីព្រួយបារម្ភ សេចក្តីភ័យខ្លាច និងអសន្តិសុខរបស់សម័យ កាលបច្ចុប្បន្នរបស់យើង។*

*ប្រសិនបើមនុស្សឃោរឃៅ ហើយអាក្រក់យង់ឃ្នង រស់នៅប្រឆាំងនឹងក្រឹត្យក្រមធម្មជាតិ និងច្បាប់សកលលោកធាតុ អំពើរបស់គេ ពាក្យសម្តីនិងគំនិតរបស់គេ ធ្វើឱ្យក្រខ្វក់បរិយាកាសទាំងមូល។ ធម្មជាតិដែលត្រូវគេបំពារបំពាន នឹងមិនផ្តល់ឱ្យនូវអ្វីដែលមនុស្សចង់ បានសម្រាប់ជីវភាពរស់នៅរបស់ពួកគេឡើយ ជាជំនួសវិញ ការប្រយុទ្ធ ការប៉ះទង្គិចជំងឺឆ្លងរាលដាល និង មហន្តរាយនឹងត្រៀមចាំទទួលពួកគេជានិច្ច។*

*ប្រសិនបើមនុស្សរស់នៅស្របតាមធម្មជាតិវិញដឹកនាំជីវភាពត្រឹមត្រូវ(សម្មាអាជីវៈ) ធ្វើឱ្យបរិយាកាសបរិសុទ្ធតាមរយៈផលល្អនៃគុណធម៌របស់គេ ហើយផ្សាយចេញនូវសេចក្តីមេត្តា ករុណាចំពោះសព្វសត្វមានជីវិតដទៃទៀត មនុស្សនោះអាចនាំមកនូវសេចក្តីសុខឱ្យមនុស្សជាតិ ។ បុគ្គលដែលស្រឡាញ់សន្តិភាពដោយពិតប្រាកដ មិនត្រូវបំពារបំពានលើសេរីភាពរបស់មនុស្សដទៃទៀតឡើយ។ វាជាកំហុសធ្ងន់ធ្ងរណាស់ចំពោះការរំខាន និងបោកបញ្ឆោតអ្នកដទៃ ។*

*លោកអ្នកអាចជាមនុស្សមានកិច្ចការរវល់ច្រើន ប៉ុន្តែចូរចំណាយពេលយ៉ាងហោចណាស់ ពីរបីនាទីក្នុងមួយថ្ងៃធ្វើភាវនាឬអានសៀវភៅ ដ៏ល្អណាមួយ។ ទម្លាប់នេះនឹងជួយកាត់បន្ថយសេចក្តីកង្វល់ចិត្តរបស់លោក-អ្នក ហើយជួយអភិវឌ្ឍចិត្តរបស់លោក-អ្នក។ សាសនាត្រៀមបម្រើអត្ថប្រយោជន៍របស់លោក-អ្នក។ ព្រោះហេតុនោះ វាជាករណីយកិច្ចរបស់លោកអ្នកត្រូវគិតគូរអំពីសាសនារបស់លោក-អ្នក។ ចូរសំចៃពេលខ្លះ ដើម្បីចូលរួមប្រជុំក្នុងបរិយាកាសសាសនាណាមួយ។ សូម្បីតែពេលវេលាខ្លីចំណាយសម្រាប់ប្រស្រ័យជាមួយមនុស្សកាន់ធម៌អាថ៌ នឹងបង្កើតឱ្យមានលទ្ធផលល្អមិនខាន។*

### ៤-សុខភាពផ្លូវចិត្ត និងទំនោរឧក្រិដ្ឋកម្ម

*ការកើនឡើងនៃជំងឺសរសៃប្រសាទ និងចិត្តវិបល្លាសគ្រប់បែប គឺជាសញ្ញាដ៏គួរឱ្យភ្ញាក់ផ្អើលបំផុតនៃជំងឺទាំងអស់របស់យុគសម័យថ្មីៗ មានអ្នកជំងឺផ្នែកសរសៃប្រសាទកាន់តែ*

ច្រើនឡើងៗហើយនៅពាសវាលពាសកាលលើពិភពលោក ជាពិសេសនៅក្នុងប្រទេសអ្នកមាន។ នៅក្នុងករណីជាច្រើន ឧក្រិដ្ឋជននៅក្នុងសង្គមរបស់យើងក៏មានគេរាប់បញ្ចូលផងដែរថា មានជំងឺសរសៃប្រសាទ។ លទ្ធផលដ៏ល្បីល្បាញមួយ ចេញមកដោយផ្ទាល់អំពីការងារស្រាវជ្រាវរបស់លោក ហ្វ្រឺត (Freud) គឺការទទួលស្គាល់ថា ពួកឧក្រិដ្ឋជននិងជនពាលអាវ៉ាសែ គឺពួកមនុស្សមានជំងឺសរសៃប្រសាទដែលត្រូវការព្យាបាល ជាជំនួសការផ្តន្ទាទោស។ នេះគឺជាទស្សនៈសេរីស្តីពីបញ្ហានេះ ដែលបានក្លាយជាគ្រឹះនៃការកែទម្រង់សង្គម «ជឿនលឿន» ទាំងអស់ដើម្បីជំនួសការ ផ្តន្ទាទោសដោយការធ្វើនីតិសម្បទាវិញ។

**៥-ចូរស្គាល់អ្នកជិតខាងរបស់លោក-អ្នក**

កាលណាយើងមិនបានឃើញថា តើមនុស្សដទៃរស់នៅយ៉ាងណានោះទេ យើងមិនអាចដឹងបែបបទផ្សេងៗនៃជីវភាពរស់នៅទេ។ ការធ្វើដំណើរ គឺជាទម្រង់អប់រំមួយដ៏ប្រសើរបំផុត។ ការជួបប្រាស្រ័យផ្ទាល់ខ្លួនជាមួយមនុស្សផ្សេងអំពីខ្លួនយើង ធ្វើឱ្យយើងមានអារម្មណ៍កាន់តែស្រឡាញ់រាប់អានគេ។ សេចក្តីមិនអត់ អធ្យាស្រ័យ ច្រើនតែកើតមកពីសេចក្តីល្ងង់មិនដឹងសេចក្តីត្រូវការ និងបែបបទគិតគូររបស់មនុស្សដទៃ។

**៦-សេចក្តីទោមនស្សរបស់មនុស្ស**

ព្រះពុទ្ធបានប្រៀនប្រដៅថា«សេចក្តីទោមនស្សទាំងអស់របស់ មនុស្សកើតចេញមកពីចំណង់អត្តទត្ថឬចំណង់អាត្មានិយម គឺចង់បានសេចក្តីសប្បាយឱ្យច្រើន ដែលប្រាក់អាចទិញបាន ចង់បានអំណាចឱ្យច្រើនលើសមនុស្សឯទៀត ហើយសំខាន់ជាងគេបំផុតគឺ ចង់រស់នៅជាអមតៈសូម្បីក្រោយពេលស្លាប់ហើយក្តី »។

ចំណង់ចង់បានអ្វីៗទាំងអស់នេះ ធ្វើឱ្យមនុស្សក្លាយជាមានគំនិតអាត្មានិយម។ គេគិតសម្រាប់តែខ្លួនគេប៉ុណ្ណោះ ចង់បានអ្វីៗសម្រាប់ខ្លួនគេប៉ុណ្ណោះ ហើយមិនរវីរវល់យកចិត្តគិតគូរអំពីអ្វីៗដែលកើតមានដល់មនុស្សដទៃឡើយ។ កាលណាសេចក្តីប្រាថ្នារបស់គេមិនបានបំពេញទេ គេក្លាយជាមនុស្សសោប់សោល់និងមានទុក្ខទោមនស្ស។ មាគ៌ាតែមួយគត់ដើម្បីគេចឱ្យផុតពីភាពតក់ក្រហល់នេះ គឺត្រូវបន្សាត់បង់នូវចំណង់ទាំងឡាយដែលបង្កឱ្យមានភាពសោប់សោល់តក់ក្រហល់នេះ។ នេះគឺជាការងារពិបាកណាស់ ប៉ុន្តែកាលណាមនុស្សអាចសម្រេចការងារនេះបានទើបគេឱ្យតម្លៃដល់ការងារនេះ។

**៧-ពេលវេលា នឹងព្យាបាលរបួសយើងឱ្យសះស្បើយ**

សេចក្តីកន្ទួលកន្ទួងផុតទៅ។ អ្វីដែលបន្តឱ្យយើងយំសោកនិងត្រូវបានបំភ្លេចចោលយ៉ាងតាប់។ លោក-អ្នកអាចនៅចាំថា លោក អ្នកបានស្រែកទ្រហោយំ ប៉ុន្តែមិនបានចងចាំថាហេតុអ្វីលោក អ្នកបានធ្វើយ៉ាងនោះទេ។ នៅពេលដែលយើងបានចម្រើនវ័យធំឡើង ហើយបានឆ្លងកាត់ជីវិតរស់នៅ យើងតែងឆ្ងល់ជាញឹកញយចំពោះហេតុយ៉ាងដូចម្តេច ដែលយើងដេកមិនលក់នៅពេលយប់ យើងត្រិះរិះពិចារណាអំពីរឿងអ្វីមួយដែលធ្វើឱ្យយើងក្រឡកចិត្តនៅពេលថ្ងៃ ឬអំពីហេតុយ៉ាងដូចម្តេចដែលនាំឱ្យយើងចិញ្ចឹមចិត្តគុំគួនអ្នកណាមួយ ដោយបណ្តោយឱ្យគំនិតដដែលៗវត់ឆ្លងកាត់សន្តានចិត្តរបស់យើងពាក់ព័ន្ធនឹងការត្រិះរិះថា តើយ៉ាងដូចម្តេចបានជាយើងមានគំនុំ។ យើងអាចប្រឡាតទឹងភ្លាមៗ ចំពោះរឿងអ្វីមួយ ហើយក្រោយបន្តិចមកចង់ដឹងថា យើងក្រោធទឹងពីរឿងអ្វី ហើយយើងភ្ញាក់ផ្អើលដោយដឹងថាយើងចំណាយពេល និងកម្លាំងឥតប្រយោជន៍។ យើងបានបន្តការក្រោធទឹងដោយចេតនាក្នុងពេលដែលយើងអាចបញ្ឈប់កំហឹងនោះបាន ហើយចាប់ផ្តើមត្រិះរិះអំពីរឿងអ្វីផ្សេងដែលល្អជាង។

ទោះជាសេចក្តីព្រួយកន្ទួលរបស់យើងជាអ្វីក៏ដោយ ហើយទោះជាយើងមានអារម្មណ៍ឈឺចាប់យ៉ាងណាក៏ដោយ ពេលវេលានឹងព្យាបាលរបួសចិត្តរបស់យើង។ ប៉ុន្តែប្រាកដណាស់ វាត្រូវតែមានអ្វីមួយដែលយើងអាចធ្វើដើម្បីរក្សាខ្លួនយើងកុំឱ្យប៉ះទង្គិចជាមុនសិន។ តើហេតុអ្វីក៏យើងបណ្តោយឱ្យអ្នកដទៃឬសេចក្តីព្រួយកន្ទួលមកបង្ខាតកម្លាំងរបស់យើង ហើយធ្វើឱ្យយើងកើតទុក្ខ? ចម្លើយ គឺអ្នកដទៃមិនបានធ្វើទេ។ គឺខ្លួនយើងទេ ដែលធ្វើឱ្យខ្លួនឯងកើតទុក្ខ។

លោក-អ្នកអាចមានកន្ទួលខ្លះនៅកន្លែងធ្វើការរបស់លោកអ្នក ប៉ុន្តែលោក-អ្នកមិនត្រូវចម្លងបរិយាកាសអ័ព្ទអ័ួរទៅក្នុងគ្រួសាររបស់លោក-អ្នកទេ។ លោក-អ្នកត្រូវដឹងច្បាស់ថាបញ្ហាទាំងឡាយនោះមានទីបញ្ចប់របស់វា។ ដំណោះស្រាយអាចរកឃើញនៅក្នុងការសម្រេចបាននូវការរំដោះ (ឬសេរីភាព) ផុតពីចំណង់អត្តទត្តភាពរបស់យើងតាមរយៈការលុបបំបាត់ភាពច្របូកច្របល់និងអវិជ្ជាក្នុងគ្រប់រូបភាព។

កាលណាយើងបរាជ័យក្នុងការរកឃើញដំណោះស្រាយចំពោះបញ្ហាណាមួយ យើងតែងមានទំនោរទម្លាក់កំហុសលើអ្នកដទៃ ដើម្បីលុបលាងកំហុសរបស់យើង។ យើងមិនបានត្រៀមខ្លួន ដើម្បីទទួលស្គាល់ ចំណុចខ្វះខាតផ្ទាល់របស់យើងទេ។ វាជាការងាយស្រួលដើម្បី

ទម្លាក់ការស្តីបន្ទោសទៅលើអ្នកដទៃ។ តាមពិតមានមនុស្សខ្លះសប្បាយនឹងប្រព្រឹត្តដូច្នេះទៀតផង។ នេះគឺជាអាកប្បកិរិយាខុសឆ្គងទាំងស្រុងមិនត្រូវប្រកាន់យក។ យើងមិនត្រូវបង្ហាញគំនិតព្យាបាទចំពោះអ្នកដទៃឡើយ។ យើងត្រូវខិតខំឱ្យអស់លទ្ធភាពដោយសេចក្តីព្យាយាមនិងដោយភាពស្ងប់ស្ងៀម ដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់យើង។ យើងត្រូវត្រៀមខ្លួនប្រឈមមុខដោះស្រាយសេចក្តីលំបាកណាមួយដែលយើងបានជួបប្រទះ។

**៨-បរិយាកាសសុខដុម**

ពាក្យកំប្លែងនិងពាក្យកត់សម្គាល់ តម្រង់មកលើខ្លួនលោក-អ្នក ក្នុងបំណងអាក្រក់ត្រូវតែបានបញ្ចៀសចេញដោយអារម្មណ៍រីករាយ។ នេះគឺជាបែបបទមួយ ដើម្បីបញ្ចៀសអរិភាពជាមួយអ្នកណាមួយ ប្រឡោតឡឹងក្នុងពេលលេងល្បែង នឹងនាំឱ្យលោក-អ្នកជាប់ចំណង។ លោក-អ្នកនឹងត្រូវបោះបង់ចោលជ័យជំនះ ដែលអាច ឈ្នះបាននោះនឹងបន្ថុចរហូតដល់សេចក្តីសប្បាយរីករាយរបស់មនុស្សទាំងឡាយដែលទស្សនាល្បែងនោះទៀតផង។

គ្មានមធ្យោបាយណាមួយ ដែលលោក-អ្នកអាចប្តូរផ្លាស់អ្នកណា មួយបានក្នុង ពិភពលោកនេះ ឱ្យទៅតាមមាគ៌ាត្រិះរិះរបស់លោក-អ្នក បានទេ។ មាគ៌ានេះសោតទៀត ក៏គ្មានអ្នកណាចង់បានដែរ។ ប្រសិនបើមនុស្សគ្រប់រូបយល់ស្របជាមួយលោក-អ្នក នោះពិភពលោកនឹងពុំមានយោបល់ខ្វែងគ្នាទេ។

មានបែបបទច្រើនយ៉ាងដើម្បីកែប្រែមនុស្ស កាលណាមនុស្សនោះប្រព្រឹត្តខុសដោយការរិះគន់ ដោយការស្តីបន្ទោស និងដោយការជេរប្រទេចទាំងកំហឹងទៅលើមនុស្សនោះជាសាធារណៈ។ លោក-អ្នក កំពុងធ្វើឱ្យគេមានអារម្មណ៍មួហ្មង អៀនខ្មាស គឺមិនមែនជួយកែលំអគេទេ។ ការរិះគន់គឺប្រាកដជាបង្កើតឱ្យមានសត្រូវកាន់តែច្រើន។ ប្រសិនបើលោក-អ្នកអាចបង្ហាញការយកចិត្តទុកដាក់ចំពោះអត្ថប្រយោជន៍អនាគតរបស់មនុស្សណាម្នាក់ ដោយប្រើពាក្យផ្អែមល្ហែម មនុស្សនោនឹងអរគុណលោក-អ្នក ចំពោះឥរិយាបថនោះនៅថ្ងៃណាមួយ។

ចូរកុំប្រើពាក្យគំរោះគំរើយ ឬពាក្យចាក់ដោត កាលណាលោក-អ្នកសម្តែងទស្សនៈរបស់លោក-អ្នក លើបញ្ហាណាមួយ។ ភាសាទូត សម្តីទន់ភ្លន់ និងពាក្យពេចន៍គួរសមមិនប៉ះទង្គិចអារម្មណ៍បុគ្គលណាឡើយ។ តាមពិតទៅពាក្យសម្តីទាំងនោះ នឹងបើកច្រកយ៉ាងច្រើនឱ្យលោក-អ្នក។

ចូរកុំមានអារម្មណ៍ចង់ប្រកែក កាលណាមានគេចង្អុលប្រាប់កំហុសផ្ទាល់ខ្លួនរបស់លោកអ្នក។ កំហុសរបស់លោក-អ្នកគឺជាផ្លាកសញ្ញាប្រាប់ផ្លូវឱ្យលោក-អ្នករៀន ធ្វើខ្លួនឱ្យបានសុក្រឹត។ សភាវៈចិត្តទោរទន់ទៅរកការលាក់បាំងចំណុចខ្វះខាតគឺជាលក្ខណៈអន់ថយ។ កាលណាអ្នកណាមួយប្រឡូតទីង អ្នកនោះនឹងស្រែកនិយាយចេញមកនូវរឿងរ៉ាវយ៉ាងច្រើន ដែលគួរតែរក្សាទុកកុំនិយាយ។ ចូរកុំបរិហារការសម្ងាត់ផ្ទាល់ខ្លួនរបស់មិត្តចាស់ណាមួយឡើយ បើទោះជាក្រោធខឹងជាមួយគេយ៉ាងណាក៏ដោយក្នុងពេលឥឡូវនេះ។ លោក-អ្នកបានត្រឹមតែបន្ទោកបន្ទាបខ្លួន លោក-អ្នកផ្ទាល់ក្នុងពេលតទៅ ហើយមនុស្សឯទៀតៗមិនអាចទទួលយកលោក-អ្នកជាមិត្រជិតស្និទ្ធបានសោះឡើយ ចាប់ពីពេលនោះទៅមុខ។ មនុស្សដទៃនឹងយល់ថា លោក-អ្នកអាចបរិហារកេរ្តិ៍គេដដែលទៀតដើម្បីធ្វើឱ្យមិត្រភក្តិចាស់ឈឺចាប់ ៖ គ្មាននរណាម្នាក់ទុកចិត្តលោក-អ្នកកើតទេ។

**៩-ចូរមានសេចក្តីក្លាហានប្រឈមមុខពាក្យរិះគន់**

រសជាតិផ្អែម បង្កើតឱ្យមានជំងឺតម្កាត់ រសជាតិល្វីងនាំមកជាមួយនូវថ្នាំ ព្យាបាលរោគ។ ពាក្យពោល សរសើរគឺជារសជាតិផ្អែម រសជាតិផ្អែមច្រើនពេក បណ្តាលឱ្យកើតជំងឺតម្កាត់ ពាក្យរិះគន់គឺប្រៀបបាននឹងគ្រាប់ ថ្នាំល្វីងដែលព្យាបាលរោគឱ្យសះស្បើយបាន។ យើងត្រូវមានសេចក្តីក្លាហានដើម្បីទទួលស្វាគមន៍ពាក្យរិះគន់ ហើយមិនត្រូវខ្លាចពាក្យរិះគន់នោះទេ។

«រូបភាពអាក្រក់ (Theugliness) ដែលយើងមើលឃើញក្នុងមនុស្សដទៃ គឺជាពុម្ពចាំងចេញពីចរិតលក្ខណៈ ផ្ទាល់របស់យើង»។

ជីវភាពរបស់មនុស្សម្នាក់ កាលៈទេសៈ និងពិភពលោក គឺជាពុម្ពចាំងចេញពីគំនិត និងជំនឿផ្ទាល់របស់មនុស្សនោះ។ មនុស្សទាំងអស់ គឺជាកញ្ចក់ឆ្លុះមើលខ្លួនឯងផ្ទាល់នូវសេចក្តីឈឺចាប់ ជំងឺតម្កាត់ និងអ្វីៗទាំងអស់។

**១០-សេចក្តីសុខ ( សុភមង្គល ) និងសម្ភារនិយម**

មនុស្សជាច្រើនជឿថា គេអាចដោះស្រាយបញ្ហារបស់គេទាំងអស់បានដោយសារមានប្រាក់។ ប៉ុន្តែគេមិនបានដឹងច្បាស់ទេថា ប្រាក់ខ្លួនវាផ្ទាល់ក៏មានបញ្ហាជាប់មកជាមួយខ្លួនវាដែរ។ ប្រាក់មិនអាចដោះស្រាយបញ្ហាទាំងអស់បានទេ។

មនុស្សភាគច្រើនមិនបានត្រិះរិះត្រឹមត្រូវទាល់តែសោះ។ ក្នុងមួយជីវិតរបស់គេ គេប្រៀបដូចជាឆ្កែប្រដេញរត់តាមក្រោយទន្សាយធ្លាក់ដូច្នោះ។ ពេលណាការប្រដេញបាន

បញ្ចប់ ចំណង់ស្ទុះស្ទារទាំងអស់ក៏ស្ងប់ម្ងាប់អស់ទៅ។ នេះគឺដូចគ្នាសុទ្ធសាធទៅនឹងចរិតនៃកាមសុខ នៅក្នុងពិភពលោក មួយពោរពេញដោយវត្ថុកាមល្អប្រណីត។ ពេលណាវត្ថុជាទីប្រាថ្នាចាប់យកបាន ហើយសេចក្តីសុខឬ(សុភមង្គល) ក៏បានបញ្ចប់ ហើយចំណង់ចង់បានអ្វីថ្មីទៀតក៏កើតឡើង។ ការបានវត្ថុជាទីប្រាថ្នា ហាក់ដូចជាមិនជាទីពេញចិត្តទាំងស្រុងដូចជាការប្រដេញដូច្នោះ។

កាលណាយើងបាត់បង់អ្វីមួយ ចូរចងចាំដំបូន្មានដូចតទៅនេះថា «ចូរកុំនិយាយថា នេះជារបស់ឯង ហើយនោះជារបស់អញ ចូរគ្រាន់តែនិយាយថា នេះទៅខាងឯង ហើយនោះមកខាងអញ ដូច្នេះយើងអាចមិនសោកស្តាយស្ទើកំពុងរលុបរលាយទៅក្នុងបណ្តាវត្ថុដ៏រុងរោចន៍ ទាំងអស់ដែលបានឈប់មានអត្ថិភាព »។

ទ្រព្យធនមិនមែនជារបស់អ្វីមួយ សម្រាប់ឱ្យលោក-អ្នកបន្សល់ ទុកដើម្បីបំប៉នតណ្ហានោះទេ។ ទ្រព្យធនទុកសម្រាប់ថែរក្សាសុខុមាលភាពរបស់លោក-អ្នកក៏ដូចជា សុខុមាលភាពរបស់អ្នកដទៃ។ ចូរខិតខំកសាងពិភពលោកឬបរិស្ថានជុំវិញលោក-អ្នក ឱ្យជាកន្លែងមួយដ៏ប្រសើរសម្រាប់រស់នៅ។ ចូរប្រើប្រាស់ទ្រព្យធនរបស់លោក-អ្នកប្រកបដោយគតិបណ្ឌិត ជួយកាត់បន្ថយទុកលំបាករបស់ជនក្រីក្រ ជនមានជំងឺតម្កាត់និងជនចាស់ជរា។ ចូរបំពេញករណីយកិច្ចរបស់លោកអ្នកចំពោះប្រជាពលរដ្ឋរបស់លោក-អ្នក ប្រទេសជាតិរបស់លោក-អ្នក និងសាសនារបស់លោក-អ្នក។ កាលណាដល់ពេលវេលា ដែលលោក-អ្នកត្រូវចាកចេញទៅចូររំពឹងគិតថា តើសន្តិភាពនិងសុភមង្គលអ្វីខ្លះ ដែលបានកើតមានក្នុងពេលលោក-អ្នករំលឹកឡើងវិញនូវអំពើជាកុសល និងមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនដែលលោក-អ្នកបានធ្វើក្នុងអតីតកាល។

ស្វែងរកទ្រព្យធនតាមរយៈល្បែងស៊ីសង គឺប្រៀបបានទឹងក្តីសង្ឃឹមរង់ចាំពពកកំពុងរសាត់មកដើម្បីបាំងថ្ងៃឱ្យយើងដូច្នោះ។ ផ្ទុយទៅវិញចង់បានសេចក្តីសម្បូរសប្បាយតាមរយៈការងារប្រកបដោយសេចក្តីព្យាយាមជាប់លាប់ គឺរ៉ាប់រងធានាបានស្មើនឹងការកសាងជម្រក ជាអចិន្ត្រៃយ៍មួយការពារ កម្តៅថ្ងៃនិងភ្លៀងខ្យល់។

«ទ្រព្យធនរបស់លោក-អ្នកនឹងសេសសល់នៅកាលណាលោក-អ្នកចែកឋានទៅ។ មិត្តភក្តិ និងញាតិសន្តានរបស់លោក-អ្នក និងជូនដំណើរលោក-អ្នកដល់ត្រឹមតែផ្លូវរបស់

លោក-អ្នកប៉ុណ្ណោះ។ ប៉ុន្តែអំពើជាកុសលឬជាអកុសលដែលលោក- អ្នក បានធ្វើហើយក្នុងអំឡុងជីវិតកាលរបស់លោក-អ្នក នឹងតាមជង្ហែលោក-អ្នកហួសពីផ្នូរទៅទៀត»។

ការបំពេញសុបិន្តអំពីទ្រព្យសម្បត្តិបាន អាចចាត់ទុកបានដូចជា ការជប់ ប៉ុន្តែសេចក្តីភ័យខ្លាចនិងសេចក្តីកង្វល់ចិត្ត ដេកចាំជានិច្ចឱ្យមន្តអាគមជប់នោះសាបរលាយទៅ។ បែបបទរស់នៅជាមួយអ្នកមានទ្រព្យរមែងនាំមកនូវចំណែកនៃចិត្តវិបល្លាសរបស់វា។ ជាមួយនឹងការប្រើប្រាស់ទ្រព្យធនខ្ជះខ្ជាយ បាតុភាពដ៏សាមញ្ញនៅក្នុងជីវិត ដូចជាមិត្តភាព ទំនុកចិត្ត និងវិសាលភាព(ភាពជិតស្និទ្ធ) ដែលធ្លាប់តែកើតមាននៅក្នុងកាលៈទេសៈដ៏ធម្មតាបំផុត ប្រែក្លាយជាពុំអាចសម្រេចបានទេ។ កាលណាបែបបទរស់នៅ មួយចាប់ផ្តើមបង្កើតឱ្យមានអសន្តិសុខវា តម្រូវឱ្យមានគតិបណ្ឌិតដើម្បីកែប្រែ តម្រង់ខ្លួនឱ្យឋិតក្នុងគន្លងត្រូវឡើងវិញ។ ធនធានតែងមានការដោះដូរធ្វើសម្បទាន សេចក្តីសុខដោយសារមានធនធាន ត្រូវបានកាត់បន្ថយតិចទៅដោយសារមានសេចក្តីភ័យខ្លាចនិងសេចក្តី ព្រួយបារម្ភអំពីការបាត់បង់ធនធានទាំងនោះ។

សម្រាប់សេចក្តីសុខផ្ទាល់ខ្លួនរបស់យើង យើងគប្បីស្វែងរកទ្រព្យឱ្យបានតាមគន្លងធម៌។ ត្រូវបានលោកសរសើរអ្នកទាំងឡាយណាដែលចេះចិញ្ចឹមជីវិតរបស់ខ្លួន ដោយមិនបៀតបៀនអ្នកដទៃ» ព្រះពុទ្ធទ្រង់បានសម្តែងយ៉ាងនេះ។ សេចក្តីសុខមិនអាចឋិតនៅបានយូរ និងមានអត្ថន័យពេញលេញទេប្រសិនបើធនធានបន្សល់ទុកនូវសេចក្តីសោកសៅ និងទុក្ខទោសនៅក្នុងគន្លងប្រព្រឹត្តទៅរបស់វា។ ធនធានដែលប្រើប្រាស់ខ្ជះខ្ជាយបង្កើតឱ្យមានសេចក្តីប្រណែនឈ្នានីស ប៉ុន្តែធនធានដែលប្រើប្រាស់ត្រឹមត្រូវល្អទាក់ទាញបាននូវសេចក្តីគោរព។

ធនធានរបស់លោក-អ្នក អាចលើកស្ទួយឥទ្ធិពលត្រកូល គ្រួសាររបស់លោក-អ្នកបានតែប៉ុណ្ណោះ ប៉ុន្តែមិនអាចលើកស្ទួយសន្តានចិត្តលោក-អ្នកបានទេ។ មានតែគុណធម៌ផ្ទាល់របស់លោក-អ្នកតែ ប៉ុណ្ណោះដែលអាចលើកស្ទួយសន្តានចិត្តលោកអ្នកបាន។ សម្លៀកបំពាក់របស់លោក-អ្នកអាចតែងលំអសរីរាង្គលោក-អ្នកបាន ប៉ុន្តែមិនអាចតែងលំអសន្តានចិត្តលោក-អ្នកបានទេ។ គឺមានតែចរិយាល្អប្រពៃរបស់លោក -អ្នកតែប៉ុណ្ណោះ ទើបអាចតែងលំអសន្តានចិត្តលោក-អ្នកបាន»។

នៅទីអវសាន្ត គេបានចាត់ទុកជាមន្គលមួយដោយបានដឹងថា សេចក្តីសុខគឺ ជាទឹកអប់ដែលលោក-អ្នកមិនអាចស្រោចស្រពលើអ្នកដទៃ ដោយមិនបានស្រោចស្រពពីរបើដំណក់លើខ្លួនលោក-អ្នកផងទេ។ ពិភពលោកមិនមែនជាអ្វីមួយដូចដែលលោក-អ្នកចង់បាននោះទេ ប៉ុន្តែលោក-អ្នកអាចសម្របសម្រួលហឫទ័យរបស់លោក-អ្នកដើម្បីរកឱ្យឃើញសេចក្តីសុខនៅក្នុងពិភពលោកនេះបាន។ គឺមានតែពេលណា ដែលលោក-អ្នកបានខិតខំអត់ធ្មត់ធ្វើអំពើល្អតែប៉ុណ្ណោះ ទើបលោកអ្នកលេចឡើង ខ្ពស់លើមនុស្សឯទៀតក្នុងសេចក្តីយល់ដឹង និងសេចក្តីសុខផ្ទាល់ខ្លួនបាន។

«ប្រសិនបើយើងចង់រកឱ្យឃើញសេចក្តីសុខ ចូរយើងឈប់ត្រិះរិះអំពីកតញ្ញូតា និងអកតញ្ញូតា ហើយចូរឱ្យដើម្បីសេចក្តីសប្បាយនិងឱ្យនៅក្នុងចិត្ត។ អកតញ្ញូតា គឺជាសភាវៈធម្មតាដូចជាស្មៅរាតត្បាត។ កតញ្ញូតាគឺដូចជាផ្កាកូឡាប។ វាត្រូវតែបានថែបំប៉ន ស្រោចទឹក ពូនជ្រំ ថ្នាក់ថ្នម និងការពារ »។

**១១-ចូរប្រព្រឹត្តប្រកបដោយគតិបណ្ឌិត**

មនុស្សត្រូវចេះប្រើប្រាស់យុវវ័យ ទ្រព្យសម្បត្តិនិងចំណេះដឹងរបស់ខ្លួនឱ្យស្របតាមពេលវេលា និងទីកន្លែងព្រមទាំងនៅក្នុងបែបបទសមស្រប ដើម្បីជាអត្ថប្រយោជន៍ផ្ទាល់ខ្លួនក៏ដូចជា ដើម្បីអត្ថប្រយោជន៍អ្នកដទៃ។ ប្រសិនបើគេប្រើប្រាស់ខុសទូវបុព្វសិទ្ធិរបស់គេ វានឹងបង្កើតឱ្យមានសេចក្តីអន្តរាយ។ មនុស្សត្រូវមានកម្លាំងពលំគ្រប់គ្រាន់ ដើម្បីស្គាល់ពេលណា គេចុះខ្សោយត្រូវមានសេចក្តីក្លាហាន គ្រប់គ្រាន់ដើម្បីជំនះសេចក្តីភ័យខ្លាច ត្រូវមានធន្ទះមោះមុតឥតចុះញ៉មក្នុងបរាជ័យប្រកបដោយយុត្តិធម៌ ត្រូវមានចរិតទន់ភ្លន់ និងសុភាពរាបសាក្នុងជ័យជំនះ» ។

មានមនុស្សខ្លះមានភ័ព្វវាសនាខ្ពស់ដោយបានទទួលទ្រព្យសម្បត្តិស្តុកស្តម្ភភ្លាមៗតាមរយៈសំណាងល្អ ឬកេរមរតក។ ប៉ុន្តែមិនមានមនុស្សច្រើននាក់ទេ ដែលប្រកបដោយគតិបណ្ឌិតចេះការពារថែរក្សាឬ ប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងគន្លងល្អ។ អ្វីមួយដែលគេបានមកដោយមិនបង្ហូរញើសថ្លាសរបស់គេទេ ច្រើនតែចំណាយខ្ជះខ្ជាយតាមរយៈការប្រើប្រាស់បំពាន។

**១២-ត្រូវចេះសម្របសម្រួលខ្លួនយើង**

ទំនៀមទម្លាប់និងប្រពៃណីគឺជាចំណងដ៏សំខាន់សម្រាប់ការរៀន និងការចែករំលែកបទពិសោធន៍របស់ មនុស្សនៅក្នុងសហគមន៍ណាមួយ។ ឧកតោកោដិកបញ្ហាឬបញ្ហាមួយ

មានចុងចំណាំងសងខាង (thedilemma) ដែលយើងកំពុងប្រឈមមុខក្នុងពិភពលោកដ៏ប្រែប្រួលឥតឈប់ឈរសព្វថ្ងៃគឺថា តើត្រូវរស់នៅជាមួយអតីតកាលឬត្រូវរស់នៅផ្តាច់ចេញពីអតីតកាល។ វាតែងកើតមាន «ចន្លោះជំនាន់» ជានិច្ចរវាងពួកមនុស្សចាស់និងពួកមនុស្សក្មេង ដោយសារមានទស្សនទាន (ឬមតិបញ្ញត្តិ) ផ្សេងពីគ្នា អំពីកាលៈទេសៈ និងតម្លៃ (វាលុសេ) ដែលកំពុងប្រែប្រួលជាប្រចាំ។ ពួកចាស់បារម្ភ ខ្លាចពួកក្មេងបោះបង់បេតិកភណ្ឌរបស់ខ្លួនចោល ឯពួកក្មេងព្រួយកង្វល់ខ្លាចបេតិកភណ្ឌបរមបុរាណនោះប្រែក្លាយជាឧបសគ្គរាំងផ្លូវក្នុងជីវភាពសម័យថ្មីនេះ។ ការប្តូរផ្លាស់ណាមួយត្រូវតែបានពិចារណាដោយល្អិតល្អន់ជានិច្ច។

វប្បធម៌ប្រជាប្រិយ៍បានបង្កើតឡើងនូវគោរពរូបបណ្តោះអាសន្ន(momentary idols) និងវីរបុរសប្រជាប្រិយ៍ដែលបង្ហាញរូបភាពនៃបែបបទរស់នៅប្រកបដោយទំនាស់។ ឧបករណ៍ឃោសនាមហាជនបានជួយផ្សព្វផ្សាយរូបភាពទាំងឡាយបែបនោះថែមទៀត ធ្វើឱ្យខួរក្បាលយុវជនទោរទន់ទទួលយកអ្វីៗដែលបានឃើញ។ វាអាចជាសេចក្តីផ្សព្វ ផ្សាយនយោបាយឬសង្គមនៅក្នុងចលនាបែបនេះ ដូចជាចលនាហ៊ីពី្វ ឬចលនាយុពី្វ (the Hippie or Yuppic movements) ប៉ុន្តែ អ្វីដែលមានសារសំខាន់ជាងអាយុជីវិតគឺ យុវជនត្រូវមានគតិបណ្ឌិតរបស់មនុស្សចាស់ ដើម្បីវែកញែកអ្វីដែលល្អចេញពីអ្វីដែលអាក្រក់។ តម្លៃដ៏ល្អរបស់អតីតៈ ដែលបានឆ្លងកាត់ពេលវេលា និងការសាកល្បងរួចហើយមិនប្រែប្រួលទេ។ តម្លៃទាំងឡាយ ដូចជាការសន្សំសំចៃ សុចរិត សប្បុរសធម៌និងការងារហ្មត់ចត់ ដើម្បីមានជីវភាពរស់នៅប្រកបដោយសេចក្តីចុំរើន ឋិតនៅថ្មីជានិច្ចក្នុងសហគមន៍ណាក៏ដោយ។

នៅក្នុងបរិយាកាសទ្វីបអាស៊ី ប្រពៃណីនិងទំនៀមទម្លាប់ អាពាហ៍ពិពាហ៍ និងបុណ្យសព មានសារសំខាន់ខ្លាំងណាស់។ បញ្ហាចោទគឺថា តើគេត្រូវចំណាយប្រាក់ និងពេលវេលាយ៉ាងច្រើនដើម្បីបន្តទ្រទ្រង់ប្រពៃណី និងទំនៀមទម្លាប់ទាំងនោះនៅក្នុងពិភពលោកបច្ចុប្បន្នឬយ៉ាងណា? តើប្រពៃណីនិងទំនៀមទម្លាប់ទាំងនោះនៅតែជាការចាំបាច់មែនឬទេ? គ្មានដំបូន្មានណាគ្រាន់បើជាងដំបូន្មានដែលព្រះពុទ្ធបានប្រទាននៅក្នុងកាលាមសូត្រថា ៖

“កាលណាអ្នកដឹងក្នុងខ្លួនអ្នកថា គំនិតទាំងឡាយនេះមិនចម្រើនទេ ប្រឈមមុខនឹងការរិះគន់ត្រូវបណ្ឌិតស្តីបន្ទោសបើប្រកាន់យកហើយប្រើប្រាស់គំនិតទាំងនោះ វានឹងនាំឱ្យមានគ្រោះថ្នាក់និង សេចក្តីទុក្ខបន្ទាប់មក អ្នកត្រូវបោះបង់ចោលគំនិតនោះទៅ...”។ កាលណា

អ្នកដឹងក្នុងខ្លួនអ្នកថា "ទស្សនៈទាំងឡាយនេះជាកុសលគ្មានការស្តីបន្ទោសត្រូវបានបណ្ឌិតទាំងឡាយពោលសរសើរ កាលបើប្រកាន់យកហើយអនុវត្តតាមទស្សនៈទាំងឡាយនោះវានឹងនាំឱ្យមានសុខុមាលភាព និងសេចក្តីសុខ តមកអ្នកត្រូវប្រតិបត្តិតាមនិងប្រកាន់យកទស្សនៈទាំងឡាយនោះចុះ"។

មនុស្សម្នាក់ៗគឺជាជីវិតមួយរបស់សកលលោកជាតុ។ ដរាបណាមនុស្សនៅតែជាប់ជំពាក់ជាមួយសង្គមមនុស្សហើយនិងការរៀបចំសណ្តាប់ធ្នាប់ពិភពលោកជាថ្មី ឱ្យមានភាពប្រសើរឡើង ពេលវេលានឹង តភ្ជាប់ចន្លោះរវាងពួកក្មេង និងពួកមនុស្សចាស់បានជាដរាប។ សេចក្តីព្រួយបារម្ភនិងសេចក្តីភ័យខ្លាចទៅលើ ទិសប្រែប្រួលនឹងកាន់តែរសាយក្រញាំរបស់វា ។ ពួកមនុស្សចាស់ត្រូវតែរំលឹកថា តើឪពុកម្តាយរបស់ពួកគាត់ផ្ទាល់បានជំទាស់ទៅនឹងបែបបទនៃការរស់នៅសម័យថ្មីខ្លះៗ ដែលគេនិយមកាលពីពេលគាត់នៅក្មេងៗយ៉ាងដូចម្តេចខ្លះ តែប៉ុណ្ណោះបានហើយ។ សេចក្តីសន្តោស ចំពោះភាពផ្សេងគ្នាស្តីពីបញ្ហាណាមួយ គឺជាគុណធម៌មួយ។ ឥរិយាបថបើកជំហរអាច ជាឥរិយាបថមួយប្រកបដោយសេចក្តីសុខ។

**១៣-ចូរយកចិត្តទុកដាក់ចុះកិច្ចផ្ទាល់របស់លោក-អ្នក**

គឺជាសុភមង្គលមួយដែលលោកអ្នកយកចិត្តគិតគូរ កិច្ចការផ្ទាល់ខ្លួនរបស់ លោកអ្នកដោយពុំមានគំនិតសង្ស័យចំពោះមនុស្សដទៃ។ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ៖ "បុគ្គលមិនត្រូវចោទប្រកាន់អ្នកដទៃចំពោះកំហុស និងរឿងហេតុដែលគេបានធ្វើនិងមិនបានធ្វើនោះឡើយ ប៉ុន្តែត្រូវចោទប្រកាន់អំពើរបស់ខ្លួនឯងផ្ទាល់ដែលបានភ្លេចធ្វើ "។

"អ្នកដែលអង្កេតឃើញកំហុសអ្នកដទៃជានិច្ច ហើយក្រោធខឹងកិលេសផ្ទាល់របស់គេរមែងកើនឡើង។ អ្នកនោះឋិតនៅឆ្ងាយអំពីការបំផ្លាញកិលេសឱ្យវិនាស"។

"គេងាយឃើញទោសកំហុសអ្នកដទៃ ប៉ុន្តែកំហុសផ្ទាល់ខ្លួនរបស់គេពិបាកមើលឃើញណាស់។ បុគ្គលបក់បង្នើរកំហុសរបស់អ្នកដទៃ បីដូចជាស្រូវ ប៉ុន្តែកំហុសរបស់ខ្លួនគេផ្ទាល់ គេខិតខំលាក់ដូចជា ព្រានប្រមាញ់ដ៏មានល្បិចកល ខិតខំលាក់បំពួនខ្លួនគេផ្ទាល់ដូច្នោះ"។ គ្មាននរណាម្នាក់គេចផុតពី ពាក្យនិន្ទាទេ។ ព្រះពុទ្ធទ្រង់មានបន្ទូលថា ៖ "មនុស្សខ្លះស្តីបន្ទោសអ្នកដទៃព្រោះគេនៅស្ងៀមស្ងាត់មិននិយាយស្តី គេស្តីបន្ទោសមនុស្សទាំងឡាយដែលនិយាយច្រើនពេកហើយ និងមនុស្សទាំងឡាយ ដែលនិយាយដឹងប្រមាណ។ ព្រោះហេតុនេះគ្មាន នរណាមួយនៅក្នុងលោកនេះមិនបានរងនូវការស្តីបន្ទោសនោះទេ"។ ព្រះអង្គ

មានបន្ទូលវែងឆ្ងាយទៀតថា ៖ "វាមិនដែលមាន ទោះនៅក្នុងអតីតកាលទោះនៅក្នុងអនាគតកាលឬនៅក្នុងបច្ចុប្បន្នកាល មនុស្សណាម្នាក់ដែលត្រូវគេស្តីបន្ទោសតែរហូត ឬគេសរសើរតែរហូតនោះទេ"។

មិនមានមនុស្សទាំងអស់ ដែលបានរិះគន់លោក-អ្នកសុទ្ធតែជាសត្រូវរបស់ លោក-អ្នកទេ។ លោក-អ្នក អាចប្រើឱកាសនៃការរិះគន់របស់គេ ដើម្បីរកឱ្យឃើញចំណុចខ្សោយនៅក្នុងខ្លួនរបស់លោកអ្នកផ្ទាល់ ដែលលោក-អ្នកមិនអាចមើលឃើញ។

លោក-អ្នកមិនគួរបោះបង់ការងារល្អ ឬការងារជាកុសលដោយសារតែពាក្យរិះគន់ប៉ុណ្ណោះទេ។ ប្រសិនបើលោក-អ្នក អាចទទួលស្គាល់ចំណុចខ្សោយផ្ទាល់ខ្លួនរបស់លោក-អ្នក នោះលោកអ្នកប្រាកដជាមានពលានុភាពញាណសតិ ដណ្តើមយកជោគជ័យបាន។ "អរិយបុគ្គលទាំងឡាយមិនគេចចេញ ពីគន្លងត្រូវទោះបីជាមានហេតុការណ៍អ្វីកើតឡើងក៏ដោយ ហើយក៏មិនឈ្លះឈ្លានរត់តាមលោកិយសុខដែរ។ បណ្ឌិតទាំងឡាយរមែងឋិតនៅស្ងប់ស្ងៀម ហើយមានចិត្តនឹងន៌ទាំងនៅក្នុងសេចក្តីសប្បាយ ទាំងនៅក្នុងសេចក្តីទុក្ខព្រួយ "។

**១៤-ចូរកុំមានចិត្តអគតិ ( ចិត្តលំអៀង )**

លោក-អ្នកមិនគួរធ្វើសេចក្តីសម្រេចចិត្ត ដ៏ប្រញាប់ប្រញាល់ណាមួយចំពោះបញ្ហាណាមួយកាលណា លោក-អ្នកមានអារម្មណ៍មួហ្មងឬឋិតក្រោមកំហឹងឆាបឆេះនោះឡើយ។ សេចក្តីសម្រេចចិត្ត ឬសេចក្តីសន្និដ្ឋានណាមួយធ្វើឡើងក្នុងអំឡុង កាលបែបនោះអាចនឹងបានជា ហេតុការណ៍មួយដែលលោកអ្នកអាចសោកស្តាយថ្ងៃណាមួយ។ ចូរទុកឱ្យចិត្តរបស់លោក-អ្នកស្ងប់ស្ងាត់ជាមុនសិន ហើយត្រិះរិះពិចារណា។ បន្ទាប់មកសេចក្តីវិនិច្ឆ័យរបស់លោក-អ្នកនឹងមិនមានអគតិទេ។

ចូរបណ្តុះបណ្តាលសេចក្តីសន្តោស ពីព្រោះសេចក្តីសន្តោស ជួយលោកអ្នកឱ្យមានសមានចិត្តជាមួយ សេចក្តីទុក្ខព្រួយរបស់មនុស្សដទៃ។ ចូរជៀសវាងសេចក្តីរិះគន់ មិនចាំបាច់។ ចូរខិតខំស្វែងយល់ថាសូម្បីតែតួអង្គ មនុស្សដ៏ល្អបំផុតក៏គេចមិនផុតពីកំហុសដែរ។ ចំណុចខ្សោយដែល លោក-អ្នកឃើញមាននៅក្នុងអ្នកជិតខាងរបស់លោក-អ្នក អាចត្រូវបានរកឃើញនៅក្នុងខ្លួនលោក-អ្នកផ្ទាល់។ គេបាននិយាយថា អ្នកមិនត្រូវចោលដុំថ្ម ទៅលើអ្នកដទៃនៅពេលលោក-អ្នកកំពុងឋិតនៅក្នុងផ្ទះកញ្ចក់នោះទេ ។

***សគារវតា*** *(ឬសេចក្តីគោរពសេចក្តីសុភាពរាបសា ការបន្ទាបខ្លួនឬបន្ទោនកាយ)*។

សគារវតា (Humility) គឺជារផ្នាន់របស់ជនជាបណ្ឌិតដើម្បីដឹងនូវភាពផ្សេងគ្នា រវាងអ្វីដែលកំពុងមានអត្ថិភាព និងអ្វីដែលមិនទាន់មានអត្ថិភាពនៅឡើយ។ ព្រះពុទ្ធព្រះអង្គឯងផ្ទាល់បានចាប់ផ្តើមការគ្រប់គ្រង និងផ្សព្វផ្សាយសាសនារបស់ព្រះអង្គ ដោយបោះបង់ចោលទាំងអស់នូវមានះជាក្សត្រិយ៍ នៅក្នុងអំពើបទ្វាបខ្លួន ឬបន្ទោនកាយ។ ព្រះអង្គបានសម្រេចអរហត្តផលនៅក្នុងអំឡុង ពេលព្រះអង្គមានព្រះជន្មគង់នៅឡើយ ប៉ុន្តែព្រះអង្គមិនដែលបាត់បង់សគារវតានេះឡើយ។ ចរិយាជាធម្មតារបស់ព្រះអង្គមិនដែលប្រកាន់ឬកពាជាបុគ្គលមានត្រកូលខ្ពង់ខ្ពស់ម្តងណាទេ។ សេចក្តីអធិប្បាយពន្យល់ និងរឿងនិទានប្រៀបធៀប (ឧបមាកថា) មិនដែលមានចរិតអួតអាង ឬក្រអឺតក្រទមសោះឡើយ។ ព្រះអង្គមានពេលគ្រប់គ្រាន់ ដើម្បីសង្រួមកាយចិត្តជាមនុស្សដ៏មានសេចក្តីគោរព និងសុភាពរាបសាបំផុត។ ព្រះអង្គមិនដែលបាត់បង់ឱកាសបង្កឱ្យមានសេចក្តីសប្បាយរីករាយម្តងណាឡើយ (a sense of humour) ។

### ១៥. ចូរកុំខ្ជះខ្ជាយពេលវេលារបស់លោក-អ្នក

ការខ្ជះខ្ជាយជីវិតរបស់មនុស្សម្នាក់ក្នុងសេចក្តី ព្រួយបារម្ភ អំពីអនាគតក្នុងក្តី សោកសៅអំពីអតីតៈឬ ក្នុងភាពខ្ជិលច្រអូស ឬក៏ក្នុងសេចក្តីធ្វេសប្រហែសគឺជាការបង្ហាញនូវភាពមិនស័ក្តិសមចំពោះទីតាំង ដ៏ប្រសើរដែលមនុស្សនេះរស់នៅក្នុងឋានៈជាសត្វដ៏ប្រសើរបំផុតនៅលើផែនដីយើងនេះ។ ដោយប្រការយ៉ាងនេះមនុស្ស នោះបានបង្កើតអំពើអាក្រក់ ឬកម្មអកុសល ដែលនឹងបន្ថយកិត្តិយសមនុស្សនោះ ទៅកាន់ទីតាំងដែលសមស្របទៅនឹងភាពខ្វះសេចក្តីថ្លៃថ្នូររបស់គេ។ ចូរចងចាំ ប្រការនេះនៅក្នុងសន្តានចិត្ត ហើយចូរធ្វើអំពើល្អក្នុងអំឡុងពេលជីវិតគង់វង្សនៅឡើយ។ ដោយការខ្ជះខ្ជាយពេលវេលារបស់លោក-អ្នក លោក-អ្នកបង្កអន្តរាយមិនមែនដល់តែខ្លួន លោក-អ្នកប៉ុណ្ណោះទេប៉ុន្តែ ដល់អ្នកដទៃផងដែរ ពីព្រោះពេលវេលារបស់លោក-អ្នក ក៏ជាពេលវេលារបស់អ្នកដទៃ ហើយក៏ជាពេលវេលារបស់លោក-អ្នកដែរ។

### ១៦-ខន្តី និងសន្តោស

ចូរមានខន្តី ឬអំណត់អត់ធនជាមួយមនុស្សទាំងអស់។ ទោសៈ ឬកំហឹងរមែងនាំបុគ្គលទៅតាមផ្លូវងងឹត។ នៅពេលដែលទោសៈ ធ្វើឱ្យអ្នកដទៃច្រឡោតខឹង និងស្អប់ខ្ពើម វាក៏ធ្វើឱ្យខ្លួនអ្នកផ្ទាល់ឈឺចាប់ដែរ។ ទោសៈបង្កឱ្យរូបកាយចុះខ្សោយ និងធ្វើឱ្យចិត្តអ័ព្ទអួរ។

ពាក្យគំរោះគំរើយ បីដូចជាព្រួញបាញ់ចេញពីធ្នូ មិនអាចលេបចូលវិញបានឡើយសូម្បី លោក-អ្នកសុំទោសរាប់ពាន់ដងក៏ដោយ ។

មានសត្វខ្លះ មិនអាចមើលឃើញក្នុងពេលវេលាថ្ងៃ ចំណែកឯសត្វខ្លះវិញងងឹតនៅពេលយប់។ ប៉ុន្តែមនុស្សម្នាក់ត្រូវទោសៈខ្វាំងក្លាគ្របសង្កត់ហើយ មើលមិនឃើញអ្វីសោះឡើយទោះជាពេលថ្ងៃ ឬពេលយប់ក៏ដោយ ។

តើជាមួយអ្នកណា ឬជាមួយអ្វីដែលលោក-អ្នកច្បាំង ឬតតាំង កាលណាលោក-អ្នកក្រោធខឹង? លោក-អ្នកច្បាំងឬតតាំងជាមួយខ្លួនឯងពីព្រោះលោក-អ្នក គឺជាសត្រូវដ៏អាក្រក់បំផុតរបស់ខ្លួនលោក-អ្នក ផ្ទាល់។ ចិត្តគឺជាមិត្តដ៏ល្អបំផុតរបស់លោក-អ្នក. ប៉ុន្តែវាក៏អាចក្លាយជាសត្រូវដ៏អាក្រក់បំផុតរបស់លោក-អ្នកដែរ ។ មានជំងឺបេះដូង ខ្លះជំងឺសរសៃប្រសាទ ខ្លះជំងឺស៊ើស្បែក ខ្លះបានកើតចេញមកពីចិត្តគំនុំសងសឹក ចិត្តព្យាបាទ និងចិត្តច្រណែនឈ្នានីសព្រំរែ។ អារម្មណ៍បំផ្លិចបំផ្លាញបែបនេះបានបំពុលបេះដូង។ វាធ្វើឱ្យរីកចម្រើននូវជំងឺ ដេកត្រាំនៅឱ្យដ៏ផ្ទៃក្នុងដោយបន្ថយកម្លាំងការពារធម្មតារបស់រូបកាយប្រឆាំងនឹងអតិសុខុមប្រាណ(មេក្រូប)បង្កជំងឺ។

**១៧-ចូលសាងតែអំពើល្អ និង ជៀសវាងអំពើអាក្រក់**

ប្រសិនបើលោក-អ្នកចង់ដោះដៃឱ្យផុតពីសត្រូវ លោក-អ្នកត្រូវសម្លាប់សត្រូវដ៏ធំបំផុតនៅក្នុងខ្លួនលោក អ្នកមុនគេគឺទោសៈ ឬកំហឹងរបស់លោក-អ្នក ។ ប្រសិនបើលោក-អ្នកត្រូវបានរំខានដោយសេចក្តីពយាបាទ ព្រោះសត្រូវរបស់លោកអ្នក នោះវាមានន័យថាលោក-អ្នក កំពុងបំពេញបំណងប្រាថ្នារបស់លោក-អ្នក ដោយចូលទៅក្នុងអន្ទាក់របស់ពួកវាដោយមិនដឹងខ្លួន។

លោក-អ្នកកុំគប្បីគិតថាលោក-អ្នកអាចរៀនសូត្រតែអំពីអ្នកទាំងឡាយដែលពោលពាក្យ សរសើរ លោក-អ្នក ជួយលោក-អ្នក និងសេពគប់ជាមួយលោក-អ្នកយ៉ាងជិតស្និទ្ធបំផុតនោះប៉ុណ្ណោះ។ លោក-អ្នកអាច រៀនសូត្រអ្វីៗជាច្រើនអំពីសត្រូវរបស់លោក-អ្នក។ លោក-អ្នកមិនត្រូវគិតថា សត្រូវរបស់លោក-អ្នក ខុសទាំងស្រុងក៏ព្រោះ តែគេជាសត្រូវរបស់លោក-អ្នកប៉ុណ្ណោះនោះ។ សត្រូវទាំងនោះ អាចមានលក្ខណៈសម្បត្តិល្អខ្លះដែរតើ ៕

លោក-អ្នកមិនអាចដោះដៃពីសត្រូវ របស់លោកអ្នកដោយសងអំពើអាក្រក់ចំពោះអំពើអាក្រក់នោះទេ។ ធ្វើយ៉ាងនេះ នឹងនាំឱ្យមានសត្រូវកាន់តែច្រើនឡើង។ វិធីដ៏ប្រសើរ

បំផុតដើម្បីទប់ទល់ នឹងសត្រូវរបស់លោក-អ្នក គឺផ្សាយមេត្តាធម៌ចំពោះមនុស្សជាសត្រូវទាំងនោះ។ លោក-អ្នកអាចគិតថាអំពើនេះមិនអាចធ្វើបានទេឬជាអ្វីមួយដែលគ្មានន័យ។ ប៉ុន្តែនេះគឺជា មាគ៌ាចូងកាត់ការពិសោធន៍របស់មនុស្ស ដែលបានទទួលការបណ្ដុះបណ្ដាលគ្រប់រូប។ ប្រសិនបើអំពើខុសឆ្គងបណ្ដាលមកពីកំហុសរបស់លោក-អ្នក លោក-អ្នកគប្បីទទួលកំហុសនោះ ហើយមិនត្រូវញញើតសុំទោសគេទេ ។ ប្រសិនបើ អំពើខុសឆ្គងកើតមកពីការមិនយល់គ្នារវាងភាគីទាំងពីរលោកអ្នក ត្រូវបំភ្លឺគេដោយការនិយាយគ្នាឱ្យអស់ពីពោះពីពុងរៀងខ្លួន។

ប្រសិនបើវាកើតមកពីសេចក្ដីប្រណែនឈ្នានីសច្ចូរចិតខំផ្សព្វផ្សាយសេចក្ដីស្រឡាញ់រាប់អានរបស់ លោក-អ្នក។ លោក-អ្នកអាចជះឥទ្ធិពលទៅលើគេតាមរយៈ មនោមយិទ្ធិ (ឬចិត្តកប្បនា)របស់លោកអ្នក។ លោក-អ្នកអាចមិនងាយយល់ថា តើឥទ្ធិពលមនោមយិទ្ធិប្រព្រឹត្ត ទៅយ៉ាងដូចម្ដេច? ប៉ុន្តែបទពិសោធន៍របស់មនុស្សជា ច្រើនបានបង្ហាញថាវាជាវិធីដ៏មានអត្ថិភាពប្រកបដោយញាណខ្ពស់បំផុត ហើយងាយស្រួលបំផុតដើម្បីរកបានមិត្តភក្តិ។ ធម៌មេត្តានេះ ត្រូវបានគេផ្ដល់តម្លៃខ្ពស់ណាស់នៅក្នុងពុទ្ធសាសនា ។ តាមពិត ដើម្បីធ្វើបែបនេះបាន លោក-អ្នកត្រូវមានទំនុកចិត្តនិងខន្តី(សេចក្ដីអត់ធ្មត់)នៅក្នុងខ្លួនលោក-អ្នក។ ដោយការធ្វើអំពើនេះ លោក-អ្នកនឹងអាចធ្វើឱ្យសត្រូវរបស់លោក-អ្នកយល់ថា ខ្លួនគេកំពុងប្រព្រឹត្តខុស។ ក្រៅពីនេះ លោក-អ្នកបានចំណេញនៅក្នុងបែបបទជាច្រើនដោយមិនផ្ដល់ជម្រកឱ្យអរិភាពឋិតនៅក្នុងសន្ដានចិត្តរបស់លោក-អ្នកបាន។

**១៨-សេចក្ដីមេត្តា-ករុណា**

ដរាបណានៅមានមនុស្ស តែម្នាក់គត់ដែលលោក-អ្នកអាចលួងលោមដោយពាក្យសម្ដីពីរោះពិសា ដែលលោក-អ្នកអាចធ្វើឱ្យ ជីវិតគេសប្បាយរីករាយដោយសារវត្តមានរបស់លោកអ្នកដែលលោកអ្នកអាច ជួយសង្គ្រោះដោយទ្រព្យសម្បត្តិលោកីយ៍របស់លោក-អ្នក ទោះបីជាទាននោះតិចតួចដូចម្ដេចក្ដីលោក-អ្នក គឺជាសម្បត្តិដ៏មានតម្លៃកាត់ថ្លៃពុំបានចំពោះពូជជាតិមនុស្ស។ លោកអ្នកមិនគប្បីអស់សេចក្ដីក្លាហាន និងអស់សង្ឃឹមឡើយ។

វាមានពេលខ្លះ កាលណាមនុស្សដែលលោក-អ្នកស្រឡាញ់ ហាក់ដូចជាមិនយកចិត្តទុកដាក់ចំពោះលោក-អ្នក ហើយលោក-អ្នកមិនស័ក្តិសមនឹងការយកចិត្តទុកដាក់នេះ ប៉ុន្តែវាមិនមែនដោយហេតុប៉ុណ្ណោះ ដើម្បីធ្វើឱ្យលោក-អ្នកធ្លាក់ទឹកចិត្តនោះទេ។ តើវាមានរឿងអ្វីគួរ

ឱ្យអស្ចារ្យដែលលោក-អ្នកដឹងថា លោក-អ្នកមានសន្តានចិត្តពោរពេញដោយសេចក្ដីមេត្តាចំពោះមនុស្សផងគ្នារបស់លោកអ្នក? គេមិនបានពឹងផ្អែកលើអ្នកដទៃ ដើម្បីបានសេចក្ដីសុខរបស់ខ្លួនគេឡើយ។ អ្នកដែលសង្ឃឹមរង់ចាំទទួលយកសេចក្ដីសោមនស្សក្នុងជីវិតអំពីអ្នកដទៃ គឺអាក្រក់ក្រៃលែងជាងស្មូមដែលលុតជង្គង់ ហើយស្រែកយំសុំអាហារប្រចាំថ្ងៃទៅទៀត។

## ១៩-ការគម្រាមកំហែងនៃការប្រើគ្រឿងញៀន

ការផឹកទឹកស្រវឹង ៖ សុរាត្រូវបានគេពិពណ៌នាថា ជាបឋម ហេតុមួយនាំដល់ការធ្លាក់ខ្លួនថោកទាបខាងរូបកាយ និងសីលធម៌របស់មនុស្ស។ បច្ចុប្បន្ននេះមានរូបភាពនៃការបំពារបំពានដ៏សែនអាក្រក់មួយទៀត ពោលគឺថ្នាំញៀនដ៏អាក្រក់ និងគ្រោះថ្នាក់ ជាពិសេសជាតិញៀនហេរ៉ូអ៊ីនបានបង្កើតឡើងនូវបញ្ហាមនុស្ស និងសង្គមដ៏ធ្ងន់ធ្ងរយ៉ាងច្រើន។ បញ្ហាឥឡូវនេះ កំពុងរីករាលដាលពាសពេញ ពិភពលោក។ ផលវិបាកនៃការប្រើប្រាស់ថ្នាំញៀនកាន់តែធ្ងន់ធ្ងរ និងកាន់តែបង្កគ្រោះថ្នាក់ដល់ស្លាប់ លើសជាងផលវិបាកនៃសុរាទៅទៀត អំពើលួចប្លន់ ឧក្រិដ្ឋកម្មទាក់ទងផ្លូវភេទ និង អំពើឆបោកប្រាក់កាសច្រើនបានកើតឡើង ក្រោមឥទ្ធិពលដ៏គ្រោះថ្នាក់នៃការ ប្រើប្រាស់គ្រឿងញៀន។

មេខ្លោងគ្រឿងញៀនមិនពេញចិត្តសោះឡើយ ក្នុងឋានៈជាឈ្មួញមរណៈបានខិតខំដើម្បីត្រួតត្រារដ្ឋាភិបាល ទន់ខ្សោយ តាមរយៈការប្រើអំពើពុករលួយ សំណូក វិទ្ធ្វតកម្ម និងការដាក់គ្រាប់បែកឱ្យផ្ទុះ។ ដោយហេតុថា វាជាបញ្ហានយោបាយសាធារណៈមួយ រដ្ឋាភិបាលបានការពារប្រជាពលរដ្ឋរបស់ខ្លួនប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន។ ប៉ុន្តែមេខ្លោងគ្រឿងញៀននៅក្នុងគម្រោងការដ៏ទុរយសរបស់ខ្លួន បានគំរាមកំហែងគ្រឹះសង្គមផ្ទាល់ គឺសេចក្ដីថ្លៃថ្នូររបស់មុស្ស។ អ្នកនាំពាក្យខាងមនសិការ (មេដឹកនាំសាសនា) និងគ្រួសារទាំងឡាយរបស់គេ បានប្រឈមមុខនឹងគ្រោះថ្នាក់ដល់ស្លាប់ជាប្រចាំ ពីព្រោះតែគេហ៊ានធ្វើងកាត់ផ្លូវក្រៅច្បាប់របស់មេខ្លោងគ្រឿងញៀន។

បើគ្មានកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទប់ស្កាត់អំពើទុច្ចរិតនេះទេ ជីវិតស៉ាននិងអនាគតរបស់ប្រជាជាតិជាច្រើន នឹងសោះកក្រោះជាប្រាកដ។ ប្រាក់ដុល្លាររកបានដោយលំបាកច្រើនលានរាប់មិនអស់ទូទាំងពិភពលោក ត្រូវបានយកមកចំណាយ ដើម្បីជួយសង្គ្រោះពួកអ្នកញៀន ឱ្យរួចផុតពីទម្លាប់ដ៏យង់ឃ្នងរបស់ពួកគេ ប៉ុន្តែភាពឆ្កួតលីលានៅតែ

បន្តកើតមាន។ វាជាករណីយកិច្ចរបស់យើងរាល់គ្នា ដើម្បីជួយក្នុងបែបបទណាមួយក៏ដោយ ឱ្យតែយើងធ្វើបាន ដើម្បីលុបបំបាត់ទម្លាប់ដ៏គ្រោះថ្នាក់នេះ ហើយការពារកូនចៅរបស់យើងឱ្យចាក ចេញផុតពី ទម្លាប់អាក្រក់ នេះ។

ជីវិតក្នុងឋានៈជាអ្នកញៀនគ្រឿងញៀនម្នាក់ឬជាអ្នកប្រមឹកស្រាម្នាក់ គឺជាជីវិតវេទារុណកម្ម និងធ្លាក់នរក នៅលើផែនដីនេះ ដែលនាំបុគ្គលនោះទៅកាន់ទីកប់ខ្មោចទាំងនៅវ័យក្មេង។

ភាពស្រវឹងស្រា (សុរាធុត្តា) ភាពស្រវឹងសុរាបាត់បង់វិចារណញ្ញាណ.ពន្ទិចសតិ (ស្មារតីចងចាំបន្ត អន្តរាយ ដល់ខួរក្បាល. បន្ទោយកម្លាំង .បញ្ចេះលោហិត (ឈាម. បង្កឱ្យមានរបួសខាងក្នុង និងខាងក្រៅ មិនអាចព្យាបាលបាន។ គឺជាអាបចំពោះរូបកាយ ជាបិសាចចំពោះចិត្ត ជាចោរចំពោះថង់ប្រាក់ ជាបណ្តាសារបស់ស្ទូម ជាសត្រូវរបស់ករិយា ជាទុក្ខព្រួយរបស់បុត្រធីតា ជារូបភាពនៃសត្វពាឡម្រឹត និងជាអំពើសម្លាប់ខ្លួនឯង អ្នកដែលផឹកដើម្បីសុខភាពអ្នកដទៃ ហើយបំផ្លាញសុខភាពខ្លួនឯងផ្ទាល់។

ក្នុងឋានៈជាមនុស្ស យើងត្រូវចេះស្វ័យគ្រប់គ្រងដើម្បីបែងចែករវាងអ្វីដែលល្អ និងអ្វីដែលអាក្រក់។ ចូរជៀសវាងការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង (សុរាមេរ័យ) ហើយចូរជួយអ្នកដទៃឱ្យជៀសវាងដូចគ្នា។ ការងារនោះនឹងបានជាសេវកិច្ចដ៏ធំធេងបំផុតចំពោះមនុស្សជាតិ។

## ២០-លោកអ្នកបង្កើតឋានសួគ៌និងឋាននរកក្នុងលោកនេះ

«ប្រសិនបើលោក-អ្នកចង់ រស់នៅក្នុងលោកនេះប្រកបដោយសេចក្តីសុខសាន្ត និងរីករាយ » ចូរអនុញ្ញាតឱ្យមនុស្សដទៃ បានរស់នៅដោយសេចក្តីសុខសាន្ត និងរីករាយផងដែរ «ធ្វើដូច្នេះលោក-អ្នកអាចកសាងពិភពលោករបស់លោក-អ្នក ជាទីឋានមួយដែលស័ក្តិសមនឹងការរស់នៅ»។ វៀរលែងតែនិងលុះត្រាតែលោកអ្នក សម្របសម្រួលខ្លួនលោក-អ្នកឱ្យរស់នៅស្របតាមគោលការណ៍ (ឬនិយាម) ដ៏ប្រសើរទាំងនេះ លោក-អ្នកមិនអាចសង្ឃឹមទទួលបានសេចក្តីសុខនិងសន្តិភាពក្នុងពិភពលោកនេះបាន។ លោក-អ្នកមិនអាចសង្ឃឹមវង់

ចាំទទួលសេចក្តីសុខ និងសន្តិភាពនេះ អំពីទេវលោកដោយគ្រាន់តែអង្វរកបន់ស្រន់នោះឡើយ។

ប្រសិនបើលោកអ្នកប្រតិបត្តិស្របតាមគោលការណ៍សីលធម៌ដោយការជ្រោងខ្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សលោក-អ្នក អាចបង្កើតឋានសួគ៌ផ្ទាល់របស់លោក-អ្នក នៅក្នុងពិភពលោកនេះផ្ទាល់តែម្តង។ លោក-អ្នកក៏អាចបង្កើតភ្លើងនរកបានផងដែរ នៅលើផែនដីនេះផ្ទាល់ ប្រសិនបើ លោក-អ្នកប្រើប្រាស់បំពានទូវជីវភាពមនុស្សដ៏មានតម្លៃ។ ដោយហេតុតែមិនដឹងថា ត្រូវរស់នៅយ៉ាងដូចម្តេច ទើបសមស្របទៅនឹងក្រឹត្យក្រមអវកាសសកលលោកធាតុនេះ យើងច្រើនតែមានជំហរឃ្លេងឃ្លោង។ ប្រសិនបើមនុស្សម្នាក់ៗខិតខំដឹកនាំជីវិតមួយស្អាតស្អំ គ្មានទោសគួរដល់ការគោរព មនុស្សអាចទទួលសោយបរមសុខឰដ៏ស្ថានសួគ៌យ៉ាងពិតប្រាកដ ប្រសើរជាងប្រភេទនៃសេចក្តីសុខដែលមនុស្សខ្លះសង្ឃឹមថា បានទទួលក្រោយពេលស្លាប់ទៅ។

វាជារឿងគ្មានប្រយោជន៍ទេ ដើម្បីបង្កើតស្ថានសួគ៌នៅទីណាមួយសម្រាប់ជារង្វាន់ដល់គុណធម៌ឬបង្កើតឋាននរកសម្រាប់ផ្តន្ទាទោសបាបធម៌។ បុណ្យនិងបាប មានប្រតិកម្មជៀសមិនផុត នៅក្នុងពិភពលោកនេះផ្ទាល់ តែម្តងដោយមិនគិតដល់ជំនឿសាសនាណាមួយទេ។ មេត្តាធម៌ផ្សាយទៅចំពោះសត្វទាំងអស់ គឺជាមាគ៌ាតែមួយគត់ដើម្បីបង្កើតឋានសួគ៌។ យើងអាចមានឧត្តមគតិដ៏រុងរោចន៍មិនអាចលាក់ទុកបាននេះ ដើម្បីជាគុណប្រយោជន៍ដល់សង្គម និងប្រទេសជាតិដោយទម្លាយប្រាប់ សេចក្តីសន្តោសនិងសមានចិត្តសម្រាប់សេចក្តីចម្រើន និងសេចក្តីសុខរបស់មនុស្សដទៃ។ យើងបានមកដល់ចំណុចនេះ ក្នុងឋានៈជាពូជជាតិមនុស្សមួយ ពីព្រោះបុគ្គលដ៏ល្បីល្បាញទាំងឡាយបានបង្ហាញប្រាប់យើងនូវមាគ៌ាដ៏ល្អនេះ។ ដោយការជួយអ្នកដទៃ តាមផ្លូវសីលធម៌ លោក-អ្នកជួយខ្លួនលោកអ្នកផ្ទាល់ ហើយដោយការជួយខ្លួនលោក-អ្នកផ្ទាល់តាមផ្លូវសីលធម៌លោក-អ្នកជួយអ្នកដទៃ។

## ២១-ជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល

នៅក្នុងអាពាហ៍ពិពាហ៍ដ៏ស្មោះត្រង់ បុរសនិងស្ត្រីរមែងគិតគូរអំពីភាពជាដៃគូ ច្រើនជាងពួកគេគិតគូរអំពីខ្លួនគេផ្ទាល់។ អាពាហ៍ពិពាហ៍ គឺជា ប៊ីស៊ីក្លេត (កង់) ធ្វើសម្រាប់មនុស្សពីរនាក់។ អារម្មណ៍សុខសាន្ត និង ត្រេកត្រអាលចេញមកពីសេចក្តីខិតខំទៅវិញទៅមក។ សេចក្តីមិនអត់ធ្មត់ និងសេចក្តីមិនយោគយល់គ្នាបង្កឱ្យមានបញ្ហា ក្នុងគ្រួសារភាគច្រើន។

*ប្រពន្ធមិនមែនជាទាសីរបស់ប្តីនាងទេ។ នាងស័ក្តិសមទទួល បានសេចក្តីគោរពស្មើគ្នា។ ថ្វីបើប្តីមានភារកិច្ចជាអ្នក រកប្រាក់កាស ចិញ្ចឹមគ្រួសារក៏ដោយការជួយធ្វើការប្រចាំថ្ងៃនៅ ផ្ទះមិនមែនមានន័យថា បន្ថយភាពខ្វះខាត ឬភាពក្រខ្សត់នៅក្នុងផ្ទះទេ។ សេចក្តីយល់ឃើញត្រឹមត្រូវ និងការប្រព្រឹត្តប្រកបដោយ សីលធម៌ គឺជាផ្នែកអនុវត្តនៃបញ្ញា ។*

*អាពាហ៍ពិពាហ៍គឺជាមង្គលមួយ ប៉ុន្តែមនុស្សជាច្រើនបង្វែរ ឬ ប្រែក្លាយជីវិតអាពាហ៍ពិពាហ៍របស់គេទៅ ជាអពមង្គលទៅវិញ។ ភាពក្រខ្សត់មិនមែនជាមូលហេតុ នៃជីវិតអាពាហ៍ពិពាហ៍ដ៏អពមង្គលទេ។ ប្តីនិងប្រពន្ធទាំងពីរនាក់ ត្រូវចេះចែករំលែក សេចក្តីសប្បាយ និងទុក្ខព្រួយកើតមកពីអ្វីៗទាំងអស់នៅក្នុងជីវិតរាល់ថ្ងៃរបស់ខ្លួន។ សេចក្តីយោគយល់ទៅវិញទៅមក គឺជាកូនសោរនៃជីវភាពគ្រួសារមានសុភមង្គល។*

**២២-ចូរកុំព្រួយបារម្ភ**

*កូនសោរសម្រាប់ការចិញ្ចឹមជីវិត ប្រកបដោយជោគជ័យមានសុភមង្គល គឺត្រូវធ្វើអ្វីដែលចាំបាច់ធ្វើឥឡូវនេះហើយ ចូរកុំព្រួយបារម្ភអំពីអតីតៈឬអនាគត។ យើងមិនអាចបង្កើតអតីតៈឡើងវិញទេ ទាំងមិនអាចរំពឹងទុក នូវអ្វីៗក្នុងអនាគតដែរ។ គឺវាមានតែពេលវេលាមួយគត់ ដែលយើងត្រូវគ្រប់គ្រងប្រកបដោយមនសិការភ្ញាក់ រលឹកនោះ គឺបច្ចុប្បន្នកាល។*

*មនុស្សជាច្រើនចូលចិត្តខ្វល់ខ្វាយព្រួយបារម្ភអំពីអនាគត។គេត្រូវចេះសម្របសម្រួលខ្លួនទៅនឹងកាលៈទេសៈ។ វិមានឬប្រាសាទ ដែលគេអាចកសាងនៅក្នុងអាកាសជាអ្វីក៏ដោយ គេអាចសុបិនឃើញជាអ្វីក៏ដោយគេត្រូវចងចាំជានិច្ចថា គេកំពុងរស់នៅក្នុងលោកនេះដែលមានការប៉ះទង្គិច និងការប្រែប្រួលជាប្រចាំ។*

*«គ្មានហ្វូងតារាណាមួយដែលយើងអាចទុកចិត្តបានទេ គ្មានពន្លឺនាំផ្លូវណាមួយទេ ប៉ុន្តែយើងដឹងថា យើងត្រូវមានសប្បុរសធម៌ មានយុត្តិធម៌មានទិដ្ឋិត្រូវ»។*

**២៣-សសរស្តម្ភនៃជោគជ័យ**

*បរាជ័យគឺជាសសរស្តម្ភនៃជោគជ័យ។ ត្រូវរៀនពីបរាជ័យរបស់យើងដើម្បីសម្រេចបានជោគជ័យ។ មិនដែលទទួលបរាជ័យសោះ គឺមិនដែលបានឈ្នះសោះ។ បើយើងមិនភ្លក់រស់ជាតិបរាជ័យ និងភាពជូរចត់របស់វាទេ នោះយើងមិនអាចឱ្យតម្លៃដល់រសជាតិផ្អែមល្ហែមនៃជ័យជំនះបានឡើយ ជ័យជំនះប្រែក្លាយទៅជាព្រឹត្តិការណ៍មួយសោះកក្រោះ ដែលមានតែឈ្មោះ ឬគ្មានអត្ថប្រយោជន៍។ បរាជ័យមិនគ្រាន់តែជួយយើងឱ្យសម្រេចជោគជ័យ*

ប៉ុណ្ណោះទេ វាថែមទាំងផ្ដល់ថាមពលឱ្យយើងធ្វើឱ្យយើងមានចិត្តសោមនស្សហើយសប្បុរេទ ពិសោធន៍ ។

"យើងរស់ យើងធ្វើការហើយយើងសុបិន ម្នាក់ៗមានផែនការតូចតាចរបស់ខ្លួន ពេលខ្លះយើងសើច ពេលខ្លះយើងយំ គឺដោយប្រការដូច្នេះទិវាកន្លងទៅ"។

**២៤-សោភ័ណភាពពិត**

រូបរាងអាក្រក់គឺមិនមែនជាពិការភាពសម្រាប់បុគ្គលមានកេរ្ដិ៍ឈ្មោះ ដ៏សង្ហាម្នាក់ទេ ។ ប្រសិនបើបុគ្គលនោះ មានរូបអាក្រក់ម្នាក់បណ្ដុះបានគុណធម៌នៃមេត្តា-ករុណាមេត្តាធម៌នោះ នឹងនាំមកនូវមាគ៌ាឈ្នះយ៉ាងច្រើន គឺដូចជាដំណើរមានចិត្តសុខស្ងប់(ឧបសមៈ) ដំណើរមាន ចិត្តសប្បាយផ្សាយចេញមេត្តាធម៌ទៅរកអ្នកដទៃ(បកស្សរៈ) ករុណានិងមុទិតា (មានចិត្ត ទន់ភ្លន់ទៅរកអ្នកដទៃ) ។ ប្រភេទទាក់ ទាញចិត្តឱ្យរីករាយនោះ នឹងជួយជួសជុលលក្ខណៈខ្វះ ខាតនៃរូបកាយបានងាយ។ តាមការប្រៀបធៀម សុភាពបុរសម្នាក់ប្រកបដោយ ទឹកមុខធ្មើង ធ្មៃត្រូវគេក្រឡេកមើលទៅគួរឱ្យស្អប់មិនចង់រាប់រក។ សម្រស់ខាងក្នុងគឺជាសោភ័ណភាព ពិត។ វាមានគុណភាពពិសេសអាចទាក់ទាញ និងញ៉ាំងចិត្តអ្នកដទៃឱ្យសប្បាយរីករាយ ។

**២៥-ព្រោះហេតុអ្វីមានការពិបាកដើម្បីចាកចោលលោកនេះ?**

ចំពោះមនុស្សភាគច្រើនសេចក្ដីស្លាប់គឺជាព្រឹត្តិការណ៍មិនទទួលស្វាគមន៍មួយ។ ជា មួយនឹងចំណង់ (តណ្ហា) ចង់សប្បាយយ៉ាងច្រើនរាប់មិនអស់ធុរកិច្ចនៃ ការរស់នៅ ទោះបី មានទុក្ខសោកដ៏ធំធេងក៏ដោយ ក៏ធុរកិច្ចនោះមិនដែលបានចប់សព្វគ្រប់សោះឡើយ។ មនុស្ស មានអារម្មណ៍សុខស្រួល ជាមួយស្រមោលនៃសេចក្ដីសុខ ជាជាង តថភាពនៃសេចក្ដីស្លាប់។ ប្រសិនបើ គេត្រូវគិតអំពីសេចក្ដីស្លាប់នេះវិញ នោះវាមានចន្លោះពេលក្នុង មោ៉ងទីដប់មួយតែ ប៉ុណ្ណោះ។

ដំណើរចិត្តជាប់ជំពាក់ចំពោះជីវិតក្នុងលោកិយ៍នេះ បង្កើតឱ្យមានសេចក្ដីភ័យខ្លាច ស្លាប់ ដ៏អាក្រក់បំផុត។ ប៉ុន្ដែសច្ចធម៌ គឺថា ជីវិតទាំងអស់គ្មានអ្វីក្រៅតែពីទុក្ខនោះទេ។ សេចក្ដី ស្លាប់ គឺជាដំណើរធម្មតាមិនអាចជៀសផុត។ គេភ័យអំពីសេចក្ដីស្លាប់ មិនបានស្ថិតពាក់ កណ្ដាលនៃគំនិតគិតអំពីស្លាប់ផ្ទាល់ផង។ ចិត្តមានសមត្ថភាពផ្ទាល់របស់ខ្លួនដើម្បីបង្កើត និង ពន្លឺសរូបភាពស្រមើស្រមៃនៃមរណៈ។ ហេតុផល គឺថាចិត្តដែលមិនបានទទួលការហ្វឹកហ្វឺន ដើម្បីមើលឃើញជីវិតជាមួយនឹងអនិច្ចភាព និងទុក្ខទោមនស្សគ្រប់យ៉ាងរបស់វា គឺទោរទន់

ទៅស្រវាំងឱបមាយាការ ដូចមនុស្សកំពុងលង់ទឹកស្រវាំតោងសូម្បីតែចម្បើងមួយទងក៏តោងដែរ។

ចិត្តគ្មានការហ្វឹកហ្វឺននេះ បង្កើតឡើងនូវភាពសោប់សោល់ ចំពោះអ្នកទាំងឡាយដែលខិតខំយ៉ាងប្តូរផ្តាច់បន់ស្រន់តួអង្គអច្ឆរិយៈប្រឌិតស្មាន ដើម្បីបានទទួលសេចក្តីសន្តោសប្រោសប្រណី និងបានទទួលកន្លែងមួយនៅក្នុងឋានសួគ៌ កាលណា ជីវិតរស់នៅហាក់ដូចជាអស់សង្ឃឹមគ្មានទីពំនឹង។ មែនហើយសេចក្តីភ័យខ្លាចស្លាប់ គឺជាការស្តែង ឡើងនៃសភាវៈគតិអត្តាភិរក្សប៉ុន្តែ គេមានមធ្យោបាយដើម្បីជំនះលើសេចក្តីភ័យខ្លាចនោះ។ បរទត្តភាពជម្រុះចោលសេចក្តីជាប់ជំពាក់ចិត្តផ្ទាល់ខ្លួនឯងទាំងអស់បាន ។

ចិត្តបរិសុទ្ធ សេចក្តីមិនជាប់ជំពាក់ចិត្តចំពោះវត្ថុកាម និងជានាវាប់រងការចាកចេញដំណើរវឹកវរយអំពីពិភពលោកនេះទៅ។ ចូរពង្រឹងចិត្តឱ្យខ្លាំងក្លាដើម្បីប្រឈមមុខនឹងរឿងពិតនិងតថភាពនៃជីវិត។ ចូរជៀសវាងមហិច្ឆតាមិនពិត និងមិនអាចអនុវត្តជាក់ស្តែងបាន។ ចូរអភិវឌ្ឍន៍សេចក្តីជឿទុកចិត្តលើខ្លួនឯងឱ្យបានធំជាត់ឡើង។ បន្ទាប់មកលោក-អ្នក នឹងមានអារម្មណ៍កាន់តែធូរស្រាល ក្នុងការជំនះលើសេចក្តីលំបាកទាំងឡាយនៅក្នុងជីវិតរបស់លោក-អ្នក។

វៀរចាកប្រព្រឹត្តធម៌ ឬច្បាប់ប្រកបដោយអគតិ ៤ យ៉ាងគឺ

១.លំអៀងចិត្តព្រោះស្រឡាញ់រាប់អាន

២.លំអៀងចិត្តព្រោះស្អប់

៣.លំអៀងចិត្តព្រោះល្ងង់

៤.លំអៀងចិត្តព្រោះខ្លាច

វៀរចាកដែលធ្វើឱ្យខ្លួនថោកទាបខាតបង់ទ្រព្យសម្បត្តិ (អបាយមុខ) ៦យ៉ាងគឺ

១.ផឹកទឹកស្រវឹងនិងសេពគ្រឿងញៀន

២.ដើរលេងយប់

៣.ដើរមើលល្បែង

៤.លេងល្បែងភ្នាល់គ្នា

៥.យកមនុស្សអាក្រក់ជាគៀន

៦.ខ្ជិលធ្វើការងារ

បុត្រធីតាគោរពប្រតិបត្តិមាតាបិតា ដោយករណី ៥ យ៉ាងគឺ ៖

១.លោកបានចិញ្ចឹមយើងមកហើយ គប្បីចិញ្ចឹមលោកវិញ

២.បម្រើលោកដោយធ្វើកិច្ចការជំនួស

៣.រក្សាវង្សត្រកូលល្អរបស់លោក

៤.ប្រព្រឹត្តខ្លួនឱ្យជាមនុស្សល្អគួរទទួលមត៌ក

៥.កាលណាលោកអនិច្ចកម្មទៅ ត្រូវធ្វើបុណ្យឧទ្ទិសផលជូន ។

មាតាបិតាគប្បីអនុគ្រោះកូនដោយករណី ៥ យ៉ាងគឺ ៖

១.ហាមធ្វើការងារអាក្រក់

២.ដឹកនាំឱ្យធ្វើការងារល្អ

៣.ទំនុកបម្រុងឱ្យសិក្សាវិជ្ជានានា

៤.រកស្វាមីភរិយាឱ្យតាមការគួរ

៥.កាលណាដល់ពេលគួរហើយប្រគល់មត៌កឱ្យ

អាចារ្យគប្បីអនុគ្រោះសិស្សដោយករណីយ៍ ៥ យ៉ាងគឺ

១.អប់រំឱ្យបានល្អ

២.បង្រៀនឱ្យបានចេះដឹង

៣.បង្រៀនឱ្យអស់ជើងមិនលាក់វិជ្ជា

៤.លើកតម្កើងសិស្សឱ្យប្រាកដ ច្បាស់លាស់ក្នុងទីប្រជុំជន

៥.ការពារកេរ្តិ៍ឈ្មោះសិស្សនិងធ្វើឱ្យសិស្សស្រឡាញ់រាប់អានគ្នា ។

សិស្សគប្បីគោរពប្រតិបត្តិអាចារ្យដោយករណី ៥ យ៉ាងគឺ

១.ដោយក្រោកឡើងទទួលដំណើរចូលនិងជូនដំណើរចេញ

២.ដោយចូលខ្លួនទៅជិតដើម្បីបម្រើ

៣.ដោយយកចិត្តទុកដាក់ស្តាប់ឪវាទ

៤.ដោយទំនុកបម្រុងផ្គងផ្គើមគ្រប់មធ្យោបាយ

៥.ដោយគោរពយ៉ាងស្មោះអស់ពីចិត្ត

បុរសជាស្វាមីគប្បីប្រតិបត្តិចំពោះភរិយាខ្លួនដោយករណី ៥ យ៉ាងគឺ

១-ដោយរាប់អានលើកតម្កើងថាជាភរិយាពិតៗ

២-ដោយមិនប្រមាថមើលងាយ

៣-ដោយមិនគប្បីក្បត់ចិត្ត (មានស្ត្រីដទៃទៀត)

៤-ដោយប្រគល់ឱ្យនូវឥស្សរភាពក្នុងគ្រួសារ

៥-ដោយឱ្យគ្រឿងសំអាង និង គ្រឿងតែងកាយ

ស្ត្រីជាភរិយាគប្បីប្រតិបត្តិស្វាមីរបស់ខ្លួន ដោយករណី ៥ យ៉ាងគឺ

១-ចាត់ចែងការងារក្នុងផ្ទះឱ្យបានល្អ

២-សង្គ្រោះញាតិខាងស្វាមីឱ្យបានសមរម្យ

៣-មិនប្រព្រឹត្តក្បត់ចិត្តស្នេហា (មានបុរសដទៃទៀត)

៤-រក្សាឱ្យគង់នូវទ្រព្យសម្បត្តិដែលស្វាមីរកបានមក

៥-ខំធ្វើកិច្ចការទាំងពួងក្នុងគ្រួសារ

កុលបុត្រគប្បីទំនុកបម្រុងមិត្រដោយករណី ៥ យ៉ាងគឺ

១.ដោយចែកប្រយោជន៍ឱ្យ

២.ដោយនិយាយពាក្យពិរោះ

៣.ដោយប្រព្រឹត្តប្រយោជន៍ឱ្យ

៤.ដោយភាវៈជាបុគ្គលមានខ្លួនស្មើៗគ្រប់វេលា

៥.ដោយមិនក្លែងពោលពាក្យឱ្យខុសពីសេចក្តីពិត

មិត្តគប្បីអនុគ្រោះកុលបុត្ររបស់មិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ

១.រក្សាខ្លួនមិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ

២.រក្សាទ្រព្យសម្បត្តិរបស់មិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ

៣.ក្នុងកាលមានអាសន្នយកខ្លួនធ្វើជាទីពឹងពំនាក់ឱ្យ

៤.មិនលះបង់ចោលគ្នាក្នុងគ្រាមានវិបត្តិ

៥.រាប់អានគ្នារហូតដល់វង្សញាតិរបស់មិត្ត

ធនបតីទំនុកបម្រុងកម្មករដោយករណី ៥ យ៉ាងគឺ

១.ចាត់ចែងការងារឱ្យធ្វើតាមគួរដល់កម្លាំងនៃសមត្ថភាព

២.ឱ្យអាហារនិងតម្លៃឈ្នួលឱ្យបានជួនល្មម

៣.រក្សាព្យាបាលយ៉ាងជិតដល់ក្នុងពេលមានជំងឺ

៤.ឱ្យរង្វាន់ជាពិសេសក្នុងកាលម្ដងៗ

កម្មករគប្បីប្រតិបត្តិធនបតី ដោយករណី ៥ យ៉ាងគឺ ៖

១-ក្រោកឡើងធ្វើការមុនធនបតិ

២-ទទួលទានដំណេកក្រោយធនបតិ

៣-កាន់យកតែរបស់ណាដែលធនបតិបានឱ្យ

៤-ធ្វើការយកតែរបស់ណាដែលធនបតិបានឱ្យ

៥-ជួយទ្រទ្រង់នូវគុណសម្បត្តិល្អរបស់ធនបតិ ។

កុលបុត្រគប្បីប្រតិបត្តិសមណព្រាហ្មណ៍ ដោយករណី ៥ យ៉ាងគឺ

១-គោរពយ៉ាងជិតដល់ដោយកាយកម្ម

២-គោរពយ៉ាងជិតដល់ដោយវចីកម្ម

៣-គោរពយ៉ាងជិកដល់ដោយមនោកម្ម

៤-គោរពដោយបើកទ្វារផ្ទះ គឺឱ្យចេញចូលតាមពេលដ៏គួរ

៥-គោរពដោយសេចក្ដីសង្គ្រោះខាងបច្ចយាហារ ។

សមណព្រាហ្មណ៍គប្បីទំនុកបម្រុងកុលបុត្រដោយករណី ៦យ៉ាងគឺ

១.ការពារមិនឱ្យធ្វើសេចក្ដីអាក្រក់

២.ឱ្យតម្កល់ខ្លួននៅក្នុងសេចក្ដីល្អ

៣.អនុគ្រោះដោយទឹកចិត្តល្អ

៤.ឱ្យបានស្ដាប់ធម៌ដែលមិនធ្លាប់បានស្ដាប់

៥.បំភ្លឺធម៌ដែលធ្លាប់បានស្ដាប់ហើយឱ្យកាន់តែចូលចិត្តច្បាស់ឡើង

៦.ប្រាប់ផ្លូវសម្រាប់ដើរទៅកាន់សេចក្ដីសុខចម្រើន។

អានិសង្សរបស់មេត្តា

១-មេត្តា គឺឥតស្ងប់ ឥតទ្វេស្ត ចាកព្យាបាទ

២-មេត្តា ជាសត្រូវនឹងរាគៈ

៣-មេត្តា ឥតលាយឡំ និង លោភៈ និង មោហៈ

៤-មេត្តា ទន់ភ្លន់ ឥតឫស្យា ឥតប្រណែន

៥-មេត្តា គ្មានកំណាញ់ គ្មានចង្អៀត

៦-មេត្តា ពិតគ្មានមានះទេ
៧-មេត្តា ជំនះបានរាល់អកុសលធម៌
៨-មេត្តា ឈ្នះបាបធម៌ទាំងឡាយ
៩-មេត្តា ឈ្នះកិលេសទាំងអស់
១០-មេត្តា ឥតលោភៈ
១១-មេត្តា ឱ្យភាពខ្ពង់ខ្ពស់ដល់អ្នកដទៃ
១២-មេត្តា ឱ្យតម្លៃគេ ឱ្យកិត្តិយសគេ
១៣-មេត្តា ឱ្យគុណគេ ហើយឥតចង់បានគុណពីគេមកវិញទេ
១៤-មេត្តា ឥតខ្វាចគេ ឥតក្លេចគុណ
១៥- មេត្តា ឥតរំលឹកគុណពីគេ ព្រោះគ្មានលោភៈ
១៦-មេត្តា ឥតទោមនស្ស ដឹងទុក្ខអ្នកដទៃ
១៧-មេត្តា រម្ងាប់ពៀរ រម្ងាប់កំហឹង ទោសៈអស់ ពៀរអស់
១៨-មេត្តា អស់ខឹង អស់គុំគួន
១៩-មេត្តា ធ្វើឱ្យបុគ្គលមានសតិគ្រប់គ្រាន់
២០-មេត្តា ធ្វើឱ្យបុគ្គលមិនមានពៀរ
២១-មេត្តា ឥតលំអៀង ឥតអគតិ
២២-មេត្តា ជួយឱ្យគេប្រែពីខុសមកត្រូវ
២៣-មេត្តា ធ្វើឱ្យគេឃើញទោសរបស់អកុសលបានច្រើន
២៤-មេត្តា សម្ងាប់ខឹងក្រោធ
២៥-មេត្តា ជាម្លប់ឈើដ៏ត្រជាក់ដល់អ្នកជ្រក
២៦-មេត្តា ជាមាតា បិតាឱ្យម្លប់ដល់កូនចៅ
២៧-មេត្តា ជាព្រះរាជាឱ្យត្រជាក់ដល់ប្រជារាស្ត្រ
២៨-មេត្តា នាំគេស្គាល់ទោសរបស់ទោសៈ មោហៈ ឫស្យាមិច្ឆា
២៩-មេត្តា ជាមហាមង្គល
៣០-មេត្តា ឥតលំអៀងឱ្យប្រយោជន៍ដល់គេ ឥតបដិឃៈ ឥតទេសៈ
៣១-មេត្តា ក្នុងមហាកុសល

៣២-មេត្តា ក្នុងឈាន (បានមួយហិតក្លិន)
៣៣-មេត្តា ក្នុងវិបស្សនា (បានមួយផ្ចាត់ក្រចក )
៣៤-មេត្តា ក្នុងអនិច្ចសញ្ញា (ស្ងប់លោកៈ)
៣៥-មេត្តា ឥតជាប់ ឥតស្រឡាញ់
៣៦-មេត្តា ជាប្រដាប់កាយ ជាគ្រឿងអលង្ការ
៣៧-មេត្តា របស់ម្តាយដូចទឹកហូរធ្លាក់មកស្រោក់ៗ
៣៨-មេត្តា ជាគ្រឹះដល់វិបស្សនា
៣៩-មេត្តា គឺមេត្តាចំពោះសត្រូវរបស់យើង ដោយពិចារណា
៤០-មេត្តា មិនចេះឆ្អែតនិងមេត្តា
៤១-មេត្តា កើនឡើង ឃើញខុសរបស់គេ ក័យនឹងកំហុសខ្លួនឯង
៤២-មេត្តា កាយកម្ម
៤៣-មេត្តា វចីកម្ម
៤៤-មេត្តា មនោកម្ម(ខាងចិត្ត)
៤៥-មេត្តា បារមីកើតដោយសតិបដ្ឋាន ៤
៤៦-មេត្តា មិនមានបុគ្គល ឥតជាប់ជំពាក់
៤៧-មេត្តា មិនស្អប់អ្នកដទៃ
៤៨-មេត្តា មិនមើលងាយអ្នកដទៃ
៤៩-មេត្តា មិនវាយឫកស្មើ
៥០-មេត្តា មិនប្រណែន
៥១-មេត្តា មិនកំណាញ់
៥២-មេត្តា មិនរមើលគុណ
៥៣-មេត្តា មិនអំណួត
៥៤-មេត្តា មិនមាយា
៥៥-មេត្តា ឥតសកាយៈ អស់អញ ។

អានិសង្ស ១១ របស់មេត្តា

១-សម្រាន្តលក់ជាសុខ

២-ភ្ញាក់ឡើងជាសុខ

៣-មិនយល់សុបិនអាក្រក់

៤-ពពួកមនុស្ស ស្រឡាញ់រាប់អាន

៥-ពពួកអមនុស្ស ស្រឡាញ់រាប់អាន

៦-ទេវតាថែរក្សា

៧-ឥតត្រូវថ្នាំពិស ឥតត្រូវសាស្ត្រាវុធ ឥតភ្លើងឆេះ

៨-មានចិត្តរឹងមាំ មានជំនឿលើខ្លួនឯង

៩-មានទឹកមុខស្រស់ជានិច្ច

១០-មិនវង្វេងពេលស្លាប់

១១-ទៅកើតឋានព្រហ្ម ។

ផលប្រយោជន៍នៃការរក្សាសីល

សីលខទី១ វៀរចាកការសម្លាប់សត្វមានជីវិត មានអានិសង្ស ២៣ យ៉ាង ៖

| | |
|---|---|
| ១.អង្គបច្ចង្គសមន្នាគតា | បរិបុណ៌ដោយអវៈយវៈតូចធំមិនពិការ |
| ២.អារោហបរិនាហសម្បត្តិ | មានរាងខ្ពស់ និងសមសួន |
| ៣.ជវសម្បត្តិ | មានការរៀសរវៃ |
| ៤.សុបតិដ្ឋិតបាទតា | មានជើងតាំងមាំល្អ |
| ៥. ចារុតា | មានរាសីរុងរឿង |
| ៦.សុចិតា | ស្អាត |
| ៧.មុទុតា | ទន់ភ្លន់ |
| ៨.សុរូបតា | មានរូបរាងស្អាត |
| ៩.សុសណ្ឋានតា | មានរាងសមសួនសង្ហារ |
| ១០.មហព្វលតា | មានកម្លាំងច្រើន |
| ១១.សូរតា | ក្លាហាន |
| ១២.វិសិដ្ឋវចនតា | មានពាក្យសម្ដីពិរោះពិសា |
| ១៣.អនន្តបរិវារតា | មានបរិវារច្រើន |

១៤.អភេសជ្ជបរិសតា បរិស័ទមិនបោះបង់ចោល
១៥.សុខិតា មានសេចក្តីសុខ
១៦.លោកបិយតា ជាទីស្រឡាញ់របស់មហាជន
១៧.អធព្ធិតា មិនភ្ញាក់ផ្អើល ភ័យខ្លាច
១៨.អសោកិតា មិនមានរឿងនាំឱ្យខូចចិត្ត
១៩.អប្បធំសិកតា សត្រូវបៀតបៀនមិនបាន
២០.បរូបក្កមេន អមរណាតា មិនស្លាប់ដោយការប៉ុនប៉ងពីអ្នកដទៃ
២១.អប្បាពាធតា មិនសូវមានជំងឺ
២២.បិយេហិមនបេហិសទ្ធឹអវិប្បយោគតា មិនព្រាត់ប្រាស់អំពីវត្ថុសត្វមនុស្ស ដែលជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន
២៣.ទីឃាយុកតា មានអាយុវែង

សីលទី ២ វៀរចាកការលួច មានអានិសង្ស១១ យ៉ាង ៖
១.មហទ្ធតា មានទ្រព្យច្រើន
២.ពហូតំ ធនញ្ញតា មានអាហារគ្រប់គ្រាន់
៣. អនន្តភោគតា រកទ្រព្យបានជាប់ជានិច្ច
៤.អនុប្បន្នភោគុប្បត្តិតា ទ្រព្យដែលមិនទាន់បានក៏នឹងរកបាន
៥.ឧប្បន្នភោគត្ថាវតោ ទ្រព្យដែលរកបានហើយក៏នឹងស្ថិតស្ថេរ
៦. ឥច្ឆិតានំ ភោគានំ ខិប្បជលាភិតា ស្វែងរករបស់ដែលប្រាថ្នា ឆាប់បានដូច ចិត្ត
៧.អសាធារណភោគតា ទ្រព្យសម្បត្តិមិនរាត់រាយខ្ចាត់ខ្ចាយឬបាត់បង់ ដោយរាជភ័យ ចោរភ័យ ឬ ញាតិបោកបញ្ឆោត
៨.អសាធារណបដិលោភតា រកទ្រព្យបានដោយមិនមានគេបែង
៩.នត្ថិកាវស្សអេចានតាអសវនតា មិនដែលស្តាប់មិនដែលបានឮពាក្យថាមិនមាន
១០.សុខវិហារិតា នៅទីណាក៏សុខកាយសុខចិត្ត
១១.លោកុត្តរធនបដិលាភតា ជាអ្នកមានសិទ្ធិត្រូវបានទទួលលោកកុត្តរសម្បត្តិ

សីលទ ទី ៣ វៀរចាកការប្រព្រឹត្តខុសក្នុងកាមមានអានិសង្ស ២០ យ៉ាង
១-វិគតបច្ចត្តិកតា មិន មានសឹកសត្រូវ

២-សព្វជនស្ស បិយតា ទីស្រឡាញ់របស់ជនទាំងពួង
៣-អកុតោ ភយតា មិនមានភ័យអំពីអ្នកណា
៤-និរាសង្កតា មិនមានអ្នកណាស្អប់
៥-សុខសយនតា ដេកលក់ជាសុខ
៦-សុខបដិពុជ្ឈនតា ភ្ញាក់ពីដេកក៏ជាសុខ
៧-អក្កោធនតា មិនឆាយខឹង
៨-សុខវិហារតា នៅទីណាក៏ជាសុខ
៩-អនជោមុខតា មានទឹកមុខជាប្រក្រតី
១០-អបតិតក្ខន្ធតា ជាអ្នកសង្ហារ
១១-បច្ចក្ខការិតា ធ្វើអ្វីៗដោយចំហរ
១២-សក្កច្ចការិតា ធ្វើអ្វីដែលរៀបរយអញ្ញបញ្ញបិយតាជួយគ្នាទៅវិញ ទៅមកជាមួយមិត្តសម្លាញ់
១៣.អញ្ញមញ្ញបិយតា ជួយគ្នាទៅវិញទៅមកជាមួយមិត្តសម្លាញ់
១៤.បរិបុណ្ណិន្ទ្រិយតា មានឥន្ទ្រីយ៍បរិបូរណ៍
១៥.បរិបុណ្ណិនលក្ខណតា មានលក្ខណៈបរិបូរណ៍
១៦.អន្នបានអត្ថសយនាទីនំបដិលាភិតា ស្វែងរកអាហារសម្លៀកបំពាក់បានឆាយ
១៧.អប្បោសង្កតា ព្យាយាមតិចមិនសូវហត់តែសម្បត្តិក៏កើតឡើង
១៨.បិយតិប្បយោគាភាវតា មិនសូវព្រាត់ពីរបស់ដែលស្រឡាញ់
១៩.អភព្វតា មិនកើតជាមនុស្សស្រី ឬ ខ្ទើយទៀត
២០.អបាយភយវិនិមុត្តតា មិនធ្លាក់ទៅក្នុងអបាយភូមិ

សីលខ ទី ៤ វៀរចាកការនិយាយកុហក មានអានិសង្ស ១៤ យ៉ាង ៖

១.វិប្បសន្និន្ទ្រិយតា មានឥន្ទ្រិយថ្លូរផង់
២.វិស្សត្ថមធុរភាណិតា មានវាចាពិរោះផ្អែមល្ហែម
៣.សមសិតសុទ្ធទន្តតា មានធ្មេញស្មើជិតល្អបរិសុទ្ធ
៤.នាតិថូលតា មិនធាត់ពេក
៥.នាតិកិសតា មិនស្គមពេក

៦.នាតិវស្សស្សតា មិនទាបពេក
៧.នាតិទីឃតា មិនខ្ពស់ពេក
៨.សុខសម្ផស្សតា មានសម្ផស្សស្រួល
៩.ឧប្បលគន្ធមុខតា មានមាត់ក្លិនដូចផ្កាឈូក
១០.សុស្សូសកបរិជនតា មានបរិវារដែលសុទ្ធតែជាមនុស្សឧស្សាហ៍
១១.អាទេយ្យវចនតា មានពាក្យសម្តីដែលគេជឿបាន
១២.មុលុលោហិតតនុជិវ្ហតា មានអណ្តាតក្រហមខ្ចីដូចជាផ្កាឈូក
១៣.អនុទ្ធតតា មានចិត្តមិនរវើរវាយ
១៤.ឧបគតម្មមនតា មិនគរ មិននិយាយជាប់មាត់

សីលខទី៥ វៀរចាកការសេពគ្រឿងស្រវឹង មានអានិសង្ស ៣៥ យ៉ាង

១-កិច្ចករណីយេសុ ខិប្បជិវិជាននតា ដឹងកិច្ចការក្នុងអតីតបច្ចុប្បន្ន និង អនាគតបានឆាប់រហ័ស
២-សទាឧបដ្ឋិតស្សតិតា មានសតិជាប់ជានិច្ច
៣-អនុមត្តកតា មិនឆ្កួតវង្វេង
៤-ញាណវត្តតា មានចំណេះដឹងច្រើន
៥-អនេឡូតា មិនវង្វេង ជាអ្នកមានហេតុផល
៦-អជឡូតា មិនវង្វេងវង្វាន់
៧-អមូគតា មិនឆ្កួត
៨-អមទតា មិនស្រវឹង
៩-អប្បមត្តតា មិនប្រមាទ
១០-អសម្មោហតា មិនឈ្លក់វង្វេង
១១-អច្ឆម្ភិតា មិនខ្លាចព្រួយ
១២-សារម្ភិតា មិនមានសេចក្តីរំខាន
១៣-អនិស្សុយិតា មិនមានអ្នកប្រស្សា
១៤-អប្បោសសុក កតា មានសេចក្តីខ្វល់ខ្វាយ តិច
១៥-សុខិតតា មានសេចក្តីសុខ

| | |
|---|---|
| ១៦-អធិសម្មតតា | មានមនុស្សគោរពកោតក្រែង |
| ១៧-សច្ចវាទិតា | និយាយតែពាក្យសច្ចៈ |
| ១៨-អបិសុណតា | មិននិយាយបញ្ឆិតបញ្ឆៀងនរណា |
| ១៩-អផរុសតា | មិននិយាយអាក្រក់ដាក់នរណា |
| ២០-អសម្ផប្បលាទិតា | មិននិយាយរោយរាយឥតប្រយោជន៍ដាក់នរណា |
| ២១-រត្តិទិវមនុិតតា | មិនខ្ជិលប្រអូលទាំងថ្ងៃទាំងយប់ |
| ២២-កតញ្ញុតា | ជាមនុស្សកតញ្ញូ |
| ២៣-កតវេទិតា | ជាអ្នកចេះតបស្នងគុណគេវិញ |
| ២៤-អមច្ឆរិយតា | មិនកំណាញ់ |
| ២៥-ចាគវន្តតា | ចេះបែងចែកលះបង់ |
| ២៦-សីលវន្តតា | មានសីលបរិសុទ្ធ |
| ២៧-ឧជុកតា | មានសេចក្តីស្មោះត្រង់ |
| ២៨-អក្កោធនតា | មិនសូវចេះខឹង |
| ២៩-ហិរិមន្តតា | មានសេចក្តីខ្មាសបាប |
| ៣០-ឱត្តប្បិតា | មានចិត្តខ្លាចរបស់អំពើបាប |
| ៣១-ឧជុទិដ្ឋិតតោ | មានការយល់ត្រូវ |
| ៣២-មហាបញ្ញតា | មានបញ្ញាច្រើន |
| ៣៣-មេធាវិតា | មានបញ្ញារុងរឿងក្នុងធម៌ |
| ៣៤-បណ្ឌិតតា | ជាបណ្ឌិតមានញាណគតិ |
| ៣៥-អត្ថានត្ថកុសលតា | ឆ្លាតដឹងក្នុងរបស់ដែលជាប្រយោជន៍ |

និងដែលជាទោស

ប៉ុន្តែលោក Bahm បានរំលឹកថា "វិធីធ្វើទស្សនវិជ្ជាប្ញីត្យិតវាមានសារប្រយោជន៍ខ្លាំងចំពោះអ្នកស្រាវជ្រាវសច្ចភាព តែវាអាចត្រូវប្រើប្រាស់ដោយក័ន្តច្រឡំ ដោយត្លុកវៃឆ្លាត និងត្លុកបញ្ញវន្តដែលអាច "បង្វែរទស្សនវិជ្ជាទៅជាការការពារភាពបន្ទំ បង្វែរបញ្ញាទៅជាភាពកំព្រើល បង្វែរភាពស៊ីជម្រៅទៅត្រឹមជាការកំប្លែង" ។

«ព្រះពុទ្ធជាកញ្ចក់ដ៏ល្អ កញ្ចក់ល្អតែងឆ្លុះបញ្ចាំងការពិតបានល្អ ។

ព្រះពុទ្ធឥតមានរកឃើញអ្វី ឥតមានថែមថយអ្វី ទៅលើសភាវៈពិតៗមែនៗ ក្នុងជីវិតឡើយ ។

ព្រះអង្គសង្កេតការពិតក្នុងភាពស្ងប់ស្ងាត់បំផុត ទាំងការពិតខាងក្នុងខ្លួន ដោយខិតចូលកាន់តែជ្រៅទៅ កាន់តែច្បាស់ឡើង ដោយគ្មានអំណួត និងជំនោរបុគ្គលក្នុងគំហើញទាំងឡាយ ហើយឆ្លុះបញ្ចាំងឱ្យគេទាំងអស់ ដឹងឮឬតាមសភាវៈពិត សភាវៈមែនតែប៉ុណ្ណោះ ។ ព្រះពុទ្ធដោះស្រាយជីវិតទាំងឡាយដោយមិនប្រើអំពើហិង្សានិងអាវុធឡើយ ព្រះអង្គឈ្នះមារទាំងឡាយដោយមេត្តាធម៌ និងសច្ចធម៌តែប៉ុណ្ណោះ» ។

សន្ទេបទ្រឹស្តីអប់រំមួយចំនួនរបស់ព្រះពុទ្ធ ៖ កុំប្រព្រឹត្តអំពើបាប ព្រះពុទ្ធបានប្រៀនប្រដៅមិនឱ្យមនុស្សប្រព្រឹត្តអំពើអាក្រក់ លះបង់នូវគំនុំគំគួនដែលមាននៅក្នុងចិត្តដោយលោកមានពុទ្ធដីកាថា ពៀររម្ងាប់ដោយការមិនចងពៀរ។ ដរាបណា គំនុំនៅតែមានក្នុងចិត្ត កំហឹងក៏នៅតែឆេះឆំជានិច្ច បើកាលណាគំនុំវិនាសអស់ នោះភ្លើងកំហឹងក៏រលត់អស់ដែរ។ ការលះបង់គំនុំគ្មានអ្វីក្រៅពីអប់រំចិត្តឱ្យស្ងប់នោះទេ ព្រោះថាគ្មានអ្វីដែលស្ងប់ប្រសើរជាងចិត្តស្ងប់នោះទេ ពុំមានសត្រូវឯណាក្រៅពីចិត្តរបស់ខ្លួនទេដែលដឹកនាំខ្លួនឱ្យសៅហ្មង ធ្វើដំណើរទៅកាន់ផ្លូវអាក្រក់។ ចិត្តសៅហ្មងកម្រើកជានិច្ចពីលោកមួយទៅលោកមួយ ផ្ទុយទៅវិញបុគ្គល ណាដែលចេះការពារចិត្តរបស់ខ្លួន ពោលគឺចេះរក្សាចិត្តតម្កល់ចិត្តឱ្យនៅនឹងថ្កល់ ទប់ទល់នឹងសេចក្តីលោភលន់ សេចក្តីខឹងក្រោធ អំពើអាក្រក់ បុគ្គលនោះនឹងប្រកបដោយសេចក្តីស្ងប់សុខពិតប្រាកដមិនចេះចប់។

ព្រះពុទ្ធតែងតែមានពុទ្ធដីកាថា បុថុជ្ជនទាំងឡាយចូរកុំប្រព្រឹត្តនូវអំពើណា ដែលមិនគប្បីដល់អ្នកដទៃឱ្យសោះ បើយើងមិនចង់ឱ្យគេប្រព្រឹត្តអំពើនោះមកលើខ្លួនយើងវិញ។ ចូរសាបព្រួសបណ្តុះតែអំពើល្អបានហើយ អ្នកទាំងឡាយគប្បីប្រកាន់ឱ្យបាននូវនិច្ចសីលជាប្រចាំ។ បុគ្គលណា ដែលអាចគ្រប់គ្រងចិត្តដោយការទូន្មានល្អ មានន័យថា សប្បាយរីករាយនឹងការទូន្មានល្អរបស់អ្នកដទៃ បុគ្គលនោះ ឈ្មោះថាជា មនុស្សមានសីលធម៌ល្អប្រពៃ។

បុគ្គលទាំងឡាយកុំសងសឹកធ្វើអ្វី ពៀររម្ងាប់ដោយការមិនចងពៀរ បើមានគេធ្វើមិនល្អមក លើយើង យើងមិនត្រូវចង់ឈ្នះទេ យើងត្រូវគិតថា «ចាញ់បានជា ព្រះឈ្នះបានជាមារ» ព្រះពុទ្ធហាមមិន ឱ្យនិន្ទាឈ្នានីស ឬថ្កោលទោសអ្នកដទៃឡើយ យើងត្រូវដឹងថា គេក៏

*ចេះខឹងដូចយើងដែរ នៅពេលដែល យើងនិយាយមិនល្អពីគេ។ ព្រះអង្គមិនឱ្យអ្នកណាប្រើពាក្យស្បថទេ ការស្បថជាពាក្យ ដែលមនុស្សមានចិត្តមិនទៀងត្រង់កំសាក ស្បថបំពាន ធ្វើយ៉ាងណាឱ្យតែគេជឿ។ មនុស្សទាំងឡាយចូររស់នៅដោយជំនះចិត្តខ្លួនឯងឱ្យបាន បើ បុគ្គលជំនះលើចិត្តខ្លួនឯងបានហើយ វាក៏ជាមហាជោគជ័យមួយធំជាងឈ្នះសត្រូវ មួយពាន់ នាក់នៅក្នុងលានប្រយុទ្ធទៅទៀត។ ដរាប ណាបុគ្គលមិនអាចគ្រប់គ្រងចិត្តរបស់ ខ្លួនបានទេ គេមិនព្រមលះបង់គំនិតថា «នេះជារបស់អញ អ្វីៗសុទ្ធតែជារបស់អញ» បានទេ ព្រោះបុគ្គលនោះធ្លាក់ទៅក្នុងតណ្ហានៃការលោភលន់ ដែលជាអំពើឥតអៀនខ្មាស់ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន។ ការដែលបុគ្គលបានរអិលធ្លាក់ទៅក្នុងអំពើឥតអៀនខ្មាស់ ការឡើងចិត្តគឃ្លើន ការវាយឫក ក្រអឺតក្រទមរើសអើងប្រកាន់ឋានៈ។ ដោយសារតែសេចក្តីលោភនេះ ទើបធ្វើឱ្យបុគ្គលអាចប្រព្រឹត្តអំពើអាក្រក់ទៅលើអ្នកដទៃបានយ៉ាងងាយ ដោយគ្មានចិត្តចេះនឹកស្តាយក្រោយឡើយ។ ប៉ុន្តែបើជាការធ្វើខ្លួនឱ្យបានសុភាពរាបសារ ការចេះគោរព នឹងផ្តល់កិត្តិយសដល់អ្នកដទៃ ការធ្វើឱ្យខ្លួនក្លាយទៅជាមនុស្សល្អជាការលំបាក ។*

*បុគ្គលទាំងឡាយចូរកុំមើលឃើញតែកំហុសរបស់អ្នកដទៃឱ្យសោះ។ ការមើលឃើញតែកំហុសរបស់អ្នកដទៃ នោះជាការងាយស្រួលទេ ប៉ុន្តែវាពិតជាការលំបាក ណាស់ដែលបុគ្គលអាច មើលឃើញកំហុសរបស់ខ្លួន ។ គេអាចប្រកាសកំហុសរបស់ អ្នកដទៃបានតែគេមិនព្រមឱ្យអ្នកណាម្នាក់ មកចង្អុល ឬទិតៀននូវកំហុសរបស់ខ្លួន ឱ្យចំៗនោះបានទេ ។ មនុស្សម្នាក់ៗ តែងតែមានគំនិតអាត្មានិយមជានិច្ច គ្រាន់តែអ្នកខ្លះមានច្រើន ហើយអ្នកខ្លះទៀតមានតិចតួចតែប៉ុណ្ណោះ។ មនុស្សគួរតែអប់រំចិត្តឱ្យស្ថិតនៅក្នុងគំនិតពីររបស់ទស្សនវិជ្ជា គឺគំនិតរិះគិតនិងគំនិតអជ្ឈាស្រ័យ។ តើគំនិតទាំង ២ខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ ?*

*(១).គំនិតរិះគិត គឺជាគំនិត ដែលមិនទទួលស្គាល់ភ្លាមនូវហេតុការណ៍មួយដោយពុំបានពិចារណានោះទេ ជាគំនិតដែលពន្យារទុកសិននូវវិនិច្ឆ័យ ហើយទុកពេលពិចារណាទើបធ្វើការសម្រេចជាក្រោយ ពោលគឺជាគំនិតគិតមុនគូរ។*

*(២).គំនិតអជ្ឈាស្រ័យ គឺជាគំនិតដែលមិនមានះថា មានតែគំនិតរបស់ខ្លួនទេដែលត្រូវ រីឯគំនិត ឬទង្វើរបស់អ្នកដទៃសុទ្ធតែខុសនោះទេ គឺថាបើខ្លួនឯងត្រូវ គេក៏អាចត្រូវដែរ បើឃើញគេខុស ត្រូវគិតថា ខ្លួនក៏អាចខុសដូចគេដែរ។ ជាគំនិតដែលទទួលយកមតិអ្នកដទៃមកពិចារណាឬគំនិតប្រជាធិបតេយ្យ។ បើបុគ្គលណាមានគំនិតទាំងពីរខាងលើនេះ បុគ្គល*

នោះនឹងមានសេរីភាពដោយអាចធ្វើជាម្ចាស់លើខ្លួនឯងបាន ហើយខ្លួនយើងអាចជាទីពឹងរបស់ខ្លួនឯងបាន ហើយក៏ជាទីពឹងរបស់អ្នកដទៃបានដែរ។

បុគ្គលទាំងឡាយគួរតែរក្សាការពារវិញ្ញាណរបស់ខ្លួនឱ្យបាន ដើម្បីទប់ទល់នឹងសត្រូវទាំងខាងក្នុង និងខាងក្រៅហើយកុំប្រហែសវាឱ្យសោះ។ បើប្រហែសតែបន្តិច វិញ្ញាណនឹងត្រូវធ្លាក់ចូលទៅក្នុងប្រវាក់ និងចំណងលោកិយ។ ដូចនេះជំហានទីមួយ នៅក្នុងការរំដោះវិញ្ញាណឱ្យរួចផុតពីប្រវាក់និងចំណងលោកិយនោះ គឺត្រូវតែគ្រប់គ្រងចិត្តរបស់ខ្លួនត្រូវជៀសវាងនូវការនិយាយច្រើនឥតប្រយោជន៍ ត្រូវមានស្មារតីប្រុងប្រយ័ត្នជានិច្ច ព្រោះមេឃមិនទុកដាននៃសត្វបក្សាបក្សី ដាននៃផ្កាយដួល ឬដាននៃខ្យល់ព្យុះទេ។ សេចក្តីទូន្មានអាក្រក់មិនអាចដឹកនាំយើងទៅកាន់ពន្លឺនៃ ការត្រាស់ដឹងបានច្រើនជាងទេ។ ប៉ុន្តែអ្នកបានសម្រេចពន្លឺនៃការត្រាស់ដឹងនឹងបាន ស្ថិតនៅក្នុងសេចក្តីស្ងប់ច្រើនជាង។

ព្រះពុទ្ធបានប្រៀនប្រដៅថា ការជាប់ជំពាក់ចិត្ត ដែលអាស្រ័យទៅដោយតណ្ហា គឺជាសភាវៈទ្រទ្រង់អភិក្រមនៃជីវិត។ អភិក្រមនៃជីវិតចេះតែបន្តកកើត និង ដុះដាលដរាបណាតណ្ហានោះនៅតែមាន។ នៅពេលដែលយើងប្រាថ្នាចង់បានអ្វីមួយនោះ យើងនឹងមានតណ្ហាឬការជាប់ជំពាក់ចិត្តចំពោះវត្ថុនោះ។ ពេលនោះហើយ ដែលយើងគួចចិត្តគោងស្ថិតនៅក្នុងចំណង់ដ៏ខ្លាំងក្លា។ ដំណើរនៃការចង់បាននោះយើង ត្រូវតែឆ្លងកាត់ភាពសង្ឃឹមជោគជ័យ និងបរាជ័យគ្រប់ជំពូក ទើបព្រះពុទ្ធទ្រង់ប្រៀនប្រដៅថា ចូរកុំជំពាក់ចិត្តនឹងអ្វីៗដែលអ្នកចូលចិត្ត ចូរកុំរុញច្រានចោលនូវអ្វី ដែលអ្នកមិនចូលចិត្ត។ ជាការពិតណាស់ អ្វីដែលយើងចូលចិត្ត ហើយសង្ឃឹមយ៉ាងមុតមាំទុកជាមុននោះ ទីបំផុតវាក៏ប្រែជារលាយសាបសូន្យ ឯអ្វីដែលយើងមិនបានសង្ឃឹមឬក៏មិនចូលចិត្តពីមុននោះ ត្រឡប់ជាបានការទៅវិញ។ ដូច្នេះ ត្រូវតែធ្វើចិត្តឱ្យនៅជាកណ្តាល មិនចូលចិត្តពេកក៏មិនស្អប់ពេក។ បើគេលុះនៅក្នុងអំណាចនៃការចូលចិត្ត និងការមិនចូលចិត្តខ្លាំងពេក ជាហេតុធ្វើឱ្យគេមិនអាចយល់ ឱ្យបានត្រឹមត្រូវអំពីន័យនៃកាលៈទេសៈទេ ទើបធ្វើឱ្យគេតែងតែចង់ដណ្តើមយកឈ្នះយកចាញ់ តែរៀងៗ ខ្លួន។ បើកាលណាគេ ចាកផុតពីការជាប់ជំពាក់ចិត្តបាន គេនឹងយល់បានយ៉ាងត្រឹមត្រូវអំពី កាលៈទេសៈនោះ ហើយអាស្រ័យហេតុនេះគេនឹងឃើញថា វត្ថុទាំងអស់តែងតែប្រែប្រួល ។ ការដែលអាចធ្វើឱ្យបុគ្គលម្នាក់អាចចាកផុតពីការជាប់ជំពាក់ចិត្តផ្សេងៗនោះបាន គឺមានតែចំណេះវិជ្ជាប៉ុណ្ណោះ ដែលអាចកម្ចាត់មន្ទិលសៅហ្មង គួរឱ្យខ្លាចជាងគេបង្អស់នោះបានគឺ មន្ទិលសៅហ្មង

នៃសេចក្ដីល្ងង់ខ្លៅ។ គេមិនអាចសង្ឃឹម នឹងធ្វើខ្លួនព្រមទាំង ធ្វើចិត្តរបស់គេឱ្យបរិសុទ្ធបានទេ ដរាបណាគេមិនអាចកម្ចាត់សេចក្ដីល្ងង់ខ្លៅចេញឱ្យអស់ពីខ្លួនគេ។ បើល្ងង់ហើយដឹងខ្លួនថាល្ងង់នោះវាប្រសើរជាងល្ងង់ ហើយនឹកស្មានថា ខ្លួនជាបណ្ឌិត។ បើស្រឡាញ់ខ្លួនត្រូវឃ្លាំមើលវាជានិច្ចកុំឱ្យវាធ្លាក់ទៅក្នុងអំពើអាក្រក់ កាលណាគេបានវៀរចាកអំពើអាក្រក់ និងកាលណាគេបានប្រកបអារម្មណ៍ស្ងប់គេនឹងជួបតែសេចក្ដីសុខ។

«អត្តាហិ អត្តនោ នាថោ» ខ្លួនត្រូវទីពឹងខ្លួន ព្រះពុទ្ធមិនអាចជួយឱ្យអ្នកណា ម្នាក់មានប្រៀបជាងអ្នកណាម្នាក់ទៀតបានទេ ឬធ្វើឱ្យអ្នកណាមានជាង ឬក្រជាង ខ្លាំងជាងអ្នកណាឡើយ។ បុគ្គលម្នាក់ៗត្រូវតែពឹងពាក់លើខ្លួនឯងជាមុនសិន ទើបព្រះជួយយើងជាក្រោយ។ ជាការពិតណាស់ ការពឹងពាក់លើខ្លួនឯងជាគុណសម្បត្តិដ៏ពិសេសមួយសម្រាប់មនុស្សម្នាក់ៗ។ ទាល់តែខិតខំតស៊ូដោះស្រាយនូវបញ្ហារបស់ខ្លួនដោយខ្លួនឯងផ្ទាល់ទើបគេហៅថា មនុស្សមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងរស់ដូចព្រូនសង្គម ឬគិតតែពីពឹងពាក់អ្នកដទៃ ត្រូវចេះរស់ដោយខ្លួនឯងទើបប្រសើរ។ ជាពិសេសមនុស្សយើងធ្វើអ្វីៗក៏ដោយ ក៏ត្រូវតែហ៊ានទទួលខុសត្រូវចំពោះ អំពើដែលខ្លួនបានប្រព្រឹត្ត ដោយចេះបង្ហាញ ការពិត ហ៊ានប្រឈមមុខនឹងការពិត ចេះកែកំហុសរបស់ខ្លួនមករកផ្លូវល្អ ដើម្បីធ្វើខ្លួនឱ្យក្លាយទៅជាមនុស្សមានសមត្ថភាព និងគួរជាទីទុកចិត្តរបស់សង្គមជាតិនិងគ្រួសារ។

ធ្វើជាមនុស្ស គឺមិនគួររស់នៅតែក្នុងអតីតកាលនោះទេ ហើយក៏មិនគួររស់នៅក្នុង ក្ដីស្រមៃនោះដែរ ពោលគឺត្រូវរស់នៅឱ្យសមស្របទៅតាមកាលៈទេសៈ មិនគួរធ្វើខ្លួនឱ្យលង់ទៅក្នុងអ្វីមួយដែលជ្រៅពេកទេ។ យើងត្រូវតែមានជំនឿចិត្តលើខ្លួនឯង ត្រូវខិតខំប្រឹងប្រែងរស់ក្នុងបច្ចុប្បន្នគឺរស់ដោយសមត្ថភាព រស់ដោយការព្យាយាមតស៊ូអំណត់អត់ធន់គ្រប់យ៉ាងទើបជីវិតរបស់យើងបានប្រសើរ។ ដូច្នេះហើយទើបព្រះពុទ្ធទ្រង់ត្រាស់ថា “ចូរកុំគិតទាក់ទាមនឹងអតីត ហើយក៏កុំរង់ចាំអនាគត កិច្ចតែមួយគត់គឺត្រូវចេះរស់នៅប្រកបដោយចិត្តនឹងន៏ក្នុងបច្ចុប្បន្នជាតិនេះឯង។ ការបំពេញកិច្ចនៅក្នុងបច្ចុប្បន្នជាតិឱ្យបានល្អជាការប្រសើរមួយ។ ចូរកុំនឹកគិតជៀសវាងកិច្ចបច្ចុប្បន្ននេះឬទុកវាធ្វើនៅថ្ងៃស្អែក បើអ្នកបំពេញកិច្ចបច្ចុប្បន្ននេះសមរម្យល្អបាន អ្នកនឹងរស់នៅបានសុខសប្បាយរីករាយពេញមួយថ្ងៃ”។ សមដូចសុភាសិតបុរាណ ពោលថា ធ្វើអ្វីត្រូវធ្វើឱ្យហើយកុំទុកឡើយបង្កើតកេ្ដី។

គ្មានអ្នកបំភ្លឺឯណាប្រសើរជាងអ្នកគតិធម៌នោះទេ ( មានចំណេះដឹងជ្រៅជ្រះខាងព្រះធម៌) គ្មានមិត្តណាប្រសើរជាងគំនិតជ្រះថ្លាទេ។ បុគ្គលទាំងឡាយតែងតែ ទំរត់គេចចេញពីអំពើអន្ធពាលនៃ សេចក្តីល្ងង់ខ្លៅនិងទុក្ខព្រួយ ហើយខិតខំស្វែងរកពន្លឺនៃចំណេះវិជ្ជា។ ដោយហេតុថា មនុស្សរស់នៅក្នុងសង្គមត្រូវតែមានចំណេះដឹង ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ជីវិតរស់នៅគ្មានចំណេះ ប្រៀបបាននឹងជីវិតរស់នៅដូចកន្ត្តបក្នុងអណ្តូង ស្ថិតនៅក្នុងភាពងងឹតងងុល។ ចំណេះវិជ្ជាជាសម្បត្តិមួយដ៏មានតម្លៃជាងទ្រព្យសម្បត្តិអ្វីៗទាំងអស់។ ចំណេះវិជ្ជា គឺជាមាគ៌ាមួយដែលដឹកនាំយើង ឱ្យឆ្ពោះទៅកាន់អនាគតដ៏ភ្លឺស្វាង។ ហេតុនេះ ហើយទើបព្រះពុទ្ធជាម្ចាស់មានពុទ្ធដីកាថា «បុគ្គលទាំងឡាយមានអ្វីក៏មិនស្មើនឹងមានចំណេះវិជ្ជាដែរ ចូរខិតខំស្វែងរកវាដោយការព្យាយាមចុះ។ ចំណេះវិជ្ជា និង គុណធម៌ គឺជាគតិបណ្ឌិតមួយដែល យើងគួរតែស្វែងរក និងស្វែងយល់ឱ្យបានច្បាស់លាស់»។

កាលណាបុគ្គលគ្រប់រូបអាចគ្រប់គ្រងកាយ និងចិត្តរបស់គេបាន នេះគឺជាសញ្ញានៃអំពើប្រកបដោយគុណធម៌ និងជាករណីយកិច្ចដ៏ខ្ពង់ខ្ពស់បំផុតមួយ។ ពេលនោះហើយ ដែលបុគ្គលមានជំនឿទុកចិត្តទៅលើខ្លួនឯង គឺមានន័យថាបុគ្គលមានការយល់ដឹងយ៉ាងច្បាស់អំពីទំហំនៃអំពើដែលខ្លួនធ្វើហើយជឿថា ខ្លួនពិតជាមានសមត្ថភាពអាចធ្វើអ្វីៗបានសម្រេច។ ជំនឿជាក់លើខ្លួនឯង គឺជាកត្តាជំរុញឱ្យការងារទទួលបានជោគជ័យ។ ជំនឿនេះ ជាជំនឿជ្រះថ្លាដែលនឹងបានជាសម្បត្តិ សេចក្តីស្មោះត្រង់ នឹងផ្តល់រសជាតិផ្អែមត្រជាក់ដល់ជីវិត ចំណែកឯការសន្សំ ប្រមូលកុសលផលបុណ្យនេះ នឹងបានជាករណីយកិច្ចមួយប្រសើរបំផុត ។

ក្នុងដំណើរនៃជីវិត ជំនឿជ្រះថ្លាជាចំណីអាហារគុណធម៌ ជាទីជម្រកគតិធម៌ ជាពន្លឺនៅពេលថ្ងៃ ការចេះប្រុងប្រយ័ត្នដ៏ត្រឹមត្រូវជាសម្ភារៈការពារនៅពេលយប់។ បុគ្គលណាចេះរស់នៅក្នុងជីវិតស្អាតបរិសុទ្ធ គ្មានអ្វីអាចមកបំផ្លាញគេបានទេ។ បុគ្គលណាឈ្នះសេចក្តីលោភលន់ដោយចេះការពារចិត្តរបស់ខ្លួនពិតជាគ្មានអ្វីអាចកំណត់សេរីភាពរបស់គេបានទេ។

គេតែងបំភ្លេចខ្លួនដើម្បីសេចក្តីស្នេហាដល់គ្រួសារ។ គេតែងតែលះបង់សេចក្តីស្នេហាគ្រួសារ ដើម្បីសេចក្តីស្នេហាភូមិស្រុក។ គេតែងតែបំភ្លេចភូមិស្រុកគេ ដើម្បីសេចក្តីស្នេហាប្រទេសជាតិគេ ។ ជាសម្រេច គេតែងតែបំភ្លេចនូវអ្វីៗទាំងអស់ ដើម្បីសេចក្តីស្នេហាពន្លឺនៃការត្រាស់ដឹង។

សេចក្តីអំណត់ ជាវិន័យមួយក្នុងចំណោមវិន័យដែលពិបាកជាងគេបង្អស់។ ប៉ុន្តែ មានតែអ្នកមានអំណត់ទេ ដែលត្រូវទទួលជោគជ័យ។ លោកនេះជាភ្លើងឆេះជានិច្ច ឆេះដោយភ្លើងរាគៈ ភ្លើងកំហឹង ភ្លើងនៃភាពលោភលន់ ភ្លើងល្ងង់ខ្លៅ។ គេតែងតែរត់ គេចពីគ្រោះ ថ្នាក់ទាំងអស់នេះជាបន្ទាន់។ ច្រេះកើតចេញអំពីដែក តែងស៊ីទម្លុះដែកវិញ។ ដូចគ្នានេះដែរ អំពើអាក្រក់កើតចេញពីចិត្តតែងស៊ីទម្លុះចិត្តវិញ។

សុភមង្គលទៅតាមក្រោយទុក្ខព្រួយ ទុក្ខព្រួយទៅតាមក្រោយសុភមង្គល។ ប៉ុន្តែ បើសិនជាគេមិនបានធ្វើការវែកញែកត្រិះរិះពិចារណាវាឱ្យដាច់រវាង សុភមង្គល និងទុក្ខព្រួយ រវាងអំពើល្អនិងអំពើអាក្រក់នោះទេ គេមិនអាចនឹងបានស្គាល់សេចក្តីសុខពិតប្រាកដបានឡើយ។

នៅក្នុងលោកនេះ គ្មានអ្វីដែលថាមិនប្រែប្រួលនោះទេ។ អ្វីៗទាំងអស់សុទ្ធ តែប្រែប្រួល អ្វីៗទាំងអស់កើតឡើងហើយតែងតែវិនាសទៅវិញជាធម្មតា គ្មានសេចក្តីស្ងប់ទេដរាបណាគេមិនអាចឆ្លងផុតពីដំណើរប្រែប្រួលនៃការរស់និងការស្លាប់នេះ គឺវិលវល់កើតចាស់ឈឺស្លាប់ក្នុងវាលវដ្តសង្សារ។ ទើបព្រះពុទ្ធត្រាស់ថា «មានរូប មានទុក្ខ មានតែការប្រែប្រួល ទេដែលឥតប្រែប្រួល»។

ជារួមព្រះពុទ្ធសាសនាបង្រៀន សង្កត់ធ្ងន់លើសតិបញ្ញានៅក្នុងទង្វើរបស់ជីវិត។ ព្រះពុទ្ធឱ្យយើងចេះកម្ចាត់ចោលនូវសេចក្តីទុក្ខដោយត្រិះរិះពិចារណារកឱ្យ ឃើញនូវដើមហេតុនៃទុក្ខ ហើយធ្វើការកែតម្រូវនិងសម្រាយឱ្យបានត្រឹមត្រូវតាមសេចក្តីពិត មិនឱ្យជឿឬប្រកាន់យកផ្លូវដោះស្រាយបញ្ហាយ៉ាងធូរៗ ងាយស្រួល ហើយប្រាសចាកហេតុផលនោះទេ។

ព្រះពុទ្ធសាសនាមិនបានហាមប្រាមថា បទណាមួយជាធម៌ពិសេសនោះទេ ទោះបីមានភាសិត ដែលគេពោលត្រឹមត្រូវដ៏គួរប្រព្រឹត្តកាន់យកក៏ជាធម៌បានដែរ។ ឯការបរិច្ចាគទានក៏ប្រកាន់ថា «ជាវត្ថុដែលគួរប្រគល់ឱ្យដល់បុគ្គលមិនកំណត់ មានកំណត់តែវត្ថុដែលគួរឱ្យគួរលះទេ។ មួយទៀតប្រដៅឱ្យមានធម៌៧ប្រការគឺ ការដឹងហេតុ ដឹងផល ដឹងខ្លួន ដឹងប្រមាណ ដឹងកាលវេលា ដឹងការប្រជុំជន និងការដឹងបុគ្គល នេះហៅថា សប្បុរសធម៌»។

ព្រះពុទ្ធសាសនា មិនបានប្រដៅឱ្យអ្នកណាម្នាក់ប្រតិបត្តិទាល់តែកើតទុក្ខខ្លួន ឯងនោះទេ ធម៌វិន័យរបស់ព្រះពុទ្ធ រមែងធ្វើឱ្យអ្នកប្រតិបត្តិបានទទួលនូវសេចក្តីសុខ សេចក្តីចម្រើនក្នុងបច្ចុប្បន្នកាល ហើយក៏ហុចសេចក្តីសុខទាំងនោះទៅរកលោក ខាងមុខទៀតដែរ។ ព្រះពុទ្ធ

*ទ្រង់ ប្រដៅយើងឱ្យទទួលយកនូវប្រយោជន៍ ៣ យ៉ាងគឺ ប្រយោជន៍នៅក្នុងបច្ចុប្បន្នជាតិមួយ ក្នុងលោកខាងមុខមួយ និងប្រយោជន៍ខ្ពង់ខ្ពស់បំផុតគឺជាមគ្គផលនិព្វានមួយ។*

**១.១.តើព្រះពុទ្ធបានធ្វើសេចក្តីសន្យាណាមួយ ឬទេ?**

*ព្រះពុទ្ធមិនបានសន្យាផ្តល់បរមសុខ និងរង្វាន់ឋានសួគ៌ដល់មនុស្សទាំងឡាយ ដែលបានហៅខ្លួនឯងថា ជាសាវ័ករបស់ព្រះអង្គទេ ។ ព្រះអង្គ មិនបានសន្យាផ្តល់ការសង្គ្រោះដល់មនុស្សទាំងឡាយ ដែលបានជឿព្រះអង្គនោះដែរ ។ ចំពោះព្រះអង្គ សាសនាមិនមែនជាទំនិញមួយត្រូវតថ្លៃទេ ប៉ុន្តែជាមាគ៌ាជីវិតដ៏ប្រសើរដើម្បីសម្រេច បានការត្រាស់ដឹង និងការសង្គ្រោះ (វិមុត្តិ) ។ ព្រះពុទ្ធមិនចង់បានសាវ័កទាំងឡាយ ប្រកបដោយសទ្ធាងងឹតងងុលនោះទេ ព្រះអង្គចង់បានមនុស្សចេះត្រិះរិះ និងចេះ ស្វែងយល់។ ពុទ្ធសាសនា គឺជាមាគ៌ាមួយដ៏ប្រសើរសម្រាប់ការរស់នៅ ដែល នៅលើមាគ៌ានេះ គ្របដណ្តប់លើសលប់គេដោយមនុស្សនិយម សមភាព យុត្តិធម៌ និងសន្តិភាព ។ អំពើសង្ស័ក អរិភាព ការផ្តន្ទាទោស និងគំនុំគុំកួន គឺជាសភាវៈ ខាងក្រៅពីព្រះធម៌ ដែល ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។*

*ពិភពលោកបានជំពាក់គុណព្រះពុទ្ធយ៉ាងច្រើនសម្រាប់ការកើតមានឡើង នៃហេតុវាទ ឬ វិចារណវាទ* (Retionalism) *ដែលជាការតវ៉ាមួយប្រឆាំងមិច្ឆាមតិ* (Supersitition) *នៃសាសនា។ ព្រះពុទ្ធហ្នឹងឯង ដែលបានរំដោះមនុស្សឱ្យចេញផុត ពីទាសភាពនៃពួកបុព្វជិត ព្រាហ្មណ៍* (Priest)*។ គឺព្រះពុទ្ធបានបង្ហាញមុនគេ នូវមាគ៌ាទៅកាន់ភាពជាមនុស្សសេរី ផុតពីចំណងអន្ទាក់នៃការបោកបញ្ឆោត និងភាពផ្តាច់ការរបស់សាសនា។*

*ក្នុងអំឡុងសម័យកាលព្រះពុទ្ធគង់នៅ គ្មានការប្រតិបត្តិសាសនាណាមួយត្រូវបានចាត់ទុកជា ការប្រតិបត្តិប្រសើរជាងធ្វើបូជាវិធី បូជានិយម និងពលីការសត្វមានជីវិត ចំពោះទេពតាទាំងឡាយទេ។ ប៉ុន្តែចំពោះព្រះពុទ្ធវិញ គ្មានការប្រតិបត្តិណាមួយអាចជាការប្រតិបត្តិនាំឱ្យមានសេចក្តីអៀនខ្មាស ឬការបន្ថោកបន្ទាបជាងនេះ សម្រាប់មនុស្សនោះទេ។ ការធ្វើពលីការបន់ស្រន់ គឺគ្មានអ្វីក្រៅតែពីការស្លូកប៉ាន់ទេ ឯការសង្គ្រោះបានមកដោយការស្លូកប៉ាន់ និងអំពើពុករលួយ គឺមិនមែនជាការសង្គ្រោះ ដែលមនុស្សណាក៏ដោយប្រកបដោយកិត្តិយស និងសេចក្តីគោរពខ្លួនឯង គួរយកចិត្តទុកដាក់ចង់បាននោះឡើយ ។*

***វាក្យស័ព្ទសាសនា*** *៖ នៅក្នុងការបញ្ចូលលទ្ធិរបស់ព្រះអង្គ ព្រះពុទ្ធពិតជាបានប្រើពាក្យ សាសនាខ្លះៗជាធរមានស្រាប់ ហើយនៅក្នុងប្រទេសឥណ្ឌានាសម័យនោះ ពីព្រោះនៅ*

ក្នុងបែបបទនេះ ព្រះអង្គអាចឋិតនៅជិតស្និទ្ធជាមួយនឹងសាវ័កជន (អ្នកស្ដាប់) របស់ព្រះអង្គ ។ ពួកគេ(អ្នកស្ដាប់) អាចចាប់ បាននូវអ្វីដែលព្រះអង្គចង់មានបន្ទូលដល់ ហើយបន្ទាប់មក ព្រះអង្គអាចបន្តដំណើរដើម្បីអភិវឌ្ឍគំនិតដើមរបស់ព្រះអង្គចេញពីមូលដ្ឋានរួមនេះ ។

ធម៌: កម៌: និព្វាណ: មោក្ស: និរយ: សង្សារ: អាត្មា គឺជាពាក្យមួយចំនួន ដែលជាពាក្យរួម សម្រាប់ប្រើក្នុងក្រុមសាសនាទាំងអស់ ក្នុងអំឡុងសម័យកាលរបស់ព្រះអង្គ។ ប៉ុន្តែនៅក្នុងការប្រៀន ប្រដៅរបស់ព្រះអង្គ ព្រះពុទ្ធបានផ្ដល់អត្ថន័យ និងការបកស្រាយដ៏ពិសេសតែមួយគត់ ហើយប្រកបដោយវិចារណកម្មបំផុត ចំពោះពាក្យសាសនាជាធរមានស្រាប់ហើយទាំងនោះ ។

**ធម្ម: (ធម៌)** ៖ ចូរយើងក្រឡេកមើលពាក្យ ធម៌: ( ឬធម្ម: ) ជាឧទាហរណ៍។ ការបកស្រាយសម័យបុរាណផ្ដល់ឱ្យដល់ពាក្យធម៌:នេះ ដូច្នេះថា ធម៌ ៖ ជាច្បាប់មួយដែលអាទិទេពប្រទានឱ្យ បើតាមជំនឿបុរាណ អាទិទេពបានសន្យាចុះមកបង្ហាញខ្លួនម្ដងម្កាលដើម្បីការពារធម៌នេះ តាមការអវតារមកកើតក្នុងអង្គផ្សេងៗ។ ព្រះពុទ្ធមិនបានទទួលស្គាល់ថា មានអាទិទេពណាមួយអាចផ្ដល់លទ្ធិ បទបញ្ញត្តិ និង ច្បាប់សាសនាឱ្យទេ។ ព្រះអង្គបានប្រើពាក្យ ធម៌: ( ធម្ម: ) សម្រាប់ពណ៌នាពាក្យ ប្រៀនប្រដៅរបស់ព្រះអង្គទាំងមូល។ ធម៌: មានន័យថា អ្វីៗដែលទ្រទ្រង់ធ្វើឱ្យឋិតថេរគាំទ្រ។

ព្រះពុទ្ធបានបង្រៀនធម៌: ដើម្បីជួយយើងឱ្យផុតពីទុក្ខបង្កឡើងដោយការកើត ( ជាតិ ) និងដើម្បីបញ្ចៀសយើងឱ្យផុតពីការបន្ទោកបន្ទាបសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការធ្លាក់ចូលទៅក្នុងស្ថានភាព ថោកទាបដូចជា នរក តិរច្ឆាន បិសាច ឬប្រេត ឬក៏ទុគ្គតិភព។ ធម៌: ដែលព្រះពុទ្ធបានបញ្ចូល រមែងទ្រទ្រង់ និងគាំទ្រយើង ហើយរំដោះយើងឱ្យផុតពីទុគ្គតិភព នៃភពទាំងនោះ ។ វាមានន័យផងដែរថា បើយើងប្រតិបត្តិតាមវិធីទាំងឡាយ ដែលព្រះអង្គសម្ដែងប្រាប់ យើងនឹងមិនធ្លាក់ទៅក្នុងកាលៈទេសៈ ដ៏អក់ឱបែបនេះឡើយ ដូចជា កើតមកខ្វាក់ភ្នែក ពិការ ថ្លង់ គ ឬឆ្កួត ។ ដូច្នេះ ក្នុងការប្រើប្រាស់ពាក្យរបស់ព្រះពុទ្ធ ពាក្យធម៌: គឺជាជំនួននានផ្ដល់ឱ្យ ដើម្បីគាំទ្រយើងក្នុងការតស៊ូរបស់យើងដើម្បីរំដោះចេញឱ្យផុតពីទុក្ខហើយ ក៏ដើម្បីលើកស្ទួយតម្លៃមនុស្សផងដែរ។ ពួកទស្សនវិទូលោក ខាងលិចពិពណ៌នាពុទ្ធសាសនា ថាជាមាគ៌ានៃជីវិតដ៏ប្រសើរឬថាជា"សាសនាមានសេរីភាព និងវិចារណញ្ញាណ" ។

ធម៌ ៖ មិនមែនជាច្បាប់ដ៏អស្ចារ្យ ដែលនរណាម្នាក់បានបង្កើតឡើង ឬបានផ្តល់ឱ្យ នោះទេ។ តួខ្លួនរបស់យើងផ្ទាល់ គឺជាធម៌:។ ចិត្តរបស់យើងផ្ទាល់គឺ ធម៌: សកលលោក ធាតុទាំងស្រុងគឺ ជាធម៌:។ ដោយការយល់ដឹងនូវធម្មជាតិ ( ចរិត) នៃរូបកាយ និងធម្មជាតិនៃចិត្ត ហើយនិងលក្ខខណ្ឌលោកិយ យើងដឹងច្បាស់ធម៌:។ ព្រះពុទ្ធបានបង្រៀន យើងឱ្យស្វែងយល់នូវធម្មជាតិ (ចរិត) នៃជីវិតរបស់យើង ប្រកបដោយហេតុផលក្នុងបែបបទមួយជាក់ស្តែង។ ជីវិតរបស់យើងទាក់ទងនឹងជីវិតរបស់សត្វលោកនីមួយនៅក្នុងលោកនេះ នាពេលឥឡូវនេះ ហើយដោយហេតុនេះ ជីវិតរបស់យើងមានអន្តរសម្ព័ន្ធជាមួយជីវិតទាំងអស់[២៧]។

តាមធម្មតា កាលណាគេនិយាយពីសាសនា គេតែងសួរថា "អ្វីជាសទ្ធារបស់អ្នក?" (What is your faith ?)។ គេបានប្រើពាក្យ សទ្ធា (faith) ។ ព្រះពុទ្ធមិនបានជាប់ព្រះទ័យ ក្នុងការអភិវឌ្ឍ "សទ្ធា" ក្នុងន័យដាច់ខាតនោះទេ ទោះបីសទ្ធានេះអាចមានប្រយោជន៍នៅក្នុង ដំណាក់កាលដំបូង នៃការអភិវឌ្ឍសាសនារបស់បុគ្គលក៏ដោយ។ គ្រោះថ្នាក់នៃការជឿទុកចិត្តលើសទ្ធាតែម្យ៉ាង ដោយគ្មានចំណេះដឹងវិភាគច្បាស់លាស់ គឺជាគ្រោះថ្នាក់ដែលអាចនាំយើងឱ្យធ្លាក់ក្នុងជំនឿងប់ងុលក្នុងសាសនា ( ទិដ្ឋិម្មាទ ) (Religious fanatics)។ ជនទាំងឡាយណា ដែលបានធ្វើឱ្យសទ្ធាចាក់ឫសរឹងមាំ នៅក្នុងដួងចិត្តរបស់ខ្លួន ហើយជនទាំងឡាយនោះមិនអាចមើលឃើញទស្សនៈវិស័យរបស់មនុស្សឯទៀតបានទេ ពីព្រោះគេបានស្ថាបនានៅក្នុងដួងចិត្តរបស់គេរួចស្រេចទៅ ហើយថាអ្វីដែលគេជឿ គឺជាសច្ចៈតែមួយគត់។ ព្រះពុទ្ធបន្ទេរីនរំលឹកជាញឹកញាប់ថា បុគ្គលមិនត្រូវជឿ សូម្បីព្រះធម៌របស់ព្រះអង្គផ្ទាល់ក៏ដោយលើមូលដ្ឋានសទ្ធា តែឯងនោះទេ។ បុគ្គលត្រូវមានចំណេះដឹង ( ពុទ្ធិ ) ហើយបន្ទាប់មកធ្វើឱ្យរីកចម្រើនសេចក្តី យល់ដឹងតាមរយៈការសិក្សា ការពិភាក្សាការនា ហើយនៅទីបំផុត តាមរយៈឈាន ( ឬបច្ចវេក្ខណ: )។ ចំណេះដឹង ( ពុទ្ធិ ) គឺជារឿងមួយ សេចក្តីយល់ដឹង គឺជារឿងមួយទៀត ។ ប្រសិនបើមានសេចក្តីយល់ដឹង បុគ្គលអាចកែតម្រូវជីវិតរបស់ខ្លួន បានឱ្យស្របទៅតាមកាលៈទេសៈកំពុងប្រែប្រួលដោយផ្អែកលើចំណេះដឹងដែលខ្លួនមាន។ យើងអាចមានឱកាសជួបមនុស្សចេះដឹង ជាពហុសូតដែលចេះដឹងអ្វីៗច្រើន ប៉ុន្តែជាមនុស្សមិនប្រកដនិយម ពីព្រោះតែអាត្មានិយមរបស់គេអត្តទត្តភាពរបស់គេ បដិឃៈរបស់គេ និងគំនុំរបស់គេ មិននាំឱ្យគេចាប់យកបាននូវឥរិយាបថផ្លូវចិត្តឥតលំអៀង និងសេចក្តីក្សេមក្សាន្ត ក្នុងចិត្តបានទេ។ កាលណា

[២៧] បណ្ឌិតសភាចារ្យ ខ្ចួត ធីតា ៖ មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ឆ្នាំ២០០៩ ទំព័រ ១៨០-១៨៥

មានករណីចាំបាច់ត្រូវធ្វើសម្បទាន យើងត្រូវចេះដឹងធ្វើសម្បទាន។ កាលណាមានករណីចាំបាច់ត្រូវសន្ដោស យើងក៏ត្រូវចេះដឹងសន្ដោសអធ្យាស្រ័យ។ កាលណាមានករណីត្រូវពង្រឹងជំហរ ម៉ឺងម៉ាត់ យើងក៏ត្រូវតែចេះដឹងពង្រឹងជំហរម៉ឺងម៉ាត់ដោយសេចក្ដីថ្លៃថ្នូរ។

**កម៌ (កម្ម:)** ៖ ចូរយើងលើកយកឧទាហរណ៍មួយទៀត គឺពាក្យកម៌ (ឬកម្ម: ) ។ ពាក្យនេះ មានន័យយ៉ាងសាមញ្ញថាអំពើ។ ប្រសិនបើ មនុស្សម្នាក់បានធ្វើកម្ម អាក្រក់សម្រាប់មនុស្សនោះ គេមិនងាយគេចផុតពីផលអាក្រក់របស់អំពើនោះឡើយ។ ដោយប្រការនេះ ឬប្រការផ្សេង បុរស ឬស្ត្រីនោះ ត្រូវប្រឈមមុខ ចំពោះផលវិបាកទាំងឡាយ ដែលហូរចេញមកពីអំពើនោះ។ យោងតាមជំនឿពីព្រេងនាយគេបានយល់ថា មានទេពតាមួយអង្គចាំបែងចែកកម្មនេះ។ ទេពតាផ្ដន្ទាទោសយោងតាមអំពើ(កម្ម)អាក្រក់របស់បុគ្គល ទេពតាផ្ដល់រង្វាន់យោងតាមអំពើ (កម្ម) ល្អរបស់បុគ្គល។ ព្រះពុទ្ធមិនបានទទួលស្គាល់ជំនឿនេះទេ។ ព្រះអង្គមានបន្ទូលថាគ្មានតួអង្គអាទិទេព ឬអានុភាពណាមួយដែលជាអ្នកចាត់ចែងប្រតិបត្តិ ការចែកផលនៃកម្មទេ។ កម្មផ្ទាល់នឹងផ្ដល់លទ្ធផលក្នុងឋានៈ ជាប្រតិបត្តិការអព្យាក្រឹតនៃក្រឹត្យក្រមហេតុនិងផល។ ព្រះអង្គបានមានបន្ទូលថា យើងអាចជៀសបានហើយនៅក្នុងករណី ខ្លះរហូតដល់ជំនះលើផលនៃកម្មបានទៀតផង ប្រសិនបើយើងប្រព្រឹត្តបានល្អ។ ព្រះអង្គបានទូន្មានថា យើងមិនត្រូវដាក់ខ្លួនយើងចុះចាញ់ឥទ្ធិពលព្រេងវាសនាដោយគិតថា កាលណាយើងបានធ្វើអំពើអាក្រក់ហើយគេគ្មានសេចក្ដីសង្ឃឹមផ្សេងទៀតទេ។ សាសនាដទៃទៀតប្រៀនប្រដៅថាទេពតា (ឬអាទិទេព) អាចធ្វើឱ្យទៅជាអហោសិកម្មបាននូវផលនៃកម្ម តាមរយៈការលើកលែងទោស ប្រសិនបើអ្នកជឿធ្វើពិធី បូជា បន់ស្រន់ និងថ្វាយពលិការ។ ប៉ុន្តែព្រះពុទ្ធប្រៀនប្រដៅថា យើងត្រូវធ្វើឱ្យសម្រេចនូវការសង្គ្រោះ ដោយកម្លាំងវិតខំផ្ទាល់របស់យើងនិងសម្អាតចិត្តឱ្យល្អផូរផង់។

"ព្រះពុទ្ធអាចចង្អុលប្រាប់អ្នកនូវអ្វីត្រូវធ្វើ ប៉ុន្តែព្រះអង្គមិនធ្វើកិច្ចការនោះជំនួសអ្នកទេ"។ អ្នកត្រូវធ្វើកិច្ចការសង្គ្រោះដោយខ្លួនឯង។ ព្រះពុទ្ធបានបញ្ជាក់យ៉ាងច្បាស់លាស់ថា គ្មាននរណាអាចធ្វើអ្វីមួយជំនួសអ្នកឯទៀតសម្រាប់ការសង្គ្រោះបានទេ លើកលែងការគ្រាន់តែបង្ហាញផ្លូវចេញ។ ព្រោះហេតុនោះយើងមិនត្រូវពឹងពាក់អាទិទេព ( ឬទេពតា) ហើយក៏មិនត្រូវពឹងពាក់ព្រះពុទ្ធផងដែរ។ យើងត្រូវដឹង នូវអ្វីជាគុណសម្បត្តិ ជាករណីយកិច្ច និងជាការទទួលខុសត្រូវក្នុងឋានៈយើងជាតួអង្គមនុស្សម្នាក់។ ព្រះអង្គទូន្មានថា ប្រសិនបើយើងបានប្រព្រឹត្តធ្វើ

កម្មអកុសលខ្លះៗ យើងមិនគប្បីខ្ជះខ្ជាយថាមពលដ៏ថ្លៃថ្លា ដោយការខកចិត្ត ឬអស់សង្ឃឹមមិនខិតខំធ្វើសេចក្ដីព្យាយាមដើម្បីកែតម្រូវអំពើនោះឡើយ ។

កិច្ចត្រូវបំពេញដំបូងបង្អស់ គឺត្រូវប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ បញ្ចប់ការប្រព្រឹត្តអំពើដដែលៗ ដូចជាបាបកម្មដោយសេចក្ដីយល់ដឹងនូវសេចក្ដីអន្តរាយ ដែលបាបកម្មនោះអាចបង្កឡើង។ កិច្ចទីពីរគឺត្រូវបណ្ដុះកុសលកម្មឱ្យបានច្រើនឡើងៗ។ កិច្ចទីបី យើងត្រូវខិតខំបន្ថយគំនិតអាក្រក់ អត្តទត្តភាព គំនុំគុំគួន ទោសៈ ប្រណែន ឈ្នានីស និងព្យាបាទ។ តាមគន្លងនេះ យើងអាចបន្ថយផលអាក្រក់នៃបាបកម្មដែលយើងបានប្រព្រឹត្ត។ នេះគឺជាវិធីរបស់ព្រះពុទ្ធសម្រាប់ជំនះផលអាក្រក់។ ព្រះអង្គមិនបានមានបន្ទូលប្រាប់ឱ្យយើង ត្រូវតែបន់ស្រន់និងគោរពបូជាព្រះអង្គ រួចហើយព្រះអង្គនឹងសន្ដោសទោសទាំងអស់របស់យើងនោះទេ។

សេចក្ដីបរិសុទ្ធ និងសេចក្ដីមិនបរិសុទ្ធ នៃចិត្តរបស់យើង អាស្រ័យលើខ្លួនយើង ផ្ទាល់។ គ្មានអាទិទេព គ្មានព្រះពុទ្ធអង្គ គ្មានតួអង្គមនុស្សណា អាចធ្វើឱ្យសៅហ្មងឬធ្វើឱ្យ បរិសុទ្ធនូវចិត្តរបស់បុគ្គលឯទៀតឡើយ។ ខ្ញុំមិនអាចបង្កើតសេចក្ដី សៅហ្មងក្នុងចិត្តរបស់ លោកបានទេ ។ ខ្ញុំមិនអាចធ្វើចិត្តរបស់ លោកអ្នកឱ្យបរិសុទ្ធ បានទេ ។ ប៉ុន្តែដោយការធ្វើតាម ពាក្យខ្ញុំ ឬធ្វើតាមអំពើរបស់ខ្ញុំ លោកអ្នកបង្កើត សេចក្ដីបរិសុទ្ធ ឬសេចក្ដីមិនបរិសុទ្ធនៅឰដ៏ផ្ទៃក្នុងរបស់លោកអ្នកបាន។ អ្នកក្រៅ ឬអ្នកឯទៀតមិនអាចធ្វើអ្វីមួយសម្រាប់ចិត្ត របស់ លោកអ្នកបានទេ ប្រសិនបើចិត្ត របស់លោកអ្នកមានកម្លាំងគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងអំពើ នេះ ។ ព្រោះហេតុនេះ ចំណេះដឹង និងសេចក្ដីយល់ដឹង គឺជាគុណធម៌សំខាន់ណាស់ ។

ព្រះពុទ្ធបានប្រៀនប្រដៅថា អ្វីដែលមនុស្សត្រូវការសម្រាប់សេចក្ដីសុខរបស់គេ គឺមិនមែនសាសនាឬគំនរទ្រឹស្ដីទេ ប៉ុន្តែគឺសេចក្ដីយល់ដឹងអំពីធម្មជាតិ (ឬចរិត) អវកាសរបស់សាកលលោកធាតុនិងប្រតិបត្តិការទាំងមូលរបស់សាកលលោកធាតុនេះ ស្របតាមក្រឹត្យក្រមហេតុនិងផល។ បើហេតុពិតនេះ មិនត្រូវបានគេយល់ដឹងយ៉ាងពេញលេញទេ សេចក្ដីយល់ដឹងរបស់មនុស្សអំពីជីវិត និងអំពីអត្ថិភាព នឹងនៅតែមិនសុក្រិតហើយខុសឆ្គង។ "មាគ៌ាដែលព្រះពុទ្ធបានចង្អុលប្រាប់យើងតាមជំនឿរបស់ខ្ញុំ គឺជាមាគ៌ាតែមួយគត់ដែលមនុស្សជាតិត្រូវដើរតាម ប្រសិនបើគេចង់ជៀសផុតពីមហន្តរាយ" ។

**និព្វាន (និរ្វាណ)** ៖ ព្រះពុទ្ធមិនធ្លាប់បានប្រកាសថា ព្រះអង្គបានបង្កើតព្រះធម៌សោះឡើយ។ អ្វីដែលព្រះអង្គបានរកឃើញ គឺជាសច្ចៈសាកលនៃធម្មជាតិពិតនៃជីវិត។ តាមពិត ពាក្យ

សាសនាមួយចំនួន ត្រូវបានគេស្គាល់ច្បាស់លាស់រួចហើយនៅក្នុងប្រទេសឥណ្ឌានៅសម័យនោះ ។ ប៉ុន្តែ ភាពគ្មានពីររបស់ព្រះពុទ្ធគឺ ព្រះអង្គបានរើសយកទស្សនៈ ឬគំនិត មានស្រាប់ទាំងនោះមកប្រើ ហើយបានផ្តល់អត្ថន័យដ៏សុខុមបំផុត និងមានអត្ថរសយ៉ាងជ្រាលជ្រៅ ។

ឧទាហរណ៍ មុនសម័យកាលព្រះពុទ្ធពាក្យ "និព្វាណៈ ( ឬនិព្វាន )" មានន័យយ៉ាងសាមញ្ញថា សន្តិភាពឬសេចក្តីរលត់។ ប៉ុន្តែ ព្រះអង្គបានផ្តល់ឱ្យពាក្យនេះ នូវទំហំនៃអត្ថន័យថ្មីទាំងស្រុង និងមានន័យថា "គ្មាន" ហើយ វាណ មានន័យថា "ចំណង" ឬ"តណ្ហា"គឺបាន ន័យថាគ្មានតណ្ហា គ្មានឧបាទាន (សេចក្តីជាប់ជំពាក់ចិត្ត ) និងគ្មានអត្តទត្តភាព។ យើងមិនអាចសោយរសជាតិ និព្វាណៈ (និព្វាន) បាន ពីព្រោះ យើងនៅមានតណ្ហា ឧបាទាន និងអត្តទត្តភាព ។ កាលណា យើងអាចរំដោះខ្លួនផុតពីកិលេសទាំងនេះ យើងអាចពិសោធ (ឬសោយ) បរមសុខនិព្វានបាន ។ ការពិសោធ ឬការសោយបរមសុខពិត គឺជារឿងពិបាក ពីព្រោះយើងមានចិត្តវេគ (Emotions) ហើយយើងអនុះសាចង់បានសេចក្តីសោមនស្ស តាមផ្លូវវិញ្ញាណ ( កាមសុខ )។ ដរាបណា យើងរស់នៅជាប់ជំពាក់ក្នុងពិភពនៃកាមសុខ យើងនឹងមិនបានពិសោធ ( ទទួលសោយ ) សេចក្តីសុខដ៏ពិតឡើយ។ មែនហើយ វាជារឿងពិតដែលថា យើងពិសោធ (ឬទទួលសោយ) សេចក្តីសុខបែបណាមួយនៅក្នុងជីវិត ប៉ុន្តែសេចក្តីសុខនេះ មិនអាចឱ្យឈ្មោះបានថាជា "សេចក្តីសុខ" នៅក្នុងន័យដាច់ខាតនៃពាក្យនោះទេ ពីព្រោះសេចក្តីសុខនេះមិនមានចរិតអចិន្ត្រៃយ៍ ។

យើងមិនអាចទទួលបានបរមសុខដោយហេតុយើងមានទោសៈ ឬគំនុំគុំគួន អត្តទត្តភាព ឬមោហៈ នៅក្នុងខ្លួននោះទេ។ម្តងម្កាល យើងទទួលបានសេចក្តីសោមនស្សចិត្ត វេគមានកម្រិតណាមួយ ប៉ុន្តែធម្មជាតិ (ឬចរិត) នៃសេចក្តីសុខនោះ គឺដូចជាផ្លេកបន្ទោរដូច្នោះ វាអណ្តែតត្រសែត។ វាងើបឡើង មួយខណៈ ហើយលិចបាត់ទៅវិញនៅខណៈបន្ទាប់។ បរមសុខពិត គឺមិនដូចនេះទេ។ ប្រសិនបើមានបរមសុខពិត យើងមុខជាទទួលបាននូវសេចក្តីក្សេមក្សាន្ត សេចក្តីសោមនស្ស និងភាពស្ងប់ស្ងាត់។ ដូច្នេះ គោលបំណងពិតនៃជីវិតរបស់យើងគប្បីជាគោលបំណងដើម្បីធ្វើចិត្តយើងឱ្យបរិសុទ្ធចាកអន្ធការភាព ចាកមោហៈ ចាកមិច្ឆា-ទស្សនៈ ហើយរំដោះខ្លួនយើងពីសេចក្តីកង្វល់ និងសេចក្តីព្រួយបារម្ភ។ ដរាបណា យើងនៅតែចំណាយពេលរបស់យើងដោះស្រាយបញ្ហាជាប្រចាំ ពិនិត្យមើលបន្ទុកទទួលខុសត្រូវជាប្រចាំ

ចោទសំណួរជាប្រចាំថា តើអ្វីត្រូវធ្វើបន្ទាប់ទៀត នោះយើងមិនអាចមានសេចក្តីស្ងប់បាន ឡើយ ។

**ការធ្វើចិត្តឱ្យរីកចម្រើន** ៖ ដំបូន្មានរបស់ព្រះពុទ្ធ គឺថា យើងគប្បីរំដោះខ្លួន ឱ្យផុតពី សេចក្តីរាយមាយទាំងនេះ ប្រសិនបើយើងចង់សោយបរមសុខ។ ប៉ុន្តែថា ការរួចរំដោះនេះ ត្រូវ តែបានមកដោយកម្លាំងវិតខំរបស់យើងផ្ទាល់ ហើយចេញពីខាងក្នុងខ្លួនយើងផ្ទាល់។ យើង មិនអាចទទួលបានសេចក្តី សង្គ្រោះអំពីទេពតា ឬពីព្រះពុទ្ធ ឬក៏ពីទេវលោកទេ។ យើងមិនអាច បានសេចក្តីរំដោះដាច់ខាតតាមរយៈ តួអង្គខាងក្រៅទេ។ តួអង្គអច្ឆរិយៈមិនអាចជួយយើងឱ្យ បានបញ្ញា និងវិមុត្តិចុងក្រោយ (សេរីភាពទាំងស្រុង) បានទេ បើទោះណាជាយើងខំគោរពបូជា តួអង្គទាំងឡាយនោះ ឬអង្វរករបន់ស្រន់តួអង្គទាំងនោះ តាមរយៈតបកម្ម អាគម មន្ត្រ: របៀន គាថា និងការសំបូងសង្រូងព្រមទាំងពលីការថ្វាយសត្វជាតុក៏ដោយ។

"យើងបច្ចុប្បន្ន គឺជាលទ្ធផលនៃអ្វីដែលយើងបានកសាងពីអតីតៈ ហើយយើង អនាគតនឹងជា លទ្ធផលនៃអ្វីដែលយើងកំពុងកសាង"។ អំពើទាំងឡាយ គាក់តែងសេចក្តី សោមនស្សឬសេចក្តីទោមនស្សរបស់យើង ហើយនៅទីបញ្ចប់ជានាវាប់វេងការសង្គ្រោះ របស់ យើង។ ការសង្គ្រោះ ឬការរំដោះ គឺជាកិច្ចការរបស់បុគ្គលម្នាក់ៗបីដូចជាមនុស្សម្នាក់ៗត្រូវស៊ី ផឹក និងទំពាអាហារ ហើយដេកសម្រាប់ខ្លួនឯងផ្ទាល់។ អំពើជាកម្មទាំងអស់ ត្រូវបានបិតថេរ នៅជាផ្នែកនៃសង្ខារ (Mental formation) របស់យើង ហើយបិតកប់នៅក្នុងទីនោះ។ យើងបាន ភ្លេចនូវអំពើទាំងឡាយក្នុងអតីតកាល ពីព្រោះសកម្មភាពចេតសិក (ឬផ្លូវចិត្ត) បាំងបិទចិត្ត ដោយហេតុនោះ ចិត្តមិនអាចរំលឹកឃើញអំពើទាំងឡាយក្នុងអតីតកាលបានទេ។ កាលណា យើងធ្វើចិត្តរបស់យើងរីកចម្រើនតាមរយៈភាវនា យើងទប់ស្កាត់បានអារម្មណ៍រាយមាយ ដែលវិញ្ញាណទាំងប្រាំបានបង្កើតឡើង។ កាលណាចិត្តជ្រះស្រឡះ ហើយវាបន្ថយបាននូវ សេចក្តីកន្ទល់តណ្ហា (ចំណង់ចង់បានខ្លាំង) សេចក្តីក្រោធ-ច្រណែន-ឈ្នានីស និង សេចក្តី វង្វេង (មោហៈ)។ ចិត្តដែលជ្រះស្រឡះល្អហើយ បានប្រែក្លាយទៅជាមានថាមពល ហើយ រវៀសក្វាក់រលឹក។ ធាតុក្លូតនេះ កើតបានកាលណា យើងអាចជះឥទ្ធិពលទៅលើសកម្មភាព ផ្លូវចិត្ត ហើយរំដោះអំណាចបង្កប់ដ៏ធំធេងនេះបាន។ នេះគឺជាមនោមយិទ្ធិ (ឬអំណាចផ្លូវចិត្ត)។ អំណាចនេះ មាននៅក្នុងខ្លួនយើងទាំងអស់គ្នាយើងគ្រាន់តែចេះរំដោះវាតាមរយៈភាវនា។ វិធី មួយបែបទៀត ដើម្បីទៅដល់សកម្មភាពផ្លូវចិត្តបង្កប់ គឺវិធីសណ្តំ (វសីករណវិជ្ជា) ។តាមរយៈ

វិធីសណ្ដំ មនុស្សខ្លះបានអភិវឌ្ឍអំណាចផ្លូវចិត្តបានមួយកម្រិត ប៉ុន្តែគេមិន ណែនាំ ឱ្យប្រព្រឹត្ត វិធីនេះទេ ពីព្រោះវិជ្ជាសណ្ដំពឹងផ្អែកលើភ្នាក់ងារឬតួអង្គផ្សេងមួយទៀត ហើយ មិនមាន ប្រសិទ្ធភាពធ្វើចិត្តឱ្យបរិសុទ្ធស្អាតបានទេ។

ព្រះពុទ្ធបានទូន្មានសាវ័កទាំងឡាយរបស់ព្រះអង្គឱ្យបណ្ដុះ និងអភិវឌ្ឍអំណាចបង្កប់ នៅក្នុងតួអង្គសាវ័កទាំងនោះ ហើយទ្រង់បានបង្ហាញប្រាប់សាវ័កទាំងឡាយនោះឱ្យចេះប្រើបាន ល្អប្រសើរនូវចិត្តពល (Will power) និងញាណសត្តិ (intelligence) របស់ខ្លួនដោយមិនត្រូវ ដាក់ខ្លួនធ្វើជាទាសាទាសី ចំពោះតួអង្គមិនស្គាល់គ្មានរូបរាងណាមួយដើម្បីរកបានសេចក្ដីសុខ ឋិតថេរនោះឡើយ។ ដោយមិនបានស្ដីបន្ទោស នរណាម្នាក់ឡើយ ពុទ្ធសាសនាបានប្រៀន ប្រដៅថា មនុស្សជាអ្នកទទួលខុសត្រូវចំពោះអំពើផ្ទាល់របស់ខ្លួន។ មនុស្សគប្បីប្រឈមមុខ ចំពោះហេតុពិតនៃជីវិត ហើយត្រូវកែតុនលើស្នាទូវការកិច្ច ទទួលខុសត្រូវនៃជីវិតដោយត្រូវ បំពេញករណីយកិច្ច និងកាតព្វកិច្ចរបស់ខ្លួនចំពោះខ្លួនឯង និងចំពោះអ្នកដទៃ។ សេចក្ដីឈឺ ចាប់ និងសេចក្ដីសប្បាយរបស់ខ្លួន គឺខ្លួនឯងបានបង្កើតឡើង ហើយខ្លួនឯងមានសមត្ថភាព កម្ចាត់ទុក្ខសោករបស់ខ្លួន ហើយទ្រទ្រង់រក្សាសន្តិភាពនិងសុភមង្គលតាមរយៈ សេចក្ដីយល់ ដឹងនូវចំណុចខ្សោយរបស់ខ្លួនហើយប្រើសេចក្ដីព្យាយាមរបស់ខ្លួនផ្ទាល់ ដើម្បីជំនះចំណុច ខ្សោយទាំងនោះ។ ចិត្តគ្មានការហ្វឹកហាត់ របស់មនុស្សត្រូវទទួលខុសត្រូវចំពោះភាពច្របូក ច្របល់ វិបត្តិភ័យ សេចក្ដីកង្វល់ ឧបទ្រពចង្រៃគ្រប់បែប ហើយរហូតដល់ការ ប្រែប្រួលធាតុ និងរូបធាតុទាំងឡាយផង។ ផ្ទុយទៅវិញចិត្តរបស់មនុស្ស អាចផ្លាស់ប្ដូរស្ថានភាពដ៏អកុសល ទាំងឡាយក្នុងពិភពលោកបាន ហើយអាចធ្វើឱ្យពិភពលោកនេះក្លាយជាទីកន្លែងមួយមានសុខ សន្តិភាពចម្រុងចម្រើន និងសម្បូរសប្បាយសម្រាប់មនុស្ស សត្វទាំងអស់រស់នៅ។ នេះអាច សម្រេចបានតែតាមរយៈបរិសុទ្ធកម្មនៃថាមពលផ្លូវចិត្ត (គឺការធ្វើចិត្តឱ្យបរិសុទ្ធមានថាមពល ) ប៉ុណ្ណោះ ។

***វិធីរបស់ព្រះពុទ្ធ*** ៖ បច្ចេកទេសបង្រៀនរបស់ព្រះពុទ្ធ មានលក្ខណៈផ្សេងពីវិធីបង្រៀន របស់មេសាសនាដទៃ។ ព្រះអង្គមិនដែលបានត្រៀមទុកមុននូវ "សង្កថា សាធារណៈ" ឬ "ធម៌ ទេសនា" មួងណាឡើយ។ ព្រះអង្គបានសម្រេចព្រះទ័យ ជានិច្ចចាប់យកប្រធានបទណាមួយ ដែលអាស្រ័យលើព្រឹត្តិការណ៍ ឬការសង្កេតឃើញភ្លាមៗ។ សញ្ញាមួយក្នុងបណ្ដាសញ្ញានៃ ពុទ្ធិដ៏ពិសិដ្ឋរបស់ព្រះពុទ្ធ ហើយនិងជំនាញរបស់ព្រះអង្គក្នុងឋានៈជាសាស្ត្រាចារ្យមួយរូប គឺ

ការអនុវត្តគុណកោសល្យដ៏ឈ្លាសវៃបំផុត ផ្ដើមពីអ្វីដែល "ស្គាល់ទៅមិនស្គាល់"។ ជាឧទាហរណ៍ នៅឱកាសមួយនាពេលព្រះអង្គ និងសាវ័ក របស់ព្រះអង្គកំពុងយាង និងនិមន្តតាមឆ្នេរទន្លេ មួយព្រះអង្គបានទតឃើញកំណាត់ឈើមួយដុំ កំពុងអណ្ដែតតាមចរន្តទឹកហូរ។ ព្រះអង្គបានឈប់ហើយទ្រង់សួរថា "តើអ្នកទាំងឡាយយល់ដូចម្ដេចចំពោះកំណាត់ឈើនោះ? សាវ័កមួយអង្គបានក្រាបទូលថា ៖ "កំណាត់ឈើនោះអាចទើរនៅលើកោះណាមួយក្នុងកណ្ដាលទន្លេ" ។ សាវ័កទាំងឡាយដទៃទៀត បានទូលតបថា "កំណាត់ឈើអាច ជោកជាំទឹក ហើយលិចបាត់ទៅ" "មនុស្សនឹងរើសកំណាត់ឈើនោះ ហើយពុះវាធ្វើជាអុស" ហើយ "កំណាត់ឈើនោះនឹងបញ្ចប់ដំណើររបស់វា ទៅដល់សមុទ្រ"។ ឥឡូវនេះតើសាវ័កណាឆ្លើយត្រឹមត្រូវ? សាវ័កណាអាចទស្សន៍ទាយវាសនានៃកំណាត់ឈើបាន? បន្ទាប់មក ព្រះពុទ្ធបានពន្យល់ថា ជីវិតរបស់យើង គឺដូចជាកំណាត់ឈើអណ្ដែតតាមខ្សែទឹកហូរអញ្ចឹង ពោរពេញដោយភាពមិនទៀងទាត់។ គ្មាននរណាអាចនិយាយបានថា នឹងមានអ្វីកើតមានឡើងដល់យើងនៅថ្ងៃបន្ទាប់ ឬនៅខែក្រោយបានទេ។ វិធីរបស់ព្រះពុទ្ធ គឺចាប់យកមេរៀនទាំងឡាយអំពីជីវភាពរាល់ថ្ងៃ ដើម្បីធ្វើឱ្យពាក្យប្រៀនប្រដៅរបស់ព្រះអង្គចាក់ឫសជាប់ជានិច្ច នៅក្នុងជីវិតរាល់ថ្ងៃនេះ ហើយទាក់ទងទាំងស្រុងទៅនឹងបទពិសោធន៍របស់មនុស្ស។

ក្នុងបែបបទនេះ ព្រះអង្គបានផ្ដល់ជំនឿសមស្របដល់មនុស្ស ដើម្បីត្រិះរិះដោយសេរី ដោយប្រើ បាកតិនិច្ឆ័យ (Common sense) របស់គេ។ ព្រះអង្គមិនបានបញ្ចូលសាសនាណាមួយ ដើម្បីឱ្យគេគោរពប្រតិបត្តិដោយងងឹតងងុល ដោយសារសេចក្ដីភ័យខ្លាចនិងដោយចំណង់ចង់បានលោកសក្ការៈលោកិយណាមួយទេ។

យោងតាមព្រះពុទ្ធឱវាទ គំនិត និងពាក្យដ៏ល្អមួយដែលមិនបង្កើតបានអំពើសមស្របទេ គឺប្រៀបដូចជាផ្កាមានពណ៌ឆើតដែលគ្មានក្លិន និងគ្មានផ្លែដូច្នោះ។ មាគ៌ាប្រាំបីយ៉ាង ដែលព្រះអង្គបានប្រៀនប្រដៅ គឺជាមេរៀនមួយមានផែនការបណ្ដុះបណ្ដាលល្អ និងធ្វើឱ្យរីកចម្រើនឱ្យដ៏ផ្ដែផ្កួង។ ដោយគ្រាន់តែពឹងពាក់ការគោរពបូជា ពិធីបុណ្យទាន និងការសូត្រធម៌យ៉ាងសាមញ្ញ គេមិនអាចធ្វើឱ្យមានវឌ្ឍនភាពក្នុងព្រះធម៌ និងក្នុងការអភិវឌ្ឍផ្ទៃក្នុងបានឡើយ។ ព្រះពុទ្ធមានព្រះបន្ទូលថា ៖ " ការសូត្រធម៌ដ៏សាមញ្ញ អង្វរករសុំសេចក្ដីអនុគ្រោះ គឺប្រៀបដូចគេសុំប្រាំងទន្លេឯនាយឱ្យរំកិលមកជិត ដើម្បីគេអាចឆ្លងទៅកាន់ត្រើយម្ខាងទៀត ដោយគ្មានកម្លាំងរិតវំផ្លាស់ខ្លួនដូច្នោះ " ។

**ការរកឃើញដោយខ្លួនឯង** ៖ សាសនាជាច្រើនតែងប្រកាសថា សារឬពាក្យប្រៀនប្រដៅទាំងឡាយត្រូវ បានអាទិទេពប្រកាសប្រាប់ដល់មនុស្សជាតិ។ ប៉ុន្តែមានពួកហេតុវាទី (Rationalists) ខ្លះ បានសួរថា ប្រសិនបើមាន អាទិទេពតែមួយអង្គប៉ុណ្ណោះហើយលោកបានប្រទានសារ ឬពាក្យប្រៀនប្រដៅរបស់លោកសម្រាប់ជាអត្ថប្រយោជន៍ដល់មនុស្សជាតិទាំងអស់ តើព្រោះហេតុអ្វីទើបមានជំនឿខុសៗគ្នាច្រើនម៉្លេះ នៅក្នុងពិភពលោក? ប្រសិនបើសារ ឬពាក្យប្រៀនប្រដៅប្រកាសឡើងសម្រាប់មនុស្សជាតិទាំងមូល តើវាមានការលំបាកអ្វីសម្រាប់អាទិទេព ដើម្បីប្រកាសផ្សាយសារ ឬពាក្យប្រៀនប្រដៅរបស់លោកជាសាធារណៈ ដើម្បីកុំឱ្យមានសេចក្ដីសង្ស័យ ឬការបកស្រាយខុស? មនុស្សគ្រប់រូបមុខតែទទួលយកសារ ឬពាក្យប្រៀនប្រដៅនោះ ហើយវានឹងមិនមានការប៉ះទង្គិច (សង្គ្រាម) ខាងសាសនា ហើយពិភពលោកទាំងមូលអាចគ្រាន់តែប្រតិបត្តិតាមសារតែមួយរបស់អាទិទេព ជាការឯករាជ្យស្រេច។

ជាច្រើនឆ្នាំកន្លងទៅហើយ មានសិក្ខាសាលាសាសនាមួយត្រូវបានគេរៀបចំឡើងនៅឯសាកលវិទ្យាល័យម៉ាឡាយ៉ា (ប្រទេសម៉ាឡេស៊ី)។ មានវាគ្មិនប្រាំរូប វាគ្មិនមួយរូបៗ មកពីសាសនានីមួយៗ។ ក្រោយពេលវាគ្មិនទាំងនោះ បាននិយាយរួច មាននិស្សិតម្នាក់បានសួរថា ៖ “កាលណាយើងខ្ញុំសិក្សាសាសនារបស់យើងខ្ញុំ យើងខ្ញុំទទួលបានព័ត៌មានខ្លះៗអំពីពិភពលោកនេះ ហើយនិងសាកលលោកជាតុ ព្រមទាំងជីវិត ។ កាលណាយើងខ្ញុំសិក្សាវិទ្យាសាស្ត្រ យើងខ្ញុំទទួលបានព័ត៌មានផ្សេងពីគ្នាទាំងស្រុង។ ព័ត៌មាននេះបដិបក្ខទៅនឹងទស្សនៈសាសនារបស់យើងខ្ញុំ។ ដូច្នេះ ខ្ញុំមិនដឹងថាតើត្រូវទទួលពាក្យប្រៀនប្រដៅរបស់សាសនាខ្ញុំ ឬការប្រៀនប្រដៅរបស់វិទ្យាសាស្ត្រ”[២៨]។

វាគ្មិនម្នាក់ ក្នុងបណ្ដាវាគ្មិនទាំងនោះបានឆ្លើយតបថា: “នៃខ្ញុំជឿថា អាទិទេពបានប្រទានលទ្ធិរបស់លោកក្នុងទម្រង់ជាសារមួយទៅឱ្យមនុស្សម្នាក់ដែលបានផ្សព្វផ្សាយសារនោះបន្តមកទៅដល់មនុស្សដទៃទៀត ដូច្នេះ យើងត្រូវជឿបទួល (សារ) របស់អាទិទេព” ។

ប៉ុន្តែនិស្សិតនោះនៅតែទទូចសួរទៀតថា ៖ “តើលោកដឹងយ៉ាងដូចម្ដេចកើត ថាមនុស្សទាំងឡាយ ដែលសារនោះត្រូវបានប្រាប់ទៅនោះ បានយល់សារនោះត្រឹមត្រូវឬទេ? តើសារនោះអាចត្រូវបាន គេបន្លុសពីច្បាប់ដើម ហើយបកស្រាយខុសទៅតាមចិត្តគំនិតរបស់គេ ហើយបន្ទាប់មកទៀតបន្តទៅឱ្យបច្ឆាជនតាជនឬទេ?”

[២៨] បណ្ឌិតសភាចារ្យ ខ្ចួត ធីតា ៖ មូលដ្ឋានគ្រឹះនៃសីលវិទ្យាសាកលលោក ឆ្នាំ២០០៩ ទំព័រ ១៩០-១៩៥

ចំណែកព្រះពុទ្ធវិញ ព្រះអង្គមិនដែលប្រកាសអះអាងអ្វីមួយដូចជាការទទួលយកពុទ្ធិ (ចំណេះដឹង) អំពីប្រភពខាងក្រៅម្ដងណាទេ។ ក្នុងអំឡុងពេលព្រះអង្គដឹកនាំ ព្រះអង្គតែងបានបញ្ជាក់ប្រាប់ជានិច្ចថា សាវ័ទជន របស់ព្រះអង្គមានសេរីភាព ចោទសួរព្រះអង្គ និងមានសេរីភាពបញ្ចេញយោបល់ប្រឆាំង ពាក្យប្រៀនប្រដៅរបស់ព្រះអង្គដើម្បីឱ្យសាវ័ជនទាំងឡាយនោះ អាចបានដឹងច្បាស់ដោយផ្ទាល់នូវសច្ចធម៌។ ព្រះអង្គមានបន្ទូលថា "ចូរមកហើយមើល" (ឯហិបស្សិកោ) ។ ព្រះអង្គ មិនបានមានបន្ទូលថា "ចូរមក ហើយជឿ" នោះទេ ។

ពេលណាព្រះអង្គមានបន្ទូលពីអ្វីមួយនោះ ក៏ព្រោះតែព្រះអង្គបានសាកល្បង ពិសោធរួចហើយ ដោយផ្ទាល់ព្រះអង្គឯង នូវសុពលភាពនៃបន្ទូលនោះចំពោះ ព្រះអង្គផ្ទាល់ ក្នុងឋានៈជាតួអង្គមនុស្សធម្មតាមួយរូប។ ព្រះអង្គមិនបានប្រកាស ទាមទារទេវភាពណាមួយទេ ។ ព្រះអង្គបានឈ្វេងយល់អ្វីៗទាំងអស់ ពីព្រោះព្រះអង្គបានស្គាល់រស់ជាតិនៃអ្វីៗទាំងអស់នោះយ៉ាងណានោះហើយ ដោយព្រះអង្គ បានរងទុក្ខ ក្នុងអំឡុងជាតិពីមុនៗដ៏ច្រើន ដោយសារ តែអំពើអាក្រក់ដែលព្រះអង្គបានប្រព្រឹត្តព្រោះតែអវិជ្ជា។ ព្រះអង្គបានស្គាល់មាគ៌ាដ៏លំបាកនេះ។ ព្រះអង្គបានទូន្មាន អ្នកជឿតាមព្រះអង្គ តាមរយៈបទពិសោធន៍ផ្ទាល់របស់ព្រះអង្គ។ ព្រះអង្គបានបំពេញ សេវកិច្ចដ៏ធំធេងចំពោះមនុស្សជាតិ ដោយការប្រតិបត្តិនិងការប្រព្រឹត្តបំពេញមហាបារមី អស់ជាតិជាអសង្ខេយ្យ ហើយនៅទីអវសាន ព្រះអង្គបានសម្រេចសោយព្រះបរមសុខដ៏ឧត្តុង្គឧត្តម។ យើងត្រូវចោទសួរខ្លួនយើង ថាតើណាមួយគួរទុកចិត្តជាតិ កស្តុតាងរបស់មនុស្សម្នាក់ ដែលនិយាយចេញពីបទពិសោធន៍ផ្ទាល់ខ្លួន ឬភស្តុតាងរបស់មនុស្សម្នាក់ដែលប្រកាសថា បានឮបទ ពិសោធន៍នេះ អំពីអ្នកណាម្នាក់ផ្សេងដែលមើលមិន ឃើញសោះនុ៎ះ ?

**សេរីភាពខាងការគិត** ៖ ដំបូន្មានរបស់ព្រះពុទ្ធ គឺមិនឱ្យពឹងផ្អែកលើទ្រឹស្ដីលើធម្មការ និងគ្រូទេ។តាមពិតនៅគ្រប់ពេលទាំងអស់យើងត្រូវឋិតនៅជាម្ចាស់លើខ្លួនយើង តាមរយៈទំនុកចិត្តលើខ្លួនឯង។ យើងមិនត្រូវបន្ទាបសេចក្ដីថ្លៃថ្នូរ ឬសកមតិ (freewill) របស់យើងឡើយ។ ព្រះពុទ្ធបានគ្រាំទ្រយ៉ាងខ្លាំងក្លានូវលទ្ធិនៃជំនឿលើខ្លួនឯង សេចក្ដីបរិសុទ្ធ សេចក្ដីគោរព សាម្មោធិ សន្តិភាព និង សេចក្ដីស្រឡាញ់ជាសកល។ ព្រះអង្គបានសង្កត់លើសេចក្ដីត្រូវការដើម្បីយល់ដឹង ពីព្រោះថា បើគ្មានសេចក្ដីយល់ដឹងទេ អជ្ឈត្តិកញាណនាំទៅកាន់បញ្ញាមិនអាចកើតមានបានទេ។ ព្រះអង្គមានបន្ទូលថា "ប្រសិនបើអ្នកចង់ឃើញការបញ្ចប់ទុក្ខសោកនិងសេចក្ដីភ័យខ្លាចរបស់អ្នក ចូរអ្នកអភិវឌ្ឍន៍វិន័យសេចក្ដីអាណិតអាសូរ (ករុណា)

និងបញ្ញា” ។ យើងត្រូវធ្វើឱ្យចិត្តរបស់យើងមានសេរីភាពដើម្បីគិត និង ដើម្បីយល់ដឹងជានិច្ច ដោយមិនពឹងផ្អែកលើឥទ្ធិពលខាងក្រៅ ។ អ្នកទាំងឡាយដែលពឹងផ្អែកអ្នកដទៃ គឺប្រៀបដូចជាកូនក្មេងបៀមដៃ។ យើងត្រូវដើរតាមគំរូព្រះពុទ្ធដែលមានបន្ទូលថា កាលព្រះអង្គធ្វើវិបស្សនាដើម្បីបានសម្រេចសម្ពោធិញ្ញាណ គ្មានអាទិទេពណាមួយចុះមកឱ្យបដាក់ព្រះកាណ៌ព្រះអង្គ បង្ហាញប្រាប់អាថ៌កំបាំងនៃអំណាចខាងស្មារតីទេ។ គ្មានអាទិទេពណាមួយ បានផ្ដល់ដល់ព្រះអង្គនូវសិក្ខាបទ ឬច្បាប់សាសនា ដើម្បីឱ្យព្រះអង្គផ្សព្វផ្សាយទេ។ ព្រះអង្គបានមានបន្ទូលថា “តថាគតមិនដែលមានគ្រូ ឬអាទិទេព (ទេវតា) ណាមកបង្រៀនតថាគត ឬប្រាប់តថាគតឱ្យសម្រេចបានសម្ពោធិញ្ញាណយ៉ាងណាៗនោះទេ។ អ្វីៗដែលតថាគត សម្រេចបានតថាគតបានធ្វើដោយសារមានសេចក្ដីឧស្សាហ៍សេចក្ដីព្យាយាមពុទ្ធិ (ចំណេះដឹង) និងបរិសុទ្ធិភាព ដើម្បីសម្រេចបានបញ្ញាបារមី” ។

ព្រោះហេតុនោះហើយ ទើបព្រះអង្គមានបន្ទូលថា បញ្ញាបានកើតមានឡើងក្នុងព្រះអង្គនៅ ពេលព្រះអង្គបានសម្រេចសម្ពោធិញាណ។ បញ្ញា គឺជាធម្មជាតិមាននៅខ្លួដ៏ផ្ទៃក្នុងនៃយើងទាំងអស់គ្នា។ យើងត្រូវការចាំបាច់ផ្ដល់លក្ខខណ្ឌត្រឹមត្រូវសម្រាប់ឱ្យបញ្ញាងើបឡើងបានប៉ុណ្ណោះ ។

ចេញពីខ្លឹមសារពុទ្ធិ និងទស្សនវិជ្ជារបស់ពុទ្ធសាសនានេះទៅ សេរីភាពខាងការគិត សេរីភាពខាងវិមង្សា (inquiry) ក៏បានកើតឡើង។ ចរិតនេះ គ្មានគូប្រៀបប្រដូចនៅក្នុងសាសនាណាមួយក្នុងបណ្ដាសាសនាទាំងឡាយដែលមានឡើងក្នុងពិភពលោកនេះទេ។ គ្មានជាប់កាតព្វកិច្ច គ្មានការដាក់កំហិតណាមួយដើម្បីឱ្យគេជឿ ឬឱ្យគេទទួលយកលទ្ធិណាមួយទេ ។

វិធី(approach) របស់ពុទ្ធសាសនាគឺវិធីឃើញ និងយល់ដឹងដ៏ជាឥរិយាបថវិទ្យាសាស្ត្រស្ដីពីចិត្ត ។ លទ្ធិជាគ្រឹះនៃទស្សនវិជ្ជាបង្រៀន នៅក្នុងពុទ្ធសាសនា គឺកាន់តែត្រូវបានបញ្ជាក់ឱ្យឃើញត្រឹមត្រូវថែមទៀត ដោយការរកឃើញថ្មីៗរបស់វិទ្យាសាស្ត្រ។ ពុទ្ធសាសនាគាំទ្រឱ្យមានជំនឿលើខ្លួនឯង ឱ្យមានការគ្រប់គ្រងលើខ្លួនឯង ឱ្យមានទំនុកចិត្តលើខ្លួនឯង និងឱ្យមានស្វ័យបរិសុទ្ធិកម្មសម្រាប់បុគ្គលម្នាក់ៗក្នុងសង្គម ។

ទស្សនៈដ៏រឹងមាំមួយរបស់ពុទ្ធសាសនាគឺ សារសំខាន់ដែលពុទ្ធសាសនាបានភ្ជាប់ខ្លួនទៅនឹងឧត្ដមគតិប្រជាធិបតេយ្យ។ ការពិភាក្សាដោយគ្មានការបង្អក់បង្អាក់ត្រូវបានគេលើកទឹក

ចិត្តឱ្យមាន សូម្បីទីណាមានទស្សនៈផ្ទុយគ្នាកើតមានក៏ដោយ។ ទស្សនៈផ្ទុយគ្នាបាននាំទៅដល់ការធ្វើចិត្តឱ្យទូលំទូលាយនិងសម្បូរបែប។ គណៈ ភិក្ខុ និងភិក្ខុនីសង្ឃ ត្រូវបានកសាងឡើង លើគោលការណ៍ប្រជាធិបតេយ្យនេះទាំងស្រុង។

ទស្សនៈនេះ សមស្របជាមួយព្រះធម៌ ដែលព្រះពុទ្ធទ្រង់បានសម្តែង។ ព្រះអង្គមានព្រះទ័យបើកចំហ និងមានសេចក្តីអង់អាចជំរុញសាវ័កទាំងឡាយរបស់ព្រះអង្គមិនឱ្យទទួលជឿអ្វីដោយមិនបានពិនិត្យពិចារណាជាមុន និងដោយគ្មានជំនឿច្បាស់លាស់ សូម្បីតែអ្វីដែលព្រះអង្គឯងផ្ទាល់បានទេសនាប្រាប់ក៏ដោយ។ តាមពិតព្រះពុទ្ធបានសម្តែងថា ព្រះធម៌គឺជាគ្រូរបស់ព្រះអង្គ ហើយអ្វីៗទាំងអស់ដែល ព្រះអង្គបានធ្វើ គឺដើម្បីបើកកកាយឱ្យឃើញសច្ចភាពនៃព្រះធម៌ជាសាកលនេះ ដែលបានឋិតនៅយ៉ាងអាថ៌កំបាំងអំពីមនុស្សដែលកំពុងជាប់លិចលង់ក្នុងអវិជ្ជារបស់គេ។ យើងត្រូវផ្តល់ឱ្យសម្បជញ្ញៈរបស់យើងនូវសេរីភាពដើម្បីគិតត្រិះរិះដោយឥតលំអៀង និងដើម្បីគិតត្រិះរិះដោយឯករាជ្យ។

កាលណាយើងនិយាយពាក្យនេះ យើងមិនសំដៅន័យថា យើងពឹងផ្អែកលើព្រះពុទ្ធទេ។ មានន័យថា បើយើងប្រតិបត្តិតាមវិធីដែលព្រះពុទ្ធបានប្រៀនប្រដៅនោះ យើងត្រូវអភិវឌ្ឍទំនុកចិត្តដើម្បីគិត គួរធ្វើការសង្គ្រោះខ្លួនរបស់យើងដោយខ្លួនយើងផ្ទាល់។ ប្រាកដណាស់ យើងមិនបានគិតថា ព្រះពុទ្ធនឹងយាងមកថ្ងៃណាមួយហើយនាំយើងទៅកាន់ "ឋានសួគ៌" ក្នុងដំណើរហោះឡើងដ៏រុងរោចន៍នោះទេ ។

មនុស្សខ្លះនិយាយថា ព្រះពុទ្ធគឺគ្រាន់តែជាមនុស្សម្នាក់ប៉ុណ្ណោះ ហើយមិនមែនជា អាទិទេពទេ ។ ព្រោះហេតុអ្វីមនុស្សត្រូវដើរតាមលោក ? មនុស្សទាំងនោះមិនអាចយល់បានថា ពុទ្ធសាសនិកជនមិន សង្ឃឹមរង់ចាំការសង្គ្រោះរបស់គេដោយផ្ទាល់អំពីព្រះពុទ្ធទេ ប៉ុន្តែដោយការប្រតិបត្តិតាមវិធីដ៏ប្រសើរ ដែលព្រះអង្គបានប្រៀនប្រដៅ។ វិធីរបស់ព្រះពុទ្ធតាំងតែពីដើមទីម៉្លេះ គឺដើម្បីហ្វឹកហ្វឺនយើង ថាតើត្រូវប្រព្រឹត្តយ៉ាងណាសម្រាប់ការអភិវឌ្ឍទំនុកចិត្តខ្លួនឯងតាមរយៈការហ្វឹកហ្វឺន វិចារណសត្តិរបស់យើង។ សេចក្តីព្យាយាមដោយខ្លួនឯង និងសេចក្តីយល់ដឹងដោយខ្លួនឯង គឺជាមាគ៌ាតែមួយគត់នាំទៅដល់ការសង្គ្រោះ ។

អ្នកណាក៏ដោយ អាចឈរត្រង់ខ្លួននៅពីខាងមុខព្រះពុទ្ធ ដោយសេចក្តីថ្លៃថ្នូរ ហើយមិនមែន ដូចជា ទាសកររទេ ។ ដោយមានសេចក្តីសង្ឃឹម និងសេចក្តីទុកចិត្ត គេអាចធ្វើសេចក្តីសម្រេចចិត្តលើជោគវាសនាផ្ទាល់ខ្លួនរបស់គេ ។ ព្រះពុទ្ធនឹងទទួលស្វាគមន៍អ្នក ប្រសិនបើ

អ្នកឈរត្រង់ខ្លួន ក្នុងឋានៈជាមនុស្ស មានសេចក្តីថ្លៃថ្នូរម្នាក់ៗ ប៉ុន្តែអ្នកត្រូវត្រៀមខ្លួនធ្វើជាមនុស្សប្រកបដោយវិចារណញ្ញាណ ហើយស្តាប់ទន្ទឹករណ៍ហេតុផល ដែលផ្ទុយទៅនឹងជំនឿរបស់អ្នក ហើយដែលមានសេចក្តីពិនិត្យសង្កេតត្រឹមត្រូវៗ នេះគឺជាឥរិយាបថរបស់មនុស្សដែលមានសេចក្តីយល់ដឹងៗ នៅពេលព្រះពុទ្ធអង្គរៀបតែនឹងចូលបរិនិព្វានមានមនុស្សសំខាន់ៗជាច្រើនរូបដូចជាព្រះអង្គម្ចាស់វដ្ដមន្ត្រីជាដើម ហើយសូម្បីតែពពួកទេពតាក៏គង់ចុះមកសម្តែងសេចក្តីគោរពចំពោះព្រះអង្គដោយបាចផ្កា ប៉ុន្តែព្រះពុទ្ធបានផ្តាំអានន្ទជាអ្នកបម្រើព្រះអង្គឱ្យប្រាប់មនុស្សទេពតា ទាំងឡាយនោះថា ប្រសិនបើនរណាម្នាក់ចង់ផ្តល់កិត្តិយស ចំពោះគ្រូរបស់គេ គេត្រូវប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់លោកៗ នេះបង្ហាញឱ្យឃើញថា ព្រះអង្គមិនប្រថ្នាចង់បានសេចក្តីថ្កុំថ្កើងផ្ទាល់ សម្រាប់ព្រះអង្គឯងឬទាមទារឱ្យមានការចុះញ៉មទាំងស្រុង ក្រោមអានុភាពរបស់ ព្រះអង្គឡើយៗ

**អនាគតិ (ភាពឥតលំអៀង)** ៖ ក្រោយពេលបានដឹងច្បាស់សច្ចធម៌ មនុស្សដែលមានសេចក្តីយល់ដឹងបានខិតខំបណ្តុះបណ្តាលវិចារណសត្តិរបស់គេ ដើម្បីរក្សានិងការពារខ្លួនផ្ទាល់ៗ មនុស្សទាំងនោះមិនទទួល ឬមិនបដិសេធអ្វីដែលនរណាម្នាក់បាននិយាយទេៗ លោកក្រីស្ណាមូរ្តិ (Krinshnamurti) និយាយថា អ្នកទាំងឡាយដែលពឹងផ្អែកជានិច្ចលើគំនិតរបស់មនុស្សដទៃ គឺជាមនុស្សថ្នាក់ទីពីរៗ ចូរកុំទទួល ឬជឿអ្វីមួយដែលគេប្រៀនប្រដៅទុកជាការប្រតិបត្តិសាសនា ហើយនៅពេលជំណាលគ្នានេះ ចូរកុំបដិសេធពាក្យប្រៀនប្រដៅនោះភ្លាមៗឡើយៗ រឿងមួយចំនួន ដែលយើងទទួលយកថាជារឿងពិត យើងអាចរកឃើញ ក្រោយមកថា ជារឿងមិនពិតទាល់តែសោះ ៗផ្ទុយទៅវិញ យើងអាចត្រូវគេបន្ទំឱ្យទទួលជឿថា រឿងមួយចំនួន ដែលយើងបានបដិសេធកាលពីដំបូង អាចជារឿងពិតទៅវិញៗ ព្រោះហេតុនោះហើយទើបព្រះពុទ្ធបានទូន្មានយើងឱ្យរង់ចាំបន្តិចសិនហើយសិក្សាត្រិះរិះ សង្កេត អង្កេត ស្រាវជ្រាវមុនយើងសម្រេចថាតើ វាមានសេចក្តីពិតអ្វីខ្លះទេ នៅក្នុងរឿងមួយចំនួនដែលយើងបានឮហើយថាតើគួរទទួលយក ឬគួរបដិសេធរឿងនោះៗ ដោយការទុកចិត្តលើចិត្តវេគ (emotions) ឬសន្ទានដឹតនង្គល ឬក៏សេចក្តីបារម្ភរបស់យើង យើងអាចនឹងទទួលជឿរឿងខ្លះ ឬក៏អាចនឹងមានសេចក្តីសង្ស័យៗ ជាលទ្ធផលនៃភាពស្ពឹកស្រពន់ ឬភាពច្របូកច្របល់នៃចិត្ត យើងអាចនឹងបដិសេធឬមិនជឿអ្វីដែលយើងឮៗ ប៉ុន្តែ យើងត្រូវតែផ្តល់ឱកាសមួយឱ្យចិត្តដើម្បីត្រិះរិះនិងស្វែងយល់ថាតើរឿងនោះពិតឬមិនពិត ៗ

សទ្ធា ៖ សទ្ធាសុទ្ធសាធគ្មានន័យអ្វីទេ ពីព្រោះ សទ្ធាត្រូវតែប្រកបដោយសេចក្ដីយល់ដឹងដែលកើតចេញមកពីការហ្វឹកហ្វឺនចិត្ត។ គោលបំណងចម្បងរបស់សាសនា ត្រូវតែជាគោលបំណងដើម្បីបង្ហាញដល់អ្នកប្រតិបត្តិតាម ថាតើត្រូវប្រើចំណេះដឹងរបស់គេប្រកបដោយសេចក្ដីយល់ដឹងជ្រៅជ្រះយ៉ាងណា ដើម្បីពង្រីកជាអតិបរមានូវអធ្យាស្រ័យរបស់គេអំពីសុខុមាលភាព និងសេចក្ដីពេញចិត្តខ្លួនឯង។ មិនមានបញ្ហាអ្វីទេ ថាតើយើងមានចំណេះដឹងយ៉ាងណានោះ ប្រសិនបើយើងមិនដកឫសរំលើងគល់អាសវៈ និង វិចិកិច្ឆា នៅក្នុងសន្ដានចិត្តរបស់យើងទេ យើងនឹងស្ថិតនៅតែក្នុងស្ថានភាពទោមនស្ស។ កាលណា យើងបានដល់ស្ថាន ភាពបរិសុទ្ធដ៏ខ្ពស់បំផុត (អរហត្ត) យើងបានរំលីងឫសគល់លោភៈទោសៈ និង មោហៈ ទាំងស្រុង ហើយកសាងបាននូវឧបេក្ខាចិត្តដ៏ពេញលេញ។ គឺនៅពេលនោះហើយដែល "បរិសុទ្ធ បុគ្គល" បានមកដល់ស្ថានភាពមួយ ដែលលោកមិនអាចបង្កើតគំនិតអកុសលណាមួយបានឡើយ។ លោកមិនអាចពោលពាក្យចាក់ដោត ឬប្រព្រឹត្តអំពើអកុសលកើតទេ។ បុគ្គលម្នាក់ដែលបានសម្អាតចិត្តឱ្យបរិសុទ្ធហើយ គឺមានឧត្ដមានុភាពរាប់រយដង ជាងអ្នកទាំងឡាយដែលមានអំណាច ឬ អ្នកទាំងឡាយដែលមានសទ្ធា ឬមានចំណេះដឹងសុទ្ធសាធ ហើយកប់លិចលង់ក្នុងភាព សៅហ្មងនៃចិត្ត។ យើងប្រកាសខ្លួនយើងថាជាជន "មានអរ្យធម៌" ប៉ុន្តែតើយើងអាចប្រកាសដូច្នេះយ៉ាងម៉េចកើត នៅពេលដែលសន្ដានចិត្តរបស់យើងបង្ហាញឱ្យឃើញចរិតអន់ថយ (មិនបរិសុទ្ធ) ដល់កម្រិតដូចគ្នានឹងចរិតបរិសុទ្ធរបស់បុព្វបុរស" ជំនាន់ដើមរបស់យើងបានប្រព្រឹត្តកាលពីរាប់ពាន់ឆ្នាំកន្លងទៅ ?

នៅលើពិភពលោកទូទៅ មនុស្សបាននាំគ្នាទៅយ៉ាងច្រើនកុះករ ក្នុងវិហារពុទ្ធសាសនា (temples) វិហារគ្រិស្ដ (churches) វិហារអ៊ិស្លាម (mosques) និងបូជនីយដ្ឋានដទៃទៀត ដើម្បីសូត្រធម៌ ធ្វើពិធីបូជា ប្រព្រឹត្តតបកម្ម។ ប៉ុន្តែកាលណាគេចេញមកក្រៅវិហារវិញ គេនៅតែមានទោសៈ លោភៈ ច្រណែនឈ្នានីស និងគំនុំគុំគួនដដែលដូចដែលគេមានពីមុន។ មនុស្សតែងប្រកាសថាខ្លួនជា "អ្នកកាន់សាសនា" កាលណាគេសូត្រធម៌ គោរពបូជា និង ធ្វើពិធីបុណ្យសាសនា ប៉ុន្តែសន្ដានចិត្តរបស់គេនៅតែមានអត្តទត្តភាពនិងវៀចវេរ។ ប្រសិនបើគេជាអ្នកកាន់សាសនាពិតមែន គេមិនត្រូវរើសអើងប្រឆាំងអ្នកដទៃ ឬធ្វើឱ្យអ្នកដទៃឈឺចាប់ ឬក៏ចំអកឡកឡឺយអ្នកដទៃ ក្នុងការប្រតិបត្តិសាសនារបស់គេទេ។ ព្រះពុទ្ធបានព្យាយាមបើកចំហ

សន្តានចិត្តរបស់យើង ទៅកាន់សេចក្តីយល់ដឹងរឿងហេតុទាំងឡាយយ៉ាងប្រពៃដោយមិនធ្វើឱ្យជំជាត់ឡើងនូវជំនឿ និងការរើសអើងសាសនាដ៏ងងឹតងងុលទេ។

អញ្ញទិដ្ឋិ (Heresy) ៖ មានហេតុផលមួយទៀតពោលថា ព្រោះហេតុអ្វីបានជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមិនធ្លាក់ចូលទៅក្នុងប្រភេទនៃសាសនាដែលមានស្រាប់ហើយ នោះក៏ព្រោះថា វាគ្មានកន្លែងសម្រាប់ "អញ្ញទិដ្ឋិ" នៅក្នុងប្រព័ន្ធនៃពាក្យប្រៀនប្រដៅនោះ។ អញ្ញទិដ្ឋិគឺជាអ្វីមួយដែល បញ្ចេញយោបល់ប្រឆាំង "បន្ទូលរបស់អាទិទេព" ព្រះពុទ្ធបានអំពាវនាវ និងអញ្ជើញដោយសេរីទាំង សាវ័ករបស់ព្រះអង្គ ទាំងអ្នកបដិបក្ខចំពោះព្រះអង្គឱ្យមានយោបល់ប្រឆាំងព្រះធម៌របស់ព្រះអង្គអំពីជ្រុងទាំងអស់ដែលអាចប្រឆាំងបាន ដើម្បីកុំឱ្យមានកន្លែងណាមួយមានសេចក្តីសង្ស័យ។ អនុវត្តតាមពាក្យ ណែនាំរបស់ព្រះអង្គសាវ័កទាំងឡាយរបស់ព្រះអង្គ បានជជែកវែកញែកអំពីលទ្ធិរបស់ព្រះអង្គ ហើយរហូតដល់គេបានបង្កើតនិកាយពុទ្ធសាសនាផ្សេងៗគ្នា ដោយអនុលោមទៅតាមសេចក្តីយល់ដឹងរបស់គេ ដោយគ្មានអំពើហិង្សា និងការបង្ហូរឈាមឡើយ។ ជាក់ស្តែងនៅសាកលវិទ្យាល័យពុទ្ធសាសនាដ៏មានឈ្មោះ ល្បីល្បាញនាលន្ទា ( ដែលត្រូវបានពួកអ្នកកាន់សាសនា ផ្សេងនិយមជ្រុលបំផ្លាញចោល) អ្នកកាន់តាមនិកាយពុទ្ធសាសនាថេរវាទ និង មហាយានបានរស់នៅជាមួយគ្នា ហើយបានសិក្សា និងជជែកដេញដោលចំណុចទស្សនៈផ្សេងគ្នារបស់គេនៅក្នុងសុខដុមភាពដ៏សុក្រឹត។ ព្រះពុទ្ធបានប្រៀនប្រដៅថា បើអ្នកណាបានជឿដោយពិតប្រាកដ ថាគេបានដឹងសច្ចធម៌នោះ គេមិនត្រូវខ្លាចនឹងយកសច្ចធម៌នោះមកប្រកួតដេញដោលទេ ពីព្រោះសច្ចធម៌នឹងឈ្នះជានិច្ច។លើសនេះទៀត ព្រះអង្គបានលើកទឹកចិត្តយ៉ាងខ្លាំងឱ្យអ្នកណាក៏ដោយបញ្ចេញមតិប្រឆាំងព្រះធម៌របស់ព្រះអង្គ ។ ចម្លើយរបស់ព្រះអង្គចំពោះ សំណួរដ៏ច្រើនបានធ្វើឱ្យធម៌សម្បូរបែប ទៅជាវិស័យសាសនាមួយធំទូលាយ ដែលត្រូវបានសាវ័ករបស់ ព្រះអង្គកត់ត្រាទុកយ៉ាងផ្ចិតផ្ចង់។ សព្វថ្ងៃយើងមានសមត្ថភាពដើម្បីឆ្លើយតបសំណួរណាមួយអំពីពុទ្ធសាសនា ដោយគ្រាន់តែយោងទៅរកសេចក្តីពន្យល់របស់ព្រះពុទ្ធ។ ការត្រិះរិះប្រកបដោយវិចារណកម្មនិងសារសំខាន់នៃការហៅរកឱ្យមានការរិះគន់ គឺជាបាតុភូតឧត្តុង្គឧត្តមបំផុតក្នុងពុទ្ធសាសនា។

វិទ្យាសាស្ត្រ ៖ ការសាកល្បងពាក្យប្រៀនប្រដៅសាសនា គឺឋិតនៅក្នុងស្ថានភាពស្របស្រួលជាមួយការរកឃើញរបស់វិទ្យាសាស្ត្រ ហើយនិងការទាក់ទាញចិត្ត ដែលការសាកល្បងនេះបានជះឥទ្ធិពលទៅលើសន្តានចិត្តមនុស្ស ដែលមានវិចារណសត្តិ (intelligence)

ស្រួចស្រាវ ។ សាសនាមួយ ចំនួនបានទទួលរងនូវភាពមិនស្រួលក្នុងចិត្តខ្លះៗ នៅពេលវិទ្យាសាស្ត្រលាតត្រដាងការរកឃើញរបស់គេ។ ជាលទ្ធផលការកែសម្រួលមួយចំនួន និងការបកស្រាយគម្ពីររបស់សាសនាទាំងនោះជាថ្មី បានក្លាយទៅជាការងារចាំបាច់។ នៅក្នុងទិដ្ឋភាព នេះ ពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅប្រកបដោយវិចារណកម្ម របស់ព្រះសម្ពុទ្ធមិនប្រឈមមុខចំពោះសេចក្តីកង្វល់បែបនោះទេ ដោយហេតុថា គោលការណ៍ទាំងឡាយជាគ្រឹះរបស់ពុទ្ធសាសនា ឋិតក្នុងសុខុដុមភាពយ៉ាងល្អកល្អឹនជាមួយនឹងការរកឃើញរបស់វិទ្យាសាស្ត្រ។ ចូរយើងសិក្សាតែឧទាហរណ៍មួយមើលចុះ ។

ក្រោមពន្លឺនៃការសិក្សាថ្មីបំផុតអំពីបរមាណូ (Atom) ទស្សនៈចាស់អំពីពិភពលោកកំពុងតែប្រែប្រួលផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅហើយឆាប់រហ័សក៏ដូចជា ទស្សនៈ អំពីបរមាណូផ្ទាល់ក៏កំពុងផ្លាស់ប្តូរប្រែប្រួលដែរ។ វាពុំមានរូបធាតុ (matter) ដូចដែលគេធ្លាប់បានជឿក្នុងអតីតកាលទេ វាត្រូវបានក្លាយទៅជាថាមពល ហើយសូម្បីតែមតិអំពីថាមពលទៀតសោត ក៏កំពុងតែបត់ទៅបន្តិចម្តងៗ ហើយអ្នកវិទ្យាសាស្ត្រខ្លួនឯងក៏មិនដឹងហៅបរមាណូនោះជាអ្វីដែរ។ អ្នកវិទ្យាសាស្ត្រទាំងនោះឥឡូវនេះបានឈានមកដល់សេចក្តីសន្និដ្ឋានថា បរមាណូ គឺ គ្រាន់តែជាមតិមួយ (concept) ប៉ុណ្ណោះ ហើយបើនិយាយឱ្យឆ្ងាយទៅ ទៀតពិភពលោកផងដែរ គឺគ្មានអ្វីក្រៅតែជាមតិបញ្ញត្តិមួយ (a conception) នោះទេ ។ អ្នកវិទ្យាសាស្ត្រទាំងនោះ កាន់តែធ្វើការស្រាវជ្រាវច្រើនឡើងទៅក្នុងរចនាសម្ព័ន្ធបរមាណូ (the structure of the atom) ពួកគេហាក់ដូចជាកាន់តែជឿលើសេចក្តីសន្និដ្ឋាននេះខ្លាំងឡើងៗ។

នៅក្នុងពុទ្ធសាសនា ទ្រឹស្តីនេះត្រូវបានគេផ្សព្វផ្សាយយ៉ាងតិចណាស់ ក៏តាំងតែពី ជប់ប្រាំមួយសតវត្សកន្លងទៅហើយ។ ប៉ុន្តែនៅក្នុងសតវត្សទី៤ នៃគ.ស. ទស្សនវិទូពុទ្ធសាសនិកគឺលោក អាសង្គៈ (Asanga) បានអភិវឌ្ឍទ្រឹស្តីមួយដែលគេស្គាល់ថា វិជ្ញប្តិ-មាត្រ ឬចិត្ត-មាត្រ (Vijnapti-matra or Cittamatra) ដែលផ្អែកលើអត្ថបទគម្ពីរដើម ដែលប្រកាសថា ពិភពលោកនេះគឺគ្រាន់តែជាមតិបញ្ញត្តិមួយ (conception) គ្រាន់តែជាគំនិតមួយ (a thought) គ្រាន់តែជាយោបល់មួយ (an idea)។ ដើម្បីបញ្ជាក់អះ អាងទ្រឹស្តីនេះ លោក អាសង្គៈ បានឱ្យនិយមន័យពាក្យបរមាណូ ហើយនិយមន័យរបស់លោកបានធ្វើឡើង កាលពីមួយពាន់ប្រាំមួយរយឆ្នាំកន្លងទៅហើយ គឺនៅតែមានសុពលភាពរហូតមកដល់សព្វថ្ងៃ។ បរមាណូ (atom) គេគួរគប្បីយល់ថា មិនមានសរីរៈទេ (និស្សរីរៈ) ។ ការកំណត់ធម្មជាតិនៃបរមាណូ គឺ ត្រូវបានធ្វើ

ឡើងដោយបញ្ញាតាមរយៈការវិភាគដ៏ល្អិតល្អន់នៃដុំរូបធាតុ (mass of matter)។ តាមពិតការជាប់ចិត្តរបស់លោកអាសង្គ: គឺមិនមែននៅក្នុងរូបវិជ្ជា (physics) ទេ ប៉ុន្តែនៅក្នុងបរមត្ថវិជ្ជា និងក្នុងទស្សនវិជ្ជា។ សេចក្តីជាប់ចិត្តរបស់លោកគឺ ដើម្បីបង្ហាញថា ពិភពលោកនេះដែលមនុស្សសាមញ្ញគិតថា ជាសារធាតុ គឺគ្មានអ្វីពិតជាក់ស្តែងទេ ប៉ុន្តែគ្រាន់តែជាមតិមួយប៉ុណ្ណោះ។ យោងតាមលោក អាល់ប៊ែរ អាំងស្តាំង (Albert Einstein) កាលណាគេវិភាគសកល លោកធាតុ (the universe) គឺវាគ្មានអ្វីដែលនៅសល់ជាសារធាតុក្រៅ តែជាកប្បនា (ការញ័រ) ឬរលកអាកាស (waves)ប៉ុណ្ណោះ។

លទ្ធិ (ធម៌) របស់ពុទ្ធសាសនាឋិតនៅសព្វថ្ងៃ គ្មានការប៉ះពាល់ដោយដំណើរពេលវេលា និងការរីកពលជាលចំណេះដឹងដូចកាលពីព្រះធម៌នេះត្រូវបានប្រកាសពីដំបូងដូច្នោះ។ បើទោះជាទំហំនៃចំណេះដឹងវិទ្យាសាស្ត្រកើនឡើងដល់កម្រិតមួយវែងឆ្ងាយ ដែលអាចពង្រីកមណ្ឌលបញ្ញារបស់មនុស្សបានធំទូលាយដូចម្តេចក្តី ក៏គង់នៅក្នុងក្របខ័ណ្ឌនៃព្រះធម៌ វាមានកន្លែងសម្រាប់ទទួលយក និងស្រូបយកនូវការរកឃើញវែងឆ្ងាយទៀតបាន។ នេះក៏ព្រោះតែពុទ្ធសាសនាមិនពឹងផ្អែកលើទស្សនៈមានកម្រិតរបស់បណ្ឌិតជំនាន់ដើម សម្រាប់បំពេញចំណូលចិត្តរបស់ខ្លួនទេ ទាំងមិនផ្អែកលើការបដិសេធគំនិតត្រិះរិះសម្រាប់បំពេញចំណូលចិត្តរបស់ខ្លួនទេ ទាំងមិនផ្អែកលើការបដិសេធ គំនិតត្រិះរិះសម្រាប់អំណាចរបស់ខ្លួនដែរ។

បដិហារ្យ (Miracles) ៖ វិទ្យាសាស្ត្រសព្វថ្ងៃមិនបដិសេធលទ្ធភាពនៃបដិហារ្យ ទេដូចដែលធ្លាប់មានពីដើម ប៉ុន្តែកំពុងចាប់ផ្តើមទទួលយកថា អ្វីដែលគេបានស្គាល់ថា បដិហារ្យនោះ គឺគ្រាន់តែជាការស្តែងឡើងនៃបាតុភូតទាំងឡាយដែលគេមិនទាន់បានដឹង។ ព្រះពុទ្ធព្រះអង្គឯងផ្ទាល់បានផ្សព្វផ្សាយទស្សនៈនេះថា ចំពោះព្រះអង្គ បដិហារ្យ មិនត្រូវបានគេចាត់ទុកជាការបង្ហាញសច្ចធម៌នៅក្នុងបដិហារ្យផ្ទាល់ទេ ប៉ុន្តែគ្រាន់តែបានបង្អួតចំណេះជំនាញនៃអានុភាព ចំពោះចំណេះដឹងតិចតួច ដែលមនុស្សខ្លះបានធ្វើឱ្យរីកចម្រើនឡើងប៉ុណ្ណោះ។ បដិហារ្យនេះមិនតម្រូវឱ្យជឿថា អ្នកចេះសម្តែងបដិហារ្យ គឺជាអ្នកត្រាស់ដឹងឬជាតួអង្គទេពតាទេ។

ដោយប្រការយ៉ាងនេះ ព្រះពុទ្ធមិនគ្រាន់តែបានប្រៀនប្រដៅសាវ័ករបស់ព្រះអង្គឱ្យប្រុងប្រយ័ត្នក្នុងការសម្តែងអានុភាពអច្ឆរិយៈ ដែលសាវ័កទាំងនោះអាចសម្រេចបានប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គនៅបាន ព្រមានសាវ័កទាំងឡាយឯទៀត មិនឱ្យចាប់ចិត្តជាប់អារម្មណ៍ដោយមិនដួនកាលចំពោះការបង្ហាញបែបនោះថែមទៀត។ ដូច្នេះ ទោះបីសាសនាដទៃៗប្រើប្រាស់

កត្តាអច្ឆរិយៈទាំងឡាយរបស់គេ ដើម្បីបញ្ចុះបញ្ចូលមហាជនពុទ្ធសាសនាវិញ ចាត់ទុករឿង ហេតុទាំងអស់បែបនោះថា វាមានសារសំខាន់តិចតួចណាស់ ហើយមិនទាក់ទងទៅនឹងកាតព្វកិច្ចពិតប្រាកដនៃការអភិវឌ្ឍខាងស្មារតី និងការរំដោះផុតទុក្ខទេ។ ចំពោះព្រះពុទ្ធបដិហារ្យដ៏ខ្ពស់បំផុត គឺការកែប្រែគេពីមនុស្សអវិជ្ជាទៅជាមនុស្សមានប្រាជ្ញា។

ទាក់ទងនឹងរឿងនេះ លោក ស្វាមី វិវេកនន្ទ និយាយថា "មតិអំពីតួអង្គអច្ឆរិយៈអាចបំផុសឡើងដល់កម្រិតណាមួយនូវអំណាចធ្វើសកម្មភាពក្នុងមនុស្ស ប៉ុន្តែអំណាចនោះ នាំមកផងដែរនូវភាពពឹងផ្អែក វានាំមកនូវសេចក្ដីភ័យខ្លាច វានាំមកនូវមិច្ឆាមតិ (superstition) ។ វាបង្កើតទៅជាជំនឿតក់ស្លុតរន្ធត់ក្នុងសភាពទន់ខ្សោយធម្មតារបស់មនុស្ស" ។

ឥរិយាបថវិទ្យាសាស្ត្រហើយនិងខ្លឹមសាររបស់ពុទ្ធសាសនាបាននាំឱ្យ លោក អាល់ ប៊ែរ អាំង ស្តាំង (Albert Einstein) និយាយថា "ប្រសិនបើមានសាសនាណាមួយដែលនឹង ដោះស្រាយបានជោគជ័យជាមួយនឹងសេចក្ដីត្រូវការវិទ្យាសាស្ត្រសម័យថ្មីនោះគឺពុទ្ធសាសនា" ។

អភិសមាចារ និង សង្គម ៖ ទិដ្ឋភាពដ៏សំខាន់ផ្សេងទៀតរបស់ពុទ្ធសាសនាក្នុងឋានៈជាសាសនាពិភពលោកមួយ គឺឥរិយាបថរបស់ពុទ្ធសាសនា ចំពោះបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហានយោបាយ។ មនុស្សខ្លះចំណេះដឹង ច្រើនមាននិន្នាការទូទៅចាត់ទុកពុទ្ធសាសនាថាជាការគេចវេះ ឬដកខ្លួនថយពីជីវភាពសកម្មទៅ ជ្រកក្នុងវិហារ ឬក្នុងល្អាងភ្នំ ឬក្នុងព្រៃ ហើយដឹកនាំជីវភាពផ្ដាច់ពីសង្គម។ ប៉ុន្តែថា ទស្សនៈនេះបណ្ដាលមកពីខ្វះសេចក្ដីយល់ដឹង ពីព្រោះព្រះពុទ្ធអង្គឯងផ្ទាល់ គឺជាបុគ្គលមួយរូបក្នុងចំណោមមនុស្សធ្វើការខ្លាំងក្លាបំផុត ដែលបានរស់នៅក្នុងលោកនេះ។ ព្រះអង្គបាន ផ្ទុំតែពីរម៉ោងកន្លះប៉ុណ្ណោះ រៀងរាល់រាត្រី ហើយពេលវេលាក្រៅពីនេះព្រះអង្គបានបំពេញពុទ្ធកិច្ច។ ព្រះអង្គបានយាងដោយព្រះបាទាពាសពេញលើផ្ទៃប្រទេសឥណ្ឌា ជួបមនុស្សមកពីគ្រប់វិជ្ជាជីវៈ មានបន្ទូលទៅកាន់មនុស្សទាំងនោះហើយប្រៀនប្រដៅមនុស្សទាំងនោះ។ ព្រះអង្គមិនបានមានបន្ទូលអំពីនិព្វាន រាល់តែពេលទៅកាន់មនុស្សគ្រប់គ្នាដែលព្រះអង្គបានជួបនោះទេ។ ព្រះអង្គបានមានបន្ទូលដោយអនុលោមទៅតាមបែបបទជីវភាព និង កម្រិតយល់ដឹងរបស់ពួកគេ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា ព្រះអង្គមិនអាចសង្ឃឹមអ្នកស្ដាប់ធម៌ដំបូង យល់ដឹងអរិយសច្ចៈដ៏ខ្ពស់បំផុតភ្លាមៗបានទេ។ ព្រះអង្គមានបន្ទូលថាមាគ៌ារបស់ព្រះអង្គគឺជាមាគ៌ាតាមលំដាប់លំដោយ (មួយថ្នាក់ម្ដងៗ)។ ដោយហេតុនោះការជួយមនុស្សនៅក្នុងបែបបទប្លែកៗស្របទៅតាមស្តង់ដារ ឬការវិវត្ត និងវឌ្ឍនភាពរបស់គេគឺ

ជាផ្នែកមួយរបស់សាសនានេះ។ ជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយដ៏សកម្មមួយមិនអាចផ្តាច់ចេញពីជីវភាពសាសនា ដ៏ពិតបានទេ។

នៅក្នុងសាសនារបស់ព្រះពុទ្ធ គេបានឃើញមានប្រព័ន្ធអភិសមាចារមួយគ្រប់ជ្រុងជ្រោយនិងបរមត្ថវិជ្ជាលោកុត្តរៈមួយ ដែលរួមបញ្ចូលទាំងចិត្តវិទ្យាដ៏ឧត្តុង្គឧត្តមផង។ សាសនានេះបំពេញបានអធ្យាស្រ័យទាំងអស់។ សម្រាប់អ្នកមានសតិបញ្ញាសាមញ្ញ សាសនានេះបានផ្តល់ឱ្យសីលសិក្ខាបទ ការគោរពបូជាដ៏ល្អប្រពៃ ហើយរហូតដល់សេចក្តីសង្ឃឹមចំពោះជីវិតក្នុងឋានសួគ៌ទៀតផង ចំពោះអ្នកមានកក្តីភាពជ្រាលជ្រៅ សាសនានេះផ្តល់ឱ្យប្រព័ន្ធនៃគំនិតដ៏បរិសុទ្ធ ទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់ និងពាក្យប្រៀនប្រដៅសីលធម៌ ដែលនាំទៅដល់ការត្រាស់ដឹងនិងការរំដោះផុតទុក្ខទាំងអស់។ ប៉ុន្តែ ព្រះធម៌ជាមូលដ្ឋាន គឺការជម្រះចិត្តមនុស្សឱ្យបរិសុទ្ធ។ វឌ្ឍនភាពខាងស្មារតី មិនអាចធ្វើទៅបានទេ សម្រាប់អ្នកណាដែលមិនដឹកនាំជីវិតក្នុងសេចក្តីបរិសុទ្ធនិងករុណា ។

នៅក្នុងទម្រង់ចាត់តាំងរបស់ខ្លួន ក្នុងឋានៈជាសាសនាមហាជន ដោយមានគេប្រតិបត្តិតាមច្រើនជាមួយនឹងពិធីបុណ្យទាន ពិធីដង្ហែក្បួន និងពិធីមហោស្រពដ៏ច្រើន ដែលបញ្ចូលទំនៀមទម្លាប់ និងប្រពៃណីផ្សេងៗ ពុទ្ធសាសនាផ្តល់ឱ្យនូវហេតុផលបទពិសោធន៍ និងទព្វសម្ភារៈយ៉ាងទូលំទូលាយសម្រាប់ការអប់រំ។ ពិធីបុណ្យក្នុងគ្រួសារ បុណ្យទាននៅក្នុងភូមិការសម្តែងសិល្បៈវប្បធម៌និងព្រឹត្តិការណ៍ទាំងឡាយដូចជា ខួបកំណើត អាពាហ៍ពិពាហ៍ មរណភាព និងពិធីរំលឹកគុណផ្តល់ការអប់រំក្នុង បែបបទមួយមិនរៀបរយ។ កុមារទាំងឡាយរៀនចេះដឹងទំនៀមទម្លាប់ របៀបរបបតម្លៃវប្បធម៌ភាគច្រើនរបស់គេ ហើយរហូតដល់យល់ដឹងបំណងប្រាថ្នា តាមការសង្កេតឬចូលរួមក្នុងសកម្មភាពអប់រំមិនរៀបរយទាំងនេះ។ យុវជន និងមនុស្សពេញវ័យក៏ទទួលផលអំពីសកម្មភាពទាំងនេះផងដែរ ។

ហួសពីកម្រិតផ្ទាល់ខ្លួន និងការរួចរំដោះរបស់បុគ្គលម្នាក់ៗ ពុទ្ធសាសនាទទួលស្គាល់គ្រួសារជា ឯកតារបស់សង្គម និងជាតិ។ ដូច្នេះ ចំពោះអ្នកមេផ្ទះធម្មតា ដែលមានគោលបំណងខ្ពស់បំផុតរបស់គេ គឺចង់បានសេចក្តីសប្បាយជាសម្ភារៈនៅក្នុងលោកនេះ ហើយចង់ទៅកាន់ស្ថានសួគ៌ បន្ទាប់ពីលោកនេះទៅពុទ្ធសាសនា បានផ្តល់នូវក្រមសីលធម៌មួយដ៏សាមញ្ញ ដូចមានសម្តែងក្នុងសិគាលោវាទសូត្រ។ ការប្រតិបត្តិតាមក្រមសីលធម៌នេះនឹងជួយពង្រឹកសាមគ្គី

ភាពសហគមន៍។ ក្រមសីលធម៌ ជួយទ្រទ្រង់ទំនាក់ទំនងត្រឹមត្រូវរវាងសមាជិកនយោជិក និងនយោជក ជាគ្រួសាររបស់សហគមន៍។

នៅក្នុងការទស្សនាផ្សេងមួយទៀត ព្រះពុទ្ធបានប្រទានឱវាទដប់យ៉ាងសម្រាប់មនុស្សគោរព និងបំពេញភាតព្វកិច្ច និងការទទួលខុសត្រូវរបស់គេ ចំពោះឪពុកម្តាយ បុត្រធីតា ប្តីប្រពន្ធ ញាតិសន្តាន ចាស់ព្រឹទ្ធាចារ្យ បុគ្គលដែលបានចែកឋានទៅហើយ ទេពតា និងដើម្បីរស់នៅជាសុខដុមក្នុងសង្គមដោយ មិនក្លាយខ្លួនជាឧបសគ្គចំពោះសាធារណជន និងដើម្បីរស់នៅគ្មានការស្តីបន្ទោស។

ការប្រៀនប្រដៅបែបនេះប្រកាន់យកសុខុមាលភាពរបស់សមាជិកទាំងអស់ នៃសង្គមទុកជាគោលដៅរបស់ខ្លួន ហើយផ្តល់ឱ្យមានការអនុវត្តធ្វើសកម្មភាពជា មិត្តភាពដ៏ត្រឹមត្រូវមួយ ដែលជាសញ្ញាសំគាល់មនុស្សម្នាក់ចុះសម្រុងក្នុងសង្គមយ៉ាងពិតប្រាកដ។ ម្យ៉ាងវិញទៀត មនុស្សមានកម្រិតស្មារតីជឿនលឿនដែលមើល ឃើញឧបសគ្គនៃជីវភាពជាគ្រហស្ថ (គឺជាមាគ៌ាមួយជិតដាមសៅហ្មងដោយរាគៈ) អាចប្រកាន់យកក្រមសីលធម៌និង អភិសមាចារមួយខ្ពស់ជាង ដូចមានចែងនៅក្នុងបទបញ្ញត្តិ សម្រាប់គណៈសង្ឃ ដែលមានឈ្មោះថា វិន័យ ។ វិនយប្បញ្ញត្តិទាំងនោះ នឹងជួយគេឱ្យអាចដឹកនាំជីវិត ក្នុងភាពបរិសុទ្ធគ្មានកិលេស(និក្កិលេស) និងភាពជា បព្វជិតដែលមិនជាប់ជំពាក់ដោយកន្ទ្វល់លោកិយ។

សីលធម៌ ៖ សីលធម៌ពុទ្ធសាសនា គឺផ្អែកលើសេរីភាព និងសេចក្តីយល់ដឹង។ ពីព្រោះសីលធម៌បានដុះចេញពីសេចក្តីត្រូវការរបស់សង្គម សម្រាប់ភាពគង់វង្សខ្លួនឯងសីលធម៌នេះត្រូវតែសម្របសម្រួលខ្លួនឯងយ៉ាងចាំបាច់ទៅនឹងពេលវេលា និងកាលៈទេសៈកំពុងប្រែ ប្រួល។ ដោយហេតុដូច្នេះ សីលធម៌ គឺជាសភាវៈប្រៀបធៀប។ តាមពិតវាពុំអាចមានសីលធម៌ ឬទស្សនៈអភិសមាចារណាមួយទេ ប្រសិនបើសីលធម៌នោះ មានទីតាំងនៅក្នុងការដាក់បន្ទំ ឬអន្តរាគមន៍អំពីភ្នាក់ងារណាមួយនៅខាងក្រៅបុគ្គលខ្លួនឯងផ្ទាល់។ បុគ្គលនោះ ត្រូវយល់ព្រមដោយសេរីនូវការកំហិតណាមួយ ដែលដាក់បន្ទំមកលើខ្លួនសម្រាប់ឱ្យសីលធម៌អនុវត្តបានប្រសិទ្ធភាពពិតប្រាកដ។

មេត្តា (Compassionat Love) គឺជាគ្រឹះនៃចរិយាសីលធម៌ និងអភិសមាចារទាំងអស់នៅក្នុងពុទ្ធសាសនា។ ចេញពីមេត្តាធម៌នេះទៅ ទើបកើតមានសិក្ខាបទអភិសមាចារ និងសីលសេវកិច្ចសង្គម យុត្តិធម៌សង្គម សុខុមាលភាពសង្គមទាំងអស់នេះជាអាទិ៍។ សមភាព ភាតរ

ភាពសន្ដោសសេចក្ដីយោគយល់ ការគោរពចំពោះជីវិត ការគោរពទស្សនៈចំពោះអ្នកដទៃ ការគោរពសាសនាអ្នកដទៃ ទាំងអស់នេះមាន ឫសគល់របស់វានៅក្នុងមេត្តា។ ផ្អែកលើគោលការណ៍ដ៏ប្រសើរខ្ពង់ខ្ពស់នេះ ពុទ្ធសាសនាត្រូវបានគេចាត់ទុកជាសាសនាសន្តិភាពជានិច្ច។ ប្រវត្តិដ៏យូរលង់របស់ព្រះពុទ្ធសាសនា បានរួចផុតពីការលោបពណ៌នៃសង្គ្រាមសាសនា ការធ្វើទុក្ខបុកម្នេញសាសនា និងការស្រាវជ្រាវលុបបំបាត់ជំនឿសាសនាដទៃ (Religious persecutions and inquisitions)។ ពុទ្ធសាសនានៅក្នុងទិដ្ឋភាពនេះ ឈរនៅជាជើងឯកក្នុងប្រវត្តិសាស្ត្រនៃសាសនាទាំងឡាយ។ ដោយសារឧទាហរណ៍ដ៏ប្រសើររបស់ព្រះពុទ្ធនៅក្នុងរឿងនេះ លោក ស្វាមីវិវេកនន្ទៈ និយាយនៅក្នុងឧទ្ទេសកថារបស់លោក ស្ដីពីកម្មយោគៈថា "ពូជជាតិមនុស្សទាំងមូល ផលិតបានមនុស្សបែបនេះតែមួយគត់ ទស្សនវិជ្ជាដ៏ខ្ពស់បែបនេះតែមួយគត់ សមានចិត្តទូលំទូលាយបែបនេះតែមួយគត់។ មហាទស្សនវិទូដែលផ្សព្វផ្សាយទស្សនវិជ្ជាដ៏ខ្ពស់បំផុត មានសមានចិត្តដ៏ជ្រាលជ្រៅបំផុត ចំពោះសត្វដ៏ទាបបំផុតហើយមិនដែលទាមទារអ្វីសម្រាប់ខ្លួនលោកនោះឡើយ។ លោកគឺជាកម្ម យោគីគំរូធ្វើសកម្មភាព ទាំងស្រុងដោយមិនចាំបាច់មានហេតុជំរុញឱ្យធ្វើ ហើយប្រវត្តិសាស្ត្រមនុស្សជាតិបង្ហាញឱ្យឃើញថា លោកជាមហាបុរសកំពូលមិនធ្លាប់ដែលមាន គ្មានគូប្រៀប ជាការផ្សំចូលគ្នាដ៏ធំបំផុតនៃហឫទ័យ និងពុទ្ធិដែលមិនធ្លាប់កើតមានសោះឡើយ"[២៩]។

# សាសនាសិក្ខ

## សាសនានៃអកាល

បណ្ដាសាសនាប្រភេទដែលមានអ្នកកាន់អាន (Living Religions) សាសនាសិក្ខ (Sikhism) ដែលមានន័យសេចក្ដីថា សាសនារបស់សិស្ស ជាសាសនាថ្មីបំផុតជាងសាសនានានាទាំងអស់ចំនួនអ្នកកាន់អានមាននៅទូទៅក្នុងលោក បច្ចុប្បន្នមានប្រមាណ៣០លាននាក់។

តាមឋានៈភូមិសាស្ត្រទីកន្លែងកើតរបស់សាសនាសិក្ខ នៅក្នុងខេត្តបញ្ចាបខាងទិសពាយ័ព្យនៃប្រទេសឥណ្ឌា ខេត្តនេះត្រូវកាត់ចេញទៅឱ្យប្រទេសប៉ាគីស្ថានស្ទើរតែទាំងអស់ ពាក្យប្រៀនប្រដៅក្នុងសាសនាចូងកាត់ពីប្រទេសឥណ្ឌាភាគខាងជើងខ្លះ ចុះមកខាងត្បូងដល់កោះលង្កា។

[២៩] បណ្ឌិតសភាចារ្យ ខ្ចួត ធីតា ៖ មូលដ្ឋានគ្រឹះនៃសីលវិទ្យាសាកលលោក ឆ្នាំ២០០៩ ទំព័រ ១៩៥-១៩៧

វៀរលែងតែសាសនាជ្វីហ្វ ឬយូដា សាសនាសិក្ខជាសាសនាតែមួយក្នុងលោក ដែលកើតឡើង ព្រោះការការគាបសង្កត់ខាងនយោបាយច្រើនបំផុត សាសនាសិក្ខកើតអំពីសេចក្តីលំបាកក្រខ្សត់ កើតពីការបង្ខិតបង្ខំ សំឡុត ដែលជនជាតិហិណ្ឌូបានទទួលពីមនុស្សក្នុងសាសនាដទៃៗ សិក្ខទើបជាសាសនារបស់អ្នកក្លាហានលះបង់ ជាសាសនារបស់ទាហានរបស់អ្នកចម្បាំង អ្នកប្រកាសសាសនាសិក្ខតាំងសេចក្តីបំណងទុកក្នុងពាក្យប្រៀនប្រដៅ ជាលទ្ធិរួមសាមគ្គីដើម្បីប្រទេសជាតិ។ ជនជាតិសិក្ខគ្រប់គ្នាទុកដូចជាទាហានក្នុងក្រុមកងមួយធំរួមគ្នាឡើងដូចជាបាច់ផ្តៅ ជាកម្លាំងការពារជាតិត្រកូលរបស់ខ្លួន សាសនាសិក្ខស្ទើរតែមិនគួរជាបញ្ញត្តិរបស់សាសនានោះឡើយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៨)

អ្នកប្រកាសសាសនានេះ បំណងរួមគឺការបែកបាក់រវាងអ្នកជម្ពូទ្វីប រាប់អានសាសនាអ៊ិស្លាម និងពួកអ្នករាប់អាន សាសនាហិណ្ឌូឱ្យនៅរួមគ្នាជាពួកតែមួយ បំណងកាត់ផ្តាច់ការបែកបាក់សាមគ្គីក្នុងរវាងលទ្ធិទាំងពីរនោះចេញតាំងលទ្ធិថ្មីនោះឡើង ឱ្យសមរម្យដល់ការតាំងនៅយ៉ាងរឹងមាំនៃជាតិត្រកូល ដែលជួបប្រទះសេចក្តីក្រខ្សត់អត់ឃ្លាន។ ព្រោះតែការបែកបាក់សាមគ្គីគ្នារបស់អ្នកដែលរាប់អានលទ្ធិទាំងពីរ ដែលមាននៅក្នុងពេលនោះ សមតាមគោលបំណងដែលប្រាកដក្នុងបញ្ញត្តិថា "ពុំមានព្រះជាម្ចាស់មួយអង្គរបស់ហិណ្ឌូ និងពុំមានព្រះ ជាម្ចាស់មួយអង្គសម្រាប់មូស្លីមផងដែរ គឺមានតែព្រះជាម្ចាស់តែមួយអង្គសម្រាប់មនុស្សទាំងពួង" អ្នកប្រកាសបញ្ញត្តិនៃលទ្ធិនេះដូចជា អ្នកកែទម្រង់ (Reformer) ដូចគ្នានឹង ម៉ាតាំង លូធើរ អ្នកប្រាជ្ញខាងសាសនារបស់ជនជាតិអាល្លឺម៉ង់ត៍ អ្នកផ្លាស់ប្តូរគម្ពីរភាគ ខ្លះនៃសាសនាគ្រិស្ត មកតាំងលទ្ធិប្រូតេស្តង់ឡើងក្នុងសម័យកណ្តាលនៃប្រវត្តិអឺរ៉ុប។

**នានក់អ្នកឱ្យកំណើត**

អ្នកឱ្យកំណើតសាសនានេះឈ្មោះ នានក់ (រវាងព.ស.២០១២-២០៨១) នៅភូមិតូចៗមួយឈ្មោះទល្វណ្ឌី (Talvandi) ឥឡូវនេះហៅថានានក់នគរតាមឈ្មោះនានក់ខាងទិសនិរតីរបស់ទីក្រុងឡាហ៊័រ (Lahore) ដែលជាទីក្រុងរបស់ខេត្តបញ្ជាបប្រហែល២០ ម៉ៃល៍ភូមិតាំងនៅលើទន្លេរាវី (Ravi) អ្នកចម្បាំងក្រិកលើកទ័ព ចូលមកវាយជម្ពូទ្វីបហៅទន្លេនេះថាអែដាពិស (Hydaspes) ឥឡូវនេះនៅក្នុងប្រទេសប៉ាគីស្ថាន។

នានក់ជាអ្នកត្រកូលជាហិណ្ឌូនៅក្នុងវណ្ណៈព្រាហ្មណ៍ បិតាធ្វើការងារ ជាអ្នកបម្រើចៅហ្វាយស្រុក មាតាជាអ្នកសាសនាយ៉ាងតឹងរឹង។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៥៩)

កាលអាយុបាន៧ឆ្នាំ ឪពុកម្តាយបានបញ្ជូនឱ្យចូលសិក្សាក្នុងសាសនាវៀន នានក់សម្តែងនូវបញ្ញា និង សមត្ថភាពសាកសួរពីរឿងរ៉ាវព្រះជាម្ចាស់ដល់គ្រូអាចារ្យ មានការចេះដឹង បែកឈានក្នុងគម្ពីរព្រះវេទតាំងពីអាយុនៅក្មេង អាយុ៩ឆ្នាំ។ នានក់ប្រាថ្នារៀនឱ្យចេះដឹងពីការប្រព្រឹត្តមករបស់សាសនា និងទេពជាម្ចាស់របស់អ្នកភូមិ ទើបសិក្សាភាសាប៉ែក្ស (អ៊ីរ៉ង់) ដើម្បីរៀនឱ្យដឹងលទ្ធិរបស់សាសនាសូរ៉ូអស្ត្រត័រ (Zeroaster) អ្នកដែលតាំងលទ្ធិ ប៉ារ៍ស៊ី (Parsi)។ ផលនៃការសិក្សា នានក់អាចឆ្លងឆ្លើយគោលនៃសាសនាជាមួយ ពួកអាចារ្យចាស់ៗបានតាំងតែពីក្មេងៗ គម្ពីរក្នុងសាសនាសិក្ខដែលហៅថាគ្រាន្ថ (Granth) យកគោលការណ៍ជាច្រើនមក អំពីគម្ពីររបស់សាស្តាចារ្យសូរ៉ូអស្ត្រត័រ ដែលចារឹកជាអក្សរប៉ែក្ស ក៏មានជនជាតិហិណ្ឌូមានជំនឿថា នានក់ ជាសាស្តារបស់ខ្លួន មានសមត្ថភាពបង្រៀនមនុស្សបានតាំងពីអាយុ ៩ ខួប។

នានក់ ជាមនុស្សចូលចិត្តប្រៀបធៀប និងកែប្រែពាក្យប្រៀនប្រដៅឱ្យសមតាមសម័យ តាមធម្មតាអ្នក នៅខេត្តបញ្ចាបចូលចិត្តកីឡាធ្វើឱ្យរាងកាយរឹងប៉ឹងគួរដល់ការជាអ្នកចម្បាំង និងធ្វើការងារសម្រាប់ស្រុកទេស។ ពួកខ្លះចូលចិត្តហ្វឹកហាត់លក់ដូរ តែនានក់មិនចូលចិត្ត តាំងគំនិតផ្តោះទៅតែការសិក្សារកចំណេះខាងផ្លូវសាសនា កែខៃជំនុំជនតែម្យ៉ាង។ ពួកញាតិបងប្អូននិងមិត្តភក្តិនាំគ្នាជួយកម្លាំងដល់នានក់ ឱ្យទៅជាមនុស្សសំខាន់ម្នាក់របស់ស្រុកទេស មានម្តងនោះអ្នកគ្រប់គ្រងបានស្នើនិងប្រគល់តំណែងរាជការជាន់ខ្ពស់ឱ្យ តែនានក់ បដិសេធ ដោយអាងថាខ្លួនមិនត្រូវការមុខងារខ្ពង់ខ្ពស់ខាងរាជការទេ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦០)

លុះមានអាយុល្មមសមគួរ បានរៀបការជាមួយស្រីត្រកូលល្អម្នាក់ក្នុងភូមិជាមួយគ្នា ភរិយាសម្រាលបានកូន ២នាក់ តែជីវិតក្នុងគ្រួសាររកសេចក្តីសុខដោយកម្រ ព្រោះនានក់ចូលចិត្តសេចក្តីស្ងប់ ភរិយាចូលចិត្តសប្បាយ នៅទីបំផុតនានក់រត់គេចចេញពីភរិយានិងកូនចេញទៅរកសេចក្តីស្ងប់ក្នុងព្រៃពេលអាយុ ៣៦ឆ្នាំ។

**ហេតុការណ៍ជាប្រាកដដំបូង**

ថ្ងៃមួយកំពុងអង្គុយដោយស្ងប់ស្ងាត់នៅក្នុងព្រៃ នានាក់ទទួលហេតុការណ៍ប្រាកដក្នុងចិត្តជាគ្រាដំបូង ដូចជាការបានផឹកទឹកអម្រិតបានមួយពែង អំពីអ្នកពូកែស័ក្តិសិទ្ធិមួយរូប។ អ្នកពូកែស័ក្តិសិទ្ធិបានប្រាប់ដល់នានាក់ថា "យើងនឹងសូមនៅជាមួយអ្នក យើងនឹងធ្វើឱ្យអ្នកមានសេចក្តីស្ងប់ស្ងាត់ ហើយនឹងធ្វើឱ្យអ្នករាល់គ្នា ដែលស្រឡាញ់យើងនៅក្នុងអ្នក និងមានសេចក្តីសុខទៅជាមួយផង។ អ្នកចូរចេញពីកន្លែងនេះទៅ ចូលទៅខាងមុខទឹកដល់យើង ប្រៀនប្រដៅមនុស្សទាំងឡាយដូចជាព្រះជាម្ចាស់កំពុងធ្វើ ចូរធ្វើឱ្យស្អាតរំឭកដល់ការទន្ទេញនាមរបស់យើងទុកជានិច្ច ចូរជាអ្នកមានមេត្តា ជាអ្នកស្អាត បូជានិងធ្វើចិត្តឱ្យជាសមាធិ ចូរអ្នកជាគុរុ (គ្រូ) របស់មនុស្សទាំងឡាយ។

នានាក់សោមនស្សនឹងហេតុការណ៍នោះ៣ថ្ងៃ ហើយធ្វើដំណើរចេញពីព្រៃ ត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួន ចាប់ផ្តើមចែកទានឱ្យដល់មនុស្សក្រខ្សត់ ឱ្យថ្នាំនឹងជួយរក្សាដល់អ្នកជំងឺឈឺចាប់ជាបឋមកិច្ច។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦១)

សម័យនោះ ការគ្រប់គ្រងរបស់ខេត្តបញ្ចាបគ្មានរបៀបរៀបរយ អ្នកមានអំណាចសង្កត់សង្កិនអ្នកតូច តុលាការមិនយុត្តិធម៌ អ្នកគ្រប់គ្រងស្រុកទេសជាអ្នកប្រហារពុំមាន សច្ចៈចំពោះប្រជាជន រោគភ័យជំងឺរាតត្បាត សេចក្តីសុខនិងសេចក្តីស្ងប់គ្មាន។ នានាក់តាំង ខ្លួនជាគ្រូត្រាច់ចរប្រៀនប្រដៅមនុស្ស តាំងខ្លួនជាគ្រូពេទ្យ ព្យាបាលមនុស្ស និងដើរណែនាំ ផ្តល់សេចក្តីយុត្តិធម៌ឱ្យដល់មនុស្សទាំងឡាយ នានាក់លះបង់សម្បត្តិផ្ទាល់ខ្លួនទាំងអស់ ដើរ ត្រាច់ចរនិងស្លៀកពាក់តែងខ្លួនតែមួយបន្ទាស់ប៉ុណ្ណោះ។

ការប្រតិបត្តិតមក នានាក់តាំងជាអ្នកមូស្លីមនិងហិណ្ឌូ សម្តែងខ្លួនជាមូស្លីមនិងហិណ្ឌូក្នុងពេលជាមួយគ្នា ឃើញបានអំពីគ្រឿងតែងខ្លួនក្នុងពេលចេញប្រៀនប្រដៅមនុស្ស នានាក់ពាក់អាវពណ៌ស្វាទុំ ដែលជាពណ៌សម្តែងឥស្សរភាពតាមលទ្ធិហិណ្ឌូ ពាក់ផ្កាំធ្វើអំពីឆ្អឹងជាប់នឹងក និងផ្តិតចិញ្ចើមផ្កាក្រអូបតាមបែបហិណ្ឌូ តែពេលជាមួយគ្នាពាក់មួកតាមបែបមូស្លីម។

គ្រឿងសំគាល់ការតែងខ្លួន ដែលនានាក់សម្តែង ដើម្បីទាក់ទាញសាសនិកទាំងពីរផ្នែក ឱ្យទទួលគតិកណ្តាល មិនប្រកាន់យកសាសនាណានីមួយៗ ដែលជាហេតុនៃការស្អប់ខ្ពើមតូះតិះដៀលទាំងពីរផ្នែក។

នានាក់ប្រៀនប្រដៅថា "សិក្ខជាសាសនារបស់អ្នកទាំងឡាយ ព្រះជាម្ចាស់ជាអ្នកប្រាសចាកអំពីភ័យអន្តរាយ ប្រាសចាកអំពីពៀរវេរា មិនមែនជាអ្នកបំផ្លាញ ជាអ្នកកសាង

យើងពុំមែនជាព្រះជាម្ចាស់របស់មូស្លីម យើងមានព្រះជាម្ចាស់តែមួយអង្គ ជាព្រះជាម្ចាស់នៃលោកទាំងមូល ព្រះអង្គមិនបានបង្កើតវណ្ណៈឬពណ៌សម្បុរ ឬលទ្ធិដែលបានបំបែកបញ្ញត្តិចេញទៅជាបែបទីមួយៗ ព្រះអង្គពុំមានការស្អប់ខ្ពើម ពុំមានការជេរប្រទេច ពុំមានការដាក់បណ្តាសាដូចព្រះជាម្ចាស់អង្គណាៗទេ”។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦២)

“ព្រះជាម្ចាស់របស់យើងពុំមាន (អាយុ) កំណត់ ព្រះអង្គរស់នៅទីនេះជារៀងរហូតសូម្បីក្នុងពេលបច្ចុប្បន្ន ព្រះអង្គពុំមានកំណើត ទ្រង់គង់នៅតែឯកឯងរបស់ព្រះអង្គ យើងអាចចូលដល់ព្រះអង្គដោយការអនុគ្រោះពីគ្រូបាអាចារ្យ (បានដល់រូបនានាក់ជាបឋម)”។

“ព្រះជាម្ចាស់របស់យើង ពុំមានអ្នកណាតែងតាំងទ្រង់ទេ ព្រះអង្គគង់ប្រថាប់ នៅតែឯកឯងមួយអង្គ ពុំមានរបស់បិទបាំងឡើយ ព្រះអង្គប្រាសចាកពីសេចក្តីស្លាប់ ប្រាសចាកពីសេចក្តីកើត ប្រាសចាកជាតិត្រកូលជា អ្នកដែលមិនមានអ្នកណាដឹងបាន ប្រាសចាករូបនិងលក្ខណៈ ខ្ញុំចូលទៅកាន់ព្រះអង្គ ក៏បានជួបព្រះអង្គខាងក្នុងរបស់ដែលប្រកបទៅដោយរូបគ្រប់យ៉ាង។

សាស្តារបស់សាសនាសិក្ខ ក្នុងកាលតមកប្រមូលពាក្យប្រៀនប្រដៅរបស់នានាក់គុរុអ្នកដែលជាបឋមសាស្តា និយាយដោយរួមគោលការណ៍របស់សិក្ខបំព្រួញមក ជាគោលធំ៤គឺ ១-សាមគ្គី, ២-ស្នេហាភាព, ៣-សទ្ធា, ៤-សេចក្តីស្រឡាញ់ (ភក្តី)។

គោលការណ៍ពីខាងដើមសម្តែងមតិ និងសេចក្តីសម្ព័ន្ធរវាងមនុស្សនិងព្រះជាម្ចាស់ (មួយអង្គនោះ) និង សេចក្តីសម្ព័ន្ធរវាងមនុស្សផងគ្នា ចំណែកគោលការណ៍២ខាងក្រោមសម្តែងមតិឬផ្លូវប្រតិបត្តិ ដែលមនុស្សនឹងគប្បីប្រតិបត្តិ ដើម្បីសម្រេចសេចក្តីសុខក្សេមក្សាន្តថ្នាក់ចុងក្រោយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៣)

## ការធ្វើដំណើរប្រៀនប្រដៅ

ព្រោះត្រូវការឱ្យមូស្លីមនិងហិណ្ឌូ ដែលកំពុងវិវាទគ្នាពីរឿងសញ្ជាតិនិងសាសនាសម្ព័ន្ធចូលគ្នា ក្នុងឋានៈដែលខ្លួនជាហិណ្ឌូ នានាក់ទើបព្យាយាមបង្រៀនឱ្យពួកមូស្លីមជ្រះថ្លាក្នុងឱវាទរបស់ខ្លួនឱ្យច្រើនបំផុត។ អាចារ្យ និងសិស្សចេញដំណើរទៅបង្រៀនតាមទីក្រុងផ្សេងៗ ក្នុងជម្ពូទ្វីបភាគខាងជើង ទៅដល់ខេត្តកុរុក្សេត្រហរិវារ, បាណិប័ត, ដេលី, វរិនទវរ័ន, គោរក្ខមាត, ពារាណសី, រហូតដល់ជួរជងទន្លេព្រហ្មបុត្រដែលជាមជ្ឈមណ្ឌល របស់សាសនាហិណ្ឌូ ឡើងទៅបង្រៀនដល់ខេត្ត (កស្សមីរៈ) និងប៉េសាវ៉ាក្នុងបច្ចុប្បន្ន។

ប្រៀនប្រដៅតាមខេត្តទាំងនោះរហូត១២ឆ្នាំ មានអ្នករាប់អានយ៉ាងច្រើន កាលបើឃើញផលអំពីខាងក្រៅនានាក់ ក៏ចូលមកកាន់ខេត្តបញ្ចាបដែលជាភូមិដ្ឋានកំណើតរបស់ខ្លួនៗ នានាក់ប្រៀនប្រដៅអស់មួយរយៈ បានផលតាមសេចក្ដីបំណង ចេញធ្វើដំណើរចូលទៅកាន់ឥណ្ឌាខាងត្បូងចុះទៅដល់ខេត្តមទូរាជ ដែលជាមជ្ឈមណ្ឌលរបស់លទ្ធិជេន ឆ្លងទៅដល់កោះលង្កា បានប្រៀនប្រដៅលទ្ធិថ្មីរបស់ខ្លួនថ្វាយព្រះរាជា និងព្រះរាជនីនៃកោះលង្កានៅមានលក្ខដ្ឋានថា នានាក់ចេញទៅបង្រៀនតាមកោះផ្សេងៗ ក្នុងមហាសមុទ្រឥណ្ឌាទៀតជាច្រើនកន្លែងៗ

ទីសំខាន់ដែលនានាក់ធ្វើដំណើរទៅប្រៀនប្រដៅលទ្ធិ "សាមគ្គីស្មើភាគ សទ្ធា និងសេចក្ដីស្រឡាញ់" របស់ខ្លួន គឺប្រទេសអារ៉ាប់ប៊ី នានាក់ធ្វើដំណើរទៅប្រៀនប្រដៅដល់ទីក្រុងមេក្កៈ ដែលជាមជ្ឈមណ្ឌលរបស់សាសនាឥស្លាម នានាក់បានឈ្មោះថា ជាសាស្ដាជាតិឥណ្ឌាដំបូងបង្អស់ដែលដើរធុតុង្គទៅដល់ទីក្រុងមេក្កៈៗ (ហេង គីមហោ*សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៤)

ចេញពីនគរមេក្កៈ នានាក់ធ្វើដំណើរប្រៀនប្រដៅជាលំដាប់លំដោយទៅដល់ទីក្រុងមេឌិនៈឆ្លងចូលទៅដល់ទីក្រុងបាកដាតក្នុងដែនដីអ៊ីរ៉ាក់ៗ នៅទីនោះនានាក់ប្រៀនប្រដៅម្ដងទៀត អ្នកស្ដាប់ទាំងអស់ជាមូស្លីម ក្នុងពេលកំពុងប្រៀនប្រដៅ មានស្រែកសួរមកថា លោកជាអ្នកណា លោករាប់អានសាសនាប្រភេទណា? នានាក់ឆ្លើយថា "គឺខ្ញុំគុរុ ខ្ញុំធ្វើដំណើរមកទីនេះដើម្បីនាំយកវត្ថុសួស្ដីមកឱ្យប្រជាជន ខ្ញុំបដិសេធនិកាយក្នុងសាសនាផ្សេងៗទាំងអស់ ខ្ញុំមិនរាប់អាននិកាយណាទេ ព្រះជាម្ចាស់តែមួយព្រះអង្គ មួយអង្គប៉ុណ្ណោះជាទីរាប់អានរបស់ខ្ញុំ ខ្ញុំរាប់អានព្រះអង្គក្នុងផែនដីនេះ ក្នុងសួគ៌និងក្នុងទីទាំងពួង"ៗ

ការធ្វើដំណើរប្រៀនប្រដៅរបស់គុរុនានាក់ ក្នុងរយៈផ្លូវដ៏វែងឆ្ងាយនិងកន្ទារ (ផ្លូវលំបាក) ពេញទៅដោយការគ្រោះថ្នាក់ ដូចគ្នានឹងដើរផ្សាយសាសនាគ្រិស្តរបស់សិស្សសំខាន់ៗនៃយេស៊ូគ្រិស្តគឺ សាំង ប៉ូល (Saint Paul) ដែលនិយាយនៅខាងមុខទៀតៗ

ជីវិតរបស់គុរុនានាក់ប្រកបដោយការគ្រោះថ្នាក់ក្នុងរវាងនៃការធ្វើដំណើរប្រៀនប្រដៅ ត្រូវគេធ្វើបាប ធ្លាប់បានទទួលទោសពីអ្នកមានអំណាច ធ្លាប់មានបដិហារិយ៍ ដើម្បីសេចក្ដីស័ក្ដិសិទ្ធិជាបុគ្គលាធិដ្ឋាន ដូចគ្នានឹងសាស្ដាក្នុងសាសនាដទៃ សូម្បីមានឧបសគ្គទាំងនេះ

ដោយប្រការណាក្ដី ក៏គុរុនានក់មិនព្រមរុញរាដែរ ជាអ្នកប្រកបដោយខន្តីធម៌ និងមេត្តាធម៌ជាអវសាន។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៥)

**អវសានគុរុនានក់**

សេចក្ដីប្រាកដក្នុងគម្ពីរគន្ថ: (ក្រាន្ថ) វគ្គទី១៨៧.១៨៨ និង១៩០.១៩១ របស់លទ្ធិនេះពិពណ៌នា អវសាននៃសាស្ដារបស់ខ្លួនថា "គុរុនានក់ដឹងអវសានរបស់ខ្លួន កាលពេលកាន់តែជិតមកដល់ ក៏ប្រគល់ធុរៈការងារឱ្យដល់អគ្គសាវ័កម្នាក់ឈ្មោះ ឡាហិនា (Lahina) សេចក្ដីពិតគុរុនានក់មានការតាំងចិត្ត និងប្រគល់ការងារផ្សេងៗឱ្យបុត្រប្រុស តែបុត្រប្រុសជាអ្នកមានបាប តឹងរឹងក្នុងលទ្ធិហិណ្ឌូមិនអាចផ្លាស់ប្ដូរគំនិតមកកាន់អានលទ្ធិរបស់បិតាបាន មាននិយាយថាគុរុនានក់ មិនអាចជួយដល់កូនរបស់ខ្លួនឱ្យមកកាន់អានលទ្ធិដែលខ្លួនប្រកាស ជាហេតុមួយនាំឱ្យកើតវិប្បដិសារី ពេលជិតដល់អវសានកាល។

សេចក្ដីក្នុងគម្ពីរសម្ដែងប្រវត្តិទាក់ទងនិងអភិនិហារទុកថា កាលបើជិតអវសានហើយគុរុនានក់ទន់ខ្សោយ ចូលទៅសម្រាកក្រោមដើមព្រឹក្សាមួយដើមនៅតំបន់គាតេបុរៈ ខេត្តបញ្ចាប ពេលនោះព្រឹក្សាចេញផ្កាស្លឹកខៀវស្រស់បំព្រងនៅពេញដើម ទទួលនិងបូជាលោកគុរុឱ្យឃើញជាការអស្ចារ្យ។

មានសាវ័កជាមូស្លីមនិងហិណ្ឌូចូលមកប្រជុំគ្នាយ៉ាងណែនណាន់តាន់តាប់ ដើម្បីរង់ចាំព្យាបាល កាលបើគ្មានសង្ឃឹមថា ជីវិតរបស់អាចារ្យមិនយឺនយូរទៅទៀត សាវ័ករបស់មូស្លីមទើបនិយាយថា បើអាជារ្យដល់ទីបំផុតហើយ នឹងនាំសពយកទៅកប់តាមបែបមូស្លីម។ សាវ័កខាងហិណ្ឌូបានឮក៏មិនព្រម ជំទាស់ថានឹងសូមជាអ្នកប្រកបពិធីសពរបស់អាចារ្យ តាមបែបទំនៀមទម្លាប់ហិណ្ឌូ (បូជា)។ លោកគ្រូបានឮសាវ័កឈ្លោះប្រកែកគ្នាទើបហាម សូមកុំឱ្យវិវាទអី សូមឱ្យសាវ័កផ្នែកហិណ្ឌូនាំផ្កាយកមកដាក់លើសពខាងស្ដាំ ឱ្យពួកមូស្លីមយកផ្កាមកដាក់ខាងឆ្វេងរង់ចាំរហូតព្រឹកឡើង ពីពេលដែលដាច់ខ្យល់ ផ្ការបស់អ្នកណារីក មុនឱ្យសពជារបស់អ្នកនោះ ចុះតអំពីនោះសូមឱ្យសាវ័កសូត្រមន្ត ឯខ្លួនឯងទាញសំពត់មួយ ផ្ទាំងឃុំរាងកាយជិតអស់តាំងសិរត្ថោះមុខទៅរកព្រះជាម្ចាស់ មានអគ្គសាវ័កអង្គុយនៅក្បែរ ខាងព្រមដោយសាវ័កផ្សេងទៀតរហូតទាល់តែព្រឹកឡើង សាវ័កបើកសំពត់ឃុំនោះចេញប្រាកដថា រាងកាយរបស់អាចារ្យបាត់សូន្យទៅហើយ ផ្កាទាំងពីរខាងរីកព្រមគ្នាជាការអស្ចារ្យ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៦)

សាវ័កទាំងពីរផ្នែកធ្វើពិធីប្រាសចាកសពអាចារ្យ កសាងជាបូជនីយដ្ឋានទុកត្រង់បរិវេណអវសានជីវិតរបស់អាចារ្យមួយកន្លែង និងនៅមាត់ស្ទឹងអាវី ដែលជាកន្លែងកំណើតរបស់អាចារ្យមួយកន្លែងទៀត។

**សាស្តានៃសាសនាសិក្ខ**

ដើម្បីសម្តែងពាក្យប្រៀនប្រដៅរបស់សាសនាសិក្ខនឹងនិយាយប្រវត្តិនៃសាស្តា តាមដែលមានប្រាកដ ចំនួន ១០ រូបគឺ ៖

១-គុរុនានក់មុនពេលអស់អាយុសង្ខារ មិនអាចពឹងពាក់កូនប្រុស២នាក់ជាអ្នកបន្តនូវលទ្ធិរបស់ខ្លួនបាន គុរុនានក់ទើបប្រកាសតែងតាំងសិស្សដែលជាទីស្រឡាញ់របស់ខ្លួនម្នាក់មានអាជីវៈវេញខ្សែលក់ឈ្មោះឡាហិនា (Lahina) ជាអ្នកបន្ត មនុស្សមានការលះបង់ចំពោះលោកគុរុរហូតមក លោកទើបផ្លាស់នាមឱ្យជាថ្មីថាអង្គ័ត (Angad) ប្រែថាអ្នកលះបង់រាងកាយ (Body Giving)។

២-គុរុអង្គ័ត (ព.ស.២០៨១-២០៩៥) ជាអ្នកភាសាសាស្រ្ត អាចផ្សព្វផ្សាយពាក្យប្រៀនប្រដៅរបស់អាចារ្យទៅបានជាជាងគុរុណាៗទាំងអស់ ជាអ្នកមុនដំបូងគេ ដែលណែនាំសាវ័កឱ្យរាប់អានគុរុនានក់ថា ជាព្រះជាម្ចាស់មួយអង្គ។

៣-គុរុអមារ៍ដាស (Amardas ព.ស.២០៩៥-២១១៧) លោកម្នាក់នេះជាមនុស្សស្លុតបូត បានតាំងអង្គការលទ្ធិសិក្ខឡើងជាច្រើន បានឈ្មោះជាអ្នកផ្តួចផ្តើមលទ្ធិសិក្ខទុកយ៉ាងខ្ជាប់ខ្ជួន។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៧)

៤-គុរុរាមដាស (Ramdas ព.ស.២១១៧-២១២៤) លោករូបនេះជាអ្នកសាងមជ្ឈមណ្ឌលរបស់លទ្ធិមួយកន្លែងឱ្យឈ្មោះថា "ហរិមន្ទី" គឺវិហារសិក្ខទុកក្នុងទន្លេសាបតូចៗមួយកន្លែងប្រហែល៣០ម៉ៃល៍ខាងទិស អាគ្នេយ៍នៃខេត្តឡាហ៊័រ ទីកន្លែងនេះហៅថាអម្រិតស្រះ (Immortal Pond) ក្លាយទៅជាទីបំពេញកុសល។ មជ្ឈមណ្ឌលរបស់លទ្ធិសិក្ខដូចគ្នានឹងទីក្រុងមេក្កៈមជ្ឈមណ្ឌលសាសនាអ៊ិស្លាមបានតាំងបែបបទទុកថា អ្នកបន្ត តំណែងគុរុចាំបាច់ ត្រូវជាប់ជាខ្សែស្រឡាយខ្លួនឯង ដូច្នេះទើបតែងតាំងកូនប្រុសរបស់ខ្លួន ជាគុរុបន្តមកទៀត។

៥-គុរុអរជុន (Arjun ព.ស.២១២៤-២១៤៩) ជាអ្នកប្រមូលគម្ពីរក្នុងលទ្ធិសិក្ខបានច្រើនជាងគេទាំងអស់ គម្ពីរប្រមូលស្រង់អំពីឱវាទរបស់គុរុ៤រូបដែលបានមានឈ្មោះពីដើម និងបន្ថែមឱវាទរបស់ខ្លួនក្នុងគម្ពីរផង។ ជាអ្នកចេញបញ្ញត្តិថា ជនជាតិសិក្ខត្រូវតែតែងខ្លួនតាម

បែបសាសនានិយម មិននិយមតែឯខ្លួនដោយរបស់មានតម្លៃ តាំងច្បាប់ក្បួនទារពន្ធ ដើម្បីទំនុកបម្រុងសាសនា បានឈ្មោះថាជាអ្នកផ្សព្វផ្សាយលទ្ធិបានយ៉ាងទូលំទូលាយ កសាង "ហារិមន្ទីរ" ឡើងទៅជាសុវណ្ណវិហារបាត់បង់ជីវិតក្នុងការតស៊ូនឹងក្សត្រិយ៍មូស្លីមអ្នកគ្រប់គ្រងក្រុងដេលី។

៦-គុរុហៅរិគោវិន្ទ (Hsri Coird ព.ស.២១៤៩-២១៨១) ជាគុរុជំបូងដែលឱ្យសិក្ខនិយមប្រើដាវ ឱ្យកាន់ដាវដើម្បីសំគាល់ជាជនជាតិសិក្ខ អ្នកតឹងរឹងក្នុងសាសនា អ្នកផ្តុំផ្តើមកម្លាំងទាហាន បង្ហាត់ឱ្យជនជាតិសិក្ខជាអ្នកក្លាហានតទល់នឹងសត្រូវឈ្លានពានរុករានទឹកដីរបស់ខ្លួន។

៧-គុរុហារិរៃ (Hari Rail ព.ស.២១៨១-២២០៧) លោករូបនេះពុំមានប្រវត្តិពិសេសឡើយ ក្រៅអំពីចម្បាំងតទល់ជាមួយឱរំាងសេហ្វក្សត្រិយ៍មូស្លីម។

៨-គុរុហរិកិសាន់ (Hari Kishan ព.ស.២២០៧-២២១៨) មានដំណើរការផ្សព្វផ្សាយលទ្ធិដោយតស៊ូនឹងក្សត្រិយ៍ ឱរំាងសេហ្វដូចគុរុអ្នកមុនៗដែរ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៨)

៩-គុរុទេពបាហាទូរ៍ (Tegh Bahadur ព.ស.២២១៨-២២២៩)ជាអ្នកចម្បាំងខ្លាំងក្លាអាចទប់ទល់ការរុករានរបស់ក្សត្រិយ៍ឥស្លាមដែលចូលមកគ្រប់គ្រងឥណ្ឌានិងគម្រាមកំហែងសាសនាដទៃ ផ្សព្វផ្សាយសាសនាសិក្ខបានទូលំទូលាយរហូតទៅខេត្តទិសពាយ័ព្យរបស់ប្រទេសឥណ្ឌា និងចុះមកទិសខាងត្បូងរហូតដល់កោះលង្កា គុរុនេះតទល់នឹងឥស្លាមគ្រប់មធ្យោបាយ មូស្លីមក្នុងសម័យនោះមិនមានសេចក្តីក្លាហានតស៊ូនឹងគុរុនេះ។

១០-គុរុគោវិន្ទសិង្ហ (Covind Singh ព.ស.២២២៩-២២៥១) ជាបុត្ររបស់គុរុទេពពាហាទូរ៍ជាអ្នកតាំងបញ្ញត្តិថ្មីក្នុងសាសនាសិក្ខ ដោយវិធីបណ្តុះបណ្តាលចិត្តសិស្សានុសិស្សឱ្យទៅជាអ្នកចម្បាំងតស៊ូជាមួយនឹងក្សត្រិយ៍មូស្លីម ចូលមកជិះជាន់សាសនាអ្នកដទៃ។ ដើម្បីនឹងលើកស្ទួយជាតិគោវិន្ទសិង្ហ តាំងមជ្ឈមណ្ឌល សម្រាប់ផ្សព្វផ្សាយលទ្ធិរបស់ខ្លួននៅទីក្រុងដាក្កា (Dacca) និងខេត្តអស្សមក្នុងបង់ក្លាដេសខាងកើត ប្រកាសដល់សិស្សានុសិស្សទាំងឡាយថា លោកគ្រប់គ្នាត្រូវតែជាអ្នកចម្បាំងនឹងសត្រូវ ដើម្បីលើកស្ទួយជាតិសាសនារបស់ខ្លួន សិក្ខគ្រប់គ្នាត្រូវតែជាអ្នកក្លាហាន ពាក្យថាសិក្ខ "គឺជាអត្ថន័យនៃពាក្យក្លាហាន ជាឈ្មោះ

បន្តខាងចុងរបស់ខ្លួនជាជាតិសិក្ខ តាំងអំពីនោះមកនិង "សិក្ខ" គ្រប់គ្នាត្រូវរួមគ្នាជាគ្រួសារមួយបរិសុទ្ធ (ក័ល្ស-Khalsa)។

គុរុគោវិន្ទសិង្ហជាអ្នកផ្តើមលទ្ធិសីលជ្រមុជទឹក (Baptismal Rite) ឡើងក្នុងលទ្ធិជាអ្នកប្រកបពិធីឱ្យអ្នក ចូលមកជាសិក្សានុសិស្សដោយវិធីប្រោះព្រំទឹកមន្តនិងវិធីឱ្យផឹកមន្តស័ក្តិសិទ្ធិដែលមានដាវមុតជ្រលក់ជាសញ្ញាថា អ្នកផឹកជាអ្នកក្លាហាន ទឹកផឹកនេះហៅថា "ទឹកអម្រឹត" អ្នកបានផឹកស្មើគ្នានឹងបានទៅដល់សេចក្តីសុខ (កល្សព្រមព្រៀងគ្នាចេញច្បាំងដើម្បីលើកស្ទួយជាតិសាសនា)។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៦៩)

មានប្រវត្តិប្រកបរឿងផ្តើមលទ្ធិពិធីនេះថា "សីលជ្រមុជទឹក" របស់គុរុវិន្ទសិង្ហដូច្នេះ ៖

ក្សត្រិយ៍មូស្លីមអ្នកមានអំណាចព្រះនាម ឱរាំងសេប្ង ចូលមកគ្រប់គ្រងឥណ្ឌាគម្រាមជាតិសាសន៍ដទៃ ពុំមានអ្នកចម្បាំងពួកណាអាចបង្ក្រាបឱរាំងសេប្ងបាន គុរុគោវិន្ទសិង្ហទើបបង្ហាត់សិស្សានុសិស្សមួយក្រុមឡើង ធ្វើសច្ចាប្រណិធាន និងតស៊ូជាមួយសត្រូវដែលមានកម្លាំងច្រើនជាង។ លុះសិស្សគ្រប់គ្នាចូលមកទីប្រជុំហើយ គុរុគោវិន្ទសិង្ហឱ្យដងទឹកពីទន្លេម្នាក់មួយផ្ទាំង ចាក់ចូលទៅក្នុងភាជនៈដ៏ធំមួយ ហើយយកដាវប្រចាំខ្លួនរបស់ គាត់មកជ្រលក់កូរទឹកបរិកម្មមន្តជាក្បួនឱវាទរបស់គុរុមុនៗ ទឹកនោះហៅថា "ទឹកអម្រឹត" ស្រោចទឹកអម្រឹត លើក្បាលរបស់សិស្ស និងឱ្យផឹកទឹកនោះ៣ដង រាប់ថាជាពិធីទទួលសីលអកាលី (ពុំមានកាលជានិរន្តរជាសព្វ នាមរបស់ព្រះជាម្ចាស់) ដែលបានបញ្ញត្តិឡើងថ្មី។

កាលបើសិស្សផឹកទឹកអម្រឹតហើយ លោកគុរុឱ្យសីល២១ ខជាសីលប្រចាំជីវិតរបស់ជនជាតិសិក្ខគឺ ៖

១-រាប់អានសាស្តាគ្រប់រូបជាបិតានិងប្រកាន់ខ្លួនជាបុត្រនៃសាស្តានោះ

២-រាប់អាននានកបុរៈទីកំណើត និងគាតេបុរៈខេត្តបញ្ចាបកន្លែងស្លាប់របស់បឋមសាស្តាជាបូជនីយដ្ឋាន

៣-លើកលែងប្រកាន់ជាន់វណ្ណៈ

៤-ហាមឈ្លោះវិវាទរវាងសិស្សជាមួយគ្នា

៥-ព្យាយាមពលីជីវិតក្នុងសមរភូមិ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៧០)

៦-បូជាវត្ថុស័ក្តិសិទ្ធិ៣ប្រការគឺ ៖

ក. ព្រះជាម្ចាស់ជាអ្នកសច្ចៈ ជាសីល ជាអកាល។

ខ. សាសនានៅវាទរបស់គុរុទាំងឡាយ

គ. សេចក្តីបរិសុទ្ធ

៧-មាន "ក" ៥ ទុកជាមួយខ្លួន កង្ខា (កងដែក) កច្ឆា (ខោជើងខ្លី) កេស (សក់) កង្ឃា (ស្និត) និង ឫបាណ (ដាវ)

៨-វៀរចាកមុសាវាទ

៩-វៀរចាកសេចក្តីក្រោធ លោភៈ មោហៈ និងរាប់អានកិរិយារបស់អ្នកទុកស្មើដូចមាតា។

១០-វៀរចាកកុំទាក់ទិនជាមួយអ្នកបរបក្សរបស់សាសនា។

១១-អ្នកណាមិនគាំពារចម្បាំង (ដើម្បីជាតិសាសនា) កុំសេពគប់នឹងអ្នកនោះ។

១២-ហាមមិនឱ្យប្រើពណ៌ក្រហម ដូចជាសម្លៀកបំពាក់ពណ៌ក្រហម (ក្រៅអំពីពណ៌ក្រហមសិក្ខ ប្រកាន់ថា ជាសញ្ញានៃសេចក្តីស្រឡាញ់និងមេត្តា ជាអារម្មណ៍ទំនាស់នឹងអារម្មណ៍) ដល់និស្ស័យអ្នកចម្បាំង។

១៣-ឱ្យប្រើជាពាក្យថា "សិង្ហ" បន្តក្រោយឈ្មោះខ្លួនតាំងពីឥឡូវនេះតទៅ។

១៤-កុំទុកក្បាលទំនេរក្រៅអំពីមុជទឹក។

១៥-វៀរចាកលេងល្បែងភ្នាល់។

១៦-ហាមកាត់ឬកោរសក់ ពុកមាត់ ពុកចង្កា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៧១)

១៧-ហាមទាក់ទងនឹងមនុស្សបៀតបៀននឹងជាតិសាសនា។

១៨-ឱ្យប្រកាន់ការជិះសេះ កាប់ដាវ និងប្រដាល់ចំបាច់ជាកិច្ចដែលត្រូវធ្វើជានិច្ច។

១៩-ឱ្យប្រកាន់ថាកើតមកដើម្បីឱ្យសេចក្តីសុខដល់អ្នកមានទុក្ខ និងធ្វើសេចក្តីចម្រើនដល់ជាតិសាសនា។

២០-វៀរចាកការហ៊ឺហារគ្មានសារប្រយោជន៍។

២១-ឱ្យប្រកាន់ថាការសេពគប់ជាមួយព្រះជាម្ចាស់ អ្នកជាអកាលនិងការសក្ការៈបូជាអ្នកដែលជាភ្ញៀវ ជាកិច្ចដែលគួរធ្វើ។

សេចក្តីបន្ថែម ៖ រឿង "ក" ៥ប្រការ (សីល១៧) ដែលសាស្តាគុរុគោវិន្ទសិង្ហបញ្ញត្តិដោយមានបំណងអប់រំជនជាតិសិក្ខឱ្យទៅជាទាហានដោយនិស្ស័យ មិនមែនជាហេតុ ការណ៍បន្ទាប់ "ក" ៥ប្រការមានផលសំខាន់ដូច្នេះ ៖

១-កឌា (ការា) កងដែលបំណងឱ្យជាខដាស់ចិត្តទាហានថា ដែលជាលោហមានតម្លៃណាស់ (ខាងការលក់ដូរនិងប្រើជាអាវុធ)។

២-កច្ឆា ខោខ្លី ក្រៅអំពីប្រពៃណីជនជាតិឥណ្ឌានិយមស្លៀកធោតី (សំពត់រុំខ្លួនវែងតាំងពីឃ្លៀករហូតដល់កជើង) មិនស្រួលក្នុងការធ្វើចម្បាំង ទើបឱ្យប្រើខោខ្លី។

៣-កេស សក់ មានន័យថាឱ្យទុកសក់វែង មានហេតុផលសំខាន់៣ប្រការគឺ ដើម្បីជាគ្រោះពាក់លើក្បាល (ដោយសក់) និងដើម្បីមើលទៅគួរឱ្យខ្លាច បំផ្លាញកម្លាំងចិត្តរបស់សត្រូវ។

៤-កង្ឃា សនិត កាលបើអនុញ្ញាតឱ្យទុកសក់វែងក៏ត្រូវមានស្និតសម្រាប់សិតសក់ជាគូដែរ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ ១៧២)

៥-ឬបាណ ដាវ ប្រយោជន៍របស់ដាវសម្រាប់អ្នកចម្បាំង ជារបស់ឃើញច្បាស់ហើយ កាលអង់គ្លេសគ្រប់គ្រងឥណ្ឌា ពួកសិក្ខនៅមិនព្រមចោលដាវ ក្នុងទីបំផុតអង់គ្លេសត្រូវច្បាប់ពិសេសលើកលែងទោសអនុញ្ញាត ឱ្យជាតិសិក្ខ សៀតដាវបាន។ កាលដែលមិនទុកឱ្យនៅទំនេរ (សីល១១៤) ក្រៅអំពីមុជទឹក មានន័យថា ទាហានរមែងមិនព្រមបើកមួកឱ្យអ្នកណា ហើយប្រការមួយទៀតឱ្យស្គាល់ខ្លួនឯងជានិច្ចថាជាទាហាន។

គម្ពីរក្នុងសាសនាសិក្ខហៅថា ក្រាន្ថសាហិបឫគន្ថ: (ក្នុងភាសាបាលី) មានន័យថាគម្ពីរឬសៀវភៅផ្នែកធំ គឺពាក្យកាព្យខ្លីៗរួមមាន ១.៤៣០ទំព័រ មានពាក្យមិនតិចជាង លានពាក្យ មាន៥.៨៩៤ ភាសិត ភាសិតទាំងនេះ ចូលជាទំនងបទភ្លេងនិងចម្រៀង រហូតដល់ ៣០សាខា ប៉ុន្តែស្មានជាក្បាល៣៧ក្បាល ភាសាដែលប្រើក្នុងគម្ពីរ មានប្រមាណជា៦ភាសា ភាសាជាគោលគឺភាសាបញ្ជាបបី (ភាសាប្រចាំខេត្តបញ្ជាបដែលជាកន្លែងកើតសាសនា) ប៉ែក្ស, ប្រាក្រិត, ហិណ្ឌីនិងមារាថី។

សាសនិកសិក្ខបុរាណប្រមាណ ៩០ ភាគរយ ដូចគ្នានឹងសាសនិកក្នុងសាសនាដទៃដែលមិនធ្លាប់ចេះដឹងក្នុងសាសនារបស់ខ្លួន គម្ពីរដីកាទើបក្លាយជាវត្ថុស័ក្តិសិទ្ធិ អ្នកដែលគ្មានការទាក់ទងមិនអាចនឹងប៉ះពាល់បានឡើយ នៅទីកន្លែងហិរមន្ទីរឬសុវណ្ណវិហារ (Golden

Temple) ក្នុងក្រុងអម្រិត (Amritsar) ខេត្តបញ្ចាបមាន ទីប្រតិស្ឋានគម្ពីរទុកជាមជ្ឈមណ្ឌលសាសនារបស់សិក្ខទាំងឡាយ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៧៣)

ក្នុងវិហាររបស់សាសនាសិក្ខបង្គាប់មិនឱ្យមានរូបភាពគោរពក្រៅអំពីគម្ពីរមាននិយមឱ្យកាន់ថាជាវត្ថុស័ក្តិសិទ្ធិដូចគ្នានឹងការទ្រទ្រង់នៅរបស់ព្រះជាម្ចាស់ ឬស្មើនឹងតួអង្គរបស់ព្រះជាម្ចាស់។ គ្រប់ពេលព្រឹកមុនពិធី សូត្រអ្នករក្សាព្រះវិហារ នាំសំពត់ប៉ាក់មានតម្លៃថ្លៃថ្មីមករុំព័ទ្ធគម្ពីរជាការប្តូរសំពត់រុំចាស់ធ្វើការសំអាតដាក់គម្ពីរលើតុបួនជ្រុង ឬទីបិទរនាំងប៉ាក់ជររំលេចដោយពេជ្រ។ លុះដល់ល្ងាចនាំគម្ពីរនោះទៅប្រតិស្ឋានលើជើងតាំងមាសក្នុងបន្ទប់ពិសេសមិនឱ្យកម្មេចកម្ទីឬធូលីប្រឡាក់បានឡើយ។

គម្ពីរដើម ឬបទដំបូងរបស់គម្ពីរហៅថាអាតិគន្ថៈរួបរួមដោយគ្រូអង្គទី៥គឺ គអរជុនស្រង់អំពីឱវាទនានាដែលគុរុអង្គដំបូងគឺនានក់ និងឱវាទរបស់សាសដទៃព្រមទាំងវាណី (ពាក្យភាសិត) របស់កគត្តគឺអ្នកប្រាជ្ញមាន ភក្តីលើសលប់ដល់លទ្ធិនេះទៀត១១រូប និងមានវាណីរបស់កគត្តអ្នកមានអាជីវប្រចាំត្រកូល មករួមទុកក្នុង អទិគន្ថៈផង។

សម័យតមកមានការរួបរួមឱវាទរបស់គុរុម្តងទៀតដោយលោកគោវិន្ទសិង្ហគុរុអង្គទី១០ ជ្រើសរើស ឱវាទទេគបាហាទូរគុរុអង្គទី៩ លោកជាបិតារបស់ខ្លួនរួមជាគម្ពីរគន្ថៈសាហិបដ៏បរិបូរណ៍។

**យ៉ាប ឬ យាប្ជី**

ការនិងយល់គម្ពីរគន្ថសាហិបដោយច្បាស់លាស់ ចាំបាច់ត្រូវយល់បទសូត្រនិងការប្រតិបត្តិតាមពាក្យបទបង្រៀន ដែលប្រាកដក្នុងគម្ពីរអទិគន្ថៈក្នុងវគ្គហៅថា យ៉ាប (Jab) ឬយាប្ជី (Japji) ផងដែរ។

យ៉ាបជាភាសាបញ្ចាបបីភាសាគោល ដែលសាស្តាគ្រប់អង្គត្រូវប្រើប្រៀនប្រដៅ ប្រែថា ការថា ការពោល ឬការទន្ទេញជាបណ្តូលពាក្យប្រៀនប្រដៅក្នុងសាសនា។ អធិប្បាយរឿងរបស់យ៉ាបជនជាតិសិក្ខគ្រប់គ្នា ត្រូវសូត្របរិកម្មគ្រប់វេលាព្រឹក។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៧៤)

យ៉ាបមាន៣៨បទ (ហៅថាប៉ៅរី Paori) ឬ៣៨ជាន់មានន័យថាសូត្រទៅបរិក ឬទៅ ម្តងមួយបទម្តងមួយជាន់ សារសំខាន់របស់យ៉ាប៣៨បទរួមហៅថាមូលមន្តរៈ (នឹងនិយាយ ខាងមុខ)។

អធិប្បាយទាក់ទងនឹងយ័បមាន៣៨បទ (៣៨ជាន់) នោះបើបរិកម្មទៅដល់បទទី៣៣និង ៣៤តគ្នា មានអធិប្បាយដល់លំដាប់នៃការប្រតិបត្តិឱ្យរួចផុតអំពីភពនេះ ដែលនឹងជូនឱ្យផល កើតបែបណាក្នុងភពខាងមុខ ការប្រតិបត្តិនេះហៅថាខណ្ឌ មាន៥គឺ ៖

១-ធម្មខណ្ឌ (ធម៌)

២-ញាណក្ខណ្ឌ (ញាណ)

៣-សរកម្មខណ្ឌ (សេចក្តីស្ងប់ចិត្ត)

៤-កម្មខណ្ឌ (កម្ម)

៥-សត្យខណ្ឌ (សច្ចៈ)

បើឱ្យអធិប្បាយរឿងយ័បឬបទសូត្ររបស់សមាគមស្រីគុរុសិង្ហសភា ដែលជាទីស្ថាន ទេសនា ពាក្យប្រៀនប្រដៅនេះហៅថា ក្នុងវគ្គជំបូងរបស់ប៉ៅរីទី៣៤(បទទី៣៤) ពោលដល់ ភពដែលបុគ្គលត្រូវប្រឈមមុខក្រោយ ពីលះបង់រាងកាយក្នុងភពនេះទៅហើយ និងទីស្ថាន នោះ (ជាទីពិភាក្សា) មានការវិនិច្ឆ័យជោគជតាកម្មដែលបុគ្គលប្រព្រឹត្តទុកកពមុនថា នឹងមាន ផលនៃការប្រតិបត្តិយ៉ាងណា។ ល។

ក្នុងការបរិកម្មប៉ៅរីទី៣៤ ប្រមាណវគ្គខាងចុងរបស់ប៉ៅរីនោះ ពិពណ៌នាអំពីភពខាង មុខម្តងទៀត ហៅភពនោះថា "សច្ចស្ថាន" (Hall of truth) ឬទីស្ថានពិភាក្សាសច្ចធម៌ដែលជា ថ្នាក់ចុងក្រោយហៅថាសច្ចខណ្ឌ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៧៥)

ខណ្ឌនីមួយៗមានអធិប្បាយសង្ខេបដូច្នេះ ៖

ធម្មខណ្ឌ គឺទាទីដែលគ្រប់គ្នាគប្បីប្រតិបត្តិ កាត់សេចក្តីកិច្ចការគ្រប់យ៉ាងដោយយុត្តិ ធម៌ឱ្យដឹងថាកិច្ចកម្ម អំពើធ្វើទុកក្នុងជីវិតនេះជាមូលហេតុឱ្យផលក្នុងភពតទៅ ៖

ញាណក្ខណ្ឌ គឺផ្នែកនៃសេចក្តីចេះដឹង បង្រៀនថាបុគ្គលត្រូវប្រើសេចក្តីចេះដឹងជា គ្រឿងប្រកបត្រូវ ប្រកបកិច្ចឱ្យបានធំដុំដូចគ្នានឹងរាមានិងក្រិស្ណៈ (អ្នកជាអវតាររបស់ព្រះវិស្ណុ) អ្នកសម្រេចសន្តិជានិរន្តរ៍ ព្រោះនាទីដែលប្រកបដោយញាណនោះ។

សរម្មខណ្ឌ (បើប្រៀបធៀបជាដួងវិញ្ញាណ) ធ្វូងចូលមកកាន់ភូមិរីករាយស្រស់ ស្រាយ ក្នុងភូមិនេះមានសេចក្តីសុខដុម ប្រាថ្នាសុខយ៉ាងណាបានតាមប្រាថ្នា សេចក្តីថោក ទាបលាមកគ្មាន មានតែសេចក្តីស្ងប់ចិត្តនិងសេចក្តីល្អ។

កម្មខណ្ឌជាភូមិនៃអំណាច អ្នកប្រតិបត្តិបានអំណាចជាពល្លិ ប្រដូចជាអ្នកមានកាយទិព្វ (ដែលបុគ្គលណាមិនអាចមើលឃើញបាន) មានលំអជានិរន្តរ៍ ប្រាសចាកសេចក្ដីកោតខ្លាចចំពោះម្រិត្យុវ រួចផុតពីការវិលវល់នៃការកើតនិងការស្លាប់ (ជាតិនិងមរណៈ)។

សត្យខណ្ឌ ជាភូមិនៃសច្ចៈ ជាភូមិចុងបំផុត ជាភូមិប្រាសចាករូបអ្នកប្រតិបត្តិ (ដួងវិញ្ញាណ) ចូលរួមទៅជាមួយមហាទេព អកាលបុរស គឺការចូលដល់ព្រះជាម្ចាស់ ឬភាវៈនៃព្រះជាម្ចាស់ (ទេពភាវៈ) ប្រហែលគ្នានឹងនិព្វានក្នុងពុទ្ធសាសនា។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៧៦)

ឥឡូវមកដល់មូលមន្តរៈរបស់យប្ជី មានអធិប្បាយលក្ខណៈនៃអកាលបុរស (ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់) ដូច្នេះ ៖

ឯក ឱង្ការ សត្យ នាម ករតា បុរុស និរភយ និរវេរ អកាល អមូរតិ អជូនី សៃភាង គុរុ បរសាទី។

ពាក្យពេចន៍ទាំងនេះ ជាគុណលក្ខណៈរបស់អកាយបុរស ដែលបានដល់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត តែអកាលបុរសនោះពុំមានលក្ខណៈដូចជាព្រះជាម្ចាស់សាសនាដទៃដែលបដិមាករជារូប។ អកាលបុរសក្នុងសាសនា សិក្ខប្រាសចាករូប ប្រាសចាកបែបជានាមធម៌និងជាសច្ចធម៌ មានន័យប្រហែលគ្នានឹងនិព្វានពុទ្ធសាសនា លំអៀងទៅខាងបរមាត្មន់ដូចព្រាហ្មណ៍ផងដែរ។

គុណលក្ខណៈតាមពាក្យពេចន៍នេះ អធិប្បាយដោយសង្ខេបដូច្នេះ ៖

ឯក មានន័យថាតែមួយ ជាអមតៈ ឬខ្ពស់បំផុតពុំមានរបស់អ្វីស្មើបាន ជាឯកពិត ប្រាកដ។

ឱង្ការឬឱម មានន័យថា អំណាចដ៏ស័ក្តិសិទ្ធិជាគ្រឿងការពារ ព្រះជាអ្នកគ្រប់គ្រង។ ឱង្ការឬឱម ជ្រៀតជ្រែកនៅក្នុងរបស់សព្វសារពើជានិរន្តរ៍ ប្រៀបដូចក្លិនតែងជ្រែកនៅក្នុងផ្កាយ៉ាងណាមិញ ឱមឬឱង្ការ រមែង ជ្រែកនៅក្នុងរបស់គ្រប់យ៉ាងដូច្នោះដែរ។

សត្យឬសច្ចៈ សំដៅយកសេចក្ដីពិត ឬភាវៈដែលពិតជាន់ខ្ពស់បំផុតដូចគ្នានឹងសច្ចៈជាន់ខ្ពស់នៅក្នុងសាសនាដទៃ ដូចជាសាសនានៅមានតៅជាបរមត្ថសច្ចៈ សាសនាព្រាហ្មណ៍ឬហិណ្ឌូ មានព្រហ្មឬបរិមាត្មន់ជា បរមត្ថសច្ចៈ សាសនាគ្រិស្តនិងអ៊ិស្លាម មានយៈហូវ៉ានិងអល្លោះហ៍ (អាល្លាហ៍) ជាបរមត្ថសច្ចៈនិងពុទ្ធសាសនា ព្រះនិព្វានជាបរមត្ថមសច្ចៈយ៉ាងណា

ម៉ិញ្ញសាសនាសិក្ខក៏មានអកាលបុរសជាបរមត្ថមសច្ចៈដូច្នេះ។ (ហេន គីមហោ *សាសនា ប្រៀបធៀប* ភាគ១ ទំព័រ១៧៧)

សាសនាសិក្ខបង្រៀនថា អ្នកដែលសង្រួមចិត្តសម្ងឹងដល់អកាលបុរស ដែលជាបរមត្ថសច្ចៈជានិច្ច អាច ចូលនៅក្នុងអកាលនោះ សំដៅដល់ការរួមគ្នាជាឯកភាព។

នាមគុណលក្ខណៈ១នេះ សំដៅដល់អកម្មនាម គឺមានដែលមិនបានកើតឡើង ព្រោះកម្ម មិនធ្លាក់ទៅក្នុងអំណាចរបស់កម្ម គ្រាន់តែជាកិរតិនាម (កិត្តិនាម) គ្រាន់ជាឈ្មោះបញ្ចេញឡើងដើម្បីជាកិត្តិយសព្រោះអាស្រ័យគុណលក្ខណៈដែលពោលមកហើយ និយាយម្យ៉ាងទៀតថា នាមធម៌។

ករតាឬកត្តា ន័យសេចក្ដីស្មើនឹងអ្នកសាង គឺជាអ្នកសាងរបស់ទាំងពួង។ សាសនាសិក្ខបង្រៀនថា ការដែលយើងអាស្រ័យនៅក្នុងលោក គួរនឹកដល់អ្នកសាងលោកឱ្យយើងអាស្រ័យនៅ១ៈ និងគួររំឭកជានិច្ចថា របស់អ្វីដែលកើតឡើងបានដោយពុំមានអ្នកធ្វើ មិនមានអ្នកសាង ពុំអាចមានឡើយ។

បុរុស ន័យសេចក្ដីក្នុងទីនេះថា ជាភាវៈពិសេសអាចជ្រៀតជ្រែកទៅបានក្នុងរបស់ទាំងពួងដែលទ្រទ្រង់សាង។

និរភយ មានន័យថាអកាលបុរសមិនខ្លាចអ្នកណា មិនធ្វើឱ្យអ្នកណាខ្លាច មិនសត្រូវនឹងអ្នកណា ពុំមានអ្នកណាជាសត្រូវ។

និរវេទ មានន័យថា ប្រាសចាកវេរា ប្រាសចាកសត្រូវបានដល់លក្ខណៈរបស់អ្នកមានតែសេចក្ដីស្រឡាញ់ និងមេត្តា។

អកាលមានន័យថា មិនទៅក្រោមកំណត់នៃកាលវេលា គឺការបិតទៅជានិរន្តរ៍ មិនមានកើត មិនមានស្លាប់ មិនមានដើម និងមិនមានទីបំផុតទើបជានិរន្តរ៍។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៧៨)

អមូរតិ បានដល់ការគ្មានរូប មានត្រឹមតែនាមប្រហែលនិព្វានរបស់ព្រះពុទ្ធ។

អជូនីឬអយោនី មិនមានកំណើត ពុំមានការទាក់ទងទៅនឹងហេតុ កាលបើមិនមានហេតុ រមែងមិនមានផល កាលបើមិនមានកើត រមែងមិនមានស្លាប់ ជាអមតៈ។

សៃភាង ពាក្យនេះចែកជាពីរសព្ទគឺ សៃ និង ភាង។ សៃ គឺពន្ទឺក្នុងភាសា បញ្ចាបបី ត្រង់នឹងសវកាយក្នុង ភាសាសំស្ក្រឹត និងសយំក្នុងភាសាបាលីប្រែថាខ្លួនឯង របស់ខ្លួនឯង

ឬដោយខ្លួនឯង។ ចំណែកភាគច្រើនមកពី ពាក្យដែលប្រែថា ពន្លឺដូច្នោះឯង សែភាគទើបមានន័យថាអ្នកមានពន្លឺភ្លឺថ្លា ឬអ្នកមានពន្លឺតាំងនៅក្នុងខ្លួនឯង។

គុរុបរសោទ មានន័យថាជាអ្នកឱ្យការសិក្សា កាលបើជាអ្នកឱ្យការសិក្សាក៏ប្រហែលគ្នានឹងគ្រូ គុណលក្ខណៈនៃគ្រូគឺជាអ្នកមានករុណា មុទិតា និងឧបេក្ខា។

សិក្ខដែលល្អកាលបើបានបរិកម្មមូលមន្តរៈនិងប្រតិបត្តិខ្លួនឱ្យចូលដល់អកាលបុរសៈ

១-រើសទីស្ថានដែលស្អាតនិងស្ងប់

២-ជម្រះរាងកាយឱ្យហ្មត់ចត់បរិសុទ្ធ

៣-មិននិយាយ មិនរំពឹងគិតរឿងណាមួយ

៤-ត្រូវយល់បទបរិកម្មនិងជឿជាក់ ត្រូវមានបញ្ញានិងមានសទ្ធា បានចំណែកខ្លះក្នុងបរិកម្ម។

៥-ត្រូវតាំងចិត្តឱ្យជាសមាធិ

៦-ត្រូវប្រតិបត្តិជានិច្ច

៧-ត្រូវរើសពេលបរិកម្មឱ្យល្អជាទីបំផុត (ប្រហែលយាមចុងក្រោយនៃរាត្រីវាំងម៉ោង៣ដល់ម៉ោង៦។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៧៩)

ខាងដើមនេះ ជាកិច្ចដែលគួរបំពេញឱ្យបានបរិបូរណ៍តទៅ ជាកិច្ចដែលត្រូវព្យាយាមលះបង់ គឺកុំបរិភោគ លើសឃ្លាន កុំលក់លើសងនុយ មិនខ្ជិលច្រអូស មិនរវើរវាយ និងកុំដេកតិចពេក។

ចរិយាធម៌ពាក្យប្រៀនប្រដៅរបស់សិក្ខ សានាសិក្ខមានពាក្យប្រាកដក្នុងគម្ពីរគន្ធសា-ហិប ដែលលោកគ្រូ ទាំងឡាយប្រកាសទាក់ទងនឹងចរិយាធម៌ ដែលជាគ្រឿងញុំាងសង្គមឱ្យមូលត្រកូលគ្នា ញុំាងប្រទេសជាតិឱ្យមាំមួនទៅបាន និងញុំាងចិត្តថ្លើមរបស់អ្នកប្រព្រឹត្តឱ្យសម្រេចដល់សេចក្តីជាន់ខ្ពស់ចុងក្រោយបាន មានន័យដោយសង្ខេបដូច្នេះ។

**ទាក់ទងនឹងព្រះជាម្ចាស់**

"រូបទាំងឡាយប្រាកដបាន តាមពាក្យប្រៀនប្រដៅរបស់ព្រះជាម្ចាស់ (អកាលបុរស) វត្ថុមានជីវិតទាំងឡាយឧប្បត្តិមក តាមពាក្យបញ្ជារបស់ព្រះជាម្ចាស់ បុត្រធីតានឹងដឹងដល់កំណើតបិតាមាតាបានយ៉ាងណា ពីព្រោះលោកថែមទាំងចងក្រងដោយអំបោះ គឺពាក្យបញ្ជារបស់ព្រះអង្គ"។

“មនុស្សទាំងឡាយមានព្រះបិតាមួយអង្គ យើងទាំងឡាយជាបុត្ររបស់ព្រះអង្គនោះ ទើបយើងជាបងប្អូនគ្នា”។

ព្រះជាម្ចាស់ជាអ្នកសាងលោក (អកាលបុរស) ដែលស្ថិតនៅក្នុងរបស់ទាំងឡាយ ព្រះអង្គទ្រង់សាង ឡើងនិងរបស់ទាំងឡាយនោះនៅក្នុងព្រះអង្គ។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៨០)

“ព្រះអាល្លាទ្រង់បានសាងពន្លឺជាលើកដំបូង សត្វទាំងឡាយបដិសន្ធិមក ព្រោះសក្តិព្រះអង្គ របស់ដែលព្រះអង្គសាងឡើងកើតមកពីពន្លឺនោះឯង។ កាលបើដូច្នេះទើបគ្មានអ្នកណាទាប អ្នកណាខ្ពស់ អ្នកណាសួរពី វណ្ណៈនិងកំណើតរបស់ខ្លួន ចូរអ្នកស្វែងរកការពិត” ដែលព្រះជាម្ចាស់សម្តែងដល់អ្នកវណ្ណៈនិងកំណើតរបស់អ្នក ប្រព្រឹត្តទៅតាមលក្ខណៈចរិតរបស់ខ្លួនឯង។

“កុំឱ្យអ្នកណាប្រកាន់ខ្លួន ព្រោះវណ្ណៈរបស់ខ្លួន អ្នកដែលដឹងព្រហ្មនោះឯង ជាព្រាហ្មណ៍ កុំប្រកាន់ខ្លួន ព្រោះវណ្ណៈសេចក្តីប្រកាន់ខ្លួនដូច្នេះ ជាអណ្តូងកើតសេចក្តីអាក្រក់”។

“មនុស្សទាំងឡាយខ្លះក៏ជាឧទាសី ខ្លះក៏ជាសន្យាសី ខ្លះក៏ជាយោគី ខ្លះជាព្រហ្មចារី ខ្លះជាយិតិ ខ្លះក៏ជាហិណ្ឌូនិងមនុស្សខ្លះទៀតជាទួរគី។ល។ មនុស្សខ្លះជាអ៊ិម៉ាមសាហ្វី ចូរកាន់ថាមនុស្សទាំងឡាយរមែងមានព្រះជាម្ចាស់តែមួយព្រះអង្គ ជាវណ្ណៈជាមួយគ្នាទាំងអស់ ករតនិងករិម (អកាលបុរស) ជាព្រះជាម្ចាស់អង្គជាមួយគ្នា ព្រះអង្គជាអ្នកប្រទានក័យកុំខុស ព្រោះការសង្ស័យនិងកុំជឿថាមានព្រះជាម្ចាស់អង្គទីពីរ មនុស្សទាំងឡាយចូរ ប្រតិបត្តិចំពោះព្រះអង្គតែមួយ អ្នកចូរដឹងថាមានរូបតែមួយនិងវិញ្ញាណតែមួយ”។

**ទាក់ទងនឹងការសាងលោក**

សិក្ខបង្រៀនថា ៖ តាំងពីដើមមានតែអកាលបុរស តមកមានពពក និងឧស្ម័នវិលវល់ទៅបានរាប់លាន កោដិឆ្នាំទើបមានព្រះធរណី ទឹក ដួងតារា អាកាស។ល។ បដិសន្ធិឡើងមក មានជីវិតបដិសន្ធិឡើងមកលើរបស់ទាំងនេះ ជីវិតទាំងនេះរាប់តាមចំនួន ៨.៤០០.០០០បែប (រួមទាំងវិញ្ញាណដែលមានកំណើតមកពីពង ពីកគ៌ ពីញើស ក្អែល (បើមើលទៅដូចជាកំណើតរបស់មនុស្សក្នុងពុទ្ធសាសនាដូច្នោះដែរ)។ មានឋានៈខ្ពង់ខ្ពស់ ព្រោះមានឱកាសបំពេញធម៌ ជាការជុសខាត់ដួងវិញ្ញាណឱ្យស្អាត ដែលជាមាគ៌ាឱ្យរួចផុតពីការកើតនិងការ ស្លាប់។ (ហេង គីមហោ *សាសនាប្រៀបធៀប* ភាគ១ ទំព័រ១៨១)

សិក្ខបង្រៀនថា លោកមានច្រើនពេក ក៏កាន់តែមានច្រើនឡើងដូចសុរិយា ដួងចន្ទ ក៏មានច្រើនតមកក៏រិតតែច្រើន អាកាសនិងអវកាសក៏ធំធេងទូលំទូលាយ ដែលមានកិលេស ដែលពិបាកដឹងឱ្យបានជិតដល់។

**ទាក់ទងនឹងការកើតថ្មី**

សិក្ខជឿថាវិញ្ញាណជាអមតៈក្នុងច្បាប់របស់វដ្ត សង្សារគឺការវិលវល់កើតស្លាប់ វិញ្ញាណនោះបានធំឡើងជាលំដាប់ បើអ្នកណាត្រូវការរួចផុតពីការកើតស្លាប់ ត្រូវធ្វើឱ្យបានសម្រេចនូវកតពនេះ ដោយការជម្រះកិលេស ដែលជាពូជធ្វើឱ្យកើតឱ្យស្លាប់ បើមិនត្រូវការស្លាប់ក៏មិនត្រូវធ្វើឱ្យកើត។

ការធ្វើមិនឱ្យកើត គឺការធ្វើខ្លួនឱ្យនៅជាមួយព្រះអង្គ ដូចជាយកទឹកទៅផ្សំជាមួយទឹកនៅក្នុងសត្យខ័ណ្ឌ (ដូចគ្នានឹងការចូលដល់និព្វានក្នុងពុទ្ធសាសនា មើលរឿងយប្ជីវគ្គសត្យខ័ណ្ឌ)។

**ទាក់ទងនឹងសង្គមសេដ្ឋកិច្ច**

សិក្ខបង្រៀនថា ៖

១-ឱ្យភ្ញាក់ពីព្រលឹម យ៉ាងតិចកន្លះម៉ោងមុនថ្ងៃរះ

២-ភ្ញាក់ឡើងឱ្យបរិកម្មខាងផ្លូវធម៌ដើម្បីដុសចិត្តថ្លើមឱ្យស្អាត

៣-ឱ្យប្រកបសម្មាជីវៈ

៤-ឱ្យបែងចែករបស់របរ ប្រាក់ចំណូល១០ភាគ ប្រគល់ដល់កងការកុសល

៥-ឱ្យលះបង់ការក្រេបគ្រឿងស្រវឹង ប្រព្រឹត្តខុសប្រពៃណី សូម្បីតែការជក់បារីក៏ហាម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨២)

កាលបើមនុស្សគ្រប់គ្នាប្រតិបត្តិតាមធម៌ទាំងអស់នេះ សេចក្តីខាតបង់ក៏មិនអាចកើតមានក្នុងសង្គមបានឡើយ។

ដែលបង្រៀនថាចង់បែងប្រាក់ចំណូល១០ភាគ ដាក់ក្នុងការសាងកុសល នោះសង្គមរបស់ជនជាតិសិក្ខ ទើបមានប្រាក់ច្រើនគ្រប់គ្រាន់ ចាក់សេដ្ឋកិច្ចឱ្យនៅក្នុងលំដាប់អត្រាប្រៀបធៀបបានដោយមិនត្រូវធ្លាក់ជាភារៈរបស់អ្នកម្នាក់នោះឡើយ សូម្បីតែអ្នកក្រីក្រ និងអ្នកគ្មានសមត្ថភាពក្នុងពពួកសិក្ខក៏អាចញ៉ាំងជីវិតនៅបាន ដោយមិនបាច់ធ្លាក់ទៅជាភារៈអ្នក

ណាឡើយ។ មានអ្នកពោលថា មិនធ្លាប់ឃើញជនជាតិសិក្ខលេងល្បែងភ្នាល់ មិនធ្លាប់ឃើញជនជាតិសិក្ខខិលប្រអូស និងជាអ្នកសុំទានក្នុងទីណាៗដែរ។

### ទាក់ទងនឹងប្រទេសជាតិ

សាសនាសិក្ខតាំងឡើងដោយគុរុនានក់ អ្នកសម្ញឹងមើលឃើញភ័យដែលប្រទេសជាតិកំពុងបានទទួលពី ជនបរទេស និងពីមនុស្សក្នុងជាតិជាមួយគ្នា គុរុនានក់បានប្រកាសធម៌ប្រៀនប្រដៅ ដើម្បីសេចក្តីគង់វង្សនៅរបស់ជាតិគុរុវាណីរបស់លោក ជាគ្រឿងដាស់តឿនឱ្យអ្នកបានស្តាប់មានសេចក្តីសាមគ្គី ស្រឡាញ់ជាតិដោយមិនស្អប់ជាតិដទៃ។

កន្លងមកដល់សម័យរបស់លោកគុរុវិន្ទសិង្ហប្រៀនប្រដៅឱ្យជនជាតិសិក្ខជាទាហានក្លាហាន លះបង់សាច់ឈាមដើម្បីជាតិសាសនា អ្នកខ្លះបានលះបង់ជីវិតដើម្បីការពារហិណ្ឌូទៀតផង។ ក្នុងការទាមទារឯករាជ្យរបស់ប្រទេសឥណ្ឌា ប្រាកដថាជនជាតិសិក្ខត្រូវលះបង់ជីវិតអស់ជាច្រើននាក់ ការលះបង់ជីវិតដើម្បីជាតិ ឬការធ្វើអំពើអ្វីមួយដើម្បីជាតិរបស់ខ្លួនសិក្ខបានបង្រៀនថាមិនត្រូវស្អប់ខ្ពើមនិងមិនព្យាបាទអ្នកដទៃ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨៣)

### ទាក់ទងនឹងឋានៈរបស់ស្រ្តី

សាសនាសិក្ខលើកតម្កើងឋានៈរបស់ស្រ្តីស្មើនឹងបុរស ស្រីមានសិទ្ធិក្នុងការសិក្សារួមសូត្រមន្តឬជាអ្នកនាំក្នុងការសូត្រមន្តស្មើនឹងបុរសគ្រប់ប្រការ។ លោកគុរុនានក់ ឱ្យឱវាទដល់ពួកព្រាហ្មណ៍ អ្នកតឹងរឹងក្នុងវណ្ណៈ៤ ពួកទុកថា ពួកលោកព្រមានស្រ្តីដោយហេតុណានោះស្រ្តីនោះជាអ្នកឱ្យកំណើតដល់រាជាគុរុសាស្តានិងសូម្បី លោកខ្លួនឯងនេះផង។

### ទាក់ទងនឹងគោលការណ៍ស្មើភាពនិងសេរីភាព

គុរុនានក់បានបង្រៀនថា“លោកទាំងអស់កើតឡើងអំពីពន្លឺជាមួយគ្នាគឺ(ព្រះជាម្ចាស់) និងថាអ្នកណាល្អ អ្នកណាអាក្រក់ជាងគ្នាមិនបានឡើយ”។

គុរុគោវិន្ទសិង្ហបង្រៀនថា “សុរ៉ៅ (មស្ស៊ិត) មន្ទីរឬវិហារជាទីស្ថានបំពេញធម៌របស់មនុស្សទាំងឡាយ ដូចគ្នាដែលឃើញបែកផ្សេងគ្នាខ្លះ ព្រោះសេចក្តីមិនដូចគ្នានៃរូបកាលៈនិងទេសៈ”។

វិហាររបស់សិក្ខមានទ្វារបួនច្រកមានន័យថា បើកសម្រាប់ឱ្យមនុស្សទាំង៤ទិស មិនចំពោះជាតិ, សាសនា, ភេទ ឬវណ្ណៈណា។ ក្នុងពេលប្រជុំខាងផ្លូវសាសនា គ្រប់ៗគ្នាទទួល

ការប្រតិបត្តិស្មើៗគ្នា អ្នកចែកនិងអ្នកទទួលអាហារអំពីរោងធ្វើម្ហូបអាហាររបស់កងការកុសល ទោះបីជាមនុស្សក្នុងវណ្ណៈណា ជាតិណាក៏បានដែរ គ្រប់គ្នាមានឋានៈត្រូវអង្គុយបរិភោគក្នុងទីកន្លែងស្មើមុខគ្នា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨៤)

រឿងតាំងរោងទាន ជារបស់សំខាន់ណាស់ក្នុងសាសនានេះ រហូតដល់គុរុរាមទាសគុរុអង្គទី៤ តាំងច្បាប់ទុកថា អ្នកណាចូលមកជួបសាស្តា ត្រូវទទួលអាហារពីរោងទានមុនគេ ដើម្បីជាការសម្តែងឱ្យឃើញច្បាស់ថា បានទទួលការស្មើភាគគ្នាពីសាស្តា។ អ្នកមានពេលអក្កបារ៍មហារាជទៅជួបគុរុរាមទាស កំពុងអង្គុយបរិភោគអាហារក្នុងទីកន្លែងជាមួយគ្នានឹងសាមញ្ញជន អក្កបារ៍ ទ្រង់ពេញព្រះទ័យថ្វាយប្រាក់ប្រចាំឆ្នាំដល់លោកសាស្តានោះ។

ប្រការមួយទៀតទោះបីជាជនណាក៏ដោយត្រូវប្រតិបត្តិពិធីសង្គត (ពិធីជំនុំសាសនិកធ្វើដោយដៃរបស់ខ្លួន គឺត្រូវជូតស្បែកជើង ដងទឹក ធ្វើគ្រប់យ៉ាងខ្លួនឯង ពុំមានអ្នកណាមួយបានទទួលការលើកតម្កើងជាពិសេសឡើយ អ្នកណាប្រតិបត្តិតាមបានច្រើនជាសិក្ខដែលល្អបំផុត។

សេរីភាពជាវិញ្ញាណរបស់សង្គមគុរុគោវិន្ទសិង្ហ ដាក់គោលប្រតិបត្តិទុកថា កុំធ្វើឱ្យអ្នកណាត្រូវខ្លាចអ្នក អ្នកកុំបំភ័យដល់អ្នកដទៃ កុំខ្លាចអ្នកណា កុំឱ្យអ្នកណាបំភ័យអ្នកក្នុងកិច្ចការពារខ្លួនឬជួយអ្នកដទៃដែលត្រូវគំរាមកំហែង បើមានវិធីការពារណាមួយមិនបានផលត្រូវចាប់ដាវ តែការប្រើដាវ មិនត្រូវឱ្យប្រាសចាកពីធម្មៈ។ មួយទៀតការគ្រប់គ្រងដ៏មានប្រៀបជាក្រុមជាពួកនោះ ជារបស់ដែលចាំបាច់ត្រូវគ្រប់គ្រងដោយមានសេរីភាពផង។

សិក្ខមានពិធីមួយហៅថាអម្រិតសង្ស្ការ គឺពិធីទទួលមនុស្សចូលក្នុងសាសនា ឱ្យសិក្ខទាំងឡាយអង្គុយ ព្រមគ្នាក្នុងទីកន្លែងមួយ ជួសអាហារបញ្ចុកមាត់ឱ្យដល់គ្នានឹងគ្នា មិនប្រកាន់វណ្ណៈអ្នកណាជាព្រាហ្មណ៍ ជាក្សត្រិយ៍ ជាពេស្យ សូទ្ររហូតដល់អ្នកបោសថ្នល់ក្តី ក៏ទទួលឱ្យចូលក្នុងសាសនាសិក្ខដូចគ្នា។

ពិធីចូលសាសនាសិក្ខ មិនថាប្រុសឬជាស្រី មានសីលប្រតិបត្តិខាងផ្លូវសាសនាដូចគ្នាទាំងពីរពួក ទាំងប្រុសទាំងស្រីទៅបូជាជាមួយគ្នាក្នុងវិហារកន្លែងតែមួយ អង្គុយព្រមគ្នាក្នុងឋានៈបងប្អូនសរសើរព្រះជាម្ចាស់តែមួយអង្គ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ១៨៥)

សេចក្តីបំណងក្នុងទីនេះ ដើម្បីបដិសេធការរាប់អានវណ្ណៈ៤ពួករបស់ពួកហិណ្ឌូ ដែលជាគ្រឿងបំផ្លាញ សាមគ្គីក្នុងពួកគណៈ និងដើម្បីឱ្យជាការបំផ្លាញមានះ បំផ្លាញសេចក្តីចចេសរឹងរូសឱ្យកើតសទ្ធានិងសេចក្តី ស្រឡាញ់រវាងគ្នានិងគ្នា។

**និកាយក្នុងសាសនាសិក្ខ**

សាសនាសិក្ខបែកចេញជានិកាយធំ២និកាយ គឺនិកាយនានកបន្ថិ ប្រែថា អ្នកប្រតិបត្តិតាមធម៌របស់គុរុ នានក លោកជាគ្រូអង្គដំបូងនិងនិកាយនិលិម្ហេ ប្រែថាអ្នកព្រាត់ប្រាសចាកមន្ទិលរាប់អានគុរុគោវិន្ទសិង្ហសាស្តា អង្គទី១០ និកាយក្រោយនេះមានន័យថា លោកគុ រុគោវិន្ទសិង្ហជាអ្នកទំនុកបម្រុងជ្រោមជ្រែង ដោយការចាត់បញ្ជូនសាវ័ករបស់លោកឱ្យចេញទៅសិក្សារៀនសូត្រក្នុងមហាវិទ្យាល័យពារាណសី។

ក្រៅអំពី២និកាយធំ នៅមាននិកាយបន្ទាប់បន្សំទៀតដូចជាឧទាសី មានន័យថាអ្នកព្រងើយកន្តើយ ចំពោះលោកសុធរេ ប្រែថា អ្នកព្រាត់បរិសុទ្ធ អកាលីគឺជាអ្នកបូជាព្រះជាម្ចាស់ជានិរន្តរ និងនៅមាននិកាយសំខាន់មួយទៀតគឺ នាមធារី ប្រែថា អ្នកទ្រទ្រង់ទុកឬអ្នកពិតប្រាកដ នៅក្នុងព្រះនាមរបស់ព្រះជាម្ចាស់។ និកាយនាមធារីតែងខ្លួនពណ៌សសុទ្ធ មិនជក់មិនផឹក (របស់ស្រវឹង) មិនស៊ីសាច់សត្វដោយកាន់ថាគុរុរបស់សាសនាមានបន្ត មកពីសាស្តាអង្គទី១០មក គ្រប់រយៈពុំមានដាច់ ខុសអំពីនិកាយដទៃដែលប្រកាសថាគុរុជាអ្នកសាស្តារបស់សិក្ខមានត្រឹម១០នាក់ មិនមានគុរុបន្តមកទៀតនឹងរាប់គម្ពីរគន្ថសាហិបថា ជាអង្គសាស្តាជំនួស។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨៦)

នៅមាននិកាយបន្ទាប់បន្សំបែកខ្ញែកចេញទៅទៀតច្រើនជាង១០និកាយ និកាយទាំងនេះមានចំណែកបែកផ្សេងគ្នាបន្តិចបន្តួច សង្កេតបានយកពីការស្លៀកពាក់ និយាយ ខ្លះហ៊ុំព័ទ្ធសំពត់ពណ៌លឿង ពួកនិកាយខ្លះ ប្រើពណ៌ផ្ទៃមេឃ ពណ៌ស និងពណ៌ក្រហមក៏មាន និកាយខ្លះបែកគ្នាទៅដោយការកាត់សក់ និងនិកាយខ្លះបែកផ្សេងគ្នាដោយការកោរពុកមាត់ ចង្ការក៏មាន។

សាសនាសិក្ខមានឋានៈជាសាសនាគង់វង្សនៅមិនស្លាប់ ញ៉ាំងអ្នកប្រតិបត្តិទាំងឡាយឱ្យមាំទាំនៅក្នុង ភាពជាឯករាជ្យរបស់អកាលបុរស ឱ្យកើតចំណុចរួមនៃសាមគ្គីធម៌ ជាគ្រឿងកំដរដែនាំផ្លូវឱ្យជាអ្នកប្រតិបត្តិ ចូលដល់នូវសច្ចៈ លះអហង្ការនិងមមង្ការចេញ បានចូលដល់

*ទេពភាវៈជាថ្នាក់ខ្ពស់ មិនអន់ថយជាងធម៌ក្នុងសាសនាទាំងឡាយឡើយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨៧)*

# សាសនាក្រុមមុខ្គោល សាសនាជិន្តូ

## សាសនាជិន្តោ

### *មាគ៌ានៃព្រះជាម្ចាស់*

*ប្រទេសជប៉ុនគឺផែនដីចុងបំផុតនៃទិសខាងកើត មានសាសនាធំជាឫសគល់របស់សង្គម២សាសនាគឺ សាសនាជិន្តោ និងពុទ្ធសាសនា។ ពាក្យប្រៀនប្រដៅរបស់សាសនាទាំងពីរ ចូលមកផ្សំផ្សំជាគ្រឿងប្រដាប់ សង្គមនិងចិត្តគំនិតរបស់ជនជាតិជប៉ុនឱ្យទៅជាជនជាតិមួយមានគុណលក្ខណៈចម្លែកពិសេស ជាជាតិមួយឡើង ក្នុងលោកដែលរកបានដោយកម្រពីគុណលក្ខណៈរបស់ជាតិទាំងឡាយ។*

*គុណលក្ខណៈដ៏ប្រសើរនេះគឺការស្រឡាញ់ជាតិ ការបូជាបុព្វបុរស បូជាជាតិ ស្រឡាញ់ជាស្អាត ស្រឡាញ់ធម្មជាតិនិងមានសេចក្តីក្លាហានជាអស្ចារ្យ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៨៩)*

*គុណលក្ខណៈដ៏ប្រសើរនេះ នឹងនិយាយចំពោះតែសាសនាជិន្តោ តែប៉ុណ្ណោះ។*

*ជិន្តោ* (Shintoism) *ជាសាសនាមានរូបរាងឡើងអំពីទេពនិទានដ៏អាថ៌កំបាំងប្របូកប្រហល់ពេលខ្លះ កាលខ្លះហួសសមត្ថភាពនឹងធ្វើការពិសោធបាន ទេពនិទានទាំងនេះអ្នកប្រាជ្ញកាន់យកជាដែនកើតរបស់សាសនា និងទំនៀមទម្លាប់ក្នុងសង្គមមួយបែបដូចគ្នា ដូច ដែលបានសម្តែងមកពីខាងដើម។ ទេពនិទានក្នុងជិន្តោជាកញ្ចក់បញ្ចាំងឱ្យឃើញជនជាតិជប៉ុននិងមនុស្សជប៉ុនជាជាងស្រមោលកញ្ចក់បន្ទះដទៃៗ។*

*ជិន្តោជាសាសនាប្រចាំជាតិជប៉ុន ជាលទ្ធិកើតឡើងនិងគង់វង្សនៅគូគ្នានឹងជប៉ុន តាំងតែអំពីចាប់ផ្តើមជាជាតិមក ជាង២ពាន់ឆ្នាំ។*

*ជិន្តោប្រែមកថាវិធីរបស់ព្រះជាម្ចាស់* (The way of gods) *ជាផ្លូវរបស់ឋានសួគ៌មានសេចក្តីថា បុគ្គល ត្រូវប្រតិបត្តិខ្លួនតាមផ្លូវរបស់ឋានសួគ៌ កក្តីភាពចំពោះព្រះជាម្ចាស់ដើម្បីផលល្អរបស់ខ្លួន។ ព្រះជាម្ចាស់ក្នុងទីនេះគឺសាសនិក។ ជិន្តោមានបំណងយកធម្មជាតិ ដែលមាននៅជុំវិញជីវិតរបស់មនុស្សដែលមនុស្សមានការសម្ព័ន្ធ។ ជិន្តោមានគតិបន្តមកពីពាក្យប្រៀនប្រដៅក្នុងសាសនាតៅនិងខុងជឺរបស់ចិនជាច្រើនប្រការ ជប៉ុនមានទេពនិទាន មានដើមទងតាំងពីបុរាណច្រើនពាន់ឆ្នាំមកថា ព្រះអាទិត្យឬបរិវាររបស់ព្រះអាទិត្យ ជាអ្នកសាងកោះ*

ជប៉ុន។ ជនជាតិជប៉ុនទាំងឡាយដែលកើតមកក្នុងកោះនេះ ជាកូនចៅរបស់ព្រះអាទិត្យ ដែលភាសាជប៉ុនហៅថា អមៈតេរៈសុឱមិគៈមិ ឈាមព្រះអាទិត្យមុនដំបូងដែលប្រាកដជាមនុស្សក្នុងប្រវត្តិសាស្ត្រយិម្មុ (តាមតួអក្សរចិនសរសេរមានន័យសេចក្តីថា ព្រះជាម្ចាស់ជាអ្នកចម្បាំង) ឬយិម្មូទេន្នោដែលជានាមចក្រពត្តិ ជាអង្គជាមនុស្សដំបូងរបស់ប្រទេសជប៉ុនអាស្រ័យគតិនិយមនេះ ជនជាតិជប៉ុនទើបមានជំនឿថា ចក្រពត្តិ របស់ខ្លួនគ្រប់ព្រះអង្គ ទ្រង់មានខ្សែស្រឡាយមកពីព្រះអាទិត្យ។ ដោយហេតុនៃការរាប់អាន ដូច្នេះជនជាតិ ជប៉ុនទាំងឡាយពីបុរាណដឹងថា ខ្លួនជាពូជពង្សពីសួគ៌ា ផែនដីរបស់ខ្លួនជាផែនដី (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩០) ដែលព្រះជាម្ចាស់សាងសង់មកឱ្យ ជនជាតិជប៉ុនមិនមែន ជាជនជាតិសាមញ្ញធម្មតា ផែនដីរបស់ជប៉ុនក៏មិនមែនជាផែនដី សាមញ្ញដូចជាផែនដីទាំងពួងដែរ សេចក្តីរាប់អាននេះបានផ្សាយចេញទៅជាច្រើនក្នុងពេលបច្ចុប្បន្ន តាំងពីនោះមក មានអ្នកគោរពនៅតឹងរឹងក៏មិនតិចឡើយ។

ហេតុនៃការយល់ដឹងប្រចាំនៅក្នុងចិត្ត ដូចបានពោលមកហើយនេះ ជាផលធ្វើឱ្យជនជាតិជប៉ុនជាមនុស្ស ស្រឡាញ់ជាតិ ស្រឡាញ់ប្រទេស ស្រឡាញ់បុព្វបុរសរបស់ខ្លួន លើសលែងជនជាតិណាៗទាំងអស់ និងព្រោះតែហេតុនៃការស្រឡាញ់នេះហើយ ដូចគតិដែលបាននិយាយមក បានទៅជាផលកើតចរិយាធម៌ឡើងមួយបែប ហៅថាបូជិដូ ជាវិន័យរបស់អ្នកចម្បាំង គឺជនជាតិជប៉ុនទូទៅទាំងជាតិនិងជាលទ្ធិជាតិនិយមយ៉ាងខ្លាំងខ្លស់ ក្នុងចំណោមជនជាតិជប៉ុនផងដែរ។

**គម្ពីរក្នុងសាសនា**

ការសិក្សាសាសនាជិន្តោ ត្រូវសិក្សារឿងរ៉ាវអំពីគម្ពីរក្នុងសាសនាជាមុន ព្រោះថារឿងរ៉ាវរបស់ព្រះជាម្ចាស់ ជារឿងរាប់អានតៗគ្នាមក រឿងរ៉ាវរបស់ផែនដីនិងរឿងរបស់ជាតិនីមួយ ដែលអាស្រ័យនៅលើផែនដី នោះរហូតដល់ចរិយាធម៌របស់មនុស្សជាតិនោះ មាននៅក្នុងគម្ពីរសាសនាទាំងអស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩១)

គម្ពីរក្នុងសាសនាជិន្តោមានដូច្នេះ

១-គោយិកិ (Ko-ji-ki) គឺសំបុត្ររឿងរ៉ាវពីបុរាណ អ្នកតែងគម្ពីរមួយក្បាលនេះជាមនុស្សនៅក្នុងរាជសំណាក់ ទទួលរាជឱង្ការអំពីស្តេចចក្រពត្តិឱ្យជាអ្នករួបរួមហេតុការណ៍ប្រហែលក្នុងរវាង(ព.ស.១៥៣)។ រឿងក្នុងគម្ពីរចាប់ផ្តើមតាំងពីកំណើតរបស់ព្រះជាម្ចាស់ ការ

ចាប់ផ្តើមរបស់កោះជប៉ុន ដែលព្រះជាម្ចាស់ជាអ្នកសាង និងចាប់ផ្តើមប្រវត្តិសាស្ត្រចក្រពត្តិអង្គដំបូងគឺ យិម្មុ ជាលំដាប់ចុះមករហូតដល់រជ្ជកាលសម័យសម្តេច ព្រះចក្រពត្តិនីស៊ុយ-កោ (ព.ស.១១៧១) ក្រៅពីនេះមានរឿងពិធីកម្មដែលនឹងធ្វើរឿងពលីការចំពោះព្រះជាម្ចាស់។

២-និហង្គី (Nihongi) ឬជិហានជោគិ ប្រែថាសំបុត្រហេតុប្រវត្តិសាស្ត្ររបស់ជប៉ុន អ្នកតែងជាអ្នកនៅ ក្នុងរាជសំណាក់ដូចគ្នា តែងឡើងកាលព.ស.១២៦៣ ក្នុងរយៈមិនឆ្ងាយប៉ុន្មានពីការតែងគម្ពីរក្បាលទីមួយ គម្ពីរមួយក្បាលនេះសរសេរជាភាសាចិនសុទ្ធ និទានអំពីរឿងរបស់ព្រះជាម្ចាស់ តាមទេពនិទានពីដើមមកដូចគ្នា មកដល់សម័យចក្រពត្តិ និយិដូ (ព.ស.១៣៥០) សៀវភៅមួយក្បាលនេះ ជាប្រវត្តិសាស្ត្រដែលអាចកំណត់បានតាមសេចក្តីពិត មានទាំងអស់៣០ក្បាល។

៣-យេនគិ សិកិ (Yengi-shiki) ជាបទសូត្រនិងពិធីកម្មក្នុងសម័យយេនគិ (ក្នុងរវាងពុទ្ធសករាជ ១៤៤៤-១៥៦៦) ជាសៀវភៅប្រមាណ៥០វគ្គ ១០វគ្គ ដំបូងអធិប្បាយអំពីរឿងទាក់ទងនឹងពិធីកម្មផ្សេងៗពីបុរាណ ក្រៅអំពីនោះជាបទសូត្រ (Nori-to) ពិធីកម្មទាំងនោះ មានជាអាទិ៍បទសូត្រក្នុងពិធីទេសកាលព្រោះ ស្រូវប្រូតកាត់ ពិធីអង្វរករព្រះជាម្ចាស់ឱ្យនាំមកនូវសេចក្តីសម្បូរហូរហៀរកើតដល់ភោគផលជាដើម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ១៩២)

៤-ម័នយោជូ (Munyo-shiu) ប្រែថា "ប្រជុំនៃស្លឹកឈើម៉ឺនសន្លឹក មានន័យថា គួរពិចារណាថា រឿងរ៉ាវក្នុងគម្ពីរមួយក្បាលនេះនិពន្ធឡើងដោយប្ញីដៃរបស់មនុស្សជាច្រើននាក់ តាំងអំពីក្សត្រិយ៍រហូតចុះមកដល់រាស្ត្រ គម្ពីរមួយក្បាលនេះ ប្រកបដោយពាក្យកាព្យឃ្លោង (ប្រមាណ៤.៤៩៦បទ) ពាក្យកាព្យឃ្លោងទាំងនោះ សម្តែងអំពីការចាប់ផ្តើមឡើងនៃផែនដីនឹងសួគ៌ ការប្រជុំរបស់ទេវតាម៉ឺនសែនអង្គ រឿងរ៉ាវរបស់សុរិយទេព អ្នកមានតេទជាស្រីរហូតដល់រឿងដែលសុរិយទេពអង្គនោះ ទ្រង់សាងកោះជប៉ុនប្រទានផែនដីឱ្យជាទីអាស្រ័យ របស់ជនជាតិជប៉ុនជាដើម គម្ពីរនេះគេយល់ថា បានរួបរួមធ្វើឡើងក្នុងរវាងសតវត្សទី៥នៃគ្រិស្តសករាជ។

មានសេចក្តីដែលគួរឱ្យសង្កេតថា គម្ពីរបួនក្បាលនោះសម្តែងពីព្រះជាម្ចាស់នៃសេចក្តីល្អនិងសេចក្តី អាក្រក់ជាគូគ្នា ដូចជាគម្ពីររបស់សាសនាដទៃៗដែលរាប់អានព្រះជាម្ចាស់ ដូចដែលបានសម្តែងមកហើយពីខាងដើម និងភាគច្រើនសម្តែងពីការប្រព្រឹត្តរបស់ធម្មជាតិ

ដែលជាមូលហេតុជួយឱ្យជប៉ុនជាអ្នកស្រឡាញ់ជាតិ សម្តែងដល់ក្តីមេត្តាហើយ និងសេចក្តីក្លាហានរបស់បុព្វបុរសអ្នកបានសាងកោះជប៉ុនមកហើយ ជាពាក្យប្រៀនប្រដៅរបស់ជនជាតិជប៉ុន មានសេចក្តីគោរពដល់បុព្វបុរសនិងមាននាទីជាអ្នករក្សាផែនដីសួគ៌របស់ខ្លួននៅកន្លែងនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៣)

**ការរាប់អានព្រះជាម្ចាស់**

អ្នកប្រាជ្ញសាសនាភាគច្រើន មានការយល់ឃើញរួមគ្នាថា ជិន្តោរបស់ជប៉ុន មានការសម្ព័ន្ធទៅអំពីលទ្ធិបុរាណរបស់ចិន ដែលអ្នកជិន្តោរបស់ជប៉ុនមួយផ្នែកមិនព្រមទទួលការយល់ឃើញ ដូចបានពោលមកហើយ ដោយសំអាងថាជប៉ុនមានលទ្ធិរបស់ខ្លួន មុននឹងបានទទួលអរិយធម៌ខាងផ្លូវសាសនាទៅអំពីចិន។ លទ្ធិជិន្តោ កើតឡើងមុនពេលដែលជប៉ុនទាក់ទងជាមួយចិន ជិន្តោរបស់ជប៉ុនជាជនជាតិជប៉ុនខ្លួនឯងផ្នែកណាមានទម្ងន់ ជាងផ្នែកណា សូមទុកឱ្យអ្នកអានវិនិច្ឆ័យចុះ។

មានតួយ៉ាងដូចជារឿងរបស់ព្រះជាម្ចាស់ អាទិទេពនៃភ្នំ ដើមឈើ ទន្លេនិងស្រែចម្ការរបស់ជនជាតិចិន មានកំណើតមកពីលោកធាតុឬធម្មជាតិ។ ជនជាតិចិនសាងធម្មជាតិឱ្យ ទៅជាព្រះជាម្ចាស់ មានកំណើតជាទេព្តាភ្នំ ទេព្តាដើមឈើ ទេព្តាទន្លេ និងស្រែចម្ការ។ ចំណែក ទេព្តារបស់ជប៉ុនកើតមកអំពីដួងវិញ្ញាណ ច្រើនពាន់ច្រើន ម៉ឺនដួងរបស់អ្នកនៅតាមទន្លេ សមុទ្រ ទេព្តានៃរូងភ្នំ ក៏គឺដួងវិញ្ញាណនៃអ្នកនៅតាមភ្នំជាច្រើនម៉ឺនច្រើនដួង រួមសេចក្តីមកថា ទេពជាម្ចាស់របស់ជប៉ុន (មួយផ្នែកកើតពីផ្នែកមនុស្ស)។

ព្រះជាម្ចាស់របស់ជប៉ុនហៅថាគៈមិ (Kami) តាមពាក្យអធិប្បាយពីដើម មានន័យថាជាន់ខ្ពស់ មានន័យសេចក្តីជាច្រើនយ៉ាងដូចជាក្លីថ្លាបរិសុទ្ធ ទ្រង់មានថាមពលគួរឱ្យចម្លែក គួរឱ្យកោតខ្លាចនិងទ្រង់មានអំណាចជាដើម មានន័យសេចក្តីរួមគឺ GODក្នុងភាសាអង់គ្លេស។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៤)

ជប៉ុនហៅព្រះជាម្ចាស់ទាំងនោះថា គៈមិសមៈ (Kami-sama) ពាក្យថាសមៈជាពាក្យសម្តែងសេចក្តីគោរព ដូចពាក្យព្រះជាពាក្យនាំមុខ។ គមិសមៈមិនមែនសំដៅចំពោះតែមនុស្សនិងធម្មជាតិដែលមនុស្សស្រឡាញ់និងកោតខ្លាចនោះទេ គៈមិសមៈមានជាច្រើន ម៉ឺនសែនទៀត សត្វនៅលើអាកាស សត្វនៅលើគោក សត្វនៅក្នុងទឹក ដើមឈើគ្រាប់ពូជ។ល។ ក៏ជាគៈមិសមៈ ផងដែរ។ ក្នុងប្រទេសជប៉ុនមានទេពារក្សផ្ទៃចចក ទេពារក្សខ្លា ទេពារក្សផ្ទៃ

ព្រៃ ទេពារក្សផ្លែឈើបែបខ្វះ។ល។ ពូជនិងសត្វទាំងនេះសុទ្ធជាគ:មិសម:ទាំងអស់ ព្រោះហេតុនេះទើបបានពាក្យនិទានថា ជប៉ុនជាកោះរបស់ព្រះជាម្ចាស់ ដូចគ្នានឹងទីក្រុងក្យូតូក្នុងប្រទេសកូមា ហៅដែននៃចេតិយ៍ ព្រោះក្យូតូ ជាទីក្រុងតែមួយ មានចេតិយ៍រាប់ម៉ឺន។ ក្នុងគម្ពីរនិហន្ទិនិយាយថា មានព្រះរបស់ជប៉ុនទាំងអស់៨០ម៉ឺន និងក្នុងគម្ពីរគោយិកិថាមានដល់ទៅ ៨០០ម៉ឺន។

គោយិកិ បទទី១៩៦ ពោលទុកដូច្នេះ

"ព្រះជាម្ចាស់ទាំងឡាយលើសួគ៌ជាន់ខ្ពស់ ព្រះជាម្ចាស់លើសួគ៌ជាន់ទាប ព្រះជាម្ចាស់ទាំងឡាយលើសួគ៌ ជាន់កណ្ដាលនិងព្រះជាម្ចាស់ទាំងឡាយលើផ្ទៃធរណី ព្រះជាម្ចាស់នៃពូជផល្លា ព្រះជាម្ចាស់លើផ្ទៃជ្រលងភ្នំ ព្រះជាម្ចាស់នៃស្ទឹង បឹងបួទាំងឡាយ។ល។ ព្រះជាម្ចាស់ទាំងឡាយ ទាំងពួង កើតមកកាលបើលោកកើតមានទាំងអស់ហើយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៥)

កាលបើចាប់ផ្ដើមមានចក្រវាល គម្ពីរសម្ដែងនាមព្រះជាម្ចាស់អ្នកសាងចក្រវាលឡើងមាន៤អង្គ អង្គដំបូងព្រះនាម អ:មេណុ:-មិនាគ:នជិ-ណុ:-គ:មិ (Ameno-Minakanushi-no-kami) ជាមហាទេពសាង លោកឬចក្រវាលជាអង្គខ្ពង់ខ្ពស់ (ប្រៀបបាននឹងបរមាត្មនរបស់ព្រាហ្មណ៍) តពីនេះមានព្រះជាម្ចាស់ជាអ្នកសាង។ បន្ទាប់មកមាន៤អង្គទៀត ព្រះនាមថា (Takami-Musubi-no-kami-musubi-no-kami, Umashi-Ashiksbihiko-no-kami, Amino-Tokotachi-no-kami) មាននាទីជាអ្នកសាងដូចគ្នា តែអង្គណាមាននាទី សាងអ្វីមិនបានប្រាប់។

គម្ពីរសម្ដែងទេពជាម្ចាស់បន្តវង្សមកទៀត ១០អង្គ រហូតដល់អ៊ិសានាគិ (Izanagi) និងអ៊ិសានាមិ (Isanami) ទេពមាតានិងតាបិតាអ្នកឱ្យកំណើតកូនប្រុសស្រី៣អង្គគឺ មួយអង្គជាទេពី អង្គសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រជប៉ុន បានដល់អ:ម:តេរ:សុអូមិគ:មិ (Amaterasu-Omikami) គឺព្រះអាទិត្យស៊ុកិយោមិ (Tsukiyomi) ទេពាយុ។

"ទេវវង្ស" តាមទេពនិទានរបស់ជិន្តោមានទេព្តាបន្តវង្សមកទៀត ៤ តំណាងរហូតដល់យិម្មុ ទេន្នោ (Jimu-Tenno) ចក្រពត្តិអង្គដំបូងរបស់ជប៉ុន ដែលជាកូនទី៤របស់ហ្ងោន របស់ដួងព្រះអាទិត្យ និងរបស់ដួងច័ន្ទ រាប់ជា "ទេពវង្ស" របស់ជប៉ុនបាន២៣អង្គ។ កាលគ្រាសាងកោះជប៉ុនទេពនិទានមានរឿងសប្បាយរីករាយ និងរឿងរ៉ាវច្របូកច្របល់ខ្វះ មានការនិទានដោយសង្ខេបថា ពេលទេព្តាអ៊ិជានាគិនិងទេព្តាអ៊ិជានាមិឱ្យកំណើតកូនប្រុសស្រី ៣អង្គ (មើលរឿងដើម) ប្រគល់ព្រះអាទិត្យគ្រប់គ្រងភូមិភាគសួគ៌ ប្រគល់ឱ្យព្រះច័ន្ទគ្រប់គ្រង ដែន ដីព្រះច័ន្ទ

(?) និងប្រគល់ឱ្យទេព្ដាខ្យល់ព្យុះ (ស៊ូណាណុះវ៉ូះ) គ្រប់គ្រងផ្ទៃនៃផែនដី។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ១៩៦)

ស៊ូសាណុះវ៉ុះ ជាទេព្ដាចិត្តបានអាក្រក់ ថ្ងៃមួយបានប្រើកម្លាំងបក់បោកបញ្ឆោតបន្ទំបងស្រី (ព្រះអាទិត្យ) មិនព្រមឱ្យចេញមកបញ្ចាំងពន្លឺបានស្រួល ព្រះអាទិត្យទើបគេចចូល ទៅនៅជ្រលងភ្នំមួយកន្លែង តាំងពីពេលនោះមកពិភពលោកក៏ងងឹត ទេវតាតូចធំក្ដៅក្រហាយទើបណាត់រកពិធីលួងលោមព្រះអាទិត្យចេញមក ក្រោយភ្នំមកបំភ្លឺតាមប្រក្រតីនិងមានមតិឱ្យបណ្ដេញស៊ូសាណុះវ៉ុះ (ទេពាយុ) ចេញអំពីទេពសមាគម ចុះទៅនៅលើផ្ទៃផែនដី មិនឱ្យឡើងទៅធានៅលើឋានសួគ៌បានទៀត។

ត្រង់នេះទេពនិទាន(តាមគម្ពីរ) ពោលថា ស៊ូសាណុះវ៉ុះ កាលបើត្រូវគេបណ្ដេញឱ្យចុះមកនៅលើផែនដី ក៏តម្រូវឱ្យតស៊ូជាមួយម្ចាស់ដីគឺស្ដេចពស់ក្បាលប្រាំបី រហូតយកជ័យជម្នះបាន ហើយរៀបការជាមួយកូនក្រមុំ ជាម្ចាស់ទឹកន្លែងនោះ (ទេវតាដូចគ្នា) ម្នាក់មានកូនប្រុសមួយប្រគល់ឱ្យគ្រប់គ្រងលើផែនដី ខ្លួនឯងធ្លងទៅ ឈូងសមុទ្រកូរ៉េ (ព្រោះហេតុដូច្នេះទេដឹងទើបចន្លោះឈូងសមុទ្រកូរ៉េនិងឈូងសមុទ្រជប៉ុនមានខ្យល់ព្យុះ ខ្លាំងក្លាជានិច្ច។

និទានពីរឿងព្រះអាទិត្យ មានសម័យថ្ងៃមួយត្រិះរិះឃើញថា ផែនដី តូយ៉ូអាជីហារ (Toyoashihara) ឈ្មោះដើមបន្ទស់របស់កោះជប៉ុន ជាដែនដីឧត្តមសម្បូរណ៍សប្បាយគួរនឹងបញ្ជូនកូនចៅចុះទៅគ្រប់គ្រង ទើបបញ្ជូនចៅមួយអង្គឈ្មោះ នីនីជិ-នូមិកុតុ (Ninigi-no-mikoto) ចុះមកកសាងកោះជប៉ុនឱ្យក្លាយជាទីក្រុង ( មានន័យថាចុះមកលើកំពូលភ្នំមួយ លើកោះកិវសិវ)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៧)

កាលដែលទ្រង់ប្រើឱ្យម្ចាស់ចៅចុះមកកសាងកោះជប៉ុននោះ (ហេតុអ្វីក៏មិនបញ្ជូនកូនចុះមកផង ក៏មិនដឹងដែរ) មានទេវបញ្ជាធ្វើឱ្យសម្បូណ៌នៅលើផែនដីនិងឱ្យគ្រប់គ្រងជាមួយគ្នារវាងវង្សាទេវតានិងមនុស្ស មិនឱ្យដាច់ខ្សែស្រឡាយ ហើយប្រគល់កញ្ចក់មួយផ្ទាំងដាវមួយនិងអញ្ញមណី (ខ្សែកពេជ្រ)។ មួយវិញទៀត រាប់ថាជារាជកកុជភណ្ឌ (គ្រឿងសញ្ញាព្រះរាជា) ប្រចាំចក្រពត្តិជប៉ុនមករហូតប្រវត្តិសាស្ត្រឱ្យជាក់ជាប់នឹងខ្លួន មកជាមួយផង។

ម្ចាស់ចៅរបស់ព្រះអាទិត្យ (អៈមៈតេរៈសុមោមិគៈមិ) អង្គនេះ បានមករៀបការនៅរួមរស់ជាមួយ បុត្ររបស់ទេព្ដានៃទន្លេ (កូនក្រមុំអ្នកនេសាទ) កើតកូនចៅសាយភាយមករហូតដល់យិម្មុ ទេន្នោបឋមចក្រពត្តិ អ្នកជាហ្មោនអង្គទី៤របស់ព្រះអាទិត្យ ជាបឋមបុព្វបុរស

របស់ជប៉ុននិងជនជាតិជប៉ុនជាញាតិសន្តានរបស់ទេវតាតមក មិនដាច់ខ្សែស្រឡាយ ដោយប្រការដូច្នេះឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៨)

**ការបូជាធម្មជាតិ**

មូលដ្ឋានចិត្តគំនិតរបស់ជនជាតិជប៉ុនគឺការទទួលថា កាលដែលព្រះជាម្ចាស់ទ្រង់សាងកោះជប៉ុនហើយ ទ្រង់សាងធម្មជាតិលើកោះជប៉ុនផងរបស់ដែលព្រះជាម្ចាស់សាងទើបមានឋានៈខ្ពស់គួរដល់ការគោរពបូជា ដូង ព្រះអាទិត្យ ដួងច័ន្ទ ព្យុះផ្គររន្ទះ មហាសមុទ្រ ស្ទឹងទន្លេ ភ្នំទឹកធ្លាក់ ផ្កាំងថ្ម ពូជព្រឹក្សា ដើមឈើ ស្មៅ សត្វព្រៃ ទាំងអស់ និងគ្រឿងប្រកបសេចក្តីស័ក្តិសិទ្ធិជាន់ខ្ពស់របស់ចក្រពត្តិ៣យ៉ាងគឺ កញ្ចក់ធ្លុះ ដាវនិងអញ្ញមណី ដែលប្រកាន់ថាជាទេវសម្បត្តិ មានវិញ្ញាណជាទេវតា ប្រទានមកជាគមិសបៈទាំងអស់។ បានសេចក្តីប្រាកដថា ជនជាតិជប៉ុនស្រឡាញ់ធម្មជាតិ ថែរក្សាព្រៃភ្នំ ព្រឹក្សាព្រៃគ្រាប់ពូជតូចធំ ដូចជាជីវិតរបស់ខ្លួន។

**ការបូជាអ្នកក្លាហាន**

ជប៉ុនជាអ្នកស្រឡាញ់ជាតិ លើកតម្កើងជាតិ ពិបាកនឹងរកជនជាតិណាមកប្រៀបបានស្រីប្រុសណាមួយ បានឧទ្ទិសជីវិតឱ្យជាតិវិញ្ញាណអ្នកនោះនឹងបានទទួលការលើកតម្កើងជាគមិសមៈគឺព្រះជាម្ចាស់ព្រមជាមួយគ្នាទាំងអស់។ ទាហានជប៉ុនដែលចេញធ្វើសង្គ្រាមចម្បាំងដោយសេចក្តីក្លាហានមិនស្តាយជីវិត ព្រោះដឹងថាបើ ស្លាប់ទៅគឺបានលើកតម្កើងជាតិនិងបានជាទេវតាមានអ្នកគោរពបូជា។ ជប៉ុនមានមហាសាលាអ្នកតាមួយ កន្លែងគឺ (Yasukumi-Shrine) តាំងនៅកណ្តាលទីក្រុងតូក្យូ មហាសាលាអ្នកតានេះជាទីកន្លែងរួមវិញ្ញាណ របស់វីរបុរសមានកិត្តិនាមទាំងអស់ មានវត្តពិធីបូជាដួងវិញ្ញាណអ្នកក្លាហានទាំងនេះ ជាប្រចាំរៀងរាល់ឆ្នាំ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៩)

**ការបូជាបុព្វបុរស**

កាលបើប្រៀបធៀបនឹងចិន ការបូជាបុព្វបុរសមើលទៅឃើញថាជប៉ុនខ្ពស់ជាងនិងស័ក្តិសិទ្ធិជាងគ្រង់ ដែលជប៉ុនព្រមទទួលស្គាល់ថា ចក្រពត្តិរបស់ខ្លួនមានខ្សែស្រឡាយជាប់បន្តមកពីទេវតា ជាការបន្តខ្សែស្រឡាយគ្មានដាច់។ ជនជាតិជប៉ុនតាំងពីដើមរហូតមកទល់បច្ចុប្បន្នជាខ្សែស្រឡាយបន្តរបស់ចក្រពត្តិ ពូជពង្សនៃទេវតា ការទៅជាបុព្វបុរស ទើបជាប់បន្តសាច់ឈាមមកជាមួយគ្នា ការបូជាបុព្វបុរសរបស់ជប៉ុន ជាពិសេស មានទាំងបុព្វបុរស

របស់គ្រួសារនីមួយៗ និងបុព្វបុរសក្នុងគ្រួសាររួមគ្នា សំដៅយកគ្រួសាររបស់ជាតិ (ជាតិជាគ្រួសារជាមួយគ្នា) ជាចំណែករួមគ្នាផង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ១៩៩)

**ការបូជាចក្រពត្តិ**

ជប៉ុនហៅអធិរាជចក្រពត្តិរបស់ខ្លួនថា មិកាដូ (Mikado) ឬតេន្នោ (Tenno) គម្ពីរនិហង្គីបានអានថា អង្គមិកាដូ ជាអ្នកបន្តវង្សត្រកូលមកអំពីដួងព្រះអាទិត្យ និងបន្តខ្សែស្រឡាយមកដោយមិនដាច់។

គតិនិយមនេះប្រហាក់ប្រហែលគ្នានឹងចិន ប្រើនតែមិនដូចចិនទេ ចិនរាប់អានចក្រពត្តិរបស់ខ្លួនថា ជាឱរសរបស់សួគ៌មិនថាអង្គណា មិនថាវង្សណា ទ្រង់សុទ្ធតែជាឱរស របស់សួគ៌ជាមួយគ្នាទាំងអស់ ចក្រពត្តិរបស់ជប៉ុនជាអង្គតែមួយខ្សែស្រឡាយតែមួយ បន្តមកពីព្រះអាទិត្យតាំងពីអង្គដំបូងគ្មានដាច់ អង្គដំបូងជាកូនចៅ ព្រះអាទិត្យ សួគ៌ជាមួយគ្នាទាំងអស់ ចក្រពត្តិរបស់ជប៉ុនជាអង្គតែមួយ ខ្សែស្រឡាយតែមួយបន្តមកពីព្រះអាទិត្យតាំងពីអង្គដំបូងគ្មានដាច់ អង្គដំបូងជាកូនចៅព្រះអាទិត្យនិងព្រះច័ន្ទ អង្គទីពីរជាចៅទួតជាប់បន្តគ្នាមក ដោយលំដាប់ ជាវង្សតែមួយពុំមានការផ្លាស់ប្តូរត្រកូលឡើយ ឋានៈរបស់ចក្រពត្តិជប៉ុនទើបជាឋានៈដែលរឹងមាំ ជាងចក្រពត្តិរបស់ចិន និងរបស់ប្រទេសដទៃទៀត។

ចក្រពត្តិចិនជាឱរសរបស់សួគ៌ តែអ្នកទីក្រុងមិនមែនជាពូជពង្សរបស់ចក្រពត្តិ ចក្រ-ពត្តិចិននិងជនជាតិចិនជាមនុស្សមានបុព្វបុរសផ្សេងគ្នា ជាអ្នកមានពូជអម្បូរម្នាក់ម្ខាង មិនមានការជាប់ទាក់ទងគ្នាទេ ចក្រពត្តិ ចិនជាមនុស្សសួគ៌ តែពលរដ្ឋចិនជាមនុស្សនៅលើផែនដី ចក្រពត្តិចិនទើបពុំមែនជាអ្នកដឹកនាំគ្រួសាររបស់ ជនជាតិចិនទូទាំងជាតិ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០០)

ចក្រពត្តិជប៉ុនជាមេដឹកនាំគ្រួសាររបស់ពលរដ្ឋជប៉ុនទូទាំងជាតិ ជប៉ុនជាគ្រួសារតែមួយទាំងអស់គ្នា ជប៉ុនព្រមលះបង់អ្វីៗក៏បាន តែមិនព្រមលះបង់មេដឹកនាំគ្រួសាររបស់ខ្លួនឡើយ។

តាំងពីមុនមកចក្រពត្តិស្តេចចេញទៅណាមិនបានឡើយ ត្រូវប្រថាប់នៅក្នុងសួគ៌ ការតឹងរឹងនេះបានបន្ធូរជាលើកដំបូង កាលបើមានការអនុញ្ញាតឱ្យម្កុដរាជកុមាររជ្ជទាយាទរបស់បល្ល័ង្កសួគ៌ ស្តេចចេញពីប្រទេសបាន។ គតិរបៀបនេះ ប្រែក្លាយចុះមកជាធម្មតាសាមញ្ញក្នុង

ពេលបច្ចុប្បន្ន ចក្រពត្តិទ្រង់មានឋានៈជាអ្នកប្រជាធិបតេយ្យមិនមែនជាមនុស្សស្ទួគិ (ការចប់សង្គ្រាមលោកលើកទីពីរ ព.ស.២៤៨៨)។

គម្ពីរនិហុង្គិអធិប្បាយរហូតដល់មានជម្រៅថា អង្គព្រះមហាចក្រពត្តិជាអវតារមកអំពីព្រះអាទិត្យ ព្រះអំណាចផ្សេងៗដែលព្រះមហាក្សត្រទ្រង់មាន ជាព្រះអំណាចដែលព្រះអាទិត្យទ្រង់ប្រគល់មកឱ្យទាំងអស់ មានពាក្យបង្រៀនឱ្យពលរដ្ឋថ្វាយអំណាច តែព្រះអង្គព្រះមហាចក្រពត្តិ ទ្រង់ជាអ្នកគ្រប់គ្រងពពួកកោះទាំង៨ កោះរបស់ជប៉ុន ក្នុងឋានៈទេវរាជអ្នកបានទទួលព្រះអំណាចដែលបានប្រគល់មកឱ្យ។

រដ្ឋធម្មនុញ្ញគ្រប់គ្រងផែនដី (ច្បាប់ដើម) មាត្រា២និង៣កំណត់ទុកថា “ផែនដី” ជប៉ុននឹងត្រូវគ្រប់គ្រងដោយសម្តេចព្រះមហាចក្រពត្តិ ជាអ្នកជំណាវង្សត្រកូលមកអំពីស្ទួគិ ជាសន្តតិវង្សមិនដាច់ខ្សែស្រឡាយជានិរន្តរ៍ ហើយសម្តេចព្រះមហាចក្រពត្តិនោះ ជាអ្នកស័ក្តិ សិទ្ធិដែលអ្នកណាមិនអាចល្មើសបាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០១)

ក្នុងសម័យចក្រពត្តិមេយ៉ី មានព្រះបរមរាជឱង្ការទាក់ទងការសិក្សារបស់ ប្រជាពលរដ្ឋ បានចេញច្បាប់ មួយក្នុងថ្ងៃទី៣០ តុលា ព.ស.២៤៣៣ សម្តែងពីយសស័ក្តិរបស់ចក្រពត្តិដូច្នេះ៖

“ពលរដ្ឋទាំងឡាយរបស់យើងចូរដឹងថា គ្រប់ៗគ្នាមាននាទីការពារនិងទ្រទ្រង់ទុកនូវសេចក្តីរុងរឿងនៃរាជបល្ល័ង្កដ៏ស័ក្តិសិទ្ធិនាស្ទួគិជាសន្តតិវង្សតទៅអស់កាលជានិច្ចនិរន្តរ៍”។

អមតេរៈសុអូមិគៈមិឬសូរិយទេព បុព្វបុរសរបស់ជប៉ុនមានទីស្ថានបូជាធំ សាងឧទ្ទិសទុកថ្វាយនៅកន្លែង សាលាអ្នកតាអ៊ីសា (Isejingu) ក្នុងខេត្តនារា នៅទិសអាគ្នេយ៍នៃទីក្រុងកៀវតូ រាជធានីចាស់របស់ជប៉ុន។

អ្នកតាអ៊ីសេមានជំនឿថា សាងឡើងដោយថ្វីដៃរបស់ព្រះជាម្ចាស់តួយ៉ូសុកិអិរិហាមៈក្នុងរជ្ជកាលរបស់ចក្រពត្តិស៊ូយិន ប្រមាណជាព.ស.៥៧៣ មកដល់ពេលនេះជិត២ពាន់ឆ្នាំ។ មានទំនៀមទម្លាប់ថា សម្តេចព្រះ ចក្រពត្តិជប៉ុន ស្តេចត្រូវទៅធ្វើពិធីសែនព្រែនដល់សុរិយទេព បុព្វបុរសរបស់ព្រះអង្គមួយឆ្នាំម្តង ដូចគ្នានឹងស្តេចចក្រពត្តិចិន ស្តេចធ្វើពិធីសែ ព្រេនសៀនទីមួយឆ្នាំម្តង (ដូចជាមានរឿងក្នុងសាសនាតៅ)។ សាលាអ្នកតាអ៊ីសេជា មហាទីស្ថានស័ក្តិសិទ្ធិរបស់ជនជាតិជប៉ុនទាំងឡាយ (ដូចជាយេរូសាលឹម របស់ជនជាតិជ្វីហ្វ ពុទ្ធ គយារប

ស់ពុទ្ធសាសនិក វាំទីកន់របស់គ្រិស្តសាសនាកាតូលិក និងទីក្រុងមេក្កៈរបស់ជនជាតិ មូស្លីម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០២)

នៅទីស្ថានសាលាអ្នកតាអ៊ីសេ មានវត្ថុសំខាន់មួយដូចដែលមាននៅតាមសាលាធំៗទូទាំងប្រទេស គឺ កញ្ចក់ស្រមោល។ រឿងកញ្ចក់ស្រមោលមានអធិប្បាយថា ជាគ្រឿងបញ្ញាក៏មានតែអធិប្បាយភាគច្រើនថា ជាគ្រឿងបញ្ញានៃសុរិយទេព ជាបុព្វបុរសអន្តជំបូងរបស់ជប៉ុន។

ក្នុងគម្ពីរនិហន្ទិសសរសេរថា "អមតេរៈសុអូមិគៈមិ ទ្រង់នាំកញ្ចក់ពិសេសចុះមក ឱ្យចៅមួយផ្ទាំង ដោយទូន្មានថា "កូនរបស់ខ្ញុំមើលកញ្ចក់មួយផ្ទាំងនេះ អ្នកនឹងឃើញខ្ញុំ" មានន័យថាកញ្ចក់ស្រមោលនេះ ជា សញ្ញារបស់ព្រះអាទិត្យ តាមគតិនេះ។

សាលាអ្នកតាអ៊ីសេ សូម្បីសាងមកតាំងពី២ពាន់ឆ្នាំ តែក៏នៅមានទំនៀមទម្លាប់បន្តគ្នាមកថា ត្រូវតែសាងបន្ថែមតាក់តែងថ្មីគ្រប់២០ឆ្នាំ។ ជនជាតិជប៉ុនតែងប្រាប់យើងថា មហាសាលាអ្នកតានេះសាងមកជិត២ ពាន់ឆ្នាំហើយ តែមើលទៅហាក់ដូចជានៅថ្មី ទើបនឹងសាង ២០ឆ្នាំ។

ការសម្តែងសេចក្តីស្រឡាញ់និងកក្តីកាពចំពោះព្រះមហាសម្តេចចក្រពត្តិ ប្រហែលគ្មាននឹងការស្រឡាញ់ កក្តីចំពោះអមៈតេរៈសុអូមិគមិផងដែរ ថ្ងៃប្រសូតរបស់មហាចក្រពត្តិប្រកាន់យកថា ជាថ្ងៃសំខាន់បំផុតរបស់ជនជាតិជប៉ុន ប្រហែលគ្មានថ្ងៃបូជាព្រះអាទិត្យ ក្នុងគ្រាដ៏ធំ ទង់ជាតិជប៉ុនមានសញ្ញាវង់ក្រហម ក្នុងផ្ទាំងទង់ជាតិគឺគ្រឿងសញ្ញារបស់ដួងអាទិត្យអ្នកជាបុព្វបុរសរបស់ខ្លួន ការដែលបានឃើញទង់ស្មើនឹងបានឃើញ ព្រះអាទិត្យនិងស្មើបានឃើញព្រះមហាចក្រពត្តិផង។ ជប៉ុនបាននាមថា "ផែនដីនៃដួងព្រះអាទិត្យ" (The land of rising the sun) ដោយមកអំពីគតិនៃការរាប់អាន ដូចបានពោលមកនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០៣)

### ការបូជាសាសនា

ការបូជាក្នុងលទ្ធិជិន្តោ បើនិយាយគឺការសំពះអ្នកតារបស់ជប៉ុន ខុសពីការសំពះអ្នកតារបស់ចិន ការសំពះអ្នកតារបស់ជប៉ុនមិនបាច់អស់ជ្រូក ទា មាន់ ស្រា ហើយមនុស្សយកមកបរិភោគដូចចិនដែរ។ ជប៉ុនចេញទៅ សំពះអ្នកតាត្រឹមតែតែងខ្លួនឱ្យស្អាតចូលទៅឱនគោរពចំពោះមុខអ្នកតាធ្មេចភ្នែក ទះដៃហៅដួងវិញ្ញាណមកទទួលការសំពះ បើមិនទះដៃក៏

ឈរស្មៀមនៅមួយសន្ទុះ ហើយក៏ត្រឡប់ចេញទៅតែអាចមានរបៀបផ្សេងៗ ទៀតខ្លះ តាមដែលអ្នកបួសឬអ្នកចាំសាលា និងជាអ្នកណែនាំឱ្យធ្វើ។

គ្រឿងអាមិសបូជា ដែលនឹងត្រូវនាំទៅសំពះអ្នកតា មានអ្នកបួសឬអ្នកចាំសាលា ជាអ្នកចាត់ចែងឱ្យ និងមានទុកជម្កល់ដូចគ្នាទាំងអស់គ្រប់សាលាអ្នកតា គ្រឿងអាមិសទាំងនោះមានស្រាសាកេ (របស់ជប៉ុន) ៤ ពែងតូចៗ បាយពំនូត១៦ដុំ អំបិល១៦ដុំ ត្រីស្រស់ផ្លែឈើសារាយសមុទ្រ និងផ្លែឈើផ្សេងៗមិនសូវជាច្រើនណាស់ណាទេ អ្នកទៅបូជាមិនបាច់បង់ប្រាក់។

កាលប្រទេសជប៉ុនទទួលយកធម្មៈ ក្នុងសាសនាខុងជឺរបស់ចិននិងពុទ្ធសាសនា ចូលទៅក្នុងពេលខាងក្រោយអ្នកប្រាជ្ញជានាក៉ាប់រងថា ជនជាតិជប៉ុនបានប្រើសេចក្ដីវៃឆ្លាតផ្លាស់ប្ដូរគោលធម៌ទាំងពីរដែលបានមកថ្មី ចូលរួមជាមួយនឹងគោលធម្មផ្សេងៗ ក្នុងសាសនាជិន្តោឱ្យផ្សំជារូបបែបរបស់ជប៉ុន ដើម្បីឱ្យសមរម្យដល់សន្តមនិងទឹកដីអាកាស ក្នុងផែនដីរបស់ខ្លួន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០៤)

បើសួរថាជនជាតិជប៉ុន រាប់អានសាសនាណាពិតប្រាកដតែអាចឆ្លើយបានថា ជនជាតិជប៉ុនរាប់អាន សាសនាជិន្តោ (ដែលមានសាសនាតៅនិងខុងជឺរួមជាមួយផង) នេះមួយយ៉ាង និងរាប់អានពុទ្ធសាសនាមួយយ៉ាងទៀត។ ជនជាតិជប៉ុនរាប់អានសាសនាជិន្តោដើម្បីរក្សាឱ្យមានឯកភាពតែមួយរបស់ជាតិ និងរាប់អានពុទ្ធសាសនាដើម្បីសាងមនុស្ស ឱ្យជាមនុស្សល្អ ជាពលរដ្ឋល្អរបស់ជាតិ បើមិនឆ្លើយដូច្នោះគេនឹងឆ្លើយថា ជប៉ុន រាប់អានសាសនាជិន្តោដើម្បីប្រយោជន៍ស្រុកទេស និងរាប់អានពុទ្ធសាសនា ដើម្បីប្រទេស ជាតិក៏បាន។ នៅក្នុងផ្ទះរបស់ជនជាតិជប៉ុនគ្រប់ផ្ទះ មានទីកន្លែងបូជានៅ២កន្លែងជាអាសនៈ បូជាជិន្តោមួយនិងអាសនៈបូជាពុទ្ធសាសនាមួយទៀត។

ប្រទេសជប៉ុនបានឈ្មោះថា ផែនដីនៃសាលាអ្នកតា មានអ្នកល្បងរាប់មើលចំពោះសាលាអ្នកតាខ្នាត កណ្ដាលនិងធំ មានជិតដល់ទៅ២០០.០០០ បើឃើញ "តេារី" ទ្វារវិញ្ញាណទាំងរបស់មនុស្សរស់និងមនុស្សស្លាប់ ដើរចូលទៅបូជាព្រះអាទិត្យ ដែលមាននិមិត្តសំគាល់នៅខាងក្នុងតាំងនៅត្រង់ទីណា ទោះបីតូចខ្លះធំខ្លះ នេះខ្លះ នោះខ្លះ គឺត្រូវមានសាលាអ្នកតា។ សាសនាអ្នកតាតូចៗដែលមិនមាន "តេារី" ក៏មាននៅមិនតិចដែរ។

កាលបើជប៉ុនជាផែនដីនៃអ្នកតា ទើបជាផែនដីនៃការបួងសួងនិងពិធីកម្ម អ្នកតាក៏កាន់តែច្រើន ព្រះជាម្ចាស់ក៏កាន់តែច្រើនដែរ ពិធីកម្មផ្សេងៗក៏កាន់តែច្រើនទៅតាមនោះដែរ បើកំណត់ថាអ្នកតាមានដល់ទៅសែន ពិធីកម្មក៏គួរត្រូវមានទៅដល់សែនដែរ។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០៥)

គម្ពីរយេនងិឝិកិ (គម្ពីរក្បាលទី៣) សរសេររឿងពិធីកម្មពាក្យសូត្រ ដែលហៅថា នោរិតុ (Nori-to) ក្នុងសាសនាទុកជាចំនួនច្រើននោរិតុ ប្រកបដោយពាក្យអញ្ជើញទេពអង្គនីមួយៗ ក្រុមនីមួយៗ ពាក្យបូជា ពាក្យសែនព្រេន ក្រាបសំពះបែបរបស់វត្ថុផ្សេងៗ ដែលប្រើក្នុងពិធីនោះៗវត្ថុបែបណាប្រើក្នុងពិធីណា មានន័យសេចក្តីយ៉ាងណាក៏ប្រាប់ទាំងអស់។ ពាក្យសម្តីក្នុងនោរិតុ ជាអក្សរសាស្ត្រជប៉ុនជាន់ខ្ពស់ ប្រាប់ការអាន ការសូត្រ មានខបង្គាប់បញ្ជាឱ្យអានឬសូត្រដោយពាក្យពេជន៍ឱ្យត្រូវអក្ខរៈច្បាស់។ បើអានមិនត្រូវតាមទំនង មិនត្រូវអក្សរទេព ដែលអញ្ជើញស្តេចនឹងមិនមកប្រោស ហើយត្រូវជំនួសពាក្យពីអញ្ជើញទេព ក៏ក្លាយជាពាក្យអញ្ជើញភូតបិសាចទៅវិញ។

លទ្ធិក្នុងសាសនាជិន្តោ ដែលមានទៅម៉ឺនសែននោះ ពិបាកនឹងពោលឱ្យបានសព្វគ្រប់។ សូមលើកមកឱ្យឃើញជាតួយ៉ាង ជាអាទិ៍ពិធីព្រោះស្រូវក្នុងស្រែ ហៅពិធីតោជិង៉ោហិ ធ្វើក្នុងខែទីពីរ លុះដល់ស្រូវចេញផ្កា ក្នុងខែទីបួនធ្វើពិធីម៉ៃកោជូក័ស្តុម្តងទៀត ហៅថាពិធីហិរោសេឱហោឥមិ។ លុះស្រូវចេញផ្លែធ្វើពិធីទទួលស្រូវថ្មី ពិធីនេះសម្តេចមហាចក្រពត្តិស្តេចជាពិធីរបស់រដ្ឋ នៅមានពិធីប្រូតកាត់ទៀតផងដែរ។ ជាប់ទាក់ទងគ្នារហូតមួយឆ្នាំនិងមានពិធីប្រចាំខែ ហើយក្នុងខែនីមួយៗ នៅមានពិធីផ្សនៗគ្នាធ្វើនៅទីក្រុងនេះមួយបែប នៅទីក្រុងនោះមួយបែបទៀត ផ្លាស់ប្តូរគ្នាធ្វើទូទាំងប្រទេស។ គេនិយាយថា បើនៅក្នុងប្រទេសជប៉ុន១ឆ្នាំ ផ្លាស់ទៅនៅទីក្រុងនីមួយៗ៧ថ្ងៃ នឹងបានឃើញពិធីជិន្តោជាប់តគ្នាគ្រប់៧ថ្ងៃ រហូតពេញមួយឆ្នាំ។ (ហេន គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២០៦)

ការសំអាត ៖ ជាគោលការណ៍ធំរបស់ជិន្តោមួយទៀត ដូច្នេះទើបគេនិយាយថា ការសំពះអ្នកតារបស់ជប៉ុនខុសពីការសំពះអ្នកតារបស់ចិន។ ក្រៅអំពីខុសគ្នាមិនបាច់មានគ្រឿងសែនព្រេនអ្នកតាដើម្បីនឹងបាន មនុស្សបរិភោគពេលចុងក្រោយ នៅមានការខុសគ្នាច្រើនត្រង់ការសំអាត។

ក្នុងគម្ពីរនិយាយច្រើន អាងពីការសំអាតទុកជាគោល តាំងពីមហាទេពឥសីណានិទេពបិតារបស់ព្រះអាទិត្យ ទ្រង់ជម្រះលាងរាងកាយរបស់ព្រះអង្គឱ្យស្អាតមុនជានិច្ចសិន ទើបកូនចៅតមកតាំងពីអមតេរៈសុឌិ មិគៈមិ (ព្រះអាទិត្យ) ព្រះមហាចក្រពត្តិនិងពលរដ្ឋទាំងឡាយ ទើបត្រូវលាងជម្រះរាងកាយឱ្យស្អាតដូចគ្នា។ ជនជាតិជប៉ុនមុនទៅសាលាអ្នកតា ត្រូវងូតទឹកជាមុន ទៅដល់មុខសាលាអ្នកតាត្រូវលាងដៃលុបលាងមុខ លាងមាត់ឱ្យស្អាតម្តងទៀត។

រឿងទាក់ទងនឹងការសំអាតក្នុងសាសនាជិន្តោ មានអធិប្បាយទូលំទូលាយទៅទៀត ក្លាយទៅជាពិធីលាងបាបដូចជាគតិនិយម ក្នុងសាសនាជាច្រើនសាសនា។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២០៧)

ជិន្តោមានពិធីមួយទៀតហៅថា ឱហោហារាសិ (The great purification) គឺពិធីជម្រះបាបយ៉ាងធំមានពាក្យអធិប្បាយរបស់អស្សតាន់ (Aston) ដែលជាអ្នកប្រាជ្ញក្នុងលទ្ធិនេះមួយវគ្គថា "ដោយព្រះមហាករុណា របស់សម្តេចព្រះមហាចក្រពត្តិ ដែលព្រះជាម្ចាស់អមតេរៈសុឌិមិគៈមិ ទ្រង់ប្រគល់អំណាចមកដល់ព្រះអង្គ។ ការធ្វើពិធីឱ្យប្រកបដោយការប្រោះ ព្រំ (ការលាងជម្រះ) ដោយទឹកបរិសុទ្ធជាដំបូង ហើយសែនព្រេនបួងសួង ប្រព្រឹត្តទៅដើម្បី ជាការតបស្នង (បាប) បណ្តាមុខមន្ត្រីនិងពលរដ្ឋរបស់ព្រះអង្គ អ្នកធ្វើពិធីនេះ ត្រូវធ្វើសេចក្តីបរិសុទ្ធឱ្យកើតដល់ខ្លួនជាមុន ដើម្បីរំដោះបាបចេញទៅឱ្យផុតអំពីខ្លួន។

"បណ្តាគ្រឿងសែនព្រេនសេពសោយ ឱ្យទម្លាក់ចោលទៅក្នុងទន្លេឬស្ទឹង ជាការនាំបាបរបស់អ្នកដែល ធ្វើឱ្យអណ្តែតទៅតាមទឹក"។

គតិនៃការជម្រះលាងបាបក្នុងជិន្តោ ធ្វើឱ្យជនជាតិជប៉ុនជាជាតិស្រឡាញ់សេចក្តីស្អាតជាជាងជនជាតិដទៃ បើនិយាយឱ្យចំត្រូវទទួលថា ស្អាតជាជាងបណ្តាអ្នកមុជទឹកក្នុងទន្លេគង្គារបស់ព្រាហ្មណ៍។

ប្រភេទរបស់ជិន្តោ

សាសនាជិន្តោ បែកចេញជា ២ ប្រភេទគឺ ៖

១-កក្កៈជិន្តោ (KokkaShinto) បានដល់ជិន្តោប្រភេទរបស់រដ្ឋ (State shinto) ជិន្តោប្រភេទនេះរដ្ឋ ទទួលជាច្បាប់រាជការផ្លាស់ប្តូរទៅជាបែបណាទៀតមិនបានឡើយ។

២-រាវហៈជិន្តោ (RyohaShinto) ឬជូហៈជិន្តោ បានដល់ជិន្តោប្រជារាស្ត្រ ប្រភេទដែលបែកខ្ញែកជានិកាយផ្សេងៗដល់ទៅ២៣និកាយ ជិន្តោប្រភេទនេះមានពិធីកម្មនិងបញ្ញត្តិរាប់អានបែបផ្សេងគ្នា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២០៨)

កត្តៈជិន្តោឬជិន្តោ នៃរដ្ឋដែលជារឿងខាងផ្លូវរាជការនិងស្រុកទេស មានសេចក្តីពិពណ៌នាដូចខាងក្រោម នេះ ៖

កាលមុនសង្គ្រាមលទ្ធិជិន្តោលូតលាស់ មិនថាជិន្តោជាផ្នែករបស់រាជការឬក៏ជាផ្នែករបស់ពលរដ្ឋ មានអង្គការរដ្ឋបាល២កន្លែងដែលចូលមកគ្រប់គ្រងនិងទំនុកបម្រុង។

ជិន្តោរបស់រដ្ឋបានទទួលការទំនុកបម្រុងពីក្រសួងមហាផ្ទៃ ក្រសួងបានដាក់ខបង្គាប់ទុកមិនឱ្យអ្នកបួស ពួកនេះត្រាច់ចរទៅធ្វើពិធីឱ្យអ្នកឯណានីមួយៗ ត្រូវនៅធ្វើកិច្ចចំពោះក្នុងសាសនា ដែលរដ្ឋបានទទួលថាជា របស់រដ្ឋអ្នកបួស ជិន្តោពួកនេះជាមនុស្សរបស់អ្នករាជការប្រហែលគ្នាជារបស់ហ្លួង។

មានច្បាប់តទៅទៀតថា ហាមមិនឱ្យឃោសនាកិច្ចការណាមិនថាជាកិច្ចការប្រៀនប្រដៅឬការចេញទៅ ធ្វើពិធី មានពិធីទាក់ទងនឹងសង្គមយ៉ាងច្រើនជាអាទិ៍ពិធីអាពាហ៍ពិពាហ៍ ពិធីបញ្ចុះសព ក៏មិនឱ្យទាក់ទងទាំងអស់។

មុនសង្គ្រាមគ្រាដំបូង (ព.ស.២៤៥៨) "ជិន្តោនៃរដ្ឋ" ពង្រីកពាក្យអធិប្បាយនិងពិធីផ្សព្វផ្សាយប្រៀនប្រដៅចេញទៅជាច្រើន "ជិន្តោនៃរដ្ឋ" បណ្តុះបណ្តាលចិត្តផ្ទើមជនជាតិជប៉ុនឱ្យក្លាហាន សាងលទ្ធិជាតិនិយម យ៉ាងខ្លាំងក្លាតាមបែបរបស់ "បូជិន្តោ" ដែលជាចរិយារបស់ជនជាតិជាតិ ជាទាហាន គឺសំដៅយកជនជាតិជប៉ុនទាំងអស់។

តាមកំណត់មិនសូវច្បាស់លាស់ ដែលជប៉ុនអាស្រ័យគោលការណ៍ "ជិន្តោនៃរដ្ឋ" អំពើបែបនេះតមក កាលពីឆ្នាំទី១៥ នៃរដ្ឋសម័យចក្រពត្តិមេយី មានព្រះបរមរាជឱង្ការ "អំពីសួគ៌" ដោយទ្រង់ចុះមកកាន់ទាហាន គ្រប់កងពលជាសេចក្តីសំខាន់៥ខ ខនីមួយៗឱ្យធ្វើនាទីរបស់ខ្លួនជាទាហាន ឱ្យស្មោះត្រង់កក្តីភាពចំពោះបល្ល័ង្កសួគ៌ និងឱ្យស្តាប់បង្គាប់បល្ល័ង្កសួគ៌ ឱ្យមានសេចក្តីក្លាហាន ឱ្យស្លាប់ដើម្បីបល្ល័ង្កសួគ៌នោះ និងឱ្យស្តាប់បង្គាប់មេបញ្ជាការជាលំដាប់ដែលឱ្យប្រកាន់ស្មើគ្នាបញ្ជាមកពីសួគ៌។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២០៩)

តាំងតែពីមានព្រះបរមរាជឱង្ការច្បាប់នោះមក ទាហានជប៉ុនក៏ក្លាយជាតុក្កតាគេមួល ឡានឱ្យដើរទាហានជប៉ុនជាទាហានរបស់អ្នកឋានសួគ៌ អ្នកណាមិនជឿស្តាប់ទាហានប្រហែល គ្មានឹងគ្មានភក្តីចំពោះចក្រពត្តិ អ្នកណាធ្វើបាបទាហាន ប្រហែលគ្នានឹងធ្វើបាបចក្រពត្តិ។

ក្នុងប្រវត្តិសាស្ត្រ ទាហានរបស់ជប៉ុនត្រូវធ្វើសង្គ្រាមជាមួយនឹងរុស្ស៊ី ក្នុងព.ស. ២៤៤៧-២៤៤៨ ទាហានរបស់សម្តេចព្រះមហាចក្រពត្តិយកឈ្នះទាហានរុស្ស៊ី ដែលមានអំណាចច្រើនជាងបាន ជប៉ុនក្លាយជាប្រទេសមហាអំណាច មានកិត្តិយសធំឡើងក្នុងទិសខាងកើត ប្រទេសជប៉ុនក្លាយទៅជាគំរូ សម្តែងថាជនជាតិទិសខាងកើតមានសមត្ថភាពស្មើនឹងជនជាតិខាងលិចដែរ។

ការឈ្នះរបស់ទាហានចក្រពត្តិក្នុងគ្រានេះ មានផលល្អក៏ពិតមែន តែត្រឡប់ជាផលអាក្រក់ក្នុងរឿងលទ្ធិជាតិនិយម សេចក្តីស្រឡាញ់ជាតិក្លាយទៅជាសេចក្តីវង្វេងជាតិ ចរិយាទាហានគឺ “បូជិន្តោ” ក្លាយជាសីលស័ក្តិសិទ្ធិហួសពីការស្មានទិងធ្វើឱ្យជប៉ុនខូចការចេះដឹងខាងផ្លូវសន្តិភាពក្នុងទីបំផុត។

តាំងតែពីការនោះមក “ជិន្តោនៃរដ្ឋ” ក៏ឈានចូលទៅកាន់សម័យថ្មី មានការរៀបចំពាក្យប្រៀនប្រដៅថ្មី ជាលទ្ធិជាតិនិយមទូលំទូលាយនិងខ្លាំងក្លាចេញទៅជារយៈៗ សូមលើកតួយ៉ាងនៃពាក្យប្រៀនប្រដៅវគ្គខ្លះ មកឱ្យឃើញជាឧទាហរណ៍ ៖ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១០)

“យើងជនជាតិជប៉ុន តាំងសេចក្តីបំណងទុកថា ដើម្បីលើកតម្កើងឋានៈនៃសម្តេចព្រះមហាចក្រពត្តិនៃយើងឱ្យទៅជាអ្នកគ្រប់គ្រងលើលោកទាំងមូល ដោយហេតុថាព្រះអង្គជាម្ចាស់ ជាអ្នកបន្តវង្សមកអំពីលោក សួគ៌ដែលពុំមានការដាច់ខ្សែស្រឡាយ គឺព្រះអង្គនេះហើយជាអ្នកតំណាងខាងដួងវិញ្ញាណនៃលោក ព្រះអង្គទ្រង់ជាអ្នករង់ចាំគ្រប់គ្រងលោក។

“ជាការពិតណាស់ថា មនុស្សជាតិទាំងឡាយនឹងផុតពីមហន្តរាយបាន ក៏ព្រោះការជួយសង្គ្រោះនៃអាណាចក្ររបស់យើង បច្ចុប្បន្ននេះជាតិទាំងឡាយ តាំងនៅគ្មានរបៀបរៀបរយទេ ជាតិផ្សេងៗតស៊ូដើម្បីប្រយោជន៍របស់ខ្លួននិងកំពុងគិតថា អ្នកដទៃជាសឹកសត្រូវរបស់ខ្លួន។ល។

"សូម្បីពុំមានវិហារបូជនីយដ្ឋានណាមួយក្តី ជាតិរបស់យើងក៏អាចតាំងនៅបាន តែបើសាសនាជិន្តោត្រូវ ឈប់ស្ងប់ស្ងាត់ជាតិរបស់យើងនឹងដល់នូវទីបំផុត ព្រោះថាជិន្តោជាមជ្ឈ-មណ្ឌលនៃអាណាចក្រផងដែរ។

"ការធ្វើសង្គ្រាមជាបិតានៃការកសាង និងជាមាតារបស់វឌ្ឍនធម៌ (សោសោះណោះចិចិបុន្តណោះហះហះ) សង្គ្រាមជារបស់ដែលមិនអាចជៀសវាងបាន អាចចូលជាមួយគ្នាបាន និងការគិតដែលថាអំណាចជាធម៌។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១១)

កក្កៈជិន្តោ "ជិន្តោនៃរដ្ឋ" មានដំណើរការផ្សព្វផ្សាយមកយ៉ាងខ្លាំងក្លា ធ្វើឱ្យកើតការយល់ខុស ឈ្លក់វង្វេងក្នុងឯកភាពរបស់ជាតិនិងរបស់ប្រជាជន ដូច្នេះក្នុងទីបំផុត ជប៉ុនទើបបានទទួលផលគឺសង្គ្រាមនិងការ វិនាសទ្រុឌទ្រោមទៅវិញ។

លុះចប់សង្គ្រាមលោកលើកទី២ទៅ សម្ព័ន្ធមិត្តអ្នកមានជ័យជម្នះក្នុងចម្បាំង មើលឃើញកយន្តរាយដែលកើតពីជិន្តោនៃរដ្ឋ ជាផលឱ្យកើតការឈ្លក់វង្វេងចំពោះជាតិ ដូចបានពោលមកហើយនោះឧត្តមសេនីយមេគអាធូរ៍បានចូលមកគ្រប់គ្រងកោះជប៉ុន ទើបចេញជាប្រកាសថ្ងៃទី១៥ តុលា ព.ស.២៤៨៨ ឱ្យលះបង់ជិន្តោនៃរដ្ឋ មិនព្រមឱ្យមានមហាសាលាអ៊ីសេ (អនុស្សាវរីយ៍វីរបុរសមាននាម លីល្បាញ ជាមជ្ឈមណ្ឌលនៃការឈ្លក់វង្វេងជាតិ តទៅទៀតឡើយ។

សម្ព័ន្ធមិត្តប្រកាសថា ព្រោះផលអាក្រក់ដែលបានមកអំពីសង្គ្រាម ទើបបង្គាប់ បញ្ជាឱ្យឈប់ជ្រើជិន្តោនៃ រដ្ឋ ៖

១-ឱ្យជប៉ុនបញ្ឈប់ការឃោសនា នាំឱ្យមានការយល់ខុសតទៅទៀត។

២-បញ្ឈប់មិនឱ្យយុវជន មានការចូលចិត្តទោរទន់ធ្វើសង្គ្រាម។

៣-ជួយឱ្យជាតិជប៉ុនមានសេរីភាពខាងផ្លូវសាសនា។

៤-ជួយឱ្យជាតិជប៉ុនរួចផុតពីទាសភាពរបស់ទេវតា។ ទាំងដោយចំពោះនិងមិនចំពោះត្រង់ពីលើតែម្តង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១២)

លុះមេគធូរ៍មេទ័ពសហរដ្ឋអាមេរិកប្រកាស ឱ្យលើកលែងឈប់មានជំនឿជិន្តោនៃរដ្ឋខាងសំណាក់ព្រះបរមរាជវាំង ក៏មានព្រះបរមរាជឱង្ការរបស់សម្តេចព្រះមហាចក្រពត្តិប្រកាសលះបង់ព្រះឋានន្តរស័ក្តិ "ឱរសនៃសូគិ" ភ្លាមមួយរំពេចនិងប្រកាសថាសេចក្តីសម្ព័ន្ធ

រវាងរាជបល្ល័ង្កនិងពលរដ្ឋនៅក្នុងឋានៈអ្នកប្រជាធិបតេយ្យជាមួយគ្នា ពុំមែននៅក្នុងឋានៈជាអ្នកសួគ៌ដូចពីមុនឡើយ។

រាវហៈជិន្តោគឺជាជិន្តោ ជាផ្នែករបស់ប្រជារាស្ត្រ (កំណត់ខាងក្រោយសម័យមេឃីដូចគ្នា) គ្មានការកិច្ច ពិធីអ្វីទាក់ទងនឹងផ្លូវរាជការទេ ជិន្តោពួកនេះពុំមានអគ្គការរដ្ឋ ជាអ្នកឃុំគ្រងឬទំនុកបម្រុងឡើយ និកាយនីមួយៗធ្វើការងាររៀងៗខ្លួន។

និកាយរបស់រាវហៈជិន្តោ ឬ (Sectarian Shinto) សេតតេវៀន ជិន្តោចែកជា ១៣ និកាយគឺ ៖

ជិន្តោហងកៀវកុឬតៃកៀវជិនរិកៀវ និងតៃសាកៀវ៣និកាយនេះប្រកាន់ថា ជាជិន្តោបរិសុទ្ធ (Pure-shinto Sects) មានបញ្ញត្តិតាមគម្ពីរ។ ដូជេហៈ និងតៃសេកៀវ ២និកាយនេះ ជាជិន្តោផ្សំសាសនាខុងជឺ (Confuction sects) យិក្កោកៀវហ្វ៊ូសោកៀវនិងមិតាកេះកៀវ ៣និកាយនេះហៅថា (Moun Tain Sects) កើតមកពីគតិរាប់អានភ្នំនិងទេព្តា មានពាក្យប្រៀន ប្រដៅជាអាថ៌កំបាំង ដូចជាអាថ៌កំបាំងភ្នំ។ ជិនជូកៀវនិង មិជោងិកៀវ២និកាយនេះ រាប់ អានទៅខាងលទ្ធិជម្រះលាងបាប (Purrfitcation sects) ហ្វ៊ូរោងិជូកៀវ គងកូ-កៀវនិងទេនរិកៀវហៅថា (Sects of Peasant origin) ជាជិន្តោប្រភេទអ្នកស្រុក គិតនឹងបញ្ញត្តិជា មួយគ្នា ឡើងដោយខ្លួនឯងតាមការយល់ មានអ្នកនិយមរាប់អានច្រើន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ២១៣)

**បញ្ញត្តិនិងចរិយាធម៌**

និកាយទាំងអស់នេះរាប់អានគោរពព្រះជាម្ចាស់ដូចគ្នាទាំងអស់ គ្រាន់តែបំបែកបញ្ញត្តិនិងពិធីកម្មខ្លះខុសគ្នា ហើយយកមកបញ្ជាក់នូវនិកាយខ្លះដែលសំខាន់ដើម្បីសម្តែងឱ្យឃើញចរិយាធម៌របស់ជិន្តោទាំងអស់នេះ។ ចរិយាធម៌របស់ជិនរិកៀវជិន្តោ ៖

១-កុំប្រព្រឹត្តកន្លងល្មើសទឹកព្រះទ័យរបស់ព្រះជាម្ចាស់ (កុំល្មើសបញ្ញត្តិរបស់ព្រះជាម្ចាស់)។

២-កុំភ្លេចសម្ព័ន្ធភាពដែលមានចំពោះបុព្វបុរស។

៣-កុំប្រព្រឹត្តល្មើសបញ្ញត្តិនៃរដ្ឋ។

៤-កុំភ្លេចសេចក្តីករុណាដ៏ជ្រាលជ្រៅរបស់ព្រះជាម្ចាស់ កាលណាបើយើងជួបប្រទះនឹងជោគអាក្រក់ សេចក្តីអន្តរាយនោះ ព្រះអង្គនឹងមកជួយឱ្យអស់ទៅ កាលបើមានការឈឺចាប់ព្រះអង្គក៏មកជួយឱ្យជាសះស្បើយបាន។

៥-កុំភ្លេចថាលោកជាគ្រួសារតែមួយ។

៦-បើមានអ្នកណាក្រោធខឹង កុំក្រោធខឹងតប។

៧-កុំខ្ជិលច្រអូសក្នុងកិច្ចការរបស់ខ្លួន។

៨-កុំធ្វើមនុស្សត្រិះដៀលពាក្យប្រៀនប្រដៅ។

៩-កុំឈ្លក់វង្វេងនឹងពាក្យប្រៀនប្រដៅរបស់ជនបរទេស។ល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១៤)

ចរិយាធម៌តែជាកៀវជិន្តោ

១-ធ្វើចិត្តឱ្យយុត្តិធម៌ដើម្បីគ្រប់គ្រងខ្លួនឯង។

២-ចូរមានសេចក្តីករុណាដល់មនុស្សទាំងឡាយ ឱ្យច្រើនជាជាងសេចក្តីករុណា ខ្លួនឯង ករុណាដល់មនុស្ស ដែលធ្វើសេចក្តីល្អជួយសង្គ្រោះឱ្យមនុស្សជាអ្នកទៀងត្រង់។

៣-គិតរកឧបាយឱ្យមានសេចក្តីសុខក្នុងចិត្ត ទាំងក្នុងពេលបច្ចុប្បន្ននិងតទៅអនាគត រកសេចក្តីឱ្យមនុស្សទាំងឡាយដូចជារកឱ្យខ្លួនឯងដែរ។ល។ បុគ្គលអ្នកធ្វើអំពើដូច្នេះបាន នឹងបានជាព្រះជាម្ចាស់ក្នុងពេលអនាគត។

ចរិយាធម៌របស់តែសេកៀវជិន្តោ

១-ឱ្យធ្វើពិធីបូជាព្រះជាម្ចាស់នៃសួគ៌ ព្រះជាម្ចាស់នៃផែនដីនិងដួងវិញ្ញាណរបស់មហាចក្រពត្តិ អ្នកមានខ្សែស្រឡាយតគ្នាមកនិងព្រះជាម្ចាស់ទាំងឡាយក្នុងទីស្ថាន (របស់ហ្លួង) ផ្សេងៗដែលជាទីគោរពបូជា។

២-ឱ្យរាប់អានបញ្ញត្តិរបស់ព្រះជាម្ចាស់ និងរក្សាបញ្ញត្តិទុកឱ្យគង់វង្សដូចជាការនៅស្ថិតស្ថេរនៃសួគ៌និងផែនដី និងជួយរក្សាបញ្ញត្តិនេះឱ្យប្រព្រឹត្តទៅដើម្បីសេចក្តីមាំទាំរបស់ជាតិ។

៣-ឱ្យព្រមទទួលនូវច្បាប់ពិតរបស់ធម្មជាតិ នឹងធ្វើឱ្យត្រិះខាងផ្លូវចិត្តឱ្យកើតសេចក្តីស្ងប់។

៤-ឱ្យយល់ន័យនៃជីវិតនិងសេចក្តីស្លាប់។

៥-ឱ្យរក្សានិងធ្វើកិច្ចការរបស់ខ្លួនឱ្យចម្រើនទៅមុខ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១៥)

៦-ឱ្យប្រតិបត្តិពិធីកម្មចំពោះព្រះជាម្ចាស់តាមដែលរាជវង្សធ្វើមក កុំឱ្យដាច់។

ចរិយាធម៌របស់មិតាកេះកៀវជិន្តោ

១-ប្រតិបត្តិតាមពាក្យណែនាំប្រៀនប្រដៅរបស់អ្នកបួសប្រចាំសាលា ប្រព្រឹត្តឱ្យជាតួយ៉ាងតាមហេតុ ផលរបស់សួគ៌និងកុំឱ្យប្រព្រឹត្តល្មើសបញ្ញត្តិរបស់ព្រះជាម្ចាស់នៃមិតាកេះ (ឈ្មោះអ្នកតាំងនិកាយ)

២-នឹកគិតដល់ព្រះជាម្ចាស់ នឹកគិតដល់សេចក្តីស្នេហាប្រទេសជាតិទុកក្នុងដួងចិត្ត ឱ្យកិត្តិយសនិងជឿ ស្តាប់ព្រះរាជឱង្ការរបស់ព្រះចក្រពត្តិ កុំល្មើសនឹងច្បាប់រដ្ឋ ចូរព្យាយាមប្រឹងប្រែងក្នុងកិច្ចការ។

៣-បូជាប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់លោកអ្នកជំទាំងឡាយ ចូរអត់ធ្មត់ដើម្បីសេចក្តីសុខ កុំមើលងាយអ្នកដទៃ ចូរជាអ្នកសុភាពរាបសា។

៤-ចូរទៀងត្រង់ស្រឡាញ់សេចក្តីពិត មិននិយាយដោយគ្មានគិត

៥-ប្រតិបត្តិចំពោះឪពុកម្តាយដោយសេចក្តីគោរពប្រតិបត្តិខ្លួនជាបងប្អូនរបស់មនុស្សទាំងឡាយ មិនថាជាអ្នកធ្វើដំណើរពីទីណាៗក្នុងករណីដែលគេមានការលំបាកនិងមានជំងឺ។

ចរិយាធម៌របស់ជិនដូកៀវជិន្តោ

១-បូជាព្រះជាម្ចាស់ទាំងឡាយក្នុងនិកាយនេះ

២-ធ្វើចិត្តឱ្យស្ងប់ ព្រោះការធ្វើចិត្តបានដូច្នេះ ជាផ្នែកមួយនៃដួងវិញ្ញាណរបស់ព្រះជាម្ចាស់

៣-គោរពចំពោះច្បាប់រដ្ឋ

៤-ប្រតិបត្តិតាមផ្លូវរបស់ព្រះជាម្ចាស់ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១៦)

៥-ភក្តីដល់អ្នកគ្រប់គ្រង

៦-ប្រតិបត្តិដល់មាតាបិតាឱ្យបានល្អជាទីបំផុត

៧-ករុណាដល់មនុស្សទាំងឡាយ

៨-ឧស្សាហ៍ក្នុងធុរៈកិច្ចការ

៩-រក្សារាងកាយឱ្យបានស្អាត។

ចរិយារបស់ជិន្តោដែលសម្តែងដោយអ្នកបួសរបស់និកាយដទៃៗ នៅមានជាច្រើនតែនឹងនៅមានប៉ុន្មានទៀតនោះ អាចឃើញបានអំពីសាលាអ្នកតាតូចធំរបស់ជិន្តោជាចំនួនម៉ឺនសែន មានអ្នកគោរពពកប់អានតាមស្ថិតិ ជាង២០លាននាក់ និងមានអ្នកព្រតនៅប្រចាំចំនួនច្រើនសែនទៀត។

សាសនាគ្រប់សាសនា រមែងមានចរិយាធម៌ជាគោល ដើម្បីញ៉ាំងជីវិតរបស់អ្នកប្រតិបត្តិឱ្យប្រព្រឹត្តទៅ រកសេចក្តីសុខក្នុងលោកនេះនិងលោកខាងមុខ តាមគតិនៃសាសនានោះៗដូចគ្នាទាំងអស់។

គោលប្រតិបត្តិដើម្បីគង់វង្សនៃជីវិតនេះឯង គឺចរិយាធម៌ក្នុងសាសនានោះៗ កាលដែលយល់ថាជិន្តោពុំមានចរិយាធម៌ ព្រោះមានតែរឿងរបស់ទេពនិទាននិងព្រះជាម្ចាស់ តែសេចក្តីពិតក្នុងទេពនិទានទាំងនោះ មានជាច្រើនវគ្គសម្តែងថា ជិន្តោមានចរិយាធម៌ដូចតួយ៉ាងដែលមានប្រាកដក្នុងគម្ពីរនិហង្គី ក្បាលទីមួយក្នុងខទី ៣០៧ បង្រៀនថា ៖

"អ្នកណានិយាយសេចក្តីពិត អ្នកនោះពុំមានមហន្តរាយ អ្នកណានិយាយកុតករ មានកកំហុសដោយ បោកបញ្ឆោត អ្នកនោះនឹងមានមហន្តរាយ។ល។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២១៧)

"ចូរលះបង់សេចក្តីប្រាថ្នាធំចេញ ដូរត្រេះតិះដៀលអំពើអាក្រក់ ចូរលើកតម្កើងសេចក្តីល្អ ឈប់ទោសៈ ឈប់មោហៈ កុំប្រណែននិន្ទាអ្នកដទៃ"។

បញ្ញត្តិក្នុងនិកាយផ្សេងៗនឹងសេចក្តីដែលប្រាកដក្នុងគម្ពីរ ដូចបានពោលទុកមកនេះ គឺជាចរិយាធម៌ ជាឫសគល់នៃសេចក្តីចម្រើនរបស់ផែនដីនិងដើម្បីជាទាហានដ៏ល្អរបស់ផែនដី។

**រឿងលោកខាងមុខ**

គតិនិយមរឿងលោកនេះនិងលោកខាងមុខរបស់ជិន្តោ ជារឿងសម្តែងចរិយាធម៌ម្យ៉ាងទៀតរបស់ជនជាតិជប៉ុន។

មូលដ្ឋានរបស់ជិន្តោដើម មានផ្នែកប្រហាក់ប្រហែលគ្នានឹងទស្សនវិជ្ជា រឿងសួគ៌និងរឿងព្រះជាម្ចាស់របស់ចិន ក្នុងទស្សនវិជ្ជារបស់ចិន មិនព្រមនិយាយអំពីរឿងលោកខាងមុខ មិនព្រមនិយាយដល់ជីវិតកាលដែលស្លាប់ទៅហើយ មិនសម្តែងកម្លាំងបញ្ជូនរបស់កម្មដែលនឹងមានដួងវិញ្ញាណរបស់អ្នកឯណានីមួយ។

គតិនិយមរបស់ជិន្តោ ក៏មិននិយាយដល់រឿងលោកខាងមុខថាមានសភាពយ៉ាងណា រឿងរបស់ជិន្តោជា រឿងរបស់ជីវិតក្នុងលោកនេះ។

គតិនិយមរបស់ជិន្តោមានថា វិញ្ញាណជារបស់មិនស្លាប់ មនុស្សស្លាប់ប្រៀបដូចជាផ្លាស់គ្រឿងតែងខ្លួនថ្មី ដួងវិញ្ញាណមិនសូន្យទៅណាទេ មិនមានឱកាសនឹងទៅ បើនឹងទៅកន្លែងណាមួយ ក៏គឺទៅរករូបរាងថ្មី ប្រៀបដូចទៅរកសម្លៀកបំពាក់ថ្មីៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១៨)

ដួងវិញ្ញាណនឹងនៅវិលវល់ជាមួយញាតិមិត្ត អ្នកនៅខាងក្រោយរង់ចាំរួមសុខទុក្ខនៅក្នុងផ្ទះសម្បែង ប្រសិនបើត្រូវការឱ្យដួងវិញ្ញាណមានសេចក្ដីសុខ អ្នកនៅខាងក្រោយត្រូវធ្វើអំពើល្អ ដើម្បីជាផលឱ្យកើតដល់ដួងវិញ្ញាណ ហើយនឹងបានទទួលពរពីដួងវិញ្ញាណផង ប្រសិនបើអ្នកនៅខាងក្រោយមិនធ្វើអំពើល្អ ផលក៏នឹងបញ្ជូនដល់វិញ្ញាណ ហើយដួងវិញ្ញាណនឹងដាក់ទោសបានដូចគ្នា។

សាសនាជិន្តោទើបមានការសែនព្រេនដួងវិញ្ញាណ តាមកាលសម័យដូចពិធីសំពះអ្នកតា ដូចជាជនជាតិចិន។

គោលប្រតិបត្តិដើម្បីសេចក្ដីល្អខ្ពង់ខ្ពស់

ពាក្យអធិប្បាយតទៅនេះ គឺគោលការណ៍ប្រតិបត្តិដើម្បីសេចក្ដីល្អខ្ពង់ខ្ពស់ ដែលជាចំណុចបំណងចុងក្រោយបង្អស់របស់អ្នកប្រតិបត្តិតាមលទ្ធិជិន្តោ។

ការប្រតិបត្តិតាមលទ្ធិជិន្តោ គឺមានស្វាមីភក្ដិចំពោះព្រះជាម្ចាស់ ចំពោះសម្ដេចព្រះមហាចក្រពត្តិ (ឱរសសួគ៌) និងប្រតិបត្តិតាមគោលចរិយាធម៌ផ្សេងៗដែលប្រាកដគោលប្រតិបត្តិ ដូចសម្ដែងមកដោយសរុបសេចក្ដី ហើយមានគោលនៃប្រតិបត្តិដើម្បីសេចក្ដីខ្ពង់ខ្ពស់នៅ ៤ ប្រការគឺ ៖

១-ឱ្យមានការគិតសប្បាយចិត្ត (អាកាតិ គោកោរោះ)

២-ឱ្យមានការគិតបរិសុទ្ធស្អាត (គិយោកិ គោកោរោះ)

៣-ឱ្យមានការគិតត្រឹមត្រូវ (ទាដាជិកិ គោកោរោះ) (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២១៩)

៤-ឱ្យមានសេចក្ដីគិតទៀងត្រង់ (នាឱកិ គោកោរោះ)។

អ្នកបានប្រតិបត្តិ ធ្វើចិត្តឱ្យមានសភាពដូចពោលមកហើយ អស់ជីវិតទៅនឹងទៅកាន់ការជាមួយគ្នានឹងព្រះជាម្ចាស់ បើនិយាយពីន័យមួយទៀត ការប្រតិបត្តិនេះនឹងនាំមនុស្សទៅកើតជាទេវតា។

ទោះបីយ៉ាងណាក្តី ត្រង់ចំណែកសរុបនេះ សូមលើកសេចក្តីយល់ឃើញរបស់អ្នកប្រាជ្ញជាច្រើនរូប សម្តែងសារសំខាន់របស់ជិន្តោ ជាផ្លូវនាំឱ្យឃើញវិញ្ញាណរបស់ជនជាតិជប៉ុនក្នុងអនាគត។

១-ជិន្តោជាមគ្គវិធីលើកស្ទួយទេពនិងទេពី (ធម្មជាតិទាំងពួង) ដែលមាននៅពីលើខ្លួនសួគ៌និងផែនដី (អ្នកប្រាជ្ញ Ise-Teijo គ.ស.១៧១៤-១៧៨៤ Amano-Nobolage គ.ស.១៦៦០-១៧៣៣)។

២-ជិន្តោជាមគ្គវិធីរបស់រដ្ឋ ឱ្យប្រើសេចក្តីត្រឹមត្រូវនិងការទៀងត្រង់ក្នុងការគ្រប់គ្រងជាមគ្គវិធីដែល ព្រះមហាចក្រពត្តិទ្រង់ប្រតិបត្តិដល់អាណាប្រជារាស្ត្រ (Hayashi-razam 1582-1657, Yaohimi-Yuikaza 1672-1761) ។

៣-ជិន្តោជាមគ្គវិធី ដែលមហាទេពជាបុព្វបុរសអមតេរៈសុឌិមិគៈមិ ទ្រង់ប្រទានមកឱ្យរដ្ឋគ្រប់គ្រងប្រទេសជាតិ។ល។ (Yokikawa koretaru 1615-94, Yamazaki 1614-82, Motoori-Norinaga 1729-1801, Hirata-Atsutane 1774-1842) ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ២២០)

៤-ជិន្តោគឺធម៌ប្រចាំថ្ងៃ ឬមាគ៌ានៃនាទីដែលមនុស្សត្រូវប្រតិបត្តិធម៌និងមាគ៌ានោះគឺនាទីរវាងអ្នកគ្រប់ គ្រងនិងអ្នកនៅក្រោមការគ្រប់គ្រងរវាងស្វាមីនិងភរិយា រវាងកូននិងឪពុករវាងបងប្អូនប្រុសស្រី និងរវាងមិត្តនិងមិត្ត។ល។ (Watarai-Nobuyoshi 1614-90)។

៥-ជិន្តោនិងសាសនារបស់ជាតិ ទេពលោកប្រទានជាមត៌កបន្តមកគ្មានដាច់ ជាទីតាំងការពារធម្មនុញ្ញ របស់ជាតិនិងសារប្រយោជន៍នៃចរិយារបស់ជាតិផង។

ជិន្តោនឹងកំណត់ថា ត្រឹមតែជាលទ្ធិឬសាសនាក៏ដោយចុះ តែឥទ្ធិពលរបស់ជិន្តោដែលប្រាកដឱ្យឃើញ បានក្នុងប្រវត្តិសាស្ត្រ មាននៅមិនតិចជាងសាសនាណាៗ និងឥទ្ធិពលរបស់ជិន្តោនោះ គួរនឹងចែកចេញបានជា២ យ៉ាង ៖

ម្យ៉ាងទៀតឥទ្ធិពលក្នុងផ្លូវខុស ដោយអាស្រ័យទេពនិទាននិងរឿងសូត្រ ដែលមានជំនឿប្រកាន់មកក្នុងលក្ខណៈគ្មានហេតុផលរហូតដល់ធ្វើឱ្យក្លាយជាការវង្វេងជាតិ ឱ្យខ្លួនវិនាសទៅជាមួយនឹងការវិនាសនោះៗ។

ឥទ្ធិពលម្យ៉ាងទៀត បើកាត់វង្វេងជាតិចេញទៅហើយ ជប៉ុនក៏នៅសល់តែចរិយាធម៌ខាងផ្នែកល្អមាន ការស្អាត សេចក្តីស្រឡាញ់មេត្តាត្រាប្រណីដល់មនុស្សទាំងពួង ឥទ្ធិពលរបស់ជិន្តោបានផ្សព្វផ្សាយនឹងធម៌ក្នុងពុទ្ធសាសនា ជួយអប់រំឧបនិស្ស័យចិត្តគំនិតរបស់ជនជាតិជប៉ុន ឱ្យជាបែបបទរបស់ជប៉ុនពិតៗ។

ជប៉ុនជាសង្គមដែលស្រឡាញ់ជាតិ ស្រឡាញ់ធម្មជាតិ មានសេចក្តីអង់អាចឧស្សាហ៍ប្រឹងប្រែង នឹងរកជនជាតិដទៃណាពិបាកនឹងប្រៀបប្រដូចបាន ជប៉ុនសាងជាតិរបស់ខ្លួនឱ្យនៅរឹងប៉ឹងមាំមួនបានដូច្នេះ ព្រោះឥទ្ធិពលរបស់ជិន្តោក្នុងខខាងក្រោយនេះឯងៗ។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២២១)

## សាសនាតៅ មាគ៌ានៃធម៌

តៅប្រែថាមាគ៌ាឬផ្លូវ ប្រសិនឱ្យទៅតាមន័យថា សភាពដែលប្រព្រឹត្តទៅដោយធម៌តាមទស្សនវិជ្ជារបស់ចិនបុរាណ។

អ្នកប្រាជ្ញរូបនេះឈ្មោះ ឡៅស៊ីឬឡៅជឺ (Lao-Tzu) ជាអ្នកប្រកាស។ ឡៅជឺកើតមុនគ្រិស្តសករាជ ៦០៤ ប្រមាណមុនពុទ្ធសករាជ៦០ឆ្នាំ នៅភូមិចូយេន ក្នុងខេត្តហូណាន សម័យរាជវង្សជីវ (ប្រមាណ១១២២-២៥៥ មុនគ.ស.) ទារកកើតក្រោមដើមមនមានសក់សឃើញច្បាស់ចេញអំពីផ្ទៃម្តាយមាននាមថា ឡៅជឺ ឬ ឡៅស៊ី ប្រែថាក្មេងចាស់ ដោយមានការអធិប្បាយថា អ្នកមានសភាពដូចក្មេង គឺអ្នកបរិសុទ្ធដូចក្មេង ឬមានន័យថា អ្នកប្រាជ្ញចាស់ទុំឬអ្នកប្រាជ្ញកំពូល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២២)

មានរឿងខ្លះសម្តែងថា ឡៅជឺ នៅក្នុងពោះម្តាយរហូត៨១ ឆ្នាំ៧២និង៦២ ក៏មានកាលប្រសូតចេញមក សក់ទើបសពេញក្បាល។ លុះប្រសូតចេញមកក៏សម្តែងបាដិហារិយ៍ដៃឆ្វេងចង្អុលទៅលើមេឃ ដៃស្តាំ ចង្អុលមកលើផែនដី បន្លឺវាចាថា "ក្នុងផ្ទៃមេឃខាងលើនិងផ្ទៃដីខាងក្រោម តៅប៉ុណ្ណោះគួរជាទីសក្ការៈ"។ គណនាថ្ងៃកំណើតរបស់ឡៅស៊ី មុនថ្ងៃកំណើតរបស់ខុងជឺ អ្នកប្រាជ្ញជាម្ចាស់លទ្ធិសំខាន់ម្នាក់ទៀតរបស់ចិន ប្រមាណ៥០ឆ្នាំ បានទទួលការសិក្សាពីធម្មជាតិច្រើនជាងការសិក្សាអំពីមនុស្ស ជាក្មេងឆ្លាតតាំងពីកុមារ។ លុះមានអាយុ

ចម្រើនធំឡើង បានទទួលតំណែងជាអ្នករាជការថ្នាក់ធំ នៅក្នុងក្រុមអាល័ក្យ ជាអ្នកប្រវត្តិសាស្ត្រ ប្រចាំព្រះរាជសំណាក់និងជាអ្នកប្រាជ្ញធំ នៅក្នុងរាជសំណាក់ទៀតផង។

អ្នកប្រាជ្ញនិងអ្នកប្រវត្តិសាស្ត្រក្រិកឈ្មោះ ហិរោដោទុស (Heradotus) ៤៨៤-៤២៥ មុន គ.ស. អាងថា ជីវិតរបស់ឡៅស៊ឺ ប្រព្រឹត្តទៅក្នុងសម័យជាមួយគ្នានឹងសាសនាចារ្យសំខាន់ៗ ក្នុងលោកជាច្រើននាក់ជាអាទិ៍ សោរោមស្សតិ៍របស់ប៉ែក្ស សាស្ត្រាព្យាករណ៍ចេរេមិអាហ៍ និងអែសាហ៍របស់ជ្វីហ្វជាដើម។ ប្រវត្តិរបស់ឡៅជឺ មានការពិបាកនឹងស្វែងរកការពិតច្បាស់លាស់ កស្តុតាងដែលស្រាវជ្រាវបានអំពីកាសាចិនមានត្រឹមតែ២៤៨ពាក្យ ប្រវត្តិទាំងនេះតែងឡើងក្រោយពីឡៅជឺអស់ជីវិតទៅហើយជាង៥០០ឆ្នាំ ប្រវត្តិភាគខាងដើមរបស់ ឡៅជឺ មានត្រឹមតែប៉ុណ្ណោះ។

នាមពិតប្រាកដរបស់ឡៅជឺ គឺ លីអ៊ួ ព្រោះកើតនៅក្រោមដើមមន នៅពេលទទួលមុខងារជានាយក ការិយាល័យបណ្ណាល័យ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៣)

មាននាទីជាអ្នកធ្វើសេចក្តីកត់ហេតុក្នុងក្រុមអាលក្សរបស់ស្តេចផែនដី បានឱកាសសិក្សាហេតុការណ៍ សិក្សាការងារកាន់តែឃើញច្រើនឡើងនិងកាន់តែធ្វើឱ្យកើតការនឿយណាយច្រើនឡើងថែមទៀត។

ឡៅជឺមានកំណើតនៅសម័យប្រទេសចិន កំពុងជួបប្រទះនឹងបញ្ហាស្មុគស្មាញ មានការពុករលួយស៊ីសំណូកសូកប៉ាន់យ៉ាងគគ្រឹកគគ្រេង ស្ថានការណ៍ស្រុកទេសប្របូកប្របល់ ធ្វើឱ្យឡៅជឺកើតមានការធុញទ្រាន់។ កាលបើឃើញថា អស់មធ្យោបាយកែប្រែឱ្យល្អឡើងវិញបាន ឡៅជឺ ទើបត្រឡប់មកតែបញ្ហាផ្ទាល់ខ្លួនវិញ ដោយការលួចរត់គេចចេញទៅពីសង្គមធ្វើដំណើរចេញពីខេត្តហូណាន និង ត្រាច់ចរគេចពីភាពស្មុគស្មាញ ទៅទិសខាងលិច (ប្រទេសឥណ្ឌាឬទីបេត៍)។

មានរឿងនិទានប្រកបជាមួយថា ឡៅជឺ ឡើងជិះក្របីពេលចេញដំណើរទៅដល់ព្រំប្រទល់ អ្នកត្រួតត្រាចេញចូលផ្លូវឆ្លងដែនបានសូមអង្វរករឡៅជឺ មុននឹងលោកចាកចេញទៅ សូមពន្យល់ពីរឿងទស្សនវិជ្ជានៃជីវិតដែលបានកន្លងមក កត់ត្រាទុកជាប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ ឡៅជឺ យល់ព្រមកត់ត្រាពាក្យប្រៀនប្រដៅរបស់ខ្លួនទុកឱ្យផ្នែកធំជារឿងគោលការណ៍សកលលោកធម្មជាតិ និងជីវិតឱ្យឈ្មោះថា “តៅ-តេ -កិង” (Tao-Ter-

Ching) ជាពាក្យប្រមាណ៥.៥០០ពាក្យ ពួកសិស្សបានប្រមូលរួបរួមឡើងជាសៀវភៅ មួយក្បាល ដែលពេលក្រោយមក ក្លាយជាគម្ពីរសំខាន់របស់សាសនាតៅ។

តាំងអំពីឡើងជិះលើខ្នងក្របី ចាកចេញទៅក្នុងគ្រានោះរួចហើយ ឡៅជឺ ក៏សាបសូន្យទៅ មិនបានត្រឡប់មកឱ្យអ្នកណាឃើញមុខទៀតឡើយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៤)

បុគ្គលិកលក្ខណៈរបស់ឡៅជឺ

លក្ខណៈរូបរាងកាយ និងអាកប្បកិរិយារបស់ឡៅជឺ ជាយ៉ាងណានោះ រកភស្តុតាងពិបាកនឹងពន្យល់ តែដែលទទួលស្គាល់បានគឺជាប្រុសក្បាលទំពែក ពុកមាត់វែង ចូលចិត្តជិះក្របី មានរឿងនិទានមកថា កាលបើឡៅជឺនៀយណាយក្នុងសង្គមហើយ បានចេញប្រៀនប្រដៅមនុស្សទូទៅ ថ្ងៃមួយបានជួបជាមួយខុងជឺ អ្នកប្រាជ្ញសំខាន់ម្នាក់របស់ចិន ដែលពេលនោះមានអាយុប្រហែល៣៥ឆ្នាំ ទាំងពីរនាក់បានបុច្ឆាវិសជ្ជនា បញ្ហាធម៌ជាមួយគ្នា។

ខុងជឺជម្រាបឡៅជឺដោយសេចក្ដីគោរពថាមានបំណងប្រាថ្នាសម្ដែងការវកិច្ច ចំពោះអ្នកប្រាជ្ញជាន់ខ្ពស់ពីអតីត ឡៅជឺឆ្លើយថា មនុស្សដែលលោកនឹងសម្ដែងការវៈទាំងនោះ ពុំមានជីវិតសេសសល់នៅទេ សល់តែផេះនិងឆ្អឹង កុំទៅគិតធ្វើអ្វី កុំប្រាថ្នាអ្វីទៀតឡើយ។ ខុងជឺសួរអំពីរឿងតៅថា សិក្សាមកក៏ច្រើនហើយដែរ នៅមិនដឹងអ្វីដែលហៅថា តៅ នោះ ឡៅជឺត្រឡប់ឆ្លើយជាទំនងសំណួរវិញថា "បើតៅចូលមកនៅក្នុងខ្លួនមនុស្សបាន តើអ្នកណានឹងមិនប្រាថ្នាតៅ ហេតុម្ដេចក៏លោកមិនរកតៅមកនៅជាមួយខ្លួនលោក"។ ខុងជឺ ត្រឡប់ទៅវិញ ពួកសិស្សសួរថា តើយ៉ាងណាខ្លះទៅ? ខុងជឺឆ្លើយថា "សត្វហើរយ៉ាងណា ខ្ញុំក៏ធ្លាប់ដឹងត្រីហែលទឹកយ៉ាងណា សត្វជទៃរត់យ៉ាងណាក៏ដឹង និងដឹងថែមទៀតថា តើនឹងចាប់សត្វនោះ បានយ៉ាងណា? សត្វពួកខ្លះ ត្រូវប្រើអន្ទាក់ចាប់ ពួកខ្លះត្រូវប្រើនុយចាប់ និងពពួកជាច្រើនខ្លះទៀតត្រូវប្រើធ្នូ ប៉ុន្តែឥឡូវនេះមានសត្វមួយបែបគឺម្ករ ខ្ញុំមិនអាចប្រាប់បានថា វាអាចវារឡើងទៅលើមេឃបានយ៉ាងណា មិនដឹងថាវាឆ្លងជុំពពកឬឆ្លងទៅ លើឋានសួគ៌ដោយវិធីណា ថ្ងៃ មួយខ្ញុំបានជួបនឹងលោកឡៅជឺ "ជាម្ករ" ដែលពិបាកនឹងយល់បាន។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ១ ទំព័រ២២៥)

ឡៅជឺប្រៀបបាននឹងម្ករ ដែលគួរឱ្យភ័យខ្លាចពិបាកនឹងអ្នកណាមួយយល់បាន ជាអ្នកនឹកគិតស្វែងរកសេចក្ដីពិតក្នុងលោកយើងនេះ ដែលនិយមចូលចិត្តដំណើរជីវិតក្នុងធម្មជាតិ អ្នកណាធ្វើខុសធ្វើត្រូវ ឡៅជឺ ឃើញថាធម្មជាតិដាក់ទោសនិងឱ្យគុណខ្លួនឯង។ ឡៅជឺសម្លឹង

ឃើញលោកជាអន្ទាក់ មានការនឿយណាយ ចំពោះលោកនេះ ឡៅជឺ ប្រាប់ថា បណ្តោយឱ្យលោកប្រព្រឹត្តទៅតាមផ្លូវរបស់វា លោកនឹងសុខសប្បាយដោយខ្លួនឯង ត្រង់នេះខុសអំពីខុងជឺ ដែលត្រូវកែប្រែលោកដោយវិធីរបស់ខ្លួនឯង និយាយឱ្យងាយយល់ ខុងជឺ ត្រូវការនៅក្នុងលោក តែ ឡៅជឺ ត្រូវការចេញអំពីលោក។

ឡៅជឺជាមនុស្សឃើញសភាពនៃលោកជារបស់ធម្មតាសាមញ្ញ ឃើញកំហុសរបស់មនុស្សទាំងឡាយជាធម្មតា ដែលនឹងអាចលើកលែងទោសឱ្យបាន អ្នកណាធ្វើអំពើអាក្រក់ឡៅជឺ ឱ្យឈ្នះអំពើអាក្រក់នោះដោយធ្វើអំពើល្អ ឱ្យឈ្នះការក្រោធខឹងរបស់មនុស្សទាំងឡាយដោយសេចក្តីករុណា។ ឡៅជឺ និយាយថា "អ្នកណាធ្វើអំពើអាក្រក់ក្រោធខឹងខ្ញុំ ខ្ញុំនឹងធ្វើអំពើល្អដល់គេវិញ អ្នកណាធ្វើអំពើល្អដល់ខ្ញុំ ខ្ញុំក៏ជាមនុស្សល្អសម្រាប់គេ អ្នកណាស្មោះត្រង់ដល់ខ្ញុំ ខ្ញុំក៏ស្មោះត្រង់ចំពោះគេ អ្នកណាមិនស្មោះត្រង់ដល់ខ្ញុំ ខ្ញុំក៏នៅតែស្មោះត្រង់ចំពោះគេគ្រប់គ្នាដែរ" (គម្ពីរ តៅតេ កិងខទី៤៩ និង៦៣)។

លក្ខណៈរបស់ឡៅជឺ ដូចបានពោលមកហើយសម្តែងឱ្យឃើញថា ជាអ្នកមានមេត្តាមើលឃើញកំហុសជាធម្មតាសាមញ្ញនិងសេចក្តីអាក្រក់ អាចអភ័យទោសឱ្យបាន។ សាស្តាជាច្រើនអង្គក្នុងសម័យក្រោយឡៅជឺ ដូចជាយេស៊ូជាដើម ក៏មានលក្ខណៈប្រចាំខ្លួនឱ្យតបស្នងសេចក្តីអាក្រក់របស់មនុស្ស ដោយអំពើល្អដូចគ្នាដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៦)

សេចក្តីមួយវគ្គក្នុងគម្ពីរតៅតេកិង សម្តែងលក្ខណៈរបស់ឡៅជឺទុកថា "ពពួកជនទាំងឡាយជាអ្នកមានសេចក្តីសុខ ខ្ញុំក៏ជាអ្នកចូលចិត្តស្ងប់ ចូលចិត្តនៅតែឯកឯង ចូររិះគន់ខ្ញុំមកចុះ ខ្ញុំមិនត្រូវការសេចក្តីសុខដូចពពួកជនទាំងឡាយ ខ្ញុំក៏ជាមនុស្សល្ងង់ មនុស្សខ្វាច ខ្ញុំជាមនុស្សបែកចេញផ្សេងអំពីអ្នកមានសេចក្តីសុខទាំងឡាយ ខ្ញុំចាកចេញអំពីមនុស្សទាំងឡាយមក ដើម្បីស្វែងរកតៅ (សភាពដែលប្រព្រឹត្តទៅតាមធម្មជាតិ)។

"មនុស្សក្នុងលោករាប់អានខ្ញុំជាអ្នកប្រាជ្ញ ប៉ុន្តែខ្ញុំពុំមែនជាមនុស្សដូច្នោះឡើយ ខ្ញុំមានសម្បត្តិ៣យ៉ាង ដែលព្យាយាមធ្វើឱ្យកើតមានឡើងក្នុងខ្លួនជានិច្ច សម្បត្តិ៣យ៉ាងនោះគឺ សេចក្តីមេត្តា ករុណា ការសន្សំសំចៃ មិនខ្ជះខ្ជាយ និងភាពទន់ភ្លន់"។

"ពាក្យសម្តីរបស់ខ្ញុំងាយនឹងយល់ ងាយដល់ការប្រតិបត្តិ តែពុំមានអ្នកណាអាចដឹងនិងប្រតិបត្តិបាន ព្រោះថាមនុស្សទាំងឡាយមិនស្គាល់ធម្មជាតិ និងមិនស្គាល់ខ្ញុំទៀតផង"។

លក្ខណៈដែលគុណធម៌៣ប្រការគឺ សេចក្តីមេត្តា ករុណា សន្សំសំចៃមិនខ្ជះខ្ជាយ និងភាពទន់ភ្លន់ប្រកាន់ថា ជាកែវ៣ប្រការខាងក្នុងខ្លួនរបស់ឡៅជឺ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៧)

ឡៅជឺ ប្រកាន់ខ្លួនជាអ្នកសន្តោស ចូលចិត្តសេចក្តីស្ងប់ស្ងាត់ ជីវិតរបស់ឡៅជឺក្នុងពេលក្រោយ ជាជីវិតរបស់អ្នកស្វែងរកធម៌ អ្នកកាន់អានលទ្ធិឡៅជឺ តមកទើបមានការបំពេញខ្លួនជាឥសីអាស្រ័យខ្លួននៅតាមភ្នំ ព្រៃព្រឹក្សា ប្រតិបត្តិខ្លួនជាអ្នកព្រៃ អ្នកលះបង់សេចក្តីប្របូកប្របល់ទាំងឡាយក្នុងលោក ហៅថាយិន គឺបុគ្គលក្នុងលទ្ធិតៅឬអ្នកប្រតិបត្តិតាមមាគ៌ា បានដល់ជាអ្នកមានការរស់នៅតាមភាវៈរបស់ធម្មជាតិ។

កាលបើអស់ជីវិតហើយ ជនជាតិចិនរាប់អានឡៅជឺជាអ្នកប្រាជ្ញដ៏កំពូល បានសាងបូជនីយវត្ថុជាទីទឹក រព្វកបូជា នាតំបន់ដែលឡៅជឺកើត។ ធម៌របស់ឡៅជឺបានផ្សព្វផ្សាយជក់នៅក្នុងចិត្តជនជាតិចិន បានឡើងសោយរាជ្យក្នុងព.ស.១១៩៣-១២៣១ ប្រកាសជារាជក្រឹត្យលើកតម្កើងឡៅជឺឡើង ជាបឋមចក្រពត្តិ ជាបុព្វបុរសកំពូល អ្នកប្រាជ្ញរបស់ចិន ការទៅជាអ្នកប្រាជ្ញរបស់ឡៅជឺមានការសម្ព័ន្ធទៅនឹងជីវិតរបស់ខុងជឺ អ្នកប្រាជ្ញម្នាក់ទៀតរបស់ជនជាតិចិន។

**គម្ពីរក្នុងសាសនា**

គម្ពីរក្នុងសាសនាតៅហៅថា តៅ-តេ-កិង (Tao-The-Ching) ឬ (តៅ-តេ-ចិង) មកពីនាមសាស្តារបស់អ្នកតាំងលទ្ធិ តៅ-តេ-កិង ជាបទកវីនិពន្ធប្រើភាសាអក្សរសាស្ត្រ រួបរួមពាក្យពេជន៍ទាំងអស់ប្រមាណ ៥.៥០០ពាក្យ ចាត់ជាជំពូក៨១ជំពូក ឡៅជឺជាអ្នកសរសេរដោយខ្លួនឯង នៅពេលដែលចេញពីរាជការ ធ្វើដំណើរទៅរកសេចក្តីស្ងប់ស្ងាត់ នៅភាគទិសខាងលិច (ទីបេត៍) មានសិស្សសំខាន់ៗរបស់ឡៅជឺ ជាអ្នករួបរួមពាក្យប្រៀនប្រដៅរបស់អាចារ្យទុកក្នុងគម្ពីរមួយក្បាលជាមួយគ្នានេះ មួយផ្នែកទៀតគឺ គម្ពីរ តៅ-តេ-កិង មានអ្នកប្រែចេញជាភាសាទិសខាងលិច ជាច្រើនគ្រានិងច្រើនភាសា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៨)

សេចក្តីសំខាន់ក្នុងគម្ពីរ តៅ-តេ-កិង មួយវគ្គ ឡៅជឺ ប្រៀនប្រដៅឱ្យឃើញសេចក្តីបរិសុទ្ធធំៗ៣ប្រការ ដែលបុគ្គលត្រូវកាន់យកជាគោលការណ៍សំខាន់របស់តៅគឺ ៖

១-សារៈ (ESSENCE) ឬមូលដ្ឋានដើម (ជីង) ខនេះសំដៅយកសួគ៌ហៅថា វូ-សិង ទៀងជុន (Wu-Shing Tien-chun) ឬទៀនប៉ៅជុន (Tien-Pao-chun) សម្តែងដោយបុគ្គលាធិដ្ឋាន

ទ្រង់ជាកំពូលនៃលោក កំពូលសួគ៌ ប្រាសចាករូប ស្ថិតនៅក្នុងអាណាចក្រនៃសេចក្ដីបរិសុទ្ធ ប្រដូចជាថ្មមានតម្លៃពិសេស អាណាចក្រនេះ ជាអាណាចក្ររបស់អ្នកមានបុណ្យ។

អធិប្បាយន័យមួយទៀត សម្ដែងឱ្យច្បាស់ជាបុគ្គលាធិដ្ឋានថា ទ្រង់ជាមហាទេពមួយអង្គ ទ្រង់ព្រះនាមថា យូជិន មហាទេពមានព្រះកាយជាថ្មទេពពិសេស ទ្រង់មានបល្ល័ង្កធ្វើអំពីមាស ទ្រង់បញ្ចេញព្រះរស្មីប្រដូច នឹងពន្លឺចេញមកពីព្រះអាទិត្យព្រះរស្មីនេះធ្វើបញ្ចាំងពន្លឺឱ្យឃើញសច្ចៈ (របស់លោក) ទាំងពួង (សាងលោក)។

២.ពលំ (Vital.force) សំដៅយកពលំ (ចិ) នៃសតិបញ្ញាសមត្ថភាពសម្ដែងជាបុគ្គលាធិដ្ឋានហៅថា វូស៊ី ទៀនជុន (Wu-Shi-Tien-chun) ឬលិង ប៉ៅជុន (Ling-Pao-chun) ទ្រង់ជាកំពូលនៃបញ្ញាស្ថិតក្នុងអាណាចក្រ នៃសេចក្ដីបរិសុទ្ធខ្ពង់ខ្ពស់ប្រាកចាកអំពីមូលដើម។

មានន័យអធិប្បាយមួយទៀត ទ្រង់ជាមហាទេព ទ្រង់ព្រះនាមថា ជាងជិន ឧប្បត្តិឡើងព្រមគ្នាជាមួយចក្រវាល (លោក) ទ្រង់មាននាទីក្នុងការចាត់ចែងបែងចែកពេលវេលាជាថ្ងៃយប់ ជារដូវរបស់លោកនេះ មានបល្ល័ង្កប្រថាប់នៅទិសខាងជើង ទ្រង់ជាទេវតានៃធម្មជាតិ គូគ្នានឹងលោក២បែបគឺ យ៉ាង និង យិន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២២៩)

៣-វិញ្ញាណ (Spirit) សម្ដែងជាបុគ្គលហៅថាហ្វាងសិងទៀនជុន (Fan-Shing Tein-hun) ឬជេនប៉ាវ ជុន (Shen pao-chun) ជាកំពូលនៃវិញ្ញាណទាំងឡាយ (ប្រហែលព្រះព្រហ្មក្នុងសាសនាព្រាហ្មណ៍) ទ្រង់ស្ថិតនៅក្នុងអាណាចក្រដែលជាអមតៈរបស់ទេវតាទាំងពួងនិងទ្រង់ជាអ្នកមានសេចក្ដីបរិសុទ្ធដ៏ខ្ពស់បំផុត។

ន័យអធិប្បាយមួយទៀត ទ្រង់ជាមហាទេព ទ្រង់ព្រះនាមថាទៃសិង មានន័យថា ស្មើនឹងខ្លួនឡៅជឺ ជាអ្នកមានវិញ្ញាណបរិសុទ្ធ អវតារចុះមកប្រៀនប្រដៅមនុស្ស។

**គតិដែលសម្ដែង**

សេចក្ដីបរិសុទ្ធយ៉ាងធំ៣ប្រការនេះ សាវ័ករបស់តៅក្នុងជំនាន់ក្រោយ ប្រកាន់យកថាជារតនត្រ័យរបស់តៅនិងមានជំនឿថា សិស្សសំខាន់ៗរបស់ឡៅជឺណាម្នាក់បានរួបរួមទុក (ក្នុងគម្ពីរតៅ តេ កិង)។ លក្ខណៈសំខាន់ក្នុងពាក្យប្រៀនប្រដៅរបស់ឡៅជឺនោះ ផ្ដោះទៅរកធម្មជាតិគឺតៅ (Tao) ឬមាគាដែលបុគ្គលគប្បី ប្រតិបត្តិ ជាផ្នែកមួយដ៏ធំ ប៉ុន្តែជាការមួយពិបាកដែរ ដែលនឹងនិយាយឱ្យត្រឹមត្រូវជាក់លាក់បានថា តៅជាអ្វី ព្រោះឡៅជឺ មិនបានដាក់ពាក្យន័យតៅឱ្យបានច្បាស់លាស់។

ពាក្យថាតៅជាអ្វី? កាលបើពិចារណាឱ្យពិតប្រាកដឃើញថា ឡៅជឺ សំដៅយកសេចក្ដីទៀងត្រង់ (ធម៌ដ៏ឧត្ដម) ដ៏សែនខ្ពង់ខ្ពស់ (Ultimate Reality) ដែលជាឯកភាពមិន មានរូបរាង មិនអាចកំណត់បានដោយ សម្ផស្ស (Sense) ទាំងឡាយ (ប្រហាក់ប្រហែលគ្នា នឹងគំនិតទាក់ទងបរិមាត្មន៍របស់ព្រាហ្មណ៍)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣០)

ឧត្ដមធម៌ដូចបានពោលមកនេះ ជ្រកពួននៅក្នុងរបស់គ្រប់យ៉ាងក្នុងធម្មជាតិគ្រប់យ៉ាង តៅសម្ដែងខ្លួន ឯងឱ្យឃើញក្នុងរូបភាពរបស់ធម្មជាតិ (Law of nature) ដែលមិនផ្លាស់ប្ដូរ ឡៅជឺប្រកាន់ថា តៅ (វិថីរបស់ធម្មជាតិ) ជាកន្លែងធ្វើឱ្យកើតពលំ (Vital Force ឬ ចិ តាម ដូចដែលបានពោលមកហើយ)។ ពលំនេះនឹងបានមក កាលបើយើងចូលទៅដល់តៅដោយការព្យាយាមយកចិត្តទុកដាក់ក្នុងវិថីរបស់លក្ខណៈធម្មជាតិ ដែលមិនអាចបរិយាយជាពាក្យនិយាយបាន។

ឡៅជឺរមែងតែងនិយាយជានិច្ចថា "មនុស្សចេះដឹងមិននិយាយ អ្នកដែលនិយាយមិនចេះសោះ" (Those who know don't say, Those who say don't know) អ្នករាប់អានសាសនាតៅក្នុងជំនាន់ក្រោយ ព្យាយាមនឹងបានពលំនេះ ដោយប្រើសេយ្យសាស្ត្រ (Magic) ដែលខុសទៅអំពីពាក្យប្រៀនប្រដៅដើមរបស់ឡៅជឺជាច្រើន។

ឡៅជឺនិយាយថា "បណ្ដាការប្រចូកប្រចល់ដែលមានច្រើន មុននឹងមានលោក ហើយនិងសួគ៌នៅគង់វង្សមានសព្វគ្រប់បរិបូណ៌ វាជាម្ចាស់នៃចក្រវាល ចំណែកនាមរបស់វា ខ្ញុំខ្លួនឯងក៏មិនអាចជ្រាបថាដូចគ្នាដែរឬទេ ទើបហៅវាថាតៅ"។

"ការព្យាយាមពិពណ៌នាពីតៅ ថាជារបស់អ្វីនោះ ជារឿងធំក្នុងចក្រវាល ដែលរាប់ថាមានអំណាចសំខាន់ធំលើសលប់៤យ៉ាងគឺ អំណាចរបស់មុស្សមកអំពីលោក អំណាចរបស់លោកមកអំពីសួគ៌ អំណាចរបស់សួគ៌មកអំពីតៅ អំណាចរបស់តៅមកពីការប្រព្រឹត្តទៅក្នុងខ្លួនរបស់តៅខ្លួនឯង" (របស់ដែលកើតឯងរស់ឯង) (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣១)

"ន័យមួយទៀតពុំមានពិតប្រាកដថា តៅជាទុក្ខគ្រាំគ្រាក្នុងចិត្តឬជាទុក្ខព្រោះជាសេចក្ដីក្រខ្សត់ តែតៅជានិរន្តរ៍ ជាការបែងចែកគ្នាដ៏ធំទូលាយ ជាសេចក្ដីទៀងត្រង់ ការទៀងត្រង់នេះហើយទើបប្រដូចជាការគួរលើកតម្កើងរាប់អាន ហើយការដែលលើកតម្កើងរាប់អាននេះ

ទំនាក់ទំនងគ្នាជាស្ថានសួគ៌ ការទាក់ទងគ្នាជាស្ថានសួគ៌ទើបមានតៅ ការមានតៅទើបមានការគង់វង្សមិនសាបសូន្យ។

យើងអាចឃើញថា សារសំខាន់នៃពាក្យប្រៀនប្រដៅរបស់ឡៅជឺ គឺការទៅរួមនៅជាមួយតៅ បំណងដល់តៅតែមួយបានដល់ការដំណើរជីវិតទៅតាមធម្មជាតិ ឡៅជឺនិយាយថា "ចូរធ្វើខ្លួនឱ្យសមនឹងធម្មជាតិ រង់ចាំទាញយកតៅជាមធ្យោបាយ" ហើយថាការជ្រួលច្របល់ទាំងឡាយក្នុងលោកនេះ កើតឡើងអំពីការធ្វើនូវអំពើទាំងពួងជារឿងគ្មានសារៈ ចូរនៅឱ្យស្ងៀមស្ងាត់។ ការព្រមទទួលដោយមិនជំទាស់ដល់ធម្មជាតិ ជាផ្លូវ ដែលនឹងនាំទៅកាន់សេចក្តីសុខ" បុគ្គលអាចធ្វើទឹកកករល្អក់ដោយកក់ជ្រាំឱ្យស្អាតថ្លាបាន ដោយការកូរទឹកនោះទៅមកៗ ហើយទុកចោលស្ងៀមទៅ មិនត្រូវធ្វើអ្វីទៀតទាំងអស់ ទឹកនឹងថ្លាមកដោយឯកឯង" ហើយ និងមួយវគ្គទៀតថា "ធ្វើមាត់ឱ្យស្ងប់ស្ងៀម បិទផ្លូវនៃការបេះដឹងខ្លួនឯងចេញបុគ្គលក៏នឹងមានជីវិតនៅយឺនយូរមិនជួបប្រទះសេចក្តីជ្រួលច្របល់ និងចូរលះបង់អំពើប្រព្រឹត្តមិនសមរម្យចេញ ទុកដាក់ខ្លួនដោយការមិនធ្វើរបស់ណាមួយ"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣២)

ឡៅជឺសង្កត់ធ្ងន់ក្នុងរឿង ការយកខ្លួនទៅនៅជាមួយធម្មជាតិ និងប្រៀនប្រដៅជីវិត "តាមធម្មជាតិ" ជាមួយទឹកទុកថា ៖

"មនុស្សល្អបំផុតដូចទឹក ទឹកឱ្យប្រយោជន៍ដល់របស់គ្រប់បែបយ៉ាង និងមិនព្យាយាមកេងប្រវ័ញ្ចជាមួយនឹងរបស់ណា ទឹកដែលរាំងទុកក្នុងទីទាបបំផុត គឺជាកន្លែងជិតតៅ"។

មានន័យថារបស់ទាំងឡាយចម្រើនលូតលាស់ឡើងដោយសារទឹក តែទឹកមិនបានព្យាយាមលូតលាស់ ខ្លួនឯងឱ្យឡើងទៅក្នុងលំដាប់ខ្ពស់ ទឹកត្រឡប់ជាពេញចិត្តនៅក្នុងទីទាប (សេចក្តីឱនលំទោនទន់ភ្លន់) នេះឯង គឺធម្មជាតិរបស់តៅ។

ជីវិតដែលប្រព្រឹត្តទៅងាយៗ ពុំមានការប្រជែងប្រណាំងគ្នា បណ្តោយឱ្យប្រព្រឹត្តទៅតាមការវិវឌ្ឍរបស់ធម្មជាតិ ពុំមានការរើបម្រះដើម្បីស្វែងរកតំណែងនាទីឱ្យកើតអំណាចដល់ខ្លួន ធ្វើប្រយោជន៍ឱ្យអ្នកដទៃដោយមិនសង្ឃឹមផលតបស្នងវិញ គឺជីវិតមានសេចក្តីសុខខ្ពស់បំផុតតាមទស្សនៈរបស់ឡៅជឺ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣៣)

សរុបសេចក្តីថា ការសម្រេចដែលពិតប្រាកដនោះ មិនមែនការយកឈ្នះអ្នកដទៃ ឬការគ្រប់គ្រងទ្រព្យសម្បត្តិនោះឡើយ។ កិត្តិយសឬការស្ទាត់ជំនាញឯណាដែលព្រមឱ្យ

សេចក្តីស្ងប់ដល់អ្នកដទៃ មានអំណត់អត់ធន់និងការប្រកាន់យកជាកណ្តាល សមតាមដែលឡៅជឺពោលទុកថា "សេចក្តីទន់ភ្លន់រមែងយកឈ្នះការរឹងចចេសបាន" (Gentles overcome strengths)។

ការអធិប្បាយទាំងនេះ មើលទៅប្រដូចឱ្យឃើញថាឡៅជឺប្រៀនប្រដៅមនុស្សឱ្យខ្ជិលច្រអូសមិនបាច់ចាំធ្វើអ្វី មិនស្វែងរករបស់អ្វី (Quitism) ប៉ុន្តែសេចក្តីពិតមិនដូច្នោះឡើយ។ ឡៅជឺ មិនបានប្រដៅមនុស្សឱ្យនៅស្ងៀម ឡៅជឺ ត្រូវការឱ្យមនុស្សធ្វើការ តែជាអំពើដែលត្រូវធ្វើ មិនត្រូវរើបម្រះ (Effortless Action) ដើម្បីសង្ឃឹមផលណាមួយ។ បើនឹងនិយាយរួមបញ្ចូល ជាមួយធម៌ ក្នុងព្រះពុទ្ធសាសនាគួរនឹងចូលជាមួយពាក្យថា អព្យាក្រឹតឬសន្តោស។

**ការផ្លាស់ប្តូរ និង និកាយ**

ពាក្យប្រៀនប្រដៅពីដើមរបស់ឡៅជឺ ត្រូវបន្ថែមបន្ថយកែប្រែខុសឃ្លាតពីដើម ពេលសាស្តាអស់ជីវិតទៅហើយ កំណត់នៃការផ្លាស់ប្តូរចែញចេញជានិកាយ ប្រហែលជាគ.ស. ៩៧ (ព.ស.៤៤៦)។

ការផ្លាស់ប្តូរចាប់ផ្តើមពីគំនិតថ្មីនៃពួកសិស្សានុសិស្សជាអ្នកគិតផ្តើមមានការសង្ស័យឈ្លោះប្រកែកគ្នា ឡៅជឺមានខ្លួនពិតប្រាកដឬទេ? ឬគ្រាន់តែជាអ្នកវិសេសម្នាក់ក្នុងនិទាន។ ពាក្យប្រៀនប្រដៅរបស់ឡៅជឺជាពាក្យប្រៀនប្រដៅឡៅជឺខ្លួនឯង ឬជាពាក្យប្រៀនប្រដៅដែលមានមកពីមុន ឡៅជឺ ពាក្យប្រៀនប្រដៅជ្រៅរឿង តៅ ដែលពិបាកនឹងយល់បាន ជាមូលហេតុសំខាន់មួយ ដែលធ្វើឱ្យពាក្យប្រៀនប្រដៅពីដើមរបស់ឡៅជឺ បែកចេញជានិកាយទៅតាមលំដាប់ និងមានលក្ខណៈអាចប៉ាន់ស្មានគឺ ៖ (ហេង គីមហោ សាសនាប្រៀបធៀបភាគ១ ទំព័រ ២៣៤)

១-ពាក្យប្រៀនប្រដៅដើម្បីស្វែងរកការមានអាយុវែ្ឋនះដោយការប្រើប្រាស់អំណាចខាងក្នុង និងអំណាចវត្ថុស័ក្តិសិទ្ធិខាងក្រៅដូចជា អំណាចរបស់ទេពជាម្ចាស់ ដោយការក្រាបសំពះសូមអំណាចដោយវិធី សេយ្យសាស្ត្រ អ្នកបួសតៅស្ទាត់ជំនាញក្នុងសេយ្យសាស្ត្រកើតមានឡើងក្នុងរយៈនោះបានអាងថា ជាអ្នកអាចទាក់ទងនឹងសួគ៌បាន រាជសំណាក់សម័យនោះ ទទួលរ៉ាប់រងទស្សនវិជ្ជានិងពិធីកម្មខាងផ្លូវ សេយ្យសាស្ត្ររបស់អ្នកបួស ពួកនេះ អ្នកស្ទាត់ជំនាញខាងសេយ្យសាស្ត្រ ក្លាយទៅជាអ្នកមានអំណាចក្នុងព្រះរាជសំណាក់

ធ្វើឱ្យអ្នកប្រាជ្ញនឹងអ្នកនយោបាយសុចរិតចុះចាញ់ចំពោះអ្នកសំអាងយកអំណាចទេវតា និង មន្តគាថាមកជាគ្រឿងរកស៊ីវិញ។

ក្នុងរយៈនេះលទ្ធិតៅ ក្លាយទៅជាលទ្ធិទេពជាម្ចាស់ប្រភេទផ្សេងៗចូលផ្សំគ្នា និងជឿ ជាផ្សំជាមួយពុទ្ធសាសនា លទ្ធិមហាយានចូលមកកាន់ប្រទេសចិនផង ជាអាទិ៍មានព្រះជា ម្ចាស់នៃការសម្បូរសប្បាយ ព្រះជាម្ចាស់នៃថ្នាំរក្សាពេគ (ភេសជ្ជៈនៃគុរុពោធិសត្វ) ព្រះជា ម្ចាស់នៃគ្រូបាធ្យាយ។ល។ ការបូជាដួងវិញ្ញាណរបស់ធម្មជាតិបានរីកសាយភាយខ្ពស់បំផុត ក្នុងរយៈនេះ ប្រមុខរបស់លទ្ធិតៅក្លាយទៅជាអ្នកធំបំផុតក្នុងផែនដី។

លទ្ធិរាប់អានសេចក្តីបរិសុទ្ធ៣ប្រការ និងពាក្យអធិប្បាយទាក់ទងពាក់ព័ន្ធរតនត្រៃ របស់តៅ មានការរីកចម្រើនក្នុងរយៈនេះផងដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ២៣៥)

២-ពាក្យបង្រៀនបានផ្លាស់រូបរាងឈានចេញទៅមួយរយៈទៀត សាវ័ករបស់ឡៅជឺ ជឿថា ការប្រតិបត្តិតាមសេចក្តីបំណងរបស់តៅធ្វើឱ្យកើតផលបន្ថែមឡើង គឺឱតខំបូជា (សួគ៌ទេពជាម្ចាស់) និងរីងរឹតតែបានទទួលពរតាមប្រាថ្នា និងជាថ្នាំអាយុវឌ្ឍនៈជួយឱ្យមាន អាយុយឺនយូរ។ ការញុំាងសេចក្តីសម្រេច ដូចបានពោលមកហើយនេះឱ្យកើតមានឡើងនូវ វិធីល្អបំផុតមួយគឺវិធីសាកល្បងខាងផ្លូវវិទ្យាសាស្ត្រ ប្រភេទកែច្នៃវត្ថុធាតុដើម និងមានជំនឿ ថាបើចេះច្នៃប្រឌិតឱ្យត្រូវ នឹងជួបប្រទះសេចក្តីបរិសុទ្ធ៣ប្រការថាបានចូលដល់តៅ ហើយ ជួនកាលអាចប្លែងខ្លួនបំបាំងរូប បាត់ខ្លួនទៅជាអ្នកវិសេសទៀតផង។

៣-មានបែបមួយនិងរយៈមួយទៀត ជារូបសេយ្យសាស្ត្រពិតទាក់ទងនឹងការពិចារ-ណាលោកជីវិត ដោយការទស្សន៍ទាយ(គ្រូទាយ) អាចទំនាក់ទំនងនឹងទេព ហើយនឹង ដួង វិញ្ញាណអ្នកស្លាប់ប្រាប់ហេតុល្អបាន។ ការពិចារណាលោកនិងជីវិត (ក្បួនទំនាយ) ពីជំនាន់ ដើមប្រើវិធីពាយខ្សាច់លើផ្ទៃដីឬផ្ទៃទឹក រងចាំមើលតាមខ្យល់បក់ចូលជាមួយនឹងគោល ការណ៍សំយោគរបស់ធម្មជាតិពីរយ៉ាងគឺ យ៉ាំងនិងយិន ដែលនិយាយថាផលគឺ ការទំនាយ គ្រោះកម្មនៃអ្នកដទៃបានផង និងជាផលឱ្យអ្នកទំនាយអាចកំណត់ដឹងកម្លាំងធម្មជាតិ (តាម អធិប្បាយរបស់ឡៅជឺ) បានផង។

**ចរិយាធម៌ក្នុងសាសនា**

ចរិយាធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ឡៅជឺ សម្តែងសេចក្តីថា សក្តិនិងអំណាចខ្ពស់បំផុតគឺតៅ ឡៅជឺប្រដៅមនុស្សឱ្យមានសេចក្តីស្ងប់ មានសភាពជាធម្មតាចូលជាមួយគ្នាបាននឹងធម្មជាតិដែលប្រព្រឹត្តទៅគ្រប់ផ្លូវ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣៦)

សូមលើកឧទាហរណ៍ ជាពាក្យប្រៀនប្រដៅ ដែលជាចរិយាធម៌របស់តៅ មានប្រាកដក្នុងគម្ពីរតៅ-តេ-កិង ឱ្យឃើញដូច្នោះ និយាយពាក្យពិតមិនពីរោះ និយាយពាក្យពីរោះ មិនពិត។

មនុស្សល្អមិនចេះឈ្លោះប្រកែក មនុស្សឈ្លោះប្រកែកមិនមែនមនុស្សល្អ។ មនុស្សឆ្លាតមិនដឹងរឿងច្រើន មនុស្សដែលដឹងរឿងច្រើនមិនមែនជាមនុស្សឆ្លាត អ្នករត់ដែលល្អ មិនបានចោលគន្លងជើងឱ្យប្រាកដ ពាក្យនិយាយល្អគ្មានចន្លោះឱ្យគេជំទាស់តវ៉ា។ អ្នកពូកែ រាប់មិនចាំបាច់ប្រើក្បាច់ ទ្វារដែលបិទល្អមិនបាច់ប្រើគន្លឹះ បំពង់ចងល្អមិនបាច់ប្រើខ្សែ មនុស្ស ល្អជាគ្រូរបស់មនុស្សអាក្រក់ មនុស្សអាក្រក់ជាមេរៀនរបស់មនុស្សល្អ។

អ្នកធ្វើអំពើណា អ្នកនោះវិនាស អ្នកណារាប់អាន អ្នកនោះខាតទុន ព្រោះហេតុនេះអ្នកមានបញ្ញាពុំគប្បីធ្វើ ពុំគួរប្រកាន់យកដើម្បីឱ្យផុតពីការវិនាស និងខាតទុន។

អ្នកណាមិនឃ្លាតចេញទៅក្រៅទ្វារ (ផ្លូវ) អ្នកនោះចេះដឹងពីចក្រវាល អ្នកណាមិនបញ្ចេញខ្លួនទៅតាមបង្អួច អ្នកនោះនឹងឃើញផ្លូវនៃឋានសួគ៌ យើងនឹងដឹងអ្វីបានដោយមិនប្រាសចាកពីចលនានោះ តើនឹងឃើញអ្វីបានទាំងអស់ បើយើងមិនឃើញវាសោះនោះ បើមិនធ្វើឱ្យខូចប្រយោជន៍ទេ ក៏នឹងសម្រេចតាមសេចក្តីប្រាថ្នាបានដូចគ្នា។

ពាក្យសម្តីទៀងត្រង់រមែងមិនពីរោះ ពាក្យសម្តីដែលមិនពីរោះរមែងកើតចេញពីការទៀងត្រង់ នៅមានរបស់ប្រសើរ៣ដែលខ្ញុំប្រកាន់ខ្ជាប់ និងមិនទទួលផលនៃការប្រកាន់នោះ ៖

១-សេចក្តីសុភាព, ២-ការសន្សំសំចៃ, ៣-ការទន់ភ្លន់ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣៧) របស់ប្រសើរ ៣ ប្រការនេះធ្វើឱ្យខ្ញុំមិនចាំបាច់ជានុយរបស់អ្នកដទៃ។

ចូរសុភាពដើម្បីសេចក្តីក្លាហាន ចូរចេះសន្សំសំចៃដើម្បីការរស់នៅ និងកុំដណ្តើមយកមុខមាត់ពីអ្នកដទៃ ដើម្បីធ្វើជាអ្នកដឹកនាំរបស់អ្នកដទៃ។

បាបដែលធ្ងន់បំផុតរបស់មនុស្ស គឺការព្រមទទួលខ្លួនទៅតាមសេចក្តីប្រាថ្នារបស់ខ្លួន គ្មានទុក្ខអ្វីជាជាងការមិនស្គាល់ មិនពេញចិត្តនឹងរបស់ដែលខ្លួនមាន ពុំមានការធ្វើអំពើអាក្រក់ណា ស្មើនឹងការលេងល្បែងស៊ីសងឡើយ។

បើចោលផែនការណ៍ចេញបាន ក៏ព្រោះតែចោលការសង្ឃឹមយកកម្រៃចេញបាន ផុះ ក៏ចោលពុំបានឈ្នះអ្នកដទៃបាន ជាអ្នកពូកែក្លាហាន តែអ្នកដែលឈ្នះខ្លួនឯងបានគឺជាព្រះ ជាម្ចាស់ឬយកឈ្នះ និងមិនត្រូវធ្វើរបស់ណាដើម្បីរំដោះទោស។ អ្នកធ្វើរបស់ណាមិនបំណង យកកម្រៃ រមែងដូចជាមនុស្សឆ្លងផុតពីខ្សែទឹកហូរ ដោយមិនទទឹកនិងឆ្លងភ្លើងទៅបានដោយមិនលោកភ្លើង។

អ្នកចេះដឹង ឬ មនុស្សពិតគឺដែលមានគម្រោងយកកម្រៃ។

អ្នកចេះដឹង រមែងមិនដាក់ទោស អ្នកចេះដឹងរមែងមិនចេះអួតខ្លួន អ្នកចេះដឹងមិនព្រម អួតថានឹងធ្វើ ដែលខ្លួនទៅមិនទាន់បានធ្វើនោះ អ្នកល្ងង់រមែងអួតអាងការងាររបស់ខ្លួន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣៥)

អ្នកចេះដឹងតែងខ្លួនល្មមៗ តែមានពេជ្រលាក់ទុកខាងក្នុង ដូចជាការលាក់ពន្លឺភ្លើងក្នុងទីងងឹត។ អ្នកចេះដឹងមិនសុបិន្តពេលដេកលក់ រមែងមិនក្តៅក្រហាយចិត្តកាលបើភ្ញាក់ឡើង និងមិនត្អូញត្អែរថាមានអាហារឆ្ងាញ់ពិសាដែរឬទេ?

អ្នកចេះដឹងរមែងធ្វើល្អដល់អ្នកធ្វើល្អចំពោះខ្លួន រមែងធ្វើល្អដល់អ្នកអន់ថយជាងខ្លួន ដែលធ្វើយ៉ាងនេះព្រោះត្រូវការជាមនុស្សល្អ។ មែនពិតទោះបីជាពាក្យប្រៀនប្រដៅរបស់ឡៅជឺ បំណងទៅខាងផ្លូវចិត្តវិញ្ញាណនិងធម្មជាតិក៏ដោយចុះ តែមិនបានបោះបង់ចោលចរិយាធម៌ ខាងផ្លូវសង្គម ឡៅជឺសង្កត់ធ្ងន់ណាស់ ក្នុងរឿងចរិយាធម៌មិនអាចចូលដល់ តៅ បានឡើយ។

ប្រសិនបើពិចារណាឱ្យបានដិតដល់ឃើញថា ចរិយាធម៌របស់ឡៅជឺ មិនឃ្លាតឆ្ងាយពីចរិយាធម៌របស់ពុទ្ធសាសនា សីល៥គឺការមិនសម្លាប់ ការមិនផឹកទឹកស្រវឹង ការមិននិយាយកុហក ការមិនលួច និងការមិន ប្រព្រឹត្តខុសព្រហ្មចារ្យ។ សាវ័ករបស់ឡៅជឺ ប្រតិបត្តិយ៉ាងតឹងរឹង និងនៅមានឧត្តមធម៌ (Virtues) ទៀតច្រើនប្រការ ជាអាទិ៍ការគោរពមាតាបិតា ការភក្តីចំពោះព្រះមហាក្សត្រិយ៍និងគ្រូអាចារ្យ ការមេត្តាដល់មនុស្សនិងសត្វ ការមានសេចក្តីអំណត់អត់ធន់ ការទប់ស្កាត់ការធ្វើអំពើអាក្រក់ ការលះបង់ឱ្យអ្នកក្រខ្សត់ទន់ទាបជាងខ្លួន ការឱ្យឥស្សរភាពដល់សព្វសត្វរហូតដល់តិណជាតិ និងរុក្ខជាតិ ការឱ្យអំណោយដូចជា ជីកអណ្តូង សាងថ្នល់ ការបង្រៀនដល់អ្នកមិនចេះ មានការសិក្សាមិនឈប់ ការបូជាទេវតា ការបង្រៀន និងប្រតិបត្តិនៅក្នុងពួកសាសនិករបស់តៅយ៉ាងតឹងរឹង រួមសេចក្តីមកថាពាក្យប្រៀនប្រដៅរបស់ឡៅជឺ ផ្សេងៗឬជាមួយគ្នានឹងធម៌ក្នុងព្រះពុទ្ធសាសនា ជាហេតុអាចកើតឡើងបាន

ព្រោះតៅបានទទួលឥទ្ធិពលមកអំពីពុទ្ធសាសនាជាច្រើន ក្នុងសម័យតមក ការប្រតិបត្តិរបស់អ្នកបួសក្នុងសាសនាតៅ ទើបប្រហាក់ប្រហែលគ្នា និងអ្នកបួសពុទ្ធសាសនា តៅមានស្ថាប័នអ្នកបួសដូចគ្នានឹងពុទ្ធសាសនាក៏មាន។ ការគ្រប់សំពត់ ការសូត្រមន្ត និងការបំពេញព្យាយាម មិនខុសពីអ្នកបួសក្នុងពុទ្ធសាសនាច្រើនណាស់ដែរ អ្នកចេញបួសក្នុងសាសនាតៅហៅថាតៅស៊ឺ។ តៅយិន លះបង់ផ្ទះសម្បែង កូនប្រពន្ធ ចេញទៅនៅតាមភ្នំព្រៃព្រឹក្សា បរិភោគបន្លែ ស្មៅជាអាហារ ដើម្បីសង្ឃឹមយកផលឱ្យដល់នូវបរមសុខគឺតៅ មិនខុសអ្វីអំពីអ្នកបួសក្នុងពុទ្ធសាសនាលះបង់ផ្ទះសម្បែង ចេញទៅបំពេញព្យាយាមនៅក្នុងព្រៃ ប្រតិបត្តិធម៌ដើម្បីឱ្យដល់នូវបរមសុខ គឺ និព្វាន។(ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៣៩)

ពេលកន្លងទៅការផ្លាស់ប្តូរក្នុងសាសនាតៅ បានពង្រីកទូលំទូលាយជាច្រើន ពួកអ្នកបួសបានចងក្រង ពាក្យប្រៀនប្រដៅនិងបែបបទក្នុងពិធីកម្មទុក ដោយអាស្រ័យគោលធម៌ខាងពុទ្ធសាសនាផ្សំចូលជាមួយគ្នាផង ចលនារឿងទាក់ទងនឹងសួគ៌និងនរក រហូតធ្វើឱ្យគតិពីខាងដើមផ្លាស់ប្តូរជាច្រើន តែគោលបំណងចំណុចសំខាន់ដើម្បីធ្វើឱ្យមនុស្សខ្លាចក្រែង ដល់ការត្រូវដាក់ទោស និងមានបីតិរីករាយចំពោះការទៅកាន់ស្ថានសួគ៌ ជាចំណុចចុងក្រោយរបស់ជីវិត ដែលមនុស្សយើងមានសេចក្តីបំណង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ ២៤០)

ពិធីកម្មសម័យថ្មីរបស់សាសនាតៅ ដែលមានឥទ្ធិពលចំពោះជីវិតជនជាតិចិនបច្ចុប្បន្ន ភាគច្រើនទាក់ទងនឹងវេទមន្ត និងការសូត្រមន្តអាគមគាថា ធ្វើឱ្យអ្នកបួសអ្នករាប់អានសាសនាតៅ ក្លាយទៅជាទីប្រឹក្សាចាំចុះឈ្មោះឫក្សយាម ជាមគ្គុលក្នុងការប្រកបពិធីផ្សេងៗ ដូចជាពិធីរៀបមង្គលការ ការបញ្ចុះសពជាដើម។ មានពាក្យទាក់ទងនឹងនរក ដូចជាស្ថានជម្រះវិញ្ញាណលាងបាបឱ្យបរិសុទ្ធបាន ដែលអ្នកបានទទួលការជម្រះបាប អាចនឹងផុតទៅពីនរក។ អ្នកបួសពួកនេះរកចិញ្ចឹមជីវិតនៅជាមួយរឿងរបស់វិញ្ញាណ ចំណែកមុខនាទីដទៃៗ សុទ្ធតែជាការរកប្រាក់ចំណេញសម្រាប់ខ្លួនឯងប៉ុណ្ណោះ ដូចជាការលក់យ័ន្តគាថា ការពារកូតបិសាចភ័យអន្តរាយផ្សេងៗជាដើម។ ដូច្នេះសាសនាតៅធ្លាប់ប្តូរស្ទើរតែទាំងអស់ក្លាយទៅជាសាសនានៃសេយ្យសាស្ត្រ អ្នកបួសទាំងនេះមានប្រុសមានស្រីពាក់មួកពណ៌លឿងជាប្រចាំ មានពាក់មួកពណ៌ក្រហមនិងពណ៌ខ្មៅតាមនិកាយដែលបែកចេញទៅក៏មាន។

តែសេចក្ដីពិតរបស់តៅ តាមទស្សនវិជ្ជាជិតក្បែរនឹងការៈរបស់និព្វាន ដោយមានពាក្យអធិប្បាយថា អ្នកណាដល់តៅ អ្នកនោះប្រហែលដល់ទីបំផុតដ៏បរមសុខ និងអធិប្បាយតទៅទៀតថា សេចក្ដីដែលនឹងដល់បាននោះ នៅត្រង់ការប្រតិបត្តិមាន ៖

១-សេចក្ដីបរិសុទ្ធ, ២-ការទន់ភ្លន់, ៣-សេចក្ដីពេញចិត្តនឹងរបស់ដែលមាន, ៤-សេចក្ដីមេត្តាចំពោះសត្វទាំងឡាយ, ៥-ចំណេះចេះដឹង, ៦-មានសមត្ថភាពបង្ក្រាប់បញ្ញាខ្លួនឯង (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៤១) ៧-ការធ្វើចិត្តឱ្យសមាធិ និងការធ្វើចិត្តឱ្យជាសមាធិនេះឯង អាចនាំទៅកាន់ផ្លូវនៃតៅ។

**ចំណុចចុងក្រោយ**

ឡៅជឺជឿថាដួងវិញ្ញាណជាអមតៈ សេចក្ដីបរិសុទ្ធសុចរិតជាផ្លូវដើមដំបូង ដែលនឹងនាំដួងវិញ្ញាណឱ្យទៅកាន់តៅ និងការធ្វើឱ្យចិត្តនឹងធឹង រៀបរយស្អាតបាត លោកទាំងអស់រមែងចុះចាញ់ដល់យើងដោយឯកឯង។

ឡៅជឺមិនជានារឿងលោកខាងមុខថា តើត្រូវប្រព្រឹត្តទៅក្នុងរូបណា បែបណាឡើយ តែជានាអះអាងថា កាលបើបុគ្គលបំពេញខ្លួនជាមនុស្សស្ងប់ស្ងាត់ហើយ ចិញ្ចឹមជីវិតទៅតាមផ្លូវ ដោយព្រមទទួលសេចក្ដីពិតរបស់ធម្មជាតិ ដែលជាការពិតមែន ជីវិតនោះក៏នឹងដល់គោលបំណង ជាផ្លូវចុងក្រោយបំផុតគឺតៅ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ១ ទំព័រ២៤២)

# ជំពូកទី៥
# សាសនា ក្រុមសេមិទិក សាសនាជ្វីហ្វ សាសនាគ្រិស្ត សាសនាអ៊ីស្លាម សាសនាជ្វីហ្វ "យូដា"

## *សាសនានៃព្រះយេហូវ៉ាជាម្ចាស់*

*មុនព្រះយេស៊ូ ឬ យីស័សគ្រិស្ត* (JUSUS CHRIST) *ជាង២ពាន់ឆ្នាំ ក្សត្រិយ៍បាបិលោនៀន លើផែនដី នាឈូងសមុទ្រប៉ែក្ស ទ្រង់ព្រះនាមថា ហ័ម្មូរាប៊ី* (Hammurabi) *ជាក្សត្រិយ៍ ទ្រង់ស័ក្តិមួយព្រះអង្គរបស់ផៅពង្ស សេមិទិក ទ្រង់រួបរួមបញ្ញត្តិខាងផ្លូវសង្គម ដែលមានមក តាំងពីបូរាណកាល ប្រមូលឡើងទុកជាច្បាប់ឱ្យចារឹកបញ្ញត្តិនោះទុកលើផ្ទាំងសិលាធំ អ្នកស្រាវជ្រាវបានប្រទះឃើញសិលានេះ ប្រហែលជាជិតមួយរយឆ្នាំ។ ផ្ទាំងសិលានោះជាប់នៅ ជាមួយនឹងចុងសសរសិលាមួយ ឆ្លាក់ជារូបភាពក្សត្រិយ៍ ហ័ម្មូរាប៊ី ក្នុងខណៈទ្រង់ទទួល បញ្ញត្តិដូចបានពោលមកហើយ អំពីមហាទេព ឆាមាស៍* (Shamash) *សុរិយទេពដ៏ធំលើសលប់ របស់ជនជាតិ បាប៊ីលោនៀន។*

*នេះគឺភាពដែលសម្តែងថា អារ្យធម៌របស់បាប៊ីលោនៀន ឈានឡើងទៅកាន់ចំណុចដ៏ ខ្ពស់បំផុត រីកសាយចូលទៅកាន់ផែនដីជិតខាងដែលជាផែនដីនៃបុព្វបុរសរបស់ជនជាតិជ្វីហ្វ និងសម្តែងឱ្យឃើញថា សាសនា ជ្វីហ្វបុរាណមួយផ្នែក មានឫសគល់មកអំពីបញ្ញត្តិ ដែល ឆ្លាក់នៅក្នុងផ្ទាំងសិលានេះ។ សាសនារបស់ពួកជ្វីហ្វ នៅមានអ្នករាប់អានក្នុងបច្ចុប្បន្ន* (Living Religions) *ចាប់ផ្តើមឡើងអំពីលទ្ធិរបស់ជនជាតិបាប៊ីលោនៀន បុរាណដែលជាលទ្ធិគ្មានអ្នក រាប់អានទៅហើយ* (Dead Religion) ។ *(ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១)*

## *បុព្វបុរសនិងផែនដី*

*សម័យមុនយេស៊ូកើតជិត២ពាន់ឆ្នាំ មានមេដឹកនាំផៅពង្សសេមិទិក* (Semitic) *មួយរូប ឈ្មោះ អាប្រាហ័ម* (Abraham) *ធ្វើដំណើរចាកចេញពីក្រុងអ៊ូរី* (UR) *នៃខេត្តចាលដៀ* (Chaldea) *ដែលតាំងនៅក្នុងចន្លោះក្បែរគ្នានឹងអាណាចក្រ អាប៊ីលោនៀន លោកនេះគឺបុព្វបុរសរបស់ ជនជាតិហេប្រ៊ូវឬយូដា (ជ្វីហ្វ) ដែលជាម្ចាស់សាសនាជ្វីហ្វ។ អាប្រាហ័ម នាំពួកសេមិទិកមួយ ក្រុមធ្វើដំណើរពនេចរសោត់អណ្តែតទៅតាមទន្លេខ្សាច់ ដើម្បីស្វែងរកទីកន្លែងប្រកបរបររក ស៊ីសមរម្យត្រង់ណា ក៏បោះជំរំសម្រាកនៅត្រង់នោះ ដូចជាជនជាតិ ទន្លេខ្សាច់ ផៅពង្សដទៃ ព្យាយាមកាប់ក្ការដីកន្លែងណាទំនេរដែលមើលទៅឃើញថាមានដីជាតិល្អ។ គ្រាដំបូង អា-*

ប្រាហាំ នាំពួកពលចូលទៅអាស្រ័យនៅនាតំបន់មួយកន្លែងឈ្មោះ ហារ៉ាន់ (Haran) ក្នុងខេត្តមីស្សូប៉ូតាមៀ (Mesopotamia) ដែនដីក្នុងចន្លោះទន្លេ តៃគ្រិស និង យូប្រេតេស ទិសនិរតីរបស់ទ្វីបអាស៊ី តែនៅមិនបានយូរ ទើបនាំគ្នាលើកគ្រួសារចូលទៅកាន់ប្រទេសអេហ្ស៊ីបដែលជាកន្លែងនៅថ្មី។ មនុស្សពួកនេះបានទទួលការឧបត្ថម្ភយ៉ាងកក់ក្ដៅជាគ្រាដំបូង តែពេលក្រោយមក ត្រូវជនជាតិអេហ្ស៊ីបបន្ថយឥស្សរភាពចុះមកជា ទាសៈ និងបង្ខំឱ្យសាងអនុស្សាវរីយ៍ដ៏មហិមា គឺពីរ៉ាមីត ដែលជាវត្ថុអស្ចារ្យរបស់សកលលោក តាំងនៅនាដងទន្លេនិល (Nile) ក្នុងឥឡូវនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២)

ទាំងជនជាតិជ្វីហ្វនិងគ្រិស្ទាន ដែលមានសាសនាជ្វីហ្វជាឫសគល់ដំបូងលើកតម្កើងរាប់អានអាប្រាហាំមថា "បិតានៃសទ្ធា" ដោយអាងថា អាប្រាហាំ ជាអ្នកមានជំនឿព្រះជាម្ចាស់ដ៏ធំនិងរាប់អានព្រះជាម្ចាស់អង្គនោះ ថាជាអ្នកទ្រទ្រង់សេចក្ដីយុត្តិធម៌ដល់ខ្លួន ហើយថាព្រះជាម្ចាស់អង្គនោះ គឺព្រះជាម្ចាស់នៃផែនដីនិងផ្ទៃមេឃរបស់ខ្លួន។

ការលើកក្រុមគ្រួសារគ្រាចុងក្រោយបំផុតរបស់អាប្រាហាំម និងបក្សពួកចូលទៅនៅក្នុងផែនដីមួយដុំទៀត ហៅថា ប៉ាឡេស្ទីន (Palestine) គឺបរិវេណមួយផ្នែករបស់ប្រទេសអ៊ីស្រាអែល (Israel) ក្នុងបច្ចុប្បន្ន តាំងនៅមាត់ទន្លេមេឌីទែរ៉ាណេខាងត្បូង កំណត់តាមភូមិសាស្ត្រនៅក្នុងទ្វីបអាស៊ី។ ផែនដីត្រង់នេះមានឈ្មោះ ម្យ៉ាងទៀតហៅថា ហ្វីលីស្ទៀ (Philistia) មនុស្សអាស្រ័យនៅលើផែនដីនេះហៅថា ហ្វីលីស្ទីន (ពាក្យថា ប៉ាឡេស្ទីន និងពាក្យថា ហ្វីលីស្ទីន ជាពាក្យតែមួយ) និងផែនដីត្រង់នេះឯង ជាកន្លែងកើតសាសនាជ្វីហ្វ។

ក្នុងគម្ពីរចាស់ (Old Testament) លើកតម្កើងអាប្រាហាំមជាបុព្វបុរសដំបូងរបស់ពួកហេប្រ៊ូ បន្តវង្សត្រកូលជាមនុស្សទី៩អំពីសេម (Shem) ដែលប្រកាន់ថាជាបឋមបុរសរបស់ផៅពង្សសេមិទិកទាំងអស់ បិតារបស់អាប្រាហាំមឈ្មោះ តេរាហ៍ (Te-rah) មានអាជីវៈជាជាងប៉ាន់ មានបងប្អូនពពោះជាមួយគ្នា ២នាក់ ទៀត ឈ្មោះ ណាហរ៍ (Nahor) និង ហារ៉ាន់ (Haran) បងប្អូនទាំងពីរនាក់នេះ ជាបុព្វបុរសផៅពង្សសេមិទិក ពួកដទៃ ដែលបែកខ្ញែកទៅបន្តវង្សត្រកូលនៅក្នុងបរិវេណជាមួយគ្នា និងក្នុងគ្រាសម័យជាមួយគ្នា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣)

លុះអាប្រាហាំមអនិច្ចកម្មទៅ អ៊ីសាក់ កូនប្រុសរបស់អាប្រាហាំម បានទទួលតំណែងជាអ្នកដឹកនាំក្រុមជំនួសឪពុក។ អ៊ីសាក់ មានកូនប្រុស២នាក់ឈ្មោះ អេដានិងយ៉ាកុប ម្ដាយ

ស្រឡាញ់កូនពៅណាស់ ទើបរកឧបាយកលឱ្យអ៊ីសាក់ជាស្វាមី ជ្រើសតាំងកូនពៅជាមេដឹកនាំជំនួសខ្លួនពេលស្លាប់ទៅ។ រឿងនេះបានធ្វើឱ្យកូនបងអាក់អន់ចិត្ត ទើបគិតព្យាបាទដល់យ៉ាកុបជាប្អូន។ យ៉ាកុបឃើញថាខ្លួនមានសេចក្ដីអន្តរាយមិនអាចនៅនឹងប៉ាឡេស្ទីនបានតទៅទៀត ក៏នាំបក្សពួកមួយក្រុមរត់គេចចេញទៅនៅឯគាលដៀ ជាស្រុកកំណើតរបស់ឪពុកយ៉ាកុប បានភរិយាមានកូន១២នាក់។ ក្នុងរយៈពេលនៅក្នុងគាលដៀ ក្រោយមកយ៉ាកុបប្រៀនប្រដៅបក្សពួករបស់ខ្លួនតាមបែបដែលបុព្វបុរស (អាប្រាហាំម) បានធ្វើមកហើយគឺឱ្យមនុស្សគ្រប់គ្នាមានជំនឿយ៉ាងខ្ជាប់ខ្ជួន ចំពោះព្រះជាម្ចាស់តែមួយព្រះអង្គ មិនគួរគោរពរាប់អានព្រះជាម្ចាស់ផ្សេងទៀត ទើបអាចនឹងមូលត្រកូលគ្នារឹងមាំបាន ខនេះគឺអនុសិទ្ធិនៃការរាប់អានព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់តែមួយព្រះអនុជរបស់ជនជាតិជ្វីហ្វតមកនាពេលខាងក្រោយ។

តែយ៉ាកុប មិនអាចធ្វើការរកស៊ីដោយសុខសាន្តនៅក្នុងគាលដៀបាន ទើបនាំប្រពន្ធកូននិងបក្សពួកមួយ ក្រុមទៀតធ្វើដំណើរចេញពីគាលដៀ ត្រឡប់ចូលទៅនៅក្នុងប៉ាឡេស្ទីនដែលជា "ផែនដីនៃសញ្ញា" ម្ដងទៀត។ ដោយហេតុនេះជាអ្នកមានសទ្ធានិងជាអ្នកមានការតឹងរ៉ឹងទើបមាននាមថា អ៊ីស្រាអែល តមកកាលបើយ៉ាកុប បានឡើងធ្វើជាធំក្នុងពួកហេប្រ៊ូវបានចែកពួកជនជាតិហេប្រ៊ូវជា១២ពួក តាមចំនួនកូន១២នាក់ តែងតាំងកូនរបស់ខ្លួនឱ្យជាមេដឹកនាំម្នាក់មួយពួកៗ ពួកហេប្រ៊ូវទើបមានឈ្មោះម្យ៉ាងទៀតថា អីស្រាអែលិច ប្រែថាកូនរបស់អ៊ីស្រាអែល (Children of Israel) ដោយប្រការដូច្នេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤)

## យោសេហ្វ បុរោហិតាចារ្យ

រហូតពេលនៃការធ្វើដំណើរពនេចររបស់ជនជាតិហេប្រ៊ូវ មានហេតុការណ៍ប្រាកដក្នុងប្រវត្តិសាស្ត្រ ក្នុងគ្រាដ៏ធំមួយរបស់ជនជាតិនេះ ជាផលប្រយោជន៍ឱ្យបុគ្គលសំខាន់កើតឡើងយ៉ាងតិច ២នាក់ គឺយោសេហ្វ បុរោហិតាចារ្យ របស់ស្ដេចហ្វារោហ៍នៃអេហ្ស៊ីបម្នាក់ និងមោសេស (Moses) អ្នកបង្កបង្កើតសាសនារបស់ជនជាតិ ជ្វីហ្វម្នាក់ទៀត។

ហេតុការណ៍ក្នុងប្រត្តិសាស្ត្រ ចាប់ផ្ដើមត្រង់ជនជាតិហេប្រ៊ូវធ្លាក់ទៅជាទាសកររបស់ជាតិអេហ្ស៊ីប។ ជីវិតរបស់មោសេស កើតឡើងក្នុងកណ្ដាលចំណោមសេចក្ដីលំបាកតោកយ៉ាករបស់ប្រវត្តិសាស្ត្រនៃការទៅជាទាសភាព។

តាមដែលបរិយាយមកហើយ កូនប្រុស១២នាក់របស់យ៉ាកុប (កូនប្រុសរបស់អ៊ីសាក់ចៅប្រុសរបស់ អាប្រាហាំម) នោះ កើតអំពីភរិយា ២នាក់គឺ លិអា ប្រពន្ធដើម និងរាជែល

ប្រពន្ធចុង។ កូនប្រុសច្បងរបស់រាជេលឈ្មោះ យោសេហ្វ ឪពុកម្ដាយស្រឡាញ់កូននេះណាស់ ព្រោះជាក្មេងរូបរាងល្អមានសតិបញ្ញា តែគ្រោះអាក្រក់ដែលយោសេហ្វ ជាកូនប្រពន្ធចុង។ ការដែលកូនប្រពន្ធចុងជាទីស្រឡាញ់របស់ឪពុកម្ដាយណាស់នោះ ធ្វើឱ្យកូនប្រពន្ធដើមមិនពេញចិត្ត ឪពុកម្ដាយឃើញថា បើបណ្ដោយឱ្យយោសេហ្វនៅក្នុងប៉ាឡេស្ទីនតទៅនឹង នាំឱ្យមានសេចក្ដីអន្តរាយ ទើបស្រុះស្រួលគ្នាបំបែកយោសេហ្វឱ្យឃ្លាតចេញពីគ្រួសារដោយវិធីប្រគល់កូនប្រុស ឱ្យអ្នកជំនួញម្នាក់ជាជាតិអេហ្ស៊ីប ដែលធ្លាប់ស្និទ្ធស្នាលគ្នានាំ ទៅនៅក្នុងប្រទេសអេហ្ស៊ីប បើមើលទៅតាមបំណងរបស់ឪពុកម្ដាយ ក៏ប្រហែលជាចង់បញ្ជូនយោសេហ្វទៅសិក្សារកចំណេះវិជ្ជាក្នុងប្រទេសអេហ្ស៊ីប ដែលក្នុងពេលនោះកំពុងរីកចម្រើនដោយវិជ្ជាការ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៥)

អ្នកជំនួញអេហ្ស៊ីប នាំយោសេហ្វទៅលក់ជាទាសៈ នៅឯផ្ទះអង្គរក្សម្នាក់របស់ស្ដេចហ្វារោហ៍ ជាឱកាស ឱ្យយោសេហ្វបានសិក្សារកចំណេះដឹងនៅក្នុងរាជសំណាក់ យោសេហ្វជាក្មេងឆ្លាតសិក្សាវិជ្ជាហោរាសាស្ត្រហួត ដល់មានសមត្ថភាពទៅជាអ្នកទស្សន៍ទាយ។ លុះធំឡើងបានទទួលដំណែងរាជការនៅជិតជាមួយហ្វារោហ៍ ទទួលបម្រើក្នុងមុខងារជាអ្នកទាយមើលឫក្សយាមលើផ្ទៃមេឃរហូតជាទីគាប់ព្រះទ័យ។ គ្រាមួយនោះ មានកើតរោគឆ្លងនិងមានការអត់ឃ្លានកើតឡើងក្នុងប្រទេសអេហ្ស៊ីប យោសេហ្វបានរិះរកវិធីការពារជួយឱ្យ អេហ្ស៊ីបរួចផុតអំពីភ័យនេះបាន នៅទីបំផុតបានទទួលតំណែងជាអគ្គសេនាបតីរបស់ហ្វារោហ៍ រាប់ថាជាជនជាតិជ្វីហ្វទីពីរក្នុងពង្សាវតារលោក ដែលបានប្រើសតិបញ្ញារបស់ខ្លួនជួយធ្វើប្រយោជន៍ឱ្យដល់ផែនដី ដែល ខ្លួនទៅនៅអាស្រ័យ។

សេមេទិក ផៅពង្សហេប្រ៊ូវ (ជ្វីហ្វ) ជាពួករឹងប៉ឹង ស៊ូអត់ទ្រាំធ្វើការងារធ្ងន់ៗបានល្អប្រសើរជាងផៅពង្សសេមេទិកផ្សេងៗ ទៅនៅទីកន្លែងណាក៏មានមានៈអត់ធន់ ប្រើបញ្ញាធ្វើឱ្យមានការរីកចម្រើនដល់ទីកន្លែងនោះៗ។ ពួកហេប្រ៊ូវ ដែលចូលមកនៅក្នុងប្រទេសអេហ្ស៊ីបសម័យយោសេហ្វ បានធ្វើឱ្យមានការរីកចម្រើន ទុកជាច្រើនកន្លែង ពីរ៉ាមីត អនុស្សាវរីយ៍ដ៏ធំធេងខាងផ្នែកស្ថាបត្យកម្មរបស់អេហ្ស៊ីប ដែលនៅមានប្រាកដដល់សព្វថ្ងៃនេះ មានន័យថាការសម្រេចទៅបានក៏ព្រោះកម្លាំងប្រាជ្ញារបស់ជនជាតិហេប្រ៊ូវ អ្នកនៅអាស្រ័យក្នុងប្រទេសអេហ្ស៊ីប ក្នុងឋានៈជាទាសកម្មកររបស់ជនជាតិនេះឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៦)

ការដែលជនជាតិហេប្រឺ ធ្លាក់ទៅជាទាសភាពរបស់អេហ្ស៊ីបមានដំណើរ២យ៉ាង ទីមួយគឺការធ្វើដំណើរចូលទៅ ដើម្បីប្រកបមុខរបររកស៊ីតាមរយៈរបស់យ៉ូសែហ្វ មួយទៀតធ្លាក់ទៅនៅក្រោមការប្រើប្រាស់របស់អេហ្ស៊ីប ដោយជនជាតិអេហ្ស៊ីបទិញយកទៅធ្វើជាទាសៈ មកនាំខ្លួនយកទៅនៅពេលដែលចូលរុករកានឈ្នានពានប៉ាឡេស្ទីនៗ

សេចក្តីចម្រើនខាងផ្នែកវិជ្ជាការនិងការកើនឡើងនៃចំនួនជនជាតិហេប្រឺ ដែលកើតមានឡើងរាល់ថ្ងៃ ធ្វើឱ្យហ្វារ៉ោហ៍របស់អេហ្ស៊ីបមិនសប្បាយព្រះទ័យ ដោយខ្លាចក្រែងថា ថ្ងៃណាមួយបើមនុស្សពួកនេះគិតក្បត់ ដណ្តើមយកផែនដី គ្មានផ្លូវណាមួយដែលអេហ្ស៊ីបអាចស៊ូបានឡើយ ទើបប្រើអំណាចសង្កត់សង្កិនមិនព្រមឱ្យជនជាតិហេប្រឺ ចូលមកនៅលាយឡំជាមួយជនជាតិអេហ្ស៊ីប តាមទីកន្លែងផ្សេងៗ។ ការភ័យខ្លាចរបស់ហ្វារ៉ោហ៍ មានការកាន់តែច្រើនឡើង រហូតដល់មានរាជបញ្ជាឱ្យសម្លាប់ក្មេងប្រុសរបស់ជនជាតិហេប្រឺទាំងអស់ដែលទើបតែនឹងកើតថ្មីៗ កូនក្មេងហេប្រឺបានបាត់បង់ជីវិតអស់ជាច្រើនក្នុងសម័យនេះៗ

**កំណើតមោសេស អ្នកតាំងសាសនាជ្វីហ្វ**

មោសេស កើតមកក្នុងសម័យដែលហ្វារ៉ោហ៍បញ្ជាឱ្យប្រហារជីវិតកុមារកើតថ្មីៗ តែពុំមានអ្នកណា សម្លាប់មោសេសបាន ទឹកដីផ្ទៃមេឃជួយឱ្យរួចពីស្លាប់ ដើម្បីធ្វើប្រយោជន៍ដល់លោកនេះ ឪពុកម្តាយរបស់មោសេសនាំកូនរបស់ខ្លួនរត់ចេញអំពីផ្ទះ អធិដ្ឋានសូមទឹកដីជួយឱ្យកូនផុតអំពីភ័យ បីកូនដាក់ក្នុងកញ្ច្រែងមួយធំ បណ្តែតទៅតាមទឹកក្នុងទន្លេនិលៗ

កញ្ច្រែងបានអណ្តែតរហូតទៅដល់កំពង់ស្រង់ទឹករបស់ព្រះធីតាហ្វារ៉ោហ៍ៗ ព្រះធីតាទ្រង់ទតឃើញគួរស្រឡាញ់ នៅរស់មានជីវិតក៏នាំមកចិញ្ចឹមតាំងនាមថា "មោសេស" ដែលប្រែថា "អ្នករួចផុតពីលង់ទឹកស្លាប់"ៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៧)

ដើម្បីនឹងឱ្យក្មេងរួចផុតពីស្លាប់អំពីកណ្តាប់ដៃពេជ្ឈឃាដ ម្ចាស់ស្ត្រីទើបលបលាក់យកមោសេសទៅប្រគល់ឱ្យស្រីហេប្រឺជិតស្និទ្ធម្នាក់យកទៅចិញ្ចឹមថែរក្សាឱ្យទទួលការសិក្សា រៀនសូត្រ និងការរស់នៅស័ក្តិសម ជាកូនចិញ្ចឹមរបស់ម្ចាស់ក្សត្រិយ៍ៗ លុះមោសេសធំឡើង ម្ចាស់ស្ត្រីក៏ពង្រាត់មោសេសអំពីមេដោះ នាំចូលទៅនៅក្នុងវាំង ប៉ុន្តែមោសេសមានឈាមហេប្រឺ ធម្មជាតិបានបង្រៀនឱ្យជាអ្នកអាណិតជនជាតិហេប្រឺ ដែលធ្លាក់ជាទាសភាពរបស់ជនជាតិអេហ្ស៊ីប នៅទីបំផុតក៏មានអ្នកមកប្រាប់ថា ខ្លួនមានឈាមជាជនជាតិហេប្រឺ មិនមែនជាជនជាតិអេហ្ស៊ីបទេៗ

ប្រវត្តិសាស្រ្តត្រង់ជំពូកនេះសរសេរថា ថ្ងៃមួយមោសេសចេញអំពីវាំងទៅមើលជនជាតិហេប្រ៊ូវធ្វើការឱ្យជនជាតិអេហ្ស៊ីប បានឃើញជនជាតិអេហ្ស៊ីបវាយដំទាសៈហេប្រ៊ូវហូតដល់ស្លាប់ មោសេសភ្លេចខ្លួនដោយអំណាចទោសៈ បានសម្លាប់អេហ្ស៊ីបម្នាក់នេះស្លាប់ហើយក៏លួចរត់ចេញពីប្រទេសអេហ្ស៊ីប ទៅដល់ក្រុងមីដៀន (Midian) ក្នុងអារ៉ាប់ចូលទៅនៅអាស្រ័យជាមួយអ្នកបួសនាក្រុងនោះ បួសជាលោកក្លែងភេទ បន្ទំឈ្មោះថា ហោបាប់ (Hobab) ឬចេទម្រោ (Jethro) រៀបការជាមួយកូនក្រមុំរបស់អ្នកបួសទីក្រុងនោះ លុះពេលវេលាកន្លងមកល្មមសមគួរ ក៏លបធ្វើដំណើរចូលទៅជួយបងប្អូនជនជាតិហេប្រ៊ូវក្នុងអេហ្ស៊ីបទៀត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨)

## មោសេសដល់អេហ្ស៊ីប

ជួបជួនហ្វារោហ៍អង្គមុនអស់ព្រះជន្ម ហ្វារោហ៍អង្គថ្មី ទ្រង់លើកលែងទោសឱ្យមោសេស ដោយគិតថាបើ សម្លាប់ទៅស្តាយការចេះដឹង ប៉ុន្តែមោសេសត្រូវតែព្រមដាក់ខ្លួនជាទាសៈ មានឋានៈដូចជនជាតិហេប្រ៊ូវទាំងឡាយ។ ចាប់តាំងពីពេលនោះមក មោសេសបានទៅជាមេដឹកនាំពួកទាសកម្មករ ជួយគេធ្វើអិដ្ឋនិងទទួលធ្វើការកសាងឱ្យជនជាតិអេហ្ស៊ីប។

មោសេសសង្រួបបង្រួមជនជាតិហេប្រ៊ូវ តាំងជាសមាគមធ្វើអិដ្ឋដើម្បីជួយគ្នាទៅវិញទៅមក អ្នកតែងពង្សាវតារនិយាយថា មោសេសគួរនឹងបានឈ្មោះថាជាអ្នកតាំងសមាគម ឬសហព័ន្ធកម្មករឡើងមុនគេក្នុង លោក។

មោសេសធ្លាប់បានទទួលស្តេចផែនដីឱ្យលើកលែងទោសជនជាតិហេប្រ៊ូវ ចេញពីទាសភាព និងទូលសូមអនុញ្ញាតនាំបងប្អូនហេប្រ៊ូវចេញពីប្រទេសអេហ្ស៊ីប តែមិនបានទទួលការអនុញ្ញាតឡើយ។ លុះកន្លងមកក៏កើត រោគឆ្លងរាតត្បាតពាសពេញប្រទេស ហ្វារោហ៍មិនអាចដោះស្រាយកែបញ្ហានេះបាន ទ្រង់យល់ក្នុងព្រះទ័យថា ព្រោះតែឃាត់ឃាំងពួកហេប្រ៊ូវទុកព្រះជាម្ចាស់របស់ហេប្រ៊ូ មិនសព្វព្រះទ័យធ្វើឱ្យកើតរោគរាតត្បាត នាំសេចក្តីវិនាសមកឱ្យ ទើបកាត់ព្រះទ័យអនុញ្ញាតឱ្យមោសេស នាំពួកហេប្រ៊ូវចេញពីប្រទេសអេហ្ស៊ីបបាន។ សេចក្តីមានប្រាកដថា មុននឹងធ្វើដំណើរចេញពីអេហ្ស៊ីប មោសេសចេញបញ្ញត្តិឱ្យគ្រប់ៗគ្នាប្រកាន់យកជាព្រះជាម្ចាស់ ជាទីពឹងតែមួយព្រះអង្គប៉ុណ្ណោះ ដើម្បីជាស្នូលនៃការមូលត្រកូលគ្នាក្នុងពួក ក្រុម និងបញ្ជាឱ្យប្រុសៗ គ្រប់គ្នាពន្ធាត់ស្បែកចុងអវយវៈភេទចេញឱ្យអស់ជាមុនសិន ដើម្បីងាយស្រួលដល់ការសំអាតក្នុងដំណើរដើរផ្លូវឆ្ងាយ (ពួកមូស្លីមទទួលលទ្ធិនេះ មក

ជាពិធីរបស់ខ្លួននៅពេលក្រោយ) តាមកំណត់ឱ្យដឹងថា កាលមោសេសនាំបងប្អូនជនជាតិហេប្រ៊ូវចេញពីអេហ្សុីបនោះមានអាយុ ៨០ឆ្នាំ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩)

**បញ្ញត្តិ ១០ប្រការ**

មោសេសឱ្យសញ្ញាដល់ជនជាតិហេប្រ៊ូវថា នឹងនាំគ្នាធ្វើដំណើរទៅដល់ "ផែនដីនៃសញ្ញា" ការធ្វើដំណើរឆ្លងកាត់ការលំបាកវេទនានេះខ្វះសព្វខ្វះគ្រប់ រហូតទៅដល់ជិតភ្នំ ស៊ីណៃ (Sinai) ជនជាតិហេប្រ៊ូវទាំងឡាយ កាលបើបានទទួលសេចក្ដីលំបាកតោកយ៉ាកក៏នាំគ្នាមានគំនិតថា មោសេសនាំពួកគេឱ្យមកស្លាប់។ សេចក្ដីជ្រះថ្លាដែលមានចំពោះមោសេស ក៏ចាប់ផ្ដើមអស់ជំនឿ សទ្ធាធ្លាប់មានចំពោះព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ដែលបុព្វបុរសរបស់ខ្លួន ធ្លាប់គោរពរាប់អានមក និងជួយឱ្យទៅដល់ផែនដីនៃសញ្ញានោះ ក៏ចាប់ផ្ដើមថយចុះមកបន្តិចម្ដងៗជាលំដាប់។ ពួកខ្លះចង់តាមមោសេសតទៅ ពួកមនុស្សខ្លះទៀតចង់ធ្វើដំណើរត្រឡប់មកវិញ។ ក្នុងទីបំផុត ហេប្រ៊ូក៏បែកបាក់សេចក្ដីសាមគ្គីគ្នា ជាច្រើនពួកច្រើនក្រុម។

លុះមនុស្សទាំងឡាយបែកបាក់សាមគ្គីគ្នា មោសេសឃើញថា ៖ អវសានរបស់ជនជាតិហេប្រ៊ូជិតនឹងមកដល់ហើយ ទើបកាត់ចិត្តដោះស្រាយហេតុការណ៍ដោយសតិបញ្ញាដ៏ស្រួចរបស់ខ្លួន។ មោសេសបានបណ្ដោយឱ្យពួកហេប្រ៊ូវនៅមួយកន្លែង ខ្លួនឯងក៏ប្រញាប់ឡើងទៅលើកំពូលភ្នំស៊ីណៃ ដោយប្រាប់ថាទៅរកសេចក្ដីស្ងប់ខាងផ្លូវចិត្ត ឬដើម្បីទៅរិះរកគំនិតចុះមកជួយពួកហេប្រ៊ូវឱ្យសាមគ្គីគ្នាឡើងវិញ។ ទោះបីជាយ៉ាងណាក្ដី មិនយូរប៉ុន្មាន មោសេសចុះមកដល់ជើងភ្នំ ព្រមទាំងកាន់បន្ទះថ្ម២ផ្ទាំង បន្ទះនីមួយៗចារឹកបញ្ញត្តិរបស់ព្រះជាម្ចាស់ ៥ បញ្ញត្តិ រួមទាំងអស់១០បញ្ញត្តិជាមួយគ្នា។

បញ្ញត្តិ ១០ប្រការនោះ មោសេសបានប្រាប់ដល់ពួកហេប្រ៊ូវទាំងឡាយថាជាបញ្ញត្តិដែលព្រះជាម្ចាស់ ប្រទានមកសូមឱ្យជឿស្ដាប់ បើមិនជឿស្ដាប់ទេ ព្រះជាម្ចាស់នឹងដាក់ទោសឱ្យមានសេចក្ដីលំបាកវេទនា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០)

បញ្ញត្តិ ៥ ប្រការដំបូង

១-កុំឱ្យមានព្រះជាម្ចាស់ដទៃនៅពីមុខយើងឡើយ។

២-កុំធ្វើរូបសម្រាប់គោរពផ្ទាល់ខ្លួន ឬសណ្ឋានជារូបណាមួយ ទោះបីជាក្នុងអាកាសខាងលើក្ដី ទោះបី មាននៅក្រោមទឹក ក្រោមផែនដីក្ដី កុំក្រាបសំពះវាឬប្រតិបត្តិដល់វា ព្រោះថាព្រះយេះហូវ៉ារបស់អ្នកជាព្រះជាម្ចាស់ហួងហែងដាក់ទោស(ដល់អ្នកធ្វើខុសបញ្ញត្តិ) ជាប់តមក

រហូតដល់កូនចៅ៣-៤ជំនាន់មនុស្ស និងសម្តែង មេត្តាករុណាដល់អ្នកដែលស្រឡាញ់យើង និងរក្សាបញ្ញត្តិរបស់យើង។

៣-កុំបញ្ចេញព្រះនាមព្រះយេះហូវ៉ា ដែលជាព្រះរបស់អ្នកដោយទទេៗនោះ អ្នកដែលបញ្ចេញព្រះនាម គ្រាន់តែថាទទេៗ ព្រះយេហូវ៉ានឹងប្រកាន់ថាពុំមានទោស នោះមិនមែនទេ។

៤-ចូរឭកដល់ថ្ងៃសប៉ាតោ (Sabbath Day គឺ Holy Day) ថ្ងៃសៅរ៍) ឱ្យប្រកាន់ទុកថា ជាថ្ងៃបរិសុទ្ធ ចូរធ្វើការនិងឱ្យការងាររបស់អ្នកចប់ស្រេចបាច់ ក្នុងកំណត់៦ថ្ងៃ តែថ្ងៃទី៧នោះ ជាថ្ងៃសប៉ាតោនៃព្រះយេះហូវ៉ារបស់អ្នក។ ក្នុងថ្ងៃនោះ ការងារអ្វីៗកុំឱ្យធ្វើខ្លួនអ្នកក្តី បុត្រាបុត្រីរបស់អ្នកក្តី ទាសៈស្រីប្រុសរបស់អ្នកក្តី សត្វបម្រើរបស់អ្នកក្តី និងភ្ញៀវដែលអាស្រ័យនៅក្នុងទ្វារផ្ទះរបស់អ្នកក្តី ព្រោះថាក្នុងកំណត់៦ថ្ងៃ ព្រះយេះហូវ៉ា បានសាងផ្ទៃមេឃ ផែនដី ទន្លេ និងរបស់សព្វសារពើដែលមាននៅក្នុងរបស់ទាំងអស់នោះ ហើយក្នុងថ្ងៃទី៧ បានឈប់ធ្វើការងារហេតុដូច្នេះ ព្រះយេះហូវ៉ា ទើបទ្រង់ប្រទានពរដល់ថ្ងៃសប៉ាតោ និងតាំង (ថ្ងៃនោះទុក) ជា ថ្ងៃបរិសុទ្ធ។

៥-ចូររាប់អានមាតាបិតារបស់អ្នក ដើម្បីអ្នកនឹងមានអាយុយឺនយូរលើផែនដី ដែលព្រះយេះហូវ៉ាជាម្ចាស់ ប្រទានទុកឱ្យដល់អ្នក។ (ហេង គឹមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១)

បញ្ញត្តិ ៥ប្រការក្រោយ

៦-កុំឱ្យសម្លាប់មនុស្ស

៧-កុំកន្លងប្រពៃណីប្តីប្រពន្ធ

៨-កុំលួចទ្រព្យគេ

៩-កុំធ្វើសាក្សីកុហកដល់អ្នកភូមិជាមួយគ្នា

១០-កុំលោភយកផ្ទះរបស់អ្នកភូមិផងគ្នា កុំលោភយកភរិយាឬទាសៈស្រីប្រុស ឬគោលា របស់គេឬ របស់ណាមួយដែលជារបស់អ្នកភូមិផងគ្នា។

**បឋមហេតុនៃពាក្យ យេះហូវ៉ានិងបញ្ញត្តិ**

មានបញ្ហាទាក់ទងនឹងបញ្ញត្តិ ១០ប្រការ ហេតុដូចម្តេចបានជាបញ្ញត្តិ ១០ប្រការ មានន័យសេចក្តីដូច្នោះ និងពាក្យថាយេះហូវ៉ានោះសំដៅយកអ្នកណា?

មោសេស ជាមនុស្សឆ្លាត ជាមេដឹកនាំពពួកមនុស្សបាន ជាសាស្តាដូចគ្នានិងសាស្តាអ្នកមានសមត្ថភាពផ្សេងៗ សាស្តាដទៃដាក់បញ្ញត្តិនិងពាក្យប្រៀនប្រដៅទុក ដើម្បីសាវ័ក

របស់ខ្លួនបាន ព្រោះហេតុផ្សេងៗ យ៉ាងណាមិញ មោសេសក៏មានហេតុផលរបស់ខ្លួនដូចគ្នាដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២)

ពិចារណាសេចក្តីតាមបញ្ញត្តិ ក្នុងខណៈដែលជនជាតិហេប្រ៊ូរកំពុងទទួលរងទុក្ខលំបាក នៅបរិវេណភ្នំស៊ីណៃ ការប្រឡូកប្រឡល់ក្នុងពួកក្រុមប៉ះទង្គិចគ្នា មានឱកាសធ្វើអំពើអាក្រក់បានងាយ ដើមដំបូងគឺការធ្វើអំពើអាក្រក់ ដោយការមិនគោរពពាក្យបង្គាប់អានរបស់ណាទីមួយៗ មួយទៀត ទីណាមានមនុស្សច្រើនរមែងមានសេចក្តី យល់ឃើញបែកខ្ញែកគ្នាជាច្រើនក្លាយទៅជាពួកជាក្រុម ជនជាតិហេប្រ៊ូរទាំងឡាយនាំគ្នាប្រព្រឹត្តខុស កូនប្រពន្ធគេ ខូចសីលធម៌ យករបស់របរអ្នកដទៃមកធ្វើជារបស់ខ្លួន និយាយត្រឡប់ត្រឡិនបោកប្រាស់គ្នាដើម្បីឱ្យបានប្រយោជន៍ដល់ខ្លួន។ ហេប្រ៊ូរពួកខ្លះសម្តែងសេចក្តីអកតញ្ញូចំពោះមាតាបិតា គ្រូបាអាចារ្យ ប្រព្រឹត្តជាមនុស្សអាក្រក់ជូជាតិ ទាំងអស់នេះគឺហេតុនៃការបំផ្លាញសង្គមដ៏ល្អ ខ្វះសេចក្តីសាមគ្គី ជាប្រទេសជាតិមិនបាន មោសេសឃើញថាគ្មានផ្លូវនឹងបង្គាប់បញ្ជាបានទៀត ទើបប្រកាសបញ្ញត្តិ ១០ប្រការ លើកយកហេតុផលនៃការប្រព្រឹត្តអាក្រក់របស់មនុស្សទាំងឡាយឡើងមកជាគំរូ ដោយប្រការដូច្នោះឯង។

បញ្ហាដែលគួរពិគ្រោះមួយទៀតគឺ បញ្ហាថា អ្នកណាគឺព្រះយ៉ះហូវ៉ា មោសេស ឬអ្នកណាជាអ្នកសន្មត ឡើងមកឬថាព្រះយ៉ះហូវ៉ានោះ មានបុគ្គលាធិដ្ឋានយ៉ាងណាដែរ។

អ្នកប្រាជ្ញឈ្មោះ ចេមស៍ ហ្វ្រីម៉ែន ខ្លាក បាននិយាយជាផ្លូវវិនិច្ឆ័យថា ពាក្យថា យ៉ះ ហូវ៉ា (Yahowah) ឬ យេហូវ៉ា (Yehowah) ជាពាក្យក្លាយមកពីពាក្យថា យាហាវេ (Yahaweh) ដែលជាភាសាជនជាតិមិដៀន ក្នុងផែនដីមោសេសធ្លាប់រត់ចេញពីអេហ្ស៊ីបទៅលាក់ខ្លួន។ ន័យមួយទៀតថា ជាភាសាហេប្រ៊ូរបុរាណ មានន័យ ត្រូវនឹងភាសាអេហ្ស៊ីបបុរាណថា Nuk-Pu-Nak ដែលមានន័យសេចក្តីក្នុងភាសាអង់គ្លេសថា I am The I am (ខ្ញុំគឺខ្ញុំ អត្ត-អាត្ម័ន)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣)

អ្នកប្រាជ្ញឈ្មោះម៉ារីសេច័ស ត្រូវអានបាឋកថារឿងសាសនារបស់ជនជាតិអ៊ីស្រាអែលរបស់គ្រិហ្វហ្វត (Crifford) ថា ពាក្យថា យ៉ាហាវេ ជាភាសាហេប្រ៊ូរដើម ក្លាយមកជាភាសាអារ៉ាប់ក្នុងពេលក្រោយ មានន័យ សេចក្តីក្នុងភាសាអង់គ្លេសថា To be ឬ To become ស្មើគ្នានឹងពាក្យថា ការកើតឯងឬសភាវៈ ន័យនេះសំដៅ ដល់ធម្មជាតិដែលប្រព្រឹត្តទៅដោយខ្លួនឯង (តាមពលំនៃធាតុគូនឹងលោក) ដូច ផ្គរ ភ្លៀងធ្លាក់ រន្ទះជាដើម។

*អ្នកប្រាជ្ញ បារ័តាន់ ស្រាវជ្រាវទៅឃើញថា ការរាប់អានព្រះយេះហូវ៉ា បានផ្សព្វផ្សាយនៅក្នុងចំណោម សេមិទិកផ្សេងៗមកពីមោសេស ត្រកូលរបស់យ៉ាកុប ដែលជាត្រកូលធំមុនសម័យមោសេស ក៏រាប់អានព្រះយេះហូវ៉ា អ្នកបួសដែលជាឪពុកក្មេករបស់មោសេស ក្នុងផែនដីអារ៉ាប់ ដែលមោសេសរត់ពីអេហ្សីបទៅសុំ សំណាក់អាស្រ័យក៏រាប់អានយេះហូវ៉ា មោសេសបានទទួលគោលការណ៍រាប់អានព្រះយេះហូវ៉ា មកអំពីត្រកូល របស់ឪពុកក្មេកដែរ។*

*បារ័តាន់ អះអាងថា យេះហូវ៉ា ជាព្រះរបស់ជនជាតិ* (Midian=Midianite) *មកមុន ក្លាយជាព្រះជាម្ចាស់ របស់ជនជាតិហេប្រ៊ូវឬអ៊ីស្រាអែលដែលមានមោសេសជាអ្នកដឹកនាំ មនុស្សពូជពង្សនេះ ជាផៅពង្សពនេចរ ត្រាច់ពីព្រំដែនប្រទេសអេហ្សីប ទៅទិសខាងកើតនៃទីក្រុងមេឌិនៈ* (Medina) *ក្នុងជ្រោយអារ៉ាប់។ ព្រះជាម្ចាស់របស់មនុស្សផៅពង្សនេះ ដូចជាព្រះជាម្ចាស់របស់ជនជាតិ សេមិទិកផៅពង្សផ្សេងៗដែររាប់អានថា យេះហូវ៉ា ឬយាហាវេ ព្រះជាម្ចាស់នៃក្សេត្រកម្ម។ មនុស្សផៅពង្សនេះលើកតម្កើងឫទ្ធានុភាពឱ្យដល់ព្រះជាម្ចាស់ (យ៉ាហាវេ) របស់ខ្លួនទុកថា អាការផ្ទុះនៃភ្នំភ្លើង និងការដែលភ្នំជាច្រើនរលំរលាយទៅក្នុងកន្លែងជាមួយគ្នា ជាហេតុឱ្យកើតទន្លេស្លាប់ គឺ* Dead Sea *ក្តី ភ្លៀងធ្លាក់ចុះមកនាបរិវេណភ្នំស៊ីណៃខ្លះក្តី ការច្បាំងបានជ័យជម្នះ អំពីមនុស្សផៅពង្សដទៃក្តី កាន់ថាកើតឡើងព្រោះឫទ្ធិរបស់ព្រះជាម្ចាស់អង្គនោះទាំងអស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤)*

*ពាក្យអធិប្បាយរបស់បារ័តាន់ ជាប្រវត្តិសទ្ធាសម្តែងឱ្យឃើញថា ព្រះជាម្ចាស់អង្គនេះមានអ្នករាប់អាន មកមុនមោសេស មិនគិតជាងពាន់ឆ្នាំ តែបារ័តាន់មិនបានសម្តែងប្រវត្តិនៃពាក្យ ឬព្រះនាមរបស់យេះហូវ៉ា ដូចជាអ្នកប្រាជ្ញ២រូប ដែលពោលមកពីខាងដើម។*

*បើទាញយកគោលអធិប្បាយ ន័យសេចក្តីនៃពាក្យរបស់អ្នកប្រាជ្ញទាំងពីរខាងដើម បញ្ហាដែលសួរថា អ្នកណាគឺយេះហូវ៉ា គួរនឹងឆ្លើយជាគោលធម៌បាន២ន័យគឺន័យដំបូង យេះ ហូវ៉ា បានដល់អត្តាខ្លួនរបស់ខ្លួនឯង* I am The I am) *ន័យមួយទៀត យេះហូវ៉ា បានដល់សភាពដែលមានឯងកើតឯង* (To be *ឬ* To become) *ការដែលប្រដៅថា កុំឱ្យមានព្រះជាម្ចាស់ ដទៃណានៅពីមុខយើង ក៏ប្រហែលគ្នាមិនឱ្យទៅរាប់អានអ្នកដទៃណា ក្រៅអំពីខ្លួនឯង កុំឱ្យ ទៅរាប់អានរបស់ណា វៀរលែងខ្លួនឯង ឬឱ្យឃើញថា របស់ទាំងឡាយដែលប្រព្រឹត្តទៅ វា មាននៅតាមសភាពរបស់ខ្លួនឯង អាចរាប់បានថា ផៅពង្សសេមិទិកបុរាណ តាំងតែពីសម័យ មោ*

សេសរហូតដល់មោសេសខ្លួនឯង អាចប្រកាសនាមព្រះជាម្ចាស់បានដោយបុគ្គលាធិដ្ឋាន ដែលសម្ដែងដល់ធម្មៈបានជាសច្ចៈ នៅទីបំផុត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៥)

**យ:ហូវ៉ា និង អាល្លាហ៍**

ផលនៃការស្រាវជ្រាវបានសេចក្ដីថា ព្រះយ:ហូវ៉ារបស់ជ្វិហ្វនិងអល្លោះហ៍ ឬព្រះអាល្លាហ៍របស់សាសនា អ៊ិស្លាម ជាអង្គតែមួយ ហេតុផលមានដូចតទៅនេះ ៖

មាននាមព្រះយ:ហូវ៉ាមួយព្រះនាមទៀត ដែលប្រាកដក្នុងពពួកហេប្រ៊ូ គឺអេល (EL) អេលោហ៊ិម (Elohim) ឬ អេលោហា (Eloha) ប្រែថា "ទ្រង់ជាអ្នកមានពលំរឹងមាំ" ព្រះនាមគឺព្រះជាម្ចាស់របស់ផៅពង្ស សេមិទិគ ក្នុងសម័យនោះ តមកនាមនេះបានក្លាយជា អល្លាហ៍ (Allah) ឬ អល្លោះហ៍ ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់របស់ជនជាតិអារ៉ាប់ និងរបស់ពពួកជនដែលរាប់អានសាសនាអ៊ិស្លាម។

លុះកាលកន្លងមកដល់សម័យនៃមោសេស ជនជាតិហេប្រ៊ូទាំងឡាយ រួមគ្នាជាក្រុមដ៏មាំទាំ មានវង្សត្រកូលខ្ជាប់ខ្ជួន ផលទាំងអស់នេះបានមកអំពីការព្យាយាមរបស់មោសេស។ អ្នកប្រាជ្ញបារាំង ស្រាវជ្រាវបានសេចក្ដីថា ការព្យាយាមដែលមោសេសអាចចងក្រងហេប្រ៊ូឱ្យរស់នៅមាំមួនបាននោះ ចែកជាហេតុមាន ៤ យ៉ាងគឺ ៖

ក-ការប្រកាសបញ្ញត្តិ ១០ប្រការ ជាគ្រឿងចងភ្ជាប់ដោយការអាងថា ជាបញ្ញត្តិរបស់ព្រះជាម្ចាស់ ជាបញ្ញត្តិរបស់ជនជាតិហេប្រ៊ូទាំងឡាយ បញ្ញត្តិនោះដូចជាគ្រឿងចងភ្ជាប់នៃជាតិ និងវង្សត្រកូល។

ខ-មោសេសព្យាយាមឱ្យពួកហេប្រ៊ូរៀបការគ្នាឯងក្នុងពួកក្រុមរបស់ខ្លួន មិនព្រមឱ្យអ្នកដទៃមកប៉ះពាល់ អ្នកបួសរៀបការគ្នាក្នុងពួកអ្នកបួស ពួកជាងឱ្យរៀបការជាមួយជាង ឱ្យកម្មកររៀបការជាមួយកម្មករ និងទៅជាហេប្រ៊ូពួកជាមួយគ្នា។

គ-ឱ្យមានបន្ទាយបរិសុទ្ធ (Holy Tent) ជាទីកន្លែងប្រកបពិធីក្នុងសាសនា មោសេសខ្លួនឯងជាអ្នកដឹកនាំពិធី និងប្រគល់ឱ្យយោឈួ (Joshua) សិស្សដៃស្ដាំ ទាយាទបន្តតំណែងជាអ្នកដឹកនាំ បន្ទាយបរិសុទ្ធនេះ តមកបានក្លាយជាបូជនីយស្ថានពួកហេប្រ៊ូ ក្លាយជាទីរួមមនុស្សរួមសទ្ធា ជួយឱ្យកើតសេចក្ដីសាមគ្គី បានជាពួក ជាក្រុម ការសាងបន្ទាយ បរិសុទ្ធក្លាយទៅជារូបវិហារ (Church) ក្នុងពេលក្រោយ។

ឃ-ឱ្យមានហិបនៃបញ្ញត្តិគឺ Box of Covenant of Yahweh ឬ Ark of Convenant of Yahweh មានថ្មស័ក្តិសិទ្ធិចារឹកបញ្ញត្តិទុក២ផ្ទាំង ផ្ទាំងនីមួយៗ ៥បញ្ញត្តិ និងទៅទីណាត្រូវជួយគ្នាសែងហិបនោះ ប្រដូចជាព្រះយ:ហូវ៉ា ស្ដេចបានរួមដំណើររួមសុខទុក្ខ រង់ចាំការពាររក្សាជនជាតិហេប្រ៊ូវទៅជាមួយផង ដើម្បីទ្រង់ជួយចងភ្ជាប់ពួកក្រុមឱ្យទៅជាបាច់តែមួយៗ

**សម័យអាណាចក្រ**

សម័យនោះប្រហែលជា ១៣០០-១២០០ឆ្នាំ មុនគ.ស. កាលដែលមោសេសនាំពួកហេប្រ៊ូវចេញពីប្រទេសអេហ្ស៊ីបរហូតទាល់តែប្រកាសបញ្ញត្តិ១០ប្រការបានហើយ នាំគ្នារសាត់អណ្តែតទៅដល់ទន្លេហ្សរដាំង ជាទឹកន្លែងសម្បូណ៌ បានតស៊ូជាមួយជនជាតិគានាអាន់ ជាម្ចាស់ទឹកដីពីដើមរហូតបានទទួលជ័យជម្នះ ទើបនាំគ្នាតាំងកាប់ក្ការនៅលើផែនដីកន្លែងនេះៗ សម័យនេះ ជនជាតិហេប្រ៊ូ ពុំមានផែនដីស្ថិតស្ថេរជារបស់ខ្លួនឯងទេ ត្រូវខ្ចាត់ព្រាត់បែកបាក់គ្នាក្នុងមួយរយ: ទីបំផុតបានមនុស្សល្អម្នាក់ឈ្មោះ សាអ៊ូល (Sa ul) លោក មានសមត្ថភាពអាចបង្រួបបង្រួមជាតិហេប្រ៊ូ តាំងជាជាតិឡើងវិញបាន សាអ៊ូលទទួលការលើកតម្កើង ជាបឋមក្សត្រិយ៍ ក្នុងប្រវត្តិសាស្ត្ររបស់ជនជាតិហេប្រ៊ូៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧)

អស់សម័យរបស់សាអ៊ូល ដាវីត (David) ឡើងបន្តរាជជំនួសៗ ស្ដេចអង្គនេះជាអ្នកប្រាជ្ញមានកុសលោបាយ ចាត់របៀបគ្រប់គ្រងជនជាតិហេប្រ៊ូបានល្អប្រសើរណាស់ ទ្រង់បានរួបរួមអាណាចក្រហេប្រ៊ូ ចូលជាមួយយ៉ាងមាំទាំពុំមានសម័យណាប្រៀបស្មើនឹងយុគរបស់ស្ដេចដាវីតនេះឡើយៗ យុគនេះជាយុគមាសរបស់ជនជាតិ ហេប្រ៊ូ អតីតកាលដ៏វែងឆ្ងាយរបស់ស្ដេចដាវីត ជាអតីតដែលជនជាតិជីហ្វគ្រប់សម័យមិនអាចបំភ្លេចបាន ស្ដេចជីហ្វព្រះអង្គនេះ ទ្រង់គ្រងរាជសម្បត្តិក្នុងរវាងឆ្នាំ ១០១៦ ដល់៩៧៦ មុនគ.ស.ៗ

ចប់សម័យដាវីត រាជឱរសនាមថា សូឡូម៉ុន (Solomon) ឡើងគ្រងរាជសម្បត្តិបន្តទៀត សម័យរបស់ សូឡូម៉ុន ជាសម័យមាសជាជាងសម័យរបស់ដាវីត ព្រោះសូឡូម៉ុន ជាអ្នកមានព្រះបញ្ញា មានសមត្ថភាពខ្ពង់ខ្ពស់ ទ្រង់ជាអ្នកប្រាជ្ញដ៏ឆ្នើម ប្រកបដោយទសពិធរាជ-ធម៌ ព្រះប្រើជាញាណរបស់សូឡូម៉ុន មានប្រាកដជាបទបង្រៀននិងអក្សរសាស្ត្រនៃលោកមានឈ្មោះមកដល់សម័យក្រោយៗជាបែប ជាច្បាប់របស់អ្នកប្រាជ្ញ និងអ្នកនយោបាយ ក្នុងពេលបច្ចុប្បន្នៗ

គ្រោះកម្មរបស់ជនជាតិហេប្រ៊ូវខាងផ្លូវអាក្រក់ ក្នុងគ្រាអស់សម័យរបស់សូឡូម៉ុន អាណាចក្ររបស់ហេប្រ៊ូ បែកចេញជាផ្នែកខាងជើងនិងខាងត្បូង អស់ពេលជិតកន្លះសតវត្ស ត្រូវច្បាំងកាប់សម្លាប់គ្នាឯងគ្នាន លោះលាត្រាប្រណីឡើយ។ ដោយអាណាចក្រហេប្រ៊ូវតាំងនៅត្រង់ចន្លោះកណ្ដាលព្រះដែន រវាងអេហ្ស៊ីបទិស ខាងលិច និងអស្ស៊ីរៀ នៅទិសខាងកើត (ពីមុនជាខ្សែបន្ទាត់ឈប់បាញ់គ្នាក្នុងសង្គ្រាម ៦ថ្ងៃ មិថុនា គ.ស. ១៩៦៧) ផែនដីរបស់ហេប្រ៊ូ ទើបក្លាយទៅជាសមរភូមិនៃការច្បាំងគ្នារវាងជាតិដែលមានអំណាច។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៨)

ជនជាតិហេប្រ៊ូវត្រូវធ្លាក់នៅក្នុងសភាពប្រឫកប្រុបល់អំពល់ទុក្ខអស់រយៈ ពេលយ៉ាងយូរ ដល់ទីបំផុតប្រហែលជាពេលមុនគ្រិស្តសករាជ ៧២២ឆ្នាំ អាណាចក្រហេប្រ៊ូ ទិសខាងជើងវិនាសសាបសូន្យអស់ពូជអម្បូរ ផៅពង្សហេប្រ៊ូវទាំង១២ពូជ ត្រូវបែកខ្ចាត់ខ្ចាយគ្នា ពុំមានឱកាសប្រមូលគ្នាបានទៀតឡើយ។ ការបែកខ្ញែករបស់ "កូនអ៊ីស្រាអែល" សម័យនោះរាប់ថាជាការបែកបាក់គ្រាធំបំផុតក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ព្រោះពួកជ្វីហ្វបានបែកខ្ញែកគ្នាជាពួកជាក្រុមទូទៅក្នុងលោក ជ្វីហ្វរង់ចាំការត្រឡប់មកកាន់ដែនដីកំណើតកន្លង មកទាល់តែចង់សង្គ្រាមលោកទីពីរកាល "កូនអ៊ីស្រាអែល" ប្រកាសឯករាជ្យឡើងជាជាតិវិញ ក្នុងដែនដីប៉ាឡេស្ទីន (គ.ស.១៩៤៧)។

ចំណែកអាណាចក្រភាគខាងត្បូងនោះ សូម្បីនៅគង់វង្សតទៅទៀតបានប្រហែលជាជាងកន្លះសតវត្ស តែក្នុងទីបំផុតក្នុងរវាងមុនគ្រិស្តសករាជ ៤៨៦ឆ្នាំ ក៏ត្រូវលិចលង់ទៀតដោយការរុករានរបស់ជាតិបាប៊ីឡូនៀ។ ជនជាតិជ្វីហ្វនៅទីក្រុង យេរូសាឡិម បានព្យាយាមវាយដណ្ដើម រើបម្រះខ្លួនឡើងវិញក្នុងគ្រាខ្លះ តែឥស្សរភាពរបស់ជនជាតិហេប្រ៊ូវ ក៏ត្រូវរលត់ឈឹងសូន្យទៅតាមជតាកម្មជ្វីហ្វធ្លាក់នៅក្រោមអំណាចរបស់ បាប៊ីឡូនៀ ប៉ែក្ស ក្រិក រ៉ូម៉ាំង និងមហាអំណាចពួកដទៃម្ដងទៀត។

ប្រវត្តិសង្ខេបរបស់ជនជាតិជ្វីហ្វខាងលើនេះ និយាយគ្រាន់តែត្រួសៗឱ្យឃើញប្រវត្តិសាស្ត្រមួយវគ្គដែលមានការទាក់ទងគ្នា នៃការប្រព្រឹត្តទៅរបស់សាសនាជ្វីហ្វដែលមានការផ្សំផ្គុំប្រែប្រួលអស់ពេលវេលាជាយូរយារ ប៉ុន្តែមកពីការផ្សំផ្គុំនិងការប្រែប្រួលសាសនាជ្វីហ្វនោះឯង ក៏បានត្រឡប់ក្លាយមកជាមេរៀនរបស់សាសនា ដែលសំខាន់បំផុត២ក្នុងលោក គឺសាសនាគ្រិស្ត និងអ៊ិស្លាមដែលនឹងអធិប្បាយតទៅខាងមុខ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៩)

ដូចបានពោលមកហើយ សាសនាប្រចាំពូជពង្សរបស់ជនជាតិជ្វីហ្វ ជាសាសនាគោរពបូជាព្រះជាម្ចាស់ច្រើនអង្គ តាំងពីសម័យបុព្វបុរស ទើបក្នុងរវាងដែលបុព្វបុរសរបស់ជនជាតិសោត់អណ្តែត ព្រោះត្រូវអំណាចខាងផ្លូវនយោបាយនិងការគាបសង្កត់ចង្អៀតចង្អល់ក្នុងការប្រកបរបររកស៊ី ធ្វើឱ្យសាសនាធ្លាប់គោរពបូជាមកពីដើម ត្រូវផ្សេផ្សាំជាមួយការគោរពបូជារបស់អ្នកនៅទឹកដីនោះៗ ការសោត់អណ្តែតនេះ ពិបាកនឹងកំណត់បានថា សាសនាជ្វីហ្វក្នុងសម័យពីដើមនោះ គោរពបូជា គោរពព្រះជាម្ចាស់អង្គណា មានចំនួនប៉ុន្មាន និងតើពិតប្រាកដយ៉ាងណាដែរ? រហូតមកដល់សម័យរបស់មោសេស គតិការគោរពបូជាសាសនារបស់ជនជាតិជ្វីហ្វ បានផ្លាស់ប្តូរទៅអស់រលីង ជនជាតិជ្វីហ្វត្រឡប់មកគោរពបូជាព្រះជាម្ចាស់តែមួយអង្គគឺយាហាវេ ឬដែលហៅម្យ៉ាងទៀតថា យេហូវ៉ា ដូចមានសេចក្តីប្រាកដក្នុងបញ្ញត្តិ ១០ប្រការ ដែលមោសេសជាអ្នកប្រកាសបានពោលរួចហើយពីខាងដើមៗ

ត្រង់នេះសូមសម្តែងបន្តិច ដល់គតិខាងផ្លូវសាសនារបស់ជនជាតិ កាណាអាន់ ម្ចាស់ផែនដីដែលមោសេស នាំបងប្អូនជាតិហេប្រ៊ូ សោត់អណ្តែតចូលទៅអាស្រ័យនៅក្នុងគ្រាចុងក្រោយបង្អស់ៗ កាលបើបាននាំគ្នារត់ចេញពីប្រទេសអេហ្ស៊ីបហើយ ដើម្បីឱ្យឃើញថា គតិការគោរពបូជាព្រះអម្ចាស់របស់ជនជាតិហេប្រ៊ូ នាំគ្នាសោត់ខ្ចាត់ខ្ចាយក្នុងពេលនោះ បានផ្សេផ្សាំជាមួយគតិក្នុងសាសនារបស់ជនជាតិកាណាអាន់យ៉ាងណាៗ (ហេង គឹមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២០)

ជនជាតិកាណាអាន់និងជនជាតិហេប្រ៊ូ មានបែបបទនៃជីវភាពខុសគ្នាៗ ហេប្រ៊ូជាពួកពនេចរសោត់អណ្តែតទៅដល់ទីណាចិញ្ចឹមជីវិតនៅទីនោះ និងទទួលគតិខាងផ្លូវសាសនារបស់អ្នកទឹកដីនោះ ផ្សេផ្សាំជាមួយនឹងសាសនារបស់ខ្លួនផងដែរៗ ចំណែកពួកកាណាអាន់រកស៊ីក្នុងមុខរបរកសិកម្ម មានគោលការណ៍ អាស្រ័យនៅនឹងមួយកន្លែង សាសនារបស់ជនជាតិកាណាអាន់ ជាសាសនាជាប់នៅនឹងទឹកដី ទេពជាម្ចាស់របស់កាណាអាន់ ជាអាទិទេពនៃកសិកម្ម ព្រះនាមថា បាល (Baal) ដែលជនជាតិកាណាអាន់ជឿប្រកាន់ថា ជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ អាចបណ្តាលឱ្យបានភោគផលសមតាមសេចក្តីប្រាថ្នាៗ

គតិនៃការគោរពបូជាទេពជាម្ចាស់ បាល ជាគតិចាស់របស់សេមិទិកជាច្រើនពូជពង្ស ដែលអាស្រ័យនៅ ក្នុងភូមិភាគខាងកើតសំដៅដល់ពួកបាប៊ីឡូនៀនិយមគោរពបូជាថា បាល ជាអាទិទេព ដែលបណ្តាលឱ្យភោគផលនិងការសម្បូណ៌សប្បាយដល់ផែនដីរបស់ខ្លួនៗ ទេព

ជាម្ចាស់អង្គនេះ សម័យខ្លះជាភេទស្រី សម័យខ្លះជាភេទប្រុស មាននាមថា អ៊ិស្តារ៍ (Ishtar) តមកមាននាមថាអែស្តារ៉ែត (Astaroth) ឬ អែស្តាទេ (Astarte)។ ពួជអម្បូរសេមិទិត បុរាណធ្វើពលិកម្មដល់ទេព ឬទេពីអង្គនេះ មុនដំបូងត្រូវសាមព្រួសដោយការសម្តែងចេញនូវការដឹកនាំក្នុងផ្នែកកាមារម្មណ៍ មានក្រមុំព្រហ្មចារីយ៍ចេញមកជន្ទជន្ទេញម៉្ញកម្មក់ ដើម្បីតម្រូវតាមព្រះទ័យព្រះជាម្ចាស់។ កាលណាជនជាតិហេប្រ៊ូវផ្លាស់ប្តូរទីកន្លែងទៅទៀត បាននាំពិធីកម្មរបៀបនេះជាប់ទៅតាមពួក តាមក្រុមរបស់ខ្លួនមានជាច្រើនដែរ ហើយនិងនាំយកគតិរាប់អានអាទិទេព បាល ជាប់ទៅតាមក្រុមខ្លួនផង ទើបជាហេតុមួយដែលធ្វើឱ្យជនជាតិហេប្រ៊ូវក្នុងជំនាន់ក្រោយរាប់អានអាទិទេពបាល ត្រូវតស៊ូនឹងគតិការរាប់អានព្រះយ៉ះហូវ៉ា ដែលប្រកាសដោយសាស្តាព្យាករណ៍ឈ្មោះ អេលិចាហ៍ (Elijah) នាភ្នំកាមេល (Camel) ក្នុងក្រុង យេរូ សាលឹម រហូតដល់ទៅកាប់សម្លាប់គ្នាស្លាប់យ៉ាងច្រើន តែខាងផ្នែកព្រះយ៉ះហូវ៉ាមានជ័យជម្នះលើពួក អាទិទេពបាល ព្រះយ៉ះហូវ៉ា ទើបបានជាធំក្នុងចំណោមជនជាតិ ហេប្រ៊ូវតែមួយ ព្រះអង្គ តាំងពីពេលនោះមក។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២១)

## សាស្តាព្យាករណ៍

សាស្តាព្យាករណ៍ ភាសាបារាំងហៅថា ប្រូហែត (Prohet) សាសនាគ្រប់សាសនា មានការសម្ព័ន្ធនៅជាមួយនឹងពួកសាស្តាព្យាករណ៍មិនអាចបែកចេញពីគ្នាបានឡើយ ដោយហេតុថាពួកសាស្តាព្យាករណ៍មានបទបែបសំខាន់ណាស់ទទួលបន្តវេនក្នុងការផ្សាយសាសនា។ ដូច្នោះ ការបន្តនូវលទ្ធិគំនិតគិតឃើញខាងផ្លូវសាសនា បានសម្រេចគង់វង្សឬសាបសូន្យប្រការណានោះ ក៏មានចំណែកទាក់ទងនឹងសាស្តាព្យាករណ៍ គឺអ្នកបន្តវេនទាំងនេះដែរ។

នាទីសំខាន់របស់សាស្តាព្យាករណ៍ ដែលអាចឃើញច្បាស់ជាដំបូង គឺនាំពាក្យប្រៀនប្រដៅដែលខ្លួនបានទទួលមកផ្សព្វផ្សាយជាអ្នកកែទម្រង់ពាក្យប្រៀនប្រដៅក្នុងសាសនានោះឱ្យប្រព្រឹត្តទៅតាមកាលៈទេសៈ ប្រហាក់ប្រហែលនឹងអ្នកផ្លាស់ប្តូរគោលធម៌ខាងផ្លូវសាសនាពីមួយបែបទៅមួយបែបទៀត។ សាស្តាព្យាករណ៍ ជាអ្នកទទួលខុសត្រូវក្នុងរឿងទាំងអស់នេះ។

ការកើតមករបស់សាសនាជ្វីហ្វ ក៏មានឋានៈយ៉ាងនេះដែរ ក្នុងជំនាន់ក្រោយៗសាស្តាព្យាករណ៍ បាននាំរឿងនៃការរាប់អានសាសនាពីដើម ចូលមកផ្សំនឹងការរាប់អានទេពជាម្ចាស់អង្គដទៃរបស់មនុស្សផៅពង្សផ្សេងម្តងបន្តិចៗ ដោយប្រៀនប្រដៅឱ្យមនុស្សទាំងនោះ

មក រាប់អានព្រះអាទិទេពយៈហូវ៉ា តែមួយព្រះអង្គរបស់ខ្លួនទៅវិញនៅពេលក្រោយមក។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២២)

ក្នុងប្រទេសអេហ្ស៊ីបនិងប្រទេសឥណ្ឌា អ្នកព្រតជាពួកមានឥទ្ធិពលច្រើនបំផុត ក្នុងការស៊ើបសាសនា ប្រទេសក្រិក ពួកចិន្តាករ និងអ្នកទស្សនវិទូ ជាអ្នកធ្វើការប្រហែលគ្នានឹងសាស្ដាព្យាករណ៍របស់សាសនាជ្វីហ្វ ដូចគ្នាដែរ។

ក្នុងលទ្ធិជ្វីហ្វបុរាណ ពាក្យថា សាស្ដាព្យាករណ៍ ជាមនុស្សម្យ៉ាងម្នាក់នឹងពាក្យថា អ្នកព្រតឬអ្នកបួស សាស្ដាព្យាករណ៍មាននាទីផ្សព្វផ្សាយសាសនា ឯអ្នកបួសមាននាទីធ្វើកិច្ចពិធីសាសនា។ អ្នកបួសជ្វីហ្វកើតឡើង ដូចជាអ្នកបួសក្នុងសាសនាបុរាណទាំងឡាយគឺ មកអំពីហេតុដែលមនុស្សត្រូវការធ្វើពលីកម្មចំពោះព្រះជាម្ចាស់ កាលណាគ្មានអ្នកដទៃអាចធ្វើបានមនុស្សពួកនេះទើបសម្ដែងនូវសេចក្ដីឆ្លៀវឆ្លាតរបស់ខ្លួន ជាអ្នកទាក់ទងនឹងព្រះជាម្ចាស់ឱ្យដល់ប្រជាជន។ ក្នុងទីបំផុតក៏ក្លាយទៅជាអ្នកបួស គឺអ្នកដឹកនាំខាងផ្លូវសាសនា មាននាទីទទួលបម្រើប្រជាជន មើលថែទាំទីស្ថាននិងមាននាទីទទួលបម្រើព្រះជាម្ចាស់ (Levite) ប្រហែលគ្នានឹងអ្នកដែលជាឆ្មាំព្រះវិហារ ប៉ុន្តែសំខាន់នាទីរបស់សាស្ដាព្យាករណ៍នោះ ពុំមានរបៀបយ៉ាងនេះឡើយ។

សាស្ដាព្យាករណ៍ គឺជាមនុស្សសំខាន់ក្នុងសាសនាជ្វីហ្វបុរាណ បំណងប្រកាសលទ្ធិរាប់អានព្រះជាម្ចាស់តែមួយព្រះអង្គ ដែលពីដើមមានជាច្រើនអង្គលាយឡំគ្នា ដើម្បីសម្ដែងឱ្យឃើញប្រាកដដូចអាម៉ុស (Amos) មានឋានៈត្រឹមតែជាក្មេងចិញ្ចឹមសត្វម្នាក់។ ពេលជនជាតិអ៊ីស្រាអែលត្រូវឈ្នះពានវិហាររបស់ព្រះយៈហូវ៉ា ត្រូវបំផ្លាញយ៉ាងអយុត្តិធម៌ គេប្រកាសថា ព្រះជាម្ចាស់នឹងពិចារណាដាក់ទោសដល់ជនជាតិអ៊ីស្រាអែលគ្រប់គ្នា ដែលព្រមឱ្យព្រះជាម្ចាស់ត្រូវគេបំផ្លាញ។ អាម៉ុស ប្រកាសថា ព្រះជាម្ចាស់នេះជាព្រះនៃសេចក្ដីយុត្តិធម៌ ភារៈ នៃការចងភ្ជាប់របស់ព្រះជាម្ចាស់នៃសេចក្ដីយុត្តិធម៌ គឺជាព្រះជាម្ចាស់របស់ជនជាតិដទៃផងដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២៣)

ហូសៀរ៍ (Hosea) ជាសាស្ដាព្យាករណ៍ម្នាក់ទៀត ព្យាយាមផ្សាយឱ្យឃើញកំហុស និងបាបកម្មរបស់ជនជាតិជ្វីហ្វ ដែលប្រព្រឹត្តល្មើសទៅអាប់ឱនក្រាបសំពះបូជាទេវតាអង្គផ្សេងៗ បានសម្ដែងគួយ៉ាងនៃកំហុសឱ្យមនុស្សដទៃឃើញ ដោយការព្រមទទួលខុស យកខ្លួនឯងជាឧទាហរណ៍។

*ចេរេមិអាហ៍* (Jeremiah) *សាស្ដាព្យាករណ៍រូបនេះ បានសម្ដែងទោសយ៉ាងធ្ងន់ដល់ជនជាតិជ្វីហ្វថា ប្រសិនបើនៅចចេសទៅរាប់អានព្រះជាម្ចាស់អង្គដទៃនោះ ក្នុងទីបំផុតជនជាតិជ្វីហ្វ ក៏នឹងត្រូវពួកបច្ចាមិត្តទាញ ក្បាលចាប់ខ្លួនទៅជាឈ្លើយមិនខាន។*

*អៃសាហ៍* (Isaiah) *លោករូបនេះ រហូតដល់ដើរអាក្រាតកាយចូលទៅក្នុងយេរូសាលឹម ប្រកាសដល់មនុស្សទាំងឡាយថា បើចចេសទៅរាប់អានក្រាបសំពះព្រះជាម្ចាស់ក្នុងសាសនាដទៃ ក្រុងយេរូសាលឹមសត្រូវនឹងដុតបំផ្លាញឱ្យវិនាស ពុំមានអ្វីសេសសល់ដូចជារាងកាយរបស់ខ្លួនដូច្នោះដែរ។*

*អេសេគិល* (Ezekiel) *លោករូបនេះកាត់ពុកមាត់របស់ខ្លួនទៅដុតភ្លើង រួចបោះឱ្យរសាត់ទៅតាមខ្យល់បក់សម្ដែងឱ្យជនជាតិជ្វីហ្វឃើញន័យថា ប្រសិនបើចចេសទៅរាប់អានក្រាបសំពះសាស្ដាដទៃ និងព្រះជាម្ចាស់ដទៃ។ សង្គមរបស់ជនជាតិជ្វីហ្វ ត្រូវព្រាត់ប្រាស់បែកខ្ញែកដូចសក់និងពុកមាត់របស់ខ្លួនយ៉ាងនោះដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ទំព័រ២៤)*

*សាស្ដាព្យាករណ៍ទាំងនេះ ជាអ្នករឹងត្អឹងនៅក្នុងលទ្ធិ រាប់អានព្រះជាម្ចាស់តែមួយព្រះអង្គ ដើម្បីសេចក្ដីសាមគ្គីចងបាច់គ្នានៃសង្គមរបស់ជនជាតិជ្វីហ្វទាំងអស់ ដោយសេចក្ដីព្យាយាមរបស់សាស្ដាព្យាករណ៍ទាំងអស់នេះហើយ បានជួយធ្វើឱ្យលទ្ធិរាប់អានព្រះជាម្ចាស់មួយអង្គ មានសភាពជាប់លាប់ច្រើនឡើង។ អ្នកប្រាជ្ញឈ្មោះ មួរ៍* (Moore) *និយាយថា លទ្ធិរាប់អានព្រះជាម្ចាស់មួយអង្គរបស់ជនជាតិជ្វីហ្វនោះ មិនមែនកើតអំពីផលនៃសេចក្ដីព្យាយាមដែលនឹងស្រាវជ្រាវគោលធម៌ ឬអំណាចដ៏ខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់ តែយ៉ាងណានោះ ប្រហែលជាកើតអំពីសេចក្ដីត្រូវការផលខាងផ្លូវប្រវត្តិសាស្ត្ររបស់ជាតិ ត្រូវការខាងសីលធម៌ និងសេចក្ដីសាមគ្គី ក្នុងសង្គមជាតិប៉ុណ្ណោះ។*

### *សេចក្ដីសង្ឃឹមថានឹងមានអ្នកមកប្រោស*

*តាំងពីអាណាចក្រទាំងផ្នែកខាងជើងនិងខាងត្បូងត្រូវបែកចេញពីគ្នា ជតាកម្មរបស់ជនជាតិជ្វីហ្វ ដូចជា របស់មួយត្រូវខណ្ឌទុកថា តើត្រូវដើរទៅតាមផ្លូវបាបកម្មដែលជនជាតិជ្វីហ្វទទួលរងទុក្ខវេទនា គ្មានទីអាស្រ័យ គ្មានកន្លែងបរិភោគ និងចិត្តគំនិតទ្រុឌទ្រោមរកកំណត់មិនបាននោះឬ?*

*ទោះបីយ៉ាងនេះក្ដីជនជាតិជ្វីហ្វទាំងឡាយ ក៏នៅមានជីវិតដោយសេចក្ដីសង្ឃឹម គ្រប់ៗគ្នាហើយមានសេចក្ដីសង្ឃឹមជានិច្ចថា ខ្លួននឹងបានទទួលសុខសន្តិភាព សេចក្ដីពេញចិត្ត រស់*

នៅមូលត្រកូលគ្នាមាំទាំ សម្បូរសប្បាយ ដូចជាធ្លាប់បានទទួលកាលសម័យក្សត្រិយ៍ ដេវិត ឡើង វិញ ព្រះជាម្ចាស់ទ្រង់មេត្តាករុណាគង់នឹងបញ្ជូនមនុស្សល្អមានសមត្ថភាពមក ប្រោស ប្រទានក្នុងថ្ងៃណាមួយមិនខាន។ អ្នកដែលនឹងមកប្រោសជ្វីហ្វ ហៅថា មេស្សិអាហ៍ (Messiah) លោករូបនេះជាអ្នកបើកជតាកម្ម ដែលសាបសូន្យទៅវិញឱ្យត្រឡប់រស់ដូចដើមឡើងវិញ។ សេចក្ដីសង្ឃឹមងងឹតងងុលអន្ធការទាំងនេះ សូម្បីមិនឃើញមានផ្លូវដ៏ភ្លឺស្វាង (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២៥) ប៉ុន្តែជនជាតិជ្វីហ្វទាំងឡាយ នៅមានជំនឿថា បុព្វបុរសមាន សមត្ថភាពរបស់ខ្លួនដែលបានរលត់សូន្យសុងទៅហើយនោះ ទោះបីជាយ៉ាងណាក្ដី ត្រូវតែ ត្រឡប់រស់ឡើងវិញ មានជីវិតឲ្យតមកជាថ្មីទៀត ដូចជា អាណាចក្រដ៏រុងរឿង សូម្បីទ្រុឌ ទ្រោមទៅហើយ នឹងត្រឡប់រុងរឿងបានជាថ្មីឡើងវិញ។

សម័យដែលជនជាតិជ្វីហ្វនៅមានសេចក្ដីសង្ឃឹមនេះ ជាចៃដន្យជនជាតិជ្វីហ្វ បាន ទទួលដំណឹងពីការបដិសន្ធិឡើងរបស់បុព្វបុរសសំខាន់ម្នាក់គឺ សូរ៉ូអស្ទ្រើរ៍ នៃប្រទេស ប៉ែក្ស។ ពាក្យប្រៀនប្រដៅរបស់សូរ៉ូអស្ទ្រើរ៍ បានផ្សព្វផ្សាយចូលមកក្នុងជនជាតិជ្វីហ្វ បង្រៀនឱ្យជនជាតិជ្វីហ្វជឿក្នុងគោលធម៌មួយថា កម្មដែលមនុស្សទទួលក្នុងបច្ចុប្បន្ន ជាផល កម្មពីក្នុងអតីត ហើយនឹងបញ្ជូនផលឱ្យប្រត្យក្សក្នុងកាលអនាគត ព្រោះហេតុនៃកម្មក្នុង បច្ចុប្បន្ន។ ជនជាតិជ្វីហ្វជឿក្នុងចិត្តថា សូរ៉ូអស្ទ្រើរ៍ ជាអមតៈបុគ្គលដែលព្រះជាម្ចាស់ ទ្រង់ បញ្ជូនឱ្យមកកើត ដើម្បីប្រោសជនជាតិប៉ែក្ស (អ៊ីរ៉ង់) ជនជាតិជ្វីហ្វចាប់ផ្ដើមជឿជាក់ថា ទោះ បីយ៉ាងណាក្ដី សេចក្ដីសង្ឃឹមចំពោះអ្នកមកប្រោសរបស់ខ្លួននោះ គង់នឹងសម្រេចបាន ដូច ជាជនជាតិប៉ែក្សបានទទួលដូច្នោះដែរ។

ក្រៅអំពីនេះទៀត ក្នុងរយៈពេលដែលពាក្យប្រៀនប្រដៅរបស់សូរ៉ូអស្ទ្រើរ៍ ផ្សព្វ ផ្សាយចូលមកក្នុងពពួកជនជាតិជ្វីហ្វនោះ ធ្វើឱ្យជនជាតិជ្វីហ្វចាប់ផ្ដើមមានគំនិតទោរទន់ទៅ លើជំនឿរឿងទាក់ទងទៅនឹងបរលោក ទាក់ទងនឹងដួងវិញ្ញាណ ជាប់ជំពាក់ជាមួយរឿងរបស់ មនុស្សនិងរឿងរបស់ជីវិតដែលរលត់សូន្យទៅហើយ ត្រូវត្រឡប់រត់មកកើតឡើងវិញក្នុងភព ថ្មីទៀត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២៦)

គតិខាងផ្លូវសាសនារបស់ជនជាតិជ្វីហ្វ ដែលឆ្លងមកដល់ដំណាក់កាលនេះ សម្ដែងឱ្យ ឃើញពីចរិយាធម៌ ផ្លូវចិត្ត កើតឡើងជាថ្មីថែមមួយថ្នាក់ទៀតគឺ ជនជាតិជ្វីហ្វមានគតិធម៌ ទាក់ទងនឹងសង្គមដ៏ជ្រាលជ្រៅរហូតដល់ថ្នាក់ថា ប្រសិនបើបុគ្គលណាមួយធ្វើបាប ក៏អាចធ្វើ

ឱ្យមនុស្សទាំងក្រុមទទួលបាបជាមួយផងដែរ ប្រសិនបើសង្គមបានរួមគ្នាធ្វើអំពើបាប សង្គមនោះនិងត្រូវរួមគ្នាសងបំណុលផលនៃការធ្វើបាបជាមួយគ្នា ទើបមានពាក្យពោលថា "កាលណាបិតាបរិភោគទំពាំងបាយជូរជូ ក៏នឹងនាំឱ្យកូនសង្កៀរធ្មេញជាមួយផងដែរ"។

គតិខាងផ្លូវសាសនា ដែលផ្សាយទូលំទូលាយជាចរិយាធម៌ដូច្នេះ អាស្រ័យការប្រកាសរបស់សាស្ដាព្យាករណ៍នីមួយៗមកដល់សម័យ ចេរេមិអាហ៍ និងអេសេគិល សាស្ដាព្យាករណ៍ដែលបាននិយាយឈ្មោះមកពីខាងដើម ប្រកាសនូវយោបល់របស់ខ្លួនដ៏ជ្រាលជ្រៅរហូតដល់ថា វិញ្ញាណដែលមានបាប ត្រូវដល់នូវសេចក្ដីវិនាស តាមធម្មតាបុគ្គលនិងជាតិដែលសាបសូន្យទៅហើយ ត្រូវត្រឡប់មកកើតថ្មីឡើងវិញ (ដើម្បីសាសនា) បើមិនដូច្នោះទេ តើសាសនានឹងគង់វង្សនៅដូចម្ដេចបាន។

សាស្ដាព្យាករណ៍ក្នុងសម័យដំបូងៗ មានគំនិតគិតឃើញថា សេចក្ដីទុក្ខលំបាករបស់ជនជាតិជ្វីហ្វនោះ ជាផលមកអំពីបាបកម្មរបស់មនុស្សជំនាន់មុនជាអ្នកបង្កបង្កើតឡើង មនុស្សជំនាន់ក្រោយទើបត្រូវទទួលទោស នៃការបំពារបំពានបទបញ្ញត្តិជំនួស (Origin of Sin) តែមានសាស្ដាព្យាករណ៍ម្នាក់គឺឌិវទេរ៉ូ អែសាយ៉ា (Deutero Isaiah) ត្រឡប់ជាប្រកាសគតិខាងផ្លូវសាសនាខនេះថា ការដែលពោលថាមនុស្សជៀសវាងសេចក្ដីទុក្ខលំបាក មិនផុតនោះជាការពិត តែមិនមែនជាការចាំបាច់របស់មនុស្ស ដែលនឹងត្រូវទទួលទុក្ខលំបាកជំនួសគ្នាឡើយ។ ការដែល "កូនអ៊ីស្រាអែល" ទាំងឡាយជួបប្រទះនឹងសេចក្ដីទុក្ខវេទនា មិនមែនកើតមកពីកំហុសរបស់ "កូនអ៊ីស្រាអែល" នោះទេ ប្រសិនបើបាបដែលបានទទួលស្មើគ្នានឹងការលោះលាងបាបជំនួស ទើបក្លាយជាអ្នករងទុក្ខវេទនារបស់ព្រះយេះហូវ៉ា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ២៧)

ព្រោះហេតុនៃការប្រកាសគតិសាសនា ដែលភាគខ្លះជាចរិយាធម៌ និងភាគខ្លះប្រព្រឹត្តទៅត្រឹមតែ សេចក្ដីសង្ឃឹមទាក់ទងនឹងអ្នកមកប្រោស ដើម្បីលោះលាងបាបនោះមានន័យផ្សេងៗ ដូចបានពោលមកហើយ ទើបជាហេតុឱ្យគតិខាងផ្លូវសាសនារបស់ជនជាតិជ្វីហ្វ ខុសប្លែកខ្វែកផ្សេងៗពីគ្នា។ ជនជាតិជ្វីហ្វទាំងឡាយមានការរើបម្រះតស៊ូជាញឹកញយ ដោយមួយពួកជាពួករាប់អានហេតុផលតាមភាពនៃការពិត ឯមួយពួកទៀត ជាពួករាប់អានលទ្ធិពិធីកម្មមានសេចក្ដីសង្ឃឹមថា នឹងមានអ្នកដែលវិសេសកើតមកលោះលាបាប។ មនុស្សទាំងពីរពួកមានគតិទាស់ទែងខ្វែងគំនិតគ្នារហូតមក ទាល់តែក្នុងទីបំផុត ផលនៃទំនាស់ដ៏ខ្លាំងក្លានេះ ជាប់

ក្នុងប្រវត្តិសាស្ត្ររបស់ជនជាតិជ្វីហ្វម្តងទៀត ផលនោះគឺព្រះយេស៊ូ បានទទួលរងនូវគ្រោះកម្ម ត្រូវគ្គាងដោយឈើឆ្កាង ព្រោះសេចក្តីមិនពេញចិត្តរបស់ជនជាតិជ្វីហ្វមួយផ្នែក ដែលនឹងសម្តែងតទៅពេលខាងមុខ។

**គម្ពីរក្នុងសាសនា**

សេចក្តីទុក្ខលំបាកវេទនានឹងកើតមានឡើងដោយស្ថានការណ៍បែបណា មើលទៅហាក់ដូចជាឃើញថា សេចក្តីទុក្ខលំបាកវេទនានោះ ជាកម្លាំងគាបសង្កត់ឱ្យជនជាតិជ្វីហ្វ មានមានះអត់ធន់ប្រណាំងប្រជែងក្នុងការតស៊ូនឹងធម្មជាតិដើម្បីផ្គត់ផ្គង់ខ្លួនឯង តស៊ូជាមួយមនុស្ស ដើម្បីទ្រទ្រង់ជាតិកាន់តែខ្លាំងឡើង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័២៨) ជនជាតិជ្វីហ្វជាអ្នកឈ្លាសវៃមានប្រាជ្ញាគួរឱ្យអស្ចារ្យ ជ្វីហ្វបានរួបរួមអ្នកមានបញ្ញា និងអ្នករឹងមាំក្នុងគំនិតនៃសាសនាទៅតាមកម្លាំងដែលអាចធ្វើបាន ចាត់ចែងដាក់របៀបរបបដែលទាក់ទងនឹងគតិផ្លូវសាសនារបស់ខ្លួន ខនេះហើយជាបុព្វហេតុឱ្យមានការរួបរួម ពាក្យប្រៀនប្រដៅគតិផ្លូវសាសនា និងឱវាទរបស់សាស្តាព្យាករណ៍ផ្សេងៗ ចារឹកទុកជាគម្ពីរ។

ការរួបរួមគម្ពីររបស់ជនជាតិជ្វីហ្វ ប្រហែលចាប់តាំងពីគ្រិស្តសតវត្សទី៩ ជាដំបូង និងមានការរួបរួមឡើងទៀតជារយៈៗ ដរាបដល់គ្រប់ទៅជារឿងសំខាន់ក្នុងប្រវត្តិសាស្ត្រ ក្លាយជាអក្សរសាស្ត្ររបស់ជាតិ។ អ្នកប្រាជ្ញក្នុងជំនាន់ក្រោយបានបំបែកចេញជា ២ភាគ ភាគខាងដើមហៅគម្ពីរចាស់ (Old Testament) គូនឹងគម្ពីរថ្មី (New Testament) ដែលជាភាគ ចាប់ផ្តើមពីជីវិតរបស់ព្រះយេស៊ូ រួមហៅថា ព្រះគម្ពីរបៃប៊ីល (Holy Bible) ឬ (ប៊ីប្លិ)។

គម្ពីរចាស់ ជាពាក្យចារឹកប្រវត្តិសាស្ត្រនៃការសាងលោក តាមគតិនិយមរបស់ជនជាតិជ្វីហ្វបុរាណ ដែលរាប់អានអំណាចព្រះយេះហូវ៉ា ថាជាអ្នកសាងប្រកបដោយបទបញ្ញត្តិការបែកខ្ញាត់ខ្ញាយនៃជាតិ ពាក្យប្រៀនប្រដៅរបស់សាស្តាព្យាករណ៍និងផ្សេងៗ រហូតមកដល់សម័យព្រះយេស៊ូ មួយភាគទៀតជាគម្ពីរថ្មី ជាភាគចាប់ផ្តើមនៃសាសនាគ្រិស្ត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័២៧៩)

គម្ពីរចាស់ ចារឹកជាភាសាជ្វីហ្វ ឬហេប្រ៊ូវបុរាណ តមកប្រែជាភាសាក្រិក ឡាតាំង និងភាសាអង់គ្លេស។ គម្ពីរចាស់មាន ៣៩ជំពូក ឬ៣៩គម្ពីរ បែងចែកជាភាគឬពួកធំៗ មាន៣ ពួក គឺ៖

១-តូរ៉ាហ៍ (Torah) ឬច្បាប់បញ្ញត្តិ (Law) បានដល់សៀវភៅ ៥ក្បាល។ ដើមដំបូងរបស់គម្ពីរចាស់គឺ Genesis, Exodus, Leviticus, Numbers និង Deuteronomy (ទាំង៥នេះហៅថា Pentateuch គឺគម្ពីរ ៥ក្បាលរបស់មោសេស) ចាប់ផ្ដើមពីការសាងលោក។ល។ ភាគច្រើនជារឿងរបស់មោសេស អ្នកប្រកាសបញ្ញត្តិ១០ប្រការ តមកជាបទបញ្ញត្តិដែលមោសេសបានកត់ត្រាទុក ដើម្បីប្រតិបត្តិចំពោះព្រះអាទិទេពដ៏ធំគឺ ព្រះយៈហូវ៉ា ខ្លះហៅថាបញ្ញត្តិរបស់មោសេស (Mosaic Law) គម្ពីរជំពូកនេះ ជាបញ្ញត្តិសំខាន់ដល់ជីវិតរបស់ជនជាតិជ្វីហ្វច្រើនជាទីបំផុត។

២-ប្រូហ្វេត (Prophet) រួបរួមរឿងទាក់ទងនឹងការប្រព្រឹត្តទៅរបស់សាស្ដាព្យាករណ៍ ពាក្យប្រៀនប្រដៅរបស់សាស្ដាព្យាករណ៍នោះៗ ភាគខ្លះជាប្រវត្តិសាស្ត្រដោយចំពោះគឺ ប្រវត្តិសាស្ត្រសម័យដែលជនជាតិ ហេប្រ៊ូវចូលទៅកាន់ដែនដីគានាអាន់ រហូតទៅដល់សម័យ ធ្លាក់ជាទាសៈរបស់ជាតិដទៃ ក្នុងគម្ពីរនេះប្រកបដោយសៀវភៅ ៣ក្បាល ឈ្មោះ Joshua Isaish និង Jeremiah ។

៣-វ៉ៃតិងស៍ (Writings) ពួកនេះប្រកបដោយសៀវភៅ២ក្បាល គឺ Psalms និង Proverbs ជារឿងបកិណ្ណក ទាក់ទងនឹងប្រវត្តិសាស្ត្រ ពាក្យកាព្យ ភាសិត ទស្សនវិទូ និងបទសូត្រ រួមជាមហាកាព្យដ៏ធំ ដែលហៅថា Song of Solomon ដែលមានការសម្ដែងពីទស្សនវិទូនៃជីវិត សេចក្ដីស្រឡាញ់និងការប្រព្រឹត្តទៅរបស់គេទ ក្រៅអំពីនោះមានសេចក្ដីសម្ដែងពីមាគ៌ាដែលនឹងប្រតិបត្តិឱ្យផុតអំពីទុក្ខលំបាក។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣០)

មានសេចក្ដីប្រកប សម្ដែងពីការប្រព្រឹត្តទៅរបស់គម្ពីរទាំងនេះថា ព្រោះហេតុតែជនជាតិជ្វីហ្វត្រូវកម្លាំងនយោបាយនិងសាសនារបស់ពូជពង្សផ្សេងចូលមកគ្របដណ្ដប់ជនជាតិជ្វីហ្វបានតស៊ូ ដើម្បីរក្សាការគង់វង្សនៃសាសនារបស់ខ្លួន។ កាលបើរបស់ណា គតិណា ត្រូវផ្សេផ្សំលាយឡំរហូតដល់គតិនោះត្រូវសាបសូន្យទៅ ក៏ព្យាយាមតស៊ូអំពាវនាវឱ្យត្រឡប់មកវិញ។ ការគាបសង្កត់ដែលបានទទួលនេះហើយ ជាផលឱ្យជនជាតិជ្វីហ្វ តាំងចិត្តព្យាយាមរួបរួមគោលធម៌ជាចរិតប្រពៃណីរបស់មនុស្សពីបុរាណ ដើម្បីសម្ដែងថា ជ្វីហ្វមានសម្បត្តិរបស់ខ្លួនដោយខ្លួនឯង ហើយកែខៃបន្ថែមរឿងរ៉ាវដែលបានរួបរួមនោះ ធ្វើជាបទអធិប្បាយទុកសាងជាតម្រាតាមបែបច្បាប់នៃគម្ពីរ ទើបមានគម្ពីរមួយក្បាលទៀតហៅថាទ័ល្មុត (Talmud)។

ទ័ល្មុត ជាពាក្យខុសឃ្លាតពីភាសាហេប្រ៊ូវបុរាណថា ឡោមេត (Lomed) មានន័យសេចក្ដីថា "សិក្សា" កំណត់ថាជាពាក្យអធិប្បាយ ឬអត្ថកថារួមបញ្ចូលពីគម្ពីរចាស់ ជ្វីហ្វប្រកាន់ថាទ័ល្មុត ជាអក្សរសាស្ត្រដ៏សំខាន់មួយរបស់ខ្លួន។

រឿងក្នុងគម្ពីរទ័ល្មុត មាន២វគ្គ វគ្គដំបូងហៅថា មិជនាហ៍ (Mishnah) ជារឿងទាក់ទងនឹងច្បាប់ស្រុកទេស ច្បាប់មត៌ក ច្បាប់អាពាហ៍ពិពាហ៍ សេចក្ដីសម្ព័ន្ធក្នុងសង្គម ច្បាប់ទាក់ទងក្បេត្រកម្មបែបនៃពិធីកម្មនិង ច្បាប់គ្រួសារដែលជនជាតិជ្វីហ្វបច្ចុប្បន្ន កាន់ទុកជាគោលប្រតិបត្តិនិងជាកស្តុតាងនៃការពិចារណាក្ដីរបស់អ្នកពិភាក្សាជ្វីហ្វក្នុងបច្ចុប្បន្ន មួយវគ្គទៀតហៅថា ហេម៉ារ៉ា (Gemara)។

ហេម៉ារ៉ា ជាភាសាអារ៉ាមិក (Aramaic) មានន័យសេចក្ដីថា "បទរៀន" ជាតម្រាច្បាប់មួយទៀតដូចគ្នា តែជាពាក្យអធិប្បាយនៃផ្នែកដែលហៅថា មិសនាហ៍ ប្រើជាតម្រារៀនច្បាប់របស់និស្សិតក្នុងបច្ចុប្បន្ន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៣១)

គម្ពីរទ័ល្មុត និងអត្ថកថាទាំងពីរ ជាផលឱ្យជនជាតិជ្វីហ្វមានស្ថាប័នសាសនាឡើងបានយ៉ាងមាំទាំ រោង សូត្រធម៌ មជ្ឈមណ្ឌលនៃការប្រតិបត្តិសាសនកិច្ចនិងសាលាយុត្តិធម៌ រហូតទៅដល់របៀបបែបផែនក្នុងគ្រួសារ និងក្នុងក្រុមព្រះព្រត អ្នកប្រតិបត្តិកិច្ចជំនួសព្រះជាម្ចាស់ ជារបៀបបែបបទនៅក្នុងបច្ចុប្បន្ន ដែលជាសាក្សីសម្ដែងថា ជនជាតិជ្វីហ្វបានកសាងរបស់សាបសូន្យទៅហើយ ព្រោះការគាបសង្កត់របស់ជនជាតិដទៃ និងសាសនាដទៃឱ្យត្រឡប់មកតាំងមាំឡើងវិញគួររំភើបចិត្ត។

**និកាយនិងការបដិរូប**

តាំងពីអស់ព្រះយេស៊ូសាសនាគ្រិស្តបានរីកផ្សាយចេញទៅក្នុងផែនដី ដែលសាសនាជ្វីហ្វផ្សព្វផ្សាយធ្វើ ឱ្យមូលដ្ឋានដើមរបស់សាសនាជ្វីហ្វផ្លាស់ប្ដូរជាច្រើន។ គតិផ្លូវសាសនាបានប្រែរូបភាពជាច្រើនយ៉ាង ច្រើនយុគ ការផ្លាស់ប្ដូរទាំងអស់នេះ ធ្វើឱ្យកើតជានិកាយផ្សេងៗ បែកចេញពីការរាប់អានជំនាន់មុនសាសនាជ្វីហ្វ និកាយ ខ្លះផ្លាស់ប្ដូរទៅស្ទើរតែមើលមិនឃើញរូបភាពក៏មាន តែជនជាតិជ្វីហ្វជាអ្នកស្រឡាញ់នូវចរិតប្រពៃណីតឹងតែងចំពោះព្រះជាម្ចាស់តែមួយរបស់ខ្លួន អាចមានសមត្ថភាពរក្សាគតិផ្លូវសាសនាពីដើមទុកបានជាបែប ជាច្បាប់ បើមិនឃើញក្នុងទីដទៃទេយ៉ាងហោចណាស់ក៏អាចឃើញបានក្នុង "ផែនដីនៃសញ្ញា" គឺប្រទេសអ៊ីស្រាអែល។

លុះវេលាកន្លងមក គតិផ្លូវសាសនារបស់ជ្វីហ្វ បែងចែកអ្នកកាប់អានទៅជា ៣ ពួកគឺ ៖

១-ហ្វារីស៊ី (Pharisee) ជាពួកមានជំនឿខ្ជាប់ក្នុងលទ្ធិនិងចារីកចាស់ទុំតាមបុរាណប្រពៃណី ដែលបានប្រកាន់យកយ៉ាងតឹងរឹង ជឿការមិនស្លាប់ ការត្រឡប់មកកើត ការស្ថិតនៅរបស់ដួងវិញ្ញាណ និងទេពបរិវារ និកាយនេះអាងថា ចរិតនិងពាក្យប្រៀនប្រដៅ ប្រតិបត្តិតាមគ្នាតៗមក មានសារសំខាន់ជាងរឿងដែលចារឹកទុកក្នុងគម្ពីរ។

២-សាឌូគូស (Sadducsu) ជាពួកដែលបែកសាខាចេញទៅ គតិសាសនារបស់ពួកនិកាយនេះ ហៅថា សាសនាជ្វីហ្វបដិរូប ពួកគេលះបង់ចោលការប្រតិបត្តិនិងពិធីកម្មបុរាណផ្លាស់ប្តូរឱ្យសមតាមយុគសម័យ ព្រមទទួលការគួរមិនគួររបស់សង្គម ព្រមទទួលយកថ្ងៃសប៉ាតោ គឺថ្ងៃសៅរ៍ មកជាថ្ងៃអាទិត្យ គឺថ្ងៃឈប់កិច្ចការ សាកល ដោយវិធីប្រតិបត្តិស្ទើរតែគ្មានការបែកផ្សេងគ្នាណាមួយអំពីគតិក្នុងគ្រិស្តសាសនា តែកាន់ខ្ជាប់នៅក្នុងបញ្ញត្តិ១០ប្រការរបស់មោសេស និងជឿថា មោសេសជាអ្នកទទួលបញ្ញត្តិនោះមកអំពីព្រះជាម្ចាស់។ បដិសេធរឿងណាៗ ដែលពុំមានលាយលក្ខណ៍អក្សរ បដិសេធពួកហ្វារិស៊ីទៅពីក្នុងខ្លួន មិនព្រមស្រាវស្រទេញជាមួយរឿងការនៅគង់វង្សរបស់ដួងវិញ្ញាណ និងរឿងទេពជាម្ចាស់ដទៃទៀត ក្រៅអំពីព្រះយេហូវ៉ាមួយព្រះអង្គ ប៉ុណ្ណោះ។

៣-អេស្សេនេស (Essenes) និកាយនេះប្រព្រឹត្តព្រហ្មចារ្យយ៉ាងតឹងរឹង មិនព្រមរៀ បការ ប្រព្រឹត្តខ្លួននៅឯកឯង ចូលចិត្តសេចក្តីស្ងប់ ជឿក្នុងទេពបរិវារ មិននិយមធ្វើពលិកម្ម មិននិយមរោងសូត្រធម៌ ដែលចម្លែកណាស់នោះគឺ ត្រឡប់ជានិយមបូជាពន្លឺ ដូចជាប្រទីបនិងបូជាដួងព្រះអាទិត្យផងដែរ (ជ្វីហ្វធ្លាប់ទទួលយកលទ្ធិបូជាភ្លើងរបស់សូរ៉ូអស្សទើរ៍ មកកាប់អានជាមួយ សូមមើលពីខាងដើម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣៣)

## គោលការណ៍បង្រៀន

គោលការណ៍បង្រៀនរបស់សាសនាជ្វីហ្វ សរុបសេចក្តីមកដូច្នេះ

### រឿងសាងលោក

គតិបាននិយាយថា លោកនេះកាលដើមឡើយមានតែភាពងងឹតសូន្យសុង។ ព្រះជាម្ចាស់ទ្រង់ជាអ្នកសាងរបស់សព្វសារពើនិងសព្វសត្វក្នុងលោក គឺថ្ងៃដំបូងទ្រង់បានសាងពន្លឺដើម្បីបំផ្លាញភាពងងឹតមួយផ្នែក ឯផ្នែកភ្លឺឱ្យហៅថា ថ្ងៃ ផ្នែកងងឹតឱ្យហៅថា យប់។ ថ្ងៃទីពីរទ្រង់សាងផ្ទៃមេឃ អាកាស (សួគ៌) ថ្ងៃទីបីទ្រង់សាងផែនដី និងកោគផលគ្រប់បែបលើផែនដី

ថ្ងៃទីបួន ទ្រង់សាងព្រះអាទិត្យប្រចាំពេលថ្ងៃ ដួងតារា (ព្រះចន្ទ) ប្រចាំពេលយប់ ថ្ងៃទីប្រាំ ទ្រង់សាងសព្វសត្វគ្រប់បែប ថ្ងៃទីប្រាំមួយ ទ្រង់សាងមនុស្សឱ្យជាម្ចាស់របស់ភោគផលនិង សត្វទាំងនោះ លើកលែងតែថ្ងៃទីប្រាំពីរ ទ្រង់មិនសាងអ្វីទាំងអស់ ឱ្យកាន់ថាថ្ងៃសប៉ាតោ (Sab-bath Day-Holy Day) គឺថ្ងៃសៅរ៍ មនុស្សឈប់ធ្វើការងារ ដូចជាព្រះជាម្ចាស់ ទ្រង់ឈប់សាងដែរ (គម្ពីរយេនិ ស៊ិស ជំពូកដំបូងរបស់គម្ពីរចាស់)។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ២ ទំព័៣៤)

ការសាងមនុស្ស មានន័យថាទ្រង់សាងពីដី ទ្រង់ផ្លុំខ្យល់ចូលតាមច្រមុះឱ្យដកដង្ហើមបាន មនុស្សនោះជាប្រុស មានឈ្មោះថាអាដាម កាលបើមានមនុស្សប្រុសតែម្នាក់ទ្រង់ក៏អាណិត ទើបទ្រង់សាងមនុស្សស្រីទុកនៅជាមួយ ដោយទ្រង់កាច់យកឆ្អឹងជំនីរបស់អាដាមមកមួយបន្ទះ សាងទៅជាមនុស្សស្រី ប្រទាននាមថា អេវ៉ាឬ អ៊ីវ៉ា (ជីវ៉ា) ប្រគល់ឱ្យជាសម្បត្តិរបស់អាដាម ស្រេចហើយទ្រង់សាងឧទ្យានឱ្យមួយកន្លែងហៅថា (Garden of Eden) ឱ្យប្រុសស្រីមួយគូនេះនៅអាស្រ័យ រហូតកើតមានកូនចៅផៅសន្តានពាសពេញ ពិភពលោក។ លុះកន្លងមកប្រហែលជា៣២ តំណមនុស្សទ្រង់ឃើញថា មនុស្សទាំងឡាយមិនស្តាប់បញ្ញត្តិ ធ្វើបាប ឋោកទាបអាក្រក់ ទើបទ្រង់បណ្តាលឱ្យភ្លៀងធ្លាក់ ៤០ថ្ងៃ មានខ្យល់ព្យុះបក់បោកផ្សំគ្នាផង លាងមនុស្ស នឹងលាងលោកនេះចេញម្តង។ ក្នុងគ្រានោះឱ្យនៅសល់តែមនុស្សម្នាក់ ជាអ្នកមានធម៌ឈ្មោះ ណូហានិងគ្រួសាររបស់គាត់ ហើយនឹងសត្វញីឈ្មោល ដែលទ្រង់ឃើញថាមិនមានបាប មួយគូៗ មួយពួកៗ។ លុះកាលណាទឹកលិចលោកស្រកចេញអស់ហើយ ព្រះជាម្ចាស់ទ្រង់សាងលោកតទៅសាជាថ្មីម្តងទៀត ណូហា រូបនេះគឺ បឋម បុព្វបុរសរបស់ពូជពង្សសេមិទិគ ជាបុព្វបុរសរបស់ជនជាតិជ្វីហ្វទូទាំងពិភពលោក។

## រឿងដួងវិញ្ញាណ

ជនជាតិជ្វីហ្វ មានជំនឿក្នុងគតិការរស់ឡើងវិញជាថ្មីនៃដួងវិញ្ញាណ ជឿថាព្រះជាម្ចាស់ទ្រង់ប្រទានសេចក្តីសុខនិងទុក្ខដោយព្រះមហាករុណា។

មានការជឿថា អំពើរបស់បុគ្គលដែលបានធ្វើនឹងបានទទួលពាក្យពិភាក្សាក្នុងថ្ងៃចុងក្រោយនៃការ រលាយសាបសូន្យទៅនៃលោក (Day of Judgment) អ្នកធ្វើអំពើល្អនឹងមានអ្នកនាំទៅកាន់ឋានសួគ៌ (នៅជាមួយព្រះជាម្ចាស់) អ្នកធ្វើអំពើអាក្រក់ ធ្លាក់ស្ថានចុះនរក។ កាលណាចិត្តរលត់ ដួងវិញ្ញាណនឹងវិលវល់នៅជិតរាងកាយ៣ថ្ងៃ ហើយទទួលពាក្យពិភាក្សាថា

ត្រូវទៅតាមផ្លូវណា សួគ៌ាដែលនឹងទៅមាន៧ជាន់ហៅថា ឋានសួគ៌នៃឧទ្យាន អេដេន (Heaven Eden) តាក់តែងដោយកែវមណី មានតម្លៃសោភាបំផុត នរកមាន៧ជាន់ដូចគ្នាដែរ។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣៥)

ព្រះជាម្ចាស់ទ្រង់សាងលោក ទ្រង់ជាឯកអគ្គប្រាសចាករូប មានតែព្រះនាម ទ្រង់មានសេចក្ដីបរិសុទ្ធ ជាព្រះបិតាទ្រទ្រង់សេចក្ដីយុត្តិធម៌ និងទ្រង់មេត្តាករុណា។

ជ្វីហ្វជឿថា ការធ្វើបាបអាចជម្រះលាងចេញបាន ដោយអាស្រ័យការបញ្ចេញព្រះនាមព្រះជាម្ចាស់ ដោយវិធីអធិ្វរកសូមឱ្យទ្រង់ជួយ ពេលអធិ្វរក បើមានទឹកភ្នែកស្រក់ចេញរឹងរឹតតែល្អ ដោយអធិប្បាយថា កែវភ្នែកគឺជាទ្វារនៃចិត្ត របស់ណាដែលចេញមកពីភ្នែករបស់នោះ គឺសញ្ញានៃសេចក្ដីពិតក្នុងចិត្ត។

មានជំនឿថា សេចក្ដីសុខនឹងកើតមានដល់បុគ្គលអ្នកបានពោលពាក្យលន់តួទោស ការលន់តួទោសធ្វើឱ្យមនុស្សអស់បាប។ ព្រះជាម្ចាស់ទ្រង់រមែងបើកទ្វារឱ្យលន់តួរទោសជានិច្ច ការលន់តួដល់ទោសដោយទឹកភ្នែក នឹងបានផលជាសុខក្នុងភពខាងមុខ ការលន់តួទោសនោះ ប្រសិនបើធ្វើនៅពេលជិតស្លាប់កាន់តែប្រសើរបំផុត ជាងពេលណាៗទាំងអស់។

ត្រង់នោះមានអធិប្បាយដោយន័យថា Summum bonum គឺការប្រតិបត្តិដើម្បីសេចក្ដីល្អខ្ពង់ខ្ពស់នោះ បានដល់ការសារភាពទោសឬការលន់តួទោស ព្រមទទួលទោសកំហុសដែលខ្លួនបានធ្វើហើយ។

**ចរិយាធម៌និងពាក្យប្រៀនប្រដៅ ប្រការខ្លះៗ**

ពាក្យពោលប្រយោគតទៅនេះ នឹងសម្ដែងឱ្យឃើញចរិយាធម៌របស់ជនជាតិជ្វីហ្វដោយសង្ខេប។

-រាងកាយ គឺសំបករបស់ដួងវិញ្ញាណ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣៦)

-ខ្លាចព្រះជាម្ចាស់រក្សាបញ្ញត្តិរបស់ព្រះអង្គជានាទីរបស់មនុស្ស ព្រោះថាព្រះជាម្ចាស់ទ្រង់ជាអ្នកនាំពាក្យ ពិភាក្សាវិនិច្ឆ័យមនុស្សទាំងផ្នែកល្អ និងផ្នែកអាក្រក់។

-អ្នកមាន ទុកព្រះជាម្ចាស់ក្នុងហោប៉ៅ អ្នកក្រ ទុកព្រះជាម្ចាស់ក្នុងចិត្ត។

-អ្នកណាបដិសេធកំហុស អ្នកនោះទទួលកំហុស២ជាន់។

-អ្នកប្រៀនប្រដៅដែលល្អបំផុត គឺចិត្តថ្មើម គ្រូដែលល្អបំផុតគឺវេលា សៀវភៅដែលល្អបំផុតគឺលោក ចិត្តដែលល្អបំផុតគឺព្រះជាម្ចាស់។

-ព្រះជាម្ចាស់ ទ្រង់ពុំបានសាងស្ត្រីអំពីខួរក្បាលរបស់មនុស្សប្រុស ដើម្បីឱ្យមកគ្រប់គ្រងមនុស្សប្រុស និងពុំបានសាងអំពីជើងមនុស្សប្រុស ដើម្បីឱ្យមកជាទាសៈ តែទ្រង់សាងអំពីឆ្អឹងជំនី (ចំហៀង) របស់ប្រុស ដើម្បីឱ្យស្រីនៅផ្ទឹមក្បែរមនុស្សប្រុស។

-ពាក្យនិយាយ១០រឿងក្នុងលោកស្រីនិយាយ៩រឿង ប្រុសនិយាយបានតែមួយរឿង។

-តាំងពីស្ត្រីចាប់ផ្តើមកើត បុរសក៏ចាប់ផ្តើមមានបាប និងត្រូវដល់នូវសេចក្តីវិនាសព្រោះបាបនោះ។

-ឱ្យអ្វីដល់អ្នកណាមិនត្រូវចងចាំ បើទទួលអ្វីអំពីអ្នកណា មិនត្រូវបំភ្លេច

-ការលក់ដូរដែលមានកម្រៃបំផុត គឺការរាប់អានបញ្ញត្តិរបស់ព្រះជាម្ចាស់។ល។

**សាសនា និង ឯករាជ្យ**

ជ្វីហ្វទូទាំងពិភពលោក ធ្វើដំណើរត្រឡប់អំពីផ្នែកផ្សេងៗនៃលោក ដែលត្រូវបែកខ្ញាត់ខ្ញាយ ដោយអត់ទ្រាំនឹងទុក្ខលំបាកអស់ពេលជាច្រើនពាន់ឆ្នាំក្នុងអតីតកាល បាននាំគ្នាត្រឡប់ចូលមកកាន់ផែនដីនៃសញ្ញា នៅពេលចប់សង្គ្រាមលោកលើកទីពីរ។

ការដែលជនជាតិជ្វីហ្វទូទាំងពិភពលោកមានផែនដីរស់នៅ តាំងទុកជាគោលរបស់ជាតិ រួមរស់ជាមួយយ៉ាងមាំទាំ ប្រកាសជារដ្ឋឯករាជ្យនោះមានហេតុផលមួយដ៏សំខាន់ គឺកម្លាំងខាងផ្លូវសាសនា។ ពលផ្លូវសាសនា ដូចពោលមកនេះ បានដល់អង្គការរបស់ជនជាតិជីហ្វ ហៅថាសៃអាន (Zion Movement) ដែលជាឈ្មោះ របស់ភ្នំមួយ ក្នុងក្រុងយេរូសាលឹមមានន័យសេចក្តីថា ក្រុងយេរូសាលឹមឬសួគ៌ា គឺជាទីកន្លែងស្ថិតនៅនៃព្រះជាម្ចាស់តែមួយរបស់ជនជាតិជ្វីហ្វ។

អង្គការសៃអាន តាំងឡើងពីការរិះគិត និងកម្លាំងទ្រព្យរបស់ជនជាតិជ្វីហ្វ ដែលអាស្រ័យនៅក្នុងទ្វីប អាមេរិក មានគោលបំណងថា នឹងនាំជនជាតិជ្វីហ្វចូលទៅកាន់ផែនដីនៃសញ្ញាដែលព្រះជាម្ចាស់ទ្រង់ប្រទានទុកឱ្យ។ ផែនដីនោះគឺ ប៉ាឡេស្ទីន ឬប្រទេសអ៊ិស្រាអែលក្នុងបច្ចុប្បន្ន អង្គការនេះបានទទួលការព្រួតដៃគ្នាពី ជនជាតិជ្វីហ្វទូទាំងពិភពលោក។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៣៨)

អង្គការសៃអានលើកយកបញ្ញត្តិខាងផ្លូវសាសនា មកជាគ្រឿងអាវុធក្នុងការទាក់ទាញជនជាតិជ្វីហ្វឱ្យត្រឡប់ទៅកាន់ផែនដីនៃសញ្ញាវិញ បាននាំគ្នាចេញទៅសម្តែងបាឋកថាតាមទីកន្លែងផ្សេងៗទូទាំងសកលលោក។ សូមឱ្យបណ្តាពួកគ្រីស្ទានយល់ចិត្តគំនិតគ្នាជួយ

សង្គ្រោះជ្វីហ្វនិងទាក់ទាញដឹកនាំជ្វីហ្វឱ្យរួមដៃគ្នាតាំងជាជាតិ។ សូមឱ្យនាំគ្នាធ្វើដំណើរត្រឡប់ទៅកាន់ប៉ាឡេស្ទីន ដែលជាកន្លែងបដិសន្ធិរបស់ព្រះយេស៊ូ ដើម្បីញ៉ាំងសាសនាព្រះជាម្ចាស់ដែលជាព្រះបិតាព្រះយេស៊ូ ឱ្យត្រឡប់ទៅកាន់ទីកន្លែងដើមវិញ។

មានជនជាតិជាចំនួនច្រើនដែលមិនប្រាថ្នាត្រឡប់ទៅកាន់ផែនដីដើម តែបានលះបង់ទ្រព្យសម្បត្តិ ទំនុកបម្រុងចលនាតស៊ូដើម្បីឯករាជ្យរបស់ជាតិនិងរឹងប៉ឹងនៃសាសនា ក្នុងពេលនោះយ៉ាងពេញទំហឹង។ មនុស្សពួកនេះមានការប្រជុំគ្នារាល់ឆ្នាំ បានប្រាក់ជាច្រើនធ្វើដើមទុន ប្រុងប្រៀបទុកជួយគ្រួសារជ្វីហ្វ ដែលត្រេកអររីករាយត្រឡប់ទៅកាន់ស្រុកខ្លួនវិញ ដោយមានអង្គការអភិវឌ្ឍន៍ដីធ្លីតាមកន្លែងរង់ចាំជួយសម្រួលនៅក្នុងទីកន្លែងដីនោះ អង្គការនេះចាត់ឱ្យមានការសាងផ្លូវថ្នល់ ប្រឡាយទឹក ផ្ទះសម្បែង ឱ្យសម្បៀកបំពាក់ដល់ពួកអ្នកវិលត្រឡប់ទៅវិញគ្រប់មធ្យោបាយ។

អង់គ្លេសគ្រប់គ្រងផែនដីនេះ តាំងពីជ្វីហ្វរួចផុតពីអំណាចរបស់អាណាចក្រអត្តូម៉ាន់ (Ottoman Empire) ពេលចប់សង្គ្រាមលោកជាគ្រាដំបូងជាកម្លាំងដ៏សំខាន់ជួយជ្រោមជ្រែងនូវសេចក្ដីបំណងរបស់ជនជាតិជ្វីហ្វ ដោយមានច្បាប់មួយហៅថា ប្រកាសរបស់បាល់ហ្វូរ៍ (Balfour) Declaration) សន្យាថានឹងឱ្យឯករាជ្យ ដល់ជនជាតិជ្វីហ្វក្នុងពេលដ៏សមគួរ ព្រោះជនជាតិជ្វីហ្វបានជួយតស៊ូសង្គ្រោះអង់គ្លេសជាមួយសត្រូវ។

សង្គ្រាមគ្រប់គ្រា ជ្វីហ្វបានជួយសង្គ្រោះអង់គ្លេស និងសម្ព័ន្ធចិត្តយ៉ាងល្អទាំងក្នុងនិងក្រៅប្រទេស សាច់ឈាមដែលជ្វីហ្វត្រូវលះបង់ទៅនិងសេចក្ដីប្រាថ្នាដ៏ខ្ជាប់ខ្ជួន បូជាទុកដើម្បីជាតិនិងសាសនា ជាផលឱ្យជនជាតិ ជ្វីហ្វទូទាំងពិភពលោក បានធ្វើដំណើរត្រឡប់មកកាន់ប្រទេសផែនដីនៃសញ្ញា ដែលជាកន្លែងរស់នៅនិងជារដ្ឋឯករាជ្យ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៣៩)

កាលបើអង់គ្លេសនិងសម្ព័ន្ធមិត្ត ព្រមប្រគល់ឯករាជ្យឱ្យដល់ជនជាតិជ្វីហ្វក្នុងផែនដីប៉ាឡេស្ទីន ពេលចប់សង្គ្រាមលោកលើកទីពីរនោះ ជនជាតិអារ៉ាប់ដែលតាំងភូមិលំនៅពីដើមមិនពេញចិត្ត ដោយអាងថា ជ្វីហ្វពុំមានសិទ្ធិត្រូវមកធ្វើជាម្ចាស់ទេ ក្នុងទីបំផុតជ្វីហ្វនិងអារ៉ាប់ក៏ផ្ទុះចម្បាំងនឹងគ្នាជ្វីហ្វបានទទួលជ័យជម្នះ។ ផលនៃការច្បាំងគ្នាគ្រាដំបូង ប៉ាឡេស្ទីនត្រូវ បែងចែកជា ២ ចំណែក។ ជ្វីហ្វបានមួយចំណែក កន្លែងដែលអារ៉ាប់តាំង ភូមិលំនៅក៏បានទៅ

*អារ៉ាប់ៗ ចំណែករបស់ជីហ្វប្រកាសជាប្រទេសអ៊ីស្រាអែល ដែលជារបស់ជនផៅពង្ស "អ្នកមានការតឹងរឹងចំពោះព្រះជាម្ចាស់" ដូចបានពោលមកហើយពីខាងដើមៗ*

***បទសរុប***

*ការពិពណ៌នាសាសនាជ្វីហ្វមកតាំងពីដើម ធ្វើឱ្យឃើញការប្រែប្រួលលំដាប់កំណត់បានជាបទសរុប សេចក្តីគួរដល់ការពិចារណាដូច្នេះៗ*

*ខដំបូង សាសនាជ្វីហ្វ ចាប់ផ្តើមមកតាំងពីជ្វីហ្វជាជាតិរសាត់អណ្តែតពនេចរ រាប់អានខ្មោច ធម្មជាតិ វិញ្ញាណ និងទេវតាជាច្រើនអង្គជួបជូនបានមនុស្សល្អមកប្រៀនប្រដៅឱ្យជនជាតិជ្វីហ្វរួមគំនិតជាធ្លុងមួយ មានការរាប់អានព្រះយេះហូវ៉ាមួយអង្គ ជាផលឱ្យកើតសេចក្តីសាមគ្គីខាងផ្លូវចិត្តរួមគ្នាៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៤០)*

*ខតមក ជនជាតិជ្វីហ្វត្រូវជួបប្រទះការបែកបាក់ រសាត់អណ្តែតពនេចរ ត្រូវប្រហារជីវិត ទទួលទុក្ខលំបាកមួយគ្រាទៀតៗ សម័យនេះ ជនជាតិជ្វីហ្វមានសេចក្តីសង្ឃឹមឡើងថាផលនៃសេចក្តីល្អ ទោះបីជាយ៉ាងណាក៏ដោយ ក៏គង់មានមនុស្សល្អដូចដែលធ្លាប់មាន ហើយត្រឡប់មកកើត* (Messianic Hpoe) *ជួយលោះលា បាបឱ្យដល់ខ្លួនទៀតៗ អ្នកដែលជនជាតិជ្វីហ្វសង្ឃឹម ទោះបីជាអ្នកណាក៏ដោយចុះ តែពេលក្រោយមក ព្រះយេស៊ូក៏បានចាប់បដិសន្ធិឡើងសមតាមសេចក្តីសង្ឃឹមនោះ ហើយទោះបីជាយ៉ាងណាក្តី ការបដិសន្ធិរបស់យេស៊ូអាចរាប់បានថា ជាចំណុចចាប់ផ្តើមនៃសាសនាគ្រិស្តៗ*

*ខតមកទៀត អក្សរសាស្ត្រឬគម្ពីរក្នុងសាសនាជ្វីហ្វ បានក្លាយមកជាអក្ខរៈដ៏ស័ក្តិសិទ្ធិដែលជនជាតិគ្រិស្ត ទូទាំងពិភពលោកជាង ១.០០០លានកាន់ នាំគ្នាថែរក្សាបូជាទុកជាសម្បត្តិមានតម្លៃរបស់ខ្លួនៗ អក្ខរៈដ៏ស័ក្តិសិទ្ធិទាំងនេះ មានភាគខ្លះមិនអាចទទួលបាន តែនៅមានសេចក្តីច្រើនវគ្គដែលក្លាយទៅជាតម្រាមានល័ក្ខដ្ឋាន គួរដល់អ្នកមានបំណងចង់សិក្សារកសេចក្តីចម្រើនខាងវិជ្ជាការៗ*

*ខចុងក្រោយ អាស្រ័យដោយការអត់ទ្រាំទទួលទុក្ខវេទនាមកជាយូររាប់ពាន់ឆ្នាំហើយជាផលល្អនាំឱ្យកើតសេចក្តីមានះព្យាយាម មានបញ្ញាសមត្ថភាពក្នុងការជួយខ្លួនឯងបានដល់កំពូលមិនចាញ់អារ្យជាតិនានាៗ សេចក្តីចម្រើនខាងវិទ្យាសាស្ត្រ និងបរមត្ថវិជ្ជាសាខាផ្សេងៗក្នុងលោកថ្មីនេះ គឺផលនៃការមានបញ្ញា មានសមត្ថភាពជាប់បន្តគ្នាមក កើតជាផលប្រាកដ*

ឡើង ញ៉ាំងសេចក្តីចម្រើនឱ្យដល់មនុស្សក្នុងលោក និងពិភពលោកដែលកំពុងទទួលនូវផល នោះ។

កាលពីសតវត្សទី១១ នៃគ្រិស្តសករាជ អ្នកនិពន្ធជ្វីហ្វម្នាក់ បានសរសេរសរុបពាក្យប្រៀនប្រដៅជាចរិយាធម៌របស់ជ្វីហ្វទុកថា "និយាយតែសេចក្តីពិត ជាមនុស្សដាក់ខ្លួនឱ្យទាប មានការរស់នៅសាមញ្ញ ពឹងខ្លួនឯង ជៀសវាងការសេពគប់មនុស្សអាក្រក់ មិនបង្កសត្រូវ ជៀសវាងសេចក្តីក្រោធ កុំប្រព្រឹត្តខ្លួនជារុយរោមរបស់ស្មោគគ្រោក។ ល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៤១)

គម្ពីរទ័ល្មុតរបស់ជ្វីហ្វមួយជំពូកបង្រៀនសេចក្តីថា "ការប្រតិបត្តិដូចជាដើរលើផ្លូវពីរ ផ្លូវមួយពោរពេញទៅដោយភ្លើង ផ្លូវមួយទៀតពោរពេញទៅដោយទឹកសន្សើម ដើរលើផ្លូវដំបូងក្តៅស្លាប់ ដើរលើផ្លូវក្រោយរងា ស្លាប់ ដើម្បីឱ្យផុតពីគ្រោះថ្នាក់ ឱ្យដើរក្នុងចន្លោះរវាងផ្លូវទាំងពីរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៤២)

## សាសនាជ្វីហ្វ សាសនានៃក្តីស្រឡាញ់

សាសនាគ្រិស្ត ជាសាសនាធំប្រហែលគ្នានឹងសាសនាធំដទៃៗ មានអ្នករាប់អានគ្រប់និកាយរួមគ្នាប្រហែលជា ១.០០០លាននាក់។

សាសនាគ្រិស្ត ជាសាសនាជាប់បន្តសម្ព័ន្ធមកពីលទ្ធិជ្វីហ្វឬយូដា បើនិយាយតាមគោលការណ៍គ្រិស្ត សាសនាជាផលនៃការផ្សព្វផ្សាយរបស់លទ្ធិជ្វីហ្វឬកើតមកពីការបដិរូបរបស់លទ្ធិជ្វីហ្វដោយពិត ដូចគ្នានឹងគម្ពីរចាស់ (Old Teatament) របស់លទ្ធិជ្វីហ្វ ជាហេតុឱ្យកើតគម្ពីរថ្មី (New Teastament)។ ពីរគម្ពីរនេះ រួមជាគម្ពីរមួយក្បាលហៅថា Bible ឬ Holy Bible ហើយបើនិយាយពី Holy Bible ឱ្យយល់ថាជាគម្ពីររបស់សាសនាជ្វីហ្វ និងសាសនាគ្រិស្តរួមគ្នា។

សាសនាគ្រិស្ត មានពាក្យអធិប្បាយកំណត់សេចក្តីដោយខ្លីថា "សាសនានៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ សាសនានៃសេចក្តីស្រឡាញ់របស់មនុស្សដែលមានព្រះយេស៊ូគ្រិស្ត (យីស៊ូ) ទ្រង់ជាអ្នកនាំមកផ្សាយក្នុងលោកនេះ។

សាសនាគ្រិស្តដូចគ្នានឹងសាសនាធំផ្សេងៗ គឺមានអ្នកបង្កើត (Founder) អ្នកបង្កបង្កើតរបស់សាសនា គ្រិស្តគឺ ព្រះយីស៊ូគ្រិស្ត ឬ យេស៊ូ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៤៣)

មុនព្រះយេស៊ូបដិសន្ធិ ប្រវត្តិសាស្ត្ររបស់ជនជាតិមានដំណាលថា ជ្វីហ្វ បានបែកខ្ញែកខ្ចាត់ខ្ចាយមិនអាចរួមគ្នា ជាពួកជាក្រុមបាន រហូតដល់សម័យធ្លាក់ខ្លួននៅក្រោមការគ្រប់គ្រងរបស់រ៉ូម៉ាំង តែមានអ្នកដឹកនាំជាបព្វជិតស្ថិតនៅនាក្រុងយេរូសាឡឹម គ្រប់គ្រងខាងផ្លូវសាសនានៅឡើយ។

យេស៊ូ ជាជនជាតិជ្វីហ្វ បដិសន្ធិឆ្នាំទី១ នៃគ្រិស្តសករាជ (គ្រិស្តសករាជចាប់ផ្ដើម តាំងពីព្រះយេស៊ូចាប់បដិសន្ធិ) ក្នុងក្រុងបេថ្លេហិម (Bathlehem) ខេត្តយូដា ក្រុងយេរូសាឡឹម ជាបុត្រាតែមួយរបស់យោសេហ្វ និង ម៉ារី ត្រកូលជាងឈើ បានទទួលការចិញ្ចឹមថែរក្សាចម្រើនវ័យធំឡើង នៅភូមិណាសារេត (Na Zareth) ខេត្តកាលិលី ខាងជើងប្រទេសអ៊ីស្រាអែល ក្នុងបច្ចុប្បន្ន តាមប្រវត្តិយេស៊ូជាក្មេងឆ្លាតមកតាំងពីតូច។

មានរឿងរ៉ាវជាច្រើន តាំងពីក្មេងសម្ដែងឱ្យឃើញថា យេស៊ូនឹងទៅជាមនុស្សសំខាន់ក្នុងថ្ងៃមុខ។ អ្នកតែងប្រវត្តិសាស្ត្រសម្ដែងទុកថា មានលក្ខណៈបានសម្រេចភូមិជាព្រះគ្រិស្តជាអ្នកមករំដោះបាប និងសេចក្ដីទុក្ខលំបាករបស់ជនជាតិជ្វីហ្វ តាមសេចក្ដីសង្ឃឹម (Messianic Hope) នឹងតាមពាក្យទំនាយដែលមានប្រាកដនៅក្នុងគម្ពីរចាស់។

សូមសម្ដែងសេចក្ដីខ្លីៗឱ្យឃើញរឿងទាក់ទងនឹងពាក្យទំនាយចំពោះអ្នកមកបដិសន្ធិថ្មី ដែលសម្ដែង សេចក្ដីខាងផ្លូវសាសនារបស់សាសនិកជន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤៤)

តាមលទ្ធិជ្វីហ្វ ព្រះយេះហូវ៉ាជាមហាទេព ទ្រង់មានព្រះករុណាជាទីពឹងដូចជាបិតារបស់មនុស្ស (ជនជាតិជ្វីហ្វ) ជាអ្នកគ្រប់គ្រងជាតិជ្វីហ្វ ជាមហាទេពតែមួយអង្គ ពុំមានទេពអង្គឯណាដទៃទៀតប្រៀបស្មើបានឡើយ។ អ្នកដែលកាន់ជឿព្រះអង្គ ត្រូវប្រព្រឹត្តតាមព្រះបញ្ញត្តិ (បានដល់បញ្ញត្តិ ១០ ប្រការដែលមោសេស ប្រកាស ដូចបានសម្ដែងមកពីដើម) នឹងមានព្យាករណ៍ទុកថា ក្នុងសម័យមួយ ជនជាតិជ្វីហ្វទាំងឡាយ កាលបើប្រព្រឹត្តល្អ មានសេចក្ដីសាមគ្គីគ្នាយ៉ាងទូលាយ និងមានអ្នកមករំដោះទុក្ខជួយសង្គ្រោះ អ្នកមកជួយរំដោះទុក្ខនោះហៅថា មេស្សីអាហ៍ (Messiah) តាមសេចក្ដីយល់របស់មនុស្សភាគច្រើនថា ព្រះយេស៊ូគឺមេស្សីអាហ៍ តាមពាក្យព្យាករណ៍។

មានការពិពណ៌នាប្រវត្តិព្រះយេស៊ូថា ការដែលជនជាតិជ្វីហ្វត្រូវជួបប្រទះសេចក្ដីក្រខ្សត់ ខ្ចាត់ខ្ចាយទៅក្នុងទីផ្សេងៗត្រូវធ្លាក់ជាឈ្លើយ ប្រព្រឹត្តតែអំពើបាបកម្ម ខុស ឃ្លាតចាកពី

ព្រះបញ្ញត្តិរបស់ព្រះយេហូវ៉ា ទោះបីជាយ៉ាងនេះក្តី ព្រះអង្គ (ព្រះយេហូវ៉ា) ក៏ទ្រង់ នៅមានព្រះករុណា ព្រមទទួលប្រទានព្រះបុត្រចុះមក ជួយសង្គ្រោះផុតទុក្ខ ព្រះបុត្រក្នុងទីនេះបានដល់ព្រះយេស៊ូ។

**បឋមវ័យ**

គម្ពីរម៉ាថាយ សម្តែងបុព្វបុរសរបស់ព្រះយេស៊ូទុកថា ជាខ្សែស្រឡាយរបស់ក្សត្រិយ៍ដាវិត អ្នកបន្តវង្សត្រកូលពីអប្រាហាម បុព្វបុរសដំបូងរបស់ត្រកូលជ្វីហ្វ រាប់តាំងពីអប្រាហាមមកដល់ក្សត្រិយ៍ដាវិត ១៥ដំណ មនុស្សរាប់ពីក្សត្រិយ៍ដាវិតហើយមក ដល់សម័យ ជីហ្វត្រូវបោសសំអាតទៅកាន់ក្រុងបាប៊ីឡោន១៤តំណមនុស្ស និងតាំងពីនោះមក ១៤តំណទៀត ទើបដល់សម័យព្រះយេស៊ូ។

ព្រះយេស៊ូបដិសន្ធិក្នុងសម័យហេរោត ក្សត្រិយ៍ដែលកាចសាហាវរបស់ជ្វីហ្វ ហេរោតទ្រង់ជ្រាបពីអាមាត្យថា មានអ្នកមានបុណ្យមកកើតនាខេត្ត បេថ្លេហិម ក្នុងដែនដី យូដា។ ទ្រង់ក្តៅព្រះទ័យ ទើបគិតកម្ចាត់កុមារនោះចេញ។ យោសេបហ្វនិងម៉ារី បិតាមាតាបាននាំកូនប្រុសកៀសខ្លួនរត់ទៅនៅក្នុងប្រទេសអេហ្ស៊ីបមួយរយៈ រហូតទាល់តែឃើញថាផុតអំពីភ័យ ទើបនាំត្រឡប់មកអាស្រ័យចិញ្ចឹមជីវិត នៅទីក្រុងណាសារេត ខេត្តកាលិលី។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤៥)

ព្រះយេស៊ូ បានទទួលការថែទាំរក្សាដោយសេចក្តីក្តីស្ងប់និងស្អាតបាត តាមដែលប្រាកដក្នុងគម្ពីរលូកាថា មានជីវិតជាជនសាមញ្ញធម្មតា របស់ដែលនៅព័ទ្ធជុំវិញផ្សេងៗក្នុងជីវិតមានតែរឿងសាសនា រឿងរបស់ធម្មតានិងអ្នកព្រតដែលបានឃើញមកតាំងពីក្មេង។ ជួនកាលរឿងទារុណកម្មរបស់អ្នកគ្រប់គ្រងប្រទេសផងដែរ ជាហេតុបណ្តាលជីវិតឱ្យជាប់ជំពាក់ក្នុងធម៌ និងការប្រៀនប្រដៅមនុស្សរហូតដល់បានសម្រេចដល់ភូមិរបស់ព្រះគ្រិស្តជាម្ចាស់អ្នកមានមេត្តាករុណាដល់មនុស្សទាំងឡាយដូច្នោះទេដឹង ?

តាំងពីអាយុបាន ១២ឆ្នាំ មានហេតុការណ៍សំខាន់ជាច្រើនយ៉ាងក្នុងជីវិតដែលជានិម្មិតថា នឹងបានទៅជាសាស្តាសម្រេចដល់ភូមិធម៌នៃព្រះគ្រិស្តក្នុងពេលខាងមុខ។

ពេលដែលយោសេបហ្វនិងម៉ារី នាំកុមារយេស៊ូមកចិញ្ចឹមនៅក្នុងទីក្រុងណាសារេត ខេត្តកាលិលី មានការចម្លែកក្នុងចិត្តថា កូនរបស់ខ្លួនជាមនុស្សនិយាយមានហេតុផលជាជាងក្មេងសាមញ្ញ បើអ្នកណាសួរបញ្ហាអ្វីនឹងយេស៊ូ យេស៊ូចូលចិត្តឆ្លើយថា ចាំបន្តិចសិន ខ្ញុំនឹង

សួរបិតារបស់ខ្ញុំ បិតាក្នុងទីនេះ ព្រះយេស៊ូសំដៅដល់ព្រះជាម្ចាស់ដែលជាលក្ខណៈសម្ដែងថា ព្រះយេស៊ូមានកូមិធម៌ បង្អួនទៅរកលក្ខណៈជាសាស្ដា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ៤៦)

## ទទួលសីលជ្រមុជទឹក

តាំងពីអាយុ ១២ ទៅដល់១៨ឆ្នាំ យេស៊ូត្រេចចរសិក្សានៅក្នុង "ផែនដីនៃសញ្ញា" យេស៊ូមានការយល់ឃើញចំពោះពាក្យប្រៀនប្រដៅជំនាន់ដើម ដែលជនជាតិជ្វីហ្វរាប់អានជឿកាន់ មានការចេះដឹងតិចច្រើនប៉ុនណា នោះមិនអាចដឹងច្បាស់ តែបានដឹងថា ព្រមធ្វើជាសិស្សសំខាន់ម្នាក់របស់ចួន ឬ (យូហាន) ដែលហៅថា John Baptist មានន័យសេចក្ដីថាចួនអ្នកឱ្យសីលជ្រមុជទឹក។

ចួន ជាជាតិជ្វីហ្វ កើតនៅជើងភ្នំយូដា មុនគ្រិស្តសករាជ ៥ឆ្នាំ សម្ដែងឱ្យឃើញថា កើតមុនយេស៊ូ៥ឆ្នាំ (ឬជំនាន់ជាមួយគ្នា) ឪពុកម្ដាយអស់ជន្មជីវិតតាំងពីក្មេង មានចិត្តជាប់ជំពាក់ក្នុងធម៌ ត្រាច់ចរទៅតាមទីកន្លែង ផ្សេងៗក្នុងលក្ខណៈជាអ្នកធុតង្គ ដើម្បីស្វែងរកធម៌បំពេញខ្លួនជាយោគី ចាប់ផ្ដើមបង្រៀនធម៌ដល់ប្រជាជនប្រហែលជាឆ្នាំទី១៤ ក្នុងរជ្ជកាលសម័យនៃក្សត្រិយ៍តៃបិរិអ៊ុស។ កាលយេស៊ូអាយុបាន ៣០ឆ្នាំ ព្រមទទួលជាសិស្សដោយការទទួលពិធីសីលជ្រមុជទឹក (Baptism) នៅទន្លេហ្សរដាំង (Jordan) សម្ដែងថាអ្នកធ្វើពិធីជាអ្នកចូលទៅដល់ព្រះជាម្ចាស់ទំនងដូចជាការទទួលត្រៃសរណគមក្នុងពុទ្ធសាសនា។ ចួនមានជីវិតរហូតមកដល់សម័យនៃក្សត្រិយ៍ហេរ៉ូត (Herod) មិនពេញចិត្តនឹងអំពើប្រព្រឹត្តរបស់ក្សត្រិយ៍នេះជាច្រើនយ៉ាង ពាក្យប្រៀនប្រដៅរបស់ខ្លួនត្រឡប់ជាអន្តរាយដល់ខ្លួនវិញ ព្រោះស្រុកទេសមិនយល់ស្រប ត្រូវក្សត្រិយ៍ហេរ៉ូត ចាប់ដាក់គុកម្ដង នៅទីបំផុតត្រូវម្ចាស់ក្សត្រិយ៍សាឡោមេ (Salome) ធីតា (ចិញ្ចឹម) រូបស្អាតរបស់ក្សត្រិយ៍ ហេរូត ប្រហារជីវិតដោយឧបាយកលរបស់នាង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ៤៧)

លុះបានទទួលសីលជ្រមុជទឹកហើយ យេស៊ូចេញពីមាត់ទន្លេហ្សរដាំង សេចក្ដីក្នុងគម្ពីរម៉ាថាយសម្ដែងថា "ស្រេចហើយផ្ទៃមេឃក៏របើកចេញត្រង់ព្រះអង្គ ទ្រង់បានឃើញព្រះវិញ្ញាណនៃព្រះជាម្ចាស់ ស្ដេចយាងចុះ មកប្រដូចជាសត្វព្រាបស្ថិតនៅលើព្រះអង្គ។ ល។

តអំពីនោះ យេស៊ូធ្វើដំណើរចូលទៅកាន់ដងព្រៃ ចាប់ផ្ដើមទេសនាប្រៀនប្រដៅជាលំដាប់លំដោយ។ គ្រាមួយនោះ ទ្រង់វង្វេងផ្លូវចូលទៅក្នុងព្រៃព្រមជាមួយនឹងអ្នកដើរតាមទ្រង់វង្វេងរហូតដល់ទៅ ៤០ថ្ងៃ ៤០ យប់តែអាចចិញ្ចឹមជីវិតរស់នៅបាន ជាហេតុអស្ចារ្យ។

**បានអគ្គសាវ័ក**

សេចក្ដីក្នុងគម្ពីរនិយាយថា មានអ្នកមកសាកល្បងបញ្ហាព្រះយេស៊ូ បើជាបុត្ររបស់ព្រះជាម្ចាស់ពិត សូមសាកមើលបញ្ហាឱ្យដុំថ្មទៅជានំបុ័ងទើបជឿ។ ព្រះយេស៊ូ អាចសែកដុំថ្មឱ្យទៅជានំបុ័ងបានឬមិនបាន តែផលដែលព្រះយេស៊ូ (ជួយអ្នកទៅតាមជាមួយ) ទ្រាំអត់ឃ្លាននៅបាន ៤០ថ្ងៃ ៤០យប់ ក៏ជាអភិនិហារសម្ដែង ថា "មាននំបុ័ង" ជួយជីវិតឱ្យរស់នៅបាន គួរឱ្យអស្ចារ្យ។

(ជាការធម្មតារបស់អ្នកមានបុណ្យ ដែលនឹងមានតំណែងជាសាស្ដាមួយអង្គរបស់មនុស្សទាំងឡាយ អ្នកតែងប្រវត្តិទើបពិពណ៌នាពីអភិនិហារឱ្យឃើញជារឿងស័ក្ដិសិទ្ធិ គួរដល់ការមានសទ្ធាជ្រះថ្លារបស់មនុស្សទូទៅ)។

យេស៊ូចេញអំពីដងព្រៃហើយ បានដឹងដំណឹងថា ក្សត្រិយ៍ហេរ៉ូត ទ្រង់បញ្ជាឱ្យចាប់ច្អូន (ឬយោហាន) អ្នកឱ្យសីលជ្រមុជទឹកដល់ខ្លួន រហូតត្រូវប្រហារជីវិត ទើបលបគេចចេញពីណាសារេត ឆ្ពោះទៅកាន់តំបន់ កាលិលី ត្រាច់រង្គាត់ទេសនានៅតាមភូមិក្បែរមាត់ទន្លេ គឺនៅទីនោះឯង ដែលយេស៊ូបានសាវ័កគាប់ព្រះទ័យ នឹងតអំពីនោះក៏បានជាបន្តបន្ទាប់ រួម ១២នាក់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤៨)

គម្ពីរម៉ាថាយ សម្ដែងថាក្នុងពេលដែលព្រះយេស៊ូធ្វើដំណើរទៅតាមមាត់ទន្លេនោះ ទ្រង់ជួយបងប្អូនអ្នក នេសាទ ២នាក់ ម្នាក់ឈ្មោះ ស៊ីម៉ូន (Simon) ឬ (ហៅនាមមួយទៀតថា) ប៉េត្រូ (ពីតឺរ៍) និងប្អូនប្រុសឈ្មោះ អេនឌ្រូវ៍ (Andrew) សួរអ្នកទាំងពីរថា ចូរតាមយើងមក យើងនឹងជួយឱ្យលោកវាយផ្លូនចាប់មនុស្ស។ អ្នកទាំងពីរជ្រះថ្លាក៏តាមទៅ។ ព្រះយេស៊ូទ្រង់ជួយបងប្អូនអ្នកនេសាទពីរនាក់ទៀត ឈ្មោះ ចេម (James) ដែលខ្លះទៀតហៅយាគោបា (ឬយ៉ាកុប) និងច្អូន ឬ យោហានប្អូនប្រុស មករកត្រីជាមួយបិតាឈ្មោះ សេបេឌី (Zebedee) ព្រះយេស៊ូទ្រង់ហៅឱ្យទៅតាមពីរនាក់បងប្អូនក៏លះបង់បិតាតាមយេស៊ូ។

តអំពីនោះ ព្រះយេស៊ូបានជួបអគ្គសាវ័កតទៅទៀត រួមទាំងអស់ ១២នាក់ មាននាមដូចតទៅនេះ ៖

១-ស៊ីម៉ូន ឬ ប៉េត្រូ

២-អេនឌ្រូវ៍

៣-យេម្ស ឬ យ៉ាកោបោ

៤-ចូន ឬ យ៉ូហាន

៥-ហ្វីលិព

៦-បារ៍ថោឡោមិវ

៧-ម៉ាថាយ (ម៉ាថាយ អ្នកទារពន្ធ)

៨-ថូម៉ាយ ឬ ថូម៉ា

៩-យេម្ស ឬ យ៉ាកោបោ (បុត្រអាល់ផាយ)

១០-លេប្បាយ្ស (Lebeus) ឬថាដា (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៤៩)

១១-ស៊ីម៉ន (អ្នកស្រុកកាណាអាន់)

១២-យូដា (ជាអ្នកក្បត់ -iscariot)

ក្នុងពេលនោះ កិត្តិស័ព្ទរបស់ព្រះយេស៊ូ ល្បីល្បាញទីទៅឆ្ងាយ បានជួយសង្គ្រោះអ្នកជំងឺដោយរោគផ្សេងៗ មានមនុស្សដែលទទួលទុក្ខលំបាក មនុស្សត្រូវខ្មោចចូល មនុស្សឆ្កួតជ្រូក និងមនុស្សពិការឱ្យជាអំពីរោគនោះៗ។

មានគ្រាមួយ ព្រះយេស៊ូចេញធ្វើដំណើរទេសនាទៅតាមភូមិស្រុក ក្នុងខេត្តកាលិលី (Galilee) ឈរទេសនាឱ្យមនុស្សទាំងឡាយស្ដាប់ មាននាយទាហានរ៉ូម៉ាំងម្នាក់ (ពេលនោះ ជ្វីហ្វធ្លាក់នៅក្នុងអំណាចរបស់រ៉ូម៉ាំង) ដើរមកជួបមនុស្សកំពុងជុំគ្នា ចូលទៅមើលឃើញព្រះយេស៊ូឈរទេសនាអាងទៅលើគុណព្រះជាម្ចាស់ កើតសេចក្ដីជ្រះថ្លា អង្វរសូមឱ្យព្រះយេស៊ូទៅជួយរក្សារោគកូនប្រុសដែលកំពុងឈឺនៅឯផ្ទះ។ ព្រះយេស៊ូប្រាប់ នាយទាហានរ៉ូម៉ាំងថា "លោកត្រឡប់ទៅរកកូនប្រុសរបស់លោកចុះ បើលោកជឿថា កូនប្រុសរបស់លោកនឹង ជាពីជំងឺ ដោយអំណាចរបស់ព្រះជាម្ចាស់ រោគនឹងអន្តរធានទៅឯង" នាយទាហានរ៉ូម៉ាំងនោះ ជឿដើរត្រឡប់ទៅផ្ទះវិញ លុះដល់ផ្ទះក៏ឃើញកូនប្រុសជាអំពីជំងឺដូចធម្មតា។

ផលនៃការទេសនា និងការជួយសង្គ្រោះមនុស្សជំងឺ មនុស្សមានទុក្ខដែលព្រះយេស៊ូបានសម្ដែងមេត្តា ដល់គេទាំងឡាយមិនរើសមុខយ៉ាងនេះ កាលបើព្រះយេស៊ូធ្វើដំណើរទៅ

ទីណា មានមនុស្សប្រចាមរោមដើរតាមទៅគ្រប់ទីកន្លែង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥០)

## ទេសនាលើខ្នងភ្នំ

ទេសនាលើខ្នងភ្នំ (Sermon on The Mount) គឺទេសនាគ្រាដ៏សំខាន់បំផុត ក្នុងរយៈដំបូងនៃជីវិត ដែលព្រះយេស៊ូទៅជាសាស្ដាកំណត់យកជាពាក្យប្រៀនប្រដៅនិងជាឫសគល់របស់សាសនា។ គម្ពីរម៉ាថាយ ចារឹក ទេសនាដ៏សំខាន់គ្រានេះ ទុកជាសេចក្ដីថា ៖

"គ្រាដែលបានទតព្រះនេត្រ ឃើញមនុស្សមកច្រើន ព្រះអង្គស្ដេចឡើងលើភ្នំប្រថាប់នៅចំកណ្ដាលសាវ័កទាំងឡាយហើយ ទើបបញ្ចេញព្រះឱស្ឋបង្រៀនពួកគេថា ៖

"បុគ្គលណាមួយមានការខ្វះខាតក្នុងវិញ្ញាណក៏ជាសុខ ព្រោះស្ថានសួគ៌ជារបស់គេហើយ"។

"បុគ្គលណាមួយសោកសៅក៏ជាសុខ ព្រោះថាគេនឹងបានទទួលការបន្ធូរបន្ថយទុក្ខនោះ។

"បុគ្គលណាមួយមានចិត្តសុភាពក៏ជាសុខ ព្រោះថាគេនឹងបានទទួលការរស់នៅយឺនយូរ ក្នុងផែនដី មានលោកនេះជាមត៌ក។

"បុគ្គលណាមានការស្រេកឃ្លានចូលចិត្តនូវធម៌ក៏ជាសុខ ព្រោះថាគេនឹងបានឆ្អែតបរិបូណ៌"។

"បុគ្គលណាមានចិត្តមេត្តាត្រាប្រណីក៏ជាសុខ ព្រោះថាគេនឹងបានទទួលសេចក្ដីមេត្តាត្រាប្រណីដូចគ្នា"។

"បុគ្គលណាមានចិត្តបរិសុទ្ធក៏ជាសុខ ព្រោះថាគេនឹងបានឃើញព្រះជាម្ចាស់"។

"បុគ្គលណាបានរម្ងាប់នូវការបែកបាក់ក៏ជាសុខ ព្រោះនឹងបានឈ្មោះថា ជាបុត្ររបស់ព្រះជាម្ចាស់"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥១)

"បុគ្គលណាបានអត់ទ្រាំនឹងការចាក់រុកបៀតបៀន ព្រោះតែចូលចិត្តនូវធម៌ក៏ជាសុខ ព្រោះថាផែនដីសួគ៌ជារបស់គេហើយ កាលបើអ្នកណាតិះដៀលសម្លុតឬនិន្ទាថា យើងជាអ្នកកូតករគេ លោកក៏ជាសុខ ចូរត្រេកអរ រីករាយចុះ ព្រោះថាគុណបំណាច់របស់លោក មានបរិបូណ៌ក្នុងសួគ៌ាហើយ ព្រោះគេបាននិន្ទាសាស្ដាព្យាករណ៍ទាំងឡាយដែលមានមកពីមុនលោកដូចគ្នាដែរ។

"លោកទាំងឡាយជាអំបិលសួតលើផែនដី បើអំបិលនោះអស់រសជាតិប្រែទៅហើយ ធ្វើឱ្យត្រឡប់ទៅជាប្រៃវិញម្ដេចកើត "ពីនោះទៅក៏គ្មានប្រយោជន៍អ្វីដែរ មានតែលះបង់ចោល សម្រាប់ឱ្យមនុស្សជាន់ឈ្លី ប៉ុណ្ណោះ"។

"លោកអ្នកទាំងឡាយជាពន្លឺនៃលោក ក្រុងដែលសាងទុកលើកំពូលភ្នំមិនអាចបិទបាំងទុកបាន កាលគេអុជចង្កៀងហើយ បើមិនបានយកធុងមកគ្របទេ រមែងចុះបញ្ចាំងពន្លឺដល់មនុស្សគ្រប់គ្នានៅក្នុងផ្ទះនោះ ឱ្យពន្លឺរបស់លោកចុះទៅចំពោះមុខមនុស្សទាំងពួង ដើម្បីគេនឹងបានឃើញសេចក្ដីល្អរបស់លោកនឹងបានសរសើរ ព្រះបិតាដែលនៅក្នុងឋានសួគ៌"។

"កុំគិតថា យើងមកបំផ្លាញព្រះបញ្ញត្តិនិងពាក្យពេចន៍របស់សាស្ដាព្យាករណ៍ យើងមិនបានមកបំផ្លាញទេ តែយើងមកដើម្បីនឹងឱ្យសម្រេច"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ ២ ទំព័៥២)

"ព្រោះយើងប្រាប់អ្នកទាំងឡាយតាមពិតថា ទោះមេឃនិងដីចេះតែកន្លងទៅព្រះបញ្ញត្តិមួយតួឬមួយចំណុច ក៏មិនអាចបាត់បង់បានឡើយ តែយើងនឹងធ្វើឱ្យសម្រេចទាំងអស់។ ហេតុដូច្នោះ អ្នកណាដែលធ្វើឱ្យខូច ក្នុងព្រះបញ្ញត្តិខណាមួយឱ្យបាត់បង់ចុះ ថែមទាំងបង្រៀនអ្នកដទៃឱ្យធ្វើយ៉ាងនោះ អ្នកនោះបានឈ្មោះថាជា អ្នកទទួលភោគផលតិចបំផុតក្នុងឋានសួគ៌។ ប៉ុន្តែបើអ្នកណាហើយបានប្រព្រឹត្តនិងបង្រៀនតាមព្រះបញ្ញត្តិ អ្នកនោះឈ្មោះ ថាជាអ្នកចំក្នុងក្រុងឋានសួគ៌ យើងប្រាប់អ្នកទាំងឡាយថា បើការចូលចិត្តធម៌របស់លោក មិនលើសពីការចូលចិត្តធម៌របស់ពួកអាលក្ខណ៍ និងពួកហ្វារិសាយ (មិច្ឆាទិដ្ឋិ) ទេ លោកនឹងពុំបានចូលទៅក្នុង ក្រុងសួគ៌ឡើយ"។

អត្ថាធិប្បាយនៃការទេសនាលើភ្នំមានជាច្រើនទៀត តែដែលសំខាន់គឺខពោលថា កុំគិតថាយើងមកបំផ្លាញព្រះបញ្ញត្តិ និងពាក្យប្រៀនប្រដៅរបស់សាស្ដាព្យាករណ៍ឱ្យខូចនោះ យើងមិនបានបំផ្លាញទេ តែយើងមកដើម្បីធ្វើឱ្យសម្រេច។

ដូចជារឿងហាមមិនឱ្យសម្លាប់មនុស្ស (បញ្ញត្តិ ខទី៦) ព្រះយេស៊ូមានន័យធំទូលាយទៀត ក្រៅអំពីការប្រទូស្តរ៉ាយខាងផ្លូវកម្លាំងកាយហើយ មានន័យដល់ការជេរ ការពោលពាក្យស៊ោកសៀតចាត់ដោតក៏មិនគួរធ្វើដែរ ការក្រោធខឹងរវាងបងប្អូនមិនគួរធ្វើសោះឡើយ ការបូជាក៏មិនគួរធ្វើក្នុងពេលដែលមានកំហឹង បាត់ខឹងសិនសឹមធ្វើ។

រឿងហាមការកន្ទួនប្រពៃណី (បញ្ញត្តិ ១៧) ព្រះយេស៊ូសំដៅទៅដល់ផ្លូវចិត្តផងដែរ គឺគ្រាន់តែគិតថា ចង់ល្មើសក៏ហាមមិនឱ្យធ្វើ បើសិនជាកែវភ្នែកនាំឱ្យវង្វេងខុស គិតឃើញថាល្អស្អាត។ ព្រះយេស៊ូបង្រៀនថា ចូរខ្វេះកែវភ្នែកចេញ បើដៃធ្វើឱ្យវង្វេងខុស ចូរកាត់ដៃនោះចោលទៅ ព្រោះខូចអវយវៈតែមួយ ល្អជាជាងខូចទៅទាំងខ្លួន (ធ្លាក់នរក)។

ខហាមពាក្យកុហក (បញ្ញត្តិ១៩) ព្រះយេស៊ូហាមទៅដល់មិនឱ្យស្បថស្បែ ប្រដៅចេះនិយាយឱ្យមនុស្សជឿ ល្អជាងនិយាយពាក្យសម្បថ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំ ៣៥៣)

ខហាមទាក់ទងនឹងសេចក្តីលោភ (បញ្ញត្តិ១០) ព្រះយេស៊ូហាមទៅដល់ថា បើអ្នកណាមកលួចអាវយើងមួយ គួរឱ្យគេមួយទៀត ពាក្យនិយាយដែលថា "ភ្នែកជំនួសភ្នែក ធ្មេញជំនួសធ្មេញ" មិនឱ្យធ្វើ ហាមមិនឱ្យតស៊ូនឹងមនុស្សអាក្រក់ បើគេទះថ្ពាល់ស្តាំ ចូរបែរថ្ពាល់ឆ្វេងឱ្យគេទះផង ត្រូវស្រឡាញ់សូម្បីតែសត្រូវរបស់ ខ្លួន។

ការធ្វើបុណ្យ មិនត្រូវយកមុខ កុំធ្វើបុណ្យដើម្បីឱ្យគេសរសើរ ធ្វើយ៉ាងណាព្រះជាម្ចាស់ដឹងអស់ បើកាន់សីលអត់ក៏មិនត្រូវធ្វើមុខស្ងួកស្ងាំង ប្រាប់គេថាកាន់សីល។

កុំសន្សំទ្រព្យក្នុងលោកនេះ ចូរសន្សំទ្រព្យទុកលើឋានសួគ៌ ហ្វូងសត្វរើសអាហារសំណល់ស៊ី ព្រះជាម្ចាស់នៅតែចិញ្ចឹមសត្វនោះឱ្យមានជីវិតរស់នៅបាន សូឡូម៉ុនតាក់តែងអង្គដូចជាក្សត្រិយ៍ ក៏មិនឃើញថាល្អជាងផ្កាឈើដែរ។

ប្រយ័ត្នអ្នកប្រាជ្ញ តែចិត្តជាសុនខ។

ដឹងមនុស្សបានដោយផលនៃការងារ ដូចគ្នានឹងការស្គាល់ដើមឈើ ព្រោះផ្លែឈើ។

អគ្គសាវ័ករបស់ព្រះយេស៊ូទាំង១២នាក់ ដែលពោលមកពីខាងដើម បានជួយជាកម្លាំងដល់ព្រះយេស៊ូច្រើនឃើញនៅពេលខាងក្រោយ កាលបើព្រះយេស៊ូយល់ថា ល្មមនឹងប្រកាស "សាសនានៃសេចក្តីស្រឡាញ់" របស់ខ្លួន ឱ្យផ្សព្វផ្សាយចេញទៅ ប្រទេសជិតខាងបានហើយ ក៏ប្រជុំសាវ័កទាំង១២នាក់ និងបញ្ជូនឱ្យចេញទៅប្រកាសសាសនា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំ៣៥៤)

ការបញ្ជូនសាវ័កចេញទៅប្រកាសសាសនា ព្រះយេស៊ូធ្វើដូចជាសាស្តាដទៃ គឺហៅមកប្រៀនប្រដៅមុន ផ្តើមណែនាំជាដំបូងថា ទៅដល់ទីណាឱ្យនិយាយប្រាប់ដល់បុគ្គលទីនោះថា "ផែនដីសួគ៌ចូលមកជិតលោកហើយ" ដូច្នេះជានិច្ច។

ក្រៅអំពីនោះ ក៏ប្រៀនប្រដៅឱ្យប្រតិបត្តិដល់ប្រជុំជន ដែលពួកមិស្សាន់នារីធ្វើនៅក្នុងបច្ចុប្បន្ន ដូចជួយរក្សាមនុស្សឈឺឱ្យជា ជួយមនុស្សស្លាប់ឱ្យរស់ ជួយមនុស្សរោគឃ្លង់ឱ្យស្អាត បណ្ដេញព្រាយបិសាចឱ្យចេញពីអ្នកខ្មោចចូល (តាមគម្ពីរប្រាកដថា មុនសាវ័កចេញធ្វើដំណើរព្រះយេស៊ូប្រគល់អំណាចបណ្ដេញខ្មោច និង អំណាចរក្សារោគឱ្យសាវ័កផងដែរ ទំនងដូចជាប្រាប់គាថាឱ្យសូត្រ)។

ទីណាគួរទៅ ទីណាមិនគួរទៅ ព្រះយេស៊ូបង្រៀនទាំងអស់ ទៅដល់ទីណាត្រូវឱ្យពរដល់មនុស្សក្នុងទីនោះជាមុនគ្រប់ពេល ផ្ទះណាគួរនឹងអាស្រ័យនៅបានឬមិនបាន បើទីកន្លែងណាមិនទទួល និងមិនស្ដាប់ពាក្យប្រៀនប្រដៅឱ្យប្រញាប់ចេញទៅ និងជជុះរលាស់ផង់ធូលីរបស់ផ្ទះនោះកុំឱ្យជីតជាប់ខ្លួនសូម្បីតែជើង។

មានវគ្គមួយ ព្រះយេស៊ូបង្រៀនសាវ័កថា "សិស្សមិនត្រូវធំជាងគ្រូ ទាសៈមិនត្រូវធំជាងនាយចៅហ្វាយរបស់ខ្លួន សិស្សគ្រាន់តែត្រឹមស្មើគ្រូ និងទាសៈគ្រាន់តែត្រឹមស្មើនឹងនាយចៅហ្វាយក៏ល្មមហើយ"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥៥)

ដែលសំខាន់បំផុតនោះ ព្រះយេស៊ូបង្រៀនសាវ័ក មុនចេញដំណើរផ្សព្វផ្សាយសាសនាថា យើងប្រើពួកអស់លោកទៅប្រដូចជាចៀមនៅកណ្ដាលហ្វូងឆ្កែចចក ព្រោះដូច្នោះ ពួកអស់លោកត្រូវជាមនុស្សឆ្លាតដូចជា ពស់ និងជាមនុស្សសុភាពដូចសត្វព្រាប។

គ្រាក្រោយមក ពេលត្រឡប់មកស្រុកទេសវិញ ព្រះយេស៊ូផ្ដើមប្រៀនប្រដៅទៀត ឱ្យមនុស្សមានសេចក្ដី ស្រឡាញ់ មេត្តាដល់គ្នានឹងគ្នា ពាក្យប្រៀនប្រដៅត្រង់វគ្គនេះ ដែលធ្វើឱ្យជនជាតិជ្វីហ្វក្នុងសម័យនោះឃើញថា ព្រះយេស៊ូល្មើសនឹងពាក្យប្រៀនប្រដៅដើម គឺពាក្យប្រដៅថា "បើអ្នកណាមកទះមុខខាងថ្ពាល់ស្ដាំ ត្រូវបែរថ្ពាល់ឆ្វេងឱ្យគេទះទៀត"។

កាលណាពាក្យប្រៀនប្រដៅទាំងនេះបានផ្សព្វផ្សាយ មនុស្សមានបញ្ញាល្មមអាចមើលឃើញថា ព្រះយេស៊ូគឺមេស្សិអាហ៍ អ្នកនឹងមកជួយលោកក្នុងនាមរបស់ព្រះជាម្ចាស់ តែអ្នកដែលមានបញ្ញាទន់ទាប ត្រឡប់ជានាំគ្នាមើលឃើញថា ព្រះយេស៊ូធ្វើខុសបញ្ញត្តិដើម និងការញុះញង់អ្នកស្រុកឱ្យប្រឆាំងដល់ពួករ៉ូមដែលកំពុងគ្រប់គ្រង។ កាលបើអ្នកមានបញ្ញាទន់ខ្សោយមានច្រើនជាងអ្នកមានបញ្ញាល្អ ព្រះយេស៊ូដែលជាមនុស្សល្អ ក៏ក្លាយទៅជាមនុស្សគ្មានគេចូលចិត្ត ពួកអ្នកព្រតជ្វីហ្វនាំគ្នាតវ៉ាពាក្យប្រៀនប្រដៅថ្មីរបស់ព្រះយេស៊ូ ទើបរកមធ្យោបាយកម្ចាត់ព្រះយេស៊ូចេញ។ ចាប់តាំងពីពេលនោះមក ព្រះយេស៊ូទៅទីកន្លែងណា

មានតែមនុស្សចាំសើចចំអកនិងបណ្ដេញចេញ ព្រះយេស៊ូក្លាយទៅជាមនុស្សដែលពុំមានអ្នកណាសេពគប់រាប់រកនិយាយ ដោយសរុបទៅ សេចក្ដីលំបាករបស់ព្រះយេស៊ូក្នុងការប្រៀនប្រដៅធម៌ កើតមកអំពីហេតុ ២ប្រការគឺ ៖

-ជនជាតិរ៉ូមមានអំណាចគ្រប់គ្រងជ្វីហ្វ ក្នុងពេលនោះមិនពេញចិត្ត នេះប្រការមួយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥៦)

-បណ្ដាពួកអ្នកព្រតជ្វីហ្វ នាំគ្នាច្រណែនឈ្នានីសសេចក្ដីល្អរបស់ព្រះយេស៊ូដោយខ្លាចថា ព្រះយេស៊ូមក ប្រកាសសាសនាដណ្ដើមយកសាវ័ករបស់ខ្លួនអស់ នេះប្រការមួយទៀត។

ទាំងពីរប្រការនេះ គឺហេតុអវសានរបស់ព្រះយេស៊ូ។

មកវគ្គខាងចុងនៃជីវិតរបស់ព្រះយេស៊ូ មានពួកមនុស្សក្រខ្សត់ មនុស្សឈឺនិងក្មេងៗបានចូលមកស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះយេស៊ូច្រើនឡើងៗ។ ក្នុងពេលនេះ ព្រះយេស៊ូបានប្រកាសលទ្ធិថ្មីថា ខ្លួនជាអ្នកនាំមនុស្សទាំងឡាយទៅកាន់អាណាចក្រនៃសួគ៌ ឬអាណាចក្រនៃព្រះជាម្ចាស់ ក្នុងទំនងថាខ្លួនឯងជាបុត្រឬជាតំណាងរបស់ព្រះជាម្ចាស់។ ពួកអ្នកព្រតជ្វីហ្វដទៃៗ ក៏កើតមានការមិនពេញចិត្តកាន់តែច្រើនឡើង បានតាំងខ្លួនជំទាស់ព្រះយេស៊ូថា យេស៊ូមិនមែនមេស្សិអាហ៍ ដែលនឹងមកជួយជាតិជ្វីហ្វ តាមពាក្យទំនាយមានក្នុងគម្ពីរនោះទេ ព្រោះអ្នកនឹងមកជាមេស្សិអាហ៍តាមការគិត របស់ជនជាតិជ្វីហ្វបុរាណនោះ មេស្សិអាហ៍ត្រូវជាបុរស អ្នកប៉ិនប្រសប់ អង់អាចជាអ្នកចម្បាំង មិនទន់ខ្សោយមិនតែងខ្លួនអាក្រក់ដូចយ៉ាងព្រះយេស៊ូ ព្រះយេស៊ូជាអ្នកមិនមានឫទ្ធិ មានតេជៈនិងមិនមានលក្ខណៈដូច្នោះ ទើបមិនមែនជាអ្នកមកជួយលោកយើងឡើយ គឺគ្រាន់តែមកធ្វើឱ្យជនជាតិជ្វីហ្វបែកបាក់គ្នាប៉ុណ្ណោះ។

មួយវិញទៀត ការដែលព្រះយេស៊ូមកប្រៀនប្រដៅឱ្យមនុស្សមានមេត្តាករុណា ឱ្យអភ័យដល់សត្រូវនោះ ខុសសេចក្ដីនិយម ពួកអ្នកព្រតជ្វីហ្វប្រកាន់យកលេសធ្វើជាហេតុកម្ចាត់ព្រះយេស៊ូចេញ តាំងខ្លួនជាដើម ចោទប្ដឹងផ្ដល់សំអាងយកកំហុសមួយធ្ងន់ថា ព្រះយេស៊ូគិតតែពីជំនុំមនុស្សបង្កការចលាចលឡើង ដើម្បីរំដោះខ្លួនឱ្យផុតពីអំណាចរបស់ក្រុងរ៉ូម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥៧)

ព្រះយេស៊ូបានសម្ដែងធម៌របស់ខ្លួនជាដើមដំបូង ដោយការមេត្តាប្រណីដល់មនុស្សទាំងឡាយ ព្រះយេស៊ូជាអ្នកស្រឡាញ់ក្មេង ចូលទៅក្នុងភូមិស្រុកណា ពួកក្មេងៗក៏នាំគ្នាមកចោមរោមព័ទ្ធពីមុខពីក្រោយសូមនិទានរឿងឱ្យស្ដាប់ ខ្លះសូមឱ្យលេងជាមួយខ្លួន ព្រះយេស៊ូ

មិនដែលជំទាស់នឹងក្មេងៗទេ។ អាស្រ័យដោយការ ធ្លាប់ត្រាច់ចរមកច្រើន ព្រះយេស៊ូទើបជាអ្នកពូកែនិទានរឿង។ ក្មេងៗចូលចិត្តដើរតាមព្រះយេស៊ូទៅគ្រប់ទីកន្លែង សូម្បីតែថ្ងៃក្តៅកណ្តាលវាលខ្សាច់។ ព្រះយេស៊ូកំណត់ថា សេចក្តីស្រឡាញ់និងសេចក្តីមេត្តា ដែលមាននៅជាមួយក្មេងនិងមនុស្សទាំងឡាយ គឺជាស្ពានជួយឱ្យអាចទេសនាប្រៀនប្រដៅក្នុងពួកមនុស្សចាស់បានដោយងាយៗ ពួកក្មេងៗដែលស្រឡាញ់រាប់អានគេនឹងជួយឱ្យមនុស្សទាំងនោះចូលទៅដល់អាណាចក្ររបស់ព្រះជាម្ចាស់ (Kingdom of God) ដែលជាសេចក្តីសុខខ្ពស់បំផុតក្នុងជីវិត (Summum bonum) ឡើងបានតាមសេចក្តីបំណង។

**អវសាននៃជីវិត**

ក្រោយពីពេលបានទេសនាប្រៀនប្រដៅមនុស្ស និងអនុគ្រោះដល់អ្នកក្រខ្សត់ អ្នកទទួលនូវសេចក្តីទុក្ខលំបាក ការឈឺចាប់ និងអ្នកមិនមានទីពឹងខាងផ្លូវចិត្តមកជាលំដាប់ តាមឋានៈនៃសាស្តាដែលរកបានដោយកម្រក្នុងលោកប្រមាណបានត្រឹម ៣ឆ្នាំប៉ុណ្ណោះ ជីវិតរបស់សាស្តានេះ ក៏ដល់នូវទីអវសាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៥៨)

សម័យនោះ អាណាចក្ររ៉ូម៉ាំងមានក្រុងរ៉ូមជារាជធានី ជាទីប្រថាប់របស់អគ្គរាជាធិរាជរ៉ូម៉ាំងមកពីមុន ការរីកចម្រើននៃក្រុងរ៉ូម មានច្រើនជាងនគរដទៃៗ អ្នកបួសដឹកនាំផ្នែកគ្រិស្តសាសនា ក្នុងទីក្រុងរ៉ូមបានទទួលការគោរពរាប់អាន ដូចជាមេដឹកនាំធំរបស់ប្រជាជនទូទៅដែរ។ អគ្គរាជាធិរាជនៃប្រទេសជិតខាងទាំងឡាយនាំគ្នាថ្វាយអំណាចរបស់ខ្លួនក្នុងផ្លូវសាសនាឱ្យដល់អ្នកបួស ជាមេដឹកនាំនៅទីក្រុងរ៉ូម ព្រោះអាងថា តំណែងជាអ្នកដឹកនាំ គឺអ្នកបួសរាប់ថាជាតំណែងបន្តមកពីសេន្តពីតឺរ ឬជាជុំសិលាមួយដុំរបស់ព្រះយេស៊ូ ក្រុងរ៉ូមបានក្លាយទៅជាមជ្ឈមណ្ឌលរបស់គ្រិស្តសករាជ (ផ្នែករ៉ូម៉ាំងកាតូលិក) ដោយហេតុដូច្នេះឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៧៨)

សម័យនោះ អាណាចក្របែកចេញជា ២ផ្នែកគឺ ភាគខាងលិចមានក្រុងរ៉ូមជារាជធានី និងភាគខាងកើតមានក្រុងកុងស្តង់ទីណូបជារាជធានី (តាំងនៅក្នុងខេត្តហៅថា បៃសេន្តិន ជារបស់ក្រិកពីដើម) បណ្តាអ្នកបួសទាំងឡាយ ក្នុងភាគខាងកើតត្រូវឡើងមកមហាសង្ឃរាជភាគខាងលិចគឺ អគ្គសន្តប៉ាប៉ នៃក្រុងរ៉ូម សង្ឃរាជក្រុងរ៉ូមមានអំណាចច្រើន រហូតដល់ស្រវឹងនឹងអំណាចនោះ។ កន្លងមកដល់សម័យរាជាធិរាជក្រុងរ៉ូម ព្រះនាមថា វ៉ាលេតិនៀនបានប្រកាសប្រគល់អំណាចខ្ពង់ខ្ពស់ឱ្យដល់ព្រះសង្ឃរាជ តែទីប្រជុំរដ្ឋសភាមិនយល់ព្រម

ជាមួយ ព្រោះត្រូវការកាត់អំណាចព្រះសង្ឃរាជខាងក្រុងរ៉ូមចេញខ្លះ ទើបប្រកាសថា ឱ្យសង្ឃរាជទីក្រុងកុងស្តង់ទីណូប មានអំណាចស្មើនឹងសង្ឃរាជក្រុងរ៉ូម ព្រោះទីក្រុងកុងស្តង់ទីណូប ជារាជធានីនិងជាទីប្រថាប់របស់អគ្គរាជាធិរាជដូចគ្នា។

កាលបើមានប្រកាសនេះចេញហើយ សង្ឃរាជក្រុងកុងស្តង់ទីណូប ទើបមានអំណាចឡើង មិនព្រមទៅចំណុះសង្ឃរាជក្រុងរ៉ូម ឯពួកក្រុងរ៉ូមក៏មិនព្រមទទួលស្គាល់អំណាចរបស់ផ្នែកខាងកើតដែរ។ លុះផ្នែកនីមួយៗមិនព្រមចុះជាមួយគ្នា រឿងសាសនាក៏បែកបាក់គ្នា បែកចេញជានិកាយ កាតូលិក (Catholic) ផ្នែកខាងលិចនិងផ្នែកខាងកើតបែកចេញជានិកាយមួយទៀត មានឈ្មោះថា អ័រថូដក្ស (Orthodox) តមកមាន និកាយមួយទៀតដែលបែកចេញទៅពេលក្រោយ គឺនិកាយប្រូតេស្តង់ (Protestant) ដែលនឹងអធិប្បាយ ទៅខាងមុខ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៧៩)

### ការបែកខ្ញែកក្នុងសាសនា

ការបែកខ្ញែករបស់គ្រិស្តសាសនិកជន បើពិចារណាតាមហេតុការណ៍ក្នុងប្រវត្តិសាស្ត្រមាន ២ ប្រការគឺ ៖

ក-ការបែកបាក់មកពីការដណ្តើមអំណាចរវាងសង្ឃនាយកនៃក្រុងរ៉ូមចាស់ ផ្នែកអាណាចក្ររ៉ូមទិសខាងលិច និងសង្ឃរាជនាយកនៃរាជធានីក្រុងខនស្តែនតិនោបេល ភាគខាងកើត។

ការបែកបាក់នេះប្រព្រឹត្តទៅដោយអំណាចរដ្ឋសភារបស់ស្តេចវាលេតិនៀន ដែលបានប្រកាសឱ្យសង្ឃនាយកអគ្គថ្មីក្នុងក្រុងកុងស្តង់ទីណូប មានអំណាចស្មើនឹងសង្ឃ នាយកបិតនៅនាទីក្រុងរ៉ូម។ កាលបើសង្ឃនាយកនាទីក្រុងរ៉ូម មិនព្រមទទួលស្គាល់ប្រការនេះសាសនាគ្រិស្តទើបបែកចេញជា ២និកាយធំៗគឺ និកាយកាតូលិកពីដើម ឡើងទៅសង្ឃនាយកទីក្រុងរ៉ូមចាស់មួយពួក និងនិយាយអរ័ថដក្ស ឡើងទៅសង្ឃនាយកថ្មី នាទីក្រុងកុងស្តង់ទីណូបមួយផ្នែកទៀត បានសេចក្តីថា ការបែកចេញរបស់សាសនាក្នុងខនេះ កើតអំពីការ ដណ្តើមគ្នាធ្វើជាធំក្នុងលទ្ធិ។

ខ-ហេតុដែលនាំឱ្យបែកបាក់មួយទៀតគឺ ការបែកខ្ញែកកើតអំពីការប្រព្រឹត្តអានាចាររបស់សង្ឃក្នុងគ្រិស្តសាសនា មានការស្វែងរកអំណាច ការស្វែងរកផលប្រយោជន៍ផ្ទាល់

ខ្ជួន សមណៈមិនតាំងនៅក្នុងផ្លូវរបស់សមណៈ។ រឿងទាំងអស់នេះជាហេតុធំដែលធ្វើឱ្យគ្រិស្តសាសនា មាននិកាយធំឡើងមួយនិកាយទៀតគឺ ប្រូតេស្តង់ ប្រែថា ជាអ្នកជំទាស់។

ក្នុងទីនេះនឹងអធិប្បាយពីការប្រព្រឹត្តនិងគោលប្រតិបត្តិរបស់និកាយធំទាំង ៣ នោះដូចតទៅ ៖

**អ័រថដក្ស**

និកាយអ័រថូ មានអ្នករាប់អានច្រើនក្នុងប្រទេសក្រិក ប្រទេសយូហ្គោស្លាវី ប៊ុលហ្គារី រុស្ស៊ី និងមានទីតាំង ជាគ្រឹះនៅខ្លះ ក្នុងក្រុងកុងស្តង់ទីណូប ជាអាណាចក្រមួយផ្នែក របស់រ៉ូម៉ាំង នាទិសខាងកើតមកពីដើម (ក្នុងប្រទេសទួរគីបច្ចុប្បន្ន)។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ២ ទំព័រ៨០)

ពាក្យថា Orthodox (អ័រថូដក្ស) មកអំពី អ័រថូស (Orthos) ជាពាក្យក្រិកប្រែថា សច្ចធម៌ ឬសេចក្តីទៀងត្រង់ផ្សំនឹងពាក្យថា Doxa ជាពាក្យក្រិកដូចគ្នា ប្រែថា សទ្ធា សេចក្តីជឿ មានន័យថា ការជឿកាន់តាមបញ្ញត្តិដ៏ពិតប្រាកដក្នុងព្រះគម្ពីរ (ដើម)។

ប្រវត្តិរបស់អ័រថូដក្ស មកអំពីលទ្ធិដ៏តឹងរឹងក្នុងផែនដី ដែលជាកន្លែងកើតសាសនាគឺ ប៉ាឡេស្ទីន លុះព្រះយេស៊ូអស់ជីវិតហើយប្រមាណ ២ខែ សិស្សម្នាក់របស់ព្រះយេស៊ូ គឺ ពីតឺរ៍ (ប្រេតូ) និងសាវ័កព្រះយេស៊ូកើតឡើងក្រោយម្នាក់ទៀតគឺ ប៉ូល (ប៉ៅឡោ) ដូចដែលមាននាមមកពីខាងដើមធ្វើដំណើរប្រៀនប្រដៅសាសនា នៅក្នុងទីផ្សេងៗរហូតដល់ក្រុងរ៉ូម អស់ជីវិតក្នុងក្រុងរ៉ូមសម័យចក្រពត្តិនីរោ។ ពាក្យប្រដៅរបស់ពីតឺរ៍ តាំងនៅយ៉ាងខ្ជាប់ខ្ជួនក្នុងទីក្រុងរ៉ូម ធ្វើឱ្យក្រុងរ៉ូមជាមជ្ឈមណ្ឌលរបស់គ្រិស្តសាសនិក (រ៉ូម៉ាំង) កាតូលិក នៅក្នុងបច្ចុប្បន្ន ដូចបានរៀបរាប់មកហើយ។

ចំណែកខាងរបស់ប៉ូល ជាផ្នែកអ័រថូដក្ស តាំងមូលដ្ឋាននៅឯភ្នំអាថូស ក្នុងប្រទេសក្រិក (មហាវិហារ សេន្តប៉ូល ក្នុងប្រទេសអង់គ្លេស សាងឧទ្ទិសដល់សាវ័ករូបនេះ)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨១)

អាថូស (Athos) តាំងនៅលើជ្រោយប្រទេសក្រិក ត្រង់កន្លែងហៅថា ឆាលស៊ីឌិក្ស (Chalcidice) ជាបរិវេណនៃជ្រលងភ្នំធំ ឃ្លាតឆ្ងាយវាលល្វឹងល្វើយ ជ្រលងភ្នំនោះលយចូលទៅក្នុងសមុទ្រអ៊ីយ៉ៀន ជាប់បន្ត មកពីសមុទ្រមេឌីតេរ៉ាណេ។ អាថូសជាភាសាក្រិក តាមការស្មាន បានមកពីនាមរបស់សេន្តអាថានាសិអុស លោកជាមហាសាសនាចារ្យនៃក្រិក សម័យដែលសាវ័ករបស់គាត់ចូលមកយកទីកន្លែងត្រង់នេះ ជាទីកន្លែងសម្រាប់សំណាក់ធម៌ ក្នុង

សម័យសតវត្សទី១០នៃគ្រិស្តសករាជ។ ក្នុងបច្ចុប្បន្នអាថូសក្លាយជាមជ្ឈមណ្ឌលធំ របស់បណ្តាអ្នកត្រូវការសេចក្តីស្ងប់ មានវិហារអ័រថូដក់ធំៗនៅប្រហែលជា ២០វិហារ មានអ្នកព្រតអ័រថូដក់មួយចំនួនហៅថា ស៊ីណូប៊ិត (Cenobite) គឺអ្នកព្រតបំពេញព្យាយាមតែឯក ឯងនៅតែក្នុងវិហារ។ មានវិហាររបស់អ្នកព្រតប្រភេទយកការបរិកម្ម ដើម្បីទទួលពរពីព្រះជាម្ចាស់ប្រហែល ៩កន្លែង មានអ្នកព្រតជា ច្រើនជាតិជាអាទិ៍ ប៊ុលហ្គារី រូស្ស៊ី ដែលច្រើនបំផុតគឺអ្នកព្រតក្រិក មានបម្រាមថា ស្រីហាមមិនឱ្យចូលទៅក្នុងបរិវេណអាថូស។

លោកសាសនាចារ្យ អាជានាសិអុស មានអាយុរស់នៅក្នុងរវាងព.ស.៨៣៩-៩១១ ជាប៊ិសប(ចៅអធិការ)នៃក្រុងអាឡិកហ្សង់ឌ្រៀដែលជារបស់ក្រិកក្នុងពេលនោះ ជាសាសនាចារ្យធំរបស់អាឡិកហ្សង់ដ្រីមហារាជបានដាក់គោលការណ៍សាសនារបស់ខ្លួនទុកថា ការរាប់អាននិងប្រតិបត្តិណាៗដែលប្រព្រឹត្តទៅតាមព្រះបំណាងរបស់សាស្តាយេស៊ូ ត្រូវកាន់យកតាមបែបបទសារ័កសំខាន់ៗរបស់ព្រះយេស៊ូបានប្រតិបត្តិមកហើយ (Apostles Creed) និងប្រតិបត្តិយកតាមចិត្តចង់ (Ecunermical Greed) ដូចដែលសាស្តាចារ្យដទៃៗ ប្រកាសនោះ មិនបានឡើយ។

តាំងអំពីនោះមក ភ្នំអាថូសក្លាយទៅជាទីស្ថានស័ក្តិសិទ្ធិខាងផ្លូវសាសនា អាថូសធ្លាប់ជាភ្នំខ្ពស់ស្ងប់ស្ងាត់ ល្បីងល្បើងជម្មតា បានក្លាយជា Holy Athos តាមនាមរបស់លោកសាសនាចារ្យ អាជានាសិអុស មកតាំងពីពេលនោះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨២)

## សទ្ធារបស់អ័រថូដក់

សទ្ធារបស់ពួកអ័រថូដក់(ខុសពីផ្នែកកាតូលិក) ដែលគួរកំណត់ពីដើមមក មានដូច្នេះ៖

១-បាបទាំងឡាយដែលបុព្វបុរស មនុស្សដើមដំបូងនៃលោកគឺ អាដាម មាននាមប្រាកដក្នុងគម្ពីរចាស់ បានប្រព្រឹត្តល្មើសពាក្យបញ្ជារបស់ព្រះជាម្ចាស់នោះ ជាបាបធ្លាក់មកលើមនុស្សទាំងឡាយផងដោយអធិប្បាយថា មនុស្សគ្រប់គ្នាជាអ្នកមានបាប។

២-អ្នកដែលនឹងផុតពីបាបទាំងនេះបាន ត្រូវអាស្រ័យព្រះករុណារបស់ព្រះជាម្ចាស់។

៣-អ្នកមានសទ្ធា នឹងធ្វើអ្វីតាមចិត្តខ្លួនចង់ពុំបានត្រូវធ្វើតាមបញ្ញត្តិ។

*៤-វិហារទាំងឡាយដែលជាទីបំពេញព្រតនោះ គឺអាណាចក្ររបស់ព្រះជាម្ចាស់* (Kingdom of God) *មានន័យថា អាណាចក្ររបស់ព្រះជាម្ចាស់ មិនមែននៅឋានសួគ៌ ដូចកាតូលិកយល់នោះទេ។*

*៥-ឱ្យជឿថា សេចក្តីសុខឬសេចក្តីទុក្ខរបស់មនុស្ស ព្រះជាម្ចាស់ជាអ្នកកំណត់ (មុនថ្ងៃលោកនេះរលាយ អស់ទៅវិញតាម* (Doctrine of Predestination) *ព្រះជាម្ចាស់នោះ ទ្រង់ជានិរន្តរ៍ ពេលក្រោយមកពាក្យប្រៀនប្រដៅ បានផ្លាស់ប្តូរទៅជាបាបបុណ្យ គុណទោសដែលអាចអស់ទៅបានពេលធ្វើពិធីសីលជ្រមុជទឹក គឺស្មើគ្នានឹងពេលចូលពិធីប្រកាស ជាគ្រិស្តសាសនិកជន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨៣)*

*អាជានាសីអុល ជាបុគ្គលបឋមហេតុធ្វើឱ្យជ្រលងភ្នំអាថូលទៅជាមជ្ឈមណ្ឌលរបស់អ័រថូដក្ស គ្រិស្តសាសនិកទទួលស្គាល់ថា ជាអ្នកប្រកាសលទ្ធិព្រះជាម្ចាស់ខ្ពង់ខ្ពស់បំផុត (យេហូវ៉ា) ជាព្រះវរបិតានិងព្រះយេស៊ូ (ព្រះបុត្រ) តែមួយជាមួយគ្នា ទាំងភាវៈនិងព្រះកិត្តិគុណ។ ដូច្នេះ ការលោះលាបាបរបស់មនុស្សសំដៅយកត្រង់ត្រឹមតែព្រះយេស៊ូ (មនុស្សធម្មតា) ដែលជាមនុស្សនិងព្រះជាម្ចាស់ផង (ព្រោះមានភាវៈតែមួយនិងព្រះជាម្ចាស់) ក៏គ្រប់គ្រាន់ហើយ បុគ្គលមិនចាំបាច់ទៅសូមការលោះលាបាបពីពួកលោកសង្ឃ មិនពិបាកទៅបង់ថ្លៃលោះលាបាបឱ្យដល់អ្នកបួសណាឡើយ (តាមបែបកាតូលិក)។*

*ពួកកាតូលិកមិនពេញចិត្តពាក្យប្រដៅរបស់អាជានាសិអុល តាំងនាំគ្នាជំទាស់ដោយប្រតិបត្តិទៅតាមការយល់ឃើញដូចពីមុន បានប្រកាស វត្តត្រូវមានធរណីសង្ឃ វត្តត្រូវមានប្រាក់ចំណូល អ្នកណាចង់លោះលាបាបត្រូវមករកព្រះសង្ឃ (សន្តប៉ាប៉ា) ព្រោះលោកជាតំណាងរបស់ព្រះជាម្ចាស់ អ្នកមានអំណាចខ្ពង់ខ្ពស់ អ្នកណាមិនសេពគប់នឹងលោកសង្ឃ អ្នកនោះមិនអាចចូលទៅដល់ព្រះជាម្ចាស់បានឡើយ។ សេចក្តីប្រកាសនេះ បើកផ្លូវឱ្យបណ្តាអ្នកព្រតក្នុងនិកាយកាតូលិកជួយជាឱកាសឱ្យរកកម្រៃបានច្រើន ឧបាសក-សិកាចូលមករកលោកសង្ឃ ក៏ក្លាយទៅជាអ្នកវង្វេងក្នុងពាក្យបញ្ញត្តិ និងការប្រដៅរបស់ពួកលោកសង្ឃដែលបំណងប្រកបមុខរបរទាំងនេះផងដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨៤)*

*ពពួកគ្រិស្តដែលជំទាស់នឹងពាក្យប្រដៅរបស់អាជានាសិអុល ក្នុងពេលនោះមានមួយក្រុមទៀតប្រកាសដោយសាសនាចារ្យឈ្មោះ អារិអុស (ព.ស.៧៩៩-៨៧៩) លោកនេះបដិសេធ "ភាវៈព្រះជាម្ចាស់" របស់ព្រះយេស៊ូថា យេស៊ូគ្រាន់តែជាមនុស្សធម្មតាសាមញ្ញ*

ប៉ុណ្ណោះ ភាវៈនៃព្រះជាម្ចាស់រមែងមាននៅក្នុងព្រះជាម្ចាស់តែមួយអង្គ ពាក្យប្រៀនប្រដៅរបស់អារិអុស មិនបានទទួលការរាប់អានយូរអង្វែងទេ បានសាបសូន្យទៅ ប្រមាណសតវត្សទី៨ នៃគ្រិស្តសករាជ។

ក្រុមរបស់អ័រថូដក្សដែលទំនាក់ទំនងជាលំដាប់តមកនឹងពាក្យប្រកាសរបស់សាសនាចារ្យអាធានាសិអុស គួរលើកយកមកពោលក្នុងទីនេះមាន ២ក្រុម និងតស៊ូជាមួយពួកកាតូលិកបានគឺ ៖

ក្រុមក្នូស្ទិក (Cnostic) ក្រុមនេះមានជំនឿលើរឿងព្រះជាម្ចាស់បែកចេញជា ២ភាវៈគឺមួយភាវៈបាន ដល់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ ជាព្រះជាម្ចាស់នៃសេចក្តីល្អមួយព្រះអង្គ ភាវៈមួយទៀត បានដល់ព្រះជាម្ចាស់ខាងអាក្រក់ (សេចក្តីល្អនិងសេចក្តីអាក្រក់) បដិសេធភាវៈជាមនុស្សធម្មតារបស់យេស៊ូប្រកាសថា (ព្រះយេស៊ូ ជាអវតារគឺដួងវិញ្ញាណ) បែងភាគចេញមកពីព្រះជាម្ចាស់ ទ្រង់ជាអ្នកមានអានុភាពដ៏ខ្ពង់ខ្ពស់មកឧប្បត្តិ ញុំាងពន្លឺឱ្យកើតឡើងដល់មនុស្សទូទៅ។

ក្រុមក្នូស្ទិក ជួយជាកម្លាំងអ័រថូដក្សច្រើន ក្នុងការរួបរួមគម្ពីរថ្មី (New Testament) និងអាងថា“ព្រះគម្ពីរ” ជារបស់សំខាន់ជាងគេ “វិហារ” កាលបើនិយាយពី “វិហារ” ត្រូវសំដៅយកព្រះគម្ពីរហើយអាងថា ក្រុមរបស់ខ្លួនជាក្រុមទទួលឱវាទត្រឹមត្រូវផ្ទាល់អំពីសាវ័កសំខាន់របស់យេស៊ូ (សេន្តពីតឺរ៍ និងប៉ូល) ដូច្នោះ ពាក្យប្រៀនប្រដៅក្នុងក្រុមរបស់ខ្លួនអាចរាប់ថាត្រឹមត្រូវពិតប្រាកដមែន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៨៥)

ក្រុមមួយទៀតឈ្មោះ គាធារី (Cathari) ឬ Albigenses កើតឡើងប្រហែលសតវត្សទី ១០ នៃគ្រិស្តសករាជ ក្រុមនេះគាំទ្រក្រុមក្នូស្ទិក ជួយគ្នានាំអ័រថូដក្សឆ្លងកាត់ប៉ូលការី ចូលទៅកាន់អឺរ៉ុបភាគខាងលិចបាន គាធារីមានជំនឿចំពោះព្រះជាម្ចាស់តែមួយ ក្នុងចក្រវាលប្រកបដោយភាវៈ២យ៉ាង គឺវត្ថុនិងធម៌ ឬ(សេចក្តីអាក្រក់និងល្អ) វត្ថុឬសេចក្តីអាក្រក់ សម្តែងចេញទៅជាការអត់ឃ្លាន ស្រេកឃ្លាន កាចសាហាវ ធម៌គឺ សេចក្តីល្អ សម្តែងចេញជាភាតរភាព សេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា។

ក្រុមគាធារីប្រកាសថា ៖

ប្រវត្តិរបស់ព្រះយេស៊ូ ដែលទាក់ទងនឹងអភិនិហារទាំងឡាយមានជាអាទិ៍ រឿងកើតពីគភ៌របស់ព្រះនាង មេរី អ្នកបរិសុទ្ធគ្គី (ដោយពុំមានស្វាមី) ការដែលព្រះយេស៊ូត្រូវឆ្កាងដោយ

ឈើឆ្កាង អស់ជីវិតហើយត្រឡប់រស់ឡើងវិញក្នុង ៣ថ្ងៃ ហើយព្រះជាម្ចាស់នាំឡើងឋានសួគ៌ (តាមគតិរបស់កាតូលិក) ទាំងនេះជារឿងយកជាការពុំបាន ព្រោះថាព្រះយេស៊ូជាមនុស្សធម្មតា ខុសគ្នាត្រង់ជាអ្នកមានព្រះវិញ្ញាណបរិសុទ្ធ ជាជាងមនុស្សធម្មតាសាមញ្ញប៉ុណ្ណោះ។ ជីវិតរបស់ព្រះអង្គជាជីវិតគំរូឱ្យសាមញ្ញជនទាំងឡាយព្យាយាមធ្វើសេចក្ដីល្អ និងការលះបង់ដូចព្រះអង្គ មិនមែនទ្រង់ឧប្បត្តិមកដើម្បីលោះលាបាប (ដែលមនុស្សទាំងឡាយធ្វើទុក្ខ) ឱ្យបាត់ទៅនោះទេ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៨៦)

ក្រុមគាធារី ប្រកាសតទៅទៀតថា ដួងវិញ្ញាណរបស់មនុស្សធ្លាក់នៅក្នុងច្បាប់នៃការវិលវល់កើតស្លាប់ ជីវិតមានវេន្ធង់របស់ខ្លួន ដួងវិញ្ញាណទាំងនោះអស់ការវិលវល់ទៅបាន (ស្រេចតែអំពើរបស់ខ្លួន) កាលណាអស់កពនេះទៅហើយ ឬក៏មិនអាចត្រឡប់មកក្រោយវិញ ពីការវិលកើតវិលស្លាប់ម្ដងទៀតនោះបានឡើយ។

គាធារីបដិសេធជំនឿក្នុងអំណាចនៃពិធីកម្មដែលជាអាមិស ការប្រើគ្រឿងក្រអូបជាពលីបូជាក្ដី ការប្រើឈើឆ្កាងជាគ្រឿងសំគាល់នៃការគោរពក្ដី ការបូជាបដិមាករណាៗក្ដី ការប្រកបពិធីជ្រមុជទឹកឱ្យដល់ទារកនិងរហូតដល់មានជំនឿថា របស់គ្រប់យ៉ាងនៅមាននិងពិសោធន៍បាន ដោយអំណាចព្រះជាម្ចាស់ (Doctrine of Transubstantion) ពួកគាធារីឃើញជាវត្ថុមិនមែនធម៌បដិសេធទាំងអស់។

សាសនិកគាធារីបែងចែកជា ២ពួក តាមថ្នាក់នៃការប្រតិបត្តិ មួយពួកជាអ្នកបួសប្រតិបត្តិយ៉ាងតឹងរ៉ឹង មួយពួកទៀតជាប្រភេទឧបាសកឬសាវ័កអ្នកប្រតិបត្តិក្នុងថ្នាក់ទាប។ បើអ្នកប្រតិបត្តិប្រាថ្នាធម៌ជាន់ខ្ពស់ ត្រូវប្ដេជ្ញាខ្លួនលះបង់វៀរចាករកមាសប្រាក់មកចិញ្ចឹមជីវិត វៀរចាកការសម្លាប់ វៀរចាករបស់នាំឱ្យឈ្លក់វង្វេង វៀរចាកការបរិភោគសាច់សត្វ មិនបរិភោគទឹកដោះ ខ្លាញ់និងពង និងត្រូវមានជីវិតដោយប្រព្រឹត្តព្រហ្មចារ្យ មិនទាក់ទងដោយកាមគុណ។

បញ្ញត្តិទាំងនេះ ពិបាកនឹងរកអ្នកប្រតិបត្តិតាម។ អ្នកប្រតិបត្តិតាមសីលទាំងនេះ បើជាសាសនិកធម្មតា រមែងប្ដេជ្ញាខ្លួនពេលជិតនឹងស្លាប់ ហេតុនេះទើបមានបញ្ញត្តិដើម្បីជួយសង្គ្រោះមនុស្សជិតស្លាប់ទុកថា ការសម្លាប់ខ្លួនឯងអនុញ្ញាតឱ្យធ្វើបាន ក្រោយពីបានប្ដេជ្ញាខ្លួនរក្សាសីលទាំងនេះបរិបូណ៌ហើយ (Consolamentum) មុនពេលចិត្តរលត់ទៅ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័៨៧)

មួយក្រុមទៀតរបស់អ័រថូដក្សដែលបដិសេធការប្រព្រឹត្តឃ្លាតចេញក្រៅពីព្រះបញ្ញត្តិរបស់ពួករ៉ូម៉ាំងកាតូលិកយ៉ាងខ្លាំង គឺក្រុមរបស់លោកសាសនាចារ្យ ពីតឺវ៉ាល់ដូ (Peterwaldo) លោកនេះតាំងក្រុមប្រឆាំងកាតូលិកឡើង ក្នុងក្រុងលីយ៉ុងប្រទេសបារាំង (ព.ស.១៧១៣) វ៉ាល់ដូរប្រតិបត្តិធម៌នៅជាមួយផ្នែកកាតូលិកក្នុងទីក្រុងរ៉ូម ឃើញពួកការឌីណាល់ (មេគណៈមណ្ឌល) និងសន្តប៉ាប៉ាប្រព្រឹត្តខុសបែបបទ ក៏ឈ្លោះទាស់ទែងគ្នា ត្រូវបញ្ចូជនីយកម្ម (បណ្ដេញចេញ) ពីក្រុងវ៉ាល់ដូ ព្រមដើរចេញនិងចេញមកផ្សព្វផ្សាយលទ្ធិរបស់ខ្លួន។

វ៉ាល់ដូ ប្រកាសថា ៖

ក-ព្រះគម្ពីរ រមែងស័ក្តិសិទ្ធិជាងអង្គសន្តប៉ាប៉ា

ខ-អំណាចរបស់សន្តប៉ាប៉ា ឬអំណាចរបស់សង្ឃ មណ្ឌលកាតូលិកខុសបញ្ញត្តិ

គ-សន្តប៉ាប៉ា មិនអាចបើកទ្វារសួគ៌ឱ្យអ្នកណាបានឡើយ

ឃ-ការប្រតិបត្តិសេចក្ដីល្អ មានការសំខាន់ជាងការចូលបួសតាមពិធី

ង-ពាក្យប្រដៅដែលកំណត់ថា មានទីស្ថានជម្រះបាប (Purgatory) ចងចាំដូងវិញ្ញាណនៅខាងមុខនោះ មិនពិតទេ។

ច-ការធ្វើពិធីបញ្ជូនដួងវិញ្ញាណមនុស្សស្លាប់ (Mass) មិនអាចប្រើបាន

ឆ-ការអង្វរករឱ្យអ្នកមានបុណ្យណាមកជួយនោះ មិនអាចប្រើបាន

ជ-អ្នកព្រតដែលល្អ ត្រូវរស់នៅដោយសន្ដោស និងមេត្តាករុណា

ឈ-ពិធីកម្មដ៏ខ្ជះខ្ជាយ (របស់កាតូលិក) ជារឿងរបស់អ្នកប្រតិបត្តិធម៌។

ចំណែកកាតូលិក បានទទួលអំណាចពីខាងអាណាចក្រ និងមានពួកខ្លាចផ្ដាក់នរកជុំវិញពីក្រោយ ទើបនាំគ្នាតតាំងនូវអំពើរបស់អ័រថូដក្សគ្រប់ក្រុម អ័រថូដក្សត្រូវប្រាទចេញថា "ក្រៅសាសនា" ខ្លះ ត្រូវអំណាចកាតូលិកគាបសង្កត់ខ្លះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ ២ ទំព័រ៨៨)

ក្នុងព.ស.១៧៥២ សន្តប៉ាប៉ានៃក្រុងរ៉ូម ប្រកាសសង្គ្រាមសាសនា (Crusade) នឹងពួកក្រៅសាសនា ហើយតាំងតុលាការសង្ឃ (Inquistion) ឡើង។ ក្នុងប្រទេសអេស្ប៉ាញតុលាការសង្ឃនេះ មាននាទីរង់ចាំស៊ើប អង្កេតពួកអ័រថូដក្ស ចាប់មកដាក់ទោសយ៉ាងធ្ងន់។ តាំងគោលបំណងថា "ពួកក្រៅសាសនាណាមិនសារភាព បាបចំពោះសង្ឃកាតូលិក ពួក

ក្រៅសាសនាណាមិនជឿដល់ព្រះវិញ្ញាណដ៏បរិសុទ្ធតាមលទ្ធិកាតូលិក ឱ្យដូនវិញ្ញាណរបស់អ្នកនោះមកជារបស់សម្រាប់លាងបាប”។

ការយកដូនវិញ្ញាណមកធ្វើជារបស់លាងបាប តុលាការលោកតាកូលិកធ្វើទុក្ខទារុណកម្មច្រើន តាមការតំណាលរបស់គ្រិស្តសាសនា ដែលសម្តែងទុកមកដូច្នេះថា ៖

“ឱ្យយកខ្លួនមកសាកសួរជាមុនសិន ឱ្យប្តូរសាសនាចេញ បើប្តូរបាននឹងដោះលែងទៅវិញ បើមិនព្រមប្តូរឱ្យប្រើវិធីគម្រាមកំហែង គ្រាដំបូងឱ្យប្រើវិធីករុណា បន្ទាប់មកធ្វើឱ្យលំបាកខ្លួនបង្អត់អាហារ យកប្រដាប់មកទាញដៃនិងជើងទាញឱ្យតឹងហើយ ទាញរហូតដល់សណ្តាកឆ្អឹងចេញពីគ្នា។ មានវិធីមួយទៀតឱ្យចងកដៃទាំងពីរ ចងខ្សែយោងទៅពិដានទាញឱ្យផុតពីក្តារ ១ទៅ២ធ្នាប់ រហូតទាល់តែពួក “ក្រៅសាសនា” ទទួលសារភាព។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៨៩)

តុលាការលោកកាតូលិកប្រទេសខ្លះ ផ្លាស់វិធីធ្វើឱ្យលំបាក គឺប្រើវិធីវាយ ឬគប់លើក្រចកខ្លះ យកដែកដុតក្រហមទៅសង្កត់លើអវៈយវៈកន្លែងណាមួយ។ តុលាការកន្លែងខ្លះទៀតមានការអាណិតបន្តិចបន្តួចគឺយក “មនុស្សក្រៅសាសនា” មកពីទីឃុំឃាំងបង្គាប់ឱ្យចូលធ្វើពិធីបញ្ជូនដូនវិញ្ញាណអ្នកស្លាប់ (Mass) ខ្លះបណ្តើរទៅស្រែកអាក្រាស តាមទីកន្លែងផ្សេងៗ ខ្លះ អ្នកខ្លះត្រូវបង្គាប់ឱ្យចងព្យួរសញ្ញាឈើឆ្កាង ពណ៌លឿងឱ្យត្រាច់ចរទៅកាន់ទីផ្សេងៗ ទៅតាមទីកន្លែងកំណត់ឱ្យដើរ ដើម្បីបង្ខំឱ្យជ្រះថ្លានិងចងចាំទុក។

វិធីផ្សព្វផ្សាយរបស់ផ្នែកកាតូលិក ដោយការគាបសង្កត់ដូច្នេះ ដោយមានបំណងសងគំនុំច្រើនជាងធ្វើឱ្យកើតសទ្ធា ពួកលោកសង្ឃកាតូលិកធ្វើបានតាមអំពើចិត្ត ព្រោះអ្នករដ្ឋការជួយជ្រោមជ្រែងឬព្រោះអ្នកគ្រប់គ្រងប្រទេសធ្លាក់នៅក្រោមអំណាចរបស់លោកសង្ឃ។

ទារុណកម្មទាំងឡាយ ផ្នែកកាតូលិកធ្វើចំពោះអ័រថូដក្សជាច្រើនរយឆ្នាំ ទើបសន្សឹមៗអស់ទៅវិញ។ កាលបើមានសាសនាចារ្យសំខាន់ម្នាក់របស់កាតូលិកកើតឡើងមក គឺលោកហ្វ្រាំងស៊ីស្កាន់ ជាកាតូលិកមាន មេត្តាធម៌ ប្រើវិធីប្រៀនប្រដៅមេត្តាជួយឱ្យកាតូលិកដទៃៗកើតមានការខ្មាសអៀន លើកលែងឈប់ធ្វើទារុណកម្មទៅបាន នៅពេលចុងក្រោយ ទោះបីយ៉ាងនេះក្តី អំណាចរបស់លោកសង្ឃកាតូលិក ក៏នៅមានលើសជាងអំណាចអាណាចក្រដដែល។

មកដល់សម័យកណ្ដាល ប្រមាណសតវត្សរ៍ទី១៤ នៃគ្រិស្ដសករាជផ្នែកសង្ឃមណ្ឌលកាតូលិកបានកែប្រែខ្លួនឯងឱ្យកាន់តែល្អឡើងទៀត ការធ្វើទារុណកម្មក៏អស់ទៅ ប៉ុន្តែនៅប្រកាន់ថា វត្តត្រូវមានប្រាក់ចំណូល វត្តត្រូវមាន "ធរណីសង្ឃ" ដើម្បីរកចំណូលបានសន្តប៉ាប៉ាត្រូវជាអ្នកតំណាងព្រះជាម្ចាស់ដោយត្រង់តែម្នាក់ឯងដូចពីពេលមុនៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩០)

ជាថែជន្យខាងប្រទេសអាល្លឺម៉ង់ មានសាសនាចារ្យសំខាន់ម្នាក់ បានកើតឡើងមកតតាំងការប្រព្រឹត្តខុសបែបបទរបស់កាតូលិកគឺ ម៉ារទិន លូធ័រ (នឹងនិយាយទៅខាងមុខ) លោកនេះបានបំបែកចេញ ទៅតាំងនិកាយប្រូតេស្តង់សម្រាប់ជំទាស់ ដើម្បីឱ្យផ្នែកកាតូលិកដឹងខ្លួនខ្លាចបាប ពង្រឹងខ្លួនឯងបានរឹងប៉ឹងច្រើន ដោយដាក់បទបញ្ញា ៖

១-បង្ខំមនុស្សឲ្យចូលមកជាគ្រិស្ដសាសនិក (ទំនងដូចកេណ្ឌទាហាន)ៗ

២-វត្តត្រូវមានចំណូលពីអ្នកមានសទ្ធា ពីអ្នកជួលដីវត្ត និងពីការចាត់ពិធីផ្សេងៗ បានជាចំណូលទុកជាទ្រព្យសម្បត្តិរបស់វត្តៗ

៣-វត្តជាអង្គការស័ក្តិសិទ្ធិមួយ អ្នកណានឹងមកជំពាក់ជំពិនមិនបានៗ

៤-សន្តប៉ាប៉ា មានអំណាចខាងផ្លូវច្បាប់គ្រប់យ៉ាងៗ

៥-អំណាចតុលាការ ការដាក់ទោស កំណើត រៀបមង្គលការ និងពិធីកម្មគ្រប់បែបវត្តជាអ្នកចាត់ការទាំងអស់ៗ

អំណាចរបស់លោកសង្ឃកាតូលិកនេះ មានរហូតមកដល់សតវត្សទី១៦ នៃគ្រិស្ដសករាជៗ

ក្រុមអ្នកព្រតប្រតិបត្តិធម៌ បដិសេធសេចក្ដីប្រព្រឹត្តខុសបែបបទ និងលំអៀងទៅក្នុងផ្លូវលោកិយ៍ នៃផ្នែកកាតូលិកដូចបានពោលពីខាងដើម ជាអ័រថូដក្សទាំងអស់ៗ

អ័រថូដក្សគ្រប់និកាយ គ្រប់ក្រុម លុះផុតគ្រិស្ដសតវត្សទី១៦ មានខ្លះនៅរួមគ្នា ប៉ុន្តែពួកបែកចេញជានិកាយតូចៗមានច្រើន សាខាធំៗបែកចេញទៅគឺសាខាក្នុងក្រុងកុងស្តង់ទីណូប នៅអាឡិកហ្សង់ដ្រៀ ក្នុងស៊ីរី អេហ្ស៊ីប ប៉ាឡេស្ទីន និងរុស្ស៊ី សាខាដែលធំបំផុតគឺ នៃសេន្ទិននៅប្រទេសក្រិក មានមជ្ឈមណ្ឌលឯជ្រលង ភ្នំអាថូស ដូចបានពិពណ៌នាមក ហើយៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩១)

សាខាសំខាន់មួយទៀតរបស់អ័រថូដក់ត្រគឺ សាខាផ្សាយចូលទៅប្រទេសរុស្ស៊ី សាខានេះប្រកាសបែកចេញជាឥស្សរៈ អំពីសាខាកុងស្តង់ទីណូប កាលពីគ.ស.១៩៩១ មុនដែលអាណាចក្រនៃសេទ្ទិនធ្លាក់ទៅនៅក្រោមអំណាចប្រទេសទួរគីៗ

អ័រថូដក់ប្រកាសគ្រប់គ្រងសាជាថ្មី អ្នកព្រតរបស់ខ្លួនជាសង្ឃមណ្ឌលមួយដោយឡែក បដិសេធការលើកតម្កើងយសស័ក្តិសន្តប៉ាប៉ាថា មិនមែនជាអ្នកតំណាងព្រះជាម្ចាស់ឡើយ និងពួកសង្ឃកាតូលិកមិនមែនជា អ្នកអាចធ្វើពិធីលុបលាងបាបឱ្យអ្នកណាបានដែរៗ

អ័រថូស ហៅអ្នកធំក្នុងសង្ឃមណ្ឌលរបស់ខ្លួនថា ប៉ាត់រិអាក៍ត ឬហៅខ្ញីថា អាក៍គប៊ិឆប (ជំនួសកាឌីណាល់របស់កាតូលិក) ជាលំដាប់ចុះមក អាក៍កប៊ិឆបអង្គនីមួយៗជាធំក្នុងនិកាយរបស់ខ្លួនមួយៗ និងប្រទេសមួយៗ ពុំមានមជ្ឈមណ្ឌលរួមគ្នា ដូចពួកកាតូលិកនាសំណាក់វ៉ាទិកង់ៗ

**ពិធីកម្មរបស់អ័រថូដក់**

កន្លែងត្រង់នេះ ចង់ជម្រាបបន្ថែមអំពីពិធីកម្មប្រការខ្លះៗ របស់គ្រិស្តសាសនានិកាយអ័រថូដក់ អាចជាគ្រឿងជួយឱ្យពិចារណាប្រៀបផ្ទឹម និងពិធីកម្មនៃនិកាយដទៃៗ តាមការគួរៗ ពិធីទាំងអស់នោះមាន ៖

ក-ពិធីធ្លងថ្ងៃកំណើតរបស់ព្រះម៉ែម៉ារី ជាអ្នកបរិសុទ្ធ (ថ្ងៃទី៨ កញ្ញា)ៗ

ខ-ពិធីបូជាឈើឆ្កាង ដែលប្រកាន់ថាជាបូជនីយវត្ថុស័ក្តិសិទ្ធិ (១៤ កញ្ញា)ៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩២)

គ-ពិធីប្រតិស្ឋានរូបព្រះម៉ែម៉ារី ជាអ្នកបរិសុទ្ធ (២១ វិច្ឆិកា)ៗ

ឃ-ពិធីធ្លងថ្ងៃប្រសូតិ របស់ព្រះយេស៊ូ (គ្រិស្តមាស ២៥ធ្នូ)

ង-ពិធីធ្លងថ្ងៃសីលជ្រមុជទឹករបស់ព្រះយេស៊ូ នៅទន្លេហ្សូរដាំង ហៅថា Epphany (៦មករា)

ច-ពិធីប្រតិស្ឋានព្រះរូបរបស់ព្រះយេស៊ូ ហៅ Candlemas (២ ឧសភា)

ឆ-ពិធីប្រកាសលើកតម្កើង ព្រះម៉ែម៉ារីជាអ្នកបរិសុទ្ធ ជាមាតារបស់ព្រះយេស៊ូ (ពួកកាតូលិកហៅថា Lady-day ២៥ មីនា)

ជ-ពិធីធ្លងថ្ងៃស្តេចចូលក្រុងយេរូសាលឹមនៃព្រះយេស៊ូ (ហៅម្យ៉ាងទៀតថា Palm Sunday) ធ្វើមុន មួយសប្តាហ៍ អ៊ិស្ទ័រ (Easter Day)

ឈ-ពិធីធ្វើថ្ងៃស្ដេចឡើងទៅកាន់ឋានសួគ៌របស់ព្រះយេស៊ូ (៤០ថ្ងៃ ខាងក្រោយថ្ងៃអ៊ិស្ទ័រ)។

ញ-ពិធីធ្វើការដែលស្ដេចចុះមកនៃព្រះវិញ្ញាណដ៏បរិសុទ្ធ ហៅថា Pentecost (៥០ថ្ងៃក្រោយពីថ្ងៃ អ៊ិស្ទ័រ ពួកកាតូលិកហៅថា White Sunday ពួកអ័រថូដក្ស ហៅថា Trinity Sunday)

ដ-ពិធីធ្វើការប្ដូរព្រះរាងកាយរបស់ព្រះយេស៊ូ (៦ សីហា)

ឋ-ពិធីធ្វើថ្ងៃ ដែលព្រះយេស៊ូនាំព្រះម៉ែឡើងឋានសួគ៌ (Assumption of the virgin) ថ្ងៃទី១០ ឬ ១៥ សីហា)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩៣)

ពិធីទាំងអស់នេះ ប្រកាន់ថាសំខាន់ក៏ពិតមែន តែមានការអនុញ្ញាតឱ្យប្ដូរកំណត់ថ្ងៃបានខ្លះប្រសិនបើមានការចាំបាច់ ក្រៅអំពីនោះនៅមានពិធីដែលពួកអ័រថូដក្សនិយមធ្វើគឺពិធីកាន់សីល (Circumcise) បកស្បែកលិង្គរបស់ព្រះយេស៊ូ ថ្ងៃទី១ មករា, ពិធីធ្វើថ្ងៃកំណើតរបស់សេន្តចន ថ្ងៃទី ២៤ មិថុនា, ពិធីធ្វើសេន្តពីត័រ និង សេន្តប៉ុល ថ្ងៃទី២៩ មិថុនា, ពិធីរំឭកថ្ងៃដែលសេន្តចនត្រូវប្រហារជីវិត ថ្ងៃទី ២៩សីហា, ពិធីធ្វើសេន្តនិគោលាស ថ្ងៃទី៦ធ្នូ, ពិធីធ្វើពេលជិតប្រសូត្ររបស់ព្រះម៉ែម៉ារីអ្នកបរិសុទ្ធ ថ្ងៃទី៩ធ្នូ, និងពិធីធ្វើឱ្យដល់សេន្តទាំងឡាយធ្វើនៅអាទិត្យដំបូង ខាងក្រោយថ្ងៃរិតសាន់ដេយ៍។

ក្រៅអំពីពិធីដូចបានពោលមកហើយពួកអ័រថូដក្ស នៅមានពិធីសីលអត់ (Fast) ដើម្បីបំពេញឱ្យចិត្ត គំនិតចូលរួមនៅជាមួយព្រះជាម្ចាស់ដោយអធិប្បាយថា ត្រូវធ្វើឱ្យរាងកាយទទួលការហ្វឹកហាត់និងមានរបៀបរៀបរយល្អ ធ្វើឱ្យដួងវិញ្ញាណស្ងប់ស្ងៀមតាមពាក្យប្រដៅដែលថា "ការអត់អាហារនិងការបញ្ចាខ្ជួនឯងបាន ជាគុណធម៌ដំបូង ជាមាតា ជាឫសកែវ និងជាទីតាំងនៃសេចក្ដីល្អទាំងឡាយ"។

ពិធីកាន់សីលអត់ ត្រូវធ្វើ ៤ឱកាស គឺ ៖

១-សីលអត់គ្រាដ៏ធំ (ចូលវស្សា) ចាប់ផ្ដើម ៧សប្ដាហ៍មុនថ្ងៃអ៊ិស្ទ័រ អត់រហូតទៅដល់ថ្ងៃអ៊ិស្ទ័រ។

២-សីលអត់ជាគ្រឿងរំឭក ដល់សិស្សសំខាន់ៗរបស់ព្រះយេស៊ូ ផ្ដើមតាំងពីថ្ងៃច័ន្ទ ៤ ថ្ងៃ ក្រោយអំពីពិធី រិតសាន់ដេយ៍ និងអស់នៅថ្ងៃទី ២៨ មិនា។

៣-សីលអត់ទទួលពិធីអស្សម៍សិន គឺមានពិធីធ្វើ ថ្ងៃដែលព្រះយេស៊ូនាំម្ដាយលោកឡើងឋានសួគ៌ តាំង ពីថ្ងៃទី១ ដល់ ១៤ សីហា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩៤)

៤-សីលអត់ទទួលថ្ងៃគ្រិស្តម៉ាស់ តាំងពីថ្ងៃទី១៥ វិច្ឆកា ដល់ ២៤ធ្នូ រួម ៤០ថ្ងៃ។

អ័រថូដក្ស អ្នកប្រកាន់តឹងតែង នៅមានការកាន់សីលអត់ក្នុងថ្ងៃពុធនិងថ្ងៃសុក្រ រាល់ថ្ងៃអ័រថូដក្ស និកាយខ្លះថែមថ្ងៃចន្ទ ១ថ្ងៃទៀត ប្រែថាក្នុង ៧ថ្ងៃ កាន់សីលអត់ ៣ថ្ងៃ រហូតមួយឆ្នាំ (ក្រៅអំពីក្នុងរវាងថ្ងៃ គ្រិស្តម៉ាស់ និងថ្ងៃទី៦ មករា ដែលជាថ្ងៃពិធីសីលជ្រមុជទឹករបស់ព្រះយេស៊ូ រវាងសប្តាហ៍នៃបុណ្យអ៊ិស្ទ័រ និង រវាងសប្តាហ៍ក្រោយថ្ងៃវិតសាន់ដេយ៍)។ ក្នុងពិធីបូជាឈើឆ្កាង ១៤ កញ្ញា ពិធីថ្ងៃរំឭកសេន្តចូនត្រូវប្រហារ ជីវិត ថ្ងៃទី ២៩ សីហា ហើយនឹងមុនថ្ងៃពិធីព្រះយេស៊ូកាន់សីលជ្រមុជទឹក ៦មករា ក៏កាន់ថាជាថ្ងៃសីលអត់ផងដែរ។

ក្នុងរវាងការកាន់សីលអត់ មានការធ្វើតឹងរ៉ឹងណាស់ ហាមមិនឱ្យបរិភោគសាច់សត្វ និងអាហារណាទាក់ទងសាច់សត្វដូចជា ពង ខ្លាញ់ ទឹកដោះជាដើម។ ការបរិភោគអាហារលាយជាមួយប្រេងនិងគ្រឿងត្រាំ ទឹកស្រវឹង ហាមជាដាច់ខាត។

**រ៉ូម៉ាំងកាតូលិក**

"កាតូលិក" ប្រែថា "សាកល" បានដល់បដិទានរបស់មនុស្សទូទៅ។ កាតូលិកតាំងឡើងជាអង្គការធំ ក្នុងលោកគ្រិស្តសាសនា ដោយកម្លាំងជំរុញខាងផ្លូវនយោបាយជួយជ្រោមជ្រែងផងនិងព្រោះសង្ឃមណ្ឌលមានអំណាចលើអ្នកនយោបាយមក តាំងពីរយៈសម័យដើមដំបូងនិងពាក់កណ្តាលសម័យនៃប្រវត្តិសាស្ត្រផង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំ ៩៥)

គតិនៃការរាប់អានមកពីខាងដើម ពួកកាតូលិកបំណងយកពាក្យប្រៀនប្រដៅនិងបដិបទាគ្រាដំបូងរបស់សេន្តពីត៏រ ដោយកាន់ថា សេន្តពីត៏រជាសាស្តាធំនិងជាអ្នកបន្តដោយផ្ទាល់ពីព្រះយេស៊ូ គឺទាញយកគោលការណ៍សំខាន់ៗ ដែលមាននៅឯវិហារសេន្តពីត៏រ ក្នុងសំណាក់វ៉ាទីកង់ នាក្រុងរ៉ូម។

កាតូលិកជាក្រុមធំ ក្នុងផ្លូវនយោបាយនិងសាសនា គ្របដណ្តប់ទូទៅទាំងពិភពលោកតាមហេតុផលនៃការប្រកាសធម៌ដោយវិធីបន្ធុំ ដោយការតាំងតុលាការសង្ឃ យកអំណាចខាងផ្លូវនយោបាយ ដែលខ្លួនគ្រប់គ្រង មកជាអាវុធក្នុងការផ្សព្វផ្សាយសាសនារបស់ខ្លួន ដូចបានពោលមកហើយ។

ក្នុងគ្រាសំខាន់បំផុត ដែលកាតូលិកផ្សាយចេញទៅយ៉ាងទូលំទូលាយ គឺចាប់ផ្តើមពីសតវត្សទី៤ នៃគ្រិស្តសករាជ រាជាធិរាជរ៉ូម៉ាំង២អង្គគឺ នាលេវិអ៊ុសនិងខនស្តែនទិន ជា

*ពិសេសខនស្ដែនទិន បានឈ្មោះថាអសោក របស់គ្រិស្តសាសនា ទ្រង់ផ្ដួងផ្ដើមពួកកាតូលិក គ្រប់មធ្យោបាយទ្រង់សាងវិហារពេងឧបោសថឧបការៈ ទំនុកបម្រុងសង្ឃមណ្ឌល កាតូលិក គ្រប់យ៉ាង ទ្រង់បានបញ្ជូនរាជបរិពារចេញទៅស៊ើបការណ៍ពីសាសនាដល់ទីក្រុង យេរូសាលឹម ឈើឆ្កាងដែលព្រះយេស៊ូត្រូវឆ្កាងមានន័យថាបានជួបប្រទះក្នុងសម័យរបស់ខនស្ដែន ទិន។*

*ខនស្ដែងទិន ត្រាស់ព្រះរាជបញ្ញត្តិមួយច្បាប់ឈ្មោះ "ច្បាប់មិលាន" ក្នុងព.ស.៨៥៦ ឱ្យអំណាចសន្តប៉ាប៉ា មានឋានន្តរស័ក្តិស្មើនឹងរាជាធិរាជរ៉ូម៉ាំងហាមរដ្ឋបាលមិន ឱ្យទារពន្ធពី វត្តជាធរណីសង្ឃ ឱ្យសង្ឃតាំងតុលាការ ជម្រះសេចក្ដីបានតាមអំពើចិត្ត។ អ្នកនៅក្នុងវត្តជាធរណីសង្ឃ មិនឱ្យអ្នករាជការទៅទាក់ទងទេ ទោះបីជាមានកំហុសក្ដី ទើបជាឱកាសបើកឱ្យមនុស្សខាងក្រៅរត់ចូលទៅនៅក្នុងពេលធ្វើខុស អ្នកនៅក្នុងវត្តខ្លះធ្វើខុសច្បាប់ តុលាការកាត់សេចក្ដីដាក់ទោស តែតុលាការសង្ឃមិនយល់ព្រមឱ្យដាក់ទោស រាជការមិនអាចដាក់ទោសបានឡើយ ប្រកាសឱ្យថ្ងៃអាទិត្យជាថ្ងៃសៈប៉ាតោ ជាថ្ងៃឱ្យអ្នករាជការឈប់ជាសាកល តាំងអំពីគ្រានោះមក។ លុះអស់សម័យរបស់ខនស្ដែនទិនផ្នែកក្រុមមិនពេញចិត្តនឹងអំណាចសង្ឃដូចជាពួកអ័រថូដក្ស និងពួកអាល្លឺម៉ង់ភាគខ្លះនាំគ្នាតទល់ ប៉ុន្តែមិនអាចទប់ទល់នឹងអំណាចរបស់ពួកកាតូលិកនេះបាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤៦)*

*កាលបើបានអំណាចហើយ ការចាយវាយខ្ជះខ្ជាយ សេចក្ដីសុខនិងការលំអខាងផ្លូវលោក ក៏កើតមានច្រើនក្នុងពួកកាតូលិក សន្តប៉ាប៉ា បង្គាប់ឱ្យតាក់តែងពេងឧបោសថ វិហារដោយសិល្បៈយ៉ាងប្រណីតដើម្បីលើកតម្កើងអំណាច។ តាំងអំពីនោះមក សន្តប៉ាប៉ាក៏ប្រកាសពាក្យប្រៀនប្រដៅ សំអាងអំណាចខ្លួនបានទទួលផ្ទាល់ពីព្រះជាម្ចាស់ អ្នកណាត្រូវការលុបលាងបាបឱ្យមករំដោះបាបនៅក្នុងវត្ត ការដែលលោកធ្វើពិធីសីលជ្រមុជទឹកម្ដងៗ អាចនឹងលាងបាបបានតាំងពីមុនៗមកទាំងអស់។*

*ខនស្ដែនទិន ជាអ្នកឧបត្ថម្ភចេញច្បាប់ជួយសង្គ្រោះកាតូលិកមួយទៀតក្នុង ព.ស. ៨៦៨ ឱ្យមនុស្សគ្រប់ គ្នាមានសទ្ធាខាងផ្លូវរាជការ គឺមិនត្រូវឱ្យមានសទ្ធាផ្សេងៗខុសអំពីច្បាប់បានប្រកាសនោះជាដាច់ខាត។ គម្ពីរទាំងអស់ត្រូវតែជាភាសាក្រិកនិងភាសាឡាតាំង អ្នកណាមានគម្ពីរទាំងនេះទុកនៅក្នុងផ្ទះរបស់ខ្លួន ត្រូវយកមកទុកក្នុងបណ្ណាល័យវត្ត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៤៧)*

សទ្ធាខាងផ្លូវរាជការ មានសេចក្ដីប្រាកដដូច្នេះ ៖

"យើងសូមសម្ដែងសទ្ធាចំពោះព្រះជាម្ចាស់តែមួយអង្គ ដែលជាព្រះបិតា (Father) ទ្រង់បានសាងរបស់សព្វសារពើ។ យើងសូមសម្ដែងសទ្ធាចំពោះព្រះយេស៊ូ ជាព្រះបុត្រ (Son) របស់ព្រះជាម្ចាស់នោះជាអ្នកតំណាងព្រះជាម្ចាស់ បានកើតមកទទួលទុក្ខដើម្បី លោះលាទុក្ខឱ្យដល់មនុស្សជាតិ ដោយការលះបង់សាច់ឈាម ព្រះអង្គអស់ជន្មាយុហើយ ស្ដេចឡើងទៅឋានសួគ៌ក្នុងថ្ងៃទី៣។ យើងសូមសម្ដែងសទ្ធាចំពោះព្រះចិត្ត (Holy Ghost ឬ Holy Spirit) របស់ព្រះអង្គ ដែលស្ដេចចូលមកដើម្បីពពួកមនុស្សទូទៅ។

ព្រោះតែសទ្ធាខាងផ្លូវរាជការនេះហើយ បានកំណត់ថា លទ្ធិត្រីនិធី (Trinity) ឬហៅថា គោលការណ៍ ត្រីឯកានុភាព បានកើតឡើងជាផ្លូវការតាំងពីគ្រានោះមក។

អាណាចក្ររ៉ូម៉ាំងកាតូលិក មានអំណាចទូលំទូលាយចេញទៅជាលំដាប់ ដោយមកពីហេតុផលច្រើនយ៉ាង។ ដើមដំបូងមនុស្សទាំងឡាយនាំគ្នាមានជំនឿថា មជ្ឈមណ្ឌលកាតូលិក មានសេន្ដពីតឺរ អគ្គសាវ័ករបស់ព្រះយេស៊ូជាអ្នកសាងដោយពាក្យ បញ្ជានិងការប្រគល់ ដោយផ្ទាល់ពីព្រះយេស៊ូ។ មួយវិញទៀត ព្រោះក្រុងរ៉ូម ជារាជធានីនៃអាណាចក្រគ្រិស្ដសាសនា ដោយអធិរាជរ៉ូម៉ាំង ព្រមទទួលយកកាតូលិក ជាសាសនារបស់រដ្ឋ អធិរាជរ៉ូម៉ាំង ទ្រង់ប្រកាសឱ្យប៉ាបលិអូទី១ (ព.ស.៩៨៣-១០០៤) ជានាយកនៃគ្រិស្ដសាសនាទូទៅក្នុងលោក តមកប៉ាបអង្គដទៃៗក៏កាន់អំណាចធំក្នុងលោកនៃគ្រិស្ដសាសនាមករហូតប្រវត្តិ-សាស្ត្រ របស់កាតូលិក។

ពេលមានអំណាចរបស់សង្ឃមណ្ឌលរ៉ូម៉ាំងកាតូលិក ជាពេលនៃការមានស្ដុកស្ដម្ភ និងពិធីកម្ម បើនិយាយម្យ៉ាងទៀតថា ពិធីកម្មធ្វើឱ្យមានស្ដុកស្ដម្ភនិងធ្វើឱ្យមានអំណាច។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩៨)

រឿងទាក់ទងនឹងពិធីកម្មផ្សេងៗនោះប្រព្រឹត្តទៅតាមបញ្ញត្តិនៃសង្ឃមណ្ឌល "អ្នកអាចទាក់ទងនឹងព្រះជាម្ចាស់ដោយត្រង់បាន" ជាលទ្ធិប្រតិបត្តិ (Sacrament) ដែលនៅគោរពប្រតិបត្តិ ៧ប្រការ និងមានលទ្ធិខ្លះកំពុងនាំគ្នាធ្វើគ្រប់និកាយគឺ ៖

១-ពិធីសីលជ្រមុជទឹក (Baptism) ហៅម្យ៉ាងទៀតថា ពិធីលាងបាបគតិដែល ប្រកាន់មកមានជំនឿថា មនុស្សគ្រប់រូបកើតមកមានបាន អំពីបាបរបស់អាដាមនិងអេវ៉ា មនុស្សគូដំបូងនៃលោកព្រះសាងឡើង ព្រោះល្មើសនិងពាក្យបញ្ជារបស់ព្រះជាម្ចាស់ បាបនោះឯង

រមែងធ្លាក់មកដល់មនុស្សគ្រប់គ្នា។ អ្នកចូលជាគ្រិស្តសាសនិកជន ត្រូវធ្វើពិធីសីលជ្រមុជទឹកជាមុនសិន កាលណាទៅជាអ្នកបរិសុទ្ធហើយ ទើបជាគ្រិស្តសាសនិកជនបាន។

កុមារកើតមកគ្រប់គ្នា ត្រូវតែឱ្យលោកធ្វើពិធីជ្រមុជទឹក មនុស្សចាស់ខ្លះធ្វើបាបអាក្រក់ ត្រូវចូលធ្វើពិធីជ្រមុជទឹកម្តងទៀត ដើម្បីលាងបាបដែលខ្លួនធ្វើ តាំងខ្លួនធ្វើសេចក្តីល្អតទៅជាថ្មី។

ពិធីសីលជ្រមុជទឹកធ្វើជាច្រើនបែប តាមនិកាយដែលបែកចេញទៅ មួយបែបពួកអ័រថូដក្សនិកាយរុស្ស៊ី ឱ្យកុមារកើតមកមិនកំណត់អាយុរកលោកលាបប្រេងឱ្យ (ភាគច្រើនជាប្រេងម្នាក់) លាបប្រេងហើយ លោកនាំកុមារចេញទៅធ្វើពិធីមុខវិហារម្តងទៀត មិនឱ្យ ឪពុកម្តាយចូលរួមពិធីនេះផងទេ។ លោកប្រាប់ថា "មាតាព្រះជាម្ចាស់" (God Mother) ជាអ្នកគ្រប់គ្រងកុមារនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ៩៨)

ពិធីជ្រមុជទឹកតាមធម្មតាធ្វើឱ្យក្មេងកំណត់អាយុក្នុងរវាងទី ៩-១៤ឆ្នាំ ដែលកំណត់អាយុដូច្នេះ ដោយទឹកប្រមាណថា ក្មេងមានការយល់ព្រះបញ្ញត្តិខ្លះហើយ។ ក្នុងពិធីនោះលោកបីក្មេងជ្រមុជទៅក្នុងចុងទឹក (មន្ត) ទាំងខ្លួនឬជួនកាលត្រឹមក្បាល បើមិនបានធ្វើក្នុងវិហារ នាំក្មេងទៅជ្រមុជក្នុងស្ទឹង ឬទន្លេក៏មាន។

វិធីមួយទៀត ហៅថា Congregation Baptism ជាពិធីជ្រមុជទឹកហៅថា "ចូលក្រុម" លោកឱ្យឪពុកម្តាយរបស់ក្មេងបីក្មេង បានយកទឹកមន្តក្នុងពាងប្រោះព្រំលើថ្ងាសរបស់ក្មេង ពោលថា "យើងក្នុងនាមរបស់ព្រះបិតា ព្រះបុត្រ និងព្រះចិត្ត ធ្វើពិធីសីលជ្រមុជទឹកឱ្យដល់អ្នក"។

វិធីមួយទៀត និកាយរ៉ូម៉ាំងកាតូលិកទូទៅ ឱ្យបិតាមាតាបីក្មេងហើយ លោកប្រទានពរដល់ក្មេងដោយវិធីយកអំបិលដាក់ក្នុងមាត់ ជាគ្រឿងសញ្ញានៃការមានបញ្ញាជាស្ថាពរ (ដូចអំបិលរក្សារសជាតិប្រៃ) លាបប្រេងនៅលើដើមទ្រូង និងខាងខ្នងក្មេងជាសញ្ញានៃការអត់ធន់រួចហើយយកប្រេងលាយជាមួយទឹកប្រោះទៅមកលើថ្ងាសរបស់ក្មេងជារូបឈើឆ្កាង។

ពិធីសីលជ្រមុជទឹកកាន់តាមសម្រាប់ពីសម័យព្រះយេស៊ូ ប្រគល់ខ្លួនធ្វើជាសិស្សរបស់ច្ចនបាបទិស្ត (John the Baptist) ពេលនោះព្រះយេស៊ូចូលពិធីសីលជ្រមុជទឹក ប្រកាសខ្លួនជាសិស្សរបស់ច្ចន និងទទួលសីល។

២-ពិធីពលំសីក (Confirmation) ឬលទ្ធិកម្ម ដើម្បីសម្តែងការមាំមួននៃចិត្ត ចំពោះព្រះចិត្តឬពិធីទទួលព្រះចិត្ត (Holy Ghost ឬ Holy Spirit) ឱ្យមកនៅក្នុងខ្លួន ធ្វើពេលក្រោយពីពិធីជ្រមុជទឹក លុបលាងកាយស្អាតហើយ ប្រដូចជាឱ្យសញ្ញាថា នឹងមានចិត្តមាំមួនតទៅ កំណត់ធ្វើរវាងអាយុ ៩ដល់១៤ឆ្នាំ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០០)

ពិធីរបស់និកាយរ៉ូម៉ាំងកាតូលិក លោកជាអ្នកធ្វើពិធីឱ្យ ដោយយកប្រេងម្កាក់ (ជួនកាលមានក្រមួនសុទ្ធផ្សំផង) យកមកលាបថ្ងាសជារូបឈើឆ្កាង លោកពោលពាក្យថា "យើងសូមឱ្យសីលដល់អ្នកដោយសញ្ញានេះ" មានប្រេងនិងក្រមួនសុទ្ធផ្សំ ដែលជាសញ្ញានៃការរំដោះទុក្ខ លុះស្រេចបាច់ហើយឱ្យពរថា "សេចក្តីសុខនឹងមានដល់អ្នក" ហើយយកដៃទះថ្ពាល់បន្តិចៗថ្នមៗ។

ក្នុងនិកាយប្រូតេស្តង់ត៍ ឱ្យអ្នកចូលពិធីអង្គុយលុតជង្គង់ត្រង់ពីមុខ ដៃស្តាំដាក់លើក្បាល ដៃឆ្វេងចាប់គម្ពីរអានជាសេចក្តីថា "ក្នុងនាមព្រះយេស៊ូជាម្ចាស់ ព្រះចិត្ត ស្តេចចូលមកសណ្ឋិតនិងចម្រើននៅក្នុងខ្លួនអ្នក" តអំពីនោះប្រកាសថា អ្នកចូលពិធីនោះជា សមាជិតរបស់ព្រះហើយ។

ពិធីនេះធ្វើតាមព្រះបញ្ញត្តិដែលប្រកាស (គម្ពីរប៊ិបចាស់ជំពូកព្រះបញ្ញត្តិ)ថា "នាឥឡូវនេះ កាលបើបណ្តាសាវ័ក ១២នាក់ (របស់ព្រះយេស៊ូ) បានជ្រាបថា ព្រមព្រៀងគ្នាទទួលព្រះវាចារបស់ព្រះអង្គហើយ បណ្តាសាវ័កទាំងនោះក៏បានប្រាប់ដល់ពីតឺរ៍ និងច្ហនថា ទ្រង់បានឱ្យពរដល់គេ ដើម្បីឱ្យគេបានទទួលព្រះចិត្ត ទ្រង់បានដាក់ដៃលើសិរសារបស់គេ និងគេក៏បានទទួលព្រះចិត្តហើយ"។

ពិធីពលំសីលនេះ និកាយអេពិស្កោប៉ាលរបស់អង់គ្លេសមិននិយមធ្វើទេ ពួកប្រូតេស្តង់បដិសេធជាដាច់ខាតតែម្តង និកាយខ្លះការចូលពលំសីលនេះស្មើនឹងការប្រកាសខ្លួនចូលទៅគ្រិស្តសាសនិកជនជំនួសពិធីជ្រមុជបាន ទើបមិនព្រមធ្វើពិធីជ្រមុជទឹកក៏មាន។

៣-ពិធីសីលសមសទ្ធា ភាសាអង់គ្លេសថា Communion ប្រែថា ការចូលនៅរួមជាមួយព្រះជាម្ចាស់ ពិធីនេះសេចក្តីបំណងដើម្បីឱ្យសាច់ឈាមយើងទាំងឡាយ និងសាច់ឈាមរបស់ព្រះយេស៊ូចូលគ្នាតែមួយ និយាយឱ្យងាយយល់ គឺការរួមគ្នាតែមួយនឹងព្រះជាម្ចាស់នោះឯង។ (ហេង គីមហោសាសនាប្រៀបធៀបភាគ២ ទំព័១០១)

សេចក្តីបំណងតាំងទុកមកដូច្នេះ ធ្វើតាមប្រវត្តិមានពីមុនមកថា ព្រះយេស៊ូមុននឹងរលត់ជីវិតក្នុងថ្ងៃចុងក្រោយ មានការបរិភោគអាហារជាមួយសាវ័កសំខាន់ ១២នាក់។ ក្នុងថ្ងៃនោះព្រះយេស៊ូយកនំបុ័ងនិងស្រា ទំពាំងបាយជូមកលៀងសាវ័ក និងប្រាប់ដល់សាវ័កមានសេចក្តីថា "នេះគឺសាច់និងឈាមរបស់ខ្ញុំ អ្នកណាបានបរិភោគនំបុ័ងនិងទឹកទំពាំងបាយជូនេះស្មើនឹងបានមកនៅជាមួយយើង"។

លទ្ធិគម្មុនី ធ្វើបែកផ្សេងគ្នាទៅតាមនិកាយមួយៗ ក្នុងនិកាយប្រេសបៃតេរិន ដែលជានិកាយមួយរបស់ប្រូតេស្តង់ ទទួលយកពិធីនេះទៅធ្វើដូចគ្នាឱ្យមានការប្រជុំគ្រិស្តសាសនិកក្នុងរោងសូត្រមន្ត ប៉ាស្ទ័រអ្នកធ្វើពិធីកាន់ថាសមានស្រាទំពាំងបាយជូ នំបុ័ងហាន់ជាចំណិតៗ ដែលលោកគ្រូធំធ្វើពិធីសែកមន្តរួចហើយ ពីតុតម្កល់បូជា នាំយកអាហារទាំងនេះ មកចែកចាយដល់អ្នកប្រជុំឱ្យបរិភោគជាពិធី។

ក្នុងនិកាយអ័រថូដក្ស តាមធម្មតាមិនត្រេកអរក្នុងការធ្វើពិធី ក៏នៅតែទទួលយកពិធីនេះមកធ្វើក្នុង ពេលដែលក្មេងទទួលសីលជ្រមុជទឹកហើយ ដោយវិធីជងទឹកទំពាំងបាយជូរឱ្យផឹក និងពេលខ្លះមាននំបុ័ងបន្ទះថែមឱ្យផង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០២)

ក្នុងនិកាយរ៉ូម៉ាំងកាតូលិក លោកគ្រូធំនាំពាងទឹកទំពាំងបាយជូរចូលទៅធ្វើពិធីបូជាចំពោះមុខតុតាំងបូជា ហើយនាំទឹកទំពាំងបាយជូរនោះចេញមកឱ្យអ្នកប្រជុំផឹក ព្រមជាមួយនំបុ័ងចំណិតក្នុងបច្ចុប្បន្ន បានព្រួថាឱ្យពួកចូលមកប្រជុំបរិភោគតែនំបុ័ងប៉ុណ្ណោះ ចំណែកទឹកទំពាំងបាយជូ ទុកឱ្យលោកសង្ឃឆាន់។

៤-ពិធីរៀបមង្គលការ (Matrimony) រ៉ូម៉ាំងកាតូលិក ព្រមទាំងអ័រថូដក្សផង កាន់តឹងតែងណាស់ ត្រូវតែធ្វើស្មើៗគ្នា លោកសង្ឃត្រូវមានចំណែកឱ្យពរក្នុងពិធីមង្គលការកូនកំលោះក្រមុំ ហេតុផលធ្វើពិធីនេះ អាងដល់ពាក្យប្រដៅរបស់ប៉ូលសិស្សសំខាន់របស់ព្រះយេស៊ូបានបង្រៀនថា "សូម្បីព្រះយេស៊ូខ្លួនឯង ទ្រង់មានសេចក្តីស្រឡាញ់ដល់រោងសូត្រព្រះអង្គឧទ្ទិសជីវិតចំពោះទីស្ថាននោះ (ស្រឡាញ់ធម៌) ព្រោះហេតុនោះ បុរសទាំងឡាយគួរស្រឡាញ់ភរិយារបស់ខ្លួន ដូចគ្នានឹងស្រឡាញ់ខ្លួនឯង"។

មានសេចក្តីអធិប្បាយថា ការឱ្យកូនកំលោះក្រមុំមកទទួលពរពីព្រះសង្ឃក៏ដើម្បីនឹងប្រកាសសេចក្តីស្រឡាញ់និងសេចក្តីស្មោះត្រង់ឱ្យព្រះជាម្ចាស់ទ្រង់ជ្រាប ហើយប្រកាសឱ្យឃើញការស្រឡាញ់ខ្ជាប់ខ្ជួនរវាងគ្នានិងគ្នា។ ដើម្បីអនាគតរបស់បុត្រធីតា ការប្រកាសយ៉ាង

នេះបង្កើតទៅ ជាផលនៃសេចក្ដីស្រឡាញ់របស់ខ្លួនផងនិងជាការធានារ៉ាប់រងខ្លួនឯង កាលបើក្មេងកើតពីផលនៃការស្រឡាញ់របស់ខ្លួន ត្រូវតែនាំយកក្មេងនោះមកប្រកាសចូលជាសាស-និកជនដូចខ្លួនដែរ។

រ៉ូម៉ាំងកាតូលិកប្រកាន់ថា ស្រីប្រុសរៀបការជាមួយគ្នា ជាសម្ព័ន្ធដ៏បរិសុទ្ធសម្រាប់មនុស្សជាតិ អ្នកដែលកើតមកថ្មី និងការចេះដឹងខាងសាសនា។ ការលែងលះគ្នានៃគូស្រករកាតូលិកថាជារឿងត្រូវហាមដាច់ខាត ក្រៅអំពីមានហេតុចាំបាច់ណាស់ និងប្រកាន់តឹងតែងថា ស្រីប្រុសណារៀបការជាមួយអ្នកលែងលះមកហើយ នាំឱ្យអប្បមង្គល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០៣)

ពិធីរៀបការធ្លាប់បានធ្វើមក គឺស្រីប្រុសនាំគ្នាចូលទៅកាន់រោងសូត្រធម៌ជាមួយអ្នកកំដរធ្វើសាក្សីទាំងពីរនាក់ លុតជង្គង់ចុះនៅមុខតុតាំងបូជា ព្រះសង្ឃមកទទួលដោយលាដៃទាំងពីរធ្វើទំនងព្រមទទួលស្គាល់ថា ការសម្ព័ន្ធនិងសេចក្ដីស្រឡាញ់បានសម្រេច ហើយប្រកាសជូនពរអ្នកទាំងពីរ គូស្រករខ្លះឱ្យលោកពាក់ម្កុដសម្រាប់ប្រើក្នុងពិធីនៃអ្នកទាំងពីរ ដើម្បីជាសញ្ញានូវភាពស្មើគ្នា និងការស្មោះស្ម័គ្រនៃជីវិត។

និកាយអេពិស្កោបាលរបស់អង់គ្លេស ប្រកាន់យកពាក្យប្ដេជ្ញារបស់កូនកំលោះ ក្រមុំជាសំខាន់ ដូច្នោះក្នុងពិធីរៀបការ កូនកំលោះ-ក្រមុំត្រូវពោលពាក្យប្ដេជ្ញា សន្យាថាស្រឡាញ់គ្នាចំពោះមុខលោកសង្ឃ។

៥-ពិធីសារភាពបាប (Confession) ពិធីនេះចាប់ផ្ដើមដោយពាក្យអធិប្បាយថា បាបកម្មណាៗធ្វើរួចមកហើយ នឹងរួចរំដោះចេញបានដោយការសារភាពដល់អ្នកដទៃ អ្នកដែលចូលមកទទួលពាក្យសារភាព ត្រូវតាំងនៅក្នុងសេចក្ដីមេត្តាករុណា ព្រមទទួលកំហុសដែលអ្នកដទៃមកសារភាពដល់ខ្លួន ហើយលើកលែងកំហុសនោះឱ្យដូចគ្នានឹងការកាត់ក្ដីក្នុងតុលាការរដ្ឋដូច្នោះដែរ។ បើចម្លើយអ្នកមានកំហុសសារភាពនូវកំហុសរបស់ខ្លួន តុលាការនឹងលោះលាទោសឱ្យទៅជាប្រយោជន៍ដល់ចម្លើយ ដែលបានទទួលសារភាព។

តែក្នុងសាសនាខុសអំពីតុលាការរដ្ឋ គឺបើសារភាពហើយ អ្នកទទួលសារភាពព្រមលើកទោសឱ្យទាំង អស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០៤)

ពិធីសារភាពបាប មានអធិប្បាយតាមតំណាលថា គ្រាមួយនោះព្រះយេស៊ូស្តេចបាន ទៅរក្សាពេគ ឱ្យដល់អ្នកកើតរោគឃ្លង់និងអ្នកមានភ្នែកខ្វាក់ដោយអំណាចចិត្ត អ្នកជំងឺជាពី រោគចង្រៃ អ្នកភ្នែកខ្វាក់ ត្រឡប់ជាបើកភ្នែកបាន។

ការរក្សារោគរបស់ព្រះយេស៊ូ មានកំណត់ថា ព្រះអង្គទ្រង់មេត្តាដល់មនុស្សទាំង ឡាយមិនរើសមុខ អ្នកមានជំងឺក្តី អ្នកខ្វាក់ភ្នែកក្តី បានឈ្មោះថាជាអ្នកមានបាប ដែលបានធ្វើ ទុកមកហើយ ព្រះជាម្ចាស់ទ្រង់ដាក់ទោសឱ្យមានបាប ព្រះជាម្ចាស់នោះឯងជាអ្នកប្រទាន ទោសមិនឱ្យមានបាប តាមតំណាលបានអះអាងពាក្យរបស់ព្រះយេស៊ូ មានប្រាកដក្នុងគម្ពីរ ម៉ាថាយ កាលទ្រង់រក្សារោគឱ្យអ្នកជំងឺថា "បាបរបស់អ្នក យើងបានលើកលែងទោសឱ្យ ហើយ"។

សេចក្តីក្នុងគម្ពីរម៉ាថាយ មានមួយវគ្គទៀតថា "សេចក្តីស្លាប់និងការដែលស្តេចមក កើតជាថ្មី(ការរស់ជីវិតឡើងវិញ) របស់ព្រះអង្គអាចជម្រះលាងបាននៃដួងវិញ្ញាណ ដែលមាន បាប ឱ្យអស់បាននោះបាន សូមព្រះអង្គទ្រង់មេត្តាប្រោសកុំឱ្យមានជំពាក់ជំពិនដល់ពួកយើង ទាំងឡាយឡើយ"។

ការសារភាពបាប តាំងពីមុនមក ធ្វើក្នុងពេលត្រូវការលោះលាបាប កាលណាមាន បាប រាប់តាំងពីព.ស. ១៧៥៨ ជាដើមមក ឱ្យឧបាសកឧបាសិកាចូលធ្វើពិធីសារភាពមួយឆ្នាំ ម្តង។ ឯអ័រថូដក្សសាខាខ្លះ ធ្វើក្នុង១ឆ្នាំ ៤-៥ដងក៏មាន មិននិយមធ្វើរួមគ្នា គឺធ្វើរៀងៗខ្លួន អ្នក សារភាពបាបលុតជង្គង់មុខតុតាំងបូជា លោកចូលមកយកសំពត់យ៉ុំរបស់លោក ដាក់ចុះលើ ស្មា អ្នកសារភាពក៏ប្រកាសសេចក្តីបរិសុទ្ធ សម្តែងឱ្យឃើញថា អ្នកសារភាពអស់បាប ហើយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០៥)

ចំណែកកាតូលិក លោកបណ្តោយឱ្យអ្នកសារភាព ពោលពាក្យសារភាពដោយឯក ឯង លោកឈរសម្ងឹងមើលទៅក្បែរនោះ មិនបាច់ធ្វើពិធីមួយឱ្យដល់អ្នកសារភាពទេ ជួនកាលខ្លះអ្នកសារភាពនៅក្រៅពីទីកំបាំង លោកស្តាប់សំឡេងសារភាព ជួនកាលខ្លះអ្នក សារភាពនៅក្រៅពីទីកំបាំង លោកស្តាប់សំឡេងសារភាពក្នុងទីកំបាំងបានបញ្ចេញសំឡេង ទទួលដឹងឮពាក្យសារភាពឱ្យឮពីទីកំបាំងចេញមកថា"ព្រះចិត្តបានទទួលបាបរបស់អ្នកហើយ បាបដែលអ្នកធ្វើចំពោះអ្នកដទៃ ក៏បានលើកទោសឱ្យហើយ" កាតូលិកអ្នកមានសទ្ធា ចាស់ក្លា ខ្លះធ្វើពិធីសារភាពបាបមួយអាទិត្យម្តង។

និកាយប្រូតេស្តង់ ធ្វើពិធីសារភាពជាពួកជាគណៈ មកអង្គុយព្រមព្រៀងគ្នាមុខតុតាំងបូជា ហើយពោលពាក្យសារភាពថា "សូមលោះលាទោសឱ្យដល់ពួកខ្ញុំ សូមឱ្យលើកលែងបាបទាំងអស់របស់ពួកខ្ញុំ" តអំពីនោះ លោកសារភាពបាបជំនួសក្រុមជនទាំងនោះថា "ពួកខ្ញុំមិនបានធ្វើក្នុងរបស់ដែលគួរធ្វើ បានធ្វើក្នុងរបស់ដែលមិនគួរធ្វើ បពិត្រព្រះអង្គ ព្រះអង្គទ្រង់ជាអ្នកមានព្រះករុណាដល់ពួកគេ" តែប៉ុណ្ណោះឈ្មោះថាពិធីស្រេចរួចរាល់ហើយ។

៦-លទ្ធិផ្តិតលាបគ្រាចុងក្រោយ ហៅជាភាសាអង់គ្លេសថា Holy unction ឬ Extreme unction ពិធីនេះធ្វើដល់អ្នកជំងឺជិតនឹងអស់ជីវិត កាន់យកជាពិធីជម្រះបាបគ្រាចុងក្រោយ ដើម្បីមិនឱ្យបាបជាប់នៅជាមួយខ្លួនមុននឹងត្រូវធ្វើដំណើរទៅកាន់ទីកន្លែងពិភាក្សា ឬទៅកាន់កន្លែងជម្រះបាបក្នុងលោកខាងមុខ និងមានជំនឿថា មិនឱ្យបិសាចមករារាំងពេលធ្វើដំណើរទៅ។

ការធ្វើពិធីនេះ កាន់តាមពាក្យប្រដៅក្នុងគម្ពីរថ្មីពួក Epistle of James ដែលមានសេចក្តីថា "មានការឈឺចាប់ណាកើតឡើងដល់អ្នកណាឱ្យអ្នកនោះចូលមករកអ្នកបួស លោកជាអាវុធសោក្នុងវិហារ ផ្តិតលាបប្រេងឱ្យគេក្នុងនាមនៃព្រះជាម្ចាស់ ពោលព្រះនាមដោយសទ្ធានឹងផុតពីការឈឺចាប់ដែលព្រះជាម្ចាស់ជួយសង្គ្រោះឱ្យផុតភ័យ បើសិនជាគេមានបាប ព្រះជាម្ចាស់នឹងជួយឱ្យគេផុតអំពីបាបបាន។

ពួកនិកាយរ៉ូម៉ាំងកាតូលិក រមែងធ្វើក្នុងពេលចិត្តជិតរលត់ ដោយមានជំនឿថា នឹងបានផលបែបណានីមួយ ព្រមជាមួយគ្នាក្នុងពេលនោះដោយកាន់ថាជាការលើក លែងទោសពីបាបដែលអាចកើតឡើងបាន។ ក្នុងខណៈផ្តិតលាបប្រេងគឺជាការលោះលាបាបក្នុង អនាគត បង្កើតឱ្យមានសទ្ធាចំពោះព្រះជាម្ចាស់ធ្វើឱ្យមានកម្លាំងចិត្ត និងធ្វើឱ្យជាពីរោគភ័យផង។

ពិធីភាគច្រើនមាន ២ពិធី ខាងអ័រថូដក្ស លោកប្រើដៃស្តាំយកសំពត់ឃ្លុំគ្របក្បាលអ្នកជំងឺ ដៃឆ្វេងកាន់ឈើឆ្កាង។ ពួកប្រូតេស្តង់និងកាតូលិកធ្វើប្រហែលគ្នា លោកយកដៃឆ្វេងចាប់ក្បាល ប្រើម្រាមដៃស្តាំចុចត្រង់ចិញ្ចើម និងមានពិធីផ្តិតលាបប្រេងតាមរាងកាយរបស់អ្នកជិតស្លាប់ ៧ដង ជួនកាល ៥ដង តាមផ្នែកផ្សេងៗនៃរាងកាយ ផ្តិតលាបពេលណា ពោលពាក្យអង្វរករព្រះជាម្ចាស់ព្រមជាមួយគ្នាផង។

៧-ពិធីចូលបួស Order ឬ Ordination ជាពិធីដែលមេវត្តធ្វើឱ្យអ្នកចូលមកសុំផ្នួសប្រហែលគ្នានឹងពិធី ប្រគល់ឱ្យធ្វើជាធម្មទូត ឬការប្រគល់មុខងារជាជំនួនដល់អ្នកនោះ។

ពួកកាតូលិកឱ្យអ្នកចូលមកធ្វើពិធីស្មៀកសជណ្ដប់សដូចគ្នាទាំងអស់គ្រប់ៗគ្នា ក្រាបបង្គំនៅមុខអាសនៈបូជា មានការឱ្ធណាល់ (មេគណមណ្ឌល) មួយរូបមកសូត្រ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០៧)

ចំណែកពួកប្រូតេស្ដង់ ឱ្យអ្នកចូលមកធ្វើពិធីត្រឹមតែអង្គុយលុតជង្គង់ទទួលពរពីលោក ប៊ិចប ពួកអ័រថូដក្សក៏ធ្វើប្រហាក់ប្រហែលគ្នា។

ពិធីនេះ មកពីពាក្យប្រដៅគម្ពីរសេន្តច្ចនដែលថា "ព្រះគ្រិស្ដបានប្រាប់ដល់សាវ័ករបស់លោកថា ដោយហេតុព្រះអង្គទ្រង់បញ្ជូនយើងមក (ជួយមនុស្ស) យើងសូមបញ្ជូនលោកទៅ (ជួយមនុស្ស) ដូចគ្នាដែរ"។

លទ្ធិប្រតិបត្តិ ៧ ប្រការ (Seven Sacraments) មានវិធីប្រតិបត្តិនិងសេចក្ដីយ៉ាងល្អិតល្អន់ខុសគ្នាខ្លះទៅតាមនិកាយមួយៗ ដូចពិធីនមស្ការកាតូលិកនិងប្រូតេស្ដង់ប្រើចុងម្រាមដៃចុចចំថ្ងាស ជាអនុស្សតិដល់ព្រះបិតា (God) ត្រង់ទ្រូងជាអនុស្សតិដល់ព្រះបុត្រ (Jesus) និងចុចត្រង់ស្មាឆ្វេងស្ដាំ ជាអនុស្សតិដល់ព្រះចិត្ត (Holy Spirit)។ ឯចំណែកអ័រថូដក្សចុចពីស្មាស្ដាំទៅឆ្វេងវិញ (មើលរឿងត្រីនិធី ឬ ត្រីឯកានុភាពខាងមុខ)។

**ប្រូតេស្ដង់**

ពាក្យថា ប្រូតេស្ដង់ ប្រែតាមសព្ទថា អ្នកជំទាស់ ជានាមរបស់និកាយថ្មីក្នុងគ្រិស្ដសាសនា តាំងឡើងដោយជនជាតិអាល្លឺម៉ង់ឈ្មោះ លូធើរ៍ និងជនជាតិបារាំងឈ្មោះ កាលវែង យកមកផ្លាស់ប្ដូរខ្លះ។ លទ្ធិរបស់និកាយថ្មីនេះ ខុសពីគោលការណ៍របស់និកាយរ៉ូម៉ាំង កាតូលិកច្រើនប្រការ ខ សំខាន់គឺការដែលសង្ឃរាជក្នុងក្រុងរ៉ូម ឬទីប្រជុំសង្ឃផ្នែកកាតូលិក ប្រែន័យរបស់សាសនាគ្រិស្ដយកតាមការយល់របស់ខ្លួន មិនរកហេតុផលសមរម្យ មិនព្រមឱ្យអ្នកណាយល់ឃើញតាមសច្ចារបស់ខ្លួន មិនព្រមបណ្ដោយឱ្យមនុស្សគ្រប់គ្នាមានសិទ្ធិក្នុងការគិត សិក្សាស្រាវជ្រាវបានតាមសេចក្ដីពេញចិត្ត រួមសេចក្ដីមក កាតូលិករក្សាសិទ្ធិតែម្នាក់ឯង ចំពោះពាក្យប្រៀនប្រដៅនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១០៨)

ការដែលនិកាយប្រូតេស្ដង់មានកំណើតឡើងបាន ផលសំខាន់ទាំងក្នុងសាសនានិងស្រុកទេសជាច្រើន។ ខាងផ្លូវសាសនាបានបំផ្លាញទំនាក់ទំនងរវាងពួកគ្រិស្ដសាសនិក និងកាត់ផ្ដាច់អំណាចរបស់សង្ឃរាជក្រុងរ៉ូមស្ទើរតែទាំងអស់ ធ្វើឱ្យពួកកាតូលិកដឹងខ្លួនមានការផ្លាស់ប្ដូររហូតដល់ធ្វើសង្គាយនា ប្រជុំគ្នាដាក់របៀបរបស់ខ្លួនឱ្យមានការរៀបរយឡើងវិញ។

ចំណែកខាងផ្លូវស្រុកទេស មានផលដែលថាសំខាន់នោះ ធ្វើឱ្យអាណាចក្រមាន ឥស្សរភាព កើតឡើងច្រើនកន្លែង ចង់លះបង់ចោលដែលមិនគួរនិយាយ ព្រោះខុសនឹងបំណងពាក្យបរិយាយនេះ។ ទោះជាយ៉ាងណាក្តី ការដែលនិកាយប្រូតេស្តង់បានកើតឡើងក្នុងគ្រានេះ មានឈ្មោះហៅថាក្នុងប្រវត្តិសាស្ត្រ ជាភាសាអង់គ្លេសថា Reformation ប្រែថា "ការផ្លាស់ប្តូរ" ឬ "ការកែទម្រង់"។

មានហេតុសំខាន់ ២ ប្រការ ដែលនិកាយប្រូតេស្តង់កើតឡើងគឺ ៖

ការដែលលោកសង្ឃតូចធំជាអលជ្ជី (ដែលឥតអៀនខ្មាស) រហូតដល់អង្គសន្តប៉ាប៉ានេះម្យ៉ាង និងការផ្សព្វផ្សាយរបស់គម្ពីរប៊ីប្លូ ព្រោះហេតុដែលមានរោងពុម្ពកើតឡើងនេះម្យ៉ាងទៀត យើងនឹងធ្វើការពិចារណាម្តងមួយៗ ៖

១-មានរឿងដំណាលថា សង្ឃរាជកេរកេរីទី៧ នៃក្រុងរ៉ូម បានព្យាយាមលាង ពួកអលជ្ជី លើកឋានៈរបស់វត្តឱ្យល្អឡើងគួរឱ្យសរសើរ រាប់តាំងពីនោះរហូតមកដល់សម័យកើតនិកាយប្រូតេស្តង់ ជារយៈពេលឃ្លាតឆ្ងាយពីគ្នា ៥០០ឆ្នាំ ការធ្វើឱ្យមានរបៀបរៀបរយដែលសង្ឃរាជកេរកេរីបានធ្វើទុកត្រឡប់ទៅជាទ្រុឌទ្រោមរបាត់របៅយអនាចារ និងអាក្រក់ជាង កាលពី៥០០ឆ្នាំកន្លងមក។ ពួកកាតូលិកនាំគ្នាលោភលន់រកមាសប្រាក់លក់មុខតំណែងសង្ឃរាជលក់ប័ណ្ណ លោះលាងបាបជាដើម។ សង្ឃរាជមួយអង្គព្រមានថា អាឡិកសាន់ឌឺរ៍ទី៦ សម្លាប់មនុស្សជាច្រើននាក់ដោយអាវុធនិងការដាក់ថ្នាំពិសដោយផ្ទាល់ដៃខ្លួនឯង ជាអ្នកចេញមុខពន្យុះ ជំរុញឱ្យអ្នកគ្រប់គ្រងស្រុកទេសបែកបាក់ធ្វើសង្គ្រាមបង្ហូរឈាមគ្នាពេញដីសង្ឃរាជយូលល៍ទី២ នាំកងទ័ពចូលសមរភូមិខ្លួនឯង សង្ឃរាជដទៃៗទៀតច្រើនអង្គ ធ្វើឱ្យអាប់ឱនកិត្តិយសពីរឿងមាសប្រាក់ដែលរាប់ថាជា កំហុសយ៉ាងខ្លាំងក្លា អ្នកមានបញ្ញា និងសេចក្តីក្លាហាន មើលឃើញថាជាការចាំបាច់ដែលត្រូវតែធ្វើការផ្លាស់ប្តូរ។

២-តាំងអំពីអឺរ៉ុបបានដឹងវិធីបោះពុម្ពឡើងកាលណា ការតាំងដំឡើងរោងពុម្ពជារឿងធ្វើឱ្យភ្ញាក់ផ្អើល តមកមានអ្នកដំឡើងរោងពុម្ពជាច្រើន ប្រទេសអាល្លឺម៉ង់តែមួយ ក្នុងពុទ្ធសករាជ ២០៤៣ មានរោងពុម្ពជាងមួយពាន់កន្លែង ប្រជាពលរដ្ឋសូម្បីនៅក្នុងថ្នាក់ទាប ក្រីក្រយ៉ាងណាក្តី ក៏នាំគ្នាហាត់សរសេរហាត់អានសៀវភៅ។ សៀវភៅដែលបោះពុម្ពឡើងច្រើនបំផុត ក្នុងពេលនោះ គឺគម្ពីរប៊ីប្លូ អ្នកប្រវត្តិសាស្ត្របានប៉ាន់ស្មានថា រយៈពេល២៨ឆ្នាំ គឺតាំងពីពុទ្ធសករាជ២០០០ ដល់២០២៨ គម្ពីរប៊ីប្លូបោះពុម្ពឡើងក្នុងអឺរ៉ុបជាង ៤០០ដង។ កាលពីមុន

មក គម្ពីរប៊ិបមិនទាន់ផ្សព្វផ្សាយ លោកសង្ឃចង់ថាយ៉ាងណា មនុស្សត្រូវតែជឿសង្ឃរាជ ឬ ទីប្រជុំសង្ឃកាតូលិកនឹងវិនិច្ឆ័យដាក់គោលការណ៍យ៉ាងណាមនុស្សត្រូវតែជឿ ព្រោះមនុស្ស ភាគច្រើនមិនដឹងពាក្យប្រៀនប្រដៅរបស់ព្រះយេស៊ូមែនពិតនោះយ៉ាងណា។

លុះបានប្រែគម្ពីរប៊ិបចេញជាភាសារបស់ប្រទេសផ្សេងៗ និងបោះពុម្ពផ្សាយចេញទៅជាច្រើន អ្នកមានបញ្ញាក្លាហានសិក្សាចេះដឹងថា ពាក្យវិនិច្ឆ័យរបស់សង្ឃរាជឬរបស់ទីប្រជុំសង្ឃ មានខ្វះខុសឃ្លាតពីលក្ខខណ្ឌ ពាក្យទូន្មានរបស់ព្រះយេស៊ូ។ កាលបើមានគម្ពីរនៅ នឹងដៃហើយ ហេតុអ្វីក៏មិនកាន់ឱ្យតឹងតែងតាមគម្ពីរ ហេតុដូចម្ដេចក៏មិនបើកឱ្យមានសេរីភាពឱ្យមនុស្សគ្រប់គ្នាមានគំនិតត្រិះរិះរកហេតុផលថា តើមានការខុសត្រូវយ៉ាងណាដោយខ្លួនឯងចុះហេតុអ្វីក៏ចាំបាច់ឱ្យសង្ឃរាជក្រុងរ៉ូម ឬ ទីប្រជុំសង្ឃដាក់លក្ខខណ្ឌជាដរាបនោះ ដែលមានពេលខ្វះដាក់ខុសពីគម្ពីរដើម ខនេះឯងហើយជាគំនិតរបស់មនុស្សសំខាន់ម្នាក់ឈ្មោះ ម៉ារតិនលូធើរ៍។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១០)

ម៉ារតិនលូធើរ៍ កើតនៅទីក្រុងអៃស្លេបេន បូរីសែកសោនី នៅថ្ងៃ ១០ វិច្ឆិកា ព.ស. ២០២៦ មាតាបិតាជាអ្នកក្រខ្សត់ ពុំបានទទួលការសិក្សាអប់រំសោះឡើយ លុះធំឡើងគ្មានប្រាក់ឱ្យកូនចូលសាលារៀន លូធើរ៍ដើរ ត្រាច់ចរច្រៀងសុំទានទៅតាមផ្ទះផ្សេងៗ ដើម្បីរកប្រាក់បង់ថ្លៃសាលារៀនខ្លួនឯង ចៃដន្យគ្រោះល្អមានស្ត្រីអ្នកមានម្នាក់កើតក្ដីមេត្តា បានជួយសង្គ្រោះឱ្យចូលរៀនក្នុងមហាវិទ្យាល័យ កាលពីពុទ្ធសករាជ ២០៤៣។ លូធើរ៍បានសិក្សាខាងផ្លូវធម៌ អក្សរសាស្ត្រ តន្ត្រី ហើយដែលយកចិត្តទុកដាក់បំផុតគឺច្បាប់ បិតារបស់លូធើរ៍ ក៏ប្រាថ្នាឱ្យកូនរបស់ខ្លួនធ្វើជាគ្រូខាងច្បាប់ផងដែរ និងលូធើរ៍ខ្លួនឯងក៏ពេញចិត្តទៅជាអ្នកច្បាប់។ លុះអាយុបាន ២២ឆ្នាំ មានហេតុការណ៍មួយកើតឡើង ដែលផ្លាស់ប្ដូរអនាគតរបស់លូធើរ៍ឱ្យត្រឡប់ត្រឡិន គឺមិត្តភក្តិរបស់លូធើរ៍ត្រូវគេសម្លាប់ក្នុងពេលអាសន្នតស៊ូនឹងបុគ្គលម្នាក់ ធ្វើឱ្យលូធើរ៍ក្លាយជាមនុស្សខ្លាចខ្មោច គ្មានសេចក្ដីក្លាហាន។ ពេលកន្លងមកបាន ២-៣ថ្ងៃ លូធើរ៍ចូលដល់ទ្វារមហាវិទ្យាល័យ ក៏កើតមានភ្លៀងធ្លាក់ ផ្គរ រន្ទះបាញ់មកជិតៗខ្លួន លូធើរ៍បានប្ដេជ្ញាក្នុងចិត្តថា បើរួចពីគ្រោះថ្នាក់បាននឹងទៅបួសជាលោកសង្ឃ ដូចជាពុទ្ធសាសនិកជនរបស់យើងចូលចិត្តបន់ស្រន់ដោយសាងផ្នួស។ តមកមិនយូរប៉ុន្មាន នៅថ្ងៃទី១៧ មករា ព.ស. ២០៤៨ លូធើរ៍ក៏ចូលទៅនៅក្នុងវត្ត តាំងចិត្តសិក្សាខាងផ្លូវសាសនា យកចិត្តទុកដាក់ជាទីបំផុត ជាអ្នក

ច្នាតវៃ និយាយពូកែ រហូតដល់ទីបំផុតបានក្លាយទៅជាគ្រូក្នុងមហាវិទ្យាល័យ វិគ្គេនប៊េរីក មានអ្នកស្រឡាញ់រាប់អានជាច្រើន។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១)

ឆ្នាំពុទ្ធសករាជ ២០៥៤ គណៈសង្ឃក្នុងប្រទេសអាល្លឺម៉ង់ បានបញ្ជូនលោកលូធឺរទៅគាល់សង្ឃរាជក្រុងរ៉ូម ដោយមានកិច្ចការម្យ៉ាង លូធឺរបានសម្លឹងឃើញជីវិតរបស់សង្ឃរាជហ៊ឺហារហួសហេតុ រហូតពុំមានមហាក្សត្រិយ៍អង្គណាប្រៀបបាន ក៏មានការអៀនខ្មាសខ្លួនឯង និងយល់ឃើញថា លោកឯងមិនគួរដំណើរជីវិតឱ្យហ៊ឺហារដល់ថ្នាក់នេះឡើយ។ គ្រានេះជាលើកដំបូងដែលលូធឺរ ចាប់ផ្ដើមដឹងថា គួរតែមានការផ្លាស់ប្ដូរខាងផ្លូវសាសនា។

តមកទៀត ៤ឆ្នាំ ពេលក្រោយកើតរឿងមិនពេញចិត្តរបស់គ្រិស្តសាសនិកជនទូទៅ គឺរឿងពិធីធ្វងបាប បើលហុទោសត្រឹមតែសូត្រមន្តអង្វរករព្រះជាម្ចាស់ក៏រួចខ្លួន តែបើជាកំហុសដ៏ខ្លាំងក្លា ត្រូវនៅធ្វើពិធីកម្ម ឬទៅធុដុង្គ។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១២)

តែលុះមកដល់ពុទ្ធសករាជ ២០៥៨ សង្ឃរាជលេអូទី ២០ ចង់សាងវិហារឱ្យស្អាតជាកិត្តិយសដល់សង្ឃរាជឱ្យលើសលប់ជាងដែលមានរួចមកហើយ ទើបតាំងបញ្ញត្តិថ្មីថា ទោះបីជាធ្វើកំហុសធ្ងន់ធ្ងរខ្លាំងក្លាយ៉ាងណាក្ដី ក៏អាចលាងបាបបានដែរ ដោយចេញប្រាក់រៃអង្គាសសាងវិហារនេះ។ បញ្ញត្តិថ្មីនេះ ជាខដែលមិនអាចប្រតិបត្តិតាមបាន ព្រោះមនុស្សទាំងឡាយយល់ឃើញថា សង្ឃរាជបញ្ញត្តិច្បាប់សាសនាតាមអំពើចិត្តចង់ និងបញ្ញត្តិ ឡើងដើម្បីបម្រើការហ៊ឺហារខ្ជះខ្ជាយរបស់សង្ឃរាជខ្លួនឯង។ តាំងពីយូរយារមកហើយ មនុស្សទាំងឡាយព្រមទទួលស្គាល់ថា សង្ឃរាជជាអ្នកតំណាងព្រះជាម្ចាស់ របស់ណាដែលសង្ឃរាជបញ្ញត្តិ របស់នោះក៏ជាបញ្ញត្តិរបស់ព្រះជាម្ចាស់ដែរ។ ឥឡូវនេះឃើញច្បាស់ហើយថា សង្ឃរាជតាំងបញ្ញត្តិហួសកម្រិតពីសេចក្ដីត្រូវការរបស់ព្រះជាម្ចាស់ទៅទៀត បើមានបញ្ញត្តិថ្មីក្នុងរឿងនេះ កើតឡើង បណ្ដាធនាគារទាំងឡាយក្នុងប្រទេសផ្សេងៗ មានប្រទេសអាល្លឺម៉ង់ជាអាទិ៍ ឃើញថានឹងមានឱកាសបានទទួលប្រាក់ជាចំនួនច្រើនធ្លាក់ទៅជាភ្នាក់ងាររបស់សង្ឃរាជ ទទួលផ្ញើប្រាក់ដែលមនុស្សទាំងឡាយបង់ជម្រះលាងបាបដោយមិនបាច់បញ្ជូនទៅក្រុងរ៉ូម ព្រឹត្តិការណ៍នេះជារបស់គួរឱ្យអាម៉ាស់បំផុតខាងផ្លូវសាសនា។

ក្នុងពេលនោះ លូធឺរនៅធ្វើជាអាចារ្យបង្រៀនសាសនា លុះខែតុលា ព.ស.២០៦០ លូធឺរក៏ចាប់ផ្ដើមជំទាស់ការបញ្ញត្តិដូច្នេះ បានប្រជុំអ្នកចេះដឹងជាច្រើនមកប្រឹក្សាចោទឆ្លើយជជែកគ្នាជាយូររហូតដឹងដំណឹងទៅដល់ត្រចៀកសង្ឃរាជ។ សង្ឃរាជបានដាស់តឿនឱ្យលូធឺរ

ប្តូរការយល់របស់ខ្លួនចេញ លូធឺរមិនព្រមតាម ប្រកាសបើកចំហរថាបញ្ញត្តិរបស់សាសនា ពុំមានអ្វីក្រៅពីសារសំខាន់ក្នុងគម្ពីរប៊ីប្លទេ អ្នកណានឹងមកកែប្រែ ឬបញ្ញត្តិជាថ្មីតាមអំពើចិត្ត នោះពុំបានឡើយ។ លុះសង្ឃរាជឃើញថាមិនអាចធ្វើឱ្យលូធឺរកែប្រែមកវិញបាន ទើបប្រកាស បព្វាជនីយកម្មលូធឺរ កាលពីខែមិថុនា ព.ស.២០៦៣។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១៣

ហេតុការណ៍ទាំងនេះ កើតឡើងក្នុងសម័យព្រះចៅធារល៍ទី៥ ទើបតែនិងបានទទួលជ្រើសរើសជាព្រះរាជាធិរាជអាល្លឺម៉ង់ មិនយូរប៉ុន្មានការដែលលូធឺរ បង្ករឿងច្របូកច្របល់ជាមួយសង្ឃរាជក្រុងរ៉ូមនោះធ្វើឱ្យមានភ័យចំពោះព្រះចៅធារល៍ទី៥ច្រើនណាស់ ព្រោះខាងរដ្ឋាភិបាលប្រទេសអាល្លឺម៉ង់បានបែកគ្នារួច ហើយបើនឹងបង្កការបែកបាក់ក្នុងផ្លូវសាសនាទៀត នឹងធ្វើឱ្យមានការច្របូកច្របល់កាត់អំណាចរបស់ព្រះរាជាធិរាជច្រើនតទៅទៀត។

ចំណែកគោលការណ៍សាសនា លូធឺរខុសឬត្រូវគ្នាជាបញ្ហាទេ ព្រះចៅធារល៍ទី៥ ចាំបាច់ត្រូវត្រិះរិះខាងផ្លូវរដ្ឋបាល ដើម្បីនឹងរក្សាអំណាចរបស់ព្រះអង្គឱ្យគង់វង្សនៅប៉ុណ្ណោះ។ ដូច្នោះ ទើបចាំបាច់ត្រូវបង្ក្រាបលូធឺរ ឱ្យទាល់តែបាន ព្រះចៅធារល្យ៍ទី៥ ហៅប្រជុំសភាដៃអេត កាលពីខែមេសា ២០៦៤ និងហៅលូធឺរមករាយការណ៍ដល់សភា លូធឺរព្រមមកតាមបញ្ជា។ ទីបំផុតសភាមិនអាចចាប់កំហុសអ្វីលូធឺរបានឡើយ ក្រៅអំពីយកអំណាចមកសម្មុតនិងចោទដាក់កំហុសតែម្យ៉ាង គឺថាចង់ប្រណាំងប្រជែងអំណាចសង្ឃរាជ សភាដៃអេតទើបប្រកាសថា លូធឺរជាមនុស្សក្រៅសាសនា ហាមមិនឱ្យអ្នកណាមកធ្វើជាសិស្សរាប់អានលទ្ធិរបស់លូថឺរ។

ក្នុងរវាងពេលនោះ លូធឺរបានតែងសៀវភៅបរិយាយអំពីការយល់ឃើញរបស់ខ្លួនសម្តែងលទ្ធិថ្មីដែលខ្លួនឃើញថា ជាលទ្ធិដ៏ត្រឹមត្រូវនិងបានប្រែគម្ពីរប៊ីប្ល ចេញជាភាសាអាល្លឺម៉ង់ រួមទាំងពាក្យប្រែរបស់អ្នកប្រាជ្ញផ្សេងៗ រួមទាំងអស់ ១៦ច្បាប់។ ច្បាប់របស់លូធឺរបានទទួលការរាប់អានជាងច្បាប់ដទៃៗ ព្រោះហេតុតែលូធឺរ កំពុងមានកេរ្តិ៍ឈ្មោះឮខ្ទឹរនេះ ម្យ៉ាងនិងម្យ៉ាងទៀតពាក្យប្រែរបស់លូធឺរ មិនដូចរបស់អ្នកដទៃ ពាក្យប្រែដែលអ្នកដទៃធ្វើរួចមកហើយ ជាពាក្យប្រែរបៀបអ្នកប្រាជ្ញអាន មនុស្សធម្មតាអានមិនយល់ តែលូធឺរប្រើភាសាងាយៗ មនុស្សសាមញ្ញយល់ជ្រួតជ្រាបគ្រប់ខគ្រប់បន្ទាត់។ តាំងពីនោះមក អ្នកណាមាន

ពាក្យប្រែរបស់លូធឺរនៅ ក្នុងដែអាចយល់បានងាយគោលការណ៍ពិតប្រាកដរបស់គ្រិស្តសាសនានោះ មានយ៉ាងណាខ្លះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១៤)

ប្រូតេស្តង់បែកចេញទៅទៀត ៤និកាយដែលសំខាន់គឺ និកាយលូធឺរ និកាយគាលវ៉ែង និកាយអង្គលិគាន ឬអេពិស្កូប៉ាល និងនិកាយប្រេសបៃតេរៀន ដែលផ្សព្វផ្សាយចូលមកដល់ជាច្រើនកន្លែង។

### អំពីគតិរឿងព្រះជាម្ចាស់

សាសនាគ្រប់សាសនា មានគតិទំនាក់ទំនងជាមួយអំណាចដ៏ខ្ពង់ខ្ពស់ ដែលមាននៅពីលើខ្លួន គប្បីខ្លួនប្រកាន់យកជាគោលការណ៍ប្រចាំជីវិត នៅរួមជាមួយគ្នាទាំងអស់ ក្នុងសាសនាគ្រិស្តក៏ដូចគ្នា។

តាមប្រវត្តិ គតិជំនឿរបស់ពពួកគ្រិស្ត ដែលជាប់ជំពាក់នឹងអំណាចដ៏ខ្ពង់ខ្ពស់ មាននៅពីលើខ្លួនបានដល់គតិទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែលបានសម្ដែងតាំងពីដើម ជាពិសេសមានការសម្ព័ន្ធជាមួយលទ្ធិជ្វីហ្វ។ គតិរបស់ពពួកគ្រិស្តនេះកំណត់បានដោយការប្រកាសពាក្យប្រៀនប្រដៅនិងពាក្យបញ្ញត្តិជាឱវាទរបស់ព្រះយេស៊ូ។ ព្រះយេស៊ូប្រកាន់យកគោលការណ៍ដើម ដែលទាក់ទងនឹងព្រះជាម្ចាស់របស់ពពួកជ្វីហ្វ តែមានការកាត់ផ្លាស់ប្ដូរប្រការខ្លះជាថ្មី ដូចជាការលើកឋានៈព្រះជាម្ចាស់របស់ជនជាតិជ្វីហ្វពីដើម មកឱ្យទ្រង់មានឋានៈ ជាព្រះរបស់ពពួកមនុស្សទាំងឡាយ ដោយកាន់ថាជាសទ្ធាដែលបុគ្គលឧទ្ទិសខ្លួន ចំពោះព្រះជាម្ចាស់ គឺគតិ១នេះ ឯងជាគតិសាសនិកគ្រិស្តកាន់ជាប់មកដល់បច្ចុប្បន្ន សមដូចវចនៈក្នុងគម្ពីរថា ព្រះជាម្ចាស់ខ្ពស់បំផុតរបស់យើង មានតែមួយព្រះអង្គ អ្នកត្រូវតែស្រឡាញ់ព្រះរបស់អ្នកដោយស្មោះអស់ពីចិត្តថ្លើម និងដោយកម្លាំងសទ្ធារបស់អ្នកទាំងអស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១៥-១១៦)

### ព្រះជាម្ចាស់ជាព្រះបិតា

គតិរបស់ពួកគ្រិស្តថា "ព្រះជាម្ចាស់ គឺព្រះបិតារបស់យើងទាំងឡាយ"។ សេចក្ដីក្នុងគម្ពីរចាស់ជាអាទិ៍ គម្ពីរអេសាយ៍ សម្ដែងគតិថា ព្រះយេះហូវ៉ា ទ្រង់ជាអ្នកមានបណ្ដាស័ក្ដិជាបិតារបស់ជនជាតិអ៊ីស្រាអែល ឬជនជាតិជ្វីហ្វ ពុំមានឃ្លាត្រង់ណាសម្ដែងថា ព្រះយេះហូវ៉ាជាព្រះទ្រង់មានបណ្ដាស័ក្ដិរបស់មនុស្សទូទាំងសកលលោកឡើយ។

មកដល់សម័យព្រះយេស៊ូ សេចក្ដីមានប្រាកដក្នុងគម្ពីរថ្មីជាច្រើនវគ្គប្រដៅថា ព្រះយេហូវ៉ានោះ ជាព្រះជាម្ចាស់ ជាព្រះបិតារបស់មនុស្សទាំងឡាយ ពុំមែនគ្រាន់តែជនជាតិជ្វីហ្វប៉ុណ្ណោះទេ ដូចមានសេចក្ដីក្នុងគម្ពីរ ម៉ាថាយនិងលូកាថា "ព្រះបិតារបស់យើងទាំងឡាយ"។ មានអ្នកកត់ត្រាទុកថា ពាក្យពេជចន៍ទាំងនេះប្រាកដ ក្នុងគម្ពីរថ្មីជាងបីរយដង ខនេះអធិប្បាយឱ្យឃើញពីនិស្ស័យរបស់ព្រះយេស៊ូថា ជាអ្នកបដិរូបសាសនាដ៏ទូលំទូលាយចេញទៅច្រើន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១១៩)

## លក្ខណៈរបស់ព្រះយេស៊ូ

លក្ខណៈរបស់សាស្ដា និងកំណត់បានថាជាយ៉ាងណានោះ អាចឃើញបានតាមពាក្យប្រៀនប្រដៅដែលសាស្ដានោះសម្ដែងមក ជីវិតរបស់ព្រះយេស៊ូ តាំងពីបដិសន្ធិមានប្រាកដក្នុងគម្ពីរលូកាថា ជាមនុស្សរ៉ឹងប៉ឹង ជាមនុស្សចិត្តទូលាយនិងមេត្តា ពេញចិត្តក្នុងការសន្ទនាយកចិត្តទុកដាក់ក្នុងសាសនាស្វែងរកសេចក្ដីស្ងប់ ចូលចិត្តត្រេចចរមិនចេះនឿយហត់សម្ដែងសេចក្ដីជាមិត្ត និងមានចិត្តល្អដល់មនុស្សទាំងឡាយមិនរើសមុខ។ នៅពេលណាដឹងថា មានការទឹងសម្បារកើតឡើងក្នុងចិត្ត ប្រើវិធីសូត្រមន្តជាគ្រឿងរម្ងាប់អារម្មណ៍ ព្រះយេស៊ូមាំមួននិងជឿជាក់ចំពោះព្រះជាម្ចាស់ដ៏កំពូល ក្នុងគម្ពីរយូហានមានប្រាកដថាយេស៊ូប្រកាសនាមរបស់ព្រះថា "ជាព្រះបិតាធំបំផុត" ដោយលក្ខណៈមានប្រចាំខ្លួនដូច្នេះ ព្រះយេស៊ូទើបចូលចិត្តសម្ដែងខ្លួនថា ជាអ្នកដូចមនុស្សទាំងឡាយដែរ ដែលមានព្រះបិតាមួយអង្គជាមួយគ្នា។ ព្រះយេស៊ូប្រៀនប្រដៅសង្កត់ធ្ងន់ឱ្យមនុស្សទាំងឡាយ រឹងជំហរចំពោះព្រះជាម្ចាស់ជា ព្រះវរបិតា និងឱ្យមនុស្សស្រឡឹមជានិច្ចថា បិតាអាចជួយសង្គ្រោះបុត្រធីតាបាន។ យ៉ាងណាមិញព្រះជាម្ចាស់ជាព្រះបិតា ក៏អាចជួយមនុស្សទាំងឡាយ ជាបុត្ររបស់ព្រះអង្គបាន ដូចគ្នាដែរ ដោយលក្ខណៈដូចបានពោលមកនេះ សាវ័ករបស់យេស៊ូទើបជឿថាយេស៊ូជាបុត្ររបស់ព្រះជាម្ចាស់ (Son of God) ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២០)

## គោលការណ៍ត្រីនិតិ និងត្រីឯកានុភាព

ត្រីនិតិ (Trinity) គឺព្រះជាម្ចាស់ ឬព្រះបិតា (God of father) ព្រះយេស៊ូឬព្រះបុត្រ (Jesus, son of God) ព្រះចិត្តឬដួងព្រះវិញ្ញាណដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ (Holy spirit ឬ Holy Ghost) ហៅខ្លីៗថាព្រះបិតា ព្រះបុត្រនិងព្រះចិត្ត រួមទាំងបីស្មើគ្នា ជារតនត្រ័យរបស់គ្រិស្តសាសនា។ ព្រះបិតា ព្រះបុត្រ និងព្រះចិត្ត សូម្បីមានតែនាមនិងឋានៈផ្សេងគ្នា តែដោយ

អានុភាពជាប់ទាក់ទងគ្នា ឬក៏តែមួយរួមគ្នា ៣ អានុភាពនេះស្មើនឹង១ ឬ១ស្មើនឹង ៣ទៀត ទើបហៅម្យ៉ាងទៀតថា ត្រីឯកានុភាព។

ហេតុឱ្យកើតគោលត្រីនិតិឬត្រីឯកានុភាព ព្រោះពួកគ្រិស្តអ្នកមានគតិការរាប់អានព្រះយ:ហូវ៉ា បន្តមកពីពួកជ្វីហ្វបុរាណនោះប្រការមួយ និងកាលព្រះយេស៊ូមកបដិសន្ធិមានមេត្តាករុណាប្រៀនប្រដៅ មនុស្សឱ្យផុតពីសេចក្តីអាក្រក់ ព្រមលះបង់ជីវិតដើម្បីសងជួយសេចក្តីអាក្រក់ទាំងឡាយដែលមនុស្សសាងមក ព្រមប្រគល់ខ្លួន "ទទួលបាប" តាមប្រវត្តិសាស្ត្រដែលមានពីបុរាណ ហើយក្រោយមកមនុស្សទាំងឡាយទទួល ព្រះយេស៊ូជាមេស្ស៊ីអាហ៍ជាបុត្ររបស់ព្រះជាម្ចាស់។ ដោយហេតុនេះ ពពួកគ្រិស្តទើបនាំគ្នារាប់អានព្រះយេស៊ូ ស្មើគ្នាជាព្រះអំណាចឬអានុភាពប្រការមួយទៀត។ មានប្រការមួយទៀតដែរដោយគតិទាំងពីរយ៉ាងនេះ គឺគតិទំនាក់ទំនងនឹងព្រះយ:ហូវ៉ា ទើបជាផលឱ្យកើតមានជំនឿក្នុងព្រះអំណាចរបស់ព្រះជាម្ចាស់ឬព្រះបិតានោះ មានព្រះអំណាចមួយទៀតតែងតែជាប់តាមជីវិតមនុស្សជានិច្ច ព្រះអំណាចនោះហៅថា (Holy Spirit ឬ Holy Gshost) តាមការរាប់អានគោល ៣ប្រការនេះ គឺគោលត្រីនិតិឬត្រីឯកានុភាព។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២១)

គ្រិស្តសាសនានិកាយអ័រថូដក្ស កាតូលិកនិងប្រូតេស្តង់ ព្រមទទួលគតិត្រីនិតិទូទៅទាំងអស់គ្នា គតិនេះ ប្រកាសដោយសារសាសនាចារ្យសំខាន់ ៣រូប គឺសាសនាចារ្យ បាស៊ិល (Bzil) សាសនាចារ្យគ្រេរីនៃនយសា (Gregory of Nasa) និងគ្រេកូរី នៃណាស៊ិអន្សាយ (Gregory of Nazianzua) ឬដែលហៅថា ក្រុមសាសនាចារ្យ ខែប្បាដូសៀនស៍ (Cappadocians) ក្នុងការប្រជុំសង្គាយនានៃសាសនាគ្រិស្តនាទីក្រុងកុងស្តង់ទីណូប ក្នុងព.ស.៩២៥ ក្រោយពេលព្រះយេស៊ូអស់ជីវិត ៣៨២ឆ្នាំ។

សាសនាចារ្យក្រុមនេះប្រកាសថា ព្រះអានុភាពទាំងនោះមានការសម្ព័ន្ធរវាងគ្នានិងគ្នាប្រដូចតែមួយជាមួយគ្នា ដូចជាដើមឈើ ផ្កាឈើ និងក្លិនរបស់ផ្កាឈើនោះ។

**គម្ពីរក្នុងសាសនា**

ដោយហេតុតែសាសនាគ្រិស្ត មានសាសនាជ្វីហ្វជាមូលដ្ឋាន ទើបអាចពោលបានថាគម្ពីររបស់សាសនាជ្វីហ្វ គឺគម្ពីរថ្មី (New Testament) មានគម្ពីរចាស់ (Old Testament) ជាគ្រឹះទាំងគម្ពីរចាស់និងគម្ពីរ ថ្មីរួមគ្នា ហៅថា ប៊ិប (Bible)។

គម្ពីរប៊ីប្លិ៍ ជំពូកដែលកាត់ចេញជាព្រះគម្ពីរថ្មី មាន២៧គម្ពីរ បែងចែកជាភាគឬផ្នែកធំៗ មាន ៤ផ្នែកគឺ ៖

១-កសប៉េល (Gospet) ឬព្រះវរសាសន៍ គម្ពីរផ្នែកនេះពិពណ៌នាអំពីប្រវត្តិជីវិត និងការទេសនាប្រៀនប្រដៅរបស់ព្រះយេស៊ូ។

២-ឯកទ៍ (Act) ឬព្រះបញ្ញត្តិ គម្ពីរផ្នែកនេះពិពណ៌នាអំពីកិច្ចការរបស់បណ្ដាសាវ័កព្រះយេស៊ូ អ្នកផ្សព្វផ្សាយសាសនា ក្រោយពីពេលសាស្ដាអស់ជីវិតដោយចំពោះ គឺការងារផ្សព្វផ្សាយសាសនារបស់ប៉ូល (ឬសន្តប៉ូល)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២២)

៣-អ៊ីពិស្តោឡារី (Epistilary) គម្ពីរផ្នែកនេះ តែងជាទំនងសំបុត្រ (ហេតុ) ខ្លីៗ មានទាំងអស់ ២១វគ្គ ក្នុងចំនួននោះ ១៤វគ្គ សម្ដែងអំពីកិច្ចការរបស់ប៉ូល និងសាវ័កដទៃទៀត ៧នាក់ និងនិយាយអំពីគតិជំនឿផ្សេងៗរបស់ជនជាតិជ្វីហ្វក្នុងសម័យព្រះយេស៊ូ គម្ពីរ១៤វគ្គនេះ ហៅម្យ៉ាងទៀតថា (Apocrypha)។

៤-អប៉ូកាលិព្ទិក (Apocalyptic) ឬ ទេពនិមិត គម្ពីរផ្នែកនេះពិពណ៌នាពីរឿងទេពនិមិត្តដែលកើតឡើងដល់ច្ចន ឬ យូហាន សាវ័កសំខាន់ម្នាក់របស់ព្រះយេស៊ូ។

គម្ពីរទាំងអស់នេះបណ្ដាអ្នកប្រាជ្ញជំនាន់ក្រោយ រួបរួមយកប្រវត្តិពាក្យប្រៀនប្រដៅរបស់ព្រះយេស៊ូ រឿងរ៉ាវរបស់សាវ័កសំខាន់ៗនិងរឿងរ៉ាវក្នុងប្រវត្តិសាស្ត្រដទៃៗ មករួមទុកជាមួយគ្នាជាល័ក្ខដ្ឋាន ប្រហែលប្រមាណព.ស.៧០០ សេស និងបានរួបរួមគ្នាទុកជាគម្ពីរដោយបរិបូណ៌ទាំងប៊ីប្លិ៍ចាស់ និងប៊ីប្លិ៍ថ្មីក្នុងសម័យព្រះបាទខុនស្ដែនទិន ជាអសោករបស់គ្រិស្ដសាសនា កាលព.ស.៨៦៨។

គម្ពីរប៊ិប្លថ្មី សរសេរជាភាសាក្រិក ដែលប្រកាន់ថាជាភាសាស័ក្តិសិទ្ធិរបស់លទ្ធិនេះ មានទំនាស់សេចក្ដីក្នុងគម្ពីរចាស់ជំពូកខ្លះ គម្ពីរទាំងអស់នេះប្រែចេញជាភាសាផ្សេងៗជាង ៥០០ភាសា។ មកដល់ជំនាន់ក្រោយ ការយល់ក្នុងគម្ពីរនៃគ្រិស្ដសាសនិកជន បានបែងចែកចេញទៅជាច្រើននិកាយទៀតដូចជា ឯប៉ិស្ដោប៉ាល, កាតូលិកបារាំងសេស, និកាយខ្វេកគ័រ, និកាយឌីអ៊ិស្ដ, និកាយម៉័រម៉ែន (Mormonism) និកាយគ្រិស្ទានសៃអែនស៍ (Scientism), និកាយយូនិតេលៀន (Unitarianism), និកាយសេវុនដេយ៍ ឯតវេន្ទិស្ដ (Adventist), និកាយអស្ស៊ុមស្សិន (Assumption), និកាយសេន្តកាប្រៀល (Gabriel), និកាយបាបទិស្ដ, និកាយកាលវិន (John Calvin) និកាយប្រេបៃតេរៀន (Prebyterian) និកាយមេថូឌិស្ដ (Mathodist) និកាយប្រ៊ូានស៊ិស្ស

កាន្ត (Franciscans) និងនិកាយសាក្សីព្រះយេហូវ៉ា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ១២៣)

និកាយសាក្សីព្រះយេហូវ៉ា ភាសាអង់គ្លេសហៅថា Jehovah's Witness តាមប្រវត្តិមានតំណាលថា ប្រហែល៨០ឆ្នាំមកនេះ មានពួកប្រូតេស្តង់ច្រើនពួកជាមួយគ្នា មានការរួញរាក្នុងចិត្ត មកពីភាពច្របូកច្របល់ ក្នុងពាក្យប្រៀនប្រដៅនិងការមិនជាក់ច្បាស់នៃគោលការណ៍ផ្សេងៗក្នុងគ្រិស្តសាសនា ទើបមានការរួមជាក្រុមឡើងនៅរដ្ឋផេនស៊ីលវេនៀ រកមធ្យោបាយកែទម្រង់ពាក្យប្រដៅឱ្យត្រឡប់ចូលទៅកាន់ដើមវិញដោយចំពោះ គឺបែបយ៉ាងក្នុងការទមស្ការព្រះយេហូវ៉ា។

អ្នកតាំងនិកាយនេះឈ្មោះ ឆាលរសេរ្សល្ល (ក្នុងរវាងព.ស.២៣៩៥ ដល់ ២៤៥៩) ជាជនជាតិអាមេរិក បានទទួលការសិក្សាសាមញ្ញធម្មតា តែជាអ្នកយកចិត្តទុកដាក់ក្នុងសាសនា បានជួបប្រទះពាក្យប្រដៅដែល និយាយពីរឿងមនុស្សត្រូវបានទទួលរងទុក្ខទោសជាប់បន្តពីអាដាម និងត្រូវមានបាបជានិរន្តរ៍។ បដិសេធសេចក្ដីមានប្រាកដក្នុងគម្ពីរចាស់ ប្រកាសថាពាក្យប្រដៅនេះខុស ហើយប្រកាសថា ព្រះយេស៊ូស្ដេចនឹងត្រឡប់មកកាន់លោកនេះ ជាលើកទីពីរក្នុងរដូវស្លឹកឈើជ្រុះរវាងព.ស.២៥១៧ ឆ្នាំនោះនិងថ្ងៃនោះជាថ្ងៃរបស់ព្រះ យេហូវ៉ា ឬថ្ងៃនៃសាក្សីព្រះយេហូវ៉ា។ ចាប់ពីពេលក្រោយនេះទៅ មនុស្សស្លាប់ទៅហើយនឹងត្រឡប់ជាមានជីវិតរស់ឡើងវិញទាំងអស់ ការពិភាក្សាពីកំហុសរបស់មនុស្ស ត្រូវប្រើពេលវេលាប្រហែល១.០០០ឆ្នាំ លុះស្រេចហើយ នឹងមានការតាំងអាណាចក្ររបស់មេស្ស៊ីអាហ៍ (Kingdom of Messiah) ឡើងលើផ្ទៃធរណី។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២៤)

តាមដូចបានប្រៀនប្រដៅតគ្នាមក សាក្សីនៃព្រះយេហូវ៉ា មានការបញ្ចេញនាមសាស្ដាព្យាករណ៍ អ្នកដែលមកឧប្បត្តិមុនសម័យព្រះយេស៊ូ មានណូអាហ៍ អាប្រាហាំ មោសេសចេរេមិអាហ៍ ទើបមកដល់ព្រះយេស៊ូ ក្រោយគេបំផុត។ ពាក្យប្រៀនប្រដៅបានអះអាងថាសាស្ដាព្យាករណ៍ទាំងនេះ គឺជាសាក្សីនៃព្រះយេហូវ៉ា ពាក្យប្រដៅធ្វើឱ្យមានការរំភើប កើតដល់ជនជាកម្មករនិងមនុស្សជាន់កណ្ដាលយ៉ាងទូលំទូលាយ។ ក្នុងព.ស.២៤២១ គណៈសាក្សីព្រះយេហូវ៉ា បានតាំងសមាគមន៍ផ្សព្វផ្សាយលទ្ធិរបស់ខ្លួនហៅថា ប៉មសង្កេតការណ៍ (Watch Tower) បានបោះពុម្ពសៀវភៅមានឈ្មោះស្មើនឹងសមាគមន៍ ចេញចំណាយទៅគ្រប់ទិសទីសមាគមន៍ អ្នករៀនគម្ពីរប៊ីប្លទូទៅ បានជួយជាកម្លាំងក្នុងការចំណាយ និងផ្សព្វផ្សាយលទ្ធិ

របស់និកាយនេះជាច្រើនៗ សមាគមន៍នេះបានបោះពុម្ពសៀវភៅមួយឈុតហៅថា Student in the Scriptures ជាចំនួនច្រើនលានក្បាល លក់ដាច់អស់គ្មានសល់ បានផលជាមាសប្រាក់និង សេចក្តីជ្រះថ្លា ជួយឱ្យគណៈសាក្សីនៃព្រះយេហូវ៉ា មានទីស្នាក់ការពាសពេញពិភពលោក មិនតិចជាង១.២០០កន្លែងៗ ធាលរស្សេលល៍ អ្នកផ្តើមតែងតាំងលទ្ធិនេះទើប នឹងអស់ជីវិត កាល ព.ស.២៤៥៩ វាំងសង្គ្រាមលោកលើកដំបូងៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១២៥)

គោលការណ៍របស់និកាយសាក្សីព្រះយេហូវ៉ា អាងពាក្យប្រៀនប្រដៅមានប្រាកដ ក្នុងគម្ពីរអេសាយ៉ា ជំពូកទី២៣ ១១០-១២ ដែលពោលទុកមកៗ ព្រះយេហូវ៉ាត្រាស់ថា អ្នក រាល់គ្នាជាសាក្សីរបស់យើង អ្នករាល់គ្នាជាអ្នកបម្រើដែលយើងបានជ្រើសរើសទុកហើយលៗ ពុំមានព្រះជាម្ចាស់អង្គណាកើតឡើងមុននៅពីមុខយើងទេ និងកើតឡើងក្រោយយើងដែរៗ ព្រះយេហូវ៉ាត្រាស់ថា យើងបានប្រកាសហើយ យើងបានជួយហើយ យើងបានសម្តែង ហើយ ពុំមានព្រះជាម្ចាស់ដទៃក្នុងវាំងអ្នករាល់គ្នាទៀតទេ ព្រោះដូច្នោះហើយអ្នកចូរជាសាក្សី នៃយើងៗ លៗ

សាសនាគ្រិស្ត ជាសាសនាធំ និងមានសារសំខាន់នៅក្នុងសង្គមគ្រិស្តសាសនិកជន គ្រប់និកាយ ជាង ១.០០០លាននាក់ ដែលខ្ចរខ្ចាយទូទៅក្នុងលោក ជាក្រុមធំនៃសង្គមដោយប ញ្ញត្តិនិងចរិយាធម៌របស់លោកជាសាស្តា បានផ្សព្វផ្សាយទូទៅជាធម៌ប្រចាំសង្គមនៃលោក មួយផ្នែកនៅក្នុងបច្ចុប្បន្នៗ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២៦)

### សាសនាអ៊ិស្លាម សាសនានៃសន្តិ

សាសនាអ៊ិស្លាម ជាសាសនាធំក្នុងចំនួនសាសនាធំក្នុងលោក ៣សាសនាគឺ សាសនា ព្រះពុទ្ធសាសនា គ្រិស្តនិងសាសនាអ៊ិស្លាម មានអ្នករាប់អានច្រើនជាង ៥០០លាននាក់ នៅ តាមផ្នែកផ្សេងៗនៃសកលលោក សាសនាអ៊ិស្លាមកើតក្នុងជ្រោយអារ៉ាប់ដ៏ធំទូលាយនៅ កណ្តាលទន្លេខ្សាច់ដ៏ក្តៅធំៗ

អ្នកប្រកាសសាសនានេះ មាននាមតាមទទួលការសរសើរថា “មហាហ្មុត” ប្រកាស គោលការណ៍ថា“ពុំមានព្រះជាម្ចាស់អង្គឯណាក្នុងលោកនេះ ក្រៅអំពីព្រះអល្ល៉ោះហ៍ (អាហ្លា) ឡើយ”ៗ សាវ័ករបស់អ៊ិស្លាម មានជំនឿថា ព្រះមហាហ្មុតជានះប៊ី គឺសាស្តាព្យាករណ៍ ដែល

បានទទួលបញ្ជាមកពីព្រះអល្លោះហ៍ព្រះអង្គនោះ ដោយប្រការដូច្នេះ ទើបរាប់បានថា អ៊ិស្លាម ជាសាសនាប្រភេទឯកទេវនិយម (Mono Theism) គឺរាប់អានព្រះតែមួយអង្គ។

"អ៊ិស្លាម" ជាភាសាអារ៉ាប់ប្រែថា "សន្តិ" មានន័យសេចក្តីខាងផ្លូវសាសនាថា ការថ្វាយខ្លួនដល់ព្រះជាម្ចាស់ (Submission to the God) ឬការថ្វាយខ្លួនចំពោះទឹកព្រះទ័យរបស់ព្រះជាម្ចាស់ដើម្បីសន្តិ បើមិនព្រមថ្វាយខ្លួនដល់ព្រះទេ រមែងមិនមានសន្តិឡើយ។ អ្នករាប់អានសាសនានេះហៅថា "មូស្លីម" ប្រែថា អ្នកស្រឡាញ់សន្តិ តាមន័យសេចក្តីផ្លូវសាសនាថា អ្នកប្រគល់កាយថ្វាយជីវិតដល់ព្រះជាម្ចាស់ដើម្បីសន្តិ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២៧)

ព្រះជាម្ចាស់មួយអង្គ ដែលមូស្លីមប្រគល់កាយថ្វាយខ្លួននោះ ទ្រង់ព្រះនាមថា អល្លោះហ៍ ឬអល្លា មានការវិនិច្ឆ័យថា ជាព្រះអង្គតែមួយជាមួយគ្នានឹងព្រះជាម្ចាស់ (មួយអង្គ) របស់ជ្វីហ្វគឺព្រះយេះហូវ៉ា ព្រះនាមយេះហូវ៉ា មានពាក្យហៅម្យ៉ាងទៀតតាមភាសារបស់ផៅពង្សសេមិទិក ក្នុងក្រុមនេះគឺ (El) អេលោហ៊ិម (Elohim) ឬអេលោហា (Eloha) ដែលប្រែថា "ទ្រង់មានពលំរឹងប៉ឹង" តមកពាក្យក្លាយជាពាក្យថា អល្លាហ៍ (Allah) គឺអល្លោះហ៍ ឬអានថា Ta-ilha ក្នុងភាសាអារ៉ាប់ ន័យសេចក្តីត្រង់ពាក្យថា God ក្នុងភាសាអង់គ្លេស (មើលរឿងព្រះយេះហូវ៉ា ក្នុងសាសនាជ្វីហ្វ)។

ការវិនិច្ឆ័យនេះ មានសេចក្តីជាច្រើនយ៉ាងប្រកបដោយពាក្យអធិប្បាយ ប្រវត្តិរបស់ព្រះមហាៈហ្មុតខ្លួនឯងថា ព្រះមហាៈហ្មុត មានជីវៈជាអ្នកលក់ដូរ ធ្វើដំណើរឆ្លងកាត់ទៅដល់ក្រុងយេរូសាលឹម គឺផែនដីប៉ាឡេស្ទីន ដែលជាប់នឹងទន្លេមេឌីតេរ៉ាណេផ្នែកខាងត្បូង ខនេះជាផ្លូវមួយ។ ឯផ្លូវមួយទៀតគឺក្នុងរវាងពេលនោះ មានពួកជ្វីហ្វចូលមកអាស្រ័យ នៅក្នុងដែនដីអារ៉ាប់ជាច្រើន ព្រះមហាៈហ្មុតបានទទួលគតិផ្លូវសាសនារបស់ជនជាតិជ្វីហ្វមកតាំងពីពេលនោះ។

ទើបសរុបសេចក្តីមកថា សាសនាអ៊ិស្លាមដែលប្រកាសដោយព្រះមហាៈហ្មុត មានគតិផ្លូវសាសនាទាក់ទងមកពីសាសនាជ្វីហ្វមួយផ្នែក និងអាចទាក់ទងមកពីសាសនាសោរអស្ទ្រឺរបស់ជនជាតិអ៊ីរ៉ង់មួយផ្នែកទៀតក៏ថាបានព្រោះមានសេចក្តីប្រាកដថា ព្រះមហាៈហ្មុត ធ្លាប់ធ្វើដំណើរឆ្លងកាត់ទៅដល់ឈូងសមុទ្រប៉ែក្សខ្លះដែរ។ ចំណែកព្រះនាមរបស់ព្រះជាម្ចាស់នោះ តាមរូបភាពដែលពោលមកពីខាងដើម គួរនឹងសន្និដ្ឋានបានថា អាល្លា និងយេះហូវ៉ា ជា

ព្រះតែមួយអង្គ ឬទាក់ទងដល់គ្នានឹងគ្នាតាមគតិផ្លូវសាសនា ដែលរាប់អានពីដើមមកនៅជ្រោយអារ៉ាប់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១២៨)

ជនជាតិអារ៉ាប់ក្នុងសម័យព្រះមហៈហ្មូត បែកខ្ញែកចេញជាច្រើនក្រុម ស្រុកទេសបែងចែកជា ៣ក្រុមគឺ ឆេបា (Sheba) នេជ្ដ (Nejd) និងហេយាស (Hejas) ពុំមានសេចក្ដីសាមគ្គីខាងការគ្រប់គ្រងក្រុមនីមួយៗ មានមេដឹកនាំដែលភាគច្រើនជាអ្នកបួស និងអ្នកជំនួញមានអំណាចគ្រប់គ្រងមនុស្សបានក្នុងផ្លូវជំនួញនិងផ្លូវសាសនា។ អារ៉ាប់ទាំងបីក្រុមដណ្ដើមអំណាចវិវាទទាស់ទែងគ្នារហូតមក ដោយមានគំនិតផ្សេងៗគ្នា មានសាសនានិងព្រះជាម្ចាស់ រាប់អានបែកខ្ញែកផ្សេងៗគ្នា។

អាជីវៈសំខាន់របស់ជនជាតិអារ៉ាប់ពីបុរាណ គឺអាជីវៈធ្វើជាងនិងអាជីវៈលក់ដូរ ដាក់ផ្ទុកទំនិញលើខ្នងអូដ្ឋ ពនេចរត្រាច់រង្គាត់ចេញទៅតាមភូមិស្រុកឆ្ងាយៗ រហូតកាត់ឆ្លងទន្លេខ្សាច់ដ៏ធំល្វឹងល្វើយ។ អ្នកជំនួញទាំងនេះមានមជ្ឈមណ្ឌលសម្រាប់ជំនុំការលក់ដូរនិងសាសនា នៅកន្លែងមួយ គឺទីក្រុងមេក្កៈ (Maca-Makkah) ប្រទេសអារ៉ាប់សាអ៊ូឌិត ដែលជាទីក្រុងឧប្បត្តិ របស់មហៈហ្មូត និងជាទីក្រុងស្ថលរបស់សាសនាអិស្លាមក្នុងបច្ចុប្បន្ន។

ទន្លេខ្សាច់ដ៏ក្ដៅធំ ធ្វើឱ្យជនជាតិអារ៉ាប់ជាមនុស្សអត់ធន់ រឹងប៉ឹង ជិះសេះពូកែ ជាមិត្តស្មោះត្រង់នឹងគ្នា មាននិស្ស័យស្រឡាញ់សត្វ ក្លាហាន ចូលចិត្តនិទានរឿងនិទានរបស់អារ៉ាប់ ជានិទានសប្បាយរីករាយជាជាងនិទានរបស់ផៅពង្សមនុស្សណាៗក្នុងលោក។ បើនឹងនិយាយថា ដោយហេតុតែនៅកណ្ដាលវាលខ្សាច់ដ៏ធំល្វឹងល្វើយនិងហ្វូងដួងតារានៅលើមេឃនេះហើយ ជាមូលហេតុឱ្យកើតកវីនិពន្ធ និងរឿងរ៉ាវគួរឱ្យចាប់ចិត្តជាអាទិ៍ រឿងដ៏វែងអន្លាយរបស់រាត្រីអារ៉ាប់ (មួយពាន់មួយយប់)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ១២៩)

## ជីវិតព្រះមហៈហ្មូត

ក្នុងក្រុងមេក្កៈ មានអារ៉ាប់ផៅពង្សគួរេជឬគួរអ៊ិជ (Qureysh) ជាពូជពង្សធំជាងគេមានអាជីវៈដូចជនជាតិអារ៉ាប់ទាំងឡាយ ដែលបានពោលមកហើយពីខាងដើម ព្រះមហៈហ្មូតឧប្បត្តិក្នុងពពួកផៅពង្សនេះ កាលពីព.ស.១១១៣ ជាបុត្ររបស់អាប់ឌុល្លាហ៍ មានឈ្មោះ ដើមថា អាប៊ូ កស៊្សិម តមក អាប៊ូ + កស៊្សិម ប្រកាស ពាក្យប្រដៅរហូតដល់មានមនុស្សជ្រះថ្លាទើបបានទទួលនាមថ្មីថា មហៈហ្មូត (មូហាំហ្មូត) ប្រែថា អ្នកគួរសរសើរបូជា។

តាមប្រវត្តិសម្តែងថា ត្រកូលរបស់របស់មហាហ្មូតតឹងរ៉ឹងក្នុងសាសនា ព្រះមហៈហ្មូត ត្រូវបាត់បង់ឪពុក មុននឹងសម្រាលចេញពីគភ៌មាតា ២ខែ លុះកើតហើយបានរវាងប្រហែល ៤ ឬ៦ឆ្នាំ មាតាក៏បាត់បង់ជីវិតទៅទៀត ត្រូវនៅក្មេងកំព្រា បានទទួលការចិញ្ចឹមថែរក្សាពីឪពុកធំ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣០)

ឪពុកធំរបស់ព្រះមហៈហ្មូតឈ្មោះ អាប៊ូ តាលិប បង្រៀនវិជ្ជាលក់ដូរដល់ក្មួយ បញ្ជូនក្មួយចេញទៅលក់ដូរតាមទីក្រុងឆ្ងាយៗ ព្រះមហៈហ្មូតបានឱកាសត្រាច់ចរសិក្សាក្នុងពេលនោះ តាមប្រវត្តិមហៈហ្មូតមិនបានចូលសាលារៀន មិនចេះអានសៀវភៅ តែមិនជាការចម្លែក ព្រោះមនុស្សមិនចេះអក្សរ បានធ្វើធំជាច្រើន។

ព្រះមហៈហ្មូត ជាជនជាតិអារ៉ាប់ខ្នាតកណ្តាល មានសម្បុរខ្មៅ សក់រួញអង្កាញ់ កែវភ្នែកខ្មៅមុតសម្តែងនិស្ស័យជាអ្នករឹងប៉ឹង ខ្លួនមានរោមក្រាស់ ជាលក្ខណៈ មនុស្សគិតច្រើន ជាមនុស្សរៀបរយស្អាតបាត ព្រះមហៈហ្មូតជាមនុស្សនិយាយពិរោះ និង មានកតញ្ញូ។

លុះមានវ័យធំឡើង ជីវិតរបស់ព្រះមហៈហ្មូតមានការលំបាកលំបិន ត្រូវធ្វើដំណើរចេញទៅលក់ដូរភូមិឆ្ងាយៗ ជួនកាលត្រូវសម្តែងការក្លាហានតស៊ូជាមួយមនុស្សផៅពង្សដទៃៗ តាមប្រវត្តិពោលថា ព្រះមហៈហ្មូត ជាមនុស្សមានរោគប្រចាំកាយ រោគមានជានិច្ចនោះគឺ រោគខ្យល់និងឈឺក្បាល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣១)

ការឧស្សាហ៍ប្រឹងប្រែង ឈ្លាសវៃក្នុងការលក់ដូរ និងជាអ្នកនិយាយស្តីពីរោះរបស់ព្រះមហៈហ្មូត ធ្វើឱ្យពេញចិត្តដល់ស្រីមេម៉ាយម្នាក់ មានមុខរបរលក់ដូរ ឈ្មោះ ខាឌិយាហ៍ (Khadejah) មានអាយុចាស់ជាង មហៈហ្មូត ១៥ឆ្នាំ។ នាងបានជួយមហៈហ្មូតមើលថែទាំទំនិញយកទៅចំណាយនៅទីក្រុងឆ្ងាយៗ ត្រឡប់មក ពេលណាបានចំណេញច្រើនរាល់លើក នាងខាធិយាហ៍ទុកចិត្តប្រគល់កិច្ចការទាំងអស់ មុខរបរលក់ដូរឱ្យដល់មហៈហ្មូត នៅទីបំផុតសេចក្តីទុកចិត្ត ក៏ក្លាយមកជាសេចក្តីស្រឡាញ់ទាំងពីរបានគ្នាជាស្វាមីភរិយារួមគ្នា ជ្រោមជ្រែងកិច្ចការរកស៊ីរួមជីវិតជាមួយគ្នា បានចម្រើនរហូតមក។

ព្រះមហៈហ្មូតជាមនុស្សចូលចិត្តសិក្សា មានការទោរទន់ទៅរកសេចក្តីស្ងប់។ ក្នុងពេលក្រោយមក ជីវិតកាន់តែរឹងប៉ឹងឡើងដោយសារភរិយា មិនចាំបាច់ត្រូវធ្វើដំណើ រត្រាច់ចរដូចពីមុន ទើបប្រើពេលវេលាទំនេរពីការលក់ដូរ ទៅស្វែងរកសេចក្តីស្ងប់តាមល្អាងភ្នំវាលល្ហល្ហេវ និងទន្លេខ្សាច់ រកសេចក្តីស្ងប់ខាងផ្លូវចិត្ត សិក្សាការប្រព្រឹត្តទៅរបស់ធម្មជាតិដ៏

ល្វឹងល្វើងល្ហាល្ហៃ ដូចដែលធ្លាប់ធ្វើមកយូរៗចិត្តកាន់តែចង់រិះរកសេចក្ដីស្ងប់ និង ចង់គេចចេញឱ្យឆ្ងាយពីការជំពាក់ជំពិនក៏រឹងរឹតតែដុះដាលឡើង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ ២ ទំព័១៣២)

**ទទួលទេវឱង្ការ**

តាមរឿងតំណាលថា យប់ថ្ងៃមួយ ក្នុងខែរ៉ាម៉ាដាន (ខែ ៩របស់អ៊ិស្លាម) ព្រះមហាហ្ម៉ូតអង្គុយរកសេចក្ដីស្ងប់នៅក្នុងល្អាងភ្នំហិរ៉ា ពេលចិត្តកំពុងតែស្ងប់ ទេវឱង្ការមួយប្រាកដឡើងក្នុងដួងចិត្ត (Revelation) ទេវឱង្ការនោះជាសំឡេងខ្សឹបរបស់មហាទេពកាប្រៀល (Gabriel) ឬយិប្រាអ៊ិល (Jibra-il) ជាអ្នកទទួលទេវឱង្ការអំពីព្រះអាហ្លាថា “ចូរអាន” ឬ “ចូរទន្ទេញ” និងថា “ក្នុងនាមរបស់ព្រះអាហ្លា ទ្រង់ជាព្រះមានព្រះគុណធំនិងព្រះមហាករុណាធំ ទ្រង់ជាអ្នកសាងលោកនិងសាងមនុស្ស ដោយព្រះលោហិត។ ល។ ហើយទឹងថា “ពុំមានព្រះជាម្ចាស់អង្គណាក្រៅអំពីព្រះអាហ្លាតែមួយអង្គប៉ុណ្ណោះ”(មើលរឿងទេពបរិវារខាងមុខ)។

កាលបើបានទទួលទេពនិមិត្ត ព្រះមហៈហ្ម៉ូតធ្វើដំណើរត្រឡប់ទៅផ្ទះប្រាប់រឿងរ៉ាវផ្សេងៗ ដែលខ្លួនបាននិមិត្តឃើញឱ្យភរិយាជ្រាប នាងខាឌីយាហ៍ ជាស្រីស្រឡាញ់ស្វាមី និងរងចាំជ្រោមជ្រែងឋានៈរបស់ស្វាមីរហូតមក នាងជាអ្នកប្រកបដោយសទ្ធាក្នុងសាសនា ទើបនិយាយលើកទឹកចិត្តប្ដីថា សំឡេងព្រខ្សឹបមកនោះ ជាសំឡេងបញ្ជារបស់ព្រះជាម្ចាស់ លោកជាមហាទេព ទ្រង់ព្រះករុណាជ្រើសរើសឱ្យជានៈប៊ី (សាស្ដាព្យាករណ៍) ជាអ្នកបន្ដពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ក្នុងពេលនោះព្រះមហៈហ្ម៉ូតមានអាយុ ៤០ឆ្នាំ។

តាំងតែពីថ្ងៃនោះមក ព្រះមហៈហ្ម៉ូតក៏មានកម្លាំងចិត្ត និងទុកចិត្តខ្លួនឯងថាជាអ្នកដែលព្រះជាម្ចាស់ទ្រង់ប្រោសប្រណីខ្លួន រាប់អាននិមិត្តដែលប្រាកដដល់ខ្លួន។ ការធ្លាប់ជាប់ជំពាក់ក្នុងសាសនា រឹងរឹតតែបន្ថែមឱ្យមានកម្លាំងចិត្ត។ ព្រះមហៈហ្ម៉ូតចាប់ផ្ដើមពិចារណានូវផលល្អផលអាក្រក់អំពីជំនឿរបស់មនុស្សទាំងឡាយ ហើយក្នុងទីបំផុតក៏សម្រេចចិត្តផ្ដើមប្រៀនប្រដៅមនុស្ស ព្រះមហៈហ្ម៉ូតបង្រៀនដំបូង គឺនាងខាឌិយាហ៍ ភរិយារបស់ខ្លួនឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣៣)

ឋានៈគ្រួសាររបស់ព្រះមហៈហ្ម៉ូត ក្នុងពេលក្រោយបានភរិយាជួយជាកម្លាំងយ៉ាងច្រើន ធ្វើឱ្យព្រះមហៈហ្ម៉ូត មានឱកាសបានសិក្សារកការចេះដឹង និងប្រកាសគតិសាសនាថ្មីរបស់ខ្លួន។ ព្រះមហៈហ្ម៉ូតមិនបាច់ធ្វើដំណើរទៅលក់ដូរដូចពីមុន នាំយកផលកម្រៃរបស់ខ្លួន

រកបានពីដើម មកចាយវាយក្នុងការបង្រៀនមនុស្ស គូស្វាមីភរិយានៅរួមសុខទុក្ខជាមួយគ្នា អស់ពេលដ៏យូរហួត ២៦ឆ្នាំ។

ទីកន្លែងព្រះមហៈហ្ម៊ូតកំណត់យក ជាកន្លែងប្រកាសសាសនារបស់ខ្លួន គ្រាដំបូង កន្លែងដែលមានមនុស្សរាប់អានសាសនាផ្សេងៗ មកជុំទុំគ្នាជាច្រើន គឺទីប្រតិស្ឋានថ្មបួនជ្រុង ពណ៌ខ្មៅ បាកាហ៍ ដែលជាមហាបូជនីយស្ថានរបស់ជនជាតិអារ៉ាប់ទាំងពួងក្នុងបច្ចុប្បន្ន។

ការរើសយកទីកន្លែងប្រជុំជនយ៉ាងនេះ ជាកន្លែងប្រកាសពាក្យប្រៀនប្រដៅ នាំឱ្យអន្ត រាយណាស់ តែអាស្រ័យដោយអ្នកធ្វើជាមនុស្សក្លាហានមានចិត្តសន្ធាយ៉ាងខ្ជាប់ខ្ជួន ជឿថា ខ្លួនអាចធ្វើបាន ហើយធ្វើបានមែន។

**ប្រកាសសាសនា**

ព្រះមហៈហ្ម៊ូតបដិសេធគតិផ្លូវសាសនា ដែលមនុស្សទាំងឡាយរាប់អានមកតាំងពី ដើម គឺការរាប់អានព្រះជាច្រើនអង្គ ព្រះមហៈហ្ម៊ូតប្រាប់មនុស្សទាំងឡាយថា ការសាងរូបព្រះ ការបូជាព្រះធម្មជាតិផ្សេងៗគ្នា មិនអាចនឹងប្រព្រឹត្តទៅដើម្បីការរួបរួមគ្នាតែមួយបានទេ ព្រះ ជាម្ចាស់ទាំងនោះ មិនមែនមានពិតទេ ព្រះជាម្ចាស់អង្គពិតប្រាកដមានតែមួយព្រះអង្គគឺ ព្រះ អាហ្លាជាអម្ចាស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣៤)

ព្រះមហៈហ្ម៊ូត មានជំនឿជឿជាក់ថា មនុស្សជាតិណាធ្វើបាបអាក្រក់ជូជាតិ ដោយការ បូជាព្រះមិនត្រឹមត្រូវនិងត្រូវកាត់សេចក្ដីរឿងបុណ្យបាបរបស់ខ្លួនក្នុងថ្ងៃលោកនេះត្រូវរលាយ រលត់ ដូចមានពាក្យប្រដៅក្នុងគម្ពីរថា “កាលបើស្ថានសួគ៌បែកខ្ទេកចេញ, កាលដួងតារាខ្ចាត់ ខ្ចាយទៅ, កាលណាបណ្ដាមហាសមុទ្ររវិលវល់ច្របូកច្របល់ និងកាលបើរណ្ដៅកប់សព ទាំងឡាយផ្ទារផ្ដាប់ត្រឡប់ត្រឡិន កាលនោះដួងវិញ្ញាណទាំងឡាយ ទើបអាចនឹករឭកដឹងថា ខ្លួនបានធ្វើអំពើណានីមួយ និងនៅមិនទាន់បានធ្វើអំពើណាខ្លះ”។

ព្រះមហៈហ្ម៊ូតជឿនិងប្រៀនប្រដៅថា ការសូត្រមន្តភាវនា ជារបស់សំខាន់ ការសូត្រ មន្តជាផ្លូវទៅកាន់ឋានសួគ៌ និងដាស់តឿនអ្នកសូត្រថា បើសូត្រតែមាត់មិនតាំងចិត្តនោះ រមែង មិនបានទទួលឱ្យចូលទៅក្នុងព្រំដែនព្រះមហាករុណា ព្រោះថា “វិបត្តិនឹងកើតមានដល់អ្នក សូត្រមន្តភាវនា ដែលមានការអណ្ដែតអណ្ដូងចំពោះការភាវនានោះ”។

“ការបែរមុខទៅទិសខាងលិច ឬទិសខាងកើត មិនមែនជារឿងរបស់ការកុសលទេ បើនឹងឱ្យបានទទួលបុណ្យកុសលគឺ ការជឿក្នុងព្រះជាម្ចាស់តែម្យ៉ាងប៉ុណ្ណោះ”។

កាលព្រះមហៈហ្ម៉ត់ចាប់ផ្តើមប្រកាសធម៌ មានអាយុ ៤៥ឆ្នាំ ឆ្នាំដំបូងៗមិនបានផល ណាស់ណាទេ តែនាងខាឌិយាហ៍ភរិយាគូជីវិត ជាអ្នករង់ចាំឱ្យកម្លាំងចិត្តដល់ស្វាមី ទើបខំ ព្យាយាមពេញទំហឹងជាជំនួយក្នុងការផ្សាយសាសនាថ្មីនេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣៥)

សេចក្តីព្យាយាមរបស់ព្រះមហៈហ្ម៉ត់ បានលទ្ធផលយឺតណាស់និងមានអន្តរាយច្រើន គឺពាក្យប្រៀនប្រដៅរបស់ព្រះមហៈហ្ម៉ត់ ត្រូវពួកគូរេជជាពូជពង្សគ្នាឯងជំទាស់គ្រប់ៗគ្នាបាន បញ្ជើចបញ្ជើនិងរង់ចាំរាំងអ្នកណាដែលមានជំនឿ។ ដួនកាលមានការលបលួចប្រទូស្តរ៉ាយ ធ្វើបាបឱ្យដេកហាលក្តៅហើយវាយដំបន្ទំចិត្ត អ្នកខ្លះរហូតដល់បាត់បង់ជីវិតក៏ មាន តែព្រះម ហៈហ្ម៉ត់មិនញញើតគឺនៅតែប្រកាសជានិច្ចថា បើប្រសិនជាអ្នកណា មិនលះ បង់សាសនា គោរពបូជារូបតាំងពីដើមមកទេ ព្រះជាម្ចាស់នឹងដាក់ទោស។

រឿងការធ្វើបាបអ្នកកាន់សាសនាថ្មី ក្លាយទៅជាការបែកបាក់យ៉ាងធំធេង រវាងសាវ័ក ថ្មីរបស់ព្រះមហៈហ្ម៉ត់និងពួកផៅពង្សគូរេជ ដែលជាពួកអ្នកកាន់សាសនាចាស់។ មកដល់ ពេលនេះ ព្រះមហៈហ្ម៉ត់សម្តែង សេចក្តីក្លាហានប្រកាសពាក្យប្រដៅច្រើនឡើង រហូតដល់ត្មះ តិះដៀលរូបគោរព ដែលបុព្វបុរសធ្លាប់គោរពបូជា ដោយចេញមុខតែម្តង ធ្វើឱ្យក្តៅក្រហាយ ដល់អាប៊ូតាលិប ជាឪពុកធំ ធ្លាប់ចិញ្ចឹមថែទាំព្រះមហៈហ្ម៉ត់មកពីដើម។ អាប៊ូតាលិប រំឭក ជាសតឿនក្មួយដោយព្រួយបារម្ភ សូមកុំឱ្យលះបង់ចោលសាសនា និងការរាប់អានតាំងពី ចាស់ទុំរបស់វង្សត្រកូល។ ព្រះមហៈហ្ម៉ត់ឆ្លើយថា "កាលបើមនុស្សពួកនោះ អាចបណ្តាលឱ្យ ព្រះអាទិត្យ មកនៅក្នុងដៃស្តាំ និងឱ្យព្រះចន្ទមកនៅក្នុងដៃឆ្វេងបាន ពេលនោះទើបហាម ប្រាមចុះ ក្មួយមិនយកចិត្តទុកដាក់អ្វីទាំងអស់ ក្រៅអំពីបញ្ជារបស់ព្រះជាម្ចាស់តែមួយព្រះអង្គ ប៉ុណ្ណោះ"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣៦)

ព្រះមហៈហ្ម៉ត់និយាយទៅហើយនឹកតូចចិត្ត ដែលត្រូវធ្វើឱ្យឪពុកធំក្តៅប្រហាយ ទើប កាត់ចិត្តឱ្យសាវ័ក និងញាតិមិត្តជិតដិតរត់ចេញទៅនៅប្រទេសអេត្យូពី ឯខ្លួនឯងប្រកាស ពាក្យប្រដៅនៅក្នុងទីក្រុងមេក្កៈដដែល បានសាវ័កសំខាន់ៗទៀតជាច្រើននាក់ ដូចជា អាប៊ូ-បាគែអ្នកជំនួញធំ (បិតារបស់ភរិយាទទួលតំណែងជំនួស កាលព្រះមហៈហ្ម៉ត់អស់អាយុ) និង អ៊ូម៉ារ៍ អ្នកក្លាហានរបស់ជនជាតិអារ៉ាប់ជាដើម សូម្បីមានអ្នកទាំងពីរជួយជាកម្លាំង តែព្រះម ហៈហ្ម៉ត់ក៏នៅតែមិនអស់ពីភ័យ ព្រោះមានអ្នកបំណងប្រទូស្តរ៉ាយ ចង់យកជីវិតរហូតមក។

ពេលក្រោយមកទៀតភ័យរបស់មហៈហ្ម៉ុតកាន់តែខ្លាំងក្លាធំឡើងៗ ស្ទើគ្មានទីងកិត្តិស័ព្ទល្បីឈ្មោះក៏ច្រើនឡើងដែរ អ្នកទីក្រុងផ្សេងៗធ្វើដំណើរមកលក់ដូរនៅមេក្កៈ។ ពួកខ្លះនាំគ្នាតាំងខ្លួនជាសត្រូវ ពួកខ្លះនាំគ្នារាប់អានលទ្ធិថ្មី ដែលព្រះមហៈហ្ម៉ុតប្រៀនប្រដៅ មនុស្ស២ពួកក៏តាំងខ្លួនជាសត្រូវនឹងគ្នា ឆ្លៀតឱកាសប្រទូស្តរ៉ាយរាវគ្នានិងគ្នា ក្រុមមេក្កៈធ្លាប់ជាទីកន្លែងសុខស្ងប់ ត្រឡប់ទៅជាទីក្រុងមានទុក្ខលំបាកអសន្តិសុខវិញ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៣៧)

ការប្រព្រឹត្តទៅនៃជីវិតមហៈហ្ម៉ុត នៅទីក្រុងមេឌិនៈក្នុងពេលនោះជាជីវិតដែលលំបាកតោកយ៉ាក មានអន្តរាយត្រូវតស៊ូការពារនៅក្បែរៗព័ទ្ធជុំវិញព្រះមហៈហ្ម៉ុត ត្រូវប្រដៅឱ្យសាវ័កអត់ទ្រាំដល់ការលំបាកឱ្យគ្រប់ៗ គ្នាមានការជួយគ្នាទៅវិញទៅមក និងគ្រប់គ្នាត្រូវតស៊ូកម្ចាត់សេចក្តីអាក្រក់ របស់សត្រូវដោយអាវុធ។ ពាក្យប្រដៅរបស់ព្រះមហៈហ្ម៉ុត ដែលមានប្រាកដក្នុងគម្ពីរកូរ៉ាន សិស្សានុសិស្សបានជួបគ្នារួបរួមទុក្ខក្នុងពេលនោះបានយ៉ាងច្រើន និងមកពីការចាំបាច់នៃជីវិតក៏មិនដឹង? ទើបមានអ្នកយល់ថា ព្រះមហៈហ្ម៉ុតប្រដៅឱ្យផ្សព្វផ្សាយសាសនាដោយកម្លាំងអាវុធ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤៦)

ជីវិតនិងការប្រកាសពាក្យប្រដៅ "លទ្ធិព្រះអាឡា ជាមហាទេពទ្រង់សក្តានុភាពតែមួយព្រះអង្គ" កាន់តែយូរថ្ងៃ ក្លាយទៅជាចម្បាំងដណ្តើមជ័យជម្នះការពារលទ្ធិថ្មី និងបំផ្លាញលទ្ធិចាស់ ចាញ់ខ្លះឈ្នះខ្លះ ពេលខ្លះ ព្រះមហៈហ្ម៉ុតនិងសិស្សានុសិស្សត្រូវពួនសម្ងំនៅក្នុងក្រុងមេឌិនៈ សត្រូវហ៊ុំព័ទ្ធជាប់ស្ទើរអត់អាហារស្លាប់ទាំងក្រុងក៏មាន។ ចម្បាំងសាសនាគ្រាធំបំផុតមាន ២ ដង គឺចម្បាំងនៅតំបន់ព័ទ្រេះ និងវាលអ៊ូហ៊ុត (Uhud) ៣ម៉ៃ ពីក្រុងមេឌិនៈ ព្រះមហៈហ្ម៉ុតនាំសាវ័កចេញច្បាំងរាល់លើក ស្ទើរតែស្លាប់ខ្លួនឯងក៏មាន។

### ជ័យជម្នះ

ព្រះមហៈហ្ម៉ុត ធ្វើការចុះព្រមជាមួយនឹងការផ្សាយសាសនា កាលណាមានកម្លាំងខ្លាំងរួមគ្នាចេញទៅបង្ក្រាបបណ្តាទីក្រុងជិតៗ ដែលមិនព្រមរាប់អានលទ្ធិរបស់ខ្លួន តែសេចក្តីប្រាថ្នារបស់ព្រះមហៈហ្ម៉ុត ពុំទាន់មានផ្លូវសម្រេចបាន ដរាបណាមិនអាចនាំសាវ័កត្រឡប់ទៅក្រុងមេក្កៈ ដែលជាកន្លែងកំណើតរបស់ខ្លួន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤៦)

សាវ័ករបស់ព្រះមហៈហ្ម៉ុត ដែលត្រូវលះបង់ភូមិកំណើតនៅឯក្រុងមេឌិនៈនិងសាស្តារបស់ខ្លួននោះ នាំគ្នាស្វែងរកឱកាសត្រឡប់ទៅក្រុងមេក្កៈវិញ បំណងនេះដក់ជាប់ក្នុងចិត្តព្រះ

មហាហ្មុតថា ទោះបីជាយ៉ាងណាក៏ដោយចុះ ត្រូវតែត្រឡប់មេក្កៈ យកឈ្នះសត្រូវឱ្យទាល់តែបានដោយកម្លាំងនៃសទ្ធា។

ព្រះមហាហ្មុតនាំសាវ័កភៀសខ្លួនមកនៅមេឌិនៈចំនួន៦ឆ្នាំ។ ថ្ងៃមួយមាននិមិត្តប្រាកដសន្សឹមថានឹង បានត្រឡប់ទៅអង្គុយកណ្ដាលក្រុងមេក្កៈ កន្លែងប្រតិស្ឋានកាបាហ៍ ថ្មខ្មៅបួនជ្រុង មានសិស្សព័ទ្ធជុំវិញជាបរិវារ។ និមិត្តនេះជាកម្លាំងបន្ថែមឱ្យព្រះមហាហ្មុត ចង់នាំសាវ័កទៅនមស្ការទីស្ថានស័ក្ដិសិទ្ធិក្នុងទីក្រុងមេក្កៈរឹតតែខ្លាំងឡើង ព្រោះមានជំនឿថា ជានិមិត្តនាំឱ្យសម្រេចក្នុងការប្រកាសលទ្ធិតទៅ។

ព្រះមហាហ្មុត បានប្រឹក្សាជាមួយសាវ័កជិតស្និទ្ធ មានយោបល់ស្របគ្នាថា នឹងព្យាយាមទាក់ទងមេដឹកនាំធំៗ ជាជនជាតិគូរេជក្នុងក្រុងមេក្កៈ សូមអនុញ្ញាតធ្វើដំណើរទៅនមស្ការថ្មខ្មៅបួនជ្រុង ដោយសន្យាថាមិនស្ពាយអាវុធជាប់នឹងខ្លួន បោះបង់ចោលការកាប់សម្លាប់គ្នា ហើយនឹកស្មានថាអ្នកដឹកនាំគូរេជនឹងយល់ព្រម។

លុះស្រុះស្រួលគ្នាហើយ ព្រះមហាហ្មុតនាំសាវ័កជាងមួយពាន់នាក់ ឡើងជិះលើខ្នងអូដ្ឋនាំក្បួនសំដៅក្រុងមេក្កៈ ដល់ជាយក្រុងប្រើកូនប្រុសម្នាក់ជាមេត្រីទូត កូនធ្វើការសម្រេចព្រះមហាហ្មុតនាំសាវ័កអ៊ិស្លាម ចូលទៅនមស្ការថ្មខ្មៅបួនជ្រុងបាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤៧)

មានរឿងពោលមកថា ព្រះមហាហ្មុតនាំសាវ័កជាងមួយពាន់នាក់ ចូលទៅក្រុងមេក្កៈនោះ មិនឃើញមានមនុស្សសូម្បីតែម្នាក់ក៏គ្មាន ដូចជាទីក្រុងគេបោះបង់ចោល ព្រះមហាហ្មុតនាំសាវ័កត្រង់ទៅមហាវិហារ កាបាហ៍ ជិះអូដ្ឋប្រទក្សិណមហាវិហារ ៧ជុំ យកឈើច្រត់គោះថ្មខ្មៅ ៧ដង។ លុះស្រេចការបូជាហើយ នាំសាវ័កសូត្រមន្តដូចធ្លាប់ធ្វើមកនៅក្រុងមេឌិនៈ នេះរាប់ថាជាការនមស្ការលើកដំបូងនាក្រុងមេក្កៈ តាំងពីព្រះមហាហ្មុតរត់ភៀសខ្លួនពីពួកគូរេជចំនួន ៦ឆ្នាំ។

តើហេតុអ្វី ពេលមហាហ្មុតនាំសាវ័កចូលក្រុងមេក្កៈ មិនឃើញមនុស្សម្នាក់សោះ តាមដំណឹងបានទទួលពេលក្រោយថា មុនព្រះមហាហ្មុតនាំសាវ័កចូលក្រុងមេក្កៈ មេដឹកនាំគូរេជបញ្ជាឱ្យមនុស្សក្នុងទីក្រុងទាំងអស់ ជាការប្រុងប្រៀបក្រែងមានភ័យកើតឡើង ដោយឃើញពួកអ៊ិស្លាមមិនមានការប្រទូស្ដរ៉ាយ ទើបនាំគ្នាលបលួចមើលពិធីសូត្រមន្តបូជាព្រះអាហ្វាហ៍ដែលមានព្រះមហាហ្មុតជាអ្នកដឹកនាំ។

តាំងពីបានធ្វើដំណើរដោយស្រួលបួល ទៅទមស្ការក្នុងក្រុងមេក្កៈ ពេលនោះព្រះ មហៈហ្មាត់ជឿថាជានិមិត្តល្អ ក៏ផ្សព្វផ្សាយពាក្យប្រៀនប្រដៅរបស់ខ្លួនដោយវិធីស្ងប់ស្ងែង។ ព្រះមហៈហ្មាត់បញ្ជូនសាវ័កសំខាន់ៗ ជាទូតទៅប្រទេសជិតខាង ដែលរាប់អានសាសនា និង បូជាព្រះជាម្ចាស់ដទៃៗក្នុងពេលនោះ ឱ្យណែនាំត្រឡប់មករាប់អាន លទ្ធិព្រះអាហ្លាតែមួយ ព្រះអង្គ សាសនាទូតរបស់ព្រះមហៈហ្មាត់ចេញធ្វើដំណើរទៅតាមទីក្រុងធំ ក្រុងតូច កណ្ដាលទន្លេខ្សាច់និងឡើងទៅដល់ប្រទេសប៉ែក្ស។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤៨)

លទ្ធផលជាដំបូង បណ្ដាសាសនាទូតបានទទួល គឺភូមិស្រុកណាធ្លាប់ឮកិត្តិសព្ទល្បីនៃសាវ័ករបស់ព្រះមហៈហ្មាត់ ក៏នាំគ្នាទទួលរាក់ទាក់ តែភាគច្រើននាំគ្នាត្មះតិះដៀលសាសនាទូតអ៊ិស្លាម បណ្ដេញមិនព្រមទទួល ប៉ុន្ដែតមកមិនយូរប៉ុន្មាន ក្រុមអារ៉ាប់តូចៗមួយក្រុម ដែលមានព្រះមហៈហ្មាត់ជាអ្នកដឹកនាំ បានក្លាយទៅជាក្រុមធំ មានអំណាចផ្សាយចេញទៅដោយ "កម្លាំងសទ្ធា" យ៉ាងធំទូលាយគួរឱ្យកោតសរសើរ។

**ទីក្រុងមេក្កៈ**

តាមដំណើរសេចក្ដីថា គ្រាព្រះមហៈហ្មាត់នាំសាវ័កទៅទមស្ការនៅទីក្រុងមេក្កៈនោះ បានសន្យាជាមួយមេដឹកនាំគូរេជថា អ៊ិស្លាមនិងគូរេជ មិនរុករានកាប់សម្លាប់គ្នាក្នុងវេលា ១០ ឆ្នាំ។ កិច្ចសន្យានេះបានត្រឹម ២ឆ្នាំ ប៉ុណ្ណោះក៏កើតមានរឿងធំឡើងដោយពួកគូរេជខុសសន្យាលើកគ្នាទៅសម្លាប់ពួកអ៊ិស្លាមស្លាប់ជាច្រើននាក់។

ព្រះមហៈហ្មាត់ដឹងដំណឹងថាពួកគូរេជខុសសន្យា ទើបប្រឹក្សាព្រមព្រៀងគ្នាថា ត្រូវចាត់ការជាមួយគូរេជដោយដាច់ខាត ត្រួតត្រាមើលកម្លាំងមនុស្សនិងអាវុធ ឃើញល្មមគ្រប់គ្រាន់ហើយនាំគ្នាចេញពីក្រុងមេឌិនៈយ៉ាងស្ងាត់ សូម្បីតែអ្នកក្រុងនេះមិនដឹងថា ព្រះមហៈ-ហ្មាត់ នាំសាវ័កទៅច្បាំងនឹងអ្នកណា។

ថ្ងៃដែលកងទ័ពព្រះមហៈហ្មាត់ដល់ជាយក្រុងមេក្កៈ ជាខែងងឹតផ្ទៃមេឃខ្មៅស្រអាប់កងទ័ពឡើងទៅតាំងនៅលើភ្នំខ្ពស់ដែលពួកគូរេជធ្លាប់លាក់ខ្លួនពួនមើលពួកអ៊ិស្លាមក្នុងពេលទៅទមស្ការគ្រាដំបូង ព្រះមហៈហ្មាត់បញ្ជាឱ្យទាហានដុតភ្លើង ឱ្យផ្សាយដំណឹងថាទ័ពអ៊ិស្លាមមានដល់មួយម៉ឺននាក់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៤៩)

ព័ត៌មានឮទៅដល់អ្នកដឹកនាំគូរេជ ក្រឡេកមើលទៅលើភ្នំឃើញពិតមែន ព្រោះធ្លាប់ដឹងអភិនិហារព្រះមហៈហ្មាត់ខ្លះៗយល់ថា បើនៅចចេសតស៊ូមិនទាន់បានប្រុងប្រៀបខ្លួន នាំ

បណ្ដាលឱ្យខូចប្រយោជន៍ ទើបព្រមចុះចាញ់ ព្រមទទួលរាប់អានលទ្ធិព្រះអាហ្លាតែមួយអង្គ។ លុះមេដឹកនាំចុះចាញ់ហើយ ពួកកូនចៅនៅក្រោមបង្គាប់ទាំងគ្នាព្រមចុះចាញ់ដែរ ព្រះមហៈហ្មុំត មិនបានខូតខាតរបៀពលឡើយ ពេលព្រឹកឡើងបែងចែកជា ៤កង ធ្វើដំណើរចូលទៅក្រុងមេក្កៈ ក្នុងឋានៈជាអ្នកឈ្នះទាំង ៤ទិស។

កិច្ចជាដំបូងដែលព្រះមហៈហ្មុំតធ្វើពេលចូលក្រុងមេក្កៈ គឺការនាំសាវ័កឆ្ពោះទៅកាន់ឋានទូតទីបូជា "កាបាហ៍" ដើរប្រទក្សិណបូជនីយវត្ថុស័ក្តិសិទ្ធិនោះ ៧ជុំ ហើយចេញបញ្ជាឱ្យបំផ្លាញរូបព្រះផ្សេងៗ ដែលធ្លាប់គោរពរាប់អានពីបុរាណមួយរំពេច។

ទីស្ថាន "កាបាហ៍" ជាកន្លែងស័ក្តិសិទ្ធិ ជាទីសំចតចូលមកបូជានៃអ្នកទន្ទេខ្សាច់ទាំងឡាយ ជាមជ្ឈមណ្ឌលនៃការរាប់អានលទ្ធិសាសនារបស់ពួកអារ៉ាប់តាំងពីបុរាណ កាបាហ៍ជាទីរួបរួមមនុស្សមកបូជា និងវត្ថុគ្រឿងសក្ការៈបូជាជាច្រើនបែប តាមតែសទ្ធារបស់មនុស្សទូទៅ ដូច្នោះ កាបាហ៍ ទើបពេញទៅដោយរូបគោរពរាប់អានចំនួន ៣៦០បែប។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៥០)

រូបគោរពទាំង ៣៦០បែបនោះ រូបគោរពដែលធំបំផុតគឺ រូបហុបាអាល់ (Hubal) ធ្វើអំពីសីលាធំតាំងកណ្ដាលក្រុងមេក្កៈ ព្រះមហៈហ្មុំតបញ្ជាឱ្យសាវ័កបំផ្លាញរូបហុបាអាល់ មុនហើយ ទើបបំផ្លាញរូបផ្សេងៗទៀត រហូតដល់អស់ពុំមានសេសសល់តាមកំពែង។ សីលាមហាវិហារកាបាហ៍ មានគូររូបភាពអាប្រាហាម (អាប្រាហាមបុព្វបុរសរបស់ជ្វីហ្វ) រូបទេពបរិវារ និងសាស្ដាព្យាករណ៍ឯទៀតៗជាច្រើន។ ព្រះមហៈហ្មុំត ក៏ចេញបញ្ជាឱ្យលុបចោលទាំងអស់ ឱ្យប្រជារាស្ត្រឃើញថា ព្រះជាម្ចាស់អង្គដទៃពុំមាន មានតែព្រះអាហ្លា ជាមហាទេពតែមួយព្រះអង្គ។ គោលការណ៍នេះតាមបញ្ញត្តិរបស់លទ្ធិក្នុងគម្ពីរថា "អ្នកមិនត្រូវធ្វើរូបសម្រាប់ខ្លួនអ្នកនូវរូបភាពណាៗឬធ្វើរបស់ណាមាននៅឋានសួគ៌ ឬក្រោមផែនដី ឬក្រោមទឹក" (ដូចនឹងបញ្ញត្តិខដំបូងនៃបញ្ញត្តិ ១០ ប្រការរបស់មោសេស)។

លុះបំផ្លាញរូបគោរពបូជាក្នុងបរិវេណនោះអស់ហើយ ព្រះមហៈហ្មុំតក៏ប្រជុំសាវ័កនិងអ្នកទីក្រុងមេក្កៈទេសនាមួយកណ្ឌ រួចសូត្រមន្តមួយចប់ប្រកាសដល់ទីប្រជុំថា កាលបើសេចក្ដីពិតមានហើយ សេចក្ដីមិនពិតរមែងបាត់ទៅ ហើយប្រកាសលើកលែងទោស ជាពិសេសគឺពួកគូរជែដែលជាសត្រូវរបស់អ៊ិស្លាមមកពីមុននេះសម្ដែងឱ្យឃើញថា ព្រះមហៈហ្មុំតជាអ្នកមានមេត្តានិងមិនព្យាបាទដល់អ្នកណាទាំងអស់។

ចរិយាវត្តមួយទៀតរបស់ព្រះមហៈហ្មុតក្នុងគ្រានោះ មិនបានគម្រាមកំហែងឱ្យមនុស្សទាំងឡាយមក រាប់អានលទ្ធិព្រះអាហ្វាប្រញាប់ប្រញាល់នោះទេ គឺមិនបង្ខំស្រេចតែមានសទ្ធាខ្លួនឯង កិច្ចការនេះបានសម្រេចដូចប្រាថ្នា។

ព្រះមហៈហ្មុតធ្វើប៉មមួយធំកណ្ដាលក្រុង ជាកន្លែងសម្រាក និងបំពេញសាសនកិច្ចគ្រប់យ៉ាង ដូចដែលធ្លាប់ធ្វើមកនៅទីក្រុងមេឌិនៈ ពេលវេលាចេះតែកន្លងទៅ ពួកគូរេជប្រុសស្រីនាំគ្នាមកជួបសន្ទនា សម្ដែងនូវសទ្ធាចំពោះព្រះនៈប៊ី ព្រះមហៈហ្មុតនាំមនុស្សទាំងនេះចូលមក ដើម្បីសម្ដែងសទ្ធា បើប្រុសឱ្យចាប់ដៃជាមួយខ្លួន ចំណែកស្រីគ្រាន់តែទទួលពាក្យសម្ដីដោយប្រការដូច្នេះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៥១)

## អវសាន

ព្រះមហៈហ្មុត បានអ្នកក្រុងមេក្កៈទុកក្នុង “សទ្ធា” របស់ខ្លួន ពេលនោះកិត្តិស័ព្ទល្បីរន្ទឺពាសពេញទន្ទេខ្សាច់ដ៏ធំធេង បណ្ដាពួកអារ៉ាប់នៅទីក្រុងផ្សេងៗនាំគ្នាមកឱនលំទោនរាប់អានថា ព្រះមហៈហ្មុតជាអ្នកគ្រប់គ្រងប្រទេសអារ៉ាប់ទាំងអស់។

ព្រះមហៈហ្មុត បានរម្ងាប់រឿងចម្រូងចម្រាស់និងញុាំងសទ្ធារបស់ពួកអ្នកក្រុងមេក្កៈប្រព្រឹត្តទៅបានល្អ ហើយក៏ធ្វើដំណើរត្រឡប់ទៅកាន់មេឌិនៈវិញ ជាផែនដីធ្លាប់អាស្រ័យនៅពេលមានភ័យ ព្រះមហៈហ្មុតធ្លាប់ ពោលថា ចង់ឱ្យអ្វីដល់អ្នកណាក៏អាចឱ្យបានដែរ សូម្បីអូដ្ឋ អាហារ និងគ្រឿងឧបភោគទាំងឡាយ តែរូបរាងកាយត្រូវឱ្យទៅអ្នកទីក្រុងមេឌិនៈ ព្រោះអ្នកមេឌិនៈជាអ្នកឱ្យជីវិតដល់យើងរហូតមក។

ព្រះមហៈហ្មុតក្នុងពេលនេះ ជាអ្នកមានបុណ្យបារមីលើផែនដីដ៏ធំ តែពុំបានសម្ដែងអំណាចឱ្យអ្នកណា ដឹងត្រឡប់មកនៅមេឌិនៈវិញ ដំណើតជីវិតជាធម្មតាគឺសំណាក់នៅផ្ទះដីដូចពីដើម ជាប់ជិតនឹងមស្ជិតកណ្ដាលទីក្រុងតាំងពីដំបូង កន្លែងនេះប្រើសម្រាប់ទទួលភ្ញៀវនិងទេសនាផង ព្រះមហៈហ្មុតធ្វើខ្លួនធម្មតាដូចមនុស្សទាំងឡាយ។

ជីវិតរបស់ព្រះមហៈហ្មុតនាចុងក្រោយ មាននិទានថា “លោកនៈប៊ី សូម្បីលោកមិនមែនជាក្សត្រិយ៍ពាក់មកុដ តែសំពត់ឈ្នួតដែលលោកជូតក្បាល តាមទំនៀមអារ៉ាប់ពីបុរាណនោះ ប្រហែលគ្នានឹងមកុដដែរ សូម្បីពុំមានរាំងជាទីប្រថាប់ តែការស្រឡាញ់កក្ដីរបស់មនុស្សទាំងឡាយមានចំពោះលោក ជាជាងព្រះរាជាវាំងជាទីប្រថាប់ទៅទៀត”។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៥២)

ធ្លាប់មានអ្នកសុំស្នើឱ្យផ្លាស់ប្តូរឈ្នួតនិងគ្រឿងស្លៀកពាក់មានតម្លៃ ដើម្បីសម្តែងនូវកិត្តិយស លក្ខណៈធំខ្ពស់ជាងមនុស្សសាមញ្ញ តែលោកនៈប៊ី បដិសេធមិនព្រមធ្វើ ធ្លាប់ប្រើគ្រឿងស្លៀកពាក់យ៉ាងណាប្រើយ៉ាងនោះ ខនេះបញ្ជាក់ថា ខុសពីពួកកាហ៊្វិប "គឺអ្នកបន្តអំពីនៈប៊ី" ដែលជាអ្នកដឹកនាំជំនាន់ក្រោយ នាំគ្នាសម្តែងខ្លួនជាសេដ្ឋី ចាយវាយខ្ជះខ្ជាយៗ

ក្នុងអវសាននៃជីវិត កាលព្រះមហាៈហ្មុ័តអាយុបាន ៦២ឆ្នាំ ដូចជាដឹងខ្លួនខ្វះៗថានឹងទ្រាំទ្រសង្ខាររបស់ខ្លួនទៅទៀតមិនបានយូរ ទើបធ្វើដំណើរទៅកាន់ក្រុងមេក្កៈវិញ ព្រមជាមួយសិក្សានុសិស្សដើម្បី "នមស្ការ នាគ្រាចុងក្រោយ" ម្តងទៀតៗ

លុះត្រឡប់ពីនមស្ការគ្រាចុងក្រោយហើយ សូម្បីរូបរាងកាយនៅរឹងប៉ឹងល្អ តែក្នុងខ្លួនដូចជាមានរោគកាន់តែច្រើនឡើង និងមានរោគថ្មីចូលមកលាយឡំទៀត មិនអាចចេញទៅសូត្រមន្ត និងទេសនាប្រដៅសាវ័កបានៗ

ព្រះមហាៈហ្មុ័ត បានទទួលការរក្សាព្យាបាលល្អណាស់ នៅផ្ទះរបស់នាងអាស៊ីហ៍ៈហ៍ ជាភរិយាម្នាក់ មានសាវ័កមកប្រជុំពេញមស្ជិត សូត្រមន្តសូមពរពីព្រះអាហ្វាឱ្យទ្រង់ជួយរក្សារាល់ថ្ងៃ តែអាការរោគកាន់តែធ្ងន់ ជិតដល់វារៈចុងក្រោយ លោកនៈប៊ីប្រាប់ឱ្យភរិយាយកមាសប្រាក់មកចែកចាយដល់មនុស្សអនាថាទាល់តែអស់ ដោយអាងថា មិនព្រមទៅជួយព្រះអាហ្វាដោយមានមាសប្រាក់ជាប់ជាមួយខ្លួនៗ លុះភរិយាបរិច្ចាគទានស្រេចហើយត្រឡប់ចូលមកគក់ប្រេបាច់វិញ រោគកាន់តែខ្លាំងឡើង ទន់ក ដៃត្រជាក់ ព្រះមហាៈហ្មុ័ត រលត់ខន្ធដោយអាការៈស្ងប់ស្ងៀមក្នុងរង្វង់ដៃនាងអាស៊ីហ៍ៈហ៍ កាលអាយុ៦៣ឆ្នាំៗ (ហេង គឹមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៥៣)

គ្រាព្រះមហាៈហ្មុ័តរលត់ខន្ធហើយអាប៊ូបារ៍ក ជាឪពុកក្មេកបន្តតំណែង(កាហ៊្វិប) ជំនួសគ្រប់គ្រងជនជាតិអារ៉ាប់ និងជាមេដឹកនាំប្រតិបត្តិកិច្ចការខាងសាសនាបន្តមកៗ អាប៊ូបារ៍ក ធ្វើការងារធ្ងន់ ព្រោះពេលអស់ព្រះមហាៈហ្មុ័តហើយ កម្លាំងសាវ័កចាប់ផ្តើមបែកខ្ញែកគ្នា អ្នកទីក្រុងមេក្កៈនិងអ្នកក្រុងផ្សេងៗដែលធ្លាប់ឱនលំទោនគោរពព្រះមហាៈហ្មុ័ត នាំគ្នារឹងទទឹងមិនព្រមស្តាប់អាប៊ូបារ៍ក ត្រូវធ្វើសឹកសង្គ្រាមនឹងអ្នកទាំងនោះមួយសន្ទុះទៀត ហើយនឹងអស់ជន្មាយុកាលពីព.ស.១១៧៧ៗ

រឿងរបស់កាហ៊្វិបក្នុងសាសនាអ៊ិស្លាម ជារឿងនៃការបន្តវេនគ្នាមកជាលំដាប់ ដោយវិធីកាហ៊្វិបមុនជាអ្នកតែងតាំង ដែលខ្លួនឃើញថាអាចបន្តតំណែងបាន កាហ៊្វិបក្នុងសាសនា

*អ៊ិស្លាមគ្រប់អង្គ កាន់យកជានយោបាយម្យ៉ាង គឺការពង្រីកព្រំដែននៃ "សទ្ធាក្នុងសាសនា" ដោយការលើកទ័ពចេញទៅច្បាំងពួកមិនព្រមមានសទ្ធា។ (ហេង គីមហោ សាសនា ប្រៀបធៀប ភាគ២ ទំព័១៥៤)*

**ភាគប្រតិបត្តិ (ដោយសទ្ធា) ៥ប្រការគឺ** *(ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ១៧១)*

*១-ប្ដេជ្ញាចំពោះព្រះអាល់ឡោះ ថាព្រះជាម្ចាស់តែមួយអង្គ និងព្រះមហៈហ្មាត់ជាសាសនាទូតរបស់ព្រះអង្គ។*

*ការប្រតិបត្តិកិច្ចនេះ ផ្ដើមដោយការពោលសរសើរព្រះនាមរបស់ព្រះអាល់ឡោះជាម្ចាស់ និងព្រះមហៈហ្មាត់ ជាសាសនៈទូត មុនធមស្ការគ្រប់ពេល (និងនិយាយទៅខាងមុខ) ពាក្យពោលសរសើរនោះ (បើមិនបញ្ចេញសំឡេងត្រូវធ្វើតែក្នុងចិត្ត) ដោយពាក្យថា លាឥលាហា ឥលឡា លល្ហ មូហាំ ហ្មាត់រាស៊ូ លូលាពុំមានព្រះជា ម្ចាស់អង្គឯណាក្រៅពីព្រះអាល់ឡោះ ព្រះអង្គទ្រង់ព្រះមេត្ដាករុណាទិគុណ ដោយព្រះករុណាខ្ពស់ ព្រះមេត្តាខ្ពស់ និងព្រះតេជៈខ្ពស់ ព្រះអង្គទ្រង់សាងរបស់សព្វសារពើ។ល។ ដូចសេចក្ដីខជំបូង ដែលមានមកហើយក្នុងភាគ ទ្រឹស្ដី។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧១)*

*សំឡេងពាក្យសម្ដីទាំងនេះ អាចឮពេលថ្ងៃត្រង់និងពេលអាធ្រាត្រ ក្នុងប្រទេសដែលរាប់អានសាសនាអ៊ិស្លាម។*

*២-ការសូត្រមន្តបួងសួង*

*ការសូត្រមន្តជាផ្លូវនាំទៅកាន់ឋានសួគ៌ សាសនាអ៊ិស្លាមប្រដៅយ៉ាងនេះ សាសនាអ៊ិស្លាមប្រដៅសង្កត់ធ្ងន់ក្នុងកិច្ចនេះ ព្រះនៈប៊ីមហៈហ្មាត់ប្រកាន់រឿងសូត្រមន្តជាកិច្ចតឹងរឹងបំផុត ត្រូវសូត្ររាល់ថ្ងៃ មួយថ្ងៃ៥ដង គឺ ពេលព្រឹកព្រហាម មុនព្រះអាទិត្យរះ ថ្ងៃត្រង់ ថ្ងៃរសៀល និងថ្ងៃលិច ពេលថ្ងៃល្ងាច ព្រលប់និងយប់។ អ្នកចូលពិធីសូត្រធមស្ការ ត្រូវសុភាពហាមមិនឱ្យពាក់ប្រដាប់ប្រដាអ្វី ប្រុសត្រូវធ្វើពិធីត្រង់តាមបែប (និងពោលទៅខាងមុខ)។ ចំណែកស្រីអនុញ្ញាតឱ្យយកដៃឱបទ្រូង ពីមុនកំណត់ឱ្យធ្វើនៅមស្ជិត តមកបន្ធូរបន្ថយ រឿងទឹកន្លែង។ ក្រៅអំពីថ្ងៃសូត្រ និងក្នុងទេសកាលពិសេសមូស្លីមកាន់ថា ការសូត្រមន្តធមស្ការបង្រួញផ្លូវទៅឋានសួគ៌បានពាក់កណ្ដាល (និកាយខ្លះធ្វើត្រឹម ៣ឬ៤ដងក៏មាន)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧២)*

"ព្រោះថាអាល់ឡោះជាម្ចាស់ ជាអ្នកសាងរបស់សព្វសារពើក្នុងលោករួមទាំងខ្លួនអ្នកផង ដែរ អ្នកគួរសូត្រមន្តរំឭកដល់គុណព្រះអង្គ មិនថាជាពេលណា"។

មុនសូត្រមន្ត ត្រូវជម្រះលាងរាងកាយឱ្យស្អាត ដើម្បីឱ្យចិត្តថ្លើមស្អាត ត្រូវលាងដៃទាំងពីរ (ដៃស្តាំមុន) ដល់កដៃ, លាងមាត់, លាងច្រមុះ, លាងមុខពីថ្ងាសមកដល់ចង្កា ពីត្រចៀកម្ខាងទៅម្ខាងទៀត លាបស្រឡាប ក្បាលដោយទឹក ប្រើមេដៃលាងត្រចៀក ព្រមទាំងប្រើម្រាមដៃលាងស្លឹកត្រចៀក និងលាងជើងទាំងពីរ (ជើងស្តាំមុន) រហូតដល់កជើង។

មុនការសូត្រ អ៊ិស្លាមមិនប្រើវិធីឱ្យមានអ្នកអំពាវនាវ (មុអាស៊ិន) អ្នកអំពាវនាវនៅលើប៉មខ្ពស់ស្រែកអំពីនោះ កាលមានមនុស្សមកប្រជុំគ្នាហើយ អ៊ិម៉ាមឬមេក្នុងពិធីសាសនាជាអ្នកដឹកនាំ (ថ្ងៃសុក្រជាថ្ងៃសូត្រមន្តធំ ប្រហែលគ្នានឹងថ្ងៃសីលក្នុងពុទ្ធសាសនា)។

ការសូត្រមន្តឬនមស្ការមាន ៣វគ្គគឺ ៖

ជំបូងហៅ អាសាន គឺពេលអាស៊ិនឡើងស្រែកអំពាវនាវលើប៉មខ្ពស់មុអាស៊ិនស្រែកអំពាវនាវដូច្នេះ ៖

"អាល់ឡោះ ព្រះធំមហិមា (៤ដង) ខ្ញុំសូមប្តេជ្ញាថា ពុំមានព្រះជាម្ចាស់ដទៃណា ក្រៅពីព្រះអាល់ឡោះ (២ដង) ខ្ញុំសូមប្តេជ្ញាថា ព្រះមហៈហ្មាត់ជាសាសនាទូតរបស់ព្រះអាល់ឡោះ (២ដង) ចូរមកនមស្ការចុះ (២ដង) ចូរមកធ្វើសេចក្តីល្អចុះ (២ដង) ការនមស្ការល្អជាងដេក (២ដង) ពុំមានព្រះជាម្ចាស់ពិតប្រាកដគួរឱ្យសក្ការៈ ក្រៅពីព្រះអាល់ឡោះជាម្ចាស់" (១ដង)។

លើកទីពីរហៅ រ៉កអាត់ ជាការចាប់ផ្តើមសង្រួមកាយវាចានិងចិត្ត គឺការពោលពាក្យ (សូត្រ) ដែលត្រឹមត្រូវ ប្រើឥរិយាបថផ្លូវកាយនិងតាំងចិត្តផ្ចង់ទៅចំពោះព្រះជាម្ចាស់មួយអង្គយ៉ាងត្រឹមត្រូវ ដើម្បីឱ្យការនមស្ការបានផលបរិបូណ៌។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័ ១៧៣)

ការនមស្ការពេលនោះ ជាការសូត្រពរនិងសរសើរព្រះគុណរបស់ព្រះជាម្ចាស់ប្រកបដោយពាក្យនិងឥរិយាបថ ៧ប្រការ ដែលអ៊ិម៉ាមឬមេដឹកនាំក្នុងពិធីជាអ្នកពោលនាំមុខ និងធ្វើព្រមគ្នាគឺ (ក) ឈរត្រង់ខ្លួន បែរមុខទិសទីតាំងក្រុងមេក្កៈ (ខ) លើកដៃទាំង ២ ត្រឹមត្រចៀកផ្ងារបាតដៃចេញ (គ) ប្រើដៃស្តាំសង្កត់ដៃឆ្វេងលើពោះ (ង) បន្ទន់ខ្លួនចុះ ដៃទាំងពីរច្រត់លើក្បាលជង្គង់ងើបខ្លួនឡើង (ច) ឈរត្រង់ខ្លួន ហើយបន្ទន់ខ្លួនក្រាបដល់កន្ទេល ដោយឱ្យម្រាម

ជើងទាំង២ បាតដៃទាំង២ ជង្គង់ទាំង២ និងថ្ងាសប៉ះក្រាលម្តង (ឆ) ងើបឡើងអង្គុយលុតជង្គង់ ដាក់ដៃទាំង២លើជង្គង់ ហើយនិង (ជ) ក្រាបជាលើកទី២។

ការមនស្ការដូចពោលមកនេះ ជាបែបដែលធ្វើរួមគ្នាមស្ជិត បើធ្វើម្នាក់ឯងត្រូវធ្វើទីដទៃ មានប្តូរពាក្យសូត្រនិងឥរិយាបថខ្លះ មូស្លីមនិកាយខ្លះទៀត លើកលែងនូវឥរិយាបថខ្លះ ខ សំខាន់ពេលនមស្ការនោះ នឹង និយាយជាមួយអ្នកណា ឬកម្រើកខ្លួនប្រាណមិនបានឡើយ។

មុនការធ្វើពិធីនមស្ការក្នុងមស្ជិត ភាគច្រើនមានការអានព្រះគម្ពីរដើម្បីឱ្យជាអនុសតិដល់អ្នកចូលរួមពិធី បើជាការនមស្ការក្នុងថ្ងៃសុក្រឬថ្ងៃសំខាន់ដទៃទៀត រមែងមានការបរិយាយធម៌ជាពិសេសផង។ មួយទៀតមូស្លីមកាន់ថា បើប្រសិនក្នុងទេសកាលពិសេស ដូចជាការចូលថ្ងៃទីបំផុតនៃការកាន់សីលអត់ (នឹងពោលនៅខាងមុខ) និងថ្ងៃចូលការលះបង់ក្នុងគ្រាដ៏ធំ (អដិលអ័ដ្ហា) គឺថ្ងៃត្រស្តិសង្រ្កាន្តរបស់សាសនាអ៊ិស្លាម ត្រូវមានការធ្វើពិធីនមស្ការរួមគ្នាជាច់មិនបាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧៤)

នៅមានការនមស្ការប្រភេទដទៃ ជាអាទិ៍ការនមស្ការពេលធ្វើពិធីបញ្ចុះសព ការនមស្ការពេលធ្វើពិធីសុំពរ សុំទឹកភ្លៀងពីព្រះជាម្ចាស់។ល។ ទៀតជាច្រើន តែទាំងអស់នេះមិនបានបន្ថក្នុងពិធីនមស្ការក្នុងពិធី នមស្ការដែលនិយាយក្នុងគោលនៃសទ្ធានេះទេ។

៣-ការកាន់សីលអត់

តាមពាក្យប្រដៅក្នុងព្រះគម្ពីរ ឱ្យអ៊ិស្លាមិកមានថ្ងៃកាន់សីលដែលមានការតឹងរឹង ជាប្រយោជន៍ដល់ការជម្រះរាងកាយ និងសាកល្បងចិត្តគំនិត។ ម្យ៉ាងទៀត គឺសីលអត់ ក្នុងខែរ៉ាម៉ាដាន (រ៉ាម៉ាដន) ខែ៩ របស់អ៊ិស្លាមជាខែតែមួយនិងខែលោកនះប៊ីមហៈហ្ម៉ុត ចេញទៅបំពេញព្យាយាមឯភ្នំហិរ៉ា ហើយបានជួបទេពនិម្មិតជាព្រះនះប៊ី។

ក្នុងរវាងការកាន់សីលអត់ (១ខែ) អ៊ិស្លាមិកត្រូវលះបង់ការបរិភោគអាហារ ផ្ទុតទឹក ផឹកទឹក សូម្បីតែការលេបទឹកមាត់ លាបស្រឡាបដោយគ្រឿងក្រអូប និងមិនត្រូវប្រកបការណាៗឱ្យជាកិលេសរាគៈ តាំងពីព្រឹករហូតដល់ថ្ងៃលិច។

គេមានជំនឿថា ក្នុងរាត្រីនៃខែរ៉ាម៉ាដនពេញមួយខែ ជា "យប់នៃអំណាច" ទ្វារឋានសួគ៌បើកចាំអ្នក មានសទ្ធាក្នុងយប់ទាំងនេះទ្វារនរកបិទ បណ្តាសាតានមារអាក្រក់ទាំងឡាយត្រូវឃុំឃាំងនៅក្នុងនរក ចេញមកប្រឆេងប្រឆាំងមិនបានឡើយ។

ការកាន់សីលអត់ (ប្រដូចជាពេលចូលវស្សាក្នុងពុទ្ធសាសនា) អ្នកដែលកាន់ត្រូវមានរាងកាយរឹងប៉ឹង អាចអត់ទ្រាំការស្រេកឃ្លានបាន ផ្ដើមអត់តាំងពីពេលព្រឹក (អរុណរះ) រហូតទៅដល់ថ្ងៃលិច កាលបើព្រះអាទិត្យលិចហើយ ចាប់ផ្ដើមបរិភោគអាហារទន់ៗជាមុនសិន ដើម្បីការពារក្រពះរហូតដល់អាហាររឹងអាចបរិភោគបានមុនថ្ងៃរះ តាមធម្មតាបើបរិភោគអាហារឆ្អែត ចង់សូត្រមន្ត ឬប្រើពេលសម្រាករហូតទៅដល់មុន ថ្ងៃរះក៏បាន។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧៥)

គោលបំណងតាមពាក្យប្រដៅ ដើម្បីឱ្យកើតការអត់ធន់ខាងរាងកាយ សាកល្បងការរឹងប៉ឹងនៃចិត្ត ប្រដៅឱ្យចេះអត់ធន់ ការលំបាកវេទនាក្នុងពេលដែលអត់អាហារបរិភោគប្រដៅឱ្យនឹកឃើញថាមនុស្សក្រខ្សត់អត់ឃ្លាននោះមានទុក្ខវេទនាប៉ុនណា។ ក្នុងរវាងខែកាន់សីលអត់ ទើបគួររឭកនឹកដល់បណ្ដាមិត្តមនុស្សអ្នកក្រខ្សត់ គួរបរិច្ចាគដល់អ្នកទីទាល់ក្រខ្សត់ផង។

លុះគម្រប់ ៣០ថ្ងៃ នឹងមានការធ្វេងនូវសេចក្ដីត្រេកអរ អាចបន្ទាប់បញ្ជាចិត្តបាន ដោយកាន់ថាប្រតិបត្តិ សម្រេចតាមការតាំងចិត្ត កិច្ចធ្វេងនេះធ្វើពិធីធំ៣ថ្ងៃ មានការតែងខ្លួនស្អាតបាតចេញដើរលេងកម្សាន្ត សាកសួរជូនវត្ថុឱ្យញាតិមិត្ត និងជប់លៀងភោជនាហារ ហើយកាន់ថាជាទេសកាល ទៅគោរពរណ្ដៅសពរបស់បុព្វបុរសផង។

៤-ការឱ្យទាន

ព្រះគម្ពីរកូរ៉ាន ប្រដៅឱ្យមនុស្សគ្រប់គ្នាមានមេត្តាប្រណីដល់គ្នានិងគ្នា អ្នកមានការអនុគ្រោះដល់ភាពក្រីក្រ អ៊ិស្លាមិកមិនព្រមឱ្យមនុស្សកើតមកត្រូវរងទុក្ខលំបាក ព្រោះគ្មានទីលំនៅ គ្មានអាហារបរិភោគ។

"ទាន" តាមគោលបំណងក្នុងសាសនាអ៊ិស្លាម មិនមែនសំដៅត្រឹមតែការឱ្យមានប្រាក់របស់ប្រើប្រាស់ ឬអាហារ គ្រឿងស្លៀកពាក់ គឺសំដៅដល់ការឱ្យមានកម្លាំងកាយ កម្លាំងសតិបញ្ញា និងការជួយសង្គ្រោះដោយប្រការផ្សេងៗ ដូចជាឱ្យសត្វចិញ្ចឹម មានអូដ្ឋ គោ ពពែ ចៀមជាដើមផង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧៦)

ពាក្យប្រៀនប្រដៅក្នុងសាសនាអ៊ិស្លាមនិយាយថា ការបរិច្ចាគទាន ជាគូនឹងការសូត្រមន្តនមស្ការសំខាន់ប្រហែលគ្នា និងកាន់ជាគោលប្រតិបត្តិថា កាលសូត្រមន្តនមស្ការហើយត្រូវបរិច្ចាគទានជួយសង្គ្រោះអ្នកកម្សត់ទុគ៌តគោកយ៉ាកជាងខ្លួន។

ការឱ្យទានអ៊ិស្លាមប្រដៅថា ជាការជម្រះចិត្តឱ្យបរិសុទ្ធប្រាសចាកកិលេស គឺសេចក្ដីកំណាញ់ មូស្លីមមានគតិដូចអ្នកកាន់ពុទ្ធសាសនាមួយគឺគតិថា សេចក្ដីមេត្តារមែងរក្សាសង្គម និងរក្សាលោក អ្នកណាជាអ្នកឱ្យ(បរិច្ចាគ) អ្នកនោះរមែងមានឡើង(ឱ្យច្រើនមិនដែលអស់)។

ការឱ្យទានប្រកបដោយអត្ថច្រើនយ៉ាង កំណត់ប្រភេទអ្នកត្រូវបានទទួលនូវទាន គឺមនុស្សក្រីក្រនិងស្រីមេម៉ាយៗលៗ ដោយវិធីចែកចំណូលចេញជា ១០ចំណែក សម្រាប់ទុកឱ្យទាន ១ចំណែក។

ការឱ្យទានមាន ២យ៉ាងគឺ សាកាត់ (Sakat) និងសាដាកាត់ (Sadakat)។ សាកាត់គឺ ការបែងចែកទ្រព្យសម្បត្តិមាសប្រាក់គ្រឿងប្រើប្រាស់មួយចំណែកធ្វើបុណ្យ។ សាដាកាត់បរិច្ចាគយ៉ាងនោះឬមិនបរិច្ចាគក៏បានពុំមានបន្ទុំ តែគ្រប់ៗគ្នាត្រូវរំលែកចំណូលរបស់ខ្លួនទុក១ចំណែកឱ្យអ្នកក្រខ្សត់។

ហេតុផលខនេះ អាចបណ្ដាលមកពីព្រះមហាហ្មាត់ ធ្លាប់ទទួលទុក្ខលំបាកនៅក្នុងក្រុងមេឌិនៈ ធ្លាប់យល់ចិត្ត យល់ទុក្ខធុរៈមនុស្សទាំងឡាយ។ អ៊ិស្លាមិកកាន់ថា ការឱ្យទានស្មើនឹងបានធ្វើដំណើរចូលទៅត្រង់ព្រះភក្ត្ររបស់ព្រះជាម្ចាស់តែម្ដង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧៧)

៥-ការធុតង្គទៅមេក្កៈ

ព្រះគម្ពីរកូរ៉ានប្រកាសថា អ៊ិស្លាមិកអ្នកមានសទ្ធាចំពោះព្រះអាល់ឡោះ ត្រូវធ្វើដំណើរទៅបូជានៅទីក្រុងមេក្កៈម្ដង ក្នុងមួយជីវិតរបស់ខ្លួន ការទៅទស្សនាកិច្ចនេះហៅថា ហៈយី (Haji) ព្រះមហាហ្មាត់ធ្លាប់ទៅ ទស្សនានៅគ្រាចុងក្រោយឯបាហ៍ ដែលជាមហាវិហារមជ្ឈមណ្ឌលនៃការបូជារបស់មូស្លីម ក្នុងក្រុងមេក្កៈ មុននឹងរលត់ខន្ធ។

បរិវេណដែលប្រតិស្ឋានមហាវិហារកាបាហ៍ មូស្លីមកាន់ថាជាទីស្ថានស័ក្ដិសិទ្ធិនៃសាសនាដទៃ ដែលសាសនិកពួកផ្សេងៗរាប់អាន ហាមមិនឱ្យមនុស្សមិន មែនជាមូស្លីមឈានចូលទៅក្នុងបរិវេណទាំងនេះ (ឥឡូវនេះការតឹងរឹងបានបន្ធូរបន្ថយខ្លះ)។

មុនចេញទៅធុតង្គនាក្រុងមេក្កៈ ត្រូវចាត់ចែងរឿងទ្រព្យសម្បត្តិនិងគ្រួសារ អ្នកនៅក្រោយឱ្យរៀបរយសិន មិនត្រូវបណ្ដោយឱ្យមានទុក្ខលំបាកនិងការជាប់ជំពាក់នៅខាងក្រោយឡើយ។ ឱ្យកាន់ថាការធ្វើដំណើរទៅកាន់មេក្កៈ ជាការទៅឋានសួគ៌ ត្រូវរក្សាសាមគ្គី គ្រប់ៗគ្នាការស្មើភាពគ្នា ជាមូស្លីមដូចគ្នាទាំងអស់។

ការធ្វើដំណើរចូលទៅដល់ខេត្តមេក្កៈ ត្រូវស្លៀកពាក់សំពត់ពណ៌សគ្រប់ៗគ្នាឱ្យស្អាតបាត គ្មានដេរតគ្នា មិនឱ្យកាត់សក់កោរពុកមាត់ ពាក់ប្រដាប់ប្រដាផ្សេងៗ ដែលនាំឱ្យកើតរាគៈនិងមិនឱ្យធ្វើបាបសត្វ សូម្បីតែកោដន៍ផល្លាក៏មិនបានដែរ ត្រូវប្រកាន់ថានៅក្នុងគ្រួសារតែមួយ ព្រះរាជាឬយាចក មានភាពស្មើគ្នាដូចកូនក្នុងពោះតែមួយ។ ក្នុងវាងធុតង្គនៅ នាក្រុងមេក្កៈ អាចពោលថា បើចង់មើលសេចក្តីសាមគ្គីដ៏ធំធេងរបស់មូស្លីម ត្រូវឱ្យទៅមើលនៅធុតង្គឯក្រុងមេក្កៈ ដែលកំណត់ឱ្យមានជាប្រពៃណីនិយម ភាគច្រើនត្រូវចំខែក្នុងរដូវក្តៅ។

លុះធុតង្គចូលដល់បរិវេណកណ្តាលក្រុងមេក្កៈ ជាទីតាំងនៃមហាវិហារកាបាហ៍ (ថ្មពណ៌ខ្មៅបួនជ្រុង) ហើយត្រូវធ្វើពិធីដូច្នេះ។

ក-រត់ទៅឆ្វេងឬដើរយ៉ាងលឿនជុំវិញថ្មខ្មៅ ៧ជុំ ឱ្យយកដៃប៉ះថ្មម្តងមួយជុំ បើអាចធ្វើបានជញ្ជក់៧ដង រឹតតែល្អ។ ការរត់៣ជុំដំបូង ឱ្យធ្វើរហ័សបំផុត តែ៤ជុំទៀតក្រោយយឺតបន្តិចម្តងៗក៏បាន រឿងជញ្ជក់ថ្មខ្មៅជារឿងចាំបាច់ លើកលែងតែក្នុងករណីមានមនុស្សណែនណាន់តាន់តាប់នឹងចូលទៅជញ្ជក់ឱ្យយឺតយូរ ត្រឹមតែយកដៃប៉ះក៏បាន ហើយជញ្ជក់ដៃជំនួស។

ខ-ធុតង្គតូច មានកំណត់ថា អ្នកស្វែងបុណ្យត្រូវដើរធុតង្គជាការហ្វឹកហ្វាត់រាងកាយដោយជើងទទេ ដើរទៅមករវាងលើខ្នងភ្នំសាហ្វានិងម៉ាវ៉ាហ៍ ៧ដង ដោយអាងតំណាលថាជាការបូជាការព្យាយាមរបស់នាង ហាកា៍ (Hgar) ដែលត្រេចចរដើររកទឹកឱ្យបុត្រាឈ្មោះអ៊ិស្មាអែល (Ishmael) ជួបអណ្តូងទឹកមួយហៅថា អណ្តូងសាំ-សាំ (ទឹកអណ្តូងនេះប្រែរហូតដល់ល្វីង បម្រុងទុកឱ្យប្រើក្នុងពិធីសាសនាតែម្យ៉ាង)។

តាមគតិនិកាយរបស់អ៊ិស្លាមិកនេះថា មានទំនាក់ទំនងពីរឿងរបស់អាប្រាហាម ក្នុងគម្ពីរប៊ីប្លចាស់របស់ជ្វិហ្វ ពួកអារ៉ាប់ប្រកាន់ថា ខ្លួនជាកូនចៅរបស់អាប្រាហាម ដែលតំណវង្សត្រកូលមកពី អ៊ិស្មាអែល កូនប្រុសរបស់អាប្រាហាម ប៉ុន្តែខាងវង្សត្រកូលជ្វិហ្វក៏គេថា គេជាត្រកូលរបស់អាប្រាហាមដូចគ្នាដែរ ខាងកូនប្រុស អាប្រាហាមឈ្មោះ អ៊ីសាក់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៧៩)

គ-ការធ្វើធុតង្គធំកាលបើស្រេចពីពិធីធុតង្គតូចហើយ មានការធ្វើធុតង្គគ្រាធំគឺ ធ្ងន់ជាងមុន។ ពេលនោះ ធុតង្គចេញទៅនៅកណ្តាលវាលមានឈ្មោះថា វាលអារៈហ្វាត់ (Arafat) ត្រង់កន្លែងនេះជាទន្លេខ្សាច់ធំល្វឹងល្វើរ នៅជើងភ្នំចេញទៅបោះឆត្រនៅស៊ីបុកដេកដើរកន្លែង

នោះ សូត្រមន្តការនាដល់ព្រះជាម្ចាស់កណ្ដាលទន្លេខ្សាច់ បើមិនធ្វើធុតង្គធំក៏ពុំមែនទៅហៈឃី គឺមិនមែនឈ្មោះថា ទៅនមស្ការដែរ។

ធុតង្គដូចពោលមកនេះ គឺការកាន់សីលអត់ម្ហូបទៀត ចំនួន ៣ថ្ងៃ ស្រេចហើយត្រឡប់ទៅបូជាឯមហាវិហារកាបាហ៍ ជាគ្រាចុងក្រោយ រាប់ថាបានកាន់សីលក្នុងគ្រាដ៏ធំនៃជីវិតបរិបូណ៌ (ប្រៀបបានខាងព្រាហ្មណ៍ និងពុទ្ធសាសនាថា បានបួសហើយ រៀនហើយ។

កាលបើដើរចេញពីទ្វារផ្ទះ រហូតដល់ពេលត្រឡប់មកវិញ អ៊ិស្លាមិកគ្រប់គ្នា ត្រូវប្រព្រឹត្តខ្លួនកាន់ខ្ជាប់ក្នុងច្បាប់ទាំងនេះគឺ វៀរចាកការវិវាទ អត់ទ្រាំនូវពាក្យជេរស្រវាទ មានការអាណិតអាសូរ មានមេត្រីភាពជាមួយបក្សពួក ដែលមកស្វែងបុណ្យជាមួយគ្នា និងត្រូវមានការធ្វើបុណ្យឱ្យទានរហូតតាមផ្លូវ។

ដែលពោលមកនេះ គឺជាអង្គប្រកប ជាគោលធំ រួមទាំងសទ្ធានិងខប្រតិបត្តិ ៥ប្រការផងដែរ នៅមានពាក្យប្រដៅក្នុងគម្ពីរកូរ៉ានច្រើនទៀតដែលជាផ្នែកសំខាន់ ជាអាទិ៍ ៖

អ៊ិស្លាមិកគ្រប់គ្នាមិនបរិភោគឈាម មិនបរិភោគសាច់ជ្រូក ការផឹកទឹកស្រវឹង គ្រឿងគ្រាំ និងលេងល្បែងភ្នាល់ ហាមដាច់ខាត ទុកជាបាបធ្ងន់ណាស់។ អនុញ្ញាតឱ្យលក់ដូរយកកម្រៃបាន តែមិនអនុញ្ញាតឱ្យបងការប្រាក់យកការ កាន់ជាបាបធ្ងន់ដែរ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៨០)

ការរៀបអាពាហ៍ពិពាហ៍ សូម្បីស្រីមានឋានៈទាបជាងប្រុស ប្រុសត្រូវប្រតិបត្តិកិរិយាដោយសេចក្ដី យុត្តិធម៌និងអនុញ្ញាតឱ្យមានភរិយា ៤នាក់ ប្រសិនបើអាចមានបាន តែត្រូវផ្ដល់សេចក្ដីសុខដល់គេស្មើមុខគ្នា បើធ្វើមិនបានជាបាបធ្ងន់ទៀត។

ការលះលែងគ្នា ឱ្យស្វាមីភរិយាចែករបស់រៀបការស្មើគ្នា បើមិនត្រូវការយកទេ ឱ្យបរិច្ចាគដល់អ្នកក្រីក្រទៅ អ្នកណាធ្វើបាបអាក្រក់នឹងទៅទទួលពាក្យពិភាក្សាផ្សេងភ្លើងក្នុងនរក ដូចគ្នានឹងអ្នកធ្វើកម្មល្អទៅកាន់ ឋានសួគ៌ដូច្នោះដែរ។

**និកាយក្នុងសាសនា**

សាសនាអ៊ិស្លាម មានសភាពដូចគ្នានឹងសាសនាដទៃៗគឺ សភាពនៃការបែកបាក់កើតពីសាវ័កអ្នកមាន ការរាប់អានព្រះគម្ពីរ មានគំនិតគិតឃើញមិនស្មើគ្នាតាមហេតុការណ៍ និងកាលសម័យកន្លងទៅ។

និកាយដែលសំខាន់ក្នុងសាសនាអ៊ិស្លាម មានដូច្នេះ ៖

១-និកាយសុន្នី (Sunni)

សុន្នីប្រែថា មគ្គ ឬចរិត ជានិកាយរបស់អ៊ិស្លាមដែលរាប់អានគម្ពីរមួយក្បាល គឺគម្ពីរសុន្នា ជាគម្ពីរអត្ថកថារបស់គម្ពីរកូរ៉ាន អ្នករាប់អានគម្ពីរសុន្នា ជាពួកតឹងរឹង ត្រូវការឱ្យគម្ពីរដើមអានងាយ យល់ងាយ ហើយត្រូវការឱ្យមនុស្សទូទៅយល់ផង ទើបតែងជាអត្ថកថាអធិប្បាយសេចក្ដីក្នុងគម្ពីរដើម ពួកនេះជាអ័រថូដក្សរបស់អ៊ិស្លាម មិនចូលចិត្តឱ្យអ្នកណាមកផ្លាស់ប្ដូរពាក្យពីដើមដែលមានក្នុងគម្ពីរ។ (ហេង គីមហោ សាសនាប្រៀប ធៀប ភាគ២ ទំព័១៨១)

ខសំខាន់ម្យ៉ាងទៀត ពួកសុន្នីប្រកាន់ថា ក្រោយពីពេលព្រះមហាហ្ម័តអស់ជីវិត មានកាហ្លិប (Khalifa) បន្តមកត្រឹម ៤នាក់ប៉ុណ្ណោះ តអំពីនោះគ្មានអ្នកបន្ត (កាហ្លិប) មានតែអ្នករាប់អានសាសនាអ៊ិស្លាមធម្មតា។ ពួកនិកាយសុន្នីប្រើមួកពណ៌ជាគ្រឿងសំគាល់ មានទូទៅក្នុងលោកជាង ២០០លាននាក់ ភាគច្រើននៅក្នុង ប្រទេសទួរគី អារ៉ាប៊ីនិងអាហ្វ្រិក កាហ្លិបដែលពួកនិកាយនេះកាន់ថា មានត្រឹម ៤គឺ អាប៊ូបារ៍ក អ៊ូម៉ា (ឬ ឱម៉ារ៍) ឱថម៉ាន (ឬ ឱសម៉ាន) និងអាលី។

**កំណត់សំគាល់ =** -អាប៊ូបារ៍ក ឪពុកក្មេកមហាហ្ម័ត។
-អ៊ូម៉ា ឪពុកក្មេកមហាហ្ម័ត។
-ឱថម៉ាន កូនប្រុសរបស់អាប៊ូបារ៍ក។
-អាលី កូនប្រសារបស់ព្រះមហាហ្ម័ត។
-កូនប្រុសអាប៊ូតាលិប ឪពុកធំព្រះមហាហ្ម័ត។

**និកាយជិអាហ៍ (Shiah)**

ជិអាហ៍ (ឬជិអេត៍) ប្រែថា អ្នកប្រតិបត្តិតាម ឬសាវ័កពាក់មួកពណ៌ក្រហម បែកចេញពីនិកាយដើម ដែលមិនព្រមឱ្យមានកាហ្លិបបន្តពីអាលីតទៅទៀត។

តាមប្រវត្តិពួកជិអាហ៍កាន់ថា តពីកាហ្លិបអាលីមកហើយ ខ្សែស្រឡាយរបស់អាលីគួរបានទទួលការតែងតាំងឬជ្រើសតាំងជាអ្នកដឹកនាំសាសនាតទៅទៀត ព្រោះជឿថា សាវ័កអ្នកបន្តពីអាលី ជាពួកបានទទួលពាក្យប្រដៅផ្ទាល់ពីអាលី។ លុះអស់ពីអាលីហើយ ទើបគួររកមនុស្សថ្មីមកជាមេដឹកនាំ មាននាមថ្មីថាអ៊ិម៉ាម។

តាមជំនឿនេះ ពួកជិអាហ៍ ទើបមានអ្នកដឹកនាំ (អ៊ិម៉ាម) ដែលបន្តដោយផ្ទាល់រួមទាំងអស់ (បញ្ចុះមកត្រឹម ១២នាក់)។

១-អាលី កូនប្រសារព្រះមហៈហ្មុំត (រៀបការជាមួយហ្វាតិម៉ាហ៍កូនស្រីពៅ)
២-អាល់-ហាសាន់ (មនុស្សទីមួយ) របស់អាលី។
៣-អាល់-ហ៊ូសេន កូនប្រុស (មនុស្សទីពីរ) របស់អាលី។
៤-អាលី (ឬសៃនូ អាល់-អានិធិន) កូនប្រុសរបស់ហ៊ូសេន។
៥-មហៈហ្មុំត អាល់បាគីរ៍ កូនប្រុសរបស់កូនហ៊ូសេន។
៦-យ៉ៈហ្វារ៍ អាស-សាឌិត កូនប្រុសរបស់អាល់-បាគីរ៍។
៧-មូសា-អាល់-គាសិម កូនប្រុសរបស់យ៉ៈហ្វារ៍។
៨-អារ៍-រ៉ាសា កូនប្រុសរបស់មូសា។
៩-មហៈហ្មុំត អាត់-តាគី កូនប្រុសរបស់ អារ៍-រ៉ាសា។
១០-អាលី អាល់-នាគី កូនប្រុសរបស់មហាហ្មុំត អាត់-តាគី។
១១-អាល់-ហាសាន់ អាល់ អ័សការី កូនប្រុសរបស់អាលី-អាល់នាគី។

១២-មហៈហ្មុំត កូនប្រុសរបស់អាល់-ហាសាន់ អាល់-អ័សការី ឬហៅនាមមួយទៀតថា អ៊ិម៉ាម អាល់-ម៉ាហៈឌី (ម៉ាហៈឌី)។ ពួកជ្វីហ្វជឿថាមានជីវិតនៅឡើយ នឹងមកឱ្យឃើញប្រាកដក្នុងថ្ងៃចុងក្រោយនៃលោក គឺថ្ងៃកាត់សេចក្ដីតាមពាក្យអធិប្បាយទាក់ទងរឿង "សេចក្ដីសង្ឃឹមនៃអ្នកមកកើតថ្មី" ដែលមានមកហើយ និងដោយរង់ចាំសេចក្ដីសង្ឃឹមដូច្នេះ កាហ្វិបរបស់ពួកជីអាហ៍ទើបត្រូវបញ្ចប់។ (ហេង គីមហោ សាសនាប្រៀប ធៀប ភាគ២ ទំព័១៨៣)

## និកាយ ឃវារិជ

និកាយឃវារិជ (Khawarij) មានន័យថា អ្នកបំបែកខ្លួនចេញកើតក្នុងសម័យពួកស៊ីរីមិនព្រមទទួលស្គាល់អាលីកូនប្រសាររបស់មហៈហ្មុំត ជាកាហ្វិបបន្ត អាលីយល់ព្រមឱ្យមានការវិនិច្ឆ័យដើម្បីកាត់សេចក្ដី ការយល់ព្រមរបស់អាលីនាំបង្កើតឱ្យមានការមិនពេញចិត្តក្នុងពួកអ្នកកាប់អានជាខ្សែស្រឡាយព្រះមហៈហ្មុំត នាំគ្នាជំទាស់បំបែកខ្លួនចេញ តាំងនិកាយមួយថ្មីប្រកាន់ខ្លួនថា អ្នកដទៃពុំមែនជាមូស្លីមពិតប្រាកដ មានតែពួកខ្លួនប៉ុណ្ណោះដែលពិតប្រាកដ មានព្រឹត្តិការណ៍ឃោរឃៅដោយអ្នកអាងថាខ្លួនជាមូស្លីម អាចត្រូវពួកនេះ សម្លាប់ចោល។

ឃវារិជអាងថា ទារកកើតពីបិតាមាតាមូស្លីម មិនអាចជាមូស្លីមបានឡើយ លុះត្រាធំឡើងល្មមអាចទទួលគោលការណ៍សាសនាអ៊ិស្លាមដោយខ្លួនឯងបាន ការដែលបដិបក្ខ

ចំពោះព្រះជាម្ចាស់មានបាបធ្ងន់ណាស់ មូស្លីមអាក្រក់ជួរជាតិប្រហែលគ្នាមិនមែនជាមូស្លីមៗ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៨៤)

និកាយ ដរូស (Druz) ជានិកាយអាថ៌កំបាំង (Mystic) ប្រហាក់ប្រហែលណកវីត កើតក្នុងប្រទេសស៊ីរី ប្រមាណគ្រិស្តសតវត្សទី១១ ផ្សព្វផ្សាយក្នុងលីបង់ៗ អ្នកឱ្យកំណើតនិកាយ គឺ ហ៊ិបគ្រប់គ្រងក្រុងគោរោ ឈ្មោះ ហាគីម មានន័យថា ជាអ្នកប្រកាសពាក្យប្រៀនប្រដៅទំនងដូចជាណកវីតទៅអំពីមូស្លីមពួកដទៃៗ ដូចជារាប់អានថា ហាគីមជាអ្នកតំណាងព្រះជាម្ចាស់និងកើតមកជាគ្រាចុងក្រោយ ហើយសាបសូន្យទៅ មិនព្រមរាប់អានសាសនា បែបអ្នកដទៃរាប់អាន ជួយគ្នាទៅវិញទៅមកតែក្នុងពួករបស់ខ្លួនៗ ពាក្យប្រដៅរបស់ហាគីម បានទទួលការជ្រោមជ្រែងផ្សព្វផ្សាយ អំពីពួកមូស្លីមជនជាតិអ៊ីរ៉ង់ ២នាក់ គឺ ហាំសា (HAMZA) និង តារាស៊ី DARAZI ឈ្មោះនិកាយមកអំពីឈ្មោះរបស់តារាស៊ីៗ

### និកាយ អ៊ិសម៉ៃលី

និកាយអ៊ិសម៉ៃលី (Ismaili) ឬ អ៊ិសមាអ៊ិល្លី ជាសាខាមួយរបស់និកាយជីអាហ៍ មានឈ្មោះតាមអ៊ិស ម៉ាអ៊ិស (កូនប្រុសរបស់យ៉ះហ្វារ៍ អ៊ីម៉ាមទី៦) មានន័យថាជាមនុស្សស្រវឹងខ្លួប ឪពុកមិនព្រមតាំងជាអ៊ីម៉ាម តែមនុស្សពួកនេះកាន់ថា អ៊ិសម៉ាអ៊ិលជាម៉ាម (មនុស្សទី៧) តពីឪពុក ប្រមុខរបស់និកាយឈ្មោះ អាកាខានៗ

និកាយនេះ មានការប្រព្រឹត្តទៅបែបអាថ៌កំបាំង ដំណើរកិច្ចការជាឯកទេស មិនសូវមានអ្នកណាដឹងរឿងច្រើនទេ ជាពួកខ្លាំងក្លាកាចសាហាវ នឹងអ្នកមិនមែនបក្សពួករបស់ខ្លួនរហូតដល់ហ៊ានប្រហារមនុស្សពួកដទៃ ដោយអាងថាដើម្បីការពារដីប៉ុនរបស់ពួកខ្លួន និងសាសនារបស់ខ្លួន មានពួកតាគិយ៉ា (Tagiyya) មួយពួកទៀត មានកំណើតមកពីពួក អ៊ិសម៉ៃលីៗ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៨៥)

### និកាយ វ៉ាហ៍ហាប៊ី

និកាយវ៉ាហ៍ហាប៊ី (Wahhabi) កើតឡើងប្រហែលគ្រិស្តសតវត្សទី ១៨ បានមកពីឈ្មោះរបស់មហៈ ហ្ម័តអាប់ឌុល វ៉ាហ៉ាប ហៅខ្លួនឯងថា ប៉ូរិតាន់ (Puritan) គឺអ្នកកាន់តឹងតែង ឬ យូនិតេរៀន (Unitarian) គឺអ្នកតឹងតែង ឬយូនិតេរៀន (Unitarian) គឺអ្នកតឹងតែងចំពោះ ព្រះជាម្ចាស់ (អាល្លា) មួយអង្គ ពុំមានអ្នកណាដទៃ សូម្បីតែព្រះនះប៊ី មហះហ្ម័ត ក៏មិនព្រម

រាប់អានដូចជានិកាយដទៃ ជានិកាយដែលកែប្រែ ផ្លាស់ប្តូរជំនឿដែលមានមកពីដើមជាច្រើន បើពោលតាមន័យមួយទៀតថា វាហ៉ា ហាប៊ី ជាប្រូតេស្តង់របស់អ៊ិស្លាម។

គោលការណ៍រាប់អាន ដែលមានការផ្លាស់ប្តូរ ទៅពីចារីតដើមកំណត់បានដូច្នេះ ៖

១-អ្នកជាមូស្លីមគឺ ពួកអានព្រះគម្ពីរកូរ៉ានបាន និងយល់ប៉ុណ្ណោះ មិនមែនជាមូស្លីមត្រឹមតែធ្វើពិធីប៉ុណ្ណោះទេ។

២-ព្រះជាម្ចាស់តែមួយព្រះអង្គទ្រង់ដឹងរឿងល្អអាក្រក់របស់មនុស្សទាំងអស់ មិនត្រូវមានសាសនទូត (ដូចព្រះនៈប៊ីមហៈហ្មាត់) រង់ចាំទាក់ទងនឹងព្រះជាម្ចាស់ ហើយមកប្រាប់មនុស្សបន្តទៀត (គ្មានអ្នកនៅរវាងព្រះជាម្ចាស់និងមនុស្ស)។

៣-ព្រះនៈប៊ីមហៈហ្មាត់អាចទាក់ទងនឹងមនុស្សបាននៅថ្ងៃទីបំផុតនៃលោកតែប៉ុណ្ណោះ។

៤-អ្នកណាធ្វើគ្រឿងប្រដាប់ តាក់តែងទីសក្ការៈបូជា ចំពោះបណ្តាមនុស្សសំខាន់ក្នុងសាសនាកាន់ថា ខុស មានបាប (កន្លែងបញ្ចុះសពរបស់ព្រះនៈប៊ីមហៈហ្មាត់ ឯក្រុងមេឌិនៈ ក៏មិនចាំបាច់ទៅនមស្ការដែរ)។

៥-មិនព្រមឱ្យស្ត្រីទៅមើលផ្នូរសពអ្នកស្លាប់ ហាមដាច់ខាតមិនឱ្យមានការសោកសង្រេងអ្វីឡើយ។

៦-បដិសេធពិធីកម្មណាៗទាំងអស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៨៦)

ការធ្វើពិធីនៅត្រឹមតែ ៤យ៉ាង ដែលអនុញ្ញាតឱ្យធ្វើនិងគួរធ្វើ គឺ ៖

ក-ពិធីឱ្យទានដល់ក្មេងកំព្រា ស្រីមេម៉ាយ មនុស្សក្រខ្សត់ ក្រោយធ្វើពិធីរួចហើយកាន់សីលអត់។

ខ-ពិធីត្រស្តសង្ក្រាន្តធំ (ពិធីអ៊ិឌិលអដ្ហហា មើលពីខាងដើម)។

គ-ពិធីអត់អាហារក្នុងថ្ងៃទី១០ នៃខែមូហារ៉ម (ខែធ្វើពិធីអាគន្ទុក របស់ម្ចាស់សេន មើលខាងដើម)។

ឃ-ពិធីរំឭកដល់យប់ ដែលព្រះជាម្ចាស់ប្រទានពាក្យប្រដៅតាមព្រះគម្ពីរកូរ៉ាន ដល់ព្រះមហៈហ្មាត់ ជាគ្រាដំបូង ក្នុងខែរ៉ាម៉ាដាន (ថ្ងៃទី ១៥) កាន់ថា ជាយប់នៃមហាអំណាច មានជំនឿថាក្នុងយប់នោះ សព្វសត្វតិណជាតិនិងរុក្ខជាតិទាំងឡាយ ដែលព្រះជាម្ចាស់ទ្រង់សាងនឹងបង្អោនចុះសម្តែងកក្តីភាពចំពោះព្រះជាម្ចាស់។

៧-មិនរួមពិធីក្នុងថ្ងៃឧប្បត្តិរបស់ព្រះនៈប៊ីមហៈហ្មាត់។

៨-មិនសែនព្រេនវត្ថុស័ក្តិសិទ្ធិខាងផ្លូវសាសនា ដោយគ្រឿងសក្ការៈណាៗ។

៩-ពេលចេញព្រះនាម ដែលជាវេវចនៈរបស់ព្រះជាម្ចាស់ ទាំង៩៩ ព្រះនាមរាប់ចំនួនដោយម្រាមដៃ មិនមែនគ្រាប់ផ្កាំ។

១០-ការបូជាសក្ការៈ គួរធ្វើឱ្យរៀបរយងាយៗ ការច្រៀងប្រគុំតន្ត្រីណាៗ មិនគួរមានរហូតដល់ការតែងខ្លួនឱ្យប្រព្រឹត្តទៅដោយសុភាព។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ ១៨៧)

សេចក្តីបំណងរបស់ការតាំងនិកាយនេះដើម្បីនឹងញ៉ាំងសេចក្តីពិតនៃព្រះគម្ពីរកូរ៉ានមិនឱ្យអ្នកណាមកប៉ះពាល់ឬអធិប្បាយសេចក្តីបន្ថែមទៀត។ គម្ពីរដើមមានសេចក្តី យ៉ាងណាឱ្យកាន់ទៅតាមនោះ ដូច្នេះ ទើបមានការជំទាស់អត្ថកថា ឬពាក្យអធិប្បាយក្នុងគម្ពីរ ដែលនិកាយសុន្នីធ្វើរួចមកហើយ។

វាហ៉ាហាប៊ី មិនរាប់អានអ្នកណាដទៃ ក្រៅអំពីព្រះអាល្លាមួយអង្គ អ្នកដទៃជាសាស្តាព្យាករណ៍ ដែលអ្នកណាៗរាប់អានថា ជាអ្នកបន្តវេនសាសនា វាហ៉ាហាប៊ីមិនព្រមរាប់អាន។ ការដែលមូស្លីមនិកាយណាៗទៅ មនស្ការរណ្តៅសពរបស់លោកសាស្តាព្យាករណ៍អង្គណានោះ វាហ៉ាហាប៊ីប្រាប់ថា ជាការត្រឡប់មកកាន់រូប គោរពដូចបែបពីដើម ខុសបញ្ញត្តិក្នុងព្រះគម្ពីរ។ និកាយនេះ បដិសេធមិនសូត្រមន្តឧទ្ទិសដល់ព្រះមហាម៉ូហ្មាត់ មិនជឿថាព្រះមហាម៉ូហ្មាត់ជាអ្នកតំណាងព្រះអាល្លា តែនឹងជាអ្នកតំណាងក្នុងថ្ងៃទីបំផុតនៃលោក ទើបគ្មានការ ធ្វើថ្ងៃឧប្បត្តិរបស់ព្រះមហាម៉ូហ្មាត់ ហាមដាច់ខាតមិនឱ្យប្រើសំពត់ព្រៃថ្មី និងរបស់ខ្ជះខ្ជាយហើយបដិសេធរូប មស្ជិតដែលធ្វើជាប៉មរង់ចាំដោយអាងថាគ្មានប្រដៅក្នុងគម្ពីរ។

មាននិកាយជាច្រើនទៀតក្នុងសាសនាអ៊ិស្លាមគឺ ៖ និកាយហ្វាគីរ៍, និកាយស៊ូហ្វី, និកាយបាហៃ ដែលការប្រកាន់ជំនឿប្លែកៗពីគ្នា ទៅតាមសាស្តាព្យាករណ៍នីមួយៗ។

**ចរិយាធម៌របស់អ៊ិស្លាម** (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៨៨)

សាសនាអ៊ិស្លាម ជាសាសនាអាចហៅថា "ភាគប្រតិបត្តិ" មានច្បាប់បទបញ្ញត្តិ ដែលមានប្រាកដក្នុងព្រះគម្ពីរ ជាគោលបញ្ញត្តិនៃជីវិតនិងសង្គម "ភាគប្រតិបត្តិ" ទាំងនេះក្លាយមកជាចរិយាធម៌របស់អ៊ិស្លាមិកទាំងឡាយក្នុងបច្ចុប្បន្ន និងផ្នែកធំរបស់ចរិយាធម៌នោះៗ កើតឡើងអំពីការប្រតិបត្តិរបស់ព្រះមហាម៉ូហ្មាត់ដែលជាសាស្តា។

វិល្លៀមមូរ៍ អ្នកសរសេរ Life of Mohamet ប្រាប់និស្ស័យចិត្តគំនិត និងការប្រតិបត្តិរបស់ព្រះមហាម៉ូហ្មាត់ទុកជាច្រើន ដែលជាផ្លូវឱ្យឃើញពីចរិយាធម៌ ដោយសំអាងថា ជាជំនឿ

របស់អ៊ិស្លាមិក ដឹងមកអំពីពាក្យសម្ដីរបស់នាងអាស៊ីហះហ៍ កិរិយាជំនិតរបស់ព្រះមហៈហ្មាត់ប្រាប់ថាដូច្នេះ ៖

"ព្រះមហៈហ្មាត់ជាមនុស្សដើរលឿន គ្មានអ្នកណាដើរតាមទាន់ (ឧស្សាហ៍)"។

"ព្រះមហៈហ្មាត់ជាអ្នកមានអំណាចក៏ពិតមែន តែមិនធ្លាប់សម្ដែងឱ្យអ្នកណាឃើញពេលបរិភោគអាហារមិនធ្លាប់សម្ដែងខ្លួនដូចព្រះរាជាមានការបរិភោគឯកឯងជាដើម។ លោកមិនធ្លាប់ឱ្យអ្នកណាដើរតាមក្រោយដល់ទៅ ២នាក់ ដោយមិនត្រូវការឱ្យគេយល់ថា លោកជានាយចៅហ្វាយអ្នកណា លោកប្រើម្រាមដៃចាប់ អាហារបរិភោគ ហើយដៃរបស់លោកស្អាតជានិច្ច លោកមិនដែលដាក់ទោសអ្នកបម្រើរបស់លោកឡើយ"។

"ពេលសូត្រមន្ត ព្រះមហៈហ្មាត់ ទ្រាំឈរយូរជាងគេទាំងអស់ ពេលសូត្រមិនដែលឈប់ មិនធ្លាប់ធ្វើចន្លាក់សូត្រមន្តឱ្យខូច សូម្បីក្នុងពេលក្អកឬហត់ ពេលទៅបញ្ចុះសពអ្នកណាមួយ មិនធ្លាប់ឡើងជិះពាហណៈ ព្រះមហៈហ្មាត់ឈប់ស្ងប់ស្ងៀម មិនកម្រើកចំពោះមុខសព ដើម្បីជាគំរូយ៉ាងដល់មនុស្សទាំងឡាយថា លោកសាស្ដាជាអ្នកមានកង្វល់ចង់ទាក់ទងជាមួយអ្នកស្លាប់"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៨៩)

"ពេលណាលោកសាស្ដាទទួលជំនូន ពីមនុស្សទាំងឡាយបរិច្ចាគដោយសទ្ធា លោកមិនដែលទុកជាប្រយោជន៍ផ្ទាល់ខ្លួន លោកប្រគល់របស់នោះៗឱ្យទៅជាទាន សូម្បីមនុស្សក្នុងគ្រួសារ ក៏លោកមិនឱ្យដែរ អ្នកណាក្នុងគ្រួសារបរិច្ចាគ លោកសុំឱ្យគ្រប់ៗគ្នានាំរបស់នោះៗទៅធ្វើទានឱ្យអស់ លោកធ្លាប់ពោលថា "ការឱ្យទានជាការញ៉ាំងសេចក្ដីបរិសុទ្ធឱ្យកើតដល់មនុស្ស"។

"លោកសាស្ដាចូលចិត្តរបស់ផ្អែម និងទឹកឃ្មុំ របស់ចូលចិត្តបន្ទាប់មកគឺ ត្រសក់ស្រូវ និងផ្លែឥន្ទុលាំស្រស់ ជួនកាលចូលចិត្តបាយដាំផ្សំជាមួយឥន្ទុលាំ"។

"ព្រះមហៈហ្មាត់ប្រើសំពត់ដណ្ដប់កាយត្រឹម២ផ្ទាំង គឺឃ្លុំខាងក្នុងមួយផ្ទាំង និងខាងក្រៅមួយផ្ទាំង សំពត់ឃ្លុំកាយនេះស្អាត ដូចរាងកាយស្អាតដែរ។ ចំណែកដទៃទៀត លោកសាស្ដាជាអ្នកចែកពេលបានល្អប្រសើរគឺ ថ្ងៃនីមួយៗលោកចែកជា ៣ពេល មួយផ្នែកជាពេលសូត្រឧទ្ទិសចំពោះព្រះជាម្ចាស់ មួយផ្នែកឱ្យដល់គ្រួសារ និងមួយផ្នែកទៀតឱ្យដល់ខ្លួនឯង ពេលក្រោយនេះ បើមានអ្នកណាមករកលោក លោកសាស្ដាចែកពេលឱ្យ ពាក់កណ្ដាល"។

*"តាមប្រពៃណីតែងខ្លួនរបស់ជនជាតិអារ៉ាប់ ប្រើសម្លៀកបំពាក់មានពណ៌ផ្សេងៗគ្នា លោកសាស្តាចូលចិត្តប្រើសម្លៀកបំពាក់ពណ៌សជាប្រចាំ ជូនកាលលោកប្រើពណ៌ផ្សេងៗខ្លះ គ្រាខ្លះជាសំពត់រោមសត្វពណ៌ខ្មៅ សំពត់ណាជាពណ៌ស្រូបក្លិន លោកមិនចូលចិត្តបែបនេះទេ"។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៩០)*

*"អាវុធដែលលោកសាស្តាចូលចិត្តប្រើ មាន ៤បែបគឺ ដាវ លំពែង ក្រោះ និងធ្នូ កន្លែងសម្រាករបស់លោកសាស្តាធ្វើអំពីឥដ្ឋឆៅ ប៉ុន់ជាបន្ទប់ៗធ្វើផ្លូវដើរជាប់ទាក់ទងគ្នាជាមួយកន្លែងសម្រាករបស់ភរិយា (ដែលមានជាច្រើននាក់ក្នុងពេលនោះ) និងរបស់កូនខ្លះ ដំបូងប្រក់ស្លឹកឥន្ទណំ"។*

*ឥឡូវនេះ នឹងសម្តែងពីចរិយាធម៌ប្រកបដោយការរាប់អានផ្អែកដទៃៗ សាសនាអ៊ិស្លាម ដោយសមគួរ ៖*

*ការនាំឱ្យដឹងពីចរិយាធម៌ ខាងផ្លូវសង្គមរបស់ជនជាតិមូស្លីមដោយច្បាស់លាស់ ត្រូវពិចារណាដល់គោលបញ្ញត្តិក្នុងសាសនាច្រើនប្រការ ដែលជាផលទាក់ទងនឹងរឿងជីវិតរបស់ព្រះមហៈហ្ម៉ត ជាសាស្តាផង់ជាមួយផង។*

*អន្តប្រកបរបស់អ៊ិស្លាមិកសម្តែងមកតាំងពីដើម ទំនាក់ទំនងដោយសទ្ធានិងការប្រតិ-បត្តិជាអាទិ៍ សទ្ធាដ៏តឹងរ៉ឹងចំពោះព្រះជាម្ចាស់មួយព្រះអង្គចំពោះព្រះគម្ពីរ ចំពោះលិខិតរបស់ព្រះជាម្ចាស់នោះក្តី ការប្រតិបត្តិតាមសទ្ធាក្នុងព្រះគម្ពីរជាអាទិ៍ ការរៀនសូត្រ ការសម្តែងសេចក្តីមេត្តាចែកកម្រៃរកបានអនុគ្រោះឱ្យជាទាន ដល់មនុស្សទាំងឡាយពួកដទៃៗ អ្នកមានឋានៈតូចទាបជាង រហូតដល់ការប្រតិបត្តិក្នុងគ្រួសារចំពោះស្វាមី ភរិយាក្តី ធ្វើឱ្យឃើញថាបណ្តាសង្គមសាវ័ករបស់ព្រះនៈប៊ីមហៈហ្ម៉ត់នោះ ជាសង្គមដែលមាំទាំ។*

*ការដែលញ៉ាំងសង្គមឱ្យរឹងប៉ឹងបាននោះ ត្រូវជាអ្នកកក្តីភាពចំពោះព្រះអាហ្លាជាម្ចាស់ និងពាក្យប្រដៅរបស់ព្រះអង្គ (ព្រះគម្ពីរកូរ៉ាន) ដែលជីវិតមិនត្រូវប្រព្រឹត្តអ្វី ទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ជាហេតុឱ្យកក្តីភាព (សទ្ធា) នោះ រាយមាយទៅវិញ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៩១)*

*ដូច្នោះ អ៊ិស្លាមិក មិនគួរញ៉ាំងសទ្ធាឱ្យរាយមាយចុះក្នុងផ្លូវត្រីទ្វារ ដោយការប្រតិបត្តិដូច្នេះ ៖*

ផ្លូវកាយ

១-មិនក្រាបសំពះគោរពរូប

២-មិនមើលងាយព្រះគម្ពីរគូរ៉ាន និងពាក្យប្រដៅរបស់បណ្ដានះប៊ី។

៣-មិនលំអៀងទៅសាសនាដទៃ ដូចការទៅប្រជុំនៅទីសាសនាដទៃ និងតែងខ្លួនតាមពិធីរបស់សាសនានោះៗ។

៤-មិនធ្វើឱ្យប្រឡាក់ប្រឡូសព្រះគម្ពីរ កែព្រះនាមរបស់ព្រះជាម្ចាស់ រហូតដល់នាមរបស់លោកនះប៊ី ទាំងឡាយ។

៥-មិនធ្វើខ្លួនជាឧបសគ្គចំពោះអ្នកមានបំណង ចូលមករាប់អានសាសនាអ៊ិស្លាម ឬមិនព្រួតដៃក្នុងការ បង្រៀនសាសនាអ៊ិស្លាម។

៦-មិនសម្ដែងកិរិយាបូកពា ដែលទាក់ទងនឹងពិធីកម្មរបស់សាសនាដទៃ មិនថាដោយការតាំងចិត្ត ឬ មិនតាំងចិត្តក៏ដោយ។

ផ្លូវវាចា

១-មិននិយាយថា ខ្លួនធ្លាប់បានឃើញព្រះអាល់្លោះ

២-មិននិយាយថា ខ្លួនធ្លាប់សន្ទនាជាមួយព្រះអាល់្លោះ

៣-មិននិយាយថា ព្រះអាល់្លោះមានរូបល្អស្អាតណាស់ ឬរូបព្រះអាល់្លោះដូចរបស់ដែលមនុស្សសាងឡើង។

៤-មិនយកព្រះនាមរបស់ព្រះអាល់្លោះ មកនិយាយអាងក្នុងការធ្វើអំពើមិនគួរគប្បី ដូចនិយាយថា "ក្នុងនាមព្រះអាល់្លោះ ខ្ញុំសូមផឹកស្រាមួយកែវ" នេះជាដើម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៩២)

៥-មិនចោទប្រកាន់ ឬតិះដៀលបណ្ដាបងប្អូនមូស្លីមថាជាអ្នកក្រៅសាសនាអ៊ិស្លាម។

៦-របស់ដែលធ្វើពុំបាន (តាមព្រះគម្ពីរ) កុំនិយាយថា ជារបស់អាចធ្វើបាន។

៧-របស់ដែលធ្វើបាន (តាមព្រះគម្ពីរ) កុំនិយាយថា ជារបស់ធ្វើពុំបាន។

៨-ការធ្វើអំពើដែលជាបាប កុំនិយាយថាគ្មានបាប។

៩-មិនជេរ ឬបណ្ដាសាបណ្ដានះប៊ី និងទេពបរិវាររបស់ព្រះអាល់្លោះជាម្ចាស់។

១០-មិននាំយកពាក្យស័ក្តិសិទ្ធិ ក្នុងសាសនាមកនិយាយលេង ដូចនិយាយថា "ពាក្យថ្វាយព្រះពរព្រះជាម្ចាស់ មិនឃើញមានប្រយោជន៍អ្វី មិនឃើញឱ្យមានស៊ីឬមានបាន ដូច្នេះជាដើម"។

**ផ្លូវចិត្ត**

១-មិនសង្ស័យថា ព្រះអាល់ឡោះជាម្ចាស់ ជាអ្នកទ្រង់សាងរបស់សព្វសារពើពិត ឬ មិនពិត ព្រះអាល់ឡោះមិន មែនមានតែមួយអង្គ ព្រះអាល់ឡោះមិនមែនមានមកតាំងពីដើម ទើបតែនឹងមានឡើង ព្រះអាល់ឡោះមានលក្ខណៈ ដូចជាអ្វីម្យ៉ាង ហើយព្រះអង្គមានពិតមែនឬទេនោះ តើទ្រង់យុត្តិធម៌ឬទេ ? និងមិនព្រមជឿក្នុងគុណលក្ខណៈណាមួយរបស់ព្រះអាល់ឡោះជាម្ចាស់។

២-មិនសង្ស័យការជាសាសនទូតរបស់ព្រះនៈប៊ីមហៈហ្ម៉ាត់ និងមិនសង្ស័យរឿងរបស់បណ្ដានៈប៊ីទាំងឡាយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៩៣)

៣-មិនសង្ស័យថា ព្រះគម្ពីរកូរ៉ាន មិនមែនបញ្ញត្តិរបស់ព្រះអាល់ឡោះជាម្ចាស់។

៤-មិនសង្ស័យថា ក្រោយពីព្រះនៈប៊ីមហៈហ្ម៉ាត់ហើយ នៅមាននៈប៊ីអង្គដទៃតទៅទៀត។

៥-មិននឹកគិតថា នឹងលះបង់រាប់អានសាសនាអ៊ីស្លាម។

៦-មិនសង្ស័យរឿងថ្ងៃទីបំផុតនៃលោក រឿងនរកនិងសួគ៌។

៧-មិនសង្ស័យរឿងពិធីកម្មផ្សេងៗ ដូចរឿងនៈមាជ (លៈហ្ម៉ាត) រឿងកាន់សីលអត់ថាគ្មានបានផលល្អ ឬមិនគួរនឹងប្រកបធ្វើ។

៨-មិនសង្ស័យពីព្រះអំណាចរបស់ព្រះអាល់ឡោះជាអម្ចាស់ មិនមានគំនិតរិបរិតថាកម្លាំងការងារផ្សេងៗ ពុំបានកើតពីព្រះអំណាចទេនោះ។

សាសនាអ៊ីស្លាមប្រដៅថា មនុស្សមានកំហុស ២ស្ថាន ស្ថានទី១ ខុសចំពោះព្រះជាម្ចាស់ និងស្ថានមួយទៀតខុសដល់មនុស្សដែលទាក់ទង ដូចជាការសម្លាប់មនុស្ស លួចគេសេពគប់ស្រីខូច។ល។ កំហុសចំពោះព្រះជាម្ចាស់ ព្រះទ្រង់អភ័យឱ្យ (បើសម្ដែងកក្តីភាព និងសារភាពជានាថាមិនប្រព្រឹត្តទៀត)។ ចំណែកកំហុស ចំពោះមនុស្សក៏ត្រូវបានទទួលអភ័យពីមនុស្សទាក់ទងពីមុនដែរ នឹងត្រូវនាំទៅពិចារណាទោសក្នុងថ្ងៃទីបំផុតនៃលោក។

អ្នកនៅក្នុងសង្គម គួរប្រព្រឹត្តខ្លួនឱ្យសមរម្យដល់សង្គម ការប្រព្រឹត្តខុសតាមគោលការណ៍តទៅនេះ គឺ ខុសពីចរិយាធម៌របស់សង្គម ជាបាបធ្ងន់នឹងមានទោសធ្ងន់។

១-បដិសេធមិនព្រមជឿព្រះអាល់ឡោះ មិនព្រមជឿគុណលក្ខណៈរបស់ព្រះអង្គ ហើយនាំយករបស់ណាមួយ មកប្រៀបធៀបនឹងព្រះអាល់ឡោះ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៩៤)

២-សម្លាប់ខ្លួនឯង រួមទាំងសម្លាប់អ្នកដទៃ។

៣-ពុំមានសេចក្តីយុត្តិធម៌ ធ្វើទុក្ខបុកម្នេញសត្វ ធ្វើឱ្យរំខានដល់មនុស្សកើតទុក្ខ សេពគប់ជនអន្ធពាល ឆបោក កញ្ឆក់កណ្តៀតវាយដំច្រំជាក់ លបប្រហារអ្នកគ្មានកំហុស និងធ្វើអំពើអាក្រក់ដល់អ្នកដទៃ។

៤-អកតញ្ញូចំពោះម៉ែឪ ដោយសម្តែងកិរិយាឫកពាមិនសុភាព មានសន្តានចិត្តអាក្រក់ ប្រព្រឹត្តខ្លួនធ្វើ ឱ្យឪពុកម្តាយមិនសប្បាយចិត្ត។

៥-មានសហាយស្មន់រួមរក្សស្រឡាញ់គ្នាដោយមិនត្រឹមត្រូវតាមគោលការណ៍ សាសនាអ៊ិស្លាម។

៦-ផឹកស្រា ឬសេពរបស់ស្រវឹង។

៧-លេងល្បែងភ្នាល់

៨-បរិភោគរបស់ដែលព្រះអាល់ឡោះទ្រង់បញ្ញត្តិហាម ដូចជា សាច់សុករ សុនខ សាច់សត្វត្រូវសម្លាប់ ដោយមិនបានពោលនាមព្រះអាល់ឡោះ និងមិនត្រឹមត្រូវតាមគោល សាសនា។

៩-លះបង់មិនធ្វើតាមបញ្ញត្តិ ដូចជា មិនកាន់សីលអត់ធ្វើលះហ្មាត (នះមាជ) មិនធ្វើទាន (សាកាត់) មិនប្រកបពិធីហះយី (កាន់បួស)។

១០-យកការប្រាក់ខុសពីធម្មតា។

១១-និយាយកុហក ឬស្បថ។

១២-ជាសាក្សីកុហក។

១៣-ញុះញង់ឱ្យមនុស្សឈ្លោះគ្នា ឬបែកបាក់គ្នា។

១៤-លាក់បាំងការសម្ងាត់របស់អ្នកធ្វើខុស។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័រ១៩៥)

១៥-តិះដៀលនិន្ទា ចោទប្រកាន់អ្នកដទៃឱ្យខូចប្រយោជន៍។

១៦-និយាយទ្រគោះបោះបោកឱ្យអ្នកដទៃក្តៅក្រហាយ។

១៧-ដាច់ការសម្ព័ន្ធជាមួយញាតិបងប្អូន។

១៨-ស៊ីសំណូក ប្រព្រឹត្តអំពើពុករលួយ។

១៩-លំអៀងមិនមានសេចក្ដីយុត្តិធម៌។

២០-ប្រព្រឹត្តធ្វើឱ្យអ្នកដទៃមិនពេញចិត្ត។

កាលបើមិនប្រព្រឹត្តអំពើអាក្រក់ដូច្នោះហើយ ត្រូវប្រព្រឹត្តអំពើល្អដូចតទៅ ៖

១-កតញ្ញូចំពោះឪពុកម្ដាយ មានការស្រឡាញ់លោកទាំងពីរ ដូចជាលោកស្រឡាញ់ និងថ្នាក់ថ្នមយើងតាំងពីតូចដល់ធំ ដោយការនឿយហត់លំបាកឱ្យបានមកឃើញលោកដ៏ធំទូលាយ។

២-ឱ្យចេះគោរពឱនលំទោន ចំពោះអ្នកមានកិត្តិយស និងអាវុសោជាងខ្លួន។

៣-ឱ្យមានចិត្តមេត្តាអាណិត និងមានករុណាប្រណីដល់អ្នកទាបជាងទន់ខ្សោយជាងខ្លួនរួមទាំងមនុស្ស និងសត្វ។

៤-ឱ្យចេះយោគយល់ចិត្តរវាងនិងគ្នា យកចិត្តគេមកដាក់ចិត្តយើង របស់អ្វីដែលយើងមិនចង់ឱ្យគេធ្វើមកលើយើង យើងកុំធ្វើរបស់នោះទៅលើគេដែរ។

៥-ប្រព្រឹត្តខ្លួនឱ្យល្អចំពោះអ្នកភូមិផងរបងជាមួយ។

៦-មានសេចក្ដីស្រឡាញ់រាប់អានមូលត្រកូលគ្នា រវាងបងប្អូននិងមិត្តភក្ដិ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៩៦)

៧-ជួយសង្គ្រោះអ្នករងទុក្ខវេទនា។

៨-ជួយសង្គ្រោះអ្នកបំណងធ្វើអំពីល្អ។

៩-ឱ្យកិត្តិយសដល់ភ្ញៀវមកសំណាក់អាស្រ័យនៅក្នុងផ្ទះ។

១០-ទៅសួរសុខទុក្ខអ្នកមានជំងឺឈឺថ្កាត់។

១១-ទៅជួយបុណ្យសពមនុស្សស្លាប់។

១២-មិននិយាយពីការសម្ងាត់របស់អ្នកដទៃ ដែលនាំឱ្យមានការអៀនខ្មាស។

១៣-ចាយវាយទ្រព្យសម្បត្តិមាសប្រាក់ទៅក្នុងផ្លូវដែលល្អ។

១៤-ណែនាំអ្នកដទៃមកចូលរួមសន្ទនាគ្នា។

១៥-ជួយបង្រៀនអ្នកល្ងង់ខ្លៅ។

១៦-ឱ្យឱវាទដល់អ្នកប្រព្រឹត្តអាក្រក់ ឱ្យលះបង់ចេញ។

១៧-កាលណាមានការងារសំខាន់ឬការងាររួមត្រូវព្រួតដៃគ្នាជួយដោយពេញកម្លាំង

១៨-ធ្វើអំពើល្អដល់មនុស្សទូទៅ។

១៩-អភ័យទោសដល់អ្នកធ្វើខុស។ល។

សាសនាអ៊ិស្លាម ព្រមទទួលស្គាល់ថា ជាសាសនាធំ ចងភ្ជាប់សង្គមមួយផ្អែកយ៉ាង ខ្ជាប់ខ្ជួន និងទូលំទូលាយ មានចរិយាធម៌ជាគ្រឿងប្រដាប់សម្រាប់ជីវិត ញ៉ាំងជីវិតឱ្យចម្រើន ក្នុងសង្គម ញ៉ាំងសង្គមឱ្យឈានទៅមុខជាលំដាប់ តាមសេចក្ដីដូចបានពិពណ៌នា មកនោះ ឯង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២ ទំព័១៩៧)

# ភាគរួមផ្សំនៃសាសនាប្រៀបធៀប

## ១-កាលវេលា និងទីស្ថានកំណើត

សាសនាព្រាហ្មណ៍ (ហិណ្ឌូ) ពេលកើតមុនពុទ្ធសករាជប្រមាណ ២០០០-២៥០០ ឆ្នាំ ទីស្ថានដែលកើត ប្រទេសឥណ្ឌា បរិវេណជងទន្លេសិន្ធុ មជ្ឈមណ្ឌលរីងមាំនៅទីក្រុង ពារាណសី មាត់ទន្លេគង្គា ក្នុងឥណ្ឌាភាគខាងត្បូង (ទ្វីបអាស៊ី) មិនមាននាមសាស្ដាប្រាកដ ច្បាស់ លាស់។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័២)

សាសនាជ្វីហ្វ (យូដា) ពេលកើតមុនពុទ្ធសករាជ ប្រមាណ១៧០០-២០០០ ឆ្នាំ បរិវេន ភ្នំស៊ីណៃ ខាងត្បូងនៃអេហ្ស៊ីបសម័យបូរាណ (អាស៊ីអាហ្វ្រិក) មោសេសជាសាស្ដា។

សាសនាជិន្តោពេលកើតប្រមាណមុនគ.ស.៦៦០(ប្រមាណមុនពុទ្ធសករាជ ១១៧ឆ្នាំ) កន្លែងកើត កោះជប៉ុន ទិសខាងកើតក្នុងមហាសមុទ្រប៉ាស៊ីហ្វិក (ទ្វីបអាស៊ី) មិនប្រាកដនាម សាស្ដាច្បាស់លាស់។

សាសនាបារ៍ស៊ី (សោរោអស្ទ្រឺរ៍) ពេលកើតប្រមាណគ.ស.៦៦០ (ប្រមាណ មុនពុទ្ធ សករាជ ១១៧ឆ្នាំ) កើតនៅប្រទេសអ៊ីរ៉ង់ (ប៉ែក្ស) ដែនដីប្រេង មជ្ឈឹមបូព៌ា (ទ្វីបអាស៊ី) សោ រោអស្ទ្រឺរ៍ ជាសាស្ដា។

សាសនាតៅ ពេលកើត ប្រមាណមុនគ.ស.៦០៤ (ប្រមាណមុនពុទ្ធសករាជ ៦១ឆ្នាំ) កន្លែងកើត ប្រទេសចិនកណ្ដាល (ទ្វីបអាស៊ី) ឡៅជឺជាសាស្ដា។

សាសនាជេន ពេលកើតប្រមាណមុនគ.ស. ៦០០ (ប្រមាណមុនពុទ្ធសករាជ ៥៧) ទីស្ថានកើតប្រទេសឥណ្ឌាភាគខាងជើង (ទ្វីបអាស៊ី) មហាវីរៈជិនវឌ្ឍមានជាសាស្ដា។

ពុទ្ធសាសនា ពេលកើត ប្រមាណមុនគ.ស. ៥៨៨ឆ្នាំ (ប្រមាណមុនពុទ្ធសករាជ ៤៥ ឆ្នាំ) ទីស្ថានកើតប្រទេសឥណ្ឌាភាគកណ្ដាល (ទ្វីបអាស៊ី) ពុទ្ធសមណគោតម ជាសាស្ដា។

សាសនាខុងជឺ ពេលកើត ប្រមាណមុនគ.ស. ៥៥០ (ប្រមាណមុនពុទ្ធសករាជ ២៧ ឆ្នាំ) កន្លែងកើត ប្រទេសចិនភាគខាងជើង (ទ្វីបអាស៊ី) ខុងជឺជាសាស្តា។ (ហេង គឹមហោ សាសនាប្រៀបធៀប ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២)

សាសនាគ្រិស្ត ពេលកើត ប្រមាណមុនគ.ស. ៤ឆ្នាំ (ប្រមាណពុទ្ធសករាជ ៥៤៧ឆ្នាំ) កន្លែងកើត ផែនដី ប៉ាឡេស្ទីន (បុរាណ) បរិវេណដើមទន្លេហ្សរដាំង ជិតទន្លេសាបកាលិលី ខេត្តក្រុងណាសារេធបច្ចុប្បន្នកំណត់ ជាខេត្តពំងស្លួត មជ្ឈឹមបូព៌ា (ទ្វីបអាស៊ី) ព្រះយេស៊ូជាសាស្តា។

សាសនាអ៊ិស្លាម ពេលកើត ប្រមាណ គ.ស.៥៧០ (ប្រមាណពុទ្ធសករាជ ១១១៣) កន្លែងកើតជ្រោយអារ៉ាប់ ក្រុងមេឌិនៈ ប្រទេសសាអ៊ុឌិ អារ៉ាប៊ី បច្ចុប្បន្ន ជាខេត្តពំងស្លួត មជ្ឈឹមបូព៌ា (ទ្វីបអាស៊ី) ព្រះនៈប៊ីមហៈ ហ្មូតជាសាស្តា។

កំណត់ហេតុនៃការប្រៀបធៀបសាសនាទាំងនេះ កើតឡើងក្នុងផ្ទៃភូមិភាគកន្ទារ (លំបាក) ឈាយឡំទៅដោយទុក្ខលំបាក មានជាតុអាកាសធាតុខ្លាំង ក្តៅខ្លាំង ពិបាកនឹងមានជីវិតរស់នៅ។ ចំណែកសំខាន់បំផុតនោះ គឺកើតក្នុងផែនដីដែលសន្និដ្ឋានតាមភូមិសាស្ត្រថា មជ្ឈឹមបូព៌ា គឺក្នុងផែនដីផ្នែកខាងកើតនៃលោក (ទ្វីបអាស៊ី) ទាំងអស់។ ហេតុផលគួរឱ្យ វិនិច្ឆ័យនូវហេតុទាំងនេះគឺ បញ្ញាមែងមិនកើតមានដល់ពពួកជន ដែលជាអ្នកសេពសោយ សេចក្តីសុខសម្រាន្ត ការគិតរឿងលោកនិងជីវិតរមែងមិនកើតក្នុងសង្គមរបស់បុគ្គលដែលមិនចាំបាច់ត្រូវនឹកដល់ជីវិតនិងលោក ការត្រាស់ដឹងរមែងកើតក្នុងដែនដីដែលគួរនៅពឹងពាក់អាស្រ័យ។

ចំណែករឿងកាលវេលា កន្លែងកើតនៃសាសនា អាចលើកកាត់ចោល មិនបាច់យកមកប្រៀបធៀបក៏បាន។ (ហេង គឹមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៤)

២-គោលប្រៀបធៀបរវាងសាសនា ២សម័យ ៖

**សាសនាសម័យបុរាណ**

សាសនាបុរាណ (Premitive Relegions ឬ Dead Religions) កើតអំពីសទ្ធារបស់មនុស្សដែលមិន បានរៀនសូត្រចេះដឹង មិនបាននៅលើហេតុផល កើតការភ័យខ្លាច សទ្ធាកើតឡើងគ្រោះការមិនដឹង និងការភ័យខ្លាចនោះ សទ្ធានោះសម្តែងចេញដោយលក្ខណៈ (រូប) ៖

ក-សទ្ធាក្នុងអំណាចរបស់ធម្មជាតិ

ខ-សទ្ធាក្នុងអំណាចរបស់វិញ្ញាណ

គ-សទ្ធាក្នុងអំណាចរបស់ខ្មោចបិសាចទេវតា

ឃ-សទ្ធាក្នុងអំណាចរបស់ព្រះជាម្ចាស់

**សាសនាសម័យបច្ចុប្បន្ន**

សាសនាបច្ចុប្បន្ន (Living Religion) (ផ្នែកធំ) ជាសទ្ធារបស់អ្នកបានរៀនចេះដឹង តាមលក្ខណៈរបស់អ្នកចម្រើនឋានៈនៃសទ្ធាកើតឡើងដោយលក្ខណៈ (រូប) ៖

ក-ប្រាសចាកពីនិទាន មានតែការពិត។

ខ-ប្រាសចាកទេវសាស្ត្រ មានតែវិទ្យាសាស្ត្រ (ឬធម្មសាស្ត្រ)។

គ-ប្រាសចាកព្រះជាម្ចាស់ មានតែខ្លួនឯង។

ឃ-ប្រាសចាកការគិតសន្មត់ មានតែហេតុផល។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័៥)

៣-គោលប្រៀនធៀបរវាងសាសនា ទេវនិយម និងអទេវនិយម

សាសនាពហុទេវនិយម (Deism) ជាសទ្ធាជឿថា មានព្រះជាម្ចាស់ជាច្រើនអង្គ (Poly Theism) ស្ថិតនៅក្នុងរបស់សព្វសារពើ តែព្រះជាម្ចាស់ទាំងនោះមិនមានអំណាចក្នុងការសាងលោក សទ្ធាប្រភេទនេះ ហៅម្យ៉ាងទៀតថា ធម្មជាតិទេវនិយម។

សាសនាទេវនិយម (Theism) ជាសទ្ធាជឿថាមានព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់តែមួយអង្គ (Mono Thism) ស្ថិតនៅជាគូនឹងលោក ព្រះជាម្ចាស់នោះទ្រង់មានអំណាចសាងលោក។

សទ្ធាទាំងផ្នែកដែលជាពហុទេវនិយមនិងទេវនិយម ជាសទ្ធាមកអំពីទេវវិទ្យា (Theolo-gy) ជាសទ្ធារបស់ពពួកជនជាតិ សេមិទិគ (Semitic Race) មិនទាក់ទងដោយច្បាប់ធម្មជាតិ (Law of Nature) ឬច្បាប់នៃការធ្វើ (Law of Karma)។

សាសនាផ្នែកនេះករូបឡើងជាសាសនាជ្វិហ្វ (យូដា) ជាមូលដ្ឋានរបស់សាសនា គ្រិស្ត និងសាសនាអ៊ិស្លាម។

សាសនាអទេវនិយម (Atheism) ជាសទ្ធាជឿច្បាប់នៃធម្មជាតិ (Law of Nature) ឬច្បាប់នៃការធ្វើរបស់បុគ្គលម្នាក់ៗ (Law of Karma) ឬច្បាប់នៃហេតុផល (Subject and Object)។ លោកសាងឡើងស្ថិតនៅនិងរលាយទៅតាមច្បាប់ទាំងនោះ ជាសទ្ធារបស់ជនជាតិអារ្យកៈមួយក្រុម ក្នុងទីនេះបានដល់សាសនាជេន (ជែនៈ) និងសាសនាពុទ្ធជាដើម។

(កំណត់សម្គាល់ ៖ សាសនាព្រាហ្មណ៍ (ហិណ្ឌូ) របស់ជនជាតិអរិយកៈ ដែលជាឫសគល់របស់សាសនាជេន និងពុទ្ធសាសនា, សាសនាតៅ សាសនាខុងជឺរបស់ចិន និងសាសនាជិន្តោរបស់ជប៉ុន ប្រសិនបើសម្តែងដោយធម្មាធិដ្ឋាន គួរនឹងរួមនៅក្នុងក្រុមនេះ)។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័៦)

៤-គោលប្រៀបធៀបគតិការសាង និងការរលាយនៃលោក

សាសនាក្រុមពហុទេវនិយម ឬធម្មជាតិទេវនិយម ពុំមានសទ្ធារឿងការសាងលោក សាងជីវិត លោកកើតយ៉ាងណា ជីវិតកើតយ៉ាងណាក៏មិនដឹង ដឹងត្រឹមតែធម្មជាតិគ្រប់យ៉ាងមានព្រះជាម្ចាស់នៅប្រចាំ។

សាសនាក្រុមទេវនិយម ៖ គតិ (សាសនាជ្វិហ្វ) មានសេចក្តីថា បឋមកាលលោកមានតែភាពងងឹត ព្រះជាម្ចាស់ (យេះហូវ៉ា) ទ្រង់មានមហិទ្ធិឫទ្ធិ ទ្រង់មានអំណាចខ្ពង់ខ្ពស់ ទ្រង់ជាអ្នកសាងសព្វសារពើ និងសព្វសត្វក្នុងលោក។ ថ្ងៃដំបូងទ្រង់សាងពន្លឺ ដើម្បីបំផ្លាញងងឹត ។ល។ ថ្ងៃទី៦ ទ្រង់សាងមនុស្សឱ្យជាម្ចាស់របស់ភោគផលនិងសត្វ ដែលទ្រង់សាងទុកហើយ ។ល។ មនុស្សទ្រង់សាងដំបូងឈ្មោះ “អាដាម” ជាប្រុស និងទ្រង់សាងមនុស្សស្រី ឈ្មោះ “អេវ៉ា” ឬ“អ៊ិហ្វ” មានកូនពូនជាចៅពេញសាកលលោក។ ពេលកន្លងមកប្រមាណ ៣២ជំណមនុស្ស “រយៈនីមួយៗ ១០០ឆ្នាំ” ព្រះជាម្ចាស់ទ្រង់ទតឃើញថា មនុស្សទាំងឡាយ មិនជឿស្តាប់ មិនប្រតិបត្តិតាមបញ្ញត្តិ មានបាប ទើបទ្រង់បណ្តាលឱ្យភ្លៀងធ្លាក់ ភ្លើងឆេះ លាងមនុស្ស លាងលោកចេញម្តង សល់តែមនុស្សនិងសត្វមានធម៌។ លុះពេលទឹកលិច លោកស្រកស្ងួតចុះ ទ្រង់ក៏សាងលោកតទៅទៀត ដោយន័យនេះហើយ (សាសនាគ្រិស្ត និងសាសនាអ៊ិស្លាមមានគតិប្រហាក់ប្រហែលគ្នា ដែលសម្តែងឱ្យឃើញការសម្ព័ន្ធគ្នានៃក្រុមសាសនានេះ និងពោលតទៅខាងមុខ)។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃ សាសនាប្រៀបធៀប ទំព័រ៧)

សាសនាក្រុមអទេវនិយម មានសទ្ធាមកអំពីច្បាប់ធម្មជាតិ និងច្បាប់របស់កម្មបដិសេធគតិរឿងលោក និងការសម្ព័ន្ធជាមួយព្រះជាម្ចាស់។ អ្នកសាងលោកនេះ គឺកំណត់ដល់ធាតុ (Supreme Elements) ដែលមាននៅគូគ្នាជាមួយនឹងលោក (ដី ទឹក ខ្យល់ ភ្លើង អាកាស) ធ្វើចលនាផ្សំប្លែកៗគ្នាដោយកម្លាំងស្រូបធក់ឬពលំ (កម្មអំពើធ្វើ) របស់ធម្មជាតិ ឬធាតុនោះៗ ករូបរបស់សព្វសារពើនិងសព្វសត្វតូចធំកើតឡើង មកក្នុងលោកដោយលក្ខណៈផ្សេងៗគ្នា តាមផលនៃកម្លាំងនោះរហូតដល់ទីបំផុតធាតុគូគ្នានោះ ទៅជាធម្មជាតិ

មានសមភាពស្ថិតស្ថេរ លោកទើបទ្រទ្រង់នៅបាន តែលោកនឹងរលាយទៅជួបនឹងសម័យកាលបើជាតុគូនៃធម្មជាតិ មានសមភាពនោះ នឹងពុំមានឡើយ (អគ្គញ្ញសូត្រទីឃនិកាយ)។

គតិសទ្ធាក្នុងសាសនាព្រាហ្មណ៍(ហិណ្ឌូ)សូម្បីមានបញ្ញត្តិក្នុងគម្ពីរព្រះវេទថា មានព្រះព្រហ្មជាអ្នកសាង ព្រះវិស្ណុជាអ្នករក្សា និងមានព្រះសិវៈជាអ្នកបំផ្លាញ បើតាមការអធិប្បាយនោះជាបុគ្គលាធិដ្ឋាន តែដើម្បីសម្តែងគោលធម្មាធិដ្ឋានឱ្យឃើញថាលោកមានសភាពកើតឡើង (ឧបាទិ) មានសភាពតាំងនៅ (ឋិត) និង ភាពរលាយទៅ (ភង្គៈ) តាមច្បាប់នៃធម្មជាតិ ឬច្បាប់នៃកម្ម (Law of Karma) ប៉ុណ្ណោះ។

៥-គោលប្រៀបធៀបសទ្ធា ដែលសម្តែងដល់ឋានៈរបស់មនុស្ស

មនុស្សក្រុមពហុទេវនិយម ឬធម្មជាតិទេវនិយម មានសទ្ធាត្រឹមតែថាឋានៈរបស់ខ្លួនស្រេចនៅលើព្រះជាម្ចាស់ ដែលស្ថិតនៅក្នុងធម្មជាតិ និងសព្វសារពើជុំវិញខ្លួនឯង។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៨)

មនុស្សក្រុមទេវនិយម មានសទ្ធាថា ឋានៈដែលជាមនុស្ស (Human status) ត្រូវឡើងឆ្ពោះទៅអ្នកសាង (ព្រះជាម្ចាស់) បដិសេធសមត្ថភាពរបស់មនុស្ស ជីវិតស្រេចតែព្រះជាម្ចាស់ទ្រង់សាងមក (លិខិត) មនុស្សត្រូវជឿតាមបញ្ញត្តិព្រះជាម្ចាស់ ប្រតិបត្តិខ្លួនទៅតាមដែលទ្រង់ព្រះមេត្តា (ឱ្យមកកើតនិងមានជីវិតរស់នៅ)។

មានសទ្ធាថា មនុស្សទាំងឡាយមានបាបជាប់មកពីកំណើត ដែលទាក់ទងមកអំពីបានមនុស្សស្រីប្រុស គូដំបូងបានធ្វើមក (Origin of Sin) បាបកម្មនោះជាប់តរៀងមកដូច្នេះ។ មនុស្សគួរប្រព្រឹត្តខ្លួនឱ្យត្រូវនឹងទឹកព្រះទ័យរបស់ព្រះជាម្ចាស់ ដោយការប្រតិបត្តិតាមចរិយាធម៌ក្នុងសង្គម ជាអាទិ៍មានសេចក្តីស្រឡាញ់ មានការខ្លាច ស្រឡាញ់អ្នកកូមិផងរបងជាមួយស្រឡាញ់សត្រូវ។ល។

(កំណត់សម្គាល់ = រឿងបាបជាប់ខ្លួនមកពីកំណើត សេន្តប៉ូល (st. Paul) សាវ័កសំខាន់របស់យេស៊ូម្នាក់ អធិប្បាយថា មនុស្សមានការទន់ខ្សោយជាប់ជាមួយខ្លួនមក តាំងពីកំណើត ការទន់ខ្សោយនេះ បានដល់ការគ្មានសមត្ថភាព ទ្រទ្រង់ជីវិតខ្លួនឯងបាន ដោយហេតុនេះ (ក្នុងសាសនាគ្រិស្ត) ទើបមានធ្វើពិធីសីលជ្រមុជទឹក (Baptism) ជាមុន។ មានសេចក្តីអធិប្បាយថា សីលជ្រមុជទឹក ជាពិធីលាងបាបឱ្យអស់អំពីខ្លួនមនុស្ស គឺ លាងការទប់ខ្សោយ ការសៅហ្មង និងការគ្មានសមត្ថភាពឱ្យអស់ទៅ។ មួយទៀតការដែលមនុស្សទទួលសីល ជ្រមុជទឹក ដោយ

វិធីមុជក្បាលទៅក្នុងទឹកនោះ មានន័យព្រមទទួលខ្លួនថាជាមនុស្សល្ងង់ ជាអ្នកទន់ខ្សោយ ត្រូវលាងបំផ្លាញការល្ងង់ខ្លៅ និងការទន់ខ្សោយហើយនិងសេចក្ដីអាក្រក់កំណាចដទៃៗឱ្យសាបសូន្យទៅ។ ការដែលក្បាលផុះចេញមកពីទឹក ប្រហែលគ្នានឹងការជម្រះសេចក្ដីសៅហ្មងទាំងពួងឬស្មើនឹងការកើតថ្មីដែរ តអំពីនេះទៅត្រូវកាន់ថា សភាពរបស់ចិត្តជាប់ទន់ខ្សោយសៅហ្មង មិនក្លឹថាដោយអំណាចបិសាច អារក្សសាតាំងទាំងឡាយ បានបាត់បង់ជ្រះស្រឡះហើយ)។ (ហេង គីមហោ សាសនាប្រៀបធៀប, កាគួរមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៩)

មានសទ្ធាថា បានជាប់ខ្លួនមកក្ដី បាបធ្វើនៅពេលក្រោយក្ដី មានពិធីកម្មអាចលាងជម្រះចេញបាន ដោយព្រះករុណារបស់ព្រះជាម្ចាស់ (God’s Grace) ដោយព្រះករុណានៃព្រះដែលទ្រង់មានចំពោះមនុស្ស។

មានសទ្ធាថា ជីវិតនេះមានតែម្ដង ដួងវិញ្ញាណដែលមានបាប នឹងត្រូវវិនាសទៅ ដួងវិញ្ញាណប្រាសចាក ពីបាបនឹងទៅកាន់ឋានសួគ៌ នៅជាមួយព្រះជាម្ចាស់ជានិរន្តរ៍។

មានសទ្ធាថា អ្នកប្រតិបត្តិដូចពោលមកហើយ នឹងសម្រេចដល់នូវសេចក្ដីសុខ ដ៏កំពូលក្នុងជីវិត គឺបានទៅនៅក្នុងអាណាចក្ររបស់ព្រះជាម្ចាស់ (Kingdom of god) ។ល។

ឋានៈរបស់មនុស្សក្នុងសាសនាក្រុមនេះ មាននាទីប្រតិបត្តិចំពោះព្រះជាម្ចាស់ ក្នុងឋានៈជាបុត្ររបស់ព្រះ និងសាងខ្លួនឱ្យមានឋានៈជាមនុស្សក្នុងឧត្ដមគតិ (តាមបញ្ញត្តិរបស់ព្រះ) នៅក្នុងសង្គមនៃលោក។

មនុស្សក្រុមអទេវនិយម មានសទ្ធាថា ឋានៈនៃការជាមនុស្ស (Human status) ឡើងធ្លាក់ទៅកម្ម គឺអំពើដែលខ្លួនឯងធ្វើ ការធ្វើក្នុងអតីត (ជាតិមុនឬថ្ងៃមុន) អាចមានកម្លាំងឱ្យផលក្នុងបច្ចុប្បន្ននិងអនាគត តាមលំដាប់ហេតុផលនៃអំពើធ្វើនោះទាក់ទងគ្នារហូតទៅ (កម្មស្សកតា សទ្ធា និង វិបាកសទ្ធា)។ (ហេង គីមហោ សាសនាប្រៀបធៀប, កាគួរមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១០)

មានសទ្ធាថា កម្មជាគ្រឿងសាងលោក សាងរបស់សព្វសារពើ និងសព្វសត្វ កម្មជាគ្រឿងដែលចែកឋានៈ ប្រភេទ លក្ខណៈរបស់មនុស្ស និងសត្វឱ្យមានការបែកផ្សេងគ្នា (កម្មំ សត្តេ វិភជតិ)។

មានសទ្ធាថា ឋានៈរបស់យើង ជាទាសរបស់កម្ម ដែលយើងធ្វើទុកខ្លួនឯង យើងមិនអាចគេចវេះពីទាសកម្មបានទេ (កម្មលិខិត) យើងជាខ្លួនរបស់យើង សាងខ្លួនយើងដោយ

អំពើធ្វើរបស់យើង យើងធ្វើកម្មណាមកហើយ នឹងបានទទួលផលនៃកម្មនោះ យើងជាទីពឹងរបស់យើងមិនមែនអ្នកដទៃទេ។

មានសទ្ធាថា ជីវិតកើតមក និងប្រព្រឹត្តទៅតាមអំណាចរបស់កម្មជាច្រើនលើកច្រើនគ្រា កាលអស់ជីវិត ហើយកម្មនឹងបញ្ជូនផលឱ្យកើតថ្មី កើតនិងស្លាប់ជាប្រវ៉ាក់ចងភ្ជាប់ វិលវល់ទៅទំរាំទៅដល់ការសម្រេចនូវការសោបសូន្យនៃកិលេស (និព្វាន ឬ មោក្ស:)។

ឋានៈរបស់មនុស្សក្នុងក្រុមនេះ មាននាទីប្រតិបត្តិដើម្បីខ្លួន មានឋានៈជាទាសៈនៃអំពើធ្វើរបស់ខ្លួន និង សាងឋានៈរបស់ខ្លួនឱ្យជាមនុស្សក្នុងឧត្តមគតិ (តាមបញ្ញត្តិនៃកម្ម) ចេញទៅពីសង្គម និងចេញទៅពីលោក។

មនុស្សក្រុមអទេវនិយម (មង្គោល) មានសទ្ធា (ដូចដើម) ថា អ្នកជំ គឺឋានសួគ៌ (ឈៀងទី) ជាអ្នកសាងលោក និងសាងខ្លួនឯង ការសាងប្រកបដោយពលំធម្មជាតិគូ ២ យ៉ាងគឺ យ៉ាំង ជាពលំខាងបូក (Posotive Power) និង យិន ជាពលំខាងសង (Negative Power) ជាអាទិ៍ ធងឹតនិងភ្លឺ ស្រឡាញ់និងស្អប់ ក្ដៅនិងត្រជាក់ ល្អនិងអាក្រក់ មានស្រីមានប្រុស ជាធាតុនៅគូនឹងលោក និយាយដោយសរុប គឺលោកធាតុ (Elements of The World) ធម្មជាតិដែលជាគូ មាននៅប្រចាំលោក។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១១)

មានសទ្ធាថា អ្នកធំឋានសួគ៌ ជាអ្នកសាងលោកនិងសាងមនុស្សឡើងជាបុព្វបុរសគួរក្រាបសំពះបូជា និង គួរលះបង់សាច់ឈាមជាពលី។ យ៉ាំង និង យិន (ធម្មជាតិគូ) ជាបឋមបុព្វបុរស ឪពុកម្ដាយជាបុព្វបុរសបន្ទាប់ ចុះមកដោយលំដាប់ ការបូជាបុព្វបុរស (ឪពុកម្ដាយ) ស្មើនឹងការបូជាសួគ៌ផងដែរ។

មានសទ្ធាថា ដួងវិញ្ញាណកាលណាលះបង់រាងកាយទៅហើយ បើមិនវិនាសគ្រោះការធ្វើបាបអាក្រក់ជាឯកភាព (Unty) គឺភាពតែមួយជាមួយគ្នានិងសួគ៌ (ឬធម្មជាតិ តាមពាក្យអធិប្បាយរបស់តៅ) ជាអមតៈ (តាមការគ្នាន់គ្នេរប្រហែលនឹងគតិបរមាត្មន័របស់ព្រាហ្មណ៍) ក្នុងសាសនាជិន្តោ ការស្លាប់ប្រហែលគ្នានឹងផ្លាស់ប្ដូរគ្រឿងតែងខ្លួនថ្មី ដួងវិញ្ញាណបើមិនវិនាសទេ ទៅជាទេព្ដា។

(ក្នុងសាសនាជិន្តោ សម្ដែងលក្ខណៈធាតុគូ អ្នកសាង ជាទេព្ដាប្រុសស្រី ២ អង្គគឺ ទេពឥសានាគិ និង ទេពីឥសានាមិ ប្រៀបធៀបប្រហែលគ្នា យ៉ាំង និង យិន។

៦-គោលការណ៍ប្រៀបធៀបជីវិតសាសា្ដ ឧបនិស្ស័យ និងការប្រតិបត្តិ។

ខគួរឱ្យប្រៀបធៀប គឺគួរយកជីវិតរបស់សាស្ដា អ្នកតាំងសាសនាធំៗ ដែលផ្សព្វផ្សាយនៅក្នុងសង្គម បច្ចុប្បន្នប៉ុណ្ណោះ អាចល្មមគ្រប់គ្រាន់ដល់សេចក្ដីត្រូវការក្នុង ការសិក្សាសាសនាប្រៀបធៀប។

ក-ជីវិតរបស់មោសេស សាស្ដានៃសាសនាជ្វីហ្វ កើតក្នុងត្រកូលអ្នកស្រុកសាមញ្ញ ទទួលទុក្ខលំបាកស្ទើរស្លាប់តាំងពីតូច មានបុណ្យបន្តិចបានទៅជាឱរសចិញ្ចឹមនៃធីតាក្សត្រិយ៍អេហ្ស៊ីប បានសិក្សាល្អ មានរាងកាយ ចិត្តរឹងប៉ឹង មាន: ក្លាហាន ដែលកើតអំពីឈាម ការតស៊ូរូបរស់ជីវិតឪពុកម្ដាយបានផ្សងសំណាងក្នុងសម័យជនជាតិជ្វីហ្វធ្លាក់ជាទាសភាពរបស់អេហ្ស៊ីប។

ឧបនិស្ស័យមាន មាន: អត់ធន់ បំណងយកជ័យជម្នះជីវិត យកឈ្នះសត្រូវ ព្រមលះបង់ជីវិត ដើម្បីជ័យជម្នះនៃផៅពង្ស និងវង្សត្រកូល ពេលមានភ័យ មានធម៌ជាមេដឹកនាំទីបំផុតបានជ័យជម្នះ នាំបងប្អូនជាតិជ្វីហ្វ រត់គេចពីទាសៈរបស់អេហ្ស៊ីបទៅបាន។

ការប្រតិបត្តិ សមជាអ្នកសាង និងជាមេដឹកនាំគ្រប់គ្រង សេចក្ដីពិតឃើញថា សទ្ធា (សាសនា) ជាឫសគល់នៃចិត្តមនុស្ស ពពួកមនុស្សដូចជាដើមឈើធំ គួរមានឫសចងភ្ជាប់គ្នាឱ្យណែន ដើម្បីដើមនៃឈើនោះ ខនេះយ៉ាងណាមិញ សទ្ធា (សាសនា) ប្រសិនបើបែកបាក់គ្នាទៅម្នាក់ម្យ៉ាងឬក៏ពីរយ៉ាង ត្រូវមានព្រះម្នាក់មួយអង្គឬពីរអង្គ តាមការពេញចិត្ត ពួកមនុស្សបែកបាក់គ្នាទៅម្នាក់ម្យ៉ាង ឬក៏ពីរយ៉ាង ត្រូវមានព្រះម្នាក់មួយអង្គ ឬពីរអង្គ តាមការពេញចិត្ត ពួកមនុស្សបែកបាក់គ្នាបាន ពួកមនុស្សក៏គួរមានសទ្ធាដូចគ្នាដែរ។

សទ្ធា (សាសនា) ដែលបុគ្គលរាប់អានមិនត្រូវផ្លូវ អាចញុំាងសេចក្ដីសាមគ្គីនៃពួកគណៈឱ្យបែកបាក់ បើរាប់អានត្រូវផ្លូវ នឹងញុំាងសេចក្ដីសាមគ្គីរឹងមាំ បានដល់ពួកគណៈមេដឹកនាំការគ្រប់គ្រងត្រូវយល់ និងប្រតិបត្តិដូចពោលមកនេះ។

មោសេស លះបង់អំពីពួកគណៈទៅទទួលទុក្ខលំបាកនៅលើភ្នំស៊ីណៃ រហូតបានទទួលបញ្ញត្តិ១០ប្រការ (Ten Commandment) ដែលព្រះជាម្ចាស់ប្រគល់ឱ្យជាគោលសាសនា (ព្រះជាម្ចាស់មួយអង្គ បញ្ញត្តិមួយក្រុម ផ្លូវតែមួយ) របស់ជនជាតិជ្វីហ្វរហូតដល់ទីបំផុតនៃជីវិត។ (ហេង គីមហោ សាសនាប្រៀបធៀប, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៣)

(កំណត់ហេតុ ៖ មោសេសជាអ្នកសាសនា ជាមេដឹកនាំគ្រប់គ្រង ជាអ្នកតស៊ូ ជាអ្នករំដោះជាតិឱ្យរួចផុត ពីទាសៈរបស់ជនជាតិដទៃ អ្នកដែលជាមេដឹកនាំគ្រប់គ្រងមនុស្ស និងជាអ្នករំដោះជាតិ ប្រសិនគ្មានធម៌ ជាអ្នកសាសនា (ជាគ្រឿងប្រកបដ៏សំខាន់) ទេនោះ ឃើញថា មិនអាចធ្វើការបានសម្រេចឡើយ)។

ខ-ជីវិតរបស់ឡៅ ជឺ អ្នកតាំងសាសនាតៅ កើតក្នុងត្រកូលអ្នកស្រែក្រខ្សត់ ខេត្តហូណាន ចិនភាគកណ្ដាល មានពួកគណៈនិងជីវិតជាសាលារៀន សិក្សាពីធម្មជាតិច្រើនជាងសិក្សាពីមនុស្ស ឆ្លាត គំនិតជ្រៅ ចូលចិត្តរិះគិតមកតាំងពីក្មេងធំឡើងទទួលការងារ ក្នុងក្រុមអាល័ក្ខណ៍រាជវាំង ជាអ្នកប្រាជ្ញប្រចាំរាជសំណាក់ មានជីវិតនៅតាមធម្មជាតិ មិនប្រាកដថាមានគ្រួសារ។

ឧបនិស្ស័យ ប្រាជ្ញាតិច សន្សំសំចៃ អាណិតមេត្តា ទន់ភ្លន់ មិនប្រកាន់ខ្លួន ស្រឡាញ់ធម្មជាតិ ស្រឡាញ់សេចក្ដីស្ងប់ ប្រើអំពើល្អប្រឆាំងនឹងអាក្រក់ ទីបំផុតនៃជីវិតចេញទៅរកសេចក្ដីស្ងប់ និងការគិតរបស់ធម្មជាតិ។

ប្រៀនប្រដៅមនុស្ស ដោយវិធីឱ្យទ្រទ្រង់ជីវិតតាមធម្មជាតិ មិនព្រមផ្លាស់ប្ដូរសង្គម យល់ថា មនុស្សធ្វើអំពើល្អ ធ្វើអំពើអាក្រក់ ធម្មជាតិជាអ្នកដាក់ទោស មិនចាំបាច់មានច្បាប់ (មើលសាសនាតៅ)។

គ-ជីវិតរបស់មហាវីរៈ អ្នកតាំងសាសនាជេន ឬ ជិនៈ (សូមទោសមិនបានប្រែប្រវត្តិសាស្ត្រារូបនេះទេ) កើតក្នុងរាជត្រកូល ខេត្តវិទេហៈ ដងទន្លេគង្គាភាគខាងជើងជម្ពូទ្វីប វង្សត្រកូលសម្ព័ន្ធនិងស្ដេចលិច្ឆវី មានបងប្អូនប្រុសស្រីម្នាងមួយ មានការសិក្សាតាមឋានៈក្សត្រិយ៍ កាន់ខ្ជាប់ក្នុងសាសនាហិណ្ឌូ រៀបការកាលអាយុបាន១៩ឆ្នាំ នៅគ្រប់គ្រងផ្ទះសម្បែងដល់អាយុ ២៨ឆ្នាំ គ្មានអ្នកបន្តវង្សត្រកូល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៨)

ព្រះនិស្ស័យ ជាអ្នកនិយាយតិច (ឬមិននិយាយសោះ) ក្លាហាន មានមត្តភាពបញ្ហាជំរឺចុះប្រេង បានទទួលនាមថា មហាវីរៈ ប្រែថា អ្នកក្លាហានណាស់ ចូលចិត្តការសិក្សាបញ្ញត្តិរបស់សាសនា ស្អប់វណ្ណៈអ្នកមានស័ក្តិខ្ពស់ ស្អប់មនុស្សមើលងាយមនុស្ស ចេញបួសព្រោះមរណកម្មនៃមាតាបិតា បំពេញទុក្ករកិរិយារហូតដល់បាត់បង់ជីវិត។

ការប្រតិបត្តិ ការលះបង់សម្បត្តិចេញបួស ប្រតិបត្តិខ្ជួនយ៉ាងតឹងរ៉ឹង បំពេញទុក្ករកិរិយា ជាអត្តកិលមថា នុយោគយ៉ាងខ្លាំង កាន់ខ្ជាប់ក្នុងការប្តេជ្ញា "ជាអ្នកស្ងៀមស្ងាត់" អស់ពេល ១២ឆ្នាំ។ មនុស្សទាំងឡាយឃើញថា ជាអ្នកបានសម្រេចជាអរហន្ត អ្នកដល់នូវមោក្ស: បដិសេធរឿងព្រះជាម្ចាស់របស់ព្រាហ្មណ៍ ទាញយកគោលបំពេញទុក្ករកិរិយា លះបាណាតិបាត ក្នុងសព្វសត្វ រុក្ខជាតិ និងតិណជាតិទាំងពួង។

ង-ជីវិតរបស់សិទ្ធត្ថ:គោតម អ្នកកតាំងពុទ្ធសាសនា ព្រះនាមដើមសិទ្ធារថ ឧប្បត្តិក្នុងត្រកូលក្សិយ៍សាក្យវង្ស ក្រុងកបិលពស្តុ ខេត្តមជ្ឈមប្រទេស ជម្ពូទ្វីបខាងជើង ព្រះមាតាអស់ព្រះជន្ម កាលអាយុបានត្រឹម តែ ៧ថ្ងៃ ព្រះមាតាមីងជាអ្នកចិញ្ចឹមថែរក្សារហូតធំឡើង។

ទ្រង់ទទួលការសិក្សាខ្ពង់ខ្ពស់ ដែលកូនក្សត្រិយ៍អាចទទួលបាន អភិសេកជាមួយម្ចាស់ក្សត្រិយ៍ក្នុងរាជត្រកូលនៃក្រុងវិទេហ: កាលនៅក្នុងយុវវ័យ ព្រះជន្មាយុត្រឹម ១៦ វស្សា។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៥)

ទ្រង់សេពសោយសុខសម្បត្តិ ក្នុងវិស័យឃរាវាសយ៉ាងឧក្រិដ្ឋ បានព្រះឱរសជាមួយព្រះជាយា ១ ព្រះអង្គ ទទួលតំណែងជាអង្គរជ្ជទាយាទ និងបានទទួលរាជសម្បត្តិពេល ខាងមុខ តែទ្រង់លះបង់ភេទឃរាវាស ស្តេចចេញទ្រង់ផ្នួសបំពេញព្រត ជួបជួនបានប្រទះ ព្រះធម៌ជាពុទ្ធ:។

ព្រះនិស្ស័យ ចូលចិត្តស្ងប់ ស្អប់ខ្ពើមការប្រហារ ទ្រង់មិននិយមការបែងចែកវណ្ណ:របស់មនុស្ស ទ្រង់មិនយល់ស្របតាមចរិយាធម៌ របស់ពួកក្សត្រិយ៍សាក្យ:ជាច្រើនយ៉ាង ទ្រង់មិនប្រកាន់ទិដ្ឋិមាន:ដូចជារាជវង្សទាំងឡាយ ទ្រង់នឿយណាយការក្រវល់ក្រវាយរបស់សង្គម មានព្រះទ័យបង្អោនទៅកាន់បព្វជ្ជាភេទ លះបង់សេចក្តីសុខផ្ទាល់ព្រះអង្គ ព្រះជាយា និងព្រះឱរស ស្តេចចេញផ្លាស់ភេទជាតាបស ស្វែងរកធម៌កាលព្រះជន្ម២៩ ព្រះវស្សា។

**ការប្រតិបត្តិ** (មើលវិធីប្រកាសសាសនា ខាងមុខ)។

ច-ជីវិតរបស់ខុងជឺ អ្នកតាំងសាសនាខុងជឺ កើតក្នុងត្រកូលទាហានទីទាល់ក្រ ក្នុងខេត្តធានទុង ចិនភាគខាងជើង ឪពុកម្តាយមានកូនប្រុសតែមួយ ឪពុកស្លាប់តាំងពីក្មេង ត្រូវធ្វើការធ្ងន់ធ្ងរ រៀនអក្សរពេលអាយុច្រើនហើយ រកស៊ីចិញ្ចឹមមាតាដោយរៀនផងធ្វើការផង បានរៀបការនឹងស្រីត្រកូលម្នាក់ មានកូនប្រុសម្នាក់ រៀបការមិនបានយូរប៉ុន្មាន មាតាក៏អស់ជីវិតទៅទៀត។

មិនបានធ្វើជាទាហានដូចជាឪពុក ទទួលធ្វើការរាជការផ្នែកស៊ីវិល មាននាទីយកពន្ធស្រូវ គ្រួសារមិនសូវស្រុះស្រួលគ្នា ព្រោះមាននិស្ស័យទោរទន់ទៅរកការសិក្សាច្រើនជាងលោកិយ៍។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៦)

ឧបនិស្ស័យ ចូលចិត្តសិក្សា ក្លាយទៅជាអ្នកដឹកនាំពិធីការ និងចរិតក្លាយជាគ្រូអាចារ្យមានសិស្សគណជាច្រើន ធ្វើការរាជការ បានមើលឃើញសេចក្ដីខុសឆ្គង របៀបគ្រប់គ្រងឃើញមានការកេងប្រវ័ញ្ចសព្វបែបយ៉ាង កើតមានសេចក្ដីទៀយណាយក្នុងសង្គម តែមានបំណងចង់កែប្រែសង្គម មិនយល់ស្របតាមការដំណើរ ជីវិតបែបឡាជឺ។

ការប្រតិបត្តិ ការងាររបស់ខុងជឺ គឺកែប្រែសង្គម ដាក់គោលការណ៍សម្ពន្ធ ៥ប្រការតាមនាទីដែលបុគ្គល គប្បីប្រតិបត្តិតៗគ្នា គឺនាទីរវាងអ្នកគ្រប់គ្រងនិងពលរដ្ឋ, បិតាមាតានិងបុត្រធីតា, ស្វាមីនិងភរិយា, អ្នកអាយុ ចាស់និងក្មេង ហើយមិត្តនិងមិត្ត។

ខុងជឺ ដាក់គោលប្រតិបត្តិ ដោយទាញយកការសម្ពន្ធ ដើម្បីសេចក្ដីចម្រើនក្នុងសង្គម ឫសគល់នៃអាណា ចក្រ គឺរដ្ឋ ឫសគល់របស់រដ្ឋ គឺគ្រួសារ ឫសគល់របស់គ្រួសារ គឺខ្លួនឯង (សូមមើល សាសនាខុងជឺ)។

ធ-ជីវិតរបស់ព្រះយេស៊ូ អ្នកតាំងសាសនាគ្រិស្ត កើតក្នុងត្រកូលជាងឈើ សម័យស្រុកទេសច្របូកច្របល់ ក្សត្រិយ៍នៃជ្វិហ្វគ្រប់គ្រងដោយទារុណកម្ម ជ្វិហ្វមួយភាគត្រូវខ្ចាត់ព្រាត់ទៅនៅប្រទេសអេហ្ស៊ីប ត្រឡប់ទៅជាជួបទារុណកម្មក្នុងអេហ្ស៊ីបទៀត ទទួលការសិក្សាតាមរបៀបអ្នករត់គេចពីភ័យ ជួបពេលសម័យជ្វិហ្វធ្លាក់នៅក្រោមការគ្រប់គ្រងរបស់រ៉ូម (មើលសាសនាជ្វិហ្វ)។

ឧបនិស្ស័យ ជាអ្នកទន់ភ្លន់ មិនប្រកាន់ខ្លួន ស្រគត់ស្រគំ (លក្ខណៈដូចមនុស្សទន់ខ្សោយ) ស្រឡាញ់ក្មេង ស្រឡាញ់អ្នកកូមិផងរបងជាមួយ កតញ្ញូមេត្តា អត់ឱនទោសដល់មនុស្សមិនរើសមុខ មិនយល់ស្របនឹងការគ្រប់គ្រងរបស់ក្រុងរ៉ូម ស្អប់ខ្ពើមអំពើទារុណកម្មតាំងចិត្តផ្លាស់ប្ដូរពាក្យប្រដៅដើម ត្រូវការយកសាសនា មានគោលមេត្តាជាដើម ជាគោលនៃការគ្រប់គ្រង មានបំណងធ្វើគ្រប់បែបយ៉ាងឱ្យជនជាតិជ្វិហ្វរួចផុតពីទារុណកម្មរបស់ក្រុងរ៉ូម ដោយវិធីរបស់សាសនា គឺការប្រើធម៌ជាអាវុធ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៧)

**ការប្រតិបត្តិ** (មើលវិធីប្រកាសសាសនាខាងមុខ)

ជ-ជីវិតព្រះមហៈហ្ម៉ត់ អ្នកតាំងសាសនាអ៊ិស្លាម កើតក្នុងត្រកូលអ្នកជំនួញ កណ្ដាលទន្លេខ្សាច់ជ្រោយអារ៉ាប់ សម័យជណ្ដើមគ្នាធ្វើធំ ក្នុងត្រកូលអារ៉ាប់ជាច្រើនត្រកូល អ្នកមានប្រាក់ច្រើន អ្នកណារួបរួមមនុស្សបាន អ្នកនោះនឹងទៅជាអ្នកធំជាងអ្នកដទៃ។

ដំណើរជីវិតលក់ដូរតាមវង្សត្រកូល មិនបានរៀនសូត្រ តែបានសិក្សាដឹងលោកនិងជីវិតរបស់មនុស្សអំពីការដែលត្រាច់ចរលក់ដូរក្នុងភូមិដ្ឋានផ្សេងៗ។

ឧបនិស្ស័យ ទន់ភ្លន់ តែម៉ឺងម៉ាត់ ដាច់ខាត មានប្រាថ្នាធំ តស៊ូតាមរបៀបទាហាន (ផ្ទុយគ្នានឹងព្រះយេស៊ូ) ដឹងហេតុនៃការជណ្ដើមយល់ឈ្នះក្នុងសង្គម និងដឹងហេតុថា ការបំបែកសាសនាជាហេតុនៃការបំបែកសង្គមផងដែរ (មើលចរិយារបស់សាស្ដារូបនេះ ក្នុងគោល "ចរិយាធម៌អ៊ិស្លាម" ដូចពោលមកហើយ)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៨)

**វិធីប្រតិបត្តិ** (មើលការប្រកាសសាសនាខាងមុខ)

ឈ-ជីវិតរបស់នាទ័កសាស្ដានៃសាសនាសិក្ខ កើតក្នុងត្រកូលហិណ្ឌូវណ្ណៈ ព្រាហ្មណ៍ អ្នកទីទាល់ក្រនៅភូមិទាល់វណ្ឌី ខាងទិសនិរតីក្រុងឡាហ៊័រ (ប៉ាគីស្ថាន) បិតាជាអ្នកបម្រើចៅហ្វាយក្រុង មាតាជាអ្នកកាន់សាសនាតឹងរឹងខ្ជាត់ មានបញ្ញាជជែកវែកញែកបញ្ហាសាសនាបានតាំងពីអាយុ ៧ឆ្នាំ បែកឈានក្នុងគម្ពីរព្រះវេទ រៀនចេះដឹងគោលសាសនាផ្សេងៗ រៀបការនឹងស្រីត្រកូលល្អភូមិជាមួយគ្នា មានកូន ២នាក់ ជីវិតគ្រួសារ មិនសូវបានសុខ ព្រោះនាទ័កតែងតែស្ងប់កិរិយាចូលចិត្តសប្បាយ ទីបំផុតរត់ចេញពីកូនប្រពន្ធទៅរកសេចក្ដីស្ងប់នៅក្នុងព្រៃ កាលអាយុ ៣៦ឆ្នាំ។

ឧបនិស្ស័យ ចូលចិត្តស្ងប់ មេត្តា ចូលចិត្តកែប្រែផ្លាស់ប្ដូរ គោលសាសនាដែលធ្វើឱ្យពិបាកយល់ ចូលចិត្ត ពុះពារឧបសគ្គ បង្រៀនមនុស្សឱ្យយល់ត្រូវ។

ការប្រតិបត្តិមិនព្រមសម្ដែងថា សាសនាណាល្អជាងសាសនាណាទេ ហិណ្ឌូឬអ៊ិស្លាមល្អស្មើគ្នា ប្រដៅឱ្យមនុស្ស ២សាសនាឈ្លោះវិវាទគ្នា ឱ្យសាមគ្គីគ្នា មិនព្រមប្រកាសខ្លួនជាសាសនិករបស់សាសនាណា ចូលចិត្ត ពោលថាខ្លួនជាសិក្ខគឺអ្នកសិក្សា។

ចេញធ្វើដំណើរប្រៀនប្រដៅយ៉ាងទូលំទូលាយ រហូតទៅដល់ជ្រោយអារ៉ាប់ ត្រូវពុះពារឧបសគ្គ ធ្លាប់ត្រូវប្រទូស្ដរ៉ាយ ធ្លាប់បានទទួលទោសពីអ្នកមានអំណាច។

៧-គោលការណ៍ប្រៀបធៀបសង្គម ក្នុងសម័យរបស់សាស្ដា

កំណត់សម្គាល់ដំបូង ៖ ការប្រៀបធៀបភាវៈក្នុងសង្គម ក្នុងសម័យរបស់សាស្ដានោះៗ កំណត់យកសាស្ដារបស់សាសនា ដែលនៅមានអ្នកកាន់អាន (Living Religions) តាមគោលការណ៍ដូចពោលមកហើយ ក្នុងរឿងជីវិតរបស់សាស្ដា។ល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ១៩)

ការកត់សម្គាល់តទៅ ៖ ការចាំបាច់ក្នុងការប្រៀបធៀបភាវៈនៃសង្គមក្នុងសម័យរបស់សាស្ដាទីមួយៗ ដើម្បីសម្ដែងឱ្យឃើញថាសាសនាទាំងឡាយដែលកើតឡើង ករូបរាងឡើងពីរបស់ព័ទ្ធជុំវិញ គឺមានការប្រព្រឹត្តទៅខាងភូមិសាស្ត្រនិងសង្គមជាដើមផ្សេងៗគ្នា សាសនាទើបមានរូបផ្សេងគ្នា បំបែកមនុស្សជាប្រភេទនិងមានឋានៈ (Human status) មិន ដូចគ្នាទាំងចំណុចតាំងរបស់សាសនានោះៗ គឺភាគធំដូចគ្នា។

រូបរបស់សាសនា កើតឡើងព្រោះអាស្រ័យការបែកផ្សេងគ្នានៃភូមិសាស្ត្រ និងសង្គមដែលហ៊ុំព័ទ្ធជុំវិញ (ជីវិតសាស្ដាអ្នកតាំងសាសនា) មានរូបដូចតទៅនេះ។

**ក-សង្គមជ្វីហ្វសម័យមោសេស**

ក-ជ្វីហ្វធ្លាក់ជាទាសៈរបស់អេហ្ស៊ីប បានទទួលទារុណកម្មនៃការជាទាសៈនោះ ជនជាតិជ្វីហ្វខ្ចាត់ខ្ចាយ មិនមានទីតាំងនៅខ្ជាប់ខ្ជួនមាំមួន។

ខ-ជ្វីហ្វមិនមានទីពឹងពិតប្រាកដ នាំគ្នាទៅរកទីពឹងរៀងខ្លួនម្នាក់ៗមានសទ្ធាមាន របស់គោរពបែកខ្ញែកគ្នាចេញទៅតាមការយល់និងពុំមានអ្នកដឹកនាំល្អ។

គ-ល្មើសសិទ្ធិនិងសម្បត្តិរវាងគ្នានិងគ្នា។

ឃ-សម្លាប់គ្នាឯង អ្នកមានកម្លាំងខ្លាំង សម្លាប់អ្នកមានកម្លាំងខ្សោយ។

ង-ការគោរព ការទន់ភ្លន់ រវាងអ្នកធំនិងអ្នកតូចគ្មាន។

ច-នៅផ្សេងៗគ្នារៀងៗខ្លួន។ល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២០)

ហេតុសង្ខេបដូចពោលមកហើយ សាសនារបស់ជ្វីហ្វ ទើបចេញមកជារូបបញ្ញត្តិ ១០ ប្រការ (Ten Command Ments) មោសេសជាអ្នកប្រកាសបញ្ញត្តិ (សំអាងព្រះជាម្ចាស់) ត្រូវការហៅប្រមូលការខូចបង់ ៦ ប្រការ ដូចបានពោលមកពីខាងដើម ក្នុងពួកជនជាតិជ្វីហ្វ ឱ្យត្រឡប់មកវិញ។

### ១-សង្គមអ៊ីរ៉ង់ សម័យសោរោអស្សត្ទីរ៍

បរិវេណទីរាបខ្ពស់ តាមការស្មានទីកន្លែងគឺ ខេត្តអាស៊ីបៃយានទិសឦសាន ជិតខេត្ត ដែនរុស្ស៊ីភាគខ្លះក្នុងបច្ចុប្បន្នជាកន្លែងអន្តរាយដល់ជីវិតមនុស្សនិងសត្វ មនុស្សរកស៊ីធ្វើចម្ការ និងចិញ្ចឹមសត្វ មានផៅពង្សទូរេនៀន និងផៅពង្សអ្នកជិតខាងចូលមកដណ្តើមរបររកស៊ី។

សភាពនៃសង្គមភាគធំ ទីទាល់ក្រ អ្នកម្ចាស់ដីគាបសង្កត់អ្នកគ្មានដី មនុស្សនិងសត្វ ទទួលទុក្ខលំបាកខាងផ្លូវចិត្តពីមនុស្ស ខាងផ្លូវកាយនិងធម្មជាតិ។

សទ្ធាពីដើមរបស់សង្គមនេះ រាប់អានមហាទេព អាហុរមាសដា ថា ទ្រង់មានឋានៈជា កំពូលនៃចក្រវាល អ្នកណាប្រាថ្នារបស់ណាទ្រង់នឹងប្រទានរបស់នោះឱ្យ ពួកអ្នកព្រតធ្វើ ហេតុធំៗបានបញ្ញត្តិថា ការបូជា អាហុរ មាសដាត្រូវពលីដោយជីវិតសត្វចិញ្ចឹម បាយត្រី អាហារ បញ្ញត្តិរបស់អ្នកព្រតនេះក៏ក្លាយទៅជាគ្រឿងបំផ្លាញ ការរស់នៅរបស់សង្គម ដែល មិនមានទីពឹងហើយនោះ ឱ្យរឹងរិតតែទីទាល់ក្រណាស់ទៅទៀត។

ទីបំផុត សទ្ធារបស់បុគ្គលគ្រប់រូបធ្លាក់នៅក្នុងលក្ខណៈឈោងចាប់របស់ដែលអាច ចាប់បាន តែគ្រប់គ្រាដែលឈោងចាប់បាននោះ ពុំមានរបស់ណាមួយជាទីពឹងបានឡើយ ធម្ម ជាតិដែលកាចសាហាវក្តី ការអមនុស្សក្តី បានបន្ថែមពីលើទុក្ខវេទនានេះទ្វេឡើងទៀត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២១)

លក្ខណៈរបស់សង្គម ឃើញច្បាស់ពីការអង្វរករអាហុរមាសដា របស់សោរោអ- ស្សត្ទីរ៍ថា "នៅមានផែនដីឯណាទៀតឬ ដែលអាត្មាអញលបលាក់ខ្លួនពួននៅបាន។ល។ អាត្មាអញប្រតិបត្តិពុំបានផលណាមួយសោះឡើយ សត្វចិញ្ចឹមត្រឹម ២-៣ក្បាល មនុស្សត្រឹម ២-៣នាក់ប៉ុណ្ណោះដែលជារបស់ខ្ញុំ ខ្ញុំគួរប្រតិបត្តិយ៉ាងណា ខ្ញុំគួរនឹងបានទទួលរង្វាន់អំពីផល នៃអំពើដែលធ្វើយ៉ាងតិចក៏សេះញី ១០ក្បាល សេះឈ្មោល ១ក្បាល និងអូដ្ឋ ប្រហែល ១ ក្បាលដែរ។ល។

សោរោអស្សត្ទីរ៍ ព្យាយាមគេចវេះពីសង្គម ព្យាយាមបំផ្លាញសទ្ធាដែលញុំាងសង្គម សោរោអស្សត្ទីរ៍ឱ្យវិលច្របូកច្របល់ដូច្នោះ ក៏សម្រេចចិត្តប្រកាសសាសនា និងវិនិច្ឆ័យ បាន ថា នឹងប្រើសាសនារបស់ខ្លួនជាគ្រឿង អាវុធខាងផ្លូវនយោបាយផង។

### គ-សង្គមជនជាតិចិន សម័យឡៅ ជឺ និង ខុង ជឺ

សង្គមជនជាតិចិនក្នុងសម័យ ឡៅ ជឺ និង ខុង ជឺ កំណត់យកការប្រតិបត្តិទៅសម័យរាជវង្សជិវ ជា គោលអធិប្បាយនិងគួររួមក្នុងសម័យតែមួយជាមួយគ្នា។

សម័យនោះ ការគ្រប់គ្រងរបស់ចិន មានម្ចាស់អ្នកគ្រប់គ្រងនគរដល់ទៅ ១៨.០០០ នគរ ឡើងវត្តោះ មកក្រោមអំណាចនៃអ្នកបរិហារភាគកណ្ដាល រាជវង្សមានទីប្រឹក្សារបស់ក្សត្រិយ៍ដល់ទៅ ៦តំណែង គ្មានការងារធ្វើប្រចាំទេ ស្រេចតែក្សត្រិយ៍ប្រើអ្នកណា ធ្វើរបស់អ្វីតាមព្រះទ័យរបស់ទ្រង់ រាជការដែលសំខាន់មានការឃ្លាំង ការព្រះរាជវាំង ការសិក្សា ការកសិកម្ម ការពាណិជ្ជកម្ម ការទាហាន ការបណ្ដុះបណ្ដាល ធ្វើជាង ការកសាង និងការសែនព្រេនបូជាក្នុងពិធីកម្ម។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃ សាសនា ប្រៀបធៀប ទំព័រ២២)

ពិធីកម្មទាក់ទងនឹងសទ្ធា ការជឿកាន់សាសនាគឺ ការបូជាបុព្វបុរសជាគោលធំ បុព្វបុរសដែលធំជាងគេគឺ សួគ៌ រាជសំណាក់ប្រកបពិធីបូជាសួគ៌ខ្ជះខ្ជាយមានបែបផ្សេងៗ។ ក្សត្រិយ៍ជាឱរសរបស់សួគ៌បានទទួលការបូជាយ៉ាងមហោឡារិក ផ្ទុយនឹងរាស្ត្រសាមញ្ញដែលគ្មានទំនាក់ទំនងនឹងសួគ៌ ពិធីកម្មរបស់អ្នកស្រុកគឺ បូជាធម្មជាតិ ដែលឱ្យគុណ ឱ្យទោស និងបុព្វបុរសក្នុងគ្រួសារ ការស់នៅខ្ជះខ្ជាយទៅក្នុងរឿងពិធីកម្មនេះ។

មានរបៀបទទួលការរាជការ ដោយបន្តវង្សត្រកូល ជនសាមញ្ញអាចឡើងជាអ្នកធំបានយ៉ាងឆាប់រហ័ស ការចិញ្ចឹមជីវិត ធ្វើស្រែចម្ការ ប្រកាន់ថាដីធ្លីជារបស់ហ្លួង ហ្លួងជាអ្នកជួលឱ្យជារបបជម្រិតយកពន្ធ អ្នកស្រែចម្ការត្រូវតែទទួលយល់ព្រមពីអ្នករាជការថ្នាក់ធំ។

របបសង្គមដែលខ្លាំងក្លាបំផុតចំពោះរាស្ត្រ គឺរបបការដាក់ទោស មានទោសកាត់ស៊ក ត្រចៀក ដាក់ខ្នោះជើង ខ្នោះដៃ ដុតទាំងរស់ ផ្ចាញ់ផ្ចាលសព ប្រហារជីវិតដោយកាត់ជាកំណាត់ ជួនកាលមានការប្រហារទាំងគ្រួសារ។ល។

ឡៅ ជឺ ធ្វើការនៅក្នុងក្រុមព្រះអាលក្សណ៍ មើលឃើញការច្របូលច្របល់នៃសង្គមកើតការនឿយណាយ ឃើញថាការមានរបៀបរបស់សង្គមល្អបំផុតនោះ គឺប្រព្រឹត្តខ្លួនឱ្យត្រឡប់ទៅតាមសភាពដើមវិញ ឡៅ ជឺ មានគោលប្រតិបត្តិប្រចាំខ្លួន ៣ ប្រការ គឺ សេចក្ដីមេត្តា ការសន្សំសំចៃ និងការទន់ភ្លន់ មិនប្រកាន់ខ្លួន ជាគ្រឿងកែប្រែសង្គម ដែលខ្លួនបានប្រាថ្នាចង់ធ្វើ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៣)

តែដោយន័យផ្ទុយទៅវិញ ខុង ជឺ មិនព្រមគេចពីសង្គម ឃើញថាសង្គមគួរកែដោយច្បាប់ដែលមនុស្សត្រូវតាំងឡើង ដើម្បីកែមនុស្សនិងចាប់ផ្ដើមចាត់របបសង្គមដោយដាក់គោលការណ៍សម្ព័ន្ធទាំង ៥ (មើលពី ខាងដើម) ការធ្វើរបស់ឡៅ ជឺ មិនមែនជាផ្លូវសំរួចទៅបានឡើយ។

ឃ-សង្គមឥណ្ឌាសម័យមហាវីរៈ តាំងសាសនាជេន(ជិនៈ)និងសម័យសិទ្ធត្ថគោតមៈ អ្នកប្រកាសពុទ្ធសាសនា។

កំណត់សម្គាល់ ៖ សង្គមដែលគួរប្រៀបធៀបក្នុងគោលការណ៍នេះ គួររួមតែមួយជាមួយគ្នាបាន ព្រោះថាសង្គមរបស់ឥណ្ឌាក្នុងសម័យរបស់អ្នកប្រកាសសាសនាជេន និងអ្នកប្រកាសពុទ្ធសាសនានៅក្នុងសម័យជាមួយគ្នា។

មនុស្សក្នុងជម្ពូទ្វីប បែកចេញជា ៤ពួក ហៅថាវណ្ណៈ គឺក្សត្រិយ៍ ពួកអង្គម្ចាស់មានមុខ ងាររក្សាស្រុកទេស ព្រាហ្មណ៍ ពួកអ្នកសិក្សារៀនសូត្រ មានមុខងារជាអ្នកបង្ហាត់បង្ហាញបង្រៀន និងធ្វើពិធីពេស្ស ពួកអ្នករកស៊ី មានការងារលក់ដូរ សូទ្រ ពួកធ្វើការមានការងារស៊ីឈ្នួលធ្វើរបស់ផ្សេងៗ។ ក្សត្រិយ៍និងព្រាហ្មណ៍ចាត់ជាជាតិខ្ពស់ ពេស្សជាជនសាមញ្ញ សូទ្រជាជនទទន់ទាប។ល។ ពួកទាំងនោះដែលមានថ្នាក់ខ្ពស់ រមែងមានមានះប្រកាន់ខ្លួនដោយជាតិនិងត្រកូលរបស់ខ្លួន ពួកក្សត្រិយ៍និងពួកព្រាហ្មណ៍រមែងស្អប់ខ្ពើមពួកជាន់ទាបចុះមក មិនព្រមយកគ្នាជាប្ដីប្រពន្ធ មិនបរិភោគរួមគ្នា។ ព្រោះហេតុនោះ ពួកក្សត្រិយ៍ក្ដី ពួកព្រាហ្មណ៍ក្ដី ទើបទទួលយកគ្នាជាប្ដីប្រពន្ធ ក្នុងពួករបស់ខ្លួន ពួកមានត្រកូលខ្ពស់រមែងមានការស្អប់ខ្ពើមពួកមានត្រកូលទាបមិនព្រមយកអ្នក ដទៃក្រៅអំពីត្រកូលរបស់ពួកខ្លួននោះឡើយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៤)

វណ្ណៈ ៤ នេះ ជាពួកធំ ក្រៅពីនេះនៅមានទៀត តែជាពួកធម្មតាសាមញ្ញ កើតពីវណ្ណៈទាំង៤នេះ រៀបការនឹងវណ្ណៈដទៃ ក្រៅពីពួករបស់ខ្លួនដូចពួកព្រាហ្មណ៍បានជាមួយសូទ្រ មានកូនមកចាត់ជាពួកមួយទៀតហៅថាចណ្ឌាល ពួកមនុស្សកើតមកពីមាតាបិតាវណ្ណៈផ្សេងៗគ្នាដូច្នេះ គេប្រកាន់ថាជាមនុស្សសាមញ្ញ ជាទីមើលងាយពីអ្នកដែលគេមានជាតិត្រកូល។ល។

មនុស្សក្នុងយុគនេះ យកចិត្តទុកដាក់ក្នុងវិជ្ជាធម៌ច្រើន ទើបជាមនុស្សមានទិដ្ឋិ ប្រកាន់ថា ស្លាប់ហើយកើតក៏មាន ប្រកាន់ថាស្លាប់ហើយសូន្យក៏មាន។ល។ ពួកខ្លះប្រកាន់ថា សត្វនិងបានសុខទុក្ខ គឺបានដោយខ្លួនឯង សុខទុក្ខគ្មានហេតុបច្ច័យ ពួកខ្លះឃើញថា សុខទុក្ខ មាន

ហេតុបច្ច័យ។ល។ ពួកខ្លះឃើញថាសុខទុក្ខមានមក ព្រោះហេតុខាងក្នុង គឺកម្ម (ទើប) បួងសួង សូមឱ្យទេវតាជួយខ្លះ ស្វែងរកក្នុងផ្លូវដទៃខ្លះ។ល។

ចំណែកមនុស្សនៅតាមក្រុងនីមួយៗកាន់តាមលទ្ធិរបស់ព្រាហ្មណ៍ ប្រព្រឹត្តតាមពាក្យប្រដៅក្នុងត្រៃវេទ កាន់ថាលោកជាតុទាំងពួង មានទេវតាជាអ្នកសាង មានទេវតា អង្គផ្សេងជាម្ចាស់ ក្រាបសំពះសែនព្រេនទេវតានោះៗ អង្វរករសូមឱ្យជួបប្រទះនូវផល ដែលខ្លួនប៉ងប្រាថ្នា ធ្វើពិធីមង្គលសួស្តី ដោយបូជាយញ្ញ គឺដុតភ្លើង សែនព្រេន មានវិធីប្រព្រឹត្តវត្តប្រតិបត្តិជាការបុណ្យ ហៅថាតបៈគឺឆ្អើរកិលេស ធ្វើពងកាយឱ្យលំបាក។ល។ បើអស់ជីវិតដោយការប្រព្រឹត្តមនុស្សនោះនឹងទៅកាន់ឋានសួគ៌។ល។

សង្គមក្នុងសម័យនោះ មានប្រការដូច្នេះ គឺហេតុញុំាងការទៀយណាយក្នុងយរាវាសសម្បត្តិឱ្យកើតដល់សាស្ដា ដោយចំពោះដល់សិទ្ធត្ថគោតមៈ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៥)

ម្យ៉ាងទៀត នៅមានវិធីនយោបាយក្នុងសម័យនោះ ជាគ្រឿងសម្ដែងសង្គមមួយបែបទៀត ដែលជាហេតុនាំឱ្យមានការចេញបួសរបស់សាស្ដាទាំងពីរនោះផងដែរ។,

### ង-សង្គមជនជាតិជ្វីហ្វ សម័យព្រះយេស៊ូ

ជនជាតិជ្វីហ្វបែកខ្ញាត់ខ្ញាយមិនអាចរួបរួមគ្នាជាបាច់បាន មួយផ្នែកធ្លាក់ជាទាសនៅក្នុងប្រទេសអេហ្ស៊ីប មួយផ្នែកទៀតអាស្រ័យនៅនាក្រុងយេរូសាលឹម ពួកដែលមិនអាចអត់ទ្រាំនៅក្រោមការគ្រប់គ្រងរបស់រ៉ូម ក៏នាំគ្នាភៀសខ្លួនទៅនៅផែនដីដទៃ ដែលអាចផុតពីភ័យបាន។

ជនជាតិជ្វីហ្វធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ចក្រពត្តិរ៉ូម៉ាំង មានអ្នកតំណាងរបស់ (ប្រតិភូធំ) របស់ចក្រពត្តិនៅប្រចាំការឃ្លាំមើលកិច្ចការ តែអនុញ្ញាតឱ្យបព្វជិត (ជ្វីហ្វ) ឋិតនៅក្រុងយេរូសាលឹម គ្រប់គ្រងខាងផ្លូវសាសនា។

ជនជាតិរ៉ូម៉ាំងចូលមកធ្វើធំ យកចិត្តពួកអែបអបឡេមឡឹម ដើម្បីជាប្រយោជន៍ខាងផ្លូវអំណាច មាស ប្រាក់និងសេចក្ដីសុខខាងផ្លូវលោកិយ៍។ មួយបែបផ្សេងទៀត បព្វជិត ធ្លាក់ទៅជាគ្រឿងប្រើប្រាស់របស់រ៉ូម៉ាំង ត្រូវបញ្ចើចបញ្ចើលះបង់ធម៌ បណ្ដោយឱ្យពួករ៉ូម៉ាំង ដែលធ្វើចំពោះជនជាតិជ្វីហ្វ។

*សេចក្តីសុខខាងផ្លូវលោកិយ៍ក្នុងសម័យនោះ គឺការខ្វះខ្វាយ ការល្មោភលង្វេងសប្បាយក្លែងខ្លួន ដែលជនជាតិរ៉ូម៉ាំងនាំចូលមកនិងស្វែងរកក្នុងចំណោមជនជាតិជ្វីហ្វ រ៉ូម៉ាំងយកពន្ធគ្រប់យ៉ាង អ្នកណាមិនត្រូវការបង់ពន្ធ ត្រូវរកប្រយោជន៍ឱ្យដល់រ៉ូម៉ាំង។ ជនជាតិជ្វីហ្វធ្លាក់ទៅក្នុងឋានៈជាអ្នកក្រខ្សត់អត់ឃ្លាន អ្នកមានសប្បាយរីករាយ គឺអ្នកលក់ដូរជាមួយរ៉ូម៉ាំង និងបព្ជិតប្រព្រឹត្តធម៌។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៦)*

*ខគួររំឭក ៖ ព្រះយេស៊ូប្រកាសសាសនា បំណងបំផ្លាញទារុណកម្មតាមបែបគ្រប់គ្រងរបស់រ៉ូម៉ាំង ព្យាយាមផ្លាស់ប្តូររបៀបគ្រប់គ្រង និងសេចក្តីអយុត្តិធម៌របស់អ្នកព្រតជ្វីហ្វ ដែលរួមដៃជាមួយរ៉ូម៉ាំង (មើលពិធីប្រកាសសាសនា)។*

**ច-សង្គមអារ៉ាប់សម័យមហៈហ្មុំត**

*ផែនដីក្រៀមស្ងួតនេះ ជាទន្លេខ្សាច់ឃ្លាតឆ្ងាយពីទន្លេក្រហម ចូលទៅប្រហែល២០គ.ម ជាទីតាំងក្រុងបុរាណឈ្មោះ មេក្កៈ ជាមជ្ឈមណ្ឌលការលក់ដូរនៃអ្នកជំនួញដែលមកពីស្រុកឆ្ងាយៗ និងជាទីរួមមនុស្សច្រើនពួក ច្រើនពូជពង្ស មនុស្សទាំងឡាយបូជារូបគោរព (ព្រះជាម្ចាស់កណ្តាលទន្លេខ្សាច់) របស់ខ្លួនតាមពួកនីមួយៗ តាមពង្សនីមួយៗ មានន័យថា រូបគោរពទាំងនោះមានជាង ៣៦០បែប។*

*ផៅពង្សដែលធំជាងផៅពង្សដទៃ គឺផៅពង្សគូរាអ៊ិជ ជាផៅពង្សរបស់ព្រះមហៈហ្មុំត មាននាទីរក្សាទីស្ថានស័ក្តិសិទ្ធិគឺ "កាបាហ៍" ដែលជាស្នូលនៃការរាប់អាន(សាសនា)របស់បុគ្គលអ្នកនៅក្នុងជ្រោយអារ៉ាប់ទាំងអស់។*

*ផៅពង្សនីមួយៗតាំងខ្លួនជាឥស្សរៈ មិនព្រមចំណុះគ្នា ការរាប់អានបូជា (រូបគោរព) ប្រព្រឹត្តទៅតាមការពេញចិត្តរបស់អ្នកដឹកនាំពូជពង្សនោះៗ ពូជពង្សទាំងអស់ដណ្តើមគ្នាធ្វើធំ សង្គមបែកខ្ញែកព្រោះសទ្ធា (សាសនា) ទៅតាមបែបម្នាក់ៗមិនរួមគ្នា អ្នកណារួបរួមសាសនាបាន អាចរួមពួកមនុស្សបានច្រើនរមែងឡើងធ្វើធំក្នុងចំណោមអ្នកស្រុក។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៧)*

*ព្រះមហៈហ្មុំតបានកម្លាំងមកពីទ្រព្យសម្បត្តិរបស់ភរិយាមេម៉ាយ (នាងគាឌិយាហ៍) កើតមានទំនុកទុកចិត្ត (ពីទេពនិមិត្ត) ប្រកាសពាក្យប្រៀនប្រដៅថ្មី (របស់ព្រះជាម្ចាស់) រកវិធីបំផ្លាញអំណាចរបស់មេដឹកនាំពូជពង្សនីមួយៗ បំផ្លាញរូបគោរព និងសទ្ធាប្រភេទផ្សេងៗបានទាំងអស់ ហើយប្រកាសសាសនាអ៊ិស្លាម មានការរាប់អានព្រះអាល់ឡោះតែមួយព្រះអង្គ (ពុំ*

មានរូបគោរព) ដោយការធ្វើសង្គ្រាមស្ទើរតែគេចជីវិតមិនផុតពីគ្រោះថ្នាក់ (មើលប្រវត្តិមហៈហ្មាត់ពីខាងដើម)។

## ៦-គោលប្រៀបធៀប វេវចនៈ និង អភិនិហារ

វេវចនៈគឺពាក្យជាគុណសព្ទសម្ដែងភាវៈនិងគុណលក្ខណៈរបស់សាស្ដា ធ្វើឱ្យឃើញឋានៈរបស់សាសនា ដែលតាំងជារូបរាងឡើងបានយ៉ាងណា។

ចំណែកអភិនិហារ គឺជាស័ក្តិសម្ដែងឱ្យឃើញអំណាចនៃការជាអ្នកវិសេសវិសាលរបស់សាស្ដានោះៗ ជាធម្មតារបស់បុគ្គលកើតមកជាមេដឹកនាំមនុស្ស រមែងប្រកបដោយគុណវិសេសដែលមានក្នុងខ្លួន និងកើតអំពីខ្លួននោះម្យ៉ាង ហើយដែលសាវ័កអ្នកឧទ្ទិសជីវិតបូជា លើកតម្កើងសាស្ដារបស់ខ្លួនឱ្យឃើញថាជាអ្នកវិសេស សមដូចជាបុគ្គលបែបនោះៗម្យ៉ាងទៀត។

មុននឹងធ្វើការប្រៀបធៀប ត្រូវកំណត់ជាដើមដំបូងមុនអ្វីៗដទៃ គឺក្នុងសាសនាផ្នែកទេវនិយម ក្រុមសេមិទិក មានសាសនាជ្វីហ្វ សាសនាគ្រិស្ដ និងសាសនាអ៊ិស្លាមជាដើម ព្រមទទួលស្គាល់ថា មានព្រះជាម្ចាស់ នៅពីលើសាស្ដារបស់ខ្លួន មោសេស (ជ្វីហ្វ) យេស៊ូ(គ្រិស្ដ) និងមហៈហ្មាត់ (អ៊ិស្លាម) ទទួលពាក្យបញ្ជា បញ្ញត្តិឬឱវាទគ្រប់យ៉ាង មកពីព្រះជាម្ចាស់សាស្ដាម្នាក់ៗមានឋានៈគ្រាន់ជាសាស្ដាព្យាករណ៍ ត្រឹមតែជាតំណាងព្រះជាម្ចាស់ ឬត្រឹមជាអ្នកទាក់ទងរវាងព្រះជាម្ចាស់និងមនុស្សប៉ុណ្ណោះ។ (ហេន គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៨)

ចំណែកក្នុងសាសនាផ្នែកក្រុមអារ្យ៉ែន មានសាសនាជេននិងសាសនាពុទ្ធជាដើម សាស្ដាព្រះមហាវីរៈនិង គោតមៈពុទ្ធ បដិសេធអំណាចព្រះជាម្ចាស់ ពុំបានទទួលបញ្ញត្តិមកពីអ្នកណា មិនបានជាអ្នកទាក់ទងរវាងអ្នកណានិងអ្នកណានោះទេ ប្រសិនបើមានគ្រាន់តែជាអ្នកទាក់ទងរវាងបុគ្គលនិងធម៌ប៉ុណ្ណោះ។

មហាវីរៈនិងគោតមៈពុទ្ធ ជាបុគ្គលក្នុងប្រវត្តិសាស្ត្រ ដែលស្វះស្វែងរកធម៌ដោយខ្លួនឯង ពុំមានព្រះជាម្ចាស់អង្គណាមកប្រៀនប្រដៅ ឬប្រគល់ភារៈឱ្យប្រៀនប្រដៅឡើយ តែជាអ្នកប្រៀនប្រដៅធម៌តាមដែលខ្លួន ស្វែងរកស្រាវជ្រាវបាននោះ គឺតួព្រះជាម្ចាស់ ឬប្រសិនបើមាន គឺខ្លួនរបស់ខ្លួននោះឯង ជាព្រះជាម្ចាស់ក្នុងខ្លួនរបស់ខ្លួនឯង។

កំណត់បានដូច្នេះ ប្រសិនបើពោលប្រៀបធៀប វេវចនៈ គឺគុណសព្ទដែលសម្តែងភាវៈ ឬគុណលក្ខណៈ និងអភិនិហារ ត្រូវញែកចេញជា ២ វគ្គ។ វគ្គទីមួយ ប្រៀបធៀបគុណលក្ខណៈរវាងព្រះជាម្ចាស់ (ផ្នែកសេមិទិក) និងធម្មៈ (ផ្នែកអារ្យ៉ន) និងមួយវគ្គទៀត ប្រៀបធៀបអភិនិហាររវាងសាស្តាអ្នកប្រកាសពាក្យប្រៀនប្រដៅ។

ព្រះចៅ ជាអ្នកសាង អ្នកប្រទានកំណើត ព្រះបិតា ព្រះទ្រង់មានបណ្តាស័ក្តិដ៏ខ្ពង់ខ្ពស់ ទ្រង់មានព្រះពលំ ទ្រង់ជាអ្នកមានអានុភាព ទ្រង់ជាអ្នកមានមេត្តាត្រាប្រណី ទ្រង់ជាអ្នកដឹងសព្វគ្រប់ ទ្រង់ជាអ្នកមានសច្ចៈ និង ទ្រង់ជាអ្នកមានយុត្តិធម៌។ល។ រួមទាំងអស់ថាមានដល់ទៅ ៩៩ព្រះនាម ឬជាងនោះប្រដូចជាព្រះនាម ដែលសម្តែងពីគុណលក្ខណៈនោះៗ នឹងកើតឡើងតាមសទ្ធារបស់បុគ្គល គឺចូលទៅក្នុងលក្ខណៈមនុស្សសាងព្រះ ជាម្ចាស់ សាងរូបឯណានីមួយ ក៏ថ្វាយព្រះគុណលក្ខណៈទៅរូបនោះៗ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ២៩)

ធម្មៈ សំដៅដល់ធម្មជាតិដែលជាសភាវៈប្រចាំលោក ធម៌នោះជាអ្នកសាងលោក ជាអ្នករក្សាលោក ទ្រទ្រង់សេចក្តីយុត្តិធម៌ក្នុងលោក ជាពលំខ្ពង់ខ្ពស់នៅក្នុងលោក ជាសន្ទិដ្ឋិក ជាអកាលិក ជាឯហិបស្សិក ជាអ្នកចិញ្ចឹមទុកនូវការប្រព្រឹត្តតាមធម៌ មិនចិញ្ចឹមទុកនូវអ្នកមិនប្រព្រឹត្តតាមធម៌ ធម៌នោះមិនទៀង ជាទុក្ខ និងមិនមានខ្លួនប្រាណ (ធម្មនិយាមសូត្រ)។

## គោលប្រៀបធៀបអភិនិហាររបស់សាស្តា

ក-មោសេស ម្តាយផ្សងព្រេងសំណាង បណ្តែតទៅតាមទឹក រួចពីស្លាប់បានជាបាដិហារិយ៍, នាំជនជាតិ អ៊ីស្រាអែល រត់គេចពីទាសភាពរបស់អេហ្ស៊ីប ព្រះជាម្ចាស់ទ្រង់បើកទន្លេក្រហមវែកផ្លូវឱ្យឆ្លងទៅ គ្រាមួយនោះ ឡើងទៅលើភ្នំស៊ីណៃ បរិកម្មទទួលបញ្ញត្តិ១០ប្រការ (ពីព្រះជាម្ចាស់) មកប្រគល់ឱ្យជនជាតិអ៊ីស្រាអែល។ល។ រាប់ជាអភិនិហារទាំងអស់។

ខ-ព្រះយេស៊ូ ពេលកើត មានដួងតារាចម្លែកនាផ្ទៃមេឃ គ្រាមួយនោះដើរប្រៀនប្រដៅមនុស្សវង្វេងផ្លូវ ចូលទៅនៅក្នុងព្រៃជាមួយសិស្សមួយចំនួនធំ វិលវល់នៅក្នុងព្រៃ ៤០ថ្ងៃ ៤០យប់ ចិញ្ចឹមសិស្សមិនឱ្យស្លាប់បានដោយការសែកនំប៉័ងឱ្យស៊ី។ រក្សាមនុស្សឃ្លង់ និងមនុស្សខ្វាក់ឱ្យជា ដោយវិធីប្រាប់ឱ្យជាតាមពាក្យបង្គាប់ និងដឹងខ្លួនដល់វារៈចុងក្រោយនៃជីវិត។ ពេលអស់ជីវិត រំពេចនោះផ្ទៃមេឃងងឹតសូន្យសុង មានព្រឹត្តិការណ៍ចម្លែកលើផ្ទៃមេឃភ្លៀងធំ អ្នកមានរោគឃ្លង់ជារោគព្រោះទឹកភ្លៀងនោះ ហើយព្រះសពស្តេចឡើងឋាន

សួគ៌ (គម្ពីរលូកា)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនា ប្រៀបធៀប ទំព័រ ៣០)

គ-ព្រះមហាៈហ្វ៊ត ពេលឧប្បត្តិមាតានិយាយថា មានរស្មីចេញពីខ្លួនព្រះមហាៈហ្វ៊ត ទៅនាប្រាសាទក្នុងស៊ីរៀ កើតហើយក្រោកឡើងដើរបាន ដួលហើយក្រោកឡើងបានទៀត បែរមុខងើយមើលទៅលើមេឃ មុនប្រកាសសាសនាមានទេវតាមកបណ្តាលចិត្តជាទេវឌ័ក្តារ ឱ្យប្រកាសគម្ពីរកូអាន។ គ្រាមួយនាំសិស្ស ៤០០ នាក់ ចេញច្បាំងជាមួយសត្រូវ ក្នុងទន្លេខ្សាច់ អត់អាហារអស់ទឹកផឹក ជិតនឹងអស់កម្លាំងទាំងកងទ័ព មានពពែមួយដើរតម្រង់មករកព្រះមហាៈហ្វ៊តបានទឹកដោះមកពីពពែនោះ ចិញ្ចឹមសិស្សរួចរស់បានទាំង ៤០០នាក់ (តាមការយល់របស់ពួកនិទានស៊ូហ្វី)។

ឃ-សិទ្ធត្ថគោតមៈ ឧប្បត្តិហើយ ទ្រង់ព្រះដំណើរបាន ៧ជំហាន មានទេវតាបង្ហូរទឹកត្រជាក់ ក្តៅ មកស្រង់ព្រះកាយថ្វាយ ប្រកាសសេចក្តីជាឯកអគ្គបុរសក្នុងលោក ប្រកាសសេចក្តីជាជាតិចុងក្រោយ ទ្រង់នឹងមិនត្រឡប់មកឧប្បត្តិទៀត។ កាលគ្រាទ្រង់នៅព្រះយុវវ័យ ស្តេចតាមព្រះជនកទៅក្នុងពិធីច្រត់ព្រះនង្គ័ល ប្រថាប់នៅឯកឯងក្រោមដើមជម្ពូព្រឹក្ស ទ្រង់ចម្រើនអាណាបានសតិកម្មដ្ឋានឈាន ញ៉ាំងបឋមឈានឱ្យកើត ខណៈនោះជាវេលាថ្ងៃរសៀលស្រមោលនៃដើមឈើរមែងជ្រេទៅតាមថ្ងៃ តែស្រមោលដើមជម្ពូ នៅត្រង់ដដែលដូចជាពេលថ្ងៃត្រង់ៗល។ អភិនិហារដទៃទៀត មិនអាចនឹងពិពណ៌នាបាន។

ការសម្តែងប្រៀបធៀបអំពីអភិនិហាររបស់សាស្តាដោយសង្ខេបប៉ុណ្ណោះ គប្បីកំណត់ថា ធម្មតាអ្នក កើតមកជាមហាបុរស ញ៉ាំងប្រយោជន៍ធំឱ្យកើតដល់លោក សូម្បីត្រឹមតែពួកគណៈក៏ដោយ រមែងមានការប្រព្រឹត្តទៅគួរឱ្យពិចារណា នេះជាផ្លូវមួយ ហើយនិងមានការប្រព្រឹត្តទៅ ដែលសាវ័កអ្នកប្រាថ្នាលើកតម្កើង សាស្តារបស់ខ្លួនឱ្យឃើញប្រាកដនូវអភិនិហារ មិនធ្លាប់មាននេះមួយផ្លូវទៀត។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនា ប្រៀបធៀប ទំព័រ៣១)

អ្នកសិក្សា គប្បីប្រើសេរីភាពនៃគំនិតពិចារណាតាមការគួរ ដល់ហេតុផលដែលមិនយល់ “ប្រដូចជា បរិភោគផ្លែឈើមានសំបកក្រាស់ មានមង្ឃុត ឬសាវម៉ាវ បើបរិភោគទាំងសំបកវាចត់ គួរបកសំបកចេញ ខ្វះយកតែសាច់ខាងក្នុង” ទើបបានជាប្រយោជន៍។

**គោលការណ៍ប្រៀបធៀបវិធីប្រកាសសាសនា**

វិធីប្រកាសសាសនា គឺវិធីធ្វើការងាររបស់សាស្ដា សម្ដែងឱ្យឃើញកុសលោបាយ (ឧបាយដ៏ប៉ិនប្រសប់) របស់សាស្ដាមួយរូបៗ ដែលប្រតិបត្តិឱ្យសមស្របតាមភូមិសាស្ត្រនិងសង្គមនោះៗ ជាខនាំឱ្យនឹកឃើញថា នៅក្នុងសង្គមបែបណា គួរប្រតិបត្តិខ្លួនយ៉ាងណា ចូលក្នុងលក្ខណៈ ដឹងកាលៈទេសៈហេតុការណ៍ និងបុគ្គល។

តទៅនេះ នឹងសម្ដែងចំពោះការងាររបស់សាស្ដាអ្នកកតាំងសាសនាធំៗ ជាអាទិ៍ សាសនាជ្វីហ្វ គ្រិស្ត អ៊ិស្លាម និងពុទ្ធសាសនា ដើម្បីជាប្រយោជន៍ដល់សង្គមដែលមានអ្នករាប់អានច្រើនក្នុងបច្ចុប្បន្ន។

## ក-វិធីប្រកាសសាសនារបស់មោសេស

មោសេស មើលឃើញការបែកបាក់គ្នា និងទុក្ខវេទនារបស់ជនជាតិជាធំដោយសង្គមរបស់ជនជាតិជ្វីហ្វ ត្រូវបំផ្លិចបំផ្លាញមកជាយូរយារ ទើបកាត់ចិត្តប្រកាសបញ្ញត្តិ ១០ប្រការ អាងយកនាមរបស់ព្រះយេហូវ៉ា មកជាធំ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣២)

សេចក្ដីព្យាយាម និងការកាត់ចិត្តរបស់មោសេស អាចចងជនជាតិជ្វីហ្វឱ្យមូលត្រកូលគ្នាបាន ទោះបីត្រូវបែកខ្ចាត់ខ្ចាយទៅនៅទឹកដីនៃដទៃណាក៏ដោយអាស្រ័យបញ្ញត្តិ ១០ ប្រការនោះ មោសេសប្រកាស (បង្គាប់) ទុកជាគោលសំខាន់ដូច្នេះ ៖

បញ្ញត្តិ ១០ប្រការ ជាគ្រឿងចងភ្ជាប់ក្រុមមនុស្ស ព្រះជាម្ចាស់បញ្ញត្តិទុកឱ្យជនជាតិជ្វីហ្វទាំងឡាយ បញ្ញត្តិនេះជាគ្រឿងចងភ្ជាប់ជាតិ និងវង្សត្រកូលឱ្យនៅចងគ្នាជាបាច់។

មោសេស ប្រកាសឱ្យក្រុមជនជាតិជ្វីហ្វ រៀបការគ្នាឯងក្នុងចំណោមពួករបស់ខ្លួន មិនព្រមឱ្យអ្នកដទៃ មកលាយឡំ។

ប្រកាសឱ្យមានបន្ទាយបរិសុទ្ធ (Holy tent) ទុកជាទីប្រកបពិធីខាងផ្លូវសាសនា មោសេសខ្លួនឯងជាអ្នកធ្វើពិធីបន្ទាយបរិសុទ្ធនេះ តមកក្លាយទៅជាវិហារ ឬបូជនីយដ្ឋានកណ្ដាលរបស់ជនជាតិជ្វីហ្វក្នុងពេលក្រោយ។

ប្រកាសឱ្យមានហិបនៃព្រះបញ្ញត្តិ (Ark of Covenant) ខាងក្នុងហិបមានថ្មស័ក្តិសិទ្ធិចារឹកបញ្ញត្តិទុក ២ ផ្ទាំង ឱ្យកាន់ថាស្មើទុកដូចព្រះជាម្ចាស់តាមមកជាមួយ (កូនអ៊ីស្រាអែល) នៅគ្រប់ទឹកដី ដើម្បីសេចក្ដីសាមគ្គីនៃជាតិវង្សត្រកូល។

## ១-វិធីប្រកាសសាសនារបស់ព្រះយេស៊ូ

ដើមដំបូង ព្រះយេស៊ូប្រកាសទេសនាលើភ្នំ (Sermon on the mount) មានសេចក្តីសំខាន់សម្តែងពីវិធីការប្រកាសសាសនាមួយប្រយោគថា "កុំគិតថាយើងមកបំផ្លាញព្រះ-បញ្ញត្តិ និងពាក្យប្រៀនប្រដៅរបស់សាស្តាព្យាករណ៍ យើងមិនបានមកបំផ្លាញទេ តែមកនេះដើម្បីនឹង (កែខៃ) ធ្វើឱ្យសម្រេច (ប្រយោជន៍)។

តអំពីការប្រកាសទេសនានោះហើយ ព្រះយេស៊ូនាំបញ្ញត្តិក្នុងបញ្ញត្តិ ១០ប្រការរបស់មោសេសខ្វះមកកែខៃ ដើម្បីប្រយោជន៍ធំដល់សង្គមឱ្យទូលំទូលាយទៅទៀតជាអាទិ៍បញ្ញត្តិ ១ ៦ (ហាមមិនឱ្យសម្លាប់មនុស្ស) ព្រះយេស៊ូពង្រីកចេញទៅដល់ការសម្លាប់សត្វ ការប្រទូស្តរ៉ាយខាងផ្លូវវាចានិងផ្លូវចិត្តជាការប្រហារទៀតផង។

បញ្ញត្តិ ១ទី៧ (មិនឱ្យកន្លងប្រវេណី) ព្រះយេស៊ូពង្រីកចេញទៅដល់ផ្លូវចិត្ត មិនឱ្យល្មើសសូម្បីតែគិតថា ចង់កន្លងប្រពៃណី (មើលរឿងក្នុងសាសនាជិហ្វ) បញ្ញត្តិ ១១០ (ទាក់ទងនឹងការលោភ) ព្រះយេស៊ូពង្រីកចេញទៅ គឺមិនឱ្យកំណាញ់ អ្នកណាសុំអាវមួយ គួរឱ្យថែមមួយទៀត ឱ្យតស៊ូនឹងអំពើអាក្រក់ដោយធ្វើល្អ បើអ្នកណាទះថ្ពាល់ស្តាំ ឱ្យគេទះម្ខាងទៀតដូច្នេះជាដើម។

អាចមកពីព្រោះហេតុ នៃការដឹងខ្លួនថាជាអ្នកមានកម្លាំងខ្សោយ អ្នកព្រតជ្វិហ្វមួយពួកមានកម្លាំងច្រើន និងជ្វិហ្វកំពុងធ្លាក់នៅក្រោមអំណាចរបស់រ៉ូម៉ាំង ព្រះយេស៊ូទើបប្រកាសសាសនាចាប់ផ្តើមពីមនុស្សក្រីក្រខ្វត់ ក្មេងទន់ខ្សោយនិងអ្នកមិនមានទីពឹងជាមុន។ ពេលបញ្ជូនសាវ័កទៅប្រកាសសាសនា ព្រះយេស៊ូហៅសិស្សមកប្រៀនប្រដៅ ឱ្យជួយរក្សាមនុស្សឈឺឱ្យជាជួយមនុស្សស្លាប់ឱ្យរស់ ជួយបណ្តេញខ្មោចបិសាចឱ្យចេញពីមនុស្ស ដែលត្រូវខ្មោចព្រាយចូល ទីណាគួរទៅមិនគួរទៅ ផ្ទះណាគួរអាស្រ័យមិនគួរអាស្រ័យ បើទីណាមិនព្រមទទួល មិនព្រមស្តាប់ពាក្យប្រៀនប្រដៅឱ្យធាប់ចេញទៅ រលាស់ផង់ធូលីរបស់ផ្ទះនោះចេញកុំឱ្យជាប់ជើង។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣៤)

បង្រៀនសិស្សថា ទៅដល់ទីណាឱ្យនិយាយប្រាប់មហាជនថា "ផែនដីសួគ៌ ចូលមកជិតលោកហើយ" និងបញ្ជាទុកជាខសំខាន់ថា "យើងប្រើពួកលោកទៅ ដូចចៀមនៅក្នុង ហ្វូងឆ្កែចចក ព្រោះដូច្នោះចូរជាអ្នកឆ្លាតដូចពស់ និងជាមនុស្សសុភាពដូចសត្វព្រាប"។

ព្រះយេស៊ូ តាំងមេត្តា ឬសេចក្ដីស្រឡាញ់ ជាមូលដ្ឋាននៃការប្រកាសសាសនា ដើម្បីទប់ទល់នឹងទារុណកម្មរបស់រ៉ូម៉ាំង ការប្រកាសសាសនា ទើបប្រព្រឹត្តទៅក្នុងលក្ខណៈទន់ភ្លន់ អនុលោមតាមទំនងដូចជាយកចិត្តដល់អ្នកទន់ខ្សោយ និងអ្នកមិនមានទីពឹងទាំងឡាយ។ មនុស្សមួយផ្នែក នាំគ្នាឱ្យអត្ថន័យជីវិត ការប្រៀនប្រដៅសាសនារបស់ព្រះយេស៊ូ "មិនស៊ូ" នឹងត្រូវគេចាប់យកទៅប្រហារ ព្រោះការទន់ខ្សោយនោះ។

### គ-វិធីប្រកាសសាសនារបស់ព្រះមហាហ្មូត

ព្រះមហាហ្មូតដឹងខ្លួនថា ជាមនុស្សមិនចេះអក្សរ ដឹងការពិតថា ពូជពង្សទាំងឡាយក្នុងជ្រោយអារ៉ាប់តាំងខ្លួនជាសត្រូវនឹងខ្លួន គ្រប់ពូជពង្សមិនព្រមទទួលពាក្យប្រៀនប្រដៅរបស់ខ្លួន នឹងបានសិក្សាវិធីប្រកាសសាសនារបស់ព្រះយេស៊ូបានយ៉ាងល្អថា សាស្ដារូបនោះត្រូវសូន្យសោះអស់ជីវិតព្រោះការទន់ខ្សោយ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣៥)

អាស្រ័យជាអ្នកអត់ធន់ មានការប្រាថ្នាធំនិងទុកចិត្តក្នុងទេពឱង្ការ ទើបប្ដូរវិធីការប្រដៅសាសនា ផ្ទុយពីព្រះយេស៊ូធ្លាប់ធ្វើមក សម្ដែងខ្លួនជាមនុស្សរឹងប៉ឹង មិនខ្លាចស្លាប់ អ្នកណាមករារាំង ប្រើកម្លាំងបង្ក្រាបភ្លាម ប្រើអាវុធជាគ្រឿងប្រកាសសាសនាជាញឹកញយ ស្ទើរតែមិនអាចរួចរស់ជីវិត ឈ្នះទីកន្លែងណាប្រកាសសាសនានិងគ្រប់គ្រងទីនោះភ្លាម ព្រះមហាហ្មូតរក្សាជីវិតរហូតមក ព្រោះការតស៊ូបានជាសាស្ដាធំ និងអ្នកត្រួតត្រាប្រទេសក្នុងគ្រាជាមួយគ្នា។

ការធ្វើសង្គ្រាមនិងការផ្សាយសាសនាអ៊ិស្លាម ជាគូនឹងគ្នាក្នុងប្រវត្តិសាស្ត្ររបស់សាសនានេះ។

### ឃ-វិធីប្រកាសសាសនារបស់សិទ្ធត្ថគោតមៈ

សិទ្ធត្ថគោតមៈ (ព្រះពុទ្ធជាម្ចាស់) អ្នកប្រកាសពុទ្ធសាសនា ស្ដេចចេញទៅកាន់ភេទបព្វជា ព្រោះទ្រង់នឿយណាយក្នុងសង្គម ដែលប្រកាន់រឹងត្អឹងដោយវណ្ណៈ (ជាន់ថ្នាក់) របស់ពពួកជនបែកចេញជាពួកជាក្រុម មើលងាយគ្នា ជិះជាន់គ្នា។ល។

ព្រះគោតមៈ ទ្រង់បំណងធ្វើឱ្យសង្គមដែលមានការបែកបាក់ ខ្ពស់ទាបជាងគ្នាឱ្យស្មើភាពគ្នាឡើង ជាតិនិងត្រកូលមិនមែនជាគ្រឿងបែងចែកមនុស្សទេ បុគ្គលគប្បីស្មើគ្នាដោយធម៌ ប្រកាសការស្មើភាពគ្នាក្នុងពួកសង្ឃសាវ័ក ចាប់ផ្ដើមពីការគ្រងសំពត់ ការរស់នៅ

ដោយអាហារបិណ្ឌបាត្រ និងគោលការណ៍គ្រប់គ្រង ដែលយកធម៌ជាធំ (ធម្មាធិបតេយ្យ) ជាជាងបុគ្គល។

ទ្រង់ប្រកាស ការគ្មានទាសៈក្នុងខ្លួន ដែលទាក់ទងនឹងបុគ្គលដទៃ ជាការលើកតម្កើងសិទ្ធិមនុស្ស ឈប់មើលងាយសង្កត់សង្កិនគ្នាក្នុងវណ្ណៈ ទ្រង់ផ្លាស់ប្តូររឿងការធ្វើបុណ្យដែលធ្លាប់សម្លាប់មនុស្ស និងសត្វបូជាយញ្ញឱ្យផ្លាស់មកជាការសង្គ្រោះគ្នាជំនួសការបៀតបៀនគ្នា។ល។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣៦)

វិធីប្រកាសសាសនារបស់ព្រះសិទ្ធត្ថគោតមៈ បំណាច់ផ្តោះទៅក្រុមអ្នកបួស ពួកអាចារ្យដែលជាកន្ទែង គារវៈបូជារបស់មនុស្សក្នុងសម័យនោះ ពីតិចទៅច្រើន បានគណៈអាចារ្យម្នាក់ហើយ នឹងមានបញ្ហាអ្វីដែលសិស្សទាំងនេះមិនទាក់ទងនឹងអ្នកមានទិដ្ឋិរឹងត្អឹង ដូចជាក្រុមក្សត្រិយ៍និងអ្នកនយោបាយក្នុងជាន់ដំបូងជាមុននោះ។

លុះទ្រង់បានផលពីជាន់ទីមួយហើយ ទ្រង់ប្រកាសចូលទៅក្នុងក្រុមក្សត្រិយ៍និងអ្នកគ្រប់គ្រងជាមេដឹកនាំ កាលបើបានក្សត្រិយ៍បានមេដឹកនាំហើយ គ្មានបញ្ហាអ្វីនឹងអ្នកទីក្រុងអ្នកស្រុកនោះទេ។

សិទ្ធត្ថគោតមៈ ទ្រង់ទទួលស្គាល់រឿងបាដិហារិយ៍ ចែកចេញជា ៣គឺ ឥទ្ធិបាដិហារិយ៍ ការសម្តែងឫទ្ធិបានជាអស្ចារ្យ អាទេសនាបាដិហារិយ៍ ការកំណត់ទាយចិត្តអ្នកដទៃបានជាអស្ចារ្យ និងអនុសាសនីយ៍បាដិហារិយ៍ ការប្រៀនប្រដៅបានជាអស្ចារ្យ តែទ្រង់លើកតម្កើងអនុសាសនីយ៍បាដិហារិយ៍តែមួយថាកំពូល ជាប្រយោជន៍ធំ។

ការប្រកាសពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ប្រព្រឹត្តទៅក្នុងលក្ខណៈអនុសាសនីយ៍បាដិហារិយ៍ គឺទ្រង់ប្រកាស ៖

ក-ឱ្យដឹងការពិត ឃើញពិតក្នុងធម៌ដែលគួរដឹង គួរឃើញ

ខ-មានហេតុផល (ពិសោធន៍បាន) ដែលអ្នកស្តាប់ឃើញបានតាមការពិត

គ-មានផលជាអស្ចារ្យ គឺអ្នកប្រតិបត្តិតាម នឹងបានទទួលផលសមដូចការប្រតិបត្តិ។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, ភាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣៧)

សិទ្ធត្ថគោតមៈ ប្រើវិធីប្រកាសសាសនា ដោយមិនព្រមជំទាស់នឹងចិត្តអ្នកណា មិនបង្ខំអ្នកណា បើកឱ្យមនុស្សគ្រប់គ្នាមានសេរីភាពក្នុងការគិត អ្នកណាចង់ជឿ ឬមិនចង់ជឿយ៉ាងណាក្តី ស្រេចលើសតិបញ្ញា ពិចារណាឃើញដោយខ្លួនឯង របស់ណាទ្រង់ឃើញថា

មិនមែនជាប្រយោជន៍ដល់ការប្រតិបត្តិធម៌ ទ្រង់នឹងមិនព្យាករណ៍របស់នោះ ទ្រង់មិនព្រមជួប ប្រទះបញ្ហាដែលទ្រង់ឃើញថា គ្មានសារប្រយោជន៍ ដែលបុគ្គលពាល ឃើញថាមានសារប្រយោជន៍។

សាសនា ដែលសិទ្ធត្ថគោតមៈ ទ្រង់ប្រកាសប្រកបដោយប្រយោជន៍ ៣ ប្រការ អ្នកប្រតិបត្តិតាម ជ្រើសរើសយកណានីមួយក៏បានគឺ ៖

ក-ប្រយោជន៍ក្នុងបច្ចុប្បន្ន ក្នុងខណៈនៅមានជីវិត (មនុស្សសម្បត្តិ)

ខ-ប្រយោជន៍ខាងមុខ កាលបើជីវិតលះពីលោកនេះទៅហើយ (សួគ៌សម្បត្តិ)

គ-ប្រយោជន៍ខ្ពង់ខ្ពស់ គឺការរួចផុតពីលោកដែលមួមៅ (និព្វានសម្បត្តិ)។ (ហេង គីមហោ សាសនាប្រៀបធៀប ភាគ២, កាគរួមផ្សំនៃសាសនាប្រៀបធៀប ទំព័រ៣៨)

# ជំពូកទី ៦
# អំពីលោកធាតុនៃសាសនា

## -លោកធាតុ

ទ្រឹស្ដីលោកធាតុ គេសំដៅយកកំណើតនៃសកលលោក។ នៅក្នុងទ្វីបលោកយើងនេះ យើងឃើញថាទ្រឹស្ដីលោកធាតុ មានលក្ខណៈផ្សេងពីកន្លែងមួយទៅកន្លែងមួយទៀតជាដរាប ។ ខ្លះមានលក្ខណៈជាទស្សនៈ ខ្លះជាទេវកថា ខ្លះជាអស្ដិរូប ខ្លះជាបដិសំយោគ និងខ្លះទៀតមានលក្ខណៈជាតារាសាស្ត្រ។ ប៉ុន្តែនៅទីនេះ យើងកម្រិតព្រំដែនសម្រាប់បរិយាយ ចំពោះតែទ្រឹស្ដីលោកធាតុនៃមហាសាសនា និងលទ្ធិទាំង ៥ ដើម្បីតម្រូវទៅតាម សេចក្ដីត្រូវ ការនៃការសិក្សារបស់យើង។

១-លទ្ធិហិណ្ឌូ ឬព្រាហ្មណ៍ ៖ ទ្រឹស្ដីលោកធាតុតាមលំអាននៃលទ្ធិនេះ យើងឃើញថាមានលក្ខណៈជាទស្សនចិន្ដាសុទ្ធសាធ។ ទ្រឹស្ដីនេះបានរីកចម្រើនឡើងតាំងពីសម័យវេទរហូតដល់សម័យឧបនិសាទ និងបុរាណៈ ហើយក្នុងសម័យនីមួយៗ យើងឃើញថាទ្រឹស្ដីនេះពុំមានលក្ខណៈស្របគ្នាសោះឡើយ[៣០]។

ក-សម័យវេទ ៖ នៅក្នុងសញ្ញាណទូទៅនៃគម្ពីរវេទ យើងឃើញថា លោកនេះមានធាតុ ៣ ផ្នែកគឺ ដី អាកាស និងមេឃ ឬឋានសួគ៌។ ប៉ុន្តែកាលណាគេពោលពីឧត្តមគតិនៃសាសនាលោក (Universe) គេប្រើព្យាង្គពាក្យថា"ឋានសួគ៌និងផែនដី (Heaven and earth)" ទៅវិញ។ ព្យាង្គទាំងពីរនេះ គេទុកជាទេព្ដាឬជាមាតាបិតានៃទេព្ដាទាំងឡាយ ទេវបុត្រ។ ទោះណាជាពាក្យទាំងពីរនេះបង្កើតឡើងដោយទេវតាក៏ដោយ។ ជួនកាលគេយល់ថា ផែនដីនិងឋានសួគ៌ទាំងពីរនេះមានព្រះឥន្ទជាអ្នកបង្កើត ឬព្រះអគ្និ ព្រះរុទ្រៈ ឬក៏ព្រះសោមៈជាអ្នកបង្កើត [៣១] ។ម្យ៉ាងទៀត គេនិយាយដោយរួបរួមគ្នាថា ឋានសួគ៌និងផែនដីបង្កើតឡើងដោយក្រុមទេព្ដាខាងលើនេះ ឬក៏ពិភពលោកទាំងមូលដែលគេប្រៀបធៀបដូចជាគេហដ្ឋានមួយ ស្ថាបនាឡើងដោយក្រុមទេព្ដាទាំងអស់។ គេយល់ថាឋានសួគ៌និងផែនដីត្រូវជាមាតាបិតានៃទេព្ដាទាំងឡាយ ហើយជួនកាលថា ផែនដីនិងឋានសួគ៌មានទេព្ដាជាអ្នកបង្កើត ហាក់ដូចជា មានន័យប្រឆាំងគ្នាទៅវិញ ប៉ុន្តែទាំងនេះ មានធម្មជាតិលំបាកយល់ ព្រមទាំងជាឧត្ដមគតិមានតម្លៃ

---

[៣០] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៧៩

[31] សូមមើល ៖ "Encyclopedia of religion & Ethics" edited by James Hasting, vol.4, pp.155-161)

បន្ថយពុំបាន ហើយមានមកតាំងពីនោះរហូតមកដល់ឥឡូវនេះ។ ដើម្បីចៀសវាងការក័ន្តច្រឡំ គេប្រកាសថា កទិតិ ជាព្រះមាតានៃទេវតានិងធម្មជាតិ ព្រមទាំងលោកនេះ ហើយមានកន្លែងខ្លះពោលថា អទិតិ បណ្ដាលឱ្យទក្សា (ផែនដី) កើតឡើង ហើយទក្សាត្រូវបង្កើតអទិតិ វិញនៅពេលខាងក្រោយមក។ ក្នុងទីនេះ អទិតិ មានលក្ខណៈអត្ថាធិប្បាយ ជារបៀបទេវកថា សម្រាប់គោលការនៃឥត្ថិភាព ឬអំណាចនៃការបង្កើត ចំណែកខាងទក្សា គឺបានដល់បុរិសភាពនៃអំណាចសម្រាប់ការបង្កើត។ ម្យ៉ាងទៀត ពាក្យថាទក្សា គេសំដៅយក បុរិស ភាវៈដែលគេយល់ថាជាធាតុឈ្មោល ដើមបង្អស់ ដែលអាចប្រែរូបនិងសភាវៈមកជាពិភពលោកយើងនេះ។ ទាំងអស់នេះមានប្រាកដមកក្នុងគម្ពីរឫគ្វេទៈ វាជសនេយិសំហិតា និង គម្ពីរតៃតិរិយៈ អារណ្យកៈជាដើម ហើយខាងក្រោយមក មានឥទ្ធិពលពីទ្រឹស្ដីនៃទេវកថា និយមថែមទៀត។

តាមឯកសាររបស់លោក មៀរ(Muir) យើងសង្កេតឃើញលោកជាតុទ្រឹស្ដីនៃសម័យវេទមានដូចតទៅនេះ ៖

ពាក្យថា បុរិសៈ សំដៅយកព្រះអាទិទេពមានក្បាលមួយពាន់ ភ្នែកមួយពាន់ និងជើងមួយពាន់។ បុរិសនេះ ស្រោបរុំដោយផែនដីគ្រប់ជ្រុងទាំងអស់ មានខ្លួនខ្ពស់ឡើងទៅលើអាកាស ហើយតួអាកាសទាំងមូលគេទុកជាម្រាមដៃទាំងដប់។ គេយល់ថាបុរិសៈនោះ គឺតួសកលលោកហ្នឹងឯង លោកជាអមតៈមានខ្លួនរីកធំឡើងដោយអាហារ។ នេះជាមហា អស្ចារ្យព្រមទាំងមានបុរិសភាពខ្ពង់ខ្ពស់ជាងអ្វីទាំងអស់នៅក្នុងលោកនេះ។ ធម្មជាតិមានជីវិត ទាំងអស់គេទុកជាជើងនៃបុរិសៈ។ មនុស្សលោក សត្វលោក និងទេវតា ព្រមទាំងធម្មជាតិ ទាំងអស់ មានវិញ្ញាណនិងឥតវិញ្ញាណ សុទ្ធតែកើតមកពីបុរិសៈទាំងអស់ [៣២]។

ដូចពោលមកខាងលើនេះ យើងសង្កេតឃើញថានៅក្នុងសម័យវេទ គេទុករូបសភាវៈនៃពិភពលោកដែលហៅថា បុរិសៈ នេះជាតួព្រះអាទិទេព។

ឯកភាពនៃទេវសភាវៈ ដែលគេទុកជាដើមបំផុតនៃលោក ហើយដែលគេបានឃើញព្រមទាំងទទួលស្គាល់ក្នុងស្លោកខាងលើនេះ គឺគេធ្វើអត្ថាធិប្បាយព្រមទាំងហៅថា "ព្រះតែមួយគត់។ ព្រះកើតឯងហើយមានឋានៈខ្ពស់ជាងទេវតាទាំងឡាយ"។ នៅក្នុងស្លោកពីរនៃគម្ពីរឫគ្វេទ (Rigveda, X.81,82) គេហៅទេវៈនោះថា "វិស្វករ" (Engineer) ហើយនៅក្នុងទេវកថា

[៣២] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨០

ខាងក្រោយមក ពាក្យនេះក្លាយជាវិស្វកម្មទេវតាទៅវិញ។ ខាងក្រោយមក គេហៅថា "ប្រជាបតិ (Prajapati)" ដែលមានលក្ខណៈដូចជាព្រះព្រហ្មដែរ។ ព្រះវិស្វករ ឬប្រជាមតិនេះ មានលក្ខណៈជាឧត្តមគតិនៃទេវកថាបុរាណ ដែលគេបញ្ជាក់ថាជាទេព្តាធំបំផុត មានកំណើតឡើងនៅក្នុងទឹកមានពណ៌ប្រាក់ (Hivanyagarbha) ជាម្ចាស់នៃទេព្តាទាំងឡាយនិងពិភពលោក ជាអ្នកបង្កើត។ ឧត្តមគតិនេះ ខាងក្រោយមកបានរីកចម្រើនទៅជា "លោកណ្ឌ (World-egg) "ឬ" ហិរណ្យគភ៌=ព្រះព្រហ្ម (Hiranyagarbha = Brahma)។

នៅក្នុងគម្ពីរអថិវវេទ យើងឃើញថាទ្រឹស្តីលោកជាតុ បានស្តែងចេញជាស្លោកមានបែបដូចជាប្រជាបតិដែរ ប៉ុន្តែមានឈ្មោះផ្សេងគ្នាជាច្រើនដូចជា រោហិតៈ (ក្រហម), អនដ្វាន (គោឧសុភ), វិមា (វិសា) មេសា, កាលៈ (ពេល) និងកាមៈ (កាមឬសេចក្តីរីករាយក្នុងកាម) ទៅវិញ។

ខ-សម័យព្រាហ្មណៈនិងឧបនិសាទ ៖ នៅក្នុងគម្ពីរព្រាហ្មណៈ យើងឃើញថាមានរឿងតំណាលជាច្រើនពីការបង្កើតលោកនៃព្រះប្រជាបតិ។ គេបរិយាយថា នៅក្នុងបឋមកប្ប មានតែព្រះប្រជាបតិមួយព្រះអង្គទេ ដែលកើតមុនគេបង្អស់ ព្រះអង្គប្រាថ្នាជាព្រះបែកកាគ (May I become many) រួចហើយទ្រង់ប្រព្រឹត្តតបៈធម៌ ទើបមានអំណាចអាចបង្កើតសត្វលោក, ឋានសួគ៌, អាកាស និងផែនដីបាន។ ជំនួសពីពាក្យថាប្រជាបតិ នៅក្នុងគម្ពីរដដែលនិយាយថា ទេព្តាជាអ្នកបង្កើតលោក មានឈ្មោះថាស្វយម្ភូ នារាយណៈ, ស្វយម្ភូព្រហ្ម ឬជួនកាល អសញ្ញាសត្វ (Non-being) ជាដើម។ បន្ទាប់ពីឈ្មោះនិងលក្ខណៈនៃការបង្កើតលោកមក គម្ពីរនេះបានពោលពីពិធីបូជាផ្សេងៗ តម្រូវទៅតាមសេចក្តីត្រូវការនៅសម័យនោះ[៣៣] ។ ឧត្តមគតិនៃការបង្កើតលោកមិនឋិតថេរដដែលទេ វារីកចម្រើនជាកិយ្យាភាពទៅទៀត។ តាមលក្ខណៈទូទៅ គេយល់ថា ជាតុទឹកគឺជាជាតុកើតមុនព្រះប្រជាបតិ។ ជាតុខ្យល់គឺជាតួ ព្រះប្រជាបតិកើតក្រោយជាតុទឹក។ បន្ទាប់ពីឧត្តមគតិនេះ គេយល់ថា ការរីកចម្រើនបានបន្តសកម្មភាពរហូតដល់គំនិតថាលោកណ្ឌ (ពងឬស៊ុតសម្រាប់បង្កើតលោក) កើតឡើងទៀត[៣៤]។

នៅក្នុងគម្ពីរ សតបថព្រាហ្មៈ យើងសង្កេតឃើញលក្ខណៈជាតុដែលកើតបន្តគ្នាដូចតទៅនេះ ៖

---

[៣៣] សូមមើលរឿងនេះនៅក្នុងគម្ពីរ ទីឃនិកាយ សុត្តន្តបិដក ត្រង់ព្រហ្មជាលសូត្រ ត្រង់ពិធីបូជាផ្សេងៗ

[៣៤] ប៉ែន សាអឿន ***សាសនាប្រៀបធៀប*** គ.ស.១៩៦៩ ទំ៨១

ពីដើម លោកនេះជាទឹក ហើយទឹកនោះប្រាថ្នាថា "តើយើងបង្កើតកូនដូចម្ដេច? កាលបើពោលដូច្នោះ ទឹកទាំងឡាយក៏ខំប្រឹងបង្កើតកូន និងធ្វើតបះ។ កាលបើប្រឹងព្យាយាម និង ធ្វើតបះយូរទៅ ក៏មានស៊ុតមានពណ៌មាសមួយកើតឡើងក្នុងរវាងមួយឆ្នាំ រួចហើយស៊ុតនោះ ក៏អណ្ដែតចុះឡើង ហើយក៏បែកជាភាពឈ្មោលមួយដែលគេហៅថា "បុរិសៈ" ក្នុងរវាងឆ្នាំមួយទៀតខាងក្រោយមក។ បុរិសៈនោះគឺព្រះប្រជាបតិនោះឯង។ ព្រះប្រជាបតិ ក៏បានបំបែកស៊ុតនោះជាច្រើនផ្នែក...។

ក្នុងរវាងមួយឆ្នាំទៀត ព្រះប្រជាបតិនេះនិយាយឡើងថា "ភូរ (Bhur)" ហើយពាក្យនេះក្លាយទៅជាផែនដីថា "ភូវ:(Bhuvah)" ផែនដីក៏មានរូបរាងឡើង បន្ទាប់មកលោកពោលថា "ស្វរ: (Svara)" អាកាសក៏កើតឡើងទៀត។ ព្រះប្រជាបតិកើតឡើងមានកម្រិតអាយុ មួយពាន់ឆ្នាំ លោកក៏ដឹងថាអាយុលោកមានទីបំផុត ដូចជាទន្លេឬស្ទឹងមានច្រាំង លោកក៏មានបំណងចង់បានកូន។ បន្ទាប់មក លោកបានបន្តការធ្វើពិធីបូជាដរាបដល់មានផ្ទៃពោះ ហើយព្រួសចេញតាមមាត់កើតសុទ្ធតែពួកទេព្ដា មនុស្ស សត្វ ជាដើម...។

ដើម្បីប្រៀបធៀបគ្នា យើងនាំយកឧត្ដមគតិនៃលោកជាតុ ដែលមានក្នុងគម្ពីរឆន្ទោគ្យៈឧបនិសាទមកបរិយាយដូចតទៅនេះ ៖

ពីដើម គ្មានលោកនេះទេ។ លុះយូរទៅក៏មានកើតឡើង បន្ទាប់មករឿងនេះក៏ក្លាយជាស៊ុតមួយ។ លុះស៊ុតនោះបិតនៅបានមួយឆ្នាំ ក៏បែកក្លាយជាពីរចំណែក មួយចំណែកជាប្រាក់ មួយចំណែកទៀតជាមាស។ ចំណែកដែលជាប្រាក់ បានក្លាយទៅជាផែនដីនេះ ឯចំណែកដែលជាមាស បានក្លាយជាអាកាស សាច់ស៊ុតពណ៌សក្រាស ក្លាយជាបព៌ត ភ្នំ, សាច់ស៊ុតសស្ដើង ក្លាយជាអ័ព្ទប្រកបដោយពពក, សរសៃស្អិតៗនៃស៊ុត កើតជាស្ទឹង ទន្លេ, ទឹកស៊ុតកើតជាមហាសមុទ្រ ហើយអ្វីដែលកើតចេញមកពីស៊ុតនោះទាំងអស់ គឺព្រះអាទិត្យជាដើម។

ដូចពោលមកខាងលើនេះ បញ្ជាក់ឱ្យឃើញថា ប្រកពទាំងពីរមានខ្សែគំនិតទាក់ទងគ្នាជាដរាប។ អ្នកនិពន្ធនៃគម្ពីរព្រាហ្មណៈ បានបរិយាយពីទ្រឹស្ដីនៃលោកជាតុ តាមលំអាននៃព្រះគម្ពីរនិងជំនឿទូទៅនៅជំនាន់នោះ, ឯអ្នកនិពន្ធនៃគម្ពីរឧបនិសាទ បានបរិយាយរឿងនេះ តាមលំអាននៃទស្សនវិជ្ជា ដើម្បីបញ្ជាក់ពីឯកភាពនៃព្រះព្រហ្ម ព្រមទាំងការប្រាកដឡើងនៃព្រហ្មសភាវៈ នៅក្នុងគ្រប់ធម្មជាតិទាំងអស់នៅក្នុងលោក[៣៥]។

[៣៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨២

*នៅក្នុងគម្ពីរ ព្រិ ហេដ អារណ្យកៈ (Br had Aranyaka-i-4) ការស្ថាបនាលោក ឋិតនៅលើអាត្ម័នដែលមានរូបរាងជាមនុស្ស (បុរុសៈ)។ លោកនេះគឺជាតួខ្លួនបុរុសៈនោះឯងមានពីរចំណែក។ ចំណែកមួយជាប្ដី មួយទៀតជាប្រពន្ធ។ ប្ដី-ប្រពន្ធទាំងពីរនេះ បានរួមរស់នៅជាមួយគ្នា បានកើតជាមនុស្សប្រុស-ស្រីទាំងឡាយក្នុងលោកនេះ។ ដទៃពីនេះ ទាំងពីរនេះបានបង្កើតធម្មជាតិមានវិញ្ញាណក្ដី ឥតវិញ្ញាណក្ដី សុទ្ធតែប្រកបដោយភេទពីរ ឬវត្ថុដូចគ្នាជាដរាប ឬក៏ប្រកបដោយគូ។ ចំណែកគម្ពីរតៃតិរីយៈឧបនិសាទ យើងឃើញថា ទ្រឹស្ដីលោកធាតុមានលំនាំប្រកបដោយទេវកថានិយមតិចតួចជាទីបំផុត។ ទ្រឹស្ដីនេះបានបញ្ជាក់ថា អាកាសកើតចេញពីខ្លួននៃព្រះព្រហ្ម, ខ្យល់ចេញពីអាកាស ភ្លើងចេញពីខ្យល់ ទឹកចេញពីភ្លើង ដីចេញពីទឹក អាហារឬវត្ថុសម្រាប់អាហារចេញពីដី ពូជជាគ្រាប់ក្ដី ជាមែកក្ដី ជាដើមក្ដី ជាឫសក្ដី មើមក្ដី ជាមនុស្សនិងសត្វទាំងឡាយក្ដី ចេញមកពីអាហារទាំងអស់។*

*ឯក្នុងគម្ពីរឆន្ទោគ្យៈឧបនិសាទបុរាណ យើងឃើញថា លោកនេះកើតឡើងដោយកម្លាំងធាតុ៣ប្រភេទ៖ ធាតុភ្លើង ធាតុទឹក និងធាតុដី។ សេចក្ដីបរិយាយពីទ្រឹស្ដីនេះមានដូចតទៅនេះ៖*

*"ឧទ្ទាលកៈ និយាយទៅកាន់ស្វេតកេតុថា ៖ ពីមុនឬពីដំបូងបង្អស់មានតែធាតុមួយគត់ ឥតពីរឡើយ។ អ្នកខ្លះនិយាយថា ៖ ពីដំបូងបង្អស់ គ្មានអ្វីដែលមានតែមួយឬទោល ប្រាសចាកពីរឡើយ ហើយគ្មានអ្វីដែលមានលក្ខណៈទទេ ហើយកើតបានជានេះជានោះឡើយ។ តើទាំងនេះអាចប្រព្រឹត្តទៅបានឬទេ? យើងឆ្លើយថាទេ តាមពិតមុនដំបូង វាមានតែមួយគត់ គ្មានពីរសោះឡើយ ទើបអាចកើតជានេះជានោះបាន។ ភាពតែមួយឬទោលនោះបានតាំងចិត្ត និងប្រាថ្នាថា "សូមឱ្យខ្ញុំទៅជាអ្នកបែងភាគនិងចម្រើនលូតលាស់យ៉ាងរហ័សមួយរំពេច"។ រួចហើយភាពទោលនោះបញ្ជូនភ្លើងឱ្យមកប្រាកដឡើង។ ភ្លើងក៏បានគិតនិងប្រាថ្នាដូចមុន ទើបបញ្ជូនទឹកឱ្យមកប្រាកដឡើងទៀត។ បានន័យថា អ្នកដែលក្ដៅស្អុះនឹងបែកញើសបណ្ដាលមកពីភ្លើងទាំងអស់។ កាលបើទឹកកើតឡើងហើយ ដីក៏កើតឡើងពីទឹកនោះដែរ។ កាលបើមានទឹក ភ្លើង ដីហើយ ធម្មជាតិគ្រប់បែបជាវត្ថុសម្រាប់អាហារក្ដី សម្រាប់វត្ថុប្រើប្រាស់ក្ដី ក៏កើតឡើងតាមលំដាប់ដែរ។ កាលបើធម្មជាតិទាំងនោះកើតឡើងហើយមនុស្ស សត្វគ្រប់បែបក៏បានកើតឡើងបន្តមកទៀត ដោយមានធាតុទាំង៣ នោះជាមូលដ្ឋាន។ មនុស្សសត្វនោះៗមានជីវអាត្ម័នគ្រប់ៗគ្នា"។*

យើងសង្កេតឃើញថាឧត្តមគតិនៃលោកជាតុខាងលើនេះ ជាគំនិតដើមរបស់ប្រព័ន្ធទស្សនវិជ្ជាសំខ្យា ដែលមានលក្ខណ:រីកចម្រើនជាបន្តមកទៀតកៅក្នុងគម្ពីរ ស្វេតអាស្វតារ: និងគម្ពីរឧបនិសាទសម័យក្រោយមក ដែលបង្កើតជាស្ពានបន្តគំនិតដើមនោះជាមួយនឹងសម័យមហាកំណាព្យនិងគម្ពីរបុរាណ: (Great Epics and Puranas) ឱ្យជាប់គ្នា ហើយលក្ខណ:សំខាន់នៃទ្រឹស្តីវិវឌ្ឍនាការនៃប្រព័ន្ធសំខ្យា មានលំនាំនិងផ្លូវផលិតចេញមកពីគម្ពីរឧបនិសាទទាំងអស់។យើងនឹងពោលរឿងនេះនៅកថាខ័ណ្ឌនៃវគ្គ(គ)ខាងមុខនេះទៅទៀត[៣៦]។

នៅទីនេះ យើងសូមបញ្ជាក់ទូទៅនូវលក្ខណ:នៃរចនាសម្ព័ន្ធនៃលោក (The Structure of the Universe) ដែលមានមកក្នុងសម័យវេទ ហើយបន្តសកម្មភាពរហូតមកដល់សម័យព្រាហ្មណ:និងឧបនិសាទ។ នៅសម័យវេទ យើងឃើញជាតុ៣បែបគឺ ដី អាកាស និងមេឃ ជាធម្មសភាវ:សម្រាប់សាងលោក ហើយទាំង៣នេះ បានបង្រួមខ្លួនចូលទៅក្នុងមហាពំនោល (Great Utterances) ៣បែបគឺ ភូរ:, ភូវ: និងស្វរ: នៃសម័យព្រាហ្មណ: និង ឧបនិសាទ។ នៅក្នុងគម្ពីរអៃតរេយ:អារណ្យក: គេបរិយាយថា ពីដំបូងបង្អស់នៃលោក អាត្ម័នគឺ ព្រះព្រហ្មបានបញ្ចូនលោកជាច្រើនគឺ អម្ភ: (ទឹក), មរីចិ (ពន្លឺ), មរ: (មរណភាព) និង អាប: (ទឹក)។ អម្ភលោកឋិតនៅខាងលើឋានសួគ៌ ឬឋានសួគ៌ជាទម្រនៃអម្ភលោក។ មរីចិ បានដល់តួអាកាស, ឯ មរ:បានដល់ផែនដី ហើយទឹកដែលនៅខាងក្រោមផែនដី លោកហៅថា អាប: ជាលោកមួយទៀត។ នៅក្នុងគម្ពីរ ព្រិហទ អារុណ្យក ឧបនិសាទ យើងឃើញមានលោក ១០យ៉ាងគឺ លោកខ្យល់ លោកអាកាស លោកគន្ធារវ: លោកព្រះអាទិត្យ លោកព្រះចន្ទ លោកផ្កាយ លោកសម្រាប់ពពួកទេព្តា លោកព្រះឥន្ទ្រ លោកព្រះប្រជាបតិ និង លោកព្រះព្រហ្ម។ បណ្តាលោកទាំងអស់នេះ លោកនីមួយៗ មានសម្ព័ន្ធភាពភ្ជាប់ដូចជា តម្បាញតាំងពីក្រោមរហូតដល់លើបំផុត។ នៅក្នុងគម្ពីរតៃតិរីយ: អារណ្យក: គេបន្ថែម លោក ៤ ទៀតទៅក្នុងចំនួនលោកដែលយើងបានឃើញហើយទាំង ៣ គឺ ភូរ: ភូវ: និងស្វរ:។ លោករាប់ថា ភូរ: ភូវ: ស្វរ: មហារ: ជន: តប: និងសត្យ:។ គេបានបញ្ជាក់ថា លោក ៣ ខាងដើម ផលិតខ្សែគំនិតចេញមកពីជាតុ ៣ គឺ ដី អាកាស និង មេឃ នៃសម័យវេទ។ ឯ ៤ខាងចុង (មហារ: ជន: តប: សត្យ:) ជាលោកដែលគេរកឃើញថា ឋិតនៅខ្ពស់ជាងគេទាំង អស់។ នៅក្នុងគម្ពីរអារុណេយ ឧបនិសាទ គេបរិយាយថា លោកទាំង៧ (ភូរ: ភូវ: ស្វរ: មហារ: ជន: តប: សត្យ:) ចែក

---

[៣៦] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨៣

ចេញមកពីលោកខាងក្រោម ៧ទៀតគឺ ៖ អតលៈ បាតាលៈ វិតលៈ សុតលៈ រសាតលៈ មហាតលៈ និងពលាតលៈ។ ចំពោះលោកទាំង៧ ទាំងពីរបែបនេះ យើងថាមានការរីកចម្រើនជាកិយ្យាភាពនៅសម័យខាងក្រោយមកទៀត[៣៧]។

គ-សម័យមហាកំណាព្យ និងបូរាណ ៖ នៅសម័យមុន លក្ខណៈលោកជាតុមាន លំនាំជាឧបកថាទាំងស្រុង។ ទ្រឹស្តីដដែលនេះ ជាពិសេសត្រង់គោលការដ៏សំខាន់ គឺគម្ពីរបូរាណបានទទួលនិងធ្វើអត្ថាធិប្បាយដោយពិស្តារ។ ទ្រឹស្តីលោកជាតុ ត្រង់ការវិនាសនិងការប្រែប្រួលនៃលោកបានពោលថា មានលក្ខណៈ ៥យ៉ាង (បញ្ចលក្ខណៈ) នៅក្នុងគម្ពីរបុរាណ។ ទ្រឹស្តីលោកជាតុបូរាណនិងសម័យមុនទាំងពីរ នៅតែមានសកម្មភាពរហូតដល់សម័យ មហាកំណាព្យនិងបូរាណនេះដដែល ប៉ុន្តែនៅសម័យក្រោយនេះ មាននិន្នាការទៀងទាត់ចំពោះការរៀបចំឱ្យក្លាយទៅជាប្រព័ន្ធដ៏ត្រឹមត្រូវជាងពីសម័យមុន។ យើងសូមបញ្ជាក់ថា ទ្រឹស្តីលោកជាតុទាំងអស់នោះច្រើនតែយកចេញមកពីវេទ-អក្សរសាស្ត្រ ហើយធ្វើឱ្យមានការរីកចម្រើនជាមួយនឹងទ្រឹស្តីសម័យថ្មីខ្លះទៀត។ ជាពិសេស កត្តាចាស់និងថ្មីទាំងពីរនេះ បានរួមចូលគ្នាជាទ្រឹស្តីតែមួយនៃលោកជាតុ។ កត្តាទាំងអស់នោះមានដូចតទៅ នេះ ៖

១-ព្រះដ៏ធំជាងគេបង្អស់ គឺព្រះព្រហ្ម ឬអាត្ម័ន ដែលមានលក្ខណៈប៉ុនគ្នានឹងនារាយនៈ វិស្ណុ ឬ សម្ភូ នៃមតិអ្នកនិពន្ធរបស់ក្រុម ឬបក្សផ្សេងៗគ្នា។

២-អាទិកប្បិកៈ ឧទកៈ ទឹកជារបស់អាទិក័ប្ប និងលោកន្ធការ។

៣-បុរុម ឬ ហិរណ្យគភ៌ ដែលកើតចេញមកពីទឹកជាអាទិក័ប្ប ឬ លោកកន្ធការ។

៤-លោកណ្ឌៈ លោកមានស៊ុត ដែលកើតបានជាព្រះពុទ្ធ ឬ ប្រជាបតិ ឬក៏បិតាមហៈ។

៥-បទុមៈ ផ្កាឈូក ដែលព្រះព្រហ្មកើតចេញមកពីនោះ ហើយជាឈូកហ្នឹងឯងដុះលូតលាស់ចេញមកពីទឹក ឬពីផ្ចិតនៃព្រះវិស្ណុ (From the Navel of Visnu) ។

៦-លោកកើតចេញមកពីព្រះព្រហ្មត្រង់តែម្តង ដែលគេហៅថា ចេតបុត្រនៃព្រះព្រហ្មមាន ៧យ៉ាងមាន អត្តៈ មរីចិ ជាដើម។

៧-លោកមានលក្ខណៈកើតនិងវិនាសទៅវិញជាធម្មតា តាមកម្លាំងជាតុ (មើលក្នុងគម្ពីរស្វេតាស្វតារៈ និងម៉ៃត្រាយានៈឧបនិសាទ)។

---

[៣៧] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨៤

គួរកត់សម្គាល់ថា កត្តាទី៧ខាងក្រោយនេះ គេធ្វើឱ្យរីកចម្រើនឡើងដើម្បីសម្រុះសម្រួលខាងខ្សែគំនិតនៃលោកធាតុដែលមានមកតាំងពីសម័យវេទ ព្រាហ្មណៈ និងឧបនិសាទ។ ប៉ុន្តែលក្ខណៈទ្រឹស្តីនេះទាក់ទងគ្នាជានិច្ច មួយកើតឡើងព្រោះអាស្រ័យមួយទៀតជាលំដាប់។ ប្រព័ន្ធនៃលោកធាតុនេះ ជារបស់ទស្សនវិជ្ជាសំខ្យា មានមកយ៉ាងពិស្តារក្នុងគម្ពីរមហាភារតៈនិងបុរាណៈ។ យើងសូមបញ្ជាក់ថា ទ្រឹស្តីលោកធាតុនៃប្រព័ន្ធសំខ្យា យើងបានពោលខ្លះមកហើយក្នុងការរីកចម្រើននៃព្រះពុទ្ធសាសនា ត្រង់មូលហេតុទី (៦) ខាងដើម ប៉ុន្តែនៅទីនេះ យើងសូមបញ្ជាក់ប្រព័ន្ធទ្រឹស្តីនេះបន្ថែមបន្តិចតទៅទៀត ដូចនេះ ៖

"លោកនេះកើតឡើងពីធាតុសំខាន់ពីរជាដើមចម-ជាអាទិគឺ បុរុមៈ (អាត្ម័ន) និងប្រក្រតិ ឬប្រធាន (ធម្មជាតិដើមបំផុត) ឬក៏រូប (Matter) ដែលបង្កើតជាគុណភាព (គុណៈ) ៣ បែបទៀតគឺ តមៈ (ងងឹត), រជៈ (ធូលី) ឬ (សកម្មភាព) និងសត្តៈ (ជាប់)។ ទាំង៣នេះ មានតុល្យភាពស្មើគ្នា។ កាលណាធាតុ ឬគុណភាពទាំងអស់នៃប្រក្រតិ មានសហវិជ្ជមាន (Co-existence) ជាមួយនឹងបុរុមៈ (អាត្ម័ន) ហើយពេលនោះទើបមានមហាន ឬ ពុទ្ធិ ចេតសិកសម្បទ័ ដែលមានប្រក្រតិជាមូលដ្ឋាន។ កាលបើមានពុទ្ធិហើយអហង្ការៈក៏កើតមានដែរ កាលបើអហង្ការៈ (មានមុខងារជាអ្នកបង្កើតសញ្ញានៃបុគ្គលភាព) មនៈក៏កើតមានដែរ គឺបញ្ចពុទ្ធិន្ទ្រិយៈ, បញ្ចកម្មិន្ទ្រិយៈ និងបរិត្ត បញ្ចរូបិន្ទ្រិយៈ ហើយឥន្ទ្រីយ៍ទាំង៣ បែបនេះ មានបច្ច័យទាក់ទងគ្នាជានិច្ច ទើបបង្កើតបានមហាភូតរូប ៥បែបទៀតគឺ អាកាសៈ ភ្លើង ខ្យល់ ទឹក ដី។ រួមធម្មកត្តាទាំងអស់ (បរុម, ប្រក្រតិ, តមៈ, រជៈ, សត្តៈ) បញ្ចាពុទ្ធិន្ទ្រិយៈ៥, បញ្ចកម្មិន្ទ្រយៈ ៥, បរិត្តបញ្ចរូបិន្ទ្រិយៈ៥, អាកាសៈ, ភ្លើង, ខ្យល់, ទឹក និងដី) ជា២៥យ៉ាង ជាអង្គនៃរចនាសម្ព័ន្ធនៃលោក របស់ប្រព័ន្ធទស្សនវិជ្ជាសំខ្យា"[៣៨]។

តាមហេតុការណ៍ដូចខាងលើ យើងឃើញថាអ្នកនិពន្ធនៃមហាភារតៈ មានបំណងចង់សម្រុះសម្រួលទ្រឹស្តីសម័យមុនឱ្យ មានលក្ខណៈស្របជាមួយនឹងទ្រឹស្តីដែលមានមកហើយក្នុងគម្ពីរឧបនិសាទ។ ប៉ុន្តែមានចំណុចពីរដែលមានលក្ខណៈមិនស្របគ្នាទាល់តែសោះ ហើយយើងពុំដឹងថា តើចំណុចនោះៗ មានឥទ្ធិពលខ្សែគំនិតពីប្រភពណាមួយឡើយ។ ឯចំណុចទាំងពីរបែបនោះគឺ ៖

[38] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨៥

១-ជំនឿដ៏មាំមួនក្នុងអាទិហេតុ ឬព្រះព្រហ្ម ឬក៏អាត្ម័ន មានការប្រឆាំងជាដាច់ខាត ចំពោះធម្មកត្តាជាអាទិហេតុនៃលោករបស់ទ្រឹស្តីសំខ្យាគឺ បុរុម: និងប្រក្រតី ហើយទាំងពីរនេះ ក្នុងការស្ថាបនាលោក ត្រូវតែជាបច្ច័យដល់គ្នានិងគ្នាទៅវិញទៅមកៗ គេមិនអស្ចារ្យសោះ ឡើយ ចំពោះឧត្តមគតិដ៏ធំទូលាយនេះ ដែលមានលក្ខណៈផ្សេងស្រឡះពីគ្នាៗ ឧទាហរណ៍ ៖ បុរុម: ផ្សេងគ្នាពីប្រក្រតិ ឬ ប្រធាន, ហិរណ្យកគភ៌: ពីពុទ្ធិ និងព្រហ្ម ពីអហង្ការជាដើមៗ

២-ទ្រឹស្តីសំខ្យាថា ធម្មកត្តាជាមនៈក្តី ជារូបក្តី បង្កើតចេញមកពីអហង្ការៈទាំងអស់ ឯ មហាកំណាព្យថា បញ្ចមហាភូត កើតចេញពីអហង្ការៈ ដែលមានលក្ខណៈប្រហែលគ្នានឹង គម្ពីរឧបនិសាទ ដែលថាធាតុទាំងអស់នៃលោក កើតចេញមកពីព្រះព្រហ្មដូច្នោះដែរៗ ដូច្នេះ យើងឃើញថាមហាកំណាព្យ ធ្វើអត្ថាធិប្បាយរឿងនេះតាមលំអាននៃជំនឿ និងទំនៀមទម្លាប់ សុទ្ធសាធតែម្តង [៣៩] ម្យ៉ាងទៀត នៅសម័យមហាកំណាព្យនោះ មានទ្រឹស្តីលោកធាតុស្តែង ចេញយ៉ាងជាក់ច្បាស់ក្នុងគម្ពីរបុរាណៈ ហើយមានលក្ខណៈផ្សេងគ្នាស្រឡះពីទ្រឹស្តីលោក ធាតុនៃមហាកំណាព្យៗ មិនតែប៉ុណ្ណោះ យើងឃើញថា នីតិក្រមនៃមនុ (The laws of manu) ក៏បានពោលពីទ្រឹស្តីលោកធាតុដែរ ហើយមានលក្ខណៈស្របគ្នាជាមួយនឹងគម្ពីរបុរាណៈ សុទ្ធសាធ, ប៉ុន្តែមានការផ្សេងគ្នាស្រឡះពីសម័យមហាកំណាព្យៗ យើងគួរបញ្ជាក់លក្ខណៈ ទ្រឹស្តីលោកធាតុ តាមលំអាននៃគម្ពីរបុរាណៈ ដោយសង្ខេបដូចតទៅនេះ [៤០]៖

"លោកនេះ កើតឡើងជាពងនិងរូបខ្មៅងងឹត, គ្មានកត់សម្គាល់បាន, គ្មានសញ្ញា, គិតមិន យល់, ដឹងមិនបាន ព្រមទាំងស្ងួនឬដេកលក់ឥតកម្រើកៗ ព្រះស្វយម្ភូ ជាទេព្តាកើតឯង យើង ពុំអាចកត់សម្គាល់បានឡើយ ប៉ុន្តែអាចបង្កើតអ្វីទាំងអស់ ដែលគេអាចកត់សម្គាល់បាន មាន លក្ខណៈស្របជាមួយអំណាចនៃព្រះអង្គ ហើយអាចបញ្ចេញភាពងងឹតបានៗ ព្រះអង្គដែល គេអាចសង្កេតមើលអង្គខាងក្នុងបាន ល្អិតតូចច្មារ មិនអាចកត់សម្គាល់បាន, ទៀង, មាន សម្ភារៈសម្រាប់បង្កើត គឺព្រះអង្គបានបង្ហាញនិងបញ្ចេញ ព្រមទាំងបង្កើតអ្វីទាំងអស់តាម ព្រះទ័យរបស់ព្រះអង្គបានៗ ខ្លួនព្រះអង្គជាសម្ភារៈសម្រាប់បង្កើតដោយមានមានៈ ជាទឹកព្រះ ទ័យជាមូលដ្ឋានៗ ជាដំបូងព្រះអង្គទ្រង់បង្កើតទឹក ហើយទ្រង់បានដាក់ពូជកំណើតក្នុងទឹក នោះៗ ពូជកំណើតនោះ កកើតបានជាស៊ុត ពង មានពណ៌មាសភ្លឺថ្លាដូចជាវង់ព្រះអាទិត្យៗ

---

[៣៩] សូមមើល ៖ The Great Epics of India, N.Y. 1901, by E.Washburn Hoplcins

[៤០] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨៦

នៅក្នុងស៊ុតនោះ ព្រះព្រហ្មកើតឡើង ដែលគេទុកជាអ្នកបង្កើតលោកទាំងមូល។ គេហៅទឹកនោះថា "នរៈ" គឺតាមពិតទឹកនោះជាកូននៃ"នរៈ" ព្រោះទឹកជាលំនៅដំបូងបំផុតរបស់នរៈ ហៅថា "អាយណៈ" ព្រោះហេតុនោះ នរៈនោះឈ្មោះថា "នារាយណៈ"។ នារាយណៈនេះ គេទុកជាអាទិទេពហេតុ បង្កើតបុរុមៈ ភេទប្រុស ដែលល្បីល្បាញឈ្មោះថា "ព្រហ្មៈ"។ ទេវសភាវៈឋិតនៅក្នុងស៊ុតពេញមួយឆ្នាំ ហើយទេវសភាវៈ គឺព្រះព្រហ្ម ដែលគេទុកជាតួអាត្ម័ននៃលោក បានចែកស៊ុតនោះជាពីរផ្នែក មួយផ្នែកកើតបានជាឋានសួគ៌ និងមួយផ្នែកទៀតកើតបានជាផែនដីជាដើម"។

យើងសូមបញ្ជាក់ថា ទ្រឹស្តីលោកធាតុនៃគម្ពីរបុរាណ មានលក្ខណៈរីកចម្រើននៅសម័យក្រោយ ហើយទ្រឹស្តីវឌ្ឍនាការនៃប្រព័ន្ធទស្សនវិជ្ជាសាំខ្យា ក៏មានការប្រែប្រួលតាមលំនាំទ្រឹស្តីរបស់វេទាន្តៈទស្សនវិជ្ជាទាំងស្រុង ត្រង់លក្ខណៈឯកភាពនៃព្រះព្រហ្ម ដោយការសន្និដ្ឋានថា បុរុមៈ និងប្រក្រតី ទាំងពីរនេះគឺជាទេព្តាដ៏ខ្ពង់ខ្ពស់បំផុត ហើយព្រះព្រហ្មហ្នឹងឯងមិនគឺអ្វីក្រៅពីទេព្តាមួយអង្គដ៏ធំបំផុត ទ្រង់ព្រះនាមថា "វាសុទេវៈ Vasu Deva" នោះឡើយ។ នៅក្នុងព្រះវាសុទេវៈ មានធម្មសភាវៈ៣យ៉ាងគឺ បុរុមៈ អាត្ម័ន ប្រធាន ឬប្រក្រតិ និងកាលៈពេលជាដើម ឬអាទិហេតុសម្រាប់បង្កើតលោក។ កាលបើមានធម្មសភាវៈទាំង៣នេះហើយ ពុទ្ធិឬមហានៈ ក៏កើតឡើងអាស្រ័យនឹងធម្មសភាវៈទាំង៣នោះ។អហង្ការៈកើតឡើង អាស្រ័យនឹងពុទ្ធិ ឬមហានៈជាលំដាប់។ លក្ខណៈធម៌ទាំងអស់នេះ មានលំនាំដូចប្រព័ន្ធទស្សនវិជ្ជាសាំខ្យាសុទ្ធសាធ។

នៅក្នុងគម្ពីរវិស្ណុបុរាណៈ យើងឃើញប្រព័ន្ធនៃលោកចែកចេញជា ៣ផ្នែក ៖ ត្រៃលោក, ផ្នែកកណ្តាលគឺ ផែនដី ដោយមានភ្នំឈ្មោះ "លោកាលោកៈ" ព័ទ្ធជុំវិញមានផែនដីក្រឡាប្រាំរយលានយោជន៍។ ផ្នែកខាងលើផែនដីគឺ ឋានសួគ៌ ហើយផ្នែកខាងក្រោមផែនដីគឺ បាតាលៈ។ តាមពិតគេចែកលោកនេះជា ២ផ្នែកក៏មាន គឺខាងលើមាន ៧, ខាងក្រោមមាន៧, រួមជា ១៤។ ឯនីតិក្រមនៃមនុ (Laws of manu) ថាមាន២១[៤១]។

ឯផ្នែកទាំងពីរនៃលោកខាងលើ-ខាងក្រោម តាមគម្ពីរវិស្ណុបុរាណៈ គឺមានឋាននរកភ្ជាប់ជាមួយផង ត្រង់ផ្នែកខាងក្រោមបំផុតណាមួយនៃលោក។ លោកផ្នែកខាងក្រោម លើកលែងនរកចេញគឺ អតលៈ វិតលៈ និកលៈ គភស្តិម័ត មហាតលៈ សុតលៈ និងបាតលៈ។ លោក

[៤១] ប៉ែន សាអឿន ***សាសនាប្រៀបធៀប*** គ.ស.១៩៦៩ ទំ៨៧

*ផ្នែកខាងលើគឺ ភូរ: (ផែនដី), ជេវ្ា, ស្វរ:, មហារ:, ជន:, តប: និងសត្យ:។ ឯបាតាលលោក គឺគេហៅរួមលោកទាំង ៧ ខាងក្រោម មានទំហំលាតសន្ធឹងទៅក្រោម ៧០ពាន់យោជន៍ ពីខាងក្រោមផ្ទៃផែនដី ហើយលោកមួយៗមានជម្រៅទៅក្រោម ១០ពាន់យោជន៍ៗ តាបាលលោក គឺជាលំនៅនៃពួកនាគ ពពួកទៃត្យ: (អសុរ:) និងពួកទានវ: (យក្សអ្នកបម្រើ) មានលំអនិងសោភណភាពដូចឋានសួគ៌ដែរៗ នៅខាងក្រោមបាតាល: មានពួកនាគជាបរិវារ ជាអ្នកទ្រលោកទាំង៧ នៃឋានបាតាល, គេហៅថា "នាគសេវ:"ៗ ដូចបានពោលរួចហើយថា ឋាននរកត្រូវឋិតនៅឋានក្រោមបាតាលលោក ប៉ុន្តែកន្លែងដ៏ទៀងទាត់នៃនរកគេពុំអាចកំណត់បានពីព្រោះកន្លែងខ្លះពោលថានៅក្រោមទឹក ខ្លះថានៅខាងលើទឹកដែលព័ទ្ធជុំវិញលោកៗ ហេតុដែលផ្សេងគ្នានេះ ហាក់ដូចជាឱ្យយើងថាឋាននរកមិនឋិតនៅទីណាក្រៅពីឋានបាល:ឡើយៗ*

*ចំណែកលោកភាគខាងលើ បានដល់ភូរលោក ភូវលោកឬជេវ្ា ឋិតនៅជិតព្រះអាទិត្យៗ ស្វរលោក លាតសន្ធឹងតាំងពីព្រះអាទិត្យទៅដល់ពពួកផ្កាយ ជាលំនៅនៃពពួកទេវ្តា ទាំងឡាយៗ លោកទាំង៣នេះ លុះដល់ភ្លើងឆេះកប្ប ត្រូវវិនាសអន្តរាយដែរៗ បន្ទាប់ពីលោក នេះទៅ មានលោកមួយទៀតឈ្មោះថា មហារលោក ជាលំនៅនៃទេវ្តា ហើយលុះដល់ភ្លើង ឆេះកប្ប ក៏ត្រូវវិនាសទៅដែរ ប៉ុន្តែបន្ទាប់មក ពពួកទេវ្តាក៏ជួសជុលឡើងវិញៗ ជនលោក មិនវិនាសដោយភ្លើងកប្បឡើយ ហើយទីនេះជាឋាននៃទេវ្តាទាំងឡាយជាកូនចៅនៃព្រះព្រហ្មៗ ឯលោកទី៦ គឺតបលោក ជាលំនៅនៃបកស្សរទេវ្តា មានពន្លឺសន្ធោសន្ធៅៗ លោកដែលខ្ពស់ជាងគេ គឺសត្យលោកឬព្រហ្មលោក ជាលំនៅនៃព្រះព្រហ្ម ពុំដែលឮពាក្យថាស្លាប់ឬវិនាសអន្តរាយឡើយៗ*

*យើងត្រូវតែពោលពីសញ្ញាណខ្លះនៃគម្ពីរបូរាណ: ដែលមានលក្ខណ:ផ្សេងគ្នាត្រង់ពពួកសត្វដែលរស់នៅលើភូរលោក ភូវរលោក និងស្វរលោកៗ គម្ពីរបូរាណទាំងអស់នេះបានពោលហើយពីពពួកសត្វនោះៗ ថាមានលក្ខណ:ផ្សេងៗគ្នា ហើយពុំដូចគ្នាឡើយៗ ឯកម្ពស់នៃលោកទាំងអស់ចាប់តាំងពីភូរលោករហូតដល់សត្យលោក ឬព្រហ្មលោក មានលក្ខណ:ខ្ពស់ជាងគ្នាតាមលំដាប់ៗ គេរាប់ដូចនេះគឺ មហារលោកមានកម្ពស់ពីប្រេកពផ្កាយចំនួន១០លានយោជន៍ៗ ជនលោកមានចំនួន ២០លានពីលោកឈ្មោះថា តបលោក[៤២]ៗ*

---

[៤២] *ប៉ែន សាអឿន **សាសនាប្រៀបធៀប** គ.ស.១៩៦៩ ទំ៨៨*

នៅក្នុងគម្ពីរយោគភាស្យៈ នៅសតវត្សទី៧ នៃគ.ស. លោកវ្យាសៈ បានពោលពីលោកផ្សេងៗជាច្រើន មានលក្ខណៈពិស្តារជាងគម្ពីរបុរាណ ប៉ុន្តែមានលំនាំដូចជាគម្ពីរបុរាណដែរ។ ប៉ុន្តែ គួរឱ្យចម្លែកដែរថាគម្ពីរនេះ មានលំនាំអត្ថាធិប្បាយដូចគ្នានឹងគម្ពីរព្រះពុទ្ធសាសនាត្រង់កន្លែងខ្លះ ហើយបញ្ជាក់ថា សត្វដែលកើតនៅទីនោះ គឺដោយអំណាចកម្លាំងសីលនិង សមាធិ។ គម្ពីរនោះ ជំណាលថាលោកទាំងអស់ឋិតនៅក្នុងលោកកណ្ឌៈ (ស៊ុតលោក) មិនគឺ អ្វីក្រៅពីផ្នែកដ៏ល្អិតតូចឆ្មារនៃកម្លាំងជាតុរបស់ប្រធានៈ ឬប្រក្រតិឡើយ, មាន៧យ៉ាងខ្ពស់ ជាងគេជាលំដាប់។ លោកដែលទាបជាងគេបង្អស់គឺ ភូរលោក លាតសន្ធឹងតាំងពីឋាននរក ខាងក្រោមបង្អស់ រហូតដល់ភ្នំព្រះមេរុ។ លោកទី២ឈ្មោះថា អន្តរិក្សលោក លាតសន្ធឹងរូម ទាំងពពួកផ្កាយទាំងអស់។ ទី៣ឈ្មោះថា ស្វរលោក ឬម៉ាហិន្ទ្រលោក, ទី៤ ឈ្មោះថា មហារលោក ឬប្រជាបត្យលោក, ឯទី៥ ទី៦ និងទី៧ ឈ្មោះថា ជនៈ តបៈ និងសត្យលោក។ លោកទាំង៣នេះគឺជាព្រហ្មលោក។ ឯភូរលោក បានដល់ឋាននរកទាំងអស់ ឋានបាតាលៈ និងផែនដី។ នៅខាងបាតនៃភូរលោក មានឋាននរក ៧គឺ អវីចិ យនៈ សលិលៈ អនលៈ អនិលៈ អាកាសៈ និងតំប្រតិស្ឋៈ។ យើងឃើញថាលើកលែងតែអវីចិមួយចេញ នរកដទៃ ទៀតហាក់មានលំនាំដូចគ្នានិងគម្ពីរបុរាណៈដែរ។ ដោយស្នាទឋាននរកនីមួយៗនៃបណ្ដាឋាននរកទាំង៦នោះ មានឈ្មោះផ្សេងទៅវិញ ដូចលោក វ្យាសៈបានពោលថា "មហាកាលៈ អម្ពរីសៈ រោរវៈ មហារោរវៈ កាលសូត្រៈ និងអន្ធតាមិសនៈ" ហើយមានឋានបាតាល ៧ ឋិតនៅខាងលើឋាននរកទាំងអស់នោះគឺ មហា-តលៈ រសាតលៈ អតលៈ សុតលៈ វិតលៈ តលាតលៈ និងបាតាលៈ។ នៅខាងលើបាតាលទាំង៧នេះ គឺលោកទី៨ (ផែនដី) ឈ្មោះថា វសុមតី ប្រកបដោយទ្វីប៧ និងមហាសមុទ្រ។

ចំពោះសត្វដែលរស់នៅក្នុងឋានទី៧នេះ យើងសង្កេតឃើញដូចតទៅនេះ ៖

១-នៅក្នុងឋានបាតាល មហាសមុទ្រ ភ្នំ និងផែនដី មានក្រុមសត្វលោករស់នៅគឺ ពួកអសុរ គន្ធវៈ កិន្នរៈ កីបុរុសៈ យក្សៈ រាក្សសៈ ភូតៈ ប្រេតៈ អបស្មារក្សៈ អប្សរៈ ព្រហ្មរក្សៈ កូស្មាណ្ឌៈ និងវិនាយកៈ។ នៅលើទ្វីបទាំង៧ មានពពួកទេព្តានិងមនុស្សលោក ហើយនៅលើភ្នំព្រះមេរុមានសួនឧទ្យានឈើនិងផ្កាយ៉ាងត្រចះត្រចង់ជាលំនៅឋាននៃពពួកទេព្តាទាំងឡាយ។

២-នៅក្នុងឋានអន្តរិក្សលោក មានសុទ្ធតែពពួកវិមានអណ្តែតនៃផ្កាយទាំងអស់។

៣-នៅក្នុងឋានមហិទ្ធិលោក មានពួកទេវតា ៦ក្រុមគឺ ត្រីទស: អគ្គិស្វាត: យាម្យ: តុសិត: អបរិនិតិវសវ័តី និង បរិនិមិតិវសវតី។

៤-នៅក្នុងឋានប្រជាបត្យាលោក មានពួកទេវតា ៥ក្រុមគឺ ៖ កុមុទ: រិភុ ប្រតជិន អញ្ជនាភ: និងប្រចិតាភ:។

៥-នៅក្នុងឋានជនលោក មានពួកព្រហ្ម ៤ក្រុមគឺ ៖ ព្រហ្មបុរោហិត ព្រហ្មកាយិក: ព្រហ្មមហាកាយិក: និងអមរ។

៦-នៅក្នុងឋានតបលោក មានពួកព្រហ្ម ៣ក្រុមគឺ អាភាស្វរ: មហាភាស្វរ: និងសត្យមហាភាស្វរ:[៤៣]។

៧-នៅក្នុងឋានសត្យលោក មានព្រះព្រហ្ម ៤ ក្រុមគឺ ៖ អច្យុត: សុទ្ធាវាស: សត្យាភ: និងសញ្ញាសញ្ញី។

គួរកត់សម្គាល់ថា តាំងពីពួកទេវតានៃឋានប្រជាបត្យាលោករហូតដល់ពួកព្រហ្មនៅក្នុងឋានសត្យលោកទាំងអស់ ត្រូវរស់នៅដោយកម្លាំងឈាន អំណាចនិងរយៈវេលានៃជីវិតមានលក្ខណៈជាលទ្ធិភាពនៃអំពើដែលខ្លួនប្រកបនៅក្នុងលោកខាងក្រោម។ ឯព្រះព្រហ្មនៅក្នុងឋានតបលោក គ្មានឱកាសចុះទៅកើតក្នុងឋានខាងក្រោមទៀតឡើយ។ ចំពោះព្រះព្រហ្មនៅក្នុងសត្យលោក ត្រាស់ដឹងដោយអំណាចអរូបឈាន ៤ គឺ សវិតក៌ សវិចារ: អានន្ទមាត្រា និងអសមិតាមាត្រា។ នៅក្នុងបាតញ្ជលី យោគសូត្រៈនៃហិណ្ឌូ និងនៅក្នុងគម្ពីរតត្វាប៉ាធិគមសូត្រ នៃលទ្ធិជេនអ្នកនិពន្ធបានបញ្ជាក់ថា ការត្រាស់ដឹងនូវរចនាសម្ព័ន្ធនៃលោកទាំងអស់នោះ សម្រេចដោយសមាធិតែម្យ៉ាង។

ដូចពោលមកខាងលើនេះ យើងឃើញច្បាស់ថា ទ្រឹស្តីលោកធាតុនៃគម្ពីរបុរាណទាំងអស់ មានលក្ខណៈជាជំនឿសុទ្ធសាធ មិនអាចធ្វើឱ្យប្រែប្រួលបានឡើយ។ ទោះណាជាមានអ្នកតារាសាស្ត្រខ្លះបានទំសម្រុះសម្រួលនូវលោកធាតុសាស្ត្រតាមប្រពៃណី នោះឱ្យស្របទៅតាមវិទ្យាសាស្ត្រខាងផ្កាយ (តារាសាស្ត្រ) ក៏ដោយ។ ក្នុងការសម្រុះសម្រួលឧត្តមគតិនេះ យើងបានឃើញក្នុងគម្ពីរសុយ៌ សិទ្ធាន្ត: ដូចតទៅនេះ ៖

---

[43] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៨៩

"ព្រហ្មាណ្ឌ: (ស៊ុតព្រះព្រហ្ម) ប្រហោងក្នុង ហើយនៅក្នុងប្រហោងនោះ មានលោកប្រកបដោយផែនដី អាកាសជាដើមៗ នៅក្នុងស៊ុតនោះ មានរាងជាអវកាស មានលំនាំដូចជាកំសៀវដាំទឹកមួយគូៗ រង្វង់មូលខាងក្នុងនៃព្រហ្មាណ្ឌ: មានសភាពជាអវកាស (Orbit)ៗ

ប្រកបដោយធាតុអាកាសដ៏ល្អិត (Ether-វេហ្ម័ន) ហើយនៅក្នុងនោះមានលោកជារាងឬសណ្ឋានផ្កាយ (Asterisms-កវ:) វិវឌ្ឍនាការឡើងបន្ទាប់បន្តគ្នាគឺ វរិសុតលោក (Saturn) , សុរគុរុលោក (Jupiter), គុជគហលោក (Mars), អាទិត្យលោក (Sun), សុក្រលោក (Venus), ពុធលោក (Mercury), ចន្ទ្រលោក (Moon), សិទ្ធលោក (The Perfected), វិទ្យាធរលោក (Possessors of knowledge) និងពពក (Clounds)ៗ នៅក្នុងព្រហ្មាណ្ឌ:នោះ មានរន្ធ៧ជាលំនៅនៃនាគ, អសុរ:, ដើមឈើជាម្ចាស់ (ធំ) នៃឋានសួគ៌ជាច្រើន, ឋានបាតាលនិងដែនដីៗ ឯរតនវត្ថុគ្រប់បែប, សុវណ្ណបព៌តឋិតនៅលើភ្នំមេរុ ត្រង់ពាក់កណ្ដាលសាកល លោក... ជាដើមៗ នេះគឺជាផ្កាយនុពគ្រោះមាន៩យ៉ាង[៤៤]ៗ

## ២-ព្រះពុទ្ធសាសនា

### ក-កថាមុខ

១-នៅសម័យមុនបំផុត គេបានចាត់ទុកទ្រឹស្ដីលោកធាតុទាំងអស់ថា មានលក្ខណ:មិនពិតប្រាកដនិងមានកំហុសយ៉ាងច្រើនមហិមាៗ យើងអាចរំឭកឃើញនូវពុទ្ធចរិយា ចំពោះពាក្យប្រៀនប្រដៅរបស់គណាចារ្យជាច្រើន ត្រង់ភាពឥតព្រំដែន និងមានព្រំដែនតូចអំពីរឿងលោក ហើយទ្រង់បានព្យាយាមប្រឹងប្រែងជាទីបំផុតតាមពុទ្ធកិច្ចឥតឈប់ឈរទេសនាប្រៀនប្រដៅសិស្សសាវ័ករបស់ព្រះអង្គឱ្យយល់ច្បាស់នូវធម្មធាតុគ្រប់បែប ដែលទាក់ទងដល់សីលធម៌ប្រចាំជីវិតទាំងផ្នែកសម្ភារ: ទាំងផ្នែកចិត្ត មានអត្ថន័យប្រកបដោយប្រយោជន៍សម្រាប់ការស្រាវជ្រាវរបស់វិទ្យាសាស្ត្រធម្មជាតិៗ នៅក្នុងគម្ពីរទីឃនិកាយយើងឃើញថាមានភិក្ខុមួយអង្គក្រាបបង្គំទូលសួរព្រះពុទ្ធជាម្ចាស់ ចង់ដឹងថា តើមហាភូតដូចជាធាតុដី ទឹក ភ្លើង និងខ្យល់ជាដើម បញ្ឈប់សកម្មភាពរបស់ខ្លួនត្រឹមណាៗ និមិត្តតែបានឮប្រស្នានេះភ្លាមព្រះពុទ្ធជាម្ចាស់បានបញ្ជាក់ចំពោះហេតុការណ៍ទូទៅ នៃការសម្រេចធម៌ជាន់ខ្ពស់របស់សិស្សសាវ័ក រួចហើយទ្រង់បញ្ជាក់ថា អ្នកដែលបានរួចចាកតណ្ហា អ្នកនោះនឹងលែងកើតក្នុងលោកនេះទៀតហើយៗ

---

[៤៤] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩០

សេចក្តីបញ្ជាក់នៃព្រះពុទ្ធ សឱ្យឃើញថាមានសភាពច្បាស់លាស់ក្នុងបញ្ហាលោកនេះៗ តាមពិត លោកខាងក្រៅអាចបិតនៅនិងវិជ្ជមានទៅបាន អាស្រ័យនឹងម្នាក់នៅមានអារម្មណ៍ជាប់ក្នុងរឿងនោះៗ

ហេតុការដ៏សំខាន់មួយទៀត ដែលយើងគួរបញ្ជាក់ពី ហេតុអ្វីបានជាទ្រឹស្តីលោកធាតុនៅក្នុងព្រះពុទ្ធសាសនាពុំមានលក្ខណៈពិស្តារ ស្តែងដោយសិស្សសាវកដែលមានគិតដល់, តាមពិត កាលដែលព្រះពុទ្ធគង់ធរមាននៅឡើយ ទ្រង់បានហាមដល់សិស្សសាវករបស់ព្រះអង្គកុំឱ្យគិតដល់បញ្ហាដែលហួសនិស្ស័យខ្លួន គឺកុំគិតដល់បញ្ហាលោកនេះជាដើម ដែលហៅថា "អចិន្តេយ្យបញ្ហា" ។ ក្នុងស្ថានហេតុប្រកបដោយតក្កវិទ្យានេះ យើងឃើញថា ការយល់ច្បាស់ និងការត្រាស់ដឹងចំពោះលោកធាតុ ជាការៈលើព្រះពុទ្ធជាម្ចាស់ សម្រាប់ដោះស្រាយនិងតទល់ជាមួយនឹងគណាចារ្យអ្នកលទ្ធិសាសនា ព្រមទាំងជាអ្នកលោកធាតុវិទូនៅជំនាន់នោះ ដែលឥណ្ឌាសម្បូរដោយអ្នកទស្សនវិទូជាទីបំផុត ព្រោះហេតុនោះ បានជាយើងឃើញថានៅក្នុងសូត្រផ្សេងៗជាច្រើន ព្រះពុទ្ធជាម្ចាស់បានសម្តែងរឿងលោកធាតុនេះមានលក្ខណៈរ៉ាត់រាយ ឯណោះខ្លះ ឯណោះខ្លះ ទៅតាមពេលវេលា និងសម័យដែលទ្រង់បានជួបជាមួយនឹងគណាចារ្យណាមួយៗ

យ៉ាងណាក៏ដោយ យើងឃើញថា នៅពេលមុនការបែកនិកាយជាពីរធំៗ ក៏លោកធាតុវិទ្យាពុំទាន់មានលក្ខណៈជាប្រព័ន្ធ ដោយការប្រមូលឧត្តមគតិទាំងអស់ទុកក្នុងកន្លែងតែមួយឡើយៗ លុះដល់សម័យការបែកនិកាយធំៗកើតឡើង ទើបយើងឃើញថា និកាយមហាយានបានប្រតិស្ឋរឿងលោកធាតុទ្រឹស្តីនេះឱ្យមានលក្ខណៈជាប្រព័ន្ធ អាចតទល់ជាមួយនឹងវិទ្យារបស់ពពួកគ្រហស្ថបាន[៤៥]ៗ

២-ចំពោះអត្ថន័យនៃលោក យើងបានសង្កេតឃើញនិងប្រមូលឯកសារសេមោជានខ្លះដូចតទៅនេះ[៤៦]៖

តាមអភិធម្មៈនៃនិកាយសវស្តិវាទ ពាក្យថាលោកធាតុវិទ្យាក្លាយពីពាក្យថា "លោកប្បបញ្ញត្តិ" ជាបញ្ញត្តិនៃលោក បានដល់លក្ខណៈសិក្សាពីកំណើតដើម, ការរៀបរយឬចេតនាសម្ព័ន្ធនិងការវិនាសទៅនៃលោកៗ លោកប្បញ្ញត្តិនៃនិកាយនេះ មិនមែនពោលតែពីការស្តាប

[៤៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩១

[៤៦] សូមមើល ៖ "Encyclopaodia of Religion and Ethics", Vol.4, edited by James Hastings, p.130-138

នានិងការវិនាសទៅវិញនៃលោកនេះប៉ុណ្ណោះទេ គឺលោកពោលថា លោកនេះចែកចេញជា២ប្រភេទ ៖ គឺភាជនលោក និងសត្វលោកថែមទៀត។ ដូច្នេះភាជនលោកបានដល់លោកធាតុសិក្សា ឯសត្វលោក បានដល់សត្តវិទ្យា (Cosmology & Zoology) ប៉ុន្តែលោកទាំងពីរ នេះមានការទាក់ទងគ្នាជានិច្ច គឺភាជនលោកសម្រាប់សត្វលោករស់នៅ។ ភូតសិក្សា មនុស្សសិក្សា និងទេវសិក្សា ក៏ត្រូវបញ្ចូលទៅក្នុងការសិក្សាលោកធាតុវិទ្យាទាំងអស់។ ទោះណាជាលោកទាំង២ នេះមិនមានចែកចេញឱ្យដាច់ពីគ្នាក៏ដោយក៏យើងឃើញថា គេអាចបញ្ជាក់ពីលក្ខណៈសំខាន់និងពិតប្រាកដជាពិសេសចំពោះការពិត តាមប្រភពដែលទាក់ទងដល់ភាជនលោកដែរ លំនៅឋាននៃពពួកទេព្តា អាយុវែងឬខ្លី ទំហំខ្លួន ព្រមទាំងកំណើតឬជាតិ។ ឯចិត្តវិទ្យាទាក់ទង ដល់កម្ម ឬការងាររបស់សត្វលោកទាំងល្អទាំងអាក្រក់ ដែលសត្វលោកត្រូវប្រកបចាប់តាំង ពីសត្វតូចល្អិត រហូតដល់ពពួកទេព្តា, ព្រះព្រហ្មជាដើមឡើងទៅ។ សត្វទាំងអស់នេះ មាន កន្លែងឬលំនៅខុសគ្នា ប៉ុន្តែមានធាតុដើមដូចគ្នា គ្រាន់តែល្អិតនិងគ្រោតគ្រាតជាងគ្នាប៉ុណ្ណោះ។

យ៉ាងណាក៏ដោយយើងសង្កេតឃើញថា ដើម្បីឱ្យយល់ច្បាស់នូវប្រព័ន្ធនៃលោក យើងគួរតែដឹងជាចាំបាច់នៃសត្វលោក។ គេចែកសត្វលោកជា៣ក្រុមគឺ ១-អរូបសត្វលោក (Immaterial beings) ជាក្រុមសត្វដែលមិនឋិតនៅក្នុងភាជនលោកនេះទេ។ ២-រូបសត្វលោក (Material beings) ជាសត្វដែលកើតឡើងពីធាតុដ៏ល្អិតតូចឆ្មារ ឋិតនៅក្នុងភាជនលោកខាងលើ។ ៣-កាមសត្វលោក ជាសត្វកើតឡើងពីកម្លាំងធាតុដ៏គ្រោតគ្រាត ឋិតនៅក្នុងកាមាវនរលោក ឬភាជនលោកភាគខាងក្រោម។ ទាំងអស់នេះ គេបរិយាតាមលំអាននៃគម្ពីរអភិធម្មៈនៃនិកាយសវស្តិវាទនៃមហាយាន[៤៧]។

៣-ប្រភព ៖ ព្រះគម្ពីរទាំងឡាយនៃព្រះពុទ្ធសាសនា ដែលយើងទុកជាមូលដ្ឋានឯកសារគឺ ៖ អភិធម្មសាស្ត្រនៃនិកាយសវស្តិវាទ អភិធម្មកោសៈនៃលោកត្រូវសុតន្ទុ, អភិធមិ កោសវ្យាក្យានៃលោកគ្រូយសោមិត្រៈ គម្ពីរភាសាទីបេត៍ឈ្មោះថា ក័លបទ្រុមៈដោយសរ៉េដ ធន្រ្ទៈ Catena of Buddhist Seriptures ដោយលោក S.Beal។ គម្ពីរអភិធម្មវិកង្គប្បករណៈ ត្រង់បច្ចយាការវិភង្គៈ, អវសានកិច្ចនៃព្រះមុនី អ៊ុម-ស៊ូ, Manual of Abhidhamma ដោយ លោកគ្រូនារទៈ នៃប្រទេសសិរីលង្កា និងវិសុទ្ធិមគ្គបាលីនៃពុទ្ធឃោសៈ។

---

[47] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩២

**មូលប្រតិស្ឋនៃលោក** (Foundation of the Universe)

១-យើងសង្កេតឃើញថា នៅពេលដែលព្រះអានន្ទៈក្រាបបង្គំទូលសួរព្រះពុទ្ធជាម្ចាស់ពីហេតុនៃការកម្រើកផែនដី ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលអានន្ទៈ ផែនដីដ៏ធំនេះស្ថាបនាឡើងនៅលើទឹក ទឹកនៅលើខ្យល់ ខ្យល់ឋិតនៅលើអាកាសឬអវកាស។ ម្នាលអានន្ទៈ នៅពេលខ្លះ ខ្យល់បក់បោកយ៉ាងខ្លាំងបណ្ដាលឱ្យទឹករញ្ជួយ ឬកម្រើកយ៉ាងខ្លាំងបណ្ដាលឱ្យ ផែនដីរញ្ជួយយ៉ាងខ្លាំង បណ្ដាលឱ្យផែនដីរញ្ជួយ ឬកម្រើកបាន (សូមមើលគម្ពីរទីឃនិកាយ សុត្តន្តបិដក, វិទ្យាវទានៈ, អង្គុត្តរនិកាយ និងមជ្ឈិមនិកាយ)។ ម្យ៉ាងទៀត មានព្រាហ្មណ៍ ម្នាក់ឈ្មោះកស្សបៈ បានក្រាបបង្គំសួរព្រះពុទ្ធជាម្ចាស់ថា "បពិត្រព្រះអង្គដ៏ចម្រើន តើផែន ដីឋិតនៅលើអ្វី?" ព្រះអង្គត្រាស់ថា "ផែនដីឋិតនៅលើទឹក, តើទឹកឋិតនៅលើអ្វី? ទឹកឋិតនៅ លើខ្យល់, តើខ្យល់ឋិតនៅលើអ្វី? ខ្យល់ឋិតនៅលើអាកាស, តើអាកាសឋិតនៅលើអ្វី? ម្នាល ព្រាហ្មណ៍ អ្នកឯងសួរនេះហួសការធម្មតាហើយ ចូរអ្នកដឹងថា អាកាសគ្មានឋិតនៅលើអ្វីឡើយ វាគ្មានអ្វីទ្រវាឡើយ" ជាដើម។

២-នៅក្នុងលក្ខណៈទូទៅនៃពុទ្ធនិយម យើងឃើញថាសត្វទាំងឡាយ មានការកើតជាខាងដើម មានការស្លាប់ឬវិនាសទៅវិញជាទីបំផុតឬជាចុងក្រោយបង្អស់។ ដូច្នេះ ការកើតនិងការស្លាប់ ឬវិនាសទៅវិញនៃសត្វលោកព្រមទាំងលោក លោកចាត់ទុកជាសភាវៈ ពិតតាមធម្មជាតិនិងប្រក្រតីដើម។ តាំងពីការកកើតរហូតដល់ការស្លាប់ឬវិនាសទៅវិញ សត្វលោកនិងលោកទាំងឡាយ ត្រូវឋិតនៅក្នុងអំណាចត្រៃលក្ខណ៍ទាំង ៣ នៃលោកធាតុ (Three characteristics of the cosmo)គឺ៖ ទុក្ខៈ (Undergoing or Suffering), អនិច្ចៈ (Impermanence or Morphology) និងអនត្តា (Soullessness or substancelessness or nothingness)។ កម្លាំងធាតុដែលផ្សំជារូបឡើងមានកម្រិតអាយុរបស់វា អាស្រ័យនឹងការអភិបាលដោយត្រឹមត្រូវនិងប្រុងប្រយ័ត្នផង។ ទុក្ខៈ អនិច្ចៈ និងអនត្តា ទាំង៣នេះ ជាសភាវៈប្រព្រឹត្តទៅក្នុងចន្លោះនៃរូបប្បវត្តិកាល។ នៅក្នុងចក្រវាលសភាវៈទាំង៣នេះឋិតនៅ ក្រោមអំណាចការគ្រប់គ្រងនៃធាតុបរមាណូ ដែលបណ្ដាលឱ្យមានថាមពលសម្រាប់បក់បង្វិលឱ្យធាតុបែកចេញពីគ្នាក៏បានឱ្យធាតុប្រមូំចូលគ្នាជាធម្មរូបឡើង(Phenomenal matters) ដូចជាការផលិតឡើងនិងសកម្មភាពជាក់ស្ដែង នៃបាតុភូតនៃផ្ទេកបន្ទោលផ្គររន្ទះ ភ្លៀងជាដើមក៏បាន[48]។

[48] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩៣

យើងសង្កេតឃើញថា ព្រះពុទ្ធជាម្ចាស់ទ្រង់លើកយក "ការកើតការស្លាប់មិនចេះឈប់ឈរ ដែលហៅថា វដ្តសង្សារនៃលោក" នេះ ជាគម្រោងការសម្រាប់ស្វែងរកការត្រាស់ដឹងនៃព្រះអង្គ។ អស់រយៈពេល៦ឆ្នាំ ព្រះពុទ្ធទ្រង់សិក្សានិងរៀនអនុវត្តក្នុងសំណាក់គណាចារ្យជាច្រើន ដែលជាជំហានឱ្យព្រះអង្គទ្រង់ត្រាស់ដឹងនូវអសង្ខតធម៌ ជាពិសេសនូវសង្គមធម៌យ៉ាងជាក់ច្បាស់។ ទុក្ករកិរិយា ៦ឆ្នាំនេះ នឹងថាឥតប្រយោជន៍ក៏មិនបាន ព្រោះដែលព្រះអង្គទ្រង់ធ្វើយ៉ាងនេះ គឺព្រះអង្គទ្រង់យល់ច្បាស់នូវមូលវិទ្យា ហើយយើងអាចចាត់ទុកថាមានលក្ខណៈស្របជាមួយនឹងពិសោធន៍វិទ្យា សម្រាប់ការស្រាវជ្រាវរាវរកការត្រាស់ដឹងនូវសច្ចធម៌នោះឯងហើយ។ បន្ទាប់មកហើយជាទីបំផុត ព្រះអង្គទ្រង់លះបង់ទុក្ករកិរិយាទាំងអស់នោះចេញ ហើយទ្រង់សោយចង្ហាន់ដូចធម្មតាវិញ។ នៅពេលនោះ ទ្រង់លើកយកពិធីសមាធិចិត្តមកអនុវត្តវិញ។ ជាដំបូងទ្រង់រាវរកកំណើតឬបដិសន្ធិ និងច្យុតិនៃសត្វលោកព្រមទាំងលោក ដោយទ្រង់លើកយក "បដិច្ចសមុប្បាទន័យនិងបដ្ឋានន័យ" មកពិចារណាបណ្ដោយ-ច្រាស់ និងច្រាស់-បណ្ដោយ ហើយទ្រង់ត្រាស់ដឹងច្បាស់ថា "សត្វលោកនិងលោកកើតឡើងនិងវិនាសទៅវិញ ដោយអំណាចកម្លាំងធាតុទាំងអស់" កាលបើត្រាស់ដឹងហើយ ទើបទ្រង់រាវរកការដោះស្រាយការរៀបចំពិធីអនុវត្តន៍តទៅទៀត។ យើងគួរបញ្ជាក់ថា ការត្រាស់ដឹងនៃព្រះពុទ្ធនេះ លោកឱ្យឈ្មោះថា "សម្មាសម្ពោធិញ្ញាណ ឬការត្រាស់ដឹងនូវអរិយសច្ចៈទាំង៤"។

ន័យធម៌ទាំង២នេះ ព្រះពុទ្ធឃោសាចារ្យបានធ្វើអធិប្បាយទុកក្នុងគម្ពីរវិសុទ្ធិមគ្គអដ្ឋកថានៃបិតកទាំងមូលដោយពិស្ដារ ដោយរួមគ្នា។ ន័យធម៌ទាំងពីរនេះ អ្នកប្រាជ្ញសម័យនេះឱ្យឈ្មោះថា "ទស្សនវិជ្ជាអាស្រ័យនិយម The philosophy of Relations" តាមប្រក្រតីដើមនិងលក្ខណៈនៃធម្មវិភាគនេះ[49]។

ចំពោះបដិច្ចសមុប្បាទន័យ (Dependence originations) ព្រះពុទ្ធជាម្ចាស់ទ្រង់ឃើញច្បាស់ថា កំណើតសត្វលោកព្រមទាំងលោក អាស្រ័យនឹងលោកធាតុដែលទ្រង់ឱ្យឈ្មោះថា "អវិជ្ជា (Ignorance)"។ លោកក៏អាស្រ័យនឹងលោកធាតុ ឯខ្លួនសត្វលោកក៏អាស្រ័យនឹងលោកធាតុដែរ។ ដូច្នេះ យើងឃើញថា លោកធាតុដែលឋិតនៅក្នុងតួខ្លួនសត្វ មានសកម្មភាពនិងថាមពលស្របគ្នានិងប្រាស្រ័យគ្នាយ៉ាងជិតស្និទ្ធជាមួយ នឹងលោកធាតុខាងក្រៅជាដរាបដូចគ្នានឹងលោកដែរ។ យើងសូមបញ្ជាក់ថា លោកធាតុគឺលោកសំដៅយកធាតុដែលឋិតនៅ

---

[49] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩៤

ក្នុងចក្រវាល ឬឱកាសលោកបានដល់ បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, អាកាសធាតុ និងមនធាតុ។ម្យ៉ាងទៀត ភាជនលោក គេហៅថា លោកខាងក្រៅ ឬហៅថា លោកធំ, សត្វលោក គេហៅថាលោកខាងក្នុង ឬលោកតូច ហើយទាំងពីរនេះរស់នៅ និង វិនាសទៅវិញដោយអាស្រ័យជាមួយនឹងលោកធាតុទាំងអស់ ព្រោះលោកទាំងពីរនេះមាន ត្រៃលក្ខណ៍នៃលោកជាមូលដ្ឋាន។ ឯតួខ្លួនរបស់អវិជ្ជាដែលជារបស់លោកធាតុគឺ ៖ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ និងមនធាតុ។ ឯអាកាសធាតុ គឺជាធាតុ ដ៏សំខាន់គ្រប់គ្រងនិងបង្កើតជាធាតុដ៏សំខាន់ទាំង៤ ហើយទាំងអស់នេះជាកត្តានៃធាតុបរមាណូ[50]។

**បឋវីធាតុ** ៖ ធាតុនេះបានដល់វិសាលភាពនៃមហាភូត (Elements of expenation or extension) គឺឧបនិស្ស័យនៃរូប (Sobstantum of matter)។ ប្រាសចាករូបនិស្ស័យនេះ ក្នុង វិស័យដទៃទៀត ពុំអាចឋិតនៅក្នុងឱកាសលោកបានឡើយ។ សភាវីងនិងទន់ទាំងពីរ លោក ចាត់ទុកជាអាការៈរបស់បឋវីធាតុ។ ធាតុនេះតែងមាននៅក្នុងដី ទឹក ភ្លើងនិងខ្យល់, ឧ.ធាតុទឹក ក្នុងអវកាស មានទឹកដែលនៅខាងក្រោមជាគ្រឿងទ្រទ្រង់។ ឯធាតុដីភ្ជាប់គ្នាជាមួយនឹងវាយោ ធាតុ អាចបង្កើតបានជាទម្រង់នៃទឹកទាំងអស់នោះ។ ភាពត្រជាក់និងក្តៅ ជាអាការៈនៃតេជោ ធាតុ ឯធាតុសើមឬអាបោម័យ គឺជាអាការៈនៃអាបោធាតុ ឬធាតុទឹក។

**អាបោធាតុ** ៖ ធាតុនេះបានដល់សំយោគធាតុ ឬអាពន្ធកធាតុ គឺលោកទុកជាទឹកបន្សា។ មិនដូចជាបឋវីធាតុទេ អាបោធាតុ គ្មានរូបអាចប៉ះពាល់ឬចាប់បានឡើយ, តាមពិតវាគ្រាន់តែ មានលក្ខណៈសើមៗប៉ុណ្ណោះ។ អំណាចឬថាមពលនៃធាតុទឹកនេះហើយ ដែលអាចប្រមូល ចំណែកល្អិតៗតូចធ្មានៃរូបឱ្យទៅជាដុំ ហើយផ្សាឱ្យជាប់ជិតស្និទ្ធឡើង។ កាលណាធាតុដុំនៃរូប នោះរលាយចូលគ្នាហើយ អាបោធាតុ ក៏ក្លាយខ្លួនជាប្រមុខ មានលទ្ធភាពជាទឹកពិតប្រាកដ ឡើង។ គេអាចរាវរកឃើញអាបោធាតុនោះៗថាជាវត្ថុមានភាពសើមទៅបាន កាលណាវត្ថុវិ ស័យមានលក្ខណៈគ្រោតគ្រាតក្លាយទៅជាម្សៅ។ ដូច្នេះយើងឃើញថា ធាតុដីនិងធាតុទឹក ទាំងពីរនេះ មានសម្ព័ន្ធភាពជាមួយគ្នាជានិច្ច មិនដែលបែកចេញពីគ្នាឡើយ។ កាលណាបើ ធាតុទឹកអស់ទៅ ធាតុដីក៏អស់ទៅជាមួយគ្នាដែរ។

**តេជោធាតុ** ៖ ធាតុនេះបានដល់ធាតុក្តៅនិងត្រជាក់។ ធាតុទាំងពីរនេះមានមុខងារ ធ្វើ ឱ្យរូបចាស់ក្លាឡើង។ តេជោធាតុនេះ គេចាត់ទុកជាថាមពល។ យើងគួរបញ្ជាក់ថា ការធ្វើឱ្យ

---

[50] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩៤-៩៥

*រូបធំធាត់និងឱ្យចាស់ទ្រុឌទ្រោមទៅវិញ ក៏អាស្រ័យនឹងតេជោធាតុនេះដែរ។ មិនដូចជាធាតុទាំង៣នោះទេ ធាតុក្តៅឬតេជោធាតុនេះមានអំណាចនិងថាមពលអាចបង្កើតរូបខ្លួនឯង[៥១]។*

***វាយោធាតុ*** *៖ ធាតុនេះឋិតនៅជាមួយនិងតេជោជានិច្ច។ ចលនានៃខ្យល់បណ្តាលមកពីវាយោធាតុនេះឯង។ វាយោធាតុនេះជាអ្នកបង្កើតកម្តៅ។ វាយោធាតុនិងតេជោធាតុនៅក្នុងរូបមានសំយោគជាលំដាប់គ្នាទៅក្នុងវិញ្ញាណនិងកម្មនៅក្នុងចិត្ត។*

*ឯមនធាតុ ឋិតនៅក្នុងអាកាសធាតុ។ កាលបើអាកាសធាតុឋិតនៅក្នុងធាតុទាំង៤ (មហាភូតទាំង៤) មនធាតុក៏ឋិតនៅក្នុងទីនោះដែរ។ អាកាសធាតុនិងមនធាតុ មានសំយោគជាមួយគ្នាជានិច្ចមិនដែលបែកចេញពីគ្នាឡើយ។ ម្យ៉ាងទៀត យើងគួរបញ្ជាក់ថា ធាតុទាំង៤ ក៏មានសហវិជ្ជមានទៅវិញទៅមកមិនដែលដាច់ចេញពីគ្នាដែរ ហើយដែលធាតុទាំង៤នេះ មាន លក្ខណៈយ៉ាងនោះ ក៏អាស្រ័យនឹងអាកាសធាតុជាចាំបាច់ ដែលយើងអាចពោលថា “ប្រធាន នៃធាតុទាំង៤ក៏បាន។ ម្យ៉ាងវិញទៀត ធាតុនីមួយៗមានអធិបតីភាពលើនាទីរបស់ខ្លួនគឺ បឋវី ធាតុនៅក្នុងដី អាបោធាតុក្នុងទឹក តេជោធាតុក្នុងភ្លើង វាយោធាតុក្នុងខ្យល់។ ន័យមួយទៀត ធាតុទាំង៤ នេះ លោកហៅថា មហាភូត* (Great essentials) *ក៏បាន ព្រះវាឋិតនៅជានិច្ច ក្នុងរូបនិងសម្ភារជាតិ រាប់តាំងពីធូលីដ៏ល្អិតតូចឆ្មារ រហូតដល់សម្ភារវត្ថុនិងសវិញ្ញាណវត្ថុ និងអវិញ្ញាណវត្ថុជាដើមឡើងទៅ។ មហាភូតទាំង៤នេះ កាលបើឧប្បត្តិឡើងជារូបរាង ឬជារូបនីមួយៗហើយ តែងមានវណ្ណៈ (ពណ៌), គន្ធៈ (ខ្លិន), រសៈ (រសា) និងឱជា (ឱជារសា) ផលិតចេញមកពីមហាភូតទាំង៤ នោះៗ។ ឧទាហរណ៍ ៖*

*ដី* { *បឋវីធាតុ*, *អាបោធាតុ*, *តេជោធាតុ*, *វាយោធាតុ* } *វណ្ណៈ, គន្ធ, រសៈ និង ឱជា*

*ទឹក* { *បឋវីធាតុ*, *អាបោធាតុ*, *តេជោធាតុ*, *វាយោធាតុ* } *វណ្ណៈ, គន្ធ, រសៈ និង ឱជា*

[51] *ប៉ែន សាអឿន* ***សាសនាប្រៀបធៀប*** *គ.ស.១៩៦៩ ទំ៩៥*

ភ្លើង { បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ } វណ្ណៈ, គន្ធ, រសៈ និង ឱជា

ខ្យល់ { បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ } វណ្ណៈ, គន្ធ, រសៈ និង ឱជា

យើងសូមបញ្ជាក់ថា ការប្រជុំព្រមនៃធាតុទាំង៨ បង្កើតជាវត្ថុមួយ ដូចជាដីជាដើម គេហៅថា សុទ្ធដ្ឋករូបកលាបៈ (Pure-cotad material group) ហើយធាតុដើមនីមួយៗ គេហៅថា "មហាភូត" ជាប្រធានលើធាតុរបស់ខ្លួនៗ ឯធាតុទាំង៤ មានសកម្មភាពនិងថាមពលទៅបានអាស្រ័យជាមួយនឹងអាកាសធាតុ ដែលនៅក្នុងអាកាសធាតុនោះ មានមនធាតុឋិតនៅជាមួយជានិច្ច ហើយមនធាតុនេះហើយដែលជាមេ ឬជាដើមចមនៃជីវិត,ព្រលឹង, ចិត្ត និងវិញ្ញាណនៃលោកព្រមទាំងសត្វលោក[៥២]ៗ

តាមទ្រឹស្តីបរមាណូបូរាណនៃឥណ្ឌា ដែលបានរីកចម្រើនរហូតដល់ពុទ្ធសម័យ យើងសង្កេតឃើញថា ១ រថសណុ មាន១៦តជ្ជារី, ១ តជ្ជារី មាន១៦អណូ ហើយ ១ អណូ មាន ១៦ បរមាណូៗ គេជឿថាបំណែកដ៏តូចឆ្មារបំផុតនៃធូលី ដែលគេឃើញហុយឡើងក្នុងពន្លឺព្រះអាទិត្យ គេហៅថា រថរេណុៗ ដូច្នេះ បរមាណូ ១គឺត្រូវជាចំណែកទី ១/៦៥៥៣៦ នៃរថរេណុ១ ហើយគេយល់ថាបរមាណូនេះ មិនអាចបំបែកឱ្យចេញជាបំណែកតូចៗទៅទៀតបានឡើយៗ ចំពោះរឿងនេះព្រះពុទ្ធបានប្រកាសថា សភាវៈទាំងអស់ទោះជាធាតុដើមក្តី វត្ថុដែលកើតឡើងពីការផ្សំធាតុនោះៗក្តី តែងតែវិនាសនិងប្រែប្រួលទៅវិញជាធម្មតាៗ

តាមពិត ធាតុ បង្កើតធាតុ ហើយសត្វលោកព្រមទាំងលោកនេះក៏កើតឡើងនិងវិនាសទៅវិញដោយអំណាចកម្លាំងធាតុដែរៗ កាលណាធាតុទាំង៤នោះឋិតនៅក្នុងអាកាស ហើយអាកាសនោះឋិតនៅយូរអស់កប្បអស់កល្បទៅ ក៏បង្កើតឱ្យមានខ្យល់ឡើង, ខ្យល់បង្កើតភ្លើង, ភ្លើងបង្កើតទឹក ហើយទឹកក៏បង្កើតដីតាមលំដាប់ៗ កាលបើមានដី ទឹក ភ្លើង និង ខ្យល់

---

[52] (ប៉ែន សាអឿន សាសនាប្រៀបធៀប គ.ស.១៩៦៩ ទំ៩៦

ហើយ ធាតុទាំង៦ គឺធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ធាតុអាកាស និងមនធាតុ ដែលជាតួខ្លួននៃអវិជ្ជា ឬហៅថាលោកធាតុ ក៏បន្តសកម្មភាពកសាងធម្មជាតិដទៃទៀត ដូចជា ផ្កាយ នុពគ្រោះ ស្មៅ ឈើ សត្វតូច-ធំ ជាដើម រហូតដល់មនុស្សលោក។ លក្ខណៈបង្កើតបែបនេះ ហើយអាចហៅថា "ទីពិសោធន៍នៃធម្មជាតិ (Natural Laboratory)" ក៏បាន។ ឯសត្វលោកឬមនុស្សលោក ដែលមានកម្មជៈ (សភាវៈកើតពីកម្ម) ចិត្តជៈ (សភាវៈកើតពីចិត្ត), ឧតុជៈ (សភាវៈកើតពីរដូវ) និងអាហារជៈ (សភាវៈកើតពីអាហារ) ដោយមានបុរិសភាវរូប (មេរូបធាតុឈ្មោល) និងឥត្ថិភាវរូប (មេរូបធាតុញី) ជាសមុដ្ឋាន ក៏អាចបង្កើតសត្វលោកតៗគ្នាទៅទៀតជាលំដាប់[៥៣]។

លក្ខណៈនៃការស្ថាបនាជាតិ-កំណើតនៃសត្វលោកដូចកងចក្រនៃកតពដែលមាននៅក្នុងទំព័របន្ទាប់ទៅនេះ ៖

កំណត់សម្គាល់ ៖ ដោយគិតពីត្រឹមកំណើតជាមនុស្សលោក ដែលវិលកើត-ស្លាប់មិនឈប់ឈរក្នុងវដ្តសង្សារ, យើងឃើញថា កងចក្រនៃកតពរបស់សត្វលោកមានធម្មកត្តាដូចនេះ គឺ ៖ អទ្ធា ៣ គឺ អតីតកាល, បច្ចុប្បន្នកាល, អនាគតកាល។ អង្គ ១២គឺ ៖ អវិជ្ជា, សង្ខារ, វិញ្ញាណ, នាមរូប, សឡាយតនៈ, ផស្សៈ, វេទនា, តណ្ហា, ឧបាទានៈ, ភវៈ, ជាតិ និងជរា-មរណៈ។ អាការៈ ២០គឺ៖ (អតីតហេតុ-អវិជ្ជា, សង្ខា, តណ្ហា, ឧបាទានៈ, ភវៈ), (បច្ចុប្បន្ន ផល-វិញ្ញាណ, នាមរូប, សឡាយនៈ, ផស្សៈ, វេទនា), (បច្ចុប្បន្នហេតុ-អវិជ្ជា, សង្ខា, តណ្ហា, ឧបាទាន, ភវៈ), (អនាគតផល-វិញ្ញាណ, នាមរូប, សឡាយតនៈ, ផស្សៈ, វេទនា)។ សន្ធិ ៣គឺ ៖ ទី១, ទី២, ទី៣។ សង្ខេប ៤គឺ ៖ អតីតហេតុទី១, បច្ចុប្បន្នផលទី២, បច្ចុប្បន្នហេតុទី៣, អនាគតផលទី៤។ វដ្តៈ ៣គឺ ៖ កិលេសវដ្តៈ, កម្មវដ្តៈ និង វិបាកវដ្តៈ, ហេតុនិងផល១។ មូល ២ គឺ ៖ អវិជ្ជា និងតណ្ហា។

ដើម្បីការជាក់ច្បាស់ សូមសង្កេតមើលបដិច្ចសមុប្បាទនៃព្រះពុទ្ធសាសនា តម្រៀបតាមមុខងារនៃធម្មកត្តាទាំងឡាយ ដែលធ្វើឱ្យមនុស្សលោកវិលកើតស្លាប់មិនចេះឈប់ឈរក្នុងវដ្តសង្សារដូចតទៅនេះ៖

[៥៣] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ៩៧

| មូល២ | ហេតុ១, ផល ១ | វដ្ដៈ៣ | អង្គ ១២ | កាលៈ៣ | សង្ខេប៤ អាការៈ ២០ | សន្ធិ៣ |
|---|---|---|---|---|---|---|
| | | កិលេសវដ្ដៈ | ១-អវិជ្ជា | | **អតីតហេតុទី១** | |
| | | ១.អវិជ្ជា | ២-សង្ខារ | | ១-អវិជ្ជា | |
| | | ២.តណ្ហា | ៣-វិញ្ញាណ | អតីតៈ | ២-តណ្ហា | |
| | កិលេសវដ្ដៈ | ៣.ឧបាទាន | ៤-នាមរូប | | ៣-ឧបាទាន | |
| ១-អវិជ្ជា | និងកម្មវដ្ដៈ | | ៥-សឡាយតនៈ | | ៤-ភវៈ | |
| | ជាហេតុ | កម្មវដ្ដៈ | ៦-ផស្សៈ | | ៥-សង្ខារ | |
| | | ១.សង្ខារ | ៧-វេទនា | | | |
| | | ២.ភវៈ | ៨-តណ្ហា | បច្ចុប្បន្ន | **បច្ចុប្បន្នផលទី២** | |
| | | វិបាកវដ្ដៈ | ៩-ឧបាទានៈ, | | ៦-វិញ្ញាណ | សន្ធិទី១ |
| | | ១-វិញ្ញាណ | ១០-ភវៈ | | ៧-នាមរូប | |
| ២-តណ្ហា | | ២-នាមរូប | ១១-ជាតិ | | ៨-សឡាយតនៈ | |
| | | ៣-សឡាយតនៈ | ១២-ជរា-មរណៈ | | ៩-ផស្សៈ | |
| | វិបាកវដ្ដៈជា | ៤-ផស្សៈ | | | ១០-វេទនា | |
| | ផល | ៥-វេទនា | | | | |
| | | ៦-ជាតិ | | | **បច្ចុប្បន្នហេតុទី៣** | |
| | | ៧-ជរា-មរណៈ | | | ១១-អវិជ្ជា | |
| | | | | | ១២-តណ្ហា | សន្ធិទី២ |
| | | | | | ១៣-ឧបាទាន | |
| | | | | | ១៤-ភវៈ | |
| | | | | | ១៥-សង្ខារ | |
| | | | | អនាគត | **អនាគតផលទី៤** | |
| | | | | | ១៦-វិញ្ញាណ | សន្ធិទី៣ |
| | | | | | ១៧-នាមរូប | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ១៨-សឡាយតនៈ<br>១៩-ផស្សៈ<br>២០-វេទនា | |

ការអធិប្បាយនិងតម្រៀបធម្មកត្តាជាតារាងមុខងារមកខាងលើនេះ ឱ្យយើងយល់ថា ជាសង្ខេបន័យនៃបដិច្ចសមុប្បាទនៃព្រះពុទ្ធសាសនា ហើយលោកទុកជាគោលការនិងទ្រឹស្តីដ៏ធំបំផុតនៃអរិយសច្ចៈទី១ (ទុក្ខ-អរិយសច្ចៈ) និងទី២ (ទុក្ខសមុទយអរិយសច្ចៈ)។

អវិជ្ជា បើពោលដោយបរមត្ថ បានដល់ភាពមិនដឹងនៃធាតុ ហើយចំហាយនៃធាតុទាំងអស់នោះ ផលិតឡើងជាមូលនៃអកុសល៣យ៉ាងគឺ ៖ លោភៈ, ទោសៈ, និងមោហៈ។ ហើយលទ្ធភាពនៃអកុសលមូលទាំង៣នោះ ផលិតឡើងជាលោកធម៌ ៨ប្រការនៅក្នុងសន្តានចិត្តនៃសត្វលោកគឺ ៖ លាភ, អលាភ, យស, និន្ទា, ការសរសើរ (បសំសា), សុខ និង ទុក្ខ។ សង្ខារៈលោកហៅថា មេជាងសម្រាប់កសាងលោកនិងសត្វលោក។ ថាមពលនៃធាតុក្នុងចក្រវាលដែលបក់បង្វិលឥតឈប់ឈរ-ត្រជាក់-ក្តៅ ជាដើមនេះឯងលោកទុកជាសង្ខារ។ កាលណាបរមត្ថធាតុទាំងអស់វិជ្ជមាន ឬឋិតនៅដរាបណា សង្ខារក៏នៅតែមានសកម្មភាពក្នុងនាទីជាមេជាងជាដរាប។ ម្យ៉ាងទៀត ការវិវឌ្ឍនាការឡើងចាប់តាំងពីកកើតឡើងនៃពិភពលោកជាដំបូងរហូតដល់ការកកើតឡើងជាមនុស្ស ព្រះពុទ្ធឱ្យឈ្មោះថា “សង្ខារលោក”។ តាំងពីពេលដែលថាមពលនៃសង្ខារ បានកំណត់ឱ្យមានកំណើតជាមនុស្សហើយ ហើយបន្ទាប់ពីសេចក្តីស្លាប់ មនុស្សត្រូវកើតទៀត (ព្រោះមានស្លាប់ បានជាមានកំណើត), ហើយនៅត្រង់តំណាក់នៃបដិសន្ធិថ្មីនេះ សង្ខារក៏ត្រូវវេនចូលទៅធ្វើសកម្មភាពជាមេជាង ដូចធម្មតាតទៅទៀត។ ដូច្នេះយើងឃើញថា នៅតំណាក់នៃបដិសន្ធិថ្មីនេះ ព្រះពុទ្ធទ្រង់បានបញ្ជាក់ថា មានសង្ខារ ៦ ប្រភេទគឺ ៖ បុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អនេញ្ជាភិសង្ខារ, កាយសង្ខារ, វចីសង្ខារ និង ចិត្តសង្ខារ។

យើងសូមបញ្ជាក់ថា អវិជ្ជា មានថាមពលអាចវិវត្តឡើងតាមនាទីរបស់ខ្លួន, ឯសង្ខារ ក៏មានថាមពលអាចវិវត្តឡើងទៅតាមនាទីរបស់ខ្លួនដែរ។ ដូច្នេះ សភាវធម៌ ឬបច្ចយាការធម៌ទាំងពីរនេះ តែងប្រព្រឹត្តទៅដោយអាស្រ័យគ្នាទៅវិញទៅមកជានិច្ច ហើយទាំងពីរនេះ ឋិតនៅក្នុងអតីតកាលជាដរាប ដែលគេទុកជាអតីតហេតុ ក្រោមមូលដ្ឋាននៃធាតុទាំង៦ (បឋវី, អាបោ, តេជោ, វាយោ, អាកាស, មនៈ) ព្រមទាំងក្រោមឥទ្ធិពលនៃត្រៃលក្ខណ៍នៃលោក,

ហើយទាំងពីរនេះអាចនាំឱ្យបច្ចុប្បន្នផលកើតឡើង ព្រមទាំងនាំឱ្យមានបច្ចុប្បន្នហេតុ សម្រាប់អនាគតផលថែមទៀត។

ចំពោះវិញ្ញាណយើងឃើញថា លោកសំដៅយកបដិសន្ធិវិញ្ញាណ ហើយអាចវិវត្តឡើងដោយអាស្រ័យជាមួយនឹងសង្ខារដែលជាមេជាងដែរ។ ឯនាម-រូប លោកសំដៅយកវិញ្ញាណកិច្ចដែលមានចេតសិកសម្បទាជាមូលដ្ឋាន និងរូប យើងទាំងអស់នេះ លោកអាចហៅថា "បញ្ចក្ខន្ធ" ហ្នឹងឯង។ ម្យ៉ាងទៀត គួរយើងយល់ថា វិញ្ញាណនិងនាម-រូបទាំងពីរនេះ លោកទុកជាបច្ចុប្បន្នផល ព្រមទាំងបង្កើតសកម្មភាពសម្រាប់អនាគតផលថែមទៀត។

កំណត់សម្គាល់ ៖ តាំងពីអវិជ្ជារហូតដល់នាម-រូប ជាសភាវធម៌ដ៏សំខាន់បំផុតក្នុងបដិច្ចសមុប្បាទ ផ្នែកទុក្ខសមុទយវិភាគ, ឯសភាវធម៌ឬបច្ចយាការធម៌ទាំង ៨ ខាងចុង គឺលោកចាត់ទុកជាលទ្ធភាពនៃសភាវធម៌ឬបច្ចយាការធម៌ទាំង ៤ខាងដើម។ ប៉ុន្តែគួរយើងកត់សម្គាល់ម្យ៉ាងទៀតថា ក្នុងលក្ខណៈវិភាគទូទៅនៃបដិច្ចសមុប្បាទន័យ គេមិនអាចទុកអង្គនៃបដិច្ចសមុប្បាទណាមួយជាអាទិហេតុ ឬជាដើមចមឡើយ -គឺយើងអាចវិភាគចាប់ពីដើម ទៅចុងក៏បាន, ពីចុងមកដើមវិញក៏បាន ឬក៏ពីកណ្តាលទៅដើម និងពីកណ្តាលទៅចុងវិញក៏បាន ឬក៏ពីចុងមកកណ្តាលវិញក៏បាន[៥៤]។

***គ-ភាគនៃលោក (ភាជនលោក)***៖ តាមលទ្ធិព្រាហ្មណ៍គេយល់ថា ត្រង់កណ្តាលនៃពិភពលោកយើងនេះ មានមហាមេរុភ្នំមួយឈ្មោះថា "មេរុ ឬ សុមេរុ ឬក៏ ហិមាល័យ" ដែល ជាលំនៅឋាននៃពពួកទេព្តា ហើយព្រះអាទិត្យបរវេជុំវិញភ្នំនោះ។ នៅខាងត្បូងនៃភ្នំនោះ គឺ ជម្ពូទ្វីប (ឥណ្ឌាសព្វថ្ងៃនេះ) ឯផ្នែកខាងលិច, ខាងកើត និងខាងជើង គឺទ្វីបទាំង៣ដទៃទៀត។ នេះគឺជាភាគភូមិសាស្ត្រនៃឥណ្ឌាសម័យបុរាណ តាមលំអាននៃលទ្ធិព្រាហ្មណ៍។

តាមគម្ពីរអភិធម្មកោសៈ និងអដ្ឋកថារបស់លោកគ្រូសោមិត្រៈ និងវសុពន្ធនៃមហាយាននិកាយ, លោកបានបញ្ជាក់ថា ខាងក្រោយភ្លើងឆេះកប្បជាយូរអង្វែង ទើបមានកាលសម្រាប់បង្កើតលោកជាថ្មីមួយទៀត។ ពេលនោះ មានឋានព្រះព្រហ្មមួយកើតឡើង មុនគេបង្អស់ ហើយមានទេព្តាជាច្រើនក្រុមចុះមកកើតនៅឋាននេះ[៥៥]។ បន្ទាប់មកទើបមានឋាន បរនិ

[៥៤] ប៉ែន សាអឿន ***សាសនាប្រៀបធៀប*** គ.ស.១៩៦៩ ទំ១០០

[៥៥] ផ្នែកថេរវាទ ហីនយាននិកាយ, សូមមើល "អគ្គញ្ញសូត្រ"នៃគម្ពីរមជ្ឈិមនិកាយ សុត្តន្តបិដកបាលី-ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ, ក្រុងភ្នំពេញ

និម្មិតវសវត្តី, និម្មានរតី, តុសិតា និង យាមៈ កើតឡើងជាបន្តបន្ទាប់គ្នាមកក្រោមទៀត។ ខាងក្រោយមកទៀត មានមណ្ឌលខ្យល់ ឋិតនៅលើអវកាសមានកម្រាស់ ១.៦០០.០០០ យោជន៍។ នៅលើមជ្ឈមណ្ឌលនៃខ្យល់នេះ, មានសមុទ្រពពកទឹកក្រហមទំហំ១.១២០.០០០ យោជន៍ បង្កើតជាមួយនៃទឹកមានអឌ្ឍមាឌ ១.២០៣.៤៥០ យោជន៍, ហើយមហាសមុទ្រនេះកម្រើកដោយខ្យល់បង្កើតជាមណ្ឌលទឹក (អាបមណ្ឌល) ភាគខាងក្រោមមកទៀត មានកម្រាស់ ៣២០.០០០យោជន៍។ បន្ទាប់មក មានភ្លៀងបង្អុរមាស, ត្បូង, ផែនដី, ទឹក, ដែកជាដើម ទៅលើផែនដីមានពណ៌មាសនោះ ដែលបង្កើតបាន ៖ ១-មជ្ឈមណ្ឌលនៃប្រព័ន្ធនៃលោក គឺភ្នំព្រះមេរុ, ២-ជួរភ្នំ ៨ជាន់ ហើយ៧ជាន់នៅជិតគ្នាបន្ទាប់ពីភ្នំព្រះមេរុមកគឺជាមាសសុទ្ធ, ឯជាន់ទី៨ ត្រង់ជាយនៃប្រព័ន្ធលោក គឺជាដែកសុទ្ធ, ៣-មហាសមុទ្រ ហូរតាមចន្លោះនៃជួរភ្នំទាំងឡាយនោះ, ៤-ទ្វីបទាំង៤ កើតឡើងក្នុងមហាសមុទ្រខាងក្រៅភាគខាងកើត, ខាងលិច, ខាងត្បូង និងខាងជើងនៃភ្នំព្រះមេរុ ត្រង់ចន្លោះជួរភ្នំទី៧ និងទី៨ (សូមមើល ៖ "Ceylon Buddism", by Gogerly, Colombo, 1908)។ ឯភ្នំទី៨ ខាងក្រៅជាវិការៈនៃដែក គឺជាភ្នំចក្រវាល ហើយឈ្មោះនេះគេហៅថា "ចាតុទ្វីបលោកធាតុ"។ ជួរភ្នំដែកដែលហៅថា "ចក្រវាល" នេះមានលក្ខណៈជាតួទ្វីប ឋិតនៅលើផែនដីជាវិការៈនៃមាស។ ភ្នំដែកនេះព័ទ្ធមហា សមុទ្រមួយ មានកំណើតពីត្រឹមផ្ទៃមហាសមុទ្រនោះទៅលើ ៣១២ យោជន៍កន្លះ, មានទទឹង ៣១២[៥៦] យោជន៍កន្លះ។ ឯភ្នំព្រះមេរុមានកម្ពស់ ១៦០.០០០យោជន៍ ខ្ពស់ជាងមហាសមុទ្រទាំងអស់ចំនួន ៨០.០០០យោជន៍ និងមានទំហំជុំវិញ ៣២០.០០០យោជន៍។ ចម្ងាយពីភ្នំព្រះមេរុទៅ កណ្តាលភ្នំចក្រវាលចំនួន ៦០០.៤៣៧.៥យោជន៍ ហើយទំហំជុំវិញភ្នំចក្រវាលមានចំនួន ១.២០០.៨៧៥ យោជន៍។

ដូចពោលខាងលើនេះ យើងឃើញថាមានលក្ខណៈផ្សេងគ្នាស្រឡះពីលក្ខណៈភូមិ-សាស្ត្រនៃលោកបុរាណនៃឥណ្ឌា តាមគតិនៃលទ្ធិព្រាហ្មណ៍។

**ឃ-ទ្វីប៤៖** នៅភាគខាងកើត, ខាងលិច, ខាងជើង និងខាងត្បូងនៃភ្នំព្រះសុមេរុ មានកោះឬទ្វីប៤, ហើយព្រះអាទិត្យបររថព័ទ្ធជុំវិញភ្នំព្រះសុមេរុនោះ ដើម្បីបំភ្លឺទ្វីបទាំង៤ មុន-ក្រោយជាងគ្នាចំនួន ៦ម៉ោង, គឺនៅទ្វីបភាគខាងកើត ៦ម៉ោង, ខាងត្បូង ៦ម៉ោង, ខាងលិច ៦ម៉ោង និងខាងជើង៦ម៉ោង, ទាំងអស់ត្រូវជា ២៤ម៉ោង-១យប់ ១ថ្ងៃ។ តាមគម្ពីរទិវ្យាវទានៈ នៃ

[៥៦] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១០១

និកាយមហាយាន, យើងឃើញថា ទ្វីបនីមួយៗ ជាវិការៈនៃប្របរីយ៉ាងវិសេស ឋិតនៅលើផែនដីមាសហៅថា "កាញ្ចនចក្រ" មានជម្រៅទៅក្នុងមហាសមុទ្រចំនួន ៨០.០០០យោជន៍ៗ ឯទ្វីបទាំង៤នេះគឺ ៖

**១-បុព្វវិទេហទ្វីប៖** ទ្វីបនេះឋិតនៅភាគខាងកើតនៃភ្នំព្រះសុមេរុ មានសណ្ឋានឬរាងដូចជា អឌ្ឍច័ន្ទ, មានប្រវែង ២០០០យោជន៍, ទំហំជុំវិញ ៦៣៥០យោជន៍ៗ មនុស្សទាំងឡាយដែលរស់នៅលើទ្វីបនេះ មានអាយុ២៥០ឆ្នាំ ហើយម្នាក់ៗមានកម្ពស់ប្រហែល ៣ម៉ែត្រ និង ៦៦សង់ទីម៉ែត្រ (8 cubite, each is 18 inches) និងមានមុខមាត់ជារាងអឌ្ឍច័ន្ទ ដូចជារាង ទ្វីបនោះដែរៗ

**២-ជម្ពូទ្វីប ៖** នេះគឺជាតួពិតពលោកដែលយើងរស់នៅសព្វថ្ងៃនេះ, ជាលោកដែលព្រះពុទ្ធគ្រប់អង្គក្នុងអតីតៈ, បច្ចុប្បន្ន និងអនាគត ទ្រង់កើតនិងបំពេញកិច្ចការប្រយោជន៍ដល់លោកនិងសត្វលោកៗ ទ្វីបនេះមានរាងដូចជារាជរថ មានប្រវែង ២០០០យោជន៍ មានទំហំជុំវិញ ៦០០៣.៥យោជន៍ៗ មនុស្សទាំងឡាយនៅលើទ្វីបនេះ មានអាយុ១០០ឆ្នាំយ៉ាងច្រើនបំផុត, ម្នាក់ៗមានកម្ពស់ ៣ហត្ថកន្លះ ឬ ៤ហត្ថ (3,50 to 4 cubits) មានមុខមាត់ជារាង ៤ ជ្រុងតិចឬច្រើនៗ

**៣-អបរគោយានទ្វីប (ឬ-គោទានទ្វីប ឬក៏គោទានីយទ្វីប)៖** -ទ្វីបនេះមានរាងមូល, មានប្រវែង២៥០០យោជន៍, មានទំហំជុំវិញ ៧៥០០យោជន៍ៗ មនុស្សទាំងឡាយដែលរស់នៅលើទ្វីបនេះមានអាយុ៥០០ឆ្នាំ ហើយម្នាក់ៗមានកម្ពស់ ១៦ហត្ថ (16 cubits)ៗ

**៤-ឧត្តរកុរុទ្វីប៖** ទ្វីបនេះមានរាងជាញាយស្រប (Oblong) មានទំហំផ្ទៃរាប ៨០០០យោជន៍ៗ ទ្វីបនេះ ពុំមានភូមិឬទីក្រុងទេ ហើយមនុស្សទាំងឡាយដែលរស់នៅក្នុងទីនេះ មានអាយុ២០០០ឆ្នាំ ព្រមទាំងម្នាក់ៗមានកម្ពស់ ៣២ហត្ថ (32 cubits)[៥៧]ៗ

**៥-អបាយលោក៖** ១-នរកក្ដៅនិងសត្វនរក ៖ អវិចិនរកមានទំហំនិងផ្ទៃ ២០.០០០យោជន៍ត្រីគុណ នៅខាងក្រោមជម្ពូទ្វីប មានជម្រៅ ២០.០០០យោជន៍ៗ នៅខាងលើ អវិចិនរកនេះ មានឋាននរកដទៃទៀត ៧គឺ៖ ក-សញ្ជីវៈ, ខ-កាលសូត្រ, គ-សង្ឃាតៈ, ឃ-រោរវៈ, ង-មហារោរវៈ, ច-តាបនៈ, ឆ-មហាតាបនៈៗ នរកនីមួយៗមានបរិវារ ៤ទៀតគឺ ៖ ក-កុក្កុលៈ, ខ-កុណបឬគូថនរក, គ-អសិបត្តៈ, ឃ-ខារោទកនទីៗ

---

[៥៧] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១០២

សត្វលោកទាំងឡាយដែលរស់នៅក្នុងនរកទាំងឡាយនោះ ត្រូវទទួលសោយទុក្ខវេទនាទៅតាមកម្មដែលខ្លួនបានប្រព្រឹត្តកាលពីពេលដែលខ្លួនរស់នៅជាមនុស្សលោក។

២-នរកត្រជាក់និងសត្វនរក ៖ តាមគម្ពីរទីបេត៏ឈ្មោះ ក៏លបទ្រម: យើងឃើញថានរកត្រជាក់គេចែកចេញជា ៨កន្លែងគឺ ៖ ១-អាពុទៈ, ២-និរពុទៈ, ៣-អដដៈ, ៤-ហហវៈ, ៥-ហុហុវៈ, ៦-ឧត្បលៈ, ៧-បទ្មៈ, ៨-មហាបទ្មៈ។ ទី១,២,៦,៧ និងទី៨ គេឱ្យឈ្មោះទៅតាមរូបរាងនៃសត្វនរកដែលរស់នៅទីនោះ។ សត្វនរកនៃឋានទី១ និងទី២ មានរាងដូចជាដុំពពុះទឹកមានលក្ខណៈជាកលលរូបនៅខែទី១នៃស៊ុត។ ឯទី៦,៦ និង៨ មានរាងដូចផ្កាឈូក។ ចំពោះ ទី៣, ៤ និងទី៥ គេហៅសត្វនរកបែបនោះទៅតាមសំនៀងស្រែក ព្រោះធ្មេញនៃសត្វទាំងឡាយនោះប៉ះទង្គិចគ្នាដោយត្រជាក់ខ្លាំងពេក ទើបបង្កើតស្នូរបែបនោះ[៥៨]។ តាមប្រភពដដែលនេះ គេបានបញ្ជាក់ថា នរកទាំងឡាយនោះមានជម្រៅ ២០០០យោជន៍ មានថ្នាក់ជាលំដាប់គ្នា ដូចគ្នានឹងនរកក្ដៅ ហើយឋិតនៅមិនឆ្ងាយប៉ុន្មានពីនរកក្ដៅទាំងឡាយនោះដែរ។

៣-សត្វតិរច្ឆាន ៖ តាមគម្ពីរមជ្ឈិមនិកាយ និងកថាវត្ថុ យើងឃើញថា សត្វតិរច្ឆានជាច្រើនបែបរស់នៅឯនាយសមុទ្រខាងក្រៅ មិនមែននៅជាមួយពពួកទេព្តាឡើយ។ ប៉ុន្តែយើងឃើញ សត្វជាច្រើនបែបដែលមានលំនៅលើផែនដីជាមួយនឹងមនុស្សលោកដែរ។

៤-ប្រេត ៖ តាមគម្ពីរបេតវត្ថុ, យើងឃើញថា ជំនឿទូទៅក្នុងរឿងពួកប្រេត ហាក់ដូចជាមានលក្ខណៈមិនប្រកបដោយប្រព័ន្ធនៅឡើយ។ ប៉ុន្តែ លោកបានបញ្ជាក់ថា ប្រេតទាំងឡាយរស់នៅក្នុងអាណាចក្រយមៈ ដែលចែកចេញជា ៣៦ខែត្រ ឋិតនៅខាងក្រោមជម្ពូទ្វីបចំនួន ៥០០យោជន៍។ ប្រេតទាំងឡាយនោះ មានអាយុ ៥០០ឆ្នាំ ហើយមួយថ្ងៃនៅទីនោះស្មើគ្នានឹងមួយខែនៃមនុស្សលោក[៥៩]។

៥-ពួកអសុរ ៖ ពួកអសុរមិនមែនជាពួកទេព្តាទេ។ ពួកនេះរស់នៅក្នុងរូងភ្នំព្រះសុមេរុយ៉ាងជ្រៅហើយធំទូលាយអស្ចារ្យ។ រូងទាំងឡាយនោះ ឋិតនៅខាងក្រោមផ្ទៃសមុទ្រ។ ហើយរូងមួយៗ មានទីក្រុងយ៉ាងល្អមួយ មានទំហំ ១១.០០០យោជន៍។ ទី១-មានជម្រៅ ២០.០០០

---

[៥៨] ផ្នែកខាងថេរវាទ ហីនយាននិកាយ, សូមមើល "សំយុត្តនិកាយ, អង្គុត្តរនិកាយ, សុត្តនិបាត, ទីឃនិកាយ" ព្រះត្រៃបិដកបាលី-ខ្មែរ។ សូមមើលទៀត "អភិធម្មត្ថសង្គហៈ" ប្រែសម្រួលដោយ ព្រះមហាមុនី អ៊ុម-ស៊ូរ ត្រង់វគ្គទី៥ (វិថីមុត្តសង្គហវគ្គៈមួយទៀត សូមមើល "វិមានវត្ថុ")។

[៥៩] ប៉ែន សាអឿន ***សាសនាប្រៀបធៀប*** គ.ស.១៩៦៩ ទំ១០៣

យោជន៍ មានរាហូជាស្តេច, ទី២-មានជម្រៅ ៤០.០០០យោជន៍ មានព្រះកណ្ឌមាលាធរៈជាស្តេច, ទី៣-មានជម្រៅ ៦០.០០០យោជន៍ មានព្រះបុស្បាមាលាធរៈជាស្តេច, ទី៤-មានជម្រៅ ៨០.០០០យោជន៍ មានព្រះវេអចិត្រាជាស្តេច។ ស្តេចពួកអសុរទាំង៤ នេះត្រូវចេញទៅកំពូលភ្នំព្រះសុមេរុរៀងរាល់រដូវស្ទឹកឈើលាស់ ដើម្បីច្បាំងជាមួយនឹងពួកព្រះឥន្ទ្រព្រមទាំងពួកនាគ និងយក្សជាសេនា។

ការពោលមកខាងលើនេះ តាមប្រភពនៃគម្ពីរជាតិទីបេត៍មួយឈ្មោះ ក៏លបទ្រុមៈទិវ្យាវទានៈ (សំស្ក្រឹត), ប៉ុន្តែតាមគម្ពីរមហាវស្តុ លោកពោលតែស្តេច៣អង្គ គឺរាហុ, វេមចិត្រី និងមុច្ចលិន្ទ។ តាមគម្ពីរអភិធម៌កោសៈ (សំស្ក្រឹត) ថាពួកអសុរបានរស់នៅនឹងចង្កេះ ភ្នំព្រះមេរុតែ ៣ កន្លែងទេ។ តាមប្រភពខ្លះទៀត (សូមមើល "និកាយ" បាលី-ខ្មែរ ព្រះត្រៃបិដក។) ពោលថា នៅលើព្រះព្រះសុមេរុ មានឋាន ៤ គ្រប់ជ្រុងទាំង ៤នៃភ្នំ។ ត្រង់ឋានទី៤ គឺជាឋានសួគ៌របស់ទេព្តាឈ្មោះថា ធាតុមហារាជិកា។ ទី១ មានទំហំ ១៦.០០០យោជន៍ ជាលំនៅ នៃពពួកយក្ស (ករោបាណិ-មានភាជន៍មូលក្នុងដៃ), ទី២ មានទំហំ ៨០០០ យោជន៍ ជាលំនៅរបស់ពួកយក្សឈ្មោះថា មាលាធរៈ (ទ្រទ្រង់កម្រងផ្កា), ទី៣ មានទំហំ ៤០០០ យោជន៍ ជាលំនៅនៃពួកយក្សឈ្មោះថា សទាមទៈ (ស្រវឹងជានិច្ច)។ បណ្តាឋានទាំង ៤នេះ ឋានទីមួយៗមានចម្ងាយពីគ្នាចំនួន ១០.០០០យោជន៍។

ច-ឋានសួគ៌ទេវលោក ៖ ១-ឋានធាតុមហារាជិកា តាមគម្ពីរទីឃនិកាយ ថាមានទំហំ ៨០.០០០យោជន៍ នៅលើជ្រុងទី៤ នៃភ្នំព្រះមេរុ ជាឋានសួគ៌ក្រោមគេបង្អស់, ជាឋាននៃទេព្តាទាំង៤ពួក មានស្តេចទេវតា ៤អង្គ គ្រប់គ្រងនៅទីនោះ, មានកំណើតពីផែនដី (ជម្ពូទ្វីប) ចំនួន ៨០.០០០យោជន៍។ លោកមានអាយុ ៥០០ឆ្នាំ, ១ថ្ងៃនៅទីនោះ ស្មើគ្នានឹង៥០ឆ្នាំនៃមនុស្សលោក ហើយមួយអង្គៗ មានកម្ពស់១/៨ (១ភាគ៨នៃយោជន៍)។

២-ពាក់កណ្តាល (ជុំវិញ) នៃភ្នំព្រះមេរុ គឺគួរាជរថនៃព្រះអាទិត្យ ហើយនៅក្រោមព្រះអាទិត្យចំនួន ១យោជន៍ គឺគួព្រះចន្ទ្រ និងពពួកផ្កាយដទៃទៀត។

៣-ឋានតាវតឹង្សៈ ជាឋាននៃពួកទេព្តា ៣៣ក្រុម មានព្រះសក្កទេវលោកជាស្តេច, ឋិតនៅលើកំពូលភ្នំព្រះមេរុ មានទីក្រុងមានទំហំរាង ៤ជ្រុងស្មើចំនួន ២៥០០ម៉ៃល៍ [60] (១ម៉ៃល៍=

[60] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១០៤

១៦០០ម៉ែត្រ), មានអាយុ ១០០០ឆ្នាំ, មួយអង្គមានកម្ពស់១/៤ នៃយោជន៍ (១ភាគ៤) ហើយ ១ ថ្ងៃនៃឋាននោះត្រូវជា ១០០ឆ្នាំ នៃមនុស្សលោក។

៤-ឋានយាមា៖ មានកម្ពស់ពីផែនដីយើងចំនួន ១៦០.០០០យោជន៍, ពីឋានតាវតឹង្ស ចំនួន ៨០.០០០យោជន៍, មានទទឹង ៨០.០០០យោជន៍ ជាឋាននៃពួកទេព្តាឈ្មោះ យាមៈ ក្រោមការគ្រប់គ្រងនៃព្រះសុយាមៈ មានអាយុ ២០០០ឆ្នាំ, ១ថ្ងៃនៃឋាននោះស្មើគ្នានឹង ២០០ ឆ្នាំនៃមនុស្សលោក, មួយអង្គៗ មានកម្ពស់ ៤នៃក្រោសៈ (១ក្រោសៈ=២ម៉ៃល៍)។

៥-ឋានតុសិតៈ ៖ (ឋានរីករាយ) ជាឋានសម្រាប់ជាទីបំផុតនៃព្រះពុទ្ធគ្រប់អង្គ មាន ស្តេចទេព្តាមួយអង្គព្រះនាម សំតុសិតៈ មានអ្នកគ្រប់គ្រង, មានអាយុ ៤០០០ឆ្នាំ, មានកម្ពស់ ជង្ខួន ១ក្រោសៈ។

៦-ឋាននិម្មានរតី៖ ក្រោមការគ្រប់គ្រងទេព្តាព្រះនាម សុនិម្មិតៈ មានព្រះជន្ម ៨០០០ឆ្នាំ, មានកម្ពស់ជង្ខួន ១, ១/៤ក្រោសៈ។

៧-ឋានបរនិម្មិតវសវតី ៖ មានកម្ពស់ពីផែនដី ១.៦៨០.០០០យោជន៍ មានទទឹង ៦៤០.០០០ យោជន៍, មានព្រះជន្ម ១៦០.០០០ឆ្នាំ, ១ថ្ងៃនៃឋាននេះ ប្រហែលឬស្មើគ្នានឹង ១៦.០០០ឆ្នាំនៃមនុស្សលោក, មួយអង្គៗមានកម្ពស់១, ១ភាគ២ក្រោសៈ។ ទេព្តាដែល ជា ស្តេចនៃឋាននេះ គឺជាមារតែងជ្រៀតជ្រែកព្រះពុទ្ធគ្រប់អង្គ។

យើងសូមបញ្ជាក់ថា តាំងពីមនុស្សលោក ដល់ឋានបរនិម្មិតវសវតី លោកហៅថាកាម លោក។

ឥ-ឋានសួគ៌ព្រហ្មលោក (រូបលោក)៖ ១-ឋានសួគ៌ឋិតនៅដោយកម្លាំងឈានទី១ (សូម មើល "ទីឃនិកាយ, មជ្ឈិមនិកាយ" បាលី-ខ្មែរ ព្រះត្រៃបិដក។ សូមមើល ៖ អភិធម្មត្ថ សង្គហៈ -ត្រង់វគ្គទី៥។) នៅឋានព្រហ្មលោកនេះ លោកចែកចេញជា ៣គឺ ៖ ក-ព្រហ្មកាយិកា ឬព្រហ្មបារិសជ្ជា មានចម្ងាយពីផែនដីទៅលើ ២.៥៨០.០០០យោជន៍, មានទំហំ ១.២៩០.០០០ យោជន៍, មានអាយុ ២០អន្តរកប្ប (២០ អន្តរកប្ប=១/៤ នៃមហាកប្ប), មានកម្ពស់ ១ ភាគ ២ នៃយោជន៍។ ខ-ព្រហ្មបុរោហិតា មានចម្ងាយពីឋានព្រហ្មកាយិកា ទ្វេគុណ, មានកម្ពស់ ១ ភាគ២ នៃមហាកប្ប, មានកម្ពស់ ១យោជន៍។ គ-មហាព្រហ្មា មានចម្ងាយពីឋានព្រហ្មបុរោ ហិតាជាទ្វេគុណ, មានអាយុ ៣ភាគ៤ នៃមហាកប្ប, មានកម្ពស់ ១ ១ភាគ២នៃយោជន៍។

២-ឋានសួគ៌ិឋិតនៅដោយកម្លាំងឈានទី២ ៖ នៅឋានព្រហ្មលោកនេះ លោកចែកចេញជា ៣គឺ ៖ ក-បរិត្តាភា មានអាយុ ២កប្ប, មានកម្ពស់ ២យោជន៍។ ខ-អប្បមាណាភា មានអាយុនិងកម្ពស់ជាទ្វេគុណពីបរិត្តាភា។ គ-អាភស្សរា មានអាយុនិងកម្ពស់ជាទ្វេគុណពីអប្បមាណាភា[៦១]។

៣-ឋានសួគ៌ិឋិតនៅដោយកម្លាំងឈានទី៣ ៖ ក-បរិត្តសុភា មានអាយុនិងកម្ពស់ជាទ្វេគុណពីអាភស្សរា។ ខ-អប្បមាណសុភា មានអាយុនិងកម្ពស់ជាទ្វេគុណពីបរិត្តសុភា។ គ-សុភកណ្ហកា មានអាយុនិងកម្ពស់ជាទ្វេគុណពីអប្បមាណសុភា។

៤-ឋានសួគ៌ិឋិតនៅដោយកម្លាំងឈានទី៤ ៖ តាមប្រភពបាលី យើងឃើញថា ឋាននេះឈ្មោះថា សុទ្ធាវាសព្រហ្មលោក ចែកចេញជា ៥គឺ ៖ ក-អវិហា, ខ-អតប្បា, គ-សុវស្សា, ឃ-សុទស្សី, ង-អកនិដ្ឋាន។ មានឋានពីទៀតឈ្មោះថា វេហប្ផលា និងអសញ្ញសត្តា។ តាមប្រភពទីបេត៍ និងសំស្រ្កឹត, យើងឃើញថា គេចែកចេញជា ៨គឺ ៖ ក-អនភ្រកាស (ឬ សុកក្រឹស្ណៈ), ខ-បុណ្យប្រសវ្វ, គ-ព្រហត្ផលៈ (វេហផលៈ), ឃ-អវ្រ្ហ, ង-អតាប្យៈ, ច-សុទ្រិសៈ, ឆ-សុទ្រិសនៈ, ជ-អកនិស្ឋៈ។

យើងសូមបញ្ជាក់ថា នៅទីបំផុតនៃរូបលោក ព្រះព្រហ្មមានអាយុ១៦.០០០ក័ប្ប, មួយអង្គៗមានកម្ពស់ ១៦.០០០យោជន៍។

ជ-អរុបលោក ៖ ឋាននេះលោកចែកចេញជា ៤ គឺ ៖ ក-អាកាសានញ្ចាយតនៈ, ខ-វិញ្ញាណញ្ចាយតនៈ, គ-អកិញ្ចញ្ញាយតនៈ និង ឃ-នេវសញ្ញា នាសញ្ញាយតនៈ, ព្រះព្រហ្មទាំងអស់នេះរស់នៅទីនោះអាស្រ័យនឹងអរូបឈាន ៤ដែរ។ ក-មានអាយុ ២០.០០០ មហាកប្ប, ខ-មានអាយុ ៤០.០០០មហាកប្ប, គ-មានអាយុ ៦០.០០០មហាកប្ប, ឃ-មានអាយុ ៨០.០០០មហាកប្ប។

ឈ-អញ្ញលោកប្រពន្ធ៖ យើងឃើញថា នៅក្នុងគម្ពីរអង្គុត្តរនិកាយ បានបញ្ជាក់ដូចតទៅនេះ ៖ ១.សហស្សី ចូឡនិកាយ លោកធាតុ (ប្រព័ន្ធនៃលោកមានប្រការ ១០០០), ២.ទ្វិសហស្សី មជ្ឈិមិកា លោកធាតុ (ប្រព័ន្ធនៃលោកជាន់មធ្យមមាន ១០០០ សហស្សី), ៣-តិសហស្សី មហាសហស្សី លោកធាតុ (ប្រព័ន្ធនៃលោកមាន ១០០០ ទ្វិសហស្សី)។ តើយើងអាចពោលថា ១០០០, ១០០០$^{២}$, ១០០០$^{៣}$ បានឬទេ ?

---

[៦១] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១០៥

ចំពោះលោកដែលមានចក្រវាលមួយពាន់ យើងឃើញថាមានទ្វីបបួនពាន់ មានភ្នំព្រះមេរុមួយពាន់, មានឋានព្រហ្មជារូបលោកថ្នាក់ទី១ មួយពាន់, មានភ្នំមួយជារបងខណ្ឌ លោកតូច ឬចក្រវាលមួយៗ, មានឋានព្រហ្មជារូបលោកថ្នាក់ទី២ជាជំបូល ហើយមានជញ្ជាំង, ជញ្ជាំងភ្ជាប់រហូតដល់ឋានព្រហ្មជារូបលោកថ្នាក់ទី៣ ដែលមានឋានទាំងអស់ចំនួនមួយពាន់ ប្រកបដោយឋានព្រហ្មជារូបលោកថ្នាក់ទី៤ ព័ទ្ធជុំវិញៗ

ចំណែកលោកដទៃទៀត យើងឃើញថាមានលក្ខណៈពុំច្បាស់លាស់សោះឡើយ ព្រោះប្រភពផ្សេងៗបានបញ្ជាក់ប្រព័ន្ធផ្សេងៗគ្នាជាដរាប[62]ៗ

៥-លទ្ធិសាកលនិយមចិន ៖ ក-ទ្រឹស្តីលោកជាតុបូរាណ ៖ យើងឃើញថា មានគំនូសបី ៨ សន្ធាត់ បង្កើតឡើងដោយលោកហ្វូ-ហ្ស៊ី (FU-SHI) មុនគ.ស.២៨៥២ៗ លោកបង្កើតគំនូសនេះឡើង មានលក្ខណៈដូចជាដើមឈើមួយបែបឈ្មោះថា (Piarmica Sihirica) (អង់គ្លេសថា Milfoil) ដែលព្រះអាទិទេពបាននិម្មិតឡើង ជាក្រឡាប្រទាក់ព្រមទាំងចងក្រងលោកនេះឱ្យបានមានស្ថិរភាពៗ ម្យ៉ាងទៀត គំនូសនោះអាចប្រៀបបានជាមួយនឹងស្នាមក្រឡាផ្សេងៗនៅលើស្នូកអណ្តើក, មានវែង, មានខ្លី (ខ្លាំងឬខ្សោយ) ជាដើមៗ ប៉ុន្តែមានយោបល់ថា គំនូសនេះ សម្រាប់បញ្ជាក់ពីមុខងារនៃកុលសម្ព័ន្ធនៃសង្គមចិន មិនមែនមានលក្ខណៈជាទេវកថា ឬលោកជាតុឡើយៗ យើងគួរសង្កេតមើលដូចតទៅនេះៗ

**គំនូសបីជាន់ ចែកចេញជា ៨ក្រុម**

នៅមុនគ.ស.១២៣១-១១៣៥ លោក ស៊ុ-ប៉េហ៍ (Si-Poh) នៅក្នុងរាជវង្សនៃយិន (Yin Dynasty) បានរៀបចំគំនូសផ្សេងពីបែបខាងលើនេះ ជា ៦៤ ក្រុមទៅវិញ តាមមូលដ្ឋាននៃក្បួន យី-គីង្គ (Yi-King)ៗ លោក ខុង ជឺ ក៏បានសិក្សាក្បួន យី-គីង នេះយ៉ាងជំនាញដែរ, ហើយលោកបានបញ្ជាក់ថាក្បួននេះមានលក្ខណៈពិបាកយល់ជាទីបំផុតៗ

លុះខាងក្រោយមក, លោកបានធ្វើអត្ថាធិប្បាយយ៉ាងពិស្តារដែលជាហេតុនាំឱ្យក្បួននោះក្លាយទៅជាក្បួនមួយវិសេសវិសាល ព្រមទាំងគេទទួលស្គាល់ពេញសាកលលោក ថែមទៀតៗ តាមអ្នកអត្ថាធិប្បាយខាងក្រោមមកទៀត, គេបានបញ្ជាក់ថា គំនូសបីជាន់ដែលចែកជា ៨ក្រុមនោះ ជាតំណាងអំណាចមនុស្ស៣ប្រភេទគឺ ឋានសួគ៌, ផែនដី និងមនុស្សលោកៗ

---

[62] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១០៦

គួរកត់សម្គាល់ថា គំនូស៣ជាន់ ជា៨ក្រុមនោះ នៅក្នុងក្បួន យី-គីង្គ គេរៀបចំគំនូសជារបៀបកែទម្រង់រូបរាងជា៦ជ្រុង(Hexagram)ទៅវិញ, ហើយគេចាត់ទុកគំនូសនោះជាតំណាងនៃកិច្ចការរបស់មនុស្សលោក និងវចនាសម្ព័ន្ធរបស់លោកទាំងពីរមាន [៦៣] សម្ព័ន្ធភាពទៅវិញទៅមកជានិច្ច។ នៅក្នុងវគ្គបន្ថែមខាងចុងនៃក្បួន យី-គីង្គ, យើងឃើញថា លោក ជូ-ហ៊ិ (Chu-His) (គ.ស.១១៣០-១២០០) បានបញ្ជាក់ថា ទ្រឹស្តីខុង-ជឺ និងទ្រឹស្តីបុរាណពីលោកជាតុ មានលក្ខណៈផ្សេងគ្នាត្រង់ជាតុជាសកម្មនិងអសកម្ម, ហើយលោកនេះមានបំណងនឹងរួបរួមទ្រឹស្តីទាំងពីរក្នុងលក្ខណៈជំនឿ និងទ្រឹស្តីទូទៅនៃកិច្ចការរបស់មនុស្សជាតិ និងឋានសួគ៌។ តាមពិត គម្រោងទ្រឹស្តីលោកជាតុរបស់លោក ជូ-ហ៊ិ បានក្លាយជាប្រជាប្រិយភាពក្នុងទស្សនចិន្តាបែបថ្មីនៃប្រជាជាតិចិនទាំងមូល។

នៅទីនេះ យើងនឹងពោលដោយសង្ខេបនូវប្រព័ន្ធដែលបានរីកចម្រើនជាលំដាប់ដោយក្បួន យី-គីង្គ ដែលក្លាយជាប្រជាប្រិយភាពរហូតដល់សព្វថ្ងៃនេះ។ ក្បួននេះបានបញ្ជាក់ថា គំនូសបីជាន់នីមួយៗ សុទ្ធតែមានឈ្មោះសម្រាប់កត់សម្គាល់ផ្សេងៗគ្នា ព្រមទាំងមានសន្តានព្រៀងលានជាធម្មជាតិនិងគុណសម្បទាផ្សេងៗគ្នាទៀត។ ដូច្នេះ, ក្រុមទី២ របស់គំនូស៣ជាន់អត្ថាធិប្បាយនិងរៀបចំដោយលោក ស៊ុ-ប៉េហ៍ មានកំណើតដូចក្រុមទី១ របស់ប្រព័ន្ធបុរាណមានបន្ទាត់វែង៣ជាប់គ្នា, មានលក្ខណៈខ្លាំង ឱ្យឈ្មោះថា"គៀង (Kien)" បានសេចក្តីថា "មានកម្លាំងឬមាំមួន" ជាតំណាងនៃឋានសួគ៌ ជាអធិរាជ និងជាព្រះបិតា ជាដើម។ ទីកន្លែងឬទីចាត់ការរបស់វានៅភាគឬទិសពាយ័ព្យ, សន្តានព្រៀងលានរបស់វាគឺអាកាសធាតុ, គុណសម្បទារបស់វាគឺភាពស្អុះស្អាប់ឬភាពសើមដែលបណ្តាលមកពីក្តៅ។ ឯគំនូស៦ជាន់ ឬ ៦ ជ្រុង (Hexagram) គឺការបូករួម ៦ក្រុមនៃគំណូស ៣ ជាន់ហ្នឹងឯង, ហើយគំនូសនីមួយៗមានឈ្មោះផ្សេងៗគ្នា ព្រមទាំងមានសម្ព័ន្ធភាពទៅនឹងបន្ទាត់ទាំងឡាយក្នុងជួរនៃគំនូស ៦ ជាន់នោះថែមទៀត។ ដូច្នេះយើងឃើញថាបន្ទាត់ទី១ ឬខាងក្រោមបង្អស់នៃគំនូស ៣ជាន់ មានការទាក់ទងទៅនឹងបន្ទាត់ទី១ នៃគំនូស៣ជាន់ខាងលើបង្អស់, មានន័យថាគឺបន្ទាត់ទី៤ នៃគំនូស ៦ ជាន់ទៅវិញ។ ឯស្ថានភាពរបស់បន្ទាត់ទាំងឡាយដទៃទៀត ជួនកាលគេឃើញមានបន្ទាត់វែងឋិតនៅជាមួយនឹងបន្ទាត់ខ្លី, ជួនកាលបន្ទាត់ខ្លីឋិតនៅជាមួយន្ទាត់វែងជាដើម។ ក្បួន យី-គីង្គ បានបញ្ជាក់ជាឧទាហរណ៍ដូចតទៅនេះ ៖

---

[៦៣] ប៉ែន សាអឿន *សាសនាប្រៀបធៀប*គ.ស.១៩៦៩ ទំ១១៣

ក្រុមទី៧ នៃគំនូស៦ជាន់ មានឈ្មោះថា "សហ្យ-SZE" គឺមាន២ក្រុមរបស់គំនូស៣ជាន់ រួមគ្នាឈ្មោះថា "កាន Kan" ដែលគេគូសជាតំណាងទឹក ហើយនឹង "ក្អុន-KWUN" ដែលគេគូសជាតំណាងផែនដី, ទឹកទាំងឡាយតែងឋិតនៅលើដីឬក្នុងទេវវាក្យៈថា ក្រុមមនុស្សលោករួបរួមគ្នាដើម្បីការពារសត្រូវ[៦៤]។

គួរកត់សម្គាល់ថា ប្រព័ន្ធទ្រឹស្តីលោកជាតុបូរាណនៃចិន មានលក្ខណៈជាទេវកថាសុទ្ធសាធ តាមអត្ថាធិប្បាយនៃលោក ស៊ិ-ប៉េហ៍ ដែលខាងក្រោយមកមានឈ្មោះល្បីថាព្រះវ៉ែន (Wen) ទៅវិញ។ ប៉ុន្តែក្នុងទ្រឹស្តីដដែលនេះ នៅជំនាន់និកាយ ស៊ុង (Sung) នៃសតវត្សទី១១ និងទី១២នៃគ.ស. លោក ជូ-ហ្ស៊ិ ជាអ្នកល្បីល្បាញឈ្មោះមួយរូបក្នុងចំណោមអ្នកទស្សនវិទូទាំងឡាយនៅជំនាន់នោះបានធ្វើអត្ថាធិប្បាយនូវទ្រឹស្តីលោកជាតុបែបថ្មីនៃប្រទេសចិន។យើងឃើញថា លោក ខុង-ជឺ និងម៉េង ជឺ ទាំងពីរនេះជាអ្នកទស្សនវិទូដ៏ប៉ិនប្រសប់ជាទីបំផុតនៅជំនាន់នោះ, ប៉ុន្តែលោក ជូ-ហ្ស៊ិ ជាអ្នកទស្សនវិទូប្រកបដោយហេតុ-ផល ជាងអ្នកទស្សនវិទូទាំងពីរនោះទៅទៀត ហើយលោករូបនេះ ពុំបានទទួលទ្រឹស្តីពីអំណាចឋានសួគ៌និងអំណាចនៃផែនដីរបស់អ្នកទស្សនវិទូនៅជំនាន់មុនឡើយ។ តាមពិត លោក ជូ-ហ្ស៊ិ បានស្ថាបនានូវប្រព័ន្ធនៃទ្រឹស្តីពីកំណើតនៃធម្មជាតុដែលលោករកឃើញក្នុងក្បួន យី-គីង្គ ទាំងអស់ ហើយដែលលោកទុកក្បួននេះជាប្រភពនៃកិច្ចការស្រាវជ្រាវរបស់លោក។ តាមប្រភពខ្លះនិយាយថា ទ្រឹស្តីរបស់លោក ជូ-ហ្ស៊ិ ទាំងអស់ មានឥទ្ធិពលពីទស្សនតាវនិងព្រះពុទ្ធសាសនា, ប៉ុន្តែសេចក្តីពិត គឺលោកនេះពុំបានគេចផុតពីទេវកថាបូរាណឡើយ។

តាមលក្ខណៈទូទៅ យើងឃើញថាទ្រឹស្តីទាំងឡាយរបស់លោក ជូ-ហ្ស៊ិ ពុំបានទាក់ទងដល់ខាងដើមឬកំណើតនៃលោកជាតុឡើយ, ឯទ្រឹស្តីនៃលោកសម័យបច្ចុប្បន្ននេះថា លោកនេះកើតឡើងហើយវិនាសទៅវិញជាធម្មតា ហើយការវិនាសទៅវិញនោះនៃលោកតែងឱ្យកំណើតដល់លោកថ្មីនេះជាដរាប។ លោក ជូ-ហ្ស៊ិ ក្នុងលក្ខណៈនៃការបង្កើតលោក ពុំបានពោលពីអ្វីដែលនាំឱ្យកើតឡើយ, ប៉ុន្តែលោកនេះបានបញ្ជាក់ពីច្បាប់របស់ធម្មជាតិមានឈ្មោះថា "LI" និងជីវជាតុមានឈ្មោះថា "K'I"។ ទោះជាយ៉ាងនោះក៏ដោយក៏លោកពុំបានបញ្ជាក់ថាតើជាតុទាំងពីរនេះឋិតនៅ និងប្រសូតចេញពីប្រភពធម្មជាតុណាមួយឡើយដែរ។ ចំពោះរឿងនេះ អ្នកទេវកថា មុខជាពោលថា ជាតុទាំងពីរនេះមានមូលដ្ឋាននិងប្រសូតចេញពីព្រះម្ចាស់

[64] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១១៤

លោក ឬអ្នកបង្កើតជាព្រះអាទិទេពពុំខាន, ប៉ុន្តែផ្ទុយទៅវិញ លោក ជូ-ហ្សិ បានបញ្ជាក់ថា វិវឌ្ឍនាការនៃលោកនេះ អាស្រ័យនឹងធាតុគី "K'I" បានសេចក្ដីថា អាកាស, ចំហាយ, ដង្ហើម រស់ ព្រមទាំងធាតុដ៏សកម្មនិងចម្បងជាងគេគឺ លី "LI" បានសេចក្ដីថា អំណាច ធម្មជាតិ។

កាលណាធាតុទាំងពីរនេះមានសម្ពពទៅវិញទៅមក ក៏បង្កើតបានជាធាតុផ្ទុយគ្នា (YANG និង YIN) ដែលគេចាត់ទុកជាពន្លឺ (ថ្ងៃ) និងងងឹត (យប់) ឋានសួគ៌និងផែនដី, ធាតុ ឈ្មោលនិងញីជាដើម យើងទាំងអស់នេះជាលក្ខណៈនៃទ្រឹស្ដីតៅ ប្រែថាអំណាចនៃធម្មជាតិ ទាំងអស់។ ធាតុយ៉ាននិងយិន (YUNG និង YIN) បង្កើតជាធាតុ៥ប្រភេទទៀតគឺ ធាតុដែក, ឈើ, ទឹក, ភ្លើង និងដី។ ធាតុមួយនៃបណ្ដាធាតុទាំង៥នេះ តែងមានធាតុ យ៉ាននិងយិន ជានិច្ច ដោយមានធាតុលី (LI) ជាមេបញ្ជាការ ឬជាអ្នកចាត់ការ[៦៥]។

ដើម្បីបញ្ជាក់ពីគោលការធំបំផុតនៃអំណាចធម្មជាតិ (LI) គេគូរតារាងរង្វង់មូលដូចខាងក្រោមនេះ៖



កំណត់សម្គាល់៖ ធាតុយ៉ាងនិងយិន គេទុកជាធាតុដើម ឬធាតុ គី (K'I) មានផ្នែកពីរ សម្រាប់ជាប្រភពនៃធាតុយ៉ាងនិងយិន, ឯអំណាចដ៏ធំបំផុតសម្រាប់បក់បង្វិលទាំងអស់ ឱ្យមានចលនាគឺធាតុលី (LI)ជាអំណាចដ៏ធំបំផុតនៃធម្មជាតិ។ នៅមានតារាងមូលមួយបែបទៀត បញ្ជាក់ថា ធាតុ គី (K'I) បែកជាធាតុសម្រាប់បង្កើតសម្ភារៈវត្ថុធាតុជា៥គឺ ធាតុដែក, ឈើ, ទឹក , ភ្លើង និងដី ហើយជួនកាលគេបានបញ្ជាក់ពីរដូវទាំង ៤នៃឆ្នាំនីមួយៗថែមទៀត ដែលគេទុកជាសកម្មភាពដ៏ទៀងទាត់នៃអំណាចធាតុ គី (K'I)។

តាមលក្ខណៈទូទៅនៃតារាងរង្វង់មូលខាងលើនេះ យើងដឹងបានថា តាមទស្សនៈរបស់លោក ជូ-ហ្សិ លោកមានកំណើតឡើងពីសកម្មភាពនៃធាតុ លី(Natural Law) (ច្បាប់ធម្មជាតិ) ជាអ្នកចាត់ការឱ្យមានធាតុ គី (K'I) ឡើង ដោយមានធាតុយ៉ាងនិងយិន ជាមូលដ្ឋាននិងជាអន្តរកម្ម ហើយកាលបើមានធាតុ គី (K'I) ហើយ ទើបមានធាតុ៥យ៉ាងទៀតគឺ ធាតុដែក , ឈើ,

[៦៥] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១១៥

ទឹក, ភ្លើង និងដី ឡើងជាលំដាប់ៗ ឋានសួគ៌និងផែនដី កើតឡើងដោយធាតុទាំងអស់នេះ, ហើយឋានសួគ៌ឋិតនៅដូចជាដំបូង ឬកំពូលនៃលោក-ផែនដីឋិតនៅជាមជ្ឈមណ្ឌល, យ៉ាំង និងយិន ជាធាតុសម្រាប់បង្វិលពេលវេលា-យប់ជាថ្ងៃ និងថ្ងៃជាយប់, ក្តៅជាត្រជាក់ និងត្រជាក់ជាក្តៅ, ខ្ទឹតជារនោច និងរនោចជាខ្ទឹត, រដូវប្រាំងជារដូវវស្សា និងរដូវវស្សាជារដូវរងា, រដូវរងាជារដូចរំហើយ ជាដើមៗ អំណាចធាតុយ៉ាំងនិងយិន អាចបង្វិលពីឆ្នាំមួយទៅឆ្នាំមួយទៀត រហូតដល់ទីផុតកប្ប គឺមួយអាយុនៃលោក មាន ១២៩.៦០០ឆ្នាំៗ កាលណាលោកនេះអស់អាយុហើយ ទើបអំណាចនៃធាតុលី ផ្តើមបង្កជាធាតុថ្មីក្នុងលក្ខណៈស្ថាបនាលោកនេះឡើងវិញទៀត [៦៦]ៗ

ខ-ទីរបស់មនុស្សនៅក្នុងធម្មជាតិ ៖ សម្រាប់កន្លែងដែលមនុស្សឋិតនៅក្នុងប្រព័ន្ធនៃធាតុទាំងអស់នោះ គឺមនុស្សកើតឡើងដោយធាតុទាំង ៥ គឺធាតុដែក, ឈើ, ទឹក, ភ្លើង និង ដី ជាមេបញ្ជាការៗ គេឱ្យឈ្មោះមនុស្សថា "លោកមានទំហំតូច (Microcosm a world in miniature)"ៗ គេបញ្ជាក់ថា គ្រប់មនុស្សទាំងអស់មានកម្មេចពន្លឺភ្លឺថ្លានៃទេវៈនៅក្នុងខ្លួន, ប៉ុន្តែមនុស្សខ្លះមានធាតុយ៉ាំងជាធំ ហើយខ្លះទៀតមានធាតុយិនជាធំៗ មនុស្សអ្នកចេះដឹងអ្នកប្រាជ្ញមានធាតុយ៉ាំងច្រើន, មនុស្សល្ងង់ មានធាតុយិនច្រើនៗ មនុស្សម្នាក់ៗមានរដូវ៤ មានយប់-ថ្ងៃ និងអស់អាយុកាលណា ធាតុដីក្លាយជាខ្សោះ ឬអស់អំណាចព្រមទាំងថាមពល ដូចជាលោកខាងក្រៅដែរៗ កិច្ចការដ៏ធំរបស់មនុស្សម្នាក់ៗ គឺត្រូវធ្វើនិងរៀបចំដំណើរជីវិតរបស់ខ្លួនយ៉ាំងណា ដើម្បីឱ្យស្រប ឬមានសមានភាពជាមួយនឹងអំណាចនៃធម្មជាតិ (Tao) ឬរបបនៃលោកបានៗ មនុស្សមិនអាចរស់នៅដោយប្រឆាំងជាមួយ នឹងអំណាចរបស់ធម្មជាតិបានឡើយៗ ដូច្នេះជីវិតរបស់មនុស្សគ្រប់រូបមានសម្ព័ន្ធភាពជាមួយនឹងអំណាចរបស់ឋានសួគ៌ និងផែនដីជានិច្ច,ព្រោះលោកខាងក្រៅនិងជីវិតមនុស្សគ្រប់រូបសុទ្ធតែជាលទ្ធភាពនៃធម្មជាតិទាំងអស់ៗ

សម្រាប់ជីវិតបន្ទាប់ពីសេចក្តីស្លាប់នៃមនុស្ស យើងឃើញថា ទោះលោកខុង-ជឺ ក្តី, លោកឡាវ-សេ ក្តី, លោក ដូ-ហ្សិ ក្តី ពុំបានបញ្ជាក់តាមទស្សនៈរបស់លោកទាំងនោះឡើយ ប៉ុន្តែគ្រាន់តែពោលទៅតាមលំអាននៃលោកខាងក្រៅថា គេនឹងត្រឡប់ទៅកាន់ធាតុដើមវិញ ដូចជា សេចក្តីវិនាសនៃលោកខាងក្រៅនោះដែរៗ ទាំងអស់នេះ មានលក្ខណៈផ្ទុយពីទស្សនៈ

[66] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១១៦

បុរាណនិងឥឡូវនេះរបស់ចិនទៅវិញ ព្រោះទស្សនៈខាងក្រោមនេះពោលថា បន្ទាប់ពី សេចក្ដី ស្លាប់នៃមនុស្ស, មនុស្សលោកម្នាក់ៗ ត្រូវត្រឡប់ទៅកាន់ឋានសួគ៌វិញជាដាច់ខាត។

តាមទស្សនចិន្ដាខាងលើនេះ យើងឃើញថា ហាក់ដូចជាមានលក្ខណៈខ្ពង់ខ្ពស់ហើយ ពិបាកយល់ ពិបាកទទួលយកជាជំនឿជាទីបំផុតសម្រាប់រាស្ត្រសាមញ្ញ។ ម្យ៉ាងទៀត យើងឃើញថា នៅក្នុងរាជព្រះចៅស៊ុង (SUNG Dynasty) មានទស្សនៈមួយកើតឡើងនៅក្នុងក្បួន លូ-សេ (Lu-She) ថា "មានមនុស្សទី១ (ជាដំបូង) បានវិវត្ត(កើត)ឡើង ហើយគេបានចាត់ទុកជាបុព្វបុរសនៃមនុស្សជាតិមានឈ្មោះថា "ប៉ាង-គូ PAN-KU"។ ប៉ុន្តែឧត្តមគតិនេះ មានប្រជាប្រិយភាពតែក្នុងចំណោមមហាជន មិនមែនក្នុងចំណោមអ្នកចេះដឹងឡើយ[៦៧]។

គ-ឋានរបស់ពួកបេតកូត ៖ នៅក្នុងខណ្ឌនេះ យើងសង្កេតឃើញថា ទោះណាជាលោក ខុង-ជឺ, ឡាវ-សេ ឬ ជូ-ហ្សិ ពុំបានពោលដល់រឿងនេះក៏ដោយ ក៏មានសេចក្ដីរាយការណ៍បុរាណបានបញ្ជាក់ថាមានពួកបេតកូតហៅថា "ក្វេ-សេន Kwei-Shen" ឋិតនៅក្នុងបុរិសរូបនៃការផ្លាស់ប្ដូរធម្មជាតិក្នុងលោក។ មានសេចក្ដីរាយការណ៍បុរាណមួយទៀត បញ្ជាក់ថា ពួកបេតកូត គឺជាពួកមន្ត្រីនៃព្រះអាទិទេព។ ពួកបេតកូត មានល្អ អាក្រក់ ឋិតនៅក្នុងធម្មជាតិទាំងអស់ក្នុងលោក។

ឃ-ឋានរបស់ព្រះអាទិទេព ៖ សម័យបុរាណ យើងឃើញថា ទេព្ដាឬព្រះម្ចាស់ទ្រង់ព្រះនាមថា "សាង-ទី Shang-Ti" គឺជាទេព្ដាធំបំផុត ហើយច្រើនតែអ្នកកាន់អំណាចរដ្ឋនៃប្រទេសចិន ទើបជឿគោរពព្រមទាំងបូជាទេព្ដាដ៏ជាធំអង្គនេះ។ លុះដល់រជ្ជកាលព្រះចៅចូវ (Chow Dynasty) នៅសតវត្សទី១២មុនគ.ស. ទើបយើងឃើញថាជំនឿក្នុងឋានសួគ៌និងផែនដី ដែលគេជឿថា ជាសកម្មភាពនៃព្រះអាទិទេពក្នុងធម្មជាតិ ហើយពាក្យថា "សាង-ទី Shang-Ti" ក៏សាបសូន្យលែងមានគេនឹកឃើញឡើយ។ ទាំងអស់នេះ អាស្រ័យនឹងទស្សនៈថ្មីរបស់លោក ខុង-ជឺ, ម៉េង ជឺ និង ជូ-ហ្សិ ជាដើម។ ជាទីបំផុតលោក ជូ-ហ្សិ បានប្រកាសថា ព្រះអាទិទេពបានដល់ធម្មជាតុ២គឺ គី(K'I) និងលី (LI)។ ឯពាក្យថា អាទិទេព ក៏ហាក់ដូចជា ឥទ្ធិពលនៅសម័យនៃលោក ជូ-ហ្សិ ប៉ុន្តែទោះជាយ៉ាងណានោះក៏ដោយ ក៏យើងឃើញថា ឥទ្ធិពលនៃទស្សនៈរបស់លោកជូ-ហ្សិ ពុំអាចមានជ័យជម្នះទៅលើទឹកចិត្ត និងជំនឿនៃ ប្រជាជាតិចិនទាំងមូលបានឡើយ។

[៦៧] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១១៧

នៅសម័យបច្ចុប្បន្ននេះ យើងឃើញថា ព្រះចៅទាំងឡាយនៃប្រទេសចិន នៅតែជឿនិងគោរពបូជាព្រះជាម្ចាស់សានទីដដែល ឯប្រជារាស្ត្រចិនទូទៅនៅតែជឿនិងគោរពបូជាព្រះម្ចាស់ សួគ៌ឬឋានសួគ៌ព្រមទាំងពួកទេវតាភូតទាំងឡាយដែលគេហៅថា"ក្វេ-សេន Kwei-Shen"។

**សភាពមនុស្ស និងវាសនាបន្ទាប់ពីសេចក្ដីស្លាប់** ៖ តាមលក្ខណៈទូទៅនៃជីវវិទ្យា យើងឃើញថាលក្ខណៈគុណសម្បទា ដែលជាសាធារណៈដល់រុក្ខា លតាវល្លិ៍ សត្វតិរច្ឆាន និងមនុស្ស,ហើយទាំងអស់នេះ គេចែកចេញស្រឡះពីធម្មជាតិដទៃទៀតតាមកំណើត និងប្រក្រតីដើម គេហៅថា "ជីវិត" ទាំងអស់។ ពាក្យថា "ជីវិត" នេះ គឺគេប្រើជានិច្ច សម្រាប់បញ្ជាក់នូវអនុក្រមទាំងអស់ និងការពិសោធន៍ទាំងអស់នៃការរស់នៅរបស់សត្វលោក និងវត្ថុមានជីវិតដទៃទៀត។ ម្យ៉ាងទៀតពាក្យថា "ជីវិត" នេះតែងមានកម្ម (ការងារ) ឬ អំពើ និងបដិកម្ម (ការងារឬអំពើជាបដិបក្ស)រវាងអង្គរបស់ឥន្ទ្រិយ៍(Organism) និងវត្ថុជុំវិញខ្លួន (Environment) របស់ធម្មជាតិ។ ប៉ុន្តែ "ជីវិត" ជាពាក្យកើត (ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១១៨) មានសង្គមធម៌, ជីវិតប្រកបដោយការបរិសុទ្ធ, ក៏ឧត្តមគតិនៃជីវិតតាមលក្ខណៈនៃជីវវិទ្យា ពុំមានគ្រោះថ្នាក់អ្វីឡើយ។ ចំពោះការអស់ទៅនៃជីវិត យើងឃើញថា អ្នកជីវវិទ្យាបាន បញ្ជាក់ថា ការរលាយឬសូន្យទៅនៃជីវិតរបស់អង្គនៃឥន្ទ្រិយ៍ ឬការវិនាសទៅរបស់ឯកភាព នៃអង្គរបស់ឥន្ទ្រិយ៍ គេហៅថា ទីបំផុតឬមរណភាពនៃជីវិត។ គេពុំពោលពីវាសនាបន្ទាប់ពី មរណភាពនៃជីវិតថា ទៅជាយ៉ាងនេះឬយ៉ាងនោះឡើយ។ ប៉ុន្តែតាមលក្ខណៈនៃឧត្តមគតិ របស់វិទ្យាសាស្ត្រធម្មជាតិព្រមទាំងរូបនិយម យើងឃើញថា គេបានបញ្ជាក់ដូចតទៅនេះ ៖

"ជីវិត កើតឡើងពីវត្ថុ ឬគ្រឿងផ្សំរបស់ធាតុ មានសំយោគពីមរណភាពនៃជីវិតតៗគ្នាជានិច្ច។ បើគ្មានជីវិត មរណៈក៏គ្មានដែរ ហើយបើគ្មានមរណៈ ជីវិតក៏សូន្យទៅតែម្ដង បានន័យថា ជីវិតឱ្យថាមពលដល់មរណៈ ហើយមរណៈឱ្យថាមពលដល់ជីវិតវិញ គឺសភាវៈទាំងពីរតែងអាស្រ័យគ្នាទៅវិញទៅមកជានិច្ចក្នុងវដ្តសង្សារនៃលោក។ នៅពេលដែលជីវិតឧប្បត្តិកើតឡើង ក៏កើតឡើងដោយច្បាប់ឬធម្មភាពរបស់ធម្មជាតិ (Natural Law) ហើយនៅទីបំផុតរបស់ជីវិតឬមរណៈក៏សម្រេចដោយច្បាប់ឬធម្មភាពរបស់ធម្មជាតិដដែល គឺរឿងកើតនិងស្លាប់របស់ជីវិតសម្រេចដោយរចនាសម្ព័ន្ធនៃធម្មជាតិទាំងអស់ (Structure of nature)[៦៨]។

[៦៨] សូមមើល "A natural science of society", by A.R. Radecliffe-Eroan, 1964, America.

ដើម្បីជានិទស្សន៍ចំពោះជីវវិទ្យាទូទៅ យើងសូមបញ្ជាក់ថា ជីវវិទ្យាគឺជាវិទ្យាសាស្ត្រនៃជីវិតមនុស្សនិងធម្មជាតិមានជីវិតទាំងអស់។ អ្នកជីវវិទូទាំងឡាយក្នុងលោក មានការចាំបាច់សិក្សានូវធម្មជាតិនិងធម្មកត្តានៃវិទ្យានេះ តាមលក្ខណៈនៃជីវិតរូបនៅក្នុងលោករួមទាំងមនុស្សលោក, សត្វតិរច្ឆានគ្រប់ផ្នែក និងដើមឈើរុក្ខា លតាវល្លិ៍គ្រប់សន្តាន។ ការសិក្សានេះត្រូវទាក់ទងដល់ភាពប្រែប្រួលនៃរូប (Morphology), សរីររូប (Physiology), កំណើតដើម (Origin), និងការផ្តល់ឬការបែងចែក (Distribution) នៃជីវកត្តានិងជីវសម្ព័ន្ធទាំងឡាយនោះៗ។ ចំពោះវិធីសិក្សានៃវិទ្យានេះ អ្នកជីវវិទូត្រូវអនុវត្តស្ថិតិវិធី (Statistical methode) សម្រាប់ប្រមូលឯកសារសេមោជាន និងសរីរវិច្ឆេទនវិធី (Anatomical Methodes) សម្រាប់ធ្វើការសង្កេត និងការពិសោធន៍រកនូវសេចក្តីពិតនៃជីវរូបទាំងឡាយនោះៗ។

នៅក្នុងសង្គមវិទ្យាយើងឃើញថាអ្នកសង្គមវិទូទាំងឡាយពុំបានសិក្សាជីវរូបទាំងឡាយឱ្យបានល្អិតល្អន់ទេ, គេទាំងឡាយគ្រាន់តែសង្កេតនូវកត្តាទាំងឡាយ ដែលជាផលវិបាកនៃជីវរូបនៃមនុស្សទៅលើសង្គមរបស់មនុស្សជាតិ និងវប្បធម៌របស់មនុស្សលោកប៉ុណ្ណោះ។ ដូច្នេះយើងសង្កេតឃើញមានជីវកត្តា ២បែប ដែលជាជំនួយដល់វិវឌ្ឍនាការនៃសង្គម[៦៩] មនុស្សលោក ៖ ១-ជីវរូបនៃមនុស្ស បានកម្រិតព្រំដែនដល់ ឬសម្រាប់ចរិយានៃវប្បធម៌ (Cultural Behaviour) , ២-ជីវរូបនៃមនុស្សបានគាំទ្រនូវគំរូនៃចរិយាខ្លះរបស់ជីវប្រក្រតីនៃមនុស្សជាតិ សម្រាប់ឱ្យសង្គមប្រតិបត្តិតាម និងខំប្រឹងបំបាត់នូវសកម្មភាពទាំងឡាយដែលផ្ទុយព្រមទាំងប្រកបដោយគ្រោះថ្នាក់ដល់សមាជិកនៃសង្គម ជាពិសេសរីកតវត្ថុ ឬវត្ថុជុំវិញខ្លួនជាធម្មជាតិ។ តាមពិតជីវប្រក្រតីនៃមនុស្សជាតិ ពុំបានមានអំណាចនិងឥទ្ធិពលទាំងស្រុងទៅលើវប្បធម៌នៃសង្គមទេ, ប៉ុន្តែវាបានបង្ហាញនូវការគាំទ្រនៃការគាប់ចិត្តចំពោះតែគំរូនៃសកម្មភាព និងកាតព្វកិច្ចទាំងឡាយព្រមទាំងកម្រិតព្រំដែននៃសកម្មភាព និងការកិច្ចទាំងអស់នោះ សម្រាប់ការអនុវត្តនៃមនុស្សទាំងឡាយនៅក្នុងសង្គមប៉ុណ្ណោះ។

តើលទ្ធិនិងសាសនាទាំងឡាយក្នុងលោក បានគិតដល់សភាពមនុស្សនិងវាសនាបន្ទាប់ពីសេចក្តីស្លាប់របស់មនុស្សដូចម្តេចខ្លះ ? ដូចបានពោលពីខាងដើមមកហើយថា លទ្ធិនិងសាសនាទាំងឡាយក្នុងលោកមានមុខងារ សម្រាប់បំពេញដល់មនុស្សទាំងឡាយក្នុងសង្គមជា ៣ ផ្នែកគឺ ៖ ១-សម្រាប់អប់រំមនុស្សម្នាក់ៗឱ្យឋិតនៅក្នុងសីលធម៌របស់មនុស្ស, ២-

---

[៦៩] ប៉ែន សាអឿន *សាសនាប្រៀបធៀប* ទំ១១៩

សម្រាប់អប់រំមនុស្សម្នាក់ៗ ឱ្យចេះដឹងនិងឱ្យចូលចិត្តមានសម្ព័ន្ធភាពជាមួយនឹងអ្នកដទៃ ដើម្បីសេចក្តីសុខសាន្តខាងផ្លូវកាយវាចា និងចិត្ត នៅក្នុងសង្គមរបស់ខ្លួននិងអ្នកដទៃ, ៣-សម្រាប់អប់រំមនុស្សម្នាក់ៗ ឬរាល់រូប ឱ្យចេះអនុវត្តវិធីក្នុងការធ្វើចិត្តឱ្យស្អាត ដើម្បីរំលាយខ្លួនទៅក្នុងអាត្ម័ន នៃព្រះអាទិទេព ឬដើម្បីកាន់ទីបំផុតទុក្ខ ឬក៏ទៅកាន់ទីដែលព្រះអាទិទេពបាន កម្រិតទុកឱ្យ។ នៅក្នុងផ្នែកទី៣នេះ យើងអាចពោលថា លទ្ធិឬសាសនា អប់រំមនុស្សម្នាក់ៗឱ្យដល់នូវទីដៅរបស់លទ្ធិឬសាសនានីមួយៗក៏បាន។

យើងសូមបញ្ជាក់ថា មុខងារទី១ និងទី៣ បានទាក់ទងដល់បញ្ហាជីវិតបច្ចុប្បន្ននិងវាសនាបន្ទាប់ពីសេចក្តីស្លាប់ ឬជីវិតអនាគតរបស់មនុស្សម្នាក់ៗ ដែលត្រូវរួមរស់នៅក្នុងសង្គមរបស់ខ្លួន ឬសង្គមដទៃទៀតក្នុងលោក ព្រោះមនុស្សម្នាក់ៗ ពុំអាចរស់នៅតែឯកឯងឬម្នាក់ឯងបានឡើយ។ ទាំងអស់នេះ មានលក្ខណៈទូទៅនិងដូចគ្នានៃលទ្ធិនិងសាសនាទាំងឡាយក្នុងលោកទៅតាមមូលដ្ឋាន ប្រក្រតីដើម, ទីដៅ, ភាពអនុវត្ត និងទ្រឹស្តីនៃលទ្ធិនិងសាសនា នីមួយៗ។

នៅទីនេះដើម្បីរកការស្រេបគ្នានៃសភាពមនុស្សនិងវាសនាបន្ទាប់ពីសេចក្តីស្លាប់, យើងសូមកម្រិតព្រំដែនសម្រាប់ការបរិយាយ ចំពោះមហាលទ្ធិនិងមហាសាសនាទាំង ៥ដូចតទៅនេះ ៖

១-លទ្ធិព្រាហ្មណ៍ឬហិណ្ឌូ ៖ នៅក្នុងលទ្ធិព្រាហ្មណ៍ឬហិណ្ឌូ គេជឿថា មនុស្សលោកក៏ជាផ្នែកមួយនៃធម្មសភាវៈ កើតឡើងដោយកម្លាំងជាតុ ទាក់ទងជាមួយនឹងលោកជាតុខាងក្រៅដែរ ដែលគេហៅថា "ព្រះព្រហ្ម" ហើយទីបំផុតនៃជីវិតមនុស្សលោក គឺត្រូវរំលាយខន្ធទៅក្នុងអាត្ម័ននៃព្រះព្រហ្មឬទៅកើតក្នុងភពផ្សេងៗ មានរូបអាក្រក់ ល្អ ជាដើម[៧០] តាមអំណាចកម្មរបស់ខ្លួន។ ប៉ុន្តែជំនឿនេះ បានប្រែពណ៌តាមលំដាប់សម័យនៃការរីកចម្រើន យើងនឹងពោលរឿងនេះដោយសង្ខេប ចំពោះតែធម្មជាតុដែលមានក្នុងចិត្តនៃអ្នកហិណ្ឌូទូទៅ ដូចទៅនេះ៖

លទ្ធិព្រាហ្មណ៍ឬហិណ្ឌូ សម្បូរដោយគំនិតជាទីបំផុតដែលគេយល់ថា គួរដល់ការសិក្សា ហើយគំនិតទាំងអស់នេះ ក្លាយជាមត៌កនិងជាមូលនិធិសម្រាប់ជនានុជនគ្រប់សម័យ តាំងពីសម័យវេទ រហូតដល់សព្វថ្ងៃនេះ, ប៉ុន្តែក្នុងគំនិតទាំងអស់នេះ គ្មានចំណងជើងឬវត្ថុអារម្មណ៍

[៧០] ប៉ែន សាអឿន *សាសនាប្រៀបធៀប* គ.ស.១៩៦៩ ទំ១២០

សូម្បីតិចតួចសម្រាប់ឱ្យយល់ច្បាស់នូវធម្មភាពសុបទូទៅស្តីពីសច្ចធម៌, សភាពមនុស្ស និង អំពើរប្រចាំជីវិតនៃមនុស្សលោកឡើយ។ នៅសម័យវេទ យើងសង្កេតឃើញថា ធម្មភាព ដែលបង្កើតអនុក្រមនិងអំពើដ៏ល្អ ឬសីលធម៌ ហើយអនុវត្តឬប្រព្រឹត្តទៅក្នុងទេវសព៌ន្ត, តារាសព៌ន្ត និងសព៌ន្តកាយនៃសត្វលោកទាំងអស់ បានធ្វើឱ្យគំនិតអ្នកនិពន្ធនៃឫគ្វេទៈ ហៅ ថា ឫតា (Ṛta)។ ឧត្តមគតិនេះ បានសម្ងាប់ខ្លួនឯងតាមលំដាប់សម័យទៅក្នុង ៖ ក-ឧត្តមគតិ អបូរ៌ៈ នៃទស្សនៈមិមាំសា គឺធម្មភាពដែលធានាអះអាងនូវផលវិបាកអនាគតនៃការប្រតិបត្តិ ដែលគេបានធ្វើនៅបច្ចុប្បន្នកាលនេះ, ខ-ទ្រឹស្តីនៃអទ្ធស្ត: របស់ទស្សនៈ ន្យាយ-វៃ សេសិកៈ , គឺធម្មជាតុដែលមើលមិនឃើញ ដែលត្រួតត្រានិងគ្រប់គ្រងរាល់ជាតុបរមាណូទៅទៀត ព្រម ទាំងនាំមកឬបង្កើតនូវសារពើវត្ថុ និងស្ថានហេតុគ្រប់យ៉ាងនៅក្នុងលោកជាដើមថែមទៀត, គ-ឧត្តមគតិទូទៅនៃកម្មៈ។

ក-មិមាំសា បានរីកចម្រើនចេញពីទិដ្ឋភាពនៃការប្រតិបត្តិនៃគម្ពីរវេទៈ ដូចជាគម្ពីរ វេទាន្តៈ បានរីកចម្រើនពីទ្រឹស្តីទាំងឡាយនៃទស្សនៈឥណ្ឌាទាំងអស់ដែរ។ យ៉ាងណាក៏ដោយ យើងឃើញថា ការអនុវត្តនៃទស្សនៈមិមាំសា លោកចែកចេញជា២ប្រភេទគឺ ៖ ១-ទេវវិជ្ជា មានមូលដ្ឋានទៅលើទេវៈ ដែលបញ្ជាក់ពីយជ្ញៈ, ២-ទស្សនវិជ្ជា មានមូលដ្ឋានទៅលើយុត្តិធម៌ ទូទៅនៃជំនឿ ដែលយជ្ញៈត្រូវពឹងផ្អែកទៅលើ។ នៅទីនេះ យើងនឹងពោលពីទិដ្ឋភាពទី២ គឺ ទស្សនវិជ្ជា ដែលទស្សនៈមិមាំសាខំប្រឹងប្រែងបញ្ជាក់ពីយជ្ញៈនៃវេទៈ។ ក្នុងលក្ខណៈនោះ យើងឃើញថា ជំនឿមានមូលដ្ឋានទៅលើយជ្ញៈនៃវេទៈ មានច្រើនប្រការណាស់ ដូចជាជំនឿ ក្នុងកំណើតអាត្ម័ន ដែលបន្ទាប់ពីសេចក្តីស្លាប់នៃមនុស្សម្នាក់ៗ អាចរស់នៅសោយផលក្នុង ឋានសួគ៌បាន, ជំនឿក្នុងថាមពល ដែលអាចរក្សានូវយជ្ញៈជាស្ថាពរ ព្រមទាំងអាចឱ្យផល បាន, ជំនឿថាមានតែគម្ពីរវេទទេ ដែលពិតប្រាកដហើយយជ្ញៈជាស្ថាពរ ព្រមទាំងអាចឱ្យផល បាន, ជំនឿថាមានតែគម្ពីរវេទ ដែលពិតប្រាកដហើយយជ្ញៈអាចឋិតនៅបាន, ជំនឿថាលោក នេះទៀង ហើយជីវិតរបស់យើងនិងអំពើដែលគេបានធ្វើនៅជាតិនេះ មុខជាមិនមែនគ្រាន់តែ យល់សប្តិឡើយជាដើម។

ការអនុវត្តដ៏សំខាន់មួយនៃទ្រឹស្តីមិមាំសា សម្រាប់ដោះស្រាយនូវបញ្ហានៃកម្ម គឺការធ្វើ យជ្ញៈ ព្រមទាំងផលវិបាកនៅក្នុងឋានសួគ៌ បានដល់ទ្រឹស្តី អបូរ៌ ៖ គឺឥទ្ធិពលនៃអាត្ម័ន សម្រាប់ការរីករាយដែលជាផលវិបាកនៃយជ្ញៈ។ អាត្ម័ន គឺជាមូលដ្ឋានធំបំផុតនៃយជ្ញៈ ជា

សភាវៈទៀងអាចទទួលផលវិបាក សព្វយ៉ាងបន្ទាប់ពីសេចក្តីស្លាប់ៗ អាត្ម័ននៅក្នុងឧត្តមគតិនៃមិមាំសា[71] មានលក្ខណៈដូចគ្នានឹងទ្រឹស្តីន្យាយៈ-វៃសេសិកៈដែរ។

ខ-អទ្ទិស្តៈ របស់ន្យាយ-វៃសេសិកៈ គឺជាកន្លែងសម្រាប់ទទួលនិងផ្ទុកកុសលនិងអកុសល ដែលជាលទ្ធភាពនៃកម្មអាក្រក់-ល្អ នៃមនុស្សម្នាក់ៗនៅក្នុងលោកនេះ។ ការរីករាយសប្បាយ និងការកើតទុក្ខទាំងអស់កើតឡើងពីអំពើរបស់ខ្លួនតែម្យ៉ាង។ ប៉ុន្តែទាំងអស់នេះនៅក្រោមមូលដ្ឋាននៃអាទិទេព គឺព្រះអាទិទេពជាមគ្គុទ្ទេសក៍ជំបំផុត។

គ-កម្មៈ នៅក្នុងទស្សនៈនៃឥណ្ឌាទូទៅ លើកលែងតែទស្សនៈ ចារវាកៈមួយចេញទទួលថាជាធម្មជាតិពិតទាំងអស់។ ដទៃពីទស្សនៈ ជេននិងពុទ្ធសាសនា យើងឃើញថា កម្មៈនៃទស្សនៈន្យាយៈ, វៃសេសិកៈ, សង្ខ្យា, យោគៈ, មិមាំសា និង វេទាន្តៈ ឋិតនៅក្រោមឥទ្ធិពលនៃព្រះអាទិទេពទាំងអស់។

នៅក្នុងលទ្ធិព្រាហ្មណ៍ យើងសង្កេតឃើញម្យ៉ាងទៀតថា វត្ថុបំណងនៃជីវិតរបស់អ្នកហិណ្ឌូទូទៅ តាមលក្ខណៈនៃទស្សនៈនិងចិត្តវិទ្យា មាន៤ប្រភេទគឺ ៖

១-ព្រហ្មចរិយាស្រម ៖ វត្ថុបំណងនៃជីវិតសម្រាប់កូនសិស្សគ្រឹម្នាក់ៗ ដែលកំពុងសិក្សារៀនសូត្រអក្សរសាស្ត្រ សិល្បសាស្ត្រ ជាដើម ត្រូវតែឋិតនៅក្នុងព្រហ្មចរិយធម៌។ អាស្រមនេះមានឥទ្ធិពលដ៏មហិមា សម្រាប់រៀបចំជីវិតទាំងផ្លូវលោក និងផ្លូវធម៌នៅក្នុងសង្គម។

២-គ្រូហស្ថាស្រម៖ វត្ថុបំណងនៃជីវិតសម្រាប់គ្រហស្ថបានកំណត់ឱ្យជនម្នាក់ៗ អាពាហ៍ពិពាហ៍ជាប្តីប្រពន្ធ។ ទាំងអស់នេះ ដោយគម្ពីរវេទបានបញ្ជាក់ថា ៖

-ប្រជនាថំ ស្រ្តិយៈ ស្រិម្នាៈ សន្តានាថំច មាណវ តស្មា សាធារណោ ធម៌ៈ ស្រ្តូតៅ បត្ន្យា សហោទិតៈ

"ដើម្បីជាម្តាយទាំងឡាយ ព្រះបានបង្កើតស្ត្រីទាំងឡាយ (ក្នុងលោក), ដើម្បីជាឪពុកទាំងឡាយ ព្រះបានបង្កើតមនុស្សប្រុសទាំងឡាយ (ក្នុងលោក) ព្រោះហេតុនោះ វេទៈបានសន្មតថា ព្រះធម៌ ត្រូវតែប្រតិបត្តិដោយប្តីនិងប្រពន្ធ"។

៣-វានប្រស្ថាស្រម ៖ វត្ថុបំណងនៃជីវិតសម្រាប់អ្នកចូលនិវត្តន៍ បានកំណត់ឱ្យជនម្នាក់ៗលះបង់ផ្ទះសម្បែងស្វែងរកព្រះធម៌នៅក្នុងព្រៃ និងរៀបចំខ្លួនដើម្បីចូលកាន់ជីវិតស្ងប់ស្ងាប់ប្រាសចាកតណ្ហា និងមន្ទិលទាំងឡាយ។

[71] ប៉ែន សារឿន *សាសនាប្រៀបធៀប* ១៩៦៩ ទំ១២១

៤-សំន្យាស្យាស្រម ៖ វត្ថុបំណងនៃជីវិតសម្រាប់ពួកតាបសអ្នកលះបង់គ្រប់យ៉ាង ដើម្បីសាងចិត្តឱ្យរួចចាកកិលេសតណ្ហា។

កាលពីដើម តាមឯកសាររបស់លោក ប-ម-មោទិ (Development of the systems of ASRAMAS) លោកម៉ាកដូណែល និងកេត (Vodic Indox), លោក វៃទ្យ: (History of Sanskrit Literature) បញ្ជាក់ថា "អាស្រម: (វត្ថុបំណងនៃជីវិត) មានតែ៣ បែបទេគឺ ៖ ព្រហ្មចរិយាស្រម: គ្ហស្ថាស្រម: និងវានប្រស្ថាស្រម: "[៧២] ឬសំន្យាសី, ប៉ុន្តែខាងក្រោយមក គេបានចែកឱ្យស្រឡះពីគ្នា៤បែបគឺ ៖ ព្រហ្មចរិយាស្រម (ជីវិតកូនសិស្ស), គ្ហស្ថាស្រម: (ជីវិតគ្រហស្ថ ឬអ្នកទ្រទ្រង់ផ្ទះ), វានប្រស្ថាស្រម: (ជីវិតគ្រហស្ថអ្នកចូលកាន់និវត្តន៍) និងសំន្យាស្យាស្រម: (ជីវិតតាបសឬអ្នកបួស)។

ម្យ៉ាងទៀត ដើម្បីទ្រទ្រង់ជីវិតសង្គមឱ្យមានស្ថិរភាព, នៅក្នុងលទ្ធិព្រាហ្មណ៍ឬហិណ្ឌូ គេចែកវណ្ណៈនៃមនុស្សជា ៤ក្រុមគឺ ព្រាហ្មណ៍វណ្ណៈ (ពួកអ្នកចេះវេទ:), ក្សត្រិយវណ្ណៈ (ពួកអ្នកគ្រប់គ្រងរដ្ឋនិងជាអ្នកចម្បាំង), វេស្សវណ្ណៈ (ពួកអ្នកជំនួញ) និងសូទ្រវណ្ណៈ (ពួកកម្មករ)។ វណ្ណៈទាំង៤នេះ គឺគេចែកតាមរចនាសម្ព័ន្ធនិងមុខងាររបស់ខ្លួន។

យើងសូមបញ្ជាក់ថា ប្រព័ន្ធទាំង ២ អាស្រមប្រព័ន្ធ និងវណ្ណប្រព័ន្ធ តែងប្រព្រឹត្តទៅនិងមានសម្ព័ន្ធភាពទៅវិញទៅមកជានិច្ច សម្រាប់បុគ្គលមួយរូបៗ និងសម្រាប់សង្គម នៅក្រោមមូលដ្ឋាននៃលទ្ធិព្រាហ្មណ៍ ឬហិណ្ឌូ។

ចំពោះវាសនាបន្ទាប់ពីសេចក្ដីស្លាប់ យើងសង្កេតឃើញទ្រឹស្ដីនិងជំនឿទូទៅនៅក្នុងលទ្ធិព្រាហ្មណ៍ឬហិណ្ឌូ ដូចតទៅនេះ ៖

ក-សម័យវេទ និងព្រាហ្មណ៍ ៖ នៅសម័យវេទ យើងឃើញថាវាសនាបន្ទាប់ពីសេចក្ដីស្លាប់នៃមនុស្សម្នាក់ៗ អ្នកប្រព្រឹត្តឬទទួលវេទជាមាគ៌ាជីវិត គឺត្រូវព្រះអគ្និបញ្ជូនភាគដែលមិនកើតឡើងទៀត (អាត្ម័ន) ទៅកាន់ធម្មិកលោក (ឋានសួគ៌) (Rigveda, X. XVI.I-5)។ ឯផ្នែកដទៃទៀត ព្រះអគ្និបានបញ្ជូនទៅព្រះយម:, ភ្នែកទៅកាន់ព្រះអាទិត្យ, ដង្ហើមទៅកាន់ខ្យល់ជាដើម។ មុនពេលដែលអាត្ម័នអាចបង្គ្រប់ថ្នាក់ពីផែនដីទៅឋានសួគ៌ថ្នាក់ទី៣, អាត្ម័នត្រូវឆ្លងកាត់ភាពងងឹតយ៉ាងឆ្ងាយជាទីបំផុត។ បន្ទាប់ពីលះបង់ភាពអាក្រក់និងមិនបរិសុទ្ធ ទាំងអស់នៅលើផែនដី រួចអណ្ដែតតាមផ្លូវដែលបុព្វបុរសធ្លាប់បានដើរហើយ, អាត្ម័នមានពន្លឺសន្ធោ

[៧២] ប៉ែន សាអឿន សាសនាប្រៀបធៀប ១៩៦៩ ទំ១២២

សន្ទៅដូចជាទេវតាទាំងឡាយដទៃទៀតដែរ។ បន្ទាប់មក អាត្មន័កបែរ រូបចូលទៅក្នុងអាណាចក្រដែលភ្លឺរន្ទាលប្រាលផ្លោជានិច្ច ហើយក៏ចូលទៅកាន់ព្រះយមៈ ដើម្បីជំនុំជម្រះអំពើផ្សេងៗ ទើបចូលទៅកាន់ឋានបរមសុខហោង (Rigveda, Z. XIV.7.)។ តាមសេចក្ដីរាយការណ៍របស់លោក រ.វេ.ហ្វ្រេស័រ[៧៣] យើងឃើញថា លោកបញ្ជាក់ដូចតទៅនេះ ៖

"នៅក្នុងសករាជនៃវេទ សេចក្ដីស្លាប់ គេទុកជាការចេញចាកពីដង្ហើមមានជីវិត (រស់) ឬផ្នែកមានគំនិតចិត្ត (ចិត្ត) ដែលឋិតនៅក្នុងបេះដូង... ឋានសួគ៌ជាទីសប្បាយរីករាយនៅលោកឯនាយដែលពពួកអ្នកទ្រទ្រង់វេទរង់ចាំជានិច្ច។ គ្រប់ស្លោកទាំងអស់នៃវេទ យើងឃើញថា ពុំមានការព្រួយបារម្ភពីជីវិត, ពុំមានទុទិដ្ឋនិយមឡើយ"។

យើងសូមបញ្ជាក់ថា បន្ទាប់ពីសេចក្ដីស្លាប់នៃមនុស្សម្នាក់ៗមក, អាត្ម័នរបស់គេទៅសោយសុខនៅឋានសួគ៌ លែងវិលត្រឡប់មកកើតជាមនុស្សទៀតឡើយ[៧៤]។ នៅក្នុងគម្ពីរ តៃតិរិយៈ ព្រាហ្មណៈ យើងសង្កេតឃើញសេចក្ដីបរិយាយពីវាសនា បន្ទាប់ពីសេចក្ដីស្លាប់ នៃមនុស្សម្នាក់ៗដូចនេះគឺ ៖ "អាត្ម័នរបស់អ្នកស្លាប់ នឹងទៅឋិតនៅក្នុងឋានសួគ៌ ខាងលើ ពួកផ្កាយ ហើយនៅក្នុងពពួកផ្កាយទាំងឡាយនោះ គឺជាពន្លឺរបស់ពពួកអ្នកធម្មិកទាំងឡាយ ដែលកើតក្នុងឋានសួគ៌"។ គម្ពីរ សតបថៈ ព្រាហ្មណ៍ ពោលថា "មរណភាព គឺជាតួ ព្រះអាទិត្យមានកាំពន្លឺភ្ជាប់ទៅនឹងដង្ហើមរស់របស់អ្នកស្លាប់", ប៉ុន្តែគម្ពីរកថៈ ឧបនិស័ទ បានប្រកាសប្រឆាំងថា "យើងមិនមែនរស់នៅដោយអំណាចដង្ហើមដកចេញ-ចូលឡើយ គឺមានធម្មសភាវៈដទៃទៀតដែលត្រួតត្រាដង្ហើមចេញ-ចូលទាំងនោះគឺអាត្ម័នមានលក្ខណៈ តួបង្ហារជាងជីវិតទៅទៀត..."។

ខ-សម័យឧបនិស័ទ ៖ នៅសម័យនេះ យើងឃើញថាទ្រឹស្ដីពោលពីវាសនាបន្ទាប់ពីសេចក្ដីស្លាប់នៃមនុស្សម្នាក់ៗ មានការប្រែប្រួលពីសម័យវេទយ៉ាងច្រើនក្នុងលក្ខណៈបន្ថែមពណ៌ខ្លះទៅលើគំនិតដើម។ គម្ពីរឧបនិស័ទបានបញ្ជាក់ថា "អាត្ម័ននៃអ្នកដែលរួចចាកតណ្ហានឹងរលាយចូលទៅក្នុងអាត្ម័ននៃព្រះព្រហ្ម"។ម្យ៉ាងទៀតយើងឃើញសេចក្ដីរាយការណ៍របស់លោក ត.វ.រីស ដាវិដ្ស ថា "វាត្រូវមានវិជ្ជមានដោយអំណាចនៃបែបទេវវិទ្យានិងប្រាជ្ញបុព្វទិដ្ឋិ ដោយសញ្ញាដែលជាវិទ្យាដ៏ល្អិតល្អន់ថា អាត្ម័នរបស់ខ្លួន ត្រូវរលាយចូលទៅក្នុងមហាត្ម័ន គឺ

[៧៣] R.W.Frazer, "Literary-History of India", London, 1808,pp.36-38

[៧៤] ប៉ែន សាអឿន *សាសនាប្រៀបធៀប* ១៩៦៩ ទំ១២៣

*ព្រះព្រហ្ម ដែលគេទុកជាមូលដ្ឋាននិងធម្មសភាវៈដ៏ពិតប្រាកដ[៧៥]។ នៅក្នុងគម្ពីរកៅស៊ីតគី ព្រាហ្មណៈ ឧបនិស័ទ គេប្រកាសថា "អាត្មន់នៃអ្នកស្លាប់នឹងទៅកាន់ព្រះចន្ទជាមុនៗ នៅក្នុងថ្ងៃពេញបូណ៌មីដែលព្រះចន្ទពេញវង់ ពន្លឺនោះជាពន្លឺនៃចិត្តរបស់អ្នកស្លាប់នោះឯង, លុះដល់ពេលរនោច ចិត្តនោះនឹងត្រូវទៅចាប់កំណើតថ្មីទៀតៗ ព្រះចន្ទគឺជាទ្វារនៃឋានសួគ៌"ៗ*

*២. ព្រះពុទ្ធសាសនា សភាពមនុស្សនៅក្នុងព្រះពុទ្ធសាសនា ដូចយើងបានឃើញ នៅក្នុងមូលប្រតិស្ឋនៃលោកខាងដើមរួចមកហើយថា អ្វីទាំងអស់ព្រមទាំងលោកទាំងមូល កើតឡើងពីកម្លាំងធាតុទាំង៤ មន្តធាតុព្រមទាំងអាកាសធាតុ ដែលលោកហៅថា "អវិជ្ជា", ហើយសារពើវត្ថុទាំងអស់នោះ ត្រូវឋិតនៅក្រោមអំណាចនៃព្រះត្រៃលក្ខណ៍ ដែលនៅក្នុងព្រះត្រៃលក្ខណ៍នោះ បានបញ្ជាក់ថាពុំមានអាត្មន៍ឬខ្លួននៅក្នុងមនុស្សសោះឡើយៗ បើពុំមានអាត្មន៍ (អនាត្មន៍) នៅក្នុងខ្លួនយើងទេ, តើបុគ្គលិកលក្ខណៈរបស់មនុស្សគ្រប់រូបឋិតនៅក្នុងទីណា? អ្វីហៅថាមនុស្ស? តើត្រូវមានសំយោគដូចម្តេចទៅវិញ កាលណាគេប្រើពាក្យថា "ខ្ញុំ" ?*

*ដើម្បីយល់ច្បាស់នូវប្រស្នាទាំងអស់នោះ មនុស្សទាំងឡាយនៅក្នុងលោក បានខិតខំស្វែងរកនិងសិក្សា យើងគេឃើញនឹងជឿថា នៅក្នុងខ្លួនរបស់មនុស្សលោក ត្រូវតែមាន "សភាវៈដ៏សំខាន់មួយ" សម្រាប់កំណត់សំគាល់ជាចាំបាច់ៗ ធម្មសភាវៈដែលគេ[៧៦] បានរកឃើញនោះ គេឱ្យឈ្មោះថា"អាត្មន៍ឬព្រលឹង,ជីវិត..."ជាដើមៗ ប៉ុន្តែបើយើងពិចារណាឱ្យត្រឹមត្រូវទៅយើងនឹងឃើញថា ធម្មកត្តានោះមិនមែនឱ្យយើងយល់ច្បាស់នូវពាក្យថា "មនុស្ស" បានឡើយៗ តាមពិតពាក្យថា "មនុស្ស គឺផ្សំឡើងពីចិត្តនិងរូប ហើយគ្រឿងផ្សំទាំងពីរនោះតែងប្រែប្រួលឥតឈប់ឈរតាំងពីកើតឡើងរហូតដល់ស្លាប់ទៅវិញ, ជាមពលនៃមរណកត្តាឱ្យកំណើតដល់បដិសន្ធិកត្តា ៗឱ្យកំណើតដល់មរណាកត្តា ហាក់ដូចជាគ្រឿងយន្ត ឬចក្រវិលទៅវិញទៅមកឥតឈប់ឈរ, លុះត្រាតែធម្មព្រឹត្តទាំងអស់នោះរលត់អស់ ទើបអស់ឥទ្ធិពលកំណើត និងការស្លាប់ទាំងនោះបាន, ហើយលក្ខណៈបែបនេះ លោកហៅថា "និព្វាន"ៗ គ្រឿងផ្សំនៃមនុស្សអាចប្រៀបបានជាមួយនឹងគ្រឿងផ្សំរទេះឬគ្រឿងយន្តៗ តើមានសំយោគដូចម្តេចដែរ កាលណាគេនិយាយថា"រទេះ?" រទេះគ្មានតាមការពិនិត្យទូទៅ, "ភាគដ៏សំខាន់ជាមជ្ឈមណ្ឌល" សោះឡើយ នៅក្នុងតួរទេះទាំងមូលៗ តាមពិតពាក្យថា "រទេះ" កើតឡើង*

---

[៧៥] T.W.Rhys Davids, "Buddhist India", London, 1903,p.254.

[៧៦] *ប៉ែន សាអឿន សាសនាប្រៀបធៀប ១៩៦៩ ទំ១២៤*

សោយគ្រឿងផ្សំ ដូចជាកាំ, កង់, ដុំ, ទូក, នឹម, បន្ទញ, និងប្រដាប់ផ្សេងៗទៀត ជាច្រើនៗ បើមិនមានវត្ថុឬប្រដាប់ជាគ្រឿងសម្រាប់ប្រកបឬផ្សំទាំងអស់នេះទេ ពាក្យថា "រទេះ" ក៏ពុំមានរូបរាងជារទេះឡើយ។ ដូច្នេះពាក្យថា "រទេះ" កើតពីវត្ថុសម្រាប់ជា គ្រឿងផ្សំផ្គុំដូចគ្នានឹងពាក្យថា "មនុស្ស" ដែលមានចិត្តនិងរូបជាគ្រឿងផ្សំឡើងដែរ។ នៅក្នុងខ្លួនមនុស្សពុំមាន "អាត្មន័ៗ ជាមជ្ឈមណ្ឌល ហើយពុំមានផ្នែកណាមួយសំខាន់ជាងផ្នែកមួយទៀតនោះឡើយ។ ត្រង់នេះព្រះពុទ្ធបានបញ្ជាក់ថា "កាលណាមនុស្សទាំងឡាយប្រកាន់ជឿថា គេបានឃើញនិងគេបានរៀនឬដឹងថាមាន "អាត្មន័" តាមពិតគេទាំងឡាយនោះ បានឃើញ និងចេះតែពីរូបសម្បទា និងចិត្តសម្បទា ដែលគេបានពិសោធរកឃើញភ្លាមៗប៉ុណ្ណោះ"។

ដើម្បីយល់ច្បាស់នូវអត្ថន័យនៃពាក្យថា "ខ្ញុំ" យើងសូមលើកយកឧទាហរណ៍ ៣ បែប មកពន្យល់ដូចតទៅនេះ ៖

១-នៅពេលដែលខ្ញុំនិយាយ "ខ្ញុំកំពុងនៅទីនេះ" ឬ "ខ្ញុំបាននៅទីនោះហើយ" តើពាក្យថា "ខ្ញុំ" នោះ មានន័យសម្គាល់ដូចម្ដេច? យើងអាចឆ្លើយថា ពាក្យថា "ខ្ញុំ" ដែលគេប្រើនៅទីនេះ មានន័យសម្រាប់សម្គាល់នូវទីកន្លែងជាពិសេស "របស់ខ្លួននៃខ្ញុំ" ប៉ុណ្ណោះទេ។ ម្យ៉ាងទៀត នៅពេលដែលខ្ញុំនិយាយ"សៀវភៅនោះនៅឯណោះ, ជងស្មោរនៅឯណោះ" ទាំងពីរប្រយោគនេះ មានន័យប៉ុនគ្នានឹងពាក្យថា "ខ្ញុំកំពុងនៅទីនេះ" ដែរ។ ដូច្នេះ នៅទីនេះ គេគ្រាន់តែបញ្ជាក់ពីទីកន្លែងផ្សេងគ្នានៃ "សៀវភៅ, ជងស្មោរ, និងខ្ញុំ", ហើយពាក្យថា "ខ្ញុំ" នៅក្នុងឧទាហរណ៍ទី ១ នេះ បានន័យតែត្រឹម "ខ្លួនរបស់ខ្ញុំ" ប៉ុណ្ណោះទេ គ្មានអ្វីប្លែកពីនេះឡើយ។

២-នៅពេលដែលខ្ញុំនិយាយ "ខ្ញុំគិត" តើពាក្យថា "ខ្ញុំ" នៅទីនេះ បានន័យដូចម្ដេច? ពាក្យថា "ខ្ញុំ" នៅទីនេះ មិនមែនបានន័យថា "ខ្លួនឬរាងកាយ" ដូចសំណួរខាងលើ[៧៧] ព្រោះតាមពិត វាអាចគិតពីនេះពីនោះ ដែលយើងអាចឱ្យអត្ថន័យតាមលក្ខណៈនិងប្រក្រតីដើមថា "ចិត្ត, ការត្រិះរិះ, គំនិត ឬការគិត" ហើយដែលមានតែចិត្តទេទើបគិតពីនេះពីនោះ ឬសន្សំនូវអារម្មណ៍ដែលដឹងបាន។

៣-នៅពេលដែលខ្ញុំនិយាយ "ខ្ញុំនិយាយ" តើពាក្យថា "ខ្ញុំ" នៅទីនេះបានន័យដូចម្ដេច ? យើងអាចពោលថា ពាក្យថា "ខ្ញុំ" នៅទីនេះ មិនមែនសម្រាប់ធម្មសភាវៈតើរូបនិងចិត្តណាមួយឡើយ, ពាក្យនេះ សម្រាប់បញ្ជាក់នូវអំពើរួមគ្នានៃចិត្តនិងរូប។ អណ្ដាតពុំអាច (ជារបស់

---

[77] ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១២៥

រាងកាយ) និយាយប្រាកចាកចិត្ត ឬចិត្តមិនអាចនិយាយប្រាសចាកអណ្តាតឡើយ។ ដូច្នេះ ការនិយាយអាចប្រព្រឹត្តទៅបានកាលណាអណ្តាតហើយនិងចិត្តរួមគ្នា។

ដូចពោលមកខាងលើនេះ យើងឃើញថា ពាក្យថា "ខ្ញុំ" គឺជួនកាលគេប្រើសម្រាប់ហៅ "ចិត្ត" ជួនកាលសម្រាប់ហៅ "រូបរាងកាយ" ហើយជួនកាលទៀត សម្រាប់ហៅដោយរួមគ្នាទាំងចិត្តទាំងកាយ ព្រោះពាក្យថា "មនុស្ស" មានគ្រឿងផ្សំជា២បែបគត់ គឺរូបសម្បទានិងចិត្តសម្បទា។ បើប្រសិនជាគេធ្វើវិភាគឱ្យវែងឆ្ងាយទៅទៀត គេនឹងឃើញថា សម្បទាទាំងពីរនេះ ប្រកបដោយធម្មកត្តា៥យ៉ាងគឺ រូប (ធាតុ៤, កាយ, វិញ្ញាណ, ប្រសាទ, វេទនា, (អារម្មណ៍, សុខ, ទុក្ខ និងអព្យាក្រឹត), សញ្ញា (ចិត្តសំយោគ, កិច្ចសំយោគ, អារម្មណ៍សំយោគ, បញ្ញត្តិសំយោគ), វិញ្ញាណ (ញាណកិច្ច)។ ធម្មកត្តាទាំង៥នេះ លោកហៅថា "បញ្ចក្ខន្ធ" ហើយពាក្យថា "មនុស្ស" ក៏គឺមានគ្រឿងផ្សំទាំង៥នេះឯង ដូចជាតុមួយមានជើងបួន និងផ្នែកគ្រឿងផ្សំផ្សេងទៀតជាច្រើន ឬដូចជារទេះ កើតឡើងដោយគ្រឿងផ្សំជាច្រើនដែរ។ គួរកត់សម្គាល់ បញ្ចក្ខន្ធទាំង៥នេះ មិនមានឯកភាពដោយខ្លួនឯងឡើយ, តាមពិត ខន្ធនីមួយៗក៏កើតឡើងដោយគ្រឿងផ្សំដែរ ហើយខន្ធនីមួយៗ មានសន្តានព្រឹត្តិរបស់ខ្លួន (អភិធម្មទាំង ៧គម្ពីរ គឺព្រះសង្ឃទ្រង់សម្តែងឡើង ដើម្បីបញ្ជាក់ពីសភាពមនុស្សតែម្យ៉ាង,សូមមើល "អភិធម្មត្ថសង្គហៈ" ប្រែសម្រួលដោយព្រះមហាមុនី អ៊ុប-ស៊ូ , មានលក់នៅពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។)។

កាលណាយើងពោលពី "មនុស្ស" យើងត្រូវពោលពីកម្មឬអំពើដែលមនុស្សត្រូវយកចិត្តនិងកាយទៅប្រកបផង។ បើប្រសិនជាមិនមានអាត្មន៍ទេ តើអ្វីសម្រាប់វិនិច្ឆ័យនិងទទួលសោយនូវអំពើឬកម្មដែលមនុស្សម្នាក់ៗ បានប្រកប? បញ្ហានេះ មានលក្ខណៈដូចគ្នានឹងបញ្ហាដែលស្តេចមិលិន្ទៈ ទ្រង់សួរចំពោះព្រះនាគសេនដែរ។ ព្រះនាគសេនឆ្លើយថា "បពិត្រ ព្រះសម្មតិទេព, រឿងនេះ ទាំងមិនមែនដូចគ្នាផ្សេងគ្នា" **(ន ចសោ្វ ន ច អញ្ញោ)**។ ព្រះនាគ សេនបានបញ្ជាក់ចម្លើយនេះ ដោយឧបមា-ឧបមេយ្យថា ដូចតទៅនេះ ៖

"បពិត្រព្រះរាជា បើគេប្រៀបមនុស្សជាមួយនឹងពន្លឺចង្កៀងថា តើចង្កៀងនោះអាចឆេះពេញមួយយប់បានឬទេ ? ព្រះរាជាមានព្រះរាជឱង្ការថា ព្រះករុណា ចង្កៀងនោះអាចឆេះពេញមួយយប់បាន [៧៨]។

"តើអណ្តាតភ្លើងចង្កៀងនៅយាមទីមួយ ដូចគ្នានឹងយាមទីពីរឬទេ ?

[78] ប៉ែន សាអឿន *សាសនាប្រៀបធៀប,* ១៩៦៩ ទំ១២៦

-ទេ, អណ្ដាតភ្លើងមិនដូចគ្នាទេ។

"តើអណ្ដាតភ្លើងនៅយាមទីពីរ ដូចគ្នានឹងយាមទីបីឬទេ?

-ទេ, មិនដូចគ្នាសោះឡើយ។

"បើដូច្នេះមែន, តើនៅយាមទី១ មានចង្កៀងមួយ, ទី២ មានមួយ និងទី៣ មានចង្កៀងមួយឬ ?

-ទេ, តាមពិត ពន្លឺចង្កៀងចេញមកពីចង្កៀងតែមួយគត់ ហើយប្រព្រឹត្តទៅគ្រប់យាមទាំង ៣ នៃយប់មួយ។

"បពិត្រព្រះរាជា នេះដូចគ្នានឹងអន្ដានព្រឹត្តិឬការប្រព្រឹត្តិទៅតៗ គ្នានៃបុរិសៈមួយឬវត្ថុមួយ ឬក៏ធម្មសភាវៈមួយដែរ។ កាលណាបុរិសៈមួយចូលមកវិជ្ជមាន, បុរិសៈមួយទៀតត្រូវវិនាសទៅវិញជាធម្មតា។ ដូច្នេះយើងអាចពោលថា ធម្មសភាវៈនោះនឹងថាដូចគ្នាក៏មិនមែន, បានន័យម្យ៉ាងទៀតថា មនុស្សនោះតែមួយគត់ ប៉ុន្ដែវាប្រព្រឹត្តទៅតាមលំដាប់ នៃជីវិត និងចិត្តរហូតដល់ទីបំផុត។

យើងអាចប្រៀបធៀបមនុស្សទៅនឹងចង្កៀង ដែលមានចិត្តអាចប្រៀបធៀបបានដូចជាអណ្ដាតភ្លើងចង្កៀង មានការប្រែប្រួលឥតឈប់ឈរសោះឡើយ, ឯរូបកាយរបស់មនុស្ស ក៏មានលក្ខណៈមិនទៀងទាត់ (អនិច្ចៈ) វាអាចប្រព្រឹត្តទៅតាមប្រក្រតីរបស់វា។ ដូច្នេះយើងអាចសម្រេចថា មនុស្សធ្វើអំពើ ឬកម្ម និងអ្នកដែលទទួលនូវផលវិបាកនៃអំពើនោះ នឹងថាដូចគ្នាក៏មិនមែន នឹងថាផ្សេងគ្នាក៏មិនមែនដែរ, ប៉ុន្ដែមានខ្សែទឹកហូរតែមួយគត់ ដែលនៅទីនោះមានរលកមួឡើងតូចៗ កើតឡើងហើយរលាយទៅវិញ ហើយឱ្យកំណើតទៅរលកថ្មីទៀតជានិច្ច។ វាអាចប្រព្រឹត្តទៅយ៉ាងនេះដរាបដល់រលត់សូន្យទៅវិញតែម្ដង។

តាមពិត, ភ្លើងឆេះនៅទីបំផុតព្រៃម្ខាងហើយ បន្តទៅឆេះនៅខាងចុងព្រៃម្ខាងទៀត, តើភ្លើងដែលឆេះនៅខាងចុងនិងភ្លើងដែលឆេះនៅព្រៃម្ខាងទៀតនោះដូចគ្នាឬផ្សេងគ្នា ? ឆ្លើយថាមិនមែនដូចទាំងមិនមែនផ្សេងគ្នា, ប៉ុន្ដែភ្លើងទាំងអស់មានសន្តានតៗជាខ្សែ ជាស៊ីងនិងប្រព្រឹត្តិ។ ចិត្តប្រព្រឹត្តិរបស់មនុស្សក៏មានលក្ខណៈដូចគ្នា។ អំពើអាក្រក់និងល្អ ដែលចិត្តបានប្រព្រឹត្ត និងបានគិតនៅឋានចុងម្ខាង នឹងប្រាកដជាបង្ហាញនូវផលវិបាកនៅចុងម្ខាងទៀតជាដរាប។ ដូច្នេះ មនុស្សមិនមានធម្មកត្តាជានិច្ចៈ (ទៀង), មិនមានអាត្ម័ន គឺមនុស្សមានចិត្ត ដែល

មានលក្ខណៈប្រែប្រួលជានិច្ច លិចអណ្តែតៗ, លិចទៅតាមទ្វារទាំង៥ (ចំពោះបដិសន្ធិនៃមនុស្ស សូមមើលអភិធម្មត្ថសង្គហៈ) ។

ចំពោះវាសនាបន្ទាប់ពីសេចក្តីស្លាប់ យើងឃើញថា ព្រះពុទ្ធសាសនាបានបញ្ជាក់ថា "យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា" "សត្វទាំងឡាយនឹងទៅសោយផលបុណ្យនិងផលបាបទៅតាមសមគួរដល់កម្មរបស់ខ្លួន(ចំពោះវាសនាបន្ទាប់ពីសេចក្តីស្លាប់សូមមើល អភិធម្មត្ថសង្គហៈដែរ)។ ចំពោះបដិសន្ធិថ្មីទៀតនៃសត្វលោក យើងឃើញថា កាលណាសត្វទាំងឡាយមិនទាន់អស់កម្មទេ ត្រូវតែកើតទៀតជាដរាប (២-សូមមើល "មូលប្រតិស្ឋនៃលោក" ត្រង់បញ្ហាលោកធាតុខាងដើមៗ)[៧៩]។

**៥-លទ្ធិសាកលនិយមចិន ៖** នៅក្នុងលទ្ធិសាកលនិយមចិន ចំពោះសភាពមនុស្សនិងវាសនាបន្ទាប់ពីសេចក្តីស្លាប់ យើងឃើញសេចក្តីសំខាន់ទូទៅដូចតទៅនេះ ៖

ថ្ងៃមួយប្រហែលជាជិត ២៥០០ ឆ្នាំកន្លងទៅហើយ កូនសិស្សម្នាក់បានសួរលោកខុង ជឺ "មហាគរុ សូមលោកមេត្តាប្រាប់យើងពីជីវិតបន្ទាប់ ពីសេចក្តីស្លាប់ឱ្យយើងបានដឹងច្បាស់ផង" លោកខុង ជឺ បានឆ្លើយថា "យើងមិនទាន់បានដឹងជីវិតនៅបច្ចុប្បន្ននេះផង តើយើងអាចដឹងនូវជីវិតបន្ទាប់ពីសេចក្តីស្លាប់ដូចម្តេចកើត [៨០]? ។

យើងសូមបញ្ជាក់ថា ប្រព័ន្ធសង្គមរបស់ចិន យ៉ាងហោចណាស់មុនពេលឥទ្ធិពលនៃលទ្ធិក្រហម, មិនមានមូលដ្ឋានទៅលើលទ្ធិសាសនាឡើយ, តាមពិត ប្រព័ន្ធខ្សែគំនិតនៃសង្គមរបស់ចិន មានមូលដ្ឋានទៅលើពាក្យប្រៀនប្រដៅប្រកបដោយសីលធម៌របស់លោកខុង ជឺ តែម្យ៉ាងៗ ឯឧត្តមគតិស្តីពីអាទិទេព ក៏ពុំមានលក្ខណៈសំខាន់ដល់ទឹកចិត្តចិនដែរ ព្រោះឧត្តមគតិនៃអាទិទេពនោះពុំមានបុគ្គលិកភាពច្បាស់លាស់ដូចជារបស់ពួកគ្រិស្ត, ហិណ្ឌូ, ជីវ និងពួកអ៊ិស្លាមឡើយ។

នៅក្នុងបុព្វប្រវត្តិសាស្រ្តនៃឧត្តមគតិទូទៅរបស់ជាតិចិន យើងឃើញថា មានអង្គជាសម្ព័ន្ធភាពជានិច្ចរវាងមនុស្សលោកនិងធម្មជាតិ។ កាលណាមនុស្សលោកណាមួយម្នាក់ប្រព្រឹត្តខុស,ឋានសួគ៌នឹងបណ្តាលឱ្យមានអួរអ័ព្ទ ហើយដែនដីនឹងមិនឱ្យផលល្អដល់ដំណាំ"។ ដើម្បីឱ្យស្របនឹងគោលគំនិតសម្ព័ន្ធភាពទាំងអស់នោះ គេត្រូវកប់ខ្មោចនៅខាងក្រោមគំនរដី

---

[៧៩] ប៉ែន សាអឿន *សាសនាប្រៀបធៀប,* ១៩៦៩ ទំ១២៨

[៨០] សូមមើល "The World's Creat Religions", Life special Edition for young Readers, p.59.

យ៉ាងខ្ពស់ ដើម្បីឱ្យជីជាតិដល់ផែនដី។ម្យ៉ាងទៀត ផ្នូរខ្មោចហើយនិងផ្ទះសម្រាប់រស់នៅរបស់គេត្រូវតែស្ថាបនាឡើង ឱ្យត្រូវតាមចង្វាក់របស់ចក្រវាល, បើមិនដូច្នោះទេ ពួកខ្មោចបិសាចនឹងមុខជាផ្ដន្ទាទោសដល់អ្នករស់នៅទីនោះពុំខាន។ ទាំងអស់នេះ គឺជាគំនិតដ៏សាហាវជាទីបំផុត ស្ដីពីឯកភាពនៃមនុស្សលោកនិងធម្មជាតិ ដែលឱ្យនូវគំនិតជារបៀបសាសនាដល់ប្រទេសចិន ទាំងផ្នែកទំនៀមទម្លាប់ ទាំងផ្នែកសេចក្ដីរីករាយក្នុងជីវិត ដែលពុំមានសាសនាទាំងឡាយណាក្នុងលោកអាចប្រៀបបានឡើយ។

ខ្សែគំនិតខាងលើនេះ បានបន្តដំណើរវិវឌ្ឍនាការរហូតដល់សម័យទស្សនវិជ្ជា គឺសម័យលោកឡាវ សេ និងខុង ជឺ។ លោកទាំងពីរនេះ បានធ្វើមូលដ្ឋានទស្សនៈរបស់ខ្លួនទៅលើពាក្យថា "តៅ" ទាំងអស់, ប៉ុន្ដែមានដំណើរខុសគ្នាត្រង់ភាគអនុវត្តន៍។ ទស្សនៈរបស់លោកឡាវ សេ បានផ្អែកទៅលើអំណាចនិងបញ្ញារបស់ធម្មជាតិ ហើយទូន្មានមនុស្សលោកឱ្យប្រព្រឹត្តតាមដំណើររបស់វា។ ឯទស្សនៈរបស់លោកខុងជឺបានផ្អែកទៅលើសីលធម៌ ហើយមានលក្ខណៈជារបៀបគ្រប់គ្រង, ហើយលោកប្រៀនប្រដៅមនុស្សលោកកុំឱ្យផ្ដេកផ្ដួលទៅលើធម្មជាតិខ្លាំងពេក។ លោកស្ទើរតែបដិសេធពាក្យថាអាទិទេព, ប៉ុន្ដែដែលមិនអាចទៅជាយ៉ាងនោះបាន បណ្ដាលមកពីហេតុមួយគឺលោកទទួលយកអំណាចរបស់ឋានសួគ៌ថាជាសភាវៈពិតដែរ។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៣៥)

ឯបញ្ហានៃ "តៅ" បានដល់សំយោគដ៏ទៀងទាត់នៃចក្រវាល (An Eternal Harmony of Universe) ជាអំណាចរបស់ធម្មជាតិ ដែលមានយ៉ាងនិងយិនជាមូលដ្ឋាន។ ប៉ុន្ដែនៅក្នុងសំយោគដ៏ទៀងទាត់នៃចក្រវាល យើងឃើញអំណាចយ៉ាងនិងយិនទាំងពីរនេះរួមគ្នា ទើបចក្រវាលមានលក្ខណៈប្រព្រឹត្តទៅបាន។

យ៉ាងបានដល់អំណាចធាតុឈ្មោល មានពណ៌ក្រហមដែលយើងអាចឃើញថាមានលក្ខណៈក្ដៅ, ភ្លឺថ្លា, មាំមួន, ស្ងួត នៅក្នុងគ្រប់សារពើវត្ថុទាំងអស់ក្នុងចក្រវាល គឺពន្លឺព្រះអាទិត្យ, ភ្លើង ជាដើម។ ឯយិន បានដល់អំណាចធាតុញី មានពណ៌ខ្មៅ ដែលយើងអាចសង្កេតឃើញនៅគ្រប់សារពើវត្ថុទាំងអស់ មានលក្ខណៈត្រជាក់, ខ្មៅងងឹត, ទន់, សើម, ពិបាកយល់, ស្ងាត់ឬសម្ងាត់ ព្រមទាំងប្រែប្រួលជានិច្ច។ ឋានសួគ៌ច្រើនតែអំណាចធាតុយ៉ាង, ឯផែនដីច្រើនតែជាធាតុយិន។ អ្វីទាំងអស់កើតចេញពីធាតុទាំងពីរនេះ។

យើងសូមបញ្ជាក់ថាគ្រប់សារពើវត្ថុទាំងអស់នៅក្នុងចក្រវាល តែងមានអំណាចធាតុទាំងពីរនេះជានិច្ច, ប៉ុន្តែជួនកាល ធាតុយិនមានកម្លាំងជាងធាតុយ៉ាង, ជួនកាលធាតុយ៉ាងមានកម្លាំងជាងធាតុយិនទៅវិញក៏មាន។ ទាំងអស់នេះ បណ្តាលមកពីពេលនិងលក្ខណៈ នៃសារពើវត្ថុទាំងអស់នោះប្រែប្រួលប្រាសចាកភាពដើម។ ឧទាហរណ៍ ៖ ឈើជាធាតុយិន កាលណាគេបោះឈើនោះចូលទៅក្នុងភ្លើង វាក្លាយទៅជាធាតុយ៉ាងទៅវិញ។ យើងសង្កេតមើលរដូវទាំង៤ គឺតែងមានតុល្យភាពនៃការប្រែប្រួលរវាងធាតុយិននិងធាតុយ៉ាងជានិច្ច។ កាលណាពន្លឺឬកម្តៅរបស់ព្រះអាទិត្យខ្សោយទៅៗ នៅខាងចុងឆ្នាំនីមួយៗ តែងឱ្យកម្លាំងដល់រដូវលំហើយដែរ។ ទាំងនេះ ជាសញ្ញានៃការផ្លាស់ប្តូរកម្លាំងធាតុ។

នៅក្នុងជីវិតរបស់មនុស្សម្នាក់ៗ ក៏ធាតុយិននិងយ៉ាងមានតុល្យភាពខាងការផ្លាស់ប្តូរនិងប្រែប្រួលដែរ។ កាលណាធាតុយ៉ាងខ្លាំង មនុស្សមានប្រាជ្ញាច្រើន, កាលណាធាតុយិនខ្លាំង មនុស្សមានប្រាជ្ញាតិច។ ម្យ៉ាងទៀត មនុស្សជួនកាលធ្វើការមានប្រសិទ្ធភាព ជួនកាលមិនមានប្រសិទ្ធភាព, ផ្លាស់ពីក្មេងទៅចាស់ ក៏បណ្តាលមកពីការផ្លាស់ប្តូរនៃធាតុយ៉ាងនិងយិនដែរ។

ជាការបញ្ជាក់ ធាតុយ៉ាងនិងយិនទាំងពីរនេះ ពុំមែនតំណាងសេចក្តីល្អនិងអាក្រក់សោះឡើយ។ តាមពិត ធាតុទាំងពីរនេះ មានការចាំបាច់ដល់ការរៀបរយនៃចក្រវាល ហើយទាំងពីរនេះ ពុំមែនសុទ្ធតែប្រឆាំងគ្នាដូចជាអាក្រក់និងល្អទេ។ កាលណាធាតុទាំងពីរនេះមានសំយោគទៅវិញទៅមក ទាំងពីរនេះតែងប្រព្រឹត្តទៅក្នុងលក្ខណៈល្អជានិច្ច។ យើងឆ្ងល់ថា "តើគេអាចកត់សម្គាល់លក្ខណៈសំយោគរបស់ធាតុទាំងពីរនេះដូចម្តេច? តើអំណាចដែលមានលក្ខណៈផ្ទុយគ្នានេះ អាចធ្វើការជាមួយគ្នា ដើម្បីបង្កើតការរៀបរយដ៏អស្ចារ្យនៃធម្មជាតិដូចម្តេចកើត? ចម្លើយចំពោះសំណួរទាំងពីរនេះគឺ ៖ ប្រភពដ៏ធំបំផុតទាំងអស់នៃការរៀបរយ នៅក្នុងលោកគឺ "តៅ"។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៣៦) ពាក្យថា "តៅ" មានន័យថា "មាគ៌ារបស់ធម្មជាតិ ឬ ធម្មភាពឬច្បាប់នៃជីវិត"។ សូម្បីឋានសួគ៌ត្រូវតែឋិតនៅក្នុងអំណាចរបស់តៅ ហើយទេវតាទាំងឡាយក៏ត្រូវប្រព្រឹត្តទៅតាមផ្លូវរបស់តៅទាំងអស់ដែរ។ ដោយអំណាច នេះ លោកឡៅសេ ពោលថា (សូមមើល "The world's creat Religions", p.61.) "បើប្រសិនជាគ្រប់គ្នាទាំងអស់សុខចិត្តប្រព្រឹត្តតាមអំណាចរបស់តៅ គេទាំងឡាយនឹង ក្លាយទៅជាធម្មតានិងសាមញ្ញ ហើយនិងមិនមានអ្នកណាម្នាក់មានមហិច្ឆតាប្រាថ្នាអំណាចឡើយ។ គ្រប់គ្នាទាំងអស់មុខជានឹងក្លាយទៅជាធម្មតានិងសាមញ្ញ ហើយនឹងមិនមានអ្នកណាម្នាក់ មាន

មហិច្ឆតាប្រាថ្នាអំណាចឡើយៗ គ្រប់គ្នាទាំងអស់មុខជានឹងមានមិត្តភាព និងភាតរភាពទៅវិញទៅមកជាការចាំបាច់ពុំខាន ហើយសង្គ្រាមនឹងពុំកើតឡើងក្នុងលោកទាល់តែសោះៗ

តើមនុស្សឋិតនៅក្នុងអំណាចរបស់ធាតុយិននិងយ៉ាងដូចម្ដេចដែរ ? ចំពោះសំណួរនេះ យើងអាចឆ្លើយថា កន្លែងឬទីរបស់មនុស្សនៅក្នុងប្រព័ន្ធនៃចក្រវាលនេះ ដូចយើងបានពោលក្នុងបញ្ហាធាតុខាងដើមរួចមកហើយ ប៉ុន្តែនៅទីនេះ យើងសូមបញ្ជាក់បន្ថិចតទៅទៀតៗ មនុស្សម្នាក់ៗត្រូវប្រកបដោយធាតុ ៥គឺ ៖ ធាតុទឹក, ភ្លើង, ឈើ, ដែក និង ដី, រួមរដូវទាំង ៤ ផង ហើយទាំងអស់នេះបង្កើតបានជាធាតុគី (ជីវធម៌) ដែលមានធាតុលី (ចិត្តធម៌) ជាអ្នកប្រតិបត្តិការសម្រាប់អូសទាញស្លូក រាងកាយរបស់មនុស្សនោះៗឱ្យមានចលនាឡើងៗ គេបានហៅ "មនុស្ស" ថា "លោកដ៏តូច-Microcosm or a world in miniature" ហើយដោយអំណាចនៃធាតុទាំងអស់នេះ មនុស្សម្នាក់ៗ ត្រូវមាននៅក្នុងខ្លួនរបស់គេនូវចំណាំងពន្លឺនៃទេវសភាវៈ"ៗ នៅក្នុងខ្លួនរបស់មនុស្សទាំងឡាយ ភាគខ្លះមានធាតុយ៉ាងច្រើនជាងធាតុយិន គឺជាអ្នកប្រាជ្ញរាជបណ្ឌិត, ឯនៅក្នុងខ្លួនរបស់មនុស្សភាគខ្លះទៀត មានធាតុយិនច្រើនជាងធាតុយ៉ាង គឺពួកអ្នកល្ងង់ខ្លៅៗ សភាពមនុស្សលោក មានលក្ខណៈដូចសភាពរបស់ធម្មជាតិដែរ តែងមានរដូវ ៤ ប្រព្រឹត្តផ្លាស់ប្ដូរគ្នាជានិច្ច, មានភ្លឺមានងងឹត, មានយប់មានថ្ងៃៗ កាលណាមនុស្សម្នាក់ៗ មានជីវិតដល់ទីបំផុត (ស្លាប់) ហើយ គឺបណ្ដាលមកពីការអស់ ការខ្សោះទៅនៃធាតុគី (ជីវធម៌) ដូចជាលោកខាងក្រៅដែរៗ កិច្ចការដ៏ធំបំផុតនៃមនុស្សម្នាក់ៗ គឺត្រូវរៀបចំដំណើរជីវិតឱ្យស្របទៅតាមតៅទាំងអស់ឬឱ្យស្របទៅតាមការរៀបរយនៃចក្រវាលៗ កាលបើបានរៀបចំជីវិតតាមគម្រោងត្រឹមត្រូវហើយ គេនឹងបានចូលរួមជាមួយនឹងអំណាចរបស់ឋានសួគ៌និងផែនដីពុំខានឡើយៗ

ចំពោះវាសនា (សូមមើលខាងដើមត្រង់ "លោកធាតុ" និងសូមមើល "Encyclopedia of Religion an Ethics" Edited by James Hastingsain, Coamogony and Cosmology, pp.138-141, vol.4) បន្ទាប់ពីសេចក្ដីស្លាប់នៃមនុស្សម្នាក់ៗ យើងឃើញថា **ឡាវ សេ** ក្ដី, **ខុង ជឺ** ក្ដីនិង **ជួហ្ស៊ិ** ក្ដី ពុំបានពោលបញ្ជាក់ថា វិញ្ញាណឬព្រលឹងរបស់មនុស្សម្នាក់ៗប្រព្រឹត្តទៅ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៣៧)ក្នុងទីណាឡើយៗ ប៉ុន្តែបើតាមទស្សនៈរបស់លោកទាំងអស់នោះ សេចក្ដីស្លាប់របស់មនុស្សម្នាក់ៗនោះ ប្រហែលជាត្រឡប់ទៅកាន់ធាតុ

ដើមវិញដូចពោលខាងក្រៅដែរ។ ម្យ៉ាងទៀតតាមការបញ្ជាក់ទូទៅទាំងបូរាណនិងសម័យថ្មី យើងឃើញថា បន្ទាប់ពីសេចក្ដីស្លាប់ មនុស្សត្រូវត្រឡប់ទៅឋានសួគ៌វិញទាំងអស់។

**អំពីសីលធម៌ និងសាសនពិធី**

មុននឹងស្ដីពីសីលធម៌នៃមហាសាសនានិងលទ្ធិទាំង ៥ ដែលជាវត្ថុអារម្មណ៍សម្រាប់ការសិក្សាសាសនាប្រៀបធៀបរបស់យើង, យើងសូមណែនាំអ្នកអានឱ្យក្រឡេក មើលទូវទិដ្ឋភាពទូទៅនៃអ្វីដែលហៅថាសីលធម៌ ដែលគ្រប់តែសាសនានិងលទ្ធិទាំងអស់ក្នុងលោកត្រូវការជាចាំបាច់នៅក្នុងខេត្តឬវិស័យនៃការអប់រំកាយ វាចា និងចិត្ត សម្រាប់សេចក្ដីសុខសាន្តនៃបុគ្គលមួយរូបៗ ព្រមទាំងសង្គមមនុស្សដែលខ្លួនកំពុងរស់នៅ, ជាពិសេសសម្រាប់ជាដំណើរជំរុញឱ្យបុគ្គលមួយរូបៗទៅដល់ទីដៅរបស់ខ្លួន។ តាមពិតនិងតាមលក្ខណៈជាសាកល, សីលធម៌, ដែលអាចប្រព្រឹត្តទៅបានក្នុងគ្រប់ចរិយា សម្រាប់ជីវិតរបស់មនុស្សម្នាក់ៗ និងរបស់សង្គម ត្រូវមានចិត្តជាមូលដ្ឋាន ដែលយើងអាចឱ្យឈ្មោះទៅតាមប្រក្រតី និងធម្មភាពរបស់វាថា "ចិត្តវិទ្យានៃសីលធម៌" ក៏បាន។ ដើម្បីពង្រីកសេចក្ដីឱ្យទូលំទូលាយទៅទៀត យើងសូមចែករឿងនេះជា ៧ក្រុមទៅតាមលក្ខណៈដែលទាក់ទងគ្នាគឺ ៖ ១-ការសិក្សាពីចិត្តសម្រាប់មើលនិងអធិប្បាយនូវអាចារៈ, ២-ប្រក្រតីនៃសេចក្ដីប្រាថ្នា, ៣-ការបណ្ដាលនិងសញ្ចេតនា, ៤-គតិនិងបំណង, ៥-ភាពសោមនស្សគឺជាប្រមុខនៃសេចក្ដីល្អ តាមលក្ខណៈចិត្តវិទ្យា, ៦-ហេតុគឺជាការបណ្ដាលឱ្យធ្វើនូវអំពើ, ៧-សេរីភាពនៃបំណង។

**១-ការសិក្សាពីចិត្តសម្រាប់មើលនិងអធិប្បាយនូវអាចារៈ**
**(Psychology as explaining Conduct)**

កិច្ចការរបស់ចិត្តវិទ្យា គឺសម្រាប់អធិប្បាយនូវអាចារៈទូទៅ មិនមែនសម្រាប់វិនិច្ឆ័យឬដាក់កំហុសដល់អាចារៈទោះល្អក្ដី អាក្រក់ក្ដីនោះឡើយ។ កាលណាគេបរិយាយនូវអំពើ, គេចង់និយាយពីសម្ព័ន្ធភាពរបស់វាទៅនឹងសេចក្ដីពិតដទៃទៀតដែលបានជាប់ទាក់ទងជាមួយគ្នាជាពិសេស គតិនៃចិត្តដែលមកមុនអំពើនៅក្នុងចិត្តនៃបុគ្គលអ្នកកំពុងធ្វើនូវអំពើនោះ។ យើងអាចនិយាយថា គតិនៃចិត្តដែលមកមុននោះអាចបណ្ដាលនូវអំពើ កាលណាយើងចាំបានថាហេតុនៃការបណ្ដាលរបស់គតិនៃចិត្តទាំងឡាយនោះ បង្កើតនូវអំពើប្រកបដោយកាយ ឬវាចា។ យើងសង្កេតឃើញគតិនៃចិត្តសម្រាប់សម្រេចនូវអាចារៈរបស់យើងមាន៤យ៉ាងគឺ ៖

ក-និន្នាការជាគ្រឿងយន្តនៃគំនិត (សូមមើល "An Introduction on to Ethics", 2004) (Ideomotor Tendency) (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៣៨)និន្នាការនេះជាស្វ័យ

ប្រវត្តិនៅក្នុងគតិនៃចិត្តរបស់មនុស្សម្នាក់ៗ ឧទាហរណ៍ខ្យល់ត្រជាក់កំពុងបក់មកចំទ្វារបន្ទប់រៀនរបស់នរណាម្នាក់ បណ្តាលឱ្យអ្នកនៅក្រោកឡើងជាស្វ័យប្រវត្តិ ហើយស្ទុះទៅបិទទ្វារនោះភ្លាមព្រោះអ្នកនោះមិនត្រូវការខ្យល់បែបនោះ។ និន្នាការបែបនេះគឺជាគតិនៃចិត្តបណ្តាលឱ្យអាចារៈកើតឡើងជាស្វ័យប្រវត្តិ។

១-សេចក្តីប្រាថ្នា (Desire) ៖ យើងធ្វើអ្វីណាមួយដោយសម្រេចមកពីសេចក្តីប្រាថ្នាឬបំណង, បើគ្មានសេចក្តីប្រាថ្នាឬបំណង យើងក៏ពុំមានចិត្តចង់ធ្វើអ្វីនោះដែរ។ យើងឃ្លានបាយ, យើងត្រូវតែប្រាថ្នាឬចង់ស៊ីបាយ, ដូច្នេះ យើងត្រូវតែស៊ីបាយនោះភ្លាមតាមចំណង់ដែលយើងចង់។

គ-វិសញ្ញិតថ្នា (Unconscious Desire) យើងធ្វើអ្វីណាមួយជួនកាលដោយចំណង់ ឬសេចក្តីប្រាថ្នាដោយមិនដឹងខ្លួន។ គតិនៃចិត្តបែបនេះហៅថា វិសញ្ញិតិថ្នា (វិសញ្ញិត+តិថ្នា)។ ម្យ៉ាងទៀត គតិនៃចិត្តនេះ ជួនកាលគេហៅថានិន្នាការនៃចិត្តដោយមិនដឹងខ្លួន (Unconscious Mental Tendency) ក៏មាន។ ប៉ុន្តែតាមធម្មតា កាលណាគតិនៃចិត្តនេះប្រព្រឹត្តទៅមួយខណៈ ទើបសញ្ញិតិថ្នា (Conscious desire) ចូលមកជួយភ្លាមជាបន្តទៅទៀត។

ឃ-សម្បជញ្ញៈ (Conscience) ៖ កាលណាយើងធ្វើអ្វីណាមួយ យើងធ្វើប្រកបដោយញាណជាកាតព្វកិច្ច (Sense of Duty) គឺប្រកបដោយសម្បជញ្ញៈជានិច្ច។

២-ប្រក្រតីនៃសេចក្តីប្រាថ្នា (Nature of Desire) សេចក្តីប្រាថ្នាទាំងឡាយកើតឡើងអាស្រ័យជាមួយនឹងនិន្នាការទាំងឡាយខ្លះនៃសភាពមនុស្ស យើងដែលអាចធ្វើឱ្យទៅជាក្រុមដូចតទៅនេះគឺ ៖

ក-សេចក្តីត្រូវការទាំងឡាយនៃឥន្ទ្រិយ៍ ៖ លោកសំដៅយកនិន្នាការទាំងឡាយនៃមនុស្សជាតិដែលចាំបាច់សម្រាប់បន្តការរស់នៅឬវិជ្ជមានព្រម ទាំងសម្រាប់បង្កើតពងកាយឱ្យជំជាត់ក្នុងលក្ខណៈធម្មតាឱ្យប្រព្រឹត្តទៅ។ តាមធម្មតា យើងជាមនុស្សជាតិគ្រប់ជាន់ថ្នាក់មានសេចក្តីត្រូវការបែបដូចជាពពួកសត្វតូច-ធំ ដទៃទៀតដែរ, មិនតែប៉ុណ្ណោះ ដូចគ្នានឹងពពួករុក្ខាលតាវល្លិ៍ថែមទៀត។ ប៉ុន្តែចំពោះសត្វល្អិតនិងពពួករុក្ខាលតាវល្លិ៍ទាំងឡាយប្រហែលជាសេចក្តីត្រូវការនៃឥន្ទ្រិយ៍ មិនប្រកបដោយការដឹងខ្លួនដូចជាមនុស្សនិងសត្វធំៗឡើយ។ ម្យ៉ាងទៀត សេចក្តីត្រូវការនៃឥន្ទ្រិយ៍របស់មនុស្សមានជំងឺ ក៏មានលក្ខណៈមិនដឹងខ្លួនដែរ។ ដូច្នេះ ការដឹងនៃសេចក្តីត្រូវការរបស់ឥន្ទ្រិយ៍បែបនោះ គេហៅថា "អាហារិថ្នា អាហារ + តិថ្នា

(Appetite)។ នៅក្នុងចិត្តវិទ្យា យើងឃើញពាក្យថា "អាហារិច្ឆា" នេះ មានលក្ខណៈទូលំទូលាយណាស់ ជាពិសេសទាក់ទងនឹងលោកគតិ (Instinet) នៃឥន្ទ្រីយ៍របស់ពួកសត្វក៏មាន, ប៉ុន្តែនៅទីនេះ (ក្នុងលក្ខណៈចិត្តវិទ្យាដែរ) អាហារិច្ឆា សំដៅយកចំណង់ក្នុងអាហារសម្រាប់ធ្វើឱ្យរាងកាយធំធាត់។ (ប៉ែន សារឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៣៩) ទាំងអស់នេះលោកចាត់ជាផ្នែកមួយនៃប្រក្រតីនៃសេចក្ដីប្រាថ្នាដែរ ដោយរួមចំណង់ដទៃទៀតផង។

ខ-សភាវគតិ (Instincts) ៖ នៅក្នុងមូលភេទនៃប្រក្រតីរបស់សេចក្ដីប្រាថ្នាសភាវគតិ លោកចាត់ជាប្រការមួយដែរក្នុងសន្ដានចិត្តទាក់ទងដល់ជីវសម្ព័ន្ធរបស់មនុស្សជាតិ។ លោក ម៉ក ដោគ័ល្ល (Mc Dougall) បានឱ្យអត្ថន័យថា សភាវៈដែលជាមតិករបស់អាការៈនៃចិត្ត-កាយ ដែលសម្រាប់ទទួលនូវវត្ថុអារម្មណ៍ ពិសោធន៍នូវអារេគភាពនៃវត្ថុអារម្មណ៍ នោះជាដើម។ សភាវគតិរបស់មនុស្សជាតិតាមលោក ម៉ក ដោគ័ល្ល មាន១០យ៉ាងគឺ ៖ ការហោះ ការខ្ពើមរអើម, ការអស្ចារ្យ, ការវាយប្រឆាំង, ការលើកនិងបន្ទាប់ខ្លួនឯង, មាតា-បិតា សភាវគតិ, មេថុនធម្ម, ការរួមរស់នៅជាក្រុម, ការចង់បាន និងការសាងសង់។

ចំពោះប្រការទាំង ១០នេះ យើងមិននឹកស្មានថាគ្រប់គ្រាន់តាមលក្ខណៈចិត្តវិទ្យាឡើយ, ប៉ុន្តែយើងសូមបញ្ជាក់ថា អ្វីដែលជាសជាតិកសភាវគតិជាមតិកនៅក្នុងប្រក្រតីរបស់មនុស្សជាតិ តែងមាននិន្នាការចំពោះការងារជាច្រើនបែបដែលប្រាកដឡើង តាំងពីកើតឡើងរហូតដល់បានរីកចម្រើនរូបរាងឡើង។ សភាវគតិទាំងអស់នេះ សម្រាប់រក្សានិងការពារខ្លួនឯងជាតិរបស់ខ្លួន, ប៉ុន្តែក្នុងការពិសោធន៍នៃនិន្នាការប្រកបដោយសភាវគតិនោះ បុគ្គលម្នាក់ៗ ពុំសូវដឹងខ្លួនថា ខ្លួនឋិតនៅក្នុងលក្ខណៈហេតុការណ៍ណាមួយឡើយ។

គ-និន្នាការជាមតិកទូទៅ(General Innate Tendencies) និន្នាការនេះមិនមែនមានលក្ខណៈពិសេសដូចជាសភាវគតិឡើយ។ វាមានអាការៈទូទៅគ្រប់មជ្ឈដ្ឋាននៃជីវិតរបស់មនុស្សជាតិ។ តាមលោក ម៉កដាគ័ល្ល និន្នាការនេះសំដៅយកការចង់រួមសុខទុក្ខជាមួយគ្នា (សមសុខទុក្ខតា-Sympathy), ការទទួលជឿតាមដោយមិនបាច់គិតដល់ការសមហេតុ-ផល (សមសទ្ធា-Suggestibility), ការចម្លងយកតាមនូវកិច្ចការនិងអាចារៈមារយាទរបស់អ្នកដទៃ (អនុករណ៍-Imitation) ការចង់លេងកម្សាន្ត (កីឡនៈ-Play) និងការចង់បង្កើតទម្លាប់ (To form habit)។ តាមអាចារៈវិធីទូទៅ ពាក្យថានិន្នាការជាមតិកទូទៅនេះ មានលក្ខណៈមិនផ្សេងពី

សភាវគតិឡើយ, ព្រោះទាំង៣ខាងដើមគឺសមសុខ-ទុក្ខតា, សមសន្ទា និងអនុករណ៍ កើតឡើងនៅជុំវិញសភាវគតិនៃការចង់រួមរស់នៅជាក្រុម។

មនុស្សលោកគ្រប់រូបតែងមានមូលភេទនៃសេចក្តីប្រាថ្នាទាំង៣ គឺអាហារិច្ឆា, សភាវគតិ និងនិទ្ទាការជាមត៌កទូទៅ តិចឬច្រើនមិនខានឡើយ ជាពិសេសប្រភេទនៃសេចក្តីប្រាថ្នាទាំងអស់នេះ មានការរីកចម្រើនតាមលំដាប់អាយុ។

៣-ហេតុបណ្តាល និងសញ្ចេតនា (Motive and Intention) ៖ ហេតុបណ្តាល (Motive) គេសំដៅយកគតិចិត្តដែលជំរុញឱ្យមនុស្សម្នាក់ៗធ្វើនូវអំពើផ្សេងៗ ដោយលើកលែង ញាណជាកាតព្វកិច្ចចេញ, ឧទាហរណ៍ បំណងក្នុងអាហារ បណ្តាលឱ្យមនុស្សបង្គាប់ឱ្យគេយកអាហារមកបរិភោគជាដើម។ ឯសញ្ចេតនា សំដៅយកញាណឬចិត្តដែលមានគម្រោងឬលទ្ធភាពនៃអំពើឬការងារប្រកបដោយការរៀបចំ ឬដោយការគិតទុកជាមុន, ឧទាហរណ៍ កុមារមួយរូបរត់ទៅរកម្តាយឱ្យជួយការពារខ្លួន ព្រោះវាឃើញឬខ្លាចសត្វចម្លែក ឬ គំនិតជាគម្រោងការឬនយោបាយដែល មនុស្សម្នាក់ៗ បានរៀបចំនិងបានគិតទុកជាច្រើនឆ្នាំ។ ការគិតនិងការរៀបចំទុកជាមុនទាំងអស់នេះ គេហៅថា "សញ្ចេតនា"។ លក្ខណៈចិត្តទាំងពីរផ្នែកនេះ គេចាត់ទុកជាធម្មតារបស់មនុស្សលោកគ្រប់ៗរូប។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤០)

៤-គតិនៃបំណង (The Process of Willing) នៅក្នុងអំពើប្រកបដោយសភាវគតិដូចជាមនុស្សម្នាក់បានវាយសំពងមនុស្សម្នាក់ទៀតដែលជាសត្រូវ, សេចក្តីប្រាថ្នាខ្លាំងនៅពេលរំពេចនោះ បានបង្ខំឱ្យសម្រេចនូវអំពើ។ ឯចំណែកក្នុងអំពើដែលប្រកបដោយសុវិចារណ៍, មានគតិនៃការជ្រើសរើសឬបំណងឋិតនៅត្រង់ចន្លោះនៃសេចក្តីប្រាថ្នានិងអំពើ។ សុវិចារណ៍និងបំណង ឬការជ្រើសរើសកើតឡើងនៅពេលដែលសេចក្តីប្រាថ្នាទាំងពីរប្រភេទប៉ះទង្គិចគ្នា។ សេចក្តីប្រាថ្នាខ្លាំងជាងគេ ត្រូវតែកើតឡើងមុនគេ។ នេះជាការធម្មតានៃចិត្តរបស់មនុស្សលោក, សេចក្តីប្រាថ្នាទាំងពីរដែលមានលក្ខណៈផ្ទុយគ្នា មិនដែលកើតឡើងក្នុងពេលជាមួយគ្នាជាដាច់ខាត។ អារម្មណ៍ល្អក្តី អាក្រក់ក្តី តែងប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ហើយសុវិចារណ៍និងទុវិចារណ៍ ត្រូវផ្លាស់វេនគ្នាកើតឡើង, កាលណាវិចារណ៍ណាមួយខ្លាំងជាងត្រូវកើតមុនគេ។

យើងសូមបញ្ជាក់ថា គតិនៃបំណងនៅក្នុងចិត្តវិទ្យា មានលក្ខណៈអត្ថាធិប្បាយដូចគ្នានឹងចិត្តនិងវិថីនៃអភិធម្មសង្គហៈ ដោយព្រះអនុរុទ្ធត្ថេរ (ថេរវាទដែរ)។

៥-ភាពសោមនស្សគឺជាប្រមុខនៃសេចក្តីល្អតាមលក្ខណៈចិត្តវិទ្យា (Phychological Hedonism) ៖ អ្នកចិត្តវិទ្យាក្រុមនេះ យល់ថាមនុស្សទាំងឡាយក្នុងលោកខំប្រឹងប្រែងចិញ្ចឹមជីវិត-រកទ្រព្យ, យសស័ក្តិ និងចំណេះវិជ្ជា ឬក៏ប្រឹងប្រែងប្រព្រឹត្តធម៌ គឺគេខំប្រឹងដើម្បីសេចក្តីសប្បាយរីករាយតែម្យ៉ាងប៉ុណ្ណោះ។ ទាំងអស់នេះ គេបានប្រមូលផ្តុំឡើងពីការពិសោធន៍និងការសង្កេតផ្ទាល់។ យើងពិបាកនឹងបដិសេធទ្រឹស្តីទាំងនោះថាមិនពិតសោះឡើយ, ព្រោះបើយើងសង្កេតទៅ យើងនឹងឃើញប្រាកដថា អ្វីទាំងអស់ដែលកើតឡើង ឬដែលគេស្វែងរកសុទ្ធតែមានបំណងឬទីដៅជាទីបំផុតជាដរាប។ មានតែផ្លូវមួយគត់ក្នុងការបដិសេធទ្រឹស្តីនេះ គឺការបញ្ជាក់ឱ្យដឹងថាមានមនុស្សលោកទាំងឡាយខ្លះស្វែងរកសភាវៈដទៃទៀត ជាជាងរកសេចក្តីសប្បាយរីករាយ។ តាមពិត យើងមិនអាចរកសំអាងណាមួយ ដើម្បីបង្ហាញ រក សេចក្តីពិតបានចំពោះទ្រឹស្តីទាំងអស់នេះ។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤១)

យើងសូមបញ្ជាក់ថា ទ្រឹស្តីចិត្តវិទ្យាថាសោមនស្ស គឺជាប្រធាននៃសេចក្តីល្អនោះ បានសង្កត់ថាទ្រឹស្តីនេះ គឺគេបង្កើតឡើងតាមប្រក្រតីនៃមនុស្សជាតិ ហើយសម្រេចនូវអំពើថែមទៀត។ គេចែកទ្រឹស្តីនេះជា ៣ប្រភេទគឺ ៖

ក-ភាពសោមនស្សនៅពេលដែលកំពុងប្រព្រឹត្តទៅអាចសម្រេចនូវអំពើបាន, ឧទាហរណ៍ អ្នកអត់បាយមានសេចក្តីស្រេកឃ្លានជាខ្លាំង អាចបង្កើតបំណងដ៏ខ្លាំងដើម្បីសម្រេចនូវអំពើ។

ខ-មនុស្សតែងធ្វើអ្វីដែលឱ្យនូវសោមនស្សភាពដល់គេ, ឧទាហរណ៍ អ្នកឈឺធ្មេញបានទៅឱ្យវេជ្ជបណ្ឌិតខាងធ្មេញយកឈឺនោះចេញ ព្រោះគេចង់ឱ្យធ្មេញនោះបាត់ឈឺ។ ការចង់ឱ្យបាត់ឈឺធ្មេញ បានសម្រេចនូវអំពើនោះបាន។

គ-ហេតុដែលបណ្តាលឱ្យសម្រេចនូវអំពើគឺប្រាកដជាសេចក្តីប្រាថ្នា ដើម្បីសេចក្តីសុខសប្បាយរីករាយនៅពេលជាអនាគត។

ប្រភេទទ្រឹស្តី ក និង ខ ហាក់ដូចជាមិនសមហេតុផលសោះ ប៉ុន្តែត្រង់ទី គ មានលក្ខណៈសមហេតុផលណាស់ (សូមមើលតទៅទៀត "An Introduction to Ethics", by William Lillie. p.40-44.)។

៦-ហេតុគឺជាការបណ្តាលឱ្យធ្វើនូវអំពើ(Reason as Motive to Action) ៖ នៅក្នុងលក្ខណៈនេះ លោកអារីស្តូត (Aristle) បានបញ្ជាក់ថា "គោលបំណងនៃគតិនៃបំណងកើតឡើង

ដោយសេចក្ដីប្រាថ្នា"។ លោកបញ្ជាក់ថែមទៀតថា "កិច្ចការរបស់ហេតុគឺការពិចារណាដោយសុភនិច្ឆ័យ រៀបចំឧបាយផ្សេងៗ មិនមែនកំណត់ទីដៅឬគោលបំណងទីបំផុតឡើយ (Aristle "Nicomachean Ethics", BK.vi.Ch.2 (1139a))។ នៅក្នុងលក្ខណៈដូចគ្នានេះ លោក ហ៊ួម (Hume) ជាទស្សនវិទូជាតិស្កត់ធីស (Scottist) បានពោលថា "ហេតុគឺជាទាសៈនៃតណ្ហា" (Hume "Treatise on Human nature", Ch.2)។ យើងសូមបញ្ជាក់ថា វត្ថុបំណង ឬទីដៅដែលយើងស្វែងរកតាមទ្រឹស្ដីទាំងពីរខាងលើនេះ គឺសម្រេចដោយសេចក្ដីប្រាថ្នារបស់យើងតែម្យ៉ាង, ឯកិច្ចការរបស់ហេតុ ឬផ្នែកខ្លះនៃសញ្ចេតនាដែលមានក្នុងចិត្ត គឺគ្រាន់តែសម្រាប់សម្រេចរកឧបាយដ៏ពិសេសដែលធ្វើឱ្យសេចក្ដីប្រាថ្នាសម្រេចជាគជ័យតែប៉ុណ្ណោះ។ ពួកអ្នកចិត្តវិទូផ្នែកសោមនស្សភាព គឺជាប្រធាននៃសេចក្ដីល្អ (Hendonism) បានទទួលនូវទ្រឹស្ដីខាងលើនេះ។ រឿងនេះ មានលក្ខណៈដូចគ្នានឹងទ្រឹស្ដីរបស់ លោក ម៉ាក់ដោគ័ល្ល ត្រង់និន្នាការជាមតិកទូទៅ (General innate tendencies) ហេតុជួយយើងក្នុងការរាវរកឱ្យឃើញនូវឧបាយដ៏ល្អជាទីបំផុត ដើម្បីបានដល់នូវទីដៅ។

ហេតុការណ៍ខាងលើទាំងអស់នេះ មានលក្ខណៈភ័ន្តច្រឡំ។ តាមពិត ហេតុមានអំណាចបណ្ដាលឱ្យធ្វើនូវអំពើទៅវិញទេ។ ប្រភេទនៃហេតុដែលសម្រាប់សម្រេចនូវអំពើនោះគឺ ៖(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤២)

ក-យុត្តិករណ៍ (Rational)

ខ-អធិករណវិនិច្ឆ័យ (Judgement)

គ-វិមំសា (Investigation)

ឃ-វិតក្កករណ៍ (Reasoning)

ង-តក្កវបៈ, ឧទ្ទរណបញ្ញត្តិ និងអនុមាណបញ្ញត្តិ (Logics: Deduction and Induction)

ច-អន្តោទស្សន៍ (Introspection)។

ទាំង៦ ខាងលើនេះ គឺជាប្រភេទរបស់ហេតុ សម្រាប់បណ្ដាលឱ្យធ្វើនូវអំពើផ្សេងៗក្នុងវិស័យសីលធម៌សម្រាប់ជីវិតរបស់មនុស្សម្នាក់ៗ និងសម្រាប់សង្គម។

៧-សេរីភាពនៃបំណង (Freedom of the Will) តាមប្រក្រតីនៃមនុស្សជាតិ, សេរីភាពនៃបំណងមានលក្ខណៈទាក់ទងជាមួយចេតសិកធម៌។ ដើម្បីចៀសវាងគ្រោះថ្នាក់តាមផ្លូវកាយ-វាចា និងចិត្ត, គេត្រូវចេះអនុវត្តសេរីភាពនៃបំណងឱ្យត្រូវតាមលំអាននៃសីលធម៌ ដែលខ្លួន

បានអប់រំនិងប្រព្រឹត្តតាម។ គតិនៃចិត្តគឺជាគ្រឿងយន្ត ចិត្តជួនកាលប្រព្រឹត្តទៅដោយ មិនដឹងខ្លួន ចិត្តត្រូវប្រកបដោយសម្បជញ្ញៈ។ ទាំងអស់នេះ ជាលក្ខណៈនៃសេរីភាពនៃបំណង។ ទាំងនេះសមនឹងពុទ្ធភាសិតថា ៖

"មនោបុព្វង្គមាធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា

តតោ នំ ទុក្ខមន្វេតិ ចក្កំ វ វហតោ បទន្តិ។ (សូមមើល "ធម្មបទដ្ឋកថា" គម្ពីរខុទ្ទកនិកាយ, យមកវគ្គ។)

ធម៌ទាំងឡាយមានចិត្តប្រព្រឹត្តទៅមុន មានចិត្តប្រសើរបំផុត មានលក្ខណៈសម្រេចពីចិត្ត, បើបុគ្គលមានចិត្តអាក្រក់ឬប្រទូស្តហើយ ទោះនិយាយក្តី ធ្វើក្តី សេចក្តីទុក្ខលំបាក តែងមានជាប់ជានិច្ចនូវបុគ្គលនោះ ដូចជាកង់ឬចក្រតែងប្រព្រឹត្តទៅតាមស្នាមជើងនោះដែរ"។

"មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា

មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា

តតោ នំ សុខមនេតិ ឆាយាវ អនុបាយិ ណីតិ។

ធម៌ទាំងឡាយ មានចិត្តប្រព្រឹត្តទៅមុន មានចិត្តប្រសើរបំផុត មានលក្ខណៈសម្រេចពីចិត្ត កាលបើបុគ្គលមានចិត្តល្អមិនប្រទូស្តហើយ ទោះនិយាយក្តី ធ្វើក្តី សេចក្តីសុខតែង តាមជាប់នូវបុគ្គលនោះជានិច្ច ដូចជាស្រមោលអន្ទោលទៅតាមប្រាណដែរ"។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៣)

ដូចពោលមកខាងលើនេះ យើងគួរកត់សម្គាល់ថា អ្វីៗទាំងអស់ដែលមនុស្សលោកត្រូវប្រកបដោយកាយ វាចា ឬចិត្ត ត្រូវមានចេតសិកធម៌ជាមូលដ្ឋានទាំងអស់។ អំពើល្អគ្រប់យ៉ាង ឬអាក្រក់គ្រប់យ៉ាង ជាលទ្ធភាពនៃទស្សនវិជ្ជា, ឯការប្រព្រឹត្តធ្វើនូវអំពើទាំងអស់នោះៗ ជាលទ្ធភាពនៃចិត្តវិទ្យា ដូច្នេះ សីលធម៌គ្រប់យ៉ាង ត្រូវមានចិត្តជាមូលដ្ឋានជាដរាប។ ឯមុននោះនៃសីលធម៌ទាំងអស់ត្រូវបំពេញដល់មនុស្សលោកគឺ ៖

ក-អប់រំមនុស្សលោកឱ្យក្លាយទៅជាអ្នកសីលធម៌ សម្រាប់ធ្វើឱ្យជីវិតនៃមនុស្សម្នាក់ៗប្រសើរឡើង។

ខ-អប់រំឱ្យមនុស្សម្នាក់ៗ ចេះរៀនរស់នៅក្នុងសង្គមមនុស្ស និងចេះទាក់ទងគ្នាដោយមិត្តភាពនិងភាតរភាព ជាបំណងនៃសាមគ្គីធម៌ និងឱ្យមនុស្សចេះដឹងព្រមទាំងចេះប្រើប្រាស់នូវសិទ្ធិនៃមនុស្សជាតិ។

គ-អប់រំមនុស្សៗឱ្យមានដំណើរ ឬឱ្យចេះរៀបចំខ្លួនដើម្បីប្រព្រឹត្តធ្វើខ្លួន ឱ្យរួចចាក កិលេសធម៌ ដើម្បីទៅដល់ឬសម្រេចទិដៅរបស់ខ្លួននាលោកនេះនិងលោកខាងមុខ។

តើសីលធម៌របស់មហាសាសនានិងលទ្ធិទាំង៥ ក្នុងសកលលោក មានលក្ខណៈស្រប គ្នានិងផ្ទុយគ្នា ព្រមទាំងបំពេញមុខងាររបស់ខ្លួនដល់មនុស្សលោក និងសង្គមលោកដូចម្ដេច ខ្លះ ? យើងសូមបរិយាយដោយសង្ខេបនូវសីលធម៌នៃលទ្ធិនិងសាសនាមួយៗដូចតទៅនេះ ៖

១-លទ្ធិព្រាហ្មណ៍៖ នៅក្នុងលទ្ធិព្រាហ្មណ៍យើងសង្កេតឃើញថា នៅក្នុងគម្ពីរបាតញ្ជលី ប្រែសម្រួលដោយស្វាមីវិវេកានន្ទៈ, ហិណ្ឌូធម៌ គឺជាទស្សនវិជ្ជានិងការប្រតិបត្តិ នៃយោគៈ ដែលជាដំណើរប្រតិបត្តិរបស់មនុស្សមួយរូបៗ ដើម្បីធ្វើឱ្យអាត្មន៍ពិតប្រាកដរបស់ខ្លួនចូលទៅ រួមជាមួយនឹងអាត្មន៍នៃលោកឬចក្រវាល (ព្រះព្រហ្ម ឬព្រះអាទិទេព)។ យោគៈ គឺជាផ្លូវតែ មួយគត់បង្ហាញនូវវិធីប្រតិបត្តិដោយផ្ទាល់និងមានរូបមន្ត យ៉ាងល្អសម្រាប់ឱ្យដល់ទីដៅ។ ម្យ៉ាងទៀត យោគៈ បានធ្វើវិភាគទានដល់ការពិសោធន៍ក្នុងធម៌ និងបច្ចេកទេសក្នុងការ ប្រតិបត្តិធម៌ថែមទៀត។

យោគៈ បានន័យថា ការប្រកប, ការប្រតិបត្តិ, ការប្រកបដោយធន្ទៈ, ការភ្ជាប់, បំណង គឺ ការបង្ហាញនូវរូបនៃវិន័យរបស់ខ្លួនជាមួយនឹងវត្ថុអារម្មណ៍របស់ ការប្រកបកាយជា មួយ នឹងអាត្មន៍, អាត្មន៍របស់មនុស្សម្នាក់ៗ ទៅនឹងឬជាមួយនឹងអាត្មន៍របស់ចក្រវាលឬលោក គឺ ព្រះព្រហ្ម ឬអាទិទេព។

គោលបំណងនិងទីដៅរបស់យោគៈ គឺដើម្បីជួយអប់រំនិងសំអាតនូវអាវេគភាពនៃចិត្ត ឱ្យមានលក្ខណៈស្ថិរភាពនឹងនរ់ឡើង។

ចំពោះគម្ពីរបាតញ្ជលី យើងឃើញថា គេទុកជាសាស្ត្រៈដ៏ប្រសើរ (Classic) ជាអត្ថបទ សម្រាប់សិក្សាយោគៈ។ គ្រប់និកាយនៃលទ្ធិព្រាហ្មណ៍ បានទទួលស្គាល់និងសិក្សាគម្ពីរនេះ ព្រមទាំងបានបញ្ជាក់ថា ជាគម្ពីរមានប្រធានារម្មណ៍ប្រសើរបំផុត។ គម្ពីរនេះ លោក យេ-ហា- វូដស៍ (J.H.Woods) (សូមមើល "Yoga System of Patanjali", Translated by J.H.Woods, Harvard Oriental Series, vol.17) បានបញ្ជាក់ថា គេបានសរសេរឡើងនៅសតវត្សទី៤ ឬទី៥ នៃគ.ស.។ ដើម្បីឱ្យជាក់ច្បាស់ សូមមើលអដ្ឋកថានៃគម្ពីរនោះទៅទៀតចុះ (សូមមើល "Rājayoga", Ramkrishna-Vivekānanda Centre II.Y.1939)។ នៅទីនេះ យើងសូមបរិយាយ ដោយសង្ខេបដូចតទៅ ៖ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៤)

**វគ្គទី២ យោគៈ និងប្រយោជន៍នៃការអប់រំចិត្ត**

ក-ទីដៅនៃយោគៈ ១-ការសង្រួមចិត្ត, ២-នៅពេលធ្វើយោគៈ, បុរុសៈ ត្រូវបិតនៅឬសម្រាកនៅក្នុងកន្លែងរបស់ខ្លួនឥតប្រែប្រួលឡើយ។ ពាក្យថា បុរុសៈនេះ មានមកក្នុងសំខ្យាទស្សនវិជ្ជា ដូចដែលបានពោលមកហើយខាងដើម។ បុរុសៈ គេហៅថា អនាគតទស្សី (អ្នកឃើញអនាគត)។

ខ-សណ្ឋាននៃចិត្ត ៖ ១-នៅពេលដ៏ទៃពីពេលធ្វើយោគៈ, គេសង្កេតឃើញបុរុសៈប្រាកដឡើងនៅក្នុងការប្រែប្រួលនៃចិត្ត, ២-ការប្រែប្រួលនៃចិត្ត គេចែកចេញជា ៥ក្រុមគឺ ចំណេះត្រូវ, អវិចារណា, មោហិតវាចា, និទ្រា និងសតិ។ ក្នុងចំណោមក្រុមនេះ ក្រុមខ្លះប្រកបដោយទុក្ខ, ខ្លះទៀតប្រកបដោយសុខៈ។ ចំណេះត្រូវបានដល់សញ្ញា, អនុមាន, ប្រតិពលនិទស្សនៈ,ទាំងអស់នេះសម្រាប់ធ្វើការសម្គាល់ដល់វត្ថុដែលខ្លួនឃើញច្បាស់។ អវិចារណាបាន ដល់ចំណេះខុស ដែលផ្ទុយពីចំណេះត្រូវ។ មោហិតវាចា បានដល់សម្ដីក័ន្តច្រឡំ ប្រាសចាកការពិត។ និទ្រាបានដល់ការដេកលក់ ដែលត្រូវក្រសោបនូវអារម្មណ៍ប្រកបដោយភាពសូន្យ, គេហៅថា សុញ្ញព្រឹត្តិក៏បាន។ សតិ បានដល់ការចាំ បាននូវអ្វីដែលខ្លួនបានឃើញ។

គ-វិធីសង្កត់ចិត្ត ៖ ១-សំវរប្រតិបត្តិ សង្រួមព្រមទាំងប្រតិបត្តិដោយប្រុងប្រយ័ត្ននិងប្រកបដោយមេត្តា, ២-អលោភៈ កុំជាប់ជំពាក់នូវអារម្មណ៍ដែលខ្លួនបានជួបប្រទះ សូម្បីខ្លួនបុរុសៈ និងចំណេះត្រូវទាំងអស់ ក៏មិនត្រូវជាប់ជំពាក់ ឬចង់បានឡើយ។

ឃ-ប្រភេទនៃយោគៈ ១-សម្មាវិជ្ជា ត្រូវចម្រើនរកនូវពុទ្ធិ ហើយត្រូវតែប្រកបដោយហេតុ, វិចារៈ, សុខៈ និងអត្តទ្រឹស្តី។ ២-សមាធិ បានដល់ការប្រតិបត្តិ ឬការចម្រើនឱ្យអស់ទៅនូវចិត្តកិច្ចទាំងអស់ ហើយរួមទាំងការចម្រើនឈានផង។

ង-មាគ៌ាផ្សេងៗនៃសមាធិ ៖ ១-រំឭកដល់ពពួកទេព្តាដែលផុសឡើងនិងប្រាកដឡើងនៅក្នុងធម្មជាតិទាំងអស់, ២-ភក្តី, ពលៈ, សតិ, សមាធិ និងវិចារៈនៃវត្ថុអារម្មណ៍ដ៏ពិតប្រាកដ, ៣-ប្រសិទ្ធិភាពគឺជាល្បឿនសម្រាប់ធ្វើឱ្យពលៈកើតឡើង, ៤-ជោគជ័យ(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៥)ព្រះយោគី មានលក្ខណៈផ្សេងគ្នាទៅតាមឧបាយ ដែលខ្លួនបានប្រកាន់យក ៖ ទន់, កណ្ដាល និងរឹងឬខ្លាំង, ៥-ដោយស្វាមីភក្តីចំពោះព្រះឥស្វរៈ។

ច-ឧមៈ ៖ ១-ព្រះឥស្វរៈគឺជាបុរុមៈពិសេសមួយ គ្មានជាប់ដោយសេចក្ដីទុក្ខព្រួយ, គ្មានអំពើ, គ្មានវិបាក និងគ្មានតណ្ហា, ២-ព្រះអង្គជានិត្យៈ ហើយវិញ្ញាណ គឺការដឹងទូទៅទាំង

អស់នៃសត្វលោកព្រមទាំងធម្មជាតិ លោកចាត់ទុកជាប្រាណៈទាំងអស់, ៣-ព្រះឥស្វរៈ គឺ ជាគ្រូរបស់គ្រូទាំងអស់ក្នុងលោក, ៤-បាតុភាពនៃពាក្យរបស់ព្រះអង្គគឺ ឧមៈ, ៥-គេត្រូវធ្វើបរិកម្មម្តងហើយម្តងទៀតញយៗ រាប់ម៉ឺន រាប់សែនដងនៃពាក្យថាឧមៈ, ៦-ឧមៈ បង្កើតបាននូវចំណេះ គឺការឃើញនូវចិត្តខាងក្នុង និងបំបាត់បង់នូវនីវរណធម៌ទាំងអស់។

ធ-សណ្ឋាននៃយោគៈនិងសមាធិ ៖ ១-រោគ, ចិត្តកោសជ្ជៈ, ឧទុស្សាហៈ, ថីនមិទ្ធៈ, អកូតសញ្ញា, អបត្តសមាធិ, បត្តនសភាវៈ, ទាំងអស់នេះ គឺជានីវរណធម៌ ធម៌សម្រាប់រាំងចិត្ត។ ២-ការសោកសៅ, ទុក្ខទោមនស្ស ការស្ទុះស្ទាប់កាយ,ការដកដង្ហើមមិនស្រួល តែងប្រព្រឹត្តទៅជាមួយយោគៈដែលប្រាសចាកនីវណធម៌។ សភាពទាំងពីរបែបខាងលើនេះ កាលបើកើតមានហើយ ព្រះយោគីត្រូវចម្រើនវត្ថុអារម្មណ៍តែមួយគត់ ទើបអាចទប់ទល់បាន។ មិនតែប៉ុណ្ណោះ ព្រះយោគីត្រូវផ្សាយមិត្តភាព, មេត្តា, មោទនភាព, អព្យាកតភាព ចំពោះអារម្មណ៍ទាំងឡាយ ទោះជាទីរីករាយក្តី មិនជាទីរីករាយក្តី ល្អក្តី អាក្រក់ក្តី ដើម្បីធ្វើឱ្យចិត្តស្ងប់ស្ងាត់។ បើមិនដូច្នោះទេ, ព្រះយោគីត្រូវតែធ្វើការដកដង្ហើមចេញចូលឱ្យស្មើ។ ដែលព្រះយោគីធ្វើដូច្នេះ គឺដើម្បីឱ្យចិត្តប្រារព្ធព្យាយាមឡើង។ ម្យ៉ាងទៀត ព្រះយោគី ត្រូវចម្រើនពន្លឺដើម្បីឱ្យចិត្តភ្លឺឡើងហួសសេចក្តីទុក្ខព្រួយគ្រប់បែប។ ៣-ព្រះយោគីត្រូវចម្រើនអលោកចិត្ត, វិទ្យាដែលចូលមកក្នុងពេលដេកលក់, កុសលចិត្ត។ កាលបើដូច្នេះ ចិត្តរបស់ព្រះយោគី នឹងចៀសផុតពីអំណាចនៃជាតុបរមាណូរបស់ធម្មជាតិ, ហើយចិត្តរបស់លោកនឹងទៅជានឹងន៌ទៅបាន។ កាលបើព្រះយោគីចម្រើនតាមលក្ខណៈខាងលើរួចហើយៗ ចិត្តរបស់លោកស្ងប់ស្ងាត់ព្រមទាំងមានពន្លឺដូចជាពេជ្រ ប្រាសចាកមន្ទិលសព្វបែបយ៉ាង។ ៤-សំឡេង, អត្ថន័យ, វិទ្យាដែលមានផលវិបាក, ទាំងអស់នេះ ឋិតនៅប្រឡូកប្របល់គ្នាហៅថា "សមាធិប្រកបដោយបញ្ញា"។ ឯសមាធិ ដែលមិនប្រកបដោយបញ្ញា គឺបានដល់សតិបរិសុទ្ធ ឬសុញ្ញ ភាវៈនៃគុណ-ឋិតនៅត្រឹមតែអត្ថន័យរបស់វត្ថុអារម្មណ៍ប្រកបដោយសមាធិប៉ុណ្ណោះ។ គតិនៃសមាធិបែបនេះ តែងប្រព្រឹត្តទៅជាមួយវិចារៈ និងអវិចារៈដែលមានអារម្មណ៍ដ៏ល្អិត មានទីបំផុតត្រឹមប្រធានៈឬប្រក្រតិ ហើយសមាធិបែបនេះ ប្រព្រឹត្តទៅជាមួយតែនឹងមូលៈប៉ុណ្ណោះ។ ម្យ៉ាងទៀត សមាធិដែលប្រាសចាកវិចារៈ កាលណាអារម្មណ៍បរិសុទ្ធស្អាតហើយ ចិត្តរបស់ព្រះយោគីក្លាយទៅជានឹងន៌មាំមួនក្រៃលែង។ វិទ្យាដែលបានមកពីសមាធិបែបនោះ ពេញប្រៀបដោយសច្ចៈ។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៦)

**វគ្គទី២ សមាធិវិធី**

***ក-ការសង្កត់សង្កិននៃទុក្ខ*** ៖ *ការធ្វើខ្លួនឱ្យលំបាក, ការសិក្សា, ការប្រគល់ខ្លួនចំពោះព្រះអាទិទេព គេហៅថា ក្រិយាយោគៈ។ ការធ្វើដូចនេះ គឺដើម្បីការប្រតិបត្តិសមាធិ និងការធ្វើឱ្យទុក្ខៈថយឬខ្សោយចុះ។ ការសង្កត់សង្កិនទុក្ខៈ គឺបានដល់នូវការសង្កត់សង្កិនអវិជ្ជា, អត្ត-ទ្រឹស្តិ, ក្រិស្នា, កវៈ និងឧបាទានៈចំពោះជីវិត។ អវិទ្យាគឺជាដើមចមនៃសភាវធម៌ដទៃទៀតទាំងអស់។*

***ខ-ឥស្សរភាពនៃបុរុមៈ*** ៖ *អវិជ្ជាគឺជាដើមចមនៃសភាវៈ ជាមេកំណើតនៃទុក្ខៈ ឯបុរុសៈគឺជាមេកំណើតនៃអទុក្ខៈ និងជាមេកំណើតនៃបញ្ញា។ កាលបើសង្កត់សង្កិនអវិជ្ជាបានហើយ, បុរុសៈទើបក្លាយជាសភាវៈមានឥស្សរភាពពិតប្រាកដបាន។*

***គ-អង្គនៃយោគៈមាន ៨យ៉ាងគឺ*** ៖ *យមៈ (សច្ចាប្រណិធាន), និយមៈ (ការសមាទាន), អាសនៈ (ឥរិយាបថ), ប្រាណាយាមៈ (ការដកដង្ហើមចេញ-ចូល), ប្រត្យាហារៈ (ការហាត់ដកអង្គ), ធារណា (ការចម្រើននូវអារម្មណ៍តែមួយ), ធ្យានៈ (ឈាន-ការដុត) និងសមាធិ (ការតាំងចិត្ត)។*

***១-យមៈ (សច្ចាប្រណិធាន)*** ៖ *ក-ការវៀរចាកការសម្លាប់, ខ-ការវៀរចាកការពោលពាក្យកុហក, គ-ការវៀរចាកការលួចទ្រព្យគេ, ឃ-ឥន្ទ្រីយ៍សំវរៈ, ង-ការវៀរចាកការទទួល។ ទាំង ៥នេះ ត្រូវរក្សាឱ្យបានខ្ជាប់ខ្ជួនកុំឱ្យដាច់ ឬវិនាសដោយអំណាចកាលៈ, ទេសៈ, បំណង និងច្បាប់របស់វណ្ណៈឡើយ។*

***២-និយមៈ (ការសមាទាន)*** ៖ *ក-ការស្អាតខាងក្នុង (ចិត្ត), ខ-ការស្អាតខាងក្រៅ (កាយ-វាចា),គ-ការសន្តោស,ឃ-តបៈ, ង-ការសិក្សា, ច-ការគោរពបន់ស្រន់ព្រះអាទិទេព , ទាំង៦នេះ ព្រះយោគីត្រូវតែមានសមាទានជានិច្ចកាល។*

***៣-អាសនៈ (ឥរិយាបថ)*** ៖ *ក-ឥរិយាបថត្រូវតែមានលក្ខណៈមាំមួននិងនឹងន, ខ-ត្រូវបន្ធូរយនិទ្រាការធម្មតា (ដែលមានលក្ខណៈមិននឹងន) រួចហើយចម្រើននូវអារម្មណ៍ដែលឥតព្រំដែន (កាលបើធ្វើដូច្នេះ ឥរិយាបថរបស់ព្រះយោគីក្លាយទៅជានឹងន និងរឹករាយ)។*

***៤-ប្រាណាយាមៈ (ការដកដង្ហើមចេញ-ចូល)*** ៖ *ក-ការសង្រួមខ្យល់ដែលដកចេញហើយការដកចូលក៏ប្រព្រឹត្តទៅតាមក្រោយ, ខ-ការប្រែប្រួលការដកដង្ហើមចេញ ឬចូល ឬក៏បញ្ឈប់ខ្យល់ទាំងស្រុងតែម្តង ត្រូវរៀបចំឡើងដោយកាល, កន្លែង, ចំនួនខ្លីឬវែង។ គ-*

សង្រួមប្រាណដោយការចុះមើលអារម្មណ៍ខាងក្រៅឬខាងក្នុង។ កាលបើធ្វើដូច្នេះ ចិត្តរបស់ព្រះយោគី ក្លាយទៅជាមានពន្លឺប្រកបដោយមនសិការ។ ឃ-ចិត្តក៏គួរដល់ធារណា គឺការចម្រើនអារម្មណ៍តែមួយបាន។

***៥-ប្រត្យាហារៈ (ការហាត់ដកអង្គ)*** ៖ ក-ព្រះយោគី កាលបើការចម្រើនអារម្មណ៍មួយៗស្ទាត់ហើយ ត្រូវរៀនហាត់ដកអង្គនៃអារម្មណ៍នោះ ឱ្យចិត្តចេញស្រឡះពីអារម្មណ៍, ខ-កាលបើហាត់ដូច្នេះបានសម្រេចហើយ ចិត្តរបស់ព្រះយោគីនឹងអាចសម្រួលឬត្រួតត្រាទៅលើអង្គរបស់អារម្មណ៍សម្រាប់ចម្រើននោះ បានដោយងាយ ជាចិត្តស្ទាត់។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៧)

***៦-ធារណា (ការចម្រើននូវអារម្មណ៍តែមួយ)*** ៖ គឺគេត្រូវធ្វើការចម្រើនទៅលើអារម្មណ៍ណាមួយ. កាលបើធ្វើដូច្នេះបានសម្រេចហើយ ជាហេតុធ្វើឱ្យយោគៈមានពលៈកម្លាំងឬអំណាចឡើង។

***៧-ធ្យានៈ (ឈាន-ការដុត)*** ៖ កាលបើព្រះយោគីចម្រើននូវអារម្មណ៍តែមួយបានហើយ ធ្យាននៃចិត្តក៏កើតមានឡើងដែរ គឺចិត្តប្រាកចាកសភាវៈដែលរារាំង។

***៨-សមាធិ (ការតាំងចិត្តស្ងប់)*** ៖ ចិត្តនៅខណៈនេះ គឺត្រូវលះបង់រូបរបស់អារម្មណ៍អស់រលីងហើយ នៅសល់តែសេចក្តីឬអត្ថៈរបស់អារម្មណ៍នោះប៉ុណ្ណោះ ជាចិត្តចូលមកថ្នាក់លើហើយ, ចិត្តមានខណៈបែបនេះលោកហៅថា ចិត្តប្រកបដោយសមាធិ គឺចិត្តដែលបានចម្រើនត្រឹមត្រូវល្អហើយ ជាចិត្តស្ងប់អារម្មណ៍ទាំងល្អទាំងអាក្រក់។

អង្គនៃយោគៈទាំង៣ ខាងចុងគឺទី៦, ៧ និងទី៨ ជាអង្គសម្រាប់ធ្វើឱ្យយោគៈមានកម្លាំង។

**វគ្គទី៣ ពលៈ**

ក-អង្គនៃយោគៈ គឺធារណា, ធ្យានៈនិងសមាធិ សម្រាប់ចម្រើនតែមួយឈ្មោះសំយមៈ។ គេត្រូវចម្រើនតាមលំដាប់ថ្នាក់ គឺតាំងពីធារណាធ្យានៈ រហូតដល់សមាធិ ដែលជាចិត្តគ្មានអារម្មណ៍ប្រកបដោយរូប។ កាលបើដូច្នេះហើយ ប្រាជ្ញាក៏ដុះចេញមកពីការចម្រើននោះ។ ប៉ុន្តែគួរកត់សម្គាល់ថា ថ្នាក់ទាំង៣នេះ ប្រព្រឹត្តនៅខាងក្នុងជាងខាងក្រៅ សូម្បីចិត្តទាំងអស់នោះឋិតនៅខាងក្រៅពីវង្វង់សមាធិដែលប្រាសចាកអារម្មណ៍ឥតរូបក៏ដោយ (អមូលសមាធិ)។ ថ្នាក់នីមួយៗ មានការប្រែប្រួលខុសគ្នា។

ខ-ការប្រែប្រួលអាការៈនៃពលៈរបស់ចិត្ត និងការឃើញច្បាស់ព្រមទាំងការត្រាស់ដឹង, ១-ដោយការធ្វើសំយមៈទៅលើការប្រែប្រួលទាំង ៣ថ្នាក់ សម្រាប់ឃើញនូវអតីតៈ និង អនាគតក៏កើតឡើង។ ២-ដោយការធ្វើសំយមៈទៅលើពាក្យ សេចក្តីនិងវិទ្យា ដែលលក្ខណៈប្របូកប្របល់, វិទ្យាសម្រាប់ស្តាប់សំឡេងសត្វក៏កើតឡើង។ ៣-ដោយការទទួលស្នូរដែលលាន់ឮឡើង, វិទ្យាសម្រាប់ដឹងនូវជីវិតអតីតៈ ក៏កើតមានឡើងជាដើម...។

គ-អំណាចដ៏ខ្ពង់ខ្ពស់បំផុត ៖ ១-ព្រះយោគីអាចនិម្មិតចិត្តចេញពីខ្លួនមួយទៅខ្លួនមួយទៀតបាន។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៨) ២-អាចដើរលើទឹក ភ្លើងបាន។ ៣-កាលបើព្រះយោគីប្រើសំយមៈឱ្យមានការទាក់ទងជាមួយនឹងអាកាស គេអាចឮសំឡេងឋាន សួគ៌ អាចហោះបានជាដើម...។

ឃ-ការរួចស្រឡះចាកអារម្មណ៍របស់ចិត្ត ៖ កាលបើចិត្តរួចចាកអារម្មណ៍ទាំងល្អ ទាំងអាក្រក់ សូម្បីឫទ្ធិដែលអាចស្តែងបានជានេះជានោះហើយ ការវិនាសសាបសូន្យនៃកិលេសធម៌ទាំងអស់កើតឡើង ហើយចិត្តរបស់យោគីក៏បានដល់នូវវិមុត្តិ (ការរួចស្រឡះ) ទាំងស្រុង ដែលហៅថា កៃវល្យៈ។ ទាំងនេះ កើតឡើងពីសេចក្តីបរិសុទ្ធនៃចិត្តកើតឡើង សត្វៈ (Sattva) និង បុរុសៈ (Purusha)។

**វគ្គទី៤ ឥស្សរភាព ឬ ឯករាជ្យ**

ក-តណ្ហានិងអារម្មណ៍នៃចិត្ត ៖ ១-សិទ្ធិឬអំណាច គេអាចបានទទួលដោយកំណើត, អំណាចគីមី, អំណាចពាក្យ, អំណាចតបៈ និងអំណាចសមាធិ។ ២-ការផ្លាស់ប្តូរទៅជាមនុស្សភេទដទៃទៀត គឺដោយការបំពេញនូវសភាវៈផ្សេងៗក្នុងធម្មជាតិ។ ៣-អំពើល្អនិងអាក្រក់ពុំមែនជាហេតុផ្ទាល់សម្រាប់ផ្លាស់ប្តូរធម្មជាតិទេ, តាមពិត អំពើទាំងពីរនេះ គ្រាន់តែជាកត្តាសម្រាប់បំបាត់នូវឧបសគ្គផ្សេងៗចំពោះវឌ្ឍនាការនៃធម្មជាតិប៉ុណ្ណោះ។ ៤-អត្តទិដ្ឋិតែមួយគត់ ដែលនាំឱ្យសត្វកើតទៀត។ ៥-ទោះណាជាចិត្តកិច្ចមានច្រើនជាទីបំផុត ក៏គង់មានចិត្តដែលជាកំណើតដើមមួយគត់អាចត្រួតត្រាចិត្តកិច្ចទាំងអស់នោះបាន។ ៦-កិច្ចការរបស់យោគីគ្មានពណ៌ខ្មៅ-សទេ, ពណ៌ខ្មៅ-ស និងពណ៌លាយគ្នាជាសភាវៈខាងក្រៅ។ ៧-ចិត្តដែលប្រកបដោយសមាធិ ជាចិត្តប្រាសចាកតណ្ហា។ ៨-ចិត្តទាំងអស់តែងប្រែប្រួលទៅតាមអារម្មណ៍, មានតែបុរុសៈ (អាត្មន) មួយគត់ដែលមិនប្រែប្រួល។ ៩-ឯកភាពនៃវត្ថុ បណ្តាលមកពីឯកភាពនៃការផ្លាស់ប្តូរ។

១-វិមុត្តិ (The wisdom of India), Edited by Lin Yutang, p.136-149) (ការរួចចាកស្រឡះ) ៖ មានតែកៃវល្យៈ (វិមុត្តិ) មួយ គឺជាថ្នាក់នៃចិត្តដែលរួចស្រឡះពីកិលេសគ្រប់យ៉ាង។ កាលណាយោគីចម្រើនដល់អមូលសមាធិ ចិត្តរបស់គេមានសេចក្តីបរិសុទ្ធស្មើគ្នារវាងសត្វៈ និងបុរសៈ ជាចិត្តដែលរលាយចូលទៅក្នុងអាត្ម័នរបស់ចក្រវាល ព្រះព្រហ្ម ឬអាទិទេព។

**២-ព្រះពុទ្ធសាសនា** ៖ មុននឹងបរិយាយពីលក្ខណៈទូទៅនៃសីលធម៌ យើងសូមបរិយាយដោយសង្ខេបនូវ ការត្រាស់ដឹងនៃព្រះពុទ្ធជាម្ចាស់ដែលមាននាមល្បីល្បាញថា "សម្មាសម្ពុទ្ធ" ការត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ដើម្បីណែនាំអ្នកអានឱ្យយល់ច្បាស់នៃដំណើរប្រតិបត្តិនៃសីលធម៌ផង នូវការទូទៅផង។

ពាក្យថា "សម្មាសម្ពុទ្ធោ" ប្រែថា "ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៤៩) មានលក្ខណៈ៧យ៉ាងគឺ ៖

ក-ចត្តារិ សច្ចានិ សម្មាសម្ពុទ្ធោ ៖ ព្រះអង្គត្រាស់ដឹងនូវពិត ៤ប្រការគឺ ៖ ទុក្ខៈ, សមុទយៈ, និរោធៈ, មគ្គៈ ដែលហៅថា "អរិយសច្ចៈ" បានន័យថា ធម៌ពិតរបស់ព្រះអរិយៈ, ធម៌ពិតនាំឱ្យឆ្ងាយចាកសឹកសត្រូវ, ធម៌ពិតញុំាងភាពជាអរិយៈឱ្យសម្រេច និងធម៌ពិតដ៏ប្រសើរ។ ធម៌ពិតរបស់ព្រះអរិយៈ បានដល់អរិយសច្ចៈដែលត្រាស់ដឹងនិងយល់ច្បាស់ ដោយព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម។ ពួកព្រះអរិយៈ មានធម៌នេះជាមគ៌ាកធម៌ពិត នាំឱ្យឆ្ងាយចាកសឹកសត្រូវ បានដល់ពួកអ្នកត្រាស់ដឹងនូវអរិយសច្ចៈទាំង៤ ហើយសឹកសត្រូវទាំងឡាយមានកិលេសជាដើម ត្រូវវិនាសបាត់បង់លែងឋិតនៅក្នុងសន្តានរបស់លោកទៀតឡើយ គឺលោកត្រូវបានឃ្លាតចាកសឹកសត្រូវទាំងអស់នោះ។ ធម៌ពិតញុំាងភាពជា អរិយៈឱ្យសម្រេច បានន័យថា អរិយសច្ចៈទាំង៤នេះ បើលោកណាដឹងច្បាស់ដោយប្រាជ្ញាថា នេះទុក្ខ, នេះហេតុនាំឱ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះជាផ្លូវប្រតិបត្តិដើម្បី រលត់ទុក្ខដូច្នេះ ជាដើម ព្រមទាំងវដ្តៈ៣ និងអាការៈ ១២ ហើយក៏អាចធ្វើឱ្យរូបនោះ សម្រេចជាអរិយៈបាន។ ឯធម៌ពិតដ៏ប្រសើរនោះ បានន័យថា អរិយសច្ចៈទាំង៤នេះ ជាធម៌ពិតមែន គឺទុក្ខ ពិតជាទុក្ខមែន, សមុទយៈ ពិតជាហេតុនាំឱ្យកើតទុក្ខមែន, និរោធៈ ពិតជាសេចក្តីរលត់ទុក្ខមែន និងមគ្គៈ ពិតជាផ្លូវនាំឱ្យរលត់ទុក្ខមែន ជាដើម។

ពាក្យថា ទុក្ខ: បើពោលដោយរួបរួម បានដល់ខន្ធ ៥ តាមបាលីថា សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធា ទុក្ខា ខន្ធ ៥ដែលជាគំនួចរបស់ឧបាទាន ហៅថា ទុក្ខៈដោយបំប្រួញ។ សមុទយៈ សំដៅយកតណ្ហា ៣ប្រភេទគឺ ៖ កាមតណ្ហា, ចវតណ្ហា, វិភតណ្ហា។ តណ្ហាទាំង ៣យ៉ាងនេះ ជាហេតុនាំឱ្យកើតទុក្ខ។ កាលបើតណ្ហាជាមេបណ្ដាលឱ្យកើតទុក្ខរលត់ហើយ ទុក្ខក៏រលត់បាត់ទៅជាមួយផង ដូចជាពន្លឺអំពិលអំពែកត្រូវពន្លឺព្រះអាទិត្យ។ និរោធ: សំដៅយកព្រះនិព្វានជាទីរលត់នៃទុក្ខទាំងអស់ និងគ្មានកើតគ្មានស្លាប់។ មគ្គ: សំដៅយកអដ្ឋង្គិកមគ្គ គឺផ្លូវប្រតិបត្តិដែលប្រកបដោយអង្គ ៨ប្រការ ជាផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វាន។ អដ្ឋង្គិកមគ្គនេះ បើពោលដោយរួបរួម មានត្រឹមតែ ៣ប្រការ “ខន្ធ” គឺជាផ្នែកបញ្ញាខន្ធមាន សម្មាទិដ្ឋិ (ការយល់ត្រូវ) និងសម្មាសង្កប្បោ (ការត្រិះរិះត្រូវ), ផ្នែកសីលខន្ធមាន សម្មាវាចា (វាចាត្រូវ), សម្មាកម្មន្តោ (ការងារត្រូវ) និងសម្មាអាជីវោ (ការចិញ្ចឹមជីវិតត្រូវ), ផ្នែកសមាធិខន្ធមានសម្មាវាយាមោ (ការព្យាយាមត្រូវ) សម្មាសតិ (ការរឭកត្រូវ) និង សម្មាសមាធិ (ការតាំងចិត្តត្រូវ)។

យើងសូមបញ្ជាក់ថា អរិយសច្ចៈទាំង៤នេះ លោកចាត់ជាហេតុនិងផលដូច្នេះគឺ ៖ សមុទយសច្ចៈ ជាហេតុ, ទុក្ខសច្ចៈ ជាផល, មគ្គសច្ចៈ ជាហេតុ, និរោធសច្ចៈ ជាផល។

ខ-និព្វានំ សម្មាសម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវព្រះនិព្វាន ៣ប្រការគឺ ៖ កិលេសនិព្វាន, ខន្ធនិព្វាន និង ធាតុនិព្វាន។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥០)

គ-អភិញ្ញេយ្យធម្មំ សម្មាសម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ គឺទុក្ខសច្ចៈដែលមានលក្ខណៈ ១២គឺ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកទុក្ខ បរិវេទទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិ សម្បយោគទុក្ខ បិយេហិ វិប្បយោគទុក្ខ យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ។ ទុក្ខទាំង ១២នេះ ប្រមូលមកមានតែឧបាទានក្ខន្ធ ៥ ជាមេទុក្ខ (សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធា ទុក្ខា)។

ឃ-បរិញ្ញេយ្យំ ធម្មំ សម្មាសម្ពុទ្ធ ព្រះអង្គត្រាស់ដឹងនូវធម៌ដែលគួរកំណត់ដឹង គឺបានដល់ទុក្ខសច្ចៈ ដែលមានលក្ខណៈ ១២ ដូចដែលបានពោលរួចមកហើយ។

ង-មហាតព្វេ ធម្មំ សម្មាសម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវធម៌ដែលគួរលះបង់ គឺបានដល់សមុទយសច្ចៈ តណ្ហាទាំង៣ ៖ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា។

ច-សច្ឆិកាតព្វំ ធមេ សម្មាសម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវធម៌ដែលគួរធ្វើឱ្យជាក់លាក់ គឺនិរោធសច្ចៈ បានដល់ព្រះនិព្វានដែលអ្នកប្រាជ្ញទាំងឡាយគួរធ្វើឱ្យជាក់ច្បាស់ ដោយមគ្គញ្ញាណទាំង ៤។

ឆ-ភាវេតព្វំ ធម្មេ សម្មាសម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវធម៌ដែលគួរចម្រើន គឺមគ្គសច្ចៈ បានដល់អរិយមគ្គៈ ដែលប្រដាប់ដោយអង្គ៨ ប្រការ មានសម្មាទិដ្ឋិជាដើម។ អរិយមគ្គទាំង៨ ប្រការនេះ គេហៅថា ធម្មទុញ្ញនៃព្រះពុទ្ធជាម្ចាស់ក៏បាន។

យើងសូមបញ្ជាក់ថា លក្ខណៈទាំង៧ប្រការនៃពាក្យថា "សម្មាសម្ពុទ្ធោ" ក៏គឺរួមទៅលើអរិយសច្ចៈទាំង៤តែប៉ុណ្ណោះ។ លក្ខណៈនៃអរិយសច្ចៈទី១ និងទី២ គឺទុក្ខសច្ចៈ និង សមុទយសច្ចៈ យើងបានពោលមកហើយខាងដើម ត្រង់មូលប្រតិស្ឋនៃលោកជាតុ។

ដើម្បីស្គាល់ពីសីលធម៌នៃព្រះពុទ្ធសាសនា យើងសូមលើកយកអរិយសច្ចៈទី៣ និងទី៤ គឺនិរោធសច្ចៈ និងមគ្គសច្ចៈ មកអធិប្បាយដោយសង្ខេបដូចតទៅនេះ ៖

សីលេ បតិដ្ឋាយ នរោ សបញ្ញោ

ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបក្កោ ភិក្ខុ តិ (សូមមើល "វិសុទ្ធិមគ្គ" ភាគ១, ដោយព្រះពុទ្ធឃោសនាចារ្យ)។

ប្រែថា ៖ "នរៈប្រកបដោយប្រាជ្ញា កាលបានតម្កល់ចិត្តយ៉ាងមាំក្នុងសីល ហើយអប់រំនូវសមាធិចិត្តនិងវិបស្សនាបញ្ញា ឈ្មោះថាអ្នកឃើញភ័យក្នុងវដ្តសង្សារ ជាអ្នកមានពិព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស និងជាអ្នកមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន"។

"សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនន្តិ" (សូមមើល "ឱវាទបាដិមោក្ខ") (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥១)

ប្រែថា ៖ ការមិនធ្វើអំពើអាក្រក់គ្រប់យ៉ាង

ការបំពេញសេចក្តីល្អ

ការជម្រះចិត្តរបស់ខ្លួនឱ្យបរិសុទ្ធស្អាត។

ទាំងអស់នេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ។

ពុទ្ធភាសិតទាំងពីរនេះ បញ្ជាក់ឱ្យឃើញនូវលក្ខណៈដ៏សំខាន់នៃសីល,សមាធិ,និងបញ្ញា ដែលជាគ្រឹះដ៏មាំមួនសម្រាប់អប់រំកាយ, វាចា និងចិត្ត ព្រមទាំងឱ្យបានប្រាជ្ញាដ៏ស្រួចស្រាល់។ ម្យ៉ាងទៀត ភាសិតទាំងពីរនេះបានទ្រោលបំភ្លឺនូវផ្លូវប្រតិបត្តិឱ្យដល់នូវនិរោធគឺ ព្រះនិព្វាន។

ការប្រតិបត្តិសីលធម៌, សមាធិធម៌និងបញ្ញាធម៌ អាចប្រព្រឹត្តទៅបានដោយប្រពៃ អាស្រ័យជាមួយនឹងការដឹងច្បាស់នូវលោកធាតុ (សូមមើលត្រង់បញ្ហាលោកធាតុខាងដើម) និងសភាពមនុស្ស (សូមមើលត្រង់បញ្ហាសភាពមនុស្សខាងដើម និងអភិធម្មត្ថសង្គហៈទាំងមូល)។

ក្នុងការអប់រំសីលធម៌ ព្រះពុទ្ធជាម្ចាស់បានលាតត្រដាងដល់មនុស្សគ្រប់ថ្នាក់គឺ ឧបាសក ឧបាសិកា, ភិក្ខុ,ភិក្ខុនី, សាមណេរ, សាមណេរី និងសិក្ខមានា (សូមមើល "សីលនិទ្ទេសពិស្តារ" ដោយលោក អ៊ុច-រស់)។ ឯសមាធិ (សូមមើល "សមាធិនិទ្ទេស" ដោយលោក អ៊ុច រស់) និងបញ្ញា (សូមមើល "បញ្ញានិទ្ទេស" ដោយបណ្ឌិត ឈឹម-ទូច) ក៏ដូចគ្នា។ សីល, សមាធិ និង បញ្ញា គឺពោលដោយរួបរួមក្នុងអរិយមគ្គ ឬអដ្ឋង្គិកមគ្គទាំង ៨ ឡើងអាស្រ័យសមាធិ, សមាធិកើតមានឡើងអាស្រ័យនឹងសីល។ ដូច្នេះ ធម៌ទាំង៣ នេះត្រូវអាស្រ័យគ្នាទៅវិញទៅមក, ហើយសីលធម៌មិនមែនគ្រាន់តែឋិតនៅក្នុងខេត្តនៃការលះបង់សេចក្តីអាក្រក់ប៉ុណ្ណោះទេ គឺត្រូវបំពេញសេចក្តីល្អថែមទៀត។ ជាទីបំផុត សីល, សមាធិ និងបញ្ញាទាំង ៣ នេះ ជាឧបាយទៅកាន់ការត្រាស់ដឹងតែម្តង។ ជាពិសេសធម៌ទាំង៣នេះ សម្រាប់ញ៉ាំងមនុស្សឱ្យឡើងឋានៈពីបុថុជ្ជនធម្មតាទៅកាន់អរិយបុថុជ្ជន, ពីអរិយបុថុជ្ជនៈ ទៅកាន់ភាពជាព្រះអរិយៈ។ ឯអរិយមគ្គ៨ ដែលពោលដោយសង្គ្រោះថាសីលក្ខន្ធ, សមាធិក្ខន្ធ និងបញ្ញាខន្ធនោះគឺ ៖

១-បញ្ញាខន្ធ

ក-សម្មាទិដ្ឋិ ការយល់ត្រូវ គេទុកជាគោលការដ៏សំខាន់នៃព្រះពុទ្ធសាសនា បានដល់ការយល់ត្រូវក្នុងស្ថានហេតុ ៣យ៉ាងគឺ ៖

-ត្រៃលក្ខណ៍ទាំង៣ ៖ អនិច្ចៈ, ទុក្ខៈ និង អនត្តា

-អរិយសច្ចៈទាំង ៤

-កម្មៈ (សូមមើលវាសនាបន្ទាប់ពីសេចក្តីស្លាប់ខាងដើមនិងអភិធម្មត្ថសង្គហៈ) និងបដិច្ចសមុប្បាទៈ (សូមមើលខាងដើម បញ្ហាលោកធាតុ ត្រង់មូលប្រតិស្ឋនៃលោក)។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥២)

ទាំងអស់នេះជាឧត្តមគតិឋិតនៅពីមុខអ្នក ដែលជាសិស្សសាវ័កនៃព្រះពុទ្ធសម្រាប់ការត្រាស់ដឹង។

១-សម្មាសង្កប្បៈ ការត្រិះរិះត្រូវ ក៏គេទុកជាគោលការដ៏សំខាន់នៃបញ្ញាខន្ធដែរ បានដល់ការត្រិះរិះជាជំនួយដល់ការយល់ត្រូវ។ ការត្រិះរិះ សំដៅយកការតាំងចិត្តយ៉ាងមាំ ដើម្បីលះបង់អ្វីទាំងអស់ដែលនាំឱ្យមានឧបសគ្គដល់ការត្រាស់ដឹងនូវស្ថានហេតុទាំង៣ខាងដើម។ ព្រះពុទ្ធទ្រង់ត្រាស់សម្ដែងថា "ម្នាលភិក្ខុទាំងឡាយ ! អ្នកគ្រប់គ្រងផ្ទះឬបុត្ររបស់អ្នកនោះបានស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ហើយមានសទ្ធាជ្រះថ្លាចំពោះព្រះអង្គ បានគិតថា "ជីវិតរបស់គ្រហស្ថជាជីវិតប្រកបដោយពលិពោធច្រើនជាអនេកប្បការ, ឯជីវិតរបស់អ្នកបួស ជាជីវិតប្រកបដោយធម៌ទូលំទូលាយដូចជាអាកាស។ ដើម្បីបំពេញធម៌ជីវិតគ្រហស្ថពិបាកនឹងប្រព្រឹត្តជាទីបំផុត។ ដូច្នេះ អាត្មាអញត្រូវតែកោរសក់-ពុកចង្កា ស្លៀកដណ្ដប់ចីពរមានពណ៌លឿង, កាន់យកផ្លូវជាអនាគារិក"។ ការត្រិះរិះត្រូវ ហើយតាំងចិត្តដូច្នេះ ឈ្មោះថា សម្មាសង្កប្បៈ។

**២-សីលក្ខន្ធ**

ដើម្បីជៀសវាងយោគៈ ជាធម៌ថោកទាបទាំងពីរគឺ ៖ កាមសុខល្លិកានុយោគ ការប្រកបខ្លួនតែក្នុងការសប្បាយរីករាយ ដូចជាការសប្បាយស៊ី សប្បាយផឹកជាដើម និង អត្តកិលមត្ថានុយោគ ការប្រកបខ្លួននៅក្នុងតបធម៌ផ្សេងៗ ដូចជាដេកអាំងថ្ងៃដើម្បីឱ្យអស់កិលេស, ការដេកលើដីខ្សាច់ក្ដៅជាដើម។ ធម៌ទាំងពីរនេះ ជារបស់ពួកអ្នកចិន្តា ២ក្រុមនៅជំនាន់និងមុនព្រះពុទ្ធជាម្ចាស់។ ទី១ គេជឿថាខាងក្រោយពីសេចក្ដីស្លាប់ មនុស្សមិនកើតទៀត បានជា នាំឱ្យគេគិតតែពីការសប្បាយនៅក្នុងលោកនេះជាដើម។ នេះជាក្រុមទស្សនៈ មារុវាគៈ ជានិកាយសម្ភារនិយមនៃឥណ្ឌា។ ទី២ គេជឿថាជីវិតអនាគត ជាជីវិតនៅក្នុងឋានសួគ៌ ជាជីវិតទៀង ជាជីវិតបរមសុខ ដែលនាំឱ្យគេស្អប់រាងកាយ ធ្វើបាបរាងកាយ ជាជីវិតត្រូវធ្វើតបៈ ដើម្បីដូរយកជីវិតឋានសួគ៌។ ព្រះពុទ្ធជាម្ចាស់បានប្រតិបត្តិធម៌ទាំងពីរនេះ មុនពេលដែលព្រះអង្គមិនទាន់បានត្រាស់ដឹងដែរ ហើយទ្រង់លះបង់ការប្រតិបត្តិនោះចេញ ទ្រង់កាន់យកការប្រតិបត្តិជារបៀបកណ្ដាលវិញ ជាផ្លូវសីលធម៌ប្រចាំខ្លួន ជាផ្លូវនាំឱ្យខ្លួនឈ្នះ។

ការប្រតិបត្តិតាមផ្លូវកណ្ដាលនោះ គឺបានដល់ ក-សម្មាវាចា វាចាឬសម្ដីត្រូវ ខ-សម្មាកម្មន្តៈ ការងារត្រូវ, គ-សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ។

ក-កម្មាវាចា ៖ វាចាឬសម្ដីត្រូវនោះ បានដល់ការវៀរចាកការពោលពាក្យកុហកដែលហៅថា មុសាវាទ, ការវៀរចាកការពោលពាក្យញុះញង់ ហៅថា បិសុណាវាទ, ការវៀរចាក

ការពោលពាក្យអាក្រក់ ហៅថា ផរុសវាទ , វៀរចាកការពោលពាក្យឥតប្រយោជន៍ ហៅថា សម្ផប្បលាបៈ។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥៣)

ខ-សម្មាកម្មន្តៈ ៖ ការងារត្រូវ បានដល់ការវៀរចាកការមិនសម្លាប់សត្វ, ការលួចទ្រព្យគេ, ការប្រព្រឹត្តិខុសក្នុងកាម។

គ-សម្មាអាជីវោ ៖ ការចិញ្ចឹមជីវិតត្រូវ បានដល់ការវៀរចាកជំនួញប្រាំប្រការ គឺការលក់គ្រឿងសាស្ត្រាវុធ, ការជួញមនុស្សឬសត្វមានជីវិត, ការជួញសាច់, ការជួញទឹកស្រវឹង និងការជួញថ្នាំពុល។ ជំនួញទាំង ៥ប្រការនេះមិនមែនជាបញ្ហារបស់ព្រះពុទ្ធជាម្ចាស់ដែលយើងកំពុងតែប្រព្រឹត្តដើម្បីព្រះនិព្វាននោះឡើយ។ កាលណាយើងប្រព្រឹត្តធ្វើនូវអំពើទាំងអស់នោះ គ្រោះថ្នាក់ខាងផ្លូវចិត្តនឹងត្រូវកើតមានឡើងនៅពេលធ្វើសមាធិ ដែលជាឧបាយតែមួយគត់ដើម្បីបានប្រាជ្ញា។ ព្រះពុទ្ធមានតម្រាស់ថា "ការប្រតិបត្តិសីល ដើម្បីឱ្យបានដល់នូវសមាធិ ដើម្បីឱ្យបានដល់នូវប្រាជ្ញា"។

### ៣-សមាធិក្ខន្ធ

អាចារៈដ៏បរិសុទ្ធដែលគេបានរក្សាហើយ ឬបានអប់រំហើយ អាចទៅជាមូលដ្ឋានដ៏សំខាន់នៃការអប់រំខាងផ្លូវចិត្ត។ ប៉ុន្តែមុននឹងស្តីពីសម្មាសមាធិ យើងសូមពោលដោយសង្ខេបពីសភាពចិត្តរបស់មនុស្សជាតិបន្តិចសិន។

តាមពិត យើងដឹងធម្មជាតិទាំងអស់នៅជុំវិញខ្លួនគ្រប់ពេលវេលាឥតដែលទំនេរឡើយ លើកលែងតែពេលដេកលក់ចេញ។ ប៉ុន្តែការដឹងទាំងអស់នេះ មិនឋិតថេរចីរកាលប៉ុន្មានឡើយ គឺយើងត្រូវភ្លេចទៅវិញជាធម្មតា។ ចិត្តរបស់យើងសម្រាប់ចាប់អារម្មណ៍ មានលក្ខណៈភ្លឹបភ្លែតៗ ដូចជាអំពីលអំពែក។ ឧទាហរណ៍ ៖ យើងកំពុងដើរតាមផ្លូវ គាប់ជួនជាឃើញ មនុស្សម្នាក់ដែលយើងស្គាល់, ដឹងច្បាស់ថា "មនុស្សនោះឈ្មោះនេះជាដើម" កាលបើយើង ដើរហួសទៅមុខទៀត យើងក៏ភ្លេចមនុស្សនោះវិញ, ព្រោះចិត្តយើងរវល់ទទួលអារម្មណ៍ ដទៃផ្សេងទៀត។ ដូច្នេះចិត្តរបស់យើង ដឹងរបស់មួយហើយភ្លេចទៅវិញ, ដឹងរបស់មួយ ហើយភ្លេចទៅវិញ, ដឹងរបស់មួយទៀត ហើយភ្លេចវាទៀត, ការដឹង-ភ្លេច, ភ្លេច-ដឹង ជាលក្ខណៈប្រព្រឹត្តទៅតាមធម្មតា ឥតមានអ្វីមករាំងបានឡើយ តាំងពីកើតមករហូតដល់ស្លាប់ទៅវិញ។ សូម្បីយើងកំពុងដេកលក់ ក៏គតិនៃចិត្តបែបនេះឥតឈប់សម្រាកឡើយ។ ប៉ុន្តែគួរសម្គាល់ថា ចិត្តរបស់យើងមិនមែនភ្លេចភ្លាមៗទាំងអស់នូវអ្វីដែលបានដឹង បានឃើញ

នោះទេ។ កាលណាចិត្តរបស់យើងបានជិតជាប់អារម្មណ៍មួយយ៉ាងខ្លាំង។ ឧទាហរណ៍ យើងកំពុងដើរតាមផ្លូវ ហើយបានឃើញដំរី ដែលជាហេតុធ្វើឱ្យចិត្តមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ទោះណាដំរីនោះបានដើរផុតទៅឆ្ងាយហើយក៏ដោយ ក៏ចិត្តរបស់យើងពុំទាន់ភ្លេចវាទៅឡើយ វាអាចបន្តពេលវេលាយ៉ាងយូរទៅទៀតបាន។ ដូច្នេះ យើងអាចឃើញថា ការដឹងនិងការភ្លេចរបស់ចិត្ត មានកន្លែងមួយសម្រាប់ផ្ទុកគឺកន្លែងដែលសង្ខារចេតសិកធ្វើការ បើតាមវិញ្ញាណវាទនៃពុទ្ធសាសនាផ្នែកនិកាយមហាយានថា "អាលយវិញ្ញាណ"។ ក្នុងលក្ខណៈកើត-រលត់នៃចិត្ត ហើយដែលមានកន្លែងសម្រាប់ផ្ទុកការដឹងនិងការមិនដឹងទាំងអស់នោះ យើងសង្កេតឃើញកត្តា ២បែបនៅក្នុងចិត្តរបស់យើងគឺ ៖ ១-ការដឹង, ការទទួលអារម្មណ៍និងការស្គែងនៃចិត្តប្រព្រឹត្តទៅក្នុងបវត្តិកាល, ២-ការប្រមូលជាគំនរទូវគំនិតនិងការចាប់អារម្មណ៍ដែលភ្លេចទាំងអស់។ តាមអ្នកចិត្ត វិទូសម័យថ្មី ចិត្តក្នុងកត្តាទី១ ហៅថាវិញ្ញាណ (Consciousness), ចិត្តក្នុងកត្តាទី២ ហៅថា ចេតសិកឬអនុវិញ្ញាណ (Sub-Consciousness)។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥៤)

មនុស្សទាំងឡាយ ច្រើនតែមានជំនឿថា អ្វីដែលប្រព្រឹត្តទៅក្នុងការដឹងឬវិញ្ញាណ តែងតែប្រកបដោយការរស់រវើកនិងសកម្ម, ឯអ្វីដែលប្រព្រឹត្តទៅក្នុងការភ្លេចឬអនុវិញ្ញាណ គឺតែងប្រកបដោយភាពស្ងាប់ និងវង្វេងឬងោកងុយ។ គំនិតនេះមានការកត្តប្រឡំទាំងស្រុង។ តាមពិត គំនិតដែលឋិតនៅក្នុងអនុវិញ្ញាណ ឬចេតសិក មានលក្ខណៈរស់រវើកនិងសកម្មព្រមទាំងតស៊ូដើម្បីគ្របសង្កត់ទៅលើគំនិតទាំងឡាយនៅក្នុងវិញ្ញាណជានិច្ច, រង់ចាំតែឱកាសនឹងចេញមកបង្ហាញនូវសកម្មភាពផ្សេងៗ។ លោក បឺគេស័ន (Bergson) អ្នកចិត្តវិទូ សម័យថ្មីនិយាយថា "អ្វីដែលយើងមានអារម្មណ៍, រាវរកនិងប៉ងប្រាថ្នា តាំងពីក្មេងមកតែង ឋិតនៅក្នុងបវត្តិកាលជានិច្ច, តែងប្រជែងចូលទ្វារនៃវិញ្ញាណគ្រប់កាលទាំងពួង"។ រឿងនេះ មានលក្ខណៈដូចជាព្រះពុទ្ធសាសនាដែរ។ ព្រះពុទ្ធទ្រង់ត្រាស់ថា បុគ្គលិកលក្ខណៈបច្ចុប្បន្នកាលរបស់យើង គឺជាលទ្ធផលនៃអ្វីទាំងអស់ដែលយើងបានធ្វើ បានមានគិតតាំងពីខាងដើមមក ឬពីអតីតកាល។ ចូរយើងសង្កេតមើល ហេតុដូចម្តេចបានជាបុគ្គលិកលក្ខណៈនៃមនុស្សជាចោរមានការផ្សេងគ្នាពីបុគ្គលិកលក្ខណៈនៃមនុស្សជាអរហន្ត។ ការផ្សេងគ្នានៃបុគ្គលិកលក្ខណៈរបស់មនុស្ស ២ពួកនេះ បណ្តាលមកពីការផ្សេងគ្នានៃគំនិតនិងអំពើដែលគេបានធ្វើមកពីមុន។ ដូច្នេះគេយល់ថា អ្វីដែលជាអតីតៈ គឺមិនមែនជាអតីតៈប្រព្រឹត្តទៅ ឬ កន្លងទៅទទេៗ

*នោះទេ,តាមពិតសភាពទាំងអស់នេះវង់ចាំនិងឋិតនៅជាមួយនឹងបច្ចុប្បន្នយើង នេះតែម្តង, វង់ចាំឱកាសនឹងចូលមកប្រជែងនៅក្នុងចិត្តឬវិញ្ញាណដែលកំពុងប្រព្រឹត្តទៅក្នុង បច្ចុប្បន្ននេះជានិច្ច, សមដូចពុទ្ធភាសិតថា ៖*

*មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា*
*មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា*
*តតោ នំ ទុក្ខមន្វេតិ ចក្កំ វ វហតោ បទំ។*
*មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា*
*មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា*
*តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី តិ* (សូមមើល "ធម្មបទដ្ឋកថា" យមកវគ្គ ទី១-២)

*"ធម៌ទាំងឡាយ មានចិត្តដល់មុន, មានចិត្តប្រសើរបំផុត, កាលបើបុគ្គលមានចិត្តប្រទូស្ត ហើយ ទោះចោលក្តី, ធ្វើក្តី, សេចក្តីទុក្ខតែងប្រព្រឹត្តជាប់ជាមួយបុគ្គលនោះជានិច្ច ដូចជាកង់ឬចក្រ ដែលទៅតាមជានជើងគោជានិច្ចនោះដែរ"។*(ប៉ែន សាអឿន*សាសនាប្រៀបធៀប*,១៩៦៩ ទំ១៥៥)

*"ធម៌ទាំងឡាយ មានចិត្តដល់មុន, មានចិត្តប្រសើរបំផុត, សម្រេចហើយពីចិត្តទាំងអស់, កាលបើបុគ្គលមានចិត្តល្អហើយ ទោះពោលក្តី, ធ្វើក្តី សេចក្តីសុខតែងប្រព្រឹត្តជាប់តាមបុគ្គលនោះជានិច្ច ដូចជាស្រមោលអន្ទោលទៅតាមប្រាណបុគ្គលនោះដែរ"។*

*យ៉ាងណាក៏ដោយ ដែលហៅថា "មនុស្ស" គឺអ្វីដែលគេបានដាក់ពណ៌ចេតសិករបស់ខ្លួន, ទីណាដែលគ្រប់តែចង្វាក់គំនិតបានប៉ះពាល់ដែលមនុស្សបានធ្វើ គឺជាបច្ចុប្បន្នកាលឬប្រវត្តិកាលប្រព្រឹត្តទៅតាមយថាហេតុដែលខ្លួនបានធ្វើ។ នេះគឺអ្វីដែលហៅថាជីវិតនៃមនុស្ស។ យើងគឺអ្វីដែលយើងបានបង្កើតខ្លួនឯងឱ្យកើតឡើងនោះឯង។*

*យើងគឺចិត្តរបស់យើង។ មនុស្សដែលបរិសុទ្ធស្អាត កាលណាចេតសិកឬអនុវិញ្ញាណរបស់គេពេញប្រៀបដោយគំនិតបរិសុទ្ធស្អាត និងអារម្មណ៍បរិសុទ្ធស្អាត, មនុស្សដែលមិនបរិសុទ្ធស្អាត កាលណាចេតសិកឬអនុវិញ្ញាណពេញប្រៀបដោយអកុសល និងសេចក្តីអាក្រក់គ្រប់បែប។ ដូច្នេះចេតសិកឬអនុវិញ្ញាណមានអំពើ ឬប្រព្រឹត្តទៅយ៉ាងខ្លាំងទៅលើវិញ្ញាណឬចិត្ត។ ឧទាហរណ៍មនុស្សជាចោរទោះជាចង់លះបង់ពីការលួច ក៏លះបង់ពុំរួច,ព្រោះចេតសិកនៃអំពើលួចនោះមានឥទ្ធិពលខ្លាំងទៅលើចិត្ត ឬវិញ្ញាណរបស់ខ្លួន។ នេះជាបញ្ហានៃ*

ការអប់រំចិត្ត។ សមាធិ គឺការចម្រើនចិត្តឬវិញ្ញាណឱ្យមានកម្លាំងទៅលើចេតសិក ឬអនុវិញ្ញាណទាំង អស់នោះ។

សមាធិ ដែលអាចប្រព្រឹត្តទៅបាន ដោយអាស្រ័យហេតុជាកត្តា ៣យ៉ាងគឺ ៖

ក-សម្មាវាយាមោ សេចក្ដីព្យាយាមត្រូវ, ខ-សម្មាសតិ ការរឭកត្រូវ, គ-សមាសមាធិ សមាធិត្រូវ។

ក-សម្មាវាយាមោ ៖ សេចក្ដីព្យាយាមត្រូវ បានដល់ការព្យាយាមត្រូវ ៤យ៉ាងគឺ ៖ ១-សេចក្ដីព្យាយាមដើម្បីការពារនូវអកុសលចិត្តទាំងឡាយមិនឱ្យកើតឡើងបាន (សំវរប្បធាន), ២-សេចក្ដីព្យាយាមដើម្បីកម្ចាត់បង់អកុសលចិត្តទាំងឡាយ ដែលកើតឡើងហើយឱ្យវិនាសទៅវិញ(មហានប្បធានៈ), ៣-សេចក្ដីព្យាយាមដើម្បីចម្រើននូវកុសលចិត្តទាំងឡាយដែលមិនទាន់កើតឡើង ឱ្យកើតឡើងបាន (ភាវនប្បធានៈ) និង៤-សេចក្ដីព្យាយាមដើម្បីរក្សានូវកុសលចិត្តទាំងឡាយដែលបានកើតឡើងហើយកុំឱ្យវិនាសទៅវិញ (អនុរក្ខណប្បធានៈ)។

ខ-សម្មាសតិ ៖ ការរឭកត្រូវ។ ពាក្យថា សតិ បានសេចក្ដីថា "ការរឭកឃើញ" ជានិច្ច។ នេះជាផ្នែកនៃការដឹង ឬញាណម្យ៉ាងដែលបង្ហាត់ឱ្យព្រះយោគីចម្រើនទៅក្នុងខ្លួនឯងឱ្យរឭកឃើញជានិច្ចនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ តាមធម្មតា កាលណាយើងឃើញអារម្មណ៍ជាទីរីករាយ ឬឮសំឡេងដ៏ពីរោះ យើងតែងតែមានចិត្តរវើរវាយជានិច្ច។ ទាំងនេះពីព្រោះអារម្មណ៍ដែលប្រមូលផ្ដុំឡើងនៅក្នុងចេតសិកពីយូរមកហើយនោះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើចិត្ត ឬវិញ្ញាណរបស់យើង។ គេអាចប្រៀបធៀបសតិនេះទៅនឹងអ្វីដែលកត់សម្គាល់បានទាំងអស់នូវអ្នកចេញនិងអ្នកចូល។ សតិនេះ ឋិតនៅត្រង់មាត់ទ្វារនៃចិត្ត ហើយដោយភាពប្រុងប្រយ័ត្ន សតិនេះមិនអនុញ្ញាតឱ្យចិត្តដែលមិនប្រកបដោយសោមនស្សចូលមកផ្ដេសផ្ដាសឡើយ។ មហាសតិប្បដ្ឋានសូត្រនៃគម្ពីរ ទីឃនិកាយ បានស្ដីពីសម្មាសតិយ៉ាងពិស្ដារ។ (ប៉ែន សាអឿន សាសនាប្រៀបធៀប, ១៩៦៩ ទំ១៥៥)

នៅក្នុងគ្រប់ប្រព័ន្ធនៃសមាធិ ទាំងបូព៌ាប្រទេស ទាំងបស្ចិមប្រទេស ព្រះយោគីឬអ្នកប្រតិបត្តិ ត្រូវតែហាត់ដកចិត្តរបស់ខ្លួនចេញពីអារម្មណ៍ខាងក្រៅ ហើយដួងចិត្តរបស់ខ្លួនទៅមើលឬរឭកខាងក្នុងទៅវិញ ដែលគេហៅថា កាយានុបស្សនា សតិប្បដ្ឋាន។ តាមពិតពាក្យថា "ខ្លួន" ឬ "មនុស្ស" មានកត្តា ២បែបគឺ ចិត្តនិងរូប ដែលគេហៅថា "បញ្ចក្ខន្ធ" (ខន្ធ ឬ គំនរប្រាំ)។ ឯកាយានុបស្សនាសតិប្បដ្ឋានា គឺត្រូវយកខន្ធទាំងប្រាំនេះជាអារម្មណ៍សម្រាប់ភាវនា។

នៅក្នុងការនាដែលមានបញ្ចក្ខន្ធជាអារម្មណ៍ មានកត្តាសម្រាប់ការនា ៣បែបគឺ ៖ ១-កាយានុប្បស្សនា សតិប្បដ្ឋានា, ២-វេទនានុប្បស្សនា សតិបដ្ឋានា, ៣-ចិត្តានុបស្សនា សតិប្បដ្ឋានា។ លោកត្រូវបន្ថែមកត្តាមួយទៀតសម្រាប់ការនា ដោយលើកយកធម៌ទាំងអស់មកជាអារម្មណ៍ ហៅថា ធម្មានុបស្សនា សតិប្បដ្ឋានា ត្រូវជា ៤ បែប។

១-កាយានុបស្សនា សតិប្បដ្ឋានា ៖ ក្នុងការចម្រើនភាវនានូវកាយានុបស្សនានេះ ព្រះយោគាវចរត្រូវតម្កល់ស្មារតីទៅលើការដកដង្ហើមចេញ-ចូលរបស់ខ្លួន មិនមែនក្នុងលក្ខណៈដកចេញឱ្យផុត ឬដកចូលឱ្យផុតនោះឡើយ។ តាមពិត ព្រះយោគាវចរ ត្រូវកំណត់ដឹងត្រឹមតែការដកដង្ហើមចេញ-ចូល ខ្លីឬវែងប៉ុណ្ណោះ។ ការដកដង្ហើមចូលដល់ណា ត្រូវកំណត់ដឹងត្រឹមនោះ ហើយការដកដង្ហើមចេញអស់ត្រឹមណា ត្រូវកំណត់ដឹងត្រឹមនោះដែរ។ ការធ្វើដូច្នេះទោះញឹកក្តី រង្វើលក្តី ក៏ព្រះយោគាវចរត្រូវកំណត់ដឹងដែរ។ ការភាវនាបែបនេះ កាលណាព្រះយោគាវចរ ប្រព្រឹត្តធ្វើយូរទៅ ជាហេតុឱ្យចិត្តទទួលនូវអារម្មណ៍ស្ងប់ ហើយស្រោលខ្លួនឡើងដូចសំឡី។ ការភាវនានេះលោកហៅថា អនាបានុស្សតិកម្មដ្ឋានសម្រាប់អ្នកដែលប្រកបដោយនីវរណធម៌រារាំងចិត្តច្រើននិងសម្រាប់អ្នកដែលមានស្មារតីទន់ខ្សោយឆាប់ភ្លេច។ សូម្បីអ្នកដែលមិនប្រព្រឹត្តតាមសាសនាណាមួយក៏អាចធ្វើឬចម្រើននូវសមាធិនេះបានដែរសម្រាប់ធ្វើឱ្យស្មារតីខ្លាំងក្លាឡើងវិញ។

មានអារម្មណ៍មួយទៀត សម្រាប់ការនានូវការយានុបស្សនាសតិប្បដ្ឋានាគឺការកម្រើកកាយរបស់ខ្លួន។ ការភាវនានេះគឺព្រះយោគាវចរត្រូវចម្រើនសតិ កំណត់សម្គាល់នូវការកម្រើកកាយត្រង់ណាមួយក៏ត្រូវឱ្យដឹងទាំងអស់។ ម្យ៉ាងទៀត ព្រះយោគាវចរដើរក៏ត្រូវកំណត់ដឹង, ឈរក៏ត្រូវកំណត់ដឹង, អង្គុយក៏ត្រូវកំណត់ដឹង, ដេកក៏ត្រូវកំណត់ដឹង, បរិភោគក៏ត្រូវកំណត់ដឹង ឬធ្វើអ្វីមួយក៏ត្រូវកំណត់ដឹងទាំងអស់ជាដើម។

ការរីកចម្រើនទាំងអស់នេះ មានគោលបំណងតែមួយគឺធ្វើឱ្យស្មារតីគ្រប់គ្រាន់ឡើង។

២-វេទនានុប្បស្សនាសតិប្បដ្ឋាន បានដល់អារម្មណ៍ប្រកបដោយសោមនស្ស និងអព្យាក្រឹត។ ព្រះយោគាវចរចម្រើនសតិសម្រាប់កំណត់ឱ្យដឹងនូវការកើតឡើង និងវិនាសទៅវិញនៃអារម្មណ៍ទាំងឡាយនោះ ទោះជាពេលប្រកបដោយសោមនស្សក្តី ទោមនស្សក្តី ឬអព្យាក្រឹតក្តី។ ការធ្វើដូច្នេះ ប្រយោជន៍ឱ្យអារម្មណ៍របស់អ្នកប្រតិបត្តិមានការស្ងប់រម្ងាប់ជាដើម។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥៧)

៣-ចិត្តានុប្បទាសតិប្បដ្ឋានា ៖ នីវរណធម៌ទាំង ៥គឺ ៖ កាមឆន្ទៈ, ព្យាបាទ, ថីនមិទ្ធៈ, កុក្កុច្ចៈ, វិចិកិច្ឆា,តែងកើតឡើងនៅក្នុងចិត្ត ហើយធ្វើឱ្យយើងមានការភ្លាំងភ្លេចជានិច្ច។ នីវរណធម៌ទាំងអស់នេះ តែងរាំងនូវការភាវនាឬការចម្រើននៃយើង, ដូច្នេះ ព្រះយោគាវចរត្រូវតែចម្រើនសម្មាសតិឱ្យខ្លាំងក្លាឡើង ដើម្បីទប់ទល់នូវការរាំងទាំងអស់នេះ។ ព្រះយោគាវចរត្រូវចម្រើនសតិនេះឱ្យទាល់តែក្លាយខ្លួនជាអ្នកជំនាញ ដូចជានាយសារថីដែលអាចបររថទៅមុខដោយពុំខ្លាចមានគ្រោះថ្នាក់ដោយសារសត្វពាហនៈមានសេះជាដើម ដែលវាអាចនាំទៅកាន់ផ្លូវខុស ឬនាំចូលព្រៃ។ កាលបើព្រះយោគាវចរបានចម្រើនសតិនេះពេញលេញ។

៤-ធម្មានុបស្សនាសតិប្បដ្ឋានា ៖ ការតាំងចិត្តចម្រើនសតិដែលមានធម៌ជាអារម្មណ៍ ធម្មារម្មណ៍នោះ បានដល់អរិយសច្ចៈទាំង ៤, អាយតនៈ៦, ខន្ធ៤, ជាពិសេសធម៌ទាំងឡាយស្តីពីសភាពមនុស្សនិងពីលោកជាតុ។ ការភាវនានេះជាប្រយោជន៍ការ ពារកុំឱ្យមិច្ឆាទិដ្ឋិចូលមកដឹកនាំចិត្តព្រះយោគាវចរឱ្យឃ្លាតចាកផ្លូវត្រូវ។

គ-សម្មាសមាធិ ៖ ការតាំងចិត្តឬសមាធិត្រូវ។ មុននឹងផ្តើមធ្វើសមាធិ, អ្នកប្រតិបត្តិឬព្រះយោគាវចរត្រូវយល់ឱ្យច្បាស់នូវព្រះត្រៃលក្ខណ៍ គឺអ្វីទាំងអស់ដែលកើត ឡើងដោយការផ្សំជាតុ មានលក្ខណៈប្រែប្រួលមិនទៀងទាត់ហៅថា អនិច្ចលក្ខណៈ, អ្វីទាំងអស់គឺជាទុក្ខហៅថាទុក្ខលក្ខណៈ និងអ្វីទាំងអស់មិនមានខ្លួនប្រាណ ហៅថា អនត្តលក្ខណៈ។ ម្យ៉ាងទៀតព្រះយោគាវចរ ត្រូវយល់ឱ្យច្បាស់ថា តណ្ហា (សេចក្តីប្រាថ្នា ឬការជាប់អារម្មណ៍) គឺជាឫសគល់នៃអំពើអាក្រក់ និងអាក្រក់គ្រប់យ៉ាងទាំងអស់។ ព្រោះតែតណ្ហានេះហើយទើបមនុស្សមានកម្ម, ប្រមូលកម្ម ហើយកើតទៀត នៅក្នុងវដ្តសង្សារមិនចេះឈប់ឈរសោះឡើយ។ តើគេត្រូវកម្ចាត់បង់តណ្ហាដោយអាស្រ័យការត្រាស់ដឹងនូវត្រៃលក្ខណ៍ដែលជាសភាពពិតនៃកំណើតទូទៅ។ ការត្រាស់ដឹងនូវព្រះត្រៃលក្ខណ៍ អាស្រ័យដោយការធ្វើសមាធិតែម្យ៉ាង។ ការធ្វើសមាធិ ជាហេតុនាំឱ្យកើតប្រាជ្ញា។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥៨)

យើងសូមបញ្ជាក់ថា សីលធម៌ និងសាសនពិធី (សូមមើល "វិសុទ្ធិមគ្គ" បាលី, ជាពិសេសសូមមើល"សីលនិទ្ទេស" រៀបរៀងដោយលោក អ៊ុច-រស់, "សមាធិនិទ្ទេស" ដោយលោក អ៊ុច-រស់ ដែរ និង "បញ្ញានិទ្ទេស" ដោយលោក ឈឹម-ទូច។ វិសុទ្ធិមគ្គ គឺជាអដ្ឋកថានៃព្រះត្រៃបិដក។) នៅក្នុងព្រះពុទ្ធសាសនា មានលក្ខណៈអប់រំមនុស្សឱ្យចេញចាកលោកនេះទៅកាន់លោកដែលជាអមតៈ។ ម្យ៉ាងទៀតសីលធម៌ត្រូវមានការបរិច្ចាគៈ គឺការធ្វើទានដែល

ជាមធ្យោបាយលះសុខខ្លួនដើម្បី អ្នកដទៃជាមូលដ្ឋានបន្ទាប់បន្សំ។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៥៨-១៥៩)




**៥-លទ្ធិសាកលនិយមចិន**

កាលណាគេពោលពីសីលធម៌នៃចិន គេត្រូវពោលតែពីសីលធម៌របស់និកាយខុង ជឺ តែម្យ៉ាង ព្រោះចិនឥតមាននិកាយសីលធម៌ដទៃទៀតឡើយ។ ច្បាប់, បញ្ញត្តិ និងបទបញ្ជា ព្រមទាំងគោលការណ៍សំខាន់ៗជាច្រើន ឋិតនៅតែក្នុងអក្សរសាស្ត្របុរាណ ដែលជាប្រធានារម្មណ៍ដ៏សំខាន់សម្រាប់អ្នកសិក្សានៃពួកអ្នកប្រាជ្ញទាំងអស់ពាសពេញប្រទេសចិនទាំងមូល។ ក្បួនទាំងអស់នេះ មិនមែនទទួលស្គាល់ដោយពួកអ្នកប្រាជ្ញសម្រាប់សិក្សាប៉ុណ្ណោះឡើយ សូម្បីអ្នកល្ងង់ក៏ទទួលដែរ ហើយក្បួនច្បាប់ទាំងឡាយនោះ ជួយដល់ការស្ថាបនាជីវិតសង្គម, មានពណ៌ដ៏ល្អស្អាត ព្រមទាំងមានឥទ្ធិពលទៅលើការបង្កើតច្បាប់និងការគ្រប់គ្រងប្រទេសថែមទៀត។ តាមបែបលទ្ធិសាសនាវិញ, ព្រះពុទ្ធសាសនានៅប្រទេសចិននិងលទ្ធិតៅ ឋិតនៅជិតខាងជាមួយនឹងលទ្ធិខុងជឺទៅវិញ ព្រោះលទ្ធិនិងសាសនាទាំងពីរនេះ មានលក្ខណៈបញ្ជាក់ពីជីវិត បន្ទាប់ពីសេចក្ដីស្លាប់យ៉ាងច្បាស់លាស់ ហើយមានភាពប្រក្រតីសម្រាប់ទឹកចិត្តមនុស្សជាតិ។ ប៉ុន្តែសម្រាប់កិច្ចការ ឬសម្ព័ន្ធភាពនៃមនុស្សជាតិនៅពេលបច្ចុប្បន្ន, គេត្រូវតែប្រព្រឹត្តតាមប្រព័ន្ធសីលធម៌របស់លទ្ធិខុង ជឺ ទាំងអស់។

ទោះណាជាលោកខុង ជឺ មានឈ្មោះជាប់នឹងនិកាយនោះ ប៉ុន្តែតាមពិត លោកពុំមានប្រវត្តិថាបានបង្កើតនិកាយនោះឡើយ។ លោកបានប្រកាសថា ខ្លួនលោកគ្រាន់តែជាអ្នកផ្សាយមិនមែនជាអ្នកធ្វើទេ ជាអ្នកជឿនិងចូលចិត្តបែបបុរាណប៉ុណ្ណោះ (សូមមើល “Confucian Analects”, VII I.)។ ដោយមានលក្ខណៈមិនប្រកបដោយប្រលោមលោក, លោកពុំមានទៀយព្រួយលំបាកក្នុងការពណ៌នានូវលក្ខណៈទូទៅនៃសីលធម៌ ព្រមទាំងពុំខ្វាចវែក

ញែកនូវសេចក្ដីផ្សេងគ្នារវាងសេចក្ដីអាក្រក់និងល្អ, ការខុសនិងការត្រូវសម្រាប់ជីវិតបច្ចុប្បន្ន សោះឡើយ។ ប៉ុន្តែលោកខុង ជឺ ពុំមានប្រុងប្រយ័ត្នសូម្បីតិចតួចសោះឡើយ ចំពោះការបង្កើត ទ្រឹស្ដីលើធម្មតានៃចិត្តរបស់មនុស្ស ព្រោះតាមពិតលោកបានពិចារណាចំពោះតែសីលធម៌ ដែលជាមធ្យោបាយសម្រាប់ដោះស្រាយដូចម្ដេចហៅថាសេចក្ដីល្អ និងដូចម្ដេចហៅថាសេចក្ដីអាក្រក់ប៉ុណ្ណោះ។ ចំពោះសីលធម៌ទាំងអស់នេះ មានអ្នកខ្លះមានជោគជ័យ អ្នកខ្លះទៀតពុំមានជោគជ័យទាល់តែសោះ។

ចំណែកសៀវភៅឈ្មោះ THE DOCTRINE OF THE MEAN យើងឃើញថាគំនិតខាងលើនេះ អ្នកនិពន្ធបានបញ្ជាក់យ៉ាងច្បាស់លាស់ ហើយតាមប្រកពទូទៅគេជឿថា សៀវភៅនេះសរសេរឡើង ដោយចៅរបស់លោកខុងជឺ ដែលមានយោងពាក្យរបស់លោកខុងជឺយ៉ាងច្រើនជាទីបំផុតនៅក្នុងសៀវភៅនោះផង។ សៀវភៅនេះបានបញ្ជាក់តទៅទៀតថា មនុស្សម្នាក់ៗទទួលភាពប្រក្រតីរបស់ខ្លួនពីស្ថានសួគ៌ ហើយកាលណាមនុស្សនោះប្រកបអំពើផ្សេងៗ គឺគេប្រកបទៅតាមភាពប្រក្រតីរបស់ខ្លួន ដែលជាផ្លូវដ៏ត្រឹមត្រូវសម្រាប់ប្រតិបត្តិ។ កាលពីដើម លោកខុង ជឺ ពុំដែលបានពោលឱ្យជាក់ ច្បាស់ឡើយ, ប៉ុន្តែឧត្តមគតិនេះបានឋិតនៅក្នុងសន្ដានចិត្តនៃសិស្ស សាវ័ករបស់លោកអស់ពេលជាច្រើនសតវត្សថា សភាពឬភាពប្រក្រតីនៃមនុស្សទាំងឡាយតាមកំណើតរបស់ខ្លួន សុទ្ធតែមានបែបល្អត្រឹមត្រូវទាំងអស់។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៦៦)

ទ្រឹស្ដីពីសភាពមនុស្សក្នុងលក្ខណៈល្អគ្រប់បែប ត្រូវបានលោកម៉េង ជឺ ដែលជាអ្នកប្រាជ្ញដ៏សំខាន់ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយហើយជាសិស្សនៃលោកខុងជឺធ្វើអត្ថាធិប្បាយយ៉ាងច្បាស់លាស់ថែមទៀត។ នៅសម័យលោកម៉េង ជឺ, មានអ្នកប្រាជ្ញម្នាក់ឈ្មោះ កៅ (KAO)ជាអ្នកទស្សនវិទូមួយរូបបានបកស្រាយថា សភាពឬភាពប្រក្រតីនៃមនុស្សមានលក្ខណៈ មិនអាក្រក់ណាមួយបាន ដូចជាទឹក បើទោះជាមានគេភាំងយ៉ាងណាក៏ដោយ ក៏ទឹកដែលហូរទៅទិសណានៅតែប្រព្រឹត្តទៅទិសនោះៗដដែលឥតប្រែប្រួលឡើយ។ ក្នុងអត្ថាធិប្បាយនេះ លោកម៉េង ជឺ ប្រឆាំងថា “ទេ, ទោះណាជាទឹកមានលក្ខណៈមិនអើពើ ឬអព្យាក្រឹត ប៉ុន្តែនិន្នាការរបស់វាគឺវាហូរទៅទីទាបជានិច្ច, ហើយដែលវាអាចហូរទៅលើបានក៏ដោយអាស្រ័យមានសម្ភារៈឬកម្លាំងជាគ្រឿងទប់ប៉ុណ្ណោះយ៉ាងណាមិញ, ឯសភាពមនុស្សមាននិន្នាការទៅរកសេចក្ដីល្អជានិច្ច, ឯសេចក្ដីអាក្រក់មិនមែនជាសភាពប្រក្រតីរបស់មនុស្ស

សោះឡើយ”។ មានទ្រឹស្តីដទៃទៀតថា មនុស្សខ្លះមានសភាពឬភាពប្រក្រតីល្អជានិច្ច, ហើយខ្លះទៀតអាក្រក់ពីកំណើតតែម្តង។ លោកម៉េងជឺបានបដិសេធថាមិនពិតទាំងអស់ទៀត ចំពោះទ្រឹស្តីនោះ។

នៅសម័យខាងក្រោយនៃលោកម៉េងជឺ, មានអ្នកទស្សនវិទូដ៏សំខាន់ម្នាក់ទៀតឈ្មោះ ស៊ុន-ជីង Hsun-Ching” បានបង្កើតទ្រឹស្តីប្រឆាំងនឹងលោកម៉េង ជឺ ថា “សភាពឬភាពប្រក្រតីនៃមនុស្សគឺការអាក្រក់, ដែលមនុស្សអាចទៅជាល្អបាន ក៏ដោយអាស្រ័យតែពាក្យថាប្រៀនប្រដៅនិងច្បាប់តែម្យ៉ាង។ ភ្នែកអាចមើលឃើញរូប ត្រចៀកអាចឮសំឡេងតាមធម្មតារបស់វា, វាមិនត្រូវការជំបូន្មានអ្វីឡើយ, ប៉ុន្តែសម្រាប់មនុស្សវិញ មានលក្ខណៈផ្សេង គឺដែលគេក្លាយទៅជាមនុស្សល្អទៅបាន ដោយអាស្រ័យការរេះដឹងនិងសេចក្តីព្យាយាមយ៉ាងខ្លាំងក្លាតែម្យ៉ាង”។

ដទៃពីនេះ មានក្បួនមួយទៀតឈ្មោះថា “មហាវិជ្ជា The Great Learning” បានបញ្ជាក់ពីរបៀបប្រតិបត្តិសីលធម៌និងរបៀបគ្រប់គ្រង។ សៀវភៅនេះមានរបៀបសិក្សាបែបខ្លីហើយមានពុទ្ធិយ៉ាងសំខាន់បិតនៅក្នុងប្រព័ន្ធនីមួយៗ ដែលជាទីចាប់ចិត្តនៃរាស្ត្រចិនទាំងអស់, ជាសៀវភៅដែលគេទុកជាក្បួនប្រសើរបំផុតក្នុងអក្សរសាស្ត្រចិនបូរាណ។ ឧត្តមគតិទាំងអស់នៅក្នុងក្បួននេះ មានលក្ខណៈដូចគ្នានឹងឧត្តមគតិរបស់លោកខុងជឺទាំងស្រុង ហើយគេជឿថាសរសេរនេះ គេបានសរសេរឡើងនៅខាងក្រោយសម័យលោកខុងជឺមិនជាឆ្ងាយប៉ុន្មាន។ សៀវភៅនេះ ពិតមែនតែមិនសរសេរឡើងដោយលោកខុងជឺ, ប៉ុន្តែមានឥទ្ធិពលយ៉ាងសំខាន់ពីឧត្តមគតិនៃលោកខុងជឺយ៉ាងសម្បើម។ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៦៧)

សីលធម៌នៃលោកខុងជឺ គេចែកជា ៥ផ្នែកគឺ ៖ ១-យេន (Jén) = បរិច្ចាគៈ (Charity), ២-ឮ (I) ភាពប្រកបដោយធម៌ (Righteousness), ៣-លី (Li) ភាពបរិសុទ្ធ (Propriety), ៤-ជីហ៍ (Chih) វិជ្ជាឬបញ្ញា (Knowledge or Wisdom) និង ៥-ហ្សិន (Hsin) សេចក្តីស្ម័គ្រ (Sincerity)។

១-យេន (Jén) (បរិច្ចាគៈ) សម្រាប់ឱ្យមានសម្ព័ន្ធភាពឬការទាក់ទងគ្នារបស់មនុស្សទៅនឹងមនុស្សដូចគ្នា។ បរិច្ចាគ (ការលះបង់ឬការឱ្យ) ត្រូវមានការអនុគ្រោះ (Benevolence) និងមនុស្សធម៌ (Humanity) ថែមទៀត។ លោកខុងជឺបានអធិប្បាយរឿងនេះ សម្រួលទៅតាមស្ថានហេតុនិងពេលវេលា ព្រមទាំងកន្លែង, ជាពិសេសទៅតាមលក្ខណៈសំណួរ ដែលគេសួរ

។ ក្នុងសន្ទេបន័យនិងលក្ខណៈសាកលនៃមូលភេទនេះ គេសំដៅយក "ការស្រឡាញ់មនុស្សទាំងអស់"។ ក្នុងន័យពិស្ដារ គេរួបរួមការគោរព, ភាពរីករាយ, ភាពស្មូតត្រង់, ភាពមិនធ្វេសប្រហែសនិងករុណានៅក្នុងការបរិច្ចាគៈថែមទៀត។ ជាលក្ខណៈទូទៅ សីលធម៌ក្នុងក្រុមនេះ គឺបានដល់ "ចូរកុំធ្វើដល់អ្នកដទៃ នូវអ្វីដែលអ្នកមិនប្រាថ្នានឹងធ្វើដល់ខ្លួនអ្នក"។ លោកខុងជឺ បានពោលដដែលៗចំពោះពាក្យខាងលើនេះ, ហើយលោកបញ្ជាក់ថាពាក្យ ខាងលើនេះ គេអាចចាត់ទុកជាមគ្គុទេសក៍សម្រាប់ជីវិតរបស់ខ្លួនម្នាក់ៗតែម្ដង។ បរិច្ចាគៈ គឺគេត្រូវធ្វើឡើងទៅលើមូលដ្ឋាន" មេត្តាទៅលើញាតិសន្ដានរបស់ខ្លួន ព្រមទាំងការបង្អោនក្នុង ភាតរភាព" ហើយកាលបើអ្នកគ្រប់គ្រងទាំងឡាយបានប្រព្រឹត្តចរិយារបស់ខ្លួន ដ៏សមរម្យទៅលើញាតិសន្ដានរបស់ខ្លួន ជាហេតុនាំឱ្យប្រជារាស្ត្រមានបរិច្ចាគៈយ៉ាងខ្លាំងក្លាឡើង។

២-ឮ (I) ភាពប្រកបដោយធម៌ ត្រូវរួមទាំងយុត្តិធម៌និងកាតព្វកិច្ចផង។ សីលធម៌នៅក្នុងក្រុមនេះ លោកទុកជាលក្ខណៈសម្រាប់ជីវិតនៃប្រជារាស្ត្រទូទៅ។ បើអ្នកណាមួយបដិសេធមិនបម្រើប្រទេសរបស់ខ្លួន អ្នកនោះឈ្មោះថា មិនប្រព្រឹត្តតាមកាតព្វកិច្ចរបស់ ខ្លួនដោយពិត។ ព្រះអង្គម្ចាស់ត្រូវតែមានយុត្តិធម៌ក្នុងការផ្ដកភារៈដ៏ធ្ងន់ទៅលើប្រជារាស្ត្រ របស់ព្រះអង្គ, កាលបើទ្រង់ប្រព្រឹត្តធ្វើដូច្នោះហើយ, ប្រជារាស្ត្រនឹងប្រាកដជាគោរពបទបញ្ជា ឬច្បាប់របស់ព្រះអង្គដោយសុទ្ធចិត្តពុំខាន។

កាលណារាជធម៌ ឬភាពប្រកបដោយធម៌ពុំមានហើយ, ឧទ្ទាមក្នុងចំណោមពួកមនុស្ស (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៦៩)មានឋានៈខ្ពស់ មុខជានឹងកើតមានឡើង, ហើយចោរកម្មផ្សេងៗ មុខជាបណ្ដាលឡើងក្នុងចំណោមពពួកមនុស្សដែលមានឋានៈទាបពុំខានឡើយ។ កាលបើប្រាសចាកភាពប្រកបដោយធម៌ហើយ សម្បត្តិនិងកិត្តិយសទាំងឡាយ មុខជាដូចពពករសាត់លើអាកាស។

៣-លី (LI) ភាពបរិសុទ្ធ ត្រូវរួមជាមួយឧត្តមគតិនៃបូជាវិធីផង ហើយអាចប្រព្រឹត្តទៅបាន។ ម្យ៉ាងទៀត សីលធម៌បែបនេះនឹងក្លាយជាឥតតម្លៃ កាលណាពុំមានបរិច្ចាគៈ ហើយទាំងអស់នេះ ត្រូវប្រព្រឹត្តទៅជាមួយនឹងការគោរពថែមទៀត។ កាលបើពុំមានធម៌ទាំងអស់នេះប្រព្រឹត្តទៅជាមួយទេ ហាក់ដូចជារាជរថអលង្ការសម្រាប់តុបតែងឱ្យល្អ។ ម្យ៉ាងទៀត កាលបើពុំមានបរិច្ចាគៈ និងធម្មបរិវារដទៃទៀតទេ ភាពគោរពកោតខ្លាចនឹងក្លាយជាភាពឥតលំអ, ភាពប្រុងប្រយ័ត្ន ជាភាពឥតក្លាហាន, ភាពក្លាហាន ជាភាពរញ៉េរ ហើយភាពស្មូតត្រង់

នឹងក្លាយជាភាពរឹងរូសមិនខាន។ ប្រាសចាកវិជ្ជាស្តីពីសេចក្តីបរិសុទ្ធ, គេមិនអាចអប់រំ កិរិយាមារយាទបានជាដាច់ខាត។ វិជ្ជាស្តីពីសេចក្តីបរិសុទ្ធត្រូវតែមានសម្ពន្ធ ភាពជាមួយ ការសិក្សាទើបជៀសវាងកំហុសឬការភ័ន្តច្រឡំបាន។

៤-ជីហ៏ (Chih) វិជ្ជា ឬប្រាជ្ញា។ ចំណេះវិជ្ជាដ៏សំខាន់បំផុត គឺសំដៅយកវិជ្ជាស្តីពីមនុស្សលោក។ ទី១-មនុស្សម្នាក់ៗត្រូវតែដឹងនូវអ្វីដែលស្ថានសួគ៌បានបញ្ជា, គឺអ្វីដែលហៅថាអាក្រក់ និងអ្វីដែលហៅថាល្អ ឬអ្វីដែលខុសនិងអ្វីដែលត្រូវ។ ទី២-ម្នាក់ៗត្រូវតែដឹងនូវច្បាប់ទាំងឡាយស្តីពីសេចក្តីបរិសុទ្ធ។ ទី៣-ម្នាក់ៗត្រូវតែចេះភាសាសម្រាប់ឱ្យដឹងនូវចរិយា-មារយាទនៃអ្នកដែលនិយាយទៅរកគេ។ វិជ្ជាដ៏ពិតប្រាកដបានដល់អ្នកដែលដឹងនូវរឿង ព្រមទាំង ស្គាល់ច្បាស់នូវរឿងដែលខ្លួនដឹងបានដល់អ្នកដែលមិនដឹងរឿង ព្រមទាំងមិនស្គាល់ច្បាស់នូវ រឿងដែលខ្លួនមិនដឹង (ដឹងនូវរបស់ដែលគួរដឹង និងមិនដឹងនូវរបស់ដែលមិនគួរដឹង)។ សេចក្តី ព្យាយាមទាំងឡាយ ដើម្បីបាននូវសីលធម៌និងត្រូវវិនាសទៅវិញ បើប្រសិនជាចំណេះវិជ្ជា មិនប្រព្រឹត្តទៅជាមួយនឹងការសិក្សា។ ដូច្នេះ ម្នាក់ៗត្រូវសិក្សាដើម្បីជាប្រយោជន៍ដល់ អភិវឌ្ឍន៍របស់ខ្លួន, មិនមែនដើម្បីបានឈ្នះនូវការអនុម័តប៉ុណ្ណោះទេ។ រៀនប្រាសចាកគំនិត គឺចំណាយកម្លាំងឥតប្រយោជន៍, ហើយគំនិតប្រាសចាកការសិក្សា គឺមានគ្រោះថ្នាក់ជានិច្ច។ លោកខុងជឺ បានពោលថា "ខ្ញុំរវល់តែគិតមួយថ្ងៃវាល់ល្ងាចប្រាសចាកបាយទឹក ហើយមួយ យប់ទល់ភ្លឺប្រាសចាកដំណេក ប៉ុន្តែឥតប្រយោជន៍សោះ ព្រោះគ្មានផែនការសម្រាប់សិក្សា។ ជាទីបំផុត សច្ចធម្មវិជ្ជា មិនស្មើសេចក្តីស្រឡាញ់វិជ្ជាឡើយ។ អ្នកចេះអក្សរ ក្លាយជាឥត ប្រយោជន៍ បើសិនជាគេខ្វះការវៃឆ្លាត។

៥-ហ្ស៊ិន (Hsin) សេចក្តីស្មោះត្រង់ រួមទាំងសច្ចធម៌ និងជំនឿថែមទៀត។ សេចក្តីសំខាន់និងការចាំបាច់នៃសីលធម៌បែបនេះ គឺគេត្រូវសិក្សាដោយប្រពៃក្នុងបែបផ្សេងៗជាច្រើន។ ភក្តីភាពនិងការស្មោះត្រង់ គេត្រូវទុកជាគោលការណ៍ទី១ ហើយប្រាសចាកសច្ចធម៌ គ្មានមនុស្សណាអាចប្រព្រឹត្តទៅក្នុងមាគ៌ាជីវិតដ៏ល្អបានឡើយ។ ចំពោះការទាក់ទងជាមួយមិត្តភ័ក្តិម្នាក់ៗត្រូវទុកការស្មោះត្រង់ខ្ពង់ខ្ពស់បំផុត។ ជាការអាក្រក់បំផុតចំពោះអ្នកដែលធ្វើពុតជាមិត្តភ័ក្តិដ៏ស្និតស្នាលជាមួយអ្នកដែលខ្លួនមិនចូលចិត្ត។ សេចក្តីស្មោះត្រង់គឺជាសម្បត្តិទី១ នៃអ្នកគ្រប់គ្រងគេ។(ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៦៩)

ដូចជាយើងបានឃើញខាងលើនេះហើយថា លោកខុងជឺបានកើតឡើងនិងបំពេញសកម្មភាពនៅសតវត្សទី៦មុនគ.ស. ហើយលោកបានសិក្សាយ៉ាងជាក់ច្បាស់នូវក្បួនបុរាណស្ដីពីសីលធម៌ដែលគេទុកជាមូលដ្ឋាននៃសីលធម៌ដ៏សំខាន់បំផុតនៃសង្គម។ មានហេតុការណ៍ដ៏សំខាន់មួយទៀត នៅក្នុងទ្រឹស្ដីសីលធម៌នៃលោកខុង ជឺ គឺឈ្នះការសងសឹកដោយការមិនសងសឹក ឬដោយមេត្តាឬសេចក្ដីល្អ។ មេត្តាដោយមេត្តា, សេចក្ដីល្អដោយសេចក្ដីល្អ, សងឈាម ដោយយុត្តិធម៌។ ម្យ៉ាងទៀតសេចក្ដីសន្ដោសប្រោសប្រណីចំពោះញាតិ សន្ដាន ខ្លួន គឺជាលក្ខណៈសំខាន់មួយទៀតនៃសីលធម៌របស់ប្រជារាស្ត្រចិន ជាគំនិតលោកខុង ជឺ ដែរ,ជាពិសេសការប្រគល់សេចក្ដីស្មោះត្រង់ចំពោះបងប្អូន ក៏ជាលក្ខណៈសំខាន់នៃសីលធម៌មួយទៀតរបស់លោកខុង ជឺ។

ជាសេចក្ដីផ្សេងពីសីលធម៌ខាងលើនេះ យើងឃើញថា ការគោរពបូជាបុព្វបុរសក៏ជាបូជាវិធីដ៏សំខាន់ដែលលោកខុងជឺហ្នឹងឯងបានប្រព្រឹត្តធ្វើក្នុងជីវិតរបស់លោក។ ដូច្នេះ រឿងនេះក្លាយទៅជាស្ថាប័នដ៏សំខាន់នៃសង្គមចិនទាំងមូល (សូមមើល "Ethics and Morality", Encyclopaedia of Religion and Ethics, Edited by Janes Hastings, vol.5, p.466-468.)។

## ៥-គោលការណ៍ប្រៀបធៀបនៃមហាលទ្ធិនិងសាសនាទាំង៥តាមគោលគំនិតទាំង៤

ក្នុងការសិក្សាសាសនាប្រៀបធៀប អ្នកសិក្សាគួរពិនិត្យនិងវិភាគលទ្ធិនិងសាសនានីមួយៗ តាមមូលវិជ្ជារបស់ខ្លួន ហើយប្រៀបធៀបតាមលក្ខណៈនៃគោលគំនិតដូចតទៅនេះ ៖

១-ទេវកថា (Myths) គេសំដៅយកគោលគំនិតដែលទាក់ទងជាមួយនឹងរឿងព្រេងប្រកបដោយអច្ឆរិយហេតុ ដូចជាព្រះឥន្ទច្បាំងជាមួយពួកអសុរជាដើម ឬដូចជាការអស្ចារ្យនៃកំណើតរបស់ព្រះយេស៊ូគ្រិស្ដក្នុងផ្ទៃនៃព្រះនាងម៉ារីជាស្រីក្រមុំព្រហ្មចារីយ៍ជាដើម, ឬដូចជាព្រះព្រហ្ម, អាទិទេព, ព្រះអាឡាហ៍, ព្រះគ្រិស្ដ, ឋានសួគ៌ ជាដើម។ ទាំងអស់នេះ គេហៅថាទេវកថា។

២-អភិរូបនិយម (Metaphysics) គេសំដៅយកគោលគំនិតប្រកបដោយការពិតឥតប្រែប្រួល គឺភាពនិយមទៅតាមប្រក្រតីនៃវត្ថុដែលវិជ្ជមាននិងអវិជ្ជមាន, ដូចឧទាហរណ៍ថា តើលោកនេះមានអ្វីជាអ្នកបង្កើត ? ឆ្លើយថា ព្រះអាទិទេពជាអ្នកបង្កើតជាដើម។ គោលគំនិតនេះបានស្មានថា នៅក្នុងអង្គរបស់ព្រះអាទិទេពមានធាតុសម្រាប់បង្កើត, គឺអ្វីៗទាំងអស់នៅក្នុងលោកនេះ មានអំណាចជាអរូបីយ៍ជាអ្នកបង្កើតជាដើម។ (ប៉ែន សារឿន *សាសនាប្រៀបធៀប*,

១៩៦៩ ទំ១៧០)ទាំងអស់នេះ គេហៅថា អស្តិរូបនិយម ជាគោលគំនិតកើតឡើងដូចជាអាជ្ញា កណ្តាលរវាងទេវកថានិងបដិសំយោគនិយម។ ប៉ុន្តែក្នុងន័យនេះ លោក អូគ្គីស្ត កុន្ត (Auguste Comte) ថាអស្តិរូបនិយម ជាគំនិតអាជ្ញាកណ្តាលរវាងទេវកថានិងវិទ្យាសាស្ត្រ។

៣-បដិសំយោគនិយម (Dialectics) គេសំដៅយកគោលគំនិតដែលរាវរកឯកភាពនៃសវិញ្ញាណកវត្ថុនិងអវិញ្ញាណកវត្ថុទាំងអស់ក្នុងលោក។ គោលគំនិតនេះ បានកើតឡើងនៅក្នុងប្រទេសអាល្លឺម៉ាញក្នុងសតវត្សទី១៥។ តាមពិតគោលគំនិតនេះ មានខ្សែស្រឡាយពីព្រះពុទ្ធសាសនាសុទ្ធសាធ។

៤-យន្តសាស្ត្រ (Dynamics) គោលគំនិតនេះសំដៅយកវិទ្យាសាស្ត្រ ដែលផ្អែកទៅលើការពិសោធន៍ត្រូវមានធាតុដែលប្រកបដោយភាពប្រែប្រួលជាមូលដ្ឋាន។

ដើម្បីប្រៀបធៀបលទ្ធិនិងសាសនាទាំង៥ តាមគោលគំនិតទាំង៤នេះ អ្នកសិក្សាត្រូវពិនិត្យធម្មជាតុនៃលទ្ធិនិងសាសនាទាំងអស់ ដូចជាបញ្ហាលោកធាតុ, បញ្ហាសភាពមនុស្សនិងវាសនាបន្ទាប់ពីសេចក្តីស្លាប់ សីលធម៌និងសាសនពិធីជាដើម, រួចហើយបញ្ចូលធម្មជាតុទាំងអស់នោះទៅតាមក្រុមគោលគំនិតនីមួយៗ។ សូមបញ្ជាក់ថា គោលគំនិតទាំង៤នេះ មានវិវឌ្ឍនាការបន្ទាប់បន្សគ្នានៅក្នុងសង្គមមនុស្សលោកយើងនេះ។ ដូច្នេះ យើងអាចគំរៀបតាមតារាងដូចតទៅនេះ ៖ (ប៉ែន សាអឿន *សាសនាប្រៀបធៀប*, ១៩៦៩ ទំ១៧១)

**គោលគំនិតទាំង៤**

| ឈ្មោះសាសនា | ទេវកថា | អស្តិរូប | បដិសំយោគ | យន្តសាស្ត្រ |
|---|---|---|---|---|
| ១-ព្រះពុទ្ធសាសនា | ០ | ០ | ព្រះពុទ្ធសាសនា | ផ្នែកខ្លះនៃព្រះពុទ្ធសាសនា៖វិទ្យាសាស្ត្រធម្មជាតិនិងរូបសាស្ត្រ |
| ២-ហិណ្ឌូ | ហិណ្ឌូ | ហិណ្ឌូ | ០ | ០ |
| ៣-គ្រិស្ត | គ្រិស្ត | គ្រិស្ត | ០ | ០ |
| ៤-អ៊ិស្លាម | អ៊ិស្លាម | អ៊ិស្លាម | ០ | ០ |

| | | | | |
|---|---|---|---|---|
| ៥-សាកលនិយមចិន | តៅនៃឡាវសេ | តៅនៃឡាវសេ | តៅនៃខុងជឺ | ០ |

# សន្និដ្ឋាន

តាមរយៈបណ្ដានិយមន័យ ដែលបានលើកឡើងខាងលើយើងអាចសន្និដ្ឋានបានថា សាសនាជាទម្រង់ មួយនៃស្មារតីរបស់មនុស្សដែលកំណត់ព្រំដែនឬបើកទូលាយ ដល់ការគិតនិងសកម្មភាពរបស់មនុស្សក្នុងការស្វែងរកសុភមង្គលផ្លូវចិត្ត។និយមន័យនេះចង់បញ្ជាក់ថាបើស្មារតីមនុស្សមិនជិតជាមដោយសាសនាណាមួយទេ ក៏គង់មានជិតជាមដោយទម្រង់ស្មារតីណាមួយផ្សេងទៀតដែលអាចត្រឹមត្រូវឬមិនត្រឹមត្រូវចំពោះខ្លួនគេ។ប៉ុន្តែទោះ ជាយ៉ាងណាក៏ដោយ ក៏ស្មារតីរបស់មនុស្សម្នាក់តែងតែមានឥទ្ធិពល តិចឬច្រើន ចំពោះការរស់នៅរបស់មនុស្សនិងបរិស្ថានជុំវិញខ្លួនគេជានិច្ច។

ព្រះធម៌ជាបញ្ញត្តិមួយគ្មាននរណាម្នាក់ស្អប់ទេ សូម្បីតែសត្វក៏ពេញចិត្តជាមួយសកម្មភាព ដែលមានធម៌របស់ម្ចាស់វាដែរ ប៉ុន្តែហេតុអ្វីក៏ពិភពលោកនៅមានសង្គ្រាមឥតឈប់ឈរ? តើសង្គ្រាមកើតឡើងដោយសារអ្វី? គឺដោយខ្វះការត្រិះរិះ ខ្វះសីលធម៌ ខ្វះមនុស្សធម៌ ខ្វះចិត្តធម៌ ខ្វះការយោគយល់អធ្យាស្រ័យ ឬ ខ្វះការអត់ឱនតាមសមធម៌ តាមក្រឹត្យក្រមច្បាប់ឬ?

ម្យ៉ាងទៀតជាប្រវត្តិសាស្ត្រមនុស្សត្រូវការជម្រក មនុស្សត្រូវការម្ហូបអាហារចិញ្ចឹមជីវិត គឺមនុស្ស ត្រូវការភាពសុខសាន្ត ទាំងខ្លួនប្រាណ ទាំងស្មារតីទៀតផង។ ភាពសុខសាន្តសំខាន់ណាស់សម្រាប់មនុស្ស ប៉ុន្តែបញ្ហានេះមិនមែនជា ការងារមួយងាយទេ ព្រោះនរណាក៏ចង់រស់ចង់សុខ ក៏ប៉ុន្តែ មកទល់ពេលនេះរកសុខនៅតែមិនទាន់ឃើញដដែល។ សម័យមុនដើម្បីភាពសុខសាន្តមានសន្តិភាពផ្ទាល់ខ្លួននិងសង្គមគ្រួសារ មនុស្សត្រូវការប្រយុទ្ធជាមួយស្ថានភាពជុំវិញខ្លាំងណាស់។ បច្ចុប្បន្ននេះជាសម័យបច្ចេកវិទ្យាទំនើប ការប្រុងប្រយ័ត្នសម្រាប់រស់កាន់តែស្មុគស្មាញថែមទៀត។ ហេតុនេះទើប យើងខ្ញុំខិតខំស្រាវជ្រាវសម្រិតសម្រាំងជ្រើសរើសយកគន្លឹះរស់នៅតាមបែបសីលធម៌សាសនាបុរាណ មករួមវិភាគទានជួយមនុស្សជាតិ និងមាតុភូមិក៏ដូចជាតំបន់និងសកលលោក។

អ្នកស្រាវជ្រាវបរទេសមួយចំនួនច្រើននិយាយថា ខ្មែរមួយចំនួនធំធាប់ភ័យ ជាមួយនឹងស្ថានភាពថ្មីណាស់ (បច្ចេកវិទ្យាទំនើប) នេះជាគំនិតពិតឬយ៉ាងណា?។ បើយើងពិនិត្យការ

វិវត្តវប្បធម៌អរិយធម៌ របស់យើងឱ្យបានល្អិតជ្រៅជ្រះបន្តិចនោះ យើងយល់ឃើញថាខ្មែរក្នុងសម័យមហានគរនិយមចូលចិត្តចារឆ្លាក់អក្សរ ពាក្យបណ្តាំជំបូន្មានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗ នៅលើផ្ទាំងថ្មតាមប្រាង្គប្រាសាទនានាណាស់ៗ មានន័យថា បុព្វបុរសខ្មែរយើងមិនខ្ជិលទេ ទោះជាគ្មានក្រដាសស្នាមក៏ដោយ ក៏គាត់ខិតខំចារឆ្លាក់ទុកបន្សល់ឱ្យយើងយល់ដឹងដែរៗ ពួកគាត់យល់ថា ឯកសារប្រភេទដែលចារឆ្លាក់នៅលើថ្មជាអាចរក្សាទុកបានយូរច្រើនសតវត្ស មិនងាយរលុប ហើយក៏មិនងាយបាត់បង់ស្រួលៗដែរៗ ម្យ៉ាងវិញទៀតសិលាចារឹក ទាំងនេះដែលរួមមានប្រាសាទតូចធំរាប់ពាន់ ជាសក្ខីភាពកស្តុតាងជាក់ស្តែងបញ្ជាក់ អំពីអនុភាពខ្លាំងពូកែ ក្លាហានមានប្រាជ្ញាភ្លឺថ្លា មុតមាំ និងស្គាល់តែសេចក្តីថ្លៃថ្នូរថ្កុំថ្កើងរបស់ខ្មែរយើងសម័យមុនៗ ត្រង់នេះបង្ហាឱ្យឃើញថា ខ្មែរពីមុនមិនមែនធាប់ក័យដូចបរទេសថានោះទេ ខ្មែរពុទ្ធសាសនិកពិតជាអាចស្ថិតនៅចំពោះមុខបច្ចេកវិទ្យាទំនើបបានដោយមិនទន់ជ្រាយជាដាច់ខាតៗ ប៉ុន្តែខ្មែរអាចទន់ជ្រាយនៅពេលណាខ្មែរបាត់បង់ធម៌ក្នុងខ្លួន បាត់បង់ពាក្យបណ្តាំ បាត់បង់សាមគ្គីភាព គឺថ្ងៃណាដែលខ្មែរលែងមានធម៌ក្នុងខ្លួនខ្មែរអាចបែកបាក់រត់ខ្ចាត់ខ្ចាយ ព្រាត់ប្រាសក្រុមគ្រួសារៗ ខ្មែរអាចនឹងរងទុក្ខវេទនា ស្គាល់តែភ្លើងសង្គ្រាមស្គាល់តែការកាប់ចាក់គ្នាៗ លោក Alleent instain បានបញ្ជាក់ថា “មិនចាំបាច់គិត ពីព្រះពុទ្ធសាសនាទេនៅសម័យបច្ចេកវិទ្យានេះ ព្រោះព្រះពុទ្ធសាសនា បានដើរហួសពីវិទ្យាសាស្ត្ររួចទៅហើយ”ៗ ចំណែកពាហិរសាសនាក៏មានបំណងមិនខុសពីព្រះពុទ្ធសាសនាដែរៗ

## គន្ថនិទេស


១- **ប៉ែន សាអឿន** *សាសនាប្រៀបធៀប ឆ្នាំ ១៩៦៩*

២- **ហេង គីមហោ** *សាសនាប្រៀបធៀប ភាគទី១*

៣- **កៅ ស៊ុម ( ព្រះឃោសធម្ម អ្នករៀបរៀង )**, *ប្រវត្តិនៃវត្តលង្កា នឹង អច្ចន្តិសូត្រ, អ្នកនិពន្ធ ភ្នំពេញ: ១៩៦៤។*

៤- **ខេ ស្រីធម្មានន្ទ**, *ហេតុអ្វីបានជាមានពុទ្ធសាសនា? យ៉ាំងហ្គូន : សមណនិស្សិតខ្មែរ ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ២០០៨។*

៥- **ខូត ជីតា** ៖ *ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅ ក្នុងសង្គមខ្មែរ ភាគ១ និង ភាគ២ រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ២០០២-២០០៣*

៦- **ខូត ជីតា** ៖ *ជំនឿសាសនាលើពិភពលោក ខែសីហា ឆ្នាំ១៩៩៩*

៧- **ខូត ជីតា** ៖ *មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោកភ្នំពេញ ឆ្នាំ២០០៣*

៨- **ខូត ជីតា** ៖ *គតិបណ្ឌិតសម្រាប់ពុទ្ធសាសនិក ឆ្នាំ ២០០៩ ភ្នំពេញ*

៩- **ខូត ជីតា** ៖ *ទស្សនវិជ្ជាសាសនានៅកម្ពុជា ឆ្នាំ២០០២*

១០-**ខៀវ ជុំ** ៖ *ប្រជាធិបតេយ្យចាស់ទុំ ព.ស.២៥១៦ គ.ស.១៩៧២*

១០-**ខៀវ ជុំ** ៖ *បញ្ហានរក-សួគ៌ និព្វាន ភ្នំពេញ ១៩៩៩*

១១-**ខៀវ ជុំ** ៖ *និព្វាននៅឯណា? ព.ស.២៥៤០ គ.ស.១៩៩៧*

១៣-**ខៀវ ជុំ** ៖ *ជីវិតឈ្នះលោក ព.ស.២៥១៣ គ.ស.១៩៦៩*

១៣-**គង់ នឿន** ៖ *វប្បធម៌ឥណ្ឌា-ខ្មែរ ព.ស.២៥១៥ គ.ស.១៩៧១*

១៤- **សម្ភារ**, *ទស្សនៈសម្តេចព្រះសង្ឃរាជជួនណាត, ភ្នំពេញ ១៩៧០*

១៥- **សំអុល**, *ព្រះមហាវីរក្សត្រីយ៍នៃប្រជាជាតិ បោះពុម្ពលើកទី២, ភ្នំពេញ ២០០៣*

១៦-**សាន់ទូ (សម្តេចព្រះមហា)** *មួយជំហានម្តង (Step by Step) ,ស្វាយរៀង, ១៩៩៣*

១៧-**ឃឹង ហុកឌី** ៖ *ទិដ្ឋភាពទូទៅអក្សរសាស្ត្រខ្មែរ ឆ្នាំ១៩៩៣*

១៨-**ន ភេន(ភិក្ខុ)**, *គុណធម៌ កសាងជាតិ បោះពុម្ពលើកទី២បាពាំង ២០០៧*

១៩-**ន ភេន(ភិក្ខុ)**, *ហីនយាន មហាយាន បោះពុម្ពលើកទី១, ឆ្នាំ បាពាំង ២០០៧*

២០-**គានអ៊ុង សួរ**, *ប្រវត្តិព្រះសក្យមុនីចេតិយ៍, ភ្នំពេញ: ២០០២*

២១-**សុខ**,*ពុទ្ធសាសនាផ្តើប្រយោជន៍ដល់សង្គមមនុស្សអ្វីខ្លះ?ភ្នំពេញ ១៩៦៦*

២២-**កឿន**,*មនុស្សសិល្បៈនិងជំនឿ*,ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញៈ ១៩៩៣
២៣-**ជួន ណាត**, *វចនានុក្រមខ្មែរភាគ១-២*, ភ្នំពេញៈ ១៩៦៧
២៤-**ជួន ណាត**, *នាមបញ្ញត្តិ*, ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញៈ ១៩៩៧
២៥-**ជួន ណាត (សម្តេចព្រះមហាសុមេធាធិបតី )**, *ប្រវត្តិនៃវត្តឧណ្ណាលោម សន្លាត់លេខ ៧ចែកផ្សាយក្នុងបុណ្យឆ្លងព្រះវិហារវត្តឧណ្ណាលោម* ភ្នំពេញៈ ១៩៦៣
២៦- **ជួន ណាត** ៖ ស្នាព្រះហស្តចុងក្រោយ ឆ្នាំ ១៩៧០
២៧-**ឈន អៀម**, *ពុទ្ធសាសនានិងការប្រតិបត្តិនៅកម្ពុជានាបច្ចុប្បន្ន*, ភ្នំពេញៈ ១៩៩២
២៨-**ឈន អៀម (បកប្រែ)** / Pun Dit (Ven.), *ការផ្តើមសិក្សាទស្សនវិជ្ជាពុទ្ធសាសនា ស្តីពីវដ្ត*, ពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញៈ ១៩៩៣
២៩-**ឈត ស្រាង/យិន សំបូរ...**, *ប្រវត្តិសង្ខេបរបស់ពុទ្ធសាសនបណ្ឌិត្យ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញៈ ២០០៥
៣០-**ឈន អៀម** ៖ កម្ពុជសុរិយាឆ្នាំ៥០ លេខ៣ ខែកក្កដា-សីហា-កញ្ញា ឆ្នាំ១៩៩៦
៣១-ព្រះគ្រូ **ប៉ាង ខាត់** ៖ ស្រីហិតោបទេស ឆ្នាំ ១៩៦៥
៣២-**ញ៉ុក ថែម**, *ពន្លឺអាស៊ីទ្វីប*, ពុទ្ធសាសនបណ្ឌិត្យ ១៩៩៥។
៣៣-**អួង នឿន**,*វិន័យសាមណេរ (បោះពុម្ពលើកទី៤)*, ភ្នំពេញ ១៩៧២។
៣៤-**ប៉ាង ខាត់**, *ព្រះពុទ្ធសាសនាដូចម្តេច?*, ភ្នំពេញៈ ១៩៧០។
៣៥-**ប៉ាង ខាត់ ( ព្រះវីរិយបណ្ឌិតោ )**, *ព្រះត្រៃបិដកជាភាសាខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញៈ ១៩៩៥។
៣៦-**ពុទ្ធសាសនបណ្ឌិត្យ**, *កម្ពុជសុរិយាលេខពិសេស ពិធីបុណ្យពុទ្ធសាសនា ២៥០០*, ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញៈ ១៩៥៧។
៣៧-**ពុទ្ធសាសនបណ្ឌិត្យ**, *ទស្សនៈព្រះពុទ្ធសាសនា ស្តីពីបរិស្ថាន*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញៈ ២០០០។
៣៨-**ម៉ិញ – ទ៉ាគ្រី**, *សាសនាគឺអ្វី? ( សួរឆ្លើយអំពីពុទ្ធសាសនានិងពាហិរសាសនា*, ការផ្សាយរបស់បណ្ណាគារត្រៃរតន៍ ភ្នំពេញៈ ១៩៥១។
៣៩-**យិន នឿន**, *គាថាធម្មបទប្រែ (បោះពុម្ពលើកទី១)*, ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញៈ ១៩៨៩។

៤០-**លាស់ ឡាយ(ព្រះធម្មលិខិត)**, *ប្រវត្តិព្រះពុទ្ធសាសនា ក្រោយព្រះពុទ្ធទ្រង់បរិនិព្វាន, វត្តមហាមន្ត្រី ភ្នំពេញ: ២០០៨។*

៤១-**លី សុវីរ**, *ព្រះរាជប្រពៃណីព្រះមហាក្សត្រ និងសម្ដេចព្រះសង្ឃរាជ,* ការផ្សាយរបស់ក្រសួងព្រះបរមរាជវាំង ភ្នំពេញ: ២០០៣។

៤២-*វរិយបណ្ឌិតគោភិក្ខុ* **ប៉ាង ខាត់** *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ ឆ្នាំ១៩៦១*

៤៣-**វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**, *សន្និសីទជាតិស្ដីពីព្រះពុទ្ធសាសនាថេរវាទ នៅកម្ពុជាបច្ចុប្បន្ននិងអនាគត, វិទ្យាស្ថានមនុស្ស សាស្ត្រនិងវិទ្យាសាស្ត្រសង្គម ភ្នំពេញ: ២០០៥។*

៤៤-**វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**, *សិក្ខាសាលាជាតិស្ដីពីស្ថានភាពសាសនានៅកម្ពុជានាពេលបច្ចុប្បន្ន, វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ភ្នំពេញ: ២០០២។*

# បណ្ឌិតសភាចារ្យ ខ្លួត ធីតា

- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
- ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យហ៊ុន សែន
- ទទួលបន្ទុកការងារធម្មការ និងសាសនា
- អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ
- សមាជិកគណៈកម្មការបណ្ឌិតសភា អនុម័តពាក្យច្បាប់

**ស្នាដៃនិពន្ធនិងបោះពុម្ព ៖**

១-ទស្សនៈអហិង្សារបស់ព្រះពុទ្ធសាសនានិងសិទ្ធិមនុស្ស ឆ្នាំ១៩៩៥

២-អហិង្សាព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ ឆ្នាំ១៩៩៦

៣-ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមខ្មែរ ឆ្នាំ១៩៩៦

៤-អត្ថបទស្តីពី ព្រះពុទ្ធសាសនាសម្រាប់ទស្សនាវដ្តី អក្សរសាស្ត្រ-មនុស្ស សាស្ត្រ ឆ្នាំ ១៩៩៦-២០០៥

៥-ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ (ភាគ១ ភាគ២) ឆ្នាំ១៩៩៦-១៩៩៨

៦-ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ឆ្នាំ១៩៩៨-១៩៩៩

៧-គួរយល់ដឹងជំនឿសាសនាលើសកលលោក ឆ្នាំ១៩៩៩

១០-ព្រះសមណគោត្តម ឆ្នាំ២០០០

៨-ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ ឆ្នាំ១៩៩៩ លើកទី២ (២០០២)

៩-បកប្រែនិងបោះពុម្ពសៀវភៅ ១០០សំណួរ១០០ចម្លើយ សាសនា នៅប្រទេសចិន ឆ្នាំ១៩៩៩

១១-ទស្សនាវដ្តីកម្ពុជសុរិយានៅពុទ្ធសាសនាបណ្ឌិតស្មារតីខ្មែរចំពោះព្រះពុទ្ធសាសនា ឆ្នាំ២០០០-២០០៦

១២-មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាសកលលោក ឆ្នាំ២០០២

១៣-ការស្វែងយល់អំពីការវិវត្ត ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ (ចុះបញ្ចាំងតាមរយៈ ទស្សនវិជ្ជា) ឆ្នាំ២០០២

១៤-ទស្សនវិជ្ជាព្រះពុទ្ធសាសនានៅសង្គមខ្មែរ (ទស្សនវិជ្ជាច្បាប់) ឆ្នាំ២០០២

១៥-ទស្សនវិជ្ជាខ្មែរ ឆ្នាំ២០០២

១៦-ទស្សនវិជ្ជាឥណ្ឌា និងតកវិជ្ជា ឆ្នាំ២០០៥

១៧-តើព្រះពុទ្ធប្រៀនប្រដៅអ្វីខ្លះ ? ឆ្នាំ២០០៧

១៨-រឿងនិទាន និងចំណោះដឹងជនជាតិភាគតិចនៅប្រទេសកម្ពុជា ឆ្នាំ២០០៧

១៩-គួរយល់ដឹងទស្សនវិជ្ជា ឆ្នាំ២០០៧

២០-គួរយល់ដឹងអំពីចំណីអាហារ លើកទី១ ឆ្នាំ២០០៨

២១-អរិយទ្រព្យដ៏ប្រសើររបស់មនុស្ស លើកទី១ ឆ្នាំ២០០៨

២២-ទស្សនវិជ្ជាសម័យអង្គរ ឆ្នាំ២០០៨

២៣-មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ឆ្នាំ២០០២

២៤-គតិបណ្ឌិតសម្រាប់ពុទ្ធសាសនិក ២០០៩

២៥-ទស្សនវិជ្ជាសម័យអង្គរ ២០១០

២៦-ទស្សនវិជ្ជាសម័យចតុមុខ លង្វែក ឧដុង្គ និងបាភ្នំ ២០១១

២៧-ព្រះពុទ្ធសាសនា និងពាហិរសាសនានៅក្នុងសង្គមខ្មែរក្រោយ ៧ មករា ១៩៧៩ (១៩៧៩-បច្ចុប្បន្ន)

២៨-ស្វែងយល់ទស្សនវិជ្ជាពិភពលោក ឆ្នាំ២០១១

២៩- ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា បោះពុម្ពឆ្នាំ២០១៣

៣០- ព្រះពុទ្ធបដិមានៅកម្ពុជា បោះពុម្ពឆ្នាំ២០១៣

**ត្រៀមបោះពុម្ពឆ្នាំ ២០១២-២០១៣**

១-ទស្សនៈខ្មែររយៈពេល ២០ សតវត្សរ៍

២-ទំនាក់ទំនងសីលធម៌និងច្បាប់នៅក្នុងសង្គមខ្មែរផ្តើមនិពន្ធឆ្នាំ២០០៥

៣-សាសនាសាកល ផ្តើមនិពន្ធឆ្នាំ ២០០៥

៤-សីលធម៌ក្នុងសង្គម ផ្តើមនិពន្ធឆ្នាំ ២០១២

៥-បណ្តុះវិស័យខ្មែរ(ទស្សនវិជ្ជាខ្មែរ) ផ្តើមនិពន្ធឆ្នាំ ២០១២

៦-ដឹកនាំសង្ខេបព្រះត្រៃបិដក ផ្តើមរៀបចំចុងឆ្នាំ ២០១១

៧-អំពីស្ត្រីខ្មែរ ឆ្នាំ២០១៤





លោកជំទាវបណ្ឌិតសភាចារ្យ ខ្លុត ធីតា



បេក្ខជនបណ្ឌិត ជំនាន់ទី២ វគ្គទី១

ឆ្នាំ២០១៨